រឿងព័ទក្នុងភូមិ
នៅសម័យខ្មែរក្រហម

រៀបរៀង និង ដឹកនាំដោយ
ផេង ពង្សអ៊ាស៊ី

មជ្ឈមណ្ឌលឯកសារកម្ពុជា
DOCUMENTATION CENTER OF CAMBODIA

©រក្សាសិទ្ធិ
មជ្ឈមណ្ឌលឯកសារកម្ពុជា / បណ្ណាល័យសម្តេចម៉ែ
ភូមិគ្រឹះលេខ ១១ ផ្លូវ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ១២០២០៧
ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ +៨៥៥ (០)១២ ៩០៥ ៥៩៥
សារអេឡិចត្រូនិច៖ dccam@online.com.kh
គេហទំព័រ៖ www.dccam.org

រឿងរ៉ាវក្នុងភូមិនៅសម័យខ្មែរក្រហម
១. ប្រទេសកម្ពុជា - ប្រវត្តិសាស្ត្រ - សិទ្ធិមនុស្ស
២. ប្រទេសកម្ពុជា - ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ - ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩
៣. ប្រទេសកម្ពុជា - ប្រវត្តិសាស្ត្រនិងអក្សរសិល្ប៍ - ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

រៀបរៀងដោយ៖
១. ឆាំង យុ
២. សោម ប៊ុនថន
៣. ផេង ពង្សវ៉ាសុី
៤. ជាវ៉ាដ្ឋេ មេត្តា
៥. ផាត ចាន់សុនិតា

រក្សាសិទ្ធិឆ្នាំ២០២៤ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង។ មិនមានផ្នែកណាមួយនៃសៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬក្នុងមធ្យោបាយណាមួយឡើយ រួមមាន ការថតចម្លង ការកត់ត្រាទុក ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពបានឡើយ។

ការអះអាង៖ ការបោះពុម្ពផ្សាយនេះ ទទួលបានជំនួយហិរញ្ញប្បទានពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ។ មតិយោបល់ ការរកឃើញ និងសេចក្តីសន្និដ្ឋាន ដែលមាននៅក្នុងឯកសារនេះ គឺជារបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងអំពីមតិយោបល់របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិឡើយ។ ទស្សនៈដែលបានបង្ហាញនៅក្នុងសៀវភៅ គឺជាទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ។

ប្រភពរូបថត៖ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

រឿងភ័យខ្លួចក្នុងភូមិ នៅសម័យខ្មែរក្រហម

រៀបរៀង និង ដឹកនាំដោយ
ផេង ពង្សភ័ស្ដុ

មជ្ឈមណ្ឌលឯកសារកម្ពុជា
DOCUMENTATION CENTER OF CAMBODIA

មាតិកា

រឿង	**ទំព័រ**
អារម្ភកថា	ក
សេចក្តីថ្លែងអំណរគុណ	ឃ
១. រឿង បាយក្តាំង	១
២. រឿង ពេលដែលម៉ែឃ្លាតទៅ	១៣
៣. រឿង ស្នាមដំបៅ	៣៧
៤. រឿង ក្រោមមេឃតែមួយ	៥៧
៥. រឿង ព្រះអាទិត្យឥតពន្លឺ	៧៣
៦. រឿង មួយថ្ងៃ មួយយប់	៨១
៧. រឿង ជើងមេឃពណ៌ក្រហម	៩៣
៨. រឿង មិនព្រមរៀបការ	១០៧
៩. រឿង អាប់សៃ	១២៥
១០. រឿង ឈ្លើយសឹក	១៣៥
១១. រឿង ផ្សែងអ័ព្ទ	១៤៩
១២. រឿង ការចងចាំម្តាយខ្ញុំ	១៧១
១៣. រឿង នៅពីក្រោយសំឡេងច្រៀង	១៧៩

១៤. រឿង រនោចជីវិត	១៩៥
១៥. រឿង ដង្ហើមស្នេហ៍ ក្បែរកម្លាំងត្បូងចប	២០៧
១៦. រឿង គ្រួសារខ្ញុំក្នុងរបបវាលពិឃាត	២២១
១៧. រឿង ជីវិតខ្មៅក្នុងរបប ប៉ុល ពត	២៣៣
១៨. រឿង អង្គរផ្លែឫស្សី	២៣៩
១៩. រឿង រស្មីពន្លឺក្រោមដំបូលមេឃនៃភពងងឹត	២៤៩
២០. រឿង ភូមិខ្ញុំក្នុងសម័យ ប៉ុល ពត	២៥៩
២១. រឿង ខ្សែជីវិតខ្ញុំក្រោមរបបកម្ពុជាប្រជាធិបតេយ្យ	២៧៧
២២. រឿង កុមារភាពនៅកងចល័ត	២៩៥
២៣. រឿង អត់ដឹងខ្យល់	៣០៧
២៤. រឿង ខោសំពត់សម្ពយ	៣១៩
២៥. រឿង គ្រួសារខ្ញុំ	៣២៩
២៦. រឿង ក្រោមមេឃងងឹត	៣៤១
២៧. រឿង រួចពីនរក	៣៤៩
២៨. រឿង ស្នាមអតីត	៣៥៧
២៩. រឿង ស្នាមដានជីវិត	៣៧៣
៣០. រឿង ពពកខ្មៅ	៣៨៥
៣១. រឿង ជីវិតក្រោមពពកខ្មៅ	៣៩៣
៣២. រឿង កម្រងផ្កាអពមង្គល	៤០១
៣៣. រឿង ប្រឡាយទឹកភ្នែក	៤១៣
៣៤. រឿង រលកជីវិត	៤២៧
៣៥. រឿង ផែនដីពណ៌ខ្មៅ	៤៤១
៣៦. រឿង ខ្សែជីវិតកុមារត្រូវបានជម្លៀសក្នុងរបប ប៉ុល ពត	៤៥១

៣៧. រឿង ចិត្តចងចាំ	៤៦៧
៣៨. រឿង ចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦	៤៧៥
៣៩. រឿង ជីវិតជាប់គុកឥតជញ្ជាំង	៤៨៣
៤០. រឿង ជីវិតទាសកររនាភូមិភាគ៣យព្យ	៤៩១
៤១. រឿង ជីវិតបុប្ផាក្នុងស្បែអន្ធការ	៥០៥
៤២. រឿង ជីវិតប្រចាំថ្ងៃ ក្នុងរបបប៉ុល ពត	៥១៧
៤៣. រឿង ជីវិតពិតកុមារា សុខ ខេង	៥២៥
៤៤. រឿង ទឹកភ្លៀងលាងគុកឥតជញ្ជាំង	៥៣៥
៤៥. រឿង នរកភ្នែកស្រស់	៥៥៣
៤៦. រឿង នរកលោកិយ៍បីឆ្នាំប្លាយ	៥៦៣
៤៧. រឿង ផ្តិលកេរជីវិត	៥៧៥
៤៨. រឿង ពេលដែលខ្ញុំបើកភ្នែក	៥៨៩
៤៩. រឿង ភ្នែកនៅក្នុងចិត្ត	៥៩៧
៥០. រឿង អត់ទេ មិនដែលសង្ឃឹមថារស់ទេ	៦១៧
៥១. រឿង រត់	៦២៣
៥២. រឿង ខ្សែជីវិតកងកុមារ	៦២៩
៥៣. រឿង ឆ្លងទន្លេ	៦៣៧
៥៤. រឿង រួចពីចំណង	៦៤៥
៥៥. រឿង វាសនាដូនចាស់ខ្ញុំ	៦៥៩
៥៦. រឿង ស្រមោលអតីតកាល	៦៧៣
៥៧. រឿង ស្រមោលអតីតកាល	៦៨៧
៥៨. រឿង អង្គការចោរប្លន់	៦៩៩
៥៩. រឿង អង្គការទុរយស	៧១១

៦០. កំណាព្យ	៧១៩
ជីវិតអន្ធការរបស់ម៉ែ	៧២០
ជីវភាពឆ្នាំ១៩៧៣-១៩៧៤	៧២១
ជីវភាពរស់នៅក្នុងរបប ប៉ុល ពត	៧២២
ជីវភាពឆ្នាំ១៩៧៧-១៩៧៨	៧២៣
ជីវិតទីពីរ	៧២៨
៦១. កំណាព្យ	៧៣១
សំណោកប្រាសាទ	៧៣២
រឿងពិតសិរីសោភ័ណ	៧៣៣
ទុក្ខសោកបាកាន	៧៣៥
៦២. កំណាព្យ	៧៣៩
សាច់រឿងពិតរបស់លោកអ៊ំ ឆាំង យុ	៧៤០

អារម្ភកថា



តថភាពប្រវត្តិសាស្ត្រដែលបានកើតឡើងពីអតីតកាលក្នុងរបបខ្មែរក្រហម គឺមិនអាចបំភ្លេច ឬកែប្រែបានឡើយ។ ប្រវត្តិរឿង៉ាវជូរចត់ជាច្រើនអន្លើ ក៏រឹតតែមិនអាចទុកចោល ឬព្រងើយកន្តើយបានដែរ ព្រោះថាវាជាភាពអយុត្តិធម៌មួយទៀត បន្ថែមពីលើជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅនាពេលបច្ចុប្បន្ន។ ប្រវត្តិរឿង៉ាវរបស់មនុស្សម្នាក់ គ្រួសារមួយ និងសហគមន៍នីមួយៗ គឺជាប្រវត្តិសាស្ត្រជាតិ។ នៅពេលដែលប្រជាជនទាំងអស់នៃប្រទេសជាតិជួបប្រទះបទពិសោធន៍ជូរចត់ដូចៗគ្នា ឬស្រដៀងគ្នា បទពិសោធន៍ទាំងនោះ គឺជាមេរៀនប្រវត្តិសាស្ត្រដ៏មានសារសំខាន់បំផុត សម្រាប់មនុស្សជំនាន់ក្រោយរៀនសូត្រ ថែរក្សា ចងក្រង និងលើកទឹកចិត្ត ឲ្យមានការសន្ទនាអន្តរជំនាន់ពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម ដើម្បីបង្កើនសមត្ថភាពចងចាំឲ្យកាន់តែល្អប្រសើរ។ ថ្វីដ្បិតតែការចែករំលែករឿង៉ាវ ឬការពង្រឹងសមត្ថភាពចងក្រងបទពិសោធន៍លំបាកៗនេះ មិនមានចែងនៅក្នុងច្បាប់ ឬរដ្ឋធម្មនុញ្ញរបស់ប្រទេសក៏ដោយក៏ប៉ុន្តែកាតព្វកិច្ចនេះគឺជាការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗស្ថាប័ននីមួយៗ ឬសង្គមនាពេលបច្ចុប្បន្ន ក្នុងការប្តេជ្ញាចិត្តចូលរួមចំណែកក្នុងការទប់ស្កាត់ការកកើតអំពើឃោរឃៅដូច ឬស្រដៀងគ្នាទៅនឹងបទពិសោធន៍ពីអតីតកាល មកលើសង្គមនាពេលបច្ចុប្បន្ន ឬទៅអនាគត។

ការចែករំលែករឿងរ៉ាវ និងការរៀនសូត្រពីរឿងរ៉ាវទាំងនោះ គឺមិនមែនជារឿងដាច់ដោយឡែកពីគ្នាឡើយ។ មនុស្សទាំងអស់ ត្រូវតែពួតដៃគ្នាក្នុងការថែរក្សាស្មេរភាពសង្គមដែលគ្មានអំពើហិង្សា ដោយចាប់ផ្តើមពីការចងចាំប្រវត្តិរឿងរ៉ាវប្រទេសរបស់ខ្លួន និងបញ្ចប់ទៅវិញជាមួយនឹងការដោះស្រាយបាននូវបេសកកម្មនៃការកសាងសន្តិភាព ការផ្សះផ្សាសង្គម ការស្វែងរកយុត្តិធម៌ និងការប្រកាន់ខ្ជាប់នូវវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។

ការកសាងស្នាដៃតែងនិពន្ធ ដែលជាការចែករំលែកដ៏អស្ចារ្យរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការខិតខំប្រឹងប្រែងចងក្រងរបស់អ្នកនិពន្ធទាំងឡាយ គឺជាឧទាហរណ៍ដ៏សំខាន់ និងមានអត្ថន័យបំផុត ដែលបង្ហាញពីការចងក្រងរឿងរ៉ាវដ៏បូងបង្អស់ ដែលរំលេចពីរសជាតិជីវិតឆ្លងកាត់អំពើប្រល័យពូជសាសន៍ ទាំងការឈឺចាប់ ការបែកបាក់ និងបាត់បង់សមាជិកគ្រួសារ របួសផ្លូវចិត្ត អនុស្សាវរីយ៍ជូរចត់រវាងម្តាយនិងកូន មនោសញ្ចេតនាឈឺចាប់ គំនុំសងសឹក ស្នេហានិរាសព្រាត់ប្រាស និងការជិះជាន់កម្លាំងពលកម្ម ជាពិសេសពលកម្មកុមារ។ សាច់រឿងទាំងអស់នេះ គឺជាសាច់រឿងចេញពីកូមិ។ និយាយឲ្យសាមញ្ញ សំដៅទៅលើរឿងរ៉ាវ និងបទពិសោធន៍ផ្ទាល់ខ្លួន រួមមានពេលវេលា ទីកន្លែង និងព្រឹត្តិការណ៍ជាក់លាក់ ត្រូវបានកត់ត្រាចងក្រង និងចែករំលែក។ រឿងរ៉ាវ និងបទពិសោធន៍ទាំងអស់របស់អ្នកភូមិ ត្រូវបានកត់ត្រាពីស្ថានភាពជីវិតរស់នៅក្នុងសង្គម វប្បធម៌ ភូមិសាស្ត្រនយោបាយ និងសាសនា។ ទាំងអ្នកនិពន្ធ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានប្រាប់រឿងរ៉ាវជីវិតរបស់ខ្លួន បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងបេសកកម្មដឹកនាំការផ្សះផ្សាក្នុងសង្គមកម្ពុជា។ អ្នកនិពន្ធទាំងឡាយ គឺជាអ្នកស្តាប់ និងធ្វើជាសាក្សីចំពោះការឈឺចាប់របស់អ្នករស់រានមានជីវិត។ នេះគឺជាទិដ្ឋភាពដ៏សំខាន់បំផុតមួយនៅក្នុងសង្គមក្រោយជម្លោះ ដែលបង្ហាញឲ្យឃើញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ៗសុទ្ធសឹងតែទទួលរងការឈឺចាប់ និរាសព្រាត់ប្រាស និងជំងឺផ្លូវចិត្តដូចៗគ្នា។

រឿង«វ៉ាវចេញពីភូមិ គឺជាផ្នែកមួយនៃ «ទឹកដីនៃការផ្សះផ្សា» ដែលអាចផ្តល់ចម្លើយចំពោះមូលហេតុ និងរបៀបដែលអំពើប្រល័យពូជសាសន៍បានកើតឡើង និងបង្ហាញពីភាពធន់របស់សហគមន៍កម្ពុជា ការរស់រានមានជីវិត និងកសាងជីវិតឡើងវិញ ព្រមទាំងបង្ហាញពីស្ថានភាពជីវិតនាពេលបច្ចុប្បន្ន។ ជាងនេះទៅទៀត ការចងក្រង «រឿង«វ៉ាវចេញពីភូមិ» គឺអាចប្រើប្រាស់ជាសម្ភារឧបទេសសម្រាប់ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀនទូទាំងប្រទេស និងជាជំនួយដ៏ល្អសម្រាប់សិស្សានុសិស្សក្នុងការស្វែងយល់បន្ថែមពីជីវិតរស់នៅក្នុងរបបខ្មែរក្រហមរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងឡាយ។

កម្រងសំណេរ «រឿង«វ៉ាវចេញពីភូមិ» គឺមិនត្រឹមតែអប់រំក្មេងៗជំនាន់ក្រោយ និងអ្នកអានពីប្រវត្តិសាស្ត្រខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកទឹកចិត្តអ្នកទាំងនោះឲ្យចងក្រងប្រវត្តិរឿង«វ៉ាវឪពុកម្តាយ ជីដូនជីតា សាច់ញាតិ និងអ្នកជិតខាងរបស់ខ្លួន ដើម្បីថែរក្សាការចងចាំពីអតីតកាល ដែលជាផ្នែកមួយនៃដំណើរការស្វែងរកការពិត និងការផ្សះផ្សា។ សរុបមក រឿងទាំងអស់នឹងផ្តល់នូវការពិពណ៌នាសង្ខេបអំពីរូបភាពទាំងមូលនៃប្រវត្តិសាស្ត្រខ្មែរក្រហម។

សេចក្តីថ្លែងអំណរគុណ



សូមអរគុណដល់ឪពុកម្តាយនិងបងៗដែលបានជំរុញនិងលើកទឹកខ្ញុំឲ្យបានរៀនសូត្រ និងអរគុណដល់លោកគ្រូអ្នកគ្រូដែលបានបង្ហាត់បង្រៀនដល់ខ្ញុំ។

ខ្ញុំក៏សូមអរគុណយ៉ាងជ្រាលជ្រៅដល់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានប្រៀនប្រដៅ និងអប់រំខ្ញុំរហូតមក។ ចំណេះដឹងដែលខ្ញុំទទួលបានពីលោក បានជួយជំរុញឲ្យខ្ញុំមានលទ្ធភាពស្រាវជ្រាវ និងសរសេររឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងរឿងរ៉ាវមួយចំនួនទៀតទាក់ទងនឹងការអប់រំ ដើម្បីបោះផ្សាយនៅលើសៀវភៅប្រវត្តិសាស្ត្រ ព្រឹត្តិបត្រ និងសារព័ត៌មានផ្សេងៗ ដែលជាការរួមចំណែកមួយផ្នែកតូចជាមួយសង្គមជាតិ។

សូមអរគុណដល់ បងប្អូន អ៊ំ ពូ មីង ដែលបានចំណាយពេលវេលាផ្ទាល់ខ្លួន ស្រាវជ្រាវ និងសរសេរសាច់រឿងទាក់ទងនឹងរបបខ្មែរក្រហម និងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា។ ស្នាដៃទាំងនេះនឹងរួមចំណែកថែរក្សាប្រវត្តិសាស្ត្រ និងរៀបរាប់ពីជីវិតរស់នៅរបស់ប្រជាជនកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត។ រឿងរ៉ាវទាំងអស់ បានរំឭកពីរបបខ្មែរក្រហម និងការចងចាំពីអតីតកាលដ៏ឃោរឃៅ ដែលបានកើតឡើង និងជាដំណើរការផ្សះផ្សាដល់ប្រជាជនកម្ពុជា ជាពិសេសអាចធ្វើឲ្យធូរស្បើយផ្លូវចិត្តសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាង ៥លាននាក់។

រហូតដល់សព្វថ្ងៃ រឿងរ៉ាវពីរបបខ្មែរក្រហម នៅតែបានលើកយកមកនិយាយ និងជជែកពិភាក្សា ដែលជាផ្នែកមួយនៃការអប់រំប្រវត្តិសាស្ត្រតាមរយៈការរៀបរាប់ផ្ទាល់មាត់។ ការអប់រំប្រវត្តិសាស្ត្រ មានតួនាទីសំខាន់ខ្លាំងណាស់នៅក្នុងសង្គម ក្នុងការចែករំលែកចំណេះដឹង និងរឿងរ៉ាវដល់គ្នាទៅវិញទៅមក និងចូលរួមចំណែកទប់ស្កាត់កុំឲ្យអំពើឃោរឃៅកើតមានម្តងទៀត ដែលភាគច្រើននៅលើពិភពលោកយើងនេះ តែងតែកើតមានអំពើហិង្សា និងការកាប់សម្លាប់ មុននឹងមានវិធានការទប់ស្កាត់។

ទោះបីយ៉ាងណា រឿងរ៉ាវដែលប្រមូលបានទាំងនេះ នឹងត្រូវបានកែសម្រួលពាក្យពេចន៍ ឃ្លាឃ្លោងមួយចំនួនដើម្បីងាយស្រួលអាន ដោយរក្សាទុកនូវអត្ថន័យនិងខ្លឹមសារដើមមុននឹងបោះពុម្ពផ្សាយ។

១

រឿងចាយក្តាំង

អ្នកនិពន្ធ ៖ អ៊ុច សំណាង

១ ~ រឿង បាយភ្លាំង

គ្រប់ពេលវេលាទាំងអស់មិនថាថ្ងៃឬយប់ រាល់ពេលដែលខ្ញុំធ្វើដំណើរឆ្លងកាត់តំបន់មួយម្តុំវត្តក្រឡោមភ្នក ខ្ញុំមិនដែលខកខានចោលកន្ទុយភ្នែកសម្លឹងមើលទៅកាន់ទីកន្លែងនោះម្តងណាឡើយ។ អារម្មណ៍របស់ខ្ញុំ តែងតែស្រមើស្រមៃដល់ជីវិតប្រចាំថ្ងៃ ដែលខ្ញុំធ្លាប់បានរស់នៅ និងរឿងរ៉ាវជាច្រើនដែលបានកើតឡើងចំពោះខ្ញុំនៅទីនោះ ព្រមទាំងរឭកពីអនុស្សាវរីយ៍រីករាយនិងកំសត់ជាមួយនឹងប្រជាជនផ្សេងៗទៀតដែលខ្ញុំបានជួប ហើយនៅតែបន្តនឹកនារហូតដល់សព្វថ្ងៃនេះ។ កន្លែងនោះមានឈ្មោះថា «ការដ្ឋានអាងទឹកត្រាំកង់» គឺជាកន្លែងដែលខ្ញុំធ្លាប់រស់នៅក្នុងសម័យខ្មែរក្រហមអំឡុងឆ្នាំ១៩៧៧ រហូតដល់ជិតពាក់កណ្តាលឆ្នាំ១៩៧៨។

នឹកដល់ព្រលប់ថ្ងៃមួយនៅក្នុងរបបខ្មែរក្រហម បន្ទាប់ពីបរិភោគបាយពេលល្ងាចរួច ខ្ញុំបានផ្តេកខ្លួនសម្រាកនៅលើកម្រាលបាវក្រចៅក្រាលផ្ទាល់នៅនឹងដីក្នុងរោងតូចមួយ។ រំពេចនោះ ស្រាប់តែមានសំឡេងយុវជនម្នាក់បានស្រែកសួរកថែមទាំងហៅឈ្មោះរបស់ខ្ញុំចេញពីខាងក្រោយរោងថា «មិត្តណាមួយឈ្មោះសាន្ត! ចេញមកមួយភ្លែតមក»។ ឮដូច្នោះ ខ្ញុំក៏ស្រែកសួរចេញពីក្នុងមុងដែលខ្ញុំកំពុងតែដេកទាំងងឿងឆ្ងល់ថា «មានការអី?» ស្របពេលគ្នានោះ ខ្ញុំក៏ស្ទុះចេញមកខាងក្រៅរោងភ្លាមៗ រួចដើរសំដៅទៅរកម្ចាស់សំឡេង។ ពេលព្រលប់បែបនេះខ្ញុំមើលមុខយុវជនម្នាក់នោះមិនសូវច្បាស់ទេ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាដូចជាប្រហាក់ប្រហែលធ្លាប់ឃើញគាត់នៅទីណាម្តងម្កាល។ ខ្ញុំហៀបតែនឹងហាមាត់សួរទៅកាន់យុវជនម្នាក់នោះទៅហើយ ប៉ុន្តែគាត់បាននិយាយមកកាន់ខ្ញុំមុនក្នុងភាពប្រញាប់ប្រញាល់ថា «មិត្តឯងទៅរោងបាយទៅជួបនឹង ម៉ែភួង ឥឡូវនេះ»។

គាត់និយាយរួច ក៏ដើរចេញទៅបាត់ភ្លាមៗ។ លុះបន្តិចក្រោយមក មានមិត្តម្នាក់ដែលធ្លាប់ស្គាល់យុវជនម្នាក់នោះបានប្រាប់ខ្ញុំថា យុវជនម្នាក់នោះ គឺជាមនុស្សជំនិតរបស់ មាហន ដែលជាកម្មាភិបាលខ្មែរក្រហម មានតួនាទីខ្ពស់ជាងគេនៅក្នុងការដ្ឋានសំណង់អាងទឹកត្រាំកង់។ មាហន គឺជាអ្នកក្តោបក្តាប់លើកម្លាំងទាំងអស់មកពីស្រុក៤២ តំបន់៤ ស្ថិតក្នុងខេត្តបាត់ដំបង។

មិនបង្អង់យូរ ខ្ញុំក៏ប្រញាប់ប្រញាល់ទាញយកសម្លៀកបំពាក់សាច់ក្រណាត់ផាឌឹបពណ៌ប្រផេះ របស់ខ្ញុំ ដែលអង្គការទើបតែបើកឲ្យថ្មីៗ យកមកស្លៀកពាក់រួចរួតរះចេញដំណើរទៅកាន់រោងបាយតាមការនិយាយប្រាប់របស់យុវជនម្នាក់នោះ។ ខ្ញុំមានអារម្មណ៍តិតព័យណាស់ ព្រោះខ្ញុំមិនដឹងថាតើនឹងមានរឿងអ្វីកើតឡើងចំពោះខ្ញុំនោះទេ ហើយមូលហេតុអ្វីបានជា ម៉ែភួង ដែលជាប្រធានរោងបាយហៅខ្ញុំឲ្យទៅជួបគាត់ទាំងក្បាលព្រលប់យ៉ាងដូច្នេះ?។

នៅពេលដែលខ្ញុំទៅដល់រោងបាយ ខ្ញុំបានឃើញស្រមោលមនុស្សមួយក្រុមកំពុងតែអង្គុយនៅលើគ្រែនាបឬស្សីមួយនិយាយគ្នាងំៗ។ នៅក្បែរគ្រែនោះមានចន្លុះមួយដើមចងភ្ជាប់ជាមួយនឹងមែកឈើ ដែលបានជះពន្លឺល្មមអាចឲ្យខ្ញុំមើលពីខាងក្រៅទៅឃើញមនុស្សទាំងអស់នោះបានច្បាស់។ ខ្ញុំឃើញមានមនុស្សស្រីពីរនាក់ និងមនុស្សប្រុសពីរនាក់ កំពុងតែហូបបាយជុំគ្នា។ ក្នុងនោះ ខ្ញុំឃើញស្ត្រីវ័យចំណាស់ម្នាក់ មានអាយុប្រហែល ៦០ឆ្នាំ ដែលក្រុមកងចល័តសុទ្ធតែបានស្គាល់គាត់ថាជា ម៉ែភួង។ ម៉ែភួង គឺជាអ្នកមូលដ្ឋានចាស់ មានស្រុកកំណើតនៅក្នុងទឹកដីស្រុកមោងឫស្សី ខេត្តបាត់ដំបង។ គាត់គឺជាមនុស្សស្រី ដែលមានសំដីផ្អែមជាងគេ ហើយថែមទាំងជាមនុស្សដែលមានចិត្តល្អទៀតផង។ គាត់ក៏ជាកម្មាភិបាលខ្មែរក្រហមមួយរូប ដែលមានឥទ្ធិពលគួរសម សូម្បីតែ មាហន ក៏មិនហ៊ានតមាត់ជាមួយនឹងគាត់ដែរ។ នៅពេលដែលខ្ញុំទៅដល់ខ្ញុំពុំទាន់ចូលទៅខាងក្នុងរោងបាយភ្លាមៗនោះទេ។ ខ្ញុំនៅឈររអាក្បែរគុកចង្រ្កាន ដែលមានចំហាយក្តៅងំ និងមានរងើកភ្លើងក្រហមឆ្អៅសេសសល់មិនទាន់រលត់អស់នៅឡើយ។ បុរសម្នាក់ដែលអង្គុយបែរមុខមកខាងក្រៅរោងបាយ បានឃើញស្រមោលរបស់ខ្ញុំស្ទុងៗ

ហើយក៏ស្រែកសួរមកកាន់ខ្ញុំថា «មិត្តណាកំពុងឈរនៅខាងក្រៅលឺបលៗ មានការអី! ម៉េចក៏មិនចូលមកខាងក្នុងរោងមក?»។ នៅពេលដែលខ្ញុំបានឮដូច្នោះ ខ្ញុំក៏ដើរចូលទៅក្នុងរោងបាយសន្សឹមៗ ហើយឆ្លើយត្រលប់ទៅបុរសនោះវិញថា «បាទ!ខ្ញុំគឺជាយុវជនកងទី៣ នៅមុននេះបន្តិចមានមិត្តម្នាក់បានទៅប្រាប់ខ្ញុំឲ្យមករោងបាយជួបជាមួយនឹង ម៉ែភួង»។ ម៉ែភួង ឃើញខ្ញុំហើយសួរដោយមិនបង្អង់យូរថា «អឺ! កូនឯងហូបបាយឬនៅ? មកហូបបាយជាមួយម៉ែ!»។

ម៉ែភួង គឺជាមនុស្សចាស់ ដែលមានសុជីវធម៌ ហើយរួសរាយរាក់ទាក់ណាស់។ គាត់តែងតែមានទំនាក់ទំនងល្អជាមួយនឹងមនុស្សទូទៅដោយមិនប្រកាន់ថាជាប្រជាជនចាស់ឬប្រជាជនថ្មីនោះទេ។ នេះគឺជាទម្លាប់របស់គាត់ ដែលខ្ញុំតែងតែកត់សម្គាល់ឃើញតាំងពីពេលដែលខ្ញុំបានស្គាល់គាត់។ ខ្ញុំក៏ប្រាប់ទៅម៉ែភួងវិញថា ខ្ញុំទើបតែហូបបាយរួច។ ម៉ែភួង ក៏ប្រាប់ឲ្យខ្ញុំអង្គុយលេងរង់ចាំគាត់ហូបបាយរួចសិន។

ខ្ញុំអង្គុយចាំ ម៉ែភួង លើអង្រឹងបាវក្រចៅមួយ ដែលចងសម្រាប់អង្គុយលេងនៅនឹងសំយាបរោងរង់ចាំទម្រាំគាត់ហូបបាយរួច។ ខ្ញុំអង្គុយយោលអង្រឹងតិចៗ ស្រូបយកក្លិនដ៏ឈ្ងុយឆ្ងាយចេញពីត្រីប្រឡាក់ទើបតែអាំងឆ្អិនថ្មីៗ ដែលបណ្តាលឲ្យខ្ញុំមានអារម្មណ៍រមូលពោះ និងឃ្លានបាយមួយរំពេច។

ក្រោយពីជួបនិងស្តាប់ការណែនាំរបស់ ម៉ែភួង រួចរាល់ហើយ ខ្ញុំបានត្រលប់មករោងស្នាក់របស់ខ្ញុំវិញដោយអស់ក្តីមន្ទិលសង្ស័យនៅក្នុងចិត្ត។ នៅក្នុងរោងស្នាក់មានសភាពស្ងាត់ជ្រងំ។ មនុស្សម្នានាំគ្នាសម្រាកអស់ហើយនៅយប់ថ្មើរនេះ ព្រោះតែភាពហត់នឿយបន្ទាប់ពីធ្វើការងារអស់រយៈពេលពេញមួយថ្ងៃ។ ខ្ញុំលូនចូលទៅក្នុងមុងថ្នមៗស្ងាត់ៗ ដោយមិនទាំងដោះសម្លៀកបំពាក់ចេញផង រួចហើយក៏សំងំដេកលង់លក់ទៅ។

ក្រោយពីធ្វើជាអ្នកកាប់ឧសមួយរយៈពេល ម៉ែភួង បានចាត់តាំងខ្ញុំឲ្យជួយធ្វើកិច្ចការជាច្រើនទៀតនៅក្នុងផ្ទះបាយ។ មិនយូរប៉ុន្មាន ខ្ញុំចេះដាំបាយបានយ៉ាងស្ទាត់ជំនាញ ដោយមានមិត្តនារី ម៉ៅជួយបង្រៀនខ្ញុំ។ ម៉ែភួង ពេញចិត្តនឹងការងារទាំងឡាយ ដែលខ្ញុំបានធ្វើឲ្យគាត់ណាស់ ជាពិសេសគឺការដាំបាយរបស់ខ្ញុំ។ ក្រោយមក ម៉ែភួង បានប្តូរការងាររបស់ខ្ញុំពីអ្នកកាប់ឧសឲ្យមកជាអ្នកដាំបាយវិញម្តង។

ឆ្លងកាត់ពេលវេលាជាច្រើនខែកន្លងផុតទៅ មនោសញ្ចេតនារវាងខ្ញុំ និង ម៉ែភួង ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែស្និទ្ធស្នាល។ ទំនាក់ទំនងរបស់ខ្ញុំនិង ម៉ែភួង ពុំមែនជាទំនាក់ទំនងរវាងអ្នកគ្រប់គ្រងនិងកូនចៅក្រោមបង្គាប់ដូចពីមុនទៀតឡើយ។ វាគឺជាទំនាក់ទំនងប្រកបដោយក្តីអាណិតស្រលាញ់ និងភាពជឿទុកចិត្តគ្នាទៅវិញទៅមក។ ម៉ែភួង តែងតែសួរនាំខ្ញុំពីនេះពីនោះ និងនិយាយលេងសើចជាមួយខ្ញុំរាល់ពេលដែលយើងទំនេរពីការងារ។ ខ្ញុំក៏តែងតែបង្ហាញការគោរពកោតខ្លាចដល់គាត់ជានិច្ច។

ខ្ញុំមានអារម្មណ៍ថាខ្លួនឯងហាក់ដូចជាទទួលបាននូវភាពកក់ក្តៅជាងមុនបន្ទាប់ពីបានជួបនឹង ម៉ែភួង។ ពេលនោះ ខ្ញុំរស់នៅយ៉ាងមានសេចក្តីសុខបំផុត ព្រោះថាមានមនុស្សកំពុងតែយកចិត្តទុកដាក់ចំពោះខ្ញុំ។ កាលពីដំបូង ពាក្យដែលខ្ញុំហៅ ម៉ែភួង ថា «ម៉ែ» គឺគ្រាន់តែជាការគោរពក្នុងនាមគាត់ជាមនុស្សចាស់ទុំ និងមានតួនាទីមើលការខុសត្រូវចំពោះរូបខ្ញុំតែប៉ុណ្ណោះ ប៉ុន្តែពេលនេះ ពាក្យដែលខ្ញុំហៅគាត់ថា «ម៉ែ» គឺជាភាសាដែលផុសចេញពីក្រអៅបេះដូងរបស់ខ្ញុំ។ ខ្ញុំតែងឃើញគាត់ញញឹមប្រកបដោយក្តីរីករើបរីករាយ ហើយមានសេចក្តីសុខជាទីបំផុត នៅពេលដែលបានឮខ្ញុំហៅគាត់ថា «ម៉ែ» ម្តងៗ។ ស្នាមញញឹមរបស់ ម៉ែភួង ពិតជាមានអនុភាពយ៉ាងក្រៃលែងចំពោះរូបខ្ញុំ ព្រោះស្នាមញញឹមនោះបានផ្តល់ឲ្យខ្ញុំនូវសុភមង្គលក្នុងចិត្ត និងជាកម្លាំងចិត្តសម្រាប់ខ្ញុំឲ្យខិតខំស្វះស្វែងបន្តដំណើរនៅលើវិថីជីវិតដ៏វែងឆ្ងាយនៅក្នុងរបបខ្មែរក្រហម។

ពេលវេលាចេះតែរំកិលទៅមុខពីមួយថ្ងៃទៅមួយថ្ងៃ សំណង់អាងទឹកត្រាំកង់ ក៏បានលេចចេញជារូបរាងពេញលេញ។ កម្លាំងកងចល័តទាំងអស់ដែលកំពុងធ្វើពលកម្មនៅក្នុងការដ្ឋាន នឹងត្រូវចាកចេញទៅបំពេញការងារនៅទីតាំងថ្មីតាមការកំណត់ដោយអង្គការ។ នៅពេលរដូវវស្សាបានចាប់ផ្តើមចូលមកដល់ ទឹកភ្លៀងបានហូរចាក់ពីជម្រាលកូនភ្នំតូចៗនៃជួរភ្នំក្រវាញ ចូលមកបំពេញក្នុងផ្ទៃអាងទឹកត្រាំកង់ជារៀងរាល់ថ្ងៃ។ ទឹកភ្លៀង បានហូរច្រោះដីខ្នងទំនប់ផតស្រុតចុះ។ អង្គការ ក៏បានយកកម្លាំងកងចល័តខ្លះ ដើម្បីយកដីពីខាងក្រៅអាងមកចាក់បំពេញខាងលើខ្នងទំនប់ និងការងារជួសជុលទំនប់ផ្សេងៗទៀតនៅនឹងការដ្ឋានទំនប់ត្រាំកង់។

ថ្ងៃមួយ អង្គការបានផ្លាស់ឲ្យ ម៉ែភួង ទៅធ្វើការនៅឯមូលដ្ឋាននៅភូមិព្រែកតូចមួយរយៈសិន។ មិត្តនារី ម៉ៅ ក៏ទៅជាមួយ ម៉ែភួង ដែរ។ មុនពេលដែល ម៉ែភួង ធ្វើដំណើរចាកចេញទៅ គាត់បានប្រាប់ខ្ញុំថា «ម៉ែចាកចេញទៅតែមួយរយៈពេលទេ កូនឯងមើលការខុសត្រូវឲ្យបានល្អនៅទីនេះ ហើយចាំពេលម៉ែត្រលប់មកវិញ ម៉ែនឹងយកដូងខ្ចីមកផ្ញើកូន»។

ក្រោយពេល ម៉ែភួង និងមិត្តនារី ម៉ៅ ចាកចេញផុតទៅ អារម្មណ៍ស្រងេះស្រងោចរបស់ខ្ញុំបានកើតឡើងម្តងទៀត ដូចនៅអំឡុងចុងឆ្នាំ១៩៧៦ នៅពេលដែលឪពុកម្តាយរបស់ខ្ញុំ បានស្លាប់ចោលខ្ញុំ។ ភាពកណ្តោចកណ្តែងបានចូលមកញាំញីផ្លូវចិត្តរបស់ខ្ញុំសាជាថ្មី។ ខ្ញុំព្យាយាមទប់អារម្មណ៍របស់ខ្ញុំ កុំឲ្យក្តីរំជើបរំជួលបង្ហាញចេញមកខាងក្រៅ ដើម្បីបិទបាំងជាមួយមនុស្សទាំងឡាយដែលនៅជុំវិញខ្លួនរបស់ខ្ញុំ។ ក្រោយពេល ម៉ែភួង ចាកចេញទៅផុតមិនបានប៉ុន្មានថ្ងៃផង ស្រាប់តែមនុស្សជំនិតរបស់ មាហាន បានមកហៅខ្ញុំឲ្យទៅជួបនឹង មាហាន នៅឯរោងដាច់ដោយឡែករបស់គាត់ចម្ងាយប្រមាណ ២០០ម៉ែត្រ ពីទីកន្លែងដែលខ្ញុំធ្វើការ។ នៅទីនោះ គឺមានតែ មាហាន ម្នាក់គត់កំពុងតែអង្គុយលើអង្រឹងសាច់ក្រណាត់នីឡុងពណ៌ស្លេ ជក់បារីថ្នាំមូរដោយស្លឹកកកោះបង្ហុយផ្សែងយឺតៗចេញមកក្រៅ ហើយសម្លឹងមើលទៅឆ្ងាយយ៉ាងស្ងៀមស្ងាត់។ ខ្ញុំដើរចូល

ទៅក្នុងរោងដោយកាយវិការលបៗ បន្ទាប់មកខ្ញុំអង្គុយលុតជង្គង់ចុះនៅក្បែរអង្រឹងរបស់ មាហន ដោយទឹកមុខស្រងូតស្រងាត់ និងចាំស្តាប់ មាហន និយាយ។ គាត់សម្លឹងមើលមុខខ្ញុំដោយកែវភ្នែកមុតស្រួចគួរឲ្យខ្លាចជាទីបំផុត។ កាយវិការរបស់ មាហន ធ្វើឲ្យខ្ញុំមានអារម្មណ៍ច្របូកច្របល់នៅក្នុងចិត្តរកស្មានមិនត្រូវ។ គាត់បោះកន្ទុយបារីចោលតាមចន្លោះបង្អួច រួចសម្លឹងមុខខ្ញុំម្តងទៀត ទើបសួរមកកាន់ខ្ញុំដោយសម្តីមួយៗធ្ងន់ៗ។

គាត់សួរខ្ញុំថា «មិត្តឯងធ្វើការនៅក្នុងរោងបាយនេះបានប៉ុន្មានឆ្នាំហើយ?»

ខ្ញុំបានឆ្លើយតបទៅ មាហន ដោយឱនមុខចុះថា «បាទមា! ខ្ញុំធ្វើការនៅរោងបាយនេះ បានប្រហែលជាបីខែហើយ»។

មាហន ស្ងៀមស្ងាត់មិននិយាយស្តីក្នុងរយៈពេលខ្លីហាក់បីដូចជាគាត់កំពុងពិចារណាទៅលើរឿងរ៉ាវអ្វីមួយ។ បន្ទាប់មកទៀត គាត់សម្លឹងមើលខ្ញុំម្តងទៀតហាក់ដូចជាសត្វសាហាវដែលកំពុងតែសម្លឹងមើលកូនម្រឹគដ៏ទន់ខ្សោយ រួចទើបគាត់បន្តសំណួរទៀតថា «មិត្តឯងចង់ធ្វើការនៅផ្ទះបាយតទៅទៀត ឬក៏ចង់ទៅរែកដីវិញ?» ខ្ញុំបានប្រាប់ទៅ មាហន វិញថាស្រេចតែលើ មាហន ចាត់តាំងទៅចុះ។ នៅពេលនោះដែរ មាហន បានលើកទ្រឹស្តីបដិវត្តន៍មកនិយាយជាមួយខ្ញុំថា «កន្លងមកគាត់ធ្លាប់បានឮគេរាយការណ៍ថាខ្ញុំមិនសូវស្មោះត្រង់ជាមួយនឹងសមូហភាព ហើយមានគំនិតបក្ខពួកនិយមទៀតផង»។ គ្រាន់តែបានស្តាប់ឮសម្តី មាហន និយាយភ្លាម ធ្វើឲ្យខ្ញុំនឹកឃើញទៅដល់សម្តីដែលប្រជាជននៅពេលនោះតែងនិយាយខ្សឹបខ្សៀវគ្នាថា «នរណាមិនស្មោះត្រង់ជាមួយសមូលហភាព គឺមានន័យថាមិនស្មោះត្រង់ជាមួយអង្គការ ហើយអ្នកទាំងនោះអាចត្រូវអង្គការហៅយកទៅរៀនសូត្រ រួចហើយក៏បាត់ខ្លួនជារៀងរហូត»។ ខ្ញុំភិតភ័យប្រហោងពោះឆ្អែងដូចគេទាញយកពោះវៀនចេញពីក្នុងពោះ។ ខ្ញុំឡើងស្រាលខ្លួន ហើយខ្ញុំភ័យស្ទើរតែគ្មានព្រលឹងនៅក្នុងខ្លួននោះទេ។ ខ្ញុំខំរកនឹកថាហេតុអ្វីបានជា មាហន ថាខ្ញុំមិនស្មោះត្រង់ជាមួយសមូហភាព។ ប៉ុន្តែទោះបីជារកនឹកយ៉ាងណាក៏នឹកមិនឃើញទាល់តែសោះ។ ថ្វីដ្បិតថាមួយរយៈពេលនេះ

ម៉ែភួង បានប្រគល់សិទ្ធិឲ្យខ្ញុំចេញចូលក្នុងឃ្លាំងស្បៀងជារៀងរាល់ថ្ងៃក៏ពិតមែន ប៉ុន្តែខ្ញុំមិនហ៊ានប៉ះពាល់របស់សមូហភាពនោះទេ។ កុំថាឡើយយកអង្ករឬត្រីងៀត សូម្បីតែប្រហុកក៏ខ្ញុំមិនហ៊ានប៉ះពាល់ដែរ។ ខ្ញុំកំពុងតែស្តុងអារម្មណ៍គិតពិចារណា ដើម្បីរកនឹកពីកំហុសដែល មាហន បានចោទសួរដល់ខ្ញុំ ស្រាប់តែគាត់បន្តឹងសំឡេងសួរខ្ញុំបន្ថែមទៀតថា «ម៉េចមិត្តឯងគិតមិនឃើញមែនទេ? មានមនុស្សបានឃើញមិត្តឯងលាក់បាយក្តាំងទុក ហើយយកឲ្យគ្នីគ្នាមិត្តឯងរាល់យប់នោះអី! ម៉េចមិត្តឯងនឹកឃើញទេ?»

សំណួរនេះបានធ្វើឲ្យខ្ញុំនឹកហួសចិត្តចំពោះអ្នកដែលលួចរាយការណ៍ប្រាប់ មាហន ទាំងគ្មានការពិតទាល់តែសោះ។ ខ្ញុំមិនដឹងថាតើរូបខ្ញុំនិងអ្នករាយការណ៍នោះធ្លាប់មានគំនុំអ្វីជាមួយគ្នាឬយ៉ាងណានោះទេ។ ទោះបីជាយ៉ាងណា ចំពោះរឿងនេះ ខ្ញុំព្យាយាមតាំងចិត្តថាត្រូវតែការពារខ្លួនរបស់ខ្ញុំតាមលទ្ធភាពដែលខ្ញុំមានក្នុងពេលនោះ ទោះជាលទ្ធផលចុងក្រោយទៅជាយ៉ាងណាក៏ដោយ។ មិនបង្អង់យូរ ខ្ញុំបានជម្រាបត្រលប់ទៅ មាហន វិញភ្លាមថា «បាទមា! ខ្ញុំពិតជាធ្លាប់ឲ្យបាយក្តាំងដល់អ្នកដែលមានស្រុកកំណើតជាមួយគ្នាហូបពិតមែន ប៉ុន្តែបាយក្តាំងនោះ ខ្ញុំមិនបានលួចរបស់សមូហភាពនោះទេ»។

មាហន បានសួរបន្តថា «ចឹងមិត្តឯងបានវាមកពីណា?»។ ខ្ញុំក៏ឆ្លើយតបទៅ មាហន ដោយស្មោះត្រង់វិញថា «បាទមា! បាយក្តាំងនោះ គឺជារបប ម៉ែភួង ដែលចែកឲ្យដល់អ្នកធ្វើការនៅក្នុងរោងបាយគ្រប់គ្នាហូប»។ សម្តីម៉ឺងម៉ាត់របស់ មាហន ធ្វើឲ្យខ្ញុំនឹកព្រួយបារម្ភណ៍ខ្លាំងណាស់។

មាហន បន្តនិយាយទៀតថា «ប៉ុន្តែមិត្តឯងធ្វើនេះក៏មិនសមដែរ! មនុស្សរាប់រយនាក់មិត្តឯងឲ្យទៅមនុស្សម្នាក់ឬពីរនាក់ ទង្វើនេះហៅថាបក្ខពួកនិយម បើហូបមិនអស់ម៉េចមិនទុកឲ្យសមូហភាពវិញ? អ្នកផ្សេងសង្ស័យលើមិត្តឯងបែបនេះក៏ត្រូវម៉្យាងដែរ ព្រោះមិត្តកំពុងធ្វើការនៅក្នុងរោងបាយដូចដែលពាក្យគេនិយាយថា មេមាន់ក្រាបពងលើជង្រុកស្រូវ គ្មាននរណាជឿថាវាមិនចឹកស្រូវនោះទេ»។

មាហន ស្ងាត់មាត់លែងសួរដេញដោលខ្ញុំមួយសន្ទុះ ប៉ុន្តែខ្ញុំដឹងថា មាហន មិនងាយបោះបង់ចោលការសង្ស័យលើខ្ញុំឡើយ។ បន្ទាប់មក មាហន បាននិយាយជាក់លក្ខណ្ឌយ៉ាងម៉ឺងម៉ាត់ចំពោះខ្ញុំថា «ណ្ហើយ,ខ្ញុំអត់ឱនឲ្យមិត្តម្តងចុះ ប៉ុន្តែជាច់ខាតមិនឲ្យមានបាតុភាពលេចឮជាលើកទីពីរទៀតនោះទេ។ ខ្ញុំដឹងហើយថាមិត្តឯង និង យាយ ភួង មានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នាខ្លាំងណាស់ ប៉ុន្តែកុំភ្លេចថា អង្គការបញ្ជូនមិត្តឯងមកដើម្បីលត់ដំ មិត្តឯងមិនទាន់ឆ្លងផុតដំណាក់កាលលត់ដំនៅឡើយទេ ដូច្នេះហើយ មិត្តឯងត្រូវតែរក្សាការសម្ងាត់តើស្តាប់បានទេ?»។

ខ្ញុំក៏ឆ្លើយទៅ មាហន ថា «បាទមា ខ្ញុំស្តាប់បានហើយ»។

រួចរាល់ហើយ ខ្ញុំបានត្រលប់មកធ្វើការនៅរោងបាយដូចធម្មតាវិញ។ គ្មាននរណាចាប់អារម្មណ៍ឬក៏សួរនាំខ្ញុំពីរឿងដែលខ្ញុំទៅជួបនឹង មាហន នោះទេ។ ទោះបីជាពេលវេលារំលងផុតទៅជាច្រើនសប្តាហ៍ហើយក៏ដោយ ប៉ុន្តែភាពភ័យខ្លាចដែលជិតជាប់នៅក្នុងចិត្តរបស់ខ្ញុំកន្លងមក នៅពុំទាន់បានជ្រះស្រឡះនៅឡើយទេ។ ពាក្យសម្តីគ្រប់ម៉ាត់របស់ មាហន ដែលនិយាយមកកាន់ខ្ញុំ នៅតែតាមលងបន្លាចចិត្តរបស់ខ្ញុំស្ទើរតែរាល់ថ្ងៃ។ ខ្ញុំពិតជាស្មុគស្មាញនៅក្នុងចិត្តខ្លាំងណាស់។ ខ្ញុំមិនចង់បន្តធ្វើការងារនៅរោងបាយតទៅទៀតទេ។ ថ្វីដ្បិតថា ខ្ញុំបានរួចខ្លួន ប៉ុន្តែខ្ញុំគឺជាមនុស្សម្នាក់ដែលបានស្ថិតក្រោមការសង្ស័យ ហើយមិនងាយនឹងជម្រះឲ្យស្អាតវិញដោយងាយៗនោះឡើយ។ ខ្ញុំចង់វិលត្រលប់ទៅរកដីដូចកាលពីមុនវិញ។ ទោះបីជា ជីវិតរស់នៅតាមកងត្រូវធ្វើការងារធ្ងន់ ហត់នឿយ ហើយថែមទាំងស្ថិតក្នុងជីវភាពលំបាកលំបិន ហូបចុកមិនគ្រប់គ្រាន់ តែបើប្រៀបធៀបទៅនឹងសម្ពាធផ្លូវចិត្តនៅពេលនោះ ខ្ញុំគិតថា ការរស់នៅដូចកាលពីមុនធ្វើឲ្យខ្ញុំមានសេចក្តីសុខដោយពុំចាំបាច់មានការភ័យខ្លាចរាល់ថ្ងៃដូច្នេះ។

មួយរយៈចុងក្រោយនេះ មាហន ឧស្សាហ៍បង្ហាញវត្តមានញឹកញាប់នៅរោងបាយណាស់។ មាហន តែងតែមករោងបាយយ៉ាងស្ងៀមស្ងាត់ ដោយពុំមានមនុស្សហែហមឡើយ។ សកម្មភាពរបស់ មាហន គឺសាមញ្ញបំផុត។ គាត់តែងតែ

ដើរក្រពត់ដៃម្ខាងទៅក្រោយ ហើយដៃម្ខាងទៀតត្បៀតបារីថ្នាំបីតបង្គុយផ្សែង និងដើរយឺតៗក្រឡឹងចង្រ្កានបាយមួយដង្ហើចវិលត្រលប់ទៅវិញបាត់។ ខ្ញុំតាមលួចមើលសកម្មភាពរបស់ មាហន ទាំងភាពតានតឹងនៅក្នុងចិត្ត។

ឥឡូវនេះជិតដល់វេលាដែលត្រូវផ្លាស់ប្តូរទីតាំងទៅការដ្ឋានថ្មី។ ម៉ែភួង និងមិត្តនារី ម៉ៅ នៅតែបាត់ស្រមោលឈឹង។ ខ្ញុំពុំបានទទួលដំណឹងអ្វីពីគាត់ទាល់តែសោះ។ រយៈពេលប៉ុន្មានយប់ផ្ទួនៗគ្នាកន្លងមកនេះ ខ្ញុំចេះតែសុបិនឃើញម្តាយបង្កើតរបស់ខ្ញុំ និងម៉ែភួង នៅជាមួយគ្នា។ ខ្ញុំឃើញគាត់ជជែកគ្នាយ៉ាងស្និទ្ធស្នាលប្រៀបដូចមនុស្សធ្លាប់ស្គាល់គ្នាពីមុនមក។ ខ្ញុំចេះតែលួចគិតនៅក្នុងចិត្តថាតើ ម៉ែភួង មានរឿងអ្វីទេដឹង។ ពីមួយថ្ងៃទៅមួយថ្ងៃ អារម្មណ៍របស់ខ្ញុំមិនស្ងប់ទាល់តែសោះ។ ខ្ញុំចង់ឃើញការវិលត្រលប់របស់ ម៉ែភួង និងមិត្តនារី ម៉ៅ ណាស់។ ខ្ញុំពិតជានឹកស្រណោះសម្តីរបស់ ម៉ែភួង ដែលធ្លាប់និយាយថា «ប្រសិនបើថ្ងៃណាមួយអង្គការដាក់ទិសដៅឲ្យគាត់ត្រលប់ទៅនៅសហករណ៍វិញ តើខ្ញុំទៅជាមួយគាត់ដែរឬទេ?»។ នៅពេលដែលខ្ញុំកាន់តែគិតពីគាត់ គឺរឹតតែធ្វើឲ្យខ្ញុំចង់ចាកចេញទៅរកគាត់ភ្លាមៗ ប៉ុន្តែខ្ញុំគ្មានសិទ្ធិធ្វើយ៉ាងដូច្នោះទេ។ ខ្ញុំបានត្រឹមតែជួបមុខ ម៉ែភួង នៅក្នុងក្តីស្រមៃប៉ុណ្ណោះ។ ហើយខ្ញុំក៏នៅតែចងចាំមិនភ្លេចចំពោះពាក្យសន្យារបស់ ម៉ែភួង ដែលថានឹងយកផ្លែដូងខ្ចីមកផ្ញើខ្ញុំពេលត្រលប់មកវិញ។

នឹកគិតដល់រឿងរ៉ាវអតីតកាលទាំងអស់នោះ ធ្វើឲ្យទឹកភ្នែករបស់ខ្ញុំហូរធ្លាក់ចុះមកដោយមិនដឹងខ្លួន។ ខ្ញុំប្រញាប់ជូតទឹកភ្នែកចេញ និងប្រមូលអារម្មណ៍ត្រលប់មកជាធម្មតាវិញ។ គាប់ជួន រថយន្តក្រុងបានចាប់ផ្តើមបន្ថយល្បឿនរួចបត់ក្បាលចូលក្នុងចំណតដើម្បីដាក់ភ្ញៀវចុះមុនពេលបន្តដំណើរទៅកាន់ប៉ោយប៉ែតបន្តទៀត។ ខ្ញុំបានយួរកាបូបចុះពីរថយន្តទាំងដំណើរឆេងឆោងព្រោះអារម្មណ៍របស់ខ្ញុំនៅមិនទាន់ឃ្លាតឆ្ងាយពីក្តីស្រមៃចំពោះខ្សែជីវិតពីអតីតកាលជាង៤០ឆ្នាំកន្លងផុតទៅនោះទេ។

ចប់


Documentation Center of Cambodia DC-Cam

២

រឿងពេលដែលម៉ែឃ្លាតទៅ

អ្នកនិពន្ធ ៖ អៀ ហុកនីម

Documentation Center of Cambodia (DC-Cam)

២ ~ រឿង ពេលដែលម៉ែឃ្លាតទៅ

ក្នុងខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ ៨ឆ្នាំ។ ខ្ញុំនៅចាំយ៉ាងច្បាស់ថា ពេលនោះ ខ្ញុំកំពុងលេងផ្លុំភឿកនៅលើបង្គាន់ដៃសាលារៀនជាមួយមិត្តភក្តិប្រុសៗ ពីរបីនាក់ ចំណែកឯមិត្តភក្តិដទៃទៀតនាំគ្នាចុះទៅលេងនៅទីធ្លាមុខសាលារៀន។

ចូលដល់ក្នុងថ្នាក់ សំឡេងជជែកគ្នាពីការចេញលេងលាន់ឮកងរំពង រកស្តាប់អ្វីមិនឮទាល់តែលោកគ្រូដើរចូលមក ទើបសិស្សគ្រប់គ្នាស្ទុះក្រោកឈរព្រមគ្នាឮតែព្រឺបៗ ស្ងាត់មាត់ជ្រៀប។ លោកគ្រូឈានជើងដើរឡើងលើជើងទម្រពីមុខក្តារខៀន ទើបឲ្យសិស្សអង្គុយចុះតាមសម្រួល។

លោកគ្រូក៏ចាប់ផ្តើមនិយាយផ្តែផ្តាំថា «ចាប់ពីស្អែកទៅយើងវ៉ាកងតូច ចូលឆ្នាំរួចហើយ បានយើងចូលរៀនវិញ នៅផ្ទះខំប្រឹងរៀន កុំទុកសៀវភៅចោលឮទេ!»។ សិស្សក៏ឆ្លើយ បាទ/ចាស៎ ព្រមៗគ្នា។ មិនបង្អង់យូរ លោកគ្រូ ក៏បាននិយាយបន្តទៀតថា «នៅផ្ទះកុំគេងទ្រមក់ ឆាប់ក្រោកពីព្រលឹម រៀនសរសេរអក្សរផ្ចង់ ឧស្សាហ៍សរសេរពេលព្រឹក ដើម្បីឲ្យធ្លាប់ដៃ ឲ្យអក្សរស្អាតល្អ»។ និយាយចប់សព្វគ្រប់លោកគ្រូ ក៏អនុញ្ញាតឲ្យយើងចេញទៅផ្ទះ។ សំឡេងសិស្សស្រែកហ៊ោកញ្ជៀវសប្បាយអរបានចេញទៅផ្ទះនិងឈប់សម្រាកក្នុងថ្ងៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរ។

មិននឹកស្មានថា ពាក្យ«វ៉ាកងតូច» របស់លោកគ្រូ បានក្លាយទៅជាវិស្សមកាលយ៉ាងយូរដូច្នេះសោះ។ ចប់ពិធីបុណ្យចូលឆ្នាំខ្មែរសឹងតែមិនទាន់ គឺនៅក្នុងថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវហាមឃាត់មិនឲ្យទៅសាលារៀនទៀតទេ ព្រោះសភាពការណ៍ស្រុកទេសប្រែប្រួលៗ ខ្ញុំឮតែចាស់ៗ នាំគ្នាជជែកគ្នាពីរឿងកន្សែងក្រហមចូលមកដល់ណា។ ខ្ញុំមិនចាប់អារម្មណ៍នឹងរឿងមនុស្សចាស់

ឡើយ។ ម៉ោងប្រហែល ២រសៀល ខ្ញុំឃើញរថក្រោះកង់កៅស៊ូបើកកាត់មុខផ្ទះរបស់ខ្ញុំបីគ្រឿងផ្ទុកដោយកងទ័ពស្លៀកពាក់ខោអាវខ្មៅពេញៗ ទៅបាត់បានប្រហែលមួយម៉ោង ទើបឃើញពួកគេត្រលប់មកវិញលឿនណាស់ធ្វើដំណើរឆ្ពោះចេញទៅខាងព្រំដែន។ មួយសន្ទុះក្រោយមក ឪពុករបស់ខ្ញុំមកដល់ផ្ទះ រួចប្រាប់ម្តាយរបស់ខ្ញុំថា «សៀមមកនិមន្តលោកតាឪទៅបាត់ហើយ»។ ខ្ញុំតក់ស្លុតជាខ្លាំង ព្រោះលោកតាឪ ជាព្រះចៅអធិការវត្តកោងកាង ដែលមិត្តភក្តិនៅសាលារៀនរបស់ខ្ញុំ ធ្លាប់បានទៅជួយគាត់រើសថ្មនៅថ្ងៃធ្វើហត្ថកម្ម ដើម្បីសាងសង់ស្ពានអូរតង ហើយពេលនោះ ព្រះតេជគុណ ក៏បានចែកឆាយាល័ក្ខណ៍របស់លោកដល់អ្នកចូលរួមម្នាក់មួយៗ ដើម្បីទុកជារបស់អនុស្សាវរីយ៍ដែរ។

ចាប់តាំងពីពេលនោះមក ខ្ញុំឃើញម្តាយរបស់ខ្ញុំរវល់ណាស់ រៀបចំមិនចេះចប់មិនចេះហើយទេ។ ជួនកាល ខ្ញុំឃើញគាត់ដេរកូនថង់រែងៗរួចយកមកព័ទ្ធចង្កេះសាកលមើល។ ពេលខ្លះគាត់យកមកលនឹងចង្កេះរបស់ខ្ញុំក៏មានដែរ។ ក្រៅពីនោះ ខ្ញុំឃើញឪពុករបស់ខ្ញុំដឹកអង្ករពីរទៅបីបាវឆ្នូត យកមកទុកក្នុងផ្ទះ។ គាត់ថាយ៉ាងណាៗមានអង្ករទុកឲ្យកូនស៊ី។ ខ្ញុំមិនខ្វល់អ្វីឡើយ គិតតែពីលេងជាមួយប្អូនៗរបស់ខ្ញុំ។ ពេលនឹកដល់សំដីលោកគ្រូដែលប្រាប់កុំទុកសៀវភៅចោលខ្ញុំពេលខ្លះក៏ចាប់កាន់សៀវភៅមកអានខ្លះៗ កុំឲ្យភ្លេចមេរៀនដែលបានរៀន។

ព្រលឹមស្រាងៗថ្ងៃមួយក្នុងខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញឡានហ្ស៊ីប មានដាក់មេក្រូ (ឧបករណ៍បំពងសំឡេង) ពាក់ពីលើឡាន បើកចុះឡើងៗ ប្រកាសឲ្យប្រជាជនចាកចេញពីលំនៅឋាន។ ពួកគេប្រកាសថា «បងប្អូនពុកម៉ែទាំងអស់គ្នាសូមប្រញាប់រួសរាន់ចាកចេញពីលំនៅឋាន ដើម្បីទុកទីកន្លែងឲ្យបក្សដើម្បីរៀបចំសណ្តាប់ធ្នាប់ឡើងវិញ ព្រោះខ្លាចយន្តហោះអាមេរិកមកទម្លាក់គ្រាប់បែកសម្លាប់បងប្អូនពុកម៉ែម្តងទៀត។ បងប្អូនអាចវិលត្រលប់ទៅស្រុកកំណើតរបស់បងប្អូនរៀងៗខ្លួនបាន។ អ្នកណាកើតនៅស្រុកណា អាចវិលត្រលប់ទៅស្រុកនោះវិញបាន បក្សមិនហាមឃាត់បងប្អូនពុកម៉ែទេ តែបើបងប្អូនណាមិនព្រមចាកចេញ បក្សនឹងបោសសម្អាត» ហើយពួកគេក៏បានស្រែកបន្តដដែលៗថា «សូមស្តាប់ៗ! បងប្អូនពុកម៉ែទាំងអស់គ្នា សូមរួសរាន់ចាកចេញពីលំនៅឋានឲ្យបានឆាប់»។

ខ្ញុំមិនដែលឮ និងឃើញព្រឹត្តិការណ៍បែបនេះទេ ហើយខ្ញុំភ័យណាស់មិនហ៊ានដើរទៅណាឆ្ងាយពីឪពុករបស់ខ្ញុំឡើយ។ កងទ័ពអាវខ្មៅមានកាំភ្លើងស្ពាយជាប់លើស្មា បានធ្វើសកម្មភាពបែបនេះពីរបីថ្ងៃ ធ្វើឲ្យទីប្រជុំជនទាំងមូលមានសភាពរំជើបរំជួលជាខ្លាំង ហើយនៅទីបំផុត គេក៏ប្រកាសដេញប្រជាពលរដ្ឋឲ្យចេញជាដាច់ខាត។ ក្រុមគ្រួសាររបស់ខ្ញុំ ក៏ដូចក្រុមគ្រួសារដទៃទៀត ត្រូវចាកចេញពីលំនៅឋានទាំងអស់គ្នាដោយក្តីអាឡោះអាល័យ។ ព្រឹកព្រលឹមស្រាងៗ សំឡេងខ្ទៀវខ្ទារកងរំពងពេញលើដងវិថី ដោយមានចំនួនមនុស្សកកកុញ និងយានយន្តគ្រប់ប្រភេទប្រជ្រៀតគ្នាស្ទើរតែទៅមុខមិនរួច។ រថយន្តឡង់រ៉ូវែរបស់ឪពុកខ្ញុំបានលូនសន្សឹមៗពីក្រោយរថយន្តដទៃទៀតបន្តកន្ទុយគ្នាឥតដាច់។ កងទ័ពអាវខ្មៅធ្វើការយាមកាមយ៉ាងតឹងតែងបំផុត ដោយសារស្រុករតនៈមណ្ឌលនៅជាប់នឹងព្រំដែនថៃ ហើយពួកគេមិនឲ្យអ្នកធ្វើដំណើរដើរឆ្ពោះទៅទិសខាងព្រំដែនឡើយ។ កងទ័ពអាវខ្មៅលើកដៃជាសញ្ញាឲ្យមនុស្សទាំងអស់ធ្វើដំណើរតម្រង់ចូលមកក្នុងខេត្ត។ អ្នកដំណើរទាំងអស់មិនហ៊ានប្រឆាំងនឹងបទបញ្ជាកងទ័ពអាវខ្មៅទេ ព្រោះពួកគេមានកាន់កាំភ្លើងច្រួងច្រាង ហើយក៏មានបាញ់កាំភ្លើងឡើងលើមួយគ្រាប់ពីគ្រាប់ ដើម្បីធ្វើឲ្យអ្នកដំណើរទាំងអស់ភ័យខ្លាចដែរ។ មិនយូរប៉ុន្មានស្រាប់តែមានការកកស្ទះរថយន្តទៅមុខមិនរួចនៅត្រង់ចំណុចភូមិស្តៅ។ ឪពុករបស់ខ្ញុំ ចុះទៅមើលមួយសន្ទុះ ក្រោយមកគាត់ត្រលប់មកប្រាប់ម្តាយរបស់ខ្ញុំវិញថា «ឯង! គេលែងឲ្យយើងយកឡានទៅមុខទៀតហើយ គេប្រមូលទុកច្រើនណាស់បន្តិចទៀតឯងឃើញហើយ មួយវាលធំ សុទ្ធតែឡាន កង់ និងម៉ូតូ។ គេឲ្យយើងទុកចោលនៅទីនោះ ហើយឲ្យយើងដើរទាំងអស់គ្នា»។ «អីចឹងយើងធ្វើយ៉ាងម៉េចទៅឯង? » ម្តាយរបស់ខ្ញុំសួរត្រលប់ទៅវិញ។ ឪពុករបស់ខ្ញុំបានប្រាប់ថាឲ្យពួកយើងយកតែរបស់ណាសំខាន់ៗទៅតាមខ្លួនបានហើយ ព្រោះឮកងទ័ពប្រកាសថាមិនយូរទេនឹងបានវិលត្រលប់មកវិញ។ ម្តាយរបស់ខ្ញុំបង្ហាញទឹកមុខព្រួយបារម្ភណ៍ណាស់ ព្រោះខ្លាចយករបស់របរហូបទៅតាមខ្លួនមិនរួច អង្ករក៏ធ្ងន់ចំណែកឯកូនសុទ្ធតែនៅតូចៗ។

ឡានរបស់ខ្ញុំរុលទៅមុខបានបន្តិចស្រាប់តែឮសំឡេងកញ្ឆែផ្ទុំច្រេចៗ បញ្ឈប់ឲ្យរថយន្តចុះចតនៅលើវាលស្រែ។ ខ្ញុំក្រឡេកមើលទៅឃើញសុទ្ធតែឡាន ម៉ូតូ និងកង់ ច្រើនណាស់ចតតម្រៀបគ្នា។ ឪពុករបស់ខ្ញុំឈប់ឡានភ្លាម ក៏រត់ទៅរកពូដែលមានរ៉ឺម៉ក ដើម្បីគិតគូរពីការរៀបចំដាក់សម្ភារៈ។ ខ្ញុំចុះពីលើឡានជាមួយម្តាយរបស់ខ្ញុំ ហើយបានឃើញសភាពជ្រួលច្របល់ខុសពីធម្មតា។ សំឡេងស្រែកយំរបស់កុមារតូចៗនៅក្រោមកំដៅថ្ងៃ សំឡេងស្រែកហៅរកគ្នាលាយឡំនឹងសំឡេងនិយាយរបស់ចំនួនមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់រកស្តាប់អ្វីមិនឮ។ ឪពុករបស់ខ្ញុំត្រលប់មកវិញយ៉ាងរួសរាន់មកបើកទ្វារឡាន ដើម្បីរើយកអីវ៉ាន់ចេញទៅដាក់លើរ៉ឺម៉ក។

ឪពុករបស់ខ្ញុំនិយាយថា «តោះឯង! រៀបចំប្រញាប់ចេញទៅ អង្គរយើងធ្វើជាមួយរ៉ឺម៉ក អាសុខ ចំណែករបស់របរដទៃទៀតយើងកាន់ខ្លួនយើង មើលរបស់ណាស្រាលៗឲ្យកូនជួយយួរខ្លះទៅ»។ ពេលឪពុករបស់ខ្ញុំនិយាយចប់ ម្តាយរបស់ខ្ញុំក៏ហុចកំសៀវទឹកមកឲ្យខ្ញុំជួយកាន់ ហើយប្រាប់ឲ្យខ្ញុំស្ពាយកាបូបមួយឲ្យជាប់នឹងខ្លួន។ ប្អូនរបស់ខ្ញុំ ក៏ស្ពាយកាបូបមួយដែរ។ យើងយកតែរបស់ចាំបាច់សម្រាប់ហូបនិងប្រើប្រាស់ប្រចាំថ្ងៃបន្តិចបន្តួចតាមខ្លួនតែប៉ុណ្ណោះ។ ទីបំផុត យើងត្រូវធ្វើដំណើរដោយថ្មើរជើងទាំងអស់គ្នា។ ក្រុមគ្រួសារខ្លះរែកអីវ៉ាន់ ខ្លះទូល ខ្លះលី ខ្លះមានរទេះដាក់រុញ ហើយខ្លះទៀតដាក់ឪពុកម្តាយជារាលើរទេះអូស។ គ្រប់រូបភាពទាំងអស់បានកើតឡើងនៅពេលជម្លៀសនេះ។ ខ្ញុំយួរកំសៀវទឹក យួរកាន់តែយួរកាន់តែធ្ងន់ឡើងៗ រួចខ្ញុំក៏លួចបើកគម្របកំសៀវមើលឃើញមានស្លាបព្រា សមចង្កឹះ ឡើងកន្លះកំសៀវ តែខ្ញុំមិនហ៊ានបោះចោលទេ សុខចិត្តទ្រាំយួរផងលីផង។ យើងចេះតែបន្តដំណើរហូតដល់មេឃធ្លាក់ពន្លឺ ស្រាប់តែមានភ្លៀងមួយមេយ៉ាងធំ។ មេឃប្រែជាងងឹតស្តុបរកមើលអ្វីមិនយល់ ឮតែសំឡេងស្រែករកកូនចៅ។ ភ្លៀងធ្លាក់ជោគជាំដី យើងមើលអ្វីមិនឃើញឡើយ សំឡេងស្រែកថ្ងូររបស់មនុស្សចាស់ក៏លាន់ឡើងដោយសារអិលដួល។

សំឡេងស្រែកថ្ងូរពោរពេញទៅដោយការឈឺចាប់បែបនេះខ្ញុំពុំធ្លាប់បានឮទេ។ ពេលនេះ ខ្ញុំមានការភិតភ័យ និងសង្វេគក្នុងចិត្តជាខ្លាំង។ ខ្ញុំកំពុងតែគិតពិចារណាអំពីរឿងទាំងនេះ ស្រាប់តែឮសំឡេង «ង៉ាៗ» ដោយការឈឺចាប់ដែលជាសំឡេងទារកស្រែកយំ។ ពុទ្ធោអើយ! នេះប្រហែលជាផ្លូវទៅកាន់ឋាននរកទេដឹង។ ខ្ញុំកាន់ដៃបងប្អូនរបស់ខ្ញុំជាប់មិនហ៊ានឲ្យរបូតទេ។ ចំណែកឯម្តាយរបស់ខ្ញុំវិញ ពប្អូនស្រីរបស់ខ្ញុំ ដែលទើបមានអាយុជាងមួយឆ្នាំ។ ឪពុករបស់ខ្ញុំ ទៅជួយរុញរ៉ឺម៉កពូសុខ។ «កាន់ដៃបងប្អូនឲ្យជាប់កុំឲ្យរបូតណា ម៉ាក់មើលមិនឃើញទេ» ម្តាយខ្ញុំស្រែកប្រាប់ ប៉ុន្តែកំពុងតែដើរស្ទាបៗ ស្រាប់តែឮសូរព្រួស។ «អូយ! បងជួយខ្ញុំផង» ប្អូនរបស់ខ្ញុំស្រែក។ ឮសំឡេងប្អូនរបស់ខ្ញុំស្រែកដូច្នោះ ខ្ញុំស្ទុះទាំងងងឹតស្លុងរាវរកប្អូន ស្រាប់តែខ្ញុំអិលជើងដួលធ្លាក់ចូលទៅក្នុងកក់ដែរ។ យើងដើរទាំងងងឹតស្លុងរហូតដល់កន្លែងដែលកងទ័ពឲ្យឈប់សម្រាក ទើបឃើញមានភ្លើងដុតបំពក់ភ្លឺព្រោងព្រាត។ កងទ័ពអនុញ្ញាតឲ្យយើងសម្រាកនៅទីនោះមួយយប់។

លុះព្រឹកឡើងមនុស្សឈរត្រៀបត្រាមិនទាន់ដឹងថាទៅណាមកណានៅឡើយទេ។ ម៉ោងប្រហែល៩ព្រឹក ទើបឃើញពូម្នាក់ស្លៀកពាក់ខោអាវខ្មៅមកបែងចែកឲ្យយើងទៅតាមទិសដៅផ្សេងៗគ្នា។ ខ្ញុំឃើញឪពុករបស់ខ្ញុំរែកថង់អង្ករពីរថង់ព្រោះកងទ័ពឲ្យ ពូសុខ ធ្វើដំណើរទៅកន្លែងផ្សេងពីយើង។ កងទ័ពលែងឲ្យយើងយកកន្ទុយរ៉ឺម៉កទៅជាមួយទៀត។ ពេលយើងទៅដល់ទីតាំងមួយដីរាងទួលបន្តិច ខ្ញុំឃើញមានតែរោងមួយធំ តែខ្ញុំមិនដឹងថាជារោងអ្វីទេ។ កងទ័ពឲ្យយើងឈប់សម្រាកនៅទីនោះ។ លុះស្អែកឡើង ខ្ញុំឃើញឪពុករបស់ខ្ញុំទៅកាប់បានកូនឈើយកមកធ្វើកូនខ្ទមតូចមួយដើម្បីស្នាក់នៅ។ ជីវិតរបស់ខ្ញុំ និងក្រុមគ្រួសារព្រមទាំងប្រជាជនទាំងអស់ ត្រូវបានផ្លាស់ប្តូរជីវភាពទាំងស្រុងចាប់តាំងពីពេលនោះមក។ ក្រោយមកអ្នកដឹកនាំនៅទីនោះ បានប្រមូលប្រជាជនឲ្យទៅចូលរួមប្រជុំ ដើម្បីទទួលយកការផ្សព្វផ្សាយព័ត៌មានពីរបបដឹកនាំថ្មី។ មនុស្សប្រុសម្នាក់ដែលមានរាងចំណាស់បន្តិច គេហៅគាត់ថា គណៈកង បានដើរឈរឡើងហើយនិយាយថា «បងប្អូនទាំងអស់គ្នា! ថ្ងៃនេះយើងបានមកជួបជុំគ្នានៅទីនេះ គឺនៅក្នុង

ភូមិអន្លង់មៀន។ យើងខ្ញុំបានធ្វើការតស៊ូខ្លាំងក្លាណាស់ទម្រាំអាចវាយផ្តួលរំលំរបបសក្តិភូមិ នាយទុន ប្រតិកិរិយា វណ្ណៈជិះជាន់បាន។ ដូច្នេះយើងខ្ញុំសង្ឃឹមថា បងប្អូនអ្នកចំណូលថ្មីទាំងអស់ នឹងរួបរួមគ្នា ដើម្បីកសាងបដិវត្តន៍យើងឲ្យបានរុងរឿងប្តុំថ្កើង ទៅមុខជានិច្ច ហើយចាប់ពីថ្ងៃនេះតទៅ យើងមានតែវណ្ណៈកសិករតែមួយគត់ គ្មានវណ្ណៈជិះជាន់ គ្មានអ្នកមាន គ្មានអ្នកក្រទេ គឺយើងរស់នៅដោយស្មើភាពគ្នា ជយោ!បដិវត្តន៍ដ៏រុងរឿង»។ សំឡេងទះដៃលាន់ឮព្រមៗគ្នាឡើងកងរំពងមួយរំពេច ហើយកងទ័ពអាវខ្មៅនោះក៏និយាយបន្តទៀតថា «ដូច្នេះសូមបងប្អូនប្រមូលទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិសួនតួទាំងអស់ មកប្រគល់ជូនអង្គការយើង ដើម្បីទុកជាសម្បត្តិរួម ហើយចាប់ពីថ្ងៃស្អែកនេះតទៅ បងប្អូននឹងមកហូបបាយរួមគ្នានៅរោងបាយមួយនោះ (គាត់លើកដៃចង្អុលទៅរោងធំមួយ) នៅពេលឮសំឡេងវាយជួងគ្រប់បីដង។ ដូច្នេះសូមបងប្អូនទៅយករបស់របរដែលមានទាំងប៉ុន្មាន យកមកប្រគល់ជូនអង្គការឥឡូវនេះភ្លាម។ បើនរណាប្រមូលមិនទាន់យកមកប្រគល់ថ្ងៃស្អែកក៏បាន»។

មិនទាន់ចប់ការប្រជុំផង អ្នកខ្លះទៅយកអីវ៉ាន់មកប្រគល់ឲ្យគេរួមមានឆ្នាំងបាយ អង្ករ សម្លៀកបំពាក់ លុយកាក់ មាសប្រាក់ រូបថតក្រុមគ្រួសារក៏មានព្រមទាំងឯកសារផ្សេងទៀត។ ម្តាយរបស់ខ្ញុំ ក៏ទៅយករបស់របរមួយចំនួនមកឲ្យគេដែរ ប៉ុន្តែខ្ញុំពុំឃើញម្តាយរបស់ខ្ញុំយកមាសឬប្រាក់កាសអ្វីមកឡើយ។ ក្រោយមកទាំងខ្មែរក្រហមនិងប្រជាជន ចាប់ផ្តើមប្រើភាសាប្លែកៗ ដែលខ្ញុំមិនធ្លាប់ឮ និងបានរៀនកន្លងមកទេ ដូចជា ពាក្យសមមិត្ត, សមមិត្តនារី, មិត្តបង, កងឈ្លប, គណៈតំបន់, គណៈសហករណ៍, មេកង និងមេក្រុមជាដើម។

ថ្ងៃស្អែកជាថ្ងៃថ្មី ព្រឹកព្រលឹមស្រាងៗ កងឈ្លបអាវខ្មៅចាប់ផ្តើមដើរចូលមកមើលតាមផ្ទះ។ ខ្ញុំឃ្លានណាស់ ព្រោះម្តាយរបស់ខ្ញុំធ្លាប់ចម្អិនអាហារឲ្យញុំាជារៀងរាល់ព្រឹកមុននឹងទៅសាលារៀន ប៉ុន្តែឥឡូវនេះពោះទទេរីឯប្អូនតូចៗរបស់ខ្ញុំធ្វើមុខក្រៀមក្រំដោយក្តីស្រេកឃ្លាន។ ការផ្លាស់ប្តូរដ៏ឆាប់រហ័សបែបនេះពិបាកនឹងទទួលយកណាស់។ កងឈ្លបចេញផុតពីផ្ទះរបស់ខ្ញុំបានបន្តិច ស្រាប់តែខ្ញុំឮ

សំឡេងស្រែកអង្វរបស់ស្ត្រីម្នាក់ថា «មិត្តបង! សូមអាណិតមេត្តាផង កូនរបស់ខ្ញុំនៅតូចវាឃ្លាន វាមិនអាចទ្រាំបាន ខ្ញុំមនុស្សចាស់មិនអីទេ តែអាណិតក្មេង»។ កងឈ្លបមិនព្រមទេ ហើយស្រែកថា «មិនបានទេ! អង្គការត្រូវតែបោសសម្អាតឲ្យអស់ក្អែលសក្តិភូមិ សួនតួនិយម វណ្ណៈនាយទុននិយម»។ ស្ត្រីម្នាក់នោះនៅតែនិយាយលន់តួរៀបរាប់ថា «ខ្ញុំជាកូនកសិករ ជាអ្នកធ្វើស្រែចម្ការទេ ប្តីរបស់ខ្ញុំស្លាប់ដោយសារតែគ្រាប់ផ្លោងធ្លាក់ត្រូវ ពេលកំពុងនេសាទត្រី ធ្វើឲ្យខ្ញុំបាត់បង់ប្តី កូនរបស់ខ្ញុំកំព្រាឪពុក ទើបធ្លាក់ខ្លួនមកលំបាកយ៉ាងដូច្នេះ»។

«យើ! អា១៧មេសា ពូកែនិយាយណាស់រ៉ឺយ តោះយើងទៅ» កងឈ្លបនិយាយហើយក៏ដើរចេញទៅ។

ខ្ញុំ ព្រមទាំងម្តាយឪពុក និងប្អូនៗ ដោយមិនដែលជួបប្រទះនូវហេតុការណ៍បែបនេះ បាននាំគ្នាលួចមើលក៏ឃើញឈ្លបបីនាក់នោះ យួរឆ្នាំងបាយនៅក្តៅហុយៗនៅឡើយ ម្នាក់ទៀតកាន់ចានស្លាបព្រា និងអីវ៉ាន់ផ្សេងៗទៀតដើរចេញទៅ។ ឃើញសភាពបែបនេះ ខ្ញុំលែងមានអារម្មណ៍ឃ្លានទៀតហើយ ចំណែកឪពុករបស់ខ្ញុំ គ្រវីក្បាលជាប់រហូត រួចពោលអ៊ូតិចៗម្នាក់ឯងថា «សោកនាដកម្មបានមកដល់ហើយ»។ យើងអង្គុយជុំគ្នាផ្ទាល់ដីក្នុងកូនខ្ទមតូចមួយ ដែលមានដំបូលប្រក់ស្បូវ ពុំមាននរណានិយាយអ្វីមួយម៉ាត់សោះឡើយ។ សំឡេងជួងបន្លឺឡើងសូរម៉ាង ម៉ាង ម៉ាង ខ្ញុំស្រឡាំងកាំងមួយសន្ទុះហាក់ច្រឡំនឹងរឿងអ្វីមួយ ធ្វើឲ្យឪពុកម្តាយរបស់ខ្ញុំសើច ហើយលាន់មាត់ថា «កូននេះប្រហែលច្រឡំស្មានតែជួងសាលាហើយមែនទេ?»។ ឮម្តាយឪពុកនិយាយដូច្នោះ ខ្ញុំមានអារម្មណ៍ចង់អួលដើមកនឹកសាលា នឹកមិត្តភក្តិ នឹកផ្ទះវីឡាធំស្តឹមស្តែ ថែមទាំងនឹកម្ហូបអាហារឆ្ងាញ់ៗ តែឥឡូវមកអង្គុយកំសត់ទាំងអស់គ្នា។ ខ្ញុំចាប់ទាញដៃប្អូនបម្រុងដើរទៅរោងបាយ តែត្រូវបានម្តាយរបស់ខ្ញុំប្រាប់ថា «មិនទាន់ទេកូន ចាំឮសំឡេងជួងបីដងសិន» ចប់សំដីម្តាយរបស់ខ្ញុំ ជួងទីពីរក៏បន្លឺឡើង អាប្អូនរបស់ខ្ញុំ ក៏និយាយទៅកាន់ម្តាយខ្ញុំថា «ដើរទៅតែម្តងទៅម៉ាក់ ទំរាំដើរដល់គេវាយជួងលើកទីបីហើយ»។ ខ្ញុំងាកទៅមើលមុខម្តាយរបស់ខ្ញុំ ដើម្បីរង់ចាំទទួលចម្លើយពីគាត់ ប៉ុន្តែរំពេចនោះ ខ្ញុំបែរជាឃើញគាត់ រលីងរលោងទឹកភ្នែកទៅវិញ។

ពេលនោះជួងលើកទីបីក៏បន្លឺឡើងល្មម ប្អូនរបស់ខ្ញុំចាប់ទាញដៃរបស់ខ្ញុំដើរទៅទាំងទទឹងទទែង ចំណែកឯ ម្តាយឪពុករបស់ខ្ញុំ ដើរតាមពីក្រោយ។ ទៅដល់រោងបាយ ខ្ញុំឃើញគេរៀបចានលើតុបីជួរយ៉ាងវែង ដោយមានរៀបចានបួន និងមួយនៅចំកណ្តាលដូចៗគ្នា។ ចាស់ៗ នាំគ្នាអង្គុយលើក្តារទម្រ។ ចំណែកខ្ញុំ និងប្អូនរបស់ខ្ញុំទាល់តែឡើងចោងលើក្តារទម្រនោះទើបអាចហូបបាន។ មនុស្សពីរនាក់ សែងចានដែកធំមួយពេញដោយបបរក្តៅមានលាយចំណិតចេកខ្ទឹងផង ហើយម្នាក់ទៀតគឺជាអ្នកដួសដាក់ចានឲ្យមួយវែកៗ មានឆៃពៅហាន់យ៉ាងល្អិតប្រហែលពីរស្លាបព្រានៅក្នុងចានចំកណ្តាលតុសម្រាប់គ្នាបួននាក់។ ខ្ញុំមិនចូលចិត្តបបរទេ ទោះបីមិនស្រួលខ្លួនម្តងម្កាលក៏ខ្ញុំមិនដែលហូបបបរដែរ ប៉ុន្តែពេលនេះ ខ្ញុំឃ្លានខ្លាំងណាស់ដូច្នេះខ្ញុំត្រូវតែហូបហើយ។ គ្រាន់តែចាប់ផ្តើមថ្ងៃដំបូងរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមភ្លាម យើងត្រូវហូបបបរលាយចេកខ្ទឹភ្លាម។ ខ្ញុំពិតជាមានអារម្មណ៍ថាពិបាកលេបណាស់ហើយក្មេងៗដទៃទៀតយំមិនព្រមហូបឡើយ។ នៅពេលដែលខ្ញុំកំពុងតែប្រឹងលេប គេក៏សែងចានដែកបបរមកដល់ម្តងទៀត។ «មានអ្នកចង់ថែមបបរទេ?» អ្នកដួសបបរសួរ។ ឪពុករបស់ខ្ញុំ ក៏ហុចចានទៅអ្នកដួសបបរជាមួយវាចារកបគួរថា «សុំថែមបន្តិចមកមិត្តបង»។

ហូបបបរហើយ យើងទាំងអស់គ្នាក៏វិលត្រលប់ទៅតាមកន្លែងរៀងៗខ្លួនវិញ។ ពេលនោះ កងឈ្លបមិនទាន់ឲ្យប្រជាជនទាំងអស់ធ្វើអ្វីទេ។ លុះបីថ្ងៃក្រោយមក ភាពនិរាសព្រាត់ប្រាស់គ្នាក៏កើតមានឡើង។ ថ្ងៃរៀបនឹងអស្តង្គតទៅហើយ សំឡេងកញ្ជែងចម្លែកមួយបានបន្លឺឡើងជាច្រើនដង។ រំពេចនោះក៏លេចចេញកងឈ្លបមួយក្រុម ដើរមកប្រាប់តាមផ្ទះឲ្យមនុស្សចាស់ៗទៅប្រជុំថា «សមមិត្តទាំងអស់គ្នាយប់នេះអង្គការមានការប្រជុំជាប្រញាប់ ទៅនាំគ្នាទៅឲ្យលឿនឡើង»។ នៅពេលកងឈ្លបមកបង្គំដល់ផ្ទះបែបនេះ ម្នាក់ៗពុំមាននរណាប្រកែកទេ។ ម្តាយរបស់ខ្ញុំទាញយកក្រមាមួយមកទទូរក្បាលរួចងាកមកនិយាយថា «នាំគ្នានៅផ្ទះកុំដើរចេញទៅណា ណាកូនណា មើលប្អូនផង យប់ហើយខ្លាចពស់ ខ្លាចក្អែបឮទេ?» ខ្ញុំក៏ឆ្លើយទៅគាត់វិញភ្លាមៗថា «បាទម៉ែ! ខ្ញុំដឹងហើយ»។

ម្តាយឪពុករបស់ខ្ញុំចេញទៅបាត់ ខ្ញុំ និងប្អូនៗ នាំគ្នាអង្គុយចាំគាត់ត្រលប់មកវិញ។ ខ្ញុំចាំយូរទៅៗក៏នាំប្អូនដេកលើគ្រែឫស្សីលក់បាត់ទៅ មិនដឹងគាត់ត្រលប់មកវិញពេលណាទេ ស្រាប់តែឮគាត់ទាំងពីរនាក់និយាយគ្នាថា «មូសខាំស្លាប់ហើយ ពុទ្ធោអើយ! នាំបងប្អូនដេកលក់ចាំម្តាយ»។

គាត់និយាយបណ្តើរទាញមុងចងឲ្យខ្ញុំបណ្តើរ រួចរាល់ហើយគាត់ចាប់ផ្តើមជជែកគ្នាពីផែនការរបស់បដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ និងសម្តែងពីក្តីកង្វល់ ដែលត្រូវឃ្លាតចាកចេញឆ្ងាយពីកូនៗ។ ខ្ញុំស្តាប់ឮពីក្តីកង្វល់របស់គាត់ដេកមិនលក់ទេ ក៏ក្រោកឡើងសួរគាត់ភ្លាមថា «ប៉ា ម៉ាក់តើគេឲ្យប៉ាម៉ាក់ទៅណា?» ម្តាយរបស់ខ្ញុំក៏និយាយសំឡេងថ្នមៗថា «ហឺ! យើងត្រូវបែកគ្នាហើយកូន ស្អែកកងឈ្លបឲ្យពុកនិងម៉ែទៅសមរភូមិមុខ លែងបាននៅជាមួយកូនហើយ ម៉ែខំប្រាប់កងឈ្លបថាមានកូនតូចទៅណាមិនកើតទេ តែគេថាកូនឯងធំអាចមើលប្អូនបាន»។ ខ្ញុំឮម្តាយរបស់ខ្ញុំនិយាយដូច្នោះក៏មានការព្រួយបារម្ភនៅក្នុងចិត្តណាស់ ព្រោះខ្ញុំមិនដែលបែកពីម្តាយឪពុកម្តងណាទេហើយក៏នឹកឆ្ងល់នឹងពាក្យដែលម្តាយនិយាយថាពុកម៉ែ ដែរ។ ម្តាយខ្ញុំបានប្រាប់ខ្ញុំថា ចាប់ពីពេលនេះតទៅ កងឈ្លបឈប់ឲ្យហៅប៉ាម៉ាក់ ទៀតហើយ កងឈ្លបឲ្យហៅថា ពុកម៉ែ ជំនួសម្តងព្រោះពាក្យ ប៉ាម៉ាក់នេះជាពាក្យហៅរបស់វណ្ណៈសក្តិភូមិ និងនាយទុន។

ខ្ញុំនៅក្មេងសេចក្តីណាស់ ពុំទាន់ដឹងអ្វីៗបានគ្រប់ជ្រុងជ្រោយនោះទេ តែខ្ញុំមានអារម្មណ៍ខឹងណាស់គ្រាន់តែខ្ញុំហៅ ប៉ាម៉ាក់ ក៏មិនបាន រស់នៅជួបជុំគ្នាក៏មិនបាន ហេតុអ្វីរបបនេះគេធ្វើដូច្នោះចំពោះយើង។ យប់នោះឪពុកម្តាយរបស់ខ្ញុំនិងខ្ញុំពុំសូវបានដេកទេ។ គាត់ផ្តាំផ្ញើខ្ញុំគ្រប់បែបយ៉ាងឲ្យមើលប្អូន មើលថែរក្សារបស់របរដែលគាត់លាក់ទុក។ គាត់ផ្តែផ្តាំខ្ញុំថា «ម៉ែមិននៅ មើលថែទាំងប្អូនពេលយប់ជាក់មុងឲ្យបានស្រួលបួលកុំឲ្យមូសខាំ ហើយនាំប្អូនដេកទៅបើមានការអ្វីកូនទៅប្រាប់យាយនៅក្បែររោងបាយនោះឲ្យដឹងឮទេ! គាត់នឹងជួយផ្តល់ដំណឹងឲ្យម៉ែ»។ និយាយរួច ម្តាយរបស់ខ្ញុំលើកដៃមកអង្អែលក្បាលខ្ញុំតិចៗពោរពេញទៅដោយមនោសញ្ចេតនារួចនិយាយបន្តទៀតថា «កូនមាសម្តាយ! នេះជាបទបញ្ជា

របស់អង្គការ ម៉ែមិនដឹងថាពេលណាអង្គការឲ្យម៉ែ និងពុកកូនត្រលប់មកវិញទេ»។ ម្តាយរបស់ខ្ញុំនិយាយដល់ត្រង់នេះ ស្រាប់តែឪពុករបស់ខ្ញុំឃាត់ឈប់ឲ្យនិយាយ ព្រោះខ្លាចមានអ្នកស្តាប់ឮអាចកើតជាទោសពៃ។

មេឃមិនទាន់ភ្លឺផង សំឡេងកញ្ជែបន្លឺឡើងយ៉ាងស្រួច កោះហៅប្រជាជនឲ្យទៅជួបជុំគ្នាដើម្បីចេញដំណើរ។ ម្តាយឪពុករបស់ខ្ញុំ ប្រញាប់ប្រញាល់រៀបចំខ្លួនដើម្បីទៅឲ្យទាន់ប្រជាជនដទៃទៀត។ ខ្ញុំឮឪពុករបស់ខ្ញុំនិយាយថា «តោះឯង! រួចរាល់ឬនៅ?» ម្តាយរបស់ខ្ញុំក៏ហុចក្រមាឲ្យឪពុករបស់ខ្ញុំទុកគ្រាន់ជូតញើស ហើយឆ្លើយតបថា រួចរាល់ហើយ។

ខ្ញុំក្រឡេកទៅខាងក្រៅឃើញមនុស្សច្រើនណាស់ដើរសំដៅទៅកន្លែងជួបជុំគ្នា ម្តាយ និងឪពុករបស់ខ្ញុំ ហាក់មិនចង់ចាកចេញពីកូនៗទេ ជាពិសេសប្អូនស្រីរបស់ខ្ញុំ ដែលមានអាយុទើបតែ១ឆ្នាំជាង។ គាត់ចេះតែលួចមើលប្អូនស្រីរបស់ខ្ញុំដែលកំពុងតែដេកលក់។ «ម៉ែទៅហើយ! មើលប្អូនឲ្យមែនទែនណាកូនណា ពេលដែលម៉ែឃ្លាតទៅ កូនត្រូវជួយមើលថែទាំប្អូន អប់រំប្អូន កុំធ្វើបាបប្អូនៗទាំងបីនាក់គ្មានសាច់ញាតិដែលជិតស្និទ្ធណាជាងកូនទេ» ម្តាយរបស់ខ្ញុំងាកមកផ្តែផ្តាំដល់ខ្ញុំចុងក្រោយ។ និយាយបណ្តើរ គាត់ទាំងពីរឱនមកថើបក្បាលរបស់ខ្ញុំបណ្តើរទាំងក្តីក្អកក្តួល។ ខ្ញុំឈរមើលម្តាយឪពុករបស់ខ្ញុំចេញដំណើរហួតផុតកន្ទុយភ្នែក។ ខ្ញុំបានបោះជំហានចូលមកក្នុងផ្ទះវិញ ទឹកភ្នែករបស់ខ្ញុំមិនដឹងជាហូរមកពីណាទេ សម្លឹងមើលទៅប្អូនៗ កំពុងតែលង់លក់ ដោយមិនដឹងថាម្តាយឪពុកកំពុងតែចាកចេញទៅចោលឡើយ។។ ក្រោកពីដេកវិញបាត់ម្តាយឪពុកអស់ក្នុងទ្រូងខ្ញុំល្ហល្ហេវរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។

ខ្ញុំអង្គុយផ្អែកទៅនឹងសសរកូនឈើកំពិកកំពកចំកណ្តាលផ្ទះ ប្អូនក៏ភ្ញាក់ខ្ញុំស្ទុះទៅពដើម្បីកុំឲ្យវាយំ។ ប្អូនរបស់ខ្ញុំចេញផុតពីមុងមិនទាន់ ស្រែកសួរកម្តាយរបស់ខ្ញុំភ្លាម។ ខ្ញុំខំនិយាយលួងលោមប្អូនថា «ឪពុកម្តាយរបស់យើងទៅធ្វើការហើយ បន្តិចទៀតបានគាត់វិលត្រលប់មកវិញ»។ បន្ទាប់មកខ្ញុំលុបមុខឲ្យប្អូនស្រីតូចរួចបន្តលុបមុខឲ្យប្អូនរបស់ខ្ញុំម្នាក់ទៀត ទើបទាញយកក្រមាមកជូតមុខឲ្យម្តងម្នាក់ៗ។

ប្អូនៗរបស់ខ្ញុំឃ្លានណាស់ តែខ្ញុំមិនដឹងធ្វើយ៉ាងណាទេ ក្នុងផ្ទះគ្មានឆ្នាំង គ្មានអង្ករ គ្មានដើងក្រានអ្វីទាំងអស់។ ខ្ញុំនាំប្អូនលេងនៅក្នុងផ្ទះមិនហ៊ានចេញទៅណាឡើយ។ ខ្ញុំបង្កើតគំនិតនាំប្អូនយកដីមកលាយទឹកច្របាច់រួចសូនជារូបផ្សេងៗ ដូចជា ឡាន និង មនុស្ស ដើម្បីលួងប្អូនកុំឲ្យយំ។ ពេលនោះខ្ញុំមានអារម្មណ៍ថាខ្ញុំបាត់បង់វ័យជាកុមារភាព ហើយក្លាយទៅជាអាណាព្យាបាលរបស់ប្អូនៗទាំងបីនាក់។ បន្ទុកនេះពិតជាធ្ងន់ណាស់ ពេលខ្លះខ្ញុំត្រូវពប្អូនដើរចេញក្រៅបោចស្លឹកឈើ ដាក់ចូលមាត់ ដើម្បីបំពេញសេចក្តីស្រេកឃ្លាន។

យប់មួយខ្ញុំឮសូរសំឡេងចង្រ្កៃងច្រើនណាស់នៅតាមផ្លូវ។ ខ្ញុំក៏លួចមើលឃើញរទេះគោដើរជាជួរកាត់តាមភូមិ ហើយឃើញក្មេងៗប្រញាប់តាមពីក្រោយហាក់ដណ្តើមអ្វីមួយ ដោយសេចក្តីស្រេកឃ្លាន។ ខ្ញុំក៏ចូលទៅជិតក្មេងៗទាំងនោះទើបដឹងថាជារទេះដឹកដំឡូង។ ខ្ញុំក៏រត់តាមរទេះ ហើយលួចបានដំឡូងមីបីដុំធំៗរួចរត់ចូលផ្ទះវិញភ្លាម។ សូប់សំឡេងរទេះ ខ្ញុំក៏ជាស់ប្អូនៗរបស់ខ្ញុំឲ្យក្រោករួចបកដំឡូងហូបឆៅទាំងយប់អស់មួយដុំទើបនាំគ្នាដេកទៅវិញ។ យើងសង៉ំមិនទាន់លក់ផង ស្រាប់តែមានអារម្មណ៍ថា ឆ្ពល់ពោះ ចង់ហៀរទឹកមាត់ទាំងអស់គ្នា ដោយមិនដឹងធ្វើយ៉ាងម៉េច ចេះតែនាំប្អូនទ្រាំរហូតទល់ភ្លឺ។ បីបួនថ្ងៃក្រោយមក ខ្ញុំបាននាំប្អូនរបស់ខ្ញុំ ដើរបេះស្លឹកឈើបំពេញក្រពះតាមទម្លាប់។ ចៃដន្យ យើងក៏បានជួបជាមួយនឹងកុមារពីរបីក្រុម ខ្លះមានពាក់ចំពាមកៅស៊ូនឹងក។ ក្មេងមួយក្រុមបានបបួលខ្ញុំទៅរកចាប់ត្រី ចាប់ក្តាមតាមប្រឡាយទឹក។ ខ្ញុំឈរគិតមួយភ្លែតទើបសម្រេចចិត្តពប្អូនទៅជាមួយក្មេងៗទាំងនោះ។ ទៅដល់វាលស្រែ ខ្ញុំឃើញទឹកប្រឡាយហូរថ្លាឆ្វង់។ ខ្ញុំមានអារម្មណ៍សប្បាយប្លែកចិត្ត ក៏ដាក់ប្អូនឲ្យឈរលើភ្លឺស្រែ រួចខ្ញុំក៏ចុះទឹក ហើយយកដើងស្ទាបៗខ្លាចរអិលដួល ព្រោះខ្ញុំមិនចេះហែលទឹកទេ។ ខ្ញុំប្រឹងដើរខាងៗដូចក្លាហានណាស់ តាមពិតខ្ញុំមិនស្គាល់រន្ធក្តាមឬរន្ធកង្កែបទេ។ ខ្ញុំដើរទៅដើរមករកក្តាមមិនបានសោះ។ ក្មេងម្នាក់ដែលបបួលខ្ញុំមក បានសួរខ្ញុំថា «អានេះ! អត់ចេះលូកក្តាមទេអី?» ខ្ញុំតបថា «អត់ចេះទេ! អត់ស្គាល់រន្ធក្តាមផង»។ ក្មេងនោះនិយាយ «មកនេះ! ចាំអញប្រាប់» រួចក្មេងនោះដើរ

លបៗតាមមាត់ទឹកឃើញរូងមួយមានស្នាមចុចៗ លើដីមាត់រណ្តៅថ្មីៗ រួចងាកមកប្រាប់ខ្ញុំថា «អ្នែងឃើញទេនេះ! ស្នាមជើងក្តាម ទើបនឹងកាយរន្ធថ្មីៗ លូកដៃចូលទៅនឹងប៉ះក្តាមហើយ តែបើរូងចាស់ដែលមានស្មៅដុសជិតកុំលូកប្រយ័ត្នពស់» ឮក្មេងនោះនិយាយដូច្នោះខ្ញុំរាងភ័យបន្តិចដែរព្រោះខ្ញុំខ្លាចប៉ះពស់។ ក្មេងនោះឲ្យខ្ញុំលូករន្ធនោះសាក ហើយខ្ញុំខំប្រឹងយកដៃលូកចូលក្នុងរូងរាងភ័យផងខ្លាចផង បានបន្តិចក៏ប្រាប់ក្មេងនោះវិញថា «អត់ឃើញអីផងហ្នឹង!» ក្មេងនោះគំហកដាក់ខ្ញុំ«យី!អានេះ អាចម៍ដីនៅថ្មីចែស ម៉េចបានអត់អ្លា?» ក្មេងនោះក៏លូកដៃវាចូលទៅយ៉ាងជ្រៅទើបលាន់មាត់ថា «ក្តាមប៉ុនណាណីវាថាអត់! លូកម្តងទៀតមើល!»។ ខ្ញុំឮក្មេងនោះប្រាប់ថាមានក្តាម ក៏មានចិត្តត្រេកអរនឹកថានឹងបានឲ្យប្អូនហូបហើយរួចខ្ញុំក៏លូកដៃចូលជាថ្មីតែនៅរាងស្ទាក់ស្ទើរនៅឡើយ។ ក្មេងនោះស្រែកគំហកដាក់ខ្ញុំខ្លាំងៗម្តងទៀត។ ខ្ញុំលូកតាមឡើងកប់ដល់ភ្លៅកទើបប៉ះរបស់រឹងៗក៏ស្រែកថា «ប៉ះអីរឹងៗ» ក្មេងនោះប្រាប់ខ្ញុំថា «អើ ! អាហ្នឹងគឺក្តាមហើយ ទាញវាចេញមក!»។ ខ្ញុំបានលូកដៃចូលបន្ថែមទៀត ដើម្បីឲ្យដល់ចំណុចមួយដែលម្រាមដៃរបស់ខ្ញុំអាចចាប់ក្តាមនោះបាន រួចក៏ទាញក្តាមចេញមក។ គ្រាន់តែផុតមាត់រន្ធភ្លាម ក្តាមបានចាប់កៀបដៃខ្ញុំមួយរំពេច។ ខ្ញុំឈឺណាស់ក៏ទម្លាក់ក្តាមចោល តែក្តាមនៅកៀបដៃរបស់ខ្ញុំមិនព្រមធ្លាក់ទេ។ ក្មេងនោះស្ទុះមកចាប់ក្តាមពីដៃខ្ញុំជាប់ហើយសើចដោយនិយាយថា «ប្រយ័ត្នវាកៀបដៃឮទេ?» រួចក្មេងនោះហុចក្តាមមកឲ្យខ្ញុំហើយបង្រៀនខ្ញុំពីរបៀបចាប់ក្តាមពីលើស្នូក។ ខ្ញុំចាប់ក្តាមលើកឡើងលើហើយបង្ហាញក្តាមឲ្យប្អូនៗរបស់ខ្ញុំមើល។ ប្អូនៗរបស់ខ្ញុំស្រែកហ៊ោកញ្ជៀវដោយក្តីត្រេកអរ។ ខ្ញុំក៏ដើរឡើងសំដៅទៅប្អូនៗ រំពេចនោះ ខ្ញុំភាន់ភាំងជាថ្មីដោយមិនដឹងធ្វើយ៉ាងណាឲ្យក្តាមងាប់។ ខ្ញុំក៏បោកក្តាមផ្ទប់នឹងដីបាក់ជើងបាក់ដៃអស់។ «អ្នែង បោកវាធ្វើអី? បើខ្លាចវារត់យកឈើទៅចាក់ប្រឡោះទ្រូងវាទៅវាងាប់ហើយ» ក្មេងនោះស្រែកប្រាប់ខ្ញុំ។ ទោះក្មេងនោះស្រែកដាក់ខ្ញុំ ក៏ខ្ញុំនៅតែមានចិត្តត្រេកអរដដែល ព្រោះខ្ញុំបានក្តាមមួយមកដុតឲ្យប្អូនហូបហើយ។

ខ្ញុំសប្បាយចិត្តណាស់ ហើយប្រាប់ប្អូនៗរបស់ខ្ញុំថា «ចាប់ពីថ្ងៃនេះទៅ បងដឹងពីរបៀបចាប់ក្តាមហើយ យើងមានរបស់ហូបហើយ អូនឯងលែងអត់ឃ្លានទៀតហើយ»។ ខ្ញុំខិតខំនាំប្អូនរបស់ខ្ញុំដើររើសដៃជើងក្តាម រួចក៏ពប្អូនស្រីរបស់ខ្ញុំរហូតដល់ម្លប់ឈើមួយ។ ខ្ញុំមានអារម្មណ៍ត្រជាក់ស្រួលណាស់។ ខ្យល់បក់ល្វើយៗ នាំមកនូវក្លិនស្រូវប្រហើរជាប់ច្រមុះ។ បន្ទាប់មកខ្ញុំឃើញក្មេងៗទាំងនោះទាញសំឡីចេញពីគូទដៃកកេះ យកមកជាក់ក្បែរបញ្ជេះរបស់វា រួចកេះបីបួនដងក៏បានឆេះហើយបង្កាត់ភ្លើងឡើង។ ខ្ញុំឃើញភ្លើងឆេះ ក៏ប្រញាប់យកក្តាមមកដុត តែក្មេងនោះហាមថា «ឈប់សិន! ចាំភ្លើងកាត់បន្តិចសិន ជើងក្តាមអ្នែងបោះចោលទៅ! ចាំអញឲ្យបងប្អូនអ្នែងស៊ីដែរ» និយាយរួចក្មេងនោះក៏លាចង្កេះខោទម្លាក់ក្តាមជាច្រើនចេញមក។ ក្មេងនោះបានយកក្តាមជាក់ដុតឡើងក្រហមស្កុក ទើបយកមកហែកចែកគ្នាស៊ី។ ខ្ញុំជាក់សាច់ក្តាមចូលមាត់ រសជាតិផ្អែមណាស់ ហើយមើលទៅប្អូនៗរបស់ខ្ញុំទំពាជើងក្តាមឡើងហៀរទឹកមាត់។ ក្មេងនោះបានសួរមកខ្ញុំថា «នែ៎! អានេះ! អ្នែងឈ្មោះអី?»។ ខ្ញុំតបថា «ខ្ញុំឈ្មោះ ភា»។ វាតបថា «ស្អីអ្ហា! និយាយសុទ្ធតែខ្ញុំ! អីក៏សុភាពម្ល៉េះ អញឈ្មោះ ផល ចុះម៉ែឪអ្នែងទៅណាអស់ហើយ?»។ ខ្ញុំបានប្រាប់ក្មេងនោះវិញថា ម្តាយឪពុករបស់ខ្ញុំទៅកងចល័តអស់ហើយ។ នឹកទៅអាណិតក្មេងនោះដែរ ម្តាយឪពុកស្លាប់ទាំងអស់។ យើងក៏បានសន្ទនាគ្នាខ្លះៗ ហើយខ្ញុំក៏ប្រាប់ក្មេងៗទាំងនោះថាខ្ញុំមកពី ប៉ៃលិន ហើយក្មេងៗទាំងនោះចំអន់ខ្ញុំថាខ្ញុំគឺជាប្រជាជនថ្មី មិនចេះចាប់ក្តាម ធ្វើឲ្យក្មេងៗជុំវិញនោះសើចខ្ញុំគ្រប់ៗគ្នា។

ផល ចិត្តល្អណាស់ នៅពេលក្តាមឆ្អិន ផលឲ្យខ្ញុំទាំងអស់ដើម្បីទុកឲ្យប្អូនរបស់ខ្ញុំហូប។ បន្ទាប់ពី ផល ឲ្យក្តាមខ្ញុំរួច ពួកគេក៏ក្រោកដើរចេញទៅ។ ថ្ងៃនេះខ្ញុំទទួលបានចំណេះដឹងចាប់ក្តាមមួយទៀតហើយរួចខ្ញុំក៏និយាយទៅប្អូនៗថា «តោះ! អូនជួយកាន់ក្តាមយកទៅផ្ទះ! គេទៅរោងបាយហូបចោលយើងអស់ទេដឹង»។ ពេលខ្ញុំទៅដល់ផ្ទះងូតទឹកឲ្យប្អូនរួច សំឡេងជួងបន្លឺឡើងល្មម។ យើងនៅរង់ចាំសំឡេងជួងលើកទីពីរ និងលើកទីបីទៀត។ ថ្ងៃនោះ យើងមិនរួសរាន់ទេ

ព្រោះក្រពះរបស់យើងបានបំពេញដោយក្តាមជាច្រើន។ បងប្អូនរបស់ខ្ញុំម្នាក់ៗ ហាក់មានកម្លាំងគ្រាន់បើជាងសព្វដង។ ទៅដល់រោងបាយ មិនខុសពីទម្លាប់សព្វមួយដងឡើយ គឺយើងបានតែទឹកបបរមួយវែកគត់ គ្មានចាននៅចំកណ្តាលវង់ទៀតទេ។ កុមារទាំងអស់គ្នាលើកចានបបរហុតរួចទម្លាក់ទុកវិញ ក៏ដើរចេញទាំងហេវហត់។ បន្ទាប់ពីហូបបបររួចខ្ញុំនាំប្អូនត្រលប់មកផ្ទះវិញ ក្នុងចិត្តសប្បាយជាងសព្វមួយដង ព្រោះយើងមានក្តាមដុតទុកនៅផ្ទះ។ ខ្ញុំមានអារម្មណ៍ដូចជាមានរបស់ពិសេសដែលមានតម្លៃនៅក្នុងផ្ទះខ្ញុំអីចឹងដែរ។ ពេលទៅដល់ផ្ទះ ខ្ញុំក៏ទាញយកក្តាមដែលលាក់ទុកក្នុងភួយចែកប្អូនៗហូប។ ខ្ញុំប្រាប់ប្អូនៗខ្ញុំថា «អូន! នាំគ្នាហូបទៅ តែកុំទំពាឮពេក ប្រយ័ត្នគេឮណាអូនណា! បើឃើញឬឮសំឡេងមនុស្សដើរមកអូនធ្វើជាដេកលក់កុំទំពាទៀតអីឮទេ?»។

យប់នោះ ខ្ញុំឃើញប្អូនៗរបស់ខ្ញុំដេកលក់ស្រួលណាស់ ព្រោះពួកគេបានហូបឆ្អែត។ ខ្ញុំនឹកអាណិតប្អូនៗណាស់។ ពេលខ្លះប្អូនរបស់ខ្ញុំនោមដាក់ភួយជោគអស់រោងទាំងយប់ ខ្ញុំមិនហ៊ានស្តីបន្ទោសប្អូនទេ។ ចាប់ពីថ្ងៃនោះមក ខ្ញុំឧស្សាហ៍នាំប្អូនទៅវាលស្រែឲ្យលេងទឹក ចំណែកខ្ញុំមានឱកាសរកក្តាមខ្យងយកមកទុកក្នុងបឹងដុងទឹកដែរ។ ពេលយប់ ខ្ញុំយកក្តាមខ្យងដែលខ្ញុំរកបានទៅបោះក្នុងផេះចង្ក្រានចុងភៅដែលនៅសល់រងើកភ្លើងតិចៗ។ មួយសន្ទុះក្រោយមក ខ្ញុំក៏កាយក្តាមខ្យងទាំងនោះចេញមកវិញ រួចប្រមូលរត់ទៅផ្ទះចែកប្អូនៗហូប។ ខ្ញុំធ្វើរបៀបនេះជាច្រើនដងដោយមិនដឹងខ្លួនថាមានកំហុសអ្វីទេ។ យប់មួយ ខ្ញុំកំពុងតែឱនប្រមូលខ្យងដែលដុតរួចដាក់ក្នុងថ្នក់អាវស្រាប់តែឮសំឡេងជើងមនុស្សដើរចូលមក។ ខ្ញុំក៏ងាកមើលក្រោយភ្លាម ស្រាប់តែឃើញយាយចុងភៅទាញវែកដួសបបរយោរមួយទំហឹងបម្រុងនឹងវាយខ្ញុំ។ ឃើញសភាពការណ៍ដូច្នោះ ខ្ញុំក៏រត់ទៅពួននៅខាងក្រោយផ្ទះយាយក្បែរនោះ ដោយឮតែសំឡេងល្វើយៗថា «អីចឹងតើបានជាអញឃើញផេះចង្ក្រានអញអារាត់អារាយរាល់យប់ យើ!វណ្ណៈនាយទុនទាំងនេះមិនចោលមាយាទសោះ»។

ខ្ញុំមានអារម្មណ៍តូចចិត្តណាស់។ ទង្វើរនេះមិនគួរជាកំហុសដែលត្រូវទទួលការវាយដំឡើយ។ ខ្ញុំគ្មានម្តាយគ្មានឪពុកនៅជិត គ្មានញាតិសន្តាន ហើយត្រូវទទួលបន្ទុកមើលថែប្អូនៗ ហេតុអីក៏គ្មានក្តីមេត្តាសោះ។ ខ្ញុំកំពុងតែសំងំលាក់ខ្លួនស្រាប់តែលេចរូបយាយម្នាក់ ដែលម៉ែរបស់ខ្ញុំគាត់ផ្តាំនៅជិតរោងចុងភៅនោះចេញមក ចាប់ទាញដៃខ្ញុំចូលទៅក្នុងផ្ទះ ហើយពន្យល់ណែនាំខ្ញុំថា «ចៅឈប់មកដុតអ្វីៗ នៅជិតរោងចុងភៅនេះទៀតណាចៅណា ថ្ងៃមុនគេចាប់បានក្មេងម្នាក់យកទៅកសាង គ្រាន់តែក្មេងនោះមកយករងើកភ្លើងទៅបង្កាត់ក៏មិនបានយាយនោះអាក្រក់ណាស់។ នេះយាយឲ្យដៃកកេះមួយ ពេលណាកេះមិនឆេះទៅមូរដៃកកេះនេះនឹងចង្កេះខោឲ្យជិតកុំឲ្យគេឃើញ យកមកឲ្យយាយដាក់ប្រេងឲ្យហើយពេលដុតក្តាម ដុតខ្យង កុំឲ្យគេឃើញណាចៅណា»។ ខ្ញុំរត់មកផ្ទះយ៉ាងលឿន ប្រញាប់មកមើលប្អូនៗ។ ពេលខ្ញុំមកដល់ផ្ទះ ពួកគេអង្គុយរង់ចាំឡើងរហង់។ ខ្ញុំប្រញាប់ប្រញាល់ដាក់មុងឲ្យប្អូនដេក។ ហេតុតែជាកុមារប្អូនៗរបស់ខ្ញុំចូលមុងតែមួយភ្លេតក៏លង់លក់អស់ទៅបន្សល់ទុកនូវតែភាពកណ្តោចកណ្តែងដល់ខ្ញុំតែម្នាក់ឯង។ ខ្ញុំដេកទាំងមិនអស់ចិត្តសោះ ចំពោះទង្វើដ៏ព្រៃផ្សៃរបស់យាយចុងភៅនោះ។

ប្រហែលដប់ថ្ងៃក្រោយមក ខ្ញុំ និងប្អូនៗដេកមិនទាន់លក់ផង ស្រាប់តែឃើញស្រមោលខ្មៅស្នងជើរចូលមកក្នុងផ្ទះយ៉ាងលឿន។ ខ្ញុំភ័យណាស់ស្ទុះក្រោកឡើងញ័រទ្រូងស្ទើរធ្លាយ។ ពេលនោះ ខ្ញុំឃើញកងឈ្លបម្នាក់ឈរនៅមុខខ្ញុំមួយសន្ទុះក៏ដើរចេញទៅដោយគ្មានស្តីអ្វីមួយមាត់។ កងឈ្លបចេញទៅបាត់ ខ្ញុំយកដៃទាំងពីរមកដាក់លើដើមទ្រូង ដើម្បីបំបាត់នូវភាពភ័យខ្លាច។ ភ្លឺស្រាងៗឡើង ខ្ញុំនាំប្អូនលុបលាងមុខរួចនាំប្អូនលេងក្នុងផ្ទះ មិនហ៊ានចេញទៅណាទេ។ ថ្ងៃរាងជ្រេបន្តិច ខ្ញុំក៏នាំប្អូនទៅវាលស្រែទៀត។ យើងនាំបងប្អូនលេងទឹកសប្បាយណាស់ ភ្លេចអស់នូវភាពស្រេកឃ្លាន និងសេចក្តីនឹករឭកដល់ម្តាយឪពុក។ ពួកយើង កំពុងតែលេងស្រាប់តែមានមនុស្សចាស់មួយក្រុមដើរមើលស្រែ។ ពួកគេស្លៀកពាក់ខ្មៅ តែស្អាតបាតណាស់ថែមទាំងមានក្រមាបង់កទៀត។

លុះគាត់ដើរមកជិតដល់ខ្ញុំ គាត់ស្រែកដេញឲ្យខ្ញុំត្រលប់ទៅក្នុងភូមិវិញ។ មនុស្សម្នាក់នៅក្នុងចំណោមនោះ និយាយថា «បែបឪពុកម្តាយទៅសមរភូមិហើយ»។ ថ្ងៃនោះទៅដល់រោងបាយ យាយចុងភៅនោះសម្លឹងមកខ្ញុំគ្មានជាក់ភ្នែកទេ។ ចំណែកខ្ញុំឱនមុខចុះមិនហ៊ានសម្លឹងទៅគាត់វិញឡើយ។ ខ្ញុំលើកចានបបរហុតរួចក៏នាំប្អូនម្ចីម្នាប្រញាប់ត្រលប់មកផ្ទះវិញ។ យប់នោះប្អូនស្រីរបស់ខ្ញុំក្តៅខ្លួនខ្លាំងណាស់ មមើមមាយនិយាយផ្តេសផ្តាសទាំងយប់។ ខ្ញុំភ័យជាខ្លាំងក៏រត់ទៅហៅយាយជិតរោងបាយទាំងយប់។ ខ្ញុំមិនដែលមករំខានគាត់ទេតាំងពីឪពុកម្តាយខ្ញុំចាកចេញទៅ។ ពេលនោះ ខ្ញុំមិនដឹងធ្វើយ៉ាងណាឡើយ នឹកឃើញតែបណ្តាំម្តាយថា «បើមានការអីកូនទៅប្រាប់យាយនៅជិតរោងបាយនោះទៅ នឹងបានដំណឹងដល់ម៉ែហើយ»។ យាយចិត្តល្អណាស់។ គាត់ដើរយ៉ាងលឿន ខ្ញុំរត់ពីក្រោយគាត់សឹងតែមិនទាន់។ ទៅដល់ផ្ទះរបស់ខ្ញុំ គាត់លូកដៃស្ទាបប្អូនរបស់ខ្ញុំភ្លាម ហើយលាន់មាត់ថា «អូយ! ក្តៅណាស់! ថ្ងៃមិញចៅឯងឲ្យប្អូនហូបអ្វីខ្លះ?» គាត់និយាយបណ្តើរទាញយកក្រមាជ្រលក់ទឹកពូតមកគ្របឲ្យប្អូនរបស់ខ្ញុំ ហើយគាត់ងាកមកនិយាយប្រាប់ខ្ញុំថា «ចាំមើលគ្របក្រមាទទឹកបន្តិចមើល បើមិនត្រជាក់ទេ ត្រូវដើរកថ្នាំហើយ»។ ខ្ញុំស្តាប់ឮគាត់និយាយធ្វើឲ្យខ្ញុំភ័យណាស់ ភ័យពីរឿងប្អូនឈឺ មិនដឹងថ្នាំសង្កូវនៅឯណា។ មួយស្របក់ក្រោយមក ខ្ញុំឃើញប្អូនស្រីរបស់ខ្ញុំដូចជាមានសភាពស្ងៀមស្ងាត់។ យាយគាត់ងាកមកនិយាយជាមួយខ្ញុំទៀតថា «អន់ក្តៅបន្តិចហើយ វាសំងំដេកហើយ ចៅឯងដេកដែរទៅ ចាំយាយមើលប្អូនឲ្យដល់ភ្លឺចាំទៅរកស្លឹកត្រជិតមកបុក»។ តាមពិត ខ្ញុំងងុយដេកស្ទើរបើកភ្នែកមិនរួចផង។ ខ្ញុំអង្គុយយោគទៅមុខយោគទៅក្រោយ តែមិនហ៊ានដេកទេ ព្រោះភ័យពីប្អូនរបស់ខ្ញុំ។ ខ្ញុំសុខចិត្តទ្រាំអង្គុយជាមួយនឹងយាយ ប៉ុន្តែស្រាប់តាំងតែដឹងខ្លួនឡើងភ្លឺចែស មិនដឹងដេកលក់តាំងពីពេលណាឡើយ។ ពេលយាយឃើញខ្ញុំភ្ញាក់ពីដេកក៏ប្រាប់ខ្ញុំថា «មើលប្អូនណា! យាយទៅសុំច្បាប់អង្គការសិន រួចយាយហួសទៅរកស្លឹកត្រជិតយកមកបុកឲ្យមីទូច ផឹក»។ និយាយហើយគាត់ក៏ដើរចេញទៅ។ ខ្ញុំមិនយល់ពីយាយនិយាយរឿងសុំច្បាប់

អ្វីទេ តែខ្ញុំនឹកអាណិតគាត់ ព្រោះយប់មិញប្រហែលជាគាត់មិនបានសម្រាន្តទេ។ រំពេចនោះ ប្អូនស្រីរបស់ខ្ញុំក៏ក្រោយឡើងមមិងមមាំងស្រែករកម៉ែ។ ខ្ញុំលូកដៃលួងប្អូនពវាឲ្យដេកវិញ។ ចំណែកអាប្អូនពីរនាក់ទៀតរបស់ខ្ញុំ ក្រោកឡើងអង្គុយក្បែរគ្នាមិនបានលាងមុខមាត់ទេ។ ថ្ងៃបន្តិចយាយបានត្រលប់មកវិញ ដាក់ស្លឹកត្រដិតបុកឡើងហ្មត់ក្នុងផ្តិលយកមកលាយទឹក ហើយដាក់ក្រមាត្រងពួតយកទឹកបានកន្លះផ្តិល រួចលាយអំបិលតិចៗ យកមកបញ្ជ្រុកប្អូនរបស់ខ្ញុំអស់ចំនួន២ស្លាបព្រា។ ប្អូនរបស់ខ្ញុំយំខ្លាំងណាស់ ព្រោះវាមិនចង់ផឹក។ បន្ទាប់ពីបញ្ជ្រុករួចរាល់ គាត់ក៏ដាក់ឲ្យប្អូនរបស់ខ្ញុំដេករួចយកកាកស្លឹកត្រដិតមកបំពោកលើខ្លួនឡើងពេញ។

ខ្ញុំត្រលប់មកពីហូបបបរ យាយក៏ដើរចេញទៅវិញ។ មួយសន្ទុះធំ គាត់បានមកដល់ ហើយមានបបរដិតពេញមួយចាន។ ខ្ញុំត្រេកអរណាស់ ព្រោះគិតថាប្អូនរបស់ខ្ញុំបានហូបឆ្អែតហើយ។ គាត់បញ្ចុកបបរប្អូនរបស់ខ្ញុំហូបជិតអស់មួយចាន។ ចំណែកអាប្អូនទាំងពីរនាក់ទៀត ប្រឹងនាំគ្នារំកិលចូលជិត ព្រោះវាចង់ស៊ីបបរដែរ តែខ្ញុំចេះតែកេះវាចេញកុំឲ្យរំខានប្អូន។ បបរនៅសល់បន្តិច យាយក៏លើកហុតអស់ទៅ។ យាយទាញយកក្រមាទទឹកមករុំខ្លួនឲ្យប្អូនស្រីខ្ញុំរួចដាក់ឲ្យដេក ទើបងាកមករកខ្ញុំហើយនិយាយថា«មើលប្អូនណា ចៅណា! បើមានការអីទៅហៅយាយ។ យាយរកទៅសម្រាកបន្តិច យប់មិញគ្មានបានដេកទេ»។ ឮដូច្នោះ ខ្ញុំក៏បានអរគុណយាយដែលខំជួយប្អូនរបស់ខ្ញុំ។ ថ្ងៃបាក់រសៀលបន្តិច ប្អូនស្រីរបស់ខ្ញុំ មានអារម្មណ៍ប្រក្រតីឡើងវិញ។ ខ្ញុំក៏ពវាលេងខាងមុខផ្ទះឲ្យស្រឡះខ្លួនស្រាប់តែពេលនោះឃើញម៉ែមកដល់ ស្លៀកពាក់អាវខ្មៅខោខ្មៅ។ យើងអរណាស់ អរអ្វីប្រៀបពុំបាន ក៏នាំគ្នាទៅឱបម៉ែទាំងទឹកភ្នែក។

ខ្ញុំយំរៀបរាប់ប្រាប់ម៉ែថា«ម៉ែអើយ! ខ្ញុំនឹកម៉ែណាស់ ម៉េចបានម៉ែទៅយូរម្ល៉េះ? ចុះឯណាពុក អាអូនវាឈឺ បានយាយមកជួយមើល»។«ម៉ែដឹងហើយ យាយគាត់ផ្តាំតាមគេឲ្យប្រាប់ម៉ែ ម៉ែក៏សុំគេមកមើលកូន ពុកកូនមកមិនបានទេ» ម៉ែរបស់ខ្ញុំនិយាយរួចហើយ ក៏ចាប់ឱបប្អូនស្រីរបស់ខ្ញុំ ឱបថើបៗបីបួនដង ទើប

គាត់និយាយថា «កូនឈប់ឈឺហើយមែនទេ? ម៉ែនឹកកូនណាស់ យល់សប្តិឃើញកូនស្ទើរាល់យប់»។ ខ្ញុំចាប់ដៃម៉ែរបស់ខ្ញុំជាប់ ហើយរៀបរាប់ពីហេតុការណ៍ទាំងឡាយឲ្យគាត់ស្តាប់ តាំងពីគាត់ឃ្លាតទៅរហូតមកដល់ពេលនេះ។ យើងនាំគ្នាឱបម្តាយជាប់មិនចេញទៅណាឡើយ ស្រាប់តែយាយមកដល់ «អូ! ម៉ែវាមកដល់ហើយ?» យាយសួរ។ ម្តាយខ្ញុំនិយាយតបទាំងដកដង្ហើមធំថា «ច៎ា ច៎ា! មកដល់អម្បាញ់មិញនេះឯងបង! ហឺ រំខានបងហើយ»។ យាយតបវិញថា «មិនអីទេ! កូនវាបានត្រជាក់ខ្លួនហើយ សល់ទឹកត្រជិតបន្តិចចាំឲ្យវាងើកថែមទៀតផង ឲ្យអស់ក្តៅព្រឹកមិញ ហូបបបរបានច្រើនទាំងបបរខ្ញុំផងជិតអស់»។ ឮនិយាយដូច្នេះទើបខ្ញុំភ្ញាក់ខ្លួនថា ខ្ញុំស្មានតែយាយសុំគេបានច្រើន តាមពិតជារបបរបស់គាត់សោះ ពុទ្ធោ! យាយពិតជាចិត្តល្អណាស់។

យប់នោះ យើងទាំងអស់គ្នាពិតជាមានសេចក្តីសុខណាស់ មានភាពកក់ក្តៅខុសពីសព្វមួយដង។ យើងដណ្តើមគ្នាដេកជិតម៉ែ ប្រជ្រៀតគ្នាចុះឡើងៗ សើចក្អាកក្អាយ។ ម្តាយរបស់ខ្ញុំ គិតតែពីចាប់ថើបកូនម្នាក់ម្តងៗ ពុំមានការនឿយណាយឡើយ។ ព្រឹកឡើង ខ្ញុំសុំម៉ែទៅរាវក្តាមខ្សងតែម្នាក់ឯង ដើម្បីឲ្យម៉ែបានហូបម្តង ហើយចង់បង្ហាញឲ្យម៉ែបានឃើញពីសមត្ថភាពរបស់ខ្ញុំផង។ ខ្ញុំក៏កាន់កូនប៊ីដុងចាស់មួយដើរយ៉ាងលឿនចេញទៅ។ នៅពេលទៅដល់វាលស្រែ ខ្ញុំរួសរាន់ញាប់ដៃដើងរកក្តាមខ្សងនឹងអាលបានត្រលប់មកជួបជុំម្តាយវិញ។ ពេលមកដល់ផ្ទះម៉ែខ្ញុំលាន់មាត់ថា «កូន ពូកែចាប់ក្តាមរាវខ្សង ដូចឪពុកកូនអីចឹង ម៉ែមិននឹកស្មានថាកូនអាចធ្វើបានសោះ»។ ម៉ែនិយាយផង ចោលភ្នែកក្រឡេកមើលជុំវិញខ្លួនហាក់មានរឿងអ្វីអាថ៌កំបាំង ទើបឱនខ្សឹបដាក់ត្រចៀកខ្ញុំថា «កូនដឹងទេ មនុស្សដែលមានចំណេះវិជ្ជាជាមូលដ្ឋានងាយនឹងឈោងចាប់យកចំណេះជំនាញដទៃទៀតជាងអ្នកមិនដែលបានរៀនសូត្រ។ បើស្រុកយើងបានសុខសាន្តត្រាណឡើងវិញ ម៉ែនឹងឲ្យកូនចូលរៀនវិញហើយ តោះកូន! យកទៅលាក់ទុកទៅចាំម៉ែចម្អិនឲ្យកូនហូប»។ ក្រោយវិលមកពីហូបបបរវិញ យើងអង្គុយជុំវិញម្តាយ ខ្លះឱបពីមុខ ខ្លះឱបពីក្រោយ។ ចំណែកម្តាយរបស់ខ្ញុំ បីប្អូនស្រីជាប់ដៃ។ យើងកំពុងតែសប្បាយ

ជុំគ្នាស្រាប់តែបងឈ្លបពីរនាក់ និងយាយចុងភៅ ចូលមកដល់ស្រែកប្រាប់ម្តាយរបស់ខ្ញុំខ្លាំងៗថា «នែមិត្តនារី! មិត្តឯងត្រូវត្រលប់ទៅសមរភូមិមុខវិញនៅថ្ងៃស្អែកកុំបីខានឮទេ ចំណែកកុមារភានេះ ក៏ត្រូវទៅចូលកងចល័តកុមារដែរ»។ ឮដូច្នោះម្តាយរបស់ខ្ញុំនិយាយអង្វរថា «សមមិត្តបង សុំឲ្យកូន ភា នៅផ្ទះជួយមើលប្អូនៗបានទេ ព្រោះខ្ញុំ និងពុកវាទៅសមរភូមិមុខហើយ»។ ឮម្តាយរបស់ខ្ញុំនិយាយយ៉ាងដូច្នេះ យាយចុងភៅក៏ស្រែកជំទាលឡើងថា «មិនបានទេ កុមារនេះធំហើយមួយថ្ងៃៗគ្មានបានអ្វីជួយដល់អង្គការទេ ស៊ីដេកៗ ជិះជាន់កម្លាំងពលកម្មគេត្រូវតែយកកុមារតូចៗនេះទៅទុកឲ្យអង្គការមើល» ដោយមិនអាចប្រកែកបានម៉ែរបស់ខ្ញុំក៏តបវិញថា «មិនអីទេ ប៉ុន្តែខ្ញុំយកកូនទៅទុកនៅក្នុងមណ្ឌលកុមាររួចរាល់សិន បានចេញទៅសមរភូមិវិញ»។

ម្តាយរបស់ខ្ញុំ បានប្រែទឹកមុខស្រពាប់ស្រពោន ព្រោះតែមនោសញ្ចេតនារវាងម្តាយ និងកូន ព្រមទាំងក្តីកង្វល់ពីសុខទុក្ខរបស់កូន។ ម្តាយរបស់ខ្ញុំបារម្ភណ៍ពីប្អូនៗណាស់ តែក្តីសង្ឃឹមចុងក្រោយរបស់គាត់គឺយាយនៅក្បែរពោងបាយនោះហើយ។ យាយជាអ្នកមើលថែក្មេងៗនៅទីនោះ។ ស្អែកឡើង ម៉ែក្រោកពីសម្រាន្តទាញខោជើងវែង ចង្កេះដាក់កៅស៊ូមួយមកស្លៀកឲ្យខ្ញុំ និងអាវដៃវែងមួយ ដោយប្រាប់ថា «ពាក់ឲ្យជិតៗទៅ កុំឲ្យក្តៅ ហើយកុំឲ្យមូសខាំពេលប្រធានក្រុមឲ្យធ្វើអីធ្វើហ្នឹងទៅ កុំមាត់កអីជាមួយគេណាកូន ហើយកុំនិយាយអ្វីផ្តេសផ្តាស។ បើមានអ្នកសួរថាពុកកូនធ្វើអ្វីពីដើមប្រាប់គេថាគាត់ធ្វើស្រែទៅបានហើយ»។ មិនទាន់ទាំងចប់ការសំណេះសំណាលជាមួយម៉ែផង ស្រាប់តែមានមនុស្សមួយក្រុមមកដល់ល្មមមានក្មេងៗបួនដប់នាក់ ក្នុងនោះក៏មាន អាផល ដែរ។ ខ្ញុំប្រាប់ម៉ែរបស់ខ្ញុំថា «ម៉ែ! ខ្ញុំស្គាល់អាមួយនេះដែរម៉ែ វាធ្លាប់ប្រាប់ខ្ញុំពីរបៀបរកគ្តាមខ្យង ហើយវាហ្នឹងជាអ្នកនាំខ្ញុំទៅវាលស្រែ»។ «ល្អហើយអីចឹងកូនមានគ្នាហើយ» និយាយជាមួយខ្ញុំរួចម៉ែក៏ងាកមកសួរអាផលថា «ក្មួយឈ្មោះអី?» ហើយគាត់ផ្តាំអាផលថា «អើ! ជួយមើលប្អូនផង ក្មួយធំជាងប្អូន ជួយមើលខុសត្រូវប្អូនផង»។ អាផល មិនបានឆ្លើយជាមួយម៉ែរបស់ខ្ញុំផង ប្រធានក្រុមក៏ផ្តុំកញ្ចែប្រមូលយកទៅ ធ្វើឲ្យខ្ញុំលាម៉ែសឹងតែមិនទាន់។

ខ្ញុំដើរឆ្ងាយណាស់ដើរឡើងទន់ជើង ហើយស្រេកទឹកស្ទើរខះក នៅតែមិនទាន់ដល់ទៀត។ យើងស្រេកទឹកពេកក៏ប្រាប់អ្នកនាំផ្លូវថា «មិត្តបង! ខ្ញុំស្រេកទឹកណាស់» អ្នកនាំផ្លូវឆ្លើយតបមកខ្ញុំវិញថា «យីស! ដើរឲ្យលឿនឡើង យប់ងងឹតឥឡូវហើយ បើទៅមិនទាន់ ច្បាស់ជាដេកក្នុងព្រៃនេះហើយ»។ អាផល ស្រែកបន្ថែមទៀតថា «ស្រេកទឹកណាស់! ហើយថែមទាំងឃ្លានទៀត តាំងពីព្រឹកមិនបានហូបអីផង»។ ឮ អាផល ស្រែកយ៉ាងដូច្នោះ អ្នកនាំផ្លូវក៏ឲ្យពួកយើងដើរកាត់ទៅរកស្ទឹងហូបទឹកសិន។ យើងដើរយ៉ាងយូរទើបឃើញទឹក រួចក៏នាំគ្នារត់សំដៅទៅក្បង់ទឹកហូបទាំងអស់គ្នា។ ពេលបានទឹកចូលពោះហើយ យើងមានអារម្មណ៍ថាស្រួលខ្លួនបន្តិច អាចបន្តដំណើរទៅមុខទៀតបាន។ ទៅដល់ទីនោះ មេយងងឹតស្ទើរតែមើលគ្នាមិនចង់ស្គាល់។ អ្នកនាំផ្លូវនាំយើងទៅរោងចុងភៅ ដើម្បីហូបបបរមួយវែកួចក៏នាំទៅកន្លែងសម្រាក។ ដោយអស់កម្លាំងពេក យើងក៏ប្រជ្រៀតគ្នាជាមួយកុមារដទៃទៀតដេកលង់ទៅ។ លុះព្រឹកឡើងទើបដឹងថា ក្នុងកងចល័តកុមារនោះ មានកុមារច្រើននាក់ណាស់។ ស្រីជាក់ដោយឡែក ប្រុសជាក់ដោយប្រុស។ ប្រធានកងបានផ្តុំកញ្ចែឲ្យយើងចូលជួរ ហើយឲ្យយើងចំណាំជួររបស់យើង។ យើងនៅជួរណាត្រូវទៅជួរនោះរហូត ឈរពីក្រោយអ្នកណា ត្រូវឈរនៅទីនោះជារៀងរហូតមិនឲ្យដូរទេ។

ប្រធានកងនាំយើងឲ្យទៅជញ្ជូនថ្មទម្លាក់ចូលស្ទឹង។ នៅកន្លែងនោះ មានមនុស្សចាស់ធ្វើការច្រើនណាស់ ខ្លះរែកដី ខ្លះកាប់ដី ខ្លះធ្វើបង្គី ខ្លះវេញខ្សែ។ ក្រុមអ្នករែកដីសុទ្ធតែរត់ ហើយស្លៀកសុទ្ធតែសម្លៀកបំពាក់ខ្មៅគ្រប់ៗគ្នា។ ការងារនៅទីនោះពិតជាលំបាកណាស់។ កងចល័តដែលហៅថា កម្លាំងជួរមុខវិញ មើលទៅមានសភាពទ្រុឌទ្រោមជាខ្លាំង រូបរាងស្គមស្គាំង ព្រោះត្រូវមេកងបង្ខំឲ្យធ្វើការងារហួសកម្លាំង ហូបមិនគ្រប់គ្រាន់ និងដេកមិនបានគ្រប់គ្រាន់។ កងកុមារ ក៏ដូចជាមនុស្សចាស់ដែរ ធ្វើការគ្មានពេលសម្រាកឡើយ។ ក្រុមកុមាររបស់ខ្ញុំសែងថ្មជាក់ក្នុងបង្គីមួយពីរនាក់ទម្លាក់ចូលទឹកស្ទឹង ដែលទឹកកំពុងហូរខ្លាំង។ ថ្ងៃមួយខ្ញុំបានឃើញ បងចន្ទ្រា អ្នកធ្លាប់ស្គាល់គ្នា រួចខ្ញុំក៏ស្រែកហៅភ្លាម។ បងចន្ទ្រាឮសំឡេង

ស្រែកហៅ គាត់ខំរកមើល ហើយឈរមើលមួយសន្ទុះ ទើបស្គាល់ថាជារូបខ្ញុំ។ គាត់ក៏តបមកវិញថា «ភា! អូនមកទីនេះដែរ? ចាំចប់ការងារសិនជួបគ្នាណា»។ និយាយចប់ហើយ គាត់ក៏រែកដីបន្តមិនហ៊ានឈប់ទេខ្លាចប្រធានកងស្តីបន្ទោស។ ល្ងាចនេះក្រោយពីត្រលប់មកពីហូបបបរវិញ ខ្ញុំនិងបងចន្ទ្រា ស្វែងរកគ្នាទម្រាំបានជួបមេឃក៏ងងឹតស្ទើរតែមើលគ្នាមិនស្គាល់។ បងចន្ទ្រានិយាយថា «ភា! បងនឹកអូនណាស់ ហេតុអ្វីប្អូនមកទីនេះដែរ? ចុះពូមីង សុខសប្បាយទេ?»។ គាត់សួរខ្ញុំជាច្រើនសំណួរ ហើយយើងសំណេះសំណាលគ្នាពីនេះពីនោះជាច្រើនរឿងទៀត។ បងចន្ទ្រា និយាយបណ្តើរងាកមើលជុំវិញខ្លួនបណ្តើររួចបន្តថា «សព្វថ្ងៃពិបាកណាស់អូនអើយ! បន្តិចអ្នកនេះមកស្នើ បន្តិចអ្នកនោះមកស្នើ បងចេះតែដោះស្រាយឲ្យរួចមួយគ្រាៗសិនទៅ»។

បន្ទាប់ពីការសន្ទនានោះ យើងឧស្សាហ៍ជួបគ្នាណាស់ ដើម្បីសម្តែងពីការលំបាកប្រាប់គ្នា និងសេចក្តីនឹករឭកឪពុកម្តាយ ជួនកាលយើងយំជាមួយគ្នា។ មិនយូរប៉ុន្មាន ទំនប់ទឹកមួយ ដ៏ធំស្តឹមស្មៃឈរនៅចំពោះមុខក្រុមកងចល័ត ដែលមានរូបរាងស្តមស្តាំងបាក់កម្លាំងដើរស្ទើរមិនរួច។ ចប់ការងារនៅទីនោះ អង្គការបានបញ្ជាឲ្យកងកុមារផ្លាស់ទៅកន្លែងផ្សេង។ ខ្ញុំបែកពី បងចន្ទ្រា រកតែឱកាសលាគាត់ក៏ពុំបានផង។ យើងនាំគ្នាដើរកាត់ព្រៃ ចេញពីព្រៃចូលវាល ចេញពីវាលចូលព្រៃរហូតទៅដល់ភូមិចាស់មួយ ខ្ញុំឃើញមានដើមពុទ្រាពីរបីដើមសុទ្ធតែមានផ្លែទុំពេញ គ្មានអ្នកណាមកដល់ទេ។ ឃើញដូច្នោះហើយ យើងក៏ស្ទុះនាំគ្នារើសហូបផង ដាក់មូរជាប់ក្នុងចង្កេះខោផង ស្រាប់តែមេកងមកដល់បញ្ជាឲ្យលាចង្កេះខោទម្លាក់ចោលទាំងអស់។ យើងស្តាយណាស់តែមិនហ៊ានប្រកែកតវ៉ានឹងមេកងទេ រួចមេកងបង្ខំឲ្យយើងដើរចេញទៅ។ ទៅមុខបន្តិច តាមផ្លូវលំ ខ្ញុំងាកមកខាងស្តាំ ឃើញអគារមួយបាត់បង្អួចអស់រុំព័ទ្ធដោយវល្លិ និងកូនឈើតូចៗ។ ខ្ញុំសែនរន្ធត់ចិត្តណាស់ ស្ទើរស្រក់ទឹកភ្នែក ព្រោះខ្ញុំស្គាល់ច្បាស់ថាជាសាលារៀនដែលត្រូវបោះបង់ចោល។ មេកងនាំកុមារទាំងអស់ឡើងលើភ្នំដើម្បីដាំត្រឡាចនៅលើភ្នំនោះ។

នៅទីនោះ បានមួយរយៈពេល ស្រាប់តែមានយប់មួយពេលដែលខ្ញុំកំពុងតែលង់លក់អាផល ដាស់ខ្ញុំ ហើយខ្សឹបថា «ភា! ក្រោកឡើង! ហែងមានឮទេសំឡេងឆ្កែៗគឺគ្រាប់កាំភ្លើងធំ»។ ខ្ញុំសួរត្រលប់ទៅ អាផល វិញថា «ម៉េចបានឯងដឹង?» «អញធ្លាប់ដឹង ដូចកាលពីសម័យគេបាញ់គ្នានៅក្នុងភូមិអញ» ផល ឆ្លើយតប «សំងំដេកទៅ កុំឲ្យគេដឹង ស្រុកយើងមានសង្គ្រាមទៀតហើយ»។ អាផល វិលបៗទៅវិញ។ ខ្ញុំដេកស្តាប់ពេលខ្សល់បក់មកម្តងៗឮសំឡេងតិចផងខ្លាំងផង។ មិនបានប៉ុន្មានថ្ងៃផង មេកងប្រកាសឲ្យពួកយើងត្រលប់ទៅភូមិវិញ។ យើងនាំគ្នាទៅតាមគេតាមឯង រហូតដល់ភូមិ ហើយស្រាប់តែមានសភាពជ្រួលច្របល់ខ្លាំង។ ម្នាក់ៗម្មីម្នារត់រកក្រុមគ្រួសារហើយស្រែកថា«ស្រុកយើងបានសុខសាន្តត្រាណហើយក៏នាំគ្នីគ្នានាំកូនជញ្ជូនចៅចូលមកទីប្រជុំជនវិញ។

ខ្ញុំសប្បាយចិត្តណាស់បានជួបជុំម្តាយឪពុកបងប្អូនរបស់ខ្ញុំវិញ។ ឪពុករបស់ខ្ញុំ នាំខ្ញុំដើររកតាមឃ្លាំងតាមរោងចក្របាក់បែកវើសយកឆ្នាំង ចាន កំសៀវយកមកទុកប្រើប្រាស់។ ឪពុករបស់ខ្ញុំ រវល់ណាស់។ គាត់ខំស្វះស្វែងរកឈើរកក្តាមកធ្វើបានផ្ទះមួយនៅជាប់មាត់ស្ទឹង។ ការដែលបានជួបជុំគ្នាវិញនេះ ធ្វើឲ្យប្រជាជនទាំងអស់ មានចិត្តសប្បាយរីករាយក្រៃលែង។ បីខែក្រោយមក ខ្ញុំ និងកុមារដទៃទៀត ត្រូវបានមេភូមិ មកហៅឲ្យទៅរៀនវិញ។ នៅក្នុងបន្ទប់សិក្សាដែលគ្មានទ្វារ គ្មានបង្អួច ដំបូលធ្លុះធ្លាយ មានអ្នកគ្រូម្នាក់យើងហៅគាត់ថាបងៗ។ គាត់ចែកសៀវភៅឲ្យយើងម្នាក់មួយ និងខ្មៅដៃមួយដើម រួចបែងចែកអ្នកដែលធ្លាប់បានរៀនដាក់ផ្សេង និងអ្នកមិនដែលបានរៀនដាក់ផ្សេង។

ទីបំផុត ខ្ញុំបានរៀនថ្នាក់ទីបី ហើយក្រៅម៉ោងរៀន ខ្ញុំត្រូវទទួលបន្ទុកជួយអ្នកគ្រូចម្លងមេរៀន ដាក់ក្តារខៀនឲ្យប្អូនៗថ្នាក់ទី១។ ដោយសារមានការខ្វះអគារសិក្សា ពេលខ្លះខ្ញុំត្រូវរៀននៅក្រោមដើមទឹកដោះគោ។ យើងរៀនពោរពេញដោយភាពរីករាយ។ ជយោ! ខ្ញុំបានចូលរៀនវិញហើយ!។

៣

រឿងស្នាមជំហៅ

អ្នកនិពន្ធ ៖ ង៉ា មឿន

៣ ~ រឿង ស្វាមដំចៅ

រដូវវស្សានាឆ្នាំ១៩៧៨ បានចូលមកដល់ ខ្ញុំ និង ណាវី ដែលត្រូវជាគូដណ្តឹងរបស់ខ្ញុំ ព្រមទាំងសមមិត្ត យុវជន យុវនារីផ្សេងទៀតសរុបចំនួន ៣៦នាក់ មកពីភូមិក្រូច ឃុំកន្សោមអក ស្រុកកំពង់ត្របែក តំបន់២៤ ភូមិភាគបូព៌ា ត្រូវអង្គការចាត់តាំងឲ្យចូលរួមក្នុងកងចល័តរបស់ឃុំកន្សោមអក ដើម្បីធ្វើការងារដកស្វូងនៅតាមភូមិ។

នៅថ្ងៃដំបូង ពេលស្វូងរួច សមមិត្តនារីប្រធាន «ខ» បានចាត់តាំងខ្ញុំ ឲ្យដើរវាស់ដីស្រែ ដែលទើបតែស្វូងរួច ដើម្បីរាយការណ៍ជូនសមមិត្តប្រធាន «គ» ឈ្មោះ សាន។ ខ្ញុំវាស់ដីស្រែដោយប្រើដងវែក ដែលមានក្រិតជាម៉ែត្រជាប់ជាមួយ។ ខ្ញុំវាស់វែងដោយលៃលកកែសម្រួលយ៉ាងណាឲ្យបានលេខគត់ៗងាយស្រួលក្នុងការគណនា។ ខ្ញុំវាស់ឃើញ ៥០ម៉ែត្របួនជ្រុង ចំនួនពីរកន្លែង។ បន្ទាប់ពីវាស់រួច ខ្ញុំរាយការណ៍ប្រាប់សមមិត្តប្រធាន «គ» ថា ខ្ញុំស្វូងបានដីទំហំ ៥០ម៉ែត្របួនជ្រុង ចំនួនពីរកន្លែង ដែលស្មើនឹងកន្លះហិកតាក្នុងមួយកន្លែង។ សមមិត្តប្រធាន «គ» ធ្វើចិញ្ចើមជ្រួញបង្ហាញនូវការងឿងឆ្ងល់ ហើយប្រាប់ឲ្យខ្ញុំគិតម្តងទៀតក្រែងខ្ញុំគិតខុស។ ខ្ញុំឆ្លើយចម្លើយដដែលទៅកាន់សមមិត្ត «គ»។ គាត់ ប្រដៅខ្ញុំថា ការរៀនសូត្រក្នុងរបបសក្តិភូមិមិនបានការអ្វីទេ ហើយការចេះដឹងរបស់ខ្ញុំដែលរៀនជិត២០ឆ្នាំ គឺមិនស្មើនឹងគាត់ដែលទើបតែរៀនបានបន្តិចបន្តួចក្នុងសម័យបដិវត្តន៍ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់អង្គការមហាលោតផ្លោះមហាអស្ចារ្យរបស់អង្គការផង។ ខ្ញុំមិនប្រកែកនឹងសមមិត្ត «គ» ទេ ហើយខ្ញុំក៏

ឆ្លើយតបស្របទៅគាត់វិញ ព្រមទាំងសម្តែងនូវកាយវិការនិងទឹកមុខគាំទ្រចំពោះមតិរបស់សមមិត្តប្រធាន «គ»។ ខ្ញុំបានប្រាប់គាត់ថា «ពិតដូចបងប្រធាននិយាយមែន ការរៀនសូត្រក្នុងរបបសក្តិភូមិ គឺពិតជាគ្មានប្រយោជន៍សម្រាប់បម្រើសង្គមឡើយ»។ ខ្ញុំខំប្រឹងនិយាយដោយធ្វើយ៉ាងណាឲ្យសមមិត្តប្រធាន «គ» មើលឃើញថា ខ្ញុំនិយាយនេះគឺជាវាចាដែលផុសចេញពីបេះដូងពិតប្រាកដ។ ខ្ញុំនឹកដល់ពំនោលមួយរបស់អ្នកទស្សនវិជ្ជា ដែលបាននិយាយថា «អ្នកប្រាជ្ញអាចយកឈ្នះលើអ្វីៗបានទាំងអស់ ប៉ុន្តែបានចុះចាញ់មនុស្សល្ងង់»។ ដូច្នេះខ្ញុំមិនត្រូវវែកញែករកខុសរកត្រូវអ្វីជាមួយមនុស្សដ៏ល្ងង់ពិតប្រាកដបែបនេះនោះឡើយ ព្រោះវាអាចឲ្យខ្ញុំមានគ្រោះថ្នាក់បាន។

ចាប់តាំងពីពេលនោះមក បើអាចធ្វើបាន ខ្ញុំតែងតែស្នើប្រធាន «ខ» ឲ្យជ្រើសរើសស្រែណាដែលមានទំហំប្រហែល៥០ម៉ែត្របួនជ្រុង ដើម្បីស្ទូង ហើយគិតទំហំថាជាកន្លះហិកតា។ ខ្ញុំធ្វើដូច្នេះ ក្រុមរបស់ខ្ញុំតែងតែស្ទូងបាន ១ហិកតាក្នុងមួយថ្ងៃបានយ៉ាងស្រួលទៅតាមផែនការរបស់អង្គការដែលបានកំណត់ថា «យើងត្រូវតែស្ទូង៥០ម៉ែត្របួនជ្រុងចំនួនពីរកន្លែង»។ ខ្ញុំពិតជាខុសដែលមិនបានយកភាពចេះដឹងរបស់ខ្ញុំទៅពង្រីកបន្ត ឬកែតម្រូវការយល់ខុសរបស់ប្រជាជន តែបែរជាយកចំណេះដឹងរបស់ខ្ញុំទៅកេងចំណេញពីភាពល្ងែល្ងង់នេះទៅវិញ។

ប៉ុន្តែខ្ញុំគិតថា ការចេះធ្វើល្ងង់ដើម្បីកេងចំណេញពីភាពល្ងង់ពិតរបស់ប្រធាន «គ» ដើម្បីរស់នេះ មិនមែនជាអំពើបាបឡើយ។ ក្នុងការបំពេញការងារដ៏កស្ទូងយ៉ាងសម្រុកបំផុត កងចល័តម្នាក់ៗ ទទួលបានរបបអាហារជាបបរគោកមួយវែកធំក្នុងមួយពេល និងទទួលបានបបរចំនួន២ពេលក្នុងមួយថ្ងៃ។ របបអាហារនេះ មិនគ្រប់គ្រាន់ទាល់តែសោះសម្រាប់ក្រុមកងចល័តដែលធ្វើការងារយ៉ាងធ្ងន់ធ្ងរ។ ស្ថានភាពនេះ ធ្វើឲ្យសុខភាពប្រជាជនម្នាក់ៗកាន់តែទ្រុឌទ្រោមពីមួយថ្ងៃទៅមួយថ្ងៃ។ ខ្ញុំឃ្លានណាស់ ហើយគ្រប់ពេល ខ្ញុំតែងតែនឹកគិតដល់ការហូបចុក និងរំពៃរកអ្វីមកហូបបន្ថែមជានិច្ច។ រៀងរាល់យប់ខ្ញុំតែងតែយល់សប្តិឃើញហូបនេះ ហូបនោះមិនចេះឆ្អែតឡើយ។

បន្ទាប់ពីបញ្ចប់ការងារនៅភូមិព្រៃអណ្តូងរួចមក កងចល័ត ត្រូវបានផ្លាស់ឲ្យមកបោះទីតាំងនៅភូមិទ័ពសៀមវិញម្តង។ ក្រុមរបស់ខ្ញុំ ត្រូវស្នាក់នៅផ្ទះប្រជាជន ដែលស្ថិតនៅផ្នែកខាងជើមផ្លូវពីមន្ទីរសន្តិសុខម្រញ ទៅកាន់វត្តសុពណ៌។ កងចល័តទាំងអស់ត្រូវសម្រុកស្ងួងនៅក្បែរតំបន់ឫស្សីចិន ដែលមានផ្ទៃដីប្រហែលជាបួនហិកតាព័ទ្ធជិតដោយគុម្ពឫស្សី។ រយៈពេលពីរថ្ងៃបានកន្លងផុតទៅ របបបបរកាន់តែថយចុះ ហើយសេចក្តីស្រេកឃ្លានកាន់តែកើនឡើងជាលំដាប់។ ពេលឃ្លានខ្លាំង ខ្ញុំស្ទើរតែលែងខ្លាចសេចក្តីស្លាប់ ដោយគិតលែលកយ៉ាងណាឲ្យតែបានហូបឆ្អែត។ រាត្រីថ្ងៃ៨កើត ខែស្រាពណ៍ ផ្ទៃមេឃស្រឡះល្អ នាម៉ោងប្រហែល ១០យប់។ ព្រះចន្ទកន្លះរង្វង់ កំពុងបណ្តែតខ្លួនលើដំបូលផ្ទះ។ ខ្ញុំមិនអាចអត់ទ្រាំនឹងសេចក្តីស្រេកឃ្លានបាន ក៏សសៀវរាវចេញពីកន្លែងដេករួមរបស់កងចល័តចុះមកដី ហើយដើរចេញទៅខាងក្រោយផ្ទះសម្លឹងរកមើលក្រែងមានអ្វីដែលអាចលួចហូបបាន។ ខ្ញុំគ្មានឃើញអ្វីដែលអាចលួចហូបបានទាល់តែសោះ រួចខ្ញុំក៏សម្រេចចិត្តលួចរត់ទៅផ្ទះនៅភូមិក្រូច ដែលមានចម្ងាយផ្លូវប្រហែលជា៣គីឡូម៉ែត្រ។ ខ្ញុំចេញដំណើរយ៉ាងថ្នមៗកុំឲ្យអ្នកផ្សេងទៀតដឹង។ ខ្ញុំធ្វើដំណើរកាត់ទឹកក្នុងវាលស្រែជាច្រើន ព្រមទាំងដើរអែបគុម្ពោតព្រៃកប់ខ្មោចក្បែរមន្ទីរសន្តិសុខម្រញ ដោយគ្មានភ័យខ្លាចអ្វីទាំងអស់ ដើម្បីទៅរកអាហារតែខ្ញុំមិនប្រាកដថានឹងបានហូបនោះឡើយ។ ម៉ោងប្រមាណជិត ១២ អធ្រាត្រ ខ្ញុំបានមកដល់ផ្ទះហើយខ្សឹបហៅម្តាយរបស់ខ្ញុំ។ ម៉ែគោះដៃកភ្លើង ហើយផ្លុំដើម្បីយកភ្លើងដុតចន្ទុះ ដែលធ្វើអំពីគ្រាប់ល្អុងប្រេង ដោតបន្តគ្នាជាចង្កាក់ ដើម្បីបំភ្លឺមើលខ្ញុំ។ ម្តាយរបស់ខ្ញុំមិនបានសួរនាំខ្ញុំថាតើខ្ញុំមកធ្វើអ្វីនោះទេ ព្រោះគាត់ស្មានដឹងយ៉ាងច្បាស់ពីគោលបំណងរបស់ខ្ញុំអស់ទៅហើយ។ គាត់បានយកអង្ករពីរកំប៉ុងទឹកដោះគោ មកដាំបាយឲ្យខ្ញុំហូប។ អង្ករទាំងអស់នេះ គាត់បានសន្សំទុកជាច្រើនថ្ងៃ ដែលក្នុងមួយថ្ងៃ គាត់បានលួចអង្ករមួយក្តាប់ដៃពីកន្លែងកិនស្រូវ និងកន្លែងជាន់អង្កររួមរបស់ភូមិ។ ទីនោះគឺជាកន្លែងដែលម៉ែរបស់ខ្ញុំធ្វើការងារ។ ម្តាយរបស់ខ្ញុំ អង្គុយដាំបាយក្នុងភាពប្រញាប់ប្រញាល់ ហើយកែវភ្នែករបស់គាត់វិញ

សម្លឹងមើលមកខ្ញុំ ដៃលមានរូបរាងស្គមកំព្រឹង។ ទឹកមុខរបស់ម៉ែពោរពេញដោយភាពខ្លោចផ្សា។ អំឡុងពេលរង់ចាំបាយឆ្អិន ខ្ញុំបានដើរចុះទៅដី ហើយដើរសំដៅទៅគុម្ពអំពៅរួចកាច់បានអំពៅខ្ចីមួយដើមប្រវែងប្រហែលកន្លះម៉ែត្រ មកខាំបកសំបក ទំពាជញ្ជក់យកទឹក។ អំពៅនោះមានរសជាតិផ្អែមឡែមៗធ្ងាញ់អស្ចារ្យណាស់។ ព្រះចន្ទបានបញ្ចេញពន្លឺភ្លឺស្រទន់ព្រាលៗ។ ទឹកអំពៅខ្ចីមួយកូនដើម និងពោតខ្ចីមួយផ្លែរួមទាំងស្នូលពោត បានចូលទៅក្នុងក្រពះរបស់ខ្ញុំ និងរង់ចាំបំពេញដោយបាយស្រួយជាំពីអង្ករពីរកំប៉ុង ដៃលខ្ញុំខានស្គាល់រសជាតិនេះជាងពីរខែកន្លងមកហើយ។ បាយស្រួយៗល្មមបានឆ្អិន។ ម្តាយរបស់ខ្ញុំ និយាយមកខ្ញុំដោយសម្តីយ៉ាងថ្នាក់ថ្នមបង្កប់ដោយភាពខ្លោចផ្សាថា «បាយឆ្អិនហើយកូន! កូនឯងហូបទាំងអស់តាមសម្រួលទៅ»។ ខ្ញុំដឹងថាម៉ែក៏ឃ្លានបាយនេះដែរ ព្រោះយើងទាំងអស់គ្នាសុទ្ធតែទទួលទានបបរមួយវែកដូចគ្នា ប៉ុន្តែម៉ែរបស់ខ្ញុំមិនបានទទួលទានបាយនោះបន្តិចឡើយ។ ខ្ញុំហូបបាយទាំងអស់ជាមួយអំបិលយ៉ាងធ្ងាញ់។

ពិតជាអកុសលណាស់ នៅពេលទទួលទានបាយដ៏សែនធ្ងាញ់ទាំងអស់នេះរួច ស្រាប់តែខ្ញុំចុកពោះ ហើយក្អួតអស់រលើងមកវិញ ទាំងបាយ ពោត និងទឹកអំពៅ។ នៅពេលដៃលម៉ែឃើញដូច្នោះ គាត់បានប្រាប់មកខ្ញុំថា គាត់នៅសល់អង្ករ ១កំប៉ុងទៀត និងដំឡូងឈើ ១មើម ឲ្យខ្ញុំដាក់ក្នុងថ្នក់ក្រមាត្រលប់ទៅកងចល័តវិញ ព្រោះដល់ពេលវេលាដៃលខ្ញុំត្រូវត្រលប់ទៅវិញហើយ។ ខ្ញុំកាន់កញ្ចប់អង្ករចេញដើរត្រលប់ទៅការដ្ឋានវិញទាំងអស់កម្លាំងពីខ្លួន។ ខ្ញុំដើរបណ្តើរខំទំពាដំឡូងនៅបណ្តើរ។ ដំឡូងនៅមួយមើមនេះ គឺជាសេចក្តីសង្ឃឹមចុងក្រោយសម្រាប់បំពេញកម្លាំងដល់ខ្ញុំ ដៃលបានបាត់បង់។ មាត់របស់ខ្ញុំទំពាដំឡូង ចំណែកឯភ្នែករំពៃមើលឆ្វេងស្តាំ ក្រែងជួបឈ្លប។ ខ្ញុំដើរទៅដល់ស្រែស្វូងប្រហែលជាម៉ោង៣ទៀបភ្លឺ ហើយខ្ញុំក៏ប្រុះខ្លួនដេកនៅលើដីទួលក្រោមដើមស្វាយព្រៃធំមួយក្បែរគុម្ពឫស្សី។ ខ្ញុំដេកយ៉ាងលង់លក់នៅទីនោះរហូតដល់ពេលដៃលកងចល័តដើរមកដល់ក្បែរនៅប្រមាណជាម៉ោង៥ភ្លឺទើបខ្ញុំភ្ញាក់។ ពេលក្រោកឡើងទើបខ្ញុំដឹងថាទួលដៃលខ្ញុំដេកនោះគឺជាផ្នូរខ្មោច ប៉ុន្តែខ្ញុំគ្មានការភ័យខ្លាចនោះទេ។

បន្ទាប់មក ខ្ញុំចុះទៅស្នងជាមួយកងចល័តដទៃទៀត ទាំងគ្មានកម្លាំងសោះ។ នៅព្រឹកនោះដែរ ជាសំណាងល្អ ស្រែដែលខ្ញុំស្នងសម្បុរទៅដោយកំពឹស និងកូនក្តាមជាច្រើន ដែលខ្ញុំអាចចាប់មកហូបនៅជាបណ្តើរៗទំរាំដល់ពេលហូបបបរថ្ងៃត្រង់។ ក្រោយពីមានអង្ករលាក់ទុកនៅក្នុងដបទឹកមក ជារៀងរាល់យប់មុននឹងដេក និងពេលទៀបភ្លឺមុននឹងចេញទៅធ្វើការ ខ្ញុំតែងតែលបលួចហូបអង្ករនៅមួយក្តាប់ដៃ ដើម្បីបន្ថយការស្រែកឃ្លាន។ ខ្ញុំហូបអង្ករនេះអស់ក្នុងរយៈពេល៣ថ្ងៃ ហើយខ្ញុំក៏គ្មានអ្វីហូបដូចមុនទៀតដែរ។

ថ្ងៃនេះ ក្រោយពីដកសំណាបរួចម៉ោងប្រហែលជា ៥ល្ងាច កងចល័តទាំងអស់បានវិលត្រលប់ទៅផ្ទះស្នាក់វិញ។ បន្ទាប់ពីងូតទឹកសម្អាតខ្លួនរួចហើយ យើងទទួលទានបបរគោកមួយវែកម្នាក់ មុននឹងចូលដេក។ នៅយប់នោះពីព្រលប់ខ្ញុំបានឃើញកងឈ្លបពីរនាក់ ដែលមូរជើងខោលើក្បាលដង្គង់ ដើរកាត់មុខផ្ទះស្នាក់របស់ខ្ញុំទៅទិសខាងកើត។ ប្រហែលជាមួយម៉ោងក្រោយមក ខ្ញុំឮសំឡេងយុវជនមួយក្រុម ដើរបណ្តើរជជែកគ្នារអ៊ូៗបណ្តើរ ទៅទិសខាងលិចវិញ។ បន្តិចក្រោយមកទៀត ខ្ញុំស្រាប់តែឮសម្រែក អូយ! អូយ! ស្រែកចេញពីទិសខាងលិច។ ក្រុមកងចល័តម្នាក់សួរថា «តើមានឮសំឡេងអ្វីដែរឬទេ?» មួយរំពេចនោះក៏មានសំឡេងនារីម្នាក់ ដែលប្រហែលជាកម្មាភិបាលនៅក្នុងភូមិស្រែកពីផ្លូវខាងក្រៅផ្ទះស្នាក់ថា «មានយុវជនម្នាក់កំពុងតែចុកពោះ»។ ក្រុមកងចល័ត សូប់ស្ងាត់ទៅវិញ។ ប្រមាណជាម៉ោង៩យប់ យុវជនម្នាក់ឈ្មោះ អ៊ុន ដែលដេកជាប់នឹងខ្ញុំខ្សឹបសួរខ្ញុំថា តើខ្ញុំមានឮសំឡេងវាយមនុស្ស និងសំឡេងស្រែកថ្ងូរដែរឬទេ។ បន្ទាប់ពីខ្ញុំបានផ្ទៀងត្រចៀកស្តាប់ឮហើយ ខ្ញុំបានខ្សឹបប្រាប់ទៅ អ៊ុន វិញកុំឲ្យនិយាយ។ ខ្ញុំនៅបន្តសម្ងំដេកស្តាប់សំឡេងនោះទៀត ហើយប្រហែលជាជាងពីរម៉ោងក្រោយមក ខ្ញុំឃើញស្រមោលមនុស្សលីអីវ៉ាន់មួយការុងមកទំលាក់ទុកនៅខាងក្រោមផ្ទះឮសូរគ្រាំង រួចដើរឡើងមកលើផ្ទះ ធំក្លិនស្រាឆួល រួចក៏ដេកនៅកន្លែងដេករបស់ សាន។ ខ្ញុំដឹងថាគាត់នោះគឺជា សាន។ ខ្ញុំដេកមិនលក់ និងមានការមន្ទិលសង្ស័យ ខ្ញុំតាមឃ្លាំមើលឥរិយាបថរបស់ សាន។ ផ្ទះដេកពុំមាន

ទ្វារបិទបាំង បានធ្វើឲ្យរស្មីផ្លាតរបស់ព្រះចន្ទ ជះចូលមកខាងក្នុងម្តងម្កាល ដែលអាចឲ្យខ្ញុំមើលឃើញ សាន ដេកគងថ្ងាសសន្ធឹកសន្ធៃ ហាក់ដូចអស់កម្លាំង និងមានកង្វល់អ្វីម៉្យាង។ ម៉ោងប្រហែល៨ទៀបភ្លឺ ខ្ញុំឮ សាន ប្រាប់មិត្ត ធន ដែលជាយុវជនជំនិតរបស់គាត់ ហើយដេកក្បែរនឹងគាត់ ឲ្យនាំគ្នាទៅស្ងួងដោយរក្សាភាពស្ងៀមស្ងាត់។

ខ្ញុំ និងកងចល័តដទៃទៀត ចុះពីលើផ្ទះបន្តបន្ទាប់គ្នា ហើយដើរទៅស្រែស្ងួង។ ដោយឡែក មិត្តធន ដែលចុះពីផ្ទះក្រោយគេបន្តិច បានទៅស្ទាបការ៉ុងដែល សាន ទុកចោលក្រោមផ្ទះ ហើយប្រញាប់ប្រញាល់ធ្វើដំណើរយ៉ាងលឿនតាមពីក្រោយកងចល័តដទៃទៀត។ មិត្តធន បានទទួលបញ្ជាពី សាន និយាយប្រាប់កងចល័តទាំងអស់ឲ្យខំប្រឹងធ្វើការដោយភាពស្ងៀមស្ងាត់។ ពិតមែនតែខ្ញុំចង់ដឹងថា តើមានអ្វីទៅនៅក្នុងការ៉ុងនោះ ប៉ុន្តែខ្ញុំមិនហ៊ានហាមាត់សួរ មិត្តធនឡើយ។ ខ្ញុំមិនទុកចិត្តអ្នកណាម្នាក់ក្រៅពីខ្លួនខ្ញុំឡើយ។ ប៉ុន្តែនៅពេលដែលកំពុងស្ងួងជាប់គ្នា មិត្តធន បានខ្សឹបប្រាប់ខ្ញុំថា នៅក្នុងការ៉ុងនោះគឺសុទ្ធតែខោអាវទទឹកទឹកជោគ។ បន្តិចក្រោយមក យុវនារីម្នាក់ដើរទៅបត់ជើងនៅក្បែរគុម្ពឫស្សី បានប្រទះឃើញខោអាវមួយពំនូកបានយកគរចោលនៅកែងភ្លឺស្រែក្បែរនោះ ហើយនិយាយរឿងទាំងអស់នេះប្រាប់កងចល័តពេលត្រលប់មកដល់វិញ។ ធន ដែលយល់អំពីសភាពការណ៍ បានប្រាប់ទៅនារីម្នាក់នោះថា កុំឲ្យនិយាយស្តីអ្វីទាំងអស់ និងគិតតែខំប្រឹងស្ងួងទៅ។ ខ្ញុំនិងកងចល័តខ្លះទៀត យល់ដឹងយ៉ាងច្បាស់ថា កាលពីយប់មិញនេះ អង្គការបានកម្ទេចមនុស្សមួយក្រុមចោល។ យើងទាំងអស់គ្នាខំរកមើលថា តើមានបាត់សមាជិកកងចល័តណាម្នាក់ឬទេទាំងអារម្មណ៍ជ្រួលច្របល់។

ព្រឹកនេះ ដៃជើងរបស់ខ្ញុំ ខំប្រឹងប្រែងធ្វើការយ៉ាងសកម្ម និងស្ងាត់ស្ងៀមបំផុតខុសប្លែកពីធម្មតា ប៉ុន្តែព្រលឹងរបស់ខ្ញុំវិញ ចេញហោះហើរទៅខាងក្រៅខ្លួនបាត់ទៅហើយ។ ខ្ញុំនឹកស្រមៃព្រួយបារម្ភអំពីវាសនាស្នេហារបស់ខ្ញុំជាមួយនឹង ណាវី។ កាលពីចុងឆ្នាំ១៩៧៦ អង្គការភូមិ បានបញ្ចុះបញ្ចូល ខ្ញុំ និងណាវី ដែលជាកូន

របស់អតីតគ្រូបង្រៀនម្នាក់ និងជាប្រជាជន ១៧មេសា ឲ្យរៀបការជាមួយគ្នា។ ដោយមិនអាចប្រកែកនឹងការចាត់ចែងរបស់អង្គការបាន យើងទាំងពីរនាក់បានយល់ព្រមតាមអង្គការ ហើយខំប្រឹងកសាងសម្ព័ន្ធភាពស្នេហាខាងផ្លូវចិត្តជាមួយគ្នាចាប់ពីពេលនោះមក។

អារម្មណ៍ស្នេហាចាប់កើតមានឡើងវិញ។ សេចក្តីស្រលាញ់ចំពោះ ណាវី ដែលជានារីស្រគត់ស្រគំ រម្យទម ពូកែធ្វើការងារ ដែលមានអាយុទើបតែ១៧ឆ្នាំ ហើយថែមទាំងមានរូបសម្បត្តិស្រស់ស្អាត បានរីកចម្រើនយ៉ាងលឿន។ យើងបាក់ចិត្តស្រលាញ់គ្នាយ៉ាងខ្លាំង។ យើងទាំងពីរពុំមានសិទ្ធិចរចា ឬសាសងគ្នាអំពីរឿងស្នេហាទេ។ ច្បាប់សីលធម៌ទី៧ របស់ខ្មែរក្រហម បានហាមជនគ្រប់រូបមិនឲ្យចរចា ឬសាសងគ្នាអំពីរឿងស្នេហាឡើយ ហើយអ្នកមានកំហុសក្នុងរឿងស្នេហានេះនឹងត្រូវអង្គការយកទៅធ្វើទារុណកម្ម ឬសម្លាប់។

មិនបានប៉ុន្មានថ្ងៃផង អង្គការបានជូនដំណឹងមកយើងវិញថា «អង្គការមិនទាន់អនុញ្ញាតឲ្យប្រជាជនថ្មីរៀបការនឹងគ្នាឡើយ ព្រោះទុកបន្តមើលគោលជំហរបដិវត្តន៍ឲ្យបានច្បាស់លាស់សិន។ ដើមទុនដួងចិត្ត បានដាក់បញ្ចូលគ្នាយ៉ាងជ្រោលជ្រៅទៅហើយនោះ ត្រូវស្ថិតក្នុងសភាពគាំងចាប់ពីពេលនោះមក។ យើងទាំងពីរ ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការក្នុងកងចល័តជាមួយគ្នាស្ទើរគ្រប់ការដ្ឋាន។ ខ្ញុំកាន់តែមានអារម្មណ៍ថា យើងពិតជាគូព្រេងនឹងគ្នា។ សេចក្តីស្រលាញ់បានត្រឹមតែជាការលួចគិតពីគ្នា លួចជៀងភ្នែកមើលគ្នាដោយប្រុងប្រយ័ត្ននិងភាពរំជួលចិត្ត។ អង្គការ បានបញ្ចុះបញ្ចូលយើងឲ្យស្រលាញ់គ្នា ប៉ុន្តែនៅពេលយើងស្រលាញ់គ្នាហើយ បែរជាមិនឲ្យយើងរៀបការទៅវិញ។

នារីម្នាក់ស្រែកយំ ព្រោះភ្ញាក់នឹងសត្វឈ្លើងធំមួយ ដែលកំពុងតែទាមជើងរបស់គាត់ ធ្វើឲ្យភ្ញាក់ដល់ការស្រមៃរបស់ខ្ញុំ។ ការដេកស្ងួងនៅថ្ងៃនេះប្រព្រឹត្តទៅក្នុងសភាពនៃការងឿងឆ្ងល់ ព្រួយបារម្ភ និងប្រុងប្រយ័ត្ន។ ពេលហូបបាយល្ងាចរួច ប្រធានភូមិទ័ពសៀម ឈ្មោះ ជា បានមកប្រាប់យុវជនម្នាក់ឈ្មោះ សីហា ឲ្យទៅរែកសំណាបនៅភូមិកំពង់ស្វាយ ដែលមានចម្ងាយប្រហែលបួនគីឡូម៉ែត្រ។ សីហា

ត្រូវទៅជួបជុំគ្នីគ្នានៅទីស្នាក់ការភូមិសិន។ សីហា មកពីភូមិទំពសៀម ប៉ុន្តែគាត់ស្ថិតនៅក្នុងក្រុមផ្សេង។ គាត់ដេកនៅផ្ទះស្នាក់ជាមួយខ្ញុំដែរ។ បន្ទាប់ពីទទួលបានព័ត៌មានភ្លាម សីហា ស្តាប់ពាក្យចុងក្រោយមិនទាន់ ក៏បានទាញឃ្នាប និងដងវែកចេញដំណើរតែម្នាក់ឯងឆ្ពោះទៅភូមិកំពង់ស្វាយ។

បន្តិចក្រោយមក ប្រធានភូមិ ឲ្យឈ្លបភូមិម្នាក់មកសួរកេ សីហា ព្រោះមិនឃើញវត្តមាន សីហា ទៅទីស្នាក់ការភូមិតាមការប្រាប់។ ខ្ញុំក៏ដូចជាកងចល័តខ្លះទៀត ដែលបានដឹងពីការសម្លាប់មនុស្សកាលពីយប់កន្លងទៅនេះ នឹកក្នុងចិត្តថា ប្រហែលជា សីហា បានដឹងរឿងនេះ ហើយកំពុងគេចខ្លួនទៅទីកន្លែងណាហើយមើលទៅ ព្រោះយើងឃើញ សីហា ប្រញាប់ប្រញាល់ចេញទៅបាត់ មិនចូលទីស្នាក់ការភូមិយ៉ាងដូច្នេះ។ គួរឲ្យរន្ធត់ចិត្តពន់ពេក ព្រឹកឡើង ស្រាប់តែឃើញវត្តមាន សីហា ឈរចាំនៅខាងមុខផ្ទះ ហើយមករាយការណ៍ប្រាប់ប្រធានក្រុមរបស់គាត់ថា គាត់បានរកសំណាបដែលត្រូវវែកមកមិនឃើញទេ រួចបានសម្រេចចិត្តដេកនៅភូមិកំពង់ស្វាយមួយយប់។ សីហា ស្នើឲ្យអង្គការអភ័យទោស។ ចំណែក អង្គការភូមិ ដែលកំពុងតែខ្វល់ខ្វាយអំពីការបាត់ខ្លួនរបស់ សីហា ស្រាប់ផង ក្រោយពីបានទទួលដំណឹងនេះភ្លាម បានមកទទួលយក សីហា ទៅមួយរំពេចហើយបញ្ជូនខ្លួនទៅបាត់។ ទិដ្ឋភាពនេះ ធ្វើឲ្យអ្នកផ្សេងទៀតមានភាពភ័យខ្លាចយ៉ាងខ្លាំង ដោយនឹកគិតថាបើ សីហា ដឹងរឿងសម្លាប់នេះច្បាស់លាស់ ហើយគេចខ្លួនចូលទៅក្នុងស្រុកបាភ្នំ ឬស្រុកកោះដែ ដែលមានព្រំប្រទល់ជាប់ភូមិកំពង់ស្វាយស្រាប់ អាចមានឱកាសរស់ខ្លះ។ ព័ត៌មានអំពីការដកហូតមនុស្សចេញពីភូមិ និងពីកងចល័ត បានកើតមានឡើងអស់រយៈពេលពីរថ្ងៃមកហើយ ប៉ុន្តែមិនទាន់មានការបាត់ខ្លួនសមាជិកណាម្នាក់នៅក្នុងក្រុមរបស់ខ្ញុំឡើយ។ យើងទាំងអស់គ្នាប្រឹងប្រែងធ្វើការងារដោយភាពស្ងាត់ស្ងៀមបំផុត។ យើងមិនអាចធ្វើអ្វីបានឡើយ ក្រៅពីរង់ចាំមើលវេនមនុស្សផ្សេងទៀត ដែលនឹងត្រូវអង្គការដកហូតចេញពីក្នុងក្រុម។ ប្រមាណជាម៉ោងជិត៣រសៀល ពេលកងចល័តក្នុងក្រុមរបស់ខ្ញុំ កំពុងតែដកសំណាបយ៉ាងស្ងាត់ស្ងៀមនៅក្បែរផ្លូវថ្នល់ពីមន្ទីរសន្តិសុខ

ម្រេញ មកកាន់ភូមិទ័ពសៀម មានឈ្មោះ អ៊ាន ដែលជាប្រធានរោងបាយទី២ នៅភូមិក្រូច បានជិះកង់តាមផ្លូវជាប់នឹងទីសំណាបខ្ញុំ។ អ៊ាន បញ្ឈប់កង់បន្តិច ហើយងាកមើលមកកងចល័ត រួចបន្តដំណើរទៅទៀត។

ប្រហែលជាម្ភៃនាទីក្រោយមក មានឈ្លបម្នាក់មកដល់ទីសំណាបដោយ ដៃទទេ ហើយសួរឈ្មោះ ណាវី។ ឈ្លបប្រាប់នាងឲ្យទៅយកសម្ភាយអ៊ីវ៉ាន់ពី ផ្ទះស្នាក់ ដើម្បីទៅតាមម្តាយ ដែលកំពុងតែរង់ចាំនៅតាមផ្លូវខាងមុខ ព្រោះត្រូវ ធ្វើដំណើរទៅកាន់តំបន់២៥។ អង្គការ បានយកពាក្យបញ្ជូនទៅតំបន់២៥នេះ សម្រាប់បោកប្រាស់ប្រជាជន ដែលត្រូវនាំទៅសម្លាប់។ ពាក្យបោកប្រាស់នេះ ពុំបានធ្វើឲ្យអ្នកណាម្នាក់ជឿឡើយ តែក៏គ្មាននរណាម្នាក់មានជម្រើសអ្វីផ្សេង ក្រៅតែពីដើរតាមពេជ្ឈឃាដទៅទីពិឃាដដែរ។

នៅពេលឮឈ្មោះរបស់ ណាវី អ្នកដទៃទៀតដែលជាប្រជាជនថ្មីដែរនោះ រួមទាំងរូបខ្ញុំ ប្រឹងធ្វើងស្តាប់ជាបន្តក្រែងមានឈ្មោះអ្នកផ្សេងទៀត។ នៅពេលនោះ គឺមានតែឈ្មោះ ណាវី ម្នាក់តែប៉ុណ្ណោះ។ ប្រជាជនផ្សេងធូរក្នុងចិត្តបន្តិច តែ ចំពោះ ណាវី និងខ្ញុំវិញ មានភាពរន្ធត់ចិត្តក្រៃលែង។ ណាវី ភ័យណាស់ដែលដឹង ថាខ្លួនត្រូវយកទៅសម្លាប់ ចំណែកឯខ្ញុំវិញអាណោចអាធ័មដល់ជីវិតរបស់មនុស្ស ដែលខ្លួនស្រលាញ់ជាគូគ្រងទៅអនាគត។

បន្ទាប់ពីឮកងឈ្លបហៅឈ្មោះភ្លាម ណាវី របូតសំណាបធ្លាក់ចេញពីដៃ ហើយងើបឈរឡើងទាំងភាពតក់ស្លុត។ ខ្ញុំ បានងើបឈរសម្លឹងមកនាងទាំង បេះដូងញ័រចំប្រប់។ ខ្ញុំ និងណាវី បានត្រឹមតែជៀងកន្ទុយភ្នែកជាក់គ្នាតែមួយភ្លែត ប៉ុណ្ណោះ។ បន្ទាប់មក ណាវី បានដើរចេញពីទីសំណាបតាមពីក្រោយអ្នកនាំសារ របស់ពេជ្ឈឃាដ ចំណែកខ្ញុំ នៅបន្តដកសំណាបតទៅទៀតទាំងបេះដូងខ្ទេចខ្ទាំ។ មួយសន្ទុះក្រោយមក ណាវី បានដើរត្រលប់មកវិញពីខាងមុខ អ៊ាន ដែលកំពុងតែ ជិះកង់តិចៗមកតាមពីក្រោយឆ្ពោះទៅទីពិឃាដ។ ក្នុងដំណើរឆ្ពោះទៅរកសេចក្តី ស្លាប់ ដៃរបស់ ណាវី កាន់ថង់អ៊ីវ៉ាន់តូចមួយ និងបបរមួយចាន ហើយ ណាវី បានក្រឡេកមើលមកខ្ញុំក្នុងទឹកមុខក្រៀមក្រំយ៉ាងខ្លាំង។ ពេលនោះ ខ្ញុំពិតជា

មិនដឹងថាតើខ្ញុំអាចធ្វើអ្វីដើម្បីជួយដល់ ណាវី បាននោះទេ ក្រៅពីឈ្លោកមុខចុះតាំងស្មារតីឲ្យនឹង ហើយធ្វើមិនដឹងមិនឮចំពោះហេតុការណ៍ដែលបានកើតឡើងនេះតែប៉ុណ្ណោះ។

ក្នុងពេលនោះ អង្គការកំពុងតែបើកយុទ្ធនាការប្រមូលប្រជាជនថ្មី ដែលជាប់ខ្សែស្រឡាយជាមួយមន្ត្រីថ្នាក់ខ្ពស់ ឬមន្ត្រីយោធារបស់របបលោក លន់ នល់ ទៅសម្លាប់ទាំងអស់។ ណាវី ត្រូវអង្គការចាត់ទុកក្នុងចំណោមគ្រួសារ ដែលមានជាប់ខ្សែស្រឡាយនេះដែរ។ បន្ទាប់ពីកន្លងអស់រយៈពេលកន្លះខែដែល ណាវី បានស្លាប់ អ៊ាន បាននិយាយប្រាប់ទៅកងយុវជន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ថា គាត់ និងប្រធានក្រុមម្នាក់ទៀត បានរំលោភ ណាវី មុនពេលវាយសម្លាប់នឹងដំបង។

ក្រោយមក អង្គការ បានប្រាប់កងចល័តឲ្យបញ្ឈប់ការដកសំណាបពីរសៀលបន្តិច ព្រោះកងចល័តត្រូវចាកចេញពីភូមិទ័ពសៀមទៅភូមិផ្សេងទៀត ប៉ុន្តែអង្គការមិនបានប្រាប់ថាទៅភូមិណាឡើយ។ ក្រោយពីហូបបបរួច កងចល័តប្រញាប់រៀបចំអីវ៉ាន់ដើម្បីចាកចេញទៅការដ្ឋានថ្មី។ អង្គការ បានបញ្ជាឲ្យទៅធ្វើការនៅការដ្ឋានថ្មី ដែលស្ថិតនៅក្នុងភូមិកន្សោម ដោយឲ្យធ្វើដំណើរទៅតាមភូមិត្រពាំងរុន រួចបត់ត្រលប់មកភូមិកន្សោមអកវិញ ដែលជាធម្មតាគឺត្រូវចេញដំណើរពីភូមិទ័ពសៀម កាត់តាមក្បែរទួលម្រេញ(កន្លែងសម្លាប់មនុស្ស) និងមកភូមិកន្សោមអក។

នៅភូមិកន្សោមអក ក្រុមរបស់ខ្ញុំ ត្រូវស្នាក់នៅផ្ទះដែលមានចម្ងាយប្រមាណជិត ១គីឡូម៉ែត្រពីទួលម្រេញ។ ពេលយប់ស្ងាត់ ម្តងម្កាលមានប្រជាជនឮស្នូរវាយនិងសម្រែកឮញយំពាក្យអង្វរករល្វើយៗ លាយឡំទៅដោយសំឡេងឧបករណ៍បំពងសំឡេង ដែលចាក់ផ្សាយដើម្បីបន្លំសំឡេងស្រែកយំ។ កងចល័ត និងអ្នកភូមិ តែងតែខ្សឹបខ្សៀវប្រាប់គ្នាអំពីរឿងនេះដោយសេចក្តីភ័យខ្លាច។

ព្រឹកឡើង កងចល័តក្រុមរបស់ខ្ញុំ ត្រូវទទួលភារកិច្ចដកសំណាបទាំងអស់គ្នា ហើយស្នងនៅពេលល្ងាចវិញ។ ពេញមួយថ្ងៃ យើងឃើញតែក្រុមយុវជន យុវនារី

បណ្តើរគ្នាជាក្រុមៗ ជាប់ហូរហែពីភូមិកំពង់ស្វាយ ភូមិក្រូច និងភូមិបល្ល័ង្ក កាត់តាមភូមិកន្សោមអក ឆ្ពោះទៅកាន់ទួលម្រេញ។ អ្នកខ្លះស្រែកច្រៀងចម្រៀងបដិវត្តន៍ដើម្បីបង្ហាញពីភាពពេញចិត្តចំពោះអង្គការ។

នាពេលរសៀលថ្ងៃមួយ ឈ្មោះ លាន ដែលជាប្រធានរោងបាយទី៧របស់ខ្ញុំនៅក្នុងភូមិក្រូច និងជាបងបង្កើតរបស់ឈ្មោះ អ៊ាន អ្នកគ្រប់គ្រងនៅការដ្ឋានចាស់របស់ខ្ញុំ បានមកដល់ភូមិកន្សោមអក។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងដោយនឹកគិតថា លាន ប្រាកដជាយកបញ្ជីឈ្មោះអ្នកដែលត្រូវសម្លាប់មកឲ្យ សាន ដែលជាប្រធាន «គ» របស់ខ្ញុំ ដើម្បីដកហូតអ្នកទាំងអស់នោះចេញពីកងចល័ត។ ខ្ញុំខំប្រឹងញញឹមស្លូតដាក់ លាន ដើម្បីសម្តែងការគួរសម ប៉ុន្តែ លាន មិនញញឹមឆ្លើយតបដាក់ខ្ញុំវិញឡើយ។ លុះពេលល្ងាចបន្តិចទើបខ្ញុំដឹងថា លាន បានមកយកក្មួយបង្កើតរបស់ប្រពន្ធខ្លួនពីផ្ទះម្តាយក្មេករបស់ លាន នៅភូមិកន្សោមអក ដើម្បីយកទៅសម្លាប់ជាមួយនឹងម្តាយរបស់កុមារនោះ។ យប់នេះ ព្រះចន្ទពេញបូណ៌ក្រុមកងចល័តរបស់ខ្ញុំ ត្រូវបាន សាន ចាត់ឲ្យទៅស្ងូងនៅពេលយប់បន្ថែមទៀត។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំឃើញ ង៉ាន់ ដែលជាប្រធានភូមិក្រូច និងធឿង ដែលជាប្រភេទមនុស្សពូកែទ្រឹស្តី ហើយចេះអែបអបបំផុតនោះជាមួយនឹងក្រុមខ្មែរក្រហមដោយមានស្គាយកាំភ្លើងមួយដើមបណ្តើរ អតីតអ្នកគ្រូបង្រៀនម្នាក់ឈ្មោះ សាលី ដែលជាសាច់ញាតិរបស់ខ្ញុំ ព្រមទាំងមនុស្សមួយចំនួនទៀតឆ្ពោះទៅទួលម្រេញ។ ការដង្ហែប្រជាជនទៅទីពិឃាដភូមិម្រេញ មានជាប់ជាហូរហែតាំងតែពីព្រលឹមស្រាងៗរហូតដល់ម៉ោងប្រហែល៩យប់។

ភាពព្រួយបារម្ភអំពីជោគវាសនាខ្លួនរបស់ប្រជាជនម្នាក់ៗ ស្ថិតនៅក្នុងភាពជ្រួលច្របល់រៀងៗខ្លួន។ ស្អែកព្រឹកឡើង ខ្ញុំបានក្រោកពីយប់ដើរទៅស្រែស្ងូងស្រូវមុនគេបង្អស់។ ខ្ញុំបានស្តាប់ឮសំឡេងអ្នកភ្ជួរដេញក្របីយ៉ាងច្បាស់ពីស្រែស្ងូងមួយក្នុងភូមិក្រូច ដែលមានព្រំប្រទល់ជាប់នឹងភូមិកន្សោមអក។ ក្រោយផ្អៀងស្តាប់បន្តិច ខ្ញុំស្គាល់ថាមានសំឡេងរបស់ពូខ្ញុំម្នាក់ដែរ។ ខ្ញុំបានសម្រេចចិត្តលួចទៅសួរពូខ្ញុំអំពីស្ថានភាពក្រុមគ្រួសាររបស់ខ្ញុំថាតើមានអ្នកណាត្រូវបាន

អង្គការបញ្ជូនទៅតំបន់២៥ ឬត្រូវយកទៅសម្លាប់ដែរឬទេ។ ពូវង បានប្រាប់ខ្ញុំ ថាក្រុមគ្រួសាររបស់ខ្ញុំទាំងអស់មិនអីនោះទេ។ ឮដូច្នោះ ខ្ញុំស្រឡះក្នុងចិត្តបន្តិច ហើយប្រញាប់ប្រញាល់លា ពូវង ដើរយ៉ាងលឿនសំដៅទៅផ្ទះរបស់ខ្ញុំ ដែលមាន ចម្ងាយជិតមួយគីឡូម៉ែត្រ។ ខ្ញុំបានជួបម៉ែ ហើយបាននិយាយលាគាត់ទុកជាមុន ខ្លាចក្រែងថ្ងៃណាមួយ ខ្ញុំត្រូវអង្គការយកខ្ញុំទៅសម្លាប់ដោយមិនបាននិយាយ លាគាត់។ ក្រសែភ្នែកបង្កប់ដោយក្តីស្រលាញ់ អាណិតអាសូរ និងព្រួយបារម្ភ របស់ម៉ែខ្ញុំ កំពុងតែសម្លឹងមករកខ្ញុំ។ ម៉ែ បានទៅយកដំឡូងឈើឆៅមួយមើមធំ ដែលគាត់លាក់ទុក យកមកឲ្យខ្ញុំហូបដើម្បីបន្តកម្លាំង។

ព្រឹកនេះ ខ្ញុំមិនឃើញមានមនុស្សដែលត្រូវអង្គការបញ្ជូនទៅសម្លាប់ទៀតទេ។ ពេលស្ទូងរួច សាន សួរនាំខ្ញុំអំពីដំណើរការងារដកស្ទូងនៅក្នុងក្រុមរបស់ខ្ញុំ។ ពេលឮ សាន សួរដូច្នេះ ខ្ញុំដូចជាមានសង្ឃឹមរស់បន្តិចដែរ ព្រោះខ្ញុំគិតថាអង្គការ នៅនិយាយរកខ្ញុំ។ នៅក្នុងរដូវវស្សា ទឹកជំនន់ទន្លេកំពុងតែឡើងយ៉ាងលឿន ហើយពីរថ្ងៃបន្ទាប់មក ទឹកបានឡើងមកលិចស្រែដែលយើងត្រូវស្ទូងទាំងអស់។ ការដកស្ទូងមិនអាចបន្តទៅទៀតបានឡើយ ហើយកងចល័តទាំងអស់ ត្រូវបាន រំសាយឲ្យត្រលប់ទៅធ្វើការងារនៅតាមភូមិរៀងៗខ្លួនវិញ។ ប្រជាជនទាំងអស់ ពុំមានការងារអ្វីធ្វើច្រើនឡើយ ក្រៅតែពីជួយធ្វើផ្នើរទុកដាក់របស់របរផ្ទះបាយ និងគ្រឿងហូបចុកឲ្យផុតពីទឹក។ ខ្ញុំមានពេលសម្រាកកម្លាំងបន្តិច ហើយអាច បាញ់កណ្តុរលង់ទឹកធ្វើជាម្ហូបអាហារលួចលាក់យ៉ាងឆ្ងាញ់ពិសារ។ ក្នុងរយៈពេល ទឹកលិចនេះ អង្គការបានប្រើខ្ញុំឲ្យធ្វើតែការងារមួយគត់ គឺច្រៀកពុះត្នោតបន្តជា ខ្សែវែងៗ ដើម្បីយកទៅចងសាកសព ដែលអណ្តែតទឹក យកមករុំនឹងដើមឈើ ទុកមួយកន្លែង។ ប្រជាជនថ្មី ៦២គ្រួសារ ដែលមានមនុស្សសរុបចំនួន ១៦២នាក់ នៅក្នុងភូមិក្រូច និងប្រជាជនថ្មីជាច្រើនរយគ្រួសារទៀតមកពីភូមិផ្សេងទៀតក្នុង ស្រុកកំពង់ត្របែក ត្រូវបានអង្គការយកទៅសម្លាប់ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ។

បន្ទាប់ពីទឹកស្រកផុតអស់ហើយ អង្គការបានឲ្យខ្ញុំធ្វើជាអ្នកបរទេះ ដើម្បី ដឹកសំណាប និងស្រូវហូបពីភូមិនានា ដែលមិនលិចទឹក និងមានសល់ស្រូវមក

ផ្តត់ផ្តង់ប្រជាជននៅក្នុងភូមិក្រូច។ ខ្ញុំជ្រើសរើសក្របីឡើងកមួយនឹមដែលធាត់ជាងគេ ហើយខិតខំប្រឹងថែទាំបានយ៉ាងល្អបំផុត។ ខ្ញុំគិតថាការងារបររទេះអាចនឹងជួយឲ្យខ្ញុំធូរស្បើយកម្លាំងច្រើន ហើយអាចទទួលបានបាយហូបប្រសើរជាងក្រុមផ្សេងទៀត។ លើសពីនេះ នៅពេលចេញទៅដឹកស្រូវពីភូមិផ្សេងមកផ្តត់ផ្តង់ដល់ភូមិក្រូច ខ្ញុំអាចលួចស្រូវបានបន្តិចបន្តួច ដើម្បីជួយសមាជិកគ្រួសាររបស់ខ្ញុំដែរ។ ខ្ញុំ ប្រុងប្រយ័ត្នខ្លាំងណាស់នៅពេលលួចស្រូវម្តងៗ ព្រោះខ្ញុំដឹងយ៉ាងច្បាស់ថា ខ្ញុំនឹងមានទោសយ៉ាងធ្ងន់ធ្ងរបើអង្គការចាប់ខ្ញុំបាន។ ពេលនេះ ម្នាក់ៗឈប់គិតពីភាពលំបាក ការឈឺចាប់ ឬការស្លាប់របស់អ្នកដទៃហើយ ប៉ុន្តែត្រូវធ្វើយ៉ាងណាដើម្បីសង្គ្រោះជីវិតខ្លួនឯងប៉ុណ្ណោះ។

រដូវវស្សាក្នុងឆ្នាំ១៩៧៨ បាតុភូតទឹកជំនន់បានកើតឡើងចំនួនពីរដង។ បន្ទាប់ពីទឹកជំនន់លើកទីមួយ បានស្រកចុះ មានសាកសពជាច្រើនដែលផុសចេញពីរណ្តៅរួមស្ថិតនៅរាយពាសពេញតាមទីវាលយ៉ាងអាណោចអាធ័ម និងសង្វេគក្រៃលែង។ បន្ទាប់ពីទឹកជំនន់ស្រកចុះផុតពីវាលស្រែប្រហែលជាជាងពីរសប្តាហ៍ ទឹកជំនន់លើកទីពីរ បានឡើងមកវិញម្តងទៀត។

អង្គការថ្នាក់មូលដ្ឋានហាក់ដូចជាមិនរឹតបន្តឹងប្រជាជនក្រោមការគ្រប់គ្រងលើទឹកដីរបស់ខ្លួនដូចពីមុនទៀតទេ។ ថ្នាក់ដឹកនាំស្រុកលែងមានកិច្ចសហការរវាងស្រុកមួយ និងស្រុកមួយទៀតហើយ។ ស្ថានភាពពេលនេះ បានធ្វើឲ្យប្រជាជនអាចលួចរត់ចេញពីស្រុកមួយទៅស្រុកមួយទៀត និងមិនត្រូវអង្គការចាប់ខ្លួនបញ្ជូនត្រលប់មកវិញដូចមុនទៀតឡើយ។ មិនតែប៉ុណ្ណោះ អង្គការថែមទាំងជួយការពារប្រជាជនកៀសខ្លួនទៀតផង។ ប្រជាជនមួយចំនួនបានរត់ចេញពីភូមិក្រូច ចូលទៅស្រុកបាភ្នំ ឬស្រុកមេសាង ហើយអ្នកខ្លះបានបន្តដំណើរទៅស្រុកផ្សេងទៀត។

ម៉ោងប្រមាណជា ៨យប់ នៅខាងក្រោមផ្ទះរបស់ខ្ញុំ ដែលទឹកកំពុងលិចជម្រៅត្រឹមក្លៀក ស្រាប់តែមានសំឡេងអុំទូកបន្លឺឡើងពីទិសខាងជើងផង និងខាងត្បូងផង។ ខ្ញុំ ផ្ទៀងស្តាប់យ៉ាងយកចិត្តទុកដាក់ និងទាញយកបង្វិចខោអាវកញ្ចាស់របស់ខ្ញុំមកដាក់ក្បែរមាត់ទ្វារផ្ទះបាយ។ បន្តិចក្រោយមក សំឡេងរបស់

ប្រធានផ្នះបាយឈ្មោះ លាន ស្រែកហៅខ្ញុំពីខាងត្បូងផ្នះថា ឲ្យខ្ញុំទៅជួយទប់ទឹកបន្តិច។ ឮពាក្យនេះភ្លាម ខ្ញុំបានសម្រួតខ្លួនជាមួយខោខ្លីទៅក្នុងទឹកដោយបន្ថឹមខ្លួននៅត្រឹមក និងរង់ចាំមើលសភាពការណ៍បន្ត ពីព្រោះខ្ញុំខ្លាចអង្គការប្រើពាក្យពេចន៍របៀបនេះ ដើម្បីចាប់ខ្ញុំ។ ខ្ញុំ បានតាំងស្មារតីយ៉ាងរឹងមាំ ដោយតាំងចិត្តថា មិននៅសម្ងំស្ងៀមឲ្យអង្គការចាប់ខ្លួនយកទៅសម្លាប់ទេ។ ខ្ញុំ តាំងចិត្តថា ត្រូវតែធ្វើការតស៊ូ ឬរត់គេចចេញពីការចាប់ចង។ មួយរំពេចនោះ ខ្ញុំបានឮសំឡេងពូវង និងយុវជនជាច្រើននាក់ទៀត និយាយគ្នាខ្ទៀវខ្ទារក្នុងសភាពមិនកិតក័យពីខាងជើងផ្នះខ្ញុំ ដែលអាចឲ្យខ្ញុំសន្មតបានថា អង្គការពិតជាហៅខ្ញុំឲ្យទៅជួយទប់ទឹកមែន។ បន្ទាប់មក ខ្ញុំបានងើបឡើងពីទឹក ហើយទៅចូលរួមទប់ទឹកជំនន់ជាមួយនឹងប្រជាជនដទៃទៀត។

ព្រឹត្តិការណ៍មួយទៀតដែលធ្វើឲ្យប្រជាជនជ្រួលច្របល់ និងរត់ចេញពីភូមិនោះគឺ ការជ្រើសរើសគ្រួសារមួយចំនួនដើម្បីបញ្ជូនទៅនៅតំបន់២៥។ គ្មាននរណាម្នាក់ដឹងពីស្ថានភាពពិតប្រាកដនៃតំបន់២៥នោះទេ ហើយមិនដឹងថាតើអង្គការបញ្ជូនប្រជាជនឲ្យទៅរស់នៅក្នុងតំបន់នោះមែន ឬគ្រាន់តែជាល្បិចដកយកប្រជាជនទៅសម្លាប់ដូចមុនទៀតនោះទេ។ ខ្ញុំធូរស្បើយក្នុងចិត្តបន្តិច ព្រោះសមាជិកគ្រួសាររបស់ខ្ញុំគ្មានឈ្មោះត្រូវបញ្ជូនទៅរស់នៅក្នុងតំបន់២៥នោះទេ។

នៅខែធ្នូឆ្នាំ១៩៧៨ ពាក្យចចាមអារ៉ាមថា នឹងមានចលនាបះបោរប្រឆាំងនឹងការគ្រប់គ្រងរបស់អង្គការ បានកើតឡើងនៅតំបន់ខាងកើតប្រទេសកម្ពុជា ហើយចលនានោះកំពុងតែវាយតតាំងជាមួយកងទ័ពរបស់ខ្មែរក្រហម។ មេខ្មែរក្រហមតាមភូមិ បានទទួលបញ្ជាពីថ្នាក់លើឲ្យស្រាវជ្រាវប្រមូលយកវិទ្យុដែលមាននៅសេសសល់បន្តិចបន្តួចឲ្យអស់ពីប្រជាជន។ ជាមួយគ្នានេះដែរ នៅក្រៅម៉ោងធ្វើការងារ កាំបិតពូថៅដែលប្រជាជនប្រើប្រាស់ប្រចាំថ្ងៃទាំងអស់ ត្រូវបានអង្គការប្រមូលយកទៅទុកនៅតាមរោងបាយរួមដែរ។

រហូតដល់ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩ ស្នូរគ្រាប់កាំភ្លើងធំលាន់ឮល្វើយៗកាន់តែញាប់ និងកាន់តែច្បាស់ ហើយខិតចូលមកកាន់តែជិតនឹងភូមិរបស់ខ្ញុំ។

ភាពរំជើបរំជួលក្នុងចំណោមប្រជាជនកាន់តែកើនច្រើនឡើងៗ រីឯព័ត៌មានអំពីការឈ្លានពានរបស់វៀតណាម ត្រូវបានអង្គការផ្សព្វផ្សាយឲ្យដឹងកាន់តែច្បាស់។ ម៉ោងប្រមាណជា ១រសៀល រោងបាយទាំងអស់ក្នុងភូមិក្រូច បានទទួលបញ្ជាពីអង្គការភូមិឲ្យរៀបចំស្បៀងអាហារ និងចានឆ្នាំងដាក់លើរទេះគោក្របី និងផ្ទៃតាមគ្រួសារខ្លះៗ ដើម្បីភៀសចេញទៅទិសខាងលិច។ ហ្វូងរទេះគោក្របី និងប្រជាជនយ៉ាងស្អេកស្កះពីភូមិឃុំនានាប៉ែកខាងកើត កំពុងធ្វើដំណើរលាយឡំគ្នាជាប់រដឹកឆ្ពោះទៅទិសដៅតែមួយតាមការចង្អុលបង្ហាញរបស់អង្គការ។ រទេះក្របីរបស់ខ្ញុំ ដែលទទួលបន្ទុកដឹកស្បៀងផ្ទះបាយលេខ ៧ទាំងស្រុង ចេញដំណើរទៅជាមួយប្រជាជនផ្សេងទៀតដែរ។ ខ្ញុំមិនអាចចូលរួមដំណើរជាមួយនឹងសមាជិកគ្រួសាររបស់ខ្ញុំបានឡើយ ព្រោះគាត់ត្រូវដើរតាមផ្លូវកាត់។ បន្ទាប់ពីបររទេះពេញមួយយប់ទល់ភ្លឺ ខ្ញុំបានទៅដល់ឈើកាច់ខាងកើតភ្នំ ប្រហែលជាម៉ោង ៨ព្រឹក។ ខ្ញុំបានឈប់នៅទីនោះ ដើម្បីឲ្យក្របីសម្រាក និងស៊ីស្មៅដែលខ្ញុំបានកាត់ទុកឲ្យ។ បន្ទាប់មក ខ្ញុំដាក់ដាំបាយជាមួយអង្ករមួយកំប៉ុង ដែលជារបបអាហារសម្រាប់ថ្ងៃត្រង់ និងពេលល្ងាចរបស់ខ្ញុំ ប៉ុន្តែខ្ញុំបានហូបបាយនោះទាំងអស់តែរយៈពេលមួយពេលថ្ងៃត្រង់នោះ។

ម៉ោងប្រហែល ២រសៀល ស្នូរយន្តហោះបន្លឺសំឡេងឡើង។ ខ្ញុំបានរំពៃរកមើលយន្តហោះនោះ។ ខ្ញុំបានឃើញយន្តហោះមួយគ្រឿងហោះកាត់ក្បែរភ្នំពីលើផ្លូវជាតិលេខ១ មុនពេលដែលស្នូរគ្រាប់បែកចំនួន ៣គ្រាប់ ផ្ទុះឡើងយ៉ាងកក្រើកដីនៅទិសខាងលិច។ មួយរំពេចនោះ យោធាខ្មែរក្រហម ៣នាក់ បានស្រែកប្រាប់ប្រជាជនឲ្យប្រញាប់បន្តដំណើរទៅមុខទៀតជាបន្ទាន់។ រទេះរបស់ខ្ញុំ ចាប់ផ្តើមចេញដំណើរយឺតៗ តាមជាយភ្នំពីខាងជើងឆ្ពោះទៅអ្នកលឿង។ ម៉ោងប្រហែលជា ៤រសៀល ស្នូរគ្រាប់កាំភ្លើងធំបានផ្ទុះឡើងយ៉ាងកក្រើកដី។ រទេះគោក្របី និងអ្នកដំណើរទាំងអស់ឈប់ទ្រឹងមួយកន្លែង។ មួយសន្ទុះក្រោយមកស្រាប់តែឃើញក្រុមខ្មែរក្រហម បានជិះម៉ូតូមកដល់ ហើយស្រែកប្រាប់ប្រជាជនដែលកំពុងតែធ្វើដំណើរឲ្យត្រលប់ថយក្រោយវិញ។ រទេះគោក្របីនិងអ្នកដំណើរទាំងអស់ចាប់ផ្តើមបត់ត្រលប់ថយក្រោយយ៉ាងតក់ក្រហល់និងលំបាកលំបិន។

ថ្ងៃទី៥ ខែមករា បានចូលមកដល់ ខ្ញុំព្រមទាំងប្រជាជនផ្សេងទៀត ដែលកំពុងតែធ្វើដំណើរត្រលប់បកមកក្រោយវិញ នៅមិនទាន់មានទិសដៅច្បាស់លាស់ថាទៅណានៅឡើយទេ។ ក្របីរបស់ខ្ញុំ ដើរលែងទៅមុខនៅពេលដែលបានត្រលប់មកដល់ផ្លូវបំបែកពីឈើកាច់ទៅកាន់រក្សជ័យ។ ខ្ញុំបានដោះក្របីចេញពីរទេះដើម្បីឲ្យវាដេកសម្រាកសិន ព្រោះក្របីរបស់ខ្ញុំ បានដើរជាប់រហូតអស់ពេលពីរថ្ងៃមកហើយ។ ខ្ញុំយកស្មៅដែលនៅសេសសល់បន្តិចដាក់ឲ្យក្របីស៊ីបង្ហើយ។ នៅតាមដងផ្លូវមានកងទ័ពខ្មែរក្រហមជាច្រើនរយនាក់ ប្រដាប់ដោយកាំភ្លើង និងគ្រាប់រំសេវពេញខ្លួន កំពុងអង្គុយជាជួរយ៉ាងស្ងាត់ស្ងៀម ដែលបង្ហាញពីភាពហៅហត់ក្នុងការធ្វើដំណើរ។ ខ្ញុំប្រថុយសួរកងទ័ពខ្មែរក្រហមម្នាក់ ដែលអង្គុយក្បែរទេះរបស់ខ្ញុំថា តើខ្ញុំគួរធ្វើដំណើរទៅទិសខាងណាវិញ។ គាត់បានប្រាប់ខ្ញុំថា គាត់មិនដឹងទេ ព្រោះសូម្បីតែក្រុមកងទ័ពរបស់គាត់ ក៏មិនដឹងថាត្រូវធ្វើដំណើរទៅទីណាដែរ ហើយគាត់កំពុងតែរង់ចាំបញ្ជាពីថ្នាក់លើ។

ម៉ោងប្រហែលជា ១០យប់ ខ្ញុំបានបន្តដំណើរទៅតាមផ្លូវ ទៅទិសខាងជើងឆ្ពោះទៅរក្សជ័យ។ ពេលទៅដល់ផ្លូវបំបែកទៅ វត្តកំរែង ខ្ញុំបានជួបអ្នកភូមិជាមួយគ្នាចំនួន ២រទេះគោទៀត ហើយបានបបួលគ្នាសម្រាកនៅទីនោះរហូតទល់ភ្លឺ។ ថ្ងៃស្អែក ខ្ញុំបានរៀបចំរទេះដើម្បីបន្តដំណើរទៅមុខទៀត។ ស្ថានការណ៍គ្រប់យ៉ាងនៅតែមិនទាន់ប្រាកដប្រជានៅឡើយ។ ប្រជាជនមួយក្រុម ដែលទើបតែធ្វើដំណើរមកពីឈើកាច់ មកដល់កន្លែងឈប់សម្រាករបស់ពួកខ្ញុំ បានប្រាប់ខ្ញុំថា កងទ័ពខ្មែរក្រហមមិនមានវត្តមាននៅតាមផ្លូវទៀតឡើយ។ គាត់បន្តទៀតថា ក្រុមរបស់គាត់បានសម្រេចចិត្តវិលត្រលប់ទៅក្នុងភូមិវិញ។ បន្តិចក្រោយមក ខ្ញុំជួបអ្នកជិះកង់ពីរនាក់ ដែលជិះយ៉ាងលឿនតាមផ្លូវពី វត្តកំរែង។ គាត់ទំនងជាអ្នកមកពីឆ្ងាយ។ ខ្ញុំបានសួរគាត់ថាតើគាត់ធ្វើដំណើរទៅណាវិញក្នុងសភាពប្រញាប់ប្រញាល់ដូច្នេះ។ គាត់បានប្រាប់ខ្ញុំថា កងទ័ពវៀតណាមមកជិតដល់ហើយ។ ឮដូច្នោះ ខ្ញុំមានការព្រួយបារម្ភដែរថា តើកងទ័ពវៀតណាមនឹងធ្វើអ្វីខ្ញុំទេ។ ខ្ញុំបានសម្រេចចិត្តថានឹងត្រូវតែវិលត្រលប់ទៅខាងក្រោយវិញដើម្បីគេចឲ្យផុតពីក្រុមខ្មែរក្រហម។ រទេះក្របី

ខ្ញុំរំកិលខ្លួនយឺតៗតាមផ្លូវលំឆ្ពោះមករកវត្តកំរែង ដើម្បីវិលត្រលប់ទៅផ្ទះវិញ។ ខ្ញុំមិនបានទទួលដំណឹងអ្វីសោះពីឪពុកម្តាយ និងប្អូនៗទាំង ៦នាក់របស់ខ្ញុំ។ នៅតាមផ្លូវ ខ្ញុំឃើញមានប្រជាជនខ្លះបានវិលត្រលប់មកដល់លំនៅឋានវិញ។ ពេលមកដល់ក្បែរ វត្តកំរែង ខ្ញុំបានជួបកងទ័ពវៀតណាមមួយឡាន កំពុងបើកសំដៅទៅទិសខាងលិច។ ខ្ញុំខំប្រឹងញញឹមដាក់កងទ័ពវៀតណាមទាំងអស់នោះ ហើយលើកដៃទាំងពីរឡើងលើ ព្រមទាំងស្រែកថា ជយោ! ជយោ! ជាច្រើនដង។ កងទ័ពវៀតណាមបានបង្អង់ល្បឿនរថយន្តបន្តិច និងសម្តែងទឹកមុខញញឹមញញែមដាក់ខ្ញុំ ថែមទាំងលើកដៃជាសញ្ញាអបអរសាទរចំពោះការវិលត្រលប់ថយក្រោយរបស់ខ្ញុំ។ បន្តិចក្រោយមក រថយន្តកងទ័ពវៀតណាមមួយគ្រឿងទៀតមកដល់ ហើយខ្ញុំក៏បានសម្តែងដាក់កងទ័ពវៀតណាមទាំងនេះដូចមុនទៀត។ កងទ័ពម្នាក់ និយាយភាសាខ្មែរយ៉ាងច្បាស់មកកាន់ខ្ញុំថា «សូមបងប្អូនកុំភ័យ កងទ័ពយើងមករំដោះបងប្អូនទាំងអស់គ្នាហើយ សូមបងប្អូនវិលត្រលប់ទៅផ្ទះរៀងៗខ្លួនវិញចុះ»។ ខ្ញុំនិងប្រជាជនផ្សេងទៀតបានលើកដៃឡើងលើ ហើយនាំគ្នាស្រែកថា ជយោៗ ជាច្រើនដងទៀតដែរ។

ពេលនេះ ខ្ញុំមើលឃើញថា កងទ័ពវៀតណាម ពិតជាបានមករំដោះជីវិតខ្ញុំ និងប្រជាជនខ្មែរ ដែលនៅសេសសល់ពីស្លាប់ពិតប្រាកដមែន។ ខ្ញុំបានត្រលប់ទៅដល់ភូមិក្រូចវិញ នៅល្ងាចថ្ងៃទី៦ មករា ១៩៧៩។ ប្រជាជននៅក្នុងភូមិភាគច្រើនបានត្រលប់មកដល់ភូមិតាំងតែពីព្រឹក។ ប្រជាជនទាំងអស់នោះ បានប្រាប់ខ្ញុំថា អ៊ាន និង លាន ដែលបានសម្លាប់ប្រជាជនអស់ជាច្រើននាក់នោះ ត្រូវអ្នកភូមិមួយក្រុមចាប់យកទៅសម្លាប់សងសឹកវិញបាត់ទៅហើយ រីឯមេខ្មែរក្រហមក្នុងភូមិក្រូចផ្សេងទៀត បាននាំគ្នារត់គេចខ្លួនបាត់អស់។

ខ្ញុំមិនចង់ឲ្យមានការសម្លាប់សងសឹកគ្នាបែបនេះនោះទេ ប៉ុន្តែការសម្រេចចិត្តរបស់ប្រជាជនដែលបានធ្វើរួចទៅហើយក្នុងពេលនោះ។ អ្វីដែលខ្ញុំត្រូវធ្វើក្នុងពេលនេះគឺខ្ញុំសូមសង្រួមកាយ វាចា ចិត្ត គោរពវិញ្ញាណក្ខន្ធបងប្អូនទាំងអស់នៅក្នុងភូមិក្រូច ដែលបានបាត់បង់ជីវិតក្រោមការសម្លាប់របស់ខ្មែរក្រហម។

ខ្ញុំសូមផ្ញើសារពិសេសជូនវិញ្ញាណក្ខន្ធរបស់ ណាវី ថា «ឈ្មោះ អ៊ាន ដែលបានធ្វើបាបអូន ចាប់រំលោភអូន មុននឹងសម្លាប់អូននោះ ត្រូវបានពលរដ្ឋក្នុងភូមិយើងកាត់ទោសសងសឹកជូនអូនរួចហើយ បងសូមបួងសួងឲ្យព្រលឹងអូនបានទៅកាន់សុគតិភពជារៀងរហូត បងសូមផ្សងចំពោះវិញ្ញាណក្ខន្ធអូន ណាវី ថា បើមានជាតិក្រោយ បងប្រាថ្នាឲ្យបានជួបអូនជាគូគាប់ពេញមួយជីវិត»។

ចប់

៤

រឿងក្រោមមេឃតែមួយ

អ្នកនិពន្ធ ៖ ឃុត សុខឿន

៤ ~ រឿង ក្រោមមេឃតែមួយ

«ឈប់យំទៅ..!» ខ្ញុំបានខ្សឹបប្រាប់ខ្លួនឯងតិចៗ ប៉ុន្តែទឹកភ្នែកហាក់មិនស្តាប់បញ្ជារបស់ខ្ញុំទាល់តែសោះ។ ទឹកភ្នែករបស់ខ្ញុំនៅតែរមៀលធ្លាក់ចុះមកលើផ្ទៃផែនថ្ពាល់ទាំងសងរបស់ខ្ញុំឥតស្រាកស្រាន្ត។ គ្រប់ពេលវេលាដែលខ្ញុំបានឃើញដើមត្នោតមួយដើមនេះ រឿង៉ាវឈឺចាប់ខ្លោចផ្សាពីអតីតរបស់ខ្ញុំ តែងផុសចេញមកជានិច្ច។ យប់ស្ងាត់ ផ្ទៃមេឃងងឹតឈឹង ប៉ុន្តែរឿង៉ាវនៅក្នុងចិត្តរបស់ខ្ញុំ បែរជាភ្លឺច្បាស់ និងមានជីវិតរស់រវើក។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនិងក្រុមគ្រួសាររបស់គូដណ្តឹងខ្ញុំត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ទៅកាន់ភាគខាងត្បូងនៃប្រទេសកម្ពុជា រួមជាមួយនឹងប្រជាជនខ្មែររាប់សែននាក់ទៀត។ អាកាសធាតុក្តៅហួតហែងនារដូវប្រាំង និងភាពណែនណាន់តាន់តាប់នៃវត្តមានរបស់មនុស្សដើរនៅតាមផ្លូវគឺមិនអាចឲ្យយើងធ្វើដំណើរទៅមុខបានលឿនឡើយ បើទោះជាមានសំឡេងស្រែកគំរាមកំហែងពីសំណាក់កងទ័ពខ្មែរក្រហមក្តី។ ទិដ្ឋភាពនៅតាមដងផ្លូវគឺជាទន្លេមនុស្សដែលពោរពេញដោយភាពក្រៀមក្រំ និងស្រងេះស្រងោចបំផុត។ មរណភាព ការនិរាសព្រាត់ប្រាស់ ការលះបង់ និងការត្អូញត្អែររបស់ប្រជាជនកម្ពុជា ដែលត្រូវបានខ្មែរក្រហមជម្លៀស គឺជារូបភាពដ៏សែនសង្រេងចិត្តបំផុតដែលខ្ញុំបានឃើញជាប់តាមផ្លូវហូរហែ។

ប៉ុន្មានថ្ងៃក្រោយមក គ្រួសាររបស់ខ្ញុំ បានធ្វើដំណើរមកដល់វត្តមួយស្ថិតនៅជាប់មាត់ទន្លេម្តុំគាខ្មៅ។ យើងទាំងអស់គ្នា ត្រូវកងទ័ពខ្មែរក្រហមបញ្ជាឲ្យចូលទៅសម្រាកនៅក្នុងវត្ត។ វត្តនោះ មើលទៅមានសភាពទ្រុឌទ្រោម និងបាក់

បែកជាអន្លើ ដោយសារតែការទម្លាក់គ្រាប់បែក និងបោះបង់ចោល។ នៅក្នុងទីធ្លាវត្ត ខ្មែរក្រហម បានប្រើឧបករណ៍បំពងសំឡេងប្រកាសស្វែងរកមន្ត្រីរបស់របបសាធារណរដ្ឋខ្មែរទៅបម្រើជាតិវិញ។ នៅក្រោមដើមស្វាយកណ្តាលវត្ត មានតុមួយដែលមានកងទ័ពខ្មែរក្រហមប្រហែលជា៥នាក់អង្គុយរង់ចាំទទួលមន្ត្រីរបស់សាធារណរដ្ឋខ្មែរ។ ឧគ្ឃោសនាសព្ទបានបន្លឺសំឡេងឡើងដដែលៗថា «អ្នកទាំងឡាយណាដែលធ្លាប់ធ្វើការងារឲ្យរដ្ឋាភិបាលរបបសាធារណរដ្ឋខ្មែរ និងធ្លាប់ធ្វើទាហាន ឬអ្នកនយោបាយពីរបបចាស់ សូមដើរចេញមកក្រៅជួរដើម្បីចុះឈ្មោះចូលធ្វើការ អង្គការត្រូវការអ្នកទាំងអស់គ្នាឲ្យចូលធ្វើការតែម្តង»។ ខ្ញុំមើលទៅកងទ័ពខ្មែរក្រហមទាំងអស់នោះដោយភាពរសាប់រសល់នៅក្នុងចិត្ត។ ភ្លាមៗនោះ អ៊ំប្រុសឈ្មោះ ឧត្តម ដែលជាឪពុកគូដណ្តឹងរបស់ខ្ញុំបាននិយាយគ្នាជាមួយនឹងអ៊ំស្រីឈ្មោះ បូរមី ដែលត្រូវជាប្រពន្ធរបស់គាត់ ដើម្បីចុះឈ្មោះត្រលប់ទៅភ្នំពេញវិញ។ គាត់ទាំងពីរនាក់ គឺជាគ្រូបង្រៀន និងជាមន្ត្រីក្រសួងឃោសនាការ។ ខ្ញុំ និង បុប្ផា ដែលជាគូដណ្តឹង បានក្រឡេកមើលមុខគ្នាដោយមិនទុកចិត្ត ហើយបានឃាត់គាត់។ ឪពុកម្តាយរបស់ បុប្ផា បានបោះបង់គំនិតទៅចុះឈ្មោះបន្តធ្វើមន្ត្រីនេះចោលដោយឃើញយើងទាំងពីរនាក់មិនគាំទ្រ។ នៅខាងមុខយើង ជួរប្រជាជនត្រូវបានបែងចែកចេញជាពីរក្រុមគឺ ក្រុមអតីតទាហាន និងអតីតមន្ត្រីរាជរដ្ឋាភិបាលរបស់របបសាធារណរដ្ឋខ្មែរ។ ប្រជាជនដែលស្ម័គ្រចិត្តចូលបម្រើការវិញ បានដើរសំដៅទៅរកតុនៅក្រោមដើមស្វាយដើម្បីចុះឈ្មោះចូលបម្រើការងារតាមតួនាទីរបស់ខ្លួន។ បេះដូងរបស់ខ្ញុំលោតខុសធម្មតា ប៉ុន្តែខ្ញុំមិនហ៊ាននិយាយស្តីអ្វីទាំងអស់។ ភ្លាមៗនោះ កងទ័ពខ្មែរក្រហមម្នាក់បានមកកន្ត្រាក់ស្បោងមួយចេញពីស្មារបស់បុរសម្នាក់ ដែលកំពុងឈរនៅក្នុងជួរជាមួយយើង ហើយរលាក់របស់របរក្នុងស្បោងនោះចេញទៅលើដី។ កងទ័ពខ្មែរក្រហមបានរើសតែឯកសណ្ឋានទាហាន លន់ នល់ ឡើងក្នុងចំណោមគំនរអីវ៉ាន់ដែលខ្ចាត់ខ្ចាយនៅលើដី។ កងទ័ពខ្មែរក្រហមបានចាប់ផ្តើមនិយាយទិគៀនបុរសនោះ ហើយរុញគាត់ទៅឲ្យកងទ័ពខ្មែរក្រហមម្នាក់ទៀត ដែលឈរនៅក្បែរនោះ។ បន្ទាប់មក គាត់ត្រូវកងទ័ពខ្មែរក្រហមភ្ជង់

នឹងកាំភ្លើងឲ្យដើរចេញទៅយ៉ាងស្ងប់ស្ងាត់ដោយមិនបានប្រឆាំងតបតវិញនោះឡើយ។ កងទ័ពខ្មែរក្រហម បានដើរសំដៅទៅកាន់គ្រួសារបន្ទាប់ទៀត ដែលកំពុងឈរនៅក្នុងជួរតែមួយ។ ការធ្វើដំណើររបស់យើង ចេះតែរំកិលទៅមុខបន្តិចម្តងៗតាមបណ្តោយដងទន្លេបាសាក់ដោយមិនអាចកំណត់គោលដៅបាន។ យប់កន្លែងណា យើងត្រូវឈប់សម្រាក បង្កាត់ភ្លើងដាំបាយ ដាំទឹក និងដេកនៅកន្លែងនោះជាបណ្តោះអាសន្នសិន។ ពេលព្រឹកឡើង យើងបន្តដំណើរទៅមុខទៀត តាមការបញ្ជារបស់កងទ័ពខ្មែរក្រហម។ យូរៗទៅ មនុស្សដែលធ្វើដំណើរជាមួយយើង កាន់តែមានចំនួនតិចទៅៗ ព្រោះគ្រួសារខ្លះ ត្រូវខ្មែរក្រហមបង្ខំឲ្យទៅតាំងទីលំនៅតាមសហករណ៍នានានៅក្បែរៗនោះ។ ចំណែកឯគ្រួសារខ្លះទៀត ត្រូវខ្មែរក្រហមដឹកតាមកាណូត និងតាមឡានទៅទិសខាងជើងវិញ។ រយៈពេលប្រហែលជាពីរអាទិត្យក្រោយមក យើងបានមកដល់ស្រុកមួយជាប់ព្រំដែនវៀតណាម។

«យើងមកដល់ណាហើយឬប៉ា?» បុប្ផា បានសួរទាំងទឹកមុខក្រៀមក្រំលាយឡំនឹងភាពហត់នឿយ។

«យើងមកដល់ស្រុកកោះធំហើយកូន» អ៊ំឧត្តម តបទៅកូនស្រីទាំងកែវភ្នែកអាណិតអាសូរ។ បុប្ផាកំពុងតែចង់ដឹងផងថាតើខ្មែរក្រហមនឹងឲ្យធ្វើដំណើរទៅមុខទៀតដែរឬទេ ស្រាប់តែខ្មែរក្រហម ដែលមានវ័យក្មេងៗ បានបញ្ជាឲ្យគ្រួសាររបស់យើងឈប់នៅក្នុងវត្តមួយទៀតនៅតាមដងផ្លូវនោះ។ នៅពេលទៅដល់ស្រុកកោះធំ ខ្ញុំបានឃើញខ្មែរក្រហម នៅតែបន្តប្រកាសរកអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរឲ្យទៅជួយកសាងប្រទេសជាតិ។ អ៊ំបូរមី បានតឿនប្តីរបស់គាត់ឲ្យទៅចុះឈ្មោះនឹងគេ ដើម្បីបានត្រលប់ទៅភ្នំពេញវិញ។ ខ្ញុំនិងបុប្ផាយល់ដូចគ្នាថា យើងមិនគួរទៅចុះឈ្មោះទេ ព្រោះកាលយើងមកដល់តាខ្មៅ យើងធ្លាប់បានឃើញខ្មែរក្រហម ប្រកាសអីចឹងដែរ។ ចំណែកប្រជាជនដែលបានចុះឈ្មោះ ត្រូវកងកម្លាំងខ្មែរក្រហមដកហូតអីវ៉ាន់ជាប់ខ្លួនអស់រលីង ហើយបំបែកចេញពីគ្រួសាររួចដឹកឡានចេញទៅបាត់មិនដឹងថាទៅទីណានោះទេ។

«មិនកើតទេដឹងអំ? កងកម្លាំងខ្មែរក្រហមជម្លៀសយើងមកដល់នេះហើយ ម៉េចនឹងអាចនាំយើងត្រលប់ទៅភ្នំពេញវិញបាននោះ?» អំប្រុស សម្លឹងមើលមុខខ្ញុំ ចំណែកឯអំស្រីរអ៊ូរតិចៗថា «ខ្ញុំមិនអាចទ្រាំរស់ទៅមុខទៀតបានទេ! ឥឡូវនេះអ្វីក៏អស់ដៃរសូម្បីតែអង្ករត្រីសាច់របស់របរប្រើប្រាស់ បើយ៉ាងហ្នឹងទៀតយើងមុខតែស្លាប់មិនខាន»។ អំប្រុសបន្ថែមថា «មែនហើយ យើងគួរវិលត្រលប់ទៅភ្នំពេញវិញ ខេមរិន្ទ គិតមើលទៅ ប្រទេសណាមិនត្រូវការគ្រូបង្រៀន និងអ្នកបច្ចេកទេសដូចយើងនោះ»។ អំស្រីដំឡើងសំឡេងជាក់ខ្ញុំថា «មែនហើយ ក្រែងកងទ័ពខ្មែរក្រហម ប្រាប់យើងហើយតើថាចេញពីភ្នំពេញតែមួយរយៈទេ ហើយឥឡូវនេះប្រហែលជារដ្ឋាភិបាលរៀបចំទីក្រុងរួចស្រេចឡើងវិញហើយមើលទៅ»។ ខ្ញុំ បានព្យាយាមអស់លទ្ធភាពដើម្បីពន្យល់អំប្រុស និងអំស្រី កុំឲ្យទុកចិត្តខ្មែរក្រហម ប៉ុន្តែអំទាំងពីរលើកហេតុផលផ្សេងៗគ្នាជាច្រើន ដើម្បីជម្នះត្រលប់ទៅភ្នំពេញវិញ។ នៅទីបំផុត អំប្រុស និងអំស្រី បានសម្រេចចិត្តទៅចុះឈ្មោះទាំងពីរនាក់ប្តីប្រពន្ធ។ គាត់បានស្នើដល់កងកម្លាំងខ្មែរក្រហមឲ្យនាំយើងទៅភ្នំពេញជាមួយគាត់ដែរ ប៉ុន្តែកងកម្លាំងខ្មែរក្រហមបានបដិសេធ។ កងកម្លាំងខ្មែរក្រហមបានសន្យាថាបើប្រទេសរៀបចំរួចរាល់ពេលណា នោះនឹងមកនាំខ្ញុំ និងអូន បុប្ផា ទៅភ្នំពេញដែរ។ កងកម្លាំងខ្មែរក្រហម បានសន្យានឹងអំប្រុស អំស្រីថា អង្គការនឹងមើលថែយើងទាំងពីរឲ្យបានល្អ ហើយនឹងផ្តល់ព័ត៌មានទៅឲ្យអំប្រុស អំស្រី គ្រប់ពេលដែលចង់ដឹងពីយើង។ ក្រោយមក យើងទាំងបួននាក់ត្រូវអង្គការបំបែកចេញពីគ្នា។ អំប្រុស និងអំស្រី ត្រូវអង្គការដឹកតាមកាណូតឡើងទៅភ្នំពេញ ហើយចាប់តាំងពីពេលនោះមក យើងបានបែកគ្នាជារៀងរហូត។

បន្ទាប់ពីឈរក្នុងជួរជាច្រើនម៉ោងរួចមក កងកម្លាំងខ្មែរក្រហមបានចាប់ផ្តើមសួរសុំណូរម្តង។ កងទ័ពខ្មែរក្រហមម្នាក់ បានដើរសំដៅមករក បុប្ផា ដែលធ្វើឲ្យគាត់កិតភ័យយ៉ាងខ្លាំង។ កងទ័ពម្នាក់នោះបានចាប់ផ្តើមរើកកាយអីវ៉ាន់របស់យើង រួចបានបើកគម្របឆ្នាំងបាយ និងគម្របធុងទឹករបស់យើង។ ខ្ញុំឃើញបុប្ផា

ភ័យឡើងញ័រខ្លួន និងមិនហ៊ានសម្លឹងមើលកងទ័ពនោះទេ។ ចំណែកខ្ញុំ ក៏កិតភ័យខ្លាំងណាស់ដែរ។ បន្ទាប់ពីឆែកឆេរួច កងទ័ពខ្មែរក្រហមម្នាក់នោះ បាននិយាយមកកាន់យើងថា «មិនអីទេមិត្ត! មិត្តឯងបានបោសសម្អាតហើយ ដូច្នេះមិត្តឯងអាចទៅបាន»។ ខ្ញុំ បានសម្តែងការអរគុណដល់កងទ័ពនោះយ៉ាងទន់ភ្លន់។ បន្ទាប់ពីយើងឆ្លងកាត់ចំណុចឆែកឆេរដោយសុវត្ថិភាព យើងបានបន្តដំណើរទៅមុខទៀត។ យើងបានមកដល់មូលដ្ឋានចុងក្រោយ ដែលខ្មែរក្រហមបានបញ្ឈប់មិនឲ្យយើងធ្វើដំណើរទៅមុខទៀត។ នៅកន្លែងថ្មីនេះ ខ្មែរក្រហមបានឆែកឆេររកបរស់បរ និងចុះឈ្មោះយើងម្តងទៀត។ ខ្ញុំនិងបុប្ផា បានសម្រេចចិត្តប្តូរឈ្មោះ និងបានប្រាប់អង្គការថា យើងជាប្តីប្រពន្ធនឹងគ្នា ដើម្បីរក្សាជីវិតឲ្យគេចផុតពីការតាមប្រមាញ់។ បន្ទាប់មក យើងត្រូវកងទ័ពខ្មែរក្រហម ដឹកតាមកាណូតឆ្លងទន្លេបាសាក់ ចុះទៅកាន់សហករណ៍ពោធិ៍ទន្លេ។

អង្គការបានបញ្ជូលខ្ញុំទៅក្នុងកងចល័ត ដោយបង្ខំឲ្យធ្វើការងារយ៉ាងធ្ងន់ធ្ងរ ដូចជា រែកដី លើកទំនប់ លើកផ្លូវ ធ្វើស្រែ និងជីកប្រឡាយ។ អង្គការ បានឲ្យខ្ញុំឡើងត្នោត ដោយសារតែខ្ញុំបានប្រាប់ដល់អង្គការថា ខ្ញុំធ្លាប់បានឡើងត្នោតពេលដែលខ្ញុំរស់នៅក្នុងខេត្តតាកែវ។ ចំណែកបុប្ផាវិញ ត្រូវអង្គការបញ្ជូលទៅក្នុងកងកាប់ឆ្ការព្រៃ ដកស្ទូង ជាមួយនឹងប្រជាជនថ្មីផ្សេងទៀត។ យើងត្រូវអង្គការប្រើឲ្យធ្វើការដូចទាសករ ដោយធ្វើការតាមតែការដាក់ទិសដៅរបស់អង្គការ។ យើងត្រូវតែធ្វើការងារឲ្យដូចសត្វគោ។

យើងបានស្គាល់ស្ត្រីមេម៉ាយម្នាក់នៅក្នុងសហករណ៍ពោធិ៍ទន្លេ។ គាត់មានកូនស្រីម្នាក់ឈ្មោះនាងសុវិទ្យា ដែលមានវ័យស្របាលនិងបុប្ផាដែរ។ ប្តីរបស់អ៊ំស្រី គឺជាគ្រូបង្រៀន ប៉ុន្តែបានស្លាប់ដោយសារការទម្លាក់គ្រាប់បែកកាលពីឆ្នាំ១៩៧២។ ការឈឺចាប់ខ្លាំងពេកចំពោះការបាត់បង់ឪពុក បានធ្វើឲ្យកូនប្រុសរបស់គាត់ទាំងពីរនាក់ ស្ម័គ្រចិត្តចូលធ្វើកងទ័ពខ្មែរក្រហម ដើម្បីច្បាំងជាមួយនឹងខ្មាំង។ ក្រោយមក កូនប្រុសរបស់គាត់ទាំងពីរនាក់ក៏បាត់ដំណឹងសូន្យឈឹង។ អ៊ំស្រី គឺជាអ្នកមូលដ្ឋានចាស់ ហើយគាត់ចិត្តល្អជាមួយយើងណាស់ មិនដូចអ្នក

មូលដ្ឋានដទៃទៀតដែលរើសអើងយើងទេ។ សុវិទ្យា តែងលួចបង្ហាត់បង្រៀនការងារ បុប្ផា តាមតែអាចធ្វើទៅបាន។ យូរៗម្តង យើងទាំងបួននាក់ មានឱកាសជួបគ្នា ដើម្បីចែករំលែកទុក្ខលំបាករៀងៗខ្លួនប្រាប់គ្នាទៅវិញទៅមក។ ជារៀងរាល់ថ្ងៃ យើងធ្វើការក្រោមការឃ្លាំមើលរបស់ប្រជាជនចាស់ និងកងឈ្លបខ្មែរក្រហម។ ការងារស្រែចម្ការធ្ងន់ធ្ងរ និងការហូបចុកមិនគ្រប់គ្រាន់ គឺជាឧបសគ្គដ៏ចម្បងរបស់ បុប្ផា ព្រោះនាងមិនធ្លាប់ឆ្លងកាត់ធ្វើការងារបែបនេះសោះឡើយពីមុនមក។ បុប្ផា គឺជាយុវតី ដែលកើតនិងធំដឹងក្តីនៅក្នុងទីក្រុង។ សុខភាពរបស់ បុប្ផា កាន់ចេះតែធ្លាក់ចុះទ្រុឌទ្រោមបន្តិចម្តងៗ។ ជួនពេលខ្លះ បុប្ផា ត្រូវមេកងរបស់នាង ស្តីបន្ទោសឲ្យឬហៅទៅប្រជុំកសាង។ នៅពេលដែលខ្ញុំជួបនឹង បុប្ផា ខ្ញុំតែងជួយនិយាយលើកទឹកចិត្តដល់នាងជានិច្ច។ ទោះជាបែបនេះក្តី សម្ព័ន្ធភាពប្តីប្រពន្ធរបស់យើង ហាក់ដូចជាស្ថិតក្នុងឋានពីរដាច់ដោយឡែកពីគ្នា។ កាលណានៅចំពោះមុខខ្មែរក្រហម យើងប្រព្រឹត្តចំពោះគ្នាដូចមនុស្សរុក្ខជាតិ ដោយស្តាប់តាមការអប់រំសីលធម៌របស់អង្គការ។ យើងមិនហ៊ានបង្ហាញក្តីអាណិតអាសូរភាពផ្អែមល្ហែម និងការយកចិត្តទុកដាក់ចំពោះប្តីឬប្រពន្ធឡើយ លើកលែងតែក្នុងទីងងឹតឬទីកំបាំងមុខទើបយើងហ៊ានបង្ហាញមនោសញ្ចេតនាពិតប្រាកដរបស់ប្តីប្រពន្ធចេញមក។ យប់មួយពេលដែលយើងត្រលប់មកពីប្រជុំនយោបាយវិញ បុប្ផា បានបង្ហាញឲ្យឃើញនូវការមិនពេញចិត្តយ៉ាងខ្លាំងចំពោះរបបថ្មីនេះ។ បុប្ផា រអ៊ូតិចៗដាក់ត្រចៀកខ្ញុំ ព្រោះខ្លាចមានកងឈ្លបលបស្តាប់នៅក្រោមរោងស្នាក់នៅរបស់យើង។ «ខ្ញុំទ្រាំទៀតលែងបានទៀតហើយ! ខ្ញុំចង់តែស្លាប់ឲ្យផុតៗទេ ព្រឹកមិញពេលចេញទៅព្រៃ ខ្ញុំឃើញមនុស្សស្លាប់ទៀតហើយ ខ្ញុំឮប្រជាជនឯទៀតនិយាយថា ប្រជាជនដែលស្លាប់នោះគឺស្លាប់ដោយសារអត់បាយចំណែកឯមនុស្សនៅក្នុងភូមិបាត់ខ្លួនស្ទើរតែរៀងរាល់ថ្ងៃ»។ បុប្ផា និយាយបណ្តើរចង់យំបណ្តើរ។ ខ្ញុំក្រសោបកាយនាងជាប់នឹងដើមទ្រូងរួចនិយាយលួងលោមខ្សឹបៗប្រាប់ឲ្យ បុប្ផា តស៊ូរស់ឲ្យបានទៅថ្ងៃមុខជាមួយខ្ញុំទៀត។ យើងនិយាយដល់ចំណុចនេះ ក៏នឹកឃើញដល់ឪពុកម្តាយរបស់យើងដែលបាត់ដំណឹងសូន្យឈឹង

មិនដឹងជាគាត់ជួបនឹងអ្វីខ្លះទេ។ បុប្ផា បានយំខ្សឹកខ្សួលតិចៗគួរឲ្យសង្វែកណាស់។ នឹកដល់រឿងបែកបាក់ និងភាពលំបាកនេះ បុប្ផា បានបបួលខ្ញុំរត់ចេញពីទីនេះទៅប្រទេសវៀតណាម ព្រោះយើងកំពុងតែស្ថិតនៅក្បែរប្រទេសវៀតណាមស្រាប់។ ខ្ញុំ បានប្រាប់ បុប្ផា កុំឲ្យនិយាយឮពេកអំពីបញ្ហានេះ ហើយខ្ញុំ ក៏បានបញ្ជាក់ប្រាប់គាត់ដែរថា ខ្ញុំ ធ្លាប់បានគិតរឿងរត់គេចនេះតាំងពីយូរហើយ ប៉ុន្តែយើងត្រូវរង់ចាំពេលវេលាបន្តិចសិន។ មុនពេលចូលដេក ខ្ញុំបានខ្សឹបប្រាប់បុប្ផាថា «ព្រឹកស្អែកពេលទៅស្រែ កុំភ្លេចធៀងចូលរោងកូរស្ករត្នោត ព្រោះបងទុកទឹកត្នោតឲ្យអូន»។

ពេលវេលាចេះតែកន្លងផុតទៅ រដូវវស្សាក៏ចូលមកដល់។ យើងឥតមានឱកាសរត់ចេញពីគុកឥតជញ្ជាំងនោះឡើយ ដោយសារកងឈ្លបខ្មែរក្រហមបានតាមដានយើងកាន់តែខ្លាំងឡើងៗ។ ស្ថានភាពជីវិតយើង និងប្រជាជន ១៧មេសា ផ្សេងទៀត កាន់តែអាក្រក់ទៅៗ។ រដូវវស្សាដូច្នេះ អង្គការបានចាប់ផ្តើមឲ្យប្រជាជនសម្រុកនឹងការងារធ្វើស្រែចម្ការវិញ។ បុប្ផា ត្រូវប្តូរឲ្យមកកងស្នូងស្រូវម្តង។ ពេលនោះ ខ្ញុំមានឱកាសជាញឹកញាប់លាក់ចំណីហូបបន្តិចបន្តួចទុកឲ្យនាង។ ល្ងាចថ្ងៃមួយ ពេលដែលបុប្ផាត្រលប់មកពីការដ្ឋានវិញ ខ្ញុំសង្កេតឃើញទឹកមុខរបស់នាង ស្លេកស្លាំងប្លែកខុសធម្មតា។ ខ្ញុំក៏ប្រញាប់សួរទៅបុប្ផាថា «កើតអីហ្នឹង? ឈឺមែនទេ?» ប៉ុន្តែនាងគ្រវីក្បាលតប ដែលជាសញ្ញាប្រាប់ថានាងមិនបានឈឺទេ។ «ចុះមានបានហូបផ្លែត្នោតទុំ ដែលបងបានលាក់ទុកនោះទេ?» ឮសំណួរនេះភ្លាមបុប្ផាស្តុតចិត្ត ហើយប្រាប់ថា នាងបានហូប ប៉ុន្តែពេលដែលនាងកំពុងតែហូបផ្លែត្នោតទុំនោះស្រាប់តែឈ្លបម្នាក់ឈ្មោះ ម៉ៅ បានមកទាន់។ បុប្ផាគិតថាឈ្លប ម៉ៅ ប្រហែលជាមិនឃើញថានាងហូបផ្លែត្នោតទុំនោះទេ ព្រោះនៅពេលដែលឈ្លប ម៉ៅមកដល់ បុប្ផា បានទម្លាក់ផ្លែត្នោតនោះចោល ហើយជាន់កប់ចូលក្នុងដីក្បែរភ្លឺស្រែបាត់ទៅហើយ។ បុប្ផានិយាយបណ្តើរ យកក្រមាជូតញើសចេញពីលើផ្ទៃមុខបណ្តើរ។

ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំ ត្រូវបានមេកងដាក់ទិសដៅភ្លាមៗឲ្យទៅកាប់ស្លឹកត្នោតនៅតាមព្រំប្រទល់វៀតណាម ដើម្បីយកស្លឹកត្នោតមកដេរ។

«មិត្តបង ខ្ញុំ សុំចាំប្រពន្ធរបស់ខ្ញុំមកពីការដ្ឋានសិនបានទេ?» ខ្ញុំសួរមិនទាន់នឹងចប់សំដីផងស្រាប់តែមេកងឆ្លើយកាត់សំដីរបស់ខ្ញុំថា «មិនបានទេមិត្ត! អង្គការដាក់ទិសដៅថ្ងៃនេះហើយ មិនអាចចាំស្អែកបានទេ! រឿងប្រពន្ធមិត្តឯង ចាំខ្ញុំឲ្យមិត្តម៉ៅ ប្រាប់ឲ្យ»។ បន្ទាប់មក ខ្ញុំត្រូវឈ្លបបណ្តើរចេញពីទីនោះ ហើយនៅតាមផ្លូវ ខ្ញុំ ឃើញឈ្លប ម៉ៅ ញញឹមជាក់ខ្ញុំតិចៗ។ ឈ្លប ម៉ៅ និងកងកម្លាំងខ្មែរក្រហមផ្សេងទៀត មិនដែលញញឹមឬបង្ហាញអាកប្បកិរិយាជាក់អ្នកថ្មីបែបនេះឡើយ។

ខ្ញុំពិតជាត្រូវអង្គការបញ្ជូនឲ្យទៅកាប់ស្លឹកត្នោតមែន។ អង្គការ បានបញ្ជូនខ្ញុំពីកន្លែងមួយទៅកន្លែងមួយថ្មីទៀតរហូតទាល់តែខ្ញុំលែងបានទទួលដំណឹងអ្វីបន្តិចសោះពីប្រពន្ធរបស់ខ្ញុំ។ ពេលខ្លះ ខ្ញុំដេកយំម្នាក់ឯងដោយនឹកអាណិតប្រពន្ធជាពន់ពេក ព្រោះនាងរសាត់អណ្តែតមកនៅស្រុកដែលមិនធ្លាប់ស្គាល់ នេះតែម្នាក់ឯងដោយសង្ឃឹមតែលើប្តី ប៉ុន្តែឥឡូវប្តីបានបែកចេញទៅឆ្ងាយទៀត។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំតែងទន្ទឹងរង់ចាំឱកាសល្អ ដើម្បីវិលទៅជួបប្រពន្ធរបស់ខ្ញុំវិញ។ ខ្ញុំខំធ្វើការឥតមានហ៊ានធ្វេសប្រហែសឡើយ ដើម្បីរក្សាជីវិតឲ្យគង់សម្រាប់ប្រពន្ធរបស់ខ្ញុំ។ យូរៗម្តង ខ្ញុំឮដំណឹងពីការងើបបះបោររបស់កងទ័ពខ្មែរក្រហមនៅក្នុងតំបន់ផ្សេង និងប្រផ្នូលផ្សេងៗ ដែលអ្នកស្រុកតែងតែខ្សឹបខ្សៀវគ្នាថា របបខ្មែរក្រហមនឹងរលាយបាត់ក្នុងពេលឆាប់ៗនេះ។

ថ្ងៃមួយ ខ្ញុំបានទទួលព័ត៌មានថា របបខ្មែរក្រហមបានដួលរលំហើយ។ ខ្ញុំនិងមិត្តៗឯទៀតទម្លាក់ការងារដែលកំពុងតែធ្វើចោល ហើយរៀបចំបង្វិចខោអាវចាកចេញពីសហករណ៍ ដែលយើងកំពុងតែរស់នៅ។ ខ្ញុំពិតជាសប្បាយរីករាយណាស់ដែលបានត្រលប់ទៅកន្លែងដើមវិញ ប៉ុន្តែខ្ញុំមិនដឹងថា ខ្ញុំនៅឆ្ងាយពីសហករណ៍ប្រពន្ធរបស់ខ្ញុំធ្វើការប៉ុណ្ណានោះទេ។ នៅតាមផ្លូវ ខ្ញុំឆ្លៀតចូលទៅក្នុងរោងបាយដែលគ្មានមនុស្សរស់នៅយកបានស្ករផែន និងអង្ករដំណើបប្រហែលកន្លះតៅទុកធ្វើប្រពន្ធរបស់ខ្ញុំ។ ខ្ញុំដឹងថានាងចូលចិត្តបាយដំណើបណាស់។ នៅពេលដែលខ្ញុំបានជួបអ្នកស្រុកដែលរត់ភៀសខ្លួន ខ្ញុំឆ្លៀតសួរកន្លែងទៅសហករណ៍ប្រពន្ធរបស់ខ្ញុំជានិច្ច រហូតទាល់តែរកផ្លូវឃើញ។ ប៉ុន្មានថ្ងៃក្រោយមក

ខ្ញុំបានធ្វើដំណើរមកដល់សហករណ៍ពោធិ៍ទន្លេដូចបំណងមែន ប៉ុន្តែអ្វីៗហាក់ប្រែប្រួលអស់រកស្មានមិនត្រូវ។ ខ្នមតូចៗដែលយើងធ្លាប់រស់នៅបានរុះរើខ្ទេចអស់គ្មានសល់។ ផ្ទះបាយរួម ជង្រុកស្រូវ ត្រូវប្រជាជនគាស់រំលើងយកឈើ យកស្រូវអស់ខ្ទេចខ្ទី។ វាលស្រែដែលធ្លាប់តែមានមនុស្សចុះធ្វើការច្រើនកុះករប្រែជាស្ងាត់ជ្រងំ។ វាលស្រែខ្លះ ត្រូវភ្លើងឆេះអស់សល់តែគល់ជញ្ជាំងខ្មៅដូចធ្យូង និងផ្សែងហុយតិចៗ។ ខ្ញុំខំស៊ើបសួរកឈ្មោះ មិត្តវិន ដែលជាឈ្មោះរបស់ប្រពន្ធខ្ញុំ ប៉ុន្តែមិនមានអ្នកណាស្គាល់ឡើយ។ ខ្ញុំស្រងាកដៃស្រងាកជើង ដើរឡេះឡះដូចមនុស្សឆ្កួតស្រែករកប្រពន្ធ រួចលត់ជង្គង់ចុះស្រែកទ្រហោយំកណ្តាលវាលស្រែម្នាក់ឯង។ រំពេចនោះ ស្រាប់តែមានដៃត្រជាក់មួយមកប៉ះចំកញ្ចឹងករបស់ខ្ញុំ។ ខ្ញុំភ្ញាក់ព្រើត នឹកអរព្រួច រួចក្រោកឈរឡើង ស្រាប់តែឃើញស្ត្រីចំណាស់ម្នាក់មានរាងកាយស្គាំងស្គម សក់កន្ទ្រើងនៅពីខាងក្រោយខ្ញុំ។ គាត់គឺជាម្តាយរបស់សុវិទ្យា។ សេចក្តីត្រេកអរ និងស្នាមញញឹមរបស់ខ្ញុំបានរលត់បាត់។ ស្ត្រីចំណាស់នោះសួរមកកាន់ខ្ញុំថា«មិត្តខេន មែនទេ?»។ «បាទគឺខ្ញុំ! ខ្ញុំមករកប្រពន្ធរបស់ខ្ញុំ តើអ៊ំស្រី មានឃើញប្រពន្ធខ្ញុំទេ?» ខ្ញុំសួរទៅកាន់ស្ត្រីចំណាស់ទាំងឱនលំទោន និងដោះក្រមាចេញពីលើក្បាល។

បន្ទាប់មកស្ត្រីចំណាស់និយាយឈ្មោះប្រពន្ធរបស់ខ្ញុំទាំងទឹកភ្នែករលីងរលោង។ គាត់មិនបាននិយាយតបយ៉ាងដូចម្តេចឡើយ ហើយគាត់ស្រាប់តែយំហ៊ូតែម្តង។ ខ្ញុំបានសួរកនាងម្តងទៀតទៅកាន់អ៊ំស្រីអំពីដំណឹងរបស់ប្រពន្ធខ្ញុំ។ ក្នុងសំឡេងយំរបស់គាត់ ខ្ញុំបានស្តាប់ឮយ៉ាងច្បាស់នូវប្រយោគខ្លីមួយ ដែលខ្ញុំស្ទើរតែមិនជឿនឹងត្រចៀករបស់ខ្ញុំទាល់តែសោះថា «មិត្តវិន ស្លាប់យូរហើយ»។ នៅពេលដែលខ្ញុំឮដំណឹងនេះ ខ្ញុំស្រែកទ្រហោយំពោរពេញដោយក្តីឈឺចាប់ ហើយទន់ជង្គង់ដួលនៅមុខស្ត្រីចំណាស់នោះទៅ។ ពេលដឹងខ្លួនឡើង ខ្ញុំស្ថិតនៅក្នុងខ្នមរបស់អ៊ំស្រីទៅហើយ។ សុវិទ្យា បានថែទាំខ្ញុំយ៉ាងយកចិត្តទុកដាក់ រីឯអ៊ំស្រីបាននិយាយលួងលោមខ្ញុំយ៉ាងច្រើនដោយលើកយកទាំងផ្លូវលោក និងផ្លូវធម៌មកនិយាយឲ្យខ្ញុំស្តាប់។ ពេលដែលខ្ញុំបានធូរចិត្តបន្តិច អ៊ំស្រី បាននាំខ្ញុំទៅមើលកន្លែង ដែលប្រពន្ធខ្ញុំស្លាប់។

«មិត្តវិន ត្រូវខ្មែរក្រហម សម្លាប់នៅកន្លែងនេះ» អ៊ំស្រីបានរៀបរាប់ប្រាប់ខ្ញុំថា កងឈ្លបបានចោទថានាងលួចគ្នោតទុំរបស់អង្គការ។ ឈ្លបម៉ៅ ថាគាត់ឃើញនាងលួចហូបគ្នោតទុំផ្ទាល់នឹងភ្នែក ហើយបានយកផ្លែគ្នោតទៅកប់នឹងដីពេលដែល ឈ្លបម៉ៅ មកទាន់។ អ៊ំស្រីបានយកក្រមាជូតទឹកភ្នែកដែលហូរចុះបន្តិចទើបបន្តប្រាប់ខ្ញុំទៀតថា «នុះហើយគឺជាកូនគ្នោតរបស់ មិត្តវិន» គាត់បានលើកដៃចង្អុលទៅកូនគ្នោតកម្ពស់ត្រឹមជង្គង់ពណ៌បៃតងខ្ចី។ ខ្ញុំបានស្គាល់ច្បាស់ពីទីកន្លែងដែលខ្ញុំបានលាក់ផ្លែគ្នោតទុំទុកឲ្យប្រពន្ធរបស់ខ្ញុំ។ ខ្ញុំដើរទៅជិត ហើយចាប់កាន់ស្លឹកគ្នោតថ្នមៗ ព្រមជាមួយនឹងទឹកភ្នែករបស់ខ្ញុំបានហូរចុះមកឥតស្រាកស្រាន្តឡើយ។

ថ្ងៃមួយមានសំឡេងជើងមនុស្សដើរលាន់ឮតិចៗនៅខាងក្រោយខ្នងខ្ញុំ ហើយស្រែកហៅខ្ញុំថា «មិត្តខេន!»។ ខ្ញុំស្រឡាំងកាំងចំពោះឈ្មោះនេះ ពីព្រោះជិត៤០ឆ្នាំកន្លងមកហើយ ដែលគ្មានអ្នកណាហៅឈ្មោះខ្ញុំបែបនេះទាល់តែសោះ។ ខ្ញុំខំបែរក្រោយហើយសម្លឹងទៅម្ចាស់សំឡេងយ៉ាងយកចិត្តទុកដាក់។ បុរសវ័យចំណាស់ដែលជាម្ចាស់សំឡេងនោះ មានរាងកាយស្គាំងស្គម កែវភ្នែកដែលសម្លឹងមករកខ្ញុំគឺមានតែម្ខាងប៉ុណ្ណោះ។ លំនឹងនៃដំហរខ្លួនរបស់គាត់វិញត្រូវទប់ដោយឈើច្រត់វែងមួយនៅផ្នែកខាងឆ្វេង។ គ្រាដំបូង ខ្ញុំមានអារម្មណ៍សង្វែកពន់ពេកចំពោះបុរសចំណាស់នេះ ប៉ុន្តែលុះពិនិត្យយូរទៅ ខ្ញុំស្រាប់តែមានភ្លើងកំហឹងឆាប់ឆេះឡើងមក។ ខ្ញុំបានស្ទុះទៅដាល់បុរសនោះពេញទំហឹង ហើយស្រែកថា «ឯង! អាម៉ៅ អាឃាតករ»។ ម៉ៅ បានដួលចុះទៅលើដី រីឯឈើច្រត់វែងក៏របូតចេញពីដៃដែរ។ សំឡេងស្រែកយំក៏ឮឡើងលាយឡំនឹងពាក្យសូមទោស។ ម៉ៅ និយាយបណ្តើរស្រវាកឈើច្រត់របស់ខ្លួនបណ្តើរ។ នៅពេលដែលខ្ញុំឃើញដូច្នោះ ខ្ញុំបានស្ទុះទៅកន្ត្រាក់ទាញឈើច្រត់ចេញពីដៃរបស់ ម៉ៅ ដែលធ្វើឲ្យគាត់ដួលច្រងាប់ច្រងិលម្តងទៀត។ កំហឹងដែលបានលាក់ទុកជិត៤០ឆ្នាំនេះ បានពុះកញ្ជ្រោលឡើងនៅក្នុងទ្រូងរបស់ខ្ញុំ។ ខ្ញុំយារឈើច្រត់មួយទំហឹងបម្រុងវាយបំបាក់ករបស់ ម៉ៅ ដើម្បីរំសាយកំហឹង ហើយ ម៉ៅ បាន

និយាយឡើងថា «បើចង់សម្លាប់ខ្ញុំ សម្លាប់មកចុះ ខ្ញុំអត់ស្តាយទេ ព្រោះខ្ញុំរស់ទទួលកម្មពៀរបស់ខ្ញុំច្រើនហើយដែរ»។ នៅពេលដែលខ្ញុំឮម៉ៅនិយាយដូច្នោះ ខ្ញុំទង់ង៉ក់រួចស្ទុះទៅក្របួចកអាវរបស់ ម៉ៅ ឲ្យក្រោកឈរឡើងហើយស្រែកថា «ម៉េចឯងពូកែនិយាយម្ល៉េះអាម៉ៅ»។ ខ្ញុំស្រែករួចហើយ ខ្ញុំបានច្រាន ម៉ៅ ផ្ងារក្រោយទាំងជំហរ។ម៉ៅនៅតែស្រាវាក្រោកឈរឡើងដោយបញ្ចេញសំឡេងតិចៗ មកកាន់ខ្ញុំថា «កាលមុន ដើម្បីអង្គការថ្នាក់លើ អ្វីក៏ខ្ញុំអាចធ្វើបានដែរ ប៉ុន្តែឥឡូវនេះ ខ្ញុំដឹងខុសហើយ ខ្ញុំខុសធ្ងន់ណាស់ ហើយខ្ញុំមកនេះដើម្បីសុំការអត់ឱនពីមិត្តឯង»។ ម៉ៅ យំខ្សឹកខ្សួលតិចៗ។

ការអភ័យទោសឬអត់ គឺជាជម្រើសរបស់ខ្ញុំនៅពេលនេះ។ ខ្ញុំដើរថយក្រោយតិចៗ ដោយសម្លឹងទៅមើលដើមត្នោតដែលបានដុះលូតខ្ពស់ទៅហើយ។ តាមចិត្តដែលខឹង ខ្ញុំចង់តែស្ទុះទៅច្របាច់ក ម៉ៅ ឲ្យស្លាប់ ឬហែករាងកាយរបស់ ម៉ៅ ជាចំណែកៗ ដើម្បីឲ្យគាត់ឈឺចាប់មុននឹងស្លាប់ ដូចអ្វីដែលគាត់បានធ្វើមកលើប្រជាជនខ្មែរ ដែលគ្មានទោសពៃនៅក្នុងរបបខ្មែរក្រហម។ ប៉ុន្តែខ្ញុំគិតដែរថា ការធ្វើបែបនេះមិនខុសពីអ្វីដែលខ្មែរក្រហម បានធ្វើមកលើប្រជាជនខ្មែរនោះទេ។ ខ្ញុំចាប់ផ្តើមប្តឹងផ្លែងពិចារណា ដោយផ្អែកលើការទូន្មានរបស់ព្រះពុទ្ធ គឺពៀរម្ងាប់ដោយការមិនចងពៀរ។ គិតរួច ខ្ញុំបានដើរទៅលើកម៉ៅ ឲ្យក្រោកឈរឡើង ហើយទៅរើសឈើច្រត់ឲ្យ ម៉ៅ ទប់ខ្លួនបាន។ អតីតឈ្លបខ្មែរក្រហមនេះបានសម្លឹងមើលមុខខ្ញុំជាប់ជានិច្ចជាមួយនឹងទឹកភ្នែកដែលហូរស្រក់ធ្លាក់មក។ គាត់បានសួរមកខ្ញុំទាំងសម្តីញ័រៗថា «ព្រមអត់ទោសឲ្យខ្ញុំហើយឬ?»។ ខ្ញុំសម្លឹងមើលមុខរបស់ ម៉ៅ ហើយងក់ក្បាលតិចៗ។ ចំណែកឯ ឈ្លបម៉ៅស្រែកយំ ហើយឱបខ្ញុំជាប់។ ខ្ញុំសង្ឃឹមថាកុសលផលបុណ្យដែលបានមកពីការអភ័យទោសដល់ឃាតករដែលសម្លាប់ បុប្ផា ជាអតីតប្រពន្ធរបស់ខ្ញុំនេះ នឹងបានដល់រូបនាង។ ខ្ញុំបានប្រាប់ឲ្យ ម៉ៅ ឆាប់ចាកចេញពីមុខខ្ញុំ ព្រោះខ្ញុំខ្លាចក្រែងកំហឹងរបស់ខ្ញុំឆាបឆេះឡើងវិញ នឹងធ្វើឲ្យខ្ញុំប្តូរគំនិតសងសឹកទៅលើ ម៉ៅ វិញ។

ស្រមោលរបស់ ម៉ៅ បានរសាត់ឆ្ងាយទៅស្របនឹងសំឡេងមាន់រងាវ បានលាន់ឮចេញពីក្នុងភូមិ ដែលបញ្ជាក់ថាថ្ងៃថ្មីបានមកដល់ហើយ។ ខ្ញុំបានដកដង្ហើមធំ ដើម្បីបញ្ចប់សុបិនទាំងភ្នែកស្រស់នារាត្រីកាលរបស់ខ្ញុំ។ សំឡេងស្រួយស្រេះរបស់នារីម្នាក់បានលាន់ឮពីខាងក្រោយខ្នងហៅខ្ញុំថា «បង»។ ខ្ញុំក្រឡេកទៅឃើញ សុវិទ្យា ដើរមករកខ្ញុំ។ នាងនិយាយទាំងកាន់ដៃរបស់ខ្ញុំថា «តោះត្រលប់ទៅផ្ទះវិញ»។ «បាទ! ឲ្យបងសូមទោសផង ដែលទុកអូននៅម្នាក់ឯង» និយាយបណ្តើរ ខ្ញុំយកដៃកៀសសក់ ដែលគ្របលើផ្ទៃមុខរបស់ប្រពន្ធខ្ញុំបណ្តើរ។ នាងនិយាយទាំងញញឹមស្រស់ជាក់ខ្ញុំវិញថា «នៅម្នាក់ឯងឯណាបង អូននៅជាមួយកូន និងម៉ែដែរទេតើ»។

សុវិទ្យា គឺជាប្រពន្ធក្រោយរបស់ខ្ញុំ។ យើងបានរៀបការក្រោយពេលដែលខ្ញុំត្រលប់មកពីស្រុកកោះធំទៅរស់នៅក្នុងទីក្រុងភ្នំពេញវិញ។ ថ្វីត្បិតតែនាងមានអាយុតិចជាង បុប្ផា ប៉ុន្តែនាងចេះគិតគូរបានវែងឆ្ងាយ ហើយនាងយល់ចិត្តខ្ញុំបានល្អទៀតផង។ ខ្ញុំសម្លឹងមើលមុខនាងបន្តិច ទើបនិយាយបន្តទៀតថា «អូន បងបានអភ័យទោសឲ្យឃាតករដែលសម្លាប់ បុប្ផា ហើយ»។ សុវិទ្យាចាប់ដៃខ្ញុំយ៉ាងណែន រួចទើបនិយាយថា «អូនស្មានទុកជាមុនហើយថាបងនឹងលើកលែងទោសដល់អតីតឈ្លបខ្មែរក្រហមម្នាក់នេះ»។ ខ្ញុំមើលមុខនាងហាក់ដូចជាឆ្ងល់ហើយសួរថា «តើអូនដឹងយ៉ាងម៉េច? កន្លងផុតជិត ៤០ឆ្នាំហើយ បងស្មានតែម៉ៅស្លាប់បាត់ទៅហើយទេតើ»។ «ពូម៉ៅមករកម៉ែនៅក្បាលព្រលប់នេះ ហើយម៉ែបានប្រាប់គាត់ឲ្យមករកបង» សុវិទ្យានិយាយពីដំណើររឿងនេះប្រាប់មកដល់ខ្ញុំ«ម៉ែប្រាប់អូនថា តាំងពីបែកអាពតទៅ ពូម៉ៅ រត់ចោលស្រុករហូតគាត់ទៅរស់នៅក្នុងជំរំ ហើយត្រលប់ពីជំរំមកវិញមិនហ៊ានចូលក្នុងស្រុកទេ ព្រោះគាត់ខ្លាចអ្នកភូមិនៅចងកំហឹងនឹងគាត់ គាត់ទៅរស់នៅលាក់ខ្លួនក្នុងខេត្តប៉ៃលិនរហូតមក ហើយទើបតែមួយរយៈពេលចុងក្រោយនេះទេ ដែលគាត់ហ៊ានចេញចូលស្រុកកំណើតវិញ គាត់ចង់ជួបបង និងអ្នករាល់គ្នា ដើម្បីសូមអភ័យទោស ចំពោះរឿងនេះ អូនគាំទ្រដល់ការសម្រេចចិត្តរបស់បង អូន

ជឿថា បងបុប្ផា ក៏គាំទ្របងដែរ»។ ខ្ញុំទាញ សុវិទ្យា មកឱបជាប់នឹងដើមទ្រូង។ សុវិទ្យា បានលើកទឹកចិត្តដល់ខ្ញុំថា មានតែការអភ័យទេ ដែលធ្វើឲ្យកំហឹងយើងបានស្ងប់។ ម្យ៉ាងវិញទៀត ឥឡូវនេះ យើងរស់នៅក្រោមមេឃតែមួយហើយ។ យើងលែងមានប្រជាជនថ្មី ប្រជាជនចាស់ ប្រជាជនបដិវត្តន៍ អ្នកចក្រពត្តិ ឬអ្នកសក្តិភូមិអ្វីទៀតហើយ។ សុវិទ្យា ស្ងាត់បន្តិចរួចនិយាយថា «បង យើងគិតត្រលប់ទៅភ្នំពេញវិញ? ចាំឆ្នាំក្រោយចាំមកទៀតណា»។

ខ្ញុំសម្លឹងមើលដើមគ្នោតជាគ្រាចុងក្រោយ រួចទើបដឹកដៃ សុវិទ្យា ចាកចេញទៅ។ ខ្ញុំសប្បាយចិត្តដែលបានធ្វើអំពើល្អបែបនេះ។ ទោះបីជាខ្ញុំមិនអាចបំភ្លេចអតីតកាលដ៏សែនជូរចត់នេះបានមែន ប៉ុន្តែខ្ញុំមិនអនុញ្ញាតឲ្យអតីតកាលមកបំផ្លាញអនាគតរបស់ខ្ញុំបានឡើយ។

ចប់

៥

រឿងព្រះអាទិត្យ ឥតពន្លឺ

អ្នកនិពន្ធ ៖ គង់ ច័ន្ទវ៉ាន់ណេត

៥ ~ រឿង ព្រះអាទិត្យឥតពន្លឺ



យប់ស្ងាត់ណាស់ ប៉ុន្តែអ្វីដែលមិនស្ងាត់គឺក្រពះរបស់មនុស្ស។ ខ្ញុំមិនខុសប្លែកអ្វីពីប្រជាជនផ្សេងទៀតដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់បណ្តាខេត្តនានានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ខ្មែរក្រហមបានបង្គាប់ឲ្យខ្ញុំធ្វើការតាំងតែពីព្រះអាទិត្យមិនទាន់រះ រហូតដល់ព្រះអាទិត្យលិចបាត់ទៅវិញ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំជីកប្រឡាយនៅពេលថ្ងៃ រីឯពេលយប់វិញ ខ្ញុំធ្វើជាចោរលួចអាហារ ព្រោះតែសេចក្តីស្រេកឃ្លាន។ ខ្ញុំ តែងតែចាកចេញពីផ្ទះនៅពេលយប់ ប៉ុន្តែម៉ែរបស់ខ្ញុំ ចេះតែហាមឃាត់រាល់ពេលដែលខ្ញុំចាកចេញទៅ។ ខ្ញុំសៀតកាំបិតនៅនឹងចង្កេះ ហើយប្រាប់ម៉ែថា បើនៅផ្ទះក៏ជាច់បាយស្លាប់ ហើយបើចេញទៅរកអាហារក្រែងមានឱកាសបានរស់។ ម៉ែរបស់ខ្ញុំ តែងតែដកដង្ហើមធំជាសញ្ញាបង្ហាញពីក្តីបារម្ភណ៍រាល់ពេលដែលខ្ញុំចាកចេញទៅលួចស្រូវ ឬដំឡូងនៅពេលយប់។ ខ្ញុំដើរចេញពីផ្ទះលបៗ និងមានភាពជឿជាក់ជាមួយកាំបិតសៀតនៅចង្កេះ។

ផ្ទះរបស់ខ្ញុំគឺស្ថិតនៅក្នុងភូមិត្រពាំងផ្លុង ខេត្តតាកែវ។ ខ្ញុំចាំបានថា ពេលនោះគឺខែស្រូវទុំ និងធ្លាក់ខ្យល់។ ខ្ញុំបានលួចកាត់ស្រូវយកមកផ្ទះ ហើយប្រសិនបើមាននរណាម្នាក់ឃើញ ខ្ញុំនឹងសម្លាប់។ នៅក្នុងរបបខ្មែរក្រហម ការលួចគឺស្មើនឹងការលះបង់ជីវិតរបស់ខ្លួនឯង ហើយប្រសិនបើមិនសម្លាប់អ្នកដែលឃើញខ្ញុំលួចគឺខ្ញុំអ្នកស្លាប់។ ខ្ញុំបានយកជីវិតរបស់ខ្ញុំទៅប្តូរជាមួយនឹងកួរស្រូវ។

នៅពេលខ្យល់ធ្លាក់ខ្លាំង គឺកាន់តែងាយស្រួលដល់ខ្ញុំ ដើម្បីលួចកាត់កួរស្រូវ។ ខ្ញុំ បានពួននៅក្នុងគុម្ពស្រូវ ដែលដុះខ្ពស់ៗ ដោយស្ងៀមស្ងាត់ ហើយរង់ចាំទាល់

តែខ្យល់បក់ដើមស្រូវរវិចៗ ទើបខ្ញុំលួចកាច់ស្រូវបានដោយគ្មានអ្នកចាប់អារម្មណ៍ ថាមានមនុស្សលួចទាញក្តារស្រូវ។ រាល់ពេលដែលខ្ញុំលួចស្រូវម្តងៗ ខ្ញុំហួសចិត្ត នឹងខ្លួនឯង។ ខ្ញុំធ្លាប់តែជាសិស្សឆ្លាតនិងពូកែ ប៉ុន្តែខ្ញុំបានប្រើភាពឆ្លាតវៃរបស់ខ្ញុំ ត្រឹមតែលួចកាត់ក្តារស្រូវនៅក្នុងរបបខ្មែរក្រហម។

ពេលកាត់ស្រូវរួច ខ្ញុំតែងតែជាក់ស្រូវនៅក្នុងថ្នក់អាវ ហើយត្រលប់មកផ្ទះវិញ យ៉ាងសុវត្ថិភាព។ ខ្ញុំបានឲ្យម៉ែយកស្រូវទៅទុក ហើយពុកជាអ្នកមើលផ្លូវ ក្រែងមានអ្នកឃើញនិងមានគ្រាប់ស្រូវជ្រុះនៅខាងមុខផ្ទះ។ ពុករបស់ខ្ញុំ តែងតែបង្កើតទម្លាប់ពីរយ៉ាងមិនឲ្យមានអ្នកណាចាប់អារម្មណ៍ឡើយ។ ទីមួយ គឺគាត់មិនសូវសម្រាន្តពេលយប់នោះទេ ដោយតែងតែធ្វើនេះធ្វើនោះ ឬដើរនៅជុំវិញផ្ទះ។ ប្រសិនបើមានកងឈ្លបខ្មែរក្រហមមក ពុកប្រាប់ថាគាត់ចាស់ហើយសម្រាន្តមិនសូវលក់។ ទីពីរ ពុកតែងតែបង្កាត់ភ្លើងក្រោមផ្ទះជានិច្ច មិនឲ្យរលត់ឡើយ មិនថាយប់ ឬថ្ងៃ។ ដូច្នេះបើគ្រួសាររបស់ខ្ញុំចង់លួចអាំង ឬដុតអ្វីដោយប្រើភ្លើង ក៏គ្មានអ្នកណាសង្ស័យដែរ។

ខ្មែរក្រហម បានចាត់ទុក ពុក និងម៉ែរបស់ខ្ញុំ នៅក្នុងក្រុមមនុស្សចាស់។ ពុក ត្រូវខ្មែរក្រហមបង្គាប់ឲ្យបិតឫស្សី ចំណែកឯ ម៉ែ ធ្វើជាអ្នកត្បាញល្អី និងកញ្ជើ។ ពុក សុំអង្គការធ្វើការនៅផ្ទះ។ គាត់យកលេសថាការងារទាំងអស់នេះ គឺជាការងារផ្ទង់ស្មារតីមិនអាចធ្វើរួមជាមួយសហការណ៍បានទេ បើមិនដូច្នេះទេ បង្គុំឫស្សីទាំងអស់នឹងរៀបខុសនៅពេលត្បាញល្អី។

ខ្ញុំធូរចិត្តច្រើនណាស់ដែលពុកនិងម៉ែអង្គុយធ្វើការងារស្រាលៗនៅផ្ទះ ដោយមិនចាំបាច់ចេញទៅធ្វើការងារធ្ងន់នៅតាមវាលស្រែ។ ត្បិតថានេះជាសំណាងមួយ ប៉ុន្តែយើងនៅតែជួបប្រទះនឹងការលំបាកព្រោះយើងទទួលបានតែបបរដែលមានគ្រាប់អង្ករមិនលើសពី២០គ្រាប់នោះទេនៅក្នុងចានរបស់យើង រាល់ពេលហូបអាហារ។

ខ្ញុំតែងតែទៅជីកប្រឡាយនៅភូមិដូចរាល់ដង។ ថ្ងៃមួយ ពេលដែលខ្ញុំកំពុងតែជីកប្រឡាយ ប្រធានកងចល័តម្នាក់បានរត់មកប្រាប់ខ្ញុំ «មិត្តសឿន! មិត្តសឿន

ឯងត្រូវផ្លាស់ទៅភូមិបាំងណាវិញ ព្រោះអង្គការត្រូវការយុវជនពេញកម្លាំងដូចមិត្តទៅជីកប្រឡាយទឹកមួយទៀត ដែលជាគម្រោងបន្ទាប់»។ ឮតែប៉ុណ្ណោះ ខ្ញុំចាប់ផ្តើមនឹកព្រួយក្នុងចិត្ត ព្រោះត្រូវទៅរស់នៅឆ្ងាយពីពុកម៉ែរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំក៏តបទៅកាន់ប្រធានកងចល័តវិញដោយការគោរព។

លុះល្ងាចឡើង ខ្ញុំរៀបចំអីវ៉ាន់ ដើម្បីត្រៀមទៅរស់នៅភូមិបាំងណា ដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ។ ត្បិតថាភូមិបាំងណា និងភូមិត្រពាំងផ្លុង នៅខេត្តផ្សេងគ្នា ប៉ុន្តែភូមិទាំងពីរនេះគឺស្ថិតនៅមួយចំហៀងម្ខាក់នៃផ្លូវជាតិលេខ៣តែប៉ុណ្ណោះ។ ភូមិត្រពាំងផ្លុង នៅខាងកើតផ្លូវជាតិលេខ៣ ឯភូមិបាំងណានៅខាងលិចផ្លូវជាតិលេខ៣ ហៅថាតំបន់៣៨។ បន្ទាប់ពីខ្ញុំរៀបអីវ៉ាន់រួច ខ្ញុំបានលាម៉ែពុកចាកចេញទៅ។ ម៉ែគ្មានអ្វីផ្តែផ្តាំខ្ញុំក្រៅពីប្រាប់ខ្ញុំថា កុំឲ្យចេញទៅលួចស្រូវ និងដំឡូងទៀត។ ម៉ែនិយាយទាំងទឹកមុខស្រពោន។ ខ្ញុំមិនចង់ឲ្យម៉ែលំបាកចិត្តនោះទេ ដោយបានតបទៅគាត់វិញថា កុំឲ្យគាត់បារម្ភណ៍នឹងខ្ញុំ ព្រោះខ្ញុំអាចរកវិធីយករួចខ្លួនបានដោយខ្លួនឯង។ បន្ទាប់ពីប្រាប់ពុកម៉ែឲ្យថែរក្សាខ្លួន ខ្ញុំក៏បានលាពុកម៉ែទាំងស្រងេះស្រងោច ហើយចាកចេញជាមួយយុវជនផ្សេងទៀត។ ក្នុងចំណោមយុវជនទាំងអស់ ខ្ញុំស្គាល់ អាធី ដែលជាមិត្តភក្តិរបស់ខ្ញុំ។ នៅពេលដែលខ្ញុំទៅដល់ភូមិបាំងណា ខ្ញុំនិង អាធី បានសម្រាកនៅផ្ទះតូចមួយជាមួយគ្នា។ យើងសម្រាកមិនទាន់បានប៉ុន្មានផង ត្រូវប្រធានក្រុមជាស់ឲ្យទៅជីកប្រឡាយ។ នៅភូមិថ្មី ខ្ញុំ និង អាធី ដេកឃ្លានស្ទើរតែរាល់យប់។ រហូតដល់ថ្ងៃមួយ អាធី បានខ្សឹបប្រាប់ខ្ញុំថា នៅយប់ស្អែកនេះ នឹងទៅភូមិត្រពាំងផ្លុង ទៅជួបម៉ែក្រែងមានអ្វីហូបខ្លះ។ នៅពេលដែលខ្ញុំឮ អាធី និយាយដូច្នេះ ខ្ញុំដេកគងថ្ងាសគិតមួយសន្ទុះ ហើយក៏ប្រាប់ទៅ អាធីវិញថា ខ្ញុំនឹងទៅជាមួយវាដែរ។ លុះស្អែកឡើងពេលព្រះអាទិត្យលិចផុតទៅ យើងក៏បញ្ចប់ការងារជីកប្រឡាយដែរ។ ខ្ញុំបានទៅលាងដៃ លាងជើងនៅឯមាត់ត្រពាំង។ ខ្ញុំស្រាប់តែឮសម្រឹបជើងមនុស្សដើរមកពីខាងក្រោយ ហើយនិយាយថា «តោះ!អាសឿន»។

យុវជនគ្រប់គ្នាចប់ការងារនាំគ្នាត្រលប់ទៅផ្ទះនៅភូមិបាំងណាវិញ ចំណែកឯខ្ញុំ និង អាធី ត្រលប់ទៅផ្ទះជួបពុកម៉ែនៅភូមិត្រពាំងផ្លុង ។ ខ្ញុំ និង អាធី ធ្វើដំណើរកាត់តាមព្រៃតូចៗដែលដុះអមសងខាងផ្លូវ ដើរច្មើរជើង និងមិនហ៊ានជជែកគ្នាទេ ។ យើងដើរបានបន្តិច ស្រាប់តែឮសំឡេងមាត់មនុស្សជជែកគ្នា ។ យើងបានក្រាបក្នុងគុម្ពព្រៃ រង់ចាំឲ្យពួកឈ្លបដើរទៅផុតឆ្ងាយសិនទើបបន្តដំណើរទៅទៀត ។ យើងបន្តដំណើរបែបនេះរហូតដល់ភូមិត្រពាំងផ្លុង រួចបំបែកផ្លូវគ្នាទៅផ្ទះរៀងៗខ្លួន ។

ពេលទៅដល់ផ្ទះភ្លាម ម៉ែ ភ្ញាក់ផ្អើលខ្លាំងណាស់ ប៉ុន្តែគាត់បានប្រញាប់ប្រញាល់ហៅឲ្យខ្ញុំចូលក្នុងផ្ទះសួរនាំ ។ ខ្ញុំបានប្រាប់ម៉ែតាមដំណើររឿង រួចហើយពុក ក៏បានលបលួចដុតដំឡូងឲ្យខ្ញុំ ។ ម៉ែ បកផងផ្តុំដំឡូងផងឲ្យត្រជាក់ រួចនិយាយថា «ចេះសំណាងហើយថ្ងៃនេះ ដែលពុកឯងទៅជួបបងធំកូនបានដំឡូង និងល្ពៅមកខ្លះ» ។ គាត់បានហុចដំឡូងមកឲ្យខ្ញុំ ហើយប្រាប់ថា ឲ្យខ្ញុំហូបឲ្យប្រញាប់ទៅ ។

ខ្ញុំទទួលយកដំឡូងពីដៃម៉ែយកមកហូប ។ បងប្រុសធំរបស់ខ្ញុំរស់នៅក្នុងភូមិកុមារាជា ស្ថិតនៅឆ្ងាយពីផ្ទះ ដែលម៉ែស្នាក់នៅដែរ ។ បងប្រុសធំរបស់ខ្ញុំ រស់នៅផ្ទះដែលជាកន្លែងទុកស្បៀងដូចជាស្រូវ ល្ពៅ និងដំឡូង ហើយបងថ្លៃស្រីរបស់ខ្ញុំគឺជាកសិករធ្វើមប្រចាំភូមិ ។ ដូច្នេះ អង្គការទុកចិត្តឲ្យបងប្រុស និងបងស្រីរបស់ខ្ញុំមើលការខុសត្រូវស្បៀងទាំងអស់នោះ ។

ខ្ញុំអង្គុយហូបដំឡូងឆ្អែត ខ្ញុំលាពុកម៉ែរបស់ខ្ញុំត្រលប់ទៅសហករណ៍វិញ ។ ខ្ញុំ និង អាធី បន្តដើរលបៗតាមព្រៃដូចដើមរហូតដល់ភូមិបាំងណា ។ ទម្រាំទៅដល់ទីនោះម៉ោង៥ទៀបភ្លឺទៅហើយ ។ យើងទាំងពីរនាក់មិនបានទៅសម្រាកនោះទេ ។ យើងចាប់កាន់ចបដើម្បីបន្តធ្វើការទៀត ។ ប្រធានសហករណ៍ បានមកដល់ ហើយសរសើរ ខ្ញុំនិង អាធី ថាជាសមមិត្តឧស្សាហ៍ និងមកធ្វើការដល់កន្លែងមុនយុវជនផ្សេងទៀតជានិច្ច ។ នៅថ្ងៃនោះ យើងបានជីកប្រឡាយដូចយុវជនផ្សេងទៀតដោយមិនបានសម្រាកនោះទេ ។

ស្ទើរតែរាល់ថ្ងៃ ដែល ខ្ញុំ និងអាធី លួចចេញទៅភូមិត្រពាំងផ្លុង ដើម្បីរកអាហារចម្អែតក្រពះ ។ យប់មួយម៉ែ បានប្រាប់ខ្ញុំដោយសេចក្តីត្រេកអរថា «ស្អែកបងកូនថានឹងលួចចែកស្រូវមកខ្លះ ដូច្នេះ ព្រលប់ស្អែក ម៉ែនឹងបុកស្រូវ ហើយដាំបាយឲ្យកូន

កូនកុំភ្លេចមកថ្ងៃស្អែកទៀតណាឮទេ» ។ ខ្ញុំសប្បាយចិត្តណាស់ពេលឮថាស្អែកបានបាយហូបដូច្នោះ ។ ខ្ញុំប្រញាប់សួរខ្សឹបៗទៅកាន់ម៉ែថា «តើយើងនឹងបានអង្ករប៉ុន្មានដៃរម៉ែ ? ហូបគ្រាន់ដៃឬទេ ?» ។ ម៉ែប្រាប់ខ្ញុំថាអង្ករគឺមិនច្រើនទេ ប៉ុន្តែគាត់ចង់ឲ្យខ្ញុំមកហូប ព្រោះខ្ញុំធ្វើការងារធ្ងន់ ។

លុះស្អែកឡើងមេឃងងឹត ខ្ញុំបបួល អាធី ទៅផ្ទះម៉ែដូចសព្វមួយដងទៀត ។ ខ្ញុំដើរទាំងសប្បាយចិត្ត ព្រោះនឹកថាយប់នេះ ខ្ញុំបានបាយហូបហើយ ។ ពេលដែលខ្ញុំមកដល់ផ្ទះ អ្វីដែលខ្ញុំឃើញគឺខុសពីសព្វមួយដង ។ ម៉ែបានចេញមកទទួលខ្ញុំទាំងទឹកភ្នែក ។ ខ្ញុំភ័យណាស់ ក៏ប្រញាប់សួរទៅម៉ែថាមានរឿងអ្វី ? ម៉ែប្រញាប់ទាញដៃខ្ញុំឡើងទៅខាងលើផ្ទះ ហើយលើកបាយមួយកូនត្រឡោក និងកូនត្រីប្រឡាក់អំបិលដុតឈ្ងុយមួយក្តាប់មក ព្រមទាំងនិយាយប្រាប់ខ្ញុំថា «បងផនរបស់ឯង ត្រូវបានអង្គការយកទៅសម្លាប់ទាំងគ្រួសារបាត់ហើយ» ។ ខ្ញុំពិតជារន្ធត់ណាស់ពេលដែលបានឮដំណឹងនេះ ។ បងផន គឺជាបងទីពីររបស់ខ្ញុំ ។ ខ្ញុំមានបងប្អូនតែ៣នាក់ទេ ហើយខ្ញុំគឺជាកូនពៅ ។ បងប្រុសធំ គឺជាប្រធានសហករណ៍ភូមិ ព្រោះគាត់ជាប្រជាជនមូលដ្ឋាននៅក្នុងភូមិ ។ ជីវិតរបស់គាត់រស់នៅមានភាពងាយស្រួលជាងប្រជាជនដទៃទៀត ។ បងផន គឺជាបងប្រុសទីពីររបស់ខ្ញុំ ។ គាត់គឺជាអតីតប៉ូលីសខេត្តកំពង់ស្ពឺនៅក្នុងសម័យសាធារណរដ្ឋខ្មែរ ។ នៅពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រងនៅទីក្រុងភ្នំពេញ ពុករបស់ខ្ញុំ បានយកឯកសារកាតសិស្ស បញ្ជីជាតិ និងរូបថតទាំងឡាយដែលយើងមាន ទៅកប់ចោលនៅក្នុងដីទាំងអស់ ។ ថ្វីត្បិតតែភស្តុតាងបានបំផ្លាញអស់ហើយក៏ពិតមែន ប៉ុន្តែប្រជាជននៅក្នុងខេត្តកំពង់ស្ពឺ នៅតែស្គាល់ថា បងផន គឺជាអតីតប៉ូលីស ។

ម៉ែរបស់ខ្ញុំ ប្រាប់ទាំងញ័រមាត់ថា អង្គការមានយុទ្ធនាការបោសសម្អាតប្រជាជន១៧ មេសា ហើយកងឈ្លបនាំគ្នាទៅឆែកឆេរផ្ទះ បងផន ។ កងឈ្លបបានរកឃើញរូបថតរបស់ បងផន ស្លៀកពាក់ជាប៉ូលីស នៅនឹងបាតកេស ។ រូបថតមានមិនច្រើនទេ ហេតុអ្វីបានជាយើងប្រមូលបំផ្លាញមិនអស់ ។ សម្រាប់ពួកខ្មែរក្រហមរូបថតសេសសល់តែមួយសន្លឹកនេះ គឺគ្រប់គ្រាន់ក្នុងការផ្តាច់ជីវិតបងប្រុសរបស់ខ្ញុំ និងក្រុមគ្រួសាររបស់គាត់ ។

ខ្ញុំហូបបាយទាំងអួលដើមក ព្រោះអាណិតបងប្រុស និងក្រុមគ្រួសាររបស់គាត់ណាស់។ យើងអង្គុយយ៉ាងស្ងៀមស្ងាត់ លួចស្រក់ទឹកភ្នែករៀងៗខ្លួនមិនហ៊ានយំសោកឲ្យឮសំឡេងនោះទេ។ ម៉ែឃើញខ្ញុំយំសោកសៅដូច្នេះក៏និយាយគឿនខ្ញុំឲ្យហូបបាយលឿនៗ ហើយប្រាប់ខ្ញុំកុំឲ្យត្រលប់មកផ្ទះមួយរយៈពេលសិន។ ម៉ែបារម្មណ៍ដល់ខ្ញុំណាស់ ព្រោះបងប្រុសច្បងរបស់ខ្ញុំទើបតែបានទទួលដំណឹងថា អង្គការចង់ចោទប្រកាន់ខ្ញុំ ប៉ុន្តែដោយសារតែខ្ញុំរស់នៅក្នុងតំបន់ផ្សេងទើបអង្គការគ្មានសិទ្ធិចាប់ខ្លួនខ្ញុំ។ ខ្ញុំមិនដឹងថាមូលហេតុអ្វីបានជាអង្គការចង់ចាប់ខ្ញុំនោះទេ ប៉ុន្តែម៉ែបានឮមកថា មានអ្នកស្អប់ខ្ញុំ រួចយកព័ត៌មានទៅប្រាប់ក្រុមកងឈ្លបដើម្បីចោទប្រកាន់ខ្ញុំ។ ខ្ញុំនឹកហួសចិត្តថា អ្នកដែលសម្លាប់ប្រជាជនគឺ មិនមែនមានតែថ្នាក់លើ ឬ ប៉ុល ពត នោះទេ។ សូម្បីតែប្រជាជនដូចគ្នា ក៏ចង់សម្លាប់ប្រជាជនផ្សេងទៀតដែរ។ ពេលហូបបាយរួចខ្ញុំក៏លាម៉ែ ហើយត្រលប់ទៅផ្ទះនៅឯភូមិបាំងណាវិញទាំងល្វើយនៅក្នុងចិត្ត។ បាយមួយត្រឡោកដែលខ្ញុំបានហូប មិនបានធ្វើឲ្យខ្ញុំមានកម្លាំងដូចដែលខ្ញុំបានរំពឹងទុកទាល់តែសោះ។

ខ្ញុំ និង អាធី ទៅដល់កន្លែងជីកប្រឡាយវិញទាន់ពេលវេលាដូចប្រក្រតី។ ពន្លឺស្រទន់ពណ៌មាស បានជះមកប៉ះផ្ទៃមាតុភូមិខ្ញុំ ដែលជិតជាមដោយឈាម និងសេចក្តីនិរាសព្រាត់ប្រាស់។ ព្រះអាទិត្យត្រលប់មកជាថ្មីម្តងទៀតមែន ប៉ុន្តែអ្វីដែលមិនត្រលប់មកវិញ គឺវត្តមានបងប្រុសរបស់ខ្ញុំ ប្រពន្ធកូនរបស់គាត់ និងប្រជាជនខ្មែរជាងពីរលាននាក់។ មិនថាយប់ មិនថាថ្ងៃ នៅក្នុងរបបខ្មែរក្រហមគឺមានសភាពខ្មៅងងឹតគ្មានពន្លឺ។ ខ្ញុំ និងអាធី ចាប់កាន់ចបជីកប្រឡាយដូចសព្វមួយដង និងគ្មានអ្នកណាដឹងឡើយថាយប់មិញយើងលួចចេញទៅភូមិមួយទៀតនោះទេ ហើយចាប់តាំងពីថ្ងៃនោះមក ខ្ញុំក៏លែងត្រលប់ទៅផ្ទះម៉ែរបស់ខ្ញុំទៀតដែរ។

ចប់

៦

រឿងមួយថ្ងៃ មួយយប់

អ្នកនិពន្ធ ៖ ម៉ៅ សុវណ្ណឌី

៦ ~ រឿង មួយយប់ មួយយប់

ស្នូរសំឡេងកញ្ជ្រែ បានលាន់ឮឡើងយ៉ាងញាប់រន្ទាន់ចេញពីមាត់ សមមិត្តមឿន។ សមមិត្តមឿន គឺជាប្រធានកងកុមារ ដែលពួកយើងហៅថា «សមមិត្ត»។ គ្រាន់តែស្នូរសំឡេងកញ្ជ្រែចេញពីមាត់ សមមិត្តមឿន មិនទាន់ផុតផង ពួកយើងរត់មកតម្រង់ជួរដោយនាំគ្នាមកអង្គុយរង់ចាំស្តាប់ប្រធានកងណែនាំ ស្តីបន្ទោសឲ្យអំពីការធ្វើការងារជូនអង្គការ។ សមមិត្តមឿន មានសក់ក្រញាញ់ សម្បុរខ្មៅគ្រាក់ ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ បង់កក្រមា ពាក់មួកយោធា និងស្បែកជើងកង់ឡាន បានដើរក្រពាត់ដៃចុះឡើងខាងមុខជួររបស់ពួកយើង ដែលមានគ្នាប្រមាណ ៣០នាក់។ បន្ទាប់ពីផ្តើមពាក្យ «ខ្ញុំគឺថាសូមគោរព» រួចប្រធានមឿន ស្រែកខ្លាំងៗថា «ថ្ងៃនេះ យើងនឹងវែកមុខរកខ្មាំងក្នុងកងឲ្យឃើញ ប៉ុន្តែបើសារភាពយើងនឹងលើកលែងទោសឲ្យ»។

ឮពាក្យនេះ ខ្ញុំនិងកុមារទាំងអស់មើលមុខគ្នាទាំងងឿងឆ្ងល់។ ពួកយើងនៅតូចៗ មានអាយុប្រហែលពី ៧ទៅ ៨ឆ្នាំ មិនទាន់យល់អ្វីជាខ្មាំងច្បាស់នៅឡើយទេ។ ជារៀងរាល់ព្រឹកមុនពេលចេញទៅធ្វើការ មេកងឲ្យពួកយើងអានអក្សរថា «ខ្មាំងចក្រពត្តិកម្ទេចបុគ្គលនិយម»។ ប្រយោគនេះពួកយើងចាំយ៉ាងស្ទាត់មាត់ ប៉ុន្តែមិនដឹងមានន័យយ៉ាងដូចម្តេចទេ ហើយនៅពេលឮពាក្យថា «ខ្មាំងក្នុងកង» ពួកយើងរឹតតែមិនយល់ថែមទៀត។ រំពេចនោះស្រាប់តែ សមមិត្តមឿន ស្រែកទៀតថា «ស្ងាត់! យើងរាប់ដល់បី បើមិនសារភាពគឺត្រូវកម្ទេច!»។ ទោះជារាប់ដល់បីក៏គ្មានអ្នកណាសារភាពដែរ ព្រោះម្នាក់ៗយល់ថាខ្លួនមិនមែន

ជាខ្មាំងនោះទេ។ មួយស្របក់ក្រោយមកមិនមានអ្នកណាសារភាព សមមិត្ត
មឿន ខឹងមុខឡើងក្រហម ភ្នែកក្រឡោត ដើរសំដៅមកកុមារម្នាក់ដែលអង្គុយ
ខាងមុខបន្ទាប់ខ្ញុំ។ កុមារនោះ ខំប្រឹងឆ្លើយប្រកែកទាំងតក់ស្លុតថា «អត់ទេ!
ខ្ញុំមិនមែនជាខ្មាំងទេ!»។ «នៅប្រកែកទៀត!» ស្រែកចប់ពាក្យភ្លាម សមមិត្ត
មឿន បានរុញកុមារនោះឲ្យដួលអុកគូទរួចចាប់ទាញរបស់ដែលលាក់នៅក្នុង
ចង្កេះខោរបស់កុមារនោះយកមកលើកបង្ហាញ ហើយសមមិត្តមឿនស្រែកទៀតថា
«នេះជាស្អី?»។ ពួកយើងសម្លឹង គឺឃើញចុងអំពៅប្រមាណបីធ្នាប់ដៃនៅសល់
ពីកុមារនោះហូប។ តើនេះឬគឺជាខ្មាំងរបស់អង្គការ? បើដូចនេះមែន កុមារ
ជិត១០នាក់នេះ គឺជាខ្មាំងតាមពាក្យ សមមិត្តមឿន ចោទប្រកាន់អស់ទៅហើយ។
នៅពេលភ្លាមៗ កុមារចំនួន៥នាក់ បានទាញកំពឹងត្នោត ដែលដុះឫសបន្តិច
មកប្រគល់ឲ្យប្រធានកងកុមារ ខ្ញុំក៏យកដំឡូងជ្វាមួយដុំដែលសត្វស៊ីជិតអស់ឲ្យ
ទៅដែរ។ «នៅមានទៀតមិនទាន់អស់ទេ!» ប្រហែលជា សមមិត្តមឿន ដឹងថា
នៅមិនទាន់អស់។ កុមារីពីរនាក់បងប្អូនធ្វើទឹកមុខអេះអុញបង្ហាញភាពស្អាក់ស្ទើរ។
ពេលឃើញកែវភ្នែក សមមិត្តមឿន សម្លឹងចំកុមារទាំងពីរនាក់បងប្អូននោះ ពួកគេ
ក៏ដើរមកតិចៗលូកដៃទាញចង្កេះសំពត់បង្ហាញកូនកង្កែបពីរក្បាលមកដាក់ជាមួយ
យើងនៅមុខសមមិត្តប្រធាន។ ក្រោយពី សមមិត្តមឿន សម្លឹងមួយត្រួសដោយ
សន្និដ្ឋានថាអស់ហើយ គាត់បាននិយាយឆ្ពារដៃឆ្ពារជើងថា «បើមិត្តណាគ្មានគំនិត
ស្មោះត្រង់នឹងអង្គការ ក្បត់សមូហភាព ភ្លេចគុណអង្គការរំដោះឲ្យរួចផុតពីរបបជិះ
ជាន់សក្តិភូមិមូលធននិយម នោះសមមិត្តគឺជាខ្មាំង ទង្វើនេះ មិត្តបានប្រព្រឹត្តជា
លើកទីមួយ ខ្ញុំគ្រាន់តែព្រមាន ប្រសិនបើមានលើកទីពីរអង្គការនឹងកម្ទេចចោល»។
សមមិត្តមឿន និយាយពាក្យហូរហែជាច្រើន រហូតដល់យើងស្តាប់លែងចូល ព្រោះ
យើងចាប់ផ្តើមឃ្លាន។ ការប្រជុំបានបញ្ចប់ ហើយកុមារទាំងអស់បានស្រែកស្រុះ
គ្នាថា «កុមារ គឺជាកូនអង្គការ ដឹងគុណអង្គការ ជយោកម្ពុជាប្រជាធិបតេយ្យ មហា
លោតផ្លោះ មហាអស្ចារ្យ» រួចយើងនាំគ្នាទះដៃបញ្ចប់និងប្រកាសរំសាយការប្រជុំ។
បន្ទាប់មក កុមារ នាំគ្នាដើរសំដៅទៅរោងបាយយ៉ាងប្រញាប់ប្រញាល់។

អង្គការបានបែងចែករោងបាយរួមជាបីផ្នែក គឺមាននៅដើមភូមិ កណ្តាលភូមិ និងចុងភូមិ។ រោងបាយរបស់ខ្ញុំ នៅឯចុងភូមិ ហើយកុមារដទៃទៀតនៅរោងបាយផ្សេងៗទៅតាមការបែងចែករបស់អង្គការ។ ថ្ងៃលិចយូរណាស់ទៅហើយ ប៉ុន្តែរោងបាយរបស់ខ្ញុំមិនទាន់មានអង្ករដាំបបរទេ។ ចំណែកឯទឹកក្នុងខ្ទះទាំងបួនតម្រៀបគ្នាពុះកញ្ជ្រោលរង់ចាំអង្ករ។ ចុងភៅចេះតែបោះអុសបញ្ចូលក្នុងចង្ក្រាន។ ទោះជាមិនទាន់ឮស្នូរជួងដល់ម៉ោងបាយក៏ដោយ អ្នកស្រុកដើរមកជាបន្តបន្ទាប់ រួចចូលមកអង្គុយតាមតុតម្រៀបជាពីរជួរវែង និងខ្លី។ កុមារខ្លះអង្គុយយ៉ាងស្ងៀមស្ងាត់ ខ្លះដើរចុះឡើងមើលខ្ទះបបរ ចំណែកក្មេងតូចៗអាយុចន្លោះ២ទៅ ៣ឆ្នាំ យំទារកអាហារ។ តាម្នាក់ ដែលជាជនជាតិចិន និយាយមិនច្បាស់ បានរអ៊ូជាក់ចុងភៅ ហើយមើងចុងភៅទ្រាំពុំបានក៏ស្រែកសម្លុតទាំងយារដៃកាន់វែកមករកតាចិន។ តាចិនឈប់និយាយ ហើយដើរមកអង្គុយនៅតុទាំងទឹកមុខមួម៉ៅ។ ទិដ្ឋភាពពេលនោះគួរឲ្យសង្វែកណាស់ មិនថាខ្ញុំ ឬប្រជាជនផ្សេងទៀតទេ គឺមានរូបរាងស្គមកំព្រឹង ពោះកំប៉ោង មុខហើមធំជាងខ្លួន ដែលរាល់ថ្ងៃមានតែសេចក្តីស្រេកឃ្លានប៉ុណ្ណោះ។ ក្មេងៗឃ្លានអាហារ ស្រែកយំគាំងលែងឮសំឡេងក៏មានដែរ។ ចំណែកចាស់ៗខ្លះក្រាបក្បាលលើតុដោយសេចក្តីហេវហត់។ រំពេចនោះ ស្នូរទេះគោង៉ែតៗ និងសំឡេងដេញគោកាត់រោងបាយ។ មើងចុងភៅ ចាប់ទាញល្អីដើរសំដៅទៅកន្លែងកស្តុកការនៅក្បែរនោះ។ បន្តិចក្រោយមក មើងចុងភៅត្រលប់មកវិញ ដោយយកអង្ករមកមិនដល់ពាក់កណ្តាលល្អីផង។ មើងចុងភៅយកត្រឡោកដួងវាល់អង្ករពីត្រឡោកស្មើៗគ្នាជាក់ក្នុងខ្ទះ ដែលមានទឹកកំពុងពុះស្រាប់។ ស្នូរជួងបាយ បានបន្លឺឡើងជាសញ្ញាប្រាប់ថាបបរឆ្អិនហើយ។ ខ្ញុំមិនទាន់ចូលអង្គុយហូបបបរទេ រង់ចាំមើល អារុន ពុក និងម៉ែ។ អារុន ទើបតែមានអាយុ ៥ឆ្នាំ។ អង្គការមិនទាន់ឲ្យ អារុន ចូលក្រុមកុមារឡើយ។ អារុន មានសាច់ឈាមគ្រាន់បើជាងកុមារដទៃទៀត។ អារុន តែងដើរតត្រុកក្នុងភូមិ ឬតាមស្រែរកចំណីអាហារ បន្ទាប់ពីអ្នកភូមិចេញទៅធ្វើការអស់។ ប្រធានភូមិហៅពុកម៉ែរបស់ខ្ញុំ ទៅណែនាំចំនួនពីរបីលើករួចមកហើយដោយសារតែ អារុន។ នៅពេលមកដល់ ខ្ញុំដឹកដៃ អារុន មកអង្គុយតុក្បែរខ្ញុំ។

ចុងភៅសែងឆ្នាំងបបរដើរតាមគុ ហើយដួសមួយវែកដាក់ក្នុងចាន ដែលមានតាមគួរចជាស្រេច រួចប្រាប់ថា «ពេលនេះរបបបានតែមួយវែកនោះទេ»។ បបរចំនួនមួយវែក គឺពេញចានល្មម ប៉ុន្តែគ្រាប់អង្ករវិញ គឺមិនបានមួយស្លាបព្រាបាយផង។ ធម្មតា យើងបានស្ងោរទឹកប្រហុកលាយជាមួយនឹងស្លឹកផ្ទីមកច្របល់លាយចូលគ្នាបន្តែម។ ពុកម៉ែរបស់ខ្ញុំ ដើរមកសំដៅតុខ្ញុំ និងអារុន ដោយកាន់ចានបបរមកជាមួយផង។ ពុកហុចមកឲ្យខ្ញុំ ឯម៉ែហុចឲ្យអារុន ដែលមានកាកបបរបន្តិចលាយស្លឹកផ្ទី ហើយគាត់និយាយថា ហូបរួចប្រញាប់ទៅផ្ទះ។ ខ្ញុំមិនតបទៅគាត់វិញទេ គឺគ្រាន់តែងក់ក្បាល គិតពីហូបបបរ ហើយក៏មិនខ្វល់ពីកុមាររួមគុកំពុងសម្លឹងមើលមុខខ្ញុំឡើយ។

នៅពេលដែលខ្ញុំទៅដល់ខ្នមមិនទាន់ស្រួលផង អារុន លូនទៅរកកន្លែងដេក ហើយម៉ែយកក្រមាចាស់ដែលមានបំណាស់ពីរបីកន្លែងមកដណ្តប់ឲ្យ អារុន រួចអង្អែលក្បាល ដែលជាទម្លាប់មុននឹងដេក។ ចំណែកពុក នៅអង្គុយឆ្កឹះចន្ទុះដែលរៀបនឹងរលត់ម្តងៗ។ ខ្ញុំសម្លឹងមុខពុកតាមពន្លឺចន្ទុះ។ មុខពុកមិនដូចមុនទេ។ ថ្ពាល់ពុកឡើងផតឃើញឆ្អឹងថ្ពាម ឯមុខម៉ែវិញ ក៏ស្តួមដូចពុកដែរ។ ម្តាយឪពុករបស់ខ្ញុំ មានអាយុ ៣០ឆ្នាំជាង ប៉ុន្តែមើលទៅរូបរាងនឹងមុខរបស់គាត់ដូចមានអាយុ៦០ឆ្នាំ។ ខ្ញុំដឹងថា ពុកម៉ែមិនដែលបានហូបឆ្អែតទេ។ ពួកគាត់ តែងតែហុតទឹកបបរ ចំណែកឯកាកបបរវិញទុកឲ្យកូនៗ។ ពុកនិងម៉ែ ខិតខំធ្វើការបម្រើអង្គការគ្មានពេលសម្រាកឡើយ។ ពុកឆ្កឹះចន្ទុះឲ្យឆេះខ្លាំងបន្តិច រួចចុះទៅចង្ក្រានដងទឹកមួយត្រឡោកផ្លុំបណ្តើរ ធឹកបណ្តើរ។ ទឹកនោះមិនមែនជាថ្នាំព្យាបាលរោគអ្វីនោះទេ។ ទឹកនោះ គឺជាមើមឈើ ស្លឹកឈើ ដែលជាបន្លែ ជាអាហារសម្រាប់ជួយសម្រន់បានខ្លះ។ ធឹកអស់មួយត្រឡោក ពុកដងទឹកមួយត្រឡោកទៀតហុចឲ្យម៉ែ។ ពុកប្រុះខ្នងដេកតិចៗមកជិតខ្ញុំ ហើយសួរមកខ្ញុំខ្សឹបៗថា «កូនចាំថ្ងៃខែឆ្នាំកំណើតទេ?»។ ខ្ញុំប្រាប់ពុកថា «ខ្ញុំកើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០»។ ពុកដកដង្ហើមធំ ហើយនិយាយទៀតថា «ឆ្នាំនេះឯងមានអាយុ៧ឆ្នាំ ៥ខែ ប្រសិនបើនៅភ្នំពេញកូនអាចចូលរៀនថ្នាក់ទី១១ហើយ»។ នៅពេលដែលឮពាក្យថាភ្នំពេញ បានធ្វើឲ្យអារម្មណ៍របស់ខ្ញុំ នឹកដល់ផ្ទះ មិត្តភក្តិ ដែលធ្លាប់រត់លេងជាមួយគ្នា

យ៉ាងសប្បាយ។ ជាពិសេសចំណីអាហារសម្បូរហូរហៀរ ហើយនៅចងចាំការចាកចេញដោយអង្គការបានបណ្តេញចេញពីទីក្រុងភ្នំពេញដែរ។ ពុកបានប្រាប់ខ្ញុំថា ខ្ញុំកើតនៅថ្ងៃរដ្ឋប្រហារ ជាថ្ងៃដែលប្រទេសកម្ពុជាមានភាពច្របូកច្របល់។ ស្តាប់ពុកនិយាយមិនបានប៉ុន្មានផង ខ្ញុំក៏ដេកលង់លក់ទៅ។

សំឡេងបំពង់ប៉ុយលាន់ឮសូរឆិកៗ។ ពុកកំពុងតែប្រឹងគោះជារឿនលើកច្រើនសារទម្រាំមានអណ្តាតភ្លើង ដើម្បីបញ្ឆេះចន្លុះសារជាថ្មី។ ខ្ញុំភ្ញាក់ទាំងសើងមមើង បើកភ្នែកឡើងឃើញ ពុក កំពុងតែយកអាវកញ្ចាស់មកពាក់ ឯម៉ែកំពុងរៀបចំបង្វែចខោអាវ។ ខ្ញុំបានឮសូរសំឡេងចេញពីមាត់ជណ្តើរ ស្រែកមិនឲ្យយកខោអាវ និងអីវ៉ាន់ ទៅតាមខ្លួនច្រើននោះទេ ព្រោះអង្គការនឹងបើកថ្មីឲ្យ។ ខ្ញុំបានសម្លឹងតាមចំណាំងពន្លឺចន្លុះ បានឃើញបុរសម្នាក់ស្លៀកពាក់ខ្មៅ មានឆំនឹងមានវ័យចំណាស់ជាងពុកបន្តិច កំពុងបឺតថ្នាំជក់មាត់ចេញផ្សែងហ៊ុយទៅមុខ។ ឯនៅម្ខាងទៀត ខ្ញុំបានឃើញស្រមោលមនុស្សស្ទង់ៗពីរនាក់ ឈរកំបាំងនឹងដើមត្នោតក្បែរខ្ទម។ ពុក មិនឆ្លើយតបនឹងបុរសម្នាក់នោះទេ រួចពុកបានទទួលបង្វែចពីម៉ែ រួចនិយាយមួយៗទាំងអួលដើមកថា «ម៉ែ អារុន មើលថែកូនផង! បងមានសង្ឃឹមតិចតួចណាស់ថានឹងបានវិលត្រលប់មកវិញ»។ ម៉ែឆ្លើយតបទាំងក្រៀមក្រំថា «ពុក អារុន ខ្ញុំ និងកូនចាំឯងត្រលប់មកវិញ»។

ពុក ចាប់ស្មាម៉ែទាញក្បាលមកជាក់ផ្អឹបនឹងដើមទ្រូង។ ខ្ញុំ ដឹងថាពុកម៉ែយំ។ នៅពេលឃើញដូចច្នោះ បុរសនៅមាត់ជណ្តើរ បានស្រែកប្រាប់មកពុកឲ្យឆាប់ចាកចេញទៅ។ ពុក និយាយបណ្តើរ ចុះមកបណ្តើរថា «អូនត្រូវតែតស៊ូរស់ដើម្បីកូន! អារ៉ែត មើលប្អូនផង កុំធ្វើឲ្យម៉ែឯងពិបាកចិត្ត ពុកទៅហើយ! ប្រពន្ធសម្លាញ់បងទៅហើយ! មើលថែរក្សាកូនផង!»។ ខ្ញុំកាន់ដៃម៉ែរបស់ខ្ញុំមើលដំណើររបស់ពុកដែលក្រុមឈ្លបបណ្តើរទៅ។ ពុក បានងាកមកមើលយើងរហូតបាំងបាត់តាមរបាំងនារាត្រីដ៏ងងឹតស្លុប។ រំពេចនោះ អារុន ភ្ញាក់ឡើងសួរពុក ម៉ែបានប្រាប់អារុនថាពុកត្រូវអង្គការឲ្យចេញទៅបោចវល្លិ៍នៅឯព្រៃ។ ឮដូច្នោះ អារុន សង្ឃឹមថាពុកនឹងបេះផ្លែឈើជាច្រើននៅពេលដែលពុកត្រលប់មកវិញ។ ពេល អារុននិយាយដូច្នោះ ម៉ែបានចាប់ក្រសោបឱបខ្លួន អារុន ហើយខ្ញុំក៏ឱបម៉ែយំ។

ស្នូរជួង បានបន្លឺឡើងក្នុងភូមិ ជាសញ្ញាដាស់អ្នកស្រុកឲ្យចេញទៅធ្វើការងារ។ ខ្ញុំបានរត់ទៅតម្រង់ជួរតាមស្នូរសំឡេងកញ្ជែ ចំណែក អារុន នៅដេកបន្តទៀត។ ព្រឹកនេះ ក្រុមកុមារ ត្រូវទៅជួយជញ្ជូនកណ្តាប់ស្រូវនៅឯវាលស្រែ ប៉ុន្តែមុនចេញទៅស្រែ សមមិត្តមឿន បានប្រាប់ថា អង្គការបានកម្ទេចខ្មាំងចំនួនពីរនាក់កាលពីយប់មិញ។ ខ្ញុំមិនបានចាប់អារម្មណ៍នឹងសំដីរបស់ប្រធានកងកុមារទេ ព្រោះពាក្យនេះខ្ញុំឮស្ទើរតែរៀងរាល់ថ្ងៃទៅហើយ។ ខ្ញុំគ្រាន់តែឆ្ងល់ក្នុងចិត្តថា ហេតុអ្វីបានជាសម្បូរខ្មាំងម្ល៉េះ ហើយតើអ្នកណាជាខ្មាំង?

ក្រុមម៉ែៗ ស្ទូងស្រូវដល់ភ្លឺស្រែម្ខាងទៅហើយ នៅតែម៉ែខ្ញុំនៅច្រឹមច្រុមកណ្តាលវាលស្រែ។ ស្ត្រីម្នាក់អាយុប្រហាក់ប្រហែលនឹងម៉ែរបស់ខ្ញុំដែរ បានឈរសម្លឹងមើលម៉ែពីលើភ្លឺស្រែ ហើយក៏ដើរលុយទឹកសំដៅទៅរកម៉ែ ហើយស្រែកថា «ធ្វើការមិនចេះមើលគេ ធ្វើការដូចគ្មានព្រលឹងក្នុងខ្លួន យ៉ាប់មែនប្រពន្ធអាខ្មាំងនេះ ចំជាទុកមិនចំណេញដកចេញក៏មិនខាតមែន»។ ម៉ែងើបមើលទាំងមិនឆ្លើយតប ប៉ុន្តែចិត្តម៉ែពោរពេញទៅដោយភាពឈឺចាប់យ៉ាងខ្លាំង។ ស្ត្រីនោះ និយាយបន្តទៀតទៅកាន់ម្តាយរបស់ខ្ញុំថា បើម្តាយខ្ញុំស្ទូងស្រូវមិនគ្រប់ផែនការ គឺមិនអាចឈប់ទៅហូបបបរបានទេ។ ម៉ែ អត់ងងុយ និងគ្មានជាតិអាហារគ្រប់គ្រាន់នៅក្នុងខ្លួន ហើយម៉ែងងឹតមុខដួលសន្លប់នៅក្នុងវាលស្រែទាំងកណ្តាប់ស្រូវនៅជាប់នៅនឹងដៃ។ មេកង ឃើញដូច្នេះ ស្ទុះទៅចាប់ម៉ែភ្ញើយផុតពីទឹក ហើយនិយាយសំដីតិះដៀលម៉ែថា គាត់ធ្វើពុតជាជំងឺខ្យល់ដួល រួចហើយក៏អុកទម្លាក់ចូលទៅក្នុងទឹកវិញ។ ខ្ញុំឃើញដូច្នោះ ក៏ស្រែកហៅម៉ែស្ទើរភ្លាត់សំឡេង ហើយស្ទុះរត់ទៅរកម៉ែ ប៉ុន្តែ សមមិត្តមឿន ចាប់ខ្ញុំជាប់ រួចសម្តែតថា ខ្ញុំមិនមែនជាគ្រូពេទ្យនោះទេ ហើយដេញខ្ញុំឲ្យឆាប់ត្រលប់ទៅធ្វើការងារវិញភ្លាម។ ខ្ញុំនៅតែស្រែករកម៉ែ ហើយខំប្រឹងរើបម្រះ ប៉ុន្តែខ្ញុំមិនអាចរួចពីកណ្តាប់ដៃដ៏មាំរបស់ សមមិត្តមឿន បាននោះទេ។ សមមិត្តមឿន អូសខ្ញុំឲ្យត្រលប់ទៅកន្លែងកុមារវិញ។ ខ្ញុំខំសម្លឹងទៅរកម៉ែ ហើយបានឃើញអ៊ំចាស់ៗ បីនាក់អូសម៉ែមកភ្លឺស្រែ។ ខ្ញុំនៅតែយំ ចង់ទៅជួបម៉ែ ប៉ុន្តែខ្ញុំមិនអាចទៅបាន។ បើខ្ញុំមិនស្តាប់សម្តីមេកងនោះទេ ខ្ញុំពិតជាត្រូវខ្មែរក្រហម ធ្វើបាបជាក់ជាមិនខាន។ ក្រុមកុមារ បានឈប់សម្រាកមុនពេលបន្តិច

ហើយហូបបបរមុនប្រជាជនផ្សេងទៀតដោយបានទទួលបបរច្រើនជាងពីមុនមួយវែក។ ខ្ញុំឮចុងភៅនិយាយថា ថ្ងៃនេះ ចុងភៅបានដកបបអាហារពី តាចិន និងមិត្តរឿន។ ចុងភៅនិយាយដូច្នោះហើយថែមទាំងបានដៀងភ្នែកសម្លឹងមុខរបស់ខ្ញុំ ដែលកំពុងតែហុតបបរ។

មិត្តរឿន គឺជាពុករបស់ខ្ញុំ ដែលអង្គការបានចាត់តាំងឲ្យទៅព្រៃពីយប់មិញ។ ចុះតា តាចិន គឺជានរណា? មីងចុងភៅនិយាយថា នៅពេលបាត់ តាចិន ធូរធ្លែងព្រោះគ្មាននរណារអ៊ូដាក់ត្រចៀកគាត់ទៀត។ ខ្ញុំហូបបបររួចមួយសន្ទុះបានឮស្នូរជួងសម្រាក ខ្ញុំក៏សម្លឹងទៅរកម៉ែ។ អ្នកធ្វើការជាមួយម៉ែ បានមកដល់ផ្ទះបាយអស់ហើយ ប៉ុន្តែខ្ញុំមិនឃើញម៉ែមកទេ។ អ៊ំស្រីម្នាក់ ធ្វើការជាមួយម៉ែរបស់ខ្ញុំ បានប្រាប់ខ្ញុំថា ម៉ែរបស់ខ្ញុំ បានដឹងខ្លួនហើយក្រោយពីគាត់បានជួយកោសខ្យល់ឲ្យ ប៉ុន្តែមេកងមិនឲ្យមកទេ ព្រោះម៉ែរបស់ខ្ញុំ មិនស្ងួងស្រូវឲ្យរួចគ្រប់ចំនួនតាមផែនការ។ ដឹងដូច្នេះ ខ្ញុំរត់ទៅរកម៉ែភ្លាម។ ម៉ែបានខិតខំប្រឹងបង្ហើយសំណាបពីរបីត្រណោតទៀតទើបងើបមកអង្គុយនៅលើភ្លឺស្រែ។ ខ្ញុំ ស្រែកហៅម៉ែ ដែលអង្គុយទាំងដង្ហក់។ ម៉ែហត់ហេវ ម៉ែស្ទើរតែដាច់ខ្យល់ ប៉ុន្តែម៉ែមិនហ៊ានតវ៉ាប្រឆាំងនឹងអង្គការទេ។ ទោះបីជាម៉ែនៅក្នុងស្ថានភាពយ៉ាងដូច្នេះ ក៏គាត់នៅតែសួរខ្ញុំថា តើខ្ញុំ និងអារុនហូបបបររួចហើយឬនៅដែរ។ ពេលនោះ ខ្ញុំគាំងយោបល់ ព្រោះអារម្មណ៍របស់ខ្ញុំវល់តែគិតដល់ម៉ែ ហើយភ្លេចប្អូនឲ្យឈឹង។ ម៉ែ ឃើញខ្ញុំនៅស្ងៀមដូច្នោះ ក៏យល់ថា អារុន ពិតជាមិនទាន់ហូបបបរទេ។ ម៉ែ ខំប្រឹងក្រោកបម្រុងដើរទៅក្នុងភូមិ។ ពេលនោះ សំឡេងហៅឈ្មោះខ្ញុំយ៉ាងរន្ថើន ហើយពេលដែលខ្ញុំងាកទៅរកសំឡេងនោះ ខ្ញុំបានឃើញ វណ្ណា រត់មករកខ្ញុំទាំងត្រហេបត្រហប រួចប្រាប់ខ្ញុំថា អារុន ប្អូនរបស់ខ្ញុំ ត្រូវអង្គការចាប់ចងនៅឯសន្តិសុខភូមិឯណោះ។ ម៉ែឮដូច្នោះភ្លាម បានដើរយ៉ាងលឿនចូលទៅក្នុងភូមិ ហើយខ្ញុំខំរត់តាមក្រោយម៉ែ។ ម៉ែ បានស្រែកហៅ អារុន ដែលកងឈ្លបកំពុងចងផ្ទោបទៅនឹងគល់ស្វាយ។ អារុន មានស្នាមជាំភ្នែក និងខ្លួន ដែលមានអង្រ្កងជាច្រើនកំពុងព័ទ្ធខាំពេញដងខ្លួនទទេរបស់វា។ ឮសំឡេងម៉ែ អារុន ខំបើកភ្នែកតិចៗស្រែកហៅម៉ែខ្សាវៗឲ្យម៉ែជួយ។

ខ្ញុំអាណិតប្អូន ចង់ជួយបំបោសអង្រ្គែងចេញពីខ្លួន ប៉ុន្តែខ្ញុំមិនហ៊ានជួយទេ ព្រោះដឹងថាមានឈ្លបម្នាក់កំពុងតែឈរសម្លឹងមកពួកយើងមិនដាក់ភ្នែក។ ម៉ែ ស្ទុះទៅរកឈ្លបពីរនាក់ដែលអង្គុយនៅលើកៅអី និងកំពុងតែជក់ថ្នាំស្លឹកសង្កែបង្គុយផ្សែង។ កែវភ្នែកយ៉ាងមុតរបស់ឈ្លបសម្លឹងមកម៉ែ ដែលកំពុងតែលត់ជង្គង់ និងលើកដៃសំពះអង្វរ។ ឈ្លបនិយាយប្រាប់ម៉ែថា ការចាប់ប្អូនខ្ញុំចងនេះគឺជាវិន័យរបស់អង្គការ ប៉ុន្តែម៉ែខ្ញុំនៅតែយំទទូចអង្វរថា អារុន នៅតូចណាស់មិនទាន់ដឹងអ្វីនោះទេ ហើយម៉ែធានាថា នឹងប្រដៅ អារុនឲ្យឈប់ប្រព្រឹត្តដូច្នោះទៀត។ វាក្រោកដើរចេញហើយបញ្ជាក់ថា អារុន បានលួចចេកអង្គការចំនួនពីរផ្លែ ដែលនេះជាទង្វើរបស់ខ្មាំង។ ម៉ែ នៅតែយំតាមសំពះអង្វរ ប៉ុន្តែទោះបីជាម៉ែអង្វរយ៉ាងណាក៏គ្មានប្រយោជន៍ដែរ។

មួយសន្ទុះក្រោយមក ខ្ញុំបានឃើញប្រធានភូមិដើរមកហៅឈ្លបទាំងពីរចូលក្នុងបន្ទប់។ ខ្ញុំមិនដឹងថា ពួកគេជជែកគ្នាអំពីរឿងអ្វីនោះទេ។ ឃ្យូរបន្តិច ខ្ញុំឃើញឈ្លបចេញមកស្រាយចំណងឲ្យ អារុន។ បន្ទាប់ពីឈ្លបស្រាយចំណងរួច អារុនដួលទាំងដំហរ។ ខ្ញុំលូកដៃទៅទ្រអារុនហើយជួយបំបោសអង្រ្គែងចេញពីខ្លួន។ ឯ ម៉ែ ត្រូវប្រធានភូមិហៅឲ្យចូលក្នុងធ្វើការណែនាំតាមទ្រឹស្តីរបស់អង្គការ។ មួយសន្ទុះធំ ម៉ែបានដើរចេញមកនាំ អារុន និងខ្ញុំ ទៅផ្ទះ។ ទៅដល់ផ្ទះ ម៉ែបានដាំទឹកក្តៅ យកក្រមាជ្រលក់ពូតឲ្យនៅក្តៅឧណ្ហៗជូតលើខ្លួន អារុន ដែលកំពុងតែដេកថ្ងូរ។ ចំណែកខ្ញុំ ដើរទៅរោងបាយសុំបបរឲ្យម៉ែ និងអារុន។ ចុងភៅប្រាប់ខ្ញុំថា ហួសពេលបាយហើយ ដូច្នេះគ្មានបបរឲ្យទៀតទេ។ ម៉ែនិងអារុន ផឹកទឹកក្តៅជំនួសអាហារ។ ថ្ងៃនេះ ម៉ែមិនទៅធ្វើការទេ ឯខ្ញុំក៏មិនទៅរោងកុមារដែរ។ ម៉ែអង្គុយក្បែរមាត់បង្អួចសម្លឹងមើលមេឃលាយឡំនឹងទឹកភ្នែកហូរហើយនិយាយតិចៗថា «ប្តីសម្លាញ់! អូននឹងទៅជួបបងក្នុងពេលឆាប់ៗនេះ បងចាំទទួលអូននិងកូនយើងផង»។ បន្ទាប់ពីឮសំដីម៉ែដូច្នេះ ខ្ញុំដឹងកាន់តែច្បាស់ថា ពុកពិតជាបានស្លាប់ពិតមែន។ ខ្ញុំស្ទុះទៅឱបម៉ែ ហើយម៉ែសម្លឹងមុខខ្ញុំនិយាយទាំងអួលអាក់ថា «កូនសម្លាញ់ អង្គការចាត់ទុកយើងជាខ្មាំង ។ យើងគ្មានសង្ឃឹម អាចរស់បានទេ

បន្តិចទៀតយប់នេះឬថ្ងៃស្អែកយើងពិតជាស្លាប់ហើយ»។ និយាយរួច ម៉ែយំខ្សឹបខ្សួលក្រសោបឱបរូបខ្ញុំក្នុងវង្វង់ដៃ ហើយយើងទាំងបីនាក់យំព្រមគ្នា។ នៅថ្ងៃនោះ ខ្ញុំគ្មានសង្ឃឹមថានឹងបានរស់ទៀតទេ។ យើងគ្មានអ្វីជាដំណោះស្រាយក្រៅតែពីដេករង់ចាំសេចក្តីស្លាប់តែប៉ុណ្ណោះ។

នៅពេលដែល រ៉ែត រៀបរាប់មកដល់ត្រឹមនេះ ក៏បានផ្អាកការរៀបរាប់បន្តិច។ គាត់អួលដើមកនិយាយលែងរួច ព្រោះទឹកភ្នែកគាត់ចេះតែស្រក់ចុះមិនឈប់។ ចំណែកខ្ញុំ ដែលជាអ្នកស្តាប់ បានខិតខំចងចាំកត់ត្រាក្នុងអារម្មណ៍អន្ទះអន្ទែងរង់ចាំស្តាប់បន្តទៀត។ ក្រោយពីលើកពែងតែផឹកបន្តិច រ៉ែត បានសម្រួលអារម្មណ៍និយាយទាំងអាក់អួល ហើយបានសុំទោស រួចគាត់បាននិយាយបញ្ជាក់ថា រាល់ពេលដែលគាត់និយាយដល់រឿងរ៉ាវរបស់គាត់ម្តងៗ អារម្មណ៍របស់គាត់នៅតែនឹកឃើញរឿងរ៉ាវទាំងអស់ដែលគាត់ធ្លាប់បានឆ្លងកាត់ហាក់បីដូចជាទើបតែកើតឡើងថ្មីៗ។ ឃើញដូច្នេះ ខ្ញុំក៏ប្រញាប់ប្រញាល់សាកសួររឿងរ៉ាវរបស់រ៉ែតបន្ត ព្រោះនៅសល់តែរយៈពេលប្រហែលជា ២ទៅ៣នាទីទៀតទេ រថយន្តក្រុងនឹងចេញដំណើរហើយ។ រ៉ែត លើកដៃមើលនាឡិកាបន្តិចហាក់យល់សភាពការណ៍ ក៏បានរៀបរាប់ប្រាប់បន្តទៀត។

នៅព្រលប់ថ្ងៃរៀបលិច គ្រួសាររបស់ខ្ញុំ គឺដេករង់ចាំសេចក្តីស្លាប់។ ពេលនោះ អ៊ំស្រី ដែលធ្លាប់ជួយកោសខ្យល់ឲ្យម៉ែរបស់ខ្ញុំ និងមីងម្នាក់ទៀត បានមកដល់ខ្ទមខ្ញុំ ដែលនៅនឹងដៃរបស់គាត់មានកាន់ឆ្នាំងបបរមកជាមួយផង។ ម៉ែ លើកដៃសំពះអរគុណពួកគាត់។ គាត់ញញឹមតបមកវិញ ហើយបានដាក់ឆ្នាំងបបរពីមុខយើងព្រមទាំងមានត្រីងៀត ៣កន្ទុយដែរ។ ខ្ញុំស្រក់ទឹកមាត់ ព្រោះឈ្ងុយត្រីងៀត។ ចំណែក អារុន ស្ទុះក្រោកទាំងកំពុងឈឺ។ ប៉ុន្តែ ម៉ែមិនសប្បាយចិត្តទេ ព្រោះគាត់យល់ថា នេះជាម្ហូបអាហារចុងក្រោយមុនពេលដែលគាត់ស្លាប់។ អ៊ំស្រីបានប្រាប់ថា គាត់ត្រូវបានខ្មែរក្រហមចាត់តាំងមកធ្វើជាប្រធានចុងភៅថ្មីជំនួសមេចុងភៅមុន។ មេភូមិ មេឃុំ មេកង ត្រូវអង្គការផ្លាស់ប្តូរទាំងអស់ដែរ។ អ៊ំបានប្រាប់ម៉ែរបស់ខ្ញុំទៀតថា ឲ្យខំហូបទៅស្អែកចូលធ្វើការវិញបញ្ជីខ្មាំងរបស់គ្រួសារយើងនឹងត្រូវលុបទាំងអស់។

ក្រោយមកទើបខ្ញុំដឹងថា អង្គការ បានចាត់តាំងក្រុមខ្មែរក្រហមពីភូមិភាគនិរតីមកចាត់ចែងជំនួសភូមិភាគទាំងអស់ក្រោយពីសភាពការណ៍បានកើតឡើងនៅក្នុងភូមិភាគបូព៌ា។ អ្នកដែលត្រូវខ្មែរក្រហមផ្លាស់ប្តូរ ត្រូវអង្គការកម្ទេចចោលដោយចោទថាក្បត់អង្គការ និងមិនធ្វើតាមទិសដៅរបស់អង្គការ។ ទោះបីជាខ្មែរក្រហម មកពីភូមិភាគនិរតីចូលមកគ្រប់គ្រងក៏ដោយ ក៏ក្រុមគ្រួសាររបស់ខ្ញុំរស់នៅលំបាក ធ្វើការហត់នឿយ និងហូបបបរវាវដែល។ ពួកយើង មិនទាន់រួចផុតពីការតាមដាននោះទេ។ គ្រួសាររបស់ខ្ញុំត្រូវចុះបញ្ជីជាប្រជាជនដែលក្បត់អង្គការជាថ្មី។ គ្រួសាររបស់ខ្ញុំ ក៏ដូចជាប្រជាជនទូទាំងប្រទេសបានរស់មកដល់សព្វថ្ងៃ ដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ ដែលមានការគាំទ្រពីកងទ័ពស្ម័គ្រចិត្តវៀតណាមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ស្នូរស៊ីផ្លេថយន្តក្រុងបន្លឺឡើង ដែលជាសញ្ញាប្រាប់ថា យើងត្រូវធ្វើដំណើរទៅមុខទៀត ក្រោយពីសម្រាកនៅអាហារដ្ឋានស្តន់តាមផ្លូវជាតិលេខ៦រយៈពេលខ្លី។

រ៉ែត ក្រោកឡើងលើកដៃសំពះលាខ្ញុំ និងនិយាយបន្ថែមទៀតថា «ខ្ញុំធ្វើជាកងទ័ពប្រយុទ្ធក្នុងសមរភូមិពីឆ្នាំ១៩៨៩ ដល់១៩៩៥។ ខ្ញុំត្រូវរបួសពិការ ក៏ខ្ញុំមិនអាចសងគុណអស់ចំពោះអ្នកដែលបានជួយខ្ញុំឲ្យឆ្លងផុតពីរបបខ្មែរក្រហមបានដែរ។

ស្នូរស៊ីផ្លេថយន្តជាលើកទី២ បានបន្លឺឡើង។ រ៉ែត ប្រញាប់ដើរសំដៅឡើងរថយន្ត ហើយឆ្លៀតងាកមកប្រាប់ខ្ញុំថា ជីវិតរបស់គាត់ចំនួន ១,៣៥៥ថ្ងៃ ក្នុងជំនាន់ ប៉ុល ពត វេទនាស្ទើរស្លាប់ស្ទើររស់។ គាត់ចាំមិនអស់នោះទេ។ អ្វីដែលគាត់ចងចាំជាងគេ គឺជីវិតមួយថ្ងៃមួយយប់នេះឯង។ ខ្ញុំឈរសម្លឹងរថយន្តក្រុងដែលបរសន្សឹមៗចេញពីអាហារដ្ឋានឆ្ពោះទៅទិសខាងកើតទឹកដីក្រុងកំពង់ចាម។

ចប់

៧

រឿងដើមមេឃ ពណ៌ក្រហម

អ្នកនិពន្ធ ៖ ឆាន់ ភុត្ថា

៧ ~ រឿង ដើងមេឃពណ៌ក្រហម

«ម៉ែ! តើពុកទៅណាបាត់យូរយ៉ាងនេះ? កូនឮថា អង្គការបានចាប់ ពុក បញ្ជូនទៅកសាង តើហេតុអីបាត់ ពុក យូរយ៉ាងនេះម៉ែ?» បងប្រុសរបស់ខ្ញុំ បានសួរទៅកាន់ម្តាយរបស់ខ្ញុំ នៅក្នុងយប់មួយពេលដែលខ្ញុំកំពុងតែក្តៅខ្លួនខ្លាំងណាស់។ ពេលនោះ ម្តាយរបស់ខ្ញុំ ទើបតែយកថ្នាំអាចម៍ទន្សាយមកពីរោងសហករណ៍ មកឲ្យខ្ញុំលេបរួច។

តាំងពីតូចរហូតដល់ធំ ខ្ញុំនៅមិនទាន់ស្គាល់នូវពាក្យថាលំបាកនៅឡើយ នោះទេ។ ឪពុករបស់ខ្ញុំ គឺជាមន្ត្រីរាជការនៅទីក្រុងភ្នំពេញ។ ក្រុមគ្រួសាររបស់ខ្ញុំ ត្រូវខ្មែរក្រហមជម្លៀសឲ្យមករស់នៅក្នុងខេត្តព្រៃវែង។ ពេលនោះ អង្គការ បានចែកផ្ទះខ្នមតូចមួយឲ្យគ្រួសាររបស់ខ្ញុំរស់នៅ។ សំណាងអាក្រក់ អង្គការបានស៊ើបដឹងថា ឪពុករបស់ខ្ញុំ ធ្លាប់ធ្វើជាមន្ត្រីរាជការនៅក្នុងរបប លន់ នល់ ហើយមិនយូរប៉ុន្មាន អង្គការបានមកចាប់ឪពុករបស់ខ្ញុំទាំងថ្ងៃ ដោយប្រាប់ថាយកទៅកសាង។

និយាយពីម្តាយខ្ញុំវិញ បានដកដង្ហើមធំ មុនពេលគាត់ងាកមកឆ្លើយតបទៅនឹងសំណួររបស់បងប្រុសរបស់ខ្ញុំដោយសំឡេងតិចៗថ្នមៗថា «កុំសួរនាំម៉ែពីរឿងនេះអី! ឪពុករបស់កូន គាត់ចាកចេញពីយើងទៅបានក្តីសុខហើយ កូនត្រូវតែប្រឹងប្រែងដើររើសអាចម៍គោមកធ្វើជីឲ្យបានច្រើន ដើម្បីកុំឲ្យសមមិត្តយើងអាក់អន់ស្រពន់ចិត្ត»។ បន្ទាប់ពីនិយាយរួច ម្តាយរបស់ខ្ញុំ បានដេញឲ្យបងប្រុសរបស់ខ្ញុំ ទៅដេកខ្លាចស្អែកអត់ងងុយធ្វើការងារមិនកើត។ «តែម៉ែ កូនបារម្ភពិតមែន កូនមិននិយាយរឿងនេះទៀតក៏បានដែរ ប៉ុន្តែ ស្ម ើ យ៉ាងមិចហើយម៉ែ? » បងប្រុសរបស់ខ្ញុំបានសួរម៉ែបន្តដោយក្តីបារម្ភណ៍ចំពោះខ្ញុំ។

ខ្ញុំឈ្មោះ រស្មី។ ខ្ញុំមានអាយុទើបតែ១០ឆ្នាំប៉ុណ្ណោះនៅក្នុងរបបខ្មែរក្រហម។ បងប្រុសរបស់ខ្ញុំឈ្មោះ សុធី មានអាយុច្រើនជាងខ្ញុំ ៤ឆ្នាំ។ រហូតមកដល់ពេលនេះ ខ្ញុំនិងក្រុមគ្រួសារ បានរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមជិតមួយឆ្នាំទៅហើយ។ ខ្ញុំអាណិតម៉ែណាស់ ខ្ញុំមិនចង់ឈឺបែបនេះទៀតទេ។ ម៉ែ ត្រូវមកលំបាកគ្រប់យ៉ាងដោយសារតែខ្ញុំ។ ម៉ែ បានដកដង្ហើមធំម្តងទៀតមុនពេលតបទៅកាន់បងប្រុសរបស់ខ្ញុំវិញថា «ប្អូនឯងមិនអីទេ! ឆាប់ទៅដេកទៅ! ហើយ ស្មី កុំនៅប្រឹងបើកភ្នែកយូរពេក សម្ងំដេកទៅកូន ព្រឹកឡើង ស្រួលខ្លួននឹងអាចទៅរោងសហករណ៍ជួយមើលគោនិងរើសជីវិញ»។ នៅពេលដែលម្តាយខ្ញុំនិយាយរួច ក៏បានផ្តុំពន្លត់ភ្លើងចង្កៀងប្រេងកាត ដែលឆេះព្រឹមៗជាក់បញ្ឆរនៅក្បែរក្បាលដំណេករបស់ខ្ញុំ។ ចំណែកខ្ញុំវិញកំពុងតែដេកភ័យបារម្មណ៍ថា ថ្ងៃស្អែកខ្ញុំអាចក្រោកពីកន្ទេលរួចឬអត់ទេ បើឥលូវនេះក្នុងខ្លួនរបស់ខ្ញុំគ្មានកម្លាំងសូម្បីតែបន្តិចសោះអីចឹង។

នៅពាក់កណ្តាលយប់នោះ ខ្ញុំឮសូរសំឡេងមាន់ស្រែកហាក់បីដូចជាមានអ្នកណាម្នាក់កំពុងតែធ្វើអ្វីវា។ ប៉ុន្តែនៅពេលដែលខ្ញុំបើកភ្នែកមក ខ្ញុំបានឃើញភ្លើងតិចៗនៅក្នុងខ្ទមចាស់របស់ខ្ញុំ។ បងប្រុសរបស់ខ្ញុំ កំពុងតែយកក្ងួយបាំងពន្លឺភ្លើងទាំងអស់នោះមិនឲ្យជះពន្លឺចេញទៅខាងក្រៅខ្ទម ហើយម្តាយខ្ញុំកំពុងតែមួលកមាន់លាន់ឮសូរក្រឹតៗមុនពេលជាក់ចូលទៅក្នុងឆ្នាំងដី ដែលមានទឹកកំពុងតែដាំពុះស្រាប់។ «បន្តិចទៀតបានសាច់មាន់ហូបហើយកូន» ម៉ែរបស់ខ្ញុំនិយាយទាំងញ័រមាត់មកកាន់ខ្ញុំ ព្រមជាមួយស្នាមញញឹមបងប្រុសរបស់ខ្ញុំដែលត្រេកអរលាយឡំនឹងភាពភ័យខ្លាច។ នៅពេលឃើញដូច្នេះ ខ្ញុំពិតជាត្រេកអរជាពន់ពេកពាក្យអ្វីមកនិយាយមិនបានទេ។ រាល់ថ្ងៃ អាហារដែលខ្ញុំទទួលបាន គឺត្រឹមតែបបរសារាវ រកគ្រាប់អង្ករនៅក្នុងចានស្ទើរតែមិនឃើញផង។

មួយសន្ទុះក្រោយមក «ស្មី អើយកូន ក្រោកឡើងមកឆាប់ហូបទៅ» ម៉ែខ្ញុំបាននិយាយខ្សឹបៗមកកាន់ខ្ញុំ។ ម៉ែបានកាច់យកភ្លៅមាន់ដែលមានជាប់រោមមាន់មួយៗយកមកឲ្យខ្ញុំហូប។ ខ្ញុំឃ្លានណាស់ទើបប្រញាប់ប្រញាល់ហូបទាំងញ័រមាត់ញ័រក។

ខ្ញុំហូប ភ្លេចទាំងខ្ចើមរោមមាន់ ដែលជាប់នៅលើស្បែកមាន់នោះ។ ម៉ែកំពុងអង្គុយមើលមុខរបស់ខ្ញុំ និងបងប្រុស ហូបដោយលេបទឹកមាត់ ប៉ុន្តែគាត់ហាក់បីដូចជាមិនចង់ហូបសោះ។ «ម៉ែ! ម៉ែហូបទៅ ម៉ែហូបឲ្យច្រើនៗទៅ» ខ្ញុំនិយាយតិចៗទៅកាន់ម៉ែ ទើបគាត់កាច់យកជើងមាន់បន្តិចយកទៅហូប។ ម៉ែរបស់ខ្ញុំ មិនហ៊ានហូបសាច់ទេ។ ខ្ញុំដឹងថាគាត់ខ្លាចកូនទាំងពីរនាក់ហូបមិនឆ្អែតទើបគាត់ធ្វើដូច្នោះ។ បន្ទាប់ពី ខ្ញុំហូបឆ្អែតហើយ ខ្ញុំស្រាប់តែនឹកឃើញដល់រឿងមួយដែលគួរឲ្យខ្លាចនោះគឺខ្លាចអង្គការមករាប់ចំនួនមាន់ ដែលជាទ្រព្យសម្បត្តិរួម។ ម៉ែរបស់ខ្ញុំ បានប្រាប់មកកូនៗថា កុំឲ្យខ្លាច ព្រោះគ្មានរឿងអ្វីនឹងកើតឡើងនោះទេ។ ក្រោយពេលហូបរួចរាល់ហើយ ម៉ែបានប្រញាប់កាយដីក្រោមគ្រែ ហើយបងប្រុសរបស់ខ្ញុំ បានយកអោមមាន់ទៅកាយកប់ក្រោមគ្រែដេករបស់ខ្ញុំដែរ។ ខ្ញុំភ័យខ្លាចណាស់។ ខ្ញុំខ្លាចគ្រប់យ៉ាង ដែលអាចនឹងកើតឡើងមក។ ខ្លាចរឿងហូបមាន់នេះបែកធ្លាយចេញទៅក្រៅ ប៉ុន្តែខ្ញុំបានព្យាយាមប្រាប់ខ្លួនឯងថាមិនអីទេៗ គ្រប់ពេលវេលា។

ព្រះអាទិត្យរះឡើងមិនទាន់ ម៉ែ បានដាស់ខ្ញុំនិងបងប្រុស ឲ្យក្រោកឡើង ហើយគាត់បានយកថ្នាំអាចម៍ទន្សាយ មកឲ្យខ្ញុំលេបមុនពេលចេញទៅរោងសហករណ៍ជាមួយបងប្រុសរបស់ខ្ញុំ។ ទោះបីជាម៉ែមានទឹកមុខញញឹមមុនពេលចាកចេញទៅធ្វើការងារ ក៏ខ្ញុំនៅតែមានការព្រួយបារម្ភខ្លះដែរ។ ខ្ញុំបានសង្កេតឃើញទឹកមុខម៉ែស្លេកស្លាំងប្លែកឧសពីធម្មតា។ ដំណើររបស់គាត់មើលទៅហាក់ដូចជាមិនសូវស្រួលសោះ។ ខ្ញុំបានអង្គុយរង់ចាំម៉ែត្រលប់មកផ្ទះវិញទាំងមានអារម្មណ៍ថាមិនសុខស្រួលក្នុងចិត្ត។ ខ្ញុំអង្គុយលេបទឹកមាត់ព្រោះខ្ញុំឃ្លានខ្លាំងណាស់ ហើយថ្ងៃត្រង់ទៅហើយ ខ្ញុំនៅមិនទាន់មានថ្នាំលេបទៀត។ មិនយូរប៉ុន្មាន ខ្ញុំបានឃើញម៉ែត្រលប់មកវិញ ដោយក្នុងដៃរបស់គាត់មានកាន់ចានមួយមកជាមួយដែរ។ នៅក្នុងចានមានបបរអាវសុទ្ធតែទឹកជាមួយបន្លែត្រកួន ដោយមិនសូវឃើញមានគ្រាប់អង្ករនោះទេ។ នេះពិតជាអាហារឆ្ងាញ់ខ្លាំងណាស់ ដែលខ្ញុំកំពុងតែទន្ទឹងរង់ចាំ។ នៅពេលម៉ែយកបបរមកដល់ គាត់បានឲ្យមកខ្ញុំហូបភ្លាមៗ

ហើយសួរខ្ញុំថា «យ៉ាងម៉េចហើយ ស្មី កូន! បានធូរខ្លះហើយឬនៅ?»។ ខ្ញុំមិនបានឆ្លើយតបទៅនឹងសំណួររបស់ម៉ែទេ ប៉ុន្តែខ្ញុំបែរជាមានអារម្មណ៍ថា នឹកពុកណាស់ ដោយព្រួយបារម្ភពី ពុក រកអ្វីមកផ្ទឹមពុំបានទេ រួចខ្ញុំក៏សួរទៅកាន់ម៉ែថា «ម៉ែ! ពុកនៅឯណា? ខ្ញុំនឹកពុកណាស់ ពុកបានបាត់ទៅច្រើនថ្ងៃហើយនៅមិនឃើញគាត់ត្រលប់មកវិញទៀត កូនភ័យណាស់ម៉ែ»។ «សួរកឱនាងឯងស្មី បង្ហាញចរិតជាខ្មាំងបង្កប់ខ្លួនច្បាស់ចែស មិត្តឯងមកផ្ទះទាំងថ្ងៃចោលរោងសហករណ៍ហ្នឹងគឺដើម្បីយកបបរមកឲ្យនាងខ្មាំងនេះស៊ីឬ? មើលទៅម្នាក់ៗ មិនដែលទុកអង្គការនៅក្នុងភ្នែកទេ ទើបប្រឹងប្រែងបញ្ចេញចរិតប្រឆាំងបែបនេះ» សំឡេងខ្លាំងៗនេះគឺចេញពីមាត់ស្ត្រីម្នាក់ដែលស្លៀកឈុតខ្មៅ ពាក់ស្បែកជើងកង់ឡាន មានឋានៈជាមេកង និងមានកូនចៅឈរនៅពីខាងក្រោយខ្នងដៃកាន់កាំភ្លើងវែងបាននិយាយមកកាន់ម្តាយរបស់ខ្ញុំ និងខ្ញុំ។ ពួកយើងភ័យតក់ស្លុតជាខ្លាំង។

«អ្នកវិនឯង គឺជាប្រជាជនថ្មីនៅទីនេះ អង្គការមានគុណបំណាច់យ៉ាងធំធេងដោយបានចែកផ្ទះឲ្យរស់នៅ ប៉ុន្តែ អ្នកវិន ឯងនៅចេះលួចយករបបអាហារមកឲ្យនាងក្មេងនេះទៀត បើវារំអួយ បើវាធ្វើអីមិនកើត មិនបាច់ឲ្យវាស៊ីស្អីក៏បានដែរ នៅសម្លឹងមុខដល់អង្កាល់ទៀត ថ្មើរណាទើបត្រលប់ទៅរោងសហករណ៍វិញ»។ ម្តាយរបស់ខ្ញុំឈ្មោះ សាវិន ទើបមេកងនារីនោះហៅកាត់ថា អ្នកវិន បែបនេះ។ អ្នកណាក៏ដឹងថាមេកងនារីដែលមានវ័យប្រហែលជាង៤០ឆ្នាំនេះ មានគំនិតផ្តាច់ការ អាងខ្លួនជាប្រពន្ធមេភូមិដើរល្បាតគ្មានខ្លាចអ្នកណាឡើយ។

«តែមិត្តអើយ! កូនរបស់ខ្ញុំ វាក្តៅខ្លួនទើបខ្ញុំស្រូតនឹងមកអើតមើលបន្តិចទៅ ប្រញាប់បានជាសះស្បើយ ទើបមានកម្លាំងទៅបម្រើអង្គការវិញ» ម៉ែរបស់ខ្ញុំតបទៅវិញដោយសំឡេងតិចៗក្នុងន័យលួងលោម។ «អង្គការយើងមិនត្រូវការពាក្យលន់តួអង្វររបស់អ្នកណាម្នាក់នោះទេ មិត្តវិន ឯងប្រយ័ត្នខ្លួនបន្តិចទៅ មិត្តវិន ឯងត្រូវចាំផងថា ប្តីរបស់ មិត្តវិន ឯងទើបតែអង្គការបញ្ជូនយកទៅរៀនសូត្រ បើសិនមិត្តវិន ឯងមិនចង់ទៅរៀនសូត្រទេនោះ ត្រូវខិតខំប្រឹងប្រែងធ្វើការងារបន្តិចទៅ» ស្ត្រីមេកងដែលត្រូវបានគេស្គាល់ថាឈ្មោះ មិត្តរឿន នោះបាននិយាយតបជាមួយ

ម្តាយខ្ញុំទាំងគំរោះគំរើយ។ ម្តាយរបស់ខ្ញុំ នៅតែព្យាយាមលួងលោមបន្តទៀត ប៉ុន្តែ មិត្តរឿន បាននិយាយកាត់សម្តីរបស់ម្តាយខ្ញុំថា «មិត្តឯងកុំព្យាយាមលន់តួអង្វរខ្ញុំអី ឆាប់ទៅរោងសហករណ៍វិញទៅ ហើយមិត្តតូចនេះឆាប់មកតាមខ្ញុំទៅរើសអាចម៍ជាមួយកងក្មេងៗវិញ»។ នៅពេល មិត្តរឿន និយាយចប់ បាននាំខ្ញុំទៅរោងសហករណ៍ក្មេងៗវិញ ដើម្បីរើសជីលេខមួយ។ មិត្តរឿនបានចោទថា ខ្ញុំលួចខ្ជិលខិលខូចមិនចង់ធ្វើការងារ។ មែនហើយ! ខ្ញុំភ្លេចគិតថា ខ្ញុំខ្ចីមអាចម៍មនុស្ស ហើយវាស្អុយពិតមែន ប៉ុន្តែនេះគឺជាបញ្ជារបស់អង្គការ។ ពេលល្ងាចក្រោយពេលចេញពីរោងសហករណ៍ ខ្ញុំចេះតែសម្លឹងរកមើលបងប្រុសរបស់ខ្ញុំ។ ខ្ញុំបានឮប្រធានកងចល័តប្រាប់ថា បងប្រុសរបស់ខ្ញុំ ត្រូវអង្គការបញ្ជូនឲ្យទៅហាត់នៅកងកុមារឆ្ងាយពីផ្ទះ។

មកដល់ផ្ទះយប់នេះ ខ្ញុំក្អកខ្លាំងណាស់ ព្រោះខ្ញុំគ្រុនផ្តាសាយមិនទាន់ជាសះស្បើយស្រួលផង អង្គការក៏បានហៅខ្ញុំឲ្យត្រលប់ទៅធ្វើការវិញ។ ម៉ែរបស់ខ្ញុំភ័យណាស់នៅពេលឃើញខ្ញុំក្អកខ្លាំងយ៉ាងនេះ។ គាត់ បានឲ្យខ្ញុំដេកទ្រោបនៅលើគ្រែ រួចបានដោះអាវខ្ញុំចេញ ដើម្បីកោសខ្យល់ឲ្យខ្ញុំ។ «ទ្រាំបន្តិចទៅកូន នៅពេលដែលម៉ែកោសខ្យល់ឲ្យរួចហើយ កូននឹងបានធូរស្បើយជាមិនខាន» ម៉ែនិយាយលួងលោមខ្ញុំដោយសំដីទន់ភ្លន់ ប៉ុន្តែខ្ញុំនៅតែគ្មួញត្អែរប្រាប់គាត់បន្ថែមទៀតថា «តែកូនពិបាកក្នុងខ្លួនណាស់ម៉ែ ប្រសិនបើកូនយ៉ាងម៉េចៗទៅ ម៉ែថែរក្សាខ្លួនផង កូនម្នាក់នេះមិនបាននៅក្បែរម៉ែបន្តទៅមុខទៀតទេ»។ ម្តាយខ្ញុំបានលើកទឹកចិត្តខ្ញុំថាខ្ញុំមិនអីទេ ហើយប្រាប់ខ្ញុំឲ្យខិតខំដេក។ សំឡេងលាន់ឮប្រាវៗពីខាងក្រៅមក រួមជាមួយសំឡេងស្រែកថា «នែ៎អ្នក! ម៉េចដុតភ្លើងដល់យប់អធ្រាត្រម្ល៉េះ»? និយាយមិនទាន់ចប់ផង មិត្តរឿន បានទម្លុះទ្វារចូលមកក្នុងខ្ទមរបស់ខ្ញុំ ដោយមានកូនចៅម្នាក់មកជាមួយផង។ ខ្ញុំនិងម៉ែ ភ័យឡើងស្លន់ហើយម៉ែបានយកម្រាមដៃដប់លើកសំពះ មិត្តរឿន ទាំងភ័យញ័រទទ្រាក់ទទ្រើតថា «អត់ទេមិត្ត! ខ្ញុំគ្រាន់តែកោសខ្យល់ឲ្យកូនទេតើ កូនរបស់ខ្ញុំវាក្អកហត់ពេកទើបខ្ញុំអុជចង្កៀងបំភ្លឺ ដើម្បីកោសខ្យល់ឲ្យវាទៅ»។ មិត្តរឿន និយាយមកកាន់

ខ្ញុំដោយសម្តីគ្រោតគ្រាត ថែមទាំងបានសម្លក់ខ្ញុំដូចចង់ស៊ីសាច់ «មិត្តឯងងាកឈឺៗប្រយ័ត្នយើងអត់មិនបានចាប់បញ្ជូនឲ្យទៅរៀនសូត្រ អង្គការចាត់តាំងមានប្រសាសន៍មិនខុសទេ ពពួកសួនតូចទុកក៏មិនចំណេញដកចេញក៏មិនខាតដែរ» និយាយរួចមិត្តរឿនបានដើរចេញត្រលប់ទៅវិញ ដោយទាញទ្វារខ្ទមបិទលាន់ឮសូរប្រាវ។ ខ្ញុំខ្លាចណាស់ទើបខ្ញុំប្រញាប់ស្រវាឱបម៉ែជាប់នៅក្នុងដៃទាំងញ័រខ្លួន។

ជើងមេឃមានពណ៌ក្រហមច្រាល នៅពេលដែលខ្ញុំសម្លឹងមើលទៅព្រះអាទិត្យកំពុងតែរះសន្សឹមៗមកបំភ្លឺផែនដីនារដូវវស្សា។ ខ្ញុំនិងកុមារផ្សេងទៀតកំពុងតែនាំគ្នាដើរជាជួរៗទៅកាន់រោងសហករណ៍របស់កងកុមារ ដោយមានកងចល័តប្រុសចំនួន ២នាក់ដើរតាមពីខាងក្រោយខ្នង។ ខ្ញុំភ្ញកតិចៗ ព្រោះអាការគ្រុនផ្តាសាយរបស់ខ្ញុំនៅមិនទាន់ជានៅឡើយទេ។ មិត្តបង ដែលជាមេកងរបស់ខ្ញុំ នៅពេលឃើញខ្ញុំឈឺបែបនេះ ចង់ឲ្យខ្ញុំត្រលប់ទៅសម្រាកនៅផ្ទះវិញ ប៉ុន្តែមិត្តរឿន បានមកដល់ហើយនិយាយថា «ហេតុអីបានជាមិត្តពីរនាក់ឯងចិត្តធំចង់ឲ្យមិត្តម្នាក់នេះឈប់សម្រាកដោយគ្មានមូលហេតុអីចឹង? ឬមិត្តពីរនាក់ឯងយកមនោសញ្ចេតនាមកប្រើនៅទីនេះ? មិត្តប្អូននេះត្រឹមតែគ្រុនផ្តាសាយប៉ុណ្ណឹងពេលធ្វើការចេញញើសលែងអីហើយ ណាមួយនៅទីនេះមិនត្រូវការមនុស្សរំអួយមកធ្វើការក្នុងសហករណ៍នោះទេ»។ មិត្តបងម្នាក់នៅតែមិនអស់ចិត្ត។ គាត់ហាក់ដូចជាស្ទាក់ស្ទើរក្នុងការបកស្រាយ ដើម្បីឲ្យខ្ញុំបានសម្រាក ព្រោះតែក្តីអាណិត។ ប៉ុន្តែ មិត្តរឿន ឆ្លើយមកថា «តែមិត្តឯងហ្នឹងមែន! ប្រយ័ត្នមាត់បន្តិចទៅមិត្តឯង កុំចង់ការពារខ្មាំងឲ្យសោះ មិត្តឯងក៏ដឹងថាមិត្តប្អូនម្នាក់នេះគឺជាប្រជាជនថ្មីដែរ មិនយូរប៉ុន្មានថ្នាក់លើច្បាស់ជាចេញច្បាប់មកដើម្បីជម្លៀសពួកគេចេញពីទីនេះមិនខាន ពេលពួកគេទៅផុតអ្នកដែលមានបញ្ហាគឺមិត្តឯងហ្នឹងហើយ»។ មិត្តរឿន បានយកចង្កុលដៃរបស់គាត់មកចង្កុលចំកណ្តាលក្បាលរបស់មិត្តបង រួចក៏ដើរចេញទៅក្នុងដំណើរពើងទ្រូងងើយមុខឡើង។

មួយថ្ងៃៗ កន្លងផុតទៅលឿនណាស់។ រាល់ព្រឹក រាល់ល្ងាច ខ្ញុំតែងសម្លឹងទៅកាន់ជើងមេឃដែលមានពណ៌ស្រស់ស្អាតគាប់ភ្នែក។ វាប្រៀបបានទៅនឹង

ទីដែលមានសេរីភាព ព្រោះអ្នកណាក៏ដឹងដែរថាទីនេះប្រៀបបានដូចឋាននរក។ ខ្ញុំមិនចង់រស់ក្នុងសភាពបែបនេះទៀតទេ។ កាលពីមិនទាន់មានរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំ រស់នៅពោរពេញទៅដោយស្នាមញញឹម មានការហូបចុកគ្រប់គ្រាន់ មិនមែនត្រូវអត់ឃ្លាន និងធ្វើការងារលំបាករាល់យប់ រាល់ថ្ងៃបែបនេះនោះទេ។ ល្ងាចនេះ នៅពេលដែលខ្ញុំត្រលប់មកផ្ទះវិញ ជាមួយកងកុមារនៅក្នុងភូមិ ខ្ញុំបានជួបម៉ែ ដែលទើបមកពីដកស្ទូងដោយចៃដន្យនៅលើផ្លូវប្រឡាយ។ ខ្ញុំ និងម៉ែ មិនសូវមានពេលបានដើរជាមួយគ្នាត្រលប់ទៅខ្នមតូចរបស់យើងឡើយ។ ខ្ញុំ ពិតជាសប្បាយចិត្តណាស់នៅពេលដែលខ្ញុំបានដើរត្រលប់ទៅផ្ទះវិញជាមួយនឹងម៉ែ។ ខ្ញុំ សម្លឹងឃើញក្តាមខ្យងនៅតាមភ្លឺស្រែជាច្រើន ប៉ុន្តែខ្ញុំមិនអាចចាប់យកទៅហូបបានទេ។ មិនយូរប៉ុន្មាន ខ្ញុំ និងម៉ែ បានដើរទៅដល់ខ្នម។ មនុស្សមួយក្រុមកំពុងតែបំផ្លាញដំណាំនៅជុំវិញខ្នមរបស់យើង ហើយនិយាយថា «ដកទៅ ដំណាំផ្លែឈើជុំវិញផ្ទះនេះ ហើយដែលវាលួចស៊ីព្រឹកល្ងាច អីចឹងតើបានគ្រួសារវាហ្នឹងធាត់ប្លែកខុសគេខុសឯង»។ នេះគឺជាសម្តីរបស់ មិត្តរឿន កំពុងតែបញ្ជាឲ្យកូនចៅរបស់គាត់ប៉ុន្មាននាក់ទៀតដកដំណាំដែលដុះជុំវិញខ្នមតូចរបស់ខ្ញុំ។ ម៉ែ និងខ្ញុំ មិនមាត់អីទេ ព្រោះខ្លាចគេចោទថាយើងជាខ្មាំង។ យើងបានត្រឹមតែឈរមើលពួកគេបំផ្លាញដំណាំហូបចុក។ ដំណាំទាំងអស់នេះ គ្រួសាររបស់ខ្ញុំ មិនដែលហ៊ានបេះហូបនោះទេ ព្រោះយើងដឹងថាប្រសិនបើយើងហ៊ានតែបេះដំណាំនោះហូប យើងនឹងត្រូវចាប់យកទៅកសាង ឬក៏យកទៅរៀនសូត្រជាមិនខានឡើយ។

ក្រោយមក អង្គការបានចាត់តាំងខ្ញុំ ឲ្យទៅធ្វើការងារនៅក្នុងកងចល័តកុមារ ដែលស្ថិតនៅឆ្ងាយពីផ្ទះវិញម្តង។ រយៈពេលប្រហែល២ ឬ ៣ខែម្តង ទើបអង្គការអនុញ្ញាតឲ្យខ្ញុំបានត្រលប់មកលេងផ្ទះ។ ខ្ញុំនឹកម៉ែណាស់ ប៉ុន្តែខ្ញុំត្រូវតែស៊ូទ្រាំ។ កុមារជាច្រើននាក់ទៀត ក៏ស្ថិតក្នុងស្ថានភាពដូចខ្ញុំដែរ។ នៅក្នុងកងចល័ត អង្គការបានឲ្យខ្ញុំ ដាំបន្លែ និងមើលថែជ្រូក។ ជួនពេលខ្លះ ខ្ញុំលួចខ្ជិលមិនចង់ធ្វើការងារទេ ព្រោះខ្ញុំហត់នឿយណាស់។ ខ្ញុំធ្វើការហួសកម្លាំងស្ទើរតែ

បោះដំហានដើរទៅមុខមិនរួចផង។ ប្រធានកង បានវាយធ្វើបាបខ្ញុំដោយរំពាត់ផ្តៅជាច្រើនលើកច្រើនសារ រហូតដល់ខ្ញុំមានដំបៅលើសាច់ពេញខ្លួន។ ខ្ញុំខ្លាចណាស់ស្ទើរតែឆ្លុតម្តងៗទៅហើយ។ ថ្ងៃមួយ ខ្ញុំបានលួចរត់ទាំងយប់ត្រលប់មកផ្ទះវិញ។ ខ្ញុំហ៊ានធ្វើដូច្នេះ ព្រោះខ្ញុំគិតថាប្រសិនបើខ្ញុំបន្តរស់នៅក្នុងកងកុមារតទៅទៀត គឺរង់ចាំតែថ្ងៃស្លាប់ ហើយប្រសិនបើខ្ញុំរត់ទៅផ្ទះវិញ ខ្ញុំក៏ស្លាប់ដែរ ប៉ុន្តែខ្ញុំបានជួបមុខម៉ែ។ ខ្ញុំមិនសូវស្គាល់ផ្លូវរត់មកផ្ទះនោះទេ ប៉ុន្តែបុងក្រោយខ្ញុំបានរត់មកដល់ផ្ទះមែន។ ខ្ញុំបានបង្ហើបមាត់ទ្វារតិចៗចូលទៅក្នុងផ្ទះ។ ខ្ញុំ ឃើញម៉ែកំពុងតែសម្រាន្តនៅលើកន្ទេលស្លឹកគ្នោតចាស់។ ខ្ញុំ នឹកម៉ែណាស់ ទើបរត់ទៅជាស់ម៉ែដោយសំឡេងតិចៗថា «ម៉ែៗគឺកូន...គឺកូន ស្ទឹ នោះអី»។ ម៉ែរបស់ខ្ញុំ ភ្ញាក់រួចស្រាំឱបខ្ញុំជាប់នៅក្នុងដើមទ្រូងរបស់គាត់។ ខ្ញុំ ដឹងតែរឿងម្យ៉ាងគត់ថា ពេលដែលខ្ញុំបាននៅក្បែរម៉ែ គឺខ្ញុំកក់ក្តៅណាស់។ ប្រសិនបើខ្ញុំស្លាប់ក៏ស្លាប់ទៅចុះ សំខាន់ដង្ហើមចុងក្រោយរបស់ខ្ញុំបាននៅក្បែរម៉ែ។ «ម៉េចបានកូនមកដល់ផ្ទះទាំងកណ្តាលយប់អីចឹងកូន? កូនទើបតែត្រលប់ទៅវិញបានជិតមួយខែសោះ ឬកូនលួចរត់មកផ្ទះកូន?» ម៉ែនិយាយផង យកដៃអង្អែលសក់ក្បាលរបស់ខ្ញុំផង។ ម៉ែ បានឃើញស្នាមរបួសដោយសារតែត្រូវវាយដោយរំពាត់នៅលើដៃរបស់ខ្ញុំ ទើបភ្លាមៗនោះគាត់បានប្រញាប់ឲ្យខ្ញុំដោះអាវឲ្យគាត់មើល។ ទឹកភ្នែករបស់ម៉ែហូរដូចទឹកភ្លៀង ព្រោះខ្លោចចិត្តពេលឃើញខ្ញុំមានស្នាមរបួសពាសពេញខ្លួនបែបនេះ។ ខ្ញុំបានប្រាប់រឿងគ្រប់យ៉ាងទៅកាន់ម៉ែទាំងទឹកភ្នែកថា «កូនពិបាកណាស់ម៉ែ ការងារទាំងអស់មិនសមស្របជាមួយនឹងកម្លាំងរបស់កូនទេ កូនភ័យ កូនខ្លាចណាស់ម៉ែ តើម៉ែអាចជួយសុំមិត្តរឿន ឲ្យកូនបានមកនៅផ្ទះវិញផងបានទេ»។ «តែកូនធ្វើបែបនេះមិនខុសពីក្បត់អង្គការនោះទេ ថ្ងៃស្អែកកូនត្រូវត្រលប់ទៅវិញឮឬនៅ? ម៉ែខ្លាចអង្គការចាត់ទុកកូនជាខ្មាំង នោះកូនច្បាស់ជាមានរឿងធំជាមិនខាន បើកូនអាណិតម៉ែ ស្អែកកូនត្រូវត្រលប់ទៅវិញ ចាំម៉ែទៅសុំមិត្តរឿនឲ្យ»។ ម៉ែ ព្យាយាមលួងលោមអង្វរខ្ញុំ ព្រោះតែគាត់មិនចង់ឲ្យខ្ញុំមានបញ្ហា។ ខ្ញុំបានងក់ក្បាលជាសញ្ញាមួយបង្ហាញថាខ្ញុំព្រមតាមគាត់ប្រាប់។ តាំងពីដើមមក ម៉ែរបស់ខ្ញុំ មិនដែលកុហកខ្ញុំទេ។ ម៉ែ តែងតែចង់ឲ្យខ្ញុំល្អ ដូច្នេះខ្ញុំត្រូវតែព្យាយាមឲ្យអស់ពីលទ្ធភាព។

មេឃនៅងងឹតនៅឡើយ ប៉ុន្តែម៉ែ បានដាស់ខ្ញុំឲ្យក្រោកឡើង។ ខ្ញុំឆ្ងល់ណាស់ហេតុអ្វីបានជាម៉ែដាស់ខ្ញុំទាំងព្រឹកព្រហាមបែបនេះ? ខ្ញុំលើកដៃញីភ្នែក រួចសួរទៅម៉ែថា «មានរឿងអ្វីទៅម៉ែ? ហេតុអ្វីបានជាឆាប់ដាស់កូនបែបនេះ?»។ «ឆាប់ក្រោកមកកូន! កូនត្រូវទៅផ្ទះមេភូមិជាមួយម៉ែឥឡូវនេះភ្លាម ព្រោះបើចាំថ្ងៃរះ យើងច្បាស់ជាមានរឿងទាំងគ្រួសារមិនខានទេ កូនបានរត់ចេញពីកងចល័តកុមារនៅស្រុកនោះ អង្គការច្បាស់ជាតាមរកកូនជាមិនខាន» ពេលម៉ែនិយាយចប់ភ្លាម គាត់បានដឹកដៃរបស់ខ្ញុំ ដែលទើបតែភ្ញាក់ពីដេកទាំងមមីមមើដើរចេញពីផ្ទះ ស្រាប់តែមានសំឡេងស្រែកឡើងថា «មិត្តឯងចិត្តធំណាស់! ហ៊ានរត់ចេញពីកងចល័តកុមារទាំងយប់ ប្រហែលចង់ទៅរៀនសូត្រហើយមើលទៅ»។ ពាក្យសម្តីរបស់មិត្តរឿនហាក់ដូចជាផ្លែដាវមកចាក់ចំកណ្តាលទ្រូងខ្ញុំ។ ចំណែកម្តាយរបស់ខ្ញុំវិញ បានក្រាបលូនលន់តួ មិត្តរឿន ឲ្យលើកលែងឲ្យខ្ញុំ។ ម៉ែរបស់ខ្ញុំបានក្រាបសំពះបាតជើង មិត្តរឿន។ រូបភាពដែលខ្ញុំចងចាំជាងគេ គឺជើង មិត្តរឿនបានយកមកជាន់ក្បាលម៉ែរបស់ខ្ញុំ ដែលកំពុងតែក្រាបសំពះ រួច មិត្តរឿនបាននិយាយផ្លែផ្កាពាក្យសម្តីជាច្រើនមុនពេលចាប់ដៃខ្ញុំចងស្លាបសេកបញ្ជូនទៅកងចល័តកុមារវិញ។

ខ្ញុំពិតជាអាក្រក់ណាស់។ ខ្ញុំបានធ្វើឲ្យម៉ែមានបញ្ហា ព្រោះតែការរត់គេចរបស់ខ្ញុំ។ ទឹកភ្នែករបស់ខ្ញុំហូរ ប៉ុន្តែ ខ្ញុំមិនហ៊ានយំដង្ហក់នោះទេ។ ខ្ញុំបានត្រឹមតែដើរតាមមិត្តទាំងពីរនាក់ ដែលចាប់បញ្ជូនខ្ញុំឲ្យត្រលប់មកវិញ។ សម្លៀកបំពាក់របស់ខ្ញុំ ប្រឡាក់សុទ្ធតែដី ព្រោះកាលពីយប់មិញ ពេលខ្ញុំលួចរត់មក ខ្ញុំបានដួលនៅតាមផ្លូវ ហើយនៅពេលដែលខ្ញុំបានមកដល់ផ្ទះ ខ្ញុំបានដេកឱបម៉ែទាំងមិនបានងូតទឹកសម្អាតខ្លួនទេ។ ពេលត្រលប់មកដល់កងចល័តកុមារវិញ មេកងបានដាក់ទារុណកម្មខ្ញុំ ដោយវាយដំខ្ញុំខ្លាំងៗ ព្រមទាំងឲ្យខ្ញុំធ្វើការដោយមិនឲ្យបាយខ្ញុំហូបទេ។ ខ្ញុំឃ្លានណាស់ទើបលួចបេះស្ពៃក្រញាញ់នៅក្នុងចម្ការហូបជំនួសបាយ។ ស្ពៃនោះធ្ងាញ់ណាស់ មានរសជាតិសាបផងល្វីងតិចៗផង។ នៅពេលហូប ភ្នែករបស់ខ្ញុំ គ្រលៀសឆ្វេងស្តាំៗ ខ្លាចមានអ្នកដើរមកឃើញ។

ក្រោយមក ខ្ញុំត្រូវបានអង្គការបញ្ជូនឲ្យមករស់នៅ និងធ្វើការនៅកងកុមារ ក្នុងភូមិវិញ។ ខ្ញុំ រីករាយយ៉ាងខ្លាំង។ ម៉ែរបស់ខ្ញុំ ក៏សប្បាយចិត្តចំពោះការវិលត្រលប់មកវិញរបស់ខ្ញុំដែរ។ ខ្ញុំ មករស់នៅផ្ទះមិនបានប៉ុន្មានថ្ងៃផង ស្រាប់តែ ម៉ែ បានទទួលដំណឹងថា បងប្រុសរបស់ខ្ញុំ បានស្លាប់បាត់ទៅហើយ ដោយសារតែគាត់ព្យាយាមលួចរត់ចេញពីកងចល័ត ព្រមទាំងបានខុសវិន័យរបស់អង្គការជាច្រើនដង។ ម៉ែនិងខ្ញុំ យំសោកសៅខ្លាំងណាស់ នៅពេលបានទទួលដំណឹងនេះ។ ម៉ែ យំឱបខ្ញុំរហូត។ គាត់ស្ទើរតែបាត់បង់សតិទៅហើយ ព្រោះគ្រួសាររបស់យើង បាត់បង់សមាជិកទៅម្តងមួយៗ សូម្បីតែខ្ញុំ ក៏មិនដឹងថានឹងអាចរក្សាជីវិតបានយូរប៉ុណ្ណាដែរ។ ម៉ែរបស់ខ្ញុំ ចាប់ផ្តើមធ្លាក់ខ្លួនឈឺ។ ខ្ញុំកិតភ័យខ្លាំងណាស់។ ពេលទៅឃ្វាលគោជាមួយក្មេងៗដទៃទៀត ខ្ញុំនិងពួកគេ តែងតែនាំគ្នាស្វែងរកមើមដំឡូងនៅក្នុងព្រៃយកមកដុតហូប។ ខ្ញុំបានលាក់ដំឡូងមួយមើមតូចល្មមក្នុងថ្នក់ក្រមាយកមកទុកឲ្យម៉ែ។ ទម្រាំខ្ញុំមកដល់ផ្ទះ មេឃបានងងឹតស្លុងទៅហើយ ប៉ុន្តែខ្ញុំ ក៏ប្រញាប់ប្រញាល់រត់ចូលទៅក្នុងខ្ទមយកដំឡូងឲ្យម៉ែហូប។ ខ្ញុំចង់ឲ្យម៉ែមានកម្លាំងដូចពីមុន។ ពេលនោះ ខ្លួនម៉ែ ក្តៅញ័រញាក់ទន្ទ្រាក់ទន្ទ្រើក បបូរមាត់ស្លេកស្លាំង ធ្វើឲ្យខ្ញុំរន្ធត់នៅក្នុងចិត្តណាស់។ ខ្ញុំ ស្រាវឱបម៉ែក្នុងដៃរួចយកដំឡូងមកឲ្យគាត់ហូប។ ម៉ែ បានហើបមាត់និយាយតិចៗមកកខ្ញុំថា «កូនស្រីមាសម្តាយ គ្រួសាររបស់យើងនៅរស់តែកូនស្រីម្នាក់គត់ កូនគឺជាក្តីសង្ឃឹមរបស់ម៉ែតែម្នាក់ កូនកុំស្លាប់ណា! កូនត្រូវតែធ្វើការតាមបញ្ជារបស់អង្គការដើម្បីរស់ ដរាបណាកូននៅមានជីវិត កូនត្រូវតែតស៊ូ កុំអស់សង្ឃឹមអីណាកូន»។ ខ្ញុំតបទៅម៉ែវិញទាំងពិបាកចិត្តថា «កូនមិនមែនរស់តែម្នាក់ឯងទេម៉ែ កូនមានម៉ែនៅក្បែរនោះអី ម៉ែច្បាស់ជាមិនអីនោះទេ»។ «ម៉ែគ្មានសង្ឃឹមរស់ទេកូនអើយ! ពេលម៉ែស្លាប់ទៅកូនត្រូវថែរក្សាខ្លួនផង ថ្ងៃណាមួយពេលកូនមានរឿងអ្វីបន្ទាន់ មាសដែលម៉ែទុកឲ្យមួយកញ្ចប់នៅក្រោមគ្រែនេះ កូនយកវាតាមខ្លួនផងចុះ មាសទាំងអស់នេះច្បាស់ជាអាចជួយកូនបានមិនខាន» ម៉ែរបស់ខ្ញុំនិយាយផង ដកដង្ហើមដង្ហក់ជាប់គ្នាមិនឈប់ធ្វើឲ្យខ្ញុំកិតភ័យជាពន់ពេក។

ខ្ញុំយំ ខ្ញុំខ្លាច ព្រោះខ្ញុំមិនចង់បាត់បង់ម៉ែទេ។ ខ្ញុំស្រលាញ់ម៉ែខ្លាំងណាស់។ ម៉ែដង្ហក់បន្តិច ក៏បិតភ្នែកស្ងៀមហើយដង្ហើមគាត់លែងដក។ ខ្ញុំដឹងយ៉ាងច្បាស់នៅក្នុងចិត្តថា ម៉ែបានចាកចេញទៅចោលខ្ញុំម្នាក់ទៀតហើយ។

ជីវិតរបស់ខ្ញុំ មិនខុសពីរុក្ខជាតិចកអណ្តែតតាមទឹកនៅរដូវស្សាឡើយ។ ខ្ញុំត្រូវប្រឈមមុខរស់នៅជាមួយនឹងពាក្យថា តស៊ូ ដែលពោរពេញទៅដោយភាពភ័យខ្លាច។ រៀងរាល់យប់ ខ្ញុំ ដេកមិនដែលបានលក់ស្រួលនោះទេ ព្រោះខ្ញុំគឺជាក្មេងស្រីតូចម្នាក់ ដែលរស់នៅពឹងផ្អែកលើជីវិតរសាត់អណ្តែតឥតកោះត្រើយតែម្នាក់ឯង។ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំជាច្រើននាក់ ត្រូវបានអង្គការហៅទៅហើយបានបាត់ខ្លួនរហូត ទៅមិនដែលឃើញត្រលប់មកផ្ទះវិញឡើយ។

នៅឆ្នាំ១៩៧៨ មុនពេលដែលខ្មែរក្រហមដួលរលំ អង្គការបានជម្លៀសខ្ញុំពីទីកន្លែងមួយទៅកាន់ទីកន្លែងមួយទៀត។ ខ្ញុំបានជួបប្រទះនឹងគ្រាប់បែក គ្រាប់ផ្លោង និងគ្រាប់កាំភ្លើងគ្រប់បែបយ៉ាង ដែលគួរឲ្យខ្លាចណាស់។ ពេលមួយ ខ្ញុំរត់ពួនគេចគ្រាប់នៅនឹងគល់ត្នោតមួយ ហើយភ្លាមៗនោះ ខ្ញុំបានឃើញអំបែងគ្រាប់ហោះមកជាប់នឹងគល់ត្នោតលាន់ឮសូរខ្លាំងៗ ប៉ុន្តែជាសំណាងល្អរបស់ខ្ញុំដែលខ្ញុំមិនត្រូវគ្រាប់ដូចប្រជាជនឯទៀត។ ប្រជាជនខ្លះរត់មកពួនមិនទាន់ពេលក៏ត្រូវគ្រាប់បាញ់ដាច់ដៃ ដាច់ជើងគួរឲ្យសង្វែកជាពន់ពេក។ ជីវិតរបស់ខ្ញុំមិនខុសពីស្លឹកឈើងាប់ ដែលត្រូវបក់រសាត់តាមខ្យល់ឥតគោលដៅនោះទេ។ ខ្ញុំបានមកដល់កំពង់ចម្លងអ្នកលឿងដោយមិនដឹងថានៅទីណាជាមួយនឹងខោអាវមួយបង្វិច។ មកដល់លើសាឡាង ខ្ញុំមានមាសខ្លះ ដែលបន្សល់ទុកពីម្តាយរបស់ខ្ញុំទុកគ្រាន់ដូរយករបស់ហូប ។

ភ្នំពេញត្រូវបានវាយរំដោះដោយកងទ័ពវៀតណាម និងកងកម្លាំងរបស់រណសិរ្សសង្គ្រោះជាតិកម្ពុជានៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ខ្ញុំត្រេកអរណាស់។ គ្រប់គ្នានៅលើសាឡាង ស្រែកហ៊ោទ្រហឹងអឺងកងពេញសាឡាង ដែលកំពុងតែចម្លងមនុស្សឆ្លងទៅត្រើយម្ខាងទៀត។ ខ្ញុំយំផង សប្បាយចិត្តផង។ ពេលនោះ ខ្ញុំមិននឹកស្មានថា ខ្ញុំនៅសល់ជីវិតរស់ដល់ថ្ងៃនេះទេ។

ក្រោយបញ្ចប់សង្គ្រាម ពាក្យថា គ្រួសារដ៏កក់ក្តៅរបស់ខ្ញុំ ត្រូវបានបញ្ចប់។ ខ្ញុំត្រលប់មកដល់ភ្នំពេញវិញ ទាំងមិនដឹងថាកោះត្រើយនៅឯណា។ ខ្ញុំអាចនិយាយថា ខ្ញុំសំណាងដែរ ដែលមានអ៊ំស្រីម្នាក់បានហៅខ្ញុំទៅរស់នៅជាមួយគាត់ ព្រោះគាត់បានបាត់បង់ក្រុមគ្រួសារនៅតែម្នាក់ឯងដូចខ្ញុំដែរ។ អ៊ំស្រីបាននាំខ្ញុំទៅរស់នៅក្នុងផ្ទះល្វែងមួយនៅម្តុំផ្សារកណ្តាល។ គាត់ស្រលាញ់ខ្ញុំដូចកូនបង្កើតរបស់គាត់អីចឹង។ ជីវិតថ្មីរបស់ខ្ញុំ ពេញទៅដោយភាពស្រស់បំព្រង។ មកដល់បច្ចុប្បន្ននេះ ខ្ញុំបានកសាងក្រុមគ្រួសារ ហើយម្យ៉ាងទៀត ខ្ញុំបានក្លាយទៅជាម្ចាស់ហាងកាត់ដេរមួយកន្លែងដ៏ធំនៅក្នុងទីក្រុងភ្នំពេញ។

ស្នាមរបួសលើស្បែកគង់នឹងជាសះស្បើយ ប៉ុន្តែអំពើឃោរឃៅ ដែលខ្ញុំបានជួបប្រទះនៅក្នុងរបបខ្មែរក្រហម នៅតែបន្តតាមលងបន្លាចខ្ញុំជាដរាប។ អរគុណពុក និងម៉ែ ដែលបានផ្តល់កំណើតដល់រូបខ្ញុំ។ របបខ្មែរក្រហម បានធ្វើឲ្យក្រុមគ្រួសាររបស់ខ្ញុំ ព្រាត់ប្រាស់គ្នាគ្មានថ្ងៃវិលវិញ។ រៀងរាល់ពេលដែលខ្ញុំនឹកពុក ម៉ែ និងបងប្រុស ខ្ញុំតែងអង្គុយសម្លឹងមើលទៅជើងមេឃពេលព្រះអាទិត្យរៀបលិច ដែលមានពណ៌ក្រហមឆ្អិនឆ្អៅ ព្រោះខ្ញុំគិតថាពួកគាត់បានធ្វើដំណើរទៅកាន់ទីកន្លែងមួយបានក្តីសុខហើយ។

ចប់

៨

រឿងមិនព្រមរៀបការ

អ្នកនិពន្ធ ៖ គឹម សាត

៨ ~ រឿង មិនព្រមរៀបការ

ភូមិក្រូច គឺជាភូមិមួយស្ថិតនៅក្នុងឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ នៅដើមឆ្នាំ១៩៧៧ ខ្ញុំបានចូលរៀនវិជ្ជាពេទ្យជាមួយសមមិត្តជាច្រើនរូប មានទាំងស្រីនិងប្រុស នៅមន្ទីរពេទ្យរបស់អង្គការក្នុងភូមិក្រូច។ ខ្ញុំបានចំណាយពេលរៀនពេទ្យប្រហែល១ឆ្នាំ ប៉ុន្តែខ្ញុំចេះបានត្រឹមតែចាក់ថ្នាំ និងស្គាល់ប្រភេទថ្នាំបានខ្លះៗតែប៉ុណ្ណោះ។

ព្រឹកព្រលឹមថ្ងៃមួយ បន្ទាប់ពីហូបបាយរួចរាល់ យុវជន យុវនារី ដែលជាសិស្សរៀនវិជ្ជាពេទ្យទាំងអស់ បានមកជួបជុំគ្នានៅក្នុងសាលាពេទ្យភូមិក្រូច។ យើងរៀនរហូតដល់ម៉ោងប្រហែលជា៩ព្រឹក ប្រធានពេទ្យ បានប្រកាសប្រាប់ថា «រសៀលថ្ងៃនេះ បុគ្គលិកពេទ្យទាំងអស់ក្នុងមន្ទីរពេទ្យយើង ត្រូវទៅជីករណ្តៅឲ្យបានម្នាក់មួយៗកុំខកខានឲ្យសោះ»។ ខ្ញុំមិនបានជីករណ្តៅតាមគម្រោងផែនការដែលប្រធានពេទ្យ បានដាក់ឲ្យនោះទេ ព្រោះខ្ញុំនៅជាប់រវល់ជួយគ្រូពេទ្យវិយចំណាស់ផ្សេងទៀត ដែលគ្មានកម្លាំងគ្រប់គ្រាន់ក្នុងការព្យាបាលជំងឺនៅឯមន្ទីរពេទ្យ។ កាលនោះ ខ្ញុំនៅក្មេងមិនសូវដឹងរឿង៉ាវអ្វីនោះទេ។ នៅក្នុងចិត្តរបស់ខ្ញុំ ចេះតែនឹកគិតថា តើអង្គការឲ្យយើងជីករណ្តៅធ្វើអ្វីទៅ? ខ្ញុំនៅតែគិតមិនយល់នឹងរឿងនេះ ហើយក៏បានសាកសួរសមមិត្តដែលជីករណ្តៅជាមួយគ្នា។ សមមិត្តនោះបានប្រាប់ខ្ញុំថា «ក្មួយឯងកុំឆ្ងល់ច្រើនពេក អង្គការប្រើឲ្យធ្វើអ្វី ធ្វើតែការងារហ្នឹងទៅ ហើយកុំសួរដេញដោលច្រើនប្រយ័ត្នមានរឿងណា!»។ នៅពេលដែលគាត់ឆ្លើយបែបនេះប្រាប់ខ្ញុំ គឺកាន់តែធ្វើឲ្យខ្ញុំឆ្ងល់ខ្លាំងឡើងថែមទៀត។

ថ្ងៃត្រង់ហើយ ខ្ញុំនៅតែជីករណ្តៅមិនទាន់រួចទៀត ព្រោះខ្ញុំវល់តែជួយការងារនៅក្នុងមន្ទីរពេទ្យសិន។ សមមិត្តផ្សេងៗ ដែលជីករណ្តៅនៅក្បែរៗខ្ញុំ បាននាំគ្នាស្ទុះស្ទាមកជួយជីករណ្តៅរបស់ខ្ញុំទាល់តែរួចរាល់។ សកម្មភាពទាំងនេះ បានធ្វើឲ្យខ្ញុំកាន់តែឆ្ងល់ថាមូលហេតុអ្វីបានជាសមមិត្តទាំងអស់មកជួយធ្វើការងារខ្ញុំ។ សមមិត្តម្នាក់ក៏បានប្រាប់ខ្ញុំបន្ថែមទៀតថា «ការងារដែលអង្គការដាក់ឲ្យធ្វើ គឺត្រូវតែធ្វើឲ្យរួចរាល់ជាដាច់ខាត បើមិនដូច្នេះទេ យើងគ្រប់គ្នានឹងមានរឿងកើតឡើងជាមិនខានទេ»។ ក្រោយមក ខ្ញុំចេះតែលួចតាមដានមើលរណ្តៅទាំងអស់នោះថាតើអង្គការនឹងយកអ្វីមកដាក់នៅក្នុងរណ្តៅ? កន្លងផុតរយៈពេលពីរទៅបីថ្ងៃក្រោយមក ខ្ញុំបានឃើញរណ្តៅត្រូវបានចាក់លុបទាំងអស់។ ខ្ញុំបានសាកសួរទៅកាន់ពេទ្យប្រុសៗ ដែលធ្វើការងារជាមួយខ្ញុំ ហើយពួកគេបានឱ្យដឹងប្រាប់ខ្ញុំថារណ្តៅទាំងអស់នោះ គឺជីកសម្រាប់កប់ខ្មោចអ្នកជំងឺដែលឈឺស្លាប់។

ក្នុងឆ្នាំ១៩៧៧ នៅមន្ទីរពេទ្យក្នុងភូមិក្រូច មានអ្នកជំងឺជាច្រើននាក់ណាស់បានស្លាប់ដោយសារតែខ្វះថ្នាំព្យាបាល។ អ្នកជំងឺទាំងអស់នោះ គឺត្រូវទុកឲ្យដេកស្លាប់តែម្តង។ ប្រជាជនជាច្រើននៅក្នុងភូមិក្រូច បានកើតជំងឺមួយដែលធ្វើឲ្យក្អួតចង្អោរ ហើយបានឆ្លងរីករាលដាលជាបន្តបន្ទាប់។ ជំងឺក្អួត អាចបណ្តាលមកពីកង្វះអនាម័យក្នុងការរស់នៅប្រចាំថ្ងៃ ដែលកើតឡើងដោយសារតែអាហារ និងផឹកទឹកកខ្វក់។

ថ្ងៃមួយ ខ្ញុំបានពិនិត្យជំងឺឲ្យបុរសម្នាក់ ដែលមកសម្រាកព្យាបាលក្នុងមន្ទីរពេទ្យភូមិក្រូច។ បុរសម្នាក់នោះ មានអាការក្តៅខ្លួនខ្លាំង។ បន្ទាប់ពីពិនិត្យជំងឺឲ្យគាត់រួច ខ្ញុំ បានចេញទៅដើរកបេះបន្លែនៅតាមផ្ទះរបស់ប្រជាជននៅក្បែរៗនោះ។ ចៃដន្យ ខ្ញុំបានជួបនឹងយោធាខ្មែរក្រហមម្នាក់ កំពុងតែដើរតាមផ្លូវតម្រង់មករកខ្ញុំ។ យោធាខ្មែរក្រហមម្នាក់នោះមានកម្ពស់ខ្ពស់បង្គួរ សម្បុរស មុខរាងពងក្រពើ។ គាត់ មានអាយុប្រហែលជាជាង២០ឆ្នាំ។ គាត់ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ដែលអង្គការបានចែកឲ្យ។ ខ្ញុំមើលទៅគាត់ទំនងជាមនុស្សកាចសាហាវណាស់។ នៅពេលដែលយោធាខ្មែរក្រហមម្នាក់នោះឃើញខ្ញុំភ្លាម គាត់ក៏ឈប់

ហើយឈរសម្លឹងមើលមុខខ្ញុំមិនដាក់ភ្នែកឡើយ។ ខ្ញុំឃើញគាត់សម្លឹងមកខ្ញុំចម្លែកយ៉ាងនេះ ខ្ញុំក៏សួរទៅកាន់គាត់ថា «តើមានការអ្វីឬពូ?»។ «តើមិត្តនារីឯងនៅឯណា? ហើយមកទីនេះរកអ្វីដែរ?» យោធាខ្មែរក្រហមនោះញញឹមមើលមុខខ្ញុំ ហើយសួរមកខ្ញុំដោយសម្តីស្លូតបូត។ ខ្ញុំចាប់ផ្តើមចម្លែកក្នុងចិត្តថា ជាធម្មតា យោធាខ្មែរក្រហម កម្រមានអ្នកនិយាយស្តីពិរោះបែបនេះណាស់ ហើយចុះយោធាម្នាក់នេះហេតុអ្វីមានសម្តីពិរោះដូច្នេះ? តើគាត់មានបំណងបែបណាទៅ? មិនបង្អង់យូរ ខ្ញុំបានឆ្លើយប្រាប់ទៅគាត់វិញថា «ខ្ញុំ គឺជាបុគ្គលិកពេទ្យ ហើយមកទីនេះដើម្បីរកបន្លែទៅស្លហូប»។ យោធាម្នាក់នោះបានសួរបន្តមកខ្ញុំទៀតថា «ខ្ញុំឧស្សាហ៍ចេញចូលក្នុងមន្ទីរពេទ្យនេះដែរ ម្តេចមិនដែលឃើញ? តើមិត្តនារីឯងសម្រាកនៅឯណាដែរ?»។ «ខ្ញុំសម្រាកនៅផ្ទះខាងជើងមន្ទីរពេទ្យយើងនេះឯង» ខ្ញុំបានឆ្លើយប្រាប់គាត់ដោយទៀងត្រង់ រួចហើយខ្ញុំប្រញាប់ប្រញាល់លាយោធាម្នាក់នោះត្រលប់ទៅផ្ទះរបស់ខ្ញុំវិញ បន្ទាប់ពីបេះផ្លែខ្នុរបាន៣ផ្លែសម្រាប់ស្លហូប។ យោធាម្នាក់នោះមិនបាននិយាយស្តីអ្វីតបមកខ្ញុំទៀតឡើយ រួចខ្ញុំក៏ចាកចេញទៅ។

មុនពេលទៅដល់ផ្ទះ ខ្ញុំបានចូលទៅក្នុងមន្ទីរពេទ្យ ដើម្បីពិនិត្យមើលអ្នកជំងឺដែលខ្ញុំបានពិនិត្យមុនពេលចាកចេញទៅបេះបន្លែសិន។ ខ្ញុំ ស្រាប់តែបានឃើញបុរសអ្នកជំងឺនោះ បានស្លាប់បាត់ទៅហើយ។ ខ្ញុំពិតជាឆ្ងល់ណាស់ថា ជំងឺនោះដូចជាមិនធ្ងន់ធ្ងរនោះទេ ចុះហេតុអ្វីបានជាគាត់ស្លាប់យ៉ាងរហ័សបែបនេះ?។ ត្រលប់មកដល់ផ្ទះវិញ ខ្ញុំបានសួរទៅកាន់លោកគ្រូពេទ្យម្នាក់ទៀតដែលនៅក្បែរផ្ទះរបស់ខ្ញុំ។ លោកគ្រូពេទ្យនោះបាននិយាយឱ្យឹបៗប្រាប់ខ្ញុំថា «បុរសអ្នកជំងឺម្នាក់នោះ គឺជាអតីតទាហាន លន់ នល់ ដូច្នេះអង្គការ បានបញ្ជាឲ្យខ្ញុំចាក់ថ្នាំសម្លាប់តែម្តង»។ មិនតែប៉ុណ្ណោះ លោកគ្រូពេទ្យនោះ ក៏បានណែនាំខ្ញុំកុំឲ្យមានចិត្តអាណិតអាសូរច្រើនពេក ព្រោះខ្លាចអង្គការយកទៅកសាង។ ខ្ញុំនៅមានចម្ងល់ជាច្រើនទៀតចង់សួរបន្ត ប៉ុន្តែខ្ញុំក៏លែងហ៊ានសួរនាំគាត់ទៀត ព្រោះយោធាម្នាក់ ដែលខ្ញុំបានជួបពីរសៀលនៅកន្លែងបេះបន្លែនោះបានដើរចូលមក។

«អូ! មិត្តវ៉ាន់! តើមកពីសមរភូមិយូរហើយ ឬក៏ទើបតែមកដល់ហ្នឹង បានជាខ្ញុំទើបតែឃើញ?»។ បន្ទាប់ពីឮលោកគ្រូពេទ្យសួរទៅកាន់យោធាម្នាក់នោះ ទើបខ្ញុំដឹងថាយោធាម្នាក់នោះ ឈ្មោះ មិត្តវ៉ាន់ ហើយទើបតែត្រលប់មកពីសមរភូមិវិញ។ មិត្តវ៉ាន់ បានសម្តែងការគួរសមដោយឆ្លើយតបទៅនឹងលោកគ្រូពេទ្យថា «អូ! បងពេទ្យទេអី! ខ្ញុំទើបតែមកប្រហែលបួនប្រាំថ្ងៃនេះទេ»។ ខ្ញុំ ចាប់ផ្តើមធ្ងល់ក្នុងចិត្តថា តើ មិត្តវ៉ាន់មកផ្ទះខ្ញុំរកអ្វី? មិត្តវ៉ាន់ បានញញឹមមកកាន់ខ្ញុំ ហើយសួរខ្ញុំថា តើខ្ញុំស្នាក់នៅផ្ទះនេះឬ? មិនតែប៉ុណ្ណោះ មិត្តវ៉ាន់ ក៏បានសួរមកខ្ញុំទៀតថា តើខ្ញុំស្នាក់នៅផ្ទះនេះចំនួនប៉ុន្មាននាក់ដែរ? ខ្ញុំកាន់តែមានចិត្តធ្ងល់ខ្លាំងឡើងថា តើមូលហេតុអ្វីបានជាមិត្តវ៉ាន់សួរមកខ្ញុំច្រើនម្ល៉េះ? តើគាត់កំពុងគិតអ្វីមួយទេដឹង? មិនបង្អង់យូរ ខ្ញុំបានប្រាប់គាត់វិញថា ខ្ញុំស្នាក់នៅផ្ទះនេះជាមួយនឹងគ្រូពេទ្យ ៣នាក់ផ្សេងទៀត។ លោកគ្រូពេទ្យ បានដើរត្រលប់ទៅផ្ទះរបស់គាត់វិញ ហើយ មិត្តវ៉ាន់ បានដើរទៅជាមួយនឹងគាត់ដែរ។ ខ្ញុំឃើញអ្នកទាំងពីរនិយាយគ្នារហូតដល់ផ្ទះ ដែលលោកគ្រូពេទ្យកំពុងស្នាក់នៅ ប៉ុន្តែខ្ញុំស្តាប់មិនបានថាគាត់និយាយអំពីអ្វីខ្លះនោះទេ។

លុះព្រឹកស្អែកឡើង ខ្ញុំទៅមន្ទីរពេទ្យដូចសព្វមួយដង។ នៅពេលដែលខ្ញុំកំពុងតែពិនិត្យជំងឺ លោកគ្រូពេទ្យ បានមកខ្សឹបៗប្រាប់ខ្ញុំថា មិត្តវ៉ាន់ស្រលាញ់ពេញចិត្តនឹងខ្ញុំ ហើយ មិត្តវ៉ាន់ បានសាកសួរអំពីប្រវត្តិរបស់ខ្ញុំកាលពីម្សិលមិញ។ លោកគ្រូពេទ្យ ក៏បានប្រាប់ប្រវត្តិរបស់ខ្ញុំទៅ មិត្តវ៉ាន់ រួចរាល់អស់ហើយដែរ ថែមទាំងគាត់ បានបញ្ជាក់ប្រាប់ខ្ញុំថា មិត្តវ៉ាន់ នឹងស្នើសុំខ្ញុំរៀបការ។ លោកគ្រូពេទ្យ ក៏ចង់ដឹងអំពីការសម្រេចចិត្តរបស់ខ្ញុំចំពោះ មិត្តវ៉ាន់ ដែរ ព្រោះលោកគ្រូពេទ្យ នឹងអាចនាំពាក្យសម្តីរបស់ខ្ញុំទៅប្រាប់ មិត្តវ៉ាន់ វិញ។ ឮសម្តីលោកគ្រូពេទ្យភ្លាម ខ្ញុំភ័យញ័រដង្ហង់។ ខ្ញុំបានប្រាប់ទៅកាន់លោកគ្រូពេទ្យវិញថា «ចាំខ្ញុំគិតមើលសិនលោកគ្រូពេទ្យ»។ ចម្លើយរបស់ខ្ញុំ គឺគ្រាន់តែឆ្លើយដើម្បីឲ្យរួចខ្លួនមួយគ្រាសិនតែប៉ុណ្ណោះ។ តាមពិត ពេលនោះខ្ញុំមិនទាន់ចង់បានប្តីនោះទេ។ ពេលបាយថ្ងៃត្រង់ស្រាប់តែ មិត្តវ៉ាន់ បានមកដល់ផ្ទះរបស់ខ្ញុំម្តងទៀត។ សាមាន និងហ៊ាប

ដែលជាមិត្តស្នាក់នៅ និងរៀនពេទ្យជាមួយខ្ញុំ បាននាំគ្នាដើរចេញពីរោងបាយ ដើរចេញទៅបាត់នៅពេលឃើញ មិត្តវ៉ាន់ ដើរមកដល់ ដោយទុកឲ្យ ខ្ញុំនិងមិត្តវ៉ាន់ នៅជាមួយគ្នាតែពីរនាក់ទៅវិញ។

នៅពេលដែលឃើញសភាពស្ងាត់ដូច្នេះ មិត្តវ៉ាន់ បានសាកសួរខ្ញុំតាមត្រង់តែម្តងថា «តាមពិត តាំងតែពីខ្ញុំបានឃើញមិត្តនារីម្តងល្ងាចមិញនេះ ខ្ញុំបានចាប់ចិត្តលើមិត្តនារីស្ទើរតែទប់ចិត្តមិនបានទៅហើយ ខ្ញុំបានសួរបងពេទ្យអស់ហើយ ប្រវត្តិរបស់មិត្តនារី ខ្ញុំបានដឹងថាមិត្តនារីមិនទាន់មានគូនោះទេ ចុះបើខ្ញុំស្នើសុំមិត្តរៀបការនឹងខ្ញុំ តើមិត្តព្រមដែរឬទេ?»។ ឮសម្តីមិត្តវ៉ាន់ភ្លាម ខ្ញុំភ័យខ្លាំងណាស់ ព្រោះខ្ញុំមិនអាចបដិសេធនៅចំពោះមុខ មិត្តវ៉ាន់ បានភ្លាមនោះទេ។ ខ្ញុំបានឆ្លើយតបទៅគាត់វិញថា « ឲ្យខ្ញុំគិតមើលសិនទៅណាពូ! ខ្ញុំទើបតែស្គាល់ពូបែបនេះ ឲ្យខ្ញុំសម្រេចចិត្តលឿនពេក ដូចជាពិបាកដែរពូ!»។ ខ្ញុំនិយាយមិនទាន់នឹងចប់ផង ស្រាប់តែ មិត្តវ៉ាន់ យកដៃតឹតជើមទ្រូងផង ដកដង្ហើមដង្ហក់ៗផង ហើយក៏ដួលសន្លប់នៅលើគ្រែក្នុងផ្ទះរបស់ខ្ញុំ។ ឃើញដូច្នោះ ខ្ញុំភ័យខ្លាំងណាស់។ ខ្ញុំបានស្រែកហៅឲ្យគេឯងជួយ។ មនុស្សម្នា បានមកជុំគ្នា ហើយជួយគក់ច្របាច់ធ្វើចលនាបេះដូងឲ្យមិត្តវ៉ាន់ រហូតដល់ មិត្តវ៉ាន់ ដឹងខ្លួនធម្មតាវិញ។ ខ្ញុំមិនដឹងថាមិត្តវ៉ាន់ មានអាម្មណ៍បែបណានោះទេ នៅពេលដែលគាត់ដឹងខ្លួន ថែមទាំងឃើញមានមនុស្សម្នាមកជុំគ្នាបែបនេះ ។ បន្ទាប់មក មិត្តវ៉ាន់ ក៏ត្រលប់ទៅវិញបាត់។ សមមិត្តដែលបានមកជួយសង្គ្រោះ មិត្តវ៉ាន់ នាំគ្នាសួរខ្ញុំអំពីរឿងរ៉ាវដែលបានកើតឡើង។ ខ្ញុំបានឆ្លើយប្រាប់សមមិត្តទាំងអស់គ្នាតាមត្រង់។ សមមិត្ត បានប្រាប់ខ្ញុំថា មិត្តវ៉ាន់ ឧស្សាហ៍សន្លប់ណាស់តាំងពីពេលដែលគាត់ត្រលប់មកពីសមរភូមិវិញ។

ល្ងាចឡើងនៅពេលដែលខ្ញុំកំពុងតែហូបបាយជុំគ្នា៣នាក់នៅផ្ទះ ស្រាប់តែ មិត្តវ៉ាន់ បានមកដល់ផ្ទះរបស់ខ្ញុំម្តងទៀត។ សាមាន និង ហ៊ាប ក៏គេចចេញទៅបាត់ទៀត។ «តើមិត្ត នារីណាន ព្រមរៀបការជាមួយខ្ញុំទេ? បើមិនព្រមទេ ខ្ញុំនឹងឲ្យគេយកនារីឯងទៅសម្លាប់ចោលជាមិនខាន» មិត្តវ៉ាន់ បានសួរនាំខ្ញុំទាំងឈរដោយនៅលើស្មាមានកាំភ្លើងស្ពាយមួយដើមផង។ ខ្ញុំកិតភ័យទន់ជង្គង់អស់ហើយ

នៅពេលដែលគាត់គំរាមខ្ញុំយ៉ាងដូច្នេះ។ ប៉ុន្តែខ្ញុំនៅតែឆ្លើយតបទៅគាត់វិញធម្មតាថា «ខ្ញុំសុំគាត់គិតមួយយប់ទៀតសិនពូ»។ មិត្តវ៉ាន់ គ្រាន់តែស្តាប់ឮខ្ញុំនិយាយតែប៉ុណ្ណឹង ក៏លីកាំភ្លើងដើរចេញទៅបាត់។

យប់ឡើង សាមាន ហ៊ាប និងខ្ញុំ បានចូលដេកតាំងពីព្រលប់។ យើងដេកជជែកគ្នាខ្សឹបៗពីបញ្ហាផ្សេងៗ ដែលកើតមានឡើងនៅក្នុងការងារប្រចាំថ្ងៃរបស់យើង។ «ណាន! តើឯងដឹងទេថា អង្គការឲ្យយើងរៀបការហើយណា» ហ៊ាប បានចាប់ផ្តើមការសន្ទនាដោយលើកយកពីរឿងរៀបការ ដែលអង្គការកំពុងតែចាត់ចែងឲ្យយើង។ ចំណែកឯខ្ញុំបានប្រាប់ទៅហ៊ាបវិញថា «ខ្ញុំដឹងហើយហ៊ាប! ដោយសារតែរឿងនេះហើយ ដែលខ្ញុំដេកគិតស្ទើរតែបែកខួរក្បាលទៅហើយ»។ «ចុះណានឯងគិតយ៉ាងម៉េចទៅ? ខ្ញុំឮថាយោធា ដែលមកជ្រើសរើសពួកយើងធ្វើជាប្រពន្ធនោះ ភាគច្រើនគឺជាជនពិការទៀតផង ខ្ញុំខ្លាចតែត្រូវបានប្តីជាជនពិការទេលោកអើយ យើងនឹងត្រូវវេទនាជាមួយប្តីអស់មួយជីវិតហើយ តើសេចក្តីសុខយើងនឹងមានមកពីណាទៅ? តើសុភមង្គលយើងនឹងកើតយ៉ាងម៉េចទៅ?» សាមាន បានបង្ហាញពីការព្រួយបារម្ភណ៍យ៉ាងខ្លាំងចំពោះអង្គការ ដែលកំពុងតែផ្គត់ផ្គងគូស្រករឲ្យយើង។ មិនមែនតែ សាមាននិងហ៊ាប ទេដែលព្រួយបារម្ភណ៍នឹងរឿងរៀបការ ចំណែកខ្ញុំវិញ បារម្ភណ៍ខ្លាំងណាស់ចំពោះរឿងនេះ។ ខ្ញុំ បានសាកសួរទៅកាន់ សាមាន និងហ៊ាប ថា «តើមិត្តទាំងពីរគិតដោះស្រាយដូចម្តេច?» រួច សាមាន ឆ្លើយទាំងអួលដើមកមកកាន់ ខ្ញុំនិងហ៊ាបវិញថា «ខ្ញុំឮថាអ្នកប្រឆាំងនឹងអង្គការគ្មានលទ្ធផលល្អទេ បើពួកយើងមិនព្រមរៀបការ នោះអង្គការនឹងចោទយើងថា យើងនៅជាប់កម្លែលចាស់ជាមិនខាន ហើយអង្គការនឹងយកយើងទៅលត់ដំឬកសាងក៏មិនដឹង ខ្ញុំខ្លាចណាស់ ចុះមិត្តឯង មូលហេតុអ្វីបានជាមិនព្រមទទួលយកមិត្តវ៉ាន់ទៅ? គាត់ខំស្រលាញ់ឯង ហើយបើតាមខ្ញុំមើលសកម្មភាពរបស់ មិត្តវ៉ាន់ រាល់ថ្ងៃឃើញថា គាត់ស្រលាញ់ឯងដោយស្មោះត្រង់ហើយណា»។ នៅពេលដែលខ្ញុំឮ សាមាន និយាយដល់ឈ្មោះ មិត្តវ៉ាន់ ភ្លាម ខ្ញុំសែនក្នាញ់និងចង់ខឹងជាមួយ សាមាន ថែមទៀត។ ខ្ញុំតបទៅ សាមាន វិញថា« តើឲ្យគ្នា

យក មិត្តវ៉ាន់ មកធ្វើជាប្តីយ៉ាងម៉េចទៅសាមាន! បើគាត់ងាកក្លឹកៗ បន្តិចសន្លប់ៗ តើឲ្យធ្វើការឬចិញ្ចឹមគ្រួសារយ៉ាងម៉េចទៅ? គ្នាក៏អាណិតគាត់ដែរ ប៉ុន្តែឲ្យគ្នារៀបការជាមួយគាត់យ៉ាងម៉េច បើគ្នាគ្មានចិត្តអ្វីបន្តិចសោះទៅលើគាត់នោះ»។ ពេលនោះ ហ៊ាប ក៏ពោលកាត់សំដីរបស់ខ្ញុំថា «ហើយចុះមិត្តឯងចង់បានយ៉ាងម៉េចទៅ? រូបរាងសមរម្យហើយតើ កម្ពស់ក៏បាន សម្បុរក៏ស មុខរាងពងក្រពើហើយឃើញថាសមរម្យហើយប៉ុណ្ណឹងនោះ កុំរើសច្រើនពេក ទោះបីជា មិត្តវ៉ាន់ ឧស្សាហ៍សន្លប់ដោយសារតែរោគរបស់គាត់កាលទៅច្បាំងនៅសមរភូមិនោះក៏ដោយ ក្រែងថ្ងៃណាមួយគាត់ជាសះស្បើយឡើងវិញ តើឯងមិនគិតស្តាយក្រោយទេអី?»។ ស្តាប់សម្តីនាងហ៊ាបមិនទាន់ចប់ផង ខ្ញុំនិយាយទាំងគំហកថា «និយាយទៅនិយាយមកតើឯងទាំងពីរចង់ឲ្យខ្ញុំយក មិត្តវ៉ាន់ ជាប្តីមែនទេ? តើមិត្តវ៉ាន់ ឲ្យឯងទាំងពីរមកធ្វើជាមេអណ្តើកឬ?»។ ហ៊ាប បានបដិសេធថាមិនបានធ្វើជាមេអណ្តើកឲ្យខ្ញុំនោះទេ។ ហ៊ាប គ្រាន់តែចង់ដឹងថា តើខ្ញុំគិតដោះស្រាយដូចម្តេចដែរប្រសិនបើអង្គការបង្ខំឲ្យខ្ញុំរៀបការជាមួយ មិត្តវ៉ាន់។ យើងពិភាក្សាគ្នាចុះឡើងចំពោះរឿងទាំងអស់នេះរួចហើយក៏នាំគ្នាដកដង្ហើមធំឲ្យធូរស្បើយក្នុងចិត្ត។ យើង ចាំស្តាប់ព័ត៌មានបន្តទៀត និងមិនទាន់សម្រេចចិត្តភ្លាមៗនោះទេ។ យើងរង់ចាំមើលខ្លាចក្រែងអង្គការមានការផ្លាស់ប្តូរផែនការផ្សេងទៀត។ និយាយចប់យើងក៏នាំគ្នាសម្រាកទៅ។ សាមាននិងហ៊ាប នាំគ្នាដេកលង់លក់ទៅ។ ចំណែកឯខ្ញុំវិញ ចេះតែគិតវិលវល់រកចម្លើយមិនឃើញសោះ។ អារម្មណ៍របស់ខ្ញុំចេះតែនឹកឃើញសម្តីដែល មិត្តវ៉ាន់ បានគំរាម កាលពីម្សិលមិញ។ ការគំរាមកំហែងរបស់ មិត្តវ៉ាន់ នៅតែងំក្នុងត្រចៀករបស់ខ្ញុំ ថែមទាំងរំជួលចិត្តរបស់ខ្ញុំ ឲ្យភ័យខ្លាចយ៉ាងខ្លាំង។ ខ្ញុំគិតរហូតដល់ឮសូរសំឡេងមាន់រងាវ ទើបខ្ញុំលង់លក់បានបន្តិច។

ព្រឹកឡើង ពេលព្យាបាលអ្នកជំងឺរួច ប្រធានពេទ្យបានប្រកាសព័ត៌មានប្រាប់ថា «នៅមន្ទីរពេទ្យព្រឹកថ្ងៃស្អែក អង្គការនឹងមានការចាប់គូឲ្យរៀបការ ដូច្នេះ សិស្សនារីពេទ្យទាំងអស់ ត្រូវរៀបចំខ្លួនឲ្យបានស្អាត ដើម្បីត្រៀមចាំមិត្តយោធា ដែល

ទើបតែត្រលប់មកពីសមរភូមិ ជ្រើសរើសនារីពេទ្យធ្វើជាប្រពន្ធ ហើយសូមពួកយើងចូលរួមកុំខានឲ្យសោះ»។ ខ្ញុំគ្មានព្រលឹងនៅក្នុងខ្លួនទាល់តែសោះបន្ទាប់ពីស្តាប់ឮការប្រកាសនេះ។ ខ្ញុំគិតថាម្តងនេះ ខ្ញុំច្បាស់ជាគេចពី មិត្តវ៉ាន់ មិនបានឡើយ។ តើខ្ញុំត្រូវធ្វើយ៉ាងណាទៅដើម្បីអាចគេចផុតពីការចាត់តាំងរបស់អង្គការបាន? ខ្ញុំកំពុងតែភ្លឹកនឹកគិតដល់រឿងនេះស្រាប់តែ សាមាន បានមកខ្សឹបប្រាប់ខ្ញុំថា «ពេលបាយថ្ងៃត្រង់យើងជួបគ្នាបន្តិច ដើម្បីពិភាក្សារឿងនេះ»។ សាមាននិយាយរួច ខ្ញុំបានងក់ក្បាលតបទៅសាមាននិងហ៊ាបវិញដោយអារម្មណ៍របស់ខ្ញុំមិននៅក្នុងខ្លួនទេ។ នៅពេលហូបបាយជុំគ្នាថ្ងៃត្រង់ ខ្ញុំបានចាប់ផ្តើមខ្សឹបតិចៗទៅកាន់ពួកគេល្មមតែអ្នកអង្គុយជុំវិញខ្លួនរបស់ខ្ញុំមិនអាចឮថា «ខ្ញុំមិនអាចយក មិត្តវ៉ាន់បានទេ ខ្ញុំសម្រេចចិត្តថា យប់នេះខ្ញុំនឹងលួចរត់ទៅមន្ទីរសន្តិសុខបាក់អាយ ហើយតើពួកឯងគិតយ៉ាងណាដែរ?»។ «ឯងនិយាយថាម៉េច? រត់? តើឯងរត់រួចដែរឬ?» សាមាន បានតបមកខ្ញុំវិញទាំងធ្វើក្អែកស្លីសម្លឹងមកខ្ញុំ។ ខ្ញុំឆ្លើយតបទៅវិញថា «រួចឬមិនរួចក៏ជាការបង្ហាញថា យើងមិនព្រមទទួលមនុស្សដែលយើងមិនស្រលាញ់ដែរ បើអង្គការចាប់បានយកទៅដាក់ទោសបែបណាចាំគិតទៀត ប៉ុន្តែខ្ញុំធ្លប់ថា គ្រាន់តែមិនព្រមរៀបការសោះ ហេតុម្តេចបានជាមានទោសរហូតដល់ថ្នាក់កសាងនោះ?»។ គំនិតលួចរត់របស់ខ្ញុំ ក៏បានចាក់ចំបេះដូងមិត្តរបស់ខ្ញុំទាំង៦នាក់។ ម្នាក់ៗហូបបាយផងគិតផងថា តើត្រូវធ្វើដូចម្តេច? ពេលនោះ ហ៊ាប បានបញ្ចេញយោបល់មុនគេថា «មិត្តឯងកុំរត់អីណា! កុំទៅចោលខ្ញុំបានទេ! បើឯងរត់តើពួកយើងគិតយ៉ាងណា?»។ សាមាន ក៏បន្ថែមទៀតដែរថា «គ្នាពួកយើងទាំងអស់៧នាក់ សុទ្ធតែត្រូវបានគេផ្តោតអារម្មណ៍អស់ហើយ កងទ័ពបានស្នើប្រធានពេទ្យទៅហើយថា សុំពួកយើងរៀបការឲ្យបាន គ្នាគិតថា បើយើងរត់អាចនឹងស្លាប់ក៏ថាបានដែរ រឿងរត់នេះ ខ្ញុំហាក់ដូចជាមិនសូវហ៊ានទេ មិត្តឯងគិតម្តងទៀតមើល! ក្រែងអាចរកផ្លូវដោះស្រាយបាន»។ «គិតក៏គិត! ចាំល្ងាច ក្រែងមានពន្លឺខ្លះ» ខ្ញុំចេះតែឆ្លើយតបឲ្យរួចពីមាត់តែប៉ុណ្ណោះ ប៉ុន្តែតាមការពិត ខ្ញុំបានសម្រេចចិត្តថា នឹងលួចរត់ក្នុងយប់នេះហើយ។ បន្ទាប់ពី

ហូបបាយរួច យើងសម្រាកបន្តិច។ ពេលរសៀល ខ្ញុំបានទៅរៀននៅឯសាលាពេទ្យធម្មតា ដើម្បីកុំឲ្យមានការសង្ស័យ។ បន្ទាប់ពីហូបបាយល្ងាចរួច ខ្ញុំបានរៀបចំអីវ៉ាន់ទុករួចជាស្រេច ដើម្បីរត់ទៅមន្ទីរសន្តិសុខបាក់អាយ ដែលនៅឆ្ងាយពីភូមិក្រូចប្រហែលជា៦គីឡូម៉ែត្រ។ ម៉ោងប្រហែល៨យប់ បរិវេណផ្ទះស្នាក់នៅរបស់ខ្ញុំមានសភាពស្ងាត់ជ្រងំ ងងឹតមើលផ្លូវសឹងតែមិនឃើញ។ កងឈ្លបតែងតែដើរលបយកការណ៍ជានិច្ចគ្រប់ទីកន្លែងនៅពេលយប់។ ខ្ញុំភ័យខ្លាំងណាស់ ប៉ុន្តែដើម្បីអនាគត ខ្ញុំត្រូវតែរត់ចេញពីទីនេះឲ្យបាន។

ក្នុងរាត្រីរនោចខែវិសាខម៉ោងប្រហែលជា៩យប់ ព្រះចន្ទចាប់ផ្តើមរះសន្សឹមៗពីទិសខាងកើត ដែលល្មមអាចឲ្យខ្ញុំមើលឃើញផ្លូវបាន។ ខ្ញុំចាប់ទាញបង្វិចលើកឡើងបម្រុងនឹងស្ពាយ ស្រាប់តែ ពុទ្ធោអើយ មានដៃនរណាចាប់ទាញបង្វិចខ្ញុំជាប់។ ខ្ញុំភ័យលោះព្រលឹងអស់ ស្រាប់តែឃើញមនុស្សជាច្រើន ពួននៅកៀនទ្វារផ្ទះរបស់ខ្ញុំ ដោយខ្ញុំមិនដឹងថាពួកគេមកតាំងពីថ្មើរណានោះទេ។ អ្នកទាញបង្វិចរបស់ខ្ញុំនោះ បានស្ទុះយកដៃមកបិទមាត់របស់ខ្ញុំជាប់។ ពេលនោះហើយដែលខ្ញុំដឹងថាគឺ សាមាន មិត្តរបស់ខ្ញុំ។ ខ្ញុំឱ្យបសួរសាមានថា «តើឯងប្រុងធ្វើស្អីសាមាន?»។ សាមានឱ្យបនៅក្បែរត្រចៀកខ្ញុំថា «ខ្ញុំក៏រត់ទៅជាមួយឯងដែរ ខ្ញុំមិននៅរៀបការជាមួយយោធាពិការទាំងអស់នោះទេ គ្នាយើងទាំងអស់ក៏រត់ទៅជាមួយយើងដែរ ពួកគេនៅពួនឯមាត់ទ្វារផ្ទះយូរហើយ»។ ខ្ញុំភ្ញាក់ព្រើតហាក់បីដូចជាសប្បាយចិត្តបន្តិច នៅពេលឃើញមិត្តរបស់ខ្ញុំមករួមដំណើរជាមួយខ្ញុំដែរ។ មិត្តដែលរួមដំណើរជាមួយខ្ញុំមាន សាមី ហ៊ាប ឈាន វណ្ណា សារឹម និងសាមាន។ ខ្ញុំដើរលបៗទៅរកពួកគេ។ យើងម្នាក់ៗសុទ្ធតែមានបង្វែចកាន់នៅជាប់ដៃរៀងៗខ្លួន។ យើងចាកចេញពីភូមិក្រូចទាំងកណ្តាលយប់ ដើរកាត់វាលស្រែដែលមានដីរឹងក្រញង់។ ឆ្លងផុតវាលស្រែបន្តិច ពួកយើងបានមកដល់ព្រៃដែលបាំងពន្លឺព្រះខែមិនឲ្យយើងឃើញដីឡើយ។ ការធ្វើដំណើរដោយថ្មើរជើងនៅពេលយប់ មិនជាលំបាកនោះទេ ប៉ុន្តែអ្វីដែលយើងបារម្មណ៍នោះ គឺយើងខ្លាចជួបក្រុមកងឈ្លប។ ប្រសិនបើយើងជួបក្រុមកងឈ្លប គឺពួកគេអាចនឹង

បាញ់យើង។ យើងនាំគ្នាដើរបានបន្តិច ពួកយើងបានមកដល់ព្រៃបាំងពន្លឺចន្លុះដែលពួកកងឈ្លបកំពុងតែរកត្រីពេលយប់។ យើងភ័យខ្លាំងណាស់ ក៏នាំគ្នាឱនក្រាបពួនសម្ងំក្រោមគុម្ពឫស្សីស៊ុបទ្រុបរង់ចាំឲ្យក្រុមកងឈ្លបទៅផុតសិន។ នៅពេលដែលយើងកំពុងតែសម្ងំ សាមាន មិត្តរបស់ខ្ញុំរកក្អក។ មិត្តម្នាក់ៗប្រហោងពោះអស់ហើយ ដោយនឹកថា ច្បាស់ជាត្រូវក្រុមកងឈ្លបឮ និងចាប់សម្លាប់ចោលមិនខានឡើយ។ ខ្ញុំបានទាញបង្វិចខោអាវុញទៅផ្ទប់មុខ សាមានយ៉ាងរហ័ស ដើម្បីឲ្យ សាមាន ក្អកដាក់បង្វិចខោអាវនោះ។ សាមាន ក្អកអស់ចិត្តទើបខ្ញុំទាញបង្វិចខោអាវរបស់ខ្ញុំចេញមកវិញ។ យើងពួនចាំនៅទីនោះទាល់តែក្រុមកងឈ្លបចេញទៅបាត់ ទើបយើងបន្តដំណើរទៅមុខទៀត។

នាពេលយប់ ព្រះចន្ទបំភ្លឺមេឃាមូលក្រឡង់ បង្ហាញនូវផ្ទៃមេឃដ៏ធំល្វឹងល្វើយប្រកបទៅដោយតារារយពាន់ត្រចះត្រចង់ ក៏ប៉ុន្តែ វាខុសពីអ្វីដែលយើងកំពុងតែឃើញនៅលើផែនដី ដែលគ្មានសេរីភាពទៅវិញ។ សំឡេងសត្វកណ្តុប និងសត្វចង្រិត បន្លឺឡើងច្រេចៗ យំពាសពេញវាលស្រែ។ នៅលើមេឃ ទីទុយទទះស្លាបហើរពាសពេញព្រៃ និងពាសពេញវាលស្រែប្រណាំងគ្នានឹងខ្លែងស្រាក ដែលហើរផេងស្រែកផង។ សំឡេងសត្វទាំងអស់នោះបានធ្វើឲ្យយើងភ័យតក់ស្លុតម្តងម្កាលដែរ។ យើងនាំគ្នាដើរអស់ប្រហែលបីទៅបួនម៉ោងទើបយើងបានមកដល់មន្ទីរសន្តិសុខបាក់អាយ។

« ឈប់សិន! ក្រុមខាងណា? មកពីទីណា? ហើយទៅណា? ទាំងកណ្តាលយប់បែបនេះ!»។ សំឡេងស្រែករបស់មនុស្សប្រុសបានបន្លឺឡើងនៅខាងមុខយើង។

ខ្ញុំភ័យបុកពោះសារជាថ្មីម្តងទៀត ដោយគិតថា ជីវិតម្តងនេះ ត្រូវធ្លើទៅលើចុងកាំភ្លើងកងឈ្លបនេះហើយមើលទៅ។ នៅពេលដែលកងឈ្លបពិនិត្យតាមពន្លឺខែ ហើយឃើញសុទ្ធតែជាស្រីៗបែបនេះ កងឈ្លបក៏ស្រែកឡើងថា «សុទ្ធតែស្រីៗតើនាំគ្នាទៅណា?»។

ខ្ញុំធូរស្បើយក្នុងចិត្តបន្តិចមកវិញ នៅពេលដែលឮសំឡេងកងឈ្លបប្រែពីសម្តីតខ្លាំងៗមកជាសំឡេងល្មមៗវិញ។ ខ្ញុំក៏ឆ្លើយទៅកាន់កងឈ្លបនោះថា

«ចាសពូ! ពួកខ្ញុំជានារីពេទ្យ! ពួកខ្ញុំរត់ចេញពីមន្ទីរពេទ្យនៅក្រូច មកមន្ទីរបាក់អាយ ដើម្បីគេចពីការរៀបការនៅថ្ងៃស្អែកនេះពូ!»។ ខ្ញុំឆ្លើយតាមត្រង់តែម្តង ព្រោះខ្ញុំគិតថាហេតុផលផ្សេងទៀតបែបជាគ្មានប្រសិទ្ធភាពទេមើលទៅ។ កងឈ្លបទាំងពីរនាក់ បានកាន់កាំភ្លើងដើរសំដៅមករកពួកខ្ញុំ ហើយនាំគ្នាសើច។

«រត់គេចពីការរៀបការ? មានន័យថាក្បត់អង្គការហើយ! ត្រូវមានទោស! ទៅ! ទៅក្នុងមន្ទីរជាមួយពួកខ្ញុំ រង់ចាំការកាត់ទោសពីប្រធានសន្តិសុខ!» កងឈ្លបនោះស្រែកមកម្តងទៀត។

ក្រុមរបស់ខ្ញុំទាំង៧នាក់ត្រូវបានក្រុមកងឈ្លបទាំងពីរនាក់បណ្តើរដោយភ្លង់កាំភ្លើងពីក្រោយតម្រង់មកបន្ទាយសន្តិសុខបាក់អាយ។ ទោះបីជាត្រូវកាំភ្លើងភ្លង់ពីក្រោយខ្នងក៏ដោយ ក៏ខ្ញុំដឹងថាជីវិតពួកយើងបានរួចផុតពីក្តីស្លាប់ហើយ។ ខ្ញុំធ្លាប់ដឹងថា ពូសាឡាត់ នៅមន្ទីរសន្តិសុខបាក់អាយ និងម្យ៉ាងទៀតប្រធានបន្ទាយកងទ័ពបាក់អាយ គឺជាមនុស្សដែលមានអធ្យាស្រ័យខ្លះដែរ។

មកដល់បន្ទាយបាក់អាយ ខ្ញុំឃើញ ពូសាឡាត់ នៅលើអង្រឹង។ គាត់ដឹងថាគឺជាខ្ញុំ ព្រោះឃើញពន្លឺចាំងព្រិចៗពីនាឡិកាដែលខ្ញុំពាក់ជ្បិតនាឡិកានេះ គឺគាត់ជាអ្នកឲ្យខ្ញុំកាលពីមួយឆ្នាំមុន។ ពូសាឡាត់ បានឲ្យគេហៅខ្ញុំឲ្យចូលក្នុងមន្ទីរបស់គាត់ដើម្បីសម្រាក។ មិត្តរបស់ខ្ញុំទាំង៦នាក់ខឹងខ្ញុំផង អរគុណខ្ញុំផងដែរ។ នេះគឺជាលើកទី១នៅក្នុងជីវិត ដែលពួកយើងត្រូវយកអាយុជីវិតមកធ្វើជាដើមទុនដូច្នេះនោះ។

ព្រលឹមឡើង លោកពូសាឡាត់បានសាកសួរខ្ញុំថា «តើនៅមន្ទីរពេទ្យមានរឿងអ្វីកើតឡើងទៅ?»។ «គេបង្ខំឲ្យខ្ញុំរៀបការជាមួយយោធា បើខ្ញុំមិនព្រមទេ អង្គការនឹងសម្លាប់ខ្ញុំចោលហើយ ខ្ញុំមិនស្រលាញ់យោធាម្នាក់នោះផង តើឲ្យខ្ញុំព្រមរៀបការយ៉ាងម៉េចទៅពូ?» ខ្ញុំតបទៅគាត់ទាំងក្តីព្រួយបារម្ភណ៍ផងនិងខឹងជាមួយអង្គការផង។ លោកពូ សាឡាត់ ឮហើយ គាត់ដកដង្ហើមធំ ប៉ុន្តែគាត់មិនបាននិយាយអ្វីទៀតឡើយ។ បន្ទាប់មក យើងបានឃើញយោធាម្នាក់ស្រង់ប្រវត្តិរូបរបស់ពួកយើងទាំង៧នាក់។ បន្តិចក្រោយមក នាយយោធាប្រចាំបន្ទាយក៏បានមកដល់ ព្រោះមន្ទីររបស់លោក ពូសាឡាត់ និងបន្ទាយយោធា នៅឃ្លាតឆ្ងាយពីគ្នាត្រឹមតែ

២០០ម៉ែត្រតែប៉ុណ្ណោះ។ ពេលនោះស្រាប់តែនាយយោធានោះភ្ញាក់ព្រើត ហើយនិយាយឡើងថា « អ្ហាក! គឺណានទេតើ! ហើយយ៉ាងម៉េចបាននាំគ្នារត់ចោលមន្ទីរពេទ្យទាំងយប់? ហើយហ៊ាប! សាមាណ! តើកើតអ្វីលើពួកក្រមុំពេទ្យទាំងអស់? ហេតុអ្វីបានជានាំគ្នារត់ចោលមន្ទីរពេទ្យ? តើបានអ្នកណានៅព្យាបាលអ្នកជំងឺទៅ?»។ ខ្ញុំបានឆ្លើយមុនគេថា «អង្គការបង្ខំឲ្យខ្ញុំរៀបការ ហើយអ្នកដែលខ្ញុំត្រូវរៀបការនោះជាមនុស្សដែលខ្ញុំមិនស្រលាញ់ តើឲ្យពួកខ្ញុំយកធ្វើម៉េចទៅ? លោកពូអ៊ិនឯងជួយគិតមើល»។ «ធ្វើម៉េច? មិនព្រមរៀបការគឺក្បត់អង្គការហើយ» គាត់និយាយហើយក៏ដើរចេញពីផ្ទះនោះភ្លាម។ នេះគឺជាសញ្ញាមួយបង្ហាញថាគាត់មិនចង់ឲ្យអ្នកផ្សេងដឹងទៀតទេថា គាត់កំពុងតែយោគយល់ដល់ពួកខ្ញុំ ។

បន្តិចក្រោយមក មានយោធាម្នាក់ទៀតបានមកប្រាប់ខ្ញុំថា ពួកខ្ញុំត្រូវឃុំខ្លួននៅក្នុងផ្ទះនេះចំនួន៣ថ្ងៃ៣យប់ទៀត។ បើបញ្ជូនទៅកាន់ស្ថាប័នចាស់វិញនោះនឹងនាំឲ្យមានរឿងកាន់តែវែងឆ្ងាយតទៅទៀត។ គាត់ត្រឹមតែឃុំពួកយើង៣ថ្ងៃប៉ុណ្ណោះ គឺជាពិតជាធូរស្រាលច្រើនមែនទែន។ រយៈពេល៣ថ្ងៃនេះ ពួកយើងបានហូបបាយស្រាប់ គឺស្រួលមែនទែន។ យើងពិបាកត្រង់ថា មិនបានងូតទឹកឲ្យបានស្រួល ហើយពេលយើងបត់ជើងគឺត្រូវមានកងយោធាតាមជាប់ពីក្រោយជានិច្ច។ ៣ថ្ងៃកន្លងផុតទៅ ខ្ញុំមិនដឹងថាដំណើរការនៃការស៊ើបរឿងរ៉ាវរបស់ពួកយើងយ៉ាងណានោះទេ។ ពួកយើងទាំង៣នាក់ បានទទួលបទបញ្ជាថ្មីមួយទៀត។ នៅក្នុងបន្ទាយ ការងារដែលយើងត្រូវធ្វើប្រចាំថ្ងៃនោះ គឺព្រលឹមឡើងងើបដាំបាយស្លឲ្យកងទ័ពខ្មែរក្រហមទាំងអស់ និងអ្នកមុខអ្នកការថ្នាក់ស្រុក ដែលឧស្សាហ៍មកបន្ទាយនេះដែរ។ ពេលថ្ងៃ និងពេលល្ងាច យើងក៏ត្រូវដាំបាយស្លដែរ។ ទាំងអស់នេះ គឺជាកិច្ចការយ៉ាងងាយស្រួលបំផុត ដែលប្រជាជនឯទៀតសម្លឹងឃើញចង់ធ្វើ។ នៅពេលនោះ ប្រជាជនម្នាក់ៗ ត្រូវរែកពន់នូវការងារធ្ងន់ៗ ដូចជាលើកទំនប់ ជីកប្រឡាយនៅខាងលិចភូមិស្ទឹង និងទំនប់បាក់អាយនេះជាដើម។ ប្រជាជននឿយហត់ណាស់ ថែមទាំងមានការហូចចុកមិនគ្រប់គ្រាន់នោះទេ។ ប្រជាជនម្នាក់ៗ តែងតែគិតថា កិច្ចការដាំស្លគឺជាកន្លែងខ្លាញ់ ព្រោះវាជាការងារស្រួលផង និងបានហូបចុកគ្រប់គ្រាន់ដែរ។

រស់នៅក្នុងបន្ទាយយោធាមិនបានប៉ុន្មានផង ក្រុមរបស់ខ្ញុំ ត្រូវយោធាខ្មែរក្រហម ដែលទើបតែមកពីសមរភូមិចាប់អារម្មណ៍។ ខ្ញុំមិនបានដឹងថា មិត្តរបស់ខ្ញុំទាំង៦នាក់ទៀតយ៉ាងណានោះទេ ប៉ុន្តែខ្ញុំដឹងថាខ្លួនខ្ញុំត្រូវបានកម្លោះម្នាក់ដែលទើបមកពីសមរភូមិចាប់ចិត្តហើយ។ បុរសនោះមានឈ្មោះថា សំអុល។ សំអុល មានរាងខ្ពស់សមរម្យ សម្បុរសស្អាត។ គាត់ បានស្នើទៅមេបញ្ជាការប្រចាំបន្ទាយសុំរៀបការជាមួយខ្ញុំ។ ថ្ងៃមួយ បន្ទាប់ពីបាយថ្ងៃត្រង់រួច ពូអ៊ន់ ដែលជាមេបញ្ជាការប្រចាំបន្ទាយបានហៅខ្ញុំឲ្យទៅជួបនៅតុបាយរបស់គាត់តែម្តង។ ខ្ញុំហាក់ដូចជាធ្ងល់បន្តិច ភ័យអរបន្តិច មិនដឹងថានឹងមានរឿងអ្វីកើតឡើងចំពោះខ្ញុំទៀតហើយនោះទេ។ ខ្ញុំឈរដួសបាយដាក់ចានឲ្យគាត់ រួចហើយងាកទៅអង្គុយនៅកៅអីមួយទៀតក្បែរនោះដែរ។

ពូអ៊ន់ បានចាប់ផ្តើមនិយាយជាមួយខ្ញុំថា «ណាន ឯងដឹងទេ? អន្ទិត សំអុល បានស្នើឯងរៀបការហើយណា៎! តើឯងគិតយ៉ាងម៉េចដែរ?»។ ខ្ញុំឆ្លើយតបទៅគាត់វិញថា « តើលោកពូ ឲ្យខ្ញុំទទួលយកគាត់ម្តេចនឹងកើតទៅ បើគាត់និយាយត្រដិតរកស្តាប់មិនបានបែបនេះនោះ»។ ខ្ញុំបានដឹងខ្លះហើយតាមរយៈកាយវិការនិងទឹកមុខរបស់មិត្តអុល នេះ គឺគេច្បាស់ជាស្រលាញ់ខ្ញុំហើយ។ «អើ! គ្រាន់តែប្រាប់ឲ្យដឹងថា អុល ស្នើសុំរៀបការនឹងក្មួយឯងហើយ ព្រមឬមិនព្រម ពូក៏មិនហ៊ានបង្ខំដែរ»។ ខ្ញុំនិងពូអ៊ន់ កំពុងនិយាយមិនបានប៉ុន្មានម៉ាត់ផង នាយសំអុលក៏មកដល់ល្មម ហើយចាប់ផ្តើមនិយាយឡើង។

«អូ...មិត្ត...នារី...ណាន...មាន...កិត្តិយស...ណាស់...បាន...មក...បាយ...ជា...មួយ...លោក...នាយ...អ៊ន់»។ ខ្ញុំស្តាប់គាត់និយាយមិនចង់បានផង។ ម្យ៉ាងទៀត ខ្ញុំឃើញមុខ នាយអុល នេះភ្លាម ខ្ញុំតាំងក្តៅស្លឹកត្រចៀកយ៉ាងម៉េចមិនដឹងទេ។ លោកអ៊ន់ ឃើញបែបនេះ ក៏យល់ការណ៍ទើបប្រើទៅ មិត្តអុល ដោយស្រែកខ្លាំងៗថា «អុល! ឯងទៅរកបេះម្ទេសឯក្បែរផ្ទះបាយឲ្យខ្ញុំបានបួនប្រាំមក»។ មិត្តអុលចេញទៅបាត់ ខ្ញុំក៏ចាប់និយាយបន្តទៀតជាមួយ ពូអ៊ន់ បន្តទៀតថា «តើឲ្យខ្ញុំយកធ្វើយ៉ាងម៉េចទៅពូ? បើគាត់បែបហ្នឹងនោះ»។ ពូអ៊ន់ តបវិញថា «ធ្វើម៉េច បើសំអុល ជួបគ្រោះថ្នាក់ខូចសំឡេងអស់បែបនេះ ក្នុងសង្គ្រាមឯ

ព្រំដែន សំអុល ប្រឹងប្រែងប្រយុទ្ធដើម្បីជាតិណាស់ យោធាទាំងអស់ ហ៊ានពលីជីវិតដើម្បីប្រជាជនយើង»។ ខ្ញុំនឹកអាណិត មិត្តសំអុល បន្តិចខ្លះដែរ។ ពូអ៊ន់ឃើញខ្ញុំអង្គុយភ្លឹកមិនដឹងខ្លួនបែបនេះ គាត់ក៏មានប្រសាសន៍បន្តទៀតថា «ស្រេចតែចិត្តក្មួយ ណាន ទេ! ទទួលឬមិនទទួលក្មួយទៅប្រាប់ មិត្តសំអុល ដោយខ្លួនឯងផង ពូមិនអាចបង្ខំបានទេ ព្រោះឃើញក្មួយធ្លាប់រត់គេចចោលពេទ្យ ព្រោះតែរឿងរៀបការនេះម្តងហើយ»។ ខ្ញុំតឹងចិត្តពេកក៏លា ពូអ៊ន់ មកចង្ក្រានបាយវិញ។ ខ្ញុំក្រឡេកឃើញ មិត្តសំអុល កំពុងតែរកបេះផ្លែម្នេសមិនទាន់បានយកទៅឲ្យពូអ៊ន់ ទេ។ នៅពេលដែលខ្ញុំឃើញនៅក្បែរនោះគ្មានឃើញមនុស្សម្នាក់សោះ ខ្ញុំក៏សម្រេចចិត្តហៅ មិត្តសំអុល មកនិយាយគ្នាឲ្យច្បាស់ថា កុំប្រាថ្នាខ្ញុំអី ព្រោះខ្ញុំមិនទាន់ចង់បានប្តីទេ។ ស្ថិតនៅពីក្រោយមិត្តសំអុលប្រហែលជា ៥ម៉ែត្រ ខ្ញុំក៏ដាច់ចិត្តហៅ មិត្តសំអុល។

«មិត្តសំអុល! » ខ្ញុំស្រែកហៅគាត់ប្រាំបីប្រាំបួនដង មិនឃើញគាត់ឆ្លើយសោះ។ ខ្ញុំឆ្ងល់យ៉ាងខ្លាំងប្រហែលគិតថា មិត្តសំអុល ខឹងនឹងខ្ញុំទេដឹង ទើបមិនឆ្លើយបែបនេះ។ កន្លះម៉ោងក្រោយមក ខ្ញុំសង្កេតឃើញអ្នកផ្សេងហៅគាត់ដែរ គឺទៅនិយាយពីមុខគាត់ហើយស្រែកខ្លាំងៗទើបគាត់ស្តាប់ឮ។ ខ្ញុំដឹងថា មិត្តសំអុលមិនត្រឹមតែត្រជិតទេ ប៉ុន្តែថ្លង់ថែមទៀត។ ខ្ញុំកាន់តែអាណិតគាត់ជាងមុន ប៉ុន្តែរឹតតែមិនអាចរៀបការជាមួយគាត់បានទេ។ ដោយខ្លាចមិត្ត សំអុល ឈឺចាប់ ខ្ញុំមិនបានប្រាប់គាត់ដោយផ្ទាល់នោះទេ។ ខ្ញុំ បានប្រាប់ សាមាណ ដែលជាមិត្តរបស់ខ្ញុំឲ្យទៅប្រាប់គាត់ថា ខ្ញុំមិនទាន់ចង់បានប្តីទេ។ លទ្ធផលពីការបដិសេធរៀបការជាមួយមិត្តសំអុល នោះគឺ ខ្ញុំត្រូវគេរៀបចំគម្រោងបញ្ឆោតយកទៅសម្លាប់ពីពីរទៅបីដងក្នុងមួយថ្ងៃ។ បើកុំតែបាន ពូសាឡាត់ ជួយការពារ ខ្ញុំត្រូវស្លាប់បាត់ទៅហើយ។

ផុតពីបញ្ហារបស់ មិត្តសំអុល មិនទាន់បានប៉ុន្មានម៉ោងផង ល្ងាចឡើងនៅពេលដែលខ្ញុំកំពុងតែដាំស្លនៅក្នុងរោងបាយ ពូអ៊ន់ បានមកប្រាប់ថា ព្រឹកស្អែកនឹងមានយោធាមួយក្រុមមកដល់មន្ទីរ ហើយគាត់ប្រាប់ឲ្យយើងត្រៀមខ្លួនតម្រង់ជួរឲ្យក្រុមយោធារើសធ្វើជាប្រពន្ធ។ ពេលដែលខ្ញុំស្តាប់ឮ ពូអ៊ន់ និយាយភ្លាម ខ្ញុំទន់ជង្គង់ដើរមិនចង់រួច។ ល្ងាចនោះ ខ្ញុំអត់បាយមួយយប់ ហូបបាយលែងកើត

ដោយខំរិះរកវិធីដោះស្រាយពេញមួយយប់ ដើម្បីគេចពីការរៀបការម្តងទៀត។ តើខ្ញុំត្រូវធ្វើយ៉ាងណាទៅ? កាលពីមុន ខ្ញុំអាងលើ ពូសាឡាត់ ទើបខ្ញុំរត់មកបន្ទាយបាក់អាយនេះ ហើយចុះឥឡូវនេះវិញ គឺខ្ញុំត្រូវរៀបការក្នុងបន្ទាយនេះតែម្តងឬ? តើឲ្យខ្ញុំគិតរកជំនួយពីខាងណាទៀតទៅ? ហេតុអ្វីជីវិតរបស់ខ្ញុំក្នុងពេលនេះវេទនាអ្វីយ៉ាងនេះ? តាំងពីល្ងាចរហូតដល់ម៉ោង៤ទៀបភ្លឺទៅហើយ ខ្ញុំដេកមិនលក់ គិតចុះគិតឡើងវិលវល់អស់។ ខ្ញុំបានយកសម្តី ពូអ៊ិន មកគិតសាជាថ្មីក៏មានសង្ឃឹមឡើងវិញត្រង់គាត់បានបញ្ជាក់ថា «ប្រសិនបើនរណាចង់បានប្តីឲ្យទៅតម្រង់ជួរជាមួយគេទៅ»។ ដូច្នេះវាហាក់បីដូចជាមានន័យថា បើយើងមិនទាន់ចង់បានប្តីទេ យើងកុំទៅតម្រង់ជួរ។ ខ្ញុំដឹងថា ខ្ញុំអាចមិនចូលរួមតម្រង់ជួរជាមួយនឹងគេបាន។ ខ្ញុំធូរស្រាលចិត្តឡើងវិញ។ ព្រលឹមឡើង កងទ័ពមកពីសមរភូមិបានមកដល់។ ស្រីៗនៅក្នុងបន្ទាយទាំងអស់ បានចូលទៅតម្រង់ជួរប្រហែលជាងម្ភៃនាក់។ ស្រីៗត្រូវកងទ័ពទាំងអស់នោះ រើសយកធ្វើជាប្រពន្ធដូចជារើសខោអាវអីចឹង។ មិត្តនារីរបស់ខ្ញុំទាំង៦នាក់ ដោយខ្លាចអង្គការ ក៏ចូលទៅតម្រង់ជួរទាំងអស់។ ចំណែកឯខ្ញុំវិញ នៅពេលដែលនារីៗតម្រង់ជួរ ខ្ញុំបានរត់ទៅពួននៅក្នុងព្រៃក្បែរផ្ទះ។ លុះពិធីបានបញ្ចប់ ទើបខ្ញុំចេញមកវិញជាធម្មតា។ មិត្តរបស់ខ្ញុំទាំង៦នាក់ ត្រូវបានយុទ្ធជនជ្រើសរើសធ្វើជាប្រពន្ធទាំងអស់ ប៉ុន្តែត្រូវបានមិត្តរបស់ខ្ញុំគ្រប់គ្នាប្រកែក ព្រោះយុទ្ធជនទាំងអស់នោះគឺជាជនពិការ។ រឿងនេះបានធ្វើឲ្យ ពូអ៊ិន និង ពូសាឡាត់ ជួយសម្រួលជាបន្ទាន់ដែរ។ សំណាងល្អណាស់ដែលយុទ្ធជនទាំងនោះព្រមទទួលនូវការសម្រុះសម្រួលពី ពូអ៊ិន និងពូសាឡាត់។ ខ្ញុំគិតថា ប្រសិនបើគ្មានពួកគាត់នោះទេ ខ្ញុំនិងមិត្តរបស់ខ្ញុំ មិនដឹងជាត្រូវស្លាប់តាំងពីពេលណាទេ។

ក្រោយមកទៀត នៅក្នុងបន្ទាយបាក់អាយ មានការតម្រង់ជួររើសនារីមករៀបការជាច្រើនដង ប៉ុន្តែនៅពេលតម្រង់ជួរម្តងៗ គឺមិនមានវត្តមានរបស់ខ្ញុំទេ។ នេះជាមូលហេតុធ្វើឲ្យមនុស្សម្នាក់ៗចេះតែឆ្ងល់ថា ហេតុអ្វីបានជាខ្ញុំអាចគេចខ្លួនរួចរហូតយ៉ាងនេះ? ដោយសម្គាល់ឃើញអវត្តមានរបស់ខ្ញុំពីការតម្រង់ជួរច្រើនដង យោធាម្នាក់ឈ្មោះ អ៊ាត បានលើករឿងខ្ញុំទៅថ្នាក់លើថា ខ្ញុំមិនធ្វើតាមបញ្ជារបស់អង្គការ។ ខ្ញុំភ័យម្តងទៀត ព្រោះការគេចវេសរបស់ខ្ញុំ ត្រូវគេដឹងហើយ។ មិនបាន

ប៉ុន្មានម៉ោងផង មិត្តអ៊ាត បានបង្ហាញអាកប្បកិរិយាថា ស្រលាញ់ខ្ញុំ។ ខ្ញុំដឹងថា មិត្តអ៊ាត មិនហ៊ានប្រាថ្នាខ្ញុំឡើយ ព្រោះយើងទាំងពីរនាក់ ធ្លាប់បានស្គាល់គ្នាតាំងតែពីតូចៗមកម្ល៉េះ។

មិត្តអ៊ាត បានណែនាំខ្ញុំឲ្យទៅយោធាម្នាក់ទៀតឈ្មោះ មិត្តយឿន ដោយឲ្យ មិត្តយឿន មកស្នើ ពូអ៊ិន សុំរៀបការជាមួយខ្ញុំ។ ក្រោយពីបានស្គាល់ខ្ញុំហើយ មិត្តយឿន ក៏អស់សង្ឃឹមមិនហ៊ានប្រាថ្នាខ្ញុំទៀតឡើយ។ អស់ពី មិត្តអ៊ាត និងមិត្តយឿន មានបុរសម្នាក់ទៀត បានចូលមកចែចូវខ្ញុំជាបន្តបន្ទាប់។ បុរសម្នាក់នោះ ឈ្មោះ មិត្តវិន។ មិត្តវិន មានសម្បុរខ្មៅ ទាបក្រអាញ ថែមទាំងមានសក់រួញអង្គាជី បានមកសុំស្រលាញ់ខ្ញុំ។

ខ្ញុំគិតថារស់នៅក្នុងបន្ទាយបាក់អាយ ត្រឹមតែ៥ខែ ខ្ញុំចេះតែមានបញ្ហាម្តងហើយម្តងទៀត។ ខ្ញុំបានសុំអង្គការទៅរៀននៅភ្នំពេញវិញក្រែងបានរួចផុតពីបញ្ហាបានខ្លះ។ បន្ទាប់ពី ខ្ញុំបានស្នើសុំឲ្យ ពូសាឡាត់ ចុះឈ្មោះឲ្យខ្ញុំបានទៅរៀននៅឯភ្នំពេញហើយ នៅពាក់កណ្តាលខែតុលា ឆ្នាំ១៩៧៧ ខ្ញុំបានទៅភ្នំពេញដូចបំណងមែន។ អ្វីដែលធ្វើឲ្យខ្ញុំកាន់តែសប្បាយចិត្តទៀតនោះ គឺមិត្តនារីទាំង ៦នាក់របស់ខ្ញុំ ដែលរត់មកពីមន្ទីរពេទ្យកូមិក្រូចជាមួយគ្នា ក៏បានទៅរៀននៅភ្នំពេញទាំងអស់គ្នាដែរ។ ប៉ុន្តែអ្វីដែលពិបាកសម្រាប់ខ្ញុំនោះ គឺខ្ញុំត្រូវបាន មិត្តវិន អង្វរឃាត់ឃាំងមិនឲ្យខ្ញុំទៅទេ។ មិត្តវិន បាននិយាយរៀបរាប់អង្វរខ្ញុំ ប៉ុន្តែខ្ញុំត្រូវតែចាកចេញទៅ។ នេះប្រហែលជា ខ្ញុំនិងមិត្តវិន មិនមែនជាគូនឹងគ្នាដូចថាស់ៗតែងតែដំណាលហើយ។ ខ្ញុំបានចាកចេញពីបន្ទាយបាក់អាយ ទៅរៀនបន្តនៅឯភ្នំពេញ។ ជីវិតជានិស្សិតក្នុងសម័យខ្មែរក្រហម ទទួលបានការបង្រៀនដោយអនុវត្តផ្ទាល់ និងគ្មានគ្រូបច្ចេកទេសបង្វឹកត្រឹមត្រូវ ក៏បានចាប់ផ្តើមឡើង។

ចប់

៩

រឿងអាប់ស៊ែ

អ្នកនិពន្ធ ៖ រឹម ទិត្យបញ្ញា

៩ ~ រឿង អាប់ស

រាត្រីកាលស្ងប់ស្ងាត់ សូម្បីតែសត្វក៏សឹងតែមិនហ៊ានស្រែកយំ ដែលហាក់បីដូចជាមានអំណាចអ្វីមួយមកគ្របសង្កត់។ ពន្លឺព្រះចន្ទ បានប្រែក្លាយទៅជាអួរអាប់ ព្រោះមានដុំពពកខ្មៅជាច្រើន បានបាំងបិទធ្វើឲ្យផែនដីប្រែងងឹតសូន្យឈឹង។ ក្រឡេកមកមើលរូបខ្ញុំនាពេលនេះមិនខុសអ្វីពីព្រះចន្ទឡើយ។ ខ្ញុំគ្មានសល់អ្វីទាល់តែសោះក្រៅពីវិបត្តិ និងវិប្បដិសារី មកតាមលងបន្លាចជារៀងរាល់ថ្ងៃ។ រាល់ពេលដែលខ្ញុំ ឮពាក្យថា អង្គការ គឺហាក់បីដូចជាមានអ្វីមកចាប់ទាញអូសខ្ញុំឲ្យនឹកដល់រឿងរ៉ាវអតីតកាលខ្មៅងងឹតភ្លាម។

«ជយោសន្តិភាព» គឺជាពាក្យដែលអង្គការខ្មែរក្រហមស្រែកប្រកាសក្តែងៗ នៅពេលដែលខ្លួនកាន់កាប់អំណាច។ ខ្ញុំខំទុកចិត្តអង្គការដោយមិននឹកស្មានថាលទ្ធផលគឺមានតែខោអាវមួយសម្រាប់ជាប់នឹងខ្លួនសោះ។

ខ្ញុំរស់នៅម្តុំផ្សារទួលទំពូង សង្កាត់លេខ៥។ ខ្ញុំ រស់នៅក្នុងក្រុមគ្រួសារដែលមានជីវភាពធូរធារ មិនធ្លាប់ស្គាល់ភាពលំបាកវេទនាឡើយ។ ឪពុករបស់ខ្ញុំគឺជាគ្រូបង្រៀន ចំណែកឯម្តាយរបស់ខ្ញុំវិញ គឺជាមេផ្ទះ។ ខ្ញុំគិតតែខំរៀនសូត្រជារៀងរាល់ថ្ងៃមិនធ្លាប់ស្គាល់ភាពលំបាកយ៉ាងណានោះទេ។ បន្ទាប់ពីរៀបការរួច ខ្ញុំមានម្តាយក្មេក ជាអ្នកទទួលរ៉ាប់រងបម្រើសព្វគ្រប់បែបយ៉ាង។ សន្តិភាពរបស់អង្គការខ្មែរក្រហម បានបំផ្លិចបំផ្លាញសុភមង្គលរបស់ខ្ញុំខ្ទេចខ្ទីគ្មានសល់។ ម្តាយ ឪពុក បងប្អូន និង សាច់ញាតិរបស់ខ្ញុំ ស្លាប់អស់គ្មាននៅសេសសល់ឡើយ។ ចំណែកខ្ញុំ ត្រូវបានខ្មែរក្រហមជម្លៀសពីទីក្រុងភ្នំពេញទៅនៅម្តុំព្រៃស្លែងជាប់

ផ្លូវជាតិលេខ២។ ជីវិតរបស់ខ្ញុំដូចចកសោត់អណ្តែតកណ្តាលគង្គា គ្មានទីពឹងពាក់ គ្មានដឹងកោះត្រើយ។ ប្តីរបស់ខ្ញុំ ត្រូវខ្មែរក្រហមបំបែកចេញពីខ្ញុំឲ្យទៅរស់នៅឯ គោកចំបក់។ ខ្ញុំរស់នៅជាមួយកូនតូចពីរនាក់ ដែលកូនច្បងរបស់ខ្ញុំមានអាយុ ៣ឆ្នាំ រីឯកូនរបស់ខ្ញុំម្នាក់ទៀត ទើបតែមានអាយុ១ឆ្នាំ។

រំលាយប់មួយ ខ្ញុំហាក់បីដូចជាចម្លែកក្នុងចិត្តភិតភ័យម្នាក់ឯង។ វាហាក់ដូចជាមានអ្វីចង់មកប៉ុនប៉ងសម្លាប់ខ្ញុំ។ សំឡេងសត្វលលកខ្មោចស្រែកយំទ្រហឹង អឺងកងពាសពេញខាងក្រោយផ្ទះរបស់ខ្ញុំ។ យប់ស្ងាត់ឈឹង ឆ្កែចេះតែលូបណ្តាក់ គ្នាកាន់តែខិតជិតផ្ទះខ្ញុំទៅៗ។ ខ្ញុំញ័ររជើងដៃអស់ហើយ ខ្លាចសំឡេងលលកខ្មោច ផង និងនឹកដល់ពាក្យចាស់ៗច្រើនពោលថា ឆ្កែលូខ្មោចដើរផង។ ខ្ញុំនឹកសង្វេគខ្លួន មានម៉ែ មានឪ ប៉ុន្តែត្រូវស្លាប់ចោលអស់ ហើយខ្ញុំមានប្តីដែរ ប៉ុន្តែប្តីត្រូវចាកចេញ ទៅរស់នៅឆ្ងាយពីគ្នា។ ជីវិតខ្ញុំអើយ ម្តេចក៏មកត្រូវវេទនារងកម្មយ៉ាងនេះ។ ខ្ញុំនៅសល់តែកូនពីរនាក់ ដេកលក់យ៉ាងស្រួលមិនដឹងថាថ្ងៃមុខទៅជាយ៉ាងណា ឡើយ។ ខ្ញុំកំពុងតែសញ្ជឹងគិតស្រមើស្រមៃម្នាក់ឯង ស្រាប់តែមានសំឡេងឆ្កែព្រូស តៗគ្នាមកដល់នឹងផ្ទះរបស់ខ្ញុំតែម្តង។ រំពេចនោះ ស្រាប់តែសំឡេងគោះទ្វារឮសូរ «ផាំង! ផាំង! » ហើយមានសំឡេងស្រែកថា «បើកទ្វារ! បើកទ្វារ!»។

ខ្ញុំខំផ្ទៀងស្តាប់ទាំងញ័រផង ភ័យផង បបូរមាត់របស់ខ្ញុំឡើងស្លេកអស់ហើយ រួចក៏សួរតបទៅវិញថា «នរណាគេ? មករកអ្វីទាំងយប់អធ្រាត្រ?»។ សំឡេង មនុស្សប្រុសបានតបមកវិញថា «ខ្ញុំប្តីឯងណា»។ ខ្ញុំខំផ្ទៀងស្តាប់យូរបន្តិចបានដឹង ថា សំឡេងនោះ ពិតជាសំឡេងប្តីរបស់ខ្ញុំមែន។ ខ្ញុំស្ទុះទៅបើកទ្វារឲ្យភ្លាមៗ ព្រោះ ខ្លាចក្រែងមានកងឈ្លបមើលឃើញ។

«ពុទ្ធោ ! ឪវាឯងមិចមកទាំងយប់អាធាត្រចឹង» ខ្ញុំសួរទាំងភ័យបារម្មណ៍។ «មិនឲ្យយប់យ៉ាងម៉េច បើទម្រាំសុំអង្គការមកបាន ខ្ញុំកុហកអង្គការថាមកមើល ឯងឈឺទៀត តើកូនយើងមិចហើយ»? ស្តាប់ប្តីខ្ញុំនិយាយចប់ស្ទើរតែមិនទាន់ ខ្ញុំ ក៏ប្រញាប់ឆ្លើយតបភ្លាមថា «កូនយើងអាតូចក្តៅខ្លួនពេញមួយថ្ងៃមិនបាត់សោះ មិនដឹងត្រូវរកអ្វីឲ្យវាផឹកទេ កូនយើងនៅតូចចឹងជាក់អ្វីចូលក៏ក្អួតដែរ កូនយើង

យំទារបៅតែដោះ ហើយខ្ញុំគ្មានទឹកដោះទេ ខ្ញុំអាណិតកូនណាស់ តែមិនដឹងបានអីឲ្យកូនស៊ីទេ បើរាល់ថ្ងៃនេះ ខ្ញុំខំដើរបេះបោចស្លឹកឈើលាយជាមួយបបរហូបឲ្យតែមានកម្លាំងកំហែង»។ ប្តីរបស់ខ្ញុំបារម្មណ៍ចំពោះកូនខ្លាំងណាស់។ យើងនិយាយគ្នាមិនបានយូរប៉ុន្មានផង គាត់បានប្រាប់ឲ្យខ្ញុំឆាប់ចូលដេកយកកម្លាំងដើម្បីទៅធ្វើការនៅថ្ងៃស្អែក។

រាល់ព្រឹក ខ្ញុំត្រូវងើបពីព្រឹកបន្តិចដើម្បីទៅបុកស្រូវ ហើយរាល់ល្ងាច ពេលប្រជាជនមកពីធ្វើការងារអស់ ខ្ញុំប្រើកូនប្រុសច្បងរបស់ខ្ញុំឲ្យទៅរើសក្បរស្រូវដែលខ្ញុំច្រូតពន្លិចទម្លាក់នៅក្នុងស្រែ។ ខ្ញុំញីស្រូវល្មមតែបកបានទើបយកមកស្ទែតិចៗ កុំឲ្យតែមានដីចូល។ អង្ករមុខ្ញុំមិនដែលខ្វល់នោះទេ។ ក្រៅពីនោះ ខ្ញុំបានបូតយកត្រួយដំឡូងមី ដើមល្អុង និងស្លឹកកប្បាស ផ្សែផ្សំចូលគ្នាគ្រាន់ល្មមអាចហូបបានដើម្បីឲ្យកូនបានឆ្អែត។ មុនពេលចេញទៅធ្វើការងារនៅតាមវាលស្រែ ខ្ញុំរៀបចំទុកដាក់សព្វគ្រប់ឲ្យកូនរួចហើយបានខ្ញុំចេញទៅ។ ម៉ោងសម្រាកបាយថ្ងៃត្រង់ ខ្ញុំឆ្លៀតពេលមកផ្ទះមើលកូនបន្តិច ហើយនៅថ្ងៃនោះ ខ្ញុំបានឃើញបុរសម្នាក់កំពុងតែឈរនៅខាងមុខគ្រែផ្ទះរបស់ខ្ញុំ។ បុរសនោះនិយាយឆ្ការដៃឆ្ការជើង។ ខ្ញុំមិនទុកចិត្តសោះពេលឃើញសកម្មភាពដូច្នេះ។ ខ្ញុំបានដើរយ៉ាងលឿនសំដៅទៅទីនោះភ្លាម។

«លោកបង!» ខ្ញុំនិយាយពីចម្ងាយ «ខ្ញុំភ័យណាស់លោកអើយ មកស្ងាត់ៗខ្ញុំស្មានតែជានរណាគេ»។ «មិចទៅអ្នក ! អ្នកឯងភ័យរឿងអ្វី?» បុរសម្នាក់នោះសួរខ្ញុំ ហើយខ្ញុំបានឆ្លើយតបទៅគាត់វិញថា «មិនឲ្យខ្ញុំភ័យយ៉ាងមិចកើតបង បើជុំៗស្មានតែឪវាមានរឿងអី ខ្ញុំកំពុងតែអត់ស្រួលក្នុងខ្លួនផងលោកបងខ្លាចតែមានរឿងអ្វីកើតឡើងបានចេះតែបារម្ភ ខ្ញុំដើរមកអំបាញ់មិញគ្មានដឹងឈឺមុតជើងមុតដៃនោះទេ»។ «អ្នកអើយមួយៗទៅ ខ្ញុំមកលេងលោកប្អូន ប៉ក់ ខ្ញុំនឹកនាគ្នាពេក យើងមិនដែលបានជួបគ្នាផងរវល់តែការងារនៅក្នុងស្រែ ហើយអស់ពីស្រែមកធ្វើការងារក្នុងប្រឡាយវិញ» ឮគាត់និយាយឈ្មោះប្តីរបស់ខ្ញុំដូច្នេះ ខ្ញុំក៏បានឃាត់គាត់កុំឲ្យនិយាយពីឈ្មោះប្តីរបស់ខ្ញុំភ្លាម ព្រោះខ្ញុំខ្លាចកងឈ្លបដឹងរួចហើយខ្ញុំក៏លាគាត់ទៅមើលកូន។

ខ្ញុំចុះពីលើផ្ទះមកខាងក្រោយ លាងទឹកអង្ករួចឆ្លៀតបេះត្រួយបន្លែផ្អែមមកលាយបាយ ស្រាប់តែឃើញឈ្លបម្នាក់ដើរកាត់ពីក្រោយផ្ទះរបស់ខ្ញុំយ៉ាងរហ័ស។ ខ្ញុំមិនហ៊ានសម្លឹងមើលមុខឈ្លបនោះចំទេ។ ខ្ញុំគិតតែបេះបន្លែឆាប់បានល្មមរួចត្រលប់មកវិញ ព្រោះសំឡេងកូនរបស់ខ្ញុំយំឃ្លានបាយទ្រហឹងពេញផ្ទះ។ ពេលល្ងាចមកពីធ្វើការមកដល់ផ្ទះភ្លាម ខ្ញុំមកមើលកូនខ្ញុំដែលឈឺមុនគេ។ ថ្ងៃនេះកូនរបស់ខ្ញុំដូចជាត្រជាក់អន់ជាងមុនបន្តិច ហើយមុខកូនរបស់ខ្ញុំ មើលទៅឡើងក្រហមដូចធម្មតាវិញ។ ឃើញដូច្នោះ ខ្ញុំហាក់បីដូចជាស្រាកស្រាន្តបានបន្តិច។ បន្ទាប់មក ខ្ញុំបានចុះមកដី និងបានឮសំឡេងពីចម្ងាយស្រែកខ្លាំងដូចមនុស្សកំពុងឈ្លោះប្រកែកគ្នា។ ខ្ញុំស្ទុះទៅមើលឃើញកងឈ្លបចំនួន៣នាក់ កំពុងតែដើរបែកដីហុយសំពោងសំដៅមកត្រង់។ ខ្ញុំច្បាស់ណាស់ថា កងឈ្លបនោះសំដៅមកផ្ទះរបស់ខ្ញុំ។ ផ្ទះរបស់ខ្ញុំស្ថិតនៅចុងគេបង្អស់ ព្រោះខ្ញុំគឺជាប្រជាជន១៧មេសា។ រំពេចនោះ ចិត្តរបស់ខ្ញុំ នឹកគិតទៅដល់សំដីដែលប្តីរបស់ខ្ញុំនិងបងសុក ធ្លាប់បាននិយាយគ្នាថ្ងៃមុនពីរឿងអង្គការ។ នៅពេលនោះ ប្តីរបស់ខ្ញុំ កំពុងតែនៅលើករងខាងក្រោយផ្ទះ ហើយខ្ញុំក៏ស្ទុះទៅប្រាប់រឿង ដែលកងឈ្លបកំពុងតែដើរសំដៅមកផ្ទះរបស់ខ្ញុំ ឲ្យគាត់បានដឹងមុន។ ខ្ញុំបានដេញឲ្យប្តីរបស់ខ្ញុំគេចខ្លួនចេញទៅ។ រំពេចនោះ ប្តីរបស់ខ្ញុំ បានស្ទុះចេញតាមផ្លូវក្រោយផ្ទះកាត់រងថ្នាំ និងចម្ការល្មមបាំងកុំឲ្យកងឈ្លបឃើញបាន។ ប្តីរបស់ខ្ញុំបានចាកចេញទៅបាត់ហើយ នៅសល់តែខ្ញុំមិនដឹងគិតរកអីមកនិយាយដោះសានឹងកងឈ្លបនោះទេ។ ខ្ញុំល្ងង់ក៏ល្ងង់។ ខ្ញុំឈរភ័យតែឯង រួចរត់មកក្នុងផ្ទះអង្គុយឱបកូនតាំងចិត្តធ្វើហាក់ដូចជាគ្មានអ្វីកើតឡើង។ មួយស្របក់ក្រោយមក ស្រាប់តែឮសំឡេងស្រែកគំហកហៅខ្លាំងៗពីក្រៅរបងផ្ទះថា «មិត្តនារី! ប្តីទៅណាហើយ»។ ខ្ញុំខំកុហកកងឈ្លបឡើងញ័រមាត់ថា «អត់ទេមិត្តបង ប្តីរបស់ខ្ញុំមិនបានមកទេ គាត់នៅឯគោកចំបក់យូរហើយមិនដែលមកទេ»។ កងឈ្លបនោះស្រែកគំរាមខ្ញុំទៀតថា «កុំឲ្យតែខ្ញុំដឹងណាមិត្ត ខ្ញុំនឹងរាយការណ៍ស្នើប្តីមិត្តយកទៅកសាងហើយ មានអ្នករាយការណ៍ឲ្យខ្ញុំច្បាស់ណាស់ថា អាប៉ក់ និងអាសុក វាប្រឆាំងនឹងអង្គការ វាហ៊ានតិះដៀលថា អង្គការមិនល្អឲ្យវាស៊ីមិនគ្រប់។ មិត្តឯងតែខ្ញុំដឹងខ្ញុំហៅទៅកសាងទាំងគ្រួសារ»។

កងឈ្លបនិយាយតែប៉ុណ្ណឹងរួចចេញទៅវិញបាត់។ ខ្ញុំទន់អស់ជើងដៃ នឹកស្រណោះអាសូរប្តី និងកូននៅតូចៗ ដែលគ្មានដឹងអ្វីទាំងអស់។ ខ្ញុំមិនចង់ឲ្យកូនអត់ឪពុកហៅ ហើយក្លាយទៅជាកូនកំព្រានោះទេ។ ខ្ញុំបានរៀបចំឲ្យកូនដេករួច ខ្ញុំក៏ទៅផ្ទះគណៈស្រុក ព្រោះគាត់តាំងពីដើមមកឧស្សាហ៍ចេញចូលផ្ទះឪពុករបស់ខ្ញុំណាស់។ ខ្ញុំដើរបណ្តើរកនឹកពាក្យនិយាយបណ្តើរ ព្រោះខ្លាចគាត់ចាប់ថ្នាក់ពាក្យខ្ញុំបាន និងមិនព្រមជួយដល់ខ្ញុំ។ មកដល់ត្រឹមជណ្តើរផ្ទះរបស់គណៈស្រុក ខ្ញុំស្រែកពីក្រោមទៅថា « លោកមា! លោកមា!»។ លោកមាបានសួរខ្ញុំយ៉ាងរាក់ទាក់ថា «នរណាគេហ្នឹង! ខ្ចា នាងឯងមានការអីព្រលប់ហើយ»។ ខ្ញុំមកផ្ទះគាត់គឺដើម្បីសុំឲ្យគាត់ជួយដល់ប្តីរបស់ខ្ញុំ ដែលកងឈ្លបនោះមានបំណងយកប្តីរបស់ខ្ញុំទៅកសាងនៅពេលដែលគាត់និយាយជាមួយ បងសុក អំពីអង្គការ។ នៅពេលដែលបានដឹងអំពីស្ថានភាពនេះហើយ គាត់បានសន្យាថានឹងជួយប្តីរបស់ខ្ញុំ ប៉ុន្តែខ្ញុំត្រូវតែយកថ្នាំឲ្យគាត់។ និយាយរួចហើយ គាត់បានប្រាប់ខ្ញុំត្រលប់មកផ្ទះវិញ។

រយៈពេលប្រហែលកន្លះខែក្រោយមក ម៉ោងជិត៧យប់ ខ្ញុំសម្លឹងមើលពីក្នុងផ្ទះចេញទៅក្រៅ ស្រាប់តែឃើញស្រមោលមនុស្សស្ទង់ៗដើរចូលមកក្នុងផ្ទះរបស់ខ្ញុំ។ ភ្លាមៗនោះស្រាប់តែឮសំឡេងលោកបងសុក ចូលមកហើយនិយាយខ្សឹបៗថា «អ្នកឯងត្រូវរឹងប៉ឹងឡើង ប្តីអ្នកឯងស្លាប់ហើយ គាត់ដួលស្លាប់នៅក្នុងការដ្ឋានគោកចំបក់ ខ្ញុំបានបញ្ចុះសាកសពគាត់ត្រឹមត្រូវហើយ អ្នកកាត់ចិត្តនឹកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មាតា បិតា ឧទ្ទិសកុសលឲ្យគាត់ផង»។ និយាយចប់ បងសុក បានដើរចេញទៅវិញបាត់ទាំងខ្ញុំមិនទាន់បានស្តីតបតទៅវិញសូម្បីតែមួយម៉ាត់។ ពាក្យសំដីរបស់បងសុកនិយាយមកទាំងអម្បាលម៉ានដូចជាអារុធដ៏មុតមកពុះទ្រូងរបស់ខ្ញុំ។ អ្វីដែលខ្ញុំខ្លាចបំផុត អ្វីដែលខ្ញុំស្អប់បំផុត គឺនៅទីបំផុតបានធ្លាក់មកលើខ្ញុំទាំងអស់។ ខ្ញុំគ្មានជម្រើសអ្វីទៀតទេ គឺមានតែយំ។ ខ្ញុំយំ ព្រោះកូនខ្ញុំក្លាយជាក្មេងកំព្រាហើយ។ យប់នេះ គឺជាយប់មួយដែលមានរយៈពេលយូរជាងយប់ណាៗទាំងអស់ និងជាយប់មួយដែលខ្ញុំមិនអាចបំភ្លេចបានពេញមួយជីវិតរបស់ខ្ញុំ។ អ្វីដែលខ្ញុំត្រូវធ្វើបន្តទៅទៀត គឺខ្ញុំត្រូវតែខំតាំងចិត្តប្រឹងកាត់ក្តី

ទុក្ខសោកដើម្បីរស់នៅសម្រាប់កូនៗរបស់ខ្ញុំ។ ខ្ញុំខំឆ្អេចភ្នែកសម្ងំដេកខ្លាចងើបមិនទាន់ទៅធ្វើការនៅថ្ងៃស្អែក ប៉ុន្តែទឹកភ្នែករបស់ខ្ញុំ ចេះតែបន្តហូរចុះមកឡើងក្តៅគគុក។ ពេលព្រឹកឡើង ខ្ញុំបើកភ្នែកមិនរួចសោះ ហើយនៅពេលដែលខ្ញុំកាន់តែប្រឹងបើកភ្នែកខ្លាំងពេក គឺធ្វើឲ្យខ្ញុំកាន់តែឈឺ។ ថ្ងៃនេះខ្ញុំទៅធ្វើការមិនរួចទេ។ ខ្ញុំបានផ្តាំតាមសមមិត្តផ្សេងទៀតប្រាប់ទៅប្រធានសហការណ៍កុំឲ្យយកទោសខ្ញុំ។ យប់នេះ ភ្នែករបស់ខ្ញុំឈឺទ្វេដងសឹងតែស្រែកយំ។ ខ្ញុំបន់ឲ្យតែភ្លឺឆាប់ៗនឹងអាលទៅរកថ្នាំមកលេប។ ខ្ញុំបានយកក្រមាពូតទឹកស្អំកែវភ្នែកជាបណ្តោះអាសន្នសិន។ នៅពេលព្រឹកឡើង ភ្នែករបស់ខ្ញុំ ក៏បានធូរគ្រាន់ជាងមុន ប៉ុន្តែផ្ទះរបស់ខ្ញុំគ្មានសេសសល់អង្ករទេ ហើយខ្ញុំទៅណាក៏មិនរួចដែរ។ ដោយសារតែគ្មានអង្ករហូបទើបខ្ញុំបានប្រើកូនប្រុសច្បងរបស់ខ្ញុំឲ្យយកកាវត្រចៀករបស់ខ្ញុំទៅដូរយកអង្ករពីប្រជាជននៅឯចុងភូមិ។ ខ្ញុំនៅផ្ទះចេះតែសម្ងំដេកមើលកូនឈឺផង និងឈឺខ្លួនឯងផង។ ខ្ញុំចេះតែទន្ទឹងចាំមើលផ្លូវកូនច្បងរបស់ខ្ញុំមិនឃើញមក ណាមួយកូនតូចរបស់ខ្ញុំចេះតែយំ។ ខ្ញុំសម្ងំដេក ព្រោះកូនខ្ញុំមិនក្តៅខ្លួនទៀតទេ។ ខ្ញុំដេករៀបនឹងលក់ទៅហើយ ស្រាប់តែសំឡេងបងស្រីជិដូនមួយរបស់ខ្ញុំស្រែកពីខាងក្រៅផ្ទះឲ្យខ្ញុំបើកទ្វារ។ ខ្ញុំងើបហើយស្រែកប្រាប់គាត់ឲ្យចូលមកទ្វារអត់បិទទេ។ បងស្រីជិដូនមួយរបស់ខ្ញុំចូលមកដល់រានខាងមុខផ្ទះភ្លាម គាត់និយាយផងអួលដើមកថា «ខ្ជា !កូននាងឯង គេចាប់វាបាននៅឯចម្ការពោត»។ ខ្ញុំគ្រាន់តែឮភ្លាម ខ្ញុំចង់សន្លប់ភ្លាម។ ទឹកភ្នែករបស់ខ្ញុំហូររហាម ដោយក្នុងចិត្តនឹកគិតថាខ្ញុំត្រូវបាត់បង់កូនម្នាក់ទៀតហើយ។ ម្សិលមិញ ប្តីរបស់ខ្ញុំបានស្លាប់ ហើយថ្ងៃនេះកូនប្រុសរបស់ខ្ញុំ ត្រូវកងឈ្លបចាប់ខ្លួនបាន។ ខ្ញុំប្រើកូនម្តងនេះដូចប្រើកូនឲ្យទៅស្លាប់។ បងជីដូនមួយរបស់ខ្ញុំបានបន្តទៀតថា កូនរបស់ខ្ញុំមិនទាន់ស្លាប់ទេ ហើយពេលនេះកូនរបស់ខ្ញុំនៅជាមួយពួកកងឈ្លប។ ពួកឈ្លបបានឲ្យកូនរបស់ខ្ញុំហូបគ្រប់គ្រាន់ណាស់។ កូនរបស់ខ្ញុំបានប្រាប់កងឈ្លបថា វាគ្មានម៉ែឪទេ ហើយរើសបានកាវត្រចៀកតាមផ្លូវមក។ ឮកូនខ្ញុំប្រាប់ដូច្នោះ ពួកឈ្លបអាណិតបានឲ្យអាហារ និងនៅជួយចាំពោតជាមួយឈ្លប។ ខ្ញុំឮអីចឹងហើយ ខ្ញុំត្រេកអរណាស់។

ខ្ញុំញញឹមទាំងទឹកភ្នែករហាមពេញមុខ។ កូនរបស់ខ្ញុំឆ្លាតណាស់ ចេះដោះសារយករួចខ្លួនបាន។ ខ្ញុំមិននឹកស្មានថាកូនរបស់ខ្ញុំអាចកុហកកងឈ្លបថាគ្មានម៉ែគ្មានឪដូច្នេះសោះ។ ខ្ញុំមិនខឹងនឹងសម្តីកូនទេ។ កូនរបស់ខ្ញុំនៅមានជីវិត គឺខ្ញុំសប្បាយចិត្តណាស់ទៅហើយ។ នៅពេលនោះ បងស្រីជីដូនមួយរបស់ខ្ញុំ បានឡើងមកលើផ្ទះរបស់ខ្ញុំ ហើយបានស្រែកយ៉ាងខ្លាំងៗថា «ខ្ញានាងឯងមកមើលនេះមកឲ្យលឿននាង»។ «ខ្ញុំមើលមិនឃើញទេបង ព្រោះខ្ញុំឈឺភ្នែក តើមានរឿងអ្វីបងបានភ្ញាក់ផ្អើលខ្លាំងម្ល៉េះបង ប្រយ័ត្នភ្ញាក់កូនខ្ញុំណាបង» ខ្ញុំតបទៅបងជីដូនមួយរបស់ខ្ញុំដែលកំពុងតែស្រែកឮៗពេញផ្ទះរបស់ខ្ញុំ។ «កូននាងឯងដេកងាប់តាំងពីអង្កាល់បានជាស្រមោចស៊ីភ្នែកអស់ដូច្នឹងនាង» បងជីដូនមួយខ្ញុំសួរ ព្រោះខ្ញុំខ្លួនឯងមិនដឹងថាកូនតូចរបស់ខ្ញុំស្លាប់ទាល់តែសោះ។ ខ្ញុំគ្រាន់តែដឹងថាកូនរបស់ខ្ញុំព្រឹកមិញនេះបានត្រជាក់សាច់ធម្មតាជាងពីម្សិលមិញទៅហើយ។ បងជីដូនមួយរបស់ខ្ញុំប្រាប់ខ្ញុំថា កូនតូចរបស់ខ្ញុំប្រហែលជាក្តៅខ្លួនខ្លាំងពេករហូតដល់អាប់សៃស្លាប់ ហើយទៅត្រជាក់សាច់វិញយ៉ាងម៉េចទៅ។

ខ្ញុំអស់ព្រលឹងពីខ្លួនបន្ទាប់ពីបងជីដូនមួយរបស់ខ្ញុំប្រាប់យ៉ាងដូច្នេះ។ ខ្ញុំឈឺចាប់ហួសថ្លែងគ្មានអ្វីអាចមកប្រៀបផ្ទឹមបានទេ។ អម្បាញ់មិញ ខ្ញុំទើបតែសើចសប្បាយដោយនឹកគិតថា កូនច្បងរបស់ខ្ញុំសុខសប្បាយ ប៉ុន្តែបែរជាកូនតូចរបស់ខ្ញុំស្លាប់ទៅវិញ។ ឱលោកាអើយ! ពិភពលោកនេះពិតជាសាហាវឃោរឃៅដាក់ទោសខ្ញុំខ្លាំងណាស់ម្ល៉េះ។ ខ្ញុំមិនអាចធ្វើអ្វីបានទេ ក្រៅពីលើកសាកសពកូនបីត្រកងផ្ទប់នឹងទ្រូងទួញទុក្ខសោក។ នេះហើយជីវិតរបស់ខ្ញុំ។

ចប់

១០
រឿងល្ខោយសឹក

អ្នកនិពន្ធ ៖ ច័ន្ទ មុនី

១០ ~ រឿង ឈ្លើយសឹក

ក្រោយពេលរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បន្ទាប់ពីខេត្តទាំង៤ នៅភូមិភាគឦសានគឺខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ត្រូវបានកាន់កាប់ដោយកងទ័ពខ្មែរក្រហម ឪពុករបស់ខ្ញុំឈ្មោះ សំ ទុំ ដែលជាអតីតទាហានធ្វើការនៅក្នុងទីរួមខេត្តមណ្ឌលគិរី បានសុំចុះចូលជាមួយកងទ័ពខ្មែរដោះ(កងទ័ពខ្មែរក្រហម)។ ក្រោយមក ឪពុករបស់ខ្ញុំ បាននាំប្រពន្ធ និងកូនចំនួន ៦នាក់ មករស់នៅជាប្រជាជនសាមញ្ញនៅក្នុងភូមិសណ្តាន់ ឃុំសណ្តាន់ ស្រុកសំបូរ ខេត្តក្រចេះ វិញ។

លុះមកដល់ឆ្នាំ១៩៧៥ ក្រោយពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ រួច ខ្មែរក្រហម បានធ្វើការប្រមែប្រមូលកងកម្លាំងប្រដាប់អាវុធរួមមាន ប៉ូលិស និងទាហាន ដែលបានចូលសារភាពកាលពីឆ្នាំ១៩៧០ នៅគ្រប់ទីកន្លែងទាំងអស់ក្នុងខេត្តក្រចេះ រួចបញ្ជូនឲ្យរស់នៅក្នុងតំបន់ព្រៃដាច់ស្រយាលមួយឈ្មោះ «ស្រែត្រែង» ដែលស្ថិតនៅដាច់ឆ្ងាយសង្វែងពីភូមិរបស់ប្រជាជនរស់នៅ។ ពួកគេបានហៅអ្នកទាំងអស់នោះថាជា «ពួកឈ្លើយសឹក» ដែលក្នុងនោះមានក្រុមគ្រួសាររបស់ខ្ញុំដែរ។

ទៅដល់ទីនោះភ្លាម ប្រជាជនម្នាក់ៗមានការភិតភ័យនិងព្រួយបារម្ភពីសុវត្ថិភាពខ្លាំងណាស់ ព្រោះយើងដឹងខ្លួនថា អង្គការប្រាកដជាមានចេតនាមិនល្អទើបយកយើងឲ្យមករស់នៅក្នុងព្រៃរហោឋានបែបនេះ។ ប្រជាជនម្នាក់ៗឆ្ងល់ថា នៅក្នុងស្រុកសំបូរទាំងមូល មិនខ្វះទេដីស្រែចម្ការសម្រាប់ឲ្យប្រជាជនធ្វើ តើចុះ

ហេតុអ្វីបាននាំប្រជាជនមកនៅទីស្ងាត់ជ្រងំយ៉ាងដូច្នេះ។ នេះគឺជាចេតនាចង់ធ្វើបាបរបស់ខ្មែរក្រហមទៅលើអតីតមន្ត្រីរាជការនិងកងកម្លាំងពីរបបចាស់។ ខ្មែរក្រហមគិតថា ប្រសិនបើទុកឲ្យប្រជាជនទាំងនោះរស់នៅក្នុងភូមិ រស់នៅតាមបណ្តោយដងទន្លេមេគង្គ ឬដងព្រែកធំៗ ដែលស្ថិតនៅក្នុងស្រុកសំបូរ នោះប្រជាជននឹងមានភាពងាយស្រួលក្នុងការរស់។ ដូច្នេះហើយបានជាខ្មែរក្រហមបញ្ជូនពួកយើងទៅរស់នៅតំបន់ដែលគ្មានអ្វីទាល់តែសោះ ក្នុងចេតនាចង់ធ្វើបាបឲ្យយើងស្លាប់នៅទីនោះ។

មិនបង្អង់យូរ អង្គការបានប្រមែប្រមូល និងបញ្ជូនពួកឈ្លើយសឹកឲ្យចូលមកនៅស្រែត្រែងជាបន្តបន្ទាប់រហូតដល់មានចំនួនសរុបជាង ៤៥០គ្រួសារ។ ពេលនោះ អង្គការបានបែងចែកដីព្រៃឲ្យប្រជាជនសង់ផ្ទះ និងខ្ទមតូចៗ ដើម្បីរស់នៅរៀងៗខ្លួន ថែមទាំងបានធ្វើការបែងចែកអង្ករតិចតួច ឲ្យយកទៅចម្អិនហូបចុកតាមគ្រួសារនីមួយៗ។ អង្គការ បានឲ្យប្រជាជនទាំងអស់ ធ្វើការកាប់គាស់ រុករានដីព្រៃនោះ ដើម្បីយកធ្វើជាស្រែចម្ការជាលក្ខណៈសមូហភាពដែរ។ ដោយសារតែអង្គការផ្តល់អង្ករបានតិចតួចពេក ប្រជាជននាំគ្នាខិតខំសន្សំសំចៃជាទីបំផុត។ គ្រប់ក្រុមគ្រួសារទាំងអស់ សុទ្ធតែនាំគ្នាហូបបបរវាវជារៀងរាល់ថ្ងៃ ព្រោះនៅទីនោះ គេពុំអាចរកបន្លែឬស្លឹកឈើអ្វីផ្សេងៗ យកមកលាយជាមួយនឹងបបរបានឡើយ។ មិនយូរប៉ុន្មាន វាបានធ្វើឲ្យប្រជាជន ជាពិសេសកុមារតូចៗ ចាប់ផ្តើមធ្លាក់ខ្លួនឈឺស្គមស្គាំង បាក់កម្លាំង និងកើតជំងឺគ្រុនចាញ់ ហើយស្លាប់ជាបណ្តើរៗ ជាហូរហែ។

ដោយទ្រាំពុំបាននឹងភាពអត់ឃ្លានដ៏ធ្ងន់ធ្ងរនេះ ថ្ងៃមួយប្អូនស្រីរបស់ខ្ញុំឈ្មោះ ច័ន្ទ ប៊ុណ្ណា ដែលជាកូនទី២ នៅក្នុងគ្រួសារបានដាច់ចិត្តលបលួចចេញពីភូមិទៅរកសុំអង្ករពីប្រជាជនមូលដ្ឋានដែលធ្លាប់រាប់អានជាមួយក្រុមគ្រួសាររបស់ខ្ញុំនៅឯភូមិសណ្តាន់។ ថ្ងៃនោះ ក្រៅពីសុំអង្ករបានចំនួនប្រហែល៧កំប៉ុង ផ្លែឈើ និងនំចំណីបន្តិចបន្តួចទៀតនោះ ប្អូនស្រីរបស់ខ្ញុំ ក៏បានជួបនឹងយុវនារីម្នាក់និងប្អូនរបស់គាត់។ អ្នកទាំងពីរនេះ សុទ្ធតែជាអ្នកបម្រើការងារនៅក្នុងជួរអង្គការជាយូរឆ្នាំមកហើយ។ ពេលដែលពួកគេបានដឹងថា ប្អូនស្រី និងក្រុមគ្រួសាររបស់ខ្ញុំ

ត្រូវបានអង្គការបញ្ជូនទៅនៅឯស្រែត្រែងភ្លាម ពួកគេមានការភ្ញាក់ផ្អើល និងសម្តែងនូវក្តីអាណិតអាសូរយ៉ាងខ្លាំង។ ពួកគេបានលួចនិយាយបង្ហើបប្រាប់ប្អូនរបស់ខ្ញុំថា «អង្គការមានការស្អប់ និងគំនុំគំកួនមកលើប្រជាជន ដែលអង្គការបញ្ជូនឲ្យទៅនៅស្រែត្រែង ទាំងអស់ខ្លាំងណាស់ ព្រោះអង្គការថា ពួកប្រជាជនទាំងនោះគឺជាពួកជិះជាន់គេ ជាពួកបម្រើឲ្យពួកកាន់អំណាចផ្តាច់ការ មូលធន សក្តិភូមិ ដែលជាខ្មាំងសត្រូវរបស់អង្គការ»។ ពួកគេទាំងពីរ បានណែនាំបញ្ចុះបញ្ចូលឲ្យប្អូនស្រីរបស់ខ្ញុំ រិះរកវិធីធ្វើយ៉ាងណា អាចចាកចេញឲ្យរួចផុតពីភូមិឈ្លើយសឹកស្រែត្រែងនេះឲ្យបានឆាប់ ហើយត្រូវសុំអង្គការមកនៅក្នុងជួរជាមួយគាត់ ឬក៏នៅតាមកងផ្សេងៗទៀត ដែលអង្គការកំពុងតែរៀបចំបង្កើតថ្មីនៅក្នុងឃុំ ដើម្បីឲ្យបានរួចផុតពីការប៉ុនប៉ងសងសឹក និងធ្វើទុក្ខបុកម្នេញផ្សេងៗ។

ពេលត្រលប់មកដល់ផ្ទះវិញ ប្អូនស្រីរបស់ខ្ញុំ បានយករឿងដែលឃុវតីទាំងពីរនោះ ប្រាប់ម្តាយរបស់ខ្ញុំសព្វគ្រប់ ហើយវាក៏បានទទូចសុំម្តាយរបស់ខ្ញុំដើម្បីទៅចូលជួរជាមួយគេឆាប់ៗនេះ។ មុនដំបូង ម្តាយរបស់ខ្ញុំ ពុំយល់ព្រមទាល់តែសោះ ព្រោះគាត់មិនបានយល់ដឹងអំពីបញ្ហាជួរ ឬកងរបស់អង្គការអ្វីនោះទេ។ រីឯ ប្អូនស្រីរបស់ខ្ញុំក៏នៅក្មេងខ្ចីទៀត។ ម្តាយរបស់ខ្ញុំ ធ្លាប់មានបញ្ហាព្រាត់ប្រាស់បែកបាក់ពីកូនចំនួន ២នាក់ទៅហើយកាលពីឆ្នាំ១៩៧០។ គាត់រាងចាល ខ្លាចមានបញ្ហាបែកបាក់ដូច្នោះទៀត។ ប៉ុន្តែក្រោយមក ដោយហាមឃាត់ប្អូនស្រីរបស់ខ្ញុំមិនស្តាប់ ហើយស្របគ្នានោះ គាត់ក៏បានដឹងថា អង្គការកំពុងបង្កើតកងចល័តឃុវតីថ្មីទៀតនៅក្នុងឃុំ ទើបម្តាយរបស់ខ្ញុំ ដាច់ចិត្តយល់ព្រមឲ្យប្អូនស្រីរបស់ខ្ញុំទៅចូលក្នុងកងចល័តនោះទៅ។

មកនៅក្នុងកងចល័តបានប្រមាណជិត១ខែ ដោយដឹងច្បាស់ថា ជីវភាពរស់នៅក្នុងកងចល័តមាន លក្ខណៈល្អប្រសើរជាងការរស់នៅក្នុងភូមិ ជាពិសេសការហូបចុក ប្អូនស្រីរបស់ខ្ញុំ ក៏ប្រញាប់ប្រញាល់សុំច្បាប់ទៅលេងក្រុមគ្រួសារភ្លាម។ បំណងសំខាន់របស់ប្អូនស្រីរបស់ខ្ញុំ គឺដើម្បីទៅនាំយកប្អូនប្រុសទី៤របស់ខ្ញុំ ឈ្មោះច័ន្ទ សុផល ឲ្យមកចូលក្នុងកងកុមារឃុំ ដែលអង្គការទើបតែបង្កើត។ ប៉ុន្តែ

នៅពេលប្អូនស្រីរបស់ខ្ញុំ និយាយប្រាប់ពីរឿងនេះភ្លាម ម្តាយរបស់ខ្ញុំ បានបដិសេធយ៉ាងដាច់អហង្ការភ្លាមៗ។ គាត់និយាយថា គាត់មិនអាចឲ្យកូនប្រុសរបស់គាត់ចាកចេញឆ្ងាយពីរូបគាត់ទៀតទេ។ គាត់អាណិតកូនខ្លាំងណាស់ ព្រោះកូនប្រុសរបស់គាត់នៅក្មេងទើបតែមានអាយុ១២ឆ្នាំតែប៉ុណ្ណោះ ពុំទាន់ចេះមើលថែខ្លួនឯងបាននៅឡើយ។ លុះស្អែកឡើងនៅពេលប្អូនស្រីរបស់ខ្ញុំរៀបចំខ្លួន ដើម្បីវិលត្រលប់ទៅកងចល័តវិញ ម្តាយរបស់ខ្ញុំ បានស្រាវឱបផង យំផងរួចនិយាយផ្តែផ្តាំថា «បើយើងវេទនាអត់ឃ្លានយ៉ាងហ្នឹង តើយើងនឹងអាចទ្រាំរស់ជីវិតបានយូរប៉ុន្មានទៀតទៅ? ម៉ែព្រួយបាម្តខ្លាំងណាស់ ខ្លាចតែមិនបានជួបមុខកូនៗទៀតទេ»។

នៅក្នុងរដូវវស្សាឆ្នាំ១៩៧៦ ប្រជាជននៅភូមិស្រែត្រែង អត់ឃ្លានតឹតតែខ្លាំងទៅៗ។ ម្តាយរបស់ខ្ញុំ បានបាក់កម្លាំងទ្រុឌទ្រោមនិងសុខភាពធ្លាក់ដុនជាបយ៉ាប់ឃឺនឡើងៗ។ គាត់មានរូបរាងស្គាំងស្គមខ្លាំងណាស់។ ថ្ងៃមួយ ពេលដែលម្តាយនិងប្អូនស្រីទី៥របស់ខ្ញុំ កំពុងតែដើរទៅចម្ការ ដើម្បីរកបន្លែយកមកលាយបបរហូប គាត់បានដួលទាំងដំហរផ្តាប់មុខទៅលើដីនៅពាក់កណ្តាលផ្លូវក្រោកលែងរួចតែម្តង។ ចំណែកប្អូនស្រីរបស់ខ្ញុំ ដែលមានអាយុទើបតែ៩ឆ្នាំនោះ ពុំអាចជួយម្តាយរបស់ខ្ញុំបានឡើយ។ វាបានរត់មកហៅគេឯងឲ្យទៅជួយម្តាយរបស់ខ្ញុំភ្លាម។ វាក៏បានជួបជាមួយបុរសពីរនាក់នៅតាមផ្លូវ។ បុរសទាំងពីរនោះ ក៏បានមកជួយយកម្តាយរបស់ខ្ញុំ ហើយនាំគ្នាជួយគ្រាហូតមកដល់ផ្ទះវិញ។ ចាប់ពីពេលនោះមក ម្តាយរបស់ខ្ញុំ ធ្លាក់ខ្លួនឈឺគ្រុនក្តៅយ៉ាងខ្លាំង។ ឪពុករបស់ខ្ញុំ បានប្រញាប់ប្រញាល់ទៅរាយការណ៍ជូនប្រធានសហករណ៍ ហើយបានស្នើសុំឲ្យជួយបញ្ជូនម្តាយរបស់ខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យឃុំ។ ប្រធានសហករណ៍ បានឯកភាពយល់ព្រមតាមសំណើឪពុករបស់ខ្ញុំ ប៉ុន្តែប្រធានសហករណ៍នោះ បានប្រាប់ឪពុករបស់ខ្ញុំថាឲ្យរង់ចាំសិន ព្រោះរទេះគោកំពុងជាប់រវល់ការងារសមូហភាព។ យើងបានរង់ចាំអស់រយៈពេល ១ថ្ងៃ ១យប់ គ្មានរទេះគោណាមកដឹកម្តាយរបស់ខ្ញុំសោះ។ ឪពុករបស់ខ្ញុំ រត់ទៅជួបប្រធានសហករណ៍ម្តងទៀត។ ឪពុករបស់ខ្ញុំ បាននិយាយរៀបរាប់ប្រាប់ប្រធានសហករណ៍ស្ទើរតែពុំទាន់ចប់ប្រយោគផង ក៏ត្រូវប្រធានសហករណ៍នោះ

ស្តីបន្ទោសឲ្យយ៉ាងគំរោះគំរើយខ្លាំងៗដាក់គាត់វិញថា «ករណីប្រពន្ធរបស់មិត្តឯងឈឺ គឺជារឿងបុគ្គល អង្គការមិនដោះស្រាយរឿងបុគ្គលទៅតាមទំនើងចិត្តរបស់មិត្តឯងបានទេ ព្រោះការងារសមូហភាពសំខាន់ណាស់»។ ឮដូច្នោះហើយ ឪពុករបស់ខ្ញុំ ក៏ប្រញាប់វិលត្រលប់ទៅផ្ទះវិញភ្លាម។ គាត់បានទ្រាំរង់ចាំរទេះគោបន្តទៅទៀតរហូតដល់ពេលរសៀល។ ដោយសង្កេតឃើញស្ថានភាពជំងឺម្តាយរបស់ខ្ញុំកាន់តែធ្ងន់ធ្ងរទៅៗ ឪពុករបស់ខ្ញុំក៏រត់ទៅជួបប្រធានសហករណ៍ម្តងទៀត ហើយបាននិយាយអង្វរករថា «ប្រសិនបើរទេះគោរបស់សហករណ៍នៅតែជាប់រវល់ទៀត តើខ្ញុំអាចស្នើសុំកម្លាំងពីអង្គការតែម្នាក់ ដើម្បីឲ្យជួយជាកម្លាំងសែងយកប្រពន្ធរបស់ខ្ញុំទៅកាន់មន្ទីរពេទ្យបានទេ ព្រោះប្រពន្ធរបស់ខ្ញុំ មានសុខភាពកាន់តែមិនស្រួលខ្លាំងហើយ?»។ ឮដូច្នោះ ប្រធានសហករណ៍បានប្រាប់ឲ្យឪពុករបស់ខ្ញុំត្រលប់ទៅរៀបចំខ្លួនទៅដើម្បីគេឲ្យរទេះគោទៅដឹកម្តាយរបស់ខ្ញុំ។ ឮដូច្នោះ ឪពុករបស់ខ្ញុំសប្បាយចិត្តណាស់ ក៏ត្រលប់មកផ្ទះរៀបចំខ្លួនចាំរទេះគោទាំងអន្ទះសា។

យើងចាំរហូតដល់ល្ងាច ព្រះអាទិត្យស្ទើរតែលិចបាត់ទៅហើយ ទើបឃើញរទេះគោបរមកដល់។ ពេលនោះ អង្គការមិនឲ្យឪពុករបស់ខ្ញុំទៅជាមួយម្តាយរបស់ខ្ញុំទេ ដោយបានបញ្ជាក់ថា «មិត្តឯងអត់ទៅណាបានទេ ព្រោះប្រពន្ធកូនរបស់មិត្តឯងឈឺទាំងអស់គ្នា អត់មានអ្នកណាធ្វើការកើត ក្រៅពីមិត្តឯងទេ ដូច្នេះហើយ មិត្តឯងត្រូវតែនៅដើម្បីទទួលខុសត្រូវការងារជូនអង្គការ»។ ដោយបារម្មណ៍ពីស្ថានភាពជំងឺរបស់ប្រពន្ធកូនខ្លាំងពេក ឪពុករបស់ខ្ញុំបានស្នើសុំគេទៀតថា «ខ្ញុំនឹងវិលត្រលប់មកកាន់ភូមិវិញភ្លាម នៅពេលដែលខ្ញុំជូនអ្នកជំងឺដល់មន្ទីរពេទ្យឃ្លាតរាល់»។ ប៉ុន្តែអង្គការបានបដិសេធទាំងស្រុងចំពោះពាក្យអង្វរកររបស់ឪពុករបស់ខ្ញុំ។ ឪពុករបស់ខ្ញុំទប់ចិត្តលែងបាន ក៏បាននិយាយចចេសតវ៉ាជាមួយអង្គការដោយឥតខ្លាចក្រែងថែមទៀតថា «ប្រពន្ធរបស់ខ្ញុំឈឺធ្ងន់យ៉ាងនេះហើយ ខ្ញុំត្រូវតែទៅ ទោះបីជាអង្គការស្តីបន្ទោសខ្ញុំយ៉ាងណា ក៏ខ្ញុំសុខចិត្តទទួលដែរ»។ ឮសម្តីឪពុករបស់ខ្ញុំនិយាយយ៉ាងដូច្នេះ ប្រធានសហករណ៍ មានការខឹងក្រេវក្រោធយ៉ាងខ្លាំង ហើយបានស្រែកគំរាមឲ្យឪពុករបស់ខ្ញុំថា គេនឹងរាយការណ៍ភ្លាមទៅឲ្យកង

សន្តិសុខ ដើម្បីឲ្យមកយកឪពុករបស់ខ្ញុំទៅកម្ទេចចោលភ្លាមៗ។ ពេលនោះ ក្មួយប្រសាឪពុករបស់ខ្ញុំឈ្មោះ សោរ បានខិតខំនិយាយអង្វរជំនួសឪពុករបស់ខ្ញុំយ៉ាងយូរ ទើបគេសុខចិត្តលើកលែងឲ្យ។ ចំណែកម្តាយ និងកូនៗ ត្រូវបានរទេះគោដឹកយកទៅកាន់មន្ទីរពេទ្យនៅពេលព្រលប់នោះទៅ។

នៅតាមផ្លូវចេញពីភូមិបានចម្ងាយប្រមាណជា ៣គីឡូម៉ែត្រ ភ្លៀងក៏បានបង្អុរធ្លាក់មកជាប់រហូត ធ្វើឲ្យអ្នកដំណើរទាំងអស់ទទឹកខ្លួនជោកគ្រប់ៗគ្នា។ លុះធ្វើដំណើរបានទៅដល់ជិតមន្ទីរពេទ្យឃុំ ទើបអ្នកបរទេះគោ ដឹងថាម្តាយរបស់ខ្ញុំបានស្លាប់បាត់ទៅហើយ។ លុះស្អែកឡើង ដំណឹងមរណភាពម្តាយរបស់ខ្ញុំ ក៏បានលេចឮពាសពេញភូមិ។ ឪពុករបស់ខ្ញុំ មានការអាណិតអាសូរប្រពន្ធពន់ពេក។ រហូតដល់ល្ងាចចប់ម៉ោងការងារ ទើបគាត់ហ៊ានទៅជួបអង្គការ ដើម្បីសុំច្បាប់ចំនួន ១ថ្ងៃ ទៅមើលពួកកូនៗ ដែលនៅមន្ទីរពេទ្យ។ ប្រធានសហករណ៍ បានបដិសេធពុំយល់ព្រមឲ្យឪពុករបស់ខ្ញុំទៅទេ។ ប្រធានសហករណ៍ ថែមទាំងបានណែនាំបំពាក់បំប៉ិនសតិអារម្មណ៍ដល់ឪពុករបស់ខ្ញុំយ៉ាងច្រើន ដើម្បីឲ្យគាត់មានការជ្រះស្រឡះ និងខិតខំកសាងខ្លួនថែមទៀត សម្រាប់ពង្រឹងគោលជំហរ និងសតិអារម្មណ៍បដិវត្តន៍ឲ្យបានល្អ កុំឲ្យទន់ជ្រាយ ដែលនាំឲ្យប៉ះពាល់ដល់មាគ៌ាលោតផ្លោះរបស់អង្គការ និងភាពអសកម្មដល់ការងារសមូហភាព។ ប៉ុន្តែពេលនោះ ឪពុករបស់ខ្ញុំនៅតែខំទទូចអង្វរករ ដោយនិយាយច្បាស់ថា «ខ្ញុំសុំច្បាប់នេះបំណងសំខាន់បំផុតគឺទៅមើលកូនស្រីពៅរបស់ខ្ញុំ ដែលគ្មានអ្វីបៅព្រោះម្តាយបានស្លាប់បាត់ទៅហើយ»។ ពេលនោះអង្គការក៏យល់ព្រមឲ្យច្បាប់គាត់ឈប់មួយថ្ងៃ ប៉ុន្តែអង្គការបានបង្ខំគាត់ឲ្យគាស់ដីចំនួនមួយឡូជូនអង្គការជាមុនសិនទើបអនុញ្ញាតឲ្យទៅ។ ប្រធានសហករណ៍ បានបញ្ជាក់ថា «ធ្វើដីនេះរួចថ្ងៃណា ទៅថ្ងៃនោះចុះ!»។ ឪពុករបស់ខ្ញុំ បានខំប្រឹងគាស់ដីទាំងយប់ ទាំងថ្ងៃមិនហ៊ានឈប់សម្រាកដេកពួនទេ ដើម្បីឲ្យបានជួបមុខកូនឆាប់ៗ។ ពីរថ្ងៃក្រោយមកទៀតទើបគាត់ធ្វើដីនោះរួច ហើយបានទៅជួបកូនដូចបំណង។ ប៉ុន្តែនៅពេលនោះ កូនស្រីពៅរបស់គាត់ ត្រូវបានអ្នកស្រុកសុំយកទៅចិញ្ចឹមបាត់ហើយមុន

ពេលគាត់មកដល់មន្ទីរពេទ្យពីរថ្ងៃ។ ឪពុករបស់ខ្ញុំ មិនបានសោកសៅអ្វីនោះទេ ថែមទាំងបានសរសើរប្អូនទី៤របស់ខ្ញុំ យ៉ាងខ្លាំង ដែលចេះដោះស្រាយបញ្ហា ហ៊ាន ឲ្យប្អូនស្រីពៅទៅគេ ដើម្បីឲ្យប្អូនរស់។ ឪពុករបស់ខ្ញុំ ក៏ត្រេកអរដែរ ដែលដឹងថាអ្នកសុំនោះ គឺជាប្រជាជនមូលដ្ឋាន។ ដូច្នេះ គាត់មានសង្ឃឹមថាកូនស្រីពៅរបស់គាត់ អាចរស់រានមានជីវិត ហើយអាចបានសុខសប្បាយជារៀងរហូត ពុំលំបាកវេទនាអត់ឃ្លានដូចជាពួកគាត់ឡើយ។

ក្រោយពេលជួបជុំជាមួយកូនៗអស់រយៈពេលប្រហែលជាង២ម៉ោង ឪពុករបស់ខ្ញុំ ក៏ប្រញាប់ប្រញាល់ត្រលប់ទៅកាន់ភូមិវិញ។ ប្រមាណជាងមួយសប្តាហ៍ក្រោយមក មានដំណឹងថាប្អូនស្រីរបស់ខ្ញុំម្នាក់ឈ្មោះ អាច្រឹប អាយុប្រហែល ៤ឆ្នាំ បានស្លាប់អស់រយៈពេល ២ថ្ងៃកន្លងមកហើយ។ ពេលនោះ ឪពុករបស់ខ្ញុំ ក៏ប្រញាប់រត់ទៅរាយការណ៍ឲ្យប្រធានសហករណ៍ដឹងភ្លាម ហើយបានស្នើសុំច្បាប់ចំនួន១ថ្ងៃ ដើម្បីទៅមើលកូនៗ ដែលនៅមានជីវិត។ ប្រធានសហករណ៍បានយល់ព្រម ហើយក៏ឲ្យលក្ខខណ្ឌឲ្យគាត់គាស់ដីជូនអង្គការដូចមុនទៀត។ ឪពុករបស់ខ្ញុំ ខិតខំគាស់ដីអស់ពេល ១ថ្ងៃ ១យប់ គ្មានបានឈប់សម្រាកទាល់តែសោះ។ លុះពេលបានជួបជាមួយកូនៗរួចហើយ ឪពុករបស់ខ្ញុំ ត្រលប់មកធ្វើការវិញធម្មតាដូចសព្វដង។ មកដល់ភូមិបានប្រហែលជា១សប្តាហ៍ ឪពុករបស់ខ្ញុំ ក៏បានទទួលដំណឹងថា កូនរបស់គាត់ឈ្មោះ អានាង អាយុខ្ចង់ ៦ឆ្នាំ បានស្លាប់ទៀត។ ចំណែកឯកូនប្រុសស្រីចំនួន ២នាក់ផ្សេងទៀត ត្រូវបានអង្គការ បញ្ជូនយកទៅកាន់មន្ទីរពេទ្យស្រុកសំបូរដែរ។ ឪពុករបស់ខ្ញុំ បានសុំច្បាប់អង្គការទៀត ហើយអង្គការក៏យល់ព្រមឲ្យច្បាប់គាត់ទៅដែរ ដោយប្រើលក្ខខណ្ឌជីកដីដូចមុនៗ។ លុះពេលគាត់បានជួបជាមួយប្អូនៗរបស់ខ្ញុំនៅក្នុងមន្ទីរពេទ្យស្រុក ប្អូនរបស់ខ្ញុំបានយំអង្វរទាមទារ សុំឲ្យគាត់យកពួកគេត្រលប់ទៅផ្ទះវិញ ព្រោះពួកគេមិនចង់សម្រាកនៅមន្ទីរពេទ្យទៀតទេ។ ពួកគេបានយំផង ស្រែកផង និយាយអង្វរពុកថា «ពុកអើយ! កូនមិនចង់រស់នៅទីនេះទៀតទេ សូមពុកឲ្យកូនត្រលប់មកផ្ទះយើងវិញទៅ បើឲ្យកូនរស់នៅទីនោះតទៅទៀត កូនច្បាស់ជាស្លាប់ចោលពុកហើយ កូនមិនរស់ទេ»។

ឮកូននិយាយដូច្នេះ ឪពុករបស់ខ្ញុំ មានការងឿងឆ្ងល់យ៉ាងខ្លាំង។ គាត់បានជជីកសួរកូនៗរកមូលហេតុ ប៉ុន្តែកូនចេះតែយំ ហើយពុំព្រមនិយាយស្តីអ្វីប្រាប់គាត់ឡើយ។ ប៉ុន្តែឪពុករបស់ខ្ញុំ មិនដាច់ចិត្តយកកូនត្រលប់ទៅក្នុងភូមិវិញទេ ព្រោះនៅក្នុងភូមិកំពុងតែជួបបញ្ហាអត់ឃ្លានខ្លាំង និងមានជំងឺ ដែលកំពុងធ្វើឲ្យអ្នកភូមិទាំងក្មេងទាំងចាស់ឈឺស្លាប់យ៉ាងរង្គាលទៀតផង។ គាត់នៅតែខិតខំនិយាយលួងលោមកូនៗថា ឲ្យកូនតស៊ូទ្រាំរស់នៅក្នុងមន្ទីរពេទ្យមួយរយៈពេលទៀត គឺរង់ចាំឲ្យដល់រដូវច្រូតកាត់និងជំងឺក្នុងភូមិបានស្ងប់ស្ងាត់ សឹមឲ្យកូនវិលត្រលប់ទៅក្នុងភូមិវិញ។ បន្ទាប់មក គាត់ក៏លួចរត់គេចចេញពីកូនត្រលប់មកផ្ទះវិញទៅ។

លុះរំលងបានរយៈពេលប្រហែល ៥ថ្ងៃ ឪពុករបស់ខ្ញុំ បានទទួលដំណឹងថាប្អូនស្រីរបស់ខ្ញុំម្នាក់ស្លាប់ទៀតហើយ។ ពេលនោះ ឪពុករបស់ខ្ញុំមានវិប្បដិសារីខ្លាំងណាស់។ គាត់គិតថា ប្រសិនបើគាត់យល់ព្រមឲ្យប្អូនស្រីរបស់ខ្ញុំត្រលប់មកផ្ទះវិញ ប្រហែលជាកូនគាត់មិនស្លាប់នោះទេ។ បន្ទាប់មក គាត់ក៏រត់ទៅសុំច្បាប់អង្គការទៀត ដើម្បីទៅយកប្អូនប្រុសរបស់ខ្ញុំ ដែលមានអាយុ ១២ឆ្នាំ ឈ្មោះចន្ទ សុផល ហៅអូនទូច ឲ្យត្រលប់មករស់នៅជាមួយគាត់វិញ។ គាត់មិនអាចទុកកូនរបស់គាត់ឲ្យរស់នៅក្នុងមន្ទីរពេទ្យបន្តទៅទៀតបានទេ។ ដោយទទួលបានការអនុញ្ញាតពីអង្គការ ឪពុករបស់ខ្ញុំ បានប្រញាប់ប្រញាល់ធ្វើដំណើរទៅយកប្អូនប្រុសរបស់ខ្ញុំចាកចេញពីមន្ទីរពេទ្យមករស់នៅក្នុងភូមិវិញ។

មកដល់ភូមិសណ្តាន់ ឪពុករបស់ខ្ញុំ បាននាំកូនចូលទៅសម្រាកនៅផ្ទះអ្នកធ្លាប់រាប់អានម្នាក់ ហើយបានហូបបាយ និងសម្រាកនៅទីនោះរយៈពេល២ម៉ោង។ ប្អូនប្រុសរបស់ខ្ញុំ បានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង រហូតដល់ប្រកាច់បាត់មាត់ បាត់កភ្លាមមួយរំពេច។ ឪពុករបស់ខ្ញុំ កិតក័យស្លន់ស្លោ ក៏បានលើកត្រកងបីកូនរត់យ៉ាងលឿនទៅកាន់មន្ទីរពេទ្យសណ្តាន់ ដែលមានចម្ងាយប្រហែលជា ១៨គីឡូម៉ែត្រពីទីកន្លែងដែលគាត់កំពុងស្នាក់នៅ។ ពេលទៅដល់មន្ទីរពេទ្យ គាត់បានជាក់ប្អូនរបស់ខ្ញុំផ្តេកទៅលើគ្រែពេទ្យភ្លាមៗទុកឲ្យគ្រូពេទ្យពិនិត្យ។ ឪពុករបស់ខ្ញុំ បានឃើញកូនរងាញាក់ ក៏ស្រាយយកអង្រឹងនៅក្បែរនោះមកដណ្តប់ឲ្យកូន ប៉ុន្តែម្ចាស់អង្រឹង

ដែលជាកម្មាភិបាលខ្មែរក្រហម បានទាញអង្រឹងយកវិញភ្លាម រួចហើយបានលើកដៃចង្អុលមុខឪពុករបស់ខ្ញុំ ហើយស្រែកឡួឡាដេរប្រមាថ តិះដៀលដល់ឪពុករបស់ខ្ញុំយ៉ាងខ្លាំង។ ពេលឃើញដូច្នោះ មានប្រជាជនមូលដ្ឋាន ដែលជាអ្នកភូមិសណ្តាន់ចំនួន ២នាក់ ដែលឃើញហេតុការណ៍នោះ និងដឹងរឿងរ៉ាវទុក្ខព្រួយក្នុងគ្រួសាររបស់ខ្ញុំ ជួយនិយាយអន្តរាគមន៍ ទើបកម្មាភិបាលខ្មែរក្រហមនោះស្ងៀមស្ងាត់ទៅវិញ។ ក្រោយមក ប្រធានពេទ្យ បានមកបង្ខំឲ្យឪពុករបស់ខ្ញុំចាកចេញពីមន្ទីរពេទ្យ ដើម្បីត្រលប់ទៅធ្វើការងារវិញ ហើយថែមទាំងប្រាប់គាត់ថា ប្រសិនបើគាត់ចង់នៅមើលថែទាំកូន គឺត្រូវតែមានលិខិតយល់ព្រមពីសហការណ៍។ ឮដូច្នោះ គាត់ក៏ខំប្រឹងដើរផង រត់ផង បំណងឲ្យបានទៅដល់ភូមិរបស់គាត់ ដើម្បីនឹងអាលបានសុំអង្គការវិលត្រលប់មកមើលថែកូនរបស់គាត់វិញ។ លើកនេះក៏ដូចជាលើកមុនៗដែរ ទោះបីជាឪពុករបស់ខ្ញុំខំលន់តួអង្វរករហូតដល់លុតជង្គង់នៅចំពោះមុខអង្គការក៏ដោយ ក៏គេនៅតែមិនអនុគ្រោះដល់គាត់ជាដាច់ខាត។ ឪពុករបស់ខ្ញុំ ខិតខំកាប់គាស់ដីតាមតម្រូវការរបស់អង្គការទាំងយប់ទាំងថ្ងៃ ដើម្បីឆាប់បានត្រលប់ទៅមើលកូនវិញ។ ជាអកុសល ប្អូនប្រុសរបស់ខ្ញុំ បានស្លាប់ចោលគាត់ម្នាក់ទៀត។

ឪពុករបស់ខ្ញុំ នៅស្ងៀមស្ងាត់ លែងនិយាយស្តីអ្វីទាំងអស់នៅពេលដឹងថាកូនម្នាក់ទៀតស្លាប់។ អ្នកភូមិគិតថាឪពុករបស់ខ្ញុំឡប់សតិទៅហើយ។ ឃើញឪពុករបស់ខ្ញុំធ្លាក់ក្នុងសភាពដូច្នោះ ក្មួយស្រី ក្មួយប្រសា និងអ្នកជិតខាងមួយចំនួន បានគាំគ្នានិយាយរំឭកទៅដល់ពួកកូនៗទាំង៣នាក់ទៀត ដែលនៅរស់រានមានជីវិតគឺ ច័ន្ទ មុនី(រូបខ្ញុំ), ច័ន្ទ ប៊ុណ្ណា និង ច័ន្ទ កុសល ក្នុងគោលបំណងពញ្ជាក់អារម្មណ៍ឲ្យគាត់បានក្លឹស្វាងឡើងវិញ និងដើម្បីកុំឲ្យគាត់អស់សង្ឃឹមក្នុងជីវិតតទៅទៀត។ ឮដូច្នោះ គាត់ក៏ស្រាប់តែភ្ញាក់ស្មារតី និងដឹងខ្លួនឡើងវិញជាបណ្តើរៗ។

លុះកន្លងផុតប្រហែលជា៣ទៅ៤ខែក្រោយមក អង្គការ បានរៀបចំផ្សំផ្គុំឪពុករបស់ខ្ញុំ ជាមួយប្រពន្ធទី២របស់គាត់ឈ្មោះ អ៊ុន សឿង ដែលជាស្ត្រីមេម៉ាយមានកូនចំនួន ៤នាក់។ ឪពុករបស់ខ្ញុំ និងប្រពន្ធទី២របស់គាត់ ពុំមានចិត្តស្រលាញ់

គ្នាទេ ព្រោះម្នាក់ៗកំពុងតែមានទុក្ខលំបាករៀងៗខ្លួន។ ដោយសារខ្លាចអំណាចអង្គការ ទើបពួកគាត់សុខចិត្តព្រមរៀបការជាមួយគ្នា។ លុះបន្ទាប់ពីបានជួបជាមួយប្រពន្ធទី២ និងកូនៗរបស់ប្រពន្ធគាត់ដែរនោះ ឪពុករបស់ខ្ញុំមានចិត្តអាណិតស្រលាញ់ដល់ពួកក្មេងៗទាំងនោះខ្លាំងណាស់។ គាត់និយាយថា គាត់មិនអាចបណ្តោយឲ្យកូនចុងរបស់គាត់ស្លាប់ដូចកូនៗរបស់គាត់មុនៗទៀតទេ។ គាត់ត្រូវតែហ៊ានតស៊ូរកអាហារយកមកជួយសង្គ្រោះជីវិតក្មេងទាំងនោះ ឲ្យបានរួចផុតពីសេចក្តីស្លាប់។ ក្រោយមក ឪពុករបស់ខ្ញុំ បានលបលួចចូលទៅបន្លំយកអង្ករបស់អង្គការពីសហករណ៍ ដែលគេធ្វើទុកឲ្យយោធាខ្មែរក្រហមសម្រាប់ហូបចុកជាប្រចាំថ្ងៃចំនួន២កំប៉ុង យកមកឲ្យប្រពន្ធនិងកូនៗរបស់គាត់ស្ទើរតែរាល់យប់។ មិនយូរប៉ុន្មាន ពួកគេ ក៏បានជាសះស្បើយពីជំងឺនិងមានកម្លាំងប្រសើរជាងមុន។

រហូតមកដល់ចុងឆ្នាំ១៩៧៨ ឪពុករបស់ខ្ញុំ មានកូនស្រីម្នាក់ទៀតជាមួយប្រពន្ធទី២របស់គាត់។ ឪពុករបស់ខ្ញុំមានស្មារតីនិងទឹកចិត្តប្រសើរឡើងវិញ។ រហូតមកដល់ថ្ងៃរំដោះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គាត់ក៏បាននាំប្រពន្ធនិងកូនរបស់គាត់ ចាកចេញពីភូមិឈ្លើយសឹកស្រែត្រែង ជាគុកឥតជញ្ជាំង និងដែនដីមរណៈ ដែលបានលេបត្របាក់យកជីវិតប្រជាជនឈ្លើយសឹកស្ទើរគ្មានសល់រលែត្រលប់មករស់នៅក្នុងភូមិថ្មី ស្ថិតក្នុងឃុំសណ្តាន់ជារៀងរហូត។ លុះមកដល់ដើមឆ្នាំ១៩៨០ ឪពុករបស់ខ្ញុំ បានធ្វើដំណើរពីស្រុកសំបូរ ខេត្តក្រចេះ មកតាមស្វែងរកខ្ញុំនិងប្អូនប្រុសទី៣ឈ្មោះ ច័ន្ទ កុសលដល់រាជធានីភ្នំពេញ។ពេលនោះពួកខ្ញុំកំពុងតែហ្វឹកហ្វឺនបណ្តុះបណ្តាលមុខជំនាញឯកទេសនៅក្នុងសាលាទ័ពមួយរបស់កងទ័ពប្រជាជនបដិវត្តន៍កម្ពុជា។ ខ្ញុំនិងប្អូនរបស់ខ្ញុំមិនបានរស់នៅជួបជុំគ្នាទេ។ កុសល ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញទៅរស់នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ចំណែកឯ ខ្ញុំ ត្រូវទៅរស់នៅឯស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

រឿងសោកសៅគួរឲ្យរន្ធត់តក់ស្លុត ដែលបានកើតឡើងមកលើប្រពន្ធកូននិងឪពុករបស់ខ្ញុំ បានធ្វើឲ្យគាត់ទទួលរងការឈឺចាប់ ខ្លោចផ្សា និងសោកស្តាយយ៉ាងក្រៃលែងក្នុងឆាកជីវិតរបស់គាត់។ គាត់បានចងចាំទុកនៅក្នុងចិត្តរបស់គាត់

រហូតមកដល់សព្វថ្ងៃនេះពុំដែលបំភ្លេចឡើយ។ ទោះបីជាបច្ចុប្បន្ននេះ ឪពុករបស់ខ្ញុំចាស់ជរាមានវ័យរហូតដល់ ៩៣ឆ្នាំក៏ដោយ ក៏គាត់នៅតែខិតខំព្យាយាមនិយាយរំឭកជារឿយៗពីរឿងដ៏សែនខ្លោចផ្សានេះឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងមានមនសិការ ដើម្បីចូលរួមថែរក្សាការពារសុខសន្តិភាពរបស់ប្រទេសជាតិនិងរារាំងកុំឲ្យរបបព្រៃផ្សៃប្រល័យពូជសាសន៍ដ៏ឃោរឃៅនេះវិលត្រលប់មកវិញសារជាថ្មីលើទឹកដីកម្ពុជាក៏សែនកំសត់ទៀត។

«ទោះបីជា ប៉ុល ពត បានស្លាប់ពិតមែនក៏ដោយ ប៉ុន្តែប្រសិនបើគ្រប់គ្នាមានការប្រមាទ ធ្វេសប្រហែស នោះ របបនេះ អាចនឹងរស់ឡើងវិញជាក់ជាពុំខាន»។

—— ចប់ ——

១១

រឿងផ្សេងអ័ព្ទ

អ្នកនិពន្ធ ៖ រ៉ែត សារ៉ុន

១១ ~ រឿង ផ្សេងអ័ព្ទ

ស្នូរគ្រាប់កាំភ្លើងបន្លឺឡើងលាន់ឮសូរផ្ទេងផាំងៗ បន្តជាប់គ្នារដឹក បែកផ្កាភ្លើងព្រាកៗ។ ស្នូរគ្រាប់បែក គ្រាប់ផ្លោង បន្លឺឡើងរង្គើលៗ ប៉ុន្តែលាន់ឮខ្លាំងពេលផ្ទុះម្តងៗ រង្គើញាប់ញ័រអស់ប្រឹថពី។ កម្លាំងទាហានរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរបានខិតខំទប់ទល់នឹងកម្លាំងទ័ពខ្មែរក្រហម ដែលកំពុងតែវាយប្រហារសម្រុកចូលមកកាន់ទីក្រុងភ្នំពេញដូចទឹកបាក់ទំនប់។ ស្នូរឃ្លោះលាន់ឮគគ្រឹកគគ្រេង រីឯនៅលើអាកាស យន្តហោះចម្បាំងហោះខ្វាត់ខ្វែងពាសពេញវេហាលាន់ឮកងរំពងផ្គើរផ្គងឆ្លើយឆ្លងគ្នាមិនដាច់សូរទាល់តែសោះ។ សូរសំឡេងយន្តហោះ និងរថក្រោះ លាន់ឮកាន់តែកៀក សរបញ្ជាក់ឲ្យឃើញថា កងទ័ពខ្មែរក្រហម កំពុងតែសម្រុកចូលទីក្រុងភ្នំពេញហើយ។

ខ្ញុំចេះតែបារម្ភនៅក្នុងចិត្តគិតថា តើប្រទេសជាតិនឹងបានសុខឬក៏សង្គ្រាមស៊ីវិលត្រូវកើតមានឥតឈប់ឈរ? ខ្ញុំគ្រាន់តែដឹងថាពេលនេះ អ្នកនយោបាយខ្មែរកំពុងតែក្លាយទៅជាកូនអុករបស់ប្រទេសមហាអំណាចពិភពលោក ដែលកំពុងតែព្យាយាមផ្សព្វផ្សាយមនោគមវិជ្ជានយោបាយរបស់ខ្លួន។ ខ្ញុំខ្លាចឥទ្ធិពលនៃសង្គ្រាមត្រជាក់នឹងធ្វើឲ្យប្រទេសជាតិធ្លាក់ទៅក្នុងសភាពខ្ទេចខ្ទី ព្រោះស្ថានភាពនយោបាយពិភពលោកកំពុងតែមានការប្រែប្រួលយ៉ាងខ្លាំង។ ពាក្យថា «ដំរីដល់គ្នាងាប់តែស្មៅ» អាចនឹងត្រូវចំពោះបរិបទសង្គមនាពេលនេះ ប៉ុន្តែយ៉ាងណា យើងមានតែរង់ចាំមើលស្ថានភាពបន្តទៅទៀត។ ខ្ញុំកំពុងតែស្តុងគិតចំពោះបញ្ហាទាំងអស់នេះ ស្រាប់តែគ្រាប់ផ្លោងហោះរំលងដំបូលផ្ទះរបស់ខ្ញុំ ទៅប៉ះនឹងអគារមួយដួលរលំខ្ទេចខ្ទី។ ខ្ញុំភ្ញាក់ខ្លួនព្រឺត ហើយមានអារម្មណ៍ដឹងថា

កងទ័ពខ្មែរក្រហមប្រាកដជាវាយយកទីក្រុងភ្នំពេញបានជាក់ជាពុំខាន ព្រោះពួកគេបានឡោមព័ទ្ធទីក្រុងភ្នំពេញបានទៅហើយ។ មិនយូរប៉ុន្មាន កងទ័ពខ្មែរក្រហមបានវាយយកទីក្រុងភ្នំពេញបានទាំងស្រុងដូចដែលខ្ញុំស្មានទុកមែន។ សំឡេងជយឃោស ស្រែកហ៊ោអបអរសាទរចំពោះជ័យជម្នះរបស់កងទ័ពខ្មែរក្រហម លាន់ឮពាសពេញទីក្រុងភ្នំពេញ។ មនុស្សម្នាទាំងឡាយសប្បាយអរនឹងជោគជ័យមួយនេះ ព្រោះគិតថាប្រទេសជាតិនឹងបានសោយសុខសន្តិភាពក្រោមការដឹកនាំរបស់រដ្ឋាភិបាលថ្មី។ ភាពសប្បាយរីករាយ ស្នាមញញឹមរបស់ប្រជាជន មិនទាន់បានយូរប៉ុន្មានផង ស្រាប់តែជំនួសមកវិញនូវទឹកភ្នែក និងភាពងឿងឆ្ងល់។ កងកម្លាំងរបស់ខ្មែរក្រហម បានបញ្ជាឲ្យប្រជាជនទាំងអស់ ចាកចេញពីទីក្រុងភ្នំពេញជាបន្ទាន់ ដោយប្រាប់ថា ខ្លាចអាមេរិកទម្លាក់គ្រាប់បែក។ ដូច្នេះពួកគេត្រូវតែជម្លៀសប្រជាជនទៅតំបន់ដែលមានសុខសុវត្ថិភាពជាជាងខាត។ ពេលនោះក៏មានប្រជាជនមួយចំនួនរឹងទទឹងមិនព្រមចាកចេញពីទីក្រុងភ្នំពេញដែរ ប៉ុន្តែពួកគេត្រូវបានកងទ័ពខ្មែរក្រហមបាញ់សម្លាប់យ៉ាងអាណោចអាធ័ម។ ឃើញសភាពបែបនេះ ប្រជាជនយើងក៏មិនហ៊ានតវ៉ាអ្វីទៀតដែរ ព្រោះពួកគេខ្លាចត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់ដូចប្រជាជនផ្សេងទៀតដែលរឹងទទឹងមិនព្រមធ្វើតាមបញ្ជារបស់កងទ័ពខ្មែរក្រហមទាំងអស់នោះ។ ម្យ៉ាងទៀត នៅលើអាកាសមានយន្តហោះចម្បាំងហោះខ្ទាត់ខ្វែងនៅឡើយ ដូច្នេះមានតែព្រមចាកចេញពីទីក្រុងទាំងបង្ខំចិត្ត។

ខ្ញុំ និងក្រុមគ្រួសារ នាំគ្នារៀបចំអីវ៉ាន់ចាកចេញពីទីក្រុងភ្នំពេញ។ ប៉ារបស់ខ្ញុំបានរៀបចំអីវ៉ាន់ដាក់លើឡានរួចជាស្រេច ចំណែក ខ្ញុំក៏នាំប្អូនប្រុសរបស់ខ្ញុំឡើងលើឡានចាកចេញទៅ។ ទឹកភ្នែកម៉ាក់របស់ខ្ញុំ ហូរចុះកាត់ផែនថ្ពាល់របស់គាត់ ដំណាលគ្នាជាមួយវាចាទាំងរអាក់រអួលថា «ពេលនេះមិនដឹងថាគេជម្លៀសយើងទៅទីណាទេ ហើយជីវិតរបស់គ្រួសារយើងក៏មិនដឹងទៅជាយ៉ាងណាដែរ?»។ ឮដូច្នោះ ប៉ារបស់ខ្ញុំ ប្រែទឹកមុខក្រៀមស្រពោន ហើយនិយាយតបទៅវិញថា «ចាប់ពីពេលនោះទៅ យើងត្រូវរស់នៅក្នុងភាពសាមញ្ញ ត្រូវលាក់សាវតារបស់យើង» កែវភ្នែកប៉ារបស់ខ្ញុំសម្លឹងមើលទៅឆ្ងាយហើយនិយាយបន្តទៀតថា

«បងគិតថាបរិបទនយោបាយរបស់ប្រទេសយើងនឹងត្រូវផ្លាស់ប្តូរទាំងស្រុង ព្រោះពេលនេះកម្លាំងទ័ពខ្មែរក្រហម បានឡើងកាន់អំណាចទៅហើយ ប្រទេសរបស់យើងប្រហែលប្រែទៅជាប្រទេសកុម្មុយនីស្តជាក់ជាពុំខាន ព្រោះថាមេដឹកនាំខ្មែរក្រហម មានទំនាក់ទំនងជិតស្និតជាមួយសហភាពសូវៀត ចិន និងវៀតណាម ហើយបងបានឃើញកងទ័ពអាវខ្មៅបាញ់សម្លាប់មន្ត្រីរាជការអស់ជាច្រើន ដូច្នេះយើងត្រូវតែលាក់សាវតារខ្លួនឯងកុំឲ្យគេដឹងឲ្យសោះថា បងជាមន្ត្រីរាជការ រីឯអូនក៏ដូចគ្នា មិនត្រូវឲ្យគេដឹងថាអូនជាវេជ្ជបណ្ឌិតជាដាច់ខាត»។ និយាយរួច ប៉ាក់បានងាកមករកខ្ញុំ ហើយញញឹមសួតបន្លឺវាចាយ៉ាងស្រទន់ថា «សុកីនាថកូន! ចាប់ពីពេលនេះទៅកូនឈប់ហៅប៉ា ថាប៉ាទៀតទៅ កូនត្រូវហៅថាពុកណាកូន!»។

នៅថ្ងៃនោះ មនុស្សម្នាចាកចេញពីទីក្រុងភ្នំពេញ តាមដងផ្លូវកកកុញណែនណាន់តាន់តាប់រកផ្លូវចេញមិនចង់រួច អ្នកខ្លះជិះឡាន ម៉ូតូ ខ្លះបណ្តើរកង់ ដឹកអីវ៉ាន់ពេញពោរ រីឯខ្លះទៀតដើរទូលអីវ៉ាន់ផង ស្ពាយសំពីងសំពោងពេញលើខ្លួន។ ខ្ញុំនឹកអាណិតដល់មនុស្សចាស់ៗ ដែលត្រូវដើរត្រដាបត្រដួសទាំងខ្លួនមានជំងឺ ខ្លះមានសំណាងបានកូនព។ ខ្ញុំឃើញពួកគាត់យំទឹកភ្នែកហូររហាមនៅតាមផ្លូវ។ ចំណែកឯ ក្មេងតូចៗវិញ ត្រូវម្តាយរបស់គេពផង កណ្តៀតផង ស្រែកយំទ្រហឹងអឺងកង។ ឃើញសភាពបែបនេះនៅតាមផ្លូវ ខ្ញុំពិបាកចិត្តណាស់។ ខ្ញុំបានសួរថា «ប៉ា! មន្ត្រីស៊ីវិលរបស់រដ្ឋាភិបាលត្រូវខ្មែរក្រហមសម្លាប់ទាំងអស់មែនទេប៉ា?»។ ខ្ញុំនិយាយមិនទាន់នឹងចប់ឃ្លាស្រួលផង ប៉ារបស់ខ្ញុំស្រែកដាក់ខ្ញុំថា«សុកីនាថ! កុំហៅថាប៉ាថាប៉ាទៀតកូន! ត្រូវហៅថាពុក! ត្រូវចាំ ដាច់ខាតដឹងទេ» និយាយរួចគាត់ក៏ត្រលប់មកឆ្លើយនឹងសំណួររបស់ខ្ញុំថា «ពិតណាស់កូន! មន្ត្រីរាជការរបស់រដ្ឋាភិបាលចាស់ ត្រូវខ្មែរក្រហមសម្លាប់ ហើយពុកបានឮមកថា ពួកកងទ័ពអាវខ្មៅវានឹងបោសសម្អាតកម្ពែលចក្រពត្តិអាមេរិកឲ្យអស់! ដូចជាពួកសាស្ត្រាចារ្យ និស្សិតបញ្ញាវន្តមួយចំនួន ត្រូវបានបាញ់សម្លាប់ ព្រោះតែពួកគេតវ៉ានឹងបញ្ញារបស់ ខ្មែរក្រហម ហើយចំណែកឯនៅតាមមន្ទីរពេទ្យវិញ វេជ្ជបណ្ឌិត ពេទ្យ គិលានុបដ្ឋាយិកាមួយចំនួន ក៏ត្រូវបានបាញ់សម្លាប់ដែរ»។

ប៉ុន្មានថ្ងៃមុននឹងកើតហេតុការណ៍ទាំងអស់នេះ ប៉ារបស់ខ្ញុំ ស្មានដឹងពីហេតុការណ៍ថាមិនស្រួល ទើបគាត់មិនទៅធ្វើការ ហើយថែមទាំងបានឃាត់ម៉ាក់របស់ខ្ញុំមិនឲ្យទៅធ្វើការដែរ។ យើងធ្វើដំណើរទៅមុខកាន់តែឆ្ងាយទៅៗ ខ្ញុំក៏សួរប៉ារបស់ខ្ញុំទៀតថា «ពុក! តើគេជម្លៀសយើងទៅណាដែរ?»។ «ពុក ក៏មិនទាន់ដឹងដែរ តែពេលនេះ គេថាឲ្យយើងទៅកាន់ខេត្តកណ្តាល!» ប៉ារបស់ខ្ញុំបានឆ្លើយតបមកវិញទាំងមិនច្បាស់លាស់។

អារម្មណ៍មួយដ៏សែនតានតឹង បានមកគ្របសង្កត់លើចិត្តរបស់ខ្ញុំ។ ខ្ញុំស្តាយការសិក្សា ថែមទាំងត្រូវបែកគ្នាពីមិត្តភក្តិមិនដឹងថា ពួកគេទៅជាយ៉ាងណាទៅហើយនោះទេ? អារម្មណ៍របស់ខ្ញុំ រឹតតែភ័យព្រួយ ព្រោះមិនដឹងថានឹងមានអ្វីកើតឡើងនៅថ្ងៃស្អែកឡើយ។ ខ្ញុំដឹងថា ប៉ារបស់ខ្ញុំ ប្រាកដជាដឹងរឿងគ្រប់យ៉ាងដែលកំពុងតែកើតឡើង តែគាត់មិនហ៊ានប្រាប់ខ្ញុំ ព្រោះគាត់មិនចង់ឲ្យខ្ញុំត្រូវភ័យព្រួយចំពោះរឿងទាំងអស់នេះ។

រថយន្តរបស់ខ្ញុំ បានបើកចេញពីវិមានឯករាជ្យតម្រង់ទៅកាន់ស្ពានព្រះមុនីវង្ស។ គ្រាន់តែឆ្លងផុតស្ពានបានបន្តិច រថយន្តក៏អស់សាំងមិនអាចធ្វើដំណើរទៅមុខទៀតបានឡើយ។ ប៉ារបស់ខ្ញុំ បានចុះទៅប្រមូលអីវ៉ាន់ចេញពីក្នុងឡានទាំងអស់។ ឃើញដូច្នោះ ម៉ាក់របស់ខ្ញុំសួរថា «តើយើងត្រូវធ្វើដូចម្តេចទៀតទៅបង?»។ «យើងត្រូវដើរដូចគេដូចឯង! ហើយទុកឡានចោលនៅទីនេះ! ឆាប់ដាស់បញ្ញាវឌ្ឍន៍ឲ្យក្រោកឡើង! សុកីនាថកូន! ឆាប់ចុះមក!» ប៉ារបស់ខ្ញុំនិយាយផង ដៃរើអីវ៉ាន់យ៉ាងប្រញាប់ប្រញាល់ផង។

ទីបំផុត យើងត្រូវបន្តដំណើរដោយថ្មើរជើងដូចប្រជាជនដទៃទៀត។ ខ្ញុំដឹកដៃប្អូនប្រុសរបស់ខ្ញុំ ចំណែកប៉ា និងម៉ាក់របស់ខ្ញុំ ស្ពាយអីវ៉ាន់ផង ទូលផងសំពីងសំពោងពេញខ្លួន។ ទឹកមុខមនុស្សម្នាក់ៗក្រៀមស្រពោន ព្រោះសេចក្តីហេវហត់។ ខ្ញុំបានឃើញលោកតាចំណាស់ម្នាក់ដើរទៅមុខលែងរួច ព្រោះធ្វើដំណើរឆ្ងាយហេវហត់អស់កម្លាំងទន់ដៃទន់ជើង។ គាត់ស្រែករកទឹក តែក្រុមគ្រួសាររបស់គាត់ ពុំបានយកទឹកមកជាមួយឡើយ។ មីងម្នាក់នៅក្បែរនោះឮហើយ

ក៏បានយកទឹកឲ្យគាត់ហូប។ ប៉ុន្តែ កងទ័ពអាវខ្មៅដែលនៅក្បែរនោះ បានមកកញ្ឆក់ទឹកពីដៃរបស់គាត់យកទៅបោះចោល ហើយស្រែកគំហកដាក់លោកតានោះថា «តាកញ្ជាស់នេះ ធ្វើពុតទន់រលេះរលួយ ព្រោះនៅជាប់កម្ពែលចក្រពត្តិ មិនបាច់ខ្វល់ពីគាត់ទេ!»។

ថាតែប៉ុណ្ណោះ កងទ័ពអាវខ្មៅ អាមេកាំភ្លើងបាញ់តម្រង់ចំដើមទ្រូងរបស់លោកតានោះ រួចបាញ់សម្លាប់មួយរំពេច។ កូនស្រីរបស់គាត់ ទម្លាក់អីវ៉ាន់ចុះរត់ទៅឱបសាកសពរបស់ឪពុកខ្លួន ក៏ត្រូវកងទ័ពអាវខ្មៅបាញ់សម្លាប់ដែរ។ ឃើញហេតុការណ៍ដូច្នោះ គ្មានអ្នកណាហ៊ានមើលទេ ម្នាក់ៗសម្ងំស្ងាត់មាត់ឈឹង គិតតែនាំគ្នាដើរទៅមុខ ព្រោះខ្លាចមានលទ្ធផលដូចឪពុកកូនគេទាំងពីរនាក់។ ខ្ញុំពិតជាតក់ស្លុតចំពោះហេតុការណ៍ នេះណាស់ ព្រោះខ្ញុំបានឃើញផ្ទាល់នឹងភ្នែករបស់ខ្ញុំ។ ឱលោកអើយ! ម្តេចក៏ឃោរឃៅខ្លាំងម្ល៉េះ? កងទ័ពអាវខ្មៅ មានគ្នាត្រឹមតែពីរបីនាក់សោះ ប៉ុន្តែអាចជម្លៀសមនុស្សរាប់រយ រាប់ពាន់នាក់បាន ដោយមិនមាននរណាហ៊ានប្រឆាំង ព្រោះតែខ្លាចត្រូវបាត់បង់ជីវិត។

ព្រះសុរិយាអស្តង្គតរលត់រស្មី លោកិយគ្របដោយស្បែអន្ធការងងឹតសូន្យសុងមើលអ្វីមិនយល់! បុរសម្នាក់ដែលដើរពីខាងមុខ ដៃកាន់កាំភ្លើងស្លៀកពាក់ពណ៌ខ្មៅ មានបង់កក្រមា ក៏បានលើកដៃស្រែកឡើងខ្លាំងៗថា «ឥឡូវនេះ យើងមកដល់ឃុំដីឥដ្ឋហើយ! យប់នេះមិត្តទាំងអស់គ្នា ត្រូវសម្រាកនៅសាលាបឋមសិក្សាដីឥដ្ឋនេះ! ចាំស្អែកចាំបន្តដំណើរទៅមុខទៀត»។ បានឮពាក្យនេះ ម្នាក់ៗហាក់បីដូចជាបានធូរចិត្តបន្តិច ព្រោះយើងដើរស្ទើរតែពេញមួយថ្ងៃទៅហើយ ហៅហត់អស់កម្លាំង ទន់ដៃទន់ជើង ដើរទៅមុខស្ទើរមិនរួច។ មនុស្សម្នាទាំងឡាយក៏បានរៀបចំទុកដាក់អីវ៉ាន់ រួចប្រមូលគល់ឈើមែកឈើមកគរដុតបំភ្លឺ។ អ្នកខ្លះបានវេចអង្ករ វេចឆ្នាំងមកតាមខ្លួន ក៏បានដាក់ដាំបាយហូប។ គ្រួសាររបស់ខ្ញុំ ជាប់មកជាមួយនំចំនួនពីរបីលូមនឹងអាចចម្អែតក្រពះបានមួយពេលដែរ។ យើងនាំគ្នាហូបរួច ប៉ារបស់ខ្ញុំ បានរៀបចំកន្លែងសម្រាប់គេង រួចគាត់ស្រែកឱ្យខ្ញុំនាំប្អូនប្រុសរបស់ខ្ញុំមកគេង។

ដោយសារភាពនឿយហត់អស់កម្លាំង ធ្វើឲ្យខ្ញុំល្វើយទន់ត្របកភ្នែក លង់លក់ដោយមិនដឹងខ្លួន។ លុះព្រឹកឡើង កងទ័ពអាវខ្មៅមួយក្រុម បានមកដល់សាលាបឋមសិក្សាជីឥដ្ឋ ហើយបានបញ្ជាឲ្យគ្រួសារនីមួយៗចូលទៅក្នុងបន្ទប់ទីចាត់ការ និងបានសួរសំណួរបញ្ជាក់ពីប្រវត្តិរូបថា «តើធ្វើការងារអ្វី? តើមានជាប់និន្នាការខ្មាំងឬទេ?»។ ពួកគេមិនត្រឹមតែសួរសោមីខ្លួនប៉ុណ្ណោះទេ ថែមទាំងសួរគ្រួសារជម្លៀសដទៃទៀតដែលស្គាល់គ្រួសារយើងថែមទៀត។ សំណាងល្អដែលអ្នកជម្លៀសទាំងអស់ពុំមានអ្នកណាស្គាល់ពីសាវតារបស់យើងពិតប្រាកដ។

រំពេចនោះ ស្រាប់តែដល់វេនគ្រួសាររបស់ខ្ញុំ ត្រូវចូលទៅក្នុងបន្ទប់ទីចាត់ការដើម្បីឲ្យគែសាកសួរព័ត៌មាន។ ប៉ារបស់ខ្ញុំ បានងាកមករកម៉ាក់របស់ខ្ញុំ និងខ្ញុំ ហើយក៏និយាយបញ្ជាក់ប្រាប់ម្តងទៀតថា «ដាច់ខាតត្រូវលាក់សាវតារពីគ្រួសាររបស់យើងកុំឲ្យគេដឹង!»។ ម៉ាក់របស់ខ្ញុំងក់ក្បាល ជាសញ្ញាប្រាប់ថាគាត់យល់ហើយ។ គ្រួសាររបស់ខ្ញុំ ក៏បានដើរចូលទៅក្នុងបន្ទប់ទីចាត់ការនោះ។ ពេលចូលទៅដល់ ខ្ញុំឃើញបុរសម្នាក់អង្គុយនៅលើកៅអីមានតុនៅចំពីមុខ។ បុរសនោះបានសួរមកកាន់ប៉ារបស់ខ្ញុំថា «មិត្តឯងធ្វើការងារអ្វី? »។ ប៉ារបស់ខ្ញុំឆ្លើយតបយ៉ាងទន់ភ្លន់ថា «បាទ! ខ្ញុំធ្វើជាកម្មកររោងចក្របារី!»។ បុរសនោះបានសួរបញ្ជាក់ថែមទៀតថា «មិត្តឯងត្រូវនិយាយស្មោះត្រង់ជាមួយអង្គការ! មិនត្រូវកុហកឡើយ! តើមិត្តឯងមានជាប់និន្នាការខ្មាំងឬទេ?»។ «ខ្ញុំមិនដឹងស្អីទេ? តើអ្វីជានិន្នាការ?» ប៉ារបស់ខ្ញុំនិយាយមិនទាន់ចប់ផង បុរសម្នាក់នោះក៏ស្រែកដាក់ប៉ារបស់ខ្ញុំ «មិត្តឯងភ្លើ ឬក៏ធ្វើភ្លើ?» រួចបុរសម្នាក់នោះនិយាយសម្រួលវិញថា «អើមិនអីទេ! មិត្តអាចចេញទៅបាន តែមិត្តឯងត្រូវជម្លៀសទៅភូមិភាគបូព៌ា ដូច្នេះមិត្តឯងត្រូវធ្វើដំណើរបន្តទៀតទៅខេត្តព្រៃវែង»។

គ្រួសារខ្លះត្រូវបានជម្លៀសមកត្រឹមខេត្តកណ្តាល ឯគ្រួសារខ្លះទៀតរួមទាំងគ្រួសារខ្ញុំ ត្រូវបន្តជម្លៀសទៅខេត្តព្រៃវែង។ ប៉ារបស់ខ្ញុំ រៀបចំអីវ៉ាន់រួចជាស្រេច គាត់ក៏ដើរតម្រង់ទៅរកលោកអ៊ំចាស់ម្នាក់ រួចសួរទៅកាន់លោកអ៊ំនោះថា «អត់ទោសលោកបង! តើលោកបងត្រូវជម្លៀសបន្តឬត្រូវនៅទីនេះ?» ហើយនៅពេលដែលប៉ារបស់ខ្ញុំដឹងថា លោកអ៊ំម្នាក់នោះត្រូវនៅទីនេះបន្តទៀត ប៉ារបស់ខ្ញុំក៏ខ្សឹបដាក់ត្រចៀកលោកអ៊ំសុំចែកដងវែករបស់គាត់ដោយសន្យាថានឹងឲ្យជាប្រាក់ខ្លះ។ មួយសន្ទុះ ប៉ារបស់ខ្ញុំដើរត្រលប់មកវិញទាំងទឹកមុខស្រពោន ហើយនិយាយថា លោកអ៊ំនោះ មិនឲ្យដងវែកទេ ព្រោះគាត់ត្រូវការវាជាចាំបាច់ដែរ ហើយលោកអ៊ំនោះ បានប្រាប់ប៉ារបស់ខ្ញុំថា សង្គមនេះលែងត្រូវការចាយលុយកាក់ហើយ មិនចាំបាច់យកលុយកាក់មកឲ្យគាត់នោះទេ ព្រោះគ្មានការលក់ដូរអ្វីទៀតទេ។

យើងនាំគ្នាស្តាយអីវ៉ាន់ចាំបាច់ដែលអាចយកទៅតាមខ្លួនបាន ហើយអីវ៉ាន់ណាយកមិនកើត យើងបោះចោលខ្លះ រួចធ្វើដំណើរសំដៅទៅខេត្តព្រៃវែង។ មនុស្សច្រើនណាស់ធ្វើដំណើរតាមផ្លូវ ពេលខ្លះយើងត្រូវដើរកាត់ព្រៃ ពេលខ្លះកាត់តាមវាល ហើយមិនយូរប៉ុន្មាន យើងបានមកដល់អ្នកលឿង ដែលជាព្រំប្រទល់ខេត្តកណ្តាលនិងព្រៃវែង។ ទូកជាច្រើនបានមកចម្លងយើង ហើយកងទ័ពអាវខ្មៅមួយក្រុមធំបានជួយជញ្ជូនអីវ៉ាន់ដាក់លើទូក និងជួយចម្លងមនុស្សទាំងអស់មិនឲ្យសេសសល់សូម្បីតែម្នាក់។ យើងត្រូវធ្វើដំណើរបន្តទៅមុខទៀត យប់កន្លែងណា សម្រាកកន្លែងហ្នឹង។ មិនយូរប៉ុន្មាន គ្រួសាររបស់ខ្ញុំ ត្រូវបានជម្លៀសដល់ស្រុកកំពង់ត្របែក។ យើងរស់នៅឃុំប្រាសាទ ក្បែរឃ្លាំងចាស់មួយនៅពោធិ៍អជ្ញាស្រី។ ខ្មែរក្រហម ប្រើឲ្យគ្រួសាររបស់យើងទៅកាប់ដើមប្រចាក់នៅក្បែរទីនោះ ដែលមានដើមប្រចាក់ដុះច្រើនអនេកលើដីទំហំរាប់ហិកតា។ ខ្មែរក្រហមឲ្យយើងធ្វើការតាំងពីព្រលឹមទល់ព្រលប់គ្មានបានសម្រាកស្រួលឡើយ។

គ្រួសាររបស់ខ្ញុំ ស្នាក់នៅទីនោះបានត្រឹមតែពីរថ្ងៃ ក៏ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅឃុំអន្សោងវិញម្តង។ យើងត្រូវបានអង្គការចាត់ឲ្យទៅ

ស្នាក់នៅជាមួយនឹងគ្រួសារមួយ ដែលមានសមាជិកបួននាក់ បូករួមជាមួយនឹងគ្រួសាររបស់ខ្ញុំមានសមាជិកបួននាក់ទៀត សរុបទៅគឺប្រាំបីនាក់។ ពេលជួបម្ចាស់ផ្ទះ ប៉ារបស់ខ្ញុំ បាននិយាយទៅកាន់ពួកគេថា «លោកបង អ្នកបងអើយ គ្រួសារខ្ញុំសូមផ្ញើខ្លួនផ្ញើប្រាណផង! យើងត្រូវបានជម្លៀសមកពីឆ្ងាយមិនស្គាល់ទិសតំបន់អ្វីទេ! សូមជួយយកអាសាគ្រួសាររបស់ខ្ញុំផង!»។ ពួកគេបានឆ្លើយតបមកវិញថា «មិនអីទេលោកប្អូន! ចាត់ទុកថាយើងគឺជាគ្រួសារតែមួយទៅចុះ! ចាប់ពីពេលនេះទៅយើងត្រូវប្រឹងប្រែងធ្វើការតាមបញ្ជារបស់អង្គការ! ឥឡូវឆាប់ចូលសម្រាកទៅ ព្រោះស្អែកត្រូវក្រោកឡើងធ្វើការផង!»។ ឮដូច្នោះហើយ ប៉ារបស់ខ្ញុំ បានអរគុណពួកគេដោយការគោរព ហើយបានរៀបចំក្រាលកន្ទេលចងមុង នៅត្រង់ល្វែងចន្ទ រួចពួកយើងនាំគ្នាចូលសម្រាន្ត។ ពិតជាសំណាងខ្លាំងណាស់ ម្ចាស់ផ្ទះនោះមានសន្តានចិត្តល្អ ព្រមជួយយកអាសាគ្រួសាររបស់ខ្ញុំដោយមិនរើសអើងទេ។

ព្រហាមឡើង ព្រះអាទិត្យរះភ្លឺច្បាស់ត្រចះល្អ អំសែម និងអំយ៉ាន បាននាំខ្ញុំ និងប៉ាម៉ាក់របស់ខ្ញុំ ទៅជីកប្រឡាយ លើកទំនប់នៅឯបឹងវែង។ ចំណែកឯ បញ្ញាវឌ្ឍន៍ប្អូនរបស់ខ្ញុំ នៅជាកុមារនៅឡើយ ដូច្នេះ បញ្ញាវឌ្ឍន៍ ត្រូវអង្គការយកទៅឲ្យស្នាក់នៅរួមជាមួយកុមារដទៃទៀត ដើម្បីរៀនសូត្រអក្សរ លេខ ខ្លះៗ។

ចម្ងាយពីផ្ទះ ទៅដល់បឹងវែង ចម្ងាយប្រមាណជា៣គីឡូម៉ែត្រ ខ្ញុំដើរទម្រាំតែដល់ទន់ជង្គង់រកកល់ចង់ដួល ប៉ុន្តែយ៉ាងណា ខ្ញុំបានជជែកគ្នាលេងខ្លះជាមួយបង យ៉ារី និងយ៉ាដា ធ្វើឲ្យខ្ញុំបានស្រាកស្រាន្តក្នុងអារម្មណ៍គួរសមដែរ។ មនុស្សម្នាច្រើន ណែនណាន់តាន់តាប់ដូចហ្វូងគោ មានសម្លៀកបំពាក់ពណ៌ខ្មៅនិលកំពុងតែញាប់ដៃញាប់ជើងជីកប្រឡាយ លើកភ្លឺធ្វើទំនប់យ៉ាងធំ ដែលគេហៅថាភ្លឺអាង។ ម្នាក់ៗប្រឹងកាប់ដី ប្រឹងរែកមិនហ៊ានឈប់និងភ្លូញភ្លែរទេ ទោះបីជាហត់នឿយយ៉ាងណា ព្រោះខ្លាចអង្គការចោទថាខ្ជាំងក្បត់ ហើយអូសកយកទៅសម្លាប់។ ដល់ម៉ោងសម្រាកបាយថ្ងៃត្រង់ ក្នុងចិត្តរបស់ខ្ញុំ ត្រេកអរជាពន់ពេក ព្រោះក្រពះរបស់ខ្ញុំស្រេកឃ្លានខ្លាំងណាស់ ដោយសារការចំណាយកម្លាំងច្រើន

ហួសប្រមាណលើការងារទាំងអស់នោះ។ ខ្ញុំត្រូវហូបរួមជាមួយសមមិត្តទាំងឡាយទៀត។ ឱអនិច្ចាអើយ! បបរវាថ្លាដូចទឹកភ្នែក ក្រូវឹកវាល់វែកហូបមិនគ្រប់គ្រាន់តើយើងមានកម្លាំងមកពីណាសម្រាប់ធ្វើការនោះបើហូបតែប៉ុណ្ណឹង? តើនរណាអាចទ្រាំទ្រួច? ឃើញដូច្នោះហើយ ទឹកភ្នែករបស់ខ្ញុំ ស្រាប់តែហូរស្រក់កាត់ផែនថ្ពាល់ដោយមិនដឹងខ្លួនទាល់តែសោះ។ បងយ៉ារី និងយាដា បានដើរមកក្បែរខ្ញុំ ហើយបានសួរនាំថា «មិត្តប្អូនកើតអី? មិត្តប្អូនមិនស្រួលខ្លួនមែនទេ? ចាំមិត្តបងទៅប្រាប់មេកងសុំការអនុញ្ញាតឲ្យមិត្តប្អូនបានសម្រាក!»។

ក្រោមកំដៅថ្ងៃក្តៅហែងនារដូវប្រាំង មនុស្សម្នាទាំងឡាយខិតខំបំពេញការងារតាមបញ្ជារបស់អង្គការ មិនហ៊ានហាមាត់តវ៉ានោះទេ។ អ្នកខ្លះធ្វើការទាំងខ្លួនមានជំងឺត្រដាបត្រដួស ពេលខ្លះក៏ត្រូវមេកងធ្វើបាប ព្រោះគិតថាពួកគេលួចខ្ជិល នៅជាប់កម្ពែលពួកចក្រពត្តិ។ ថ្ងៃបណ្តើរកូនព្រិចៗ ម្នាក់ៗប្រឹងកាប់គាស់វែកទូល ហូរញើសជោគអស់ខោអាវ។ នេះហើយ គឺជាផែនការយុទ្ធសាស្ត្ររបស់អង្គការ ដែលត្រូវជីកប្រឡាយ លើកទំនប់ភ្លឺស្រែ ព្រោះអង្គការចង់បង្កើតឲ្យមានប្រព័ន្ធជារាសាស្ត្រ មិនចង់ធ្វើស្រែប្រវាស់នឹងមេឃ។ ឱ ផែនការមហាលោតផ្លោះអើយ ដូចបង្ខំរាស្ត្រឲ្យទៅស្លាប់អីចឹង! ពេលណាក៏ខ្ញុំឮមេកងស្រែកបញ្ជាឲ្យយើងទាំងអស់គ្នាធ្វើការវាយសម្រុកសម្រេចផលស្រូវឆ្នាំ១៩៧៨ ខាងមុខយកបីតោនកន្លះ និងប្រាំពីរតោនក្នុងមួយហិកតាឲ្យបានមួយរយភាគរយជាដាច់ខាតដែរ។ ហឺ! បដិវត្តន៍ដ៏ស្អាតបរិសុទ្ធអើយ! វិទ្យាសាស្ត្រពិភពលោកដើរដល់ណាដល់ណីហើយ តែបដិវត្តន៍នេះបែរជាវិលត្រលប់ក្រោយទៅរកលក្ខណៈបុរាណទៅវិញ។ ហឺ! ប្រៃប្រួលអស់ហើយ ខ្មែរក្រហម បានលុបបំបាត់អស់ហើយវប្បធម៌ដ៏ល្អផូរផង់ ព្រះសង្ឃត្រូវគេសម្លាប់ឬចាប់ផ្សឹក វត្តអារាមខ្លះត្រូវបានកម្ទេចចោល ហើយអង្គការតែងតែនិយាយថា កម្ទេចព្រះមួយអង្គ ចំណេញស៊ីម៉ង់ត៍មួយបាវ! ជយោ! អង្គការបដិវត្តន៍ដ៏រុងរឿង រុះផ្ទះក្បឿងទៅនៅផ្ទះស្បូវ ជយោ! អង្គការបដិវត្តន៍ដ៏ត្រឹមត្រូវ រុះផ្ទះស្បូវទៅនៅក្នុងព្រៃ។

ខ្ញុំវល់តែគិត ក៏ភ្លេចថាដល់ម៉ោងឈប់សម្រាក បងយ៉ារី និងយ៉ាដា មកហៅខ្ញុំឲ្យទៅផ្ទះ។ ខ្ញុំទាំងបីនាក់រួតរះប្រញាប់ទៅមុន ចំណែកឯ ប៉ា ម៉ាក់ អ៊ំសែម និងអ៊ំយ៉ាន ដើរមកតាមក្រោយ។ ពួកខ្ញុំដើរដល់ខាងមុខបន្តិច បានជួបជាមួយនឹងសមមិត្តបុរសម្នាក់ ដើរតែឯង ទឹកមុខក្រៀមក្រំស្រពាប់ស្រពោន មានរង្វង់ភ្នែកខ្មៅ បបូរមាត់ស្លេកស្លាំង។ ខ្ញុំអាចស្មានបានថា សមមិត្តរូបនោះ ប្រាកដជាមានជំងឺជាប់នឹងខ្លួនជាក់ជាពុំខាន។ បងយ៉ារី មើលមុខសមមិត្តបុរសនោះហើយ ក៏វាចាសួរថា «ឧត្តម! មិត្តឯងឈឺមែនទេ បានជាទឹកមុខស្លេកស្លាំងយ៉ាងនេះ? »។ ឧត្តមឆ្លើយតបទាំងគ្មានកម្លាំងថា «បាទមិត្តបង! ខ្ញុំមានអារម្មណ៍ដូចជាមិនសូវស្រួលខ្លួន នេះប្រហែលមកពីខ្ញុំហូបមិនគ្រប់គ្រាន់ សម្រាកមិនគ្រប់គ្រាន់ហើយមើលទៅ?»។ ឮដូច្នោះ បងយ៉ារី ណែនាំឲ្យ ឧត្តម រាយការណ៍ប្រាប់អង្គការ ក្រែងបានឈប់សម្រាកមើលជំងឺ ខ្លាចគ្មានកម្លាំងធ្វើការ ហើយនឹងត្រូវអង្គការចោទប្រកាន់និងអាចរឹតបន្តឹងចំពោះឧត្តមជាងនេះទៀត។ ប៉ុន្តែ ឧត្តម មិនព្រមទេ ហាក់បីដូចជាភ័យខ្លាចមិនចង់ឲ្យអង្គការដឹង ហើយនិយាយតបវិញថា «ខ្ញុំមិនអីទេមិត្តបង! ស្អែកទៅ ខ្ញុំលែងអីហើយ! ខ្ញុំមិនចង់ឲ្យអង្គការចោទប្រកាន់ថាខ្ញុំផ្តេកផ្សំផ្តួលរមួលផ្សំគ្រិច ឈឺតិចៗថាឈឺខ្លាំងនោះទេ»។ ឧត្តម បានងាកមកមើលមុខ ហើយញញឹមសួតមកកាន់ខ្ញុំ ដោយសួរថា «មិត្តនារីនេះជាមូលដ្ឋានថ្មីឬ? ខ្ញុំដូចជាមិនដែលឃើញ មិនដែលស្គាល់ពីមុនមក»។ យ៉ាដា ក៏បានណែនាំខ្ញុំឲ្យ ឧត្តម ស្គាល់ថា «ចា៎! ពិតមែនហើយ សុភីនាថ ជាអ្នក ១៧មេសា ត្រូវបានជម្លៀសចេញពីភ្នំពេញមកទីនេះ ហើយសព្វថ្ងៃមិត្តរស់នៅផ្ទះជាមួយនឹងគ្រួសារខ្ញុំ»។ ភ្លាមនោះ បងយ៉ារី ក៏បាននិយាយកាត់ថា «ឧត្តម! ខ្ញុំគិតថាយើងជជែកគ្នាលេងតែប៉ុណ្ណោះបានហើយ នេះបើអង្គការឃើញច្បាស់ជាគិតថាមិត្តឯង ហើយនឹងពួកខ្ញុំនិយាយបែបលែបខាយពាក្យសម្តីស្រីប្រុសជាក់ជាពុំខាន ដូច្នេះពួកខ្ញុំគិតថា សុំទៅមុនហើយណា»។

ខ្ញុំងាកមើលទៅសមមិត្ត ឧត្តម រួចញញឹមជាក់គាត់ដោយភាពទន់ភ្លន់ គាត់ក៏ញញឹមតបមកខ្ញុំវិញមុននឹងយើងបែកគ្នា។ ពួកខ្ញុំទាំងបី ក៏ដើរទៅមុនតម្រង់ទៅផ្ទះ។ ទៅដល់ផ្ទះភ្លាម ពួកយើងក៏ម្នីម្នាទៅផ្ទះបាយ ដើម្បីទទួលយកចំណែក

បបរ ដែលអង្គការបានចែកឲ្យ។ ខ្ញុំជាអ្នកមូលដ្ឋានថ្មី ត្រូវគេមើលងាយ និយាយឌឺដងនិងរើសអើងសព្វគ្រប់បែបយ៉ាង សូម្បីតែមេចុងភៅ ពេលដួសបបរឲ្យខ្ញុំ ក៏ដួសមិនពេញស្រួលដូចប្រជាជនដទៃទៀតដែរ។ មេចុងភៅ គ្រលែងវែកឲ្យកំពប់បបរចេញស្ទើរពាក់កណ្តាល។ ខ្ញុំទទួលបាន អាហារហូបមិនដែលគ្រប់គ្រាន់ទេ ហើយត្រូវអ្នកមូលដ្ឋានចាស់និយាយចោលដឹងទាំងដងមកថា អ្នក១៧មេសា ជាអ្នកបញ្ឆើក្អែក ឬក៏ថា អ្នកថ្មីគ្មានអ្វីក្រៅពីពោះអាចម៍ និងពោះទឹកទេ។ ខ្ញុំហូបបបរួចហើយ ក៏ប្រញាប់ប្រញាល់ទៅផ្ទះ ដើម្បីងូតទឹកសម្អាតកាយដោយមិនខ្វល់នឹងសំដីទាំងអស់នោះឡើយ។ ខោអាវមានតែមួយចង្កេះ ឆ្អេះនឹងខ្លួន មិនមានខោអាវផ្លាស់ប្តូរផ្សេងទេ ធ្វើការក៏ស្លៀកមួយបំលាស់ហ្នឹង ពេលគេងក៏មួយបំលាស់ហ្នឹង ពេលងូតទឹកមិនដែលហ៊ានបោកសម្អាតទេ ព្រោះខ្លាចមិនស្ងួតមិនមានខោអាវសម្រាប់ស្លៀកទៅធ្វើការ ទោះបីជាធំក្លិនឆ្អេះឆ្អាបយ៉ាងណាក៏ចេះតែទ្រាំទៅ។ ខោអាវរបស់ប្រជាជនម្នាក់ៗ ត្រូវញើសបែកផ្តាំអំបិល ក្អែលប្រឡាក់ខ្មៅ ដីជាប់ឲ្យស្រមក។ ខ្ញុំគ្រាន់តែលើករលាស់ក៏យកមកស្លៀកវិញ ហើយក៏ប្រាសខ្លួនចូលគេងទៅ។

រៀងរាល់ព្រឹកឡើង ខ្ញុំត្រូវកាន់ចប បង្គី ទៅជីកប្រឡាយនិងលើកទំនប់បន្តទៀត។ ពេលនេះ អង្គការ បានចែកចំណែកឲ្យខ្ញុំបីនាក់ បងយ៉ារី និងយ៉ាដា។ យើងត្រូវជីកដីពីរម៉ែត្រគូបឲ្យហើយក្នុងមួយថ្ងៃ។ កន្លែងដែលខ្ញុំត្រូវជីក គឺនៅក្បែរគ្នាជាមួយនឹងសមមិត្ត ឧត្តម ដែលខ្ញុំបានជួបកាលពីម្សិលមិញដែរ។ យើងមិនហ៊ាននិយាយស្តីរកគ្នាឡើយ។ ម្នាក់ៗខិតខំប្រឹងតែរៀងៗខ្លួន ព្រោះខ្លាចជីកដីមិនហើយត្រូវអង្គការពិន័យ។ ណាមួយពួកខ្ញុំជាស្រី មិនសូវមានកម្លាំង ដូច្នេះមានតែខំប្រឹងឲ្យអស់សមត្ថភាព។ មេកងចេះតែដើរក្រវែលក្បែរខ្ញុំ ខ្ញុំកាន់តែមានអារម្មណ៍ភិតភ័យក្នុងចិត្ត ឱនមុខចុះប្រឹងប្រែងធ្វើការ។ មេកងបាននិយាយដោយសម្តីមុតស្រួចថា «កង់ប្រវត្តិសាស្ត្រវិលទៅមុខជានិច្ច បើអ្នកណាជំទាស់ប៉ះដៃកិនដៃ ប៉ះជើងកិនជើង»។ ឮដូច្នោះហើយ ពួកយើង មិនដែលហ៊ានតវ៉ាទេ យើងចេះតែខំធ្វើការទាំងត្រដាបត្រដួស ព្រោះខ្លាចអង្គការយកទៅរៀនសូត្រ។ ឱលោកអើយ! ពេលណាទើបយើងរួចផុតពីនឹមដែកអម្រែកទុក្ខគុកឥតជញ្ជាំងមួយនេះ?

ពេលល្ងាច មុនចូលដំណេក ខ្ញុំនឹកដល់ បញ្ញាវឌ្ឍន៍ ប្អូនប្រុសរបស់ខ្ញុំ។ បញ្ញាវឌ្ឍន៍ រស់នៅជាមួយកងកុមារ មិនដឹងថាបានសុខឬយ៉ាងណានោះទេ? ណាមួយបែកពីប្អូនរាប់ខែ មិនដែលបានជួបប្អូនសូម្បីតែម្តង។ ខ្ញុំបាននិយាយពិភាក្សាជាមួយប៉ាម៉ាក់របស់ខ្ញុំថា «ពុក ម៉ែ! ខ្ញុំនឹកបញ្ញាវឌ្ឍន៍ខ្លាំងណាស់ ខ្ញុំចង់ជួបប្អូនណាស់ តើធ្វើម្តេចទៅ ទើបបានជួបគេ មិនដឹងថាគេបានសុខ ឬទុក្ខយ៉ាងណាទេ?»។ ប៉ារបស់ខ្ញុំឆ្លើយថា «ចាំពុកសាកស្នើសុំថ្នាក់លើ ដើម្បីសុំជួបបញ្ញាវឌ្ឍន៍ ម្តង! ចាំស្អែក ចាំពុកសាកល្បងស្នើសុំទៅអង្គការ ឥឡូវកូនសម្រាកទៅ ព្រោះស្អែកត្រូវក្រោកឡើងទៅធ្វើការផង»។

ព្រឹកឡើង ខ្ញុំក្រោកទៅធ្វើការជាធម្មតា តែអ្វីដែលខ្ញុំទន្ទឹងនោះ គឺចង់ជួបប្អូនប្រុសសំណព្វរបស់ខ្ញុំ មិនដឹងថាបានជួបគេឬអត់ទេ? ដល់ម៉ោងសម្រាក ហូបបាយថ្ងៃត្រង់ ប៉ាម៉ាក់របស់ខ្ញុំ ក៏ដើរសំដៅមកកាន់ខ្ញុំ រួចនិយាយប្រាប់ថា «ថ្ងៃនេះ អង្គការអនុញ្ញាតឲ្យយើងទៅជួប បញ្ញាវឌ្ឍន៍ ដូច្នេះកូនឆាប់ហូបបបរឲ្យអស់ទៅនឹងអាលបានទៅជួបប្អូន»។

ខ្ញុំត្រេកអរខ្លាំងពេករហូតដល់ស្រក់ហូរទឹកភ្នែកមិនដឹងខ្លួន។ ខ្ញុំ បានស្តាត់ទៅជួបប្អូនប្រុសរបស់ខ្ញុំជាមួយប៉ានិងម៉ាក់។ គ្រាន់តែឃើញ បញ្ញាវឌ្ឍន៍ ភ្លាមទឹកភ្នែករបស់ខ្ញុំហូរស្រក់មកមិនឈប់សោះ ព្រោះនឹកអាណិតប្អូនខ្លោចចិត្ត។ បញ្ញាវឌ្ឍន៍ រត់មកឱបខ្ញុំ ហើយខ្ញុំក៏យកដៃទាំងពីរឱបប្អូនប្រុសខ្ញុំវិញយ៉ាងណែន ប៉ុន្តែដៃរបស់ខ្ញុំដូចជាមិនបានប៉ះនូវរាងកាយដែលមានសាច់ទ្រលុកទ្រលន់របស់ប្អូនដូចពីមុនទៀតទេ។ ដៃរបស់ខ្ញុំហាក់បីដូចជាឱបគ្រោងឆ្អឹងទៅវិញ។ ឱប្អូនប្រុសខ្ញុំអើយ! ស្តមសល់តែស្បែកដណ្តប់ឆ្អឹង មុខមាត់ស្លក់ ស្តមសល់តែក្បាលនិងក្បាលជង្គង់។ ខ្ញុំបានអង្អែលក្បាលប្អូនប្រុស ហើយសួរនាំប្អូនថា «ម្តេចក៏អូនឯងស្តមដល់ថ្នាក់នេះ?»។ ប្អូនខ្ញុំឆ្លើយថា «ខ្ញុំហូបមិនដែលបានឆ្អែតទេបង ហូបបានតិចតួចតែប៉ុណ្ណោះ ពេលខ្លះត្រូវគេដណ្តើមរបស់ខ្ញុំអស់រលីងក៏មានដែរ»។

ឮសម្តីរបស់ប្អូនប្រុស ទឹកភ្នែករបស់ខ្ញុំរឹតតែហូរស្រក់ មិនអាចទប់បាន។ ខ្ញុំអាណិតប្អូនណាស់ តែមិនដឹងថាត្រូវជួយគាត់តាមរបៀបណា មានតែបណ្តោយតាមយថាកម្ម។ ពួកយើងបានជួប បញ្ញាវឌ្ឍន៍ ត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះ ព្រោះថា

ដល់ពេលដែលយើងត្រូវទៅធ្វើការវិញ។ ខ្ញុំ និងប៉ាម៉ាក់ បានឱប បញ្ញាវឌ្ឍន៍ មុនចាកចេញទៅ។ ខ្ញុំឈានជើងចាកចេញពីប្អូនប្រុសទាំងអួលណែនក្នុងចិត្តតែធ្វើម្តេចយើងគ្មានសិទ្ធិសេរីភាពគ្រប់គ្រាន់ រស់នៅក្រោមគំនាបរបស់អង្គការយ៉ាងដូច្នេះ។

បន្ទាប់ពីបានជួប បញ្ញាវឌ្ឍន៍ ពីរថ្ងៃក្រោយមក ខ្ញុំស្រាប់តែបានទទួលដំណឹងថា «បញ្ញាវឌ្ឍន៍ ធ្លាក់ខ្លួនឈឺធ្ងន់។ ខ្ញុំ និងប៉ាម៉ាក់របស់ខ្ញុំ បានទៅមើលបញ្ញាវឌ្ឍន៍។ ឱពុទ្ធោលោកអើយ! គេទុកប្អូនខ្ញុំចោលឲ្យដេកលើគ្រែសន្ធឹកសន្ធែត្រដរខ្យល់តែម្នាក់ឯង ថ្នាំពេទ្យក៏គ្មាន កន្លែងព្យាបាលក៏គ្មានអនាម័យ ឈឺអ្វីក៏ច្រកតែស្គរគ្នោត។ ប្អូនរបស់ខ្ញុំឈឺដល់ម្ល៉ឹងហើយ មុខឡើងស្លេកស្លាំង បបូរមាត់ឡើងសអស់ទៅហើយ ក្រុមគ្រូពេទ្យទាំងនោះធ្វើព្រងើយកន្តើយ មិនខ្វីអើពើជាមួយប្អូនរបស់ខ្ញុំទេ។ ខ្ញុំរត់ទៅជិតគ្រែដែលប្អូនប្រុសរបស់ខ្ញុំកំពុងគេង ខ្ញុំហាមាត់និយាយទាំងទឹកភ្នែកទៅកាន់ប្អូនប្រុសរបស់ខ្ញុំថា «បញ្ញាវឌ្ឍន៍អូន! និយាយរកបងមួយម៉ាត់មកអូន! ពេលនេះអូនយ៉ាងម៉េចហើយ? និយាយប្រាប់បងមកអូន!»។

សំឡេងដង្ហើយហៅរបស់ខ្ញុំទាំងអម្បាលម៉ាន ហាក់ដូចជាមិនចូលត្រចៀករបស់ បញ្ញាវឌ្ឍន៍ទាល់តែសោះ។ គេលែងដឹងខ្លួនហើយ គេមិនអាចមើលឃើញខ្ញុំ មិនអាចស្តាប់ឮសំឡេងដែលខ្ញុំនិយាយទៀតទេ។ មច្ចុរាជ មិនប្រណីមេត្តាបានមកផ្តាច់សង្ខារប្អូនប្រុសរបស់ខ្ញុំ ឲ្យចាកចេញឆ្ងាយពីគ្រួសារជារៀងរហូតហើយ។ ខ្ញុំទប់ទឹកភ្នែកមិនបាន យំឱបសពប្អូនប្រុស ដោយក្តីសោកស្តាយ និងអាឡោះអាល័យ។ ខ្ញុំយំរហូតដល់គាំង និយាយលែងចេញ។ ម៉ាក់របស់ខ្ញុំយំខ្សឹកខ្សួលតិចៗ មិនមាននិយាយស្តីអ្វីទាំងអស់សូម្បីតែមួយម៉ាត់។ អង្គការមិនទុកពេលឲ្យយើងនៅយំយែកសោកស្តាយអាឡោះអាល័យយូរឡើយ។ ខ្ញុំបានឲ្យបងយ៉ារីទៅហៅលោកអ៊ំ សែម និងអ៊ំយ៉ាន ដើម្បីជួយយកសាកសពប្អូនប្រុសរបស់ខ្ញុំទៅបញ្ចុះ។ ពេលនោះ សមមិត្តឧត្តម ក៏បានមកជួយយកសពប្អូនប្រុសរបស់ខ្ញុំទៅបញ្ចុះនៅក្រោមដើមពោធិ៍ខាងក្រោយផ្ទះរបស់អ៊ំសែមដែរ។ ក្រោយពីបានបញ្ចុះសពប្អូនប្រុសខ្ញុំរួចហើយ ខ្ញុំជូតទឹកភ្នែក ហើយទៅធ្វើការជាធម្មតា ព្រោះខ្លាចត្រូវអង្គការយកទៅអប់រំ។ ខ្ញុំត្រូវព្យាយាមកាត់ចិត្តពីភាពអាឡោះអាល័យសោកស្តាយ ហើយប្រឹងប្រែងកាន់ចបបង្គី ធ្វើការតាមមុខនាទីរបស់ខ្លួន។

រដូវវស្សាបានចូលមកដល់ មនុស្សម្នាទាំងឡាយត្រូវមមាញឹកជាមួយនឹងការងារស្រែចម្ការ ស្ទូង ដក គ្មានពេលឈប់ឈរ។ ភ្លៀងបង្អុរមកជោកជាំដី ប្រឡាយនីមួយៗមានទឹកពេញប្រៀប។ ស្រែនីមួយៗមានមនុស្សម្នាយ៉ាងច្រើនកំពុងតែភ្ជួររាស់និងដកស្ទូង។ ការងារធ្វើគ្មានស្រាកស្រាន្ត គ្មានទំនេរដៃ។ ពេលខ្លះ អង្គការកំណត់ឲ្យធ្វើឲ្យហើយ បើធ្វើមិនហើយទេ នឹងអាចត្រូវដកសមាជិកចេញ ហើយតម្រូវឲ្យធ្វើទាល់តែហើយ ទើបអនុញ្ញាតឲ្យឈប់សម្រាក។ ប្រុសៗនាំគ្នាភ្ជួររាស់ រែកកណ្តាប់ ស្រីដកស្ទូង។

រដូវវស្សាភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃ យើងត្រូវធ្វើការហាលភ្លៀងហាលខ្យល់ខោអាវតែមួយបំលាស់ ត្រូវទឹកភ្លៀងផង ញើសផង មានក្លិនផ្អូមជូរ កើតទៅជាចៃចេញពីសាច់តែម្តង។ អ្នកខ្លះក៏កើតទៅជារោលកន្ទួលរមាស់ពេញខ្លួន ប៉ុន្តែគ្មានថ្នាំអ្វីព្យាបាលទេ។ យើងប្រើទឹកត្នោតជូរ បានធូរស្រាលខ្លះដែរ។ ក្រោយពីការងារដកស្ទូងរួចរាល់ ប្រជាជនមិនបានឈប់សម្រាកទេ។ ម្នាក់ៗត្រូវកាន់ការងារផ្សេងគ្នា ដូចពួកខ្ញុំ ត្រូវអង្គការឲ្យទៅលាយដីលេខមួយ ទុកប្រើប្រាស់សម្រាប់ស្រូវស្រែ។ ស្រូវស្រែរីកបែកគុម្ព ត្រសុំត្រសាយស្រស់ខៀវខ្ចី។ មនុស្សម្នាប្រុសស្រីមានទឹកចិត្តត្រេកអរសង្ឃឹមថា នឹងបានហូបគ្រប់គ្រាន់ ព្រោះស្រូវដែលខ្លួនបានខិតខំដកស្ទូងពេលនេះ លូតលាស់ល្អចេញផ្លែផ្កាគ្រប់ៗស្រែ។

ម៉ែនយូរប៉ុន្មាន រដូវច្រូតបានមកដល់ យើងចាប់ផ្តើមឃ្មាតខ្ចី ធ្វើការច្រូតកាត់បន្តទៀត។ ម្នាក់ៗខំធ្វើការគ្មានបន្ទុរបន្តុយដៃទេ។ ស្រូវស្រែផ្លែដូចគេចាក់ក្រាលប្រមូលផលបានប្រមាណកន្លះខែទៅហើយ ប៉ុន្តែយើងនៅតែហូបមិនគ្រប់គ្រាន់ដដែល។ ចុះស្រូវអង្ករទាំងនោះ យកទៅណា? ខ្ញុំនៅតែហុតបបរថ្លា វាល់វែកដដែល។ ឱ! មហាលោតផ្លោះ មហាអស្ចារ្យ ហុតទឹកបបរថ្លាហូរស្រក់ទឹកភ្នែក។ កាលដែលធ្វើស្រែប្រវាស់នឹងមេឃរាស្ត្រស៊ីបាយ ដល់ពេលធ្វើស្រែប្រវាស់នឹងប្រឡាយរាស្ត្រហុតបបរ។ នេះបានចំជាមហាបដិវត្តន៍ មហារុងរឿងមែន។

ព្រឹកស្អែក ប៉ារបស់ខ្ញុំ ត្រូវបានអង្គការចាត់ទុកឲ្យជួយដឹកអង្ករទៅឧបត្ថម្ភកម្លាំងទ័ពនៅភូមិភាគនិរតី។ ដូច្នេះគាត់ត្រូវឃ្លាតឆ្ងាយពីគ្រួសារមួយរយៈ ព្រោះថាគាត់ត្រូវធ្វើដំណើរផ្លូវឆ្ងាយ មិនដឹងថាពេលណាទើបគាត់វិលត្រលប់មកវិញទេ។

ខ្ញុំសែនពិបាកចិត្តស្អិតទ្រូង មិនចង់ឃ្លាតពីប៉ារបស់ខ្ញុំឡើយ។ ប្អូនប្រុសរបស់ខ្ញុំ បានឃ្លាតចាកឆ្ងាយពីក្រុមគ្រួសារទៅហើយហេតុនេះហើយអារម្មណ៍របស់ខ្ញុំចេះតែខ្លាចចេះតែបារម្ភពីរឿងនេះ ប៉ុន្តែយើងមិនអាចប្រឆាំងជាមួយអង្គការបានទេ។ ល្ងាចនេះ ប៉ារបស់ខ្ញុំ មានទឹកមុខក្រៀមក្រំមិនមាត់មិនកអ្វីសោះ មើលទៅគាត់ដូចជាមិនចង់ឃ្លាតចាកឆ្ងាយពីគ្រួសារឡើយ។ គាត់បាននិយាយមកកាន់ខ្ញុំថា «សុកីនាថ! មើលថែខ្លួនឯង និងម្តាយឯងផង ពុកមិនដឹងជាពេលណាទើបត្រលប់មកវិញទេ»។

ប៉ារបស់ខ្ញុំ បានធ្វើដំណើរចេញទៅតាំងពីព្រលឹមស្រាងៗ ខ្ញុំនិងម៉ាក់របស់ខ្ញុំបានត្រឹមតែតាមមើលគាត់បរទេះចេញទៅទាំងអាល័យ និងក្តីបារម្ភ។ បន្ទាប់មកខ្ញុំទៅច្រូតកាត់ដូចសព្វដង។ កន្លងទៅប្រហែលបីថ្ងៃ ខ្ញុំសែននឹករឭកដល់ប៉ារបស់ខ្ញុំណាស់ មិនដឹងថាគាត់ទៅជាយ៉ាងណាទេ? ហើយក៏មិនដឹងថាពេលណាគាត់ត្រលប់មកវិញដែរ? ចាប់តាំងពីប៉ារបស់ខ្ញុំចាកចេញទៅឆ្ងាយ មានរឿងរ៉ាវមិនស្រួលចេះតែកើតមានឡើងជាហូរហែ។ អ្វីដែលធ្វើឲ្យខ្ញុំមិនស្រួលចិត្តនោះ គឺសមមិត្ត កន ដែលជាមេកង ចេះតែមកធាវៅខ្ញុំ និយាយសម្តីលែបខាយ និងនិយាយបញ្ឆិតបញ្ឆៀងធ្វើឲ្យខ្ញុំស្អប់ណាស់។ ទោះបីខ្ញុំមិនចូលចិត្តសមមិត្តកន ខ្ញុំសុខចិត្តមិនតបតគ្រាន់តែញញឹមតិចៗតែប៉ុណ្ណោះ។ រដូវច្រូតបានបញ្ចប់ជាងកន្លះខែទៅហើយ បាត់ដំណឹងប៉ារបស់ខ្ញុំសូន្យឈឹង។ ខ្ញុំកើតទុក្ខរែងរៃគ្មានពេលស្រាកស្រាន្ត ព្រោះមិនដឹងថាប៉ារបស់ខ្ញុំ បានសុខឬទុក្ខយ៉ាងណានោះទេ? ពេលល្ងាច ក្រោយងូតទឹករួចខ្ញុំបានអង្គុយជុំគ្នាជាមួយអ៊ំសែមអ៊ំយ៉ាន បងយ៉ារី យ៉ាជា និងម៉ាក់របស់ខ្ញុំ។ ខ្ញុំបាននិយាយពីក្តីបារម្ភរបស់ខ្ញុំប្រាប់ទៅពួកគាត់។ អ៊ំសែម បាននិយាយលួងលោមខ្ញុំថា «មិនអីទេក្មួយ! កុំបារម្ភខ្លាំងពេក ពីរបីថ្ងៃទៀតពុកក្មួយនឹងមកដល់ជាក់ជាមិនខាន ដ្បិតអីភូមិភាគនិរតីផ្លូវឆ្ងាយ ដូច្នេះទាំងទៅទាំងមកត្រូវប្រើពេលយូរ កុំគិតច្រើនពេក អ៊ំថាមិនអីគឺមិនអីហើយ»។ ខ្ញុំញញឹមទទួលយកពាក្យលួងលោមរបស់ អ៊ំសែម។

ភ្លាមនោះ បងយ៉ារី និយាយទាំងសស្លើតសស្លក់ថា «និយាយអីចឹង ខ្ញុំមានរឿងមួយចង់និយាយដែរថា កាលពីថ្ងៃមុន ខ្ញុំបានឮ សមមិត្តកន ដែលជាមេកងសហការណ៍យើងនេះ ចង់ស្នើទៅខាងអង្គការសុំរៀបការជាមួយ សុកីនាថ

ខ្ញុំឮនិយាយផ្ទាល់ត្រចៀក»។ អ៊ំសែម ដកដង្ហើមធំ និយាយទាំងមុខស្រពាប់ស្រពោនថា «ហឺ! រឿងនេះពិតជាពិបាកប្រកែកតវ៉ាជាមួយខ្លាំងណាស់ ព្រោះជាមេកង បើយើងប្រកែកតវ៉ាជាមួយ ខ្លាចក្រែងតែមានលទ្ធផលមិនល្អ អ៊ំមិនដឹងថាជួយក្មួយយ៉ាងម៉េចទេ? នេះបើរឿងវាជាការពិតមែន បញ្ហានេះយើងពិតជាពុំអាចប្រឆាំងតវ៉ានឹងគេបានទេ បើប្រឆាំងដូចយកពងមាន់ទៅជល់នឹងថ្មអីចឹង»។

យប់នោះ ខ្ញុំគេងមិនលក់សោះ ចេះតែរសាប់រសល់ក្នុងចិត្ត ណាមួយប៉ាត្រូវឃ្លោតធ្ងាយ មួយទៀតឮ ថា សមមិត្តកន ស្នើអង្គការសុំរៀបការជាមួយខ្ញុំទៀត។ បើថារៀបការជាមួយ សមមិត្តកន ខ្ញុំសុខចិត្តស្លាប់ល្អជាង ព្រោះខ្ញុំមិនចង់រួមរាសនាជីវិតជាមួយមនុស្សអាក្រក់ដូចគេឡើយ។ ហឺ! ទុក្ខជាន់លើទុក្ខតែម្តង រឿងមួយមិនទាន់បានធូរស្រាលផង ត្រូវជួបរឿងមួយទៀត។ នេះទេវតាមិនជួយមនុស្សល្អផងទេឬ?

លុះព្រឹកស្អែកឡើង ខ្ញុំបានជួបនឹងសមមិត្ត ឧត្តម។ ខ្ញុំបាននិយាយរឿងរ៉ាវរបស់សមមិត្ត កន ចង់ស្នើអង្គការសុំរៀបការជាមួយខ្ញុំប្រាប់ដល់គាត់។ គាត់ប្រែប្រួលទឹកមុខទៅជាក្រៀមក្រំភ្លាមៗហាក់ដូចជាព្រួយបារម្ភចំពោះខ្ញុំ រួចគាត់ងាកមកនិយាយថា «ខ្ញុំសុំសួរមិត្តដោយត្រង់ តើមិត្តស្ម័គ្រចិត្តព្រមរៀបការជាមួយសមមិត្ត កន ឬទេ?»។ ខ្ញុំឆ្លើយតបភ្លាមថា «ខ្ញុំមិនចង់រៀបការជាមួយគេទេ ខ្ញុំស្អប់គេដល់ឆ្អឹង»។ សមមិត្ត ឧត្តម លើកដៃចង្អុលបាំងមាត់របស់គាត់ ជាសញ្ញាបញ្ជាក់ថាកុំឲ្យនិយាយឮពេក រួចខ្ញុំក៏លែងហ៊ាននិយាយ។ មិត្ត ឧត្តម និយាយបន្តទៀតថា «ខ្ញុំមានវិធីមួយអាចជួយមិត្តបាន តែមិនដឹងថាមិត្តព្រមឲ្យខ្ញុំជួយឬអត់?» រួចមិត្ត ឧត្តម មកឈរក្បែរខ្ញុំ ហើយនិយាយខ្សឹបៗដាក់ត្រចៀកខ្ញុំថា «ខ្ញុំគិតថានឹងស្នើអង្គការសុំរៀបការជាមួយមិត្តឯងឲ្យបានមុនសមមិត្ត កន ហើយយើងរៀបការជាមួយគ្នាគ្រាន់តែជាការសម្តែងតែប៉ុណ្ណោះ តើមិត្តយល់យ៉ាងណាដែរ?»។ ខ្ញុំយល់ព្រមជាមួយនឹងសមមិត្ត ឧត្តម ធ្វើយ៉ាងណាយករួចខ្លួនឲ្យបានមួយគ្រាសិន។

ថ្ងៃរៀបការក៏បានមកដល់ វាពិតជាចម្លែកខ្លាំងណាស់ ព្រោះថាការរៀបការថ្ងៃនេះ គឺមានរហូតដល់ទៅម្ភៃគូឯណោះ។ ខ្ញុំក៏មិនដែលធ្លាប់ជួបប្រទះដែរ ទើបតែពេលនេះ។ ចំណែកឯចាស់ទុំ និងអ្នកចូលរួមក៏គ្មាន គឺមានតែម៉ែឪកូនក្រមុំ

កូនកំលោះ និងអង្គការពីរបីនាក់តែប៉ុណ្ណោះ។ ខ្ញុំ មានតែម្តាយមកចូលរួម ចំណែកឯសមមិត្ត ឧត្តម វិញ គ្មាននរណាមកចូលរួមទេ។ ឪពុកម្តាយរបស់គាត់ស្លាប់ចោលទាំងអស់ រស់នៅកំព្រាតែម្នាក់ឯង។

នៅថ្ងៃរៀបការ អង្គការ បានឡើងធ្វើចំណាប់អារម្មណ៍ ហើយប្រកាសទទួលស្គាល់កូនកំលោះកូនក្រមុំទាំងម្តែគូនេះជាប្តីប្រពន្ធ ដោយឲ្យត្រូវចាត់ទុកអង្គការជាម្តាយឪពុក ព្រមទាំងខិតខំបំពេញការងារជូនអង្គការតរៀងទៅ។ កម្មវិធីត្រូវបានបញ្ចប់ មនុស្សម្នាទាំងឡាយក៏ទះដៃអបអរសាទរ រួចក៏នាំគ្នាទៅធ្វើការរៀងៗខ្លួន។ ចាប់ពីពេលនេះទៅ ខ្ញុំត្រូវរស់នៅជាមួយនឹងសមមិត្ត ឧត្តម ដែលជាប្តីក្លែងក្លាយរបស់ខ្ញុំ។ ខ្ញុំសែនអាណិតដល់សមមិត្ត ឧត្តម ដែលត្រូវចូលខ្លួនមកពាក់ព័ន្ធក្នុងរឿងរបស់ខ្ញុំ។ ពេលដែលខ្ញុំរៀបការជាមួយនឹងសមមិត្ត ឧត្តម សមមិត្ត កន ខឹងខ្លាំងណាស់ ហើយព្យាយាមបំបែកបំបាក់យើងទាំងពីរនាក់។ ខ្ញុំរៀបការបានតែប៉ុន្មានថ្ងៃ សមមិត្ត កន បានស្នើទៅអង្គការបញ្ជាឲ្យសមមិត្ត ឧត្តម ទៅដឹកប្រឡាយនៅបឹងកន្ទឹប។ ពេលនេះ ខ្ញុំ និងសមមិត្ត ឧត្តម ត្រូវរស់នៅឆ្ងាយពីគ្នាហើយព្រោះគាត់ត្រូវអង្គការចាត់តាំងឲ្យទៅរស់នៅឃុំថ្កូវ មួយរយៈពេលសិន ដើម្បីជួយលើកទំនប់ប្រឡាយឲ្យទាន់តាមផែនការដែលអង្គការបានកំណត់ទុក។ យូរៗម្តង ទើបអង្គការអនុញ្ញាតឲ្យខ្ញុំបានជួបនឹងសមមិត្ត ឧត្តម ម្តង។ ខ្ញុំនឹកអាណិតគាត់ជាពន់ពេក ដែលត្រូវទទួលរងនូវការលំបាកដោយសារតែខ្ញុំ។ ពេលខ្ញុំបានជួបគាត់ អារម្មណ៍របស់ខ្ញុំហាក់បីដូចជាប្រពន្ធ និងប្តី ដែលនឹករឭកគ្នា។ ខ្ញុំរត់ទៅឱបគាត់។ ទឹកភ្នែករបស់ខ្ញុំហូរស្រក់កាត់ថ្ពាល់មិនឈប់ឈរ។ សមមិត្ត ឧត្តម យកក្រមាជូតទឹកភ្នែកឲ្យខ្ញុំ ប៉ុន្តែពេលវេលាមិនអនុគ្រោះឲ្យយើងទាំងពីរនាក់ឡើយ។ យើងជួបគ្នាបានតែមួយក្លែត ក៏ត្រូវបែកគ្នាទៅវិញ។ ចំណែកឯនៅពេលយប់ ខ្ញុំចាប់ផ្តើមនឹកមមៃដល់សមមិត្ត ឧត្តម។ ខ្ញុំចាប់ផ្តើមមានចិត្តស្រលាញ់ចំពោះគាត់ហើយ។

ពេលវេលាចេះតែដើរទៅមុខ សភាពការណ៍នយោបាយក្នុងប្រទេសកាន់តែប្រែប្រួល។ នៅក្នុង របបកម្ពុជាប្រជាធិបតេយ្យ ថ្នាក់ដឹកនាំចាប់ផ្តើមមិនទុកចិត្តគ្នា។ អ្នកគ្រប់គ្រងតាមភូមិភាគមួយចំនួន ត្រូវបានគេសម្លាប់ដូចជានៅភូមិភាគបូព៌ានេះជាដើម។ ខ្ញុំចេះតែមមៃគិតថា ប្រទេសជាតិនឹងអាចរួចផុត

ពីសោកនាដកម្មមួយនេះក្នុងពេលឆាប់ៗ។ ប្រសិនជាប្រទេសបានសន្តិភាព សេរីភាពវិញមែន ខ្ញុំប្រហែលជាមិនអាចសប្បាយចិត្តបានទេ ព្រោះថាប៉ាររបស់ខ្ញុំ ក៏ត្រូវឃ្លាតឆ្ងាយបាត់ដំណឹងសូន្យឈឹង មិនដឹងថាគាត់ស្លាប់ ឬរស់? ចំណែកឯ សមមិត្តឧត្តម វិញស្ងាត់ដំណឹងសូន្យឈឹងដូចគ្នាដែរ។ តើឲ្យខ្ញុំសប្បាយរីករាយ ម្តេចនឹងកើត? ពិតជាដូចអ្វីដែលខ្ញុំថាមែន! ពេលនេះកម្លាំងរំដោះប្រទេសកំពុងតែ ព្យាយាមវាយរំដោះហើយ។

មកដល់ថ្ងៃទី០៣ ខែមករា នេះ កងទ័ពរំដោះនិងកងទ័ពវៀតណាម បាន វាយរំដោះយកបានខេត្តស្វាយរៀង។ សភាពការណ៍មិនស្រួល អង្គការ បាន ជម្លៀសប្រជាជនឲ្យចាកចេញពីខេត្តព្រៃវែងទៅកាន់ភូមិភាគដទៃ។ ពេលជម្លៀស ខ្ញុំបានកាន់ដៃម៉ាក់របស់ខ្ញុំជាប់ ព្រោះខ្ញុំខ្លាចត្រូវឃ្លាតឆ្ងាយពីគាត់ម្នាក់ទៀត។ ពេលល្ងាច យើងបានជម្លៀសទៅដល់ទន្លេត្រពែក។ យើងត្រូវឆ្លងកាត់ទន្លេ ភ្លាមនោះកម្លាំងរំដោះបានវាយស្កាត់មុខកងទ័ពខ្មែរក្រហម។ ប្រជាជនទាំងអស់ នាំគ្នារត់គេចយកតែរួចខ្លួន។ ខ្ញុំ និងម្តាយរបស់ខ្ញុំ បានរត់ទៅពួននៅក្នុងគុម្ពោត ព្រៃមួយ។ ពេលនោះស្រាប់តែខ្ញុំបានជួបនឹងសមមិត្ត ឧត្តម។ ខ្ញុំរត់ទៅឱបគាត់ យ៉ាងណែន ដោយសេចក្តីនឹករឭក។ ទឹកភ្នែករបស់ខ្ញុំហូរមកច្រោកៗមិនអាចនឹង ឃាត់ឃាំងបាន។ ខ្ញុំសប្បាយ ចិត្តយ៉ាងខ្លាំងនៅពេលដែលដឹងថា សមមិត្តឧត្តម នៅមានជីវិតនៅឡើយ។ ប្រជាជនមួយចំនួនធំ នាំគ្នាលូចរត់ត្រលប់មកផ្ទះសម្បែង វិញ។ ទីបំផុតភូមិភាគបូព៌ា ត្រូវបានរំដោះ ហើយយើងរស់នៅដោយភាពរីករាយ។

រហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កងកម្លាំងរំដោះ បានវាយរំដោះ បានទីក្រុងភ្នំពេញនៅវេលាម៉ោង ១២កន្លះ។ ក្នុងរយៈពេលប្រមាណតែបី សប្តាហ៍ប៉ុណ្ណោះ កងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ព វៀតណាម បានវាយរំដោះប្រទេសជាតិ បានស្ទើរទាំងស្រុងពីរបបប្រល័យ ពូជសាសន៍នេះ។ ប្រជាជនគ្រប់គ្នាដូចបានរស់រានមានជីវិតសាជាថ្មី គ្រែកអរ រកអ្វីប្រៀបផ្ទឹមពុំបាន។ ពេលនេះបានសុខសន្តិភាពហើយ បានរួចផុតពី យុគអន្ធការគុកឥតជញ្ជាំង និងនឹមដែកអម្រែកទុក្ខហើយ។ ប្រជាជនមួយ ចំនួនក៏បានវិលត្រលប់ទៅកាន់ស្រុកកំណើតរបស់ខ្លួនវិញ។ ប្រជាជនខ្លះទៀត

សម្រេចចិត្តមិនត្រលប់ទៅស្រុកកំណើត ហើយសុខចិត្តរស់នៅតំបន់ថ្មីនេះ កសាងជីវិតគ្រួសាររបស់ខ្លួនសាជាថ្មី។ ចំណែកខ្ញុំ និងម៉ាក់របស់ខ្ញុំ សម្រេចចិត្តថា នឹងរស់នៅលើទឹកដីខេត្តព្រៃវែងបន្តទៅទៀត ព្រោះយើងមានអនុស្សាវរីយ៍នៅទីនេះច្រើនណាស់ ណាមួយខ្ញុំក៏បានកសាងជីវិតគ្រួសារជាមួយបង ឧត្តម ដែរ។

ការគិតរបស់យើងស្រាប់តែផ្ទុយស្រឡះ អ្វីដែលមិនគួរឲ្យជឿបានកើតមានឡើង។ ប៉ារបស់ខ្ញុំ បានវិលត្រលប់មកដល់ផ្ទះវិញ ដែលមានឯកសណ្ឋានជាកងទ័ព។ ខ្ញុំត្រេកអរខ្លាំងក្លឹកក្លាំងអស់ស្មារតី។ ខ្ញុំរត់ទៅឱបប៉ារបស់ខ្ញុំយ៉ាងណែន។ ម៉ាក់របស់ខ្ញុំ ក៏រត់មកឱប ខ្ញុំនិងប៉ា ដែរ។ យើងទាំងបីនាក់សប្បាយចិត្តជាពន់ពេករកអ្វីប្រៀបផ្ទឹមបានឡើយ។ បន្ទាប់មក ខ្ញុំ បានប្រាប់រឿងរ៉ាវរបស់ខ្ញុំជាមួយនឹង ឧត្តម ឲ្យគាត់ស្តាប់។ ប៉ារបស់ខ្ញុំញញឹម ហើយគាត់ក៏បានរៀបរាប់រឿងរ៉ាវ ដែលគាត់បានរត់ទៅធ្វើទ័ពតស៊ូរំដោះប្រទេស រួចនិយាយថា «ឥឡូវស្រុកទេសរបស់យើងទទួលបានសន្តិភាពវិញហើយ! ពុកនឹងនាំក្រុមគ្រួសាររបស់យើងទៅរស់នៅទីក្រុងភ្នំពេញវិញ ម្យ៉ាងទៀត ពុក ត្រូវទទួលតំណែងជាមន្ត្រីរាជការវិញដដែល! យើងនឹងរស់នៅប្រកបដោយសុភមង្គលជាមិនខាន»។

យើងទាំងអស់គ្នាសើចក្អាកក្អាយសប្បាយក្នុងចិត្តឥតឧបមា ព្រោះពេលនេះយើងបានស្គាល់សុភមង្គលជីវិតសាជាថ្មីក្រោយពីបានឆ្លងកាត់ទុក្ខលំបាកអស់រយៈពេលជិត៤ឆ្នាំ ៕

ចប់

១២

រឿងការចងចាំអ្នកយខ្ញុំ

អ្នកនិពន្ធ ៖ ហ៊ួត ទាសនា

១២ ~ រឿង ការចងចាំម្តាយខ្ញុំ

ម្តាយរបស់ខ្ញុំឈ្មោះ សោភ័ណ តែអ្នកផ្ទះរបស់គាត់តែងតែហៅគាត់ថា អាប៉ូច។ ម្តាយរបស់ខ្ញុំគឺជាកូនស្រីពៅក្នុងចំណោមបងប្អូន៤នាក់ ដែលក្នុងនោះមានប្រុសម្នាក់។ គាត់គ្មានឪពុកទេ មានតែម្តាយរកស៊ីចិញ្ចឹមកូនៗ។ គាត់កើតនៅភូមិដើមជ្រៃ ឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល។ ថ្ងៃមួយបន្ទាប់ពីហូបអាហារពេលល្ងាចរួច ខ្ញុំបានសុំឲ្យម្តាយរបស់ខ្ញុំរៀបរាប់ពីរឿងរ៉ាវជីវិតដែលគាត់បានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម ប្រាប់ដល់ខ្ញុំ។ គាត់បានរឭករឿងរ៉ាវដែលគាត់នៅចងចាំថា៖

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលកងទ័ពអាវខ្មៅវាយយកនិងកាន់កាប់ទីក្រុងភ្នំពេញបានទាំងស្រុង។ ពួកអាវខ្មៅ បានប្រកាសឲ្យប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ ចាកចេញពីទីក្រុងជាបន្ទាន់។ ពួកគេប្រកាសប្រាប់ប្រជាជនថា ៣ថ្ងៃក្រោយ អាមេរិកនឹងទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញហើយ។

កាលកងទ័ពខ្មែរក្រហមវាយបែកភ្នំពេញ ខ្ញុំមានវ័យប្រហែល១៤ឆ្នាំ។ គ្រួសាររបស់ខ្ញុំ ជាប្រជាជនមូលដ្ឋាន។ អង្គការមិនបានជម្លៀសពួកយើងចេញទៅណាឆ្ងាយពីភូមិនោះទេ។ ចំណែកការរស់នៅរបស់យើង ក៏មិនសូវជាលំបាកដូចប្រជាជនចំណូលថ្មី ដែលទើបតែជម្លៀសមកពីភ្នំពេញដែរ។

ចូលដល់ឆ្នាំ១៩៧៦ ក្រុមគ្រួសាររបស់ខ្ញុំ លែងបានរស់នៅជួបជុំគ្នាទៀត។ ម្តាយរបស់ខ្ញុំ ត្រូវអង្គការចាត់តាំងឲ្យនៅតា្បញក្រមា បន្ទាប់មកត្រូវផ្លាស់ឲ្យទៅរស់នៅក្នុងខ្ទមតូចមួយឯចុងភូមិ។ បងជាន ដែលជាបងប្រុសធំរបស់ខ្ញុំ ត្រូវអង្គការ

ផ្សំផ្គុំឲ្យរៀបការកាលពីចុងឆ្នាំ១៩៧៥ ហើយមិនយូរប៉ុន្មានបន្ទាប់ពីរៀបការរួច គាត់ត្រូវអង្គការផ្លាស់ឲ្យទៅរស់នៅក្នុងសហករណ៍នៅឯស្ពានថ្មីជាមួយប្រពន្ធរបស់គាត់។ ចំណែក បងប៉ិច ដែលជាបងស្រីទីពីរ ត្រូវអង្គការចាត់តាំងឲ្យធ្វើជាពេទ្យប្រចាំនៅភូមិចុងព្រែក។ បងប៉ុក វិញ ជាបងស្រីទីបី ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាគ្រូបង្រៀននយោបាយដល់ក្មេងៗនៅរកាកោង១។ រីឯខ្ញុំ ត្រូវបានអង្គការចាត់ឲ្យចូលក្រុមកងកម្លាំងទី១។ កងកម្លាំងទី១ គឺជាកម្លាំងជួរមុខ។ ទីកន្លែងណាត្រូវដីកប្រឡាយ ស្ពារប្រឡាយ និងលើកទំនប់ គឺច្បាស់ជាមានវត្តមានខ្ញុំនៅទីនោះហើយ។

ថ្ងៃមួយ កងរបស់ខ្ញុំ ប្រហែលជា២៥នាក់ ត្រូវបានអង្គការចាត់តាំងឲ្យទៅជីកប្រឡាយមួយខ្សែនៅឯស្រុកអូររាំងឪ។ ពេលជិតបញ្ចប់ផែនការជីកប្រឡាយស្រាប់តែមានហេតុការណ៍រន្ធត់មួយបានកើតឡើងនៅកន្លែងធ្វើការរបស់ខ្ញុំ។ នៅពេលដែលខ្ញុំកំពុងញាប់ដៃកាយដីដាក់បង្គី ស្រាប់តែមានសំឡេងកាំភ្លើងលាន់ឡើងនៅក្បែរៗខ្លួនរបស់ខ្ញុំ។ ខ្ញុំឈរភាំង ព្រោះមិត្តក្នុងក្រុមម្នាក់ ត្រូវបានឈ្លបខ្មែរក្រហមបាញ់សម្លាប់ដួលក្បែរជើងរបស់ខ្ញុំ។ ពេលឈ្លប បាញ់សម្លាប់រួចហើយ គេបានស្រែកបញ្ជាឲ្យខ្ញុំ និងមិត្តម្នាក់ទៀត ដែលកំពុងកាប់ដីក្បែរនោះ សែងខ្មោចនោះយកទៅបោះក្នុងរណ្ដៅ នៅក្បែរការដ្ឋាន។ មិត្តដែលធ្លាប់ធ្វើការជាមួយគ្នា ដេកក្នុងខ្ទមជាមួយគ្នា ពេលនេះស្លាប់ទៅហើយ។ ចំណែកខ្ញុំ ក៏ត្រូវមកសែងសាកសពរបស់គាត់យកទៅទម្លាក់ក្នុងរណ្ដៅដោយផ្ទាល់ដៃទៀត។

ក្រោយពីបញ្ចប់ផែនការនៅអូររាំងឪ ក្រុមកម្លាំងទី១របស់ខ្ញុំ នៅសល់តែ២៤នាក់ទេ ហើយត្រូវបន្តដំណើរទៅធ្វើការនៅការដ្ឋានថ្មីឯខាងស្វាយអន្ទរ រួចចេញពីស្វាយអន្ទរហួសទៅខេត្តស្វាយរៀង មុននឹងវិលត្រលប់មកឃុំរកាកោងវិញ។ ពេលមួយនោះ ប្រធានសហករណ៍នៅឯរកាកោង បានចាត់តាំងឲ្យខ្ញុំនិងគ្នីគ្នាចំនួន១០នាក់ទៀត អុំទូកឆ្លងទៅបេះបន្លែនៅកោះមួយទល់មុខវត្តរកាកោង។ នៅលើកោះនោះ មានបន្លែជាច្រើន ហើយសម្បូរត្រកួនណាស់។ ខ្ញុំឃើញមានរងដំឡូងជ្វា ដែលកសិករទើបនឹងក្ឋររួច ព្រោះស្នាមគន្លងដីនៅថ្មីៗនៅឡើយ។

ដំឡូងចេញមើមធំៗប៉ុនកំភួនដៃរបស់ខ្ញុំ។ ចំណែក ផ្លែពោតធំៗល្អណាស់ដែរ។ ក្នុងចិត្តខ្ញុំស្រមៃថា ប្រសិនបានដំឡូង និងពោតទាំងនោះមកដុតហូប មិនដឹងជាឆ្ងាញ់យ៉ាងណានោះទេ។ ប៉ុន្តែមិនអាចឡើយ ការស្រមៃនៅតែជាការស្រមៃ ព្រោះថាបើសិនជាខ្ញុំឬមិត្តណាម្នាក់ ហ៊ានហូបដំឡូងនោះ ច្បាស់ជាត្រូវអង្គការយកទៅកសាងជាមិនខាន។

ពេលល្ងាចមកដល់ យើងត្រូវដឹកជញ្ជូនបន្លែ ដែលបេះបានតាមទូកវិលត្រលប់មកកាកោងវិញ។ ដ្បិតថា បន្លែបេះបានច្រើន មានទាំងពោតនិងដំឡូង ប៉ុន្តែយើងមិនដែលបានហូបឆ្អែតនោះទេ។ របបអាហារ ដែលយើងទទួលបានបន្ទាប់ពីការរែកដី លើកទំនប់ និងដីកប្រឡាយ ហាលថ្ងៃ ហាលភ្លៀងទាំងឈឺទាំងជា គឺបានត្រឹមតែបបរមួយចានរាវៗតែប៉ុណ្ណោះ។ ពេលខ្លះ យើងមានសម្លដែរ ហើយបើជាសម្លត្រកួនវិញ គឺស្លទាំងឫសគ្មានបេះសម្អាតអ្វីឡើយ។ បើជាសម្លដើមចេក គឺហាន់ទាំងកង់ៗ ធ្វើឲ្យសម្លនោះមើលទៅដូចបបរបាយជ្រូកអីចឹង។

ការអត់ឃ្លានកើតមានគ្រប់ទីកន្លែង។ ថ្ងៃមួយ ខ្ញុំបានទៅលេងបងប្រុសរបស់ខ្ញុំឈ្មោះ ផាន នៅឯស្ពានថ្មី។ ខ្ញុំស្លុតចិត្តយ៉ាងខ្លាំងពេលបានជួបគាត់ ព្រោះរូបរាងរបស់គាត់ស្គមស្គាំង មានតែក្បាលជង្គង់។ មិនថាតែបងប្រុសរបស់ខ្ញុំទេ ប្រជាជនដទៃទៀត ក៏មានសភាពមិនសូវជាខុសគ្នាប៉ុន្មានដែរ។

នៅក្នុងរបបខ្មែរក្រហម មានហេតុការណ៍មួយទៀត ដែលធ្វើឲ្យខ្ញុំចងចាំមិនភ្លេចទាល់តែសោះ។ ល្ងាចមួយ មេឃងងឹតទៅហើយ ប្រធានសហករណ៍ បានកោះប្រជុំក្រុមកងកម្លាំងទី១ទាំងអស់ ហើយប្រកាសថា ស្អែកអង្គការ បានដាក់ផែនការឲ្យជីករណ្តៅធំមួយ ដែលមានជម្រៅ៣ម៉ែត្រ ទទឹង៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ ឲ្យហើយក្នុងពេលតែមួយថ្ងៃ។ លុះស្អែកឡើង កម្លាំងទី១ បានបញ្ចប់ផែនការជីករណ្តៅរឿនឆាប់រហ័សមុនពេលកំណត់ ទើបវេលារសៀលជ្រេបន្តិចបានវិលពីការដ្ឋានត្រលប់មកផ្ទះវិញ។ មិត្តបងប្រធានសហករណ៍បានពោលសរសើរ និងចែកដំឡូងស្ងោរឲ្យក្នុងម្នាក់ចំនួន ៣មើម ហើយបានអនុញ្ញាតឲ្យទៅលេងផ្ទះទៀតផង។ ក្រោយបានទទួលដំឡូង និងឮការប្រកាស

បែបនេះភ្លាម សម្រែកជយឃោសថា «ជយោអង្គការ! ជយោអង្គការ!» បានបន្លឺឡើងកងរំពង។ ខ្ញុំវិញសប្បាយចិត្តណាស់ ព្រោះបានដំឡូងស្ងោរមកបំពេញក្រពះ ដែលកំពុងតែស្រេកឃ្លានមួយនេះ។ រំពេចនោះ ខ្ញុំស្រាប់តែនឹកឃើញម្តាយរបស់ខ្ញុំ។ ខ្ញុំក៏ប្រញាប់ស្រូតដំណើរទៅរកគាត់ភ្លាម។ គ្រាន់តែមកដល់ផ្ទះរបស់គាត់ ខ្ញុំបម្រុងឈានជើងឡើងជណ្តើរទៅហើយ ស្រាប់តែសំឡេងមួយបន្លឺឡើងពីខាងលើផ្ទះមកបង្អាក់ខ្ញុំមួយរំពេច។

«កាប៉ុក! ហង ស៊ីពោតនេះឲ្យលឿនៗទៅ ក្រែងមានឈ្លបណាមកទាន់ មានបញ្ហាណា ហង! ស៊ីទៅ ព្រោះអញមិនស៊ី អញទុកឲ្យតែហងទេ! កាប៊ិច និង កាប៉ូច វាគ្មានសំណាងដូចហងទេ ពេលបានស៊ីហើយតិចរមាស់មាត់ទៅនិយាយអួត ក្រែងវាខឹងទៅប្តឹងឈ្លបថា អញនិងហង ក្បត់អង្គការអីចប់មិនខានទេ»។

គ្រាន់តែឮសំឡេងនេះភ្លាម ទឹកភ្នែករបស់ខ្ញុំហូរដោយមិនដឹងខ្លួន។ ខ្ញុំចេញពីទីនោះ ហើយរត់យ៉ាងលឿនកាត់គ្រាប់ភ្លៀងសំដៅមករកកន្លែងបងប៊ិច នៅឯចុងព្រៃក។ ខ្ញុំយំឱប បងប៊ិច ហើយរៀបរាប់ប្រាប់គាត់ថា «បង! ម៉ែមិនស្រលាញ់យើងទេ! មានអីហូបគាត់ទុកឲ្យតែ បងប៉ុក»។ បងប៊ិច បានអង្អែលខ្នងខ្ញុំហាក់យល់ចិត្ត ហើយនិយាយថា «បានហើយ កាប៉ូច មិនមែនម៉ែមិនស្រលាញ់យើងទេ គ្រាន់តែយើងនៅឆ្ងាយពីគាត់ ហើយ កាប៉ុក នៅក្បែរខ្លួនគាត់ ទើបធ្វើឲ្យគាត់យកចិត្តទុកដាក់នឹងវាច្រើនជាងយើង គ្មានម៉ែណាមិនស្រលាញ់កូននោះទេ ឈប់យំទៅ» និយាយរួចគាត់ក៏សួរខ្ញុំថាមានអ្វីនៅបង្ខិចក្រមានោះ។ ខ្ញុំបានបង្ហាញដំឡូងស្ងោរ ដែលប្រធានសហករណ៍បានឲ្យមកខ្ញុំ រួចចែក បងប៊ិច ហូបដែរ។ ខ្ញុំប្រាប់គាត់ថាដំឡូងនោះបានមកដោយសារតែខ្ញុំជីករណ្តៅ ដែលអង្គការដាក់ឲ្យធ្វើបានឆាប់រួចរាល់មុនពេលកំណត់។ បងប៊ិច ដឹងរឿងនេះ ហើយបាននិយាយមកខ្ញុំវិញថា «ឯងដឹងទេ! រណ្តៅនោះ គឺទុកសម្រាប់កប់កងកម្លាំងទី១របស់ពួកឯងហ្នឹងហើយ! ឯងត្រូវគេឲ្យជីករណ្តៅដើម្បីកប់ខ្លួនឯងហ្នឹង!បងឮថាប្រហែលបីថ្ងៃទៀត ខ្មែរក្រហម នឹងវាយសម្លាប់ប្រជាជនទម្លាក់ក្នុងរណ្តៅនោះ»។

ពាក្យ បងប៉ិច និយាយធ្វើឲ្យខ្ញុំអុកគូទដួលចុះមួយរំពេច។ បីថ្ងៃទៀត ខ្ញុំ រួមទាំងប្រជាជនជាច្រើនទៀត នឹងត្រូវវាយសម្លាប់ទម្លាក់ក្នុងរណ្តៅហើយ តើមែនទេ? តើមានអ្នកណាមិនស្លុតចិត្ត បើដឹងថាខ្លួនឯងត្រូវមកស្លាប់នៅ ថ្ងៃណាបែបនេះនោះ?

ប៉ុន្តែខ្ញុំពិតជាមានសំណាងណាស់ ថ្ងៃទីបីដែលខ្មែរក្រហមត្រូវយកពួកយើង ទៅវាយចោល បែរជាឮដំណឹងថា ភ្នំពេញ ត្រូវបានរំដោះពីកណ្តាប់ដៃខ្មែរក្រហម ទៅវិញ។ ខ្ញុំក៏រួចរស់ជីវិតរហូតមកដល់សព្វថ្ងៃនេះ។

ខ្ញុំស្តាប់រឿងម្តាយរបស់ខ្ញុំជក់ចិត្តយ៉ាងខ្លាំងនៅលើទោងដែលយោលយឺតៗ ខាងមុខផ្ទះ។ យប់ថ្មើរនេះ ជាធម្មតា ជាពេលដែលខ្ញុំកំពុងដេកលក់ ប៉ុន្តែយប់នេះ ខ្ញុំបែរជាមិនងងុយដេកទាល់តែសោះ។ ខ្ញុំជក់ចិត្តស្តាប់ម្តាយរបស់ខ្ញុំរៀបរាប់រឿងរ៉ាវ ជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហម។ ទោះជាម្តាយរបស់ខ្ញុំរៀបរាប់មិនបាន សព្វគ្រប់ជ្រុងជ្រោយ ប៉ុន្តែការចងចាំរបស់គាត់ដែលបានរៀបរាប់ទាំងប៉ុន្មាន បានចូលក្នុងអារម្មណ៍របស់ខ្ញុំឡើងស្តួងដូចកំពុងតែមើលរឿងភាពយន្ត។

ខ្ញុំតាមមើលម្តាយរបស់ខ្ញុំរហូតដល់គាត់ដើរចូលផុតទៅក្នុងផ្ទះបន្ទាប់ពីគាត់ និយាយរឿងក្នុងរបបខ្មែរក្រហមប្រាប់ខ្ញុំរួច។ ការចងចាំរបស់ម្តាយខ្ញុំកាលពីជំនាន់ ប៉ុល ពត ជ្បិតថាខ្លី ប៉ុន្តែខ្ញុំបានរៀនសូត្រពីរបបនោះច្រើនទោះបីជារបបនេះបាន កន្លងផុតជាង ៤០ឆ្នាំហើយយ៉ាងណាក៏ដោយ។

១៣

រឿងនៅពីក្រោយសំឡេងច្រៀង

អ្នកនិពន្ធ ៖ ម៉ក់ ខេមរិន្ទ

១៣ ~ រឿង ដែលកើតឡើងក្រោយសំឡេងច្រៀង

ថ្ងៃនេះ គ្រាន់តែឮចម្រៀងបទ «ឱ! ភ្នំពេញអើយ» ភ្លាម ខ្ញុំក៏ដើរទៅយកវិទ្យុមកមួលបន្ថែមសំឡេងឲ្យឮកាន់តែខ្លាំងឡើង ព្រោះអីខ្ញុំស្រលាញ់បទនេះខ្លាំងណាស់។ កាលខ្ញុំនៅពីក្មេង ឲ្យតែពេលយប់ឡើងរៀបនឹងចូលគេង ម៉ែរបស់ខ្ញុំតែងច្រៀងចម្រៀងបទនេះឲ្យខ្ញុំស្តាប់ ហើយវាជាបទចម្រៀងដែលម្តាយរបស់ខ្ញុំចូលចិត្តណាស់។

កាលពី១៣ឆ្នាំមុន ...

យប់មួយនោះ មិនដឹងជាម៉ែកើតអ្វីទេ គាត់កំពុងតែច្រៀងសុខៗស្រាប់តែស្ងាត់លែងឮសំឡេងរបស់គាត់ច្រៀងទៀត។ ខ្ញុំនឹកស្មានតែគាត់សម្រាន្ត ផ្ទុយទៅវិញម៉ែរបស់ខ្ញុំកំពុងតែដូតសម្បារខ្សឹតៗ។ «ម៉ែកើតអី?» ខ្ញុំសួរទៅគាត់ទាំងដឹងហើយថាគាត់យំ។ «គ្មានអីទេកូន!» ម៉ែនិយាយបណ្តើរ យកដៃដូតទឹកភ្នែកចេញពីថ្ពាល់បណ្តើរ ដោយភ្ជាប់ជាមួយស្នាមញញឹមស្ងួតមករកខ្ញុំ។

ខ្ញុំដឹងថាម៉ែច្បាស់ជានឹកឃើញដល់រឿងរ៉ាវចាស់ៗដែលគាត់ធ្លាប់ឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមពេលស្តាប់ចម្រៀងបទ«ឱ! ភ្នំពេញអើយ» នេះ។ ឃើញដូច្នោះខ្ញុំរឹតតែចង់ដឹងថាគាត់បានជួបនឹងអ្វីខ្លះបានជាធ្វើឲ្យគាត់រំជួលចិត្តយ៉ាងដូច្នេះ។ ខ្ញុំបានទទូចសុំឲ្យម៉ែរបស់ខ្ញុំនិយាយរឿងរបស់គាត់ប្រាប់ខ្ញុំ ហើយម៉ែក៏យល់ព្រម។ ខាងក្រោមនេះជាការរៀបរាប់របស់ម្តាយខ្ញុំពីរឿងរ៉ាវរបស់គាត់និងក្រុមគ្រួសារចាប់តាំងពីឆ្នាំ១៩៧៤៖

ចុងឆ្នាំ១៩៧៤

ចុងឆ្នាំ១៩៧៤ គ្រួសាររបស់ខ្ញុំ ចាប់ផ្តើមបែកគ្នាទៅរៀងៗខ្លួន។ ឪពុករបស់ខ្ញុំ ត្រូវចាកចេញទៅធ្វើជាលេខាបកប្រែភាសានៅប្រទេសថៃជាមួយនឹងចៅហ្វាយរបស់គាត់ ដែលជាអតីតទាហានក្នុងរបប លន់ នល់។ ឪពុករបស់ខ្ញុំចេះនិយាយ និងសរសេរភាសាថៃបានយ៉ាងស្ទាត់ជំនាញ។ កាលនោះ ខ្ញុំមានអាយុត្រឹមតែ១១ឆ្នាំ ហើយកំពុងតែរៀនថ្នាក់ទី៨។ ដោយសារតែឪពុករបស់ខ្ញុំមិនទុកចិត្តនឹងសភាពការណ៍ក្នុងស្រុក គាត់ បានយកខ្ញុំ និងម្តាយរបស់ខ្ញុំ ទៅផ្ញើនឹងញាតិសាច់ឆ្ងាយនៅឯខេត្តសៀមរាប។ ពេលនោះ បងប្រុសទី ១ និងទី២របស់ខ្ញុំ កំពុងបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅឯទីក្រុងភ្នំពេញឯណោះ។ ចំណែកឯបងប្រុសទី៣របស់ខ្ញុំ ត្រូវប្រឡងថ្នាក់ឱប្លូមនៅក្នុងស្រុកក្រឡាញ់ ហើយម្តាយរបស់ខ្ញុំជាអ្នកមើលការខុសត្រូវ។

ម្តាយរបស់ខ្ញុំមានដីស្រែ៤ប្លង់ ទុកសម្រាប់ធ្វើខ្លួនឯងខ្លះ និងជួលឲ្យគេធ្វើខ្លះ។ ក្រុមគ្រួសាររបស់ខ្ញុំមានអ្នកស្គាល់ច្រើនណាស់ ព្រោះឪពុករបស់ខ្ញុំធ្វើជាទាហាន ហើយម្តាយរបស់ខ្ញុំ រកស៊ីជួញដូរ។ ជីវភាពរបស់យើង ធូរធារគ្រាន់បើដែរ។

មុនពេលឪពុករបស់ខ្ញុំឡើងយន្តហោះ គាត់បានផ្តាំផ្ញើយ៉ាងច្រើន។ គាត់ផ្តែផ្តាំម្តាយរបស់ខ្ញុំ ឲ្យជួយមើលថែកូនៗឲ្យបានល្អ ព្រោះអីគាត់ទៅយូរណាស់កន្លះឆ្នាំអីទើបបានមកម្តង។ ឪពុកខ្ញុំបារម្ភដល់កូនៗដែលនៅភ្នំពេញណាស់ ព្រោះពេលនោះបញ្ហានយោបាយក្នុងប្រទេស កំពុងមានភាពល្អក់កករផង ហើយបញ្ហាអសន្តិសុខទៀត។ ផ្តាំផ្ញើរួចស្រេច ឪពុករបស់ខ្ញុំ ក៏ឡើងយន្តហោះចេញដំណើរបាត់ទៅ។ ម្តាយខ្ញុំ បែរជាហូរទឹកភ្នែកសស្រាក់ ហាក់ដូចជាមានប្រផ្នូលថាគាត់នឹងមិនអាចមានឱកាសជួបគ្នាវិញទៀតទេ។

ឆ្នាំ១៩៧៥ ចូលមកដល់...

ប្រហែល ២ខែកន្លងផុតទៅ ខ្ទង់ពាក់កណ្តាលខែមករា ឆ្នាំ១៩៧៥ ម្តាយរបស់ខ្ញុំ បានទទួលសំបុត្រពីឪពុករបស់ខ្ញុំ តាមរយៈទាហាន ដែលទៅថៃ

ជាមួយគ្នា។ នៅក្នុងសំបុត្រនោះបានផ្តាំថា ឲ្យនាំកូនទាំង២នាក់ទៅលេងថៃ ហើយឪពុករបស់ខ្ញុំនឹងមកនៅចាំទទួលនៅអារញ្ញ។ ម្តាយរបស់ខ្ញុំ រួតរះម្ដីម្នាក់ រៀបចំអីវ៉ាន់ល្មមគួរសមសម្រាប់ធ្វើដំណើរ ត្បិតខ្លាចមានសភាពការណាមួយមិនប្រក្រតីនឹងអាចធ្វើឲ្យខកពេលវេលានេះ។

ការធ្វើដំណើរទៅប្រទេសថៃតាមផ្លូវគោក ពិតជាមិនងាយស្រួលទេ ព្រោះនៅអំឡុងឆ្នាំ១៩៧៥ប្រទេសខ្មែរបានធ្លាក់ចូលក្នុងសង្គ្រាមហែកហួរគ្នាជាបណ្តើរៗទៅហើយ។ នៅតាមផ្លូវពិបាកធ្វើដំណើរណាស់ ត្បិតពេលនោះមានកងកម្លាំងដែលខ្ញុំមិនច្បាស់ថាកម្លាំងខាងណានោះទេ បានបង្កប់គ្រាប់មីននៅតាមផ្លូវ ហើយផ្ទះមួយចំនួន បានខូចខាតដោយសារការទម្លាក់គ្រាប់ និងការបាញ់គ្រាប់ផ្លោង។ ពេលមកដល់ស្រុកក្រឡាញ់ ស្ពានផ្លូវត្រូវដាច់ខូចខាតជាច្រើនកន្លែង ធ្វើឲ្យយើងមិនអាចបន្តដំណើរទៅមុខទៀតបានទេ។ យើងត្រូវឈប់សម្រាកជាច្រើនថ្ងៃនៅទីនោះ។ ដោយមិនអាចនៅរង់ចាំបាន ឪពុករបស់ខ្ញុំបានផ្ញើសំបុត្រមួយច្បាប់ ថ្នាំលេប និងលុយមួយចំនួន មកឲ្យពួកយើងដែលនៅសំចតតាមផ្លូវ ឲ្យធ្វើដំណើរត្រលប់ទៅផ្ទះវិញ ព្រោះគាត់បានទទួលដំណឹងតាមរយៈអង្គភាពរបស់គាត់ថា នៅតាមព្រំដែនចាប់ផ្តើមតឹងរ៉ឹង និងពុំមានសុវត្ថិភាពសម្រាប់ប្រពន្ធ និងកូនរបស់គាត់ឡើយ។ យើងបាននាំគ្នាត្រលប់មកស្រុកកំណើតរង់ចាំស្តាប់សភាពការណ៍បន្តទៅទៀត។

លុះចូលមកដល់ខែមេសា ឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំ បានផ្ញើសំបុត្រឲ្យយើងធ្វើដំណើរទៅប្រទេសថៃម្តងទៀត ត្បិតគាត់បានទទួលដំណឹងថា សង្គ្រាមចាប់ផ្តើមផ្ទុះឡើងនៅតាមតំបន់មួយចំនួននៅក្នុងប្រទេសកម្ពុជាហើយ។ ម្តាយរបស់ខ្ញុំ បានរៀបចំអីវ៉ាន់ ហើយធ្វើដំណើរពីខេត្តសៀមរាប ដើម្បីមកយកបងទី៣របស់ខ្ញុំ នៅស្រុកក្រឡាញ់ ឲ្យទៅជាមួយគ្នា។ យើងទើបតែមកដល់ឃុំសសរស្តម្ភ ស្រាប់តែប្រទះនឹងការប្រយុទ្ធគ្នាទ្រង់ទ្រាយតូចរវាងទាហានលន់ នល់ និងកងទ័ពខ្មែរក្រហម ដែលទើបតែបញ្ចប់ថ្មីៗ។ ហេតុដូចនេះហើយ យើងសម្រេចចិត្តវិលត្រលប់មកសៀមរាបវិញ ព្រោះខ្លាចថាបើយើងធ្វើដំណើរទៅមុខទៀតនឹងជួបកងទ័ពខ្មែរក្រហម។

ម្តាយរបស់ខ្ញុំមានការបារម្ភណ៍ណាស់ ព្រោះគាត់ទទួលបានដំណឹងថា ខ្មែរក្រហមបានវាយរំដោះបានទីក្រុងភ្នំពេញ ហើយចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ គាត់មានការតក់ស្លុតយ៉ាងខ្លាំង ព្រោះគាត់មិនដែលបានទទួលបានដំណឹងពីកូនប្រុសស្រីទាំងពីរនាក់ដែលរស់នៅភ្នំពេញទៀតសោះតាំងពីដើមខែមេសាមក។

រាល់ពេលចូលឆ្នាំថ្មី ក្រុមគ្រួសាររបស់ខ្ញុំតែងតែជួបជុំគ្នា ទិញសម្លៀកបំពាក់ថ្មីៗ ហូបអាហារជុំគ្នានិងជួបជុំគ្នានិយាយគ្នាលេងសើចក្អាកក្អាយ។ ប៉ុន្តែឆ្នាំនេះយើងមិនបានជុំគ្នាទៀតទេ។ បងៗទាំង២នាក់របស់ខ្ញុំដែលរស់នៅភ្នំពេញបាត់ដំណឹងសូន្យឈឹង។ បងទី៣ ក៏មិនអាចឡើងមកសៀមរាបជួបពួកយើងបានព្រោះមានកងទ័ពនៅរាយគ្នាតាមផ្លូវតឹតជាច់។

ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជន

ចប់ថ្ងៃចូលឆ្នាំខ្មែរស្ទើរតែមិនទាន់ កងទ័ពខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីភ្នំពេញ ហើយជម្លៀសប្រជាជនពីទីប្រជុំជនឲ្យទៅនៅកន្លែងផ្សេងៗ។ ទទួលបានដំណឹងដូច្នោះ ខ្ញុំនិងម្តាយរបស់ខ្ញុំ បានលាបងប្អូន ទៅរកបងទី៣របស់ខ្ញុំនៅឯក្រឡាញ់។ មកដល់ជិតផ្សារក្រឡាញ់ភ្លាម ម្តាយរបស់ខ្ញុំបានសាកសួរដំណឹងពីឪពុករបស់ខ្ញុំពីសាច់ថ្លៃរបស់គាត់។ បងថ្លៃរបស់ម្តាយខ្ញុំប្រាប់ថា គាត់មិនដែលបានទទួលដំណឹងពីឪពុករបស់ខ្ញុំសោះរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ គាត់ ប្រាប់ម្តាយរបស់ខ្ញុំថាឲ្យយកលុយដែលមានទៅទិញរបស់របរប្រើប្រាស់ ដែលចាំបាច់ទុកប្រើប្រាស់ដូចជាថ្នាំពេទ្យ អង្ករ ប្រហុក ស្ករ និង អំបិលជាដើម។ គាត់ឲ្យយើងឆ្លងស្ទឹងទៅរស់នៅភូមិតាដែក ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ វិញ ដើម្បីកុំឲ្យមានអ្នកដឹងពីប្រវត្តិក្រុមគ្រួសាររបស់យើង។

ពេលឆ្លងទៅដល់ភូមិតាដែក យើងបានជួបជាមួយនឹងសាច់ញាតិខាងឪពុករបស់ខ្ញុំមួយចំនួន ហើយបានសុំស្នាក់នៅទីនោះជាមួយពួកគេ។ នៅទីនោះ យើងហូបបាយល្ងាចពីព្រលប់ ហើយម៉ោង៦ល្ងាចមិនទាន់ទេ យើងនាំគ្នាបិទទ្វាររបង

ចូលសម្ងំនៅតែក្នុងផ្ទះ។ គ្មាននរណាហ៊ានដើរចល័តទៅណាមកណីទេ ព្រោះចេះតែមានពាក្យខ្សឹបខ្សៀវថា «ខ្លាចខ្មែរក្រហម» តែគ្មាននរណាស្គាល់ខ្មែរក្រហមទេ។ ការទំនាក់ទំនងរវាងគ្នានិងគ្នា ចាប់ផ្តើមកាត់បន្ថយ ព្រោះយើងខ្លាចគ្នារៀងៗខ្លួន។

ក្រុមគ្រួសាររបស់ខ្ញុំ និងសាច់ញាតិ រស់នៅភូមិតាដែកបានប្រហែលជា ១០ថ្ងៃ ទើបប្រធានភូមិចាប់ផ្តើមប្រកាសឲ្យយើងជម្លៀសចេញពីភូមិ ទៅរស់នៅភូមិមួយទៀតទាំងព្រឹកព្រលឹម។ យើងនាំគ្នារៀបចំអីវ៉ាន់ភ្លាមៗ ចំណែកឯអ្នកភូមិផ្សេងទៀត ចាប់ផ្តើមប្រមូលកូនចៅ។ ប្រជាជនខ្លះមានរទេះគោ ក៏លើកអីវ៉ាន់ដាក់រទេះគោ ខ្លះដាក់លើកង់ឬលើសត្វពាហនៈរបស់ខ្លួន។ ក្រុមគ្រួសាររបស់ខ្ញុំ ទើបតែប្តូរកន្លែងរស់នៅថ្មីៗ ទើបគ្មានមធ្យោបាយអីដឹកជញ្ជូនដូចប្រជាជនផ្សេងទៀតទេ។ យើង លីផង ទូលផង និងរែកផង មានតាំងពីមុង ក្អួយ ចាន ឆ្នាំង អង្ករ និងរបស់របរប្រើប្រាស់ចាំបាច់ផ្សេងៗទៀត។ ចំណែក ខ្ញុំ នៅតូចជាងគេលីកន្ទេលផ្តៅចំនួន២តែប៉ុណ្ណោះ។ យើងធ្វើដំណើរពេញមួយថ្ងៃ ទើបទៅដល់ចុងភូមិសំរោង ហើយសម្រាកនៅទីនោះមួយយប់ ដើម្បីយកកម្លាំងបន្តដំណើរនៅថ្ងៃស្អែកទៀត។

លុះព្រឹកឡើង អ្នកដំណើរក៏ចាប់ផ្តើមចេញពីភូមិបន្តទៅមុខទៀត។ គ្រួសាររបស់ខ្ញុំចាប់ផ្តើមបោះអីវ៉ាន់ដែលមិនចាំបាច់ចោលខ្លះ ព្រោះយើងចង់រក្សាកម្លាំងដើរទៅមុខទៀត។ រីឯ ខ្ញុំ លីកន្ទេលធ្ងន់ពេក ដើរបណ្តើរយំបណ្តើរ ហើយបានបងប្រុសរបស់ខ្ញុំជួយលីខ្លះៗនៅតាមផ្លូវ។ ព្រឹកថ្ងៃបន្ទាប់ ពួកយើងចាប់ផ្តើមបន្តដំណើរទៅមុខទៀត រហូតដល់ពេលបាយថ្ងៃត្រង់ទើបយើងមកដល់ភូមិអូរផ្ទោល ឃុំប្រាសាទ ដែលជាទីកន្លែងយើងត្រូវរស់នៅ។ នៅទីនោះគ្មានផ្ទះសម្បែងទេ គឺមានតែវាលស្រែធំល្វឹងល្វើយដាច់កន្ទុយភ្នែក។ ក្រោយពីហូបបាយថ្ងៃត្រង់រួច គ្រួសារនីមួយៗ ចាប់ផ្តើមទៅរកកាប់កូនឈើ និងកាប់ឫស្សី ដើម្បីមកបាំងឬធ្វើជាកូនខ្ទម ទៅតាមលទ្ធភាពរៀងខ្លួន។ បងប្រុសនិងសាច់ញាតិខាងឪពុករបស់ខ្ញុំ ជួយគ្នាសង់ខ្ទមតូចមួយឲ្យពួកយើងរស់នៅ។ ៣ថ្ងៃក្រោយមក គ្រួសាររបស់ខ្ញុំ មានកូនខ្ទមតូចមួយរស់នៅផ្ទាល់ខ្លួន។

ទៅដល់ទីនោះដំបូង អង្គការមិនទាន់បានកំណត់ឲ្យអ្នកភូមិធ្វើការងារនៅឡើយទេ។ អង្គការ គ្រាន់តែមិនអនុញ្ញាតឲ្យយើងចេញដើរទៅណារហេតរហូតឡើយ លើកលែងតែក្នុងករណីខ្លះដូចជា មានគ្រួសារណាគ្មានអង្ករហូប ទើបគេអនុញ្ញាតឲ្យសមាជិកគ្រួសារណាម្នាក់ ចេញមកភូមិចាស់វិញ ដើម្បីយកស្បៀងទៅហូប។

ថ្ងៃមួយនោះ មេឃមានផ្គរលាន់ក្នាំងៗ លាយជាមួយទឹកភ្លៀងស្រក់ចុះយ៉ាងខ្លាំង។ យើង មិនអាចចេញទៅធ្វើការងារខាងក្រៅបានទេ។ ពេលដែលយើងកំពុងតែអង្គុយជុំគ្នារៀបចំដាំបាយ ស្រាប់តែមានអ៊ំដែលស្នាក់នៅក្នុងខ្នមក្បែរគ្នា ដើរមកប្រាប់យើងថា «អង្គការប្រាប់ថាដល់រដូវវស្សាហើយ អង្គការនឹងឲ្យយើងត្រលប់ទៅនៅភូមិចារក្រោមវិញ ដើម្បីជួយធ្វើស្រែបង្កបង្កើនផល»។ ម្នាក់ៗសប្បាយរីករាយជាងមុន ព្រោះគិតថាអាចទៅនៅផ្ទះវិញឆាប់ៗនេះហើយ។ យើងញាប់ដៃជើងជួយប្រមូលខោអាវ និងរបស់របរ ដែលត្រូវប្រើប្រាស់ចាំបាច់បន្តិចបន្តួចទុកដាក់ត្រៀមចេញដំណើរក្រោយពេលមេឃភ្លៀង។

ចាប់ផ្តើមរស់នៅជាសហករណ៍

លុះក្រោយពេលមកដល់ភូមិចារក្រោម ប្រធានភូមិបានប្រកាសឲ្យអ្នកភូមិទាំងអស់យកស្រូវ អង្ករ និងគ្រឿងទេសផ្សេងៗយកទៅដាក់រួមគ្នា។ ពេលនោះគ្រប់គ្នាត្រូវបែងចែកទៅតាមក្រុម។ ក្នុងមួយក្រុមមានចំនួន៣ទៅ៥គ្រួសារ ទៅរស់នៅតាមផ្ទះ ដែលត្រូវបានបោះបង់ចោលជាមួយគ្នា។ ចំពោះរបបអាហារអង្គការចែកអង្ករឲ្យក្នុងម្នាក់ទទួលបានអង្ករ២កំប៉ុងក្នុង១ថ្ងៃ។ ពេលនោះយើងមិនទាន់ខ្វះអ្វីហូបនៅឡើយទេ ព្រោះការគ្រប់គ្រងនៅធូរលុងនៅឡើយ។ អ្នកភូមិ អាចទៅរកត្រីសាច់តាមលទ្ធភាពរៀងៗខ្លួន ហើយការងារបន្តិចបន្តួច ដែលត្រូវធ្វើ គឺស្រីៗទៅបោចត្រកួនពីវាលស្រែ ហើយក្រុមប្រុសៗភ្ជួរាស់តាមក្រោយ។

តាំងពីចូលដល់រដូវវស្សាមក ការទទួលបានអង្ករចាប់ផ្តើមស្បើយ។ ម្នាក់ៗទទួលបានតែរបបអង្ករ ក្នុងម្នាក់១កំប៉ុងតែប៉ុណ្ណោះក្នុងមួយថ្ងៃ។ អង្គការ ចាប់ផ្តើមបង្កើតឲ្យមានកងឈ្លប ហើយកងឈ្លបនោះគឺរើសចេញពីក្មេងៗនៅក្នុងភូមិដែលមានអាយុចាប់ពីអាយុ៦ទៅ៧ឆ្នាំឡើង។ កងឈ្លបខ្លះក៏ជំទង់ៗដែរ។

រហូតមកដល់ឆ្នាំ១៩៧៦ ពួកយើងមិនដែលបានទទួលដំណឹងសូម្បីតែបន្តិច ឡើយពីឪពុករបស់ខ្ញុំ និងបងប្រុសទាំងពីរនាក់។ រហូតដល់ឆ្នាំ១៩៧៧ យើងត្រូវ បានអង្គការផ្លាស់ឲ្យមកនៅភូមិតាសៀវ (កំពង់ថ្កូវត្រើយខាងលិច) ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ចាប់ពីពេលនោះមក របបអង្គរដែល យើងទទួលបាន ចាប់ផ្តើមថយចុះបន្តិចម្តងៗ ហើយក្រោយៗមក យើងហូប បបរជុំគ្នា។ ដោយសារតែយើងហូបមិនបានគ្រប់គ្រាន់ យើងតែងតែលួចដើររើស កួរស្រូវ ដែលធ្លាក់ក្នុងស្រែក្រោយពីច្រូតរួចយកមកដាំបាយហូបបន្ថែម។ មានថ្ងៃមួយ ក្រោយពីខ្ញុំមកពីរើសកួរស្រូវ ស្រាប់តែជួបនឹងឈ្លបម្នាក់ដែល ធ្លាប់ស្គាល់គ្នានៅតាមផ្លូវ។ ឈ្លបនោះ បានដើរមកបើកមើល ឃើញខ្ញុំមានកួរស្រូវ ស្រាប់តែស្តីឲ្យពីរនាក់យើងយ៉ាងខ្លាំងៗ ហើយយកស្រូវដែលយើងរើសបាននោះ ទៅចាក់ចោលអស់។ ក្រៅពីស្តីបន្ទោសហើយ គាត់ថែមទាំងបានពោលពាក្យមួយ ឃ្លាទៀតថា «ឲ្យសមមុខទៅចុះ ខ្ញុំធ្លាប់ឃើញតែឃ្លោកអណ្តែត តែឥឡូវនេះលិច ហើយ កុំចង់ខ្លាំងប្រឆាំងជាមួយអង្គការឲ្យសោះ សម័យនេះ ឃ្លោកលិច អម្បែង អណ្តែតណ៎ាមិត្ត»។ ពេលនោះ ម្តាយរបស់ខ្ញុំខឹងផង អន់ចិត្តផង តែមិនតបត អ្វីទេ ព្រោះខ្លាចក្រែងឈ្លបដែលធ្លាប់ស្គាល់គ្នានោះទៅរាយការណ៍ឲ្យអង្គការដឹង ក្រុមគ្រួសាររបស់ខ្ញុំ។

បន្ទាប់ពីដូវច្រូតកាត់បានបញ្ចប់ទៅ ស្ថានភាពស្រុកភូមិកាន់តែតឹងរ៉ឹង ខ្ញុំ ត្រូវបានអង្គការឲ្យទៅដើររើសកួរស្រូវឯព្រៃរនាមជាមួយក្មេងស្រីឯទៀត។ រីឯ បងទី៣របស់ខ្ញុំ អង្គការ ចាត់ឲ្យទៅធ្វើជាប្រធានកងកុមារនៅកំពង់ថ្កូវខាងស្រុក ក្រឡាញ់វិញ។ ពេលធ្វើដំណើរទៅព្រៃរនាម ខ្ញុំឃ្លានខ្លាំងពេកធ្វើឲ្យខ្ញុំឈឺពោះយ៉ាង ខ្លាំង។ បន្ទាប់ពីអង្គការ បានឲ្យបាយខ្ញុំហូប ខ្ញុំក៏បាត់ឈឺភ្លាម តែខ្ញុំនៅប្រាប់អង្គការ ថា ខ្ញុំនៅឈឺដដែល ព្រោះខ្លាចអង្គការចោទថាខ្ញុំឈឺសតិអារម្មណ៍។ ពេលទៅ ដល់ព្រៃ អង្គការក៏បានឲ្យថ្នាំអាចម៍ទន្សាយមកខ្ញុំលេបទៀត តែខ្ញុំនៅតែប្រាប់ អង្គការថា ខ្ញុំនៅតែមិនទាន់បាត់ឈឺទេ។ ប្រហែល៨ថ្ងៃ ក្រោយ អង្គការ អនុញ្ញាត ឲ្យខ្ញុំត្រលប់មកនៅភូមិតាសៀវវិញ។

បានប្រហែលកន្លះឆ្នាំ ម្តាយរបស់ខ្ញុំ ត្រូវផ្ទេរឲ្យទៅនៅភូមិតាសៀវរៀចជាមួយក្រុមស្ត្រីមេម៉ាយ ដើម្បីជួយមើលថែទាំកុមារតូចៗ និងត្បាញមួកស្លឹកត្នោត។ រីឯខ្ញុំវិញ អង្គការឲ្យដើរកាប់ទន្ទ្រានខែត្រជាមួយកុមារផ្សេងទៀតទុកធ្វើជី។ ចំណែកបងរបស់ខ្ញុំ ក្រៅពីគ្រប់គ្រង និងជួយធ្វើការជាមួយកុមារ គាត់មានតួនាទីមួយទៀតគឺជួយបង្រៀនអក្សរដល់ពួកក្មេងៗ។

លុះចូលដល់ឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមមកពីនិរតី បានចូលមកគ្រប់គ្រងនៅតំបន់ដែលខ្ញុំរស់នៅ។ ដោយឃើញខ្ញុំឧស្សាហ៍ និងឆ្លាតផង មិត្តនារីម្នាក់ដែលគ្រប់គ្រងលើពួកកុមារ ស្រលាញ់ចូលចិត្តខ្ញុំណាស់ ហើយបានឲ្យខ្ញុំមករស់នៅលើផ្ទះជាមួយគាត់។ នៅឆ្នាំនោះ ថ្វីត្បិតការរស់នៅ និងធ្វើការមិនសូវជាតឹងតែងខ្លាំង ប៉ុន្តែរបបអាហារកាន់តែកាត់បន្ថយតិចទៅៗ។ កងកុមារដែលខ្ញុំរស់នៅ ត្រូវហូបបបរួមគ្នាទាំងអស់។

មករស់នៅទីនេះបានយូរបន្តិច មិត្តនារីនោះ បានស្នើសុំឲ្យម្តាយរបស់ខ្ញុំមកពីតាសៀវរៀចវិញ ដើម្បីបានជួយមើលថែផ្ទះផង និងបាននៅជាមួយខ្ញុំផង។ ក្រោយពីម្តាយរបស់ខ្ញុំមកដល់ មិត្តនារីនោះ រឹតតែស្រលាញ់ក្រុមគ្រួសាររបស់ខ្ញុំច្រើនឡើង ព្រោះគាត់ឃើញម្តាយរបស់ខ្ញុំចេះធ្វើការងារច្រើន ថែមទាំងចេះដាំដំណាំទៀតផង។ ពួកគេស្រលាញ់ទុកចិត្តខ្ញុំណាស់។ ថ្ងៃខ្លះគេប្រើឲ្យខ្ញុំ ចូលទៅក្នុងឃ្លាំងដាក់អីវ៉ាន់យកនេះ យកនោះ ក្នុងនោះក៏មានស្រូវ និងអង្ករផងដែរ។ ថ្ងៃមួយខ្ញុំបែកគំនិត ពេលហូបបាយរួច ក៏ដើររើសស្លឹកត្នោតមកចាក់ធ្វើកាតំមួយធំល្មម។ លុះពេលដែលគេប្រើខ្ញុំទៅឃ្លាំងលើកក្រោយ ខ្ញុំក៏លួចយកអង្ករច្រកចូលក្នុងកាតំដែលបានចាក់ទុក យកទៅផ្ញើនឹងចុងភៅដែលស្គាល់គ្នា ឲ្យគាត់ជួយដាក់ចូលខ្នះពេល ដាំបបរ។ អង្ករនេះ មិនមែនចេះតែអាចហូបបានរាល់ថ្ងៃទេ យូរៗទើបហ៊ានលួចម្តង ដើម្បីកុំឲ្យសង្ស័យ។

នៅប្រហែលពាក់កណ្តាលឆ្នាំ ពួកនិរតី ត្រូវបានអង្គការដកចេញទៅណាក៏មិនដឹង។ សភាពការណ៍ កាន់តែមានភាពតឹងតែងឡើង។ មុនពេលចាកចេញ មិត្តនារី ដែលធ្លាប់ស្រលាញ់គ្រួសាររបស់ខ្ញុំ បានផ្តាំផ្ញើយើងថា ត្រូវរស់នៅ និង

និយាយស្តីឲ្យប្រយ័ត្នប្រយែងខ្លួនឲ្យមែនទែន អស់ពីពួកគាត់ទៅក្រុមដែលមកនៅតាមក្រោយនេះ គឺតឹងរ៉ឹងណាស់។ បើមានបញ្ហា ឬទំនាស់អី មិនត្រូវប្រកែកតវ៉ាជាមួយនឹងគេទេ។ គាត់ថែមទាំងបានឲ្យស្ករ អំបិល និងអង្ករខ្លះៗទុកនឹងចុងភៅ ហើយផ្តាំចុងភៅឲ្យជួយមើលថែគ្រួសាររបស់ខ្ញុំ។ ផ្តាំហើយ គាត់លាចេញទៅ។ ចាប់តាំងពីពេលនោះមក យើងមិនដែលបានជួប ឬឮដំណឹងពីគាត់ទៀតទេ។

បន្ទាប់ពីពួកអ្នកថ្មីចូលមកគ្រប់គ្រងភ្លាម យើងទាំងអស់គ្នាដល់ពេលចាប់ផ្តើមធ្វើការងារស្រែចម្ការទៀតហើយ។ ម្នាក់ៗខំប្រឹងធ្វើការងារ ឥតហ៊ានប្រកែកតវ៉ាទេ។ វិន័យកាន់តែតឹង ការសម្លាប់ប្រជាជនមានកាន់តែច្រើនឡើង។ ការប្រជុំផ្ទៃក្នុង ដែលជាទូទៅប្រជុំរៀងរាល់១ខែម្តងនោះ ត្រូវបានប្រែមកជាប្រជុំកាន់តែញឹកញាប់។ ខ្លឹមសារប្រជុំគ្មានអ្វីប្លែកទេ ក្រៅពីប្រជុំលើកសរសើរអង្គការ ជំរុញឲ្យអ្នកភូមិខិតខំធ្វើការងារស្រែចម្ការ ជីកប្រឡាយ ធ្វើផ្លូវគមនាគមន៍ឲ្យសម្រេចទៅតាមផែនការរបស់អង្គការ និងសម្តែតគំរាមប្រជាជនកុំឲ្យមានចិត្តក្បត់នឹងអង្គការ ឬមានគំនិតចង់ធ្វើបដិវត្តជាដើម។ បន្ទាប់ពីប្រជុំចប់ យើងត្រូវស្រែកបន្លឺថា «ជយោ! ជយោ! អង្គការមហាលោតផ្លោះ មហាអស្ចារ្យ»។

ខែមករា ឆ្នាំ១៩៧៩

ថ្ងៃនោះបងប្រុសទី៣របស់ខ្ញុំ បានឆ្លងពីត្រើយម្ខាងមកជួបម្តាយរបស់ខ្ញុំ ហើយខ្សឹបផ្តល់ដំណឹងថា សភាពការណ៍នៅតាមព្រំដែនភាគខាងកើតចាប់ផ្តើមប្រែប្រួលហើយ។ គាត់ថា ឥឡូវកងទ័ពវៀតណាមចូលស្រុកហើយ។ ម្តាយរបស់ខ្ញុំមិនជឿបងរបស់ខ្ញុំទេ ថែមទាំងស្តីបន្ទោសគាត់ទៀតថា «កុំចេះតែនិយាយផ្តេសផ្តាស ប្រយ័ត្នឈ្លបមកឮហើយរាយការណ៍ទៅប្រាប់អង្គការទៅ គ្រួសារយើងច្បាស់ជាមិនរួចខ្លួនទេ»។ បងប្រុសរបស់ខ្ញុំប្រាប់ថា គាត់បានឮរឿងនេះពីមិត្តរបស់គាត់ម្នាក់ ដែលជាប្រជាជនមូលដ្ឋាន បានប្រាប់គាត់ច្បាស់ណាស់ ហើយរឿងនេះក៏មានចាក់ផ្សាយតាមវិទ្យុដែរ។ ពេលនោះម្តាយរបស់ខ្ញុំ មិនមាត់កអ្វីទៀតដែរ មានតែនាំគ្នារង់ចាំមើលសភាពការណ៍ជាក់ស្តែង។

ថ្ងៃមួយ ម្តាយរបស់ខ្ញុំកើតខ្យល់មិនស្រួលខ្លួន។ គាត់បានហៅអ៊ំចុងភៅមកជួយកោសខ្យល់ឲ្យ។ ដំណាលគ្នានោះដែរ ខាងអង្គការ បានប្រើពួកឈ្លបឲ្យដើរឆែកឆេរតាមផ្ទះអ្នកស្រុក ដើម្បីប្រមូលយកមាសតាមផ្ទះ។ ម្តាយរបស់ខ្ញុំ មានមាសជាច្រើនដែលសន្សំទុកមកតាំងពីចេញពីស្រុកក្រឡាញ់មក។ គាត់ទុកដាក់តាមខ្លួនជានិច្ច។ ជួនកាល គាត់យកខ្សែកមកតជាមួយខ្សែដៃពាក់ធ្វើជាខ្សែចង្កេះ ជួនគាត់លាក់ទុកក្នុងហោប៉ៅអាវក្នុង។ ថ្ងៃនោះ កងឈ្លប ឡើងមកដល់លើផ្ទះ រួចឆែកឆេរក្នុងផ្ទះ ដើម្បីរកមើលក្រែងលោម្តាយរបស់ខ្ញុំមានលាក់ទុកមាស ប៉ុន្តែពួកគេរើមិនឃើញមានមាសទេ។ កងឈ្លប បានរកឃើញសំពត់ហូល ផាមួង និងអន្លូញ១ឈុត ហើយស្តីឲ្យម្តាយរបស់ខ្ញុំថា «យាយឯងនេះជាមនុស្សកម្មសិទ្ធិក្រាស់ណាស់ យាយឯងហ៊ានលួចលាក់ទុកសំពត់ល្អៗ មិនព្រមយកទៅជូនអង្គការ យាយឯងគង់តែមានថ្ងៃអង្គការយកទៅរៀនសូត្រទេ»។

កងឈ្លបបម្រុងនឹងយកសំពត់ទាំងអស់នោះទៅហើយ ស្រាប់តែប្រធានភូមិមកជួយនិយាយថា ថ្នាក់លើដាក់បញ្ជាមកឲ្យប្រមូលតែមាសទេ មិនបានឲ្យយករបស់ផ្សេងទៀតទេ។ កងឈ្លបឮដូច្នោះ ដូចជាខឹង ក៏ទម្លាក់ទុកវិញ។ ប៉ុន្តែមិនទាន់ចប់ទេ ឈ្លបស្រីរាងចំណាស់ម្នាក់ទៅឆែកឆេរខ្លួនរបស់ម្តាយខ្ញុំ ស្ទាបប៉ះខ្សែក ខ្សែដៃមាស និងបន្តោងខ្សែកមួយដែលមានរូបម្តាយនិងឪពុករបស់ខ្ញុំ។ គ្រាន់តែបើកឃើញរូបថតភ្លាម ឈ្លបស្រាប់តែភ្ញាក់ផ្អើល ដោយសារឃើញអាវដែលឪពុករបស់ខ្ញុំពាក់មានស័ក្តិ។ កងឈ្លបចែកគ្នាជួយមើល ហើយបែរមកគំរាមម្តាយរបស់ខ្ញុំថា «ប្តីយាយឯងនេះ សង្ស័យតែធ្វើការធំក្នុងជួររាជការរហើយ បានមានស័ក្តិមានអីពាក់ដូចនេះ ម៉្យាងទៀតបើអ្នកល្មមៗក៏គ្មានលទ្ធភាពទៅធ្វើបន្តោងខ្សែកបែបនេះដែរ»។ ថាហើយពួកវាគំរាមម្តាយរបស់ខ្ញុំ ថានឹងយករូបនោះទៅឲ្យអង្គការលើពិនិត្យមើល។ បើសិនជាពួកវារកឃើញថា ឪពុករបស់ខ្ញុំ ជាអ្នកធ្វើការក្នុងសម័យ លន់ នល់ មែន ក្រុមគ្រួសាររបស់ខ្ញុំនឹងមិនរួចខ្លួនទេ។

ចាប់តាំងពីពេលដែលកងឈ្លបចាកចេញទៅ ម្តាយរបស់ខ្ញុំគិតតែពីយំ មិនព្រមហូបបាយទឹកទេ ហើយក៏មិនព្រមទៅធ្វើការដែរ។ អ្នកជិតខាងដែលនៅក្បែរគ្នានោះបារម្ភពីគាត់ណាស់ ចេះតែជួយលួងលោមឲ្យគាត់ត្រលប់ទៅធ្វើការ

វិញទៅ ហើយឈប់យំយែកទៀត ព្រោះខ្លាចអង្គការយកទៅធ្វើបាប។ ប្រពន្ធ របស់ប្រធានភូមិ បានមកជួបម្តាយរបស់ខ្ញុំ ហើយជួយនិយាយលួងលោមថា គាត់បានជួយនិយាយជាមួយកងឈ្លបរឿងខ្សែកនោះហើយ។ ឮដូច្នោះហើយ ម៉ាក់បានធូរស្បើយចិត្តត្រលប់ទៅធ្វើការងារវិញ ហើយផ្តែផ្តាំឲ្យប្រពន្ធប្រធាន ភូមិជួយរកបន្តោងខ្សែកនោះមកឲ្យវិញផង។ ទោះបីជាដូច្នោះក្តី កងឈ្លប នោះ បានប្រាប់ប្រពន្ធប្រធានភូមិថា ចាំ២០ថ្ងៃទៀត នឹងមកចាប់ម្តាយរបស់ខ្ញុំយក ទៅរៀនសូត្រហើយ។

ទើបតែបានជាង១០ថ្ងៃក្រោយ មេឃមិនទាន់ទាំងភ្លឺស្រួលបួលផង សូរ សំឡេងផ្ទុះ ផ្ទង។!លាន់ឮតៗគ្នាឥតដាច់។ ប្រជាជននៅក្នុងភូមិចាប់ផ្តើម ជ្រួលច្របល់ ចេញមកជួបជុំគ្នាមុខខ្ទម ហើយនិយាយខ្សឹបខ្សៀវគ្នា។ បាន មួយសន្ទុះ ពួកខ្មែរក្រហម ក៏ចេញមកប្រកាសប្រាប់ថា «ឲ្យសមមិត្តទាំងអស់ នាំគ្នារៀបចំអីវ៉ាន់ ហើយចេញដំណើរទៅទិសខាងលិច ដ្បិតអីពួកវៀតណាម ចូលស្រុកហើយ ដូច្នេះពួកយើងមិនអាចនៅទីនេះបានទៀតទេ»។

សូរកាំភ្លើងកាន់តែឮច្បាស់ទៅៗ រីឯម្តាយរបស់ខ្ញុំ ក្រោយពីរៀបចំបង្វែច ខោអាវរួច ក៏ចាប់ផ្តើមឆ្លេឆ្លា ព្រោះនឹកឃើញកូនប្រុសរបស់គាត់ដែលនៅត្រើយម្ខាង ទៀត។ សូរសំឡេងតឿនប្រជាជនក៏ចេះតែឮបន្តគ្នាជាហូរហែថា «លឿនឡើងៗ! ពួកវៀតណាមចូលស្រុកហើយ ឆាប់ទៅៗ! ខ្មាំងចូលស្រុកហើយ»។ ម្តាយរបស់ខ្ញុំ ភ័យពេក ក៏ផ្តាំប្រាប់ខ្ញុំឲ្យនៅចាំគាត់ក្នុងផ្ទះនេះកុំទៅណាឲ្យសោះ។ ម្តាយរបស់ខ្ញុំ នឹងឆ្លងទៅត្រើយម្ខាងទៅរកបងរបស់ខ្ញុំ។ ផ្តាំផ្ញើរួចហើយ ម្តាយរបស់ខ្ញុំក៏ឆ្លងស្ទឹង ទៅជាមួយអ៊ំម្នាក់ទៀត ដែលមានកូននៅត្រើយម្ខាងដែរ។ ចំណែកខ្ញុំ ដោយ ភ័យខ្លាចផង និងនៅចាំម្តាយផង ក៏រត់ចូលទៅពួននៅក្នុងផ្ទះ មិនហ៊ានចេញទៅ ណាទេ ទម្រាំពួកគាត់ត្រលប់មកដល់វិញ។

ក្រុមគ្រួសាររបស់ខ្ញុំ បានជួបនឹងអ៊ំៗក្រុមអ្នកឡើងភ្នំតប្រហែល១០ គ្រួសារ ដែលមិនចេញទៅណាតាមគេទេ។ ពួកគាត់ ក៏បបួលម្តាយរបស់ខ្ញុំ ជញ្ជូន អីវ៉ាន់ដាក់ទូកធំមួយជាមួយគ្នាទៅតាមផ្លូវទឹកវិញ។ លុះដោលទូកទៅជិតដល់ តាសៀវរៀច ក្រុមអ្នកចុះទូក បានឃើញក្រុមខ្មែរក្រហមដែរ តែដោយសារពួក

នោះ កំពុងបាក់ទ័ព ទើបគ្មានខ្មែរក្រហមណាមកបង្ខំ ឬគំរាមកំហែងពួកយើងឲ្យរត់ទៅទេ។ ពេលទៅដល់តាសៀវវៀច ស្នូរកាំភ្លើងដៃ និងគ្រាប់ផ្លោង បានស្ងប់ស្ងាត់បន្តិច។ ពួកយើងគិតគ្នាមិនរត់តាមខ្មែរក្រហមទេ រួចនាំគ្នាចុះទូកបណ្តែតមកដល់កំពង់ថ្កូវវិញ។ យប់នោះស្ទើរតែគ្មាននរណាហ៊ានដេកទេ ព្រោះឮស្នូរឆ្កែលូផង ឮស្នូរគ្រាប់ផ្លោងផាំងៗ!ផង។ ចាស់ៗក៏នាំគ្នាជួបជុំគ្នា រួចនិយាយថា «បែកហើយយើង! អាពតបែកហើយ!»។ អារម្មណ៍ពេលនោះ ភ័យផង អរផង ព្រោះយើងមិនដឹងថាតើស្ថានការណ៍បន្តទៀតវានឹងទៅជាយ៉ាងណាទេ។

ស្រាប់តែព្រឹកឡើងមានប្រជាជនមួយចំនួន នាំគ្នារត់មកពីភាគខាងលិចវិញ ហើយស្រែកប្រាប់ថា «មិត្តអើយ! យួនចូលស្រុកហើយ! វៀតណាមរំដោះហើយ! ឈប់មានអាពតហើយ! យើងបានទៅផ្ទះវិញហើយ! យើងបានទៅស្រុកកំណើតយើងវិញហើយ!»។ គ្រាន់តែឮដូច្នេះ ម្នាក់ៗសែនត្រេកអរ ដូចទើបតែស្លាប់ហើយរស់ឡើងវិញអីចឹង។ យើងនាំគ្នាកិនស្រូវ កិនអង្ករគគ្រឹកគគ្រេង។ អ្នកភូមិ នាំគ្នាទៅគាស់ជង្រុក យកស្រូវអង្ករមកច្រកទុក ហើយអ្នកខ្លះចូលផ្ទះបាយបានអំបិល បានស្ករ ត្រីសាច់ និងចានឆ្នាំងដែរ យកមកចែកគ្នាហូប។

ក្រុមគ្រួសាររបស់ខ្ញុំត្រលប់មកផ្ទះវិញ

លុះសភាពការណ៍បានស្ងប់ស្ងាត់ល្អវិញហើយ ពួកយើង បានត្រលប់មករស់នៅក្នុងភូមិក្រឡាញ់វិញ។ នៅក្នុងភូមិ មានទាំងប្រជាជនចាស់និងប្រជាជនថ្មីរស់នៅជាមួយគ្នា។ ផ្ទះសម្បែងនិងដីធ្លីរបស់យើង ត្រូវបានប្រជាជនផ្សេងយកជាអស់ខ្លះបាត់ទៅហើយ។ ដោយមិនចង់មានរឿងរ៉ាវ គ្រួសាររបស់ខ្ញុំនាំគ្នាទៅរស់នៅលើដីមួយកន្លែងផ្សេងទៀតដែលមិនទាន់មានម្ចាស់ ហើយចាប់ផ្តើមប្រកបរបរកសិចិញ្ចឹមជីវិតឡើងវិញ។

ពេលនោះ ម្តាយរបស់ខ្ញុំ ចាប់ផ្តើមរបរលក់នំបញ្ចុកដើម្បីចិញ្ចឹមកូន។ មួយថ្ងៃហើយ មួយថ្ងៃទៀត មួយខែហើយ មួយខែទៀត យើងចេះតែសង្ឃឹមថានឹងបានជួបមុខឪពុករបស់ខ្ញុំនិងបងៗទាំងពីរ ប៉ុន្តែយើងមិនដែលបានទទួលដំណឹងអ្វីសោះ។ ដំណឹងពីពុកនិងបងទាំងពីររបស់ខ្ញុំ។

ក្រោយពីរបបខ្មែរក្រហមបានដួលរលំ យើងមិនដែលអស់សង្ឃឹមទេ ទោះបីជាយើងបានទទួលដំណឹងថា ទាហានដែលធ្លាប់បានទៅស្រុកសៀម ត្រូវបានខ្មែរក្រហមយកមកសម្លាប់ចោលនៅតាមផ្លូវក៏ដោយ។ លុះប្រហែលជា៣ឆ្នាំក្រោយមក យើងបានទទួលដំណឹងតាមរយៈមីងម្នាក់ដែលធ្លាប់ស្គាល់គ្នាថា បងរបស់ខ្ញុំ ស្លាប់បាត់អស់ហើយ។ កាលនោះ មីងនោះ បានជួបបងរបស់ខ្ញុំទាំងពីរនៅគល់ស្ពានជ្រោយចង្វារ ពេលដែលខ្មែរក្រហមបណ្តេញប្រជាជនចេញពីទីក្រុង។ គាត់ បានបបួលបងរបស់ខ្ញុំ មកជាមួយគ្រួសារគាត់ដែរ តែបងរបស់ខ្ញុំមិនជាច់ចិត្តរត់ចោលមា ដែលគាត់ធ្លាប់ស្នាក់នៅជាមួយ។ ក្រោយពីរៀតណាមរំដោះបាន មីងនោះ បានដំណឹងថាគ្រួសាររបស់មា និងអ្នកនៅជាមួយគាត់ ត្រូវបានគេយកទៅសម្លាប់ចោលអស់ទៅហើយ។ មុនដំបូង ខ្មែរក្រហមសម្លាប់បងទី១របស់ខ្ញុំ ដែលជានិស្សិតពេទ្យទើបនឹងប្រឡងជាប់ទៅរៀននៅអាមេរិក។ បន្ទាប់មក ខ្មែរក្រហមសម្លាប់បងស្រីទី២ ដែលធ្វើជាគ្រូបង្រៀន ហើយចុងក្រោយ ខ្មែរក្រហម សម្លាប់គ្រួសាររបស់មាមួយគ្រួសារតែម្តង។

ចូលដល់ឆ្នាំ១៩៨៩ ម្តាយរបស់ខ្ញុំ បានទៅជួប អ៊ំហ៊ីង ដែលបានរៀបការជាមួយស្ត្រីថៃនៅក្នុងប្រទេសថៃតាំងពីមុនពេលពុករបស់ខ្ញុំ ចូលធ្វើការម្ល៉េះ ព្រោះគាត់ដឹងពីដំណឹងឪពុករបស់ខ្ញុំ។ អ៊ំហ៊ីង បានប្រគល់ខ្សែកមួយខ្សែដែលជារបស់ឪពុករបស់ខ្ញុំ ឲ្យមកម្តាយរបស់ខ្ញុំ។ ពេលម្តាយរបស់ខ្ញុំ ឃើញខ្សែកនោះ គាត់អាចដឹងពីជោគវាសនារបស់ឪពុករបស់ខ្ញុំហើយ។ អ៊ំហ៊ីង បានប្រាប់ម្តាយរបស់ខ្ញុំថា គាត់ព្យាយាមឃាត់ដំណើរ ឪពុករបស់ខ្ញុំដែរ តែគាត់មិនស្តាប់ ហើយនៅតែរឹងរូសត្រលប់មកស្រុកខ្មែរវិញ។ អ៊ំហ៊ីង រៀបរាប់ថា ខ្មែរក្រហម បានផ្ញើលិខិតទៅស្ថានទូតនៅប្រទេសថៃឲ្យបញ្ជូនទាហានដែលទៅរៀននៅថៃត្រលប់មកស្រុកវិញឲ្យអស់ ហើយឪពុករបស់ខ្ញុំ បារម្ភពីប្រពន្ធកូនដែលរស់នៅក្នុងស្រុកខ្មែរពេក ក៏ត្រលប់មកវិញ។

ក្រោមពន្លឺព្រះខែនាយប់ពេញបូណ៌មី ម្តាយរបស់ខ្ញុំ បានច្រៀងរាយទំនុកបន្តនូវបទ «ឱ!ភ្នំពេញអើយ» បំពេឲ្យខ្ញុំគេងរហូតលង់លក់ក្នុងសម័យដែលសន្តិភាពមានប្រាកដក្នុងដែនកម្ពុជា ៕

ចប់

១៤
រឿងរន្ធោចជីវិត

អ្នកនិពន្ធ ៖ ឆាក់ សុភឿន

១៤ ~ រឿង រឭកជីវិត

នៅថ្ងៃដំបូងដែលប្រជាជនកម្ពុជា ត្រូវខ្មែរក្រហមជម្លៀសចេញពីផ្ទះមួយរយៈ ដោយខ្មែរក្រហមបានកុហកប្រជាជនថា អាមេរិកនឹងទម្លាក់គ្រាប់បែក។ ពេលធ្វើដំណើរ ប្រជាជនខ្លះមានរទេះគោក្របី សម្រាប់ដឹកជញ្ជូនអីវ៉ាន់ ខ្លះគ្មានរទេះក៏រែករបស់របរតាមដែលអាចយកទៅបាន និងអ្នកខ្លះទូលសំពីងសំពោង ធ្វើដំណើរណែនពាសពេញផ្លូវចេញពីទីក្រុងភ្នំពេញ។

ពូនេត និង មីងកី មានកូនស្រីចំនួន ២នាក់។ កូនស្រីច្បងរបស់គាត់ឈ្មោះ ភាព មានអាយុ៤ឆ្នាំ និងកូនទីពីរឈ្មោះ ផល អាយុទើបតែជាងមួយខួបប៉ុណ្ណោះ។

ក្រុមគ្រួសាររបស់ ពូនេត ក៏មិនខុសពីប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញដែរ។ ពួកគាត់ ត្រូវខ្មែរក្រហម ជម្លៀសចេញពីភូមិកំណើតឲ្យទៅរស់នៅកន្លែងផ្សេង។ នៅពេលជម្លៀស មីងកី បានដាក់កូនតូចរបស់គាត់ក្នុងសង្រែក ហើយសង្រែកម្ខាងទៀតដាក់អីវ៉ាន់រែកដើរតាមផ្លូវ។ ចំណែក ពូនេត វិញ បររទេះគោដឹករបស់របរ ចាន ឆ្នាំង អង្ករ កូនស្រីច្បង ព្រមទាំងម្តាយរបស់គាត់ទៅជាមួយដែរ។ ពួកគាត់រួមជាមួយនឹងអ្នកភូមិ បានធ្វើដំណើរទាំងយប់ ចាកចេញពីភូមិត្រពាំងរុន ឃុំតានី ឆ្ពោះទៅទិសខាងកើត។ ពេលសំឡេងគ្រាប់កាំភ្លើងស្ងាត់បន្តិច ពួកគាត់នាំគ្នាសម្រាកនៅក្បែរជើងភ្នំមួយរហូតដល់មេឃភ្លឺបន្តិចទើបដឹងថាពួកគាត់មកដល់ជើងភ្នំសន្លុង ដែលស្ថិតក្នុងខេត្តតាកែវ។ ពួកគាត់ សម្រាកដាំបាយហូបនៅទីនោះ ដោយមិនទាន់សម្រេចចិត្តថានឹងធ្វើដំណើរទៅទីណាទៀត។ ពួកគាត់ចេះតែធ្វើដំណើរទៅរហូតជិតដល់ព្រំដែនវៀតណាម ស្រាប់តែ

មានកងឈ្លបមួយក្រុម ស្គាយអាវុធ ព្រមទាំងមានគ្រាប់ជាប់ពេញទាំងខ្លួន មកប្រាប់ថា ឲ្យត្រលប់ទៅក្រោយវិញ ព្រោះខ្លាចមានគ្រោះថ្នាក់។

យើងមិនបានវិលត្រលប់ទៅផ្ទះវិញទេ ព្រោះសង្គ្រាមបានកើតឡើងហើយ។ ប្រជាជនម្នាក់ៗព្រួយបារម្ភគ្រប់គ្នា។ នៅតាមផ្លូវ ប្រជាជនណាដែលមានរទេះគោ និងសម្ភារផ្សេងៗ ត្រូវអង្គការដកហូតយកទៅជាក់ជារបស់រួមទាំងអស់ លើកលែងតែសម្លៀកបំពាក់តែប៉ុណ្ណោះ។ ពូនេត និងក្រុមគ្រួសារ បានមកដល់ទីតាំងថ្មីមួយ នៅស្រុកជុំគីរី ដែលជាតំបន់ដាច់ស្រយាល ជាប់ព្រំដែនខេត្តកំពង់ស្ពឺ។

ខ្មែរក្រហមឲ្យពួកគាត់ឈប់ធ្វើដំណើរទៅមុខទៀត ហើយឲ្យតាំងទីលំនៅនៅទីនោះ។ ប្រជាជន ចាប់ផ្តើមរស់នៅរួម ធ្វើការរួម ចំណែកឯ កងទ័ពខ្មែរក្រហមកាន់តែកើនឡើង ព្រោះមានប្រជាជនជាច្រើនចូលធ្វើកងទ័ព។ ការរស់នៅទីនោះគ្មាននរណាមាន នរណាក្រទេ។ ប្រជាជនរស់នៅដូចៗគ្នា ស្លៀកពាក់ខោអាវខ្មៅដូចគ្នា ធ្វើការរួមគ្នា ហូបរួមគ្នា និងគ្មានអ្វីជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ អ្វីៗជាកម្មសិទ្ធិរបស់អង្គការទាំងអស់។ ប្រសិនបើនរណាមិនព្រមធ្វើតាមអង្គការនោះទេ នឹងត្រូវចាត់ទុកជាខ្មាំង ហើយត្រូវយកទៅសម្លាប់ចោល។ ចំណែកឯការប្រមូលផ្តុំមនុស្សជាក្រុមវិញ គឺត្រូវចែកជាផ្នែកផ្សេងពីគ្នាដូចជា ក្រុមកុមារ ក្រុមយុវជន និងក្រុមមនុស្សចាស់។ ចំណែកឯ ប្តី និងប្រពន្ធត្រូវរស់នៅបែកពីគ្នា មិនអាចឲ្យនៅជាមួយគ្នា ឬជិតគ្នាទេ ព្រោះខ្លាចរួមផ្សំគំនិតគ្នាក្បត់អង្គការ ឬវល់តែជួយគ្នាខាតការងាររបស់អង្គការ។ កុមារតូចៗ ត្រូវអង្គការចាត់ឲ្យដើររើសអាចម៍គោ និងកាប់ដើមទន្ទ្រានខែត្រ យកទៅធ្វើជី។ យុវជនវ័យជំទង់ និងជនពេញកម្លាំងអង្គការចាត់ឲ្យឃ្វាលគោ លើកភ្លឺស្រែ ជីកប្រឡាយ និងលើកជាទំនប់។ ការងារទាំងអស់សុទ្ធតែមានកំណត់ និងតឹងរឹងណាស់។

ពូនេត និងយុវជនមួយក្រុមទៀត ត្រូវបានអង្គការបញ្ជូនឲ្យទៅភ្ជួរស្រែ និងឃ្វាលក្របី នៅឯភូមិតាកុក ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត។ ចំណែកឯ មីងកី ត្រូវអង្គការចាត់ឲ្យនៅជាមួយកងនារីក្នុងភូមិត្រពាំងរាំង ឆ្ងាយពី ពូនេត រាប់គីឡូម៉ែត្រ។ ឯកូនតូចរបស់គាត់ រស់នៅជាមួយយាយចាស់ៗ ហើយកូនច្បង

ត្រូវអង្គការចាត់ចូលក្នុងកងកុមារ។ អំឡុងពេលនោះ ការហូបចុកមិនគ្រប់គ្រាន់នោះទេ ចុងភៅបបរអង្ករសុទ្ធតែទឹកបង់តែអំបិល ពេលខ្លះឥតអំបិលទៀត ចែកឲ្យហូបកំណត់ក្នុងម្នាក់តែមួយវែកប៉ុណ្ណោះ ជួនកាលទៀត បបរមានលាយជាមួយដើមចេក ព្រលិត និងត្រកួនក៏មានដែរ។ ដោយសារតែអាហារ ការរស់នៅខ្វះអនាម័យ និងការងារធ្ងន់ធ្ងរ ប្រជាជនមួយចំនួនធ្លាក់ខ្លួនឈឺ រាករូសស្លាប់ជាហូរហែ។

ពូនេត ខំធ្វើការងារខ្លាំងពេករហូតធ្លាក់ខ្លួនឈឺ។ កងឈ្លបតែងតែមកតាមពូនេត ដល់ផ្ទះ ខ្លាចគាត់ធ្វើពុតជាឈឺខ្ជិលធ្វើការ។ ថ្ងៃមួយឈ្លបមកដល់ស្រែកសួរពូនេត ថា «មិត្តនេត! ម៉េចមិនឃើញទៅធ្វើការ?»។ ឮដូច្នោះ ពូនេត ឆ្លើយតបទៅវិញភ្លាមៗថា «មិត្តប្អូន!ខ្ញុំឈឺពីរបីថ្ងៃហើយ ងើបក៏មិនរួចទើបមិនបានទៅធ្វើការ»។ ពូនេត កំពុងដណ្តប់ភួយញាក់រង្គើពេញទាំងខ្លួន សាច់ក្តៅស្លេកស្លាំងកម្លាំងក៏ខ្សោយ ឈ្លបម្នាក់វៃចំណាស់ យកដៃស្ទាបមើលឃើញថាឈឺមែនក៏សួរថា «តើមានបានលេបថ្នាំហើយឬនៅ មិត្តនេត? បើនៅទេ ចាំខ្ញុំស្នើទៅអង្គការឲ្យមិត្តសម្រាកបានពីរបីថ្ងៃទៀត ហើយស្នើថ្នាំមកឲ្យលេប! ឥឡូវមិត្តនេតឯងសម្រាកសិនចុះ?»។ ឮដូច្នោះ ពូនេត ធូរស្រាលក្នុងចិត្តបន្តិច ហើយក៏ស្នើសុំទៅឈ្លបនោះថា «មិត្តបង ខ្ញុំសុំឲ្យប្រពន្ធខ្ញុំមកមើលខ្ញុំបានទេ? ខ្ញុំឈឺច្រើនថ្ងៃហើយ ប្រពន្ធខ្ញុំមិនទាន់ដឹងទេ ហើយខ្ញុំឈឺធ្ងន់ខ្លាចមើលមិនជា»។ ពេលនោះ អ្នករស់នៅជាមួយគ្នានៅទីនោះក៏ឡើងមក ហើយជួយនិយាយថា «មិត្តនេតនេះឈឺពីរបីថ្ងៃហើយ មិត្តបងជួយស្នើឲ្យប្រពន្ធគាត់មកមើលផង កុំឲ្យគាត់បារម្ភក្រែងឆាប់ជា ព្រោះគ្មាននរណានៅមើលគាត់ទេ គាត់ឈឺមែន មិនមែនធ្វើពុតទេ ដូចឃើញស្រាប់ហើយ»។ ឈ្លបក៏យល់ព្រមស្នើទៅអង្គការឲ្យ ពូនេត។

ចំណែកឯ មីងកីវិញ បានចូលធ្វើការនៅកន្លែងចុងភៅបានមួយរយៈហើយ។ មីងគ្រីស បាននាំ មីងកី មកធ្វើការនៅកន្លែងចុងភៅនៅភូមិត្រពាំងរាំង ឃុំតានី។ មីងគ្រីស ធ្លាប់ស្គាល់ម្តាយ មីងកី ហើយដោយឃើញ មីងកី ជាមនុស្សស្លូតបូត មីងគ្រីស បានសុំប្រធានក្រុមឲ្យ មីងកី មកធ្វើចុងភៅជាមួយ។ ស្អែកឡើង មីងកី

បានទទួលដំណឹងពីអ្នកមកយកបាយកន្លែងចុងភៅ ប្រាប់ថា ប្តីរបស់គាត់ឈឺធ្ងន់។ ឮដូច្នោះ មីងកី បានសុំឲ្យ មីងគ្រីស ជួយមើលកូន ព្រោះផ្លូវឆ្ងាយពិបាកយកកូនទៅតាម។ មីងគ្រីស ឮហើយនិយាយថា «កីឯង យកបាយ និងសាច់ក្របីអាំងខ្លះទៅ ហើយខ្ចប់ដំឡូងស្ងោខ្លះទៅ ឲ្យវាហូបក្រែងឆាប់ជាជំងឺ សម័យនេះគ្មានអ្វីក្រៅពីអត់ឃ្លានទេ យើងជាចុងភៅអាចហូបបាយស្រួល មានម្ហូបហូបខ្លះ អ្នកឯទៀតមិនដែលទាំងស្គាល់បាយផង កុំថាឡើយដល់ម្ហូប»។ និយាយរួច មីងគ្រីស ដេញមីងកី ឲ្យឆាប់ចាកចេញទៅ។

មីងកី ទៅដល់ផ្ទះប្តីរបស់គាត់ ថ្ងៃលិចល្ម។ ពេលគាត់ទៅដល់ឃើញប្តីរបស់គាត់ដេកស្ទើរតែលែងដឹងខ្លួនទៅហើយ មីងកី ក៏ហៅតិចៗថា៖

មីងកី៖ «ឪវ៉ា! ឪវ៉ា!ឯងយ៉ាងម៉េចហើយ?ឈឺប៉ុន្មានថ្ងៃហើយ?»

ពូនេត៖ «មកហើយ? ឈឺពីរបីថ្ងៃហើយ គ្មាននរណាមើលទេ»

មីងកី៖ «នរណាមកមើល នៅសម័យនេះនោះ។ ឪវ៉ាឯងហូបបាយសិនទៅ ឲ្យមានកម្លាំងសិនចាំខ្ញុំឲ្យលេបថ្នាំ ប្រហែលជាលែងអីហើយ»។

ពូនេត៖ «ហូបជាមួយអី?»

មីងកី៖ «ម្ហូបសាច់ក្របី ចៃគ្រីស ឲ្យហើយមានដំឡូងផ្ងាស្ងោខ្លះដែរ ឯងងើបមកខំហូបទៅ លុះត្រាតែទ្រាំ ទើបរស់បានណាឪវ៉ា»។

មីងកី គ្រាប្តីឲ្យងើបរួចគក់ច្របាច់ឲ្យប្តី។ ចំណែកឯ ពូនេត ពេលបានឃើញបាយនិងម្ហូប គាត់ខំហូបទាល់តែអស់ ហើយស្ងួរកទៀត។ ក្រោយពេលគាត់ហូបបាយហើយ ក៏មានកម្លាំងវិញ។ ត្រឹមតែមួយថ្ងៃគត់ គាត់បានធូរស្បើយពីជំងឺ។ ក្រោយប្តីហូបហើយ មីងកី ស្រូតមកកន្លែងរបស់គាត់វិញ។ មីងកី តែងលួចលាក់ផ្ញើបាយកញ្ចប់ និងដំឡូងស្ងោតាមអ្នកស្គាល់គ្នាឲ្យមកប្តីរបស់គាត់។ មីងកី តែងលួចយកបាយ ឬដំឡូងស្ងោពីកន្លែងចុងភៅមកផ្ញើប្តី ហេតុនេះគ្រប់ពេលដែលចុងភៅយកបាយមកឲ្យអ្នកភ្ជួរ ពូនេត តែងចងក្របីលបដើរមកព្រៃក្បែរផ្លូវ លួចហូបទាល់តែអស់ ហើយពេលខ្លះគាត់ទុកខ្លះមូរចង្កេះខោ ទុកហូបនៅផ្ទះទៀត។

ការឃ្វាលក្របី មិនមែនជាការងាយស្រួលនោះទេ បើបាត់ក្របី អង្គការ ច្បាស់ជាយកទៅសម្លាប់ចោល មិនដូច្នោះទេគឺយកទៅទឹមជំនួសក្របីមួយព្រឹក។ ថ្ងៃមួយ ពូនេត ឃ្វាលបាត់ក្របីមួយ ព្រោះគាត់ក្របីច្រើនពេក។ គាត់ភ័យណាស់ គិតថានឹងស្លាប់ជាមិនខានឡើយ។ គាត់ សម្រេចចិត្តរត់ចោលហ្វូងក្របី ឈប់ឃ្វាលក្របីឈប់ក្ងរស្រែ។ គាត់រត់កាត់ព្រៃពីកន្លែងមួយទៅកន្លែងមួយយ៉ាងវេទនា មានតែខោអាវខ្មៅមួយចង្កេះដាច់រយ៉ៃ ដើម្បីគេចពីក្តីស្លាប់។ ឈួប ដឹង ហើយដើរតាមរកគាត់តាំងពីព្រឹក រហូតដល់យប់។ ពូនេត រត់តាំងពីភូមិតាកុក ឆ្លងកាត់ភ្នំសែនហានទាំងយប់។ នៅសម័យនោះ ភ្នំសែនហាន មានអមដោយភ្នំតូចៗពីរទៀត ហ៊ុមព័ទ្ធដោយព្រៃក្រាស់ៗ ដើមឈើធំៗ ជាព្រៃខ្លាព្រៃដំរី ទោះជានៅវាលទំនាបជើងភ្នំ ក៏មានព្រៃឈើក្រាស់ៗមើលដាច់កន្ទុយភ្នែកដែរ។ ពេលយប់ សត្វខ្លាចេញរកចំណីជួបជាមួយ ពូនេត។ គាត់ភ័យណាស់ ក៏រត់ចូលនៅក្នុងលូមួយតូចអាចចូលបានត្រឹមខ្លួនមនុស្ស។ ពូនេត ភ័យពេក ចេះតែលូនចូលទៅ។ ខ្លាពីរ ដេញដល់រន្ធលូនោះ ហើយឈរនៅខាងមុខលូម្ខាងម្នាក់។ វាលូកចូលចាប់ទាញ ពូនេត តែមិនដល់ នៅខ្វះតែមួយចង្អាមទៀតប៉ុណ្ណោះ។ ខ្លានោះនៅយាមរន្ធរហូតដល់ថ្ងៃរះទើបវាចេញទៅលាក់ខ្លួនបាត់។ ចំណែក ពូនេត មានឱកាសក៏រត់ចេញបន្តទៀត។ ពូនេត រត់បីយប់បីថ្ងៃ អត់បាយមានតែទឹកប៉ុណ្ណោះ។ គាត់រត់សំដៅទៅរកប្រពន្ធរបស់គាត់ ក្រែងប្រពន្ធគាត់បាត់ដំណឹងរបស់គាត់។ ក្នុងគ្រានោះ មីងកី ត្រូវអង្គការផ្លាស់ឲ្យមករស់នៅខាងលិចភ្នំសែនហាន ក្នុងភូមិត្រពាំងត្រគៀត ឃុំដំបូកខ្ពស់ ស្រុកឈូក ខេត្តកំពតវិញ។

ថ្ងៃមួយអង្គការឲ្យ មីងកី និងចៃគ្រីស យកបាយទៅឲ្យមេកងនៅកន្លែងអ្នកទោស។ ទីនោះជាកន្លែងដាក់អ្នកទោស គេហៅថា «ពួកថ្មី»។ ពួកថ្មីនេះ ខ្មែរក្រហមធ្វើបាបជាងពួកចាស់។ នៅពេលគាត់ដើរចូលដល់កន្លែងនោះ គាត់ឃើញអ្នកទោសជាច្រើន ត្រូវដាក់គុកដាច់ៗពីគ្នា ដាក់ចម្រឹងឈើ និងចាក់សោជាប់។ ចៃគ្រីស និងមីងកី ទូលបាយក្នុងកញ្ជើ មានដំឡូងជ្វាស្ងោ និងចេកអំបូងទុំផងនោះ សម្រាប់ឲ្យមេកងធំមកពីអង្គការលើ។ ទៅដល់កណ្តាលបន្ទប់

មិនធ្លាយពីបន្ទប់អ្នកទោសប៉ុន្មានទេ មេកងធំដែលគ្រប់គ្រងលើក្រុមអ្នកទោស និងជាមេដឹកនាំគ្រប់គ្រងនៅតំបន់នោះទាំងមូល ចំនួនប្រាំនាក់ ស្លៀកពាក់ខ្មៅ បង់កក្រមា និងស្ពាយកាំភ្លើង មានទាំងគ្រាប់ពេញទាំងខ្លួន បានមកចាត់ចែង ពិភាក្សាគ្នាបន្តផែនការតទៅទៀត។ ក្នុងនោះ មានម្នាក់ជាត់មានឋធំចម្លែក គ្មាន នរណាស្គាល់គាត់ទេ។ មីងកី និងចែគ្រីស ជាក់កញ្ជើបាយ និងចេកអំបូងឲ្យ។ អ្នក ទាំងនោះពិភាក្សាគ្នាផង ហូបចេកអំបូងផង និយាយពីនេះពីនោះ គ្មាននរណាដឹង ថានិយាយពីអ្វីទេ ព្រោះឥតមាននរណានៅជិតឡើយ មិនហ៊ានទាំងមើលមុខផង។

ចុងឆ្នាំ១៩៧៨ មីងកី និងចែគ្រីស ត្រូវអង្គការឲ្យមករស់នៅកងផ្សេងទៀត។ ជីវិតរបស់ពួកគាត់ផ្លាស់ប្តូរទៅតាមអង្គការកំណត់។ អង្គការបានអនុញ្ញាតឲ្យ កូនច្បងរបស់ មីងកី មករស់នៅជាមួយគាត់ ព្រោះកូនរបស់គាត់ឈឺ។ ចំណែកឯ ភាព ដែលជាកូនទីពីររបស់គាត់វិញ នៅតូចហូបមិនឆ្អែត បានទៅលួចបូតស្លឹក ដំឡូងជ្វាទាំងចាស់យកមកស្ងោជ្រលក់អំបិលហូប ធ្វើឲ្យហើមពោះរាក ស្គម មានតែឆ្អឹង ស្កេកស្លាំង ពោះឡើងខៀវ។ មីងកី ភ័យណាស់ មិនដឹងធ្វើយ៉ាងម៉េច ទេ មិនដឹងបានថ្នាំពីណា ចេះតែដីកឫសឈើដាំទឹកឲ្យហូប ក្រោយមកក៏បានធូរ បន្តិចម្តងៗហើយជាឡើងវិញ។ ចំណែកឯ ពូនេត រត់ចោលជួរ មកតាមរកប្រពន្ធ។ នៅតាមផ្លូវគាត់លួចបេះដូង លួចដំឡូង លួចចេកទុំ ដែលអ្នកភូមិរត់ចោលស្រុក អាចឲ្យគាត់រស់បានមួយគ្រាៗ។ ក្រោយមកគាត់បានជួបអ្នកភូមិជាមួយគ្នា ឈ្មោះ ជន។ គាត់បានរៀបរាប់ប្រាប់ពីរឿងរបស់គាត់តាមរកប្រពន្ធ។ ពូជន បាន សុំមេក្រុមឲ្យនៅជាមួយដោយប្រាប់ថា ពូនេត ជាសាច់ញាតិរបស់គាត់ ហើយ ក៏បានប្រាប់ពីកន្លែងប្រពន្ធគាត់រស់នៅ។ ពូនេត បាននៅទីនោះក្បែរប្រពន្ធ របស់គាត់។ ថ្ងៃមួយយប់ស្ងាត់ ពូនេត បានស្កាត់ទៅរកប្រពន្ធ។

ពូនេត ៖ «ម៉ែវ៉ា!»

មីងកី៖ «ឱវ៉ា!ម៉េចក៏ឯងមករកខ្ញុំ ឃើញ?» មីងកីភ្ញាក់ព្រើតពេលឮសំឡេង ដឹងថាប្តីរបស់គាត់។

ពូនេត៖ «ខ្ញុំសួរ ពូជន គាត់ថាឯងនៅទីនេះ ខ្ញុំក៏មករកខ្លាចឯងមិនដឹងខ្ញុំ នៅឯណា»

មីងកី៖ «ហើយឯងមកមាននរណាដឹងទេ?»

ពូនេត៖ «មិនដឹងទេ ខ្ញុំចាំដល់យប់គេដេកអស់ទើបមក!ហើយថាកូនឈឺម៉េចហើយ?»

មីងកី៖ «វាធូរបន្តិចហើយ ខ្ញុំដាំទឹកឫសឈើឲ្យវាផឹក មកពីវាស៊ីស្លឹកដំឡូងស្ងោទាំងចាស់ច្រើនពេកទើបរាក ពោះឡើងខៀវ តែប្រហែលជាលែងអីហើយ! ឯងប្រញាប់ទៅវិញទៅ ខ្លាចគេឃើញ តែពួកវាឃើញ វាយកទៅកសាងមិនខាន»

ពូនេត៖ «ខ្ញុំមកប្រាប់ឯងឲ្យដឹងខ្ញុំទៅវិញហើយ» ពួកគាត់ និយាយគ្នាខ្សឹបៗ មិនឲ្យគេឮទេ រួចពូនេត លូនចេញតាមក្រោយទៅវិញ។

រៀងរាល់យប់ពេលគេដេកអស់ ពូនេត តែងទៅលួចដកដំឡូង បេះដូងបេះចេក មិនថាចេកទុំឬទេ គាត់លួចបេះទាំងអស់ ទោះជាដឹងថាមានគ្រោះថ្នាក់ក៏ដោយ។ ពេលបេះបានហើយ គាត់យកមកដុតក្នុងដី ព្រោះខ្លាចគេឃើញ។ គាត់ចេះជីកជីរួចដាក់ដំឡូងក្នុងដី រុំឲ្យជិតរួចដុតភ្លើងពីលើឆ្អិនយកមកហូប ហើយយកមកឲ្យប្រពន្ធកូនទៀត។

មិនថាតែ ពូនេត ទេ ប្រជាជនមួយចំនួន គឺតែងតែលួចបែបនេះដូចគ្នា ព្រោះតែឃ្លាននិងហូបមិនឆ្អែត។ មីងកី បារម្មណ៍ពី ពូនេត ណាស់ពេលឃើញខ្មែរក្រហមចាប់បានអ្នកទោសយកទៅធ្វើទារុណកម្មនិងសម្លាប់។ គាត់ខ្លាចប្តីរបស់គាត់ត្រូវចាប់បានយកទៅសម្លាប់ចោលដែរ ប៉ុន្តែទោះជា មីងកី ប្រាប់ប្តីរបស់គាត់យ៉ាងណា ក៏ប្តីគាត់មិនស្តាប់ដែរ ព្រោះតែភាពអត់ឃ្លាន។

ក្រោយមក អង្គការបានបំបែកក្រុមប្រុសៗ ឲ្យទៅនៅឯឆ្ងាយពីក្រុមនារី។ ពូនេត មិនមានពេលមកមើលប្រពន្ធរបស់គាត់ទៀតទេ។ បើស្តាត់មកក៏ឆ្ងាយដែរ ហើយគាត់ខ្លាចឈ្លបចាប់បានយកទៅសម្លាប់ចោល។ នៅថ្ងៃមួយ មីងកី ធ្លាក់ខ្លួនឈឺ។ គាត់ទៅធ្វើការលែងកើត។ ចៃគ្រីស បានទៅសុំមេកងថា មីងកី ឈឺ ប៉ុន្តែមេកងមិនជឿទេ។ ពួកគេមកតាមមើល និងដេញឲ្យ មីងកី ទៅធ្វើការទៀត។ ឈ្លបពីរនាក់តាមមកមើលហើយស្រែកសួរទៅ មីងកីថា «មើ!មិត្តកី ថាឈឺយ៉ាងម៉េចហើយដើររួចទេ?»។ មីងកីឆ្លើយតបទៅដោយសំឡេងល្វើយថា

«ដើរមិនរួចទេមិត្តបង ខ្ញុំក្តៅខ្លួនហើយរងារខ្លាំងណាស់ អស់កម្លាំងវិលមុខផង ហូបអីក៏មិនបានពីរបីថ្ងៃហើយ»។ ពេលនោះ ឈ្លបម្នាក់វ័យក្មេង និយាយពាក្យអសុរោះដល់គាត់យ៉ាងច្រើនថា «មិត្តឯងក្រោកមើ មនុស្សឥឡូវគំនិតអាក្រក់ណាស់ ខ្ជិលធ្វើពុតជាឈឺស្ទើរគ្រប់គ្នា គ្រុនអី គ្រុនញាក់ គ្រុនញ័រ គ្រុនអាត្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនខ្ជិលធ្វើការ ខាតការងារអង្គការអស់ហើយ បើម្នាក់ៗពុតខ្ជិលគ្រប់គ្នាបែបនេះ»។

មីងកី អស់កម្លាំងពេកឈប់និយាយត ហើយសម្ងំដេកទៅ។ ពួកឈ្លបទាំងពីរនាក់នោះ ត្រលប់ទៅវិញបាត់ទៅ។ ដល់ព្រលប់ៗ មានឈ្លបផ្សេងមកមួយក្រុមទៀត មានស្រីមានប្រុស ឈរអើតពីក្រោមផ្ទះមកស្រែកសួរ ក្រែងមីងកី ធ្វើពុតជាឈឺ។ ឈ្លបម្នាក់មានវ័យកណ្តាល ជាមនុស្សនៅក្នុងភូមិជាមួយគ្នា ឈ្មោះ យ៉ែន។ យ៉ែន ជាឈ្លបអង្គការ ពេលមានមុខមានមាត់ លែងស្គាល់គ្នាឯង និងអ្នកភូមិហើយ។ គាត់មកសួរនាំ មីងកី តាមដានមើលតើឈឺមែនឬអត់។ គាត់ឈរស្រែកពីក្រោមផ្ទះមក មិនហ៊ានឡើងលើផ្ទះជិតអ្នកជំងឺទេព្រោះខ្លាចឆ្លង។ ថ្មីៗនេះ មានអ្នកឈឺដូច មីងកី ច្រើនណាស់ ឆ្លងគ្នាស្លាប់បន្តគ្នារហូត។

យ៉ែន៖ «អើ! មិត្តកី! ឮថាមិត្តឯងឈឺមែនឬអត់?»

មីងកី ឮសំឡេងស្គាល់ថា ពូយ៉ែន ព្រោះជាមនុស្សស្រុកភូមិជាមួយគ្នា ក៏ឆ្លើយតបទៅវិញ។

មីងកី៖ «ខ្ញុំឈឺពីរបីថ្ងៃហើយបងងើបមិនរួចទេ»

យ៉ែន៖ «មិនមែនពុតជាឈឺគេចពីការងារទេឬ? »

មីងកី៖ «ឱបងអើយ! បើបងមិនជឿម៉េចមិនឡើងមកមើល បងឯងមិនដែលស្គាល់ខ្ញុំទេអី? ខ្ញុំចេះធ្វើពុតពីពេលណាមក»

យ៉ែន៖ «អើ!ឮថាមិត្តឯងហ្នឹង ធ្វើពុតទេ ទើបគេឲ្យខ្ញុំមកមើល»

ចៃគ្រីស នៅថៃ មីងកី ក្បែរនោះក៏ឆ្លើយថា

ចៃគ្រីស៖ «បើមិត្តបងឯងមិនជឿម៉េចមិនឡើងមកមើលឲ្យឃើញ»

យ៉ែន៖ «ខ្ញុំមិនឡើងទេខ្លាចឆ្លងអាសន្នរោគ»។ គាត់ក៏លែងសួរ លែង

ឆ្លងឆ្លើយគ្នា តែនៅចាំលបមើលក្រែង មីងកី មានការនិយាយគ្នាពីរឿងអី។ គាត់ក៏អើតលបៗងើបមើលតាមប្រហោងរនាប ចំពេលដែល មីងកី ចង់ក្អួត ក៏ក្អួតតាមប្រលោះប្រហោងរនាបមកដី ឈ្លប យ៉ែន រត់ចេញស្ទើរមិនទាន់។ លុះស្អែកឡើងទើបក្រុមពេទ្យរបស់អង្គការ បានយកថ្នាំមកឲ្យ មីងកី មានថ្នាំលេប និងថ្នាំចាក់។

ជីវិតរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហម មិនខុសគ្នាប៉ុន្មាននោះទេ។ ប្រជាជនម្នាក់ៗខំធ្វើការតាំងពីព្រឹកដល់យប់ទៅតាមការកំណត់របស់អង្គការ ប្តូរបបរវារមួយវែក ដើម្បីរក្សាជីវិតឲ្យរស់។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ទើបប្រជាជនបានវិលមករស់នៅតាមផ្ទះសម្បែង ស្រុកកំណើតរបស់ខ្លួនជួបជុំក្រុមគ្រួសារវិញ ប៉ុន្តែប្រជាជនខ្លះ ត្រូវព្រាត់ប្រាស់ក្រុមគ្រួសារជារៀងរហូត ដោយសារពួកខ្មាំងអប្បិយយកទៅសម្លាប់នៅក្នុងរបបខ្មែរក្រហម។

ចប់

១៥

រឿងដង្កើមស្នេហ៍ ក្បែរកម្ពាំង ត្បូងចប

អ្នកនិពន្ធ ៖ តាំង យ៉ែន

១៥ ~ រឿង ដង្កើមស្នេហ៍ក្បែរកម្លាំងត្បូងចប

សម្រស់អាចអូន ដូនអាល័យ

សំឡេងមាន់រងាវបានបន្លឺឡើងផ្ទួនៗហាក់បីដូចជាសំឡេងគាំងអង្រួនឮសូរញាប់រន្ធាន់។ មិនយូរប៉ុន្មាន ស្បៃអន្ធការដែលគ្របដណ្តប់លើផែនពសុធាបានរសាយរសាត់ផាយផាត់ឆ្ងាយបន្តិចម្តងៗ ដោយជំនួសមកវិញនូវផ្ទៃវេហាពណ៌លឿងទុំ លាយឡំផ្ទៃមេឃពណ៌ខៀវស្រទន់យ៉ាងស្រស់បំព្រង។ ព្រះសុរិយាបានអើតអង្គបង្ហាញកាយមិនឆ្ងាយពីមាត់ព្រៃព្រឹក្សានៅក្បែរភូមិត្រពាំងថ្មកណ្តាលឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ ក្នុងភូមិនេះ មានផ្ទះបិតមួយខ្នងយ៉ាងស្រស់ស្អាតប្លែកពីគេ។ វាបានបង្អួតកាយ បង្ហាញសម្រស់ជាផ្ទះម៉ូតខ្មែរបុរាណ យ៉ាងចំណានលម្អទៅដោយដំបូលប្រក់ក្បឿងពណ៌ក្រហមស្រគាំលេចឡើងនៅចំកណ្តាលរុក្ខជាតិពណ៌បៃតងស្រស់។

នៅក្រោមផ្ទះនេះ មានដូនចាស់ម្នាក់ ដែលមានអាយុប្រហែល៦១ឆ្នាំ កំពុងញាប់ដៃញាប់ជើងចម្អិនម្ហូបអាហារ។ ដូនចាស់មានឈ្មោះថាដូន សុន។ គាត់មានកូនប្រុសតែម្នាក់គត់ឈ្មោះ សុខ រស់ ដែលមានប្រពន្ធឈ្មោះនាង សុភាព ហើយពួកគេរស់នៅភូមិផ្សេងពីដូន សុន។ កូនស្រីច្បងរបស់ សុខ រស់ និងនាង សុភាព បានមករស់នៅជាមួយដូន សុន ដើម្បីបានរៀនសូត្រ និងនៅបម្រើដូន សុន ផង។ ចៅស្រីដូនសុន មានឈ្មោះថា ធីតា ជាសិស្សថ្នាក់ទី៩ ក នៃវិទ្យាល័យមួយក្នុងស្រុកភ្នំស្រុក។ វេលាម៉ោង១១ និង២០នាទីព្រឹក សំឡេងឡាន ម៉ូតូ កង់

និងសំឡេងមាត់មនុស្សជាច្រើន ដើរយ៉ាងអ៊ូអរ កើតមានតាមផ្លូវលាន់ឮមិនដាច់សូរ ពីព្រោះជាពេលដែលសិស្សានុសិស្ស មន្ត្រីរាជការ ចេញពីរៀន និងចេញពីកន្លែងធ្វើការងារ។ មិនយូរប៉ុន្មាន មានម៉ូតូហុងដាឌ្រីមស៊ើរីឆ្នាំ២០១៩ ពណ៌ខ្មៅរលើបរលោងយ៉ាងស្រស់សង្ហា បានបើកចូលទៅក្រោមផ្ទះដូន សុន។ ក្មេងស្រីជំទង់ម្នាក់ដែលមានសម្រស់ស្រស់សោភា បានស្លាយកាបូបសិក្សាពណ៌ក្រហមពាក់អាវដៃវែងពណ៌ស និងស្លៀកសំពត់ពណ៌ខៀវទឹកបិក។ នាងពន្លត់ម៉ាស៊ីនម៉ូតូ ហើយដើរសំដៅទៅរកដូន សុន។ លុះទៅដល់ហើយនាងក៏ឱនក្បាល និងលើកដៃសំពះដោយដាក់ចុងម្រាមដៃត្រឹមច្រមុះហើយបន្លឺវាចាថា «ជម្រាបសួរលោកយាយ! ចៅមកពីសាលារៀនវិញហើយ»។ ដូនសុន ងាកមុខមកដោយដៃរបស់គាត់មានកាន់វែកធ្វើម្ហូបជាប់ផងនោះ ឆ្លើយតបដោយទឹកមុខញញឹមថា «ល្អហើយចៅស្រី ចៅទៅងូតទឹកផ្លាស់សម្លៀកបំពាក់ទៅ រួចសឹមមកហូបបាយជាមួយគ្នា»។

ក្រោយពី ធីតា បានងូតទឹកផ្លាស់សម្លៀកបំពាក់រួចហើយ នាងបានមកហូបបាយថ្ងៃត្រង់ជាមួយជីដូន រួចរាល់ហើយក៏ប្រញាប់ប្រញាល់ឆុបជីដូនទៅកាន់វត្តត្រពាំងថ្ម។ បន្ទាប់ពីចេញពីវត្ត ដូន សុន បានឲ្យចៅស្រីរបស់គាត់ដូនគាត់ទៅលម្ហែនៅអាងត្រពាំងថ្ម ដែលគាត់ហៅថា «អាងអូន ជីដូនអាល័យ»។ ដូនសុនធ្លាប់មានអនុស្សាវរីយ៍យ៉ាងច្រើនសន្ធឹកសន្ធាប់ជាមួយនឹងអាងនេះ។ អាងត្រពាំងថ្មបច្ចុប្បន្ននេះ ស្ថិតនៅក្នុងឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ សម្រស់អាងអូន ដូនអាល័យ ដែលដូនសុន តែងតែហៅឈ្មោះជាប់មាត់របស់គាត់នោះ គឺគាត់សំដៅដល់អាងត្រពាំងថ្មនេះតែម្តង។ អាងអើយអាង អ្នកស្រស់ស្អាតអ្វីម្ល៉េះ? ផ្ទៃទឹកធំល្វឹងល្វើយ ហាក់បីដូចជាមហាទន្លេដែលបំពេរដោយរលកបោកបក់គ្រាំៗ យោលអន្ទោលទៅមកដោយកម្លាំងព្រះវាយោក្នុងផ្ទៃទឹករងថ្លាត្រជាក់ដល់ក្រអៅបេះដូងនៃទេសចរគ្រប់ប្រាណ ដែលមកសម្រាកសម្រាន្តទស្សនា និងងូតទឹកលេងជាមួយមិត្តភក្តិ ឬក្រុមគ្រួសារ។ ក្នុងទឹកពេញដោយរុក្ខជាតិ ឈូកព្រលិត លំចង់ រីកផ្តាំរហង់ចម្រុះពណ៌ ក្រហម លឿង ស ស្វាយ ចោលក្លិនក្រអូបសាយសព្វគ្រប់ទិសឋាន។

ខ្នងអាងធំយ៉ាងមាំទាំ ដាំលម្អទៅដោយរុក្ខជាតិជាជួរៗ ចោលម្លប់យ៉ាងត្រឈឹងត្រឈៃ ជាកន្លែងអង្គុយលេងយ៉ាងមនោរម្យរបស់ជននានាក្នុងការគយគន់ទេសភាពអាង និងស្រូបខ្យល់ជំនោរដ៏បរិសុទ្ធជុំវិញអាងត្រពាំងថ្ម។ ខាងក្រោមខ្នងអាង សុទ្ធតែវាលស្រែស្រូវ កំពុងលូតលាស់បង្អួតសម្រស់ម្ចាស់កសិដ្ឋានឲ្យមានទឹកមុខញញឹម នឹងសង្ឃឹមជានិច្ចចំពោះកសិផលរបស់ខ្លួន ថានឹងបានកើតកើន ចម្រើនផល ផ្តល់នូវស្រូវបរិបូណ៌សម្រាប់ហូបចុក និងលក់ដូរ។ អាងត្រពាំងថ្ម ក៏ជាកន្លែងអភិរក្សសត្វស្លាបយ៉ាងធំមួយនៅក្នុងប្រទេសកម្ពុជាដែរ។ នាពេលសុរិយារៀបលិចឯនាយមាត់ព្រៃ ផ្ទៃមេឃចាប់ផ្តើមប្រែពណ៌ជាក្រហម ទូកតូចមួយបានបណ្តែតកាយចូលទៅលើផ្ទៃទឹកសន្សឹមៗ។ នៅលើទូកនោះ មាននារីម្នាក់កំពុងអង្គុយនៅចុងក្បាលទូក ហើយដៃនាងម្ខាងកាន់ច្រវា និងដៃនាងម្ខាងទៀតដកព្រលឹត លំចង់មកស្រង់ក្លិន។ នាងបន្លឺសំឡេងយ៉ាងល្វើយៗថា «ឱ!គូសង្សារថ្លើមប្រម៉ាត់ កម្មអ្វីមកកាត់ពីឱព ឲ្យអូនកំព្រាព្រាត់ស្នេហា រស់រងទុក្ខាផ្សាគ្មានស្បើយ...»។ ដូនសុន ដែលកំពុងអង្គុយក្រោមដើមព្រីងធំមួយដើមប្របមាត់អាងជាមួយ ធីតា បានឮសំឡេងកំណាព្យយ៉ាងកម្សត់។ ដូនសុនចាប់ផ្តើមដកដង្ហើមធំ ហើយទឹកភ្នែកជាច្រើនតំណក់បានស្រក់ចុះ។ ធីតា បានហុចកន្សែងតូចមួយឲ្យទៅជីដូន ហើយបានបន្លឺសំឡេងថា «ជិតយប់ហើយលោកយាយ! តោះ!យើងទៅផ្ទះវិញ!»

ចម្ងល់ចៅស្រី

ក្រោយពីងូតទឹក ហូបអាហារពេលល្ងាចជាមួយជីដូនរួចរាល់ ធីតា បានរៀននិងធ្វើលំហាត់ ដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះក្រោមពន្លឺចង្កៀងភ្លើងអគ្គិសនីយ៉ាងភ្លឺត្រចះត្រចង់។ ដូនសុន អង្គុយមើលទូរទស្សន៍កម្មវិធីព្រះពុទ្ធសាសនា និងសង្គមខ្មែរយ៉ាងយកចិត្តទុកដាក់។ ក្រោយពេលរៀន និងបានធ្វើលំហាត់រយៈពេល២ម៉ោងរួចមក ធីតា បានដើរលបៗមកក្បែរជីដូន ហើយបានគក់ច្របាច់ជូនជីដូនថ្នមៗ។ ធីតា ចាប់ផ្តើមសួរជីដូនទាក់ទងនឹងអាងត្រពាំងថ្មដែលនាងនិងជីដូនទើបទៅអង្គុយលេងពីល្ងាច។

ធីតា៖ «លោកយាយ! តើអាងត្រពាំងថ្មកសាងឡើងនៅពេលណាដែរ?»

ដូនសុន៖ «គេជីកនៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺពួកក្រុមយាយ និងយុវជនជាច្រើននាក់ទៀតបានជីកអាងនេះឡើង»

ធីតា៖ «ខ្ញុំបានឃើញលោកយាយហូរទឹកភ្នែកកាលពីល្ងាចមិញនេះនៅអាងត្រពាំងថ្ម តើលោកយាយមានរឿងអ្វីលាក់ក្នុងចិត្តឬ?»

ដូនសុន៖ «យាយស្រណោះរឿងអតីតកាល ពីព្រោះយាយមានអនុស្សាវរីយ៍ជាច្រើននៅអាងនេះ យាយតែងហៅអាងនេះថា អាងអូន ដូនអាល័យ ដើម្បីរំឭកដល់ស្នេហារបស់យាយ និងតារបស់ចៅឯង»

ធីតា៖ «លោកយាយជួយប្រាប់ចៅផងមក ឲ្យចៅបានអស់ឆ្ងល់ និងបានដឹងអំពីព្រឹត្តិការណ៍នានាក្នុងសម័យប៉ុល ពត នោះផង ពីព្រោះចៅក៏បានសិក្សាមេរៀនប្រវត្តិវិទ្យាថ្នាក់ទី៩ អំពីសម័យកាលហ្នឹងដែរ»។

ដូនសុន បានចាប់ផ្តើមនិយាយពីរឿងរ៉ាវដែលគាត់បានដឹងពីរបបខ្មែរក្រហមប្រាប់ដល់ចៅ។

គុកឥតជញ្ជាំង រនាំងស្នេហ៍ឫស្សា

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម បានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ។ ពួក ប៉ុល ពត បានដឹកនាំប្រទេសជាតិដាក់ឈ្មោះរបបនោះថា «កម្ពុជាប្រជាធិបតេយ្យ»។ ពួក ប៉ុល ពត បានផ្តាច់មនោសញ្ចេតនារវាងប្តីប្រពន្ធ ជីដូនជីតា ឪពុកម្តាយ បងប្អូន និងក្រុមគ្រួសារ។ ប្រជាជនគ្រប់គ្នាព្រាត់ប្រាស់គ្រួសារ លះបង់ប្តី ប្រពន្ធ កូន ចៅ ហើយប្រជាជនពេញកម្លាំង ត្រូវចូលបម្រើកងទ័ពនៅសមរភូមិដើម្បីការពារប្រទេសជាតិ។ ខ្មែរក្រហម បានបែងចែកទឹកដីប្រទេសកម្ពុជា ជាភូមិភាគ ជាតំបន់ និងជាសមូហភាពមូលដ្ឋាន(ឃុំ និងភូមិ)។ ខ្មែរក្រហម បានបង្ខំឲ្យប្រជាជនធ្វើការលើសលប់ ហើយឲ្យហូបតែបបរវាលាយត្រកួនព្រលិត។ យើងគ្មានសម្លៀកបំពាក់ស្អាតបាតឡើយ គឺមានតែសំពត់ឬខោអាវពណ៌ខ្មៅដូចៗគ្នា គ្មានជម្រក គ្មានថ្នាំសង្កូវ សម្រាប់ព្យាបាលជំងឺទេ។ ប្រជាជនត្រូវរស់នៅរួមគ្នា ហូបរួមគ្នា និងធ្វើការរួមគ្នា។ ខ្មែរក្រហមកម្ទេចវត្តអារាម

ផ្សឹកព្រះសង្ឃ បិទសាលារៀន ហើយមន្ត្រីរាជការក្នុងរបបចាស់ និងប្រជាជនស្លូតត្រង់ជាង៣លាន់នាក់ បានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម។ និយាយដល់ត្រឹមនេះ ទឹកភ្នែកដួន សុន កាន់តែហូរស្រក់មកខ្លាំងឡើងៗ។

ឃើញដូច្នោះហើយ ធីតា បានសួរដួន សុនបន្តទៀតថា «ចុះលោកយាយ និងលោកតាបានជួបគ្នាដោយរបៀបណាវិញ?» ដួន សុន ជូតទឹកភ្នែក ហើយដកដង្ហើមយ៉ាងវែង រួចឆ្លើយតបទៅចៅស្រីរបស់គាត់ថា «សេចក្តីស្នេហារបស់យាយ និងតា កាន់តែកម្សត់ជាងនេះទៅទៀត»។ ដួនសុន បានក្រេបទឹកតែដើម្បីផ្សើមបំពង់ករបស់គាត់បន្តិច រួចហើយគាត់បាននិយាយបន្តទាំងទឹកមុខអស់សង្ឃឹមញញឹមលាយឡំទឹកភ្នែកហូររលីងរលោង។

៨ឆ្នើមស្នេហ៍ ក្បែរកម្លាំងត្បូងចប

កាលយាយអាយុ១៨ឆ្នាំ យាយមានទំនាក់ទំនងស្នេហាជាមួយកំលោះសង្ហាក្នុងភូមិយើងម្នាក់។ គាត់មានឈ្មោះថា ធាន។ កាលនោះគឺនៅឆ្នាំ១៩៧៥។

ដួនសុន បានចាប់ផ្តើមរំឭករឿងកាលកន្លងជាច្រើនឆ្នាំប្រាប់ធីតាចៅស្រីរបស់គាត់។

ធាន៖ «សុន! បងពិតជាស្រលាញ់អូនខ្លាំងណាស់! បងនឹងរៀបការជាមួយអូន និងធ្វើជាប្តីល្អដល់អូននិងកូនៗរបស់យើង»

សុន ៖ «អូន អរគុណខ្លាំងណាស់បងធាន! ប៉ុន្តែប្រទេសយើងប្រែប្រួលបានផ្លាស់ប្តូររបបគ្រប់គ្រង អូនបារម្ភពីវាសនាស្នេហាយើងខ្លាំងណាស់ បងត្រូវគេជម្លៀសចេញទៅមូលដ្ឋានការងារកសិកម្មនៅភូមិភាគឆ្ងាយពីអូន អូនមិនដឹងថាសុខទុក្ខបងដូចម្តេច? បងសម្លាញ់! អូនភ័យណាស់! ភ័យខ្លាចនារីមូលដ្ឋានដទៃដណ្តើមបងពីទ្រូងអូន»

ធាន៖ «អូនកុំបារម្ភអី! បងនៅតែជាបង! បងស្រលាញ់អូនលុះថ្ងៃមរណា» និយាយដល់ត្រឹមនេះ ធាន បានលូកដៃឱបក្រសោបចង្កេះ សុន ថ្នមៗ ដើម្បីផ្តល់ភាពកក់ក្តៅ និងភាពជឿជាក់នៃសេចក្តីស្រលាញ់ មួយសន្ទុះក្រោយការសន្ទនារវាង ធាន និង សុន ត្រូវបានបញ្ចប់។ អ្នកទាំងពីរបានត្រលប់ទៅផ្ទះរៀងៗខ្លួនដើម្បីសម្រាកយកកម្លាំងសម្រាប់ថ្ងៃស្អែកចេញទៅការដ្ឋានជីកអាងរៀងៗខ្លួន។

នាងសុន និងមិត្តភក្តិ ក្នុងភូមិរបស់នាងពីរនាក់ទៀតគឺនាងចំប៉ី និងនាងណាំ ព្រមទាំងក្រុមយុវជនជាច្រើនទៀត មកពីចម្រុះតំបន់គ្នា ត្រូវបានអង្គការ កេណ្ឌ ឲ្យជីកអាងត្រពាំងថ្ម។ ប្រជាជនម្នាក់ៗ ត្រូវខិតខំប្រឹងប្រែងធ្វើទាំងថ្ងៃ ទាំងយប់ ឥតហ៊ានឈប់សម្រាកទេ ពីព្រោះក្រសែភ្នែករបស់អង្គការ កំពុងតែឃ្លាំចាំមើលដូចភ្នែកម្នាស់។ នាងវតី ជាជនចំណូលថ្មី ដែលបានជម្លៀសមកពីភ្នំពេញប្រឹងធ្វើការទាំងឈឺគ្រុនរងា រហូតដល់ងងឹតមុខដេកដួលស្លាប់ក្នុងការដ្ឋានយ៉ាងខ្លោចផ្សាបំផុត។ នាងសុន និងមិត្តភក្តិ បានត្រឹមតែលួចសម្រក់ទឹកភ្នែកអាណិត នាងវតីតែប៉ុណ្ណោះ។

ថ្ងៃមួយ នាងសុន ជីកដីប៉ះរន្ទពស់វែក។ ពស់វែកបានដេញចឹកនាង។ នាងភ័យខ្លាំងណាស់ នាងរត់បណ្តើរ ស្រែកឲ្យគេជួយបណ្តើរ។

ង៉ែវ ៖«សមមិត្តសុន ៗ! រត់ឡើងមកខាងនេះ!» ង៉ែវ បានហុចដៃឲ្យនាងសុន ចាប់លើកឡើងពីក្នុងរណ្តៅអាង រួចផុតពីពស់កំណាចនោះទៅ។ នាងសុនបានសម្លឹងមើល ង៉ែវ តាំងពីក្បាលដល់ចុងជើង ដោយក្រសែភ្នែករីសអើង ហើយដើរចេញបាត់ទៅ សូម្បីពាក្យអរគុណចំពោះ ង៉ែវ មួយម៉ាត់ក៏គ្មានដែរ។

ង៉ែវ ជាកំលោះម្នាក់ ដែលរស់នៅក្នុងឃុំ ស្រុក និងខេត្តជាមួយនាងសុន ដែរ ប៉ុន្តែដោយគាត់ មិនសង្ហា សម្បុរខ្មៅ សក់រួញក្រញ៉ាញ់ ទាបកន្ទឹ ថែមទាំងមាត់ និងភ្នែកវៀចទៀតនោះ ទើបក្រមុំនានាមិនសូវស្គាល់គាត់ និងមិនសូវចាប់អារម្មណ៍លើគាត់ទេ។ តាំងពីថ្ងៃបានជួយសង្គ្រោះនាងសុន មក ង៉ែវ តែងលួចញញឹមម្នាក់ឯង។ ថ្ងៃមួយ ង៉ែវ កំពុងតែគិតស្រមៃម្នាក់ឯងក្រោមដើមត្នោត ដែលដុះលម្អជាជួរតាមផ្លូវស្រាប់តែសំឡេងមួយបានមកកាត់សង្វាក់ក្តីស្រមៃរបស់គាត់ថា «សមមិត្តង៉ែវ! កំពុងគិតអ្វីហ្នឹង? ញញឹមអរសប្បាយរីករាយតែម្នាក់ឯងហ្នឹង? ឱ! ប្រហែលមានស្នេហាហើយមែនទេ? ស្រលាញ់ក្រមុំណា? ឆាប់ស្នើគេទៅ!ប្រយ័ត្នកំលោះដទៃគេស្នើបានមុនណា!» ចំប៉ី បាននិយាយចំអន់ ង៉ែវ។ ង៉ែវ មុខឡើងក្រហមដោយសេចក្តីអៀនប្រៀន ហើយឆ្លើយតបទៅ ចំប៉ី ទាំងញ័រមាត់ញ័រកថា «ខ្ញុំលួចស្រលាញ់ សុន តាំងពីពេលដែលខ្ញុំបានជួយសង្គ្រោះ

នាងពីសត្វពស់កំណាចនោះមកម្ល៉េះ! នេះចំប៉ី ខ្ញុំបានព្យាយាមត្បាញកន្ទេលកក់ដោយដៃខ្ញុំផ្ទាល់ ជូន សុន ទុកក្រាលគេង ហើយចំប៉ី ប្រាប់ សុន ផងថា ខ្ញុំស្រលាញ់សុនខ្លាំងណាស់ ខ្ញុំនឹងស្នើសុនរៀបការឆាប់ៗនេះ»។ ចំប៉ី បើកភ្នែកធំៗ ហើយនិយាយទាំងអស់សំណើចថា «ស្អីគេ? ង៉ែវឯងហ្នឹងស្រលាញ់ សុន ចង់ស្នើសុនរៀបការជាមួយ? មានមើលរូបរាង មុខមាត់ខ្លួនឯងឬទេ? សុន មានមនុស្សក្នុងបេះដូងរួចទៅហើយ ជាកំលោះសង្ហាឈ្មោះសមមិត្តធាន! គេទាំងពីរនាក់ស្រលាញ់គ្នាណាស់ សមគ្នាណាស់ សុន ជាស្រីស្អាត ធាន ជាប្រុសសង្ហា! ង៉ែវ ឯងកំពុងសុបិនទាំងថ្ងៃហើយ! តោះទៅជីក និងសែងរែកដីប្រយ័ត្នអង្គការយកទៅកសាង»។

ពេលយប់ ចំប៉ី និង ណាំ បានជួប សុន ហើយបានប្រគល់កន្ទេលកក់ឲ្យ សុន ថែមទាំងបានរៀបរាប់ប្រាប់ សុន តាមដំណើររឿងទាំងអស់ ធ្វើឲ្យ សុន កាន់តែស្អប់ ង៉ែវ ទ្វេដង។ ក្រោយពេលបានដឹងរឿងថា ង៉ែវ ស្រលាញ់ខ្លួន នាងសុន មិនដែលនិយាយស្តីរក ង៉ែវ ទេ។ ង៉ែវ តែងព្យាយាមបង្ហាញទឹកចិត្តស្រលាញ់ចំពោះនាង សុន ជានិច្ច។ កន្លងទៅជាង៣ខែ ការដ្ឋានជីកអាងត្រពាំងថ្មជិតរួចរាល់ហើយ មេកង បានស្នើទៅថ្នាក់លើឲ្យមានការរៀបការជាមួយមនុស្សដែលខ្លួនស្រលាញ់ក្នុងក្រុមការដ្ឋាននេះ។ ជាឱកាស ង៉ែវ បានស្នើសុំរៀបការជាមួយ នាងសុន។ គ្រប់គូក្នុងការរៀបការនេះ ស្ទើតែគ្មានគូណាមួយ ដែលធ្លាប់បានស្រលាញ់គ្នាពីមុនមកសោះ។ នាងសុន នាងចំប៉ី និងនាងណាំជានារី ដែលមានទឹកមុខក្រៀមក្រំជាងគេ ពីព្រោះពួកនាងមិនបានស្រលាញ់បុរសដែលបានស្នើនាងរៀបការនោះទេ ហើយ នាងសុន ក៏មានសង្សារបណ្តូលចិត្តរួចទៅហើយដែរ។ ពួកនាងបានត្រៀមខ្លួនរួចជាស្រេចថាមិនព្រមប្រគល់ខ្លួនប្រាណឲ្យបុរសទាំងអស់នោះទេ។

ថ្ងៃរៀបការបានមកដល់ អង្គការ បានឲ្យយុវជន និងយុវនារី ចាប់ដៃគ្នាទាំង៣០គូ ហើយប្តេជ្ញាចិត្តចំពោះមុខអង្គការនិងទង់បក្ស។ ង៉ែវ ចាប់ដៃនាង សុន ដោយសេចក្តីស្រលាញ់យ៉ាងជ្រាលជ្រៅ និងទឹកមុខទឹកចិត្តយ៉ាងកក់ក្តៅ និងភាពស្រស់ថ្លាត្រជាក់ត្រជុំ។ រីឯ នាងសុន ទឹកមុខទឹកចិត្តពោរពេញដោយ

កំហឹង ការស្អប់ខ្ពើម និងការខូចចិត្ត ឈឺចាប់រកទីបំផុតគ្មាន។ នាងសុន នាង ចំប៉ី និងនាងណាំ ស្ទើរតែស្រែកចេញមកថាមិនព្រមរៀបការទេ តែដោយខ្លាច អំណាចពួកខ្មែរក្រហម នាងសុខចិត្តស៊ូទ្រាំខាំមាត់ សង្កត់ចិត្ត។ រាត្រីផ្សំដំណេក បានមកដល់ ង៉ែវ បានយល់ដឹងគ្រប់យ៉ាងថា នាងសុន មិនបានស្រលាញ់ខ្លួន នោះទេ ង៉ែវ ជាសុភាពបុរស ទោះបីគាត់មានរូប និងមុខអាក្រក់ក៏ដោយ ប៉ុន្តែ ចិត្តគាត់ល្អបរិសុទ្ធ និងមានស្នេហាស្មោះស្ម័គ្រខ្លាំងណាស់។ គាត់ស្រលាញ់នាង សុន ដោយចិត្តស្នេហ៍ភក្តី ហើយហ៊ានលះបង់គ្រប់យ៉ាងដើម្បី នាងសុន បាន សេចក្តីសុខ។

រីឯនាង ចំប៉ី រាត្រីផ្សំដំណេករបស់នាង មិនមែនជារាត្រីទឹកឃ្មុំសម្រាប់ នាងទេ។ នាងត្រូវប្តីនាងចាប់ រំលោភ។ នាងបានយកចបវាយចំក្បាលប្តីនាង រហូតដល់ស្លាប់ក្នុងថ្កុកឈាម។ ឈ្លបម្នាក់ឈ្មោះហាប់ បានមកឃើញហេតុការណ៍ នេះ ហើយចាប់ នាងចំប៉ី ចងស្លាបសេកយកទៅវាយចោលក្នុងរណ្តៅអាងត្រពាំង ថ្មយ៉ាងសាហាវព្រៃផ្សៃ។ លុះព្រឹកឡើង នាងសុន និងនាងណាំ បានឃើញ សាកសព នាងចំប៉ី ដេកស្លាប់ក្នុងថ្កុកឈាមយ៉ាងអាណោចអាធ័ម។ ពួកនាង ស្ទើរតែគាំងបេះដូងស្លាប់ ពួកនាងបានត្រឹមលួចយំអាណិតមិត្តដែលស្លាប់ទាំង វ័យក្មេង។ មួយសប្តាហ៍ក្រោយមក ដោយរងសំពាធកាន់តែធ្ងន់ទៅៗ ពីប្តី នាងណាំ បានសម្រេចចិត្តចងកសម្លាប់ខ្លួននឹងបង្អោងដើមត្នោត ដោយបានសរសេរទុក លើដីថា «ខ្ញុំស្អប់របបខ្មែរក្រហម»។

ព្រឹកឡើង នាងសុន បានឃើញ នាងណាំ ជាមិត្តខ្លួនបានចងក នាងស្ទើរតែ ធ្លុតស្លាប់។ នាងសុន អានពាក្យដៃល នាងណាំ បានសរសេរ ហើយនាងយំ បោកខ្លួននឹងដីយ៉ាងខ្លាំង។ មួយខែកន្លងផុតទៅ រាត្រីកាលបានចូលមកដល់។ ឈ្លបហាប់ បានមកលបលួចលាក់ខ្លួនពួនកាយក្បែរកន្លែង នាងសុន និងប្តីនាង ដេក ហើយក៏បានដឹងថា នាងក្បត់អង្គការដោយមិនព្រមឲ្យប្តីរួមរ័កជាមួយ។

ឈ្លបហាប់៖ «នាងសុន ក្បត់អង្គការឬ? ព្រឹកនេះអញចាប់យកទៅកសាង អប់រំសីលធម៌ហើយ ត្រៀមខ្លួន! ហឺះ! ស្រីចង្រៃ!»

នាងសុន៖« “ឱ! ពុទ្ធោអើយ! ខ្ញុំមិនទាន់ចង់ស្លាប់ទេ! ខ្ញុំចង់រួមរស់ជាមួយបងធានសង្សារបណ្តូលចិត្តរបស់ខ្ញុំ! ង៉ែវ ជួយខ្ញុំផងៗ!»

ង៉ែវ ៖ «ឈប់យំទៅ សុន! ព្រឹកនេះនាងមិនស្លាប់ទេ! »។

ព្រឹកឡើង ង៉ែវ បានចូលខ្លួនឲ្យ ឈ្លបហាប់ ចាប់ចង ដោយកុហកថា ខ្លួនជាអ្នកក្បត់អង្គការ មិនមែននាងសុនទេ។ មានមនុស្ស១០នាក់ដែលឈ្លបហាប់បានអូសក្បាលយកទៅវាយចោលក្នុងរណ្តៅក្នុងព្រៃក្បែរភូមិមួយមិនឆ្ងាយពីអាងត្រពាំងថ្ម។ ជនទី១០ ដែលឈ្លបហាប់ វាយសម្លាប់នឹងត្បូងចបនោះគឺ ង៉ែវ។

ទារុណកម្មបេះដូងរបស់សមមិត្តសុន

នាងសុន បានបាត់បង់ស្វាមី និងមិត្តជិតស្និទ្ធម្តងមួយៗ។ នាងមានអារម្មណ៍កាន់តែខ្លាច កាន់តែឯកា និងឈឺចាប់ក្នុងចិត្តរកទីបំផុតគ្មាន។ នាងសង្ឃឹមថា នាងនឹងបានជួបធានសង្សារបណ្តូលចិត្តរបស់នាង ហើយរួមរស់ជាមួយគ្នាប្រកបដោយសេចក្តីសុខ។ មួយអាទិត្យក្រោយមក មានក្រុមយុវជន យុវនារីជាច្រើននាក់បានមកជួយជីកអាងត្រពាំងថ្ម។ នាងសុន បានជួបសមមិត្តស្រីថ្មីម្នាក់ ឈ្មោះ នាងហៈ។

នាងសុន ៖«ហៈ! សមមិត្តធ្វើការនៅកន្លែងចាស់មានស្គាល់ឈ្មោះសមមិត្តធានឬទេ?»

នាងហៈ៖ «ចាស! ស្គាល់តើ! សមមិត្ត គាត់មានប្រពន្ធហើយ គាត់ទើបតែចាប់ដៃគ្នាកាលពីពីរខែមុននេះ»

នាងសុន ៖«ថាម៉េច! គាត់មានប្រពន្ធហើយ! មែនឬ?»។ នាងសុន បានប្តូរទឹកមុខយ៉ាងក្រៀមក្រំ ហើយស្ទើរតែគាំងបេះដូងស្លាប់ពេលដឹងថាសង្សារបណ្តូលចិត្តរបស់ខ្លួនដែលធ្លាប់បានស្រលាញ់គ្នាជាង៣ឆ្នាំ បែរជាក្បត់ចិត្តនាងលួចមានប្រពន្ធទៅវិញ!

នាងហៈ ៖ «ចាស! មែន! ប្រពន្ធរបស់គាត់ ជាអ្នកភូមិរបស់ខ្ញុំដែរ»។

ពេលរាត្រីស្ងាត់ មនុស្សម្នា បានដេកលង់លក់យ៉ាងសុខសាន្ត។ នាងសុនដេកមិនលក់សោះ។ នាងដេកបង្ហូរទឹកភ្នែកនឹកឃើញដល់ ធាន នឹកដល់ពាក្យស្នេហាផ្អែមល្ហែម នឹកដល់ពាក្យសន្យាថារៀបការនឹងគ្នា កាន់តែនឹក កាន់តែគិត ទឹកភ្នែកនាងកាន់តែហូរ។ នាងឈឺចិត្ត។ នាងខូចចិត្ត។ នាងគិតថា ជីវិត

នាងលែងមានខ្លឹមសារទៀតហើយ។ នាងនឹងបញ្ចប់វាក្នុងយប់នេះ។ គិតរួច នាងសុន ក្រោកដើរលបៗទៅក្រោមដើមត្នោត ហើយសម្លឹង រកបង្គោងដែលចងភ្ជាប់នឹងដើមត្នោតនោះ។ ពេលបានឃើញហើយ នាងបានយកក្រមាដែលនាងបង់ក មកចងនឹងបង្គោងនោះបម្រុងនឹងធ្វើអត្តឃាត។ នាងបានឡើងជាន់បង្គោងមួយៗ យឺតៗ ទឹកភ្នែក បានរមៀលស្រក់ជោគជាំផែនថ្ពាល់ទាំងសងខាងរបស់នាង។ បេះដូងនាងបានលោតកាន់តែញាប់ នាងកាន់តែឈឺចាប់ ឈឺហួសនឹងថ្លែង។ នាងបានលើកក្រមា ដែលចងជារង្វង់មកពាក់នឹងក រួចនាងទម្លាក់ខ្លួនដោយអារម្មណ៍ហោះត្រសែតអណ្តែតទៅរក ង៉ែវ ជាស្វាមី និងមិត្តភក្តិរបស់នាង។ ត្រឹមមួយរំពេចភ្នែក ខ្លួនប្រាណរបស់ នាងសុន បានធ្លាក់ដល់ដីឡើងហុយដីទ្រលោម ដោយសារតែខ្នែងបង្គោងផុយស្រួយបាក់ជាច់មកទាំងសំណុំ។ នាងហៃ ភ្ញាក់ដូចគេចាប់អង្រួន ហើយបានរត់ទៅរកប្រកពសំឡេង រួចស្រែកថា «សមមិត្តសុនៗ! ឯងធ្វើអីហ្នឹង? ឯងធ្លួតហើយឬ! ឯងមានវិបត្តិអ្វី?»។ នាងសុនយកខ្នងប្រអប់ដៃទាំងសងខាងជូតទឹកភ្នែក ហើយឆ្លើយតបទាំងអួលដើមកវិញថា «សមមិត្តហៃ!ធានជាសង្សារខ្ញុំ!គាត់បានក្បត់ខ្ញុំទៅមានប្រពន្ធហើយ!ខ្ញុំឈឺចិត្តណាស់ៗ!»។ នាងសុននិយាយព្រមជាមួយសំឡេងស្រែកយំមួយទំហឹង។ នាងហៃ បានលូកដៃឱបនាងសុន ហើយអង្អែលក្បាលនាងសុនថ្នមៗ ៖«សមមិត្ត! ខ្ញុំយល់អាម្មណ៍មួយនេះ! សមមិត្តយំមកចុះ!យំឲ្យអស់ចិត្តទៅ! ហើយព្យាយាមទទួលស្គាល់ការពិតថា នរណាដែលស្រលាញ់យើងពិតប្រាកដ? នរណាដែលស្រលាញ់យើងតែមាត់?»។

កន្ទេលកក់បាត់ម្ចាស់

ពេលវេលាចេះតែកន្លងផុតទៅ នាងសុន នឹករលឹកដល់មិត្តភក្តិ ដែលបានចែកឋានទៅយ៉ាងអយុត្តិធម៌។ នាង រឹតតែនឹកឃើញដល់ ង៉ែវ ដែលធ្លាប់តែជួយការងារធ្ងន់ស្រាល និងបម្រើនាងដោយសេចក្តីស្រលាញ់។ នាងបានយកកន្ទេលកក់ដែល ង៉ែវ បានជូននាងមកឱបថើបថ្នមៗ ហើយរវើរវាយ អណ្តែតអណ្តូងតែម្នាក់ឯងយ៉ាងកម្សត់។ នាងហៃ ឃើញដូច្នោះ ក៏តឿន នាងសុន ឲ្យឆាប់ចូលដេកព្រោះស្អែកត្រូវក្រោកពីព្រឹកទៅការដ្ឋានជីកដីបង្ហើយ។

លុះព្រឹកឡើងនាងសុន នាងហៈ និងក្រុមយុវជន យុវនារីបានដើរយ៉ាងស្វាហាប់ទៅកាន់ការដ្ឋានអាងត្រពាំងថ្ម។ សម្រាប់ការងារនាពេលថ្ងៃត្រង់ នាងសុន និងនាងហៈ បានជួបនឹង ធាន និងប្រពន្ធគាត់ដោយចៃដន្យ។

ធាន ៖ «សុន! ឲ្យបងសូមទោសអូនផង! បងគ្មានចេតនាចង់ក្បត់ចិត្តអូនទេ! ប៉ុន្តែ! បងនៃក... »

នាងសុន៖ «ខ្ញុំមិនស្គាល់សមមិត្តទេ! អ្នកជានរណា?»។ នាងសុន និយាយទាំងទ្រូងស្ទើរឆេះ នាងប្រឹងទប់ទឹកភ្នែកមិនឲ្យស្រក់ចុះ។ នាងហៈ ឃើញដូច្នោះក៏បបួល។

ចន្ទ្រាដួបតារា បុប្ផាត្រូវឥទ្ធិកសន្សើម

នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបង្កើតឡើង ដែលមានអ្នកស្នេហាជាតិគ្រប់តំបន់ក្នុងប្រទេសកម្ពុជា បានចូលរួមដើម្បីរំដោះប្រទេសជាតិ ឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ហើយកសាងប្រទេសកម្ពុជាស្របតាមឆន្ទៈ និងគោលបំណងរបស់ប្រជាជន។ ប្រជាជនខ្មែរ កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានរំដោះប្រទេសកម្ពុជាបានពីរបបប្រល័យពូជសាសន៍នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ប្រទេសកម្ពុជា បានបង្រួមបង្រួមជាតិឡើងវិញប្រកបដោយសេចក្តីសុខនិងសន្តិភាព។ ក្រោយរបបប៉ុលពតបានដួលរលំ ប្រជាជនខ្មែរមួយចំនួន បានទៅរស់នៅប្រទេសទី៣ ដូចជា អាមេរិក បារាំង អូស្ត្រាលីជាដើម។ ចំណែកឯ នាងហៈ និងប្រជាជនផ្សេងទៀត បានវិលត្រលប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។ ធាន និងប្រពន្ធកូន បានរស់នៅក្នុងភូមិ ឃុំ ស្រុក ខេត្តជាមួយនឹង នាងសុន ដែរ។ ធាន ព្យាយាមគាស់កកាយរើកភ្លើងស្នេហ៍ចាស់ជាមួយនាងសុន សាជាថ្មីវិញ តែនាងសុនបដិសេធរហូត ព្រោះនៅក្នុងចិត្ត នាងសុន នឹករឭកដល់ ង៉ែវ ដែលជាមនុស្សស្មោះនឹងនាងតែម្នាក់ប៉ុណ្ណោះ។

ល្ងាចមួយនាងសុនបានដើរលំហែកាយតាមមាត់អាងត្រពាំងថ្មតែម្នាក់ឯង។ នាងឈរក្រោមដើមត្នោតកន្លែងដែលនាងបានសុបិនឃើញ ង៉ែវ ដោយទឹកមុខក្រៀមក្រំ។ សំឡេងបុរសម្នាក់បានហៅឈ្មោះនាងយ៉ាងថ្នមៗនៅពីក្រោយខ្នង

របស់នាងថា «អូនសុន!»។ នាងសុន បានងាកវេបែរកប្រកពសំឡេងយ៉ាងស្រាលស្រទន់នោះដោយយឺតៗ។ នាងបើកភ្នែកធំៗ ចំហមាត់ ទឹកភ្នែកស្រក់ហូរ ហើយរត់មួយទំហឹងទៅឱបបុរសនោះយ៉ាងណែនជាប់នឹងកាយរបស់នាង រួចនិយាយថា «បងង៉ែវ!ៗ! ប្តីសម្លាញ់ចិត្តអូនៗ! បងមិនទាន់ស្លាប់មែនៗ! បងសម្លាញ់! អូននឹកប្តីណាស់! បងកុំទៅណាចោលអូនណា! អូនសូមអរគុណទេវតាដែលបានជួយបងឲ្យមកជួបជុំជាមួយអូនវិញ»។

ង៉ែវ បានរៀបរាប់ប្រាប់ នាងសុនថា «បងជាអ្នកទី១០ ដែលឈ្លបខ្មែរក្រហមវាយសម្លាប់ កម្លាំងដៃអ្នកវាយហាក់ដូចជាចុះខ្សោយ ពេលវាវាយបងឱនក្បាលងាកវេស្របពេលវាយមកត្រូវចំស្មាបង បងក៏ផ្តួលខ្លួនលើគំនរសពទាំងនោះ អ្នកវាយដើរចេញបាត់យប់ស្ងាត់បងរត់ទាំងឈឺរបួសយ៉ាងធ្ងន់ទៅលាក់ខ្លួនជ្រកកោនតាមជាយដែនខ្មែរថៃ រហូតដល់បានចូលរួមវាយកម្ចាត់ទ័ពខ្មែរក្រហម ទទួលបានជោគជ័យជាមួយបងប្អូនយុទ្ធជនខ្មែរដទៃទៀត»។

និយាយដល់ត្រង់នេះ ធីតា ដែលជាចៅស្រីរបស់ ដូនសុន លាន់មាត់ថា «អូ! រឿងលោកយាយវែងឆ្ងាយ និងកម្សត់ខ្លាំងណាស់ ចៅបានទទួលបទពិសោធច្រើនណាស់ពីរបបខ្មែរក្រហមពីរឿង៉ាវរបស់លោកយាយ»។

ដូនសុន បានដឹកដៃចៅស្រីចូលក្នុងបន្ទប់គេងបន្ទាប់ពីនិយាយរឿង៉ាវរបស់គាត់អស់ពេញមួយក្បាលព្រលប់នេះ។

ចប់

១៦

រឿងគ្រួសារខ្ញុំក្នុងរបបនាលពិឃាត

អ្នកនិពន្ធ ៖ រ័ត្នន៍ សេនា

១៦ ~ រឿង គ្រួសារខ្ញុំក្នុងរបប នាលពិឃាត

នៅឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំ រួមមាន ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ ចំនួន៦នាក់ បានរស់នៅក្នុងស្រុកកំណើតដែលស្ថិតក្នុងភូមិអង្គ្រង ឃុំស្វាយរំពារ ស្រុកស្វាយទាប ខេត្តស្វាយរៀងនៅឡើយទេ។ លុះដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមមានផែនការជម្លៀសប្រជាជនដែលរស់នៅក្នុងខេត្តស្វាយរៀងទៅរស់នៅកន្លែងផ្សេងៗ។ ភាគច្រើនគេហៅយើងថា ពួកបូ៉ត។ ខ្មែរក្រហមចោទ ពួកបូ៉ត ថាមាននិន្នាការក្បត់អង្គការ ដូច្នេះហើយ ប្រជាជនទាំងអស់តម្រូវឲ្យចាកចេញពីភូមិកំណើតរបស់ខ្លួន។

ជម្លៀសទៅខេត្តពោធិ៍សាត់

ថ្ងៃមួយ អ្នកភូមិអង្គ្រង រួមជាមួយអ្នកភូមិដទៃទៀតនៅក្នុងខេត្តស្វាយរៀង នាំគ្នាធ្វើដំណើរដោយថ្មើរជើងតាមផ្លូវថ្នល់ឆ្ពោះទៅកាន់ព្រំដែនវៀតណាម ក្នុងគោលបំណងគេចចេញពីខ្មែរក្រហម ហើយឆ្លងចូលទៅរស់នៅក្នុងប្រទេសវៀតណាម។ យើងធ្វើដំណើរទើបតែដល់ភូមិព្រៃស្រគំ ឃុំបុស្សមន ស្រុករំដួល ពួកខ្មែរក្រហម បានតាមមកទាន់ រួចបានឃាត់ប្រជាជនឲ្យត្រលប់បកក្រោយវិញ។ ប្រជាជនជាងពាក់កណ្តាល បានរត់គេចរួចខ្លួនចូលទៅក្នុងទឹកដីវៀតណាម។ ម្តាយមីងរបស់ខ្ញុំម្នាក់ បានទៅរស់នៅប្រទេសវៀតណាមរហូតដល់ឆ្នាំ ១៩៧៩ ទើបត្រលប់មកស្រុកកំណើតវិញ។

ក្រុមគ្រួសារនិងអ្នកភូមិរបស់ខ្ញុំ ត្រូវខ្មែរក្រហម កំណត់ឲ្យធ្វើដំណើរថ្មើរជើង តាមផ្លូវជាតិលេខ១ ឆ្ពោះទៅទិសខាងលិចអស់រយៈពេលជាច្រើនថ្ងៃក៏បានមកដល់ អ្នកលឿង។ យប់ជ្រៅបន្តិច ខ្មែរក្រហម បាននាំយើងចុះជិះកប៉ាល់ បន្តធ្វើដំណើរ តាមដងទន្លេមេគង្គតម្រង់ទៅកាន់រាជធានីភ្នំពេញ។ ព្រលឹមស្រាងៗ កប៉ាល់បាន មកដល់និងឈប់សំចតនៅកំពង់ផែមួយម្តុំផ្សារច្បារអំពៅ។ ក្រុមខ្មែរក្រហម បាន ចែកបាយនិងត្រីចំហុយឲ្យយើងហូបឆ្អែតគ្រប់ៗគ្នា រួចទើបយកឡានមកដឹកពួក យើងទៅកាន់ស្ថានីយរថភ្លើង រួចឡើងជិះរថភ្លើងធ្វើដំណើរបន្តឆ្ពោះទៅកាន់ភាគ ខាងជើង។ អ្នកភូមិរបស់ខ្ញុំជាច្រើនគ្រួសារ ត្រូវជិះក្នុងទូររថភ្លើងជាមួយគ្នា។ អស់រយៈពេលជាច្រើនម៉ោង ហើយកាន់តែយប់ជ្រៅទៅៗ រថភ្លើង បានទៅដល់ ស្ថានីយមួយស្ថិតក្នុងទឹកដីស្រុកបាកាន ខេត្តពោធិ៍សាត់។ នៅក្នុងស្ថានីយរថភ្លើង មានពួកខ្មែរក្រហមដែលជាម្ចាស់ស្រុកនៅទីនោះ ឈរចាំពួកយើងរួចជាស្រេច។ ពួកគេឲ្យបងប្អូនអ្នកភូមិរបស់ខ្ញុំរស់នៅទីនេះតែម្តង រីឯប្រជាជនដទៃទៀតដែល ជិះនៅទូររថភ្លើងផ្សេងៗ ត្រូវបន្តដំណើរទៅមុខទៀត។

សហករណ៍ស្តុកខ្លា

ទីនេះជាសហករណ៍ស្តុកខ្លា ស្ថិតនៅក្នុងភូមិស្វាយស ស្រុកបាកាន ខេត្ត ពោធិ៍សាត់ ហើយនៅក្បែរ សហករណ៍អូរចែង សហករណ៍តាលោ និងសហករណ៍ សំរោង។ នៅទីនោះ មានផ្ទះក្បឿងដំបូលបីខ្នងធំៗជាច្រើន ដែលមានដើមល្មុត នៅព័ទ្ធជុំវិញផ្ទះ។ ផ្ទះនោះជាផ្ទះដែលអង្គការប្រគល់ឲ្យប្រជាជនថ្មីស្នាក់នៅ។ ក្នុងផ្ទះនីមួយៗ អង្គការឲ្យយើងរស់នៅចាប់ពីពីរគ្រួសារឡើង ទៅតាមសមាជិក គ្រួសារតិចឬច្រើន។

ថ្ងៃស្អែកឡើង អង្គការចាប់ផ្តើមបែងចែកការងារឲ្យប្រជាជនថ្មីធ្វើគ្រប់ៗគ្នា។ គេបំបែកសមាជិកក្នុងក្រុមគ្រួសារនីមួយៗចេញពីគ្នា មិនឲ្យរស់នៅជួបជុំម៉ែឪ បងប្អូនដូចមុនទៀតឡើយ លើកលែងតែកុមារតូចៗ។ អង្គការ បានផ្សព្វផ្សាយមិន ឲ្យប្រើប្រាស់សម្លៀកបំពាក់ដែលមានពណ៌ឆើតឆាយទៀតទេ។ ពណ៌សម្លៀក បំពាក់ដែលគេកំណត់ឲ្យប្រើនាពេលនោះគឺ ពណ៌ខ្មៅ ហើយប្រសិនបើយើងគ្មាន

ខោអាវពណ៌ខ្មៅទេយើងត្រូវយកខោអាវពណ៌ផ្សេងៗទៅជ្រលក់ ធ្វើយ៉ាងណាឲ្យចេញទៅជាពណ៌ខ្មៅ។ មិនតែប៉ុណ្ណោះ យើងត្រូវហៅគ្នាថា«សមមិត្តឬមិត្ត»។

ឪពុករបស់ខ្ញុំ ត្រូវអង្គការឲ្យធ្វើការនៅផ្នែកដាំថ្នាំជក់។ ជារៀងរាល់ពេលយប់ងងឹតបន្តិចទើបខ្ញុំឃើញពុករបស់ខ្ញុំមកដល់ផ្ទះវិញ ហើយមេយមិនទាន់ភ្លឺផង គាត់ត្រូវចាកចេញពីផ្ទះទៅធ្វើការបាត់ទៀត។ ជារឿយៗ ឪពុករបស់ខ្ញុំ តែងតែលួចសន្លឹកថ្នាំជក់ដែលគាត់ដាំបានទៅដូរយកត្រីពីក្រុមនេសាទ ហើយគាត់យកត្រីនោះមកផ្ទះដុតឲ្យកូនប្រពន្ធហូបនៅពេលយប់ស្ងាត់យ៉ាងលាក់បាំងបំផុត។

ឯម្តាយរបស់ខ្ញុំវិញ ត្រូវអង្គការឲ្យទៅច្រូតស្រូវ កាប់គាស់ដី និងដាំបន្លែផ្សេងៗ។ គាត់ទៅធ្វើការតាំងពីព្រលឹមរហូតដល់ព្រលប់ទើបត្រលប់មកវិញដូចពុករបស់ខ្ញុំដែរ។ រៀងរាល់ល្ងាចពេលមកដល់ផ្ទះ ម៉ែតែងស្រាយជាយក្រមាយកកំប៉ុងវាល់អង្ករចេញមក។ ក្នុងកំប៉ុងនោះ មានបាយរបបប្រចាំថ្ងៃរបស់គាត់។ គាត់បេះពីមាត់ពីក ហូបខ្លះលួចញាត់ទុកខ្លះយកមកផ្ទះ។ ម៉ែធ្វើបែបនេះគឺដើម្បីលួចលាក់ទុកមកឲ្យខ្ញុំ។ ម៉ែរបស់ខ្ញុំខ្លាចកូនឃ្លានៅពេលយប់។

«ឱ! អ្នកម្តាយខ្ញុំអើយ! ពេលកន្លងផុតទៅជាច្រើនខែឆ្នាំ ទើបកូនកាន់តែយល់ច្បាស់ពីជម្រៅទឹកចិត្តរបស់ម៉ែ ថាមានទំហំធំប៉ុណ្ណាមកលើកូន» រាល់ពេលឲ្យតែខ្ញុំនឹកឃើញដល់រឿងនេះម្តងៗ ខ្ញុំក្តុកក្តួលរំជួលចិត្តឥតឧបមា ទឹកនេត្រាហូរស្រក់ចុះមកដោយពុំដឹងខ្លួន។

ប្រាកដណាស់ថា ក្នុងសម័យខ្មែរក្រហម ប្រជាជនទាំងអស់ ហូបមិនដែលបានឆ្អែតគ្រប់គ្រាន់ម្តងណាឡើយ។ ទោះបីជាក្នុងសហករណ៍ស្តុកខ្លានេះមានរបបអាហារជាបាយ ហើយមិនហូបបបរដូចសហករណ៍ដទៃក៏ដោយ ក៏យើងនៅតែខ្វះខាត ហូបមិនឆ្អែតទេ។

ខ្ញុំមានបងប្រុសចំនួន ៤នាក់ គឺវ័ត្ន ផល្លា, វ័ត្ន សុខា, វ័ត្ន សេដ្ឋា និង វ័ត្ន សុវត្ថា ត្រូវបានខ្មែរក្រហមបំបែកឲ្យទៅនៅដោយឡែកពីគ្នា។ អ្នកខ្លះរស់នៅក្នុងសហករណ៍ស្តុកខ្លា អូរចែង ស្រោង និងសហករណ៍ផ្សេងៗដែលនៅឆ្ងាយៗពីគ្នា។ ចំណែកឯប្អូនស្រីរបស់ខ្ញុំម្នាក់នៅតូច កើតជំងឺកញ្ជ្រឹលគ្មានថ្នាំធឹកព្យាបាលទេ។

ឪពុកម្តាយរបស់ខ្ញុំ បានត្រឹមដុតធាងត្នោត ផ្តាត្នោត ដាំទឹកឲ្យងូតនិងផឹក។ មិនបានប៉ុន្មានផង ប្អូនស្រីរបស់ខ្ញុំ បានស្លាប់បាត់បង់ជីវិត។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំពុំសូវបានជួបបងប្អូនរបស់ខ្ញុំទេ។ ខ្ញុំបានជួបញឹកញាប់តែបងប្រុសទីបួនរបស់ខ្ញុំម្នាក់តែប៉ុណ្ណោះ ព្រោះកងកុមារពិសេសរបស់គាត់នៅជិតសហករណ៍ស្តុកខ្លា ដែលខ្ញុំរស់នៅ។ ខ្ញុំបានជួប សុខា ដែលជាបងប្រុសទីពីររបស់ខ្ញុំម្តងតែប៉ុណ្ណោះ ពេលដែលអង្គការអនុញ្ញាតឲ្យគាត់មកផ្ទះ សម្រាកព្យាបាលរបួសជើងរបស់គាត់។ ចំណែកឯបងទីមួយនិងបងទីបី ខ្ញុំមិនដែលបានជួបគាត់រហូតដិតដល់ថ្ងៃរំដោះ ទើបពួកគាត់មានឱកាសបានត្រលប់មកជួបជុំគ្នាវិញ។

ជីវិតក្នុងកងកុមាររបស់យើង

ស្ថានភាពរស់នៅរបស់កុមារក្នុងសម័យខ្មែរក្រហមពុំសូវខុសគ្នាប៉ុន្មានទេ។ ខ្មែរក្រហម បានបែងចែកកងកុមារខុសៗគ្នា ទោះបីជាកុមារមានអាយុស្របាលគ្នាក៏ដោយ។ ខ្មែរក្រហម បែងចែកដោយផ្តោតទៅលើរូបរាងកាយសម្បទា។ កុមារណាដែលមានមាឌរាងមាំទាំ គឺគេយកទៅដាក់មួយក្រុមផ្សេង ហើយក្រុមនោះនឹងទទួលការងារលើសកុមារផ្សេងទៀតដែរ។ ការងាររបស់កងកុមារនៅពេលនោះរួមមាន ជីកដី សែងដី ដោយធ្វើការងារធ្ងន់ៗ ចង់ស្មើនឹងពួកយុវជនឬក្រុមមនុស្សចាស់ដែរ។

បងប្រុសសុខា ត្រូវអង្គការចាត់ចូលក្នុងក្រុមកងកុមារធ្វើការងារធ្ងន់នេះ។ គាត់ត្រូវទៅជីកប្រឡាយនៅសហករណ៍ស្រោង និងបន្ទាប់មកទៀត អង្គការផ្លាស់គាត់ឲ្យទៅនៅសហករណ៍តាលោ។ នៅក្នុងសហករណ៍តាលោ ការងារកាន់តែពិបាកទ្វេឡើង ហើយក្នុងមួយអាទិត្យទើបគាត់បានងូតទឹកម្តង។ នៅពេលងូតទឹក អង្គការ បាននាំកុមារទៅកន្លែងងូតទឹកមួយនៅចម្ងាយជាងមួយគីឡូម៉ែត្រពីកន្លែងស្នាក់នៅ។ ទឹកនោះគឺជាទឹកកណ្តោងនៅបាតស្រែប្រាំង។

ថ្ងៃមួយជើងបងរបស់ខ្ញុំ មុតនឹងផ្លែចបពេលកំពុងជីកស្រះ។ ច្រើនថ្ងៃក្រោយមក ដំបៅនោះបានក្លាយកាន់តែធំ និងមានដង្កូវនៅក្នុងសាច់ទៀតផង។ គាត់ក្តៅខ្លួនយ៉ាងខ្លាំង មិនអាចធ្វើការបានទេ ហើយត្រូវសម្រាកនៅក្នុង

សហករណ៍។ ថ្ងៃមួយពេលដែលបងរបស់ខ្ញុំអង្គុយនៅលើភ្លឺស្រែក្បែរកន្លែងស្នាក់នៅ គាត់បានជួបជាមួយស្ត្រីពីរនាក់ ដែលត្រូវជាមីងជីទួតមួយរបស់យើង គឺមីង ថន់ និងមីង ណាំ។ ពេលឃើញបងប្រុសរបស់ខ្ញុំដូច្នេះ គាត់ក៏ចូលទៅសុំមេកងអនុញ្ញាតឲ្យបងប្រុសរបស់ខ្ញុំ បានត្រលប់ទៅផ្ទះដើម្បីព្យាបាលមុខរបួស។ ទៅដល់ផ្ទះ យើងគ្មានថ្នាំល្អៗព្យាបាលគាត់ទេ។ ម៉ែរបស់ខ្ញុំ បានដើរចាប់កង្កែប អាចម៍គោ មកបុកលាយជាមួយស្លឹករុក្ខជាតិផ្សេងៗ បិតបំពោកលើដំបៅនោះជារៀងរាល់ថ្ងៃ។ យូរៗទៅ ដំបៅនោះក៏បានជាសះស្បើយ។

ចំណែកឯបងប្រុស សុវត្ថាវិញ ពេលដែលកងកុមាររបស់គាត់ ធ្វើដំណើរត្រលប់មកពីធ្វើការឆ្លងកាត់ចម្ការត្រប់ គ្នីគ្នារបស់គាត់ម្នាក់ បានលួចបេះត្រប់មួយផ្លែ រួចកាច់ពាក់កណ្តាលឲ្យទៅគាត់ស៊ី។ ពួកគាត់នាំគ្នាខាំស៊ីយ៉ាងឆ្ងាញ់ ប៉ុន្តែពេលនោះ ក្មេងអ្នកស្រុកម្នាក់ បានមើលឃើញ ហើយទៅរាយការណ៍ឲ្យមេកង។ ដោយសារតែរឿងត្រប់នេះ បងប្រុសរបស់ខ្ញុំ ត្រូវអង្គការបង្អត់បាយ។ សុខា ដឹងថាប្អូនមានរឿងមិនស្រួល ក៏ទៅសុំអង្ករគេឲ្យប្អូន ទើបបានរួចទុក្ខព្រួយនាពេលនោះទៅ។

ចំណែកខ្ញុំ និងអាវ៉ែ ដែលជាបងប្អូនជីទួតមួយ បាននាំគ្នាដើរវ៉ែកណ្តូបចង្រិត និងកង្កែបអាចម៍គោយកមកទុកដុតស៊ី។ ថ្ងៃនោះ យើងប្រទះឃើញដើមស្វាយនៅមាត់អូរមានផ្លែទុំជាច្រើន មានផ្លែខ្លះធ្លាក់ជ្រុះទៅក្នុងទឹកជម្រៅត្រឹមទ្រូងរបស់ពួកយើង។ ឃើញដូច្នោះ យើងទាំងពីរនាក់ បានលោតចុះទឹកប្រុង ស្រវាដើរសផ្លែស្វាយដោយក្តីតក់ក្រហល់និងស្រេកឃ្លាន។ នៅក្នុងអូរនោះ មានស្លឹកស្វាយទុំងាប់ជ្រុះគ្របផ្ទៃទឹកជិតស្តុង យើងគិតតែពីកាយស្លឹកស្វាយបណ្តើរ រើសផ្លែស្វាយបណ្តើរ។ យើងកាយចុះកាយឡើង ស្រាប់តែកាយប៉ះសាកសពមនុស្ស ដែលគេសម្លាប់បោះចោលក្នុងអូរនោះ ហើមអណ្តែតក្រោមស្លឹកស្វាយ។ យើងភ័យខ្លាចខ្លាំងណាស់ ក៏នាំគ្នារត់ឡើងយ៉ាងប្រញាប់ប្រញាល់ត្រលប់មកផ្ទះវិញ។ ទោះបីជាជួបសាកសពក៏ដោយ តែយើងមិនបោះចោលផ្លែស្វាយនោះទេ។ យើងនាំគ្នាជូតសម្អាតផ្លែស្វាយ រួចខាំហែកស៊ីយ៉ាងឆ្ងាញ់។

មានពេលម្តងនោះ ខ្ញុំឃ្លានខ្លាំងពេក ខ្ញុំបានលបចូលទៅលួចត្រីប្រហុកដែលគេហាលក្បែរសហករណ៍។ ខ្ញុំលួចបានមិនជាច្រើនប៉ុន្មានទេ រួចដើរកកន្លែងដើម្បីដុតត្រីនោះស៊ី។ ខ្ញុំបានទៅដល់ផ្ទះមួយនៅជាប់ស្រយាលពីគេ ហើយឃើញមានចង្ក្រានសុទ្ធតែរងើកភ្លើងក្រហមរងាល។ មិនបង្អង់យូរ ខ្ញុំដាក់ត្រីនោះដុតក្នុងភ្លើងរហូតដល់ឆ្អិន។ ថ្ងៃនោះ ខ្ញុំសប្បាយចិត្តណាស់ កាន់ត្រីស៊ីបណ្តើរ ដើរបណ្តើរតម្រង់មកផ្ទះវិញ។

រឿងវ៉ាឥសម្លាប់មនុស្សក្នុងសហករណ៍ស្តុកខ្លា

ជារឿយៗ យើងឃើញគេចងបណ្តើរមនុស្សយកទៅសម្លាប់ចោលនៅក្នុងសហករណ៍ស្តុកខ្លាដែលក្រុមគ្រួសាររបស់ខ្ញុំរស់នៅ។ អ្នកទោសខ្លះមានទោសដោយសារអង្គការចោទប្រកាន់ថាមានជាប់ទាក់ទងនឹងរបបចាស់ អ្នកខ្លះមានទោសព្រោះតែនិយាយពីទុក្ខលំបាកឬពាក្យសម្តីមិនពេញចិត្តនឹងអង្គការហើយត្រូវបានកងឈ្លបស្តាប់ឮ ចំណែកអ្នកខ្លះទៀតមានទោស ព្រោះលួចរត់ចេញពីសហករណ៍មួយទៅសហករណ៍មួយទៀត។ ចំណែកឯ ទោសធ្ងន់ជាងគេនោះគឺការលួចរបស់របររបស់អង្គការដោយសារស្រេកឃ្លាន។ អ្នកទោសខ្លះ ត្រូវអង្គការនាំយកទៅសម្លាប់នៅវេលាយប់ស្ងាត់មិនឲ្យអ្នកនៅក្នុងសហករណ៍ដឹងទេ សូម្បីតែក្រុមគ្រួសារក៏ដឹងត្រឹមតែថា គេនាំយកទៅរៀនសូត្រតែប៉ុណ្ណោះ។ ឯអ្នកទោសខ្លះទៀត ត្រូវអង្គការចងបណ្តើរទាំងកណ្តាលថ្ងៃ ពីដើមភូមិដល់ចុងភូមិនិងបង្ខំឲ្យស្រែកខ្លាំងៗថា «បងប្អូនអើយ! កុំយកតម្រាប់តាមខ្ញុំ ខ្ញុំខុសហើយបងប្អូនអើយៗ» រួចអង្គការនាំដើរបង្ហួសសំដៅទៅកាន់កន្លែងសម្លាប់។

ខ្ញុំធ្លាប់ឃើញកងឈ្លបបណ្តើរអ្នកទោសយកទៅសម្លាប់។ ជួនកាល ខ្ញុំលួចដើរតាមមើលរហូតជិតដល់រណ្តៅដែលពួកគេត្រូវប្រហារជីវិតអ្នកទោស។ ខ្ញុំ ពួនពីចម្ងាយលួចមើល តែមើលមិនសូវច្បាស់ទេ។ ខ្ញុំឮតែសំឡេងវាយមនុស្ស និងសំឡេងស្រែក ហើយក៏ស្ងាត់ឈឹងទៅវិញ។

ពួកខ្ញុំនៅក្មេងៗចេះតែលួចដើរទៅនេះទៅនោះ អីចឹងហើយបានជាខ្ញុំដួបទីកន្លែងសម្លាប់មនុស្សច្រើន។ ខ្ញុំបានឃើញរណ្តៅខ្លះគេមិនទាំងកាយដីខ្មោចផង។

ពេលដែលខ្ញុំឃើញសាកសពដែលគេវាយចោលលើកដំបូង ខ្ញុំភ័យខ្លាចខ្លាំងណាស់។ ខ្ញុំតែងរត់សំដៅទៅផ្ទះវិញយ៉ាងលឿន។ តែក្រោយពេលដែលខ្ញុំជួបសាកសពញឹកញាប់ពេក ខ្ញុំលែងសូវមានការភ្ញាក់ផ្អើលឬភ័យខ្លាចខ្លាំងដូចមុនទៀតហើយ។

ថ្ងៃមួយនោះ ខ្ញុំនិងបងប្រុស សុវត្ថា បានប្រទះឃើញសាកសពមនុស្សមួយគ្រួសារ មានគ្នាចំនួនប្រាំពីរនាក់ ត្រូវបានសម្លាប់រួចដុតឆេះរោលៗនៅក្រោមគុម្ពឫស្សីមួយ។ ពួកគេប្រហែលជាមានទោសធ្ងន់ហើយទើបត្រូវអង្គការសម្លាប់ចោលមួយគ្រួសារបែបនេះ។

ចាប់ពីចុងឆ្នាំ ១៩៧៨

ចុងឆ្នាំ ១៩៧៨ និងដើមឆ្នាំ ១៩៧៩ ស្ថានការណ៍ចាប់ផ្តើមប្រែប្រួលបន្តិចម្តងៗ។ ការសម្លាប់មនុស្សកាន់តែកើនឡើង នេះប្រហែលជាពួកខ្មែរក្រហមបានដឹងពីចលនារណសិរ្យសាមគ្គីសង្គ្រោះជាតិកម្ពុជា រួមជាមួយនឹងកងទ័ពរំដោះរបស់វៀតណាម កំពុងមកវាយរំដោះនៅក្នុងប្រទេសកម្ពុជា។

មួយរយៈចុងក្រោយនេះ អង្គការបានបញ្ជាឲ្យអ្នកភូមិរបស់ខ្ញុំ ដែលរស់នៅក្នុងសហករណ៍ស្តុកខ្លា នាំគ្នាជីករណ្តៅ ហើយអង្គការប្រាប់ថា ពេលជីករួច យើងនឹងធ្វើពិធីជប់លៀងឲ្យសប្បាយម្តង និងលែងហូបខ្វះខាតទៀតហើយ។ ឮដូច្នោះ យើងនាំគ្នាជីករណ្តៅដោយទឹកចិត្តសប្បាយរីករាយណាស់ ទាំងមនុស្សចាស់ទាំងក្មេង ខិតខំជីករណ្តៅយ៉ាងសស្រាក់សស្រាំ។ យើងជីករណ្តៅមិនទាន់រួចរាល់ផងស្រាប់តែឮស្នូរគ្រាប់កាំភ្លើង និងគ្រាប់ផ្លោងគ្រាំងៗ ហើយស្រែកថា «សូមពុកម៉ែបងប្អូនទាំងអស់! ធ្វើដំណើរទៅកាន់សហករណ៍ស្រោង នៅទិសខាងជើង អង្គការយើងនាំបងប្អូនទៅកាន់តំបន់ផ្សេងទៀតដើម្បីគេចចេញពីទុក្ខភ័យ គេចពីពួកអាខ្មាំងយួនវាចូលមកដល់ហើយ វានឹងអារកសម្លាប់ពួកយើង»។

អ្នកភូមិរបស់ខ្ញុំ បានពិភាក្សាគ្នា ហើយសម្រេចចិត្តមិនធ្វើដំណើរទៅតាមខ្មែរក្រហមទេ។ យើងនាំគ្នាដើរត្រលប់មកទិសខាងត្បូងវិញរហូតដល់ប៊ឹងខ្នារ ឃុំត្រពាំងជង ស្រុកបាកាន ហើយបានជួបកងទ័ពរណសិរ្យ និងកងទ័ពវៀតណាម។

បន្ទាប់ពីថ្ងៃរំដោះ ក្រុមគ្រួសារនិងអ្នកភូមិរបស់ខ្ញុំ បានធ្វើដំណើរវិលត្រលប់ទៅកាន់ស្រុកកំណើតវិញដោយថ្មើរជើង។ យើងប្រើរយៈពេលជាងពីរខែចេញពីស្រុកបាកាន ខេត្តពោធិ៍សាត់ ទើបដល់ខេត្តស្វាយរៀង។ ដោយសារតែប្រជាជនម្នាក់ៗមានរូបរាងស្គមស្គាំង កម្លាំងក៏ថមថយ ហើយអ្នកខ្លះមានជំងឺ ដូច្នេះការធ្វើដំណើរមិនបានលឿននោះទេ។ នៅតាមផ្លូវត្រលប់មកស្រុកកំណើតវិញ យើងឃើញតែគេចាប់បានពួកខ្មែរក្រហមដែលគេចខ្លួន ហើយប្រជាពលរដ្ឋនាំយកមកកាត់ទោសឆៅៗតាមតែកំហឹង។ យើងទទួលបានជំនួយជាស្បៀងអាហារពីកងទ័ពកម្ពុជាខ្លះ និងកងទ័ពវៀតណាមខ្លះ ដែលនៅការពារតាមដងផ្លូវ។

មកដល់ទីក្រុងភ្នំពេញ មានផ្ទះឋិជាច្រើនគ្មានមនុស្សរស់នៅទេ។ អ្នកខ្លះជំនុំគ្នាថាយើងគួររស់នៅទីនេះឬយ៉ាងណា? ប្រជាជនភាគច្រើនឆ្លើយថា «ទេ! យើងនឹកស្រុកកំណើតណាស់» រួចក៏នាំគ្នាធ្វើដំណើរទៅមុខឆ្ពោះទៅកាន់ផ្លូវជាតិលេខ១បន្តទៅទៀត។ មានសាច់ញាតិរបស់ខ្ញុំប៉ុន្មានគ្រួសារដែរ ដែលបានសម្រេចចិត្តស្នាក់នៅទីក្រុងភ្នំពេញ។

មកដល់ស្រុកកំណើត គឺផុតរដូវធ្វើស្រែទៅហើយ។ ពួកយើងត្រូវពឹងលើអង្ករសាលី និងគ្រាប់ពោតដែលជាអំណោយរបស់រដ្ឋាភិបាលចែកឲ្យ ប៉ុន្តែយើងហូបមិនគ្រប់គ្រាន់ទេ។ ជារៀងរាល់ថ្ងៃ យើងបានយកអង្ករសាលី និងគ្រាប់ពោតមួយកំប៉ុង មកដាំបបរលាយជាមួយបន្លែផ្សេងៗ និងគល់ចេកដើម្បីចម្អែតក្រពះ។ ពួកយើងហូបបែបនេះជាច្រើនខែ ទើបមានអង្ករដាំបាយហូបបានប្រសើរឡើងវិញខ្លះ។ ក្នុងពេលដែលអត់ ឪពុករបស់ខ្ញុំ បាននាំកូនៗដើរជីកកណ្តុរពន្លាត់ស្បែកកាត់កន្ទុយរបស់វា ហាលឲ្យស្ងួតយកទៅដូរអង្ករពីប្រទេសវៀតណាម។

ប៉ុន្តែទោះបីស្ថិតក្នុងស្ថានភាពបែបនេះក្តី យើងទាំងអស់គ្នាយល់ថាវាប្រសើរណាស់ទៅហើយ។

៧ មករា ១៩៧៩ ថ្ងៃរស់ឡើងវិញ

ប្រាំពីរមករាចិតប្រាំបួន រួចខ្លួនពីជ្រោះមរណា
របបយោរយៅខ្មៅឫស្យា ហៅសែនមហាសោកនាដកម្ម។
វាយនឹងត្បូងចបគល់ឫស្សី ក្មេងចាស់ប្រុសស្រីចូរចងចាំ
ខ្មែរស្លាប់រាប់លានជាងបីផ្នាំ រងទារុណកម្មយ៉ាងខ្លោចផ្សា។
គ្មានបាយហុតតែទឹកបបរ ត្រដរប្រឹងរស់ព្រោះអង្គការ
គ្មានសេរីភាពនិងអាហារ ទេវតាលោកអើយ!ជួយខ្ញុំផង។
គុណរណសិរ្សបានសង្គ្រោះ រួចរស់ជីវិតញាតិប្អូនបង
ប្រជាមានសិទ្ធិផុតសៅហ្មង ទុក្ខភ័យកន្លងសូន្យបង់បាត់។
ប្រាំពីរមករាគឺជាថ្ងៃ ដ៏មានតម្លៃពុំអាចកាត់
មានជាតិសាសនាមហាក្សត្រ សូប់ស្ងាត់សន្តិសេរីភាព។

ចប់



១៧

រឿងជីវិតខ្មៅក្នុងរបប ប៉ុល ពត

អ្នកនិពន្ធ ៖ ឈាង សោភ័ណ្ឌា

១៧ ~ រឿង ជីវិតខ្មៅក្នុង របប ប៉ុល ពត

សោភ័ណ្ឌ គឺជាឈ្មោះរបស់ខ្ញុំ។ អ្វីដែលខ្ញុំបានដឹងគឺស្រដៀងទៅនឹងអ្វីដែលប្រជាជនកម្ពុជាបានដឹងដែរ អំពីការគ្រប់គ្រងរបស់ខ្មែរក្រហមនៅទីក្រុងភ្នំពេញ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ប្រជាជនទាំងអស់ ត្រូវខ្មែរក្រហមជម្លៀសចេញពីទីប្រជុំជន ទៅកាន់ទីជនបទ ដើម្បីបង្កបង្កើនផល។ ខ្ញុំត្រូវខ្មែរក្រហមជម្លៀសឲ្យទៅនៅសហករណ៍មួយក្បែរជើងភ្នំឱ៉ាល់ ខេត្តកំពង់ស្ពឺ។ នៅទីនោះមានប្រជាជនទាំងប្រុសទាំងស្រីជាច្រើន បានខិតខំធ្វើការងារនៅក្នុងសហករណ៍ណាស់។ នៅពេលដែលខ្ញុំមកដល់ទីនេះដំបូង ខ្ញុំធ្វើការមិនខ្លាចនឿយហត់នោះទេ ព្រោះខ្ញុំគិតថាវាជាការងារដើម្បីជួយអភិវឌ្ឍន៍ជាតិ។ ថ្ងៃមួយ កម្មាភិបាល បានហៅប្រជាជនទាំងអស់នៅក្នុងសហករណ៍ ទៅប្រជុំអំពីការអប់រំ និងការនិយាយស្តី។ អង្គការបានបង្រៀនថា ពាក្យ សមមិត្តបង គឺសំដៅទៅលើការហៅថ្នាក់ដឹកនាំ ទោះបីជាថ្នាក់ដឹកនាំនោះមានអាយុតិច ឬច្រើនក៏ដោយ ហើយយើងត្រូវហៅមិត្តរួមការងារថា មិត្តប្អូនឬមិត្តបង។ នៅក្នុងរបបខ្មែរក្រហម សមមិត្តបង សុទ្ធតែជាយុវជនដែលមានអាយុប្រហែល១០ឆ្នាំទៅ ១៥ឆ្នាំ ដែលមានកាន់កាំភ្លើង និងទទួលបានការបណ្តុះបណ្តាលមនោគមវិជ្ជា។ ខ្ញុំត្រូវបានអង្គការបញ្ជាឲ្យទៅដាំដំណាំ លីសែង ស្វងស្រូវ ហើយដល់រដូវច្រូតកាត់ គឺខ្ញុំត្រូវទៅច្រូតស្រូវ។ ទោះបីជាខ្ញុំធ្វើការងារធ្ងន់យ៉ាងណា ខ្ញុំមិនដែលបានហូបគ្រប់គ្រាន់ទេ។ របប

អាហារដែលខ្ញុំទទួលបានគឺត្រឹមតែបបរមួយវែក ហើយពេលខ្លះមានអំបិល និងទឹកត្រីលាយជាមួយបន្តិចបន្តួចតែប៉ុណ្ណោះ។ អាហារទាំងអស់នេះ គ្មានជីវជាតិនោះទេ។ យើងមានរូបរាងស្គមស្គាំងសល់តែស្បែកដណ្តប់ឆ្អឹង។

ថ្ងៃមួយនៅក្នុងខែកក្កដា ឆ្នាំ១៩៧៦ ខ្ញុំនិងសមមិត្តក្រុមជាមួយគ្នាបានទៅភ្ជួរស្រែ។ នៅពេលដែលខ្ញុំបានដាក់នង្គ័លចុះ ស្រាប់តែមានសមមិត្តបងម្នាក់ បានមកដល់កន្លែង ហើយនិយាយមកកាន់ខ្ញុំថា «នែ៎! មិត្តឯងបានលួចដំឡូងកាលពីបីថ្ងៃមុន ដោយមិនមានការអនុញ្ញាតពីអង្គការមែនទេ?»។ ខ្ញុំបានឆ្លើយតបយ៉ាងតក់ស្លុតថា «ខ្ញុំមិនបានលួចដំឡូងនោះទេ ខ្ញុំបានរើសដំឡូងដែលមានមើមស្អុយយកមកហូប ព្រោះខ្ញុំឃើញដំឡូងនោះបោះចោល»។ ទោះបីជាខ្ញុំខំនិយាយយ៉ាងណា ក៏សមមិត្តបងមិនយល់ស្របដែរ ហើយថែមទាំងបានបញ្ជាខ្ញុំឲ្យប្រាប់ឈ្មោះអ្នកដែលបានរើសយកដំឡូងនោះមកហូបជាមួយខ្ញុំដែរ។

សមមិត្តបានប្រាប់ឲ្យមិត្តដែលមិនបានហូបដំឡូងនោះមកឈរម្តុំ និងមិត្តដែលបានហូបដំឡូងមកឈរកន្លែងផ្សេងក្បែរនោះ ហើយប្រាប់ថា «អ្នកដែលបានហូបដំឡូងត្រូវទទួលទណ្ឌកម្មឈរនៅក្នុងរន្ធសត្វស្រមោចរយៈពេលមួយម៉ោង និងត្រូវវាយចំនួន៥០ខ្សែតី»។ ខ្លួនប្រាណរបស់ខ្ញុំឈឺចាប់ខ្លាំងណាស់ គ្មានកម្លាំងទប់ទល់ជាមួយនឹងទារុណកម្មបែបនេះបានទេ។ មិនតែប៉ុណ្ណោះ មិត្តៗដែលបានហូបដំឡូង ត្រូវបានសមមិត្តបងប្រាប់ថានឹងយកទៅអប់រំ និងកសាងទាំងអស់គ្នា។ ខ្ញុំឮដូច្នោះហើយមានចិត្តបារម្មណ៍ណាស់ព្រោះ ខ្ញុំដឹងថាប្រជាជនដែលអង្គការបានយកទៅអប់រំនិងកសាងនៅម្តុំអមលាំង មិនដែលឃើញត្រលប់មកវិញឡើយ។

នៅដើមខែធ្នូ ឆ្នាំ១៩៧៧ អង្គការមានផែនការ ឲ្យសមមិត្តទាំងអស់ក្នុងសហករណ៍ ជីកប្រឡាយឲ្យបានបួនគីឡូម៉ែត្រនិងជម្រៅប្រាំម៉ែត្រក្នុងរយៈពេលត្រឹមតែមួយខែ។ ខ្ញុំនិងមិត្តទាំងអស់ បានខិតខំធ្វើការងារយ៉ាងខ្លាំងដើម្បីឲ្យឆាប់រួចទៅតាមបញ្ជារបស់សមមិត្តបង។ មួយខែក្រោយមក ប្រឡាយបានជីករួចរាល់តាមផែនការពិតមែន។ ការជីកប្រឡាយនេះ ធ្វើឲ្យអង្គការពេញចិត្តនឹងយើងជាខ្លាំង។

នៅក្នុងខែមករា ឆ្នាំ១៩៧៨ រដូវរងាបានចូលមកដល់។ អាកាសធាតុបានផ្លាស់ប្តូរទៅជាត្រជាក់ខ្លាំងណាស់។ មិត្តៗទាំងអស់ចាប់ផ្តើមឈឺ និងក្អក។ ថ្នាំដែលអង្គការមានលេបមិនបានជួយឲ្យជាសះស្បើយឡើយ។ ប្រជាជនខ្លះ បានស្លាប់នៅពេលនោះព្រោះស៊ូទ្រាំទៅនឹងជំងឺមិនបាន។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ អង្គការបានរៀបចំឲ្យប្រជាជនមានគូស្រករ។ បុរសរូបរាងស្អាតមានប្រពន្ធមិនស្អាត ហើយនារីដែលមិនស្អាតនឹងបានរៀបការជាមួយប្តីស្អាត។ មិត្តខ្លះចង់ប្រកែកជំទាស់នឹងអង្គការដែលរើសគូស្រករឲ្យ ប៉ុន្តែមិនហ៊ានប្រកែកឡើយ។ ក្រោយពីរៀបការរួច ប្តីនិងប្រពន្ធ រស់នៅជាមួយគ្នាមិនបាន ៣ថ្ងៃផង ត្រូវអង្គការជម្លៀសនារីទាំងអស់ឲ្យទៅនៅឆ្ងាយពីស្វាមី ព្រោះពេលនោះអង្គការត្រូវការកម្លាំង។

ក្នុងខែមិថុនា ឆ្នាំ១៩៧៨ គឺជារដូវវស្សាមានភ្លៀងធ្លាក់ជោគជាំ។ ពេលនោះខ្ញុំបាននាំសមមិត្តផ្សេងៗទៀតទៅភ្ជួរស្រែតាមបទបញ្ជារបស់អង្គការ។ ចៃដន្យថ្ងៃនេះ គោមិនដើរទៅមុខទាល់តែសោះ ហើយខ្ញុំឃើញម៉ោង១២ថ្ងៃត្រង់ ខ្ញុំបានឈប់សម្រាកមួយភ្លែតហូបបបរ រួចក៏ចុះភ្ជួរស្រែទៀត។ គោរបស់ខ្ញុំ ទន់ជង្គង់ឈប់ដើរ ហើយនៅពេលដែលសមមិត្តបងឃើញដូច្នោះ ក៏បានយកកាំភ្លើងមកបាញ់គោទាំងនោះងាប់អស់។ សមមិត្តបង បានបញ្ជាឲ្យមនុស្សភ្ជួរស្រែជំនួសឲ្យសត្វគោវិញម្តង។ ខ្ញុំភ្ជួរបណ្តើរនិយាយខ្សឹបៗសុំទោសមិត្តប្អូនបណ្តើរ។

យប់មួយក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ពេលដែលខ្ញុំអង្គុយម្នាក់ឯងនៅក្រោមជើមសង្កែ ខ្ញុំបានឃើញ មនុស្សមួយក្រុមស្លៀកពាក់សម្លៀកបំពាក់ខ្មៅមានទាំងស្រីទាំងប្រុស។ មនុស្សស្រីតុបតែងខ្លួនជាមនុស្សប្រុសទាំងអស់ ហើយដើរសំដៅមករកខ្ញុំ។ ខ្ញុំមើលស្រមោលព្រាលៗដែលក្នុងចំណោមនោះមាននារីម្នាក់ ខ្ញុំស្គាល់ច្បាស់។ នាងឈ្មោះចន្ធី គឺជាសង្សាចាស់របស់ខ្ញុំ។ មនុស្សប្រុសស្រីទាំងអស់នោះមកបបួលខ្ញុំរត់នៅវេលាម៉ោងបីកន្លះទៀបភ្លឺ។ ឮដូច្នោះ ខ្ញុំបានសម្រេចចិត្តរត់ទៅជាមួយពួកគេ។

រាត្រីនោះ យើងនាំគ្នាដេកនៅទីស្ងាត់ៗក្បែរជើងភ្នំឱ៉ាល់។ ចំណែក ចន្ទី បានយកក្បាលរបស់នាងមកកើយលើជើងរបស់ខ្ញុំ ហើយបានសួរខ្ញុំថា «តើមិត្ត បងស្រលាញ់អូនទេ?» ចន្ទីបានសួរខ្ញុំជាច្រើនសំណួរស្ទើរតែពេញមួយយប់។ ខ្ញុំវិញក៏ដេកមិនលក់ដែរ។ ខ្ញុំនិយាយជាមួយចន្ទីបណ្តើរដូតទឹកភ្នែកឲ្យនាង បណ្តើរ។ ខ្ញុំអាណិតចន្ទីណាស់ ហើយខ្ញុំបានឆ្លើយប្រាប់ចន្ទីវិញថា «ខ្ញុំមិនដែល បំភ្លេចនាងឡើយ ទោះបីជានាងរស់ ឬស្លាប់ក៏ដោយ»។

និយាយចប់សព្វគ្រប់ ម៉ោងប្រហែល៣កន្លះ យើងនាំគ្នារត់ចេញដោយ ស្ងាត់ស្ងៀមពីតំបន់នៅស្រុកឱ៉ាល់ ឆ្ពោះទៅភាគខាងត្បូងនៃខេត្តកំពង់ស្ពឺ។ យើងដើរព្រៃអស់រយៈពេលមួយអាទិត្យ បានជួបបញ្ហាលំបាកជាច្រើនណាស់។ អង្គការ បានដឹងដំណឹងពីកន្លែងដែលយើងធ្លាប់លាក់ខ្លួននៅ ហើយព្យាយាមតាម រកយើង។ ថ្ងៃនោះ សត្វព្រៃជាច្រើនហ្វូង បានផ្អើលស្រែកំពងស្ទើរពេញអាកាស។ ពេលនោះហើយដែលមិត្តរបស់ខ្ញុំឈ្មោះអនិច្ចា សង្ហា និងមិត្តម្នាក់ទៀត បានយក អាសារខ្ញុំ ប៉ុន្តែគួរឲ្យអនិច្ចា មិត្តរបស់ខ្ញុំម្នាក់ រត់ឆ្លងប្រឡាយមិនទាន់ ត្រូវកងកម្លាំង របស់អង្គការបាញ់រះធ្វើឲ្យបាត់បង់ជីវិតភ្លាមៗ។ ខ្ញុំនៅសល់តែគ្នីគ្នាចំនួន៥នាក់ ប៉ុណ្ណោះ បន្តធ្វើដំណើរទៅមុខទៀតជាមួយគ្នា។

អស់រយៈពេលប្រហែលជា៥ខែហើយដែលយើងទាំង៥នាក់ហូបតែស្លឹកឈើ ផឹកទឹកអូរ ទឹកជ្រោះស្ទើរតែរាល់ថ្ងៃ ប្រៀបដូចជីវិតរបស់សត្វរស់នៅក្នុងព្រៃ។ រហូតដល់ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ខ្ញុំ ចន្ទីនិងមិត្តទាំង៣នាក់របស់ខ្ញុំ បានឮសូរ គ្រាប់កាំភ្លើងផ្ទុះឡើង ហើយដឹងថាកំពុងតែមានកងទ័ពវៀតណាមវាយចូលមក រំដោះយើងហើយ។

ចប់

១៨

រឿងអក្សរផ្ចង់ឫសប្បី

អ្នកនិពន្ធ ៖ កែវ ពុទ្ធិន

១៨ ~ រឿង អង្គរផ្លែឫស្សី

ពេលខ្មែរក្រហមចូលមកគ្រប់គ្រងប្រទេសកម្ពុជា ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញទាំងអស់ ត្រូវខ្មែរក្រហមជម្លៀសទៅកាន់ទីជនបទតាមទីតាំងផ្សេងៗគ្នា។ ពេលនោះប្រជាជនមួយក្រុម ត្រូវខ្មែរក្រហម ជម្លៀសចេញទៅភូមិភាគបស្ចិម។ ភូមិភាគបស្ចិម មានព្រំប្រទល់ជាប់នឹងភូមិភាគនិរតី ភូមិភាគបូព៌ ភូមិភាគកណ្តាល និងភូមិភាគពាយព្យ។ ភូមិភាគបស្ចិម បែងចែកជាបួនតំបន់ផ្សេងៗគ្នាគឺ តំបន់១១ ស្ថិតក្នុងខេត្តកោះកុង, តំបន់៣១ ស្ថិតក្នុងខេត្តកំពង់ឆ្នាំង, តំបន់៣២ ស្ថិតក្នុងខេត្តកំពង់ស្ពឺ និងតំបន់៣៧ ស្ថិតក្នុងខេត្តព្រះសីហនុ។ សមមិត្ត ជួន ជេត ហៅ ថាង ស៊ី ឬ ហៅ តាស៊ី គឺជាប្រធានគ្រប់គ្រងក្នុងភូមិភាគបស្ចិម។ តាស៊ី គឺជាមេដឹកនាំសំខាន់មួយរូបនៅក្នុងភូមិភាគនិរតីជាមួយនឹងតាម៉ុក។ គាត់មិនមែនជាមនុស្សកោងកាចឬឃោរឃៅខុសបែបបទនោះទេ។ គាត់គឺជាមនុស្សហ្មត់ចត់ ម៉ឺងម៉ាត់ក្នុងការសម្រេចចិត្តអនុវត្តផែនការរបស់អង្គការ។

ជីវិតនៅក្នុងរបបខ្មែរក្រហមពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជនទាំងចាស់ទាំងក្មេងតែងតែមានវត្តមាននៅតាមការដ្ឋានជានិច្ច។ មនុស្សចាស់ធ្វើការតាមកម្លាំងមនុស្សចាស់ មនុស្សពេញវ័យធ្វើការតាមកម្លាំងមនុស្សធំ រីឯក្មេងៗវិញ ធ្វើការតាមកម្លាំងក្មេងៗ ដែលអង្គការបានបែងចែកឲ្យធ្វើ។ នៅតាមផ្ទះនីមួយៗមានសភាពស្ងាត់សូន្យ ហាក់ដូចជាគ្មានមនុស្សរស់នៅ ហើយយូរៗម្តង សត្វមាន់និងសត្វឆ្កែ រត់ចុះរត់ឡើងហាក់ដូចជាកំពុងតែចាំយាមផ្ទះ។

គ្រួសារយាយសយ គ្រួសារតាប្រុក និងគ្រួសារតាចូច គឺជាក្រុមគ្រួសារដែលអង្គការសង្ស័យថាជាគិញសម្ងាត់របស់សត្រូវ ហើយអង្គការមិនទុកចិត្ត

ក្រុមគ្រួសារទាំងអស់នេះទេ។ អង្គការ បម្រុងនឹងយកក្រុមគ្រួសារទាំងអស់នោះ ទៅសម្លាប់ដែរ ប៉ុន្តែ តាហួត ដែលជាប្រជាជនក្នុងមូលដ្ឋាន បានចេញមុខជានាការពារថា ធ្លាប់ស្គាល់ក្រុមគ្រួសារទាំងនោះពីមុនៗមក។ ហេតុដូច្នោះហើយ ទើបអង្គការសម្រេចចិត្តឲ្យក្រុមគ្រួសារនោះរស់នៅជាបណ្តោះអាសន្នសិន។ ចាប់តាំងពីពេលនោះមក ទាំងបួនគ្រួសារ ស្រលាញ់រាប់អានគ្នាណាស់។

ប្រពន្ធរបស់ តាហួត បានស្លាប់មុនមួយឆ្នាំមុនពេលដែលកងទ័ពវៀតណាមចូលមកដល់។ ប្រពន្ធរបស់តាហួត បានស្លាប់ដោយសារជំងឺ និងបានបន្សល់ទុកនូវកូនចំនួន៤នាក់ មានកូនប្រុសចំនួន ២នាក់ និងកូនស្រីចំនួន ២នាក់ដែរ។

នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ តាហួត បានធ្វើដំណើរជាមួយកូនៗ ដោយដាក់កូនតូចប្រុសពៅនៅក្នុងសង្រែកម្ខាង ហើយសង្រែកម្ខាងទៀតសម្រាប់ដាក់ឆ្នាំង អង្ករនិងប្រហុក។ គាត់រែកសង្រែកនោះដើរតាមប្រជាជនដទៃទៀត យប់ត្រង់កន្លែងណាសម្រាកត្រង់កន្លែងនោះ ហើយពេលមេឃភ្លឺឡើងពួកគាត់ចេះតែធ្វើដំណើរទៅមុខទៀត។ ស្ថានការណ៍ពេលនោះកំពុងតែច្របូកច្របល់ខ្លាំង តាហួត បានព្រាត់បាត់កូនរបស់គាត់ចំនួនបីនាក់ទៀត។ តាហួត ចេះតែស៊ើបសួរកដំណឹងកូនរបស់គាត់ដោយក្តីព្រួយបារម្ភ និងនឹករឭក។ តាហួត ជួបនឹងមនុស្សម្នាក់សួរម្នាក់ ជួបមនុស្សពីរនាក់សួរពីរនាក់ ហើយដល់កន្លែងណាសួរក៏សួរកកន្លែងហ្នឹង។ គាត់ព្យាយាមសួរគេឯងណាស់ ប៉ុន្តែនៅគ្មានដំណឹងពីកូនរបស់គាត់ ។ នៅតាមផ្លូវធ្វើដំណើរ ដៃរបស់តាហួតម្ខាងទប់ដងរែកនៅលើស្មា ហើយដៃម្ខាងទៀតរែកព្រៃដើរ រីឯមាត់របស់គាត់ចេះតែស្រែកសួររកកូនៗរបស់គាត់។ តាហួត និងកូនតូច បានធ្វើដំណើរអស់រយៈពេលពីរសប្តាហ៍ ហើយបានមកដល់ភ្នំព្រៃ។ គាត់ ចេះតែដើរតត្រុកសួរពីដំណឹងកូនរបស់គាត់។ គាត់នឹកនៅក្នុងចិត្តថា «ឱកូនអញអើយ! មិនដឹងស្លាប់ឬរស់យ៉ាងណាទេ? ដាច់ពោះស្លាប់នៅទីណាក៏មិនដឹងដែរ! តើកូនវេទនាយ៉ាងណាទៅ! បើគ្រាន់តែមនុស្សចាស់វេទនាស្ទើរស្លាប់ស្ទើររស់យ៉ាងនេះទៅហើយនោះ»។

ប្រជាជនដែលរត់គេចជាមួយគ្នានៅពេលនោះ ចេះស្រលាញ់រាប់អានគ្នាដូចជាគ្រួសារតែមួយអីចឹង។ អ្នកណាមានអង្ករចេះចែករំលែកដល់អ្នកអត់អង្ករ

ដើម្បីបានបាយហូបដូចៗគ្នា។ ចំណែកម្ហូបវិញគ្មានអ្វីក្រៅពីអំបិលនិងប្រហុកនោះទេ។ ថ្ងៃមួយម៉ោងប្រហែល ៦ល្ងាច មនុស្សមួយក្រុមបានធ្វើដំណើរមកដល់ភ្នំព្រះដែរ។ ទោះបីជាប្រជាជនមកជុំគ្នាយ៉ាងណាក៏ដោយ សំឡេងនិយាយគ្នាអ៊ូអរកម្រមានណាស់។ រំពេចនោះ តាហួត បានឃើញកូនស្រីរបស់គាត់ដែលមានមុខមាត់ប្រឡាក់ស្រមក ស្រងូតស្រងាត់ ទឹកភ្នែករលីងរលោង រូបរាងពិបាកមើលណាស់ កំពុងតែដើរកាន់កន្ទុយព្រែករទេះគោរបស់ប្រជាជនដែលធ្វើដំណើរចូលមក។ តាហួត បានស្រែកហៅកូនទាំងក្នុងចិត្តក្តុកក្តួលថា «ឡៃស៊ីមកូន»។ នៅពេលឮសំឡេងហើយដឹងថាជាសំឡេងរបស់ឪពុក ឡៃស៊ីម ក៏ក្រឡេកភ្នែកសម្លឹងរកសំឡេងនោះភ្លាមរួចស្រែកទ្រហោយំរត់ទៅឱបឪពុក។ តាហួត និងកូនយំដូចគ្នា។ តាហួត ស្រែកសួរកូនស្រីរបស់គាត់ថា «កូនឯង មានឃើញបងៗអត់?» «ខ្ញុំអត់ឃើញទេឪអើយ» ឡៃស៊ីម និយាយរួចហើយក៏យំឱបឪពុកកាន់តែខ្លាំងជាងមុនទៅទៀត។ តាហួត ក្រឡេកឃើញបាតជើងកូនស្រីរបស់គាត់ក្រហមរលាកជាដុំៗដូចរងើកភ្លើង រឹតតែសង្វេគក្នុងចិត្ត។ មិនបង្អង់យូរ តាហួត បានទៅរកបាយទឹកឲ្យកូន និងទៅបោចវល្លិ៍ បកសំបកឈើ និងជីកយកឫសឈើយកមកដាំទឹកត្រាំជើងឲ្យកូន ដើម្បីបន្សាបជាតិពិស និងបំបាត់ការឈឺចុកចាប់។ ឡៃស៊ីមមិនបានស្លាប់តាមផ្លូវដោយសារតែ យាយយ៉ុននិងតាប្រុក ជួយយកអាសា។

ពេលកំពុងសម្រាកជុំគ្នានៅឯភ្នំព្រះ កងទ័ពខ្មែរក្រហមម្នាក់បានឲ្យដំណឹងថា កងទ័ពវៀតណាម បានវាយបែកបន្ទាយអស់ហើយ និងកំពុងតែវាយបន្តមកទៀត។ កងទ័ពខ្មែរក្រហម បានបញ្ជាឲ្យប្រជាជនធ្វើដំណើរទៅមុខទៀតទាំងយប់ ដើម្បីឆាប់បានទៅដល់គោលដៅមុនពេលកងទ័ពវៀតណាមវាយបែកតំបន់ភូមិភាគពិសេស។ មួយសប្តាហ៍ក្រោយមក ខ្មែរក្រហមបានដឹកនាំប្រជាជនទៅដល់ភ្នំពីស ដែលជាកន្លែងជំរំបង្គប់មួយ។ ភ្នំពីស ស្ថិតនៅដាច់ស្រយាលពីភូមិអ្នកស្រុក និងជាតំបន់ព្រៃជ្រៅ ដែលមានព្រៃស្តុកខ្ពស់ក្រាស់ឃ្មឹកកម្រមានមនុស្សទៅដល់ណាស់។ ភ្នំពីស ក៏ជាតំបន់គ្រុនចាញ់ ហើយសម្បូរសត្វព្រៃគ្រប់ប្រភេទទាំងអស់។ វាមានភូមិសាស្ត្រល្អ ថែមទាំងមានកូនភ្នំព័ទ្ធជាព្រំសីមា

មើលទៅដូចជាភ្នំមួយដែលដុះផុសចេញពីជ្រលងជ្រោះ ហើយក៏ជាសមរភូមិពិបាកវាយលុកពីសត្រូវនិងងាយស្រួលការពារ។ ខ្មែរក្រហម បានប្រើប្រាស់ភ្នំពីសជាឃ្លាំងស្តុកអាវុធដ៏ធំមួយ។ ប្រជាជនភាគច្រើនលួចខ្សឹបតៗគ្នាថា នៅភ្នំពីសខ្មែរក្រហម មិនត្រឹមតែលាក់អាវុធនោះទេ ថែមទាំងមានលាក់មាសប្រាក់រាប់តោនផ្សេងទៀត។ កងទ័ពខ្មែរក្រហម យាមល្បាតភ្នំពីសយ៉ាងតឹងរឹងទាំងយប់ទាំងថ្ងៃ។ ជាអកុសល ប្រជាជនស្នាក់នៅជាមួយកងទ័ពខ្មែរក្រហមមិនបានយូរប៉ុន្មានផងភ្នំពីសបានក្លាយជាទីលានសមរភូមិប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។ កងទ័ពវៀតណាម បានវាយសម្រុកខ្លាំងផ្ទួនៗគ្នាតាំងពីព្រឹករហូតទល់ព្រលប់ត្រឹមតែរយៈពេល១០ថ្ងៃ បានធ្វើឲ្យកងទ័ពខ្មែរក្រហមបាក់ទ័ពរត់ចូលទៅក្នុងព្រៃអស់។ ចំណែកឯប្រជាជនវិញ ភិតភ័យស្លន់ស្លោខ្លាចគ្រាប់មីន គ្រាប់កាំភ្លើង បាននាំគ្នារត់ប្រសេចប្រសាចពាសពេញព្រៃ ដឹកដៃកូនពួនសម្ងំតាមផ្នាំងថ្មដើមឈើ តាមល្អាង និងក្នុងជ្រោះ ដើម្បីគេចពីគ្រាប់កាំភ្លើង។ ការប្រយុទ្ធលើកនេះធ្វើឲ្យប្រជាជនរត់កាត់ព្រៃ ជាប់បាយជាប់ទឹកយ៉ាងវេទនាខ្លោចផ្សាកណ្តាលព្រៃ។

រយៈពេល ១យប់ ២ថ្ងៃ អ្នកភូមិត្បែង ប្រញាប់រត់កៀសខ្លួនទៅដល់ស្ទឹងប្រៀច។ នៅទីនោះ តាហោ ដែលជាហ្មដំរីជើងចាស់ម្នាក់ទទួលរៀបចំឲ្យស្នាក់នៅ។ ដំរីរបស់ តាហោ ធំណាស់ ហើយវាស្តាប់បង្គាប់ តាហោ។ តាហោ គ្មានកូនចៅសាច់ញាតិរស់នៅជាមួយទេ គឺមានតែដំរីនេះ ដែលជាសាច់ញាតិរបស់គាត់។ នៅពេលជួប តាហោ ហើយ យើងសង្ឃឹមថានឹងបានសេចក្តីសុខ។ ប្រជាជនម្នាក់ៗពេលហូបបាយទឹករួច ក៏សម្ងំដេក ព្រោះអស់កម្លាំងជាច្រើនថ្ងៃ។ មិនយូរប៉ុន្មានស្នូរគ្រាប់កាំភ្លើងលាន់ឮសូរ ផាំង ផាំង បានបន្លឺឡើង ប្រហែល ៦គ្រាប់ជាប់ៗគ្នា។ តាហោ ក៏ដេកដួលស្លាប់នៅនឹងដី។ រំពេចនោះ សំឡេងរបស់ តាហានស្រែកឡើងថា «គេបាញ់សម្លាប់តាហោ! តាហោស្លាប់ហើយ!»។ ចំណែកឯសត្វដំរីរបស់ តាហោ ដែលចងជាប់នៅក្បែរនោះ ក៏ស្រែករោទ៍ទ្រហឹងស្ទើរតែបែកមេឃ រើបម្រាសចុះឡើងហាក់ដូចជាមានបំណងចង់ទៅជួយម្ចាស់របស់វា។ ជាអកុសល ដំរីនោះ ត្រូវបានបាញ់ជាង១០គ្រាប់ងាប់ភ្លាមៗនៅក្នុងថ្ពក់ឈាមក្បែរ តាហោ ដែរ។

នឹកដល់រឿង តាហោ ប្រជាជនម្នាក់ៗនៅតែហួសចិត្តស្តាយស្រណោះគាត់គ្រប់ៗគ្នា ព្រោះគាត់គឺជាមនុស្សល្អ ស្លូតបូត មិនគួរជួបរឿងអភ័ព្វបែបនេះសោះ។ ៥ថ្ងៃបន្ទាប់ ប្រជាជននាំគ្នារត់ទៅដល់ភ្នំឱល(កន្ទួត) ហើយទៅសុំអង្គរពី តាសាល ដែលជាប្រធានព័ស្តុភារនៅទីនោះ។ តាសាល មិនសូវហ៊ានឲ្យអង្គរយើងច្រើននោះទេ ព្រោះពេលកំពុងប្រយុទ្ធធ្វើសង្គ្រាម កងទ័ពត្រូវការស្បៀងច្រើន ហើយស្បៀងទាំងអស់នោះ ត្រៀមទុកសម្រាប់តែប្រជាជន និងកងទ័ពខ្មែរក្រហមនៅក្នុងតំបន់តែប៉ុណ្ណោះ។

បន្ទាប់ពីសុំអង្គរបានខ្លះរួចមក ប្រជាជននាំគ្នាស្រូតធ្វើដំណើរចូលទៅក្នុងព្រៃបន្តទៀត ព្រោះដឹងថាកងទ័ពវៀតណាមនឹងមកដល់ឆាប់ៗ។ នៅពេលប្រទះឃើញកងទ័ពវៀតណាម ឬកងទ័ពខ្មែរក្រហម ប្រជាជន តែងលាក់ខ្លួនសម្ងំទាល់តែស្ងាត់ទើបចេញបន្តដំណើរទៅមុខទៀត។ តាហួត តាចូច តាប្រុក តាហាន និងតាថែម នាំគ្នាទៅកាប់កូនឈើធ្វើជាបង់បាញ់ ឬខ្នម ចំណែកស្រីៗដើរបេះស្លឹកឈើ និងដេរភ្ជាប់គ្នាធ្វើដូចស្លឹកកណ្តប ដើម្បីប្រក់ដំបូលខ្នម។ ក្នុងមួយគ្រួសារៗ សង់ជាកូនខ្នមមួយ។ បន្ទាប់មក ស្រីៗទៅច្រូតស្បូវយកមកប្រក់ដំបូល និងជញ្ជាំងបន្ថែមទៀត។ ចំណែកឯប្រុសៗវិញ ដើររកម្ហូបអាហារ ដូចជាចាប់ត្រី ចាប់ក្តាម និងរើសខ្យងជាដើម។ កងទ័ពខ្មែរក្រហមខ្លះ ដែលរត់ចោលជួរបានដោះឯកសណ្ឋានបោះចោល ហើយមករួមរស់នៅជាមួយប្រជាជនតាមជើងភ្នំដែរ។ នៅពេលទ័លច្រកអត់មានអង្គរ ប្រជាជនបាននាំគ្នា ដើរបេះផ្លែឫស្សីយកមកដាំបាយឬដាំបបរហូប។ រាល់ថ្ងៃ ប្រជាជនទាំងប្រុសទាំងស្រី ដើរវាយទម្លាក់ផ្លែឫស្សី ហើយក្មេងៗ ជាអ្នកដើររើសដាក់ក្នុងថ្នក់ក្រមានិងបំពង់។ រយៈពេលត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ ផ្លែឫស្សី ដែលធ្លាប់តែចាស់ទុំច្រួងច្រាង រណោងរណោងពេញដើម នៅសល់ត្រឹមតែដើមទទេច្រងែងច្រងាង។ ពេលផ្លែឫស្សីនៅក្បែរៗកន្លែងស្នាក់ទុំលែងទាន់ហូប ប្រជាជនក៏នាំគ្នាទៅរកបេះផ្លែឫស្សីតាមទីឆ្ងាយៗម្តង។ ផ្លែឫស្សីដែលយកមកបាន ត្រូវដាក់ក្នុងថ្នក់ដាយក្រមា ឬក្រណាត់ រួចវាយដំផ្ចប់ទៅនឹងថ្មរហូតទាល់តែរបកសំបកចេញ ទើបយកមកដាក់ចាន ឬ

បាតដៃ ដើម្បីស្ទែយកសំបកវាចេញឲ្យស្អាត។ បន្ទាប់មកយើងយកទៅដាំដូចបាយ ប៉ុន្តែផ្លែឫស្សីមិនរីកដូចបាយនោះទេ ហើយថែមទាំងនៅរឹង និងគ្មានជាតិអ្វីសោះឡើយ។ នៅព្រៃភ្នំសម្បូរបន្លែណាស់ ហើយបន្លែនោះបានជួយប្រជាជនឲ្យរស់ជីវិតបាន។ យូរៗម្តង ប្រជាជន ជាក់អន្ទាក់យកសត្វព្រៃ ដូចជាជ្រូកព្រៃ មាន់ព្រៃ ទន្សាយ និងសត្វឈ្លូសជាដើម មកធ្វើជាម្ហូបអាហារ។ ប្រជាជនរស់នៅក្នុងខ្ទមស្លឹក និងហូបផ្លែឫស្សីជំនួសឲ្យអង្ករអស់រយៈពេលជាង១ឆ្នាំ។ ប្រជាជនមួយក្រុមនេះ បានរស់នៅក្នុងព្រៃយូរពេក ក៏ដាច់ខ្សែរយៈនិងដំណឹងពីអ្នកស្រុកភូមិអស់ ហើយមិនយូរប៉ុន្មានក៏ត្រូវនិរទេសខ្លួនម្តងទៀត។

ថ្ងៃមួយកណ្តាលថ្ងៃត្រង់ កងទ័ពវៀតណាម ដើរគំរាមកំហែងបណ្តេញប្រជាជនដែលរស់នៅតាមជ្រលងភ្នំឲ្យចាកចេញពីខ្ទម។ ប្រជាជនកិតភ័យណាស់ពេលឮកងទ័ពវៀតណាមនិយាយភាសាវៀតណាម ហើយប្រជាជនស្តាប់មិនបានសោះ។ ប្រជាជនខ្លាចកងទ័ពវៀតណាម មិនហ៊ានរត់គេចទៀតទេ ហើយក៏នាំគ្នាប្រមូលផ្តុំ។ ចំណែកកងទ័ពវៀតណាម ដែលមានគ្នីគ្នារាប់រយនាក់ បំពាក់ដោយអាវុធជាប់នៅនឹងខ្លួន ដើររុះរើខ្ទមរបស់ប្រជាជនអស់ខ្ចេចខ្ចីអស់គ្មានសល់។ កងទ័ពវៀតណាម បានដើរពិនិត្យមើលគ្រប់ទីកន្លែងព្រោះកងទ័ពវៀតណាមសង្ស័យថាប្រជាជនមានលួចលាក់របស់របរ និងអាវុធជាដើម។ បន្ទាប់ពីពិនិត្យរួចរាល់ហើយ កងទ័ពវៀតណាម បានធ្វើជាសញ្ញា និងនិយាយភាសាខ្មែរមិនសូវច្បាស់ ឲ្យប្រជាជនខ្មែរវិលត្រលប់ទៅកាន់ស្រុកកំណើតវិញ។ នៅពេលនោះ ប្រសិនបើមានប្រជាជនណាម្នាក់មិនព្រមស្តាប់បញ្ជារបស់កងទ័ពវៀតណាម ដោយហ៊ានរត់គេចចេញផ្តេសផ្តាសនោះ កងទ័ពវៀតណាមនឹងបាញ់សម្លាប់នៅកន្លែងភ្លាមៗតែម្តង។

បន្ទាប់មក ប្រជាជននាំកូនចៅដើរទៅមុខតាមបញ្ជារបស់កងទ័ពវៀតណាម ដោយកិតភ័យ ព្រោះកងទ័ពវៀតណាម មានស្តាយកាំភ្លើងដើរជាប់ពីក្រោយពីមុខ និងឆ្វេងស្តាំជានិច្ច។ នៅតាមផ្លូវ ប្រជាជនឃើញតែកងទ័ពវៀតណាម យកកាំបិតចាក់ទម្លុះបង្វិចប្រជាជនរហូតមក។ ប្រជាជនម្នាក់ៗបានត្រឹមតែលាក់ទុក្ខព្រួយ

មិនហ៊ាននិយាយស្តីអ្វីបន្តិចណាសោះឡើយ។ កងទ័ពវៀតណាម បានដើរកៀងប្រជាជន រហូតមកដល់អមលាំង។ ត្រលប់មកដល់ទឹកដីអមលាំង ប្រជាជនមានអារម្មណ៍ធូរស្បើយជាងពេលចេញមកពីភ្នំ ហើយមានក្តីសង្ឃឹមសារជាថ្មីឡើងវិញ។ ប្រជាជនជាច្រើន បានចេញមកជួបជុំគ្នានៅក្រោមម្លប់ឈើដ៏ធំស្តឹមស្តែក្បែរមាត់ស្ទឹង។ កងទ័ពម្នាក់បានចាប់ផ្តើមឃោសនាថា «បងប្អូន! បងប្អូនយើងមានសេរីភាពវិញហើយ! ពួកយើងគឺជាកងទ័ពរំដោះ ឥឡូវនេះយើងទទួលបានជោគជ័យទាំងស្រុងលើរបបខ្មែរក្រហម ដែលបានជិះជាន់បងប្អូនគ្មានត្រាប្រណីអស់រាប់ឆ្នាំមកហើយ កងទ័ពវៀតណាម បានមកជួយរំដោះ ជួយសង្គ្រោះជីវិតរបស់យើងឲ្យរួចផុតចេញពីរបបខ្មែរក្រហម សូមបងប្អូនរៀលត្រលប់ទៅផ្ទះសម្បែងជួបជុំសាច់ញាតិវិញចុះ»។

មកដល់ពេលនេះទើបប្រជាជនទាំងអស់ដឹងថា កងទ័ពទាំងអស់នេះសុទ្ធតែជាកងទ័ពរំដោះប្រជាជនខ្មែរពីរបបខ្មែរក្រហម។ ក្នុងចំណោមកងទ័ពរំដោះជាតិប្រជាជនកម្ពុជាទាំងនោះ ក៏មានវត្តមានកូនប្រុសច្បងរបស់ តាហួត ដែលមានឈ្មោះថា ក្តី ដែរ។ តាហួត នៅពេលបានឃើញកូនប្រុសពិតជារំភើបគ្មានអ្វីប្រៀបបានឡើយ។ គាត់និងកូនបែកគ្នារាប់ឆ្នាំដោយគ្មានសង្ឃឹមថាកូនរបស់គាត់នៅមានជីវិតរស់ដូច្នេះទេ។ ក្រោយបំបែកអង្គប្រជុំ ប្រជាជន បានដើរហែតាមផ្លូវឆ្ពោះសំដៅទៅរកផ្ទះរបស់ខ្លួនរៀងៗខ្លួនវិញ។

ពេលមកដល់ផ្ទះ ប្រជាជនមួយចំនួនធំសង្ឃាតដើរចាប់គោ ក្របី ដែលដើរពាសវាលពាសកាលគ្មានម្ចាស់ យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ប្រជាជនក៏នាំគ្នាទៅរកអាហារនៅតាមមន្ទីរព័ស្តុការ ប៉ុន្តែត្រូវកងទ័ពវៀតណាម ជាក់របងរនាំងយាមយ៉ាងតឹងរឹងបំផុតមិនឲ្យនរណាម្នាក់ចេញចូលនោះទេ។ ថ្ងៃក្រោយមក គោ ក្របី ដែលប្រជាជនខិតខំដើរស្នាក់ចាប់នោះ ត្រូវកងទ័ពសង្គ្រោះជាតិបញ្ជាឲ្យយកទៅជាក់ជារបស់រួមវិញទាំងអស់។ ក្រោយមក រដ្ឋការ ចាប់ផ្តើមចែកជូនដល់ប្រជាជនវិញ រួមមាន គោឈ្មោល២ក្បាល គោមេ១ក្បាល ដីស្រែ ដីផ្ទះ និងអង្ករ សម្រាប់គ្រួសារនីមួយៗ។ សកម្មភាពទាំងអស់នេះ បានរំសាយចិត្តប្រជាជន

ឲ្យសប្បាយរីករាយឡើងវិញ។ គ្រួសាររបស់ តាហួត ក៏បានជួបជុំគ្នាដែរ។ កូនស្រីរបស់តាហួតឈ្មោះ អេន បានវិលត្រលប់មកដល់ផ្ទះវិញដោយសុវត្ថិភាព។

ក្រោយពីចែកដី ចែកផ្ទះ ចែកគោ ក្របី ឲ្យប្រជាជនរួចរាល់ហើយ ក្សត្រឡាន ដំរីទឹកបានដឹករបស់របរពេញៗ ចេញពីមន្ទីរតូចធំ ដោយចងតង់គ្របឡានយ៉ាងជិតៗ បើកបរដោយកងទ័ពសំដៅទៅទិសបូព៌ា។ ចាប់តាំងពីថ្ងៃនោះមក កងទ័ពវៀតណាមក៏ឈប់យាមនៅតាមមន្ទីរទាំងនោះទៀតដែរ។ ចំណែកប្រជាជន នាំគ្នាចាប់ផ្តើមជីវិតថ្មី រស់នៅប្រកបមុខរបរធ្វើស្រែ ចិញ្ចឹមសត្វតាមក្រុមគ្រួសាររៀងៗខ្លួនមក។

ចប់

១៩

រឿងរស្មីពន្លឺក្រោមដំបូលមេឃនៃភពដីត

អ្នកនិពន្ធ ៖ តែ ហោចលី

១៩ ~ រឿង រស្មីពន្លឺក្រោមដំបូល មេឃនៃភពចិត

ស្រមោលអន្ធការខ្មៅងងឹតលើដែនដីសុវណ្ណភូមិក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) បង្កើតបានជាអនុស្សាវរីយ៍ ដែលបំភ្លេចមិនបានគ្រប់ជំនាន់ ដោយសារតែភាពខ្លោចផ្សា ការឈឺចាប់ និងការព្រាត់ប្រាស់។ រយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ បានក្លាយជាការចងចាំមិនភ្លេចរបស់ប្រជាជនខ្មែរគ្រប់រូប ជាពិសេសអ្នកដែលមានកំព្វសំណាងបានរស់ជីវិតរហូតដល់សព្វថ្ងៃ។

បទពិសោធន៍របស់ កុក លៀង

ខ្ញុំឈ្មោះ កុក លៀង រស់នៅក្នុងទីក្រុងភ្នំពេញ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុ ២៣ឆ្នាំ និងមានបងប្អូនចំនួន ៩នាក់ ហើយខ្ញុំជាកូនពៅក្នុងគ្រួសារចិនក្រីក្រមួយ។ នៅសម័យខ្មែរក្រហម ខ្ញុំ ត្រូវខ្មែរក្រហម បង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ ឆ្ពោះទៅកាន់ស្រុកកោះធំ ខេត្តកណ្តាល។ ឪពុករបស់ខ្ញុំ បានស្លាប់ដោយសារអត់អាហារ។ គ្រានោះមានទឹកជំនន់ហូរជន់ខ្លាំង ខ្មែរក្រហមបានជម្លៀសខ្ញុំ និងក្រុមគ្រួសារ ទៅកាន់ខេត្តព្រះវិហារវិញ ដោយធ្វើដំណើរថ្មើរជើងអស់រយៈពេលប្រហែល១ខែ។ ទោះបីជាតាមផ្លូវពោរពេញដោយសាកសពដេកស្លាប់ពេញផ្លូវយ៉ាងណា ខ្ញុំនៅតែគិតថា បើមិនស៊ូប្រាកដជាស្លាប់ដូចសាកសពទាំងអស់នោះ។

នៅពេលទៅដល់ខេត្តព្រះវិហារ ខ្ញុំ និងបងប្អូនរបស់ខ្ញុំ បានចាប់ផ្តើមបែកបាក់គ្នា។ ខ្ញុំ រស់នៅជាមួយម្តាយនៅភូមិផ្ទារ ស្រុកជ័យសែន ខេត្តព្រះវិហារ ជិតព្រំដែន

ឡាវជាមួយនឹងជនជាតិភាគតិចក្តួយ។ ជីវិតរបស់ប្រជាជនគ្រប់ៗគ្នាមិនដូចគ្នានោះទេ។ ខ្ញុំមានជីវិតខុសពីប្រជាជនផ្សេងទៀតនៅលើទឹកដីខេត្តព្រះវិហារ។ ខ្ញុំមិនចាំបាច់ក្រោកតាំងពីម៉ោង៣ទៀបភ្លឺ ដើម្បីចូលជួរធ្វើការដូចប្រជាជនផ្សេងទេ។ នៅតំបន់ដែលខ្ញុំរស់នោះ មានអាកាសធាតុត្រជាក់ណាស់ ដូច្នេះទាល់តែមេឃភ្លឺ ទើបបានអង្គការហៅងើបឲ្យចូលជួរទៅធ្វើការ។ ការងាររបស់ខ្ញុំគឺលើកទំនប់ និងជីកប្រឡាយ រហូតដល់ម៉ោង ១១ថ្ងៃត្រង់ ទើបអាចឈប់សម្រាកហូបបាយបាន ហើយម៉ោង ១រសៀល ខ្ញុំត្រូវបន្តធ្វើការទៀតរហូតដល់ព្រលប់ទើបអាចត្រលប់ទៅផ្ទះវិញបាន។

នៅពេលសម្រាកពីការងារ ខ្ញុំ អាចធ្វើការកាប់ឆ្អារព្រៃ ដាំបន្លែ បានផលយកមកហូបខ្លួនឯងបាន។ មួយវិញទៀត នៅពេលខ្ញុំរកត្រីបាន ខ្ញុំចែកឲ្យទៅសហការណ៍ពាក់កណ្តាល ទុកហូបខ្លួនឯងពាក់កណ្តាល ហើយនៅពេលឈ្លបចូលមកទាន់ ខ្ញុំបានប្រាប់គេថា «ខ្ញុំរកត្រីជាក់សហការណ៍រួចហើយ នេះគ្រាន់តែជាត្រីតិចតួច ដែលនៅសល់ ទើបបានអាំងហូបខ្លួនឯង»។ ឈ្លបក៏មិនប្រកាន់ទោសអ្វីដែរ ព្រោះខ្ញុំបានជួយដល់សហការណ៍ច្រើន។

និយាយដល់ជនជាតិក្តួយ ពួកគេមិនចេះប្រើសន្ទូចចាប់ត្រីនោះទេ។ អីចឹងនៅពេលចាប់ត្រី ពួកគេប្រើវល្លិ៍ព្រៃបំពុលត្រីសិន។ វាពិបាកណាស់ និងពួកគេរកបានតិចតួច។ ខ្ញុំចេះប្រើសន្ទូចស្ទូចបានត្រីច្រើនយកចូលសហការណ៍រាល់ថ្ងៃ ទើបអ្នកនៅទីនោះស្រលាញ់ចូលចិត្តខ្ញុំទាំងមេកងនិងប្រជាជន។ សម្រាប់ការហូបចុក ខ្ញុំមិនខ្វះហូបដូចគេទេ។ ខ្ញុំហូបបាយ មានម្ហូបត្រឹមត្រូវ ដោយសារស្រុកនោះសម្បូរ។

ម្តាយរបស់ខ្ញុំឈ្មោះ លឹម ជូរ។ កាលហ្នឹងគាត់មានអាយុប្រហែល ៦៦ឆ្នាំ។ ម្តាយរបស់ខ្ញុំធ្វើការនៅក្រុមមនុស្សចាស់។ គាត់ធ្លាប់ប្រកបរបរជាជាងដេរខោអាវ។ ភាគច្រើនជាជនជាតិក្តួយ មិនដែលចេះវិជ្ជាដេរខោអាវស្លៀកពាក់នោះទេ។ ម្តាយរបស់ខ្ញុំបង្រៀនពួកគេ ដូចនេះអ្នកនៅទីនោះស្រលាញ់រាប់អានគាត់ណាស់។ នៅតំបន់ដែលខ្ញុំរស់នៅមិនខ្វះខាតសម្លៀកបំពាក់អ្វីទេ ហើយយើងក៏មិនចាំបាច់ស្លៀកពាក់សម្លៀកបំពាក់ពណ៌ខ្មៅដែរ។ ខ្ញុំមិនសូវជួបការលំបាកទេ ទោះបីជាខ្ញុំជាប្រជាជនថ្មីក៏ដោយ។

នៅខេត្តព្រះវិហារជាខេត្តដែលខ្មែរក្រហមមិនសូវយកចិត្តទុកដាក់ឬសង្ស័យអ្វីទេ ទើបយើងមានអាហារហូបចុក រស់នៅស្រួល និងមានសេរីភាពជាងមនុស្សទូទៅ។ យើងអាចសង់ផ្ទះ ដាំដំណាំ និងរកម្ហូបដោយខ្លួនឯងបាន ដោយគ្មានទោសក្បត់អង្គការឡើយ ព្រោះខេត្តព្រះវិហារ គឺជាតំបន់ចាញ់។ អ្នកធ្វើដំណើរមកជាមួយក្រុមគ្រួសាររបស់ខ្ញុំប្រហែល ២០០គ្រួសារ ឈឺគ្រុនចាញ់ស្លាប់អស់ស្ទើរគ្មានសល់។

ជារៀងរាល់ព្រឹក មានកម្មាភិបាលខ្មែរក្រហម តែងតែសែងសាកសពដែលស្លាប់ដោយសារកើតជំងឺគ្រុនចាញ់ជាក់ពេញៗរទេះយកទៅកប់។ ពួកកម្មាភិបាលខ្មែរក្រហមនៅតំបន់នោះ មិនសូវបង្កគ្រោះអាហារ ឬធ្វើទណ្ឌកម្មធ្ងន់ធ្ងរទៅលើប្រជាជនទេ ពីព្រោះអ្នកដែលចូលមកដល់ទឹកដីនោះ ប្រាកដជាឈឺចាញ់ស្លាប់ដោយខ្លួនឯង។

ខ្ញុំចាំមិនភ្លេចឡើយពេលដែលខ្ញុំរៀបចំធ្វើដំណើរចាកចេញពីខេត្តព្រះវិហារមកស្រុកកំណើតវិញបន្ទាប់ពីខ្មែរក្រហមដួលរលំ។ ប្រជាជននៅទីនោះ បានឃាត់ខ្ញុំឲ្យរស់នៅទីនោះមួយរយៈទៀត រង់ចាំឲ្យស្រួលបួលសិនចាំចេញទៅ។ ប៉ុន្តែខ្ញុំនិងក្រុមគ្រួសារមិនព្រម ដូច្នោះពួកគេ បានរៀបចំមានគោ មានស្រូវ មាន់ទាព្រមទាំងជើរអមហូរហែជូនដំណើរខ្ញុំរហូតដល់ឡើងឡានចាកចេញផុតទៅ។ ពេលទៅដល់ខេត្តកំពង់ធំ ខ្ញុំក៏ឡើងឡានជិះតរហូតដល់ទីក្រុងភ្នំពេញ។ ត្រឹមតែបីថ្ងៃប៉ុណ្ណោះ ខ្ញុំបានមកដល់ស្រុកកំណើតវិញ ហើយយករបស់របរដែលអ្នកភូមិឲ្យធ្វើជាដើមទុនរកស៊ីចិញ្ចឹមជីវិត។

បទពិសោធន៍របស់ លឹម សៀកជន

ខ្ញុំឈ្មោះ លឹម សៀកជន ជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលធ្លាប់រស់នៅក្នុងភូមិអូរ ហៅភូមិចិនយំ ស្ថិតនៅក្នុងខេត្តពោធិ៍សាត់។ នៅក្នុងភូមិនោះមានសុទ្ធតែជនជាតិចិននិងយួន។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុទើបតែ ១៤ឆ្នាំ។ អង្គការបានចាត់តាំងឲ្យខ្ញុំចូលក្នុងកងកុមារស្រូច។ ពេលទៅដល់ជំរំភ្លាម អង្គការបានជជីកសួរជីវប្រវត្តិរបស់ខ្ញុំ។ ខ្ញុំបានលាក់បាំងពីសាវតារគ្រួសាររបស់ខ្ញុំ មិនអាចឲ្យនរណាដឹងបានទេ ខ្លាចខ្មែរក្រហមសម្លាប់ផ្តាច់ពូជ ព្រោះបងប្រុសរបស់ខ្ញុំគឺជាគ្រូបង្រៀន និងបងម្នាក់ទៀតជាអតីតទាហាន លន់ នល់ ក្នុងខេត្តពោធិ៍សាត់។

ខ្មែរក្រហម បានឲ្យខ្ញុំធ្វើការនឿយហត់គ្មានកម្លាំងជារៀងរាល់ថ្ងៃមិនដែលបានឈប់សម្រាកឡើយ តែខ្ញុំនៅតែតស៊ូមិនព្រមចុះចាញ់ទេ។ នៅឆ្នាំមួយក្នុងឆ្នាំ១៩៧៨ ខ្ញុំត្រូវបានអង្គការចាត់ឲ្យទៅសម្រាកនៅជំរំក្មេងវ័យជំទង់។ ពេលនោះ មេកងបានហៅឈ្មោះអ្នកនៅក្នុងជំរំ ដោយប្រាប់ថា យកក្រុមវ័យជំទង់ទៅដាំដំឡូង និងឆ្ការចំការពោតជាដើម ប៉ុន្តែគោលបំណងរបស់ខ្មែរក្រហមគឺយកទៅសម្លាប់ចោល។ ខ្ញុំមានសំណាងណាស់ព្រោះខ្ញុំគ្មានឈ្មោះទៅនឹងគេ។

ប៉ុន្មានខែក្រោយមក សង្គ្រាម បានកើតឡើងនៅស្ទើរគ្រប់តំបន់ក្នុងប្រទេសកម្ពុជា។ ខ្ញុំបានទៅជួបជុំជាមួយបងប្អូនស្រីរបស់ខ្ញុំនៅក្នុងខួមមួយ។ នៅយប់នោះ មានកងឈ្លបបម្រុងចូលចាប់បងប្អូនរបស់យើងទាំងបីនាក់យកទៅសម្លាប់ ប៉ុន្តែសំណាងល្អ គ្រានោះខ្ញុំបានដឹងខ្លួនមុន ហើយធ្វើជាដេកលក់។ កងឈ្លបម្នាក់ក្នុងចំណោមកងឈ្លបទាំង៣នាក់ បានឃាត់មិនឲ្យយកយើងទៅសម្លាប់ទេ ព្រោះគាត់មានចិត្តអាណិតឃើញយើងជាក្មេងកំព្រា។

បទពិសោធន៍របស់ កែវ សំណាងកវី

ខ្ញុំឈ្មោះ កែវ សំណានកវី មានអាយុ១១ឆ្នាំ ក្នុងរបបខ្មែរក្រហម។ ខ្ញុំរស់នៅទីក្រុងភ្នំពេញ ហើយត្រូវខ្មែរក្រហមជម្លៀសទាំងក្រុមគ្រួសារចេញពីភ្នំពេញទៅកាន់ខេត្តព្រៃវែង។ យើងធ្វើដំណើរដោយថ្មើរជើងក្នុងស្ថានភាពជ្រួលច្របល់ណាស់។ មនុស្សម្នាជាច្រើនធ្វើដំណើរតាមផ្លូវងងឹតទ្រុប ឃើញដូច្នោះម្តាយរបស់ខ្ញុំ បានយកខ្សែមកចងជើងចងដៃបងប្អូនទាំង៥នាក់របស់ខ្ញុំជាប់ៗគ្នា ព្រោះខ្លាចវង្វេងគ្នាតាមផ្លូវ។

នៅពេលខ្ញុំទៅដល់ស្រុកពាមជ្រៃ ខេត្តព្រៃវែង ខ្ញុំត្រូវបានអង្គការយកទៅដាក់ក្នុងកងកុមារតូចៗដែលមានយាយៗនៅចាំមើលថែរក្សា។ អង្គការប្រើខ្ញុំឲ្យដើររើសអាចម៍គោ និងកាត់ទន្ទ្រានខែត្រយកមកធ្វើជីជាមួយក្មេងដទៃទៀត។ នៅពេលធ្វើការងារចប់ ខ្ញុំបានឆ្លៀតដើររើសខ្ចៅខ្ចងនិងក្តាមតាមវាលស្រែបានយ៉ាងច្រើនយកមកហូប។ ឃាយដែលនៅមើលថែខ្ញុំ មិនសូវជាកាចនោះទេ ទើបខ្ញុំ និងក្មេងៗដទៃទៀត អាចចេញដើរលេងបានតាមចិត្ត។

លុះឆ្នាំ១៩៧៨ ខ្ញុំបានចូលកងកុមារស្រួច មានតួនាទីជាអ្នកឃ្វាលក្របី។ ខ្ញុំពិបាកណាស់ពេលទៅឃ្វាលក្របី ព្រោះខ្ញុំជាក្មេងរស់នៅទីក្រុងមិនដែលឃ្វាលគោ ក្របីនោះទេ ហើយណាមួយទៀត សត្វក្របី មានមាឌធំខ្ពស់ មានកម្លាំងខ្លាំង អូសខ្ញុំម្តងៗចង់ផ្តាប់មុខលើដី។ ខ្ញុំត្រូវទៅឃ្វាលក្របី ឆ្ងាយពីភូមិប្រហែល៥គីឡូម៉ែត្រ វាពិតជាពិបាកណាស់។ ពេលបានត្រលប់មកដល់ខ្នមមួយថ្ងៃ ដូចបានរួចជីវិតមួយថ្ងៃដែរ។

បទពិសោធន៍របស់ ព្រំ ស៊ីសាផាឡា

ខ្ញុំគឺជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំជាអតីតសិល្បៈករនៃរបាំបាឡេបែបមជ្ឈិមប្រទេស។ ពេលខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ខ្មែរក្រហមបានឲ្យខ្ញុំរស់នៅជាមួយក្រុមគ្រួសារអ្នកភូមិ។ ខ្មែរក្រហម បែងចែកឲ្យប្រជាជនរស់នៅតាមអ្នកថ្មី និងអ្នកមូលដ្ឋាន។ នៅពេលនោះ យើងនៅហូបចុកដោយឡែកពីគ្នានៅឡើយ។ ពេលយូរបន្តិចទៅ អង្គការបើកអង្ករឲ្យមួយថ្ងៃមួយកំប៉ុង។ ក្នុងរយៈពេលប្រហែល ៩ខែកន្លងទៅ អង្គការ បានដកប្រជាជនមួយចំនួនដើម្បីយកទៅរស់នៅកន្លែងផ្សេងទៀត ព្រោះចំនួនប្រជាជនក្នុងភូមិមានច្រើនជាងចំនួនប្រជាជនដែលខ្មែរក្រហមត្រូវការ។ គ្រួសាររបស់ខ្ញុំ ក៏ស្ម័គ្រចិត្តចេញពីភូមិនោះ។ ខ្មែរក្រហមបានដឹកពួកយើងតាមឡាន ហើយឲ្យយើងជិះរថភ្លើងបន្តដំណើរទៅមុខទៀត។ ទៅដល់ស្ថានីយរថភ្លើងមួយ ខ្មែរក្រហមទម្លាក់ប្រជាជនម្តងដប់ទៅដប់ប្រាំគ្រួសារ ហើយក្រុមគ្រួសាររបស់ខ្ញុំ ត្រូវខ្មែរក្រហមឲ្យឈប់នៅខេត្តបាត់ដំបង។

នៅពេលទៅដល់ខេត្តបាត់ដំបងភ្លាម ក្រុមគ្រួសាររបស់ខ្ញុំ អស់ស្បៀងរលីង។ នៅទីនោះសូម្បីផ្ទះអ្នកភូមិមួយក៏យើងអត់ឃើញដែរ។ ខ្ញុំឃើញមានតែរោងមួយដែលប្រចាំការសម្រាប់បើកអង្ករឲ្យប្រជាជនតែប៉ុណ្ណោះ។ ខ្ញុំរស់នៅក្នុងភូមិនោះជាមួយជនជាតិភាគតិច ។ ពួកគេមិនដែលស្គាល់ផ្សារ ឬទីក្រុងនោះទេ។ ពួកគេនៅតែក្នុងព្រៃ ចិញ្ចឹមជីវិតដោយការដាក់អន្ទាក់សត្វ និងដាំស្រូវបន្តិចបន្តួចតែប៉ុណ្ណោះ។

ខ្ញុំគ្មានអ្វីជាប់ខ្លួនទេពេលទៅដល់ទីនោះ។ ខ្ញុំទទួលបានអាហារមិនខុសពីតំបន់ផ្សេងដែរ។ ពេលខ្លះមានបបរខាប់ ពេលខ្លះបបររាវ បើដល់ខែច្រូតកាត់ទើបបានបាយមួយវែក។ ខ្ញុំធ្លាប់បានទទួលអាហារឆ្ងាញ់ម្តងគឺក្នុងអំឡុងពេលចូលឆ្នាំខ្មែរ។ ពេលនោះ ចុងភៅ បានកាប់ត្រយ៉ូងចេកហាន់ជាកង់ៗ ហើយកាប់សាច់ជ្រូកជាក់ស្ងោរ មានខ្លាញ់ជ្រូកដុំធំៗអណ្តែតគ្រៀបគ្រាលើឆ្នាំងសម្ល។ នេះជារសជាតិសម្លតែមួយគត់ដែលឆ្ងាញ់បំផុតនៅក្នុងរបបខ្មែរក្រហម។

បទពិសោធន៍របស់ អ៊ុន ឥណ្ណា

កាលនោះ ខ្ញុំទើបតែមានអាយុ១១ឆ្នាំ នៅក្នុងថ្ងៃដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។ កងទ័ពខ្មែរក្រហម បានបណ្តេញខ្ញុំនិងក្រុមគ្រួសារចេញពីទីក្រុងភ្នំពេញ ហើយយើងបានធ្វើដំណើរទៅដល់ព្រៃកញ្ជៅ។ នៅពេលនោះ ខ្មែរក្រហម បានដុតផ្ទះគ្រប់ខ្នងឆេះរាបដល់ដីហុយផ្សែងអ័ព្ទពាសពេញផ្ទៃមេឃ។ បន្ទាប់មក កងទ័ពខ្មែរក្រហម បណ្តេញគ្រួសាររបស់ខ្ញុំ ឲ្យចូលទៅព្រៃជ្រៅ ហើយបញ្ជាឲ្យពួកយើងកាប់ឆ្ការបង្កបង្កើនផលនៅភូមិជ្រៃ មួយរយៈពេល។

លុះដល់ឆ្នាំ១៩៧៦ អង្គការ បានបញ្ជូនគ្រួសាររបស់ខ្ញុំបន្តទៅកាន់ខេត្តពោធិ៍សាត់ទៀត ដោយឲ្យយើងធ្វើដំណើរថ្មើរជើងអស់រយៈពេលជាង១ខែ ទើបមកដល់ទីរួមខេត្ត ហើយយើងក៏ធ្វើដំណើរបន្តទៅកាន់ស្រុកអូររំចេក។ អង្គការ បានចាត់ឲ្យខ្ញុំធ្វើការបង្កបង្កើនផលនៅតាមកងកុមារ ធ្វើការងារដូចជា ដើររើសអាចម៍គោ កាត់ទន្ទ្រានខែត្រ ធ្វើដី និងឃ្វាលគោក្របី ដោយមានយាយៗចំនួន ៣នាក់ចាំយាមពួកយើង។ ក្នុងរយៈពេលមួយឆ្នាំនៅទីនោះ ទាំងការរស់នៅនិងការហូបចុករបស់ខ្ញុំ មានលក្ខណៈធម្មតា។ ខ្មែរក្រហមមិនសូវធ្វើទុក្ខបុកម្នេញបង្អត់អាហារដល់កុមារទេ។

នៅឆ្នាំ១៩៧៨ ខ្ញុំនិងក្រុមគ្រួសារ បានផ្លាស់មកនៅភូមិមួយទៀតក្នុងខេត្តពោធិ៍សាត់ដដែល។ ខ្ញុំមានអារម្មណ៍សង្វេគណាស់ពេលទៅដល់នោះ។ នៅក្នុងភូមិ មានផ្ទះតែអត់មនុស្សនៅ មានផ្លូវតែអត់មនុស្សដើរ។ ផ្ទះទាំងល្វែងមើលទៅជាច់កន្ទុយភ្នែក តែគ្មានមនុស្សរស់នៅទេ។ ប្រជាជនថ្មី ដែលជម្លៀសមកទីនេះ បានស្លាប់ស្ទើរតែទាំងអស់ ដោយសារធ្វើការងារហួសកម្លាំង និងគ្មានអាហារហូបចុកគ្រប់គ្រាន់។

នៅទីនោះ ខ្ញុំត្រូវបានអង្គការចាត់ឲ្យទៅជីកប្រឡាយជាមួយនឹងប្រជាជនផ្សេងទៀត ប្រវែង១០ម៉ែត្រឲ្យរួចក្នុងរយៈពេល១ខែ។ ម្នាក់ៗខិតខំធ្វើការទាំងថ្ងៃទាំងយប់ ថ្ងៃខ្លះយើងជីកប្រឡាយរហូតដល់ម៉ោង១០យប់ក៏មានដែរ ព្រោះយើងខ្លាចធ្វើការមិនទាន់ឲ្យអង្គការ ហើយត្រូវទទួលរងទារុណកម្ម។ ចំណែកឯការហូបចុកវិញ អង្គការបានបែងចែកតាមកងជាក្រុមតូចៗមានគ្នា៥នាក់ ហើយបាយនោះចែកជាពំនូក។ ពេលខ្លះយើងបានបាយហូបជាមួយអំបិល ពេលខ្លះក៏អត់ យើងហូបមិនសូវឆ្អែតទេ។ ពេលទំនេរចន្លោះម៉ោងសម្រាកពីការងារ ខ្ញុំតែងលួចចេញទៅខ្វេះក្តាម ខ្ចៅខ្យង ចាប់កង្កែប និងកូនក្អាត់ មកហូបបន្ថែម។ ពេលខ្លះ ខ្ញុំបានលួចទៅស្ទូចត្រី មកអាំងហូបបន្ថែមដើម្បីបំពេញកម្លាំង។

បទពិសោធន៍របស់ ផេង

នៅក្នុងរបបខ្មែរក្រហម ការរស់នៅរបស់ខ្ញុំមិនសូវជួបការលំបាកប៉ុន្មានទេ។ កាលនោះ ខ្ញុំមានអាយុ១០ឆ្នាំ។ ខ្ញុំនិងក្រុមគ្រួសារ ត្រូវខ្មែរក្រហមជម្លៀសចេញពីភ្នំពេញទៅខេត្តក្រចេះ។ យើងដើរដោយថ្មើរជើងអស់រយៈពេលច្រើនខែទើបបានដល់ខេត្តក្រចេះ។ នៅទីនោះ ឪពុករបស់ខ្ញុំឈ្មោះ ហ៊ុយ ដែលជាជនជាតិចិន ត្រូវអង្គការចាត់ឲ្យនៅធ្វើការក្នុងក្រុមមនុស្សចាស់ជាមួយម្តាយរបស់ខ្ញុំ ដើម្បីធ្វើកន្ទេលនិងកញ្ជើ។ ពេលនោះ ខ្ញុំនៅក្មេង ត្រូវបានអង្គការយកទៅដាក់នៅក្នុងកងកុមារឲ្យដើរើសអាចម៍គោ និងកាត់ទន្ទ្រានខែត្រយកទៅធ្វើជី។ មេកងនៅផ្ទះបាយស្រលាញ់ខ្ញុំណាស់ ព្រោះខ្ញុំពូកែសំដី ហើយខ្ញុំតែងតែមានអាហារហូបគ្រប់គ្រាន់។ ពេលទំនេរពីការងារ ខ្ញុំតែងតែដើរស្ទូចត្រី ចាប់ក្តាម ខ្យងមកហូបបន្ថែមទៀត។

ព្រឹកខ្លះ ខ្ញុំបានស្ម័គ្រចិត្តទៅដេញចាបជាមួយមិត្តក្នុងកងសប្បាយដែរ។ ខ្ញុំសំណាងណាស់ បងប្អូនរបស់ខ្ញុំ មិនត្រូវបានខ្មែរក្រហមសម្លាប់ទេ ថែមទាំងយើងទទួលបានការហូបចុកគ្រប់គ្រាន់ទៀតផង។ អ្វីដែលយើងលំបាកនោះ គឺប្រឈមមុខនឹងជំងឺគ្រុនចាញ់នៅក្នុងតំបន់នោះ។ ប្អូនប្រុសរបស់ខ្ញុំម្នាក់ បានស្លាប់ដោយសារតែជំងឺគ្រុនចាញ់ ហើយយើងគ្មានថ្នាំព្យាបាលទាន់ពេលវេលា។

បទពិសោធន៍របស់ ឈិត ណេត

ខ្ញុំធ្លាប់ធ្វើជាកងទ័ពខ្មែរក្រហម ហើយស្ទើរតែបាត់បង់ជីវិតពេលដែលខ្ញុំប្រឆាំងនឹងអង្គការ។ ខ្ញុំគឺជាកសិករម្នាក់នៅខេត្តកំពង់ធំ។ ក្នុងឆ្នាំ១៩៧០ តំបន់របស់ខ្ញុំ ត្រូវបានខ្មែរក្រហមចូលមកកាន់កាប់ ហើយពេលនោះ មានពូៗមួយក្រុមបានមកផ្ទះរបស់ខ្ញុំ ដើម្បីហៅឲ្យចូលរួមបដិវត្តន៍ជាមួយពួកគេ។ ខ្ញុំបានចូលធ្វើកងទ័ពទាំងបង្ខំ។ ខ្មែរក្រហម បាននាំខ្ញុំ និងអ្នកភូមិជាច្រើននាក់ទៀត ទៅចូលរៀនពីបដិវត្តន៍ដោយនិយាយលើកសរសើរពីអង្គការ ព្រមទាំងបានបណ្តុះស្មារតីឲ្យស្មោះត្រង់នឹងអង្គការតែមួយគត់ ដោយឲ្យយើងបំភ្លេច ឪពុកម្តាយ ប្តី ប្រពន្ធ កូន និងសាច់ញាតិបងប្អូន។ ខ្មែរក្រហម បានបង្រៀនខ្ញុំឲ្យចេះបាញ់កាំភ្លើងទៀតផង។

ចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៦ ខ្ញុំនៅមានអាហារបរិភោគគ្រប់គ្រាន់នៅឡើយ ប៉ុន្តែចូលដល់ឆ្នាំ១៩៧៧ ខ្ញុំហូបតែបបរទេ ទោះបីជាខ្ញុំធ្វើជាកងទ័ពខ្មែរក្រហមក៏ដោយ។ ដោយសារតែភាពអត់ឃ្លាន ខ្ញុំ បាននាំគ្នា ប្រឆាំងអង្គការ រហូតដល់អង្គការ មានបំណងបញ្ជូនខ្ញុំទៅឃុំឃាំងនៅមន្ទីរស-២១ (គុកទួលស្លែង)។ នៅពេលកងទ័ពវៀតណាមវាយចូលមក កងទ័ពខ្មែរក្រហមបានជម្លៀសខ្ញុំទៅជាមួយ ហើយដល់ពាក់កណ្តាលផ្លូវ កងទ័ពវៀតណាម បានចាប់ខ្លួនរបស់ខ្ញុំទុក។ មួយឆ្នាំក្រោយទើបបានកងទ័ពវៀតណាម ដោះលែងខ្ញុំឲ្យមានសេរីភាពវិញ។

ខ្ញុំ ជាមនុស្សម្នាក់ដែលមានសំណាងបំផុតក្នុងចំណោមអ្នកប្រឆាំងអង្គការទាំងអស់នោះ ដែលរួចជីវិតមកដល់សព្វថ្ងៃនេះ។

ចប់

២០
រឿងភូមិខ្ញុំក្នុងសម័យប៉ុលពត

អ្នកនិពន្ធ ៖ សង ហោង

២០ ~ រឿង ភូមិខ្ញុំ ក្នុងសម័យ ប៉ុល ពត

ជ័យជម្នះ១៧មេសា

សម័យកម្ពុជាប្រជាធិបតេយ្យ ឬសម័យ ប៉ុល ពត បានក្តោបក្តាប់អំណាចនយោបាយនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយកជ័យជម្នះដោយប្រើអាវុធប្រយុទ្ធបង្ហូរឈាមលើសមរភូមិពេញផ្ទៃប្រទេស ផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយសេនាប្រមុខ លន់ នល់។

បន្ទាប់ពីទទួលបានជ័យជម្នះភ្លាម រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានលុបចោលរបៀបរបបគ្រប់គ្រងនយោបាយពីសង្គមចាស់ ហើយរៀបចំចាត់តាំងរចនាសម្ព័ន្ធគ្រប់គ្រងអំណាចគ្រប់លំដាប់ថ្នាក់សារជាថ្មី។ សមាសភាពនៃអ្នកដឹកនាំមូលដ្ឋាន ដូចជាប្រធានក្រុម ប្រធានកង ប្រធានឈ្លប ប្រធានភូមិ គណៈឃុំ ត្រូវបានជ្រើសរើសចេញពីគ្រួសារជាកសិករ ឬកម្មករ ដែលមានជីវភាពក្រីក្រ។ ពាក្យថា «អង្គការ» គឺសំដៅទៅលើថ្នាក់ដឹកនាំរដ្ឋអំណាចពីថ្នាក់ក្រោមដល់ថ្នាក់លើ។ ពាក្យថា «កម្មាភិបាល» សំដៅលើសមាសភាពអ្នកកាន់អំណាចកំពូលៗរបស់អង្គការ រួមមាន គណៈតំបន់ គណៈភូមិភាគ គណៈមជ្ឈិមបក្ស ជាដើម។

ប្រជាជនប្រុសស្រី ចាស់ក្មេង នៅភូមិបឹង ឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ម្នាក់ៗមានទឹកមុខរីករាយ ញញឹមញញែម ត្រេកអរនឹងជ័យជម្នះថ្ងៃ១៧ មេសា។ សំឡេងឧគ្ឃោសនសព្ទ បានបន្លឺក្តែងៗ ចេញពីវេទិកាប្រជុំនៅកណ្តាលវាលស្រែខាងលិចភូមិ បន្ទរដោយស្នូរទះដៃប្រារព្ធៗ និងសម្រែកជយឃោសយ៉ាងកងរំពងថា

«ជយោ! ថ្ងៃជ័យជម្នះ១៧មេសា មហារុងរឿង .... ជយោ! ជយោ! ជយោ!»

«ជយោ! បដិវត្តន៍កម្ពុជា ដ៏មហិមា ....ជយោ! ជយោ! ជយោ! »

«ជយោ! វណ្ណៈកសិករ វណ្ណៈកម្មករ ដ៏ក្លាហាន ....ជយោ! ជយោ! ជយោ!»

«បរាជ័យ! ចក្រពត្តិអាមេរិក និងពួកបរិវារ .... បរាជ័យ! បរាជ័យ!បរាជ័យ!»

បន្ទាប់ពីកម្មាភិបាលខ្មែរក្រហម ដែលស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ បង់ក្រមា ពាក់មួកកន្តិបពណ៌ស្លែ និងពាក់ស្បែកជើងកង់ឡាន មានមតិយោបល់ក្នុងអង្គប្រជុំ ហើយស្រែកជយឃោសយ៉ាងទ្រហឹងអឺងកងរួច នៅវេលាថ្ងៃជិតត្រង់អង្គប្រជុំត្រូវប្រកាសរំសាយ។

ខ្ញុំ និងក្រុមគ្រួសាររួមទាំងប្រជាជនជាច្រើនកុះករផ្សេងទៀត ដើរកាត់វាលស្រែវិលត្រលប់មកផ្ទះរៀងៗខ្លួន ដោយទឹកមុខស្រស់ស្រាយសប្បាយរីករាយឥតឧបមា។ ល្ងាចនេះ មនុស្សម្នា ជួបជុំគ្នាជាក្រុមៗ បួនប្រាំនាក់ៗ នៅតាមមុខផ្ទះ មានភាពខ្ញៀវខ្ញារីករាយខុសប្លែកជាងពេលមុនៗ។

ការមកដល់របស់ប្រជាជនពីភ្នំពេញ

ក្នុងខែមេសា ឆ្នាំ១៩៧៥ អាកាសធាតុក្តៅហែងស្ទើរឆេះ រុក្ខជាតិស្វិតរញ្ជួយ ថ្ងៃបណ្តើរកូនព្រិចៗនៅឯវាលស្រែ។ យូរៗម្តង ខ្យល់កួចដីហុយទ្រលោម។ ប្រជាជនកម្ពុជាទាំងប្រុសទាំងស្រី ចម្រុះវ័យ កំពុងធ្វើដំណើរហូរហែលើទ្រូងផ្លូវជាតិលេខ៦ ក្នុងទឹកដីស្រុកបារាយណ៍ ខេត្តកំពង់ធំ។ អ្នកខ្លះទូល ខ្លះរែក ខ្លះយួរ ខ្លះបណ្តើរកង់ និងខ្លះជាក់ស្តីក្លូ ផ្ទុកអីវ៉ាន់រយីងរយោង។ ស្ត្រីពពោះ ស្ត្រីបីកូនតូចចាស់ជរា និងក្មេងតូចៗ ធ្វើដំណើរយឺតៗ ហើយយូរៗទើបអាចសម្រាកបានម្តងក្នុងសភាពហត់ហៅវ៉ៅយ៉ាងស្រពាប់ស្រពោន។ អ្នកដំណើរខ្លះបន្តទៅមុខ ខ្លះបែកចូលតាមផ្លូវទៅកាន់ភូមិអ្នកស្រុក។ តាមផ្លូវលំពីភូមិជនជាតិចាម ត្រពាំងឈូកចូលទៅកាន់ភូមិបឹង មានអ្នកដំណើរដើរបន្តគ្នាដឹកចូលទៅក្នុងភូមិ។

«អ្នកដំណើរមកកាន់ភូមិយើងរាល់ថ្ងៃហ្នឹង តើពួកគេមកពីណា?» ខ្ញុំសួរទៅកាន់ម្តាយរបស់ខ្ញុំ។

ម្តាយរបស់ខ្ញុំឆ្លើយតបថា «អាហែង! ពួកគេមកពីភ្នំពេញ ត្រូវអង្គការបដិវត្តន៍ជម្លៀសឲ្យមករស់នៅតាមជនបទស្រុកស្រែចម្ការជាមួយនឹងយើងហ្នឹងណា»។

«មិនយូរប៉ុន្មានទេ ផ្ទះយើងក៏ប្រហែលជាមានអ្នកមកសុំរស់នៅជាមួយដែរ ហើយ»ឪពុករបស់ខ្ញុំដែលមានវ័យ៥៥ឆ្នាំ ឆ្លើយបន្ថែម។ គាត់បាននិយាយបន្ត ទៀតថា «យប់មិញ ប៉ាត់យ៉ូអាមេរិកាំង បាននិយាយថា កងយោធាអង្គការបដិវត្តន៍ ខ្មែរក្រហម បានបាញ់រះទៅលើអាកាស និងបាញ់សម្លាប់ចោលចំពោះជនណា ដែលចចេសរឹងរូស មិនព្រមចាកចេញពីទីក្រុងភ្នំពេញ និងមិនស្តាប់បញ្ជារបស់ អង្គការ! មើលសភាពការណ៍ប្រទេសជាតិ ដូចជាមិនស្រួលទេដឹងម៉ែវា! ហើយ រាល់យប់មានផ្តាយដុះកន្ទុយនៅទិសខាងលិចទៀតផង តិចស្រុកយើងប្រែប្រួល យ៉ាងម៉េចៗទៅ?»។

ស្នើរជារៀងរាល់ថ្ងៃ អ្នកចំណូលថ្មីមកកាន់ស្រុកនេះ នៅតែបន្តចូលមកកាន់ ភូមិបឹងជាបន្តបន្ទាប់។ គ្រួសាររបស់ខ្ញុំ បានទទួលសមាជិកថ្មីម្នាក់ ដែលត្រូវជា សាច់ញាតិរបស់យើង មកស្នាក់នៅជាមួយ។ ឯគ្រួសារនៅខាងលិចផ្ទះរបស់ខ្ញុំ និងផ្ទះគ្រួសារផ្សេងទៀត ក៏ឃើញមានប្រជាជនចំណូលថ្មីមកស្នាក់នៅជាមួយ ដែរ។ ប្រធានភូមិ និងប្រធានក្រុម បានបែងចែករៀបចំក្រុមចំណាកស្រុកមកពី ភ្នំពេញនេះ ឲ្យមានពួក មានក្រុម រស់នៅជាមួយប្រជាជនមូលដ្ឋាន។ ភាគច្រើន ពួកគេរស់នៅក្រោមផ្ទះ សំយាបផ្ទះ សង់ខ្ទមតូចៗ ឬជ្រកនឹងជង្រុកស្រូវរបស់ ប្រជាជនមូលដ្ឋាន។ អ្នកទាំងអស់ ត្រូវបានអង្គការហៅថា «ប្រជាជនថ្មី ឬ ប្រជាជន១៧មេសា»។

ការប្រមូលទ្រព្យសម្បត្តិជាកំរួម

នៅកណ្តាលវាលខាងលិចភូមិ មានរោងដ៏លមួយ ដែលតុបតែងលម្អដោយ ស្លឹកដូង ស្លឹកជ្រៃក្រឹម និងមានមីក្រូមួយគ្រឿងបានចងភ្ជាប់នឹងឫស្សីមួយដើម លើកខ្ពស់ផុតពីរោង។ ទីនេះហើយដែលប្រធានក្រុមបានប្រាប់ប្រជាជនកាលពី ល្ងាចមិញ ឲ្យទៅចូលរួមប្រជុំស្តាប់អង្គការថ្នាក់លើ។ ទាំងប្រជាជនចាស់ ទាំង ប្រជាជនថ្មី បានអង្គុយត្រៀបត្រាស្តាប់មតិយោបល់របស់អង្គការ។ ខ្ញុំបានត្រលប់ មកផ្ទះវិញមុនអង្គប្រជុំបានបញ្ចប់ ដើម្បីដាំបាយ។

វេលាថ្ងៃជិតត្រង់ ឪពុកម្តាយរបស់ខ្ញុំបានមកដល់ផ្ទះ។ ពេលហូបបាយរួច ពួកគាត់ស្ងៀមស្ងាត់មិនមាត់មិនកដូចពេលមុនៗសោះ។ ឃើញបែបនេះខ្ញុំសួរគាត់ដោយងឿយឆ្ងល់ថា «ម៉ែពុក! មានរឿងអីបានធ្វើមុខក្រៀមៗអីចឹង? ម្ហូបរបស់ខ្ញុំធ្វើ ហូបមិនឆ្ងាញ់ឬ?»។

«ស្រុកយើងប្រែប្រួលហើយកូន ចាប់ពីពេលនេះទៅ យើងត្រូវប្រមូលរបស់របរទ្រព្យសម្បត្តិ សម្ភារទាំងអស់ប្រគល់ឲ្យអង្គការយកទៅជាក់រួម លែងមានហូបបាយតាមផ្ទះ លែងចាយលុយ លែងមានផ្សារលក់ដូរទៀតហើយ» ឪពុករបស់ខ្ញុំឆ្លើយតបទាំងទឹកមុខក្រៀមក្រំ។

ឮដូច្នោះ បងប្រុសរបស់ខ្ញុំ មិនអស់ចិត្ត ក៏សួរបន្តភ្លាមៗថា «អីចឹង គោយើងទាំងអស់យកជាក់រួមដែរ?» ។

ឪពុករបស់ខ្ញុំ ទំពាបាយបណ្តើរ និយាយបណ្តើរថា «គោក្របី ជ្រូក មាន់ ទា ស្រូវ អង្ករ ចាន ឆ្នាំ កែវ វែក ស្លាបព្រា ត្រូវយកទៅជាក់ជាសមូហភាពទាំងអស់ស្អែកមេគោ និងអាកូនវាពីរក្បាលហ្នឹង ត្រូវដឹកយកទៅទុកនៅវត្តជើងចាស់ ឯចានឆ្នាំងត្រូវយកទៅទុកនៅផ្ទះយាយ ដឹប»។

បរិភោគបាយរួច ខ្ញុំបានទៅផ្ទះម្តាយមីងរបស់ខ្ញុំ ដែលនៅជាប់របងគ្នា។ ខ្ញុំឃើញបង្វេចខ្មៅមួយទុកនៅក្រោមគ្រែដំណេក ដែលពីមុនមិនដែលឃើញសោះ។ ខ្ញុំឆ្ងល់ក៏បានសួរទៅគាត់ថា «មីង! ស្អីខ្មៅមួយដុំធំនៅក្រោមគ្រែនោះ?» មីងមើលមកខ្ញុំ ក្នុងអារម្មណ៍ភ្ញាក់ផ្អើល ហើយគាត់បន្លឺថា «កុំប្រាប់គេ អាហេង! អញលាក់អង្ករទុកដាំបាយស៊ីខ្លះ ស្អែកប្រមូលឲ្យអង្គការអស់ហើយ»។

មិនបានយូរប៉ុន្មានផង ម្តាយមីងក៏ទាញស្បោងក្រោមគ្រែនោះចេញមកវិញ ប្រហែលជាខ្លាចបែកការពីខ្ញុំហើយមើលទៅ។ ពេលរសៀល ខ្ញុំយកមេគោទៅចងឲ្យស៊ីស្មៅដូចសព្វដង ហើយក៏ហួសទៅផ្ទះមិត្តកក្តិរបស់ខ្ញុំនៅកណ្តាលភូមិ។

«អាឃ្លី! ហ្អែងជីកដីធ្វើអ្វីហ្នឹង?» ខ្ញុំសួរមិត្តកក្តិរបស់ខ្ញុំ។

«កុំនិយាយឮៗអានេះ! ប្រយ័ត្នគេដឹង ម៉ែអញឲ្យជីកដីកប់ចាន ហ្អែងដើរចេញទៅ ប្រយ័ត្នម៉ែអញស្តីឲ្យ» អាឃ្លី តប។ ពេលមកដល់ផ្ទះ ខ្ញុំបានឃើញ

ម្តាយរបស់ខ្ញុំរៀបកែវធំៗ ចានថ្មល្អៗដាក់ក្នុងឆ្នាំងដែក ហើយបងប្រុសរបស់ខ្ញុំលើកយកទៅក្រោយផ្ទះ។ ខ្ញុំដឹងថា គាត់ច្បាស់ជាយកទៅកប់លាក់ទុកដែរហើយ។

រាត្រីកាលឈានមកបន្តិចម្តងៗ។ យប់នេះសំឡេងឆ្កែព្រូស រ៉ូសៗ លាន់ឮពាសពេញភូមិ។ មុនពេលចូលដំណេក ខ្ញុំឃើញម្តាយរបស់ខ្ញុំ ដើរទៅមុខទៅក្រោយ ប្រហែលចាក់ស្រេះដោយបញ្ហាស្មុគស្មាញហើយមើលទៅ។

អរុណោទ័យ ចាំងស្មើពីទិសបូព៌ា។ ប្រជាជនក្មេងចាស់ប្រុសស្រី ខ្លះយួរ ខ្លះលី ខ្លះទូល ខ្លះដឹកដោយកង់ ដោយរទេះគោ នាំយកសម្ភារ របស់របរប្រើប្រាស់យកទៅដាក់ជាសមូហភាព។ ខ្ញុំដឹកគោ៣ក្បាល បងប្រុសរបស់ខ្ញុំកាន់រំពាត់ដេញគោពីក្រោយ។ បន្ទាប់ពីយកគោប្រគល់ឲ្យអង្គការហើយ ខ្ញុំត្រលប់មកដល់ផ្ទះវិញ យើងដេញចាប់ទាបានបួនប្រាំក្បាលយកទៅដាក់រួមក្នុងត្រពាំងដែលហ៊ុំព័ទ្ធដោយព្រួលរៀបបម្រុងទុកជាស្រេច។ របស់របរទាំងឡាយណាដែលយកទៅមិនទាន់អស់ ត្រូវរក្សាទុកបណ្តោះអាសន្ននៅតាមផ្ទះសិន ហើយប្រធានរោងបាយ មកចាប់យកទៅធ្វើម្ហូបជារៀងរាល់ថ្ងៃ។

ការហូបរួម

ការដាំស្លហូបបាយនៅតាមគ្រួសារ បានលុបបំបាត់ចោលទាំងស្រុងនៅក្នុងភូមិរបស់ខ្ញុំ។ អង្គការបានបង្កើតទីកន្លែងដាំស្លនិងបរិភោគរួមគ្នាមួយហៅថា «រោងបាយ»។ «ប្រធានរោងបាយ» ឬហៅម៉្យាងទៀតថា«ប្រធានចុងភៅ» ជាអ្នកគ្រប់គ្រងការងាររោងបាយ និងមានអំណាចកាត់បន្ថយរបបអាហារ ឬផ្តាច់របបអាហារ មួយពេល មួយថ្ងៃ ឬលើសពីនេះ ចំពោះជនណាដែលអង្គការបានកំណត់មុខសញ្ញាជាមុន ដូចជាអ្នកមិនសកម្មការងារ អ្នកមិនទៅធ្វើការងារ អ្នកធ្វើពុតជាឈឺ និងអ្នកគេចវេសពីការងារ។ សំឡេងជួងរោទ៍ ម៉ឹង! ម៉ឹង! ម៉ឹង! ពេលថ្ងៃត្រង់ និង ម៉ឹង! ម៉ឹង! ម៉ឹង! ពេលព្រលប់ គឺជាសញ្ញាប្រាប់ថា ដល់ពេលហូបបាយហើយ។ ម្នាក់ៗត្រូវអង្គុយតាមក្រុម ទល់មុខគ្នាលើកៅអីក្តារបន្ទះវែងៗធ្វើអំពីឈើបន្ទះប្រវែងបីបួនម៉ែត្រ តម្រៀបជាជួរវង់ចាំហូបបាយតាមការចាត់ចែងរបស់ចុងភៅ។ ការហូបរបៀបនេះ ចាត់ចែងដំណើរការបានតែពីដំបូងប៉ុណ្ណោះ។

រយៈពេលពេលក្រោយៗមក យើងមិនចាំបាច់ហូបអង្គុយតាមក្រុមទៀតទេ គឺចុងភៅជាអ្នកផ្តល់របបបាយឬបបរទៅតាមបុគ្គលម្នាក់ៗ ដែលកាន់ចាននិងស្លាបព្រារៀងៗខ្លួន ឈរតម្រង់ជាជួរដើរទៅរកចុងភៅ ដែលកាន់វែកត្រឡោកដួង ឈរជ្រែងនៅជាប់នឹងឆ្នាំងខ្ទះបាយ។ បន្ទាប់ពីទទួលរបបអាហាររួមម្នាក់ៗ ត្រូវមកអង្គុយបរិភោគរៀងៗខ្លួន។

«អាហេង! ម៉េចបបរហ្អែងបានតិចម៉េស?» មិត្តរួមការងារហុតបបរគ្រូកៗរួចសួរមកខ្ញុំ។

«ចុងភៅថាអញដកសំណាបមិនគ្រប់ចំនួនកណ្តាប់ អីចឹងគាត់កាត់របបបបរអញ ឲ្យតែកន្លះវែកទេ» ខ្ញុំតបតិចៗ។

វាឮដូច្នោះហើយក៏និយាយប្រាប់ខ្ញុំបន្ថែមទៀតថា «អើ! ថ្ងៃមុន អាឆន និងអញ ចុងភៅផ្តាច់របបមួយពេលដែរ ព្រោះអញទាំងពីរអត់ទៅកាប់ទន្រ្ទានខែត្រ»។

កងកម្លាំងពលកម្មមនុស្សពេញវ័យ ពួកគេទៅធ្វើការឆ្ងាយៗពីភូមិ មិនសូវបានហូបរួមនៅទីនេះដូចកងកុមារឡើយ។ ពួកគេទៅធ្វើការនៅទីណាហូបរួមគ្នានៅទីនោះ។

កងកុមារ

អង្គការបានបែងចែកកម្លាំងពលកម្មទៅតាមវ័យមនុស្ស។ កងចល័តកុមារគឺមានអាយុប្រហាក់ប្រហែល១៣ឆ្នាំចុះក្រោម។ ខ្ញុំព្រមទាំងកុមារទាំងអស់បានរៀនអក្សរ។ នៅសាលារៀនបឋមសិក្សា «ស្វាយអម្ពា» ដែលមានទីតាំងនៅខាងកើតជាប់ភូមិបឹង។ អង្គការមិនឲ្យយើងហៅគ្រូបង្រៀនថា «លោកគ្រូឬអ្នកគ្រូ»ទេ យើងត្រូវហៅថា«បង»។ រីឯកុមារៗដូចគ្នា ត្រូវហៅថា«មិត្ត» ហើយត្រូវប្រើពាក្យ«ហូប» មិនឲ្យនិយាយថា«ស៊ី ឬធឹក» នោះទេ។ កាលពីដំបូងការសិក្សារៀនសូត្ររបស់យើង រៀនជាប់លាប់ជាធម្មតា តែពេលក្រោយៗមករៀនអក្សរ ក ឬ ខ បានបួនដប់នាទី ហើយក៏ចេញទៅធ្វើពលកម្ម។ កម្មាភិបាលអង្គការថ្នាក់លើបានចុះមកជួបសំណេះសំណាលជាមួយកងកុមារ ព្រមទាំងចែកដីសមួយកំណាត់ដើម សៀវភៅមួយ និងកំណាត់ខ្មៅដៃមួយកំណាត់ ដល់កុមារ

គ្រប់ៗគ្នា ហើយបន្តឹវាចាខ្លាំងៗ ដោយវាសដៃចុះឡើងៗថា «ប្រទេសយើងក្រលំបាកវេទនាដោយសារពួកសក្តិភូមិ នាយទុន បនប្រតិកិរិយា ចក្រពត្តិអាមេរិក ពួកវាជិះជាន់កេងប្រវ័ញ្ច ជញ្ជក់ញើសឈាមវណ្ណៈកសិករ កម្មករយើង ឥឡូវយើងបានជ័យជម្នះយ៉ាងត្រចះត្រចង់ យើងមានអង្គការបដិវត្តន៍ដ៏ត្រឹមត្រូវ ជាម៉ែឪរបស់យើងទាំងអស់គ្នា តែខ្មាំងសឹរួងផ្ទៃក្នុងនៅមិនទាន់អស់នៅឡើយទេ ដូចនេះកុមារទាំងអស់ ដែលជាកូនចៅអង្គការត្រូវស៊ើបការណ៍ រាយការណ៍ ប្រាប់អង្គការអំពីខ្សែរយៈខ្មាំងបង្កប់ ពួក សេ អឺ អា ឬ កា ហ្សេ បេ»។

សាលាដែលធ្លាប់រៀនពីមុនត្រូវបានរុះរើ ដើម្បីយកឈើធ្វើជាជង្រុកស្រូវ។ ការសិក្សាត្រូវប្តូរមករៀននៅក្រោមផ្ទះរបស់ប្រជាជនវិញ។ ថ្នាក់រៀនថ្មីនេះ មិនមានជញ្ជាំងបិទបាំងនោះទេ។ មានតែតុឈើចាស់ៗហើយយើងត្រូវអង្គុយប្រជ្រៀតគ្នា។ សរសេរអក្សរដោយប្រើធ្យូង។ បន្ទាប់ពីរៀន ក ខ គ ឃ ង បានបួនដប់នាទីមក បងៗ(គ្រូ) បានដឹកនាំកុមារធ្វើការងារពលកម្ម ដូចជា លើករងដាំត្រកួន ពូនរងដាំដំឡូងជ្វា និងកាប់ដើមទន្ទ្រានខែត្រ យកមកធ្វើជី។

មិនយូរប៉ុន្មាន ការសិក្សានៅក្រោមផ្ទះត្រូវបានបញ្ឈប់ទាំងស្រុង។ កុមារត្រូវបែងចែកជាក្រុមៗ ដើម្បីធ្វើពលកម្មយ៉ាងពេញទំហឹង។ ម៉ោងប្រហែល៥ទៀបភ្លឺស្មៅជួងបន្លឺឡើងពីរោងបាយ រោទ៍ជាច្រើនម៉ឺង បន្ទាប់មកស្នូរកញ្ជែស្រែកឡើងច្រែក! ច្រែក! ជាសញ្ញាថាឲ្យកុមារទៅធ្វើពលកម្មតាមផែនការដែលបានកំណត់ដោយប្រធានកង។ ក្រុមរបស់ខ្ញុំ មានសមាជិកមិនលើសពី១០នាក់ទេ ត្រូវដើរកាប់ទន្ទ្រានខែត្រក្នុងមួយថ្ងៃឲ្យបាន ៤ពំនូក យកទៅកាប់ចិញ្ច្រាំនៅឃ្លាំងផ្ទុកជីអាចម៍គោ។ ពេលដែលយើងធ្វើការងារពលកម្មតាមវាលស្រែ យើងអាចបេះស្លឹកឈើ ផ្លែឈើ រកឃ្មុំតាមគុម្ពោតព្រៃ ចុះទឹកបេះផ្លែព្រលឹត ផ្លែស្រវាគោក ចាប់ត្រីខ្យង ក្តាម កង្កែប លួចបរិភោគ ដើម្បីសម្រន់នៃការស្រេកឃ្លានបានខ្លះៗដែរ។ ក្នុងទឹកសម្បុរត្រីណាស់ យើងយកបង្គីជញ្ជាត់ ឬ ចាប់ដោយដៃទទេ ក៏អាចបានដែរ។

«ជួយផង! ជួយផង!» សំឡេងមិត្តនារី បិច ដោះមួក គ្រវីគ្រវាត់ស្រែកអោយគេជួយ។

«យ៉ាងម៉េច កាប៉ិច ឃ្មុំទិចមែន?» មិត្តយ៉ុន សួរ។

«កាប់ត្រូវសំបុកស្រាំង វាដេញទិច តែមិនអីទេ រត់ចេញទាន់» មិត្តនារី ប៉ិច ឆ្លើយ។

«អើ! ថ្ងៃមុន ខ្ញុំប៉ោងភ្នែកម្ខាងដែរ ៣ថ្ងៃបានបាត់ហើម» មិត្ត ធន ប្រាប់ទៅមិត្តរួមការងារ។

ការងាររបស់យើងប្រែប្រួលទៅតាមរដូវកាល។ ខែប្រាំង យើងនាំគ្នាដើរ រើសក្តួរស្រូវតាមវាលស្រែដែលកំពុងច្រូតកាត់ កើបអាចម៍គោ កើបជីលេខ១ (ជីលាមកមនុស្សលាយផេះ) កាប់ទន្ទ្រានខែត្រ រៀបលានបញ្ជាន់ស្រូវ។ រីឯខែវស្សា យើងដកសំណាប ដកស្មៅក្នុងសន្ទូង អូសកណ្តាប់ស្រូវសម្រាប់មនុស្សចាស់ស្ងួង ចាប់ក្តាមតាមភ្លឺស្រែ ជីករន្ធកណ្តុរតាមភ្លឺស្រែ ឬតាមគម្ពោតព្រៃ។ កណ្តុរដែលយើងចាប់បាន ត្រូវព្រលាត់ដោតចង្កាក់ហាលថ្ងៃ ទុកធ្វើជាម្ហូបរួម។

ការងារហត់នឿយ ពោះក៏ឃ្លាន តែបានភាពធូរស្បើយមកបន្តប់ខ្លះៗ ដោយយើងនាំគ្នាហែលទឹកលេងតាមអូរ តាមប្រឡាយខ្ចាត់ខ្ចែងលាតសន្ធឹងកាត់វាលស្រែធំល្វឹងល្វើយ។

កងចល័ត

បុរសនារី ពេញវ័យ ពេញកម្លាំង ត្រូវបានអង្គការហៅថា «កងចល័ត»។ ការងារដែលធ្ងន់ៗ ត្រូវសម្រេចដោយកម្លាំងស្រួចនេះ។ កងចល័ត ច្រើនតែធ្វើការងារនៅឆ្ងាយៗពីភូមិស្រុក។ ពួកគេធ្វើការងារកន្លែងណា គឺត្រូវបោះជំរំស្នាក់នៅនិងហូបចុកនៅកន្លែងនោះ។ ខែប្រាំងបន្ទាប់ពីការងារច្រូតកាត់រួច ការងាររបស់កងចល័ត គឺជីកប្រឡាយនិងលើកទំនប់។ អូរ ប្រឡាយតូចធំ រាក់ជ្រៅ សណ្តូកខ្លួនត្រង់ភ្លឹងតាមវាលស្រែ គឺជាសមិទ្ធផលនៃកម្លាំងសាច់ដុំដៃ សាច់ដុំស្មា កាប់នឹងចប រែកនឹងបង្គី ប្រឹងយ៉ាងសស្រាក់សស្រាំរបស់កងយុវពលករនេះ។ បងប្រុសរបស់ខ្ញុំបីនាក់ ជាកងចល័ត។ ឃ្យេៗម្តងទើបពួកគាត់អាចសុំច្បាប់ប្រធានកងមកលេងផ្ទះបានមួយព្រឹក មួយល្ងាច ឬមួយថ្ងៃ។ ពួកគាត់សម្បុរខ្មៅ ស្គមកំព្រឹង សក់ក្បាលចាក់ត្រចៀក មើលសឹងតែមិនស្គាល់។

«អាហេង! ម៉ែមិនទាន់មកផ្ទះទេ?» បងប្រុសសួរមកខ្ញុំ។

«ម៉ែ ល្ងាចបានមកផ្ទះ បងឯងមកប៉ុន្មានថ្ងៃ?» ខ្ញុំសួរត្រលប់ទៅគាត់វិញ។

«សុំច្បាប់ប្រធានកងបានមួយល្ងាច ស្អែកងើបពីយប់ទៅការដ្ឋានវិញ នៅលើផ្ទះមានអីហូបអត់?» បងប្រុសរបស់ខ្ញុំសួរដោយសេចក្តីស្រេកឃ្លាន។

«អត់មានទេ ល្ងាចមិញម៉ែ បានស្ករត្នោតមួយដុំ ទុកនៅក្បែរពាងទឹក យកហូបទៅ» បងខ្ញុំដើរសំដៅទៅក្រោយ តាមការប្រាប់របស់ខ្ញុំ។

ពេលព្រលប់បន្តិច ឪពុកម្តាយរបស់ខ្ញុំមកដល់ផ្ទះ។ មុនពេលលង់លក់ក្នុងដំណេក បងប្រុសទី១នេះ បាននិយាយជាមួយម្តាយរបស់ខ្ញុំតិចៗថា «ប្រយ័ត្នប្រយែងៗ....» ខ្ញុំស្តាប់ឮផុតៗមិនយល់អស់សេចក្តី ហើយស្ងប់ស្ងាត់លង់លក់ក្នុងរាត្រីសូន្យឈឹង។

កងមនុស្សចាស់

កងមនុស្សចាស់មានពីរប្រភេទ គឺមនុស្សវ័យកណ្តាល ដែលមានអាយុប្រហាក់ប្រហែល៤៥ឆ្នាំចុះក្រោម និងមួយប្រភេទទៀត គឺមនុស្សដែលមានវ័យលើសពីនេះ រហូតដល់ចាស់ជរា។

មុខព្រួញការងាររបស់ក្រុមមនុស្សវ័យកណ្តាល គឺការងារបង្កបង្កើនផលក្នុងសហករណ៍។ រដូវធ្វើស្រែ ពួកគាត់ ធ្វើការងារភ្ជួររាស់ ដកស្មូង ជាក់រហាត់ទឹក បាចទឹកបញ្ចេញបញ្ចូលក្នុងស្រែ ច្រូតកាត់ បោកបែន និងការងារផ្សេងៗទៀតដែលអង្គការបានដាក់ឲ្យ។ ក្រៅពីការងារក្នុងសហករណ៍ មានអ្នកខ្លះឡើងត្នោត នេសាទត្រី កាប់ឧស ដាំបន្លែ ចិញ្ចឹមមាន់ទា ជ្រូក និងឃ្វាលគោ។ ក្រោយពីបញ្ចប់ការងារស្រែស្រូវ ក្រុមវ័យកណ្តាលនេះក៏សកម្មប្រយុទ្ធមុខព្រួញការងារជីកប្រឡាយ និងលើកទំនប់មិនខុសពីកងចល័តឡើយ។

«ម៉ែ! ម៉េចក៏យប់ជ្រៅម្ល៉េះ?» ខ្ញុំសួរទៅម៉ែ ដែលទើបមកពីសហករណ៍ប្រហែលម៉ោង៩យប់។

«យប់នេះអង្គការ ឲ្យសម្រុកស្មូងបង្ហើយដីស្រែ មីង។ខ្លះមិនទាន់មកដល់ផង» ម៉ែឆ្លើយទាំងសភាពហេវហត់។

«អ្នកហុងអើយ! មកដល់ផ្ទះនៅ?» សំឡេងស្ត្រី ដើរកៀនផ្ទះស្រែកសួរ។

«មកដល់មួយសន្ទុះហើយ អ្នកឃុត» ម៉ែតបវិញ។

ក្រុមយាយៗ តាៗ ក៏មមាញឹកនឹងការងារសិប្បកម្មដៃរ។ ទីកន្លែងធ្វើការរបស់ពួកគាត់នៅក្នុងភូមិហើយការងារពលកម្មនៅលាយឡំជាមួយស្ត្រីមានផ្ទៃពោះ និងស្ត្រីកូនខ្ចី។ ការងារប្រចាំថ្ងៃគឺមើលថែទាំក្មេងតូចៗ ដែលម្តាយរបស់ពួកគេទៅធ្វើការងារ ត្បាញកន្ទេល ដេរស្លឹកកណ្តាប ក្រងស្បូវ ធ្វើបង្គី វេញខ្សែគោ ត្បាញល្អីកញ្ជើ ចង្អេរ ជួសជុលនង្គ័ល រនាស់ រទេះគោ ធ្វើត្បាល់កិនស្រូវ ជាន់អង្ករ កិនស្រូវ និងអុំអង្ករ។

របបអាហារ

យើងទទួលបានរបបអាហារប្រចាំថ្ងៃចំនួន ២ពេលក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់ និងពេលល្ងាច។ កាលពីដំបូង ចុងភៅបានរៀបចំម្ហូបអាហារ បាយសម្លគ្រប់គ្រាន់សម្រាប់បរិភោគ ប៉ុន្តែក្រោយៗបន្តបន្ទាប់មក អាហារដែលយើងទទួលបានកាន់តែខ្សត់ទៅៗគួរឲ្យសង្វេគណាស់។ បបររាវ មានគ្រាប់អង្ករមួយៗ លាយជាមួយត្រកួន ព្រលឹត ដំឡូងជ្វា និងដំឡូងឈើ។ ម្នាក់ៗទទួលរបបមួយវែកដែលធ្វើពីត្រឡោកដូង ហូបជាមួយទឹកប្រហុកស្ងោរ ឬ សម្លម្ហូរព្រលឹត និងស្ងោរត្រឡាចជាដើម។ រដូវដែកស្វូងគឺជាខែដែលខ្សត់ខ្សោយអាហារបំផុត។ ប្រជាជនម្នាក់ៗដើរបេះ ស្លឹកឈើ ផ្លែឈើ មើមឈើ ចាប់ខ្យង ក្តាម ត្រី កង្កែប ចង្រិត លួចដុតបរិភោគនៅពេលយប់ស្ងាត់។ យប់មួយនៅក្រោយផ្ទះ ខ្ញុំសួរទៅកាន់ម៉ែថា «ម៉ែ! កំពុងធ្វើអ្វីហ្នឹង?»។

«កុំមាត់! ប្រយ័ត្នបែកការណ៍ បើគេដឹងយកទៅវាយចោលទាំងគ្រួសារអញស្ងោរគេល់ចេក បន្តិចទៀតឆ្អិនហើយ» ម៉ែនិយាយបណ្តើរ ឈ្ងោកមុខផ្លុំភ្លើងផែតៗ។ យប់នោះ ខ្ញុំបរិភោគគល់ចេកស្ងោរពាក់ឪពុកម្តាយយ៉ាងឆ្ងាញ់ពិសារ។

យប់មួយ មេឃងងឹតឈឹង រលឹមស្រិចៗ ឪពុកម្តាយរបស់ខ្ញុំ មិនឃើញមកផ្ទះសោះ។ ខ្ញុំខ្លាចអើយខ្លាច ហើយឃ្លានខ្លាំងណាស់។ ខ្ញុំអង្គុយឱបក្បាលជង្គង់រង់ចាំស្តាប់ស្នូរជួងពីវាំងបាយ។ យប់ជ្រៅណាស់ទៅហើយ ទើបខ្ញុំឮសូរជួង ម៉ឹង!

ម៉ឺង! ពន្លឺចេញពីរោងបាយ។ ខ្ញុំនិងកុមារដទៃទៀត ដើរកាត់ភ្លៀងរលឹមទៅរោងបាយ។ ក្រោមពន្លឺភ្លើងចន្លុះក្រហមព្រាលៗ ខ្ញុំឃើញមានចេកណាំវ៉ាបួនដប់ស្និតជាក់នៅលើតុ។ ខ្ញុំចូលតម្រង់ជួរជាមួយមនុស្សជាច្រើននាក់ទៀត រង់ចាំទទួលរបបអាហារ។ ពុទ្ធោ! ចុងភៅហុចចេកឲ្យយើងម្នាក់មួយផ្លែៗ។ មួយសន្ទុះធំទើបម៉ែរបស់ខ្ញុំមកដល់ផ្ទះ គាត់សួរខ្ញុំថា «អាហោង! មកពីណាទទឹកក្បាលជោក?»។ ខ្ញុំឆ្លើយតបទៅម៉ែវិញទាំងមិនសប្បាយចិត្តថា «ខ្ញុំមកពីរោងបាយ បានតែចេកមួយទេម៉ែអើយ»។ ម៉ែខ្ញុំប្រាប់វិញថា «ដេកសិនទៅ យប់នេះម៉ែមានគល់ល្ពុង»។

យប់នេះបានហូបគល់ល្ពុងស្ងោរឆ្ងាញ់ដូចបានហូបគល់ចេកស្ងោរ កាលពីពេលយប់មុនអីចឹងដែរ។ រសជាតិគល់ល្ពុងស្ងោរ បានធ្វើឲ្យខ្ញុំបាត់ឃ្លាន បាត់ក្រពោះ បន្តរស់សម្រាប់ថ្ងៃស្អែក។

«ទៅនៅដីថ្មី» គឺជាពាក្យដែលអង្គការ ប្រាប់ទៅប្រជាជន១៧មេសា ឲ្យទៅតាំងទីលំនៅក្នុងភូមិស្រុកថ្មី ដែលរៀបចំដោយអង្គការបដិវត្តន៍។ ប្រជាជនដែលអង្គការបញ្ជូនឲ្យទៅរស់នៅដីថ្មី គឺបាត់ដំណឹងជារៀងរហូត។ ពាក្យនេះ ប្រើជំនួសការយកប្រជាជនទៅសម្លាប់។

ពេលព្រឹកព្រលឹមមួយ មានរទេះគោជាជួរផ្ទុកដោយក្រុមគ្រួសារ១៧មេសា។ មិត្តកុមាររបស់ខ្ញុំ៣នាក់នៅលើរទេះគោផ្សេងពីគ្នា។ អាឡុង ជិះរទេះជាមួយគ្រួសារវា។ វាស្រែកមកកាន់ខ្ញុំដោយភាពរីករាយថា «អេ! អាហោង អញទៅនៅដីថ្មីហើយ អញលែងបានលេងហែលទឹក ជាមួយហ្អែងហើយ»។ «មិត្តទាំងអស់គ្នា! លាសិនហើយ ចាំស្រុកសម្បូរសប្បាយ ចាំយើងជួបគ្នា» អាឆាត ជាកុមារដែលមានមាឌធំជាងគេនៅក្នុងក្រុមពលកម្មស្រែកបន្ទាប់ពី អាឡុង។ វាស្រែកពីលើរទេះមកកាន់ក្រុមកុមារ ដែលកំពុងដើរកាប់ទន្រ្ទានខែត្រតាមដងផ្លូវ។

គ្រួសារអ្នក១៧មេសា បានដឹកជញ្ជូនឲ្យទៅរស់នៅដីថ្មីជាបន្តបន្ទាប់។ ពេលក្រោយៗមក យើងមានទឹកមុខស្រពាប់ស្រពោនណាស់ ព្រោះឮដំណឹងចុងមាត់ចុងកថា អ្នកទៅមុនៗ ត្រូវបានយកទៅវ៉ៃសម្លាប់ចោលនៅព្រៃភូមិស្រឡៅតូង ដែលជាតំបន់ព្រៃក្រាស់ក្នុងភូមិសាស្ត្រទឹកដីឃុំបល្ល័ង្កកំពង់ថ្ម ជាប់ព្រំប្រទល់ស្រុកចម្ការលើ ខេត្តកំពង់ចាម។

ជំនឿទំនៀមទម្លាប់ប្រពៃណី

ជំនឿវប្បធម៌ទំនៀមទម្លាប់ខ្មែរ ដែលមានតាំងពីយូរណាស់មកហើយ ត្រូវលុបបំបាត់ចោលទាំងស្រុង។ ការប្រណិប័តន៍សាសនា ពិធីបុណ្យ ការរៀបការ ការច្រៀងរាំកម្សាន្ត ត្រូវចាត់ទុកជាវប្បធម៌ចាស់គំរឹល ពាលាអាវាសៃ អន់ថយប្រតិកិរិយា នាំឲ្យខាតបង់ការងារពលកម្ម ត្រូវលុបបំបាត់ចោលទាំងស្រុង។ អង្គការតម្រូវឲ្យដើរតាមមាគ៌ាបដិវត្តន៍ដ៏ត្រឹមត្រូវ មហាលោតផ្លោះ មហាអស្ចារ្យ មហារុងរឿង។

ថ្ងៃមួយវេលាថ្ងៃជិតត្រង់នៅទីសក្ការៈវត្ត «ជើងចាស់» មានបុរសម្នាក់កំពុងលើកញញួរវាយកម្ទេចរូបព្រះពុទ្ធបដិមាឮសូរ កូសៗ រួចស្រែកថា «ពួកហ្អែង ឈរមើលស្អី ចង់ងាប់ឬ?» ជនដែលកាន់ញញួរ ចង្អុលមកកងកុមារ ដែលដើរកាត់ទីនេះ ដើម្បីឲ្យទៅធ្វើពលកម្មនៅជិតរោងស្ករត្នោត។ មួយរយៈក្រោយមក វត្តនោះក្លាយទៅជាទ្រុងចិញ្ចឹមជ្រូក។

ការរៀបអាពាហ៍ពិពាហ៍ តាមប្រពៃណីជាតិមិនមានទៀតទេ។ អង្គការជាអ្នករៀបការឲ្យ។ យុវជនពិការរបស់អង្គការ មានសិទ្ធិជ្រើសរើសយុវនារីតាមបំណង។ បុរសនារី ត្រូវតែទទួលយកគ្នាជាប្តីប្រពន្ធ តាមការចាត់ចែងរបស់អង្គការ។ ពិធីរៀបការត្រូវធ្វើឡើងដំណាលគ្នាក្នុងពេលតែមួយ ហើយមានជាច្រើនគូ។ ការចូលរួមរបស់ឪពុកម្តាយនិងបងប្អូនសាច់ញាតិមិនចាំបាច់ទេ។ ពិធីលៀងអាហារ ការរៀបចំពិធីតាមប្រពៃណី ការរាំកម្សាន្ត ពុំមានឡើយ។ កូនកំលោះកូនក្រមុំ ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ បង់កក្រមាថ្មី ដែលអង្គការទើបនឹងចែកឲ្យ ហើយត្រូវអង្គុយលើកៅអីជាជួរទល់មុខគ្នា ស្តាប់មតិយោបល់របស់អង្គការ ហើយចុងក្រោយគូស្វាមីភរិយាថ្មី ងើបឈរប្តេជ្ញាចិត្តស្មោះត្រង់ចំពោះអង្គការ។ អង្គការអនុញ្ញាតឲ្យប្តីប្រពន្ធថ្មីថ្មោងនេះ ឈប់សម្រាកពីការងារពលកម្មពីរបីថ្ងៃបន្ទាប់មក យើងត្រូវទៅធ្វើការតាមមុខព្រួញរៀងៗខ្លួន។

ចំណែកឯ សាកសព មិនមានធ្វើបុណ្យត្រូវរុំនឹងកន្ទេល យកទៅព្រៃភ្លាមៗ ដោយពុំរង់ចាំញាតិសន្តានចូលរួម ឬរៀបចំពិធីតាមជំនឿប្រពៃណី ទំនៀមទម្លាប់អ្វីឡើយ។

សុខាភិបាល

កុំថាឡើយជំងឺធ្ងន់ធ្ងរ សូម្បីតែកើតកមរមាស់ ទឹកស៊ីជើង អាត់ស៊ីដៃ ឈឺភ្នែក ក៏ពុំមានឱសថវេជ្ជសាស្ត្រសម្រាប់ព្យាបាលឡើយ។ សាប៊ូកក់សក់ សាប៊ូដុសខ្លួន សាប៊ូបោកខោអាវក៏គ្មានដែរ។ ប្រជាជនយកស្លឹកឈើ សំបកឈើ ឬឫសឈើ ផ្សែផ្សំធ្វើជាឱសថសម្រាប់ព្យាបាលជំងឺដោយខ្លួនឯង។

មន្ទីរពេទ្យអង្គការមួយកន្លែង ទីតាំងស្ថិតនៅវត្តពណ្ណាយ។ នៅលើសាលាធាន់មួយខ្នង មានអ្នកជំងឺច្រើនស្អេកស្កះ ភាគច្រើនជាស្ត្រីមានវ័យចំណាស់។ គ្រូពេទ្យដើរចែកថ្នាំឱសថសូនមូលៗ ដូចអាចម៍ទន្សាយឲ្យអ្នកជំងឺ។ ម្តាយរបស់ខ្ញុំក៏បានដូចគេគ្រប់ៗគ្នាដែរ។ នៅខាងកើតសាលាធាន់ មានអ្នកកាប់ចិញ្ច្រាំឫសឈើ មើមឈើ ស្លឹកឈើ និងសំបកឈើ ដែលហាលជាច្រើនកន្ទេលរាល់ថ្ងៃ។ នៅកន្លែងសម្រាកព្យាបាលជំងឺ សូរសេព្ទអឺងកង ខ្លះថ្ងូរ ខ្លះនិយាយ ទារកយំង៉ោងង៉ាង។ អ្នកជំងឺតេតាណូស ដែលពេទ្យចងភ្ជាប់នឹងគ្រែ ខ្លះស្រែកច្រៀង ខ្លះស្រែកដេរ។ ម្តាយរបស់ខ្ញុំ បានសម្រាកពេទ្យនៅទីនេះប្រហែលបីយប់ក៏ត្រលប់មកផ្ទះវិញ។

«អ្នកហុង! ទៅផ្ទះវិញ អើតមើលអាតូចកូនខ្ញុំផង ខ្ញុំមិនទាន់បានទៅទេ» មីងម្នាក់នៅភូមិជាមួយផ្តាំផ្ញើម៉ែរបស់ខ្ញុំ។

«មិនអីទេ អ្នកឃុត ចាំខ្ញុំអើតទៅមើលវាឲ្យ។ តោះ! អាហេង យកកំសៀវជាក់ក្នុងកន្ត្រកត្រលប់ទៅផ្ទះវិញ» ម្តាយរបស់ខ្ញុំវេចថ្នាំចំណាំងឈើជាក់ក្នុងថ្នក់ក្រមា រៀបចំចេញមកផ្ទះ។

ដីកស្មៅដីកទាំងឫស

ពាក្យ «ដីកស្មៅដីកទាំងឫស» ជាពាក្យដែលតែងតែនិយាយនៅក្នុងរបបខ្មែរក្រហម មានន័យថា «ក្នុងគ្រួសារ បើសមាជិកគ្រួសារណាម្នាក់ត្រូវអង្គការយកទៅសម្លាប់ គឺត្រូវសម្លាប់ចោលទាំងគ្រួសារ» ឬ មានន័យម្យ៉ាងទៀត «បើថ្នាក់ដឹកនាំឬកម្មាភិបាលណាម្នាក់ ត្រូវអង្គការថ្នាក់លើចោទថាក្បត់ សមាសភាពដែលជាសហការីក៏ក្បត់ដែរ ហើយត្រូវអង្គការយកទៅសម្លាប់ចោលទាំងអស់» ឬប្រើពាក្យភ្ជាប់គ្នាថា «ដីកស្មៅដីកទាំងឫស សម្លាប់មនុស្សសម្លាប់ទាំងពូជ»។

ប្រធានភូមិទី១ឈ្មោះ ម៉ង់ ចាប់ផ្តើមរឹតបន្តឹងនៅក្នុងភូមិបន្តិចម្តងៗ ចំពោះការរស់នៅរបស់ប្រជាជន ហើយក៏ចាប់ផ្តើមដឹកប្រជាជន១៧មេសាយកទៅឲ្យរស់នៅដីថ្មី។ ពួកគេដឹកប្រជាជនចេញពីភូមិដោយរទេះគោ ហើយឡើងរថយន្តដែលត្រៀមចាំជាស្រេចនៅលើកំណាត់ផ្លូវជាតិលេខប្រាំមួយបន្តទៅភូមិត្រពាំងឈូក ហើយបញ្ជូនយកទៅសម្លាប់ចោលនៅព្រៃស្រឡៅតូង។ មិនបានយូរប៉ុន្មានផង សមមិត្តប្រធានភូមិទី១នេះ ត្រូវអង្គការថ្នាក់លើ ស្នើឲ្យទៅរៀនសូត្រដែរ។ រីឯបក្សពួកខ្សែស្រឡាយ ត្រូវបាត់ខ្លួនជាបន្តបន្ទាប់។

ប្រធានភូមិទី២ ឈ្មោះ យៀន ឡើងកាន់កាប់អំណាចជំនួសប្រធានភូមិទី១។ ប្រធានភូមិឡើងថ្មីនេះ បានបន្តសកម្មភាពដឹកប្រជាជន១៧មេសា យកទៅនៅដីថ្មីដូចមុនដែរ ព្រមទាំងស្រាវជ្រាវយ៉ាងសកម្មរកមុខសញ្ញាខ្មាំងប្រឆាំងអង្គការបដិវត្តន៍។ ប្រជាជនមូលដ្ឋាន ដែលជាប់ខ្សែស្រឡាយកូនចៅចិន ចាម អ្នកធ្វើជំនួញ អ្នករដ្ឋការ អ្នករៀនបានខ្ពង់ខ្ពស់ និងអ្នកមាននិន្នាការនយោបាយពីសង្គមចាស់ ត្រូវស្នើឲ្យទៅរៀនសូត្រជាបន្តបន្ទាប់។ ចឹកបួយ ចាំង ចឹកហាក់ ធុង ជាអ្នកមានធនធានក្នុងភូមិ ត្រូវអង្គការចាប់យកទៅវ៉ៃសម្លាប់ចោលទាំងគ្រួសារ ហើយកូនចៅគ្រួសារទាំងពីរនេះ ក៏ត្រូវចាប់ខ្លួនយកទៅសម្លាប់ចោលជាបន្តបន្ទាប់ដែរ។

បងប្រុសទី១របស់ខ្ញុំឈ្មោះ លៀង និងមិត្តភក្តិរបស់គាត់ឈ្មោះ ខា ត្រូវអង្គការចាប់បង្ខំបញ្ជូនឲ្យទៅសមរភូមិមុខ។ ម្តាយរបស់ខ្ញុំ និងម្តាយរបស់ ខា នាំគ្នាយំទឹកភ្នែកហូរសស្រាក់ លន់តួសំពះអង្វរប្រធានភូមិថា «សូមសមមិត្ត កុំយកកូនខ្ញុំទៅអី វានៅក្មេងណាស់ ទុកវាសិនទៅ ខ្ញុំសុំសំពះ សមមិត្តបង»។ មិនបង្អង់យូរ ប្រធានភូមិឆ្លើយតបមកវិញភ្លាមៗថា «គ្រាន់តែប៉ុណ្ណឹងមិនហ៊ានលះបង់សមមិត្តនារីមិនដាច់ខាតចំពោះអង្គការ នេះមិនមែនជាជនបដិវត្តន៍ទេ» រួចប្រធានភូមិគំហកខ្លាំងៗទៀតថា «ទៅ! នាំវាទៅ! ចំណែកមិត្តនារីត្រូវទៅធ្វើការងារ កុំរឹងទទឹងនឹងមាគ៌ាបដិវត្តន៍ កង់ប្រវត្តិសាស្ត្រកំពុងវិល បើលូកដៃដាច់ដៃ លូកជើងដាច់ជើង»។ ឮដូច្នោះ កងឈ្លបក៏បាននាំយុវជនទាំងពីរនាក់ចាកចេញទៅ។

ក្រោមការគ្រប់គ្រងរបស់ប្រធានភូមិទី២នេះ ប្រជាជនអត់បាយក្រហាយទឹក លើសពីពេលមុនៗទៅទៀត ហើយដេកស្លាប់ស្ទើរជារៀងរាល់ថ្ងៃ។ ខ្ញុំឃ្លាន

ហៅហត់ស្ទើរទន់ជង្គង់ដើរឡើងឆ្លងផ្លូវលំពុំចង់រួច។ ថ្ងៃមួយពេលព្រលប់ ម៉ែរបស់ខ្ញុំទើបត្រលប់មកពីសហករណ៍វិញ ខ្ញុំសួរគាត់ថា «ម៉ែ! ម៉េចមិនយកគល់ចេកមកស្ងោរហូបទៀត?» ម៉ែតបតិចៗ ដោយប្រញាប់យកដៃមកខ្ទប់មាត់ខ្ញុំផងថា «កុំមាត់! មិនបានទេអាហោង ប្រធានភូមិក្រោយនេះមកពីខេត្តតាកែវ និយាយរដឹនៗ កាចសាហាវខ្លាំងណាស់ ហើយមានកងឈ្លបស៊ើបការណ៍តាមដានប្រជាជនគ្រប់ច្រកល្ហកទៀតផង ដេកទៅកុំមាត់! »។

យប់នេះខ្ញុំឃ្លានពេក ដេកមិនលក់ ខ្ញុំក៏ចុះទៅដី ដើម្បីទៅលួចដកកំផើមស្រូវក្នុងស្រែហូប។ មិនទាន់ទាំងចេញពីក្រោមផ្ទះផង ស្រាប់តែភ្លើងពិលវាសឆ្ងាចៗ ពីផ្លូវលំខាងមុខផ្ទះមក។ ខ្ញុំភ័យណាស់ក៏ប្រញាប់លាក់ខ្លួន ពួនអែបក្បែរជណ្តើរផ្ទះ។ ស្បែរាត្រីកាលដ៏ងងឹតអាប់អួរ បានមកគ្រប់មុខ បិទភ្នែកខ្ញុំ បង្ខំឲ្យលង់លក់ក្នុងដំណេកពោរពេញដោយក្តីស្រេកឃ្លានឥតឧបមា។

មិនយូរប៉ុន្មាន ប្រធានភូមិទី២ ត្រូវបានកម្មាភិបាលថ្នាក់លើចោទថាក្បត់អង្គការ ហើយត្រូវចាប់បញ្ជូនយកទៅឲ្យរៀនសូត្រលត់ដំខ្លួន។ អស់ពីប្រធានភូមិទី២ទៅ អង្គការបានចាត់ឲ្យមានប្រធានភូមិទី៣ ដែលមានឈ្មោះ កាញ់។ ពេលនោះ ខ្ញុំសង្កេតឃើញមានឈ្លបសន្តិសុខមុខប្លែកៗ ដែលមិនមែនជាមនុស្សធ្លាប់រស់នៅភូមិនេះទេ។ កងសន្តិសុខដែលគួរឲ្យខ្លាចជាងគេគឺឈ្មោះ រ័ត្ន។ រ័ត្នគឺជាជនពិការ ស្លៀកពាក់ពណ៌ខ្មៅ បង់កក្រមា ពាក់មួករបប ស្បែកជើងកង់ឡាន និងមានខ្សែអង្រឹងមួយចង្វាយ និងកាំបិតស្នៀតច្រកស្រោមជាប់នឹងចង្កេះ ហើយស្ពាយពិលមួយដើម ដែលលម្អដោយស្រោមរំយោល ថែមទាំងមានស្ពាយកាំភ្លើងអាកាបត់មួយដើមផងដែរ។

ក្នុងរយៈកាលនៃប្រធានភូមិទី១ និងទី២ ប្រជាជន១៧មេសា ត្រូវបានបោសសម្អាតទាំងស្រុង ហើយប្រជាជនមូលដ្ឋានដែលអង្គការចាត់ទុកថាជា «ព្រួនសង្គមទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ក៏កម្ទេចចោលជាបន្តបន្ទាប់ដែរ។ ប្រធានភូមិទី៣ នេះ រួមទាំងកងសន្តិសុខ បានបន្តតាមដានស៊ើបការណ៍សម្ងាត់ស្រាវជ្រាវបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុងពីក្នុងចំណោមប្រជាជន ដែលនៅសេសសល់ពីការកាប់សម្លាប់។ ឪពុករបស់ខ្ញុំ ត្រូវប្រធានសន្តិសុខឈ្មោះ រ័ត្ន ចាប់ខ្លួន ចងដៃ

នឹងខ្សែអង្រឹងក្រពត់មកក្រោយបណ្តើរលើខ្នងទំនប់ យកទៅទុកធ្វើទារុណកម្ម នៅមន្ទីរសន្តិសុខវត្តជ្រង ស្ថិតក្នុងឃុំឈូកខ្សាច់។ រយៈពេលប្រហែលបួនប្រាំថ្ងៃ គ្រួសាររបស់ខ្ញុំ និងគ្រួសារម្តាយមីង ត្រូវកម្មាភិបាលមកពីគណៈតំបន់ស្នើសុំប្រធានភូមិបឹង ដឹកដោយរទេះគោយកទៅនៅភូមិថ្មី ជាប់នឹងរបងមន្ទីរសន្តិសុខវត្តជ្រង។

ហានដ្ឋះអត់មនុស្សនៅ ហានផ្លូវអត់មនុស្សដើរ

ប្រជាជន១៧មេសាដែលរស់នៅក្នុងភូមិត្រូវអង្គការដឹកយកទៅសម្លាប់ចោលគ្មានសល់។ ប្រជាជនដែលអង្គការកំណត់មុខសញ្ញា «ខ្មាំងបដិវត្តន៍» ត្រូវចាប់ចងយកទៅសម្លាប់ចោលជាបន្តបន្ទាប់។ យុវជន ត្រូវចាប់បញ្ជូនទៅសមរភូមិមុខធ្វើកងទ័ពជាហូរហែ។ ប្រជាជនដេកស្លាប់ដោយអត់អាហារ ដោយជំងឺស្ទើរមិនចន្លោះថ្ងៃ។ ទីបំផុតប្រជាជននៃភូមិបឹងណុងម៉ូវ ដែលនៅសេសសល់ទាំងប៉ុន្មានត្រូវជម្លៀសចេញពីភូមិឲ្យទៅតាំងទីលំនៅក្នុងតំបន់ព្រៃក្រាស់។ ភូមិត្រពាំងឈូកនេះហើយ ដែលជាទីកន្លែងរស់នៅថ្មីរបស់ប្រជាជនភូមិបឹងណុងម៉ូវ រស់នៅលើគេហដ្ឋានប្រជាជនខ្មែរឥស្លាម។

ណុងម៉ូវ ធ្លាប់ជាភូមិដែលមានធម្មជាតិស្រស់បំព្រងព័ទ្ធជុំវិញដោយវាលស្រូវខៀវស្រងាត់ ឥឡូវប្រែជាស្រពោនក្រៀមក្រោះ មានស្មៅដុះស៊ុបទ្រុបស្លឹកឈើជ្រុះបើងរាយ កាំជណ្តើរធ្លាក់ជ្រុះរយើករយោក ហើយវល្លិ៍ព្រៃតោងជាប់ពេញជញ្ជាំងផ្ទះ គ្មានមនុស្សនៅមើលថែរក្សាទេ។

អរុណោទ័យថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ភ្លឺត្រចះត្រចង់ រះកម្ងាត់អ័ព្ទខ្មៅងងឹតនៃរបបកម្ពុជាប្រជាធិបតេយ្យ។ វាយោដើមរដូវ បក់មកពីទិសឧត្តរនាំមកនូវក្លិនពិភោរដ៏ក្រអូបប្រហើរនៃបុប្ផាធម្មជាតិ។ ទឹកសន្សើមពេលព្រឹកព្រលឹម ទើរលើចុងស្មៅត្រជាក់ស្រិប ចាំងរស្មីព្រិចៗដូចគ្រាប់ពេជ្រត្បូងចរណៃ។ ផ្កាផ្នក់ទឹកពណ៌លឿងខ្ចី ព្រឹក្សាព្រៃដុះលូតខៀវស្រងាត់ រីឯបក្សាបក្សី ត្រជាងស្លាបរំភើយលើវេហាស៍ មនុស្សម្នាខ្ញៀវខ្ញារើករាយសប្បាយ។ តែអនិច្ចា បឹងណុងម៉ូវ នៅតែក្រៀមស្វិត ឥតខ្លឹមសារ ក្លាយជាព្រៃស្មសាន ហានស្ងាត់ឈឹង ស្លាប់បាត់ព្រលឹង គ្មានម្ចាស់រក្សានៅ។ ឱភូមិខ្ញុំអើយ!។

ចប់

២១

ខ្សែជីវិតខ្មែក្រោម របបកម្ពុជាប្រជាធិបតេយ្យ

អ្នកនិពន្ធ ៖ កែវ សាន

២១ ~ ខ្សែជីវិតខ្ញុំក្រោមរបប កម្ពុជាប្រជាធិបតេយ្យ

«វាលវង្គសង្សារ មហាធំធេង សុទ្ធតែវង្វេង ក្នុងភពអន្ធការ យកចាញ់យកឈ្នះ ក្នុងអនត្តា មិនគិតអាត្មា កាយមិនមែនកាយ» នេះជាឃ្លាមួយក្នុងសំនៀងរបស់លោក ស៊ិន ស៊ីសាមុត តាំងពីសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ ប៉ុន្តែជីវិតរបស់ខ្ញុំដែលបានឆ្លងកាត់សង្គ្រាម និងការផ្លាស់ប្តូរក្នុងសង្គមជាតិច្រើនដំណាក់កាល ក៏មិនខុសអ្វីពីវាចារបស់អ្នកនិពន្ធបទចម្រៀងនេះដែរ។

ខ្ញុំគ្រាន់តែកើតមកឃើញពន្លឺព្រះអាទិត្យបាន៩ឆ្នាំប៉ុណ្ណោះ ខ្ញុំបានស្គាល់ភ្លើងសង្គ្រាមទៅហើយ។ ដំណើរឆ្លងកាត់ភ្លើងសង្គ្រាមច្រើនដំណាក់កាលនេះ ធ្វើឲ្យខ្ញុំស្គាល់រសជាតិជីវិតគ្រប់បែបយ៉ាង។ ក្នុងសម័យសង្គ្រាមឆ្នាំ១៩៧០ ដល់១៩៧៥ ក៏ដូចសម័យរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ដល់១៩៧៩ ខ្ញុំខំរិះរកវិធីរក្សាជីវិតឲ្យបានរួចផុតពីរបបដឹកនាំទាំងអស់នោះ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានប្រើវិធីសម្របខ្លួនផង ប្រឆាំងដោយស្ងាត់កំបាំងផង និងប្រឆាំងចំពោះមុខតិចតួចបំផុត។ ពេលនោះ ការកាន់កាប់របស់ពួកខ្មែរក្រហមនៅក្នុងភូមិរបស់ខ្ញុំមានភាពធូរលុងដែរ ពុំសូវអនុវត្តនយោបាយក្តៅគគុកដូចតំបន់ផ្សេងៗទៀតទេ ដូច្នេះបញ្ហា និងឧបសគ្គ ដែលខ្ញុំបានជួបប្រទះមិនធ្ងន់ធ្ងរលើសសមត្ថភាពរបស់ខ្ញុំដោះស្រាយឡើយ។

ខ្ញុំបានមើលឃើញចំណុចតូចមួយ គឺក្តីរីករាយដែលសេសសល់ក្នុងចន្លោះដ៏តូចចង្អៀតនៃទុក្ខសោកមហាសាល ដែលប្រជាជនមូលដ្ឋានដូចខ្ញុំទទួលបាន។ ក្នុងអារម្មណ៍បែបនេះ ខ្ញុំក៏សម្រេចចិត្តសរសេរអត្ថបទនេះឡើង ដែលបរិយាយពីជីវិតរបស់ខ្ញុំ ជាកុមារភាពក្នុងតំបន់រំដោះ ដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហម ដោយលើកយកភាពរីករាយ និងបទពិសោធន៍ផ្សេងៗ នៅពេលនោះមកតាក់តែង។

កុមារតំបន់រំដោះ

ភូមិអណ្តូងខ្មត់ ស្ថិតក្នុងឃុំសំបួរ ស្រុករមាសហែក ខេត្តស្វាយរៀង។ មុនឆ្នាំ១៩៧០ ភូមិនេះ រីកចម្រើនជាងគេ ហើយប្រជាជនមានជីវភាពធូរធារជាងភូមិដទៃទៀតក្នុងឃុំ។ ដីស្រែកម្មសិទ្ធិតាមគ្រួសារនីមួយៗគិតជាមធ្យមប្រហែល ៥ហិកតា មានគ្រួសារភាគតិចណាស់ ដែលមានដីស្រែតិចជាង៣ហិកតានោះ។ នៅក្នុងភូមិមានប្រជាជនប្រហែល៥០គ្រួសារ មានផ្ទះប្រក់ក្បឿង១៥ខ្នង ប្រកស័ង្កសី៣ខ្នង ក្រៅពីនោះផ្ទះប្រក់ស្លឹកត្នោត។

ក្រុមគ្រួសាររបស់ខ្ញុំមានដីស្រែជាង៨ហិកតា ផ្ទះប្រក់ក្បឿង មានវិទ្យុទោចក្រយាន រទេះ និងក្របី៦ក្បាល។ បងប្អូនរបស់ខ្ញុំទាំងអស់ បានចូលរៀនទាំងអស់។ ខ្ញុំបានរៀនត្រឹមតែថ្នាក់ទី៣ ប៉ុណ្ណោះ។ បើប្រៀបទៅនឹងប្រជាជនក្នុងភូមិ គ្រួសាររបស់ខ្ញុំស្ថិតក្នុងជីវភាពកម្រិតមធ្យម។

ខ្ញុំកើតនៅភូមិអណ្តូងខ្មត់ នៅឆ្នាំ១៩៦១។ នៅឆ្នាំ១៩៦៨ ដល់ ១៩៦៩ ខ្ញុំបានទៅរៀននៅសាលាអមលាំង ខេត្តកំពង់ស្ពឺ ហើយបានត្រលប់មករៀននៅក្រុងស្វាយរៀងវិញមុនថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០។ ជាអកុសល ការរៀនសូត្ររបស់ខ្ញុំត្រូវបានបញ្ចប់នៅពេលដែលខ្ញុំត្រលប់មកភូមិកំណើតវិញ ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ មកដល់ស្រុកកំណើត ភូមិរបស់ខ្ញុំ ត្រូវបានខ្មែរក្រហមកាន់កាប់រួចស្រេចទៅហើយ។ ខ្មែរក្រហម បានមកប្រជុំតាមភូមិយ៉ាងញឹកញាប់ក្នុងបំណងផ្សព្វផ្សាយពីមាគ៌ា និងគោលនយោបាយរបស់ពួកគេ។ ស្អែកឡើង ខ្ញុំទៅឃ្វាលក្របីនៅវាលស្រែជាមួយមិត្តភក្តិជាច្រើន ក្នុងនោះមាន

បង គង់ សេងនៅ ដែរ។ នៅពេលជុំគ្នាច្រើន បងសេងនៅ ដែលពូកែនិយាយកំប្លែងបានស្រែកពីលើខ្នងក្របីថា «បងប្អូនទាំងអស់គ្នាចាំស្តាប់ ខ្ញុំមានយោបល់»។ យើងទាំងអស់គ្នាក៏ឈប់ស្ងៀមចាំស្តាប់។

គាត់បន្តថា «បងប្អូនត្រូវរួមចំណែកវាយខ្ទាំង ហើយខំបង្កបង្កើនផលដូចជា ចិញ្ចឹមត្រកួន ដាំមាន់ ដាំទា ដាំគោក្របីជាដើម»។

ខ្ញុំសួរទៅគាត់ថា «ម៉េចក៏ទៅជាចិញ្ចឹមត្រកួន ដាំមាន់ដាំទាអីចឹង»។

គាត់និយាយថា «អើ!បើអង្គការនិយាយថា អីចឹង មិនឲ្យអញថាអីចឹងយ៉ាងម៉េច»។ ពួកយើងសើចហើយយកពាក្យនេះទៅប្រាប់គ្នាបន្តទៀត។ យើងដឹងថា ខ្មែរក្រហមមិនមែនជាអ្នកចេះដឹង សូម្បីតែនិយាយទៅកាន់ប្រជាជនក៏និយាយមិនត្រូវផងៗ ក្រៅពីបង សេងនៅ មានមិត្តរិន ក៏ពូកែខាងនិយាយលេងសើចដែរ។ ថ្ងៃមួយពេលរសៀល មិត្តរិន និងខ្ញុំ អង្គុយក្រោមដើមឈើមួយក្រោយពីបានដោតបង្កៀរួចហើយ។

មិត្តរិន សួរខ្ញុំថា«ហេតុអ្វីបាជាអង្គការនិយាយពាក្យ «ដើម្បី» ច្រើនម្ល៉េះ។ ខ្ញុំសួរមិត្តរិន ថានិយាយប៉ុន្មានដង។ មិត្តរិន ឆ្លើយថា «អញអត់បានរាប់ទេ»។ ខ្ញុំឲ្យយោបល់ថា ពេលអង្គការឡើងនិយាយឯងយកឈើគូសដីម្តងមួយៗ ទើបដឹងអង្គការនិយាយពាក្យ «ដើម្បី» ប៉ុន្មានដង។

ថ្ងៃក្រោយពេលជួបខ្ញុំ មិត្តរិន សើចហើយប្រាប់ខ្ញុំថា «អញរាប់ឃើញអង្គការនិយាយពាក្យ ដើម្បី ជិតហាសិបដង» យើងក៏នាំសើចទាំងអស់គ្នាទៅ។

យ៉ាងណា ខ្មែរក្រហម មិនទាន់រឹតត្បិតសេរីភាព និងបង្ខំប្រជាជនឲ្យអនុវត្តនូវគោលនយោបាយណាមួយនៅឡើយទេ។ ពួកគេព្យាយាមឃោសនាគោលនយោបាយរបស់ពួកគេតាមរយៈការសម្តែងសិល្បៈ។ ពួកគេឃោសនាពីវីរភាពរបស់អ្នកតស៊ូបដិវត្តន៍ និងបំផុសកំហឹងប្រឆាំងអ្នកជិះជាន់ និងចក្រពត្តិ។ មុនការសម្តែង មេភូមិ និងឈ្លប បានដើរប្រាប់ប្រជាជនតាមផ្ទះ ឲ្យត្រៀមហូបបាយឲ្យរួចរាល់ពីមេឃភ្លឺ ដើម្បីត្រៀមខ្លួនទៅមើលសិល្បៈតំបន់ដែលមកសម្តែងនៅពេលល្ងាច។

នៅល្ងាចថ្ងៃនោះ សំឡេងមេក្រូចាក់បទចម្រៀងបដិវត្តន៍បន្លឺឡើង ចិត្តខ្ញុំចាប់ផ្តើមពុះកញ្ជ្រោល ក៏ប្រញាប់ប្រញាល់យកក្របីទៅចង ហើយក្នុងចិត្តរំភើបចង់ទៅមើលសិល្បៈរបស់គេ។ ទៅដល់ផ្ទះ ម៉ែជាំស្លរួចជាស្រេច ខ្ញុំ និងបងប្អូនរបស់ខ្ញុំដែលជាក្មេងៗហូបបាយមុនបងៗ និងពុកម៉ែ។ ខ្ញុំហូបបាយមិនទាន់ឆ្អែតស្រួលបួលផង ក៏ជាក់ចានបាយចុះ រត់ទៅមើលគេរៀបចំឆាករហូតដល់គេសម្តែងនៅម៉ោង៧ល្ងាច។ ក្រុមសិល្បៈចាប់ផ្តើមពីចម្រៀង និងកាយវិការបែបបដិវត្តន៍ ហើយយប់ជ្រៅបន្តិចទើបចាប់ផ្តើមសម្តែងល្ខោន។ ប្រជាជនហាក់ជក់ចិត្តសម្លឹមណាស់ ទៅលើទស្សនីយភាព ដែលយើងកម្របានឃើញដូច្នេះប្រជាជនមកមើលស្ទើរតែគ្រប់គ្រួសារ។ ខ្ញុំអង្គុយនៅមុខគេក្នុងចំណោមអ្នកទស្សនាប្រហែលជា៥០០នាក់ ដែលមានមកពីភូមិក្បែរៗនោះ។ ខ្ញុំមិនបានយល់ជ្រួតជ្រាបមនោគមន៍វិជ្ជាបដិវត្តន៍ប៉ុន្មានទេ តែខ្ញុំសប្បាយរីករាយក្នុងចិត្តណាស់ដែលបានទស្សនាសិល្បៈម្តងៗ។ ខ្មែរក្រហម បានប្រកាសក្នុងអង្គប្រជុំហាមមិនឲ្យប្រជាជនស្តាប់ប៉ុស្តិ៍វិទ្យុណាដែលប្រឆាំងនឹងបដិវត្តន៍ទេ តែប្រជាជននៅតែលួចស្តាប់។

ពុករបស់ខ្ញុំចូលចិត្តស្តាប់ប៉ុស្តិ៍ប៊ែកាំងណាស់។ វាជាប៉ុស្តិ៍ដែលខ្មែរក្រហមអនុញ្ញាតឲ្យស្តាប់។ បើឪពុករបស់ខ្ញុំដឹងថាមានសំឡេងសម្តេចឪនៅក្នុងមាតិកាហើយ គាត់នៅរង់ចាំស្តាប់រហូតដល់ចប់កម្មវិធី។ ចំណែកខ្ញុំ និងបងប្អូនរបស់ខ្ញុំជាក្មេងៗតែងតែឆ្លៀតស្តាប់ប៉ុស្តិ៍ភ្នំពេញ ព្រោះមានកម្មវិធីសិល្បៈច្រើន។ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងស្តាប់ប៉ុស្តិ៍ភ្នំពេញទេ សូម្បីតែបទចម្រៀងពីដើមៗក៏គេមិនអនុញ្ញាតឲ្យស្តាប់ដែរ។

សង្គ្រាមរវាងខ្មែរក្រហម និងរដ្ឋាភិបាល លន់ នល់ ពីមួយឆ្នាំទៅមួយឆ្នាំកាន់តែមានសភាពខ្លាំងឡើងជាបន្តបន្ទាប់។ ការឃោសនា ត្រូវបានធ្វើទូទាំងតំបន់រំដោះ ទាំងទ្រង់ទ្រាយតូច ទាំងទ្រង់ទ្រាយធំ។ ថ្ងៃមួយ ម៉ែរបស់ខ្ញុំ ត្រលប់មកពីប្រជុំវិញ បាននិយាយប្រាប់កូនៗថា អង្គការឲ្យយើងប្រុងប្រយ័ត្នកុំឲ្យចាញ់ការឃោសនារបស់ខ្មាំង ព្រោះគេថាខ្មាំងយកការបដិវត្តន៍វាយបដិវត្តន៍។

គេថាខ្មាំងបានលើកពាក្យជួនថា «បំបាត់នាយទុនបញ្ចេញអង្គការ បំបាត់ពន្ធដារ បញ្ចេញវិភាគទាន បំបាត់អ្នកមានបញ្ចេញអ្នកក្រ បំបាត់អាវពណ៌បញ្ចេញអាវខ្មៅ បំបាត់អ្នកចេះបញ្ចេញអ្នកខ្លៅ បំបាត់ប្រៀនប្រដៅបញ្ចេញលត់ដំ»។ និយាយរួច គាត់សើចហាក់ដូចជាចំអកឲ្យអ្នកនិយាយពាក្យនេះ។

ក្នុងគោលដៅបំបាត់អំពើជិះជាន់ និងការកេងប្រវ័ញ្ច អង្គការបដិវត្តន៍បានប្រកាសឲ្យប្រជាជនក្នុងតំបន់រំដោះឈប់ចាយលុយ ហើយយកលុយប្រគល់ជូនអង្គការវិញ។ នៅចុងខែតុលា ឆ្នាំ១៩៧៤ ខ្ញុំឃើញគណៈឃុំម្នាក់ ប្រធានភូមិម្នាក់ ឈ្លបឃុំបីនាក់ លីការ៉ុងដើរប្រមូលលុយតាមផ្ទះប្រជាជន។ ពុកម៉ែរបស់ខ្ញុំមានលុយច្រើន ព្រោះពួកគាត់រកបានពីលក់ស្រូវ ជ្រូក ទៅឲ្យផ្សារងងឹតរបស់ពួកយៀកកុង និងលក់ស្រាឲ្យអ្នកភូមិ។ គាត់បានញាត់លុយបាន ៥កេសគ្រាប់បែក រួចយកទៅកប់ក្នុងដីក្បែរជើងសសរផ្ទះ។ ពេលអង្គការមកប្រមូលលុយពុកម៉ែរបស់ខ្ញុំប្រាប់ថា «ខ្ញុំចាយលុយអស់ហើយនៅសល់តែបន្តិចបន្តួចជូនអង្គការ»។ គាត់ក៏ហុចលុយប្រហែលជាប៉ុន្មានពាន់រៀលប៉ុណ្ណោះឲ្យទៅអ្នកមកប្រមូល។ ពួកគេមិនបានសួរដេញដោលអ្វីទេ ដោយសារមិនបានដឹងថា ពុកម៉ែរបស់ខ្ញុំមានលុយច្រើន។

ថ្ងៃជ័យជម្នះ ១៧មេសា

ពេលវេលាពោរពេញដោយមោទនភាពរបស់ប្រជាជនតំបន់រំដោះបានមកដល់ នៅពេលដែលដំណឹងជ័យជម្នះតាមសមភូមិនានា បានផ្សាយចេញពីវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា សារព័ត៌មានពន្លឺបូព៌ា និងការប្រកាសប្រាប់ពីអង្គការបដិវត្តន៍។ នៅក្នុងពិធីបុណ្យចូលឆ្នាំខ្មែរឆ្នាំ១៩៧៥ មានយុទ្ធជន យុទ្ធនារី កម្មាភិបាលថ្នាក់ស្រុក យុវជន និងប្រជាជនក្មេងចាស់ ចូលរួមពិធីបុណ្យចូលឆ្នាំនៅវត្តត្បែងរាំ។ កម្មាភិបាល ឈ្លប និងតំណាងអង្គការស្រុក ឡើងប្រកាសពីក្តីសង្ឃឹមដែលជ័យជម្នះនឹងមកដល់នៅពេលឆាប់ៗខាងមុខ អមដោយសំឡេងអបអរស្រែកជយឃោស។ ខ្ញុំ ក៏មានវត្តមានក្នុងចំណោមក្មេងចាស់ជាច្រើននៅក្នុងវត្តដែរ។ ពេលនោះ ល្បែងប្រពៃណីខ្មែរ យើងនៅតែបន្តលេង តែត្រូវប្តូរទំនុក

ឬបែបបទទៅជាបែបបទដិវត្តន៍វិញ ដូចជាពេលដែលយើងលេងបោះឈូង យើងនៅលេងធម្មតាប៉ុន្តែត្រូវច្រៀងបទបដិវត្តន៍ថា «ខ្ញុំបោះឈូងទៅមិត្តអើយ ឈូងតំរមេញពួកអាភ្នំពេញ មិត្តអើយ ជិតដល់ថ្ងៃបរាជ័យ»។ មានទំនុកច្រៀងជាច្រើនទៀតដែលប្រជាជនច្រៀងពេលលេងបោះឈូង ដែលមានអត្ថន័យប្រឆាំងរបបលន់ នល់ និង អាមេរិក ជាដើម។

ពេលហូបបាយថ្ងៃត្រង់រួច ពុកម៉ែរបស់ខ្ញុំ សម្រាន្ត ខ្ញុំយកវិទ្យុមកបើកស្តាប់ឆ្ងាយពីគាត់។ វិទ្យុភ្នំពេញពេលនោះមិនសូវផ្សាយពីការលេងកម្សាន្តទេ ច្រើនតែផ្សាយពីការប្រកាសរឹតបន្តឹងសន្តិសុខដូចជាការបិទចរាចរណ៍ពីម៉ោង៦ល្ងាចដល់ម៉ោង៦ព្រឹក និងវិធានការផ្សេងៗទៀតជាច្រើន។ ដោយសារផ្ទះរបស់ខ្ញុំមានរបងឫស្សីព័ទ្ធជុំវិញ និងមានឆ្កែធំៗពីរក្បាលផងនោះ គ្រួសាររបស់ខ្ញុំ អាចបើកវិទ្យុប៉ុស្តិ៍ភ្នំពេញស្តាប់ រាល់ថ្ងៃបានដោយមិនសូវបារម្ភទេ។ សភាពការណ៍ក្រុងភ្នំពេញកាន់តែតឹងតែង ចំណែកឯពុកម៉ែរបស់ខ្ញុំកាន់តែតាមដានខ្លាំងជាងមុនទៅទៀត។ ព្រឹកថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ បន្ទាប់ពីស្រោចដំណាំក្បែរផ្ទះរួច ខ្ញុំឡើងទៅលើផ្ទះហើយយកវិទ្យុមកបើកប៉ុស្តិ៍ភ្នំពេញស្តាប់។ ខ្ញុំមិនឮមានកម្មវិធីអ្វីសោះ មានតែភ្លេងសុទ្ធរហូត។ នៅម៉ោងជិត១០ព្រឹកពេលដែលខ្ញុំកំពុងធ្វើការ ខ្ញុំងាកទៅទ្វាររបងផ្ទះ ឃើញលោកបង គឹមសិន ដែលបួសនៅវត្តត្បែងរាំ និមន្តយ៉ាងលឿនសំដៅមកផ្ទះយើង។ ពេលមកដល់មុខផ្ទះ លោកបងក៏មានដីកាទាំងត្រហេបត្រហបថា «ឯណាញោមទៅណាហើយ មានបើកវិទ្យុស្តាប់ទេ គេវាយបែកភ្នំពេញហើយ»។ ពុកម៉ែរបស់ខ្ញុំ ក៏ប្រើខ្ញុំឲ្យឡើងទៅបើកវិទ្យុនៅលើផ្ទះ។ ពេលបើកវិទ្យុ ខ្ញុំឮមេទ័ពខ្មែរក្រហម និយាយតាមវិទ្យុថា «កងទ័ពបដិវត្តន៍យើងបានរំដោះក្រុងភ្នំពេញបានទាំងស្រុងនឹងជាស្តាពរ ដោយការប្រយុទ្ធយ៉ាងស្វិតស្វាញគ្មានចរចា គ្មានសម្រុះសម្រួលអ្វីទាំងអស់ យើងខ្ញុំសូមអញ្ជើញលោក លន់ នល់ មកកាន់ទីចាត់ការជាបន្ទាន់»។ បន្ទាប់មកមនុស្សម្នាក់ទៀតនិយាយតាមវិទ្យុថា «ខ្ញុំសូមអញ្ជើញលោក សុខ សុខុន និងលោក ចាប ឆុន មកជួបខ្ញុំនៅមន្ទីរយោសនាការ ខ្ញុំ ឋេន ជឿន»។ បន្ទាប់ពីឆាន់ចង្ហាន់ថ្ងៃត្រង់រួច លោកបង គឹម សិន

មិនទាន់និមន្តទៅវត្តវិញទេ លោកបងមកក្បែរពុកម៉ែ ហើយមានសង្ឃដីកាថា «ញោមអើយ កាលសង្គ្រាមវាយចក្រពត្តិស្លាប់មនុស្សប៉ុណ្ណឹង ដល់ពេលសង្គ្រាមវាយវណ្ណៈស្លាប់មនុស្សលើសនឹងច្រើនដងទៀត»។ ខ្ញុំនៅអង្គុយក្បែរនោះដែរ ក៏ស៊កសម្តីបន្តិចថា «បើអីចឹង ឯករាជ្យម្តងហ្នឹង មិនដូចឯករាជ្យមុនទេ»។ ឮដូច្នេះ ម៉ែគំរាមខ្ញុំថា «ឯងជាកូនក្មេងកុំមាត់រអិលពេក»។ ប្រជាជនក្នុងភូមិភាគច្រើនសប្បាយរីករាយនឹងជ័យជម្នះនេះ មេគ្រួសារខ្លះលោតតន្ត្រំរហូតដល់បាក់រនាបផ្ទះ។

ពេលល្ងាចលោកបង គឹម ស៊ន និមន្តត្រលប់ទៅវត្តវិញ ខ្ញុំសង្កេតឃើញពុកម៉ែរបស់ខ្ញុំ មានទឹកមុខស្រពាប់ស្រពោន ហាក់ដូចជាមានវិបត្តិអ្វីក្នុងចិត្តរបស់ពួកគាត់។ ក្រោយជ័យជម្នះនេះ ការរស់នៅរបស់ប្រជាជនមិនទាន់មានការប្រែប្រួលភ្លាមទេ ដោយសារអង្គការបញ្ឈប់ការចាយលុយតាំងពីឆ្នាំ១៩៧៤ មក។ ដូច្នេះ ការទិញដូរភាគច្រើន គេយកតម្លៃស្រូវធ្វើជាគោល ទៅដូររបស់របរផ្សេងៗ។

ក្រោយជ័យជម្នះរបស់ខ្មែរក្រហមមក ប្រជាជនតាមទីប្រជុំជននានា ត្រូវជម្លៀសទៅតាមទីជនបទ។ ពុករបស់ខ្ញុំ មានប្អូន២គ្រួសារ ដែលរស់នៅក្រុងស្វាយរៀង គឺគ្រួសាររបស់មីងនាង និងពូខែ។ ពួកគាត់ ក៏ត្រូវខ្មែរក្រហមជម្លៀសដូចប្រជាជនដទៃនៅក្រុងស្វាយរៀងដែរ។ ជាងពីរសប្តាហ៍ហើយដែលពុកម៉ែរបស់ខ្ញុំ ទន្ទឹងរង់ចាំដំណឹងពីពួកគាត់ ហើយយើងមិនមានដំណឹងអ្វីទាល់តែសោះ។ មួយសប្តាហ៍ក្រោយថ្ងៃ១៧ មេសា មក ប្រជាជនថ្មី បានមកដល់ភូមិរបស់ខ្ញុំជាបណ្តើរៗ។ យើងទាំងអស់គ្នាបារម្ភពីគាត់ខ្លាំងណាស់។ នៅរសៀលថ្ងៃមួយដើមខែឧសភា ឆ្នាំ១៩៧៥ អ្នកភូមិម្នាក់ បានដើរកង់ពីភូមិព្រែកត្នោតមកប្រាប់យើងថាគាត់ឃើញមីងនាង បណ្តើរកង់មក។ យើងទាំងអស់គ្នា សប្បាយចិត្ត ខ្ញុំនឹងបងប្អូនរបស់ខ្ញុំ រត់ប្រញាប់ប្រញាល់ទៅទទួលគាត់នៅពាក់កណ្តាលផ្លូវ។ ខ្ញុំជម្រាបសួរពូមីងបងប្អូន និងជួយកាន់អីវ៉ាន់របស់គាត់។ ពុកម៉ែរបស់ខ្ញុំសប្បាយចិត្តណាស់ គាត់ប្រញាប់សួរកប្អូនប្រុសរបស់គាត់។ មីងប្រាប់ថា «ប្អូនប្រុសរបស់គាត់ទៅនៅស្រុកខាងប្រពន្ធហើយ»។ ដោយសារយើងរស់នៅតែពីរគ្រួសារជាបងប្អូន

បង្កើតដូច្នេះ ពុកម៉ែរបស់ខ្ញុំ បានលួចកាប់ជ្រូកតូចៗធ្វើម្ហូបឲ្យបានមុនប្រធានភូមិមកចុះជ្រូកនោះក្នុងបញ្ជីរបស់ពួកគេ។ ពុករបស់ខ្ញុំ បានទៅពឹងប្រជាជនថ្មីម្នាក់ដែលស្និទ្ធស្នាលនឹងគ្នាឈ្មោះ សារាយ ឲ្យមកជួយកាប់ជ្រូកហូប។ នៅពេលថ្ងៃជិតលិច គាត់វាយសម្លាប់ជ្រូកតូចៗ បីក្បាលមិនឲ្យស្រែកឮឡើយ។ ពេលកាប់ជ្រូករួចរាល់ហើយ យើងបានបោសសម្អាតកាកសំណល់យកទៅកប់ក្នុងរណ្តៅដើម្បីកុំឲ្យគេសង្ស័យ។ ពុកម៉ែរបស់ខ្ញុំ បានឲ្យសាច់ជ្រូកទៅពូសារាយ និងលៃលកទុកហូបថ្ងៃក្រោយខ្លះ។

ពីកងកុមារភូមិ ទៅកងចល័ត

នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានអង្គការចាត់ចូលក្នុងកងកុមារតាំងពីឆ្នាំ ១៩៧៥ មកម្លេះ ហើយ ឲ្យខ្ញុំឃ្វាលក្របីជាប្រចាំ។ ឃ្លៀងម្តង ខ្ញុំក៏ត្រូវបានអង្គការចាត់ឲ្យសែងលាមកមនុស្ស ដើម្បីធ្វើជីដែរ។ ការងារទាំងនោះ នៅមិនទាន់ចាត់ទុកថាជាការងារធ្ងន់ធ្ងរនៅឡើយទេ។ ក្រៅពីការងារនេះ កុមារត្រូវទទួលការអប់រំបំពាក់បំប៉នមនោគមន៍វិជ្ជារបស់បដិវត្តន៍នៅពេលរៀន ប្រជុំ និងការបំពាក់បំប៉នតាមរយៈសិល្បៈ។ ការប្រជុំធ្វើឡើងនៅម៉ោង៦ល្ងាច ប្រហែលជាកន្លះម៉ោង ដែលមានការចូលរួមពីផ្នែកវប្បធម៌ភូមិ។ អង្គការប្រជុំកុមារ ដើម្បីអប់រំសតិអារម្មណ៍កុមារឲ្យស្របតាមមាគ៌ាបដិវត្តន៍របស់អង្គការ។ បើគ្មានផ្នែកវប្បធម៌ភូមិចូលរួមក្នុងការប្រជុំនោះទេ វាធ្វើឡើងត្រឹមតែ១០នាទីតែប៉ុណ្ណោះ ព្រោះពួកកុមារយើងប្រញាប់រាំច្រៀងលេងកម្សាន្ត។ ក្មេងៗក្នុងភូមិរបស់ខ្ញុំប្រហែល២០នាក់ មានខ្ញុំ មិត្តសឿន និងមិត្តចាន់ប៉ា ជាអ្នកចម្រៀងប្រុស ហើយមិត្តភឿន មិត្តសាមី មិត្តណន និងយីម ជាអ្នកចម្រៀងស្រី ហើយនឹងក្មេងៗដទៃទៀតជាអ្នកវាយស្គរ អ្នកឡកឆែយ៉ាំ និងអ្នករាំ។ យើងសប្បាយរីករាយយ៉ាងខ្លាំង ហើយយើងមិនសូវខ្វល់ខ្វាយពីមនោគមន៍វិជ្ជាបដិវត្តន៍របស់ខ្មែរក្រហមប៉ុន្មានទេ បើទោះជាគ្រប់ទំនុកច្រៀងសុទ្ធតែជាបទបដិវត្តន៍ក៏ដោយ។ យើងភាគច្រើនច្រៀងរាំនៅពេលខែភ្លឺ ហើយយើងសប្បាយនឹងរាំច្រៀងទៅតាមលំនាំបទភ្លេងពីសង្គម។

ដើមខែមករា ឆ្នាំ១៩៧៧ ខ្ញុំមានអាយុ១៧ឆ្នាំ ជាពេលដែលខ្ញុំចេញពីកងកុមារចូលទៅកងចល័ត។ រសៀលថ្ងៃមួយ មានគេមកប្រាប់ខ្ញុំថា ខ្ញុំមានឈ្មោះទៅកងចល័ត។ ខ្ញុំមិនមានការព្រួយបារម្ភប៉ុន្មានទេ ព្រោះខ្ញុំដឹងថាការងារពេលនោះមិនសូវតឹងរឹង ឯបាយក៏សម្បូរដែរ គ្រាន់តែម្តូបមិនសូវឆ្ងាញ់។ ខ្ញុំទៅដល់កន្លែងនោះនៅពេលល្ងាច តែខ្ញុំខកចិត្តយ៉ាងខ្លាំង ព្រោះពេលចេញពីផ្ទះគេប្រាប់ថាឲ្យខ្ញុំថានៅកងបង ម៉ន ដែលនៅភូមិជាមួយគ្នា តែពេលមកដល់បែរជានៅកងផ្សេងទៅវិញ។ ការងារដែលខ្ញុំធ្វើនៅកងចល័តនោះ ជាការងារធម្មតា ដែលអ្នករស់នៅជនបទបានធ្វើដូចជា ច្រូតស្រូវ លើកភ្លឺស្រែ និងជីកប្រឡាយ ដោយមិនមានដាក់កំណត់ ឬបង្ខំឲ្យធ្វើធ្ងន់ធ្ងរនោះទេ។ ទោះជាយ៉ាងណា ជីវិតរបស់ខ្ញុំបានធ្លាក់ក្នុងស្ថានភាពងងឹតដូចគ្នា ព្រោះយើងបានបាត់អស់ហើយនូវសិទ្ធិក្នុងការដើរហើរ និយាយស្តី ការអប់រំត្រឹមត្រូវ ឬការទទួលបានការគាំពារសុខភាព។

ការងារលើកប្រព័ន្ធភ្លឺស្រែ និងជីកប្រឡាយក្នុងឃុំសំបួរ បានបញ្ចប់រួចរាល់នៅចុងខែឧសភា ឆ្នាំ១៩៧៧។ ក្រោយមក អង្គការលើកទិសដៅបញ្ជូនកងចល័តឃុំ ឲ្យទៅជាកងចល័តស្រុកវិញ។ ពេលកងចល័តថ្នាក់ឃុំ អង្គការតម្រូវឲ្យកងនីមួយៗ មានមនុស្សមកពីគ្រប់ភូមិរស់នៅចម្រុះគ្នា តែផែនការនេះអនុវត្តន៍ បានតែយុវជន ឯយុវនារីប្រកែក ហើយទាមទាររស់នៅតាមភូមិ គឺប្រធានកងនៅភូមិណាសមាជិកនៅភូមិនោះដែរ។ ពេលរៀបចំឲ្យទៅជាកងចល័តស្រុក អង្គការចង់ឲ្យសមាសភាពក្នុងកងមានមនុស្សមកពីគ្រប់ឃុំ។ ឈ្មោះប្រធានកងធំ និងប្រធានកងតូចត្រូវបានប្រកាសតាមឧគ្ឃោសនាសព្ទ។ ខ្ញុំរង់ចាំស្តាប់ក្រែងឮឈ្មោះប្រធានកងទៅពីឃុំសំបួរ តែខ្ញុំមិនឮសោះ។ ខ្ញុំ នាំគ្នាដើរទៅចូលកង ដែលយើងមិនស្គាល់ឈ្មោះប្រធានពីមុនមក ហើយប្រាប់ឈ្មោះយើងឲ្យប្រធានកងសរសេរចូលក្នុងបញ្ជី។ ប៉ុន្តែខ្ញុំសំណាងល្អ ព្រោះខ្ញុំប៉ះចំប្រធានកងស្លូតបូត។ ការរៀបចំកងផ្នែកយុវជនបានរួចរាល់នៅម៉ោងប្រហែល ១រសៀល ឯការរៀបចំកងយុវនារីមានការលំបាកច្រើន ដោយសារពួកនាងមិនចង់បែកពីអ្នកភូមិជាមួយគ្នាទេ។ ពេលអង្គការ ប្រកាសហៅឲ្យចូលជួរ ពួកនាងដើរយឺតៗដោយយកក្រមាបាំងមុខ

ព្រោះនាងកំពុងយំ ឯអ្នកមិនទាន់ចូលជួរ នាំគ្នាអង្គុយឈ្លោក ខ្លះយកក្រមាខ្ទប់មុខយំ មើលទៅគួរឲ្យអាណិត។ យើងត្រូវទៅរស់នៅទីតាំងដាច់ដោយឡែកសម្រាប់កងចល័តនៅព្រៃតារាម ក្នុងឃុំក្រសាំង។ នៅពេលនោះ យើងត្រូវបានចាត់តាំងឲ្យធ្វើការដកស្ទូង ច្រូតកាត់ និងកាប់ព្រៃជាដើម។

ល្ងាចថ្ងៃមួយ ប្រធានកង បានប្រកាសប្រាប់កងចល័តរបស់ខ្ញុំថា ថ្ងៃស្អែកអង្គការឲ្យទៅចាប់ខ្មាំង។ កងចល័តទាំងអស់ ក្នុងស្រុកក្រសាំងដែលមានគ្នាជិតមួយពាន់នាក់ ជាមួយប្រជាជនសហការណ៍រាប់រយនាក់ផ្សេងទៀត ត្រូវបានអង្គការចាត់ឲ្យស្វែងរកខ្មាំងដែលបានរត់គេចពីយោធាតំបន់តាំងឆ្នាំ១៩៧៦ មកម្ល៉េះ។ យោធាម្នាក់ឈ្មោះ ប៉ែន ផន បានរត់ចេញពីអង្គភាពយោធាតំបន់មកផ្ទះ ហើយនាំឪពុករត់ចូលព្រៃលាក់ខ្លួននៅព្រៃបិទមាស។ កងចល័ត ត្រូវអង្គការចាត់តាំងឲ្យរុកព្រៃបីថ្ងៃ។ ពេលព្រលឹមឡើងមេកង បានហៅប្រជុំមុនចេញដំណើររុកព្រៃ។ ខ្ញុំមិនចង់ទៅរុកក្នុងព្រៃទេ ព្រោះព្រៃនោះក្រាស់ លំបាករុកណាស់។ ខ្ញុំក៏ធ្វើពុតជាឈឺ។ ខ្ញុំបានប្រាប់មេកងថា ខ្ញុំឈឺក្បាល ខ្ញុំមិនអាចទៅរុកព្រៃបានទេ។ មេកង ព្រមអនុញ្ញាតឲ្យខ្ញុំសម្រាក។ ករណីតាមចាប់យោធានេះធ្វើឲ្យខ្ញុំកាន់តែមើលឃើញពីគុកឥតជញ្ជាំងរបស់ខ្មែរក្រហម។ អ្នកដែលប្រឆាំងឬមិនចង់រស់នៅក្រោមការដឹកនាំរបស់ខ្មែរក្រហម គឺត្រូវបានអង្គការចាត់ទុកជាខ្មាំងហើយត្រូវតាមចាប់ឲ្យទាល់តែបាន។ នៅចុងឆ្នាំ១៩៧៧ ឪពុកកូនទាំងពីរនាក់នោះ ត្រូវបានយោធា ដែលមានការសហការជាមួយប្រជាជន និងកងចល័តចាប់បាន។ នេះធ្វើឲ្យខ្ញុំដឹងថា យើងរឹតតែមិនអាចប្រឆាំងជាមួយអង្គការបាន។

សំឡៀងសង្គមចាស់

នៅរដូវចម្រូតនាដើមខែវិច្ឆិកាឆ្នាំ១៩៧៧ ប្រធានកង បានចាត់ឲ្យខ្ញុំកាប់មែកឈើធ្វើស្លាបកណ្តៀវ។ រសៀលនោះ ខ្ញុំកំពុងរកកាប់ឈើក្នុងព្រៃតារាមតែម្នាក់ឯង ស្រាប់តែឮសំឡេងនារីច្រៀងចម្រៀងពីសង្គមចាស់របស់អ្នកនាងរស់ សេរីសុទ្ធា ថា «ភូមិត្រពាំងសាបកុលាបរោយស្ងួត! ឱ!ព្រហ្មលិខិតប្រហារខ្ញុំទៅ!»។ សំនៀងនេះ ប្រហែលជាអត្ថន័យនៃជីវិតរបស់នារីម្នាក់នោះ ដែល

កំពុងតែជួបប្រទះហើយ។ គ្រាន់តែផុតកន្ទុយសំឡេងភ្លាម ខ្ញុំ ក៏ស្រែកច្រៀងបទលោក ស៊ិន ស៊ីសាមុត តបទៅវិញថា «រំអើយកុំយំឲ្យខ្ញុំទឹកភ្នែក! តឹងទ្រូងស្ទើរបែក រំលែកទុក្ខផង!»។ ខ្ញុំហាក់ឆ្លើយតបយ៉ាងលឿន ហើយអត្ថន័យនៃបទចម្រៀងក៏បង្ហាញពីទុក្ខសោកដែលខ្ញុំជួបប្រទះខ្លះៗដែរ។ នារីអ្នកច្រៀងនោះក៏ស្រែកថា «យើ!» ហើយខ្ញុំដើរចេញពីទីនោះយ៉ាងលឿន ព្រោះខ្លាចគេដឹងថាខ្ញុំជាអ្នកច្រៀង នាំឲ្យមានរឿងមិនល្អដល់ខ្លួន។

អាពាហ៍ពិពាហ៍មិនស្គាល់គ្នា

ដំណឹងស្តីពីការរៀបការជាក្រុមបានឮសុះសាយក្នុងជួរកងចល័ត និងសហករណ៍ តាំងពីដើមខែ ខែតុលា ឆ្នាំ១៩៧៨។ យុវជននៅលីវជាច្រើនហាក់ដូចជាជ្រួលច្របល់ខ្លាចឱកាសនេះកន្លងផុតទៅ។ ខ្ញុំបបួលមិត្តរបស់ខ្ញុំ ៣នាក់ទៀត គឺមិត្តយឿ មិត្តយឿន និងមិត្តលី សន្យាគ្នាថា កុំទាន់យកប្រពន្ធ។ ពួកយើងបានសន្យាជាមួយគ្នា តែកិច្ចសន្យារវាងពួកយើងទាំង៤នាក់ ត្រូវរបេះម្តងមួយៗ ហើយទីបំផុតនៅសល់តែខ្ញុំម្នាក់ ដែលកំពុងរវែករៀបការ។ មិនយូរប៉ុន្មាន មិត្តរបស់ខ្ញុំ មានគូរៀងខ្លួន ឯខ្ញុំនៅតាំងចិត្តថានៅលីវមួយរយៈសិន។ ដោយសារពុកម៉ែ និងបងៗរបស់ខ្ញុំលួងលោមញយៗ ខ្ញុំក៏ទន់ចិត្តព្រមឲ្យគាត់រកប្រពន្ធឲ្យខ្ញុំ។ ដំណឹងល្អក៏បានឮដល់ត្រចៀកខ្ញុំ គឺខាងនារីគេយល់ព្រមរៀបការជាមួយខ្ញុំ។ ប៉ុន្តែប្រហែលជាបីថ្ងៃក្រោយមក បែរជាឮដំណឹងអាក្រក់ថាខាងស្រីគេផ្តាច់ទំនាក់ទំនងមិនរៀបការជាមួយខ្ញុំវិញ។ ពេលកំណត់ថ្ងៃរៀបការជាក្រុមកាន់តែខិតជិតមកដល់ មិត្តភក្តិរបស់ខ្ញុំចេះតែឌឺដងជាក់ខ្ញុំ។ ល្ងាចមួយខ្ញុំទៅលេងផ្ទះ ម៉ែរបស់ខ្ញុំប្រាប់ថា «ប្រធាននារីភូមិ លើកកូនក្រមុំឲ្យឯង បើឯងព្រមគេធានាសុំប្បាប់ការលើគេទាំងអស់» តែខ្ញុំបដិសេធដាច់ខាត។ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៨ ជាថ្ងៃកំណត់រៀបការ ហើយខ្ញុំសង្ឃឹមថានឹងអាចរួចពីចំណងនេះ។ ស្រាប់តែនៅថ្ងៃទី២២ ខែតុលា បងស្រីរបស់ខ្ញុំបានមកប្រាប់ខ្ញុំថា «នារីដែលផ្តាច់ពាក្យពីខ្ញុំវិញនោះ ឥឡូវគេឲ្យយើងចូលស្តីដណ្តឹងម្តងទៀតហើយ គេឈប់ប្រកែកហើយ»។ ខ្ញុំដកដង្ហើមធំ មិនដឹងគិតដូចម្តេច ហើយទីបំផុតខ្ញុំក៏យល់ព្រម ព្រោះអាណិត

ពុកម៉ែ។ ថ្ងៃទី២៤ ខែតុលា បងឈីន មកយកបញ្ជីឈ្មោះអ្នកដែលត្រូវរៀបការ មកពិនិត្យ។ គាត់ភ្ញាក់ផ្អើលដោយឃើញឈ្មោះខ្ញុំត្រូវរៀបការដែរ។ គាត់បង្អាប់ លេងសើចជាមួយខ្ញុំយ៉ាងខ្លាំង ដោយសារខ្ញុំធ្លាប់ប្តេជ្ញាថាមិនទាន់ចង់រៀបការ។ ខ្ញុំសើច រួចក៏ដើរចេញទៅ។ ល្ងាចថ្ងៃនោះ ខ្ញុំទៅដេកផ្ទះ តែខ្ញុំមិនទៅហូបបាយនៅរោងបាយរួមទេ។ យប់បន្តិច ម៉ែរបស់ខ្ញុំបានយកបាយមកឲ្យខ្ញុំហូប។ ខ្ញុំហូបបាយ រួចចូលដេកដោយមិនទាំងនឹងងូតទឹកផង។ យប់នោះ ខ្ញុំដេកមិនសូវលក់ នឹកគិត ពីគូដណ្តឹង ដែលត្រូវរៀបការនៅថ្ងៃស្អែក។ ថ្វីបើយើងរស់នៅភូមិជាមួយគ្នា តែ ខ្ញុំមិនស្គាល់នាងទេ ព្រោះខ្ញុំឃើញនាងតាំងតែពីនៅតូច ពេលធំឡើងមិនដែល ជួបនាងម្តងណាសោះ មិនដឹងជានាងមានមុខមាត់ រាងរៅ ពណ៌សម្បុរដូចម្តេច ឡើយ។ ថ្ងៃទី២៥ ខែតុលា ខ្ញុំដេកដល់ថ្ងៃរះ។ ម៉ែរបស់ខ្ញុំបានជាស់ខ្ញុំឲ្យងូតទឹក រួចនាំទៅកាត់សក់។ ខ្ញុំស្លៀកខោពណ៌ខ្មៅ ពាក់អាវពណ៌ខៀវចាស់ ដែលម៉ែលាក់ ទុកយូរហើយ មើលទៅដូចជាហឺហាជាងគេបន្តិច។ ខ្ញុំទៅដល់រោងពិធីក្រោយគេ។ ខ្ញុំមើលទៅតុគណៈអធិបតីប្រទះភ្នែកជាច្រើនគូកំពុងសម្លក់សម្លឹងមកខ្ញុំ ដែល នាំឲ្យឃឺតកម្មវិធីគេ។ ក្នុងចំណោមគូស្រករទាំង២៧គូ ពួកគេអង្គុយតាមគូគេ អស់ទៅហើយ នៅសល់តែខ្ញុំរកគូមិនឃើញសោះ ទើបមានអ្នកមកដឹកដៃរបស់ខ្ញុំ ទៅជាក់ ទើបខ្ញុំរកឃើញគូ។ ពិធីនេះមានការចូលរួមពី ប្រធានកងចល័តតំណាង ឃុំសំបួរ តំណាងឃុំស្មោងខាងត្បូង កងចល័ត និងប្រជាជនក្នុងឃុំសំបួរដែរ។ កម្មវិធីចាប់ផ្តើមដោយការគោរពទង់ជាតិ គោរពទង់បក្ស គោរពវិញ្ញាណក្ខន្ធ។ បន្ទាប់មកមានការអានឈ្មោះសាមីខ្លួន គណៈអធិបតីឡើងចាប់អារម្មណ៍ និង មតិផ្តាំផ្ញើចុងក្រោយតំណាងសាមីខ្លួន ដែលមានឈ្មោះ សៅ សារឿន ឡើង ប្តេជ្ញាចិត្ត។ ពេលចប់កម្មវិធី គូស្វាមីភរិយាថ្មីបណ្តើរគ្នាត្រសងទៅផ្ទះ ដោយឡែក តែគូខ្ញុំ និងគូមិត្តយឿន មួយទៅលិចមួយទៅកើត តាមផ្ទះកំណើតរៀងខ្លួន។ គ្រាន់តែថ្ងៃលិចភ្លាម ពុកម៉ែរបស់ខ្ញុំ មិនដឹងជាលួចរៀបចំពីថ្មើរណាទេ បានជា មាននំ និងមាន់ស្ងោរ នាំខ្ញុំទៅធ្វើពិធីសែនព្រេននៅផ្ទះខាងស្រី។ គូទើបរៀបការថ្មី ទាំងអស់ ត្រូវបានអង្គការអនុញ្ញាតឲ្យមករស់នៅតាមសហករណ៍ជុំប្តីប្រពន្ធ ប៉ុន្តែ

បើត្រូវចាត់ឲ្យទៅធ្វើការឆ្ងាយពីភូមិគឺទៅទាំងគូ។ ការរៀបការរបស់ខ្ញុំនៅពេលនោះ មើលទៅហាក់ដូចជាធូរលុងមែនទែន ហើយប្រជាជនហាក់មានសេរីភាពខ្លះៗ ក្នុងការជ្រើសរើសដៃគូជីវិតរបស់ខ្លួនដែរ។ អង្គការបើកសេរីភាពឲ្យយើងបែបនេះ គឺដើម្បីជំរុញឲ្យប្រជាជនជម្លៀសចេញពីភូមិ ហើយធ្វើដំណើរទៅភូមិភាគពាយ័ព្យ ទៅខាងខេត្តពោធិ៍សាត់ និងបាត់ដំបង

ក្រោយពីយើងរៀបការបានប្រហែលមួយសប្តាហ៍ ក៏ចាប់ផ្តើមមានការបញ្ជូនប្រជាជនទៅភូមិភាគពាយ័ព្យជាបណ្តើរៗ។ ខ្ញុំហាក់សំណាងល្អដែលមិនមានឈ្មោះក្នុងបញ្ជីដែលត្រូវបញ្ជូនចេញដំបូងៗ។

ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩

ចូលដល់ពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៨ អ្នកទើបរៀបការ ត្រូវអង្គការចាត់ឲ្យទៅច្រូតស្រូវនៅភូមិសិរីឱ ឃុំត្រស់។ យើងច្រូតស្រូវនៅទីនោះមិនទាន់ហើយរួចរាល់ផង ស្រាប់តែអង្គការបញ្ជាឲ្យយើងត្រលប់មកភូមិវិញនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩។ ពេលដែលខ្ញុំមកដល់ផ្ទះនៅរសៀលថ្ងៃនោះ បានឃើញអ្វីៗប្រែប្រួលរកស្មានមិនដល់។ គេឈប់ហូបបាយរួម ហើយសម្ភារចាំបាច់ដូចជា កាំបិត ពូថៅ និងចានឆ្នាំងត្រូវចែកតាមគ្រួសារវិញ។ ចំណែកឯ ប្រធានសហករណ៍វិញ កំពុងមមាញឹកក្នុងការបញ្ជូនអ្នកមានឈ្មោះទៅភូមិភាគពាយ័ព្យឲ្យបានឆាប់រហ័ស។ អ្នកធ្វើការនៅរោងសិប្បកម្មខំកិនស្រូវបុកអង្ករទុកឲ្យបានច្រើនតាមគ្រួសាររបស់ខ្លួន។ មានប្រជាជនជាច្រើនបានភៀសខ្លួនចូលមកក្នុងភូមិអណ្តូងខ្មែរនេះ ពីតាមព្រំដែនវៀតណាមមក។ ភូមិរបស់ខ្ញុំ ស្ថិតនៅចម្ងាយមិនដល់៣០គីឡូម៉ែតផងពីព្រំដែនខេត្តតែនិញ ប្រទេសវៀតណាម។ អ្នកដែលភៀសខ្លួនមកនោះ ពេលមកដល់ភូមិរបស់យើងភ្លាម ពួកគាត់ស្នើសុំស្រូវ ដើម្បីកិនបុកទុកធ្វើដំណើរបន្តទៅមុខទៀត។ ដំណឹងពីកងទ័ពវៀតណាម វាយចូលខេត្តស្វាយរៀងបានឮជាបន្តបន្ទាប់តាមរយៈការខ្សឹបខ្សៀវតៗគ្នា។ ប្រជាជនគ្រប់គ្រួសារបានត្រៀមខ្លួនជាការស្រេចក្នុងការភៀសខ្លួនចេញ ។ អ្នកធ្លាប់មានរទេះពីមុនមកបានទៅយករទេះពីសហករណ៍ យកមកជុសជុល និងរៀបចំឲ្យរួចរាល់។

ថ្ងៃទី០៤ មករា ប្រធានសហករណ៍ បានមកប្រាប់ប្រជាជនថា «ត្រូវរៀបចំដើម្បីកៀសខ្លួនចេញនៅថ្ងៃស្អែក»។ យប់នោះខ្ញុំឃើញបុរសចាស់ៗចេញចូលផ្ទះឪពុកក្មេករបស់ខ្ញុំ យ៉ាងញឹកញាប់។ គាត់និយាយខ្សឹបជាក់គ្នារហូត។ ព្រឹកថ្ងៃទី០៥ ខែមករា ខ្ញុំដើរទៅមករវាងផ្ទះខ្ញុំ និងផ្ទះឪពុកក្មេករបស់ខ្ញុំ ដើម្បីស្តាប់សភាពការណ៍ និងជួយរៀបចំសម្ភារ។ ប្រហែលម៉ោង១២ថ្ងៃត្រង់ទៅហើយ ពុំមាននរណាម្នាក់ចេញពីភូមិឡើយ។ អ្នកភូមិដូចជារកលេសពន្យារពេលចេញដំណើរទាល់តែម៉ោង៣រសៀលទើបចេញដំណើរ យឺតៗ ព្រោះពុំចង់ទៅឆ្ងាយឡើយ។ ពីពេលចេញដំណើរពីម៉ោង ៣ល្ងាចដល់ម៉ោង៥ល្ងាច អ្នកភូមិទើបតែទៅដល់ភូមិសូកី ដែលចម្ងាយត្រឹមតែ២គីឡូម៉ែត្រប៉ុណ្ណោះ។ ការធ្វើដំណើរនេះ មិនលំបាកប៉ុន្មានទេ តែខ្ញុំមើលទៅអ្នកភូមិអណ្តែងខ្មត់ ដូចជាចង់ពន្យាពេលឲ្យយឺតយូរ ដើម្បីរង់ចាំឱកាសត្រលប់មកផ្ទះវិញ។

យប់នោះ យើងរៀបចំកន្លែងដេកនៅកណ្តាលភូមិសូកី បន្ទាប់មក មានកងទ័ព៥នាក់ មកគំរាមឲ្យយើងចេញដំណើរទាំងយប់ តែយាយតាចាស់ៗ បានសូមអង្វរដោយលើកហេតុផលផ្សេងៗ។ ពួកគេក៏យល់ព្រមហើយដើរចេញបាត់ទៅ។ ព្រឹកថ្ងៃទី ៦ ខែមករា ស្រីៗនាំគ្នាដាំស្លសម្រាប់ហូបពេលព្រឹក និងទុកសម្រាប់ហូបតាមផ្លូវដែរ ប្រសិនបើត្រូវចេញដំណើរទៅទៀត។ ម៉ោង៧ព្រឹក មានកងទ័ពខ្មែរក្រហម មកពីភូមិភាគនិរតី ប្រហែលសាមសិបនាក់និយាយរដឹនមកគំរាមឲ្យយើងទៅជាមួយពួកគេ។ អ្នកភូមិចេះតែអង្វរតែពួកគេមិនព្រម ព្រមទាំងគំរាមទៀតថា «ទៅឬមិនទៅ បើមិនទៅទុកឲ្យនៅហ្នឹងឥឡូវហើយ»។ នេះ បានន័យថាបើយើងមិនទៅគេសម្លាប់ចោលនៅទីនោះតែម្តង។ អ្នកភូមិឮដូច្នោះ ក៏ចាប់ក្របីទឹមរទេះទៅតាមពួកគេ។ ខ្ញុំរែកឆ្នាំងបាយ ឆ្នាំងសម្ល និងចានស្លាបព្រា ដើរទៅខាងមុខរទេះ។ ពេលដើរទៅឆ្ងាយពីរទេះ ខ្ញុំដាក់សង្រែក ហើយដួសបាយហូប។ ពេលនោះ អ៊ំចាស់ម្នាក់ស្តីឲ្យខ្ញុំថា «គេភ័យគ្រប់គ្នាឯងគិតតែស៊ីបាយ»។ ខ្ញុំតបទៅគាត់វិញថា «ព្រោះតែខ្ញុំភ័យបានជាខ្ញុំខំហូបបាយ»។ រួចហើយ ខ្ញុំលើកសង្រែករែកបន្ត ទៅទៀត។

ពួកកងទ័ពខ្មែរក្រហម ដើរគំរាមយើងរហូត លុះទៅដល់ភូមិជើងចាប ស្រុកមេសាង ដែលមានចំងាយប្រហែលជា២០គីឡូម៉ែត្រពីភូមិយើង ពួកកងទ័ពខ្មែរក្រហម គេចចូលព្រៃបាត់អស់។ អ្នកភូមិក៏ឈប់ហូបបាយនៅទីនោះ។ ដោយគ្មាននរណាមកបញ្ជា ពួកយើងមិនហ៊ានទៅមុខ ឬថយក្រោយទេ ទើបសម្រេចចិត្តដេកនៅភូមិជើងចាននេះមួយយប់សិន។ នៅព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ យើងមិនដឹងទៅណា គិតតែដាំបាយហូបហើយរង់ចាំស្តាប់សភាពការណ៍យ៉ាងតក់ក្រហល់។ ម៉ោងពីរសៀលមានមនុស្សមួយក្រុមស្លៀកពាក់ដូចកងទ័ពខ្មែរក្រហម តែគ្មានអាវុធទេបានមកប្រាប់យើងថា «ត្រលប់ទៅផ្ទះវិញ ហើយរស់នៅធ្វើការរកស៊ីឯកជនដូចពីដើម»។ គ្រាន់តែឮភ្លាម អ្នកភូមិ ក៏ប្រញាប់ទឹមរទេះត្រលប់មកភូមិអណ្តូងខ្ពត់វិញយ៉ាងប្រញាប់ប្រញាល់។ ខ្ញុំរែកចានឆ្នាំងដើរផងរត់ផង បានមកដល់ផ្ទះមុនគេនៅម៉ោងប្រហែល៦ល្ងាច។ ខ្ញុំរត់ទៅមើលឃ្លាំងសហករណ៍ តែគ្មានឃើញសល់អ្វីទេ មិនដឹងនរណាចូលមកយកអស់រលីង។

ក្រោយការដួលរលំរបបខ្មែរក្រហម និងក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ខ្ញុំតែងតែស្រមៃចង់ទៅរកដីថ្មី ដើម្បីរស់នៅជាអ្នកស្រែចម្ការនៅខេត្តពោធិ៍សាត់ និងបាត់ដំបង ដែលដីមានជីជាតិ និងដីទំនេរច្រើន។ តែជាអកុសល ប្រទេសយើងនៅពុំទាន់មានសន្តិសុខពេញផ្ទៃប្រទេសនៅឡើយ។

ក្រោយឆ្នាំ១៩៩៨ ខ្ញុំចាប់ផ្តើមរៀបគម្រោងទៅខេត្តទាំងពីរនោះ តែជីវភាពគ្រួសារ កូនកំពុងរៀន និងកត្តាផ្សេងៗបានពន្យារពេលរបស់ខ្ញុំរហូតដល់ឆ្នាំ២០០៨ ទើបខ្ញុំបានទៅរកដីមួយកន្លែងនៅតំបន់ភ្នំក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ ដើម្បីរស់នៅ និងធ្វើចម្ការ។

ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅអស់រយៈពេលជាង៤០ឆ្នាំកន្លងមកហើយក៏ដោយ អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម នូវតែមិនទាន់អាចភ្លេចរឿងរ៉ាវទាំងនោះទេ។ អ្វីដែលខ្ញុំបានដកស្រង់រឿងរ៉ាវខ្សែជីវិតរបស់ខ្ញុំខាងលើនេះ វាគ្រាន់តែជាចំណែកតូចមួយ ដែលខ្ញុំបានឆ្លងកាត់តែប៉ុណ្ណោះ។

ចប់

២២

រឿងកុមារភាព នៅកងចល័ត

អ្នកនិពន្ធ ៖ យន សុភាព

២២ ~ រឿង កុមារភាពដៅ កងចល័ត

ខ្ញុំឈ្មោះ ប្រាក់ ណន កើតនៅភូមិអូរអំបែង ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ខ្ញុំគឺជាកូនទី៣ ក្នុងចំណោមបងប្អូនប្រុសស្រី ៦នាក់។ មុនពេលខ្មែរក្រហមឡើងកាន់កាប់អំណាច ក្រុមគ្រួសាររបស់ខ្ញុំរស់នៅជួបជុំគ្នាយ៉ាងសប្បាយរីករាយប្រកបដោយសុភមង្គល។ ក្រុមគ្រួសាររបស់ខ្ញុំ មានជីវភាពមធ្យមមានហូបចុកគ្រប់គ្រាន់។ ប៉ុន្តែបន្ទាប់ពីខ្មែរក្រហមចូលមកកាន់កាប់មិនទាន់បានប៉ុន្មាន ខ្ញុំត្រូវឃ្លាតឆ្ងាយពីសាច់ញាតិ ទៅធ្វើការនៅតាមការដ្ឋាននានាតាមតែអង្គការចាត់តាំង។

ចាកឆ្ងាយពីគ្រួសារ

ការដ្ឋានដំបូងដែលអង្គការចាត់ឲ្យខ្ញុំទៅធ្វើគឺនៅការដ្ឋាន សដុល ក្បែរស្ទឹងដូងស្រុកប្រាសាទបល្ល័ង ខេត្តកំពង់ធំ។ កាលនោះ ខ្ញុំមានអាយុប្រហែល១២ ឬ១៣ឆ្នាំប៉ុណ្ណោះ។ ខ្ញុំតែងតែគិតថា មិនដឹងពេលណាខ្ញុំ បានមកជួបពុកម៉ែខ្ញុំវិញនោះទេ? ទោះបីជាខ្ញុំចង់ប្រកែកក៏មិនអាចប្រកែកបាន ព្រោះជាបញ្ជារបស់អង្គការ។ ពេលចាកចេញទៅ ខ្ញុំមិនបានយកអ្វីទៅច្រើនទេ ព្រោះអង្គការបានប្រកាសក្តែងៗថាទៅដល់នោះ អង្គការមានសម្លៀកបំពាក់ឲ្យហើយ។ ពេលធ្វើដំណើរ មានមនុស្សច្រើនអ៊ូអរណាស់នៅតាមផ្លូវ។ នៅសងខាងផ្លូវសុទ្ធតែព្រៃ រួមផ្សំដោយសំឡេងសត្វយំចចេកចចាច រីឯអ្នកធ្វើដំណើរជាមួយខ្ញុំខ្លះនិយាយលេងសើច អ្នកខ្លះ

មានទឹកមុខស្រងូតស្រងាត់។ ចំណែកខ្ញុំដើរបណ្តើរ ក្នុងចិត្តគិតបណ្តើរ ព្រោះចិត្តមិនចង់បែកពីពុកម៉ែទេ ណាមួយខ្ញុំមិនទាន់ដឹងអ្វីផង មិនដឹងថាអង្គការនាំទៅកន្លែងណាទៀត។

ការដ្ឋានលើ សជុល

ពេលទៅដល់ សជុល អង្គការឲ្យយើងឈប់នៅទីនោះ ដើម្បីរៀបចំកន្លែងដេកនៅក្នុងព្រៃ។ អង្គការបានប្រាប់យើងថា យើងត្រូវធ្វើការនៅក្នុងការដ្ឋានសជុលនេះ។ យើងចាប់ផ្តើមហូបបាយជុំគ្នា លែងមានអ្នកណាដាំបាយហូបតែឯងដូចពេលមុនៗទៀតហើយ។ ចំណែកឯការដេកក៏អីចឹងដែរ អង្គការធ្វើរោងវែងៗឲ្យយើងដេកជុំគ្នា។

ពេលនោះ ដល់រដូវធ្វើស្រែល្មម។ ម៉ោង៤ទៀបភ្លឺ ប្រធានកង ឲ្យយើងចេញទៅដកសំណាប ដោយមិនទាន់មានអ្វីហូបទ្រាប់ពោះនៅឡើយទេ។ ខ្ញុំដកសំណាបបណ្តើរពោះកូរបណ្តើរ។ ក្រុមកងចល័ត មានទឹកមុខក្រៀមក្រំ ព្រោះតែភាពស្រេកឃ្លាន។ យើងត្រូវធ្វើការរហូតដល់ម៉ោង១០ព្រឹក ទើបប្រធានកងអនុញ្ញាតឲ្យយើងហូបបបរបង់អំបិលដែលមានរសជាតិប្រៃឡែមៗ ដែលចុងភៅចែកឲ្យហូបមានកំណត់។ សមាជិកក្នុងកងចល័តរបស់ខ្ញុំខំប្រឹងហុតបបរឮសូរគ្រូកៗ ទាល់តែអស់មិនមានសល់ជាប់នឹងចានសូម្បីតែគ្រាប់អង្ករមួយគ្រាប់។ ទោះបីជាឆ្អែត ឬមិនឆ្អែត ខ្ញុំមិនដឹងថាទៅរកឯណាបានហូបទៀតទេ មានតែពាក្យថាទ្រាំតែប៉ុណ្ណោះ។ យើងសម្រាកបានតែមួយភ្លែត ហើយត្រូវចេញទៅដកសំណាបបន្តទៀត។ នៅពេលថ្ងៃមេឃក្តៅ និងហត់ខ្លាំង យើងមានតែទឹកផឹកប៉ុណ្ណោះ ដែលអាចជួយទ្រទ្រង់រាងកាយរបស់យើងអាចបន្តធ្វើការរហូតដល់ម៉ោង៤ល្ងាច ទើបប្រធានកងអនុញ្ញាតឲ្យសម្រាកហូបបាយ។ អាហារពេលល្ងាចក៏មិនខុសពីអាហារពេលព្រឹកដែរ។ បាយដែលចុងភៅចែកឲ្យមានតែបន្តិចបន្តួចជាមួយសម្លបង់ប្រហុក។ បន្ទាប់ពីហូបបាយរួច យើងត្រូវត្រលប់ទៅធ្វើការបន្តរហូតដល់ម៉ោង១០យប់ ទើបសម្រាកបាន។

ពេលដេក ឮសំឡេងចង្រិតយំ ធ្វើឲ្យខ្ញុំចាប់ផ្តើមនឹករឭកផ្ទះយ៉ាងខ្លាំង។ នៅផ្ទះ ថ្ងៃខ្លះម្តាយរបស់ខ្ញុំ បាននិទានរឿងឲ្យខ្ញុំស្តាប់។ រឿងខ្លះសប្បាយ រឿងខ្លះធ្វើឲ្យខ្ញុំចង់ស្រក់ទឹកភ្នែក ហើយស្តាប់រហូតដល់តែដេកលក់។ ខ្ញុំកាន់តែគិតធ្វើឲ្យចិត្តខ្ញុំកាន់តែនឹក។ ម៉ោង៤ ទៀបភ្លឺ ខ្ញុំបានឮសំឡេងល្វើយៗទាំងដែលខ្ញុំមិនទាន់ឈប់យល់សប្តិនៅឡើយ។ ប្រធានកង បានដើរមកជិត ហើយជាស់ឲ្យយើងក្រោកពីព្រឹកទាំងមិនទាន់អស់ងងុយ អោយចេញទៅធ្វើការបន្តទៀត។

នៅថ្ងៃអាទិត្យ ប្រធានកង ឲ្យយើងសម្រាកមួយថ្ងៃ ហើយចុងភៅក៏មានបាយទ្រាបម្នាក់មួយកូនដុំឲ្យហូបដែរ។ ក្រៅពីនេះ ខ្ញុំបបួលអ្នកស្នាក់នៅរោងជាមួយគ្នាទៅរកបេះបន្លែ ដូចជា ផ្ទឹ ស្លឹកបាស និងបន្លែផ្សេងៗទៀតយកមកធ្វើភិ (ម្ហូបមានបន្លែលាយគ្នាជាច្រើនមុខ) ហូបបន្ថែម។ កាលណោះ ប្រធានកងមិនហាមយើងបេះ ឬធ្វើអ្វីហូបទេ។ យើងចង់ធ្វើហូបអ្វី គឺយើងអាចធ្វើហូបបាន ប៉ុន្តែដល់ថ្ងៃធ្វើការធម្មតាត្រូវទៅធ្វើការជាដាច់ខាត ដោយមិនអាចទៅរកអ្វីមកធ្វើហូបបាននោះទេ។

ធ្លាក់ខ្លួនឈឺ

ថ្ងៃមួយខ្ញុំបានធ្លាក់ខ្លួនឈឺដោយសារសុខភាពរបស់ខ្ញុំមិនអាចទ្រទ្រង់នឹងទុក្ខលំបាកទាំងនេះបាន។ ដំបូង ខ្ញុំមិនទាន់ឈឺធ្ងន់ទេ។ ខ្ញុំចេះតែខំប្រឹងក្រោក និងទៅធ្វើការបន្ត ដោយមិនហ៊ានប្រាប់ប្រធានកងទេ។ នៅយប់នោះ ខ្ញុំរងាយ៉ាងខ្លាំង។ ខ្ញុំខំប្រឹងដេកឱបដៃទាំងញ័រញាក់ ប៉ុន្តែសំណាងល្អ បានបងស្រីម្នាក់ដេកក្បែរឱបខ្ញុំទាំងដែលខ្លួនខ្ញុំក្តៅងំៗ។ ខ្ញុំដេកលក់បានតែមួយភ្លែតប៉ុណ្ណោះ ដល់ពេលម៉ោង៤ព្រឹក ប្រធានកង មកហៅឲ្យទៅធ្វើការបន្តទៀត ប៉ុន្តែបងស្រីដែលដេកក្បែរខ្ញុំ បានជួយប្រាប់ប្រធានកងថា ខ្ញុំគ្រុនទៅមិនរួចទេ។ ពេលនោះ ខ្ញុំបានឮសំឡេងជើងដើរមកក្បែរខ្ញុំ។ ខ្ញុំព្យាយាមបើកភ្នែកមើលគាត់ទាំងដែលបើកភ្នែកមិនចង់រួច។ ប្រធានកងបានយកដៃស្ទាបក្បាលរបស់ខ្ញុំ ទើបដឹងថា ខ្ញុំគ្រុនមែន។ គាត់ប្រាប់ថា មិនអីទេ បើគ្រុនទៅមិនរួច សម្រាកចុះ។ សំណាងដែរដែលខ្ញុំមានប្រធានកងមិនសូវតឹងតែង។

ប្រធានកង បានប្រាប់ពេទ្យឲ្យមកមើលខ្ញុំ។ មួយសន្ទុះក្រោយមក មានគ្រូពេទ្យ ម្នាក់ ដើរមកស្ទាបក្បាលខ្ញុំ ហើយមិនបានប្រាប់ថា ខ្ញុំឈឺអ្វីទេ។ ពេទ្យបានឲ្យថ្នាំ ខ្ញុំលេប ហើយត្រលប់ទៅវិញបាត់។ ពេលដល់ម៉ោងហូបបបរ ខ្ញុំមិនហ៊ានទៅ ហូបទេ។ បងដែលដេកនៅក្បែរខ្ញុំបានទៅយកបបរឲ្យខ្ញុំ។ ខ្ញុំខំប្រឹងហូបដែរ ប៉ុន្តែទោះបីជាបបរនោះតិចក៏ដោយ ក៏ខ្ញុំហូបមិនអស់ដែរ។ ប្រធានកង បានឲ្យ ខ្ញុំសម្រាកពីការងារបាន៣ថ្ងៃ។ ពេលដែលខ្ញុំបានធូរស្រាលឡើងវិញ ខ្ញុំបាន ចេញទៅដកសំណាប និងស្ទូងស្រូវជាមួយកងចល័ត។

បន្ទាប់ពីខែដកស្ទូងរួច ខ្ញុំត្រូវមើលថែទាំស្រូវរហូតដល់ស្រូវទុំ។ ខ្ញុំចាប់ផ្តើម ច្រូតកាត់ និងបោកបែន បន្ទាប់មក ខ្ញុំទៅលើកទំនប់ទប់ស្ទឹងដូងបន្តទៀត។ ពេលនោះ ខ្ញុំកាន់តែនឹកបងប្អូន និងក្រុមគ្រួសាររបស់ខ្ញុំតែខ្ញុំមិនដឹងថាត្រូវទៅ សុំអនុញ្ញាតពីនរណាទេ។ នៅទីនោះ ការងារកាន់តែធ្ងន់ជាងមុន ប៉ុន្តែខ្ញុំអាចតស៊ូ បានរហូតដល់ការងារនេះបិទបញ្ចប់តាមផែនការរបស់អង្គការ។

ដំណើរដ៏សែនរីករាយ

ថ្ងៃមួយ បន្ទាប់ពីបញ្ចប់ផែនការដែលអង្គការដាក់ឲ្យធ្វើ ប្រធានកង អនុញ្ញាតឲ្យយើងត្រលប់ទៅផ្ទះវិញ ប៉ុន្តែពេលនោះព្រលប់ទៅហើយ ដូច្នេះយើង ត្រូវដេកនៅទីនោះមួយយប់ទៀត។ ពេលឮដូច្នេះ ខ្ញុំសែនសប្បាយចិត្ត ខ្ញុំចង់លោត ផង ចង់ស្រែកផង។ ខ្ញុំបានប្រញាប់ប្រញាល់ទៅរៀបចំអីវ៉ាន់រួចជាស្រេចមុនគេ។ ទឹកមុខរបស់ខ្ញុំស្រស់បំព្រងដូចផ្ការទើបតែរីក។ មិនមែនតែខ្ញុំទេ អ្នកផ្សេងទៀតក៏ ដូច្នោះដែរ។ ម្នាក់ៗនិយាយសើចក្អាកក្អាយ។ ទិដ្ឋភាពរីករាយបែបនេះ ខ្ញុំខាន ឃើញជាយូរណាស់មកហើយ។ នៅយប់នោះ ខ្ញុំដេកមិនលក់សោះ ព្រោះតែខ្ញុំ សប្បាយចិត្តខ្លាំងពេក។ ខ្ញុំគិតស្រមៃថា ពេលដែលខ្ញុំមកដល់ផ្ទះ ភាពសប្បាយ រីករាយនឹងកើតមានឡើងដូចកាលពីមុន ដូចជា ម៉ែអាចនិទានរឿងឲ្យខ្ញុំស្តាប់មុន ពេលខ្ញុំចូលដេក ហើយខ្ញុំអាចធ្វើអ្វីៗបានជាច្រើនទៀត។

ដល់ព្រឹកម៉ោង៤ ខ្ញុំប្រមូលអីវ៉ាន់ដែលបានច្រកទុករួចជាស្រេច ហើយ ចេញដំណើរទាំងមេឃមិនទាន់ទាំងភ្លឺស្រួលបួលផង។ នៅតាមផ្លូវ ម្នាក់ៗនិយាយ

គ្នាមិនដឹងជារឿងអ្វីៗខ្លះទេ ឮតែសំឡេងអ៊ូអរ រឹងទឹកមុខរបស់ខ្ញុំវិញខុសស្រឡះពីទឹកមុខកាលចេញមកពីផ្ទះ។ ខ្ញុំដើរបណ្តើរ ខ្ញុំយកជើងឈូសខ្សាច់នៅតាមផ្លូវលេងបណ្តើរ។ នៅតាមផ្លូវនោះមានព្រៃស្រោង និងមានសត្វយំសំឡេងឡើងគ្រលួច។ កាលនោះ បើខ្មែរក្រហម ឲ្យខ្ញុំដើរម្នាក់ឯង ក៏ខ្ញុំមិនហ៊ានដើរដែរ ព្រោះផ្ទះរបស់ខ្ញុំមិនមែននៅតាមផ្លូវនោះទេ។ ខ្ញុំដើរយូរទើបបានមកដល់ផ្ទះប្រជាជន ប៉ុន្តែផ្ទះនោះមានតែសំបកប៉ុណ្ណោះ គឺមិនមានមនុស្សរស់នៅឡើយ។ ខ្ញុំដើរជិតមួយថ្ងៃហើយនៅមិនទាន់ដល់ផ្ទះទៀត ព្រោះតែផ្លូវឆ្ងាយណាស់។ បន្ទាប់ពីដើរមកជិតដល់ភូមិប្រធានកងបានប្រាប់ថា ល្ងាចនេះយើងសម្រាកនៅផ្ទះរៀងៗខ្លួនចុះ ហើយព្រឹកឡើង យើងត្រូវក្រោកទៅធ្វើការនៅភូមិប្រឡាយទៀត។ ពេលឮបែបនេះ ទើបខ្ញុំដឹងថា តាមពិតប្រធានកងឲ្យមកនេះមិនមែនមកនៅជួបជុំក្រុមគ្រួសារទេ គឺមកធ្វើការកន្លែងថ្មីទៀត។

ជួបគ្រួសារដ៏ឆោតភាពសោកសៅ

ថ្ងៃគងមាត់ព្រៃទៅហើយ ខ្ញុំចាប់ផ្តើមបន្តដំណើរទៅផ្ទះយ៉ាងប្រញាប់ ព្រោះខ្ញុំដឹងថា ខ្ញុំគ្មានពេលនៅជាមួយគ្រួសាររបស់ខ្ញុំបានយូរនោះទេ។ ពេលទៅដល់ផ្ទះ ខ្ញុំឃើញម៉ែ និងពុករបស់ខ្ញុំ កំពុងនៅលើផ្ទះ។ ខ្ញុំបានរត់ឡើងទៅឱបម៉ែឱបពុក ដោយសេចក្តីនឹករឭកជាមួយនឹងតំណក់ទឹកភ្នែក ដែលហូរចុះមិនអាចបញ្ឈប់បាន។ ឃើញផ្ទះស្ងាត់ជ្រងំ ខ្ញុំបានសួរទៅកាន់ម៉ែថា «តើបងៗ និងប្អូនៗទៅណាអស់ហើយ?» គាត់ឆ្លើយទាំងទឹកមុខក្រៀមក្រំថា «ពួកគេទៅធ្វើការតាមការដ្ឋានអស់ហើយ»។ ពេលនោះ ខ្ញុំតែងតែដឹងថាអ្វីដែលខ្ញុំសង្ឃឹមពីការដ្ឋាននៅសជុលនោះ គឺខុសទាំងស្រុង។ ពុកម៉ែរបស់ខ្ញុំ បានសួរនាំខ្ញុំជាច្រើនពីការដ្ឋាននៅសជុល ហើយខ្ញុំបានរៀបរាប់ប្រាប់គាត់ទៅតាមដំណើររឿង។ បន្ទាប់មក ខ្ញុំបានប្រាប់ម៉ែថា «ស្អែកនេះ ខ្ញុំត្រូវទៅលើកដីនៅភូមិប្រឡាយទៀតហើយម៉ែ»។ ពុកម៉ែរបស់ខ្ញុំ មានទឹកមុខក្រៀមក្រំ មិនសប្បាយចិត្តទេពេលឮខ្ញុំនិយាយដូច្នោះ ព្រោះពួកគាត់មិនចង់បែកពីខ្ញុំឡើយ។

ការដ្ឋាននៅប្រឡាយ

ពេលព្រឹកឡើងមេយមិនទាន់ទាំងភ្លឺផង មាន់ក៏រងាវដាស់ខ្ញុំពីដំណេក ដើម្បីឲ្យខ្ញុំរៀបចំអីវ៉ាន់ត្រៀមបន្តដំណើរទៅទៀត។ មិនយូរប៉ុន្មាន ខ្ញុំឮសំឡេងមនុស្សអ៊ូអរដើរមកដល់ក្បែរផ្ទះរបស់ខ្ញុំ ហើយមានមនុស្សស្រែកហៅខ្ញុំឲ្យចុះទៅដី។ ខ្ញុំក្រាបថ្វាយបង្គំលាម៉ែនិងពុករបស់ខ្ញុំ។ ខ្ញុំដើរចុះបណ្តើរ មើលគាត់បណ្តើរ បង្ហាញពីភាពមិនដាច់អាល័យពីគាត់ឡើយ។ នៅតាមផ្លូវលើកនេះ មិនខុសពីមុនទេ ទឹកមុខខ្ញុំស្ងិតស្រពោន។ ការដ្ឋានលើកនេះ នៅក្បែរផ្ទះគ្រាន់បើជាងមុន។ បន្ទាប់ពីធ្វើដំណើរអស់មួយព្រឹកក្រុមរបស់ខ្ញុំបានទៅដល់ការដ្ឋាននៅប្រឡាយ។ ប្រធានកងឲ្យយើងរៀបចំកន្លែងដេក មិនខុសពីនៅការដ្ឋានសជុលទេ។ អង្គការ បានសង់រោងមួយវែងសម្រាប់ដាក់មនុស្សដេកនៅជុំគ្នាច្រើន ប៉ុន្តែពេលថ្ងៃមិនមានមនុស្សនៅទេ ព្រោះយើងចេញទៅធ្វើការនៅតាមការដ្ឋានអស់ហើយ។ រោងយើងស្ថិតនៅក្នុងស្រែ ខុសពីរោងនៅការដ្ឋានសជុល ដែលស្ថិតនៅក្នុងព្រៃ។ ចំណែកការងាររបស់យើងមិនខុសគ្នាទេ។ ពេលព្រឹក យើងត្រូវក្រោកពីម៉ោង៤ភ្លឺ ទៅធ្វើការ និងមកហូបបបរវិញនៅម៉ោង១០ រួចក៏ទៅធ្វើការបន្តរហូតដល់ម៉ោង៤រសៀលទើបសម្រាកហូបបាយ។ យើងគ្មានម្ហូបឆ្ងាញ់ទេ។ ជួនកាលចុងភៅស្លសម្លត្រាវ ជួនកាលស្លសម្លបង់ប្រហុកដោយមិនមានបង់បន្លែ និងត្រីទេ។ ហូបអាហារល្ងាចរួច យើងត្រូវបន្តទៅធ្វើការនៅតាមវាលស្រែរហូតដល់ម៉ោង១០យប់ទើបអាចសម្រាកបាន។ ការងារនៅការដ្ឋាននេះ ប្រធានកងឲ្យខ្ញុំរែកដី ឬដីកដីដាក់បង្គី។ ថ្វីត្បិតតែការងារហត់បន្តិចពិតមែន ប៉ុន្តែពេលខ្លះក៏សប្បាយដែរ ព្រោះមានមនុស្សអ៊ូអរដូចជាពិធីបុណ្យចូលឆ្នាំនៅវត្តដែរ។ ក្នុងមួយសប្តាហ៍ ប្រធានកងឲ្យធ្វើការចំនួន៦ថ្ងៃ ដោយទុកថ្ងៃអាទិត្យមួយថ្ងៃសម្រាក ហើយចុងភៅបានធ្វើបាយទ្រាបឲ្យយើងហូបក្នុងម្នាក់បានមួយដុំដែរ។

ថ្ងៃមួយ ខ្ញុំបានធ្លាក់ខ្លួនឈឺដូចពេលដែលខ្ញុំនៅការដ្ឋានសជុលអីចឹង។ ដំបូងខ្ញុំគ្រាន់តែក្តៅខ្លួនបន្តិចតែប៉ុណ្ណោះ ខ្ញុំនៅតែទៅធ្វើការជាធម្មតាដោយមិនបានប្រាប់ប្រធានកងទេ ព្រោះខ្លាចមានអ្នកទិតៀន។ នៅថ្ងៃបន្ទាប់ ខ្ញុំក្តៅរងាខ្លាំង ហើយខ្ញុំ

បានប្រាប់ប្រធានកងថា ខ្ញុំមិនអាចទៅធ្វើការបានទេ។ ប្រធានកងក៏មិនបានថាអ្វីដែរ ព្រោះប្រហែលជាគាត់មើលឃើញអាការៈខ្ញុំដូច្នោះមែន។ គាត់បានប្រាប់មិត្តភក្តិរបស់ខ្ញុំ ឲ្យទៅប្រាប់ពេទ្យ។ ពេលនោះ ខ្ញុំចាប់ផ្តើមនឹកដល់ម៉ែជាខ្លាំង ព្រោះកាលពីមុនពេលដែលខ្ញុំឈឺម៉ែ តែងតែនៅសួរនាំ និងថែទាំខ្ញុំជានិច្ច ប៉ុន្តែពេលនេះខ្ញុំត្រូវដេកនៅរោងតែម្នាក់ឯង រងាក៏រងា រកអ្នកណានៅជាមួយក៏គ្មានដែរ។ ខ្ញុំបានបន់ស្រន់នៅក្នុងចិត្តទាំងដែលដឹងថាខុសនឹងច្បាប់របស់អង្គការ។ ខ្ញុំកំពុងតែបន់ស្រន់ ស្រាប់តែឮសំឡេងជើងមនុស្សដើរស្រើបៗមកកាន់តែជិតខ្ញុំ ធ្វើឲ្យខ្ញុំភ្ញាក់ព្រើត។ ខ្ញុំប្រឹងក្រោកមើល ស្រាប់តែឮសំឡេងសួរខ្ញុំថា «កើតអីសមមិត្ត?» ខ្ញុំក្រឡេកមើលទៅឃើញថា គាត់ជាគ្រូពេទ្យទើបខ្ញុំតបវិញថា «ខ្ញុំមិនស្រួលខ្លួន មិនដឹងជាកើតអ្វីទេ ខ្ញុំចេះតែក្តៅខ្លួនហើយព្រឺរងាៗ ប្រហែលជាគ្រុនហើយទេដឹង»។ គាត់ដើរមកក្បែរខ្ញុំ ហើយយកដៃស្ទាបកខ្ញុំ រួចនិយាយថា «ក្តួយគ្រុនហើយ» រួចគាត់យកថ្នាំហុចឲ្យខ្ញុំលេប។ ខ្ញុំលេបថ្នាំនោះហើយ ក៏មិនឃើញមានការធូរស្រាលអ្វីទេ ប៉ុន្តែខ្ញុំបានសម្រាកប្រហែល៣ថ្ងៃ ខ្ញុំក៏មានអាការៈគ្រាន់បើឡើងវិញ។

បន្ទាប់ពីបានធូរពីជំងឺបន្តិច ខ្ញុំបន្តទៅធ្វើការងារទៀតទាំងដែលមិនទាន់មានកម្លាំងនៅឡើយ។ ពេលខ្ញុំកំពុងធ្វើការ ខ្ញុំអស់កម្លាំងឡើងញ័ររជើងញ័រដៃ ប៉ុន្តែនៅតែតស៊ូ បើមិនដូច្នោះអង្គការនឹងថា យើងធ្វើពុតជាក់ជាមិនខាន។ ខ្ញុំតស៊ូធ្វើការនៅការដ្ឋាននោះរហូតដល់បិទវគ្គ។ អង្គការ បានធ្វើកម្មវិធីបិទវគ្គចំនួនមួយព្រឹក នៅសល់មួយល្ងាច បានអនុញ្ញាតឲ្យពួកយើងត្រលប់មកលេងផ្ទះ ប៉ុន្តែអង្គការបានប្រាប់យើងថា ព្រឹកឡើង ពួកយើងចាប់ផ្តើមចេញដំណើរទៅត្បូងក្រពើបន្តទៀត។ ឮថាបានទៅលេងផ្ទះ ខ្ញុំសប្បាយចិត្តជាខ្លាំងក្នុងចិត្តរបស់ខ្ញុំស្ទើរតែផ្ទុះទៅហើយ។ ខ្ញុំនិងមិត្តភក្តិរត់ផង សើចផងចេញទៅ ដើម្បីប្រញាប់មករៀបចំសម្ភារចេញដំណើរទៅផ្ទះ។ ចម្ងាយផ្លូវពីប្រឡាយទៅផ្ទះរបស់ខ្ញុំ មិនឆ្ងាយប៉ុន្មានទេ។ ខ្ញុំត្រូវចំណាយពេលជាងមួយម៉ោងដោយធ្វើដំណើរថ្មើរជើង។

ជួបគ្រួសារជាថ្មី

ទោះបីជាពេលធ្វើដំណើរជួបអាកាសធាតុក្តៅខ្លាំងយ៉ាងណា ក៏ខ្ញុំមិនមានអារម្មណ៍ថាអាកាសធាតុក្តៅនោះទេ ព្រោះខ្ញុំសប្បាយចិត្តដែលបានទៅជួបជាមួយម៉ែពុកនិងបងប្អូនរបស់ខ្ញុំសារជាថ្មី។ កាលនោះនៅតាមផ្លូវសុទ្ធតែព្រៃមានទាំងសត្វស្លាប និងសត្វចតុប្បាទផ្សេងៗទៀត។ ពួកវាយំកងរំពងពាសពេញព្រៃ។ ខ្ញុំដើរផងធ្វើសំឡេងតាមសត្វទាំងនោះផង បង្កភាពកាន់តែសប្បាយរីករាយនៅតាមថែមទៀត។ បន្ទាប់ពីធ្វើដំណើរអស់ជាង១ម៉ោង ខ្ញុំបានទៅដល់ផ្ទះ ម៉ែពុកនិងប្អូនរបស់ខ្ញុំដែលមកលេងផ្ទះ បានឃើញខ្ញុំ ហើយហៅខ្ញុំដោយសំឡេងខ្លាំងៗ បង្ហាញពីក្តីនឹករឭកជាខ្លាំង។ យើងរត់ឱបគ្នាជាមួយនឹងទឹកភ្នែកហូរចេញមកដោយមិនដឹងខ្លួន។ យើងខានហូបបាយជាមួយគ្នាបែបនេះយូរហើយ។ យើងនិយាយលេងជាមួយគ្នាបណ្តើរ រៀបរាប់ពីអ្វីដែលយើងបានជួបប្រទះបណ្តើរ។ ម៉ែរបស់ខ្ញុំ ប្រែប្រួលទឹកមុខអាណិតខ្ញុំ ហើយគាត់បានប្រាប់ និងណែនាំខ្ញុំឲ្យប្រឹងអត់ធ្មត់ កុំឲ្យតមាត់ជាមួយអង្គការ។ ពេលព្រឹក ខ្ញុំក្រោកឡើងពីព្រលឹម ដើម្បីរៀបចំចេញដំណើរទៅការដ្ឋាននៅត្បូងក្រពើទៀត។

ភាពជូរចត់នៅត្បូងក្រពើ

យើងត្រូវចំណាយពេលអស់ពេញ១ថ្ងៃទើបធ្វើដំណើរទៅដល់ត្បូងក្រពើ។ បន្ទាប់ពីទៅដល់ យើងចាប់ផ្តើមនាំគ្នាសង់រោងសម្រាប់ដេកដូចនៅតាមការដ្ឋានមុនៗដែរ។ ការងារដែលពួកយើងធ្វើនៅទីនោះ ក៏មិនខុសពីការដ្ឋាននៅប្រឡាយដែរ គឺយើងត្រូវលើកដីធ្វើប្រឡាយ និងទំនប់ សម្រាប់បំពេញតម្រូវការខាងវិស័យកសិកម្ម។

ដោយសារតែធ្វើការងារធ្ងន់ជារៀងរាល់ថ្ងៃ ខ្លួនប្រាណរបស់ខ្ញុំនិងប្រជាជនផ្សេងទៀតធ្លាក់ស្គមស្គាំងមានតែឆ្អឹង។ ថ្ងៃមួយ ខ្ញុំធ្លាក់ខ្លួនឈឺម្តងទៀត។ ខ្ញុំឈឺលើកនេះ មិនដូចលើកមុនទេ។ ខ្ញុំឈឺរហូតដល់ដេកនៅលើកន្ទេល ទោះពេទ្យឲ្យថ្នាំលេបហើយ ក៏មិនបានជាសះស្បើយដែរ។ ប្រធានកង ឃើញខ្ញុំបែបនេះ បានអនុញ្ញាតឲ្យខ្ញុំសម្រាកបណ្តោះអាសន្នសិន។ ប្រធានកងម្នាក់នេះ មិនសូវកាចទេ។ គាត់ចេះយល់ពីទុក្ខធុរៈកូនក្រុមណាស់។

ថ្ងៃមួយ ពុករបស់ខ្ញុំ បរទេះដឹកបន្លែ និងលាមកទៅក្បែរតំបន់ការដ្ឋាន របស់ខ្ញុំ។ គាត់បានចូលមើលខ្ញុំ និងបានយំ ព្រោះតែអាណិតខ្ញុំ។ គាត់ចង់យក ខ្ញុំមកផ្ទះ ប៉ុន្តែគាត់មិនអាចធ្វើដូច្នោះបានទេ។ គាត់បានត្រឹមតែយំអាណិតកូន ប៉ុណ្ណោះ។ ក្រោយមក ខ្ញុំបានជាសះស្បើយ ហើយទៅធ្វើការបន្តរហូតដល់ចប់ ការដ្ឋាននៅត្បូងក្រពើទៀត។ មិនយូរប៉ុន្មាន របបខ្មែរក្រហម បានបញ្ចប់ដែរ។

យើងទាំងអស់គ្នា បានវិលត្រលប់មកផ្ទះវិញរៀងៗខ្លួន ដោយមានរដ្ឋអំណាច ចែកស្រូវបន្តិចបន្តួចឲ្យសម្រាប់យកទៅបរិភោគ និងធ្វើជាពូជបន្តទៀត។

ចប់

២៣
រឿងអត់ដឹងខ្យល់

អ្នកនិពន្ធ ៖ អោម ចែតច័ន្ទថារី

២៣ ~ រឿង អត់ដឹងខ្យល់

ថ្ងៃមួយម៉ែកំពុងតែបោសសម្អាតគ្រាប់បាយ ដែលជ្រុះរាយប៉ាត់រប៉ាយ ពាសពេញឥដ្ឋ។ ទឹកមុខរបស់ម៉ែហាក់មិនសប្បាយចិត្តពេលឃើញចៅតូចៗ ហូបបាយខ្ជះខ្ជាយយ៉ាងដូច្នេះ។ ខ្ញុំបានជូតសម្អាតតុបាយ រួចប្រមូលចានយកទៅលាង។ ម៉ែរបស់ខ្ញុំ និយាយរអ៊ូតែម្នាក់ឯងថា «ក្មេងៗសម័យនេះ ពិតជាមិនដឹងថាតើគ្រាប់បាយមួយគ្រាប់ៗមានតម្លៃយ៉ាងណានោះទេសម្រាប់អ្នកអត់ឃ្លាន»។ ខ្ញុំយល់ពីអ្វីដែលម៉ែនិយាយនិងមិនសប្បាយចិត្តចំពោះភាពខ្ជះខ្ជាយរបស់យើង។ ម៉ែតែងតែប្រាប់ខ្ញុំអំពីរឿងកម្សត់អត់ឃ្លាន ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។

ខាងក្រោមនេះជាដំណាលរឿងរ៉ាវម្តាយរបស់ខ្ញុំ ដែលបានឆ្លងកាត់របបខ្មែរក្រហម៖

កាលខ្ញុំនៅពីតូច ខ្ញុំបានឮប្រជាជនភាគច្រើននិយាយគ្នាថា ប្រទេសជាតិមានស្ថានភាពមិនស្រួលទេ ប៉ុន្តែគ្មាននរណាម្នាក់ដឹងថានឹងមានអ្វីកើតឡើងឡើយ។ ខ្ញុំគ្រាន់តែឮចាស់ៗនិយាយខ្សឹបខ្សៀវគ្នាពីស្ថានភាពក្នុងប្រទេស ហើយនៅពេលដែលមានក្មេងៗដើរមកជិត គាត់ក៏ឈប់និយាយគ្នា។

នៅឆ្នាំ១៩៧៤ ខ្ញុំមានអាយុ១៣ឆ្នាំ។ ខ្ញុំសប្បាយរីករាយនឹងកុមារភាពជាអ្នកទីក្រុងដូចកុមារដទៃជាច្រើនទៀតនៅក្នុងការជួបជុំគ្រួសារ។ ខ្ញុំមានម្តាយឈ្មោះ ដួង សាន ហើយឪពុកឈ្មោះ ប្រាជ្ញ ដឹម។ ខ្ញុំមានបងប្អូនស្រីចំនួន៧នាក់។ ក្នុងឆ្នាំនោះ ឪពុករបស់ខ្ញុំ ឈប់ធ្វើទាហាន ហើយឈប់ទៅបន្ទាយទៀត។ បន្ទាប់ពី

ឈប់ធ្វើទាហាន ឪពុករបស់ខ្ញុំ មកធ្វើជាចុងភៅឲ្យដំណាក់របស់ព្រះអង្គម្ចាស់កាលុញ វិញម្តង។ កាលនោះដំណាក់របស់ព្រះអង្គម្ចាស់កាលុញ ស្ថិតនៅវីឡាចំការមន និងពេលខ្លះនៅវីឡាទួលគោក។ ខ្ញុំចូលចិត្តដើរទៅណាមកណាជាមួយឪពុករបស់ខ្ញុំណាស់។ ឪពុកម្តាយរបស់ខ្ញុំ បានទិញដីនៅម្តុំបឹងពោងពាយចំនួន ១ហិកតា ហើយ ពូរុណ ដែលជាប្អូនឪពុករបស់ខ្ញុំ ក៏បានទិញដីនៅក្បែរនោះ ១ហិកតាដែរ។ បន្ទាប់មក យើងបានកាប់ឆ្ការព្រៃ ដើម្បីធ្វើផ្ទះ និងដាំដំណាំ។ ពូរុណ គឺជាគ្រូពេទ្យ។ ពូរុណ ដឹងស្ថានការណ៍ថា ប្រទេសជាតិចាប់ផ្តើមមិនស្រួលហើយ។ គាត់បានប្រាប់ថាខាងកងកម្លាំងខ្មែរក្រហមនឹងជិតចូលដល់ក្រុងភ្នំពេញ។ នៅពេលដែលដឹងដូច្នោះ ពូរុណ បានលក់ដីឲ្យគ្រួសារខ្ញុំ។ ពេលនោះ ឪពុករបស់ខ្ញុំបានទិញដីរបស់គាត់ថែម ១ហិកតាទៀត។ គ្រួសាររបស់ខ្ញុំបានសាងសង់ផ្ទះរួចរាល់ ហើយយើងបានផ្លាស់ប្តូរពីម្តុំវត្តកែវកាំភ្លើងមករស់នៅម្តុំបឹងពោងពាយវិញ។ ឪពុករបស់ខ្ញុំ បានដាំដំណាំគ្រប់ប្រភេទនៅលើផ្ទៃដីនោះ។ ក្រោយៗមក ប្រជាជនបាននាំគ្នាចាប់ផ្តើមលក់ដី ហើយរយៈពេលប្រហែលជាមួយខែក្រោយមក ខ្ញុំចាប់ផ្តើមឮគ្រាប់ផ្លោងផ្ទុះ ភាគច្រើនផ្ទុះនៅពេលយប់។ នៅពេលដែលប្រទេសជាតិចាប់ផ្តើមមិនស្រួល ព្រះអង្គម្ចាស់កាលុញ ទ្រង់នាំគ្នារៀបចេញដំណើរទៅប្រទេសបារាំង។ ព្រះអង្គ បានហៅឪពុករបស់ខ្ញុំ និងឲ្យយកប្រពន្ធកូនទៅប្រទេសបារាំងជាមួយគាត់ដែរ ប៉ុន្តែឪពុករបស់ខ្ញុំបានបដិសេធ។ ឪពុករបស់ខ្ញុំ មិនចង់បែកពីឪពុកម្តាយរបស់គាត់ ដែលកំពុងតែស្នាក់នៅក្នុងស្រុកត្រាំកក់ ក្នុងខេត្តតាកែវ នោះទេ។

ក្នុងខែមេសា ដែលជារដូវប្រាំងក្តៅហួតហែង ខ្មែរក្រហម បានបង្ខំឲ្យយើងចាកចេញពីផ្ទះ ពីទីក្រុងភ្នំពេញជាបន្ទាន់។ ផ្ទះរបស់ខ្ញុំ មានអីវ៉ាន់ពេញផ្ទះ ព្រោះយើងបានរៀបចំសម្រាប់ថ្ងៃរៀបការរបស់ បងឡុង ដែលជាបងស្រីធំរបស់ខ្ញុំ។ យើងបានប្រមែប្រមូលរបស់របរដោយប្រញាប់បំផុត ដោយយកតែរបស់របរណាចាំបាច់ប្រើប្រាស់តែប៉ុណ្ណោះ។ ឪពុករបស់ខ្ញុំបានអូសកង់ ដោយមានអង្ករមួយបាវសេ និងអីវ៉ាន់សំពីងសំពោងជាច្រើនទៀតនៅលើកង់។ ចំណែកម្តាយ

របស់ខ្ញុំ ពប្អូនតូច ទើបនឹងចេះដើរតិចៗ។ ដៃម្ខាងទៀតរបស់ម្តាយខ្ញុំ កាន់ដៃប្អូនស្រីទី៦ ឈ្មោះ ធំ ដែលមានអាយុលើសប្អូនពៅរបស់ខ្ញុំមួយឆ្នាំ។ មីងរិទ្ធ អូសកង់មួយដឹកមេទាចំនួន ១០ក្បាល និងអីវ៉ាន់ជាច្រើនទៀតឡើងទ្រោម កង់មិនចាញ់ឪពុករបស់ខ្ញុំទេ។ បងប្អូនផ្សេងទៀតនិងខ្ញុំ ដើរពីខាងក្រោយកង់ឪពុករបស់ខ្ញុំ។ យើងម្នាក់ៗចេះតែដើរទៅមុខជាមួយនឹងប្រជាជនជាច្រើននាក់នៅតាមផ្លូវ។ យើងដើរកាត់ពោធិ៍ចិនតុង រួចធ្វើដំណើរឆ្ពោះទៅខេត្តតាកែវ។ ពេលឈប់ត្រង់កន្លែងណា យើងដាំបាយហូបត្រង់កន្លែងនោះ។ យើងសប្បាយចិត្តជាមួយនឹងមេទាទាំង១០ក្បាលនោះណាស់ ដែលតែងផ្តល់ពងឲ្យយើងបានស្ងោរហូបជាប់តាមផ្លូវមកជានិច្ច។ នៅពេលដែលម្តាយរបស់ខ្ញុំឃើញក្រុមខ្មែរក្រហមឆែកឆេរប្រជាជន ដែលជម្លៀសនៅតាមផ្លូវ គាត់កិតក៏យខ្លាំងណាស់ ព្រោះក្នុងបាវអង្ករបស់យើងមានកាំភ្លើងខ្លីមួយដើម។ ម៉ែបានឲ្យឪពុករបស់ខ្ញុំ កាយយកកាំភ្លើងទៅចោលមុនអង្គការឆែកមកដល់គ្រួសារយើង។ ម្តាយរបស់ខ្ញុំ មានលុយមួយបាវ និងខ្សែកខ្សែដៃជិតដប់តម្លឹងយកមកតាមខ្លួន។ ក្រុមខ្មែរក្រហម បានឆែកឃើញលុយមួយបាវ ហើយបានយកលុយទាំងអស់នោះទៅដុតចោល រួចប្រាប់យើងថា «បងប្អូនណាមានលុយ ចោលទៅ យើងអត់ចាយទៀតទេ»។ ក្រុមគ្រួសាររបស់ខ្ញុំ បានធ្វើដំណើរទៅកាន់ខេត្តតាកែវ ដោយមានគម្រោងទៅរស់នៅក្នុងឃុំលាយបូរ ស្រុកត្រាំកក់ ដែលជាស្រុកកំណើតរបស់ឪពុកខ្ញុំ ប៉ុន្តែយាយមិច និងតាជីម បានស្តាត់ចាំជួបយើងនៅអង្គតាសោម ហើយប្រាប់យើងថា កុំឲ្យយើងទៅស្រុក ព្រោះអ្នកស្រុកគ្រប់គ្នាបានស្គាល់យើង ហើយថែមទាំងដឹងថាឪពុករបស់ខ្ញុំ ធ្លាប់ធ្វើទាហានពីមុនមក។ យាយមិច និងតាជីម ខ្លាចខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំចោល។ នៅពេលដែលយើងដឹងដូច្នោះ យើងបាននាំគ្នាធ្វើដំណើរហួសទៅស្រុកទ្រាំង ដែលជាស្រុកជីដូនជីតារបស់ខ្ញុំ។ ក្រុមគ្រួសាររបស់ខ្ញុំមានសមាជិកសរុបចំនួន១២នាក់ បានស្នាក់នៅផ្ទះមួយ ដែលអង្គការបានចែកឲ្យ។ ម្តាយរបស់ខ្ញុំបានលាក់ខ្សែដៃខ្សែកនៅតាមបំពង់ឫស្សីនៅក្នុងផ្ទះ។ នៅពេលទៅដល់ស្រុកទ្រាំង អង្គការបាន

ហៅយើងសួរម្នាក់ម្តងៗ។ ដំបូងអង្គការសួរ បងឡុង បងសុខ រួចខ្មៅ និងសាង ហើយបន្ទាប់មកអង្គការបានសួរខ្ញុំ ថា «ក្មួយឯងប្រាប់តាមត្រង់មក តើឪពុកធ្លាប់ធ្វើការអ្វីដែរ?» ខ្ញុំបានឆ្លើយតបទៅគាត់វិញថា «ឪពុករបស់ខ្ញុំធ្លាប់ធ្វើជាអ្នកជាំបាយ»។ អង្គការ បានសួរបញ្ជាក់ពាក្យសំដីដែលខ្ញុំនិយាយថាពាក្យថា ឪ ទៀត។ អង្គការ គិតថាខ្ញុំហៅឪពុករបស់ខ្ញុំថា ប៉ា ព្រោះខ្ញុំមកពីទីក្រុងភ្នំពេញ។ ខ្ញុំបានប្រកែក ព្រោះជាការពិតខ្ញុំហៅតែ ឪ ទេ។ រយៈពេលប្រហែលជា១០ថ្ងៃ ក្រោយមក អង្គការ បានឲ្យឪពុករបស់ខ្ញុំ ទៅនៅកងចល័ត។ ក្រោយមកទៀត អង្គការ បានឲ្យម្តាយរបស់ខ្ញុំចេញទៅទៀត។ បន្ទាប់មក បងឡុង និងបងសុខ ទៅធ្វើការងារនៅកងនារី និងកងយុវជនពិសេស។ ឪពុកម្តាយ និងបងៗរបស់ខ្ញុំ ទៅធ្វើការតាមកងក្នុងភូមិ ហើយអាចត្រលប់មកសម្រាកនៅផ្ទះវិញបាន ប៉ុន្តែប្រសិនបើពួកគាត់ទៅធ្វើការនៅទីឆ្ងាយៗពីភូមិ គឺគាត់មិនអាចត្រលប់មកសម្រាកនៅផ្ទះវិញបានទេ។ ចំណែកឯ ប្អូនម៉ៅ និងសាង បាននាំគ្នាទៅធ្វើការងារនៅកងកុមារតូចៗផ្សេងទៀត។ សមាជិកក្រុមគ្រួសាររបស់ខ្ញុំ ត្រូវអង្គការចាត់តាំងឲ្យនៅតាមអង្គភាពផ្សេងៗរៀងខ្លួន។ តា នៅផ្ទះផ្សេង រីឯយាយនៅផ្ទះផ្សេង។ ខ្ញុំទៅនៅកងកុមារី គឺមានតែក្មេងស្រីៗ រីឯក្មេងប្រុសនៅតាមប្រុសដែលស្នាក់នៅជិតៗក្នុងវត្តព្រៃផ្តេរ។

នៅក្នុងរបបខ្មែរក្រហម ឪពុករបស់ខ្ញុំ ហូបបបរដំបូងៗគឺពាក់ហូត។ យើងមិននឹកស្មានថាគាត់ អាចស៊ូទ្រាំបានរស់ផង ប៉ុន្តែក្រោយមកគាត់ក៏ប្រសើរឡើងវិញ។ អង្គការបានឲ្យយាយតារបស់ខ្ញុំ ចិញ្ចឹមមាន់។ ពេលខ្លះតារបស់ខ្ញុំបានលួចបុកស្រូវ យកមកឲ្យចៅដែលខ្វះខាតអាហារហូបដែរ។ ក្រោយៗមក សមាជិកក្រុមគ្រួសាររបស់ខ្ញុំ ចេះតែបែកឃ្លាតចេញពីគ្នាម្តងបន្តិចៗទៅធ្វើការនៅឆ្ងាយរៀងៗខ្លួន។ រៀងរាល់ខែប្រាំង អង្គការបានប្រើឲ្យប្រជាជនជីកប្រឡាយ។ នៅពេលនោះ ខ្ញុំត្រូវអង្គការ ប្រើឲ្យទៅរែកដីដែរ។ ខ្ញុំរែកដីដល់ម៉ោង១០យប់ទើបបានឈប់សម្រាក។ ជួនពេលខ្លះ ខ្ញុំលួចដេកបិទភ្នែកមួយភ្លែតៗនៅពេលរែកដី។ ក្រៅពីរែកដី អង្គការបានប្រើឲ្យខ្ញុំទៅកាប់ដើមទន្ទ្រានខែត្រ

ប្រមូលអាចម៍គោ និងលាមកមនុស្ស ដាក់ក្នុងបង្គី កណ្តៀតយកទៅបាចចូលក្នុងស្រែធ្វើជាជី។ នៅពេលធ្វើស្រែ អង្គការបានឲ្យខ្ញុំ ទៅវត្តប្រសិទ្ធ ដើរបោះសំណាបឲ្យចាស់ៗស្ងួងស្រូវ។ អង្គការ បានផ្តល់អាហារឲ្យទៅប្រជាជនទៅតាមរដូវកាល។ នៅពេលដែលភ្លៀងធ្លាក់កាន់តែខ្លាំង បបរគឺកាន់តែរាវ។ នៅរដូវប្រាំងច្រូតកាត់ យើងទទួលបានអាហារល្មមគ្រាន់នឹងហូប។ ព្រលឹមម៉ោង៥ព្រឹក អង្គការ បានដាស់ប្រជាជនឲ្យជុំគ្នា និងដើរចម្ងាយពី៣ទៅ៥គីឡូម៉ែត្រ អាស្រ័យទៅលើទីតាំងដែលអង្គការបានកំណត់ឲ្យធ្វើការ។ ក្នុងមួយក្រុមៗ មានមនុស្សប្រហែល១៥នាក់ ហើយក្នុងអំឡុងពេលធ្វើការងារ មានអ្នកខ្លះលួចរត់ អ្នកខ្លះឈឺក្តៅ ដូច្នេះហើយក្នុងមួយក្រុមនៅសល់ប្រហែល១០នាក់ទេ។ ប្រជាជនម្នាក់ៗ ខំធ្វើការពីមួយថ្ងៃទៅមួយថ្ងៃ និងមានរូបរាងកាន់តែស្គមទៅៗ។ ខោអាវមានតែពីរសម្រាប់ ថ្ងៃខ្លះធ្វើការទាំងសើមខោអាវ ហើយដេកទាំងខោអាវសើមទៀតផង។ យើងមានក្លិនស្អុយឆ្អេះឆ្អាបដូចតែគ្នា គ្មាននរណាល្អជាងនរណានោះទេ។

ខ្ញុំត្រូវអង្គការឲ្យនៅធ្វើការងារនៅក្នុងកងកុមារ ពេលណាដែលខ្ញុំនឹកម៉ែពុកពេក ទោះបីជាកណ្តាលយប់ ក៏ខ្ញុំហ៊ានលួចរត់មកផ្ទះដែរ។ នៅពេលបានជួបម៉ែពុកហើយ ទើបខ្ញុំរត់ត្រលប់ទៅកងវិញ។ ថ្ងៃខ្លះអង្គការ ចុះមកពិនិត្យមើល ហើយអង្គការដឹងថាបាត់ខ្ញុំទើបក្រើនរឭកប្រាប់ខ្ញុំថា «អូនឯងលើកក្រោយ កុំលួចរត់ទៅទៀត ប្រយ័ត្នអង្គការយកវាយចោល»។ នៅក្នុងរបបខ្មែរក្រហម ការងារមិនចេះខ្វះឲ្យយើងធ្វើទេ។ ពីមួយថ្ងៃទៅមួយថ្ងៃ មួយរដូវទៅមួយរដូវ គឺអង្គការមានការងារឲ្យយើងធ្វើរហូត។ យើងចេះតែរស់នៅបែបហ្នឹងពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ ហើយអ្វីដែលយើងប្រាថ្នាចង់បាននោះគឺត្រឹមតែហូបឲ្យឆ្អែតពីមួយថ្ងៃៗ ដោយមិនគិតចង់មានចង់បានអ្វីឡើយ។

ពេលមួយ អង្គការ បានជ្រើសរើសសមាជិកគ្រួសារតាមភូមិឲ្យទៅធ្វើស្រែប្រាំងនៅអន្លង់ទៀន។ នៅពេលដែលឃើញអង្គការជ្រើសរើសដូច្នោះ បងឡុងបងសុខ និងឪពុករបស់ខ្ញុំ នឹកថាសប្បាយបានទៅជុំគ្នាបងប្អូន។ ខ្ញុំយំសុំតាមទៅជាមួយដែរ ហើយអង្គការបានយល់ព្រមឲ្យខ្ញុំទៅ។ នៅពេលដែលទៅដល់

អន្លង់ទៀន សមាជិកក្រុមគ្រួសាររបស់ខ្ញុំ បែរជាបែកគ្នាទាំងអស់។ បងឡុង និងបងសុខូល ធ្វើការងារនៅក្នុងកងពិសេសនារី ចំណែកឯឪពុករបស់ខ្ញុំ ធ្វើការងារនៅក្នុងកងយុវជនពិសេស។ ខ្ញុំទៅដល់ដំបូង អង្គការ បានឲ្យខ្ញុំទៅបោចស្មៅ។ ពេលនោះ ខ្ញុំបានឃើញចាស់ៗកាប់ព្រៃត្រូវពស់ចឹកស្លាប់នៅនឹងភ្នែក ព្រោះទីនោះជាព្រៃលិចទឹក ហើយស្មៅដុះខ្ពស់ទ្រុបទ្រុលសម្បូរសត្វមានពិសណាស់។ ថ្ងៃឡើង អង្គការបានឲ្យខ្ញុំដើរដេញចាប់កណ្តុរក្នុងម្នាក់រកឲ្យបាន២០ក្បាល។ យើងត្រូវយកកណ្តុរទៅបង្ហាញអង្គការ ទើបយើងអាច សម្រាកបាន។ ខ្ញុំត្រូវកណ្តុរខាំរហែកដៃរហែកជើងអស់។ នៅពេលស្រូវដាក់គ្រាប់ អង្គការ បានឲ្យខ្ញុំដេញចាបកុំឲ្យស៊ីស្រូវ។ កន្លែងដែលខ្ញុំរស់នៅនោះ គឺអាចលួចចាប់ត្រីបានហូបបានខ្លះៗ។ អ្នកភូមិនៅទីនេះមិនសូវហូបត្រីទេ។ ពួកគេចូលចិត្តហូបកណ្តុរប្រេងធំៗ និងកណ្តុរដែលស៊ីស្រូវជាង។ អ្នកភូមិ បានចាប់កណ្តុរមកអាំង និងនាំគ្នាហូបពេញមួយអង្គភាព ប៉ុន្តែដំបូងៗខ្ញុំមិនហ៊ានហូបទេ។ នៅពេលដែលអង្គការអាំងសាច់កណ្តុរ វាមានក្លិនឈ្ងុយណាស់ ហើយមិត្តភក្តិក្នុងក្រុមរបស់ខ្ញុំ បានចាប់ដៃខ្ញុំ និងបញ្ចុកសាច់កណ្តុរនោះចូលក្នុងមាត់រួចបង្ខំឲ្យខ្ញុំហូប។ ពេលចូលក្នុងមាត់ខ្ញុំហូបទៅមានរសជាតិឆ្ងាញ់មែន។ អង្គភាពរបស់ខ្ញុំមានដុតអណ្តើកហូបទៀត។ មិត្តភក្តិរបស់ខ្ញុំ បានចាប់ដៃ ចាប់ហែកមាត់ឲ្យខ្ញុំហូបទៀត។ សាច់អណ្តើកក៏ឆ្ងាញ់ណាស់ដែរ។ មួយរយៈពេលដែលខ្ញុំរស់នៅទីនោះ ខ្ញុំបានហូបត្រី កណ្តុរអាំង និងអណ្តើកឆ្អែតៗ ព្រោះវាសម្បូរពេក។ រស់នៅទីនោះ ខ្ញុំចាញ់រងាណាស់ ហើយចេះតែគ្រុនក្តៅ។ ថ្ងៃមួយ បងស្រីតំណាងកងឈ្មោះ សិក្សា បានឃើញមុខខ្ញុំស្លេកហើយសួរថា «ម៉េចអូនឈឺឬ?» ខ្ញុំឆ្លើយប្រាប់គាត់វិញថា «អត់ដឹងឈឺម៉េច មិនដឹងឈឺម៉េចទេ ខ្ញុំមិនដែលដឹងឈឺផង»។ គាត់បានសួរខ្ញុំទៀតថា «ខ្យល់ទេដឹង?» ខ្ញុំនៅតែឆ្លើយថា មិនដឹង។ គាត់គ្រវីក្បាល រួចគាត់បាននិយាយថា «អត់ដឹងខ្យល់អី អត់ដឹងថាខ្លួនឯងឈឺទេឬ»។ គាត់និងសមាជិកក្រុម២នាក់ បានចាប់ដៃ ចាប់ជើងរបស់ខ្ញុំ យកស្លាបព្រាបាយកោសខ្យល់ឲ្យខ្ញុំភ្លាមៗ។ បន្ទាប់ពីកោសខ្យល់ជាំៗពេញខ្លួនហើយ ខ្ញុំក៏បាត់ឈឺក្បាល និងបាត់ក្តៅខ្លួនទៅ។

នៅពេលដែលយើងច្រូតកាត់ និងរៀបចំស្រូវទុកជាក់ស្រួលហើយ ទើបអង្គការបានឲ្យកុមារត្រលប់ទៅក្នុងភូមិស្រុកវិញ ប៉ុន្តែមនុស្សចាស់ៗនៅធ្វើការបន្តទៀត។ ក្រោយមក អង្គការ បានឲ្យខ្ញុំនៅចាំទួលសម្រាប់បោះតង់។ ទួលនោះមានព្រៃត្រែង ដុះលិចៗក្បាលជុំវិញ។ ខ្ញុំខ្លាចពស់ណាស់។ ខ្ញុំសុំអង្គការអត់នៅទួលទេ ហើយសុំទៅដេញចាបជំនួសវិញ។ នៅពេលដែលខ្ញុំទៅដេញចាប មេយក្តៅហែង ហើយខ្ញុំខ្ជិលឈរ ក៏ដោះអាវពីខ្លួន និងដោះកន្សែងពីក្បាល យកទៅធ្វើទីងមោងឲ្យចាបផ្អើល រួចយកជាក់ចំកណ្តាលវាលស្រែ ហើយខ្ញុំអង្គុយស្រែកដេញចាបក្នុងម្លប់។ បន្ទាប់មក កងទ័ពខ្មែរក្រហម ២នាក់ បានដើរមកឃើញខ្ញុំអង្គុយខ្លួនទទេ អត់កន្សែងនិងអត់អាវដូច្នោះ កងទ័ពខ្មែរក្រហមម្នាក់ ក៏បានដោះកន្សែងហុចឲ្យខ្ញុំ។ ស្អែកឡើងពេលថ្មើរហ្នឹង កងទ័ពខ្មែរក្រហមដដែល បានមកដល់កន្លែងខ្ញុំចាំចាបម្តងទៀត។ គាត់ពាក់អាវខ្មៅ បង់កន្សែងឆ្នូតក្រហម ពាក់មួក និងពាក់ស្បែកជើងកង់ឡាន បានមកសុំខ្ញុំធ្វើជាប្អូនធម៌របស់គាត់។ គាត់និយាយមកកាន់ខ្ញុំថា គាត់បានបែកពីប្អូនដែលមានមុខមាត់ស្រដៀងនឹងខ្ញុំ។ ខ្ញុំមិនយល់ពីអ្វីដែលគាត់បាននិយាយនោះទេ ហើយខ្ញុំចេះតែគ្រវីក្បាល។ ខ្ញុំមិនដឹងពាក្យប្អូនធម៌មានន័យថាដូចម្តេចនោះទេ។ ក្រោយមក ខ្ញុំឈឺ អង្គការបានឲ្យខ្ញុំសម្រាក។ ស្អែកឡើង ខ្ញុំបានឃើញមុខកងទ័ពម្នាក់នោះមកដល់កន្លែងខ្ញុំទៀត។ គាត់ប្រាប់ថា គាត់បានទៅរកខ្ញុំដល់ទួលចាំចាប តែបាត់ខ្ញុំទើបគាត់មករកដល់ទីនេះ។ សិក្សា បានសួរខ្ញុំថា «ហេតុអ្វីបានខ្ញុំស្គាល់គាត់»? ខ្ញុំបានរៀបរាប់តាមដំណើររឿងប្រាប់ទៅ សិក្សា។ ស្អែកឡើង កងទ័ពម្នាក់នេះ យកថ្នាំមកឲ្យខ្ញុំ ហើយប្រាប់សិក្សាថា «ឲ្យជួយមើលប្អូនរបស់ខ្ញុំផង»។ បន្ទាប់មកកងទ័ពនោះបានលើកដៃចង្អុលទៅផ្ទះ ដែលមានប្រក់សង្កសីនៅក្បែរនោះរួចនិយាយថា «ពេលប្អូនរបស់ខ្ញុំជា ឲ្យទៅលេងនឹងខ្ញុំផង»។ បន្ទាប់ពីកងទ័ពផ្តាំដូច្នោះ សិក្សាបានដាំបបរ និងអាំងត្រីងៀតឲ្យខ្ញុំហូប។ កងទ័ពនោះគឺជាអ្នកយកត្រីងៀត ក្រណាត់ខ្មៅ និងស្បែកជើងមួយគូ ប៉ុន្តែទំហំធំប៉ុននឹងជើង សិក្សា រួចសិក្សាក៏យកពាក់។ សិក្សាអត់សូវប្រើខ្ញុំដូចពេលមុនទេ ហើយថែមទាំងបានសួរមកខ្ញុំថា «អូនឯងមានបានទៅលេងផ្ទះបងកងទ័ពនោះរួចឬនៅ»។ សិក្សា ប្រាប់ថា បើទៅបងជាអ្នកជូនទៅ។ ខ្ញុំមិនបានទៅទេ។ កងទ័ពមកលេងខ្ញុំមានគ្នា ៣នាក់ និងសួរសុខទុក្ខខ្ញុំជាច្រើន។

រំលងបានប្រហែលមួយអាទិត្យ អង្គការបានចាប់ផ្តើមឲ្យខ្ញុំដេញចាប់កណ្តុរ រាប់ក្បាលឲ្យអង្គការទៀតហើយ។ នៅម៉ោងប្រហែល៨ព្រឹក ខ្ញុំបានកាប់ដីផុងផ្លែចបរួចអើតមើលទៅឃើញរន្ធធំ ដោយក្នុងចិត្តត្រេកអរថាមានកណ្តុរធំណាស់ ហើយមើលទៅ។ ខ្ញុំបានកាប់ដីបង្វិលចុះឡើងនៅតែមិនទាន់ដល់ ចំណែកឯសិក្សាវិញដើរមើលពីក្រោយ និងជួយកាប់ខ្ញុំខ្លះដែរ។ ខ្ញុំលូកដៃចូលរន្ធនោះចាប់កណ្តុរស្រាប់តែឮសំឡេងគ្រហឹម។ ខ្ញុំស្ទាបទៅរាងរលោងៗដោយគិតថាជាកណ្តុរប្រែង។ នៅពេលដែលខ្ញុំតោងខ្លាំង ស្រាប់តែជាសត្វពស់ទៅវិញ។ វាបានបុកធ្លុះដី ហើយរត់គេចខ្លួនពីខ្ញុំ។ ខ្ញុំនិងសិក្សា ភ័យញ័រទាំងខ្លួន។ កងទ័ពខ្មែរក្រហមបានឃើញដូច្នោះ នាំគ្នាដេញចាប់ហើយវាយសត្វពស់នោះងាប់ទៅ។ កងទ័ពទាំងអស់នោះថាគឺជាពស់វែកនាម។ បន្ទាប់មក កងទ័ព បានយកពស់នោះទៅធ្វើជាបបរគ្រឿង។ ខ្ញុំក៏បានហូបបបរដែរ។ ថ្ងៃមួយទៀត ខ្ញុំ និងមិត្តម្នាក់ បានដើរដល់កន្លែងចាស់ៗជាន់រហាត់ទឹកបង្ហូរដោក់ស្រូវ។ ថ្ងៃត្រង់ចាស់ៗសម្រាក ខ្ញុំនឹកឃើញចង់ទៅជាន់រហាត់ទឹកលេង។ ខ្ញុំនិយាយទៅ ទាវ ថា «ទាវ ទាវអើយ! តោះទៅជាន់រហាត់ទឹកលេងម្នាងម្នាក់! ទៅរៀនជាន់រហាត់ទឹក»។ ខ្ញុំមិនទាន់ដើរដល់ផង ខ្ញុំឃើញពស់ពីរនៅក្រោមរហាត់ទឹក កំពុងតែបើកវែក ប៉ុន្តែពេលនោះ ខ្ញុំគិតថាពស់នោះកំពុងតែរាំ។ ខ្ញុំបានហៅទាវឲ្យជួយមើលថា ពស់រាំស្អាតណាស់។ យាយម្នាក់ឮខ្ញុំនិយាយដូច្នោះ គាត់មកទាញកាន់ដៃខ្ញុំម្ខាង និងទាញដៃទាវម្ខាងរត់រំលងមួយស្រែ ទើបគាត់ឈប់រត់ទាំងហត់ដង្ហក់។ យាយគាត់ភ័យស្លុតឃើញខ្ញុំទៅលេងជាមួយពស់ដែលកំពុងតែរកចឹកខ្ញុំ។

មិនយូរប៉ុន្មាន កងទ័ពវៀតណាម បានចូលតាមស្រុកភូមិរបស់ខ្ញុំ។ ពេលខ្ញុំនៅស្រែ ខ្ញុំបានឃើញមានឡានធំៗដឹកកងទ័ពវៀតណាម។ ម្ខាងទ័ព ប៉ុល ពត ម្ខាងទៀតទ័ពវៀតណាមប្រយុទ្ធគ្នាទៅវិញទៅមក។ ស្ថានភាពក្នុងប្រទេសជ្រួលច្របល់ខ្លាំងណាស់។ មនុស្សម្នា នាំគ្នារត់គេចពីគ្រាប់ផ្លោង និងការបាញ់របស់កងទ័ពទាំងពីរ។ អ្នកខ្លះរត់បែកពីបងប្អូនអស់។ ម្តាយឪពុករបស់ខ្ញុំ បានដឹកបងប្អូនរបស់ខ្ញុំទៅទិសខាងកើត។ ខ្ញុំ និងបងឡុង រត់ទៅទិសផ្សេងទៀត។

យើងរត់តាមផ្លូវក្រោបផង លូនផងខ្លាចត្រូវគ្រាប់។ ខ្ញុំរត់តាមផ្លូវរហូត ទៅដល់ទីណាកាយដីដាំបាយត្រង់នោះ។ យូរៗទៅខ្ញុំអស់អង្គរ ហើយបានសម្រេចចិត្ត នាំគ្នាចូលមើលតាមផ្ទះអ្នកភូមិដែលរត់គេចចេញបាត់។ នៅពេលដែលខ្ញុំរកបានស្រូវ យើងយកទៅបុក និងយកមកអុំ។ ខ្ញុំ និងបងឡុង ចេះតែធ្វើៗទៅឲ្យតែបានដាំបាយហូប។ បន្ទាប់មក ខ្ញុំបានឃើញចាស់ៗរត់ ហើយយើងរត់តាមចាស់ៗបន្តទៀត។ ខ្ញុំ និងបងឡុង បានរត់ទៅដល់ស្រុកទ្រាំង រួចបានជួបជាមួយនឹងបងសុខ ដែលគាត់កំពុងតែគ្រុនញាក់ ហើយក៏បានជួបនឹង បងខ្លឹម ដែរ។ បងឡុងត្រូវអង្គការប្តេជ្ញាឲ្យមានប្តីរួចហើយ បងខ្លឹម ជាអ្នកស្នើ។ បងខ្លឹម បានដើររក បងឡុង គ្រប់ទិសទី។ ពេលដែលគាត់បានជួប បងឡុងហើយ គាត់បានហៅ បងឡុង ឲ្យទៅជាមួយ។ ខ្ញុំបានប្រាប់ បងឡុង ឲ្យទៅជាមួយប្តីរបស់គាត់ចុះ។ ចាប់ពីពេលនោះមក ខ្ញុំបានបែកពី បងឡុង ហើយដើរជាមួយ បងសុខ វិញ។ បងសុខដើរយឺតៗ។ ខ្ញុំដឹកដៃបង ហើយកាន់របស់របរដៃម្ខាងទៀត។ នៅពេលដែលខ្ញុំដើរយូរៗទៅ ខ្ញុំបានប្រទះឃើញម្តាយរបស់ខ្ញុំ រួចបន្ទាប់មកក៏ជួបឪពុក និងបងប្អូនរបស់ខ្ញុំ នៅត្រពាំងអណ្តើក។ កងទ័ពវៀតណាម បានដកទ័ពទៅវិញម្តង ហើយសភាពការណ៍បានស្ងាត់មួយរយៈខ្លី។ គ្រួសាររបស់យើង បានមករស់នៅភូមិលាយបូរវិញ។ យើងជញ្ជូនស្រូវបានច្រើនដាក់ពេញជង្រុក។ មិនយូរប៉ុន្មាន ការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាម បានចាប់ផ្តើមសារជាថ្មីម្តងទៀត ធ្វើឲ្យប្រជាជនរត់ឈូឆរចេញពីផ្ទះ។ គ្រួសាររបស់ខ្ញុំបានរត់ទៅហួសអង្គតាសោម រហូតដល់ស្ងប់ស្ងាត់ទើបរត់ត្រលប់មកផ្ទះវិញ។

បន្ទាប់ពីប្រទេសជាតិស្ងប់ស្ងាត់បន្តិច ឪពុករបស់ខ្ញុំ បានទៅមើលផ្ទះរបស់ខ្ញុំនៅភ្នំពេញដែរ ប៉ុន្តែកងទ័ពវៀតណាម បានចូលទៅនៅពេញខាងក្នុងផ្ទះ។ គាត់ប្រាប់ថា ផ្ទះធំៗ គឺកងទ័ពវៀតណាមនៅពាសពេញអស់ទៅហើយ។ ឪពុករបស់ខ្ញុំបានកប់មាសក្រោមការ៉ូក្នុងដំណាក់ព្រះអង្គម្ចាស់កាលុញនៅឯទួលគោកមុនចេញពីភ្នំពេញ ប៉ុន្តែពេលដែលគាត់ទៅមើល គាត់បានឃើញកន្លែងនោះត្រូវបានកកាយយកបាត់អស់ទៅហើយ។ ម្តាយរបស់ខ្ញុំ នៅសល់មាស៣តម្លឹង។

គាត់បានយកមាសនោះទៅលក់ទិញអង្ករហូប។ យើងរស់នៅជួបជុំគ្នាសារជាថ្មីនៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវជាប់រហូតមក។ ប្រជាជននៅក្នុងភូមិ ធ្វើស្រែរួមគ្នាអស់រយៈពេល២ឆ្នាំ ហើយក្រោយមកទើបមានការបែងចែកជាកម្មសិទ្ធឯកជន។ បងឡុង កើតបានកូនស្រីម្នាក់។ យើងទទួលបានក្មួយស្រីដំបូងនៅក្នុងគ្រួសារដែលមានឈ្មោះ គន្ធា។ ចាស់ទុំបានរៀបចំពិធីរៀបការបងឡុង និងបងខ្លឹម ទៅតាមប្រពៃណីខ្មែរ។

ចប់

២៤

រឿងខោសំពត់សម្លុយ

អ្នកនិពន្ធ ៖ ម៉ៅ សំអុន

២៤ ~ រឿង ខោសំពត់សម្លុយ

នៅក្នុងភូមិដំរីឆ្លង ឃុំស្អាងក្នុំ ស្រុកស្អាង ខេត្តកណ្តាល ក្រោយថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ លោកគង់ សំអឿន និង ប្រពន្ធរបស់គាត់ទាំងពីរនាក់ និង លោកគង់ សំអាត ប្រពន្ធ កូន បងប្អូន និង ពុកម៉ែរបស់គាត់ បាននាំគ្នាបើករថយន្ត មកផ្ទះរបស់ខ្ញុំ។ ពួកគាត់ ត្រូវជាសាច់ញាតិយាយរបស់ខ្ញុំ។ ល្ងាចឡើង លោក គង់ សំអឿន និងប្រពន្ធរបស់គាត់ទាំងពីរនាក់ បានសម្រាន្តនៅលើផ្ទះរបស់ខ្ញុំ ចំណែក ឯលោក គង់ សំអាត ប្រពន្ធ កូន បងប្អូននិងពុកម៉ែរបស់គាត់ ទៅសម្រាន្តនៅផ្ទះ យាយរបស់ខ្ញុំ។ ក្រោយមក លោក គង់ សំអឿន និងប្រពន្ធរបស់គាត់ រួមទាំងក្រុម គ្រួសារដទៃទៀត ដែលរស់នៅទីនោះ ត្រូវជម្លៀសបន្តទៅមុខទៀត។

ជីវិតរបស់ខ្ញុំនៅក្នុងកងកុមារ

ខ្ញុំកើតនៅក្នុងឆ្នាំ១៩៧០។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានអង្គការបញ្ជូន ឲ្យទៅនៅក្នុងកងកុមារ។ ថ្ងៃមួយ ខ្ញុំបានលួចរត់ពីកងកុមារត្រលប់មកផ្ទះវិញ ព្រោះ នៅក្នុងកងកុមារ ខ្ញុំហូបមិនដែលឆ្អែតទេ ហើយខ្ញុំនឹកពុកម៉ែណាស់។ ពេលដែរ ខ្ញុំរត់ចេញពីកងកុមារ ខ្ញុំបានជួបនឹង មិត្តផល នៅតាមផ្លូវដោយចៃដន្យ។ មិត្ត ផល ប្រាប់ខ្ញុំថា គាត់មិនដែលចូលផ្ទះទេ។ ពេលនោះដែរ មិត្តផល បានបបួល ខ្ញុំទៅលួចបេះល្អុង។ ខ្ញុំយល់ព្រមទៅលួចល្អុងជាមួយ មិត្តផល ព្រោះពេលនោះខ្ញុំ ឃ្លានពេក។ មិត្តផល ជំនាញណាស់ខាងឡើងដើមឈើ។ មិត្តផល បានប្រាប់ខ្ញុំ ថា បើគាត់បេះផ្លែល្អុងទម្លាក់ចុះមកឲ្យខ្ញុំហើយនោះ ខ្ញុំត្រូវតែឆាប់រត់ទៅកាន់ព្រៃ ឫស្សីភ្លាម។ មែន! គ្រាន់តែ មិត្តផល បេះផ្លែល្អុងទម្លាក់ដល់ដៃភ្លាម ខ្ញុំរត់យ៉ាង

លឿនចូលទៅក្នុងព្រៃ។ កងឈ្លប បានឃើញខ្ញុំ ហើយស្រែកថា «តើអ្នកណាបេះផ្លែល្អុង?» រួចកងឈ្លបបានរត់ដេញតាមចាប់ខ្ញុំ ប៉ុន្តែកងឈ្លបនោះដេញពួកខ្ញុំមិនទាន់ទេ ព្រោះពួកខ្ញុំរត់លឿនណាស់។ មិត្តផល ស្ទាត់ខាងលួចណាស់ ប្រៀបដូចជាសត្វស្វាអីចឹង។ មិត្តផល រស់នៅតែក្នុងព្រៃ ហូបតែស្លឹកឈើ លួចដកសណ្តែកដីហូប និងជួនពេលខ្លះ មិត្តផល មកលួចប្រហុកដែលម្តាយរបស់គាត់យកទៅដោះដូរនៅផ្ទះយកទៅជ្រលក់ជាមួយពពាយហូបជាអាហារ។ ខ្ញុំបានដើរតាម មិត្តផល ដោយមិនចូលផ្ទះអស់ចំនួន២យប់។ ខ្ញុំគ្មានអ្វីហូបទេ ហើយខ្ញុំនឹកម៉ែនឹកពុករបស់ខ្ញុំណាស់។ ខ្ញុំបានសម្រេចចិត្តត្រលប់មកផ្ទះវិញពេលយប់ព្រោះខ្ញុំគិតថាគ្មាននរណាអាចមើលខ្ញុំឃើញទេពេលដែលខ្ញុំធ្វើដំណើរនៅតាមផ្លូវ។ ម៉ែពុករបស់ខ្ញុំ ត្រលប់មកពីធ្វើការងារវិញ គាត់បានស្ងោរដំឡូងមីឲ្យខ្ញុំហូប ព្រោះខ្ញុំគ្មានបាយហូបនោះទេ។ រំពេចនោះ យើងបានឮសូរសំឡេងរបស់សមមិត្ត ប៉ា និង សមមិត្ត ភ័ក្រ បានស្រែកពីខាងក្រោមផ្ទះរបស់ខ្ញុំថា «មីងរឿន ពូរ៉ែត! ខ្ញុំមកយកកូនពូ អាសារឿន ទៅនៅកងកុមារវិញ»។ គ្រាន់តែឮសំឡេង ខ្ញុំភ័យឡើងញ័រដៃញ័រជើង។ ស្របពេលនោះ សមមិត្តទាំង២នាក់ បានឡើងមកលើផ្ទះរបស់ខ្ញុំ។ ខ្ញុំស្ទុះទៅបើកទ្វារក្រោយ រួចចុះទៅខាងក្រោមផ្ទះ ហើយបើកទ្វារឡានពណ៌ខៀវរបស់ពូ គង់ សំអឿន ដែលយកមកចតចោលទីនោះ ចូលក្រាបពួនកុំឲ្យសមមិត្តទាំង២នាក់នោះរកខ្ញុំឃើញ។ ការលាក់ខ្លួនរបស់ខ្ញុំ មិនបានសម្រេចនោះទេ។ សមមិត្តប៉ា បានបើកទ្វារឡានទាញខ្ញុំចេញពីរថយន្ត។ គាត់បានប្រឹងប្រលេះដៃរបស់ខ្ញុំដែលកំពុងតែទាញឡានចេញ។ ខ្ញុំក្រាញនៀលយំស្រែកមិនព្រមទៅទេ។ ម៉ែពុករបស់ខ្ញុំ បានមកដល់ឡានយំខ្សឹកខ្សួល មិនមានពាក្យអ្វីក្រៅពីទឹកភ្នែកស្រក់ចុះ។ ខ្ញុំមើលមុខម៉ែរបស់ខ្ញុំ ហើយគិតថា «ហេតុអ្វីម៉ែរបស់ខ្ញុំមិននិយាយថា លែងកូនខ្ញុំទៅ» ប៉ុន្តែខ្ញុំបែរជាឮ សមមិត្តប៉ា និយាយថា «មីងរឿន ពូរ៉ែត ម៉េចមិនមកជួយចាប់បញ្ជូនកូនទៅឲ្យអង្គការទេឬ? មីងឯងចង់ងាប់មួយពូជឬ? ដឹងស្រាប់ហើយ អង្គការយើង គឺហូបរួម ដេករួម និងធ្វើការងាររួម ហើយទ្រព្យសម្បត្តិទាំងអស់ជារបស់អង្គការ គឺគ្មានកម្មសិទ្ធិបុគ្គលនោះទេ»។ ម៉ែ

របស់ខ្ញុំ បានជួយប្រលេះដៃរបស់ខ្ញុំ ដៃលប្រឹងខ្ចាំនឹងពូកឡាន ដើម្បីបញ្ជូនខ្ញុំឲ្យទៅកងកុមារវិញទាំងយប់។ ខ្ញុំស្រែកយំខ្លាំងៗណាស់។ សមមិត្តវ៉ា និងសមមិត្តភ័ក្រ បានអូសដៃខ្ញុំ ចំណែកខ្ញុំវិញ ខិតខំទប់ក្រាញនៀលមិនព្រមទៅទេ។ សមមិត្តទាំង២នាក់ បានអូសដៃខ្ញុំម្នាក់ម្ខាងរហូតដល់របង ក៏បានទាត់ខ្ញុំម្នាក់មួយជើងយ៉ាងខ្លាំង។ ខ្ញុំខំដើរទ្រេតទ្រោតតាម ព្រោះសមមិត្តទាំង២នាក់នោះបានស្រែកថា «បើមិនដើរតាមអញទេ! អញទាត់ម្តែងឲ្យងាប់អាសារឿន»។ ខ្ញុំដើររហូតដល់កងកុមារទាំងឈឺខ្លួន ហើយក៏ដេកលង់លក់ទៅ។ ស្អែកឡើង ប្រធានកងបានដាក់ផែនការឲ្យចាប់កណ្តុរក្នុងម្នាក់ឲ្យបាន១០ក្បាល ដើម្បីកុំឲ្យកណ្តុរស៊ីស្រូវ។ កុមារគ្រប់គ្នាត្រូវមាន ដំបង និងកង្វារ ដើរពេញស្រែ ដើម្បីដេញចាប់កណ្តុរ ហើយដើរលូករន្ធគ្រប់ទីកន្លែង។ ខ្ញុំបានលូកទៅចំរន្ធពស់វែក ឮសូរសំឡេងឈីត ឈីត។ ខ្ញុំគ្រាន់តែឃើញពស់នោះ ខ្ញុំរត់មិនងាកក្រោយឡើយ។ ខ្ញុំរត់អស់មួយស្របក់ រួចខ្ញុំបានស្ទាបកណ្តុរ ដែលខ្ញុំចាប់បានដាក់នៅចង្កេះនោះ។ ខ្ញុំនៅខ្វះកណ្តុរចំនួន២ទៀត ទើបគ្រប់ចំនួនដែលមេកងបានកំណត់ឲ្យរក។ ខ្ញុំមិនដឹងធ្វើម៉េច ហើយជិតដល់ម៉ោងទៀត ខ្ញុំបានវះពោះកណ្តុរ ដែលចាប់បាននោះមើលក្រែងមានកូនក្នុងពោះ។ សំណាងណាស់ កណ្តុរនោះមានកូនក្នុងពោះចំនួន២ក្បាល គ្រប់ល្មមសម្រាប់ខ្ញុំយកទៅបង្ហាញមេកង។ បន្ទាប់មក ខ្ញុំបានទៅរោងហូបបាយជុំគ្នា បានក្រាលកន្ទេលស្លឹកត្នោតទ្រាប់អង្គុយ។ បន្ទាប់ពីហូបបាយរួចហើយ ខ្ញុំបានដើរទៅដួសទឹកពាងថ្លាធ្ងង់ ដែលមានដាក់ផ្តិលនៅជិតនោះផឹកមួយឆ្អែត និងទៅមុជទឹកត្រពាំងនៅក្បែររោងស្នាក់ រួចដេកជុំគ្នាលើកន្ទេលស្លឹកត្នោត។

ភ្លឺឡើង កុមារក្នុងរោងទាំងអស់ បានរៀបចំចេញដំណើរទៅរកចាប់កណ្តុរតាមវាលស្រែដូចរាល់ថ្ងៃ។ ថ្ងៃនេះ ខ្ញុំបានឆ្កែមួយក្បាលឈ្មោះ អាខ្មៅ ដែលនៅរោងបាយ រត់តាមខ្ញុំ។ វារត់លឿន ហើយពូកែហិតរន្ធកណ្តុរណាស់។ នៅពេលមានរន្ធ អាខ្មៅ ក៏ព្រូសរួចខ្ញុំរត់ទៅរកតាមកន្លែងឆ្កែព្រូសនោះ ហើយចាប់បានកណ្តុរច្រើនណាស់។ ថ្ងៃត្រង់មកដល់ កុមារទាំងអស់នាំគ្នាទៅហូបបាយ។ បន្ទាប់ពីហូបបាយរួចខ្ញុំបានដើរប្រមូលបាយនិងទឹកសម្លសល់នៅតាមតុចាក់ឲ្យ អាខ្មៅ ស៊ី។

អាខ្មៅ អត់ស៊ីទេ ព្រោះនៅក្នុងនោះមានតែទឹកសម្លនិងបាយ៧ឬ៨គ្រាប់តែប៉ុណ្ណោះ។ នៅពេលគេឃើញដូច្នេះ គេក៏ប្រាប់ ប្រធានសហករណ៍ភ្លាម។ រំពេចនោះ ប្រធានសហករណ៍ ឈ្មោះ សមមិត្តរ៉ុ បានដើរមកដល់ ហើយចង្អុលមុខខ្ញុំទាំងកំហឹង ថែមទាំងស្រែកគំហកដាក់ខ្ញុំថា « អ្នែង ! បំផ្លាញអង្គការ! មិនចាំបាច់ទៅចាប់កណ្តុរទៀតទេ។ នៅទីនេះហើយអ្នែង! រង់ចាំទូកមកដឹកទៅកោះគរ»។

កោះគរ ស្ថិតនៅកណ្តាលទឹកទល់មុខវត្តឈូងលាភ ទំនប់ទួលក្រសាំង។ ខ្ញុំភ័យណាស់រួចអង្គុយយំនៅចាំគេម្នាក់ឯងរហូតដល់ជិតល្ងាចមិនឃើញទូកមកយកខ្ញុំទេ។ មេសហករណ៍ ក៏ប្រាប់ទៅមេកងថា ឲ្យយកខ្ញុំទៅកងកុមារវិញ។ ស្របពេលជាមួយគ្នានោះ ម៉ោងបាយក៏មកដល់។ គ្រប់ៗគ្នា ដៃលដើរកាត់ខ្ញុំលាន់មាត់ថា « អ្នែង! សំណាងហើយ ទូកមិនមកយកកុំអីងាប់បាត់ហើយ»។

ក្រោយពីហូបបាយល្ងាចហើយ កុមារទាំងអស់ក៏ដើរត្រលប់ទៅសម្រាកនៅឯរោងវែងវិញ។ ម្នាក់ៗសុទ្ធតែស្គាល់គ្នា ប៉ុន្តែភាគច្រើនកុមារទាំងអស់នោះ មិននិយាយសួរសុខទុក្ខគ្នានោះទេ។ ពីមួយថ្ងៃទៅមួយថ្ងៃ កុមារទទួលរងការធ្វើបាបទាំងផ្លូវចិត្តនិងផ្លូវកាយ ដោយហត់នឿយ មិនបានសម្រាក មិនបានរៀនសូត្រ រស់នៅបែកម៉ែ បែកឪ បងប្អូន ថែមទាំងហូបមិនឆ្អែតទៀត និងពេលខ្លះត្រូវអង្គការវាយធ្វើបាប បង្អត់អាហារ ព្រោះតែធ្វើការមិនគ្រប់តាមផែនការរបស់គេ ហើយនៅពេលដៃលយើងឈឺ គឺគ្មានថ្នាំព្យាបាលនោះទេ។

ពេលវេលាដើរទៅមុខជានិច្ច។ កុមារខ្លះឈឺគ្រុនចាញ់ស្គមរីងរៃ កើតដំបៅអ្នកខ្លះឈឺភ្នែកក្រហម ខ្លះទៀតរាករូស រហូតដល់ស្លាប់ក៏មានដែរ។ ក្នុងរបបកម្មជាប្រជាធិបតេយ្យ គ្មាននរណាហ៊ាននិយាយស្តីអ្វីទាំងអស់។ ម្នាក់ៗដឹងតែពីខិតខំធ្វើការងារ សម្រុកធ្វើឲ្យចប់ផែនការមួយ និងចូលដល់ផែនការមួយទៀតតាមតែសមមិត្តបញ្ជា។ ពួកខ្ញុំ មេកងឲ្យលើកភ្លឺស្រែ។ ចំណែកពួកធំៗ ឆ្លាតណាស់គេចាប់យកតែកន្លែងណាដៃលជាដីទួលស្រាប់ នោះគេនឹងធាប់បានសម្រេចតាមផែនការ ហើយចេញទៅហូបបាយអស់។ ចំណែកខ្ញុំ គេទុកឲ្យលើកភ្លឺស្រែនៅកន្លែងដីទំនាប។ ខ្ញុំរែកចាក់មួយប៉ែលៗ បានតិចៗ ព្រោះខ្ញុំនៅតូចគ្មានកម្លាំងគ្រប់គ្រាន់នោះទេ។ ខ្ញុំតែងតែលើកភ្លឺស្រែរួចក្រោយគេថែមទាំងមិនត្រង់ជួរដូច

គេនោះទេ។ ពេលទៅដល់រោងបាយ គេបានប្រាប់មេសហករណ៍ថា កុំឲ្យបាយខ្ញុំហូប ព្រោះលើកក្តីមិនស្មើអ្នកផ្សេង។ ខ្ញុំឃ្លានតាំងព្រឹកមិនបានហូបអីសោះ ឡើងញ័រដៃញ័រជើង។ ខ្ញុំអង្គុយយំនៅក្រោមដើមគគីរខាងមុខរោងបាយ។ ខ្ញុំយំឡើងទឹកភ្នែកហូររហាម ដោយអាណិតខ្លួនពេក ព្រោះខំប្រឹងធ្វើការចង់ស្លាប់ទៅហើយនៅមិនបានបាយហូបទៀត។ កុមារគ្រប់គ្នាដើរទៅប្រុយៗ ទោះខ្ញុំស្រែកយំយ៉ាងណាក៏គ្មានអ្នកណាសួរនាំ ឬហៅ ខ្ញុំហូបបាយដែរ។ កុមារគ្រប់គ្នាមិននិយាយរកខ្ញុំ ឬអាណិតអាសូរខ្ញុំទេ។ កុមារម្នាក់ៗសម្ងំយកតែសុខរៀងៗខ្លួន ដូចដែលអង្គការបានចែងថា «សក់អ្នកណា ក្បាលអ្នកហ្នឹង»។ ពេលនោះ សមមិត្តពៅ ដែលធ្វើការនៅក្នុងសហករណ៍បានដិះសេះមកដល់ ហើយបានចងសេះនៅក្រោមដើមគគីរក្បែរនោះ។ គាត់បានសួរនាំខ្ញុំ ហើយខ្ញុំក៏បានរៀបរាប់ប្រាប់គាត់ទៅតាមដំណើររឿង។ សមមិត្តពៅ បានហៅខ្ញុំឲ្យដើរតាមគាត់ ហើយប្រាប់ចុងភៅឲ្យយកបាយមកឲ្យខ្ញុំហូប។ ខ្ញុំបែរជាមានសំណាងទៅវិញនៅថ្ងៃនេះ ព្រោះបានហូបបាយឆ្អែត ហើយមានសម្ពធ្ងាញ់ទៀត។ ពេលហូបឆ្អែតហើយ ខ្ញុំក៏ទៅដួសទឹកពាងផឹកហើយមានកម្លាំងឡើងវិញ។ ថ្ងៃឡើង ខ្ញុំបានបន្តទៅលើកក្តីស្រែទៀត។

នៅអំឡុងឆ្នាំ១៩៧៨ ស្រូវចាប់ផ្តើមបែកគុម្ពល្អណាស់ពាសពេញស្រែ។ ផែនការថ្មីរបស់កងកុមារគឺដកស្មៅដែលដុះនៅក្នុងស្រូវឲ្យបានសម្រេចតាមផែនការទើបបានហូបបាយ។ ខ្ញុំធ្វើមិនសម្រេចតាមផែនការនោះទេ ព្រោះកុមារធំៗដកលឿនទៅមុខដោយទុកប្រលោះធំឲ្យខ្ញុំធ្វើម្នាក់ឯងចង់ស្លាប់ខ្លួន។ ខ្ញុំបោចស្មៅរួចក្រោយគេ ហើយពេលទៅដល់កន្លែងគេមិនឲ្យបាយខ្ញុំហូបទៀតហើយ។ ខ្ញុំខឹងក៏ស្រែកយំរួចខ្ញុំដើរសំដៅទៅទឹកត្រពាំងមួយ ដើម្បីប្រុងនឹងសម្លាប់ខ្លួន។ ខ្ញុំដើរៗមិនទាន់ទៅដល់ត្រពាំងផង ខ្ញុំបានឃើញផ្លែថ្កូវទុំក្រហមឆ្អៅ ក្រោមគុម្ពឫស្សី។ ខ្ញុំមិនដឹងថាជារបស់អ្នកណានោះទេ។ ខ្ញុំរត់ទៅរើសយកមកខាំហូបភ្លាមៗ។ ផ្លែថ្កូវនោះ ធ្ងាញ់ណាស់ ហូបហើយមានកម្លាំងតែម្តង។ នៅពេលនោះ ខ្ញុំមិនខ្វល់ថាផ្លែថ្កូវនោះជារបស់អ្នកណានោះទេ។ ខ្ញុំដឹងត្រឹមថា បើខ្ញុំមិនហូបទេ ខ្ញុំនឹងស្លាប់ហើយនៅថ្ងៃនោះ។ ខ្ញុំហូបទាល់តែអស់ចំនួន៤ផ្លែទើបឆ្អែត ហើយនៅសល់ផ្លែថ្កូវចំនួន១ផ្លែ ខ្ញុំទុកនៅកន្លែងដើមវិញ។ ខ្ញុំក៏ប្រញាប់ដើរចេញទៅកន្លែងធ្វើការវិញភ្លាម។

បន្ទាប់ពីបញ្ចប់ការងារដកស្មៅ គឺចូលដល់រដូវច្រូតកាត់ម្តង។ កងកុមារទាំងអស់មានតួនាទីដើរប្រមូលកណ្តាប់ស្រូវនៅតាមវាលស្រែ។ ដល់ម៉ោងបាយរទេះគោ បានដឹកបាយយកទៅដល់វាលស្រែតែម្តង។ នៅពេលឃើញរទេះគោដឹកបាយទៅ ម្នាក់ៗ រត់ប្រសាច ដណ្តើមចាន ស្លាបព្រាគ្នា ដើម្បីដួសបាយហូប។ ពេលយើងហូបបាយឆ្អែត យើងនាំគ្នាដើរសំដៅទៅបឹង ដែលមានសុទ្ធតែស្លឹកព្រលឹត។ ខ្ញុំយកដៃវែកៗខាងលើដែលមានស្លឹកព្រលឹត និងរុក្ខជាតិផ្សេងទៀត ចេញឲ្យស្អាតរួចក៏ក្បង់ទឹកផឹក។

ពេលវេលាដើរទៅមុខជានិច្ច ខោរបស់ខ្ញុំបានរហែកពីមួយថ្ងៃបន្តិចៗ ហើយគ្មានម្ជុលដេរឡើយ។ យូរៗទៅ ខោរបស់ខ្ញុំបានប្រែក្លាយទៅជាសំពត់សម្លុយ។ ចំណែក ឯអាវរបស់ខ្ញុំវិញ រហែក មើលមិនយល់។ ជើងទាំងគូរបស់ខ្ញុំ ដំបៅគ្រប់ចន្លោះម្រាម ព្រោះខ្ញុំគ្មានស្បែកជើងពាក់ទេ។

ខ្ញុំធ្វើការនៅវាលស្រែប្រមូលកណ្តាប់ស្រូវបណ្តើរ និងស្តាប់វិទ្យុបណ្តើរ។ កងទ័ពរំដោះ បានវាយចូលមកដល់ភ្នំពេញហើយ។ សំឡេងគ្រាប់ផ្លោងឮសូរឆាំង! ឆាំង! រីឯស្នូរកាំភ្លើងឮសូរ ទ្រហឹងអឺងកង បែកផ្គាភ្លើងព្រោងព្រាត។ សំឡេងយន្តហោះ បានហោះឆ្លងកាត់ទ្រហឹងទៅមកវាយព្រះធរណី។ នៅខាងក្រោយឯណោះវិញ មនុស្សដើរទាំងហ្វូងៗ មកតាមភ្លឺស្រែ មានសម្ពាយរៀងខ្លួន ដើរជាជួរៗ មានទាំងចាស់ និងក្មេងដើរតាមយោធា ហើយស្រែកថា «ទៅមុខទៅមុខទៀត»។ នៅឯខាងស្រែខ្ញុំវិញ មនុស្សចាប់ផ្តើមងាកមើលគេដើរ ហើយអ្នកខ្លះឈប់ច្រូត ក៏ចាប់ផ្តើមឡើងពីស្រែបណ្តើរៗ រួចដើរទៅតាមខ្នែរក្រហមកៀរ។ ខ្ញុំ និង មិត្តង៉ែត បានដើរទៅតាមគេដែរ។ ទៅដល់ខាងមុខបានមួយសន្ទុះ មីងម្នាក់ បានសួរមកខ្ញុំថា «ក្មួយឯងទៅណា មានម៉ែមានពុកទេ ទៅរកពុកម៉ែទៅ»។

ពេលនោះខ្ញុំ និងមិត្តង៉ែត បានដើរបញ្ជ្រាសគេត្រលប់មកភូមិដីឆ្លងវិញ។ មកដល់ផ្ទះ យាយសយ គាត់ស្រែកដោយអំណរថា «ចៅយាយ! យាយនៅចាំចៅមិនទៅណាទេ»។ ពេលគាត់និយាយចប់ ខ្ញុំរត់ទៅឱបយាយស្រែកយំដោយក្តីរំភើបពន់ពេក។ ចំណែក មិត្តង៉ែត បានដើរទៅផ្ទះរកពុកម៉ែរបស់គាត់ដែលនៅ

ក្បែរផ្ទះរបស់ខ្ញុំដែរ។ បន្ទាប់ពីរៀបចំរួចរាល់ យាយសយ តាទូច កូនប្រុស កូនស្រី របស់គាត់ និងខ្ញុំ បានធ្វើដំណើរទៅផ្ទះម៉ែរបស់ខ្ញុំ។ បន្ទាប់មកខ្មែរក្រហម ចេះតែ កៀរក្រុមគ្រួសាររបស់ខ្ញុំទៅមុខបន្តទៀត។ ក្រុមគ្រួសារខ្ញុំ បានរៀបចំអូសពុក ដែលគាត់ពិការជើង ដើម្បីបន្តដំណើរទៅមុខជាមួយគ្នា។ យើងបានស្នាក់នៅភូមិ នៅក្បែរនោះ បាន២យប់ ហើយយើងក៏ត្រលប់មកភូមិដំរីឆ្លងវិញ។ ក្រុមគ្រួសារ របស់ខ្ញុំ បាននាំគ្នាទៅច្រូតស្រូវដាក់ផ្ទះ និងបុកអង្ករ ដើម្បីដាំបាយហូប។

របបកម្ពុជាប្រជាធិបតេយ្យដែលមានរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ បាន បញ្ចប់ទៅ។ បន្ទាប់ពីខ្មែរក្រហមបានដួលរលំប្រហែល៦ខែ ខ្ញុំបានមករស់នៅ ទីក្រុងភ្នំពេញវិញជាមួយនឹង យាយសយ តាទូច និងកូនប្រុសកូនស្រីរបស់គាត់។ ស្ថាប័នផ្សេងៗ បានចាប់ផ្តើមបើកទ្វារឡើងវិញ។ ខ្ញុំនិងកុមារផ្សេងទៀតក៏បាន ចូលរៀនដែរ។ ក្រោយមក ខ្ញុំបានចូលបម្រើការងារនៅក្នុងក្រសួងវប្បធម៌និង វិចិត្រសិល្បៈ ហើយរៀបការមានកូនប្រុសម្នាក់ និងស្រីចំនួន ២នាក់។

ចប់

២៥

រឿងគ្រួសារខ្ញុំ

អ្នកនិពន្ធ៖ ធី ចាន់នី

២៥ ~ រឿង គ្រួសារខ្ញុំ

ប៉ារបស់ខ្ញុំឈ្មោះ ឡាច ឈន ធ្វើការនៅអយស្ម័យយានកម្ពុជា។ ខ្ញុំមានស្រុកកំណើតនៅខេត្តបាត់ដំបង។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម បានវាយចូលមកដល់ទីក្រុងភ្នំពេញ។ ពេញមួយយប់រហូតដល់មេឃភ្លឺ ភាពចលាចលកើតឡើងពាសពេញទីក្រុងភ្នំពេញ។ ប្រជាជនរត់ទៅមុខទៅក្រោយដោយភាពស្លន់ស្លោ។ មីងម្នាក់ឈ្មោះ សយ កិតភ័យខ្លាំងពេកគិតតែពីអុជធូបបន់ស្រន់។ សន្ធឹករថក្រោះ និងរថយន្តជាច្រើនគ្រឿងរបស់កងទ័ពខ្មែរក្រហម បានបើកសម្រុកចូលពេញផ្លូវ។ ប្រជាជននាំគ្នាយកក្រណាត់ពណ៌ស មកចងធ្វើជាទង់គ្រីឡើង ដើម្បីទទួលស្វាគមន៍ និងអបអរសាទរជ័យជម្នះរបស់ខ្មែរក្រហម។ ផ្ទុយពីការគិត កងទ័ពខ្មែរក្រហម បានបាញ់គំរាមប្រជាជនឲ្យចេញពីផ្ទះ រួចស្រែកប្រកាសថា «ទុកឲ្យអង្គការធ្វើការសិន ខ្លាចពួកអាចក្រពត្តិវាយធ្មក់»។

ប្អូនរបស់ខ្ញុំឈ្មោះ គ្រី គឺជាយោធាខ្មែរក្រហម ដែលត្រូវទាហាន លន់ នល់ បាញ់ត្រូវរបួសរួចបញ្ជូនឲ្យមកសម្រាកព្យាបាលនៅមន្ទីពេទ្យទីក្រុងភ្នំពេញ។ គ្រី បានប្រាប់ឪពុកម្តាយរបស់ខ្ញុំថា ប្រសិនបើខ្មែរក្រហមបញ្ជាឲ្យចាកចេញពីផ្ទះ សូមកុំរឹងទទឹងឲ្យសោះ ហើយកុំយកឡានទៅជាមួយ។ បន្ទាប់ពីប្អូនប្រុសរបស់ខ្ញុំនិយាយប្រាប់ ស្រាប់តែស្នូរអាវុធនៅផ្លូវខាងក្រោយវត្តព្រះពុទ្ធ ផ្ទុះឡើង ហើយឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំចំនួន១២នាក់ ប្រញាប់ប្រញាល់រៀបចំរបស់របរមួយចំនួនរួមមាន ប្លង់ដី បញ្ជីជាតិ សៀវភៅគ្រួសារ សញ្ញាបត្រ និងសៀវភៅល្អៗដែលយើងទិញមកពីប្រទេសបារាំងនិងខោអាវដាក់តាមខ្លួន។ ចំណែកលុយ

ឪពុកម្តាយរបស់ខ្ញុំ បានយកទៅដាក់ធនាគារ។ យើងបានចាកចេញពីផ្ទះទាំងសោកស្តាយ ព្រោះយើងនៅសល់អីវ៉ាន់ជាច្រើនដែលមិនអាចដឹកជញ្ជូនយកមកជាមួយបាន។

គ្រួសាររបស់ខ្ញុំបានធ្វើដំណើរសំដៅទៅស្នឹងមានជ័យ ដែលមានមនុស្សដើរជ្រៀតគ្នាយ៉ាងច្រើនកុះករនៅតាមដងផ្លូវ។ នៅពេលដែលយើងធ្វើដំណើរមកដល់រោងចក្រកែវ ខ្ញុំឃើញកងទ័ពខ្មែរក្រហម ដែលមានកាន់អាវុធនៅក្នុងដៃបានប្រមូលយុវជនមានសក់វែងបញ្ជូលទៅក្នុងបរិវេណរោងចក្រ។ យុវជនប្រុសៗប្រមាណជាង១០នាក់ ដែលមានពាក់តែខោវែង ត្រូវបានកងទ័ពខ្មែរក្រហមយកខ្សែលួសមកដោតនឹងបាទដៃបន្តគ្នា ហើយមានកងការពារដើរពីខាងមុខនិងខាងក្រោយ។ ពេលយើងកំពុងបន្តដំណើរទៅមុខសន្សឹមៗ ស្រាប់តែខ្ញុំឮម្តាយរបស់ខ្ញុំស្រែកប្រាប់ថា ឈប់សិន ព្រោះឪពុក និងបងប្រុសរបស់ខ្ញុំ ត្រូវកងទ័ពខ្មែរក្រហមឃាត់ខ្លួនហើយ។ មួយសន្ទុះក្រោយមក ទើបខ្ញុំឃើញប៉ា និងបងប្រុសរបស់ខ្ញុំ ត្រលប់មកវិញដោយទឹកមុខស្លន់ស្លោ ព្រោះកងទ័ពខ្មែរក្រហមបានចោទប្រកាន់ឪពុកនិងបងប្រុសរបស់ខ្ញុំថា ជាអតីតទាហានលន់ នល់។ បន្ទាប់ពីបងប្រុសរបស់ខ្ញុំ បានបង្ហាញកាតនិស្សិតមហាវិទ្យាល័យច្បាប់ និងពាណិជ្ជកម្ម ដែលសរសេរជាភាសារបារាំងឲ្យមើល ទើបកងទ័ពខ្មែរក្រហមព្រមដោះលែងគាត់ត្រលប់មកវិញ។ ពេលព្រលប់ យើងបានធ្វើដំណើរមកដល់ស្នឹងកន្ធត។ គ្រួសាររបស់ខ្ញុំ និងប្រជាជនដទៃទៀតដែលជម្លៀសមកជាមួយគ្នាបានបោះជម្រកស្នាក់នៅនិងដាំបាយហូប។ មកដល់នៅទីនោះ បងប្អូនរបស់ខ្ញុំបានប្តូរពីការហៅប៉ាម៉ាក់ មកហៅពុកម៉ែវិញម្តង។ ម៉ែបង្ខំឲ្យបងស្រីទាំង២នាក់ និងខ្ញុំកាត់សក់ខ្លី។ ខ្ញុំយំយ៉ាងខ្លាំង ព្រោះខ្ញុំស្តាយសក់របស់ខ្ញុំណាស់។ ខ្ញុំបានដោះអាវ ដែលខ្ញុំកំពុងតែពាក់ចេញ ហើយយកខោអាវនោះទៅប្រលាក់ភក់ដើម្បីអោយឃើញពណ៌ខ្មៅ។ នៅពេលយប់ជ្រៅ ប៉ារបស់ខ្ញុំ បានយកកន្សែងយ័ន្តដែលមានរូបព្រះពុទ្ធ និងព្រះកំចាយតូចៗធ្វើពីប្រាក់ និងសំរិទ្ធ មកចែកឲ្យកូនៗម្នាក់មួយលាក់ទុករៀងខ្លួនទុកគ្រាន់ការពារខ្លួនសុំសេចក្តីសុខ។

នៅស្ទឹងកន្ទួត អ្នកភូមិបានយកសាច់មកដូរយកអង្ករ។ ចំណែកមាសមួយជី ដូរអង្ករបានត្រឹមមួយកំប៉ុងតែប៉ុណ្ណោះ។ មួយរយៈក្រោយមក ប្រជាជនដែលជម្លៀស និងស្នាក់នៅក្បែរៗខ្ញុំចាប់ផ្តើមខ្វះអង្ករ។ ម៉ែរបស់ខ្ញុំ បានចែកអង្ករខ្លះឲ្យទៅអ្នកដែលខ្វះខាតទាំងនោះ ហើយអង្ករមួយចំនួន គាត់យកទៅដូរយកសាច់ទុកគ្រាន់ធ្វើជាម្ហូបអាហារប្រចាំថ្ងៃ។ គ្រួសាររបស់ខ្ញុំ បានស្នាក់នៅទីនោះចំនួន ៥ថ្ងៃ ហើយក៏ចាកចេញ ព្រោះកងទ័ពខ្មែរក្រហម បានប្រកាសថា «ត្រូវបន្តដំណើរទៅមុខទៀត អង្គការមិនអនុញ្ញាតឲ្យនៅទីនេះទេ»។ អ្នកជម្លៀសម្នាក់បានសួរទៅកាន់កងទ័ពខ្មែរក្រហម ថា «លោកខ្ញុំសូមស្នាក់នៅទីនេះតើបានដែរឬទេ?» ពេលនោះស្រាប់តែកងទ័ពខ្មែរក្រហម បានយកកាំភ្លើងមកបុកទ្រូងរបស់គាត់ បណ្តាលឲ្យដួលទៅក្រោយ ហើយស្រែកគំរាមថា «គ្មានលោកគ្មានស្តីទេនៅទីនេះ គឺមានតែសមមិត្តបង ដែលទទួលការកិច្ចពីអង្គការ ហើយបញ្ជាឲ្យបងប្អូនបន្តដំណើរទៅមុខទៀត»។

ឪពុកម្តាយរបស់ខ្ញុំ បានសម្រេចចិត្តបន្តដំណើរទៅកាន់ស្រុកកោះធំទាំងមិនស្គាល់ផ្លូវ។ នៅតាមផ្លូវ ខ្ញុំឃើញមានប្រជាជនខ្លះជិះកង់ និងប្រជាជនខ្លះជិះម៉ូតូ។ ចំណែកគ្រួសាររបស់ខ្ញុំវិញ មានមនុស្សចាស់ជរាធ្វើដំណើរជាមួយ តែយើងគ្មានមធ្យោបាយធ្វើដំណើរនោះទេ។ យើងបានយកឈើចងខ្វែងជាជើងក្អែកដើម្បីអូសគាត់ទៅមុខ។ នៅពេលធ្វើដំណើរទៅកាន់ស្រុកកោះធំ ខ្ញុំឃើញមានប្រជាជនខ្លះស្លាប់នៅក្រោមដើមឈើ ប្រជាជនខ្លះទៀតស្លាប់នៅលើចិញ្ចើមផ្លូវដោយសារពុំមានអាហារបរិភោគ និងខ្វះថ្នាំព្យាបាល។

គ្រួសាររបស់ខ្ញុំ បាននាំគ្នាដើរតាមដោយគ្មានទិសដៅឡើយ។ យើងមិនសូវឃើញមានអ្នកជម្លៀសដើរកាត់តាមទីនោះទេ។ ប្រជាជនមូលដ្ឋាន បានសម្លឹងមើលមកឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ យ៉ាងចម្លែកក្នុងចិត្ត ប៉ុន្តែប្រជាជនមូលដ្ឋានខ្លះមានចិត្តសប្បុរសណាស់។ ពួកគេបានយកស្ករត្នោត មួកស្លឹកត្នោត និងទឹកត្នោតឲ្យយើងផឹកបានឆ្អែតគ្រប់គ្នា។ ពេលមេឃងងឹត យើងនាំគ្នាទៅជ្រកនៅក្បែរវត្ត។ នៅពេលនោះ ខ្ញុំបានឃើញកងទ័ពខ្មែរក្រហម មានទាំងប្រុស និងស្រី ឈរតម្រង់

ជួរច្រៀងបទចម្រៀងអបអរជ័យជម្នះថ្ងៃ១៧ មេសា លាន់ឮខ្ទរពេញវត្ត។ បន្ទាប់មក កងឈ្លបពានាក់ បង់កក្រមា ពាក់មួកប៉ាវ៉ា និងស្បែកជើងកង់ឡាន បានយកកាំភ្លើងមកក្ខង់ឪពុករបស់ខ្ញុំ ដោយចោទថា គាត់គឺជាអតីតទាហានលន់ នល់ ហើយថែមទាំងបានរឹបអូសយកនាឡិកាដៃ មុង កាតាប កំសៀវទឹក និងឆ្នាំងបាយ រួចប្រាប់ថាជារបស់អង្គការសុំស្នើទៅវិញ។ ចំណែកឯ ឯកសារប្លង់ដី ប្លង់ផ្ទះ សញ្ញាបត្រ និងបញ្ជីជាតិ ត្រូវអង្គការយកទៅដុតកម្ទេចចោលទាំងអស់។ គ្រួសាររបស់ខ្ញុំ នៅសេសសល់តែអីវ៉ាន់បន្តិចបន្តួចប៉ុណ្ណោះ។ នៅពេលដែលយើងគ្មានអាហារហូប យើងបាននាំគ្នាទៅជញ្ជាត់ត្រី ចាប់ក្តាម និងខ្យងយកមកធ្វើម្ហូប។

នៅពេលដែលយើងធ្វើដំណើរមកដល់ស្រុកកោះធំ កងឈ្លបបានឲ្យយើងចូលទៅស្នាក់នៅក្នុងវត្តកំពង់សំបួរ រង់ចាំអង្គការបែងចែក។ ឪពុករបស់ខ្ញុំ សុំកងឈ្លបរស់នៅជិតផ្ទះបងប្រុសរបស់ខ្ញុំក្នុងភូមិពោធិ៍រាមា ឃុំព្រែកស្តី ប៉ុន្តែកងឈ្លបមិនអនុញ្ញាតនោះទេ។ ក្រោយពីធ្វើប្រវត្តិរូបរួច អង្គការបានបង្ខំឲ្យគ្រួសារឪពុករបស់ខ្ញុំ ឆ្លងទន្លេទៅរស់នៅឃុំជ្រោយតាកែវ។ ទោះបីជាឪពុកម្តាយរបស់ខ្ញុំខំលាក់ប្រវត្តិរូបយ៉ាងណាក៏ដោយ ក៏អង្គការនៅតែចោទប្រកាន់ថា យើងជាអ្នកមូលធនដែរ។ បន្ទាប់ពីពីរបីថ្ងៃក្រោយមក ប្រជាជនជម្លៀសទាំងអស់ ទទួលបានបាយខ្ចប់ស្លឹកចេក ត្រីអាំង ត្រីងៀត ឆៃប៉ូវ អម្ពិលបុក និងអំបិលគ្រួស ម្នាក់មួយកញ្ចប់ពីប្រជាជនមូលដ្ឋាន។ ពេលនោះ ខ្ញុំបានឃើញប្រជាជនជម្លៀសផ្សេងទៀតទទួលបានបាយពណ៌លឿង ខ្ញុំក៏បានទៅសុំដូរយកបាយពណ៌លឿងដែរ។ តាមពិតបាយនោះ គឺជាបាយដែលដាំលាយជាមួយនឹងគ្រាប់ពោតតែប៉ុណ្ណោះ។

រយៈពេលជិត១ខែ ខ្ញុំនិងឪពុកម្តាយរបស់ខ្ញុំ បានធ្វើដំណើរទៅដល់ឃុំជ្រោយតាកែវ ស្រុកកោះធំ។ នៅទីនោះ បងប្រុសទី៤របស់ខ្ញុំ តែងតែលួចហែលឆ្លងទឹកទន្លេមកសួរសុខទុក្ខយើង ដោយមានយកក្តាម និងត្រីមកផ្ញើផងដែរ។ បងប្រុសរបស់ខ្ញុំ បានហាមយើងមិនឲ្យនិយាយអ្វីប៉ះពាល់ដល់អង្គការ និងដើរទៅណាមកណាស្រេចតាមចិត្តនោះទេ។ ក្រោយពីដឹងរឿងបងប្រុសរបស់ខ្ញុំលួចមកជួបយើង កងឈ្លប បានមកចាប់បញ្ជូនបងប្រុសរបស់ខ្ញុំតាមទូកយកទៅវិញ។

ពេលនោះ យើងមិនអាចជួយគាត់បានទេ គឺបានត្រឹមតែឈរមើលពីចម្ងាយ និងយំអាណិតអាសូរតែប៉ុណ្ណោះ។ អង្គការ បានចាប់យកបងប្រុសទី៤របស់ខ្ញុំទៅឃុំឃាំងអស់រយៈពេល៤ទៅ៥ថ្ងៃ ដោយប្រាប់ថានឹងយកគាត់ទៅអប់រំ ព្រោះបងប្រុសរបស់ខ្ញុំ ដើរសេរី ឆ្លងចូលឃុំផ្សេងៗ ហើយមិនគោរពវិន័យរបស់អង្គការទេ។ បងប្រុសរបស់ខ្ញុំ មិនបានអនុញ្ញាតឲ្យមកជួបប្រពន្ធ ឪពុកម្តាយនិងបងប្អូនឡើយ។ សំណាងល្អ ប្រពន្ធរបស់បងប្រុសខ្ញុំ គឺជាប្រជាជនមូលដ្ឋានបានទៅសុំគណៈឃុំព្រែកស្តី ឲ្យជួយសរសេរសំបុត្រធានាបងប្រុសរបស់ខ្ញុំ ទើបអង្គការព្រមដោះលែងគាត់មកវិញ។ នៅយប់មួយ បងប្រុសរបស់ខ្ញុំ បានបន្តលួចហែលទឹកឆ្លងទន្លេ ដើម្បីយកម្ហូបអាហារមកឲ្យឪពុកម្តាយរបស់ខ្ញុំទៀត ប៉ុន្តែយប់នេះ គាត់មិនហ៊ាននៅយូរទេ ព្រោះខ្លាចអង្គការចោទប្រកាន់ និងចាប់ឃុំឃាំងម្តងទៀត។

នៅក្នុងរបបខ្មែរក្រហម ក្រុមគ្រួសាររបស់ខ្ញុំ បានទទួលរងការងារលត់ដំជាច្រើន។ ឪពុកម្តាយរបស់ខ្ញុំបានមករស់នៅលើផ្ទះប្រជាជនមូលដ្ឋានក្នុងភូមិលេខ៤ ឃុំជ្រោយតាកែវ ដែលមានសមាជិកគ្រួសារចំនួន៦នាក់ និងសមាជិកគ្រួសារចិនចំនួន៣នាក់ទៀត។ អង្គការ បានបែងចែកឲ្យគ្រួសារទាំងអស់ដែលស្នាក់នៅក្នុងផ្ទះនេះទៅធ្វើការតាមក្រុមរៀងៗខ្លួន តាមភេទ និងតាមអាយុជាមួយនឹងប្រជាជនមូលដ្ឋាន។ នៅទីនោះ ប្រជាជនមូលដ្ឋានតែងតែសើចចំអកឲ្យខ្ញុំ ព្រោះតែខ្ញុំមានកាយវិការច្រេងច្រងាងខុសអ្នកឯទៀត នៅពេលដែលខ្ញុំអុំអង្ករ និងរែកទឹកដាក់ក្នុងពាង។ មួយរយៈក្រោយមក ប្អូនរបស់ខ្ញុំទាំងអស់ ត្រូវអង្គការលត់ដំឲ្យធ្វើការកាន់តែធ្ងន់ជាងមុនទៅទៀត។ អង្គការបានឲ្យពួកគេ រែកដី កាប់ព្រៃ ច្រូតស្រូវ គាស់គល់ឈើ លើកទំនប់ និងជីកប្រឡាយ។ នៅពេលឃើញពួកគេលំបាកដូច្នោះ ម្តាយរបស់ខ្ញុំ មិនដែលចោលកន្ទក់នោះទេបន្ទាប់ពីរែងអង្ករម្តងៗ។ ខ្ញុំហូបតែពោតជាមួយនឹងម្ហូប ជួនពេលខ្លះខ្ញុំមិនមានអ្វីហូបនោះទេ។ ចំណែកឯការងារវិញ ខ្ញុំត្រូវក្រោកទៅធ្វើការតាំងពីព្រលឹមរហូតដល់ព្រលប់ទើបត្រលប់មកកន្លែងស្នាក់នៅវិញ។ ថ្ងៃខ្លះ ខ្ញុំត្រូវប្រជុំបំពាក់បំប៉នគោលជំហរបដិវត្តន៍រហូតដល់យប់ជ្រៅថែមទៀត។

ថ្ងៃមួយពេលសម្រាកហូបបាយថ្ងៃត្រង់ សារ៉េត ដែលធ្លាប់រៀនជាមួយខ្ញុំមុនពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ បានឱ្យឪបប្រាប់ខ្ញុំថា នៅក្នុងក្រុមរបស់គាត់ អង្គការបានយកនារីម្នាក់ចេញទៅបាត់ដោយប្រាប់ថា យកទៅរៀនសូត្រ ព្រោះនារីនោះជាប្រពន្ធទីបីរបស់ឧត្តមសេនីយ៍នៅក្នុងរបប លន់ នល់។ ចំណែកខ្ញុំវិញ បានប្រាប់ទៅ សារ៉េត អំពីការងារធ្ងន់ដែលអង្គការបានដាក់ឲ្យខ្ញុំធ្វើ ហើយបានបង្ហាញពីកំភួនជើងរបស់ខ្ញុំដែលមានសុទ្ធតែស្នាមឆូត និងដំបៅ។

នៅពេលល្ងាច ខ្ញុំតែងតែភ័យខ្លាចសំឡេងសត្វយំក្នុងព្រៃកក់។ នៅពេលដែលខ្ញុំងាកមើលជុំវិញខ្លួន ហើយពុំឃើញមានអ្នកណាម្នាក់ ខ្ញុំបានរត់កាត់ស្មៅនិងបន្លាបណ្តាលឲ្យមុតជើងចេញឈាមជាច្រើនកន្លែង។ នៅពេលមកដល់ផ្ទះ ខ្ញុំឃើញម្តាយរបស់ខ្ញុំ មានរូបរាងស្គមស្គាំង ចំណែកឪពុករបស់ខ្ញុំ ដែលធ្លាប់មានក្បាលពោះគឺនៅសល់តែធ្នឹងជំនីតែប៉ុណ្ណោះ។ នៅពេលដែលខ្ញុំឃើញដូច្នេះហើយ ខ្ញុំបានរត់ទៅឱបម្តាយរួចយំឱ្យឪបប្រាប់គាត់ថា «ម៉ែកូនអាចស៊ូទ្រាំបាន»។ ខ្ញុំដឹងថាឪពុករបស់ខ្ញុំបាក់ទឹកចិត្ត ប៉ុន្តែខ្ញុំ និងម្តាយមិនអាចជួយគាត់បានទេ។ ខ្ញុំបានជួយប៉ះខោអាវឲ្យប្រជាជនមូលដ្ឋានបានស្អាត ទើបប្រជាជននៅទីនេះរាប់អាន និងស្រលាញ់ចូលចិត្តខ្ញុំ។ ពេលខ្លះ ខ្ញុំយកអាវផ្កាស្អាតៗមកកាត់ដេរជាអាវទ្រនាប់លក់ឲ្យនារីមូលដ្ឋាន និងដូរបានអង្ករ ត្រី អន្ទង់ និងឈ្នាង ដែរ។ បន្ទាប់មក អង្គការបានចាត់តាំងឲ្យខ្ញុំទៅច្រូតកក់ និងកាប់ឧស។ ខ្ញុំពិបាកណាស់ព្រោះខ្ញុំត្រូវដើរឆ្លងកាត់ទឹកជ្រៅៗ ថែមទាំងក្បាលរបស់ខ្ញុំ ត្រូវទូលឧសដើរបញ្ច្រាស់ខ្យល់ទៀត។ ប៉ុន្តែខ្ញុំសំណាងដែរ ដែលមានមិត្តនារីម្នាក់ មានចិត្តល្អបានជួយបង្រៀនខ្ញុំឲ្យចេះទូលឧស ព្រោះគាត់ឃើញខ្ញុំនៅតូច និងដើរបន្លឺមទឹកត្រឹមច្រមុះផុតធើយៗ។

ថ្ងៃមួយនៅរដូវប្រាំង កងនារី ត្រូវអង្គការស្នើឲ្យមកជួយស្ងួងស្រូវប្រាំងនៅជាប់មាត់ព្រែក ដែលស្ថិតនៅឃុំព្រែកស្តី។ នៅពេលសម្រាកថ្ងៃត្រង់ ខ្ញុំបានលួចកង់របស់អ្នកភូមិ ដើម្បីយកបបរដង់ឡូងរបស់ខ្ញុំទៅផ្ញើឪពុក ហើយនៅតាមផ្លូវ ខ្ញុំបានឈប់កង់ ដើម្បីលួចបេះប៉េងបោះទុំបាន ៨ផ្លែដែរ។ ទៅដល់ក្នុងផ្ទះ ខ្ញុំបានឃើញ

ឪពុករបស់ខ្ញុំ មានជំងឺវង្វេងម្តងៗ ហើយគាត់កំពុងតែគ្រវាត់កន្ទេល ខ្នើយ និងរបស់របរប្រើប្រាស់បោះចោល។ ឪពុករបស់ខ្ញុំ បានត្រឹមតែស្រក់ទឹកភ្នែក និងបានប្រគល់នាឡិកាដៃមួយគ្រឿងឲ្យមកខ្ញុំបន្ទាប់ពីពេលដែលគាត់បានឃើញដំឡូងដែលខ្ញុំយកទៅផ្ញើគាត់ហូប។

នៅពេលធ្វើការ ប្រជាជនជាច្រើនតែងតែចោទខ្ញុំថាជាអ្នកមូលធន និងមិនសូវនិយាយលេងជាមួយខ្ញុំទេ ទោះបីជាខ្ញុំព្យាយាមសួរគេក៏ដោយ។ ពេលរសៀលអង្គការបានដកក្រុមរបស់ខ្ញុំ ឲ្យទៅច្រូតស្រូវដែលទុំបាក់កនៅទួលដំរីស្លាប់ក្នុងភូមិអន្លង់សាន។ ពេលនោះ ខ្ញុំខំច្រូតស្រូវមិនហ៊ានឈប់សម្រាកទេ ទោះបីជាហេវហត់ឬក្តៅយ៉ាងណាក៏ដោយ។ ម៉ោងប្រហែលជា ១ថ្ងៃត្រង់ទើបប្រធានកងបានឲ្យខ្ញុំឈប់សម្រាកហូបបាយនៅក្រោមម្លប់ដើមក្តុល។ រយៈពេល៣ថ្ងៃក្រោយមក ចាស់ៗមកពីភូមិ បានប្រាប់ខ្ញុំថាឪពុករបស់ខ្ញុំស្លាប់ហើយបន្ទាប់ពីគ្រូពេទ្យបុរាណបានឲ្យគាត់លេបថ្នាំចំនួន២គ្រាប់។ ពេលដែលខ្ញុំឮដូច្នោះ ខ្ញុំបានដើរទៅសុំច្បាប់ប្រធានកង ដើម្បីទៅចូលរួមបុណ្យសពឪពុករបស់ខ្ញុំនៅឯផ្ទះ ប៉ុន្តែអង្គការមិនអនុញ្ញាតទេ ថែមទាំងនិយាយថា «មិត្តឯងមិនឃើញការងារកំពុងសម្រុកទេឬ? ហើយនរណាជាអ្នកប្រាប់រឿងនេះដល់មិត្តឯង»។ សមាជិកនៅក្នុងកងនៅស្ងៀម និងខំប្រឹងច្រូតស្រូវបន្តទៀត។ មួយសន្ទុះក្រោយមក ប្រធានកងបានអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកមួយថ្ងៃ ព្រោះគាត់ឃើញខ្ញុំស្រក់ទឹកភ្នែកមិនហូបបាយ និងមិននិយាយស្តីដោយសាររឿងឪពុករបស់ខ្ញុំស្លាប់។ នៅពេលដែលខ្ញុំទៅដល់ផ្ទះ សាកសពឪពុករបស់ខ្ញុំ ត្រូវអ្នកស្រុកយកទៅកប់រួចជាស្រេច។ ខ្ញុំបានឃើញម្តាយរបស់ខ្ញុំមានទឹកមុខស្លេកស្លាំងដើរត្រលប់មកពីធ្វើការវិញ។ យប់នេះ ខ្ញុំបានសម្រាកជាមួយម្តាយរបស់ខ្ញុំបានមួយយប់ដែរ។

បន្ទាប់ពីធ្វើការងារនៅក្នុងភូមិអន្លង់សានរួចមក ក្រុមរបស់ខ្ញុំ ត្រូវប្តូរមកស្នាក់នៅជង្រុកស្រូវក្នុងវត្តទួលទំនប់ក្បែរអនុវិទ្យាល័យកំពុងកុងវិញ។ នៅទីនោះ មិត្តឈាង ជាគណៈមេកង បានមកបំផុសឲ្យយើងរែកដីម្នាងពីរបង្គី ដោយប្រកាសថា សូមយកគំរូយុទ្ធមិត្តស្រែអំបិល ដែលអាចរែកដីបានបែបនេះ

មិនចាញ់យុវជនឡើយ។ រយៈពេល ៤ទៅ ៥ថ្ងៃ អង្គការ បានបើកសន្និបាតនៅឃុំកំពង់កុង។ បន្ទាប់ពីបញ្ចប់កិច្ចប្រជុំ ប្រធាន «គ» បានហៅខ្ញុំឲ្យទៅបើកសំពត់អាវ និងក្រមាថ្មី។ ទន្ទឹមពេលនោះ គណៈស្រុកបាននិយាយរិះគន់ពីរបបសង្គមចាស់ដែលពាក់អាវវាលកចំហទ្រូង។ គណៈស្រុកបន្ថែមថា មានខ្មាំងច្រើនណាស់ចូលមកបន្លំខ្លួនក្នុងជួរបដិវត្តន៍ ដូចជាខ្លះចាក់បាយចោល ខ្លះធ្វើឲ្យបាត់ខ្សែ និងបាត់ដងវែកជាដើម ប៉ុន្តែអង្គការ ឈ្លាសវៃដឹងពីសកម្មភាពក្បត់នេះបានមុន និងប្តេជ្ញាកម្ទេចខ្មាំងមិនឲ្យសេសសល់ ដើម្បីភាពស្រស់ថ្លានៃបដិវត្តន៍មហាអស្ចារ្យមហារុងរឿង។ បន្ទាប់មក អង្គប្រជុំទះដៃទាំងអស់គ្នា រួចអញ្ជើញសមាជិកសន្និបាតឡើងមានចំណាប់អារម្មណ៍។

ពេលទឹកស្រក អង្គការត្រូវការកម្លាំងនារី១៧មេសា ជាច្រើនចុះស្ទូង ចំណែកឯយុវជនសម្រុកជីកប្រឡាយ។ ចំណែកខ្ញុំ ត្រូវជញ្ជូនកម្ទេចឈើទៅគរទុកសម្រាប់ដុតចោល។ កន្លះខែក្រោយមក ពេលដែលខ្ញុំកំពុងដកព្រលឹត និងដើមឈូក មាននារីពេទ្យ និងកុមារនិសោរបស់គណៈវរៈបានមកហៅប្រធានកង ប្រធានក្រុមឲ្យទៅជួប។ ពេលនោះ ប្រធានកង បានហៅឈ្មោះបងស្រី និងនារី ៨ទៅ ៩នាក់ទៀតទៅកាន់រោងដើម្បីផ្លាស់កង។ ទៅដល់រោង ប្រធានកង បានប្រាប់យើងទៅរៀបចំខោអាវ ដោយមិនចាំបាច់យកអ្វីទៅជាមួយទេ។ នៅពេលល្ងាច ស៊ាន ដែលជាម្ចាស់ផ្ទះ បានប្រគល់កាតាបខោអាវ និងមុង ដែលបងស្រីរបស់ខ្ញុំផ្ញើឲ្យ ហើយផ្តាំខ្ញុំថា «កុំឲ្យប្រាប់ម៉ែឲ្យសោះ»។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានជួបនឹងបងស្រីទៀតទេ។ យប់មួយនៅពេលដែលខ្ញុំដើរទៅដកសំណាបនៅវាលស្រែ ខ្ញុំបានជួបជាមួយនឹងបងប្រុសទីបួនរបស់ខ្ញុំដែលមានរូបរាងស្គមស្គាំងកំពុងតែធាក់រហាត់ទឹក។ ខ្ញុំមិនបានប្រាប់គាត់អំពីរឿងបងស្រីរបស់ខ្ញុំទេ ។

ក្រោយមក ខ្ញុំត្រូវទៅលើកទំនប់ ១៧មេសា ដែលភ្ជាប់ពីទន្លេកោះធំ ទៅស្រុកលើកដែក ហើយខ្ញុំត្រូវស្នាក់នៅរោងក្នុងបឹងក្បែរទំនប់នោះ។ មិត្តនារីលន បានមកខ្សឹបប្រាប់ខ្ញុំឲ្យប្រយ័ត្នប្រយែងមាត់ ព្រោះគាត់បានឮប្រធាន «គ» ប្រាប់ មិត្តស៊ីង ដែលជាកងឈ្លបក្នុងក្រុមឲ្យតាមដានខ្ញុំ។ ប្រធាន «គ» សង្ស័យ

ថាខ្ញុំគឺជាខ្សែរយៈ សេ-អ៊ី-អា។ ឮដូចនេះ ខ្ញុំភ័យយ៉ាងខ្លាំង។ ថ្ងៃមួយ អង្គការបានចាត់តាំងឲ្យខ្ញុំចុះបឹង ដែលមានជម្រៅត្រឹមច្រមុះ ស្រាប់តែពេលនោះមានបុរសចំនួន ៨នាក់ បានកាន់ផ្តាក់ និងកណ្តៀវមកសួរចម្លើយខ្ញុំ ដើម្បីឲ្យខ្ញុំឆ្លើយថាជា សេ-អ៊ី-អា ឬជា កា-ហ្សេ-បេ។ ចម្លើយរបស់ខ្ញុំ គឺនៅតែជាសិស្សដដែល។ បន្ទាប់មក ក្រុមសួរចម្លើយបានបញ្ជាឲ្យខ្ញុំទៅធ្វើការ និងហាមខ្ញុំមិនឲ្យនិយាយប្រាប់ពីរឿងរ៉ាវនេះដល់អ្នកដទៃឡើយ។

នៅពេលដែលទំនប់ ១៧មេសា បានលើកជិតមកដល់ភូមិ អង្គការបានចាត់តាំងខ្ញុំឲ្យដឹកដីពីបាតព្រែក។ ថ្ងៃមួយព្រះអាទិត្យបញ្ចេញកំដៅយ៉ាងខ្លាំងដែលធ្វើឲ្យមិត្តនារីម្នាក់ក្នុងកងរបស់ខ្ញុំខ្យល់គរដួលស្លាប់ទាំងដៃកាន់ចប។ ព្រលប់ថ្ងៃនោះ មេយជិតធ្លាក់ភ្លៀង ហើយមានធ្លាក់ខ្យល់ខ្លាំងណាស់។ ខ្ញុំត្រូវខ្យល់បើងដួលរមៀលធ្លាក់ចូលទៅក្នុងបាតទំនប់។ ខ្ញុំងើបឡើងពីបាតទំនប់មិនរួចទេ ទើបមិត្តកក្តិរបស់ខ្ញុំ ចុះមកជួយអូសខ្ញុំឡើងទៅលើ។

ក្រោយមក រដូវស្រូវទុំ បានមកដល់ អង្គការស្នើឲ្យមិត្តនារី និងយុវជន ១៧មេសា ទៅជួយសម្រុកច្រូតស្រូវនៅក្នុងឃុំសំពៅពូន។ ចំណែកយុវជនចំនួន២នាក់ ដឹកជញ្ជូនកណ្តាប់ និងបោកស្រូវ។ បន្ទាប់ពីហូបបាយរួច អង្គការបានបញ្ជាឲ្យយើងចុះច្រូតស្រូវក្បែរមាត់ប្រឡាយ ហើយបានប្រហែលជាកន្លះម៉ោង មិត្តនារីម្នាក់ដែលច្រូតស្រូវក្បែរខ្ញុំ បាននិយាយតិចៗប្រាប់ខ្ញុំឲ្យមើលយុវជនប្រមាណ១០នាក់ ដែលត្រូវកងឈ្លបបណ្តើរយកទៅ។ ក្នុងចំណោមនោះ ខ្ញុំស្គាល់ច្បាស់យុវជនម្នាក់គឺជាបងប្រុសទី៤របស់ខ្ញុំ។ ខ្ញុំមិនអាចជួយអ្វីដល់គាត់បានទេ គឺបានត្រឹមតែសម្រក់ទឹកភ្នែកតែប៉ុណ្ណោះ។

មិនយូរប៉ុន្មាន អង្គការ បានផ្លាស់ខ្ញុំឲ្យទៅធ្វើការងារនៅក្បែរទួលគុហាវិញ។ នៅទីនោះ រែកដី លំបាកណាស់ ព្រោះមានភ្លៀងធ្លាក់ខ្លាំង។ អង្គការ រឹតបន្តឹងមិនអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកសូម្បីតែមួយថ្ងៃនោះទេ ទោះបីជាជើងរបស់ខ្ញុំមុតចបមិនអាចដើរបានក៏ដោយ។ ខ្ញុំបានយកខ្សែមកចងមុខរបួសឲ្យជិត កុំឲ្យចូលដី ហើយចុះទៅធ្វើការបន្តទៀត ព្រោះខ្លាចអង្គការចាប់កំហុសថាខ្ញុំខ្ជិល

ធ្វើការងារ។ ខ្ញុំខ្លាចណាស់ ស្ថិតក្នុងកាល:ទេស:ណាក៏អង្គការចោទប្រកាន់បានដែរ។ ថ្ងៃនោះ នៅពេលដែលសមាជិកក្នុងក្រុមរបស់ខ្ញុំមានជំងឺ និងពេលធ្វើការបានរអិលជើងធ្លាក់ចូលក្នុងប្រឡាយ ប្រធាន «គ» បានចោទប្រកាន់នារីនោះថាបង្កើតសកម្មភាពខ្មាំង រួចបានបញ្ជាឲ្យទៅរៀបចំខោអាវ ដើម្បីផ្លាស់ប្តូរភ្លាម។ មួយសន្ទុះក្រោយមក ប្រធានក្រុមបានរត់មកប្រាប់ថា នារីម្នាក់នោះបានលេបគ្រាប់ស្លែងស្លាប់បាត់ទៅហើយ។

ក្រោយមក ខ្ញុំបានរៀបការជាមួយបុរសម្នាក់ ហើយត្រូវមករស់នៅក្នុងខ្ទមតូចៗ តម្រៀបជួរគ្នាក្បែរមាត់ស្ទឹង ដើម្បីកាត់ក្បាលត្រីធ្វើប្រហុក និងក្លួរាស់ដកស្ងួតវិញ។ ពេលថ្ងៃ យើងទៅធ្វើការរៀងៗខ្លួន ហើយពេលព្រលប់ យើងនាំគ្នាអង្គុយនៅបាតរណ្តៅផ្អែកនឹងជញ្ជាំង ដើម្បីស្តាប់ស្នូរគ្រាប់កាំភ្លើងផ្ទុះ។ មិនយូរប៉ុន្មាន នៅពេលដែលខ្ញុំកំពុងស្ងួតស្រូវនៅខាងត្បូងរោង ស្រាប់តែខ្ញុំឃើញមនុស្សជាច្រើន ដើរលើទំនប់ ៦មករា ឆ្លងស្ទឹងទៅកាន់ខេត្តតាកែវ។ ខ្ញុំភ័យណាស់ ហើយបានអង្គុយសម្ងំក្នុងខ្ទមរៀបចំខោអាវច្រកចូលក្នុងកាតាប ដើម្បីរង់ចាំប្តីដែលទៅភ្ជួរនៅឆ្ងាយត្រលប់មកវិញ។ ខ្ញុំស្ពាយកាតាបចំនួន ២យ៉ាង ធ្ងន់ រត់ទៅមុខតាមប្រជាជនដោយភ្នែកសម្លឹងរកមើលប្តី និងព្យាយាមស៊ើបសួរដំណឹងពីប្តី។ ខ្ញុំបានធ្វើដំណើរជាច្រើនម៉ោង រួចក៏បានជួបប្តីរបស់ខ្ញុំនៅមាត់ស្ទឹង ហើយយើងបាននាំគ្នារត់ទៅខេត្តតាកែវ។

ទោះបីជារបបខ្មែរក្រហមដួលរលំ ខ្ញុំនៅតែមិនអាចបំភ្លេចបាននូវរឿងដែលខ្មែរក្រហមធ្វើមកលើខ្ញុំ គ្រួសារ និងបងប្អូនរបស់ខ្ញុំ ដែលបានស្លាប់បាត់បង់ជីវិតឡើយ។ នៅពេលនឹកឃើញដល់រឿងនេះ ទឹកភ្នែករបស់ខ្ញុំតែងតែចាប់ផ្តើមស្រក់ដោយមិនដឹងខ្លួន។

ចប់

២៦

រឿងក្រោមមេឃដីគ

ផ្អែកតាមរឿងពិតរបស់អ្នកស្រី ង៉ា ស្រីមុំ

អ្នកនិពន្ធ ៖ លឹម ថាន់ណា

២៦ ~ រឿង ក្រោមមេឃដដែរ

ផ្អែកតាមរឿងពិតរបស់អ្នកស្រី ខ៉ា ស្រីមុំ

ព្រឹកនេះ ពេលទៅដល់កន្លែងធ្វើការ ខ្ញុំបានឃើញព័ត៌មានក្នុងបណ្តាញសង្គម ចុះផ្សាយព្រោងព្រាតអំពីដំណឹងមរណភាពរបស់អតីតមេដឹកនាំខ្មែរក្រហមម្នាក់ គឺ លោក នួន ជា។ រឿងនេះ បានក្លាយជាប្រធានបទ ដែលមិត្តរួមការងាររបស់ខ្ញុំ នាំគ្នាជជែកវិភាគតាមទស្សនៈរៀងៗខ្លួន។ យ៉ាងណាមិញ ការស្លាប់របស់អតីតមេដឹកនាំខ្មែរក្រហមម្នាក់នេះ ហាក់មិនបានធ្វើឲ្យនរណាម្នាក់ មានអារម្មណ៍សោកស្តាយនោះទេ។ ពេលត្រលប់មកដល់ផ្ទះវិញ ខ្ញុំបានឮប៉ាម៉ាក់របស់ខ្ញុំជជែកពីរឿងនេះដែរ។ ពួកគាត់សុទ្ធតែជាអ្នកដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម។

«អហោសិកម្មឲ្យគាត់ធ្វើយ៉ាងម៉េចបើគាត់ស្លាប់ហើយ» នេះជាសំឡេងម៉ាក់របស់ខ្ញុំ ដែលនិយាយទៅកាន់ប៉ា ហើយប៉ាក៏តបទៅម៉ាក់វិញដែរថា «អ្នកខ្លះក៏បានសប់ចិត្ត ពេលគាត់ស្លាប់ វាអាស្រ័យលើការឈឺចាប់ខ្លាំងឬតិចរបស់អ្នកដែលឆ្លងកាត់របបហ្នឹង»។

ខ្ញុំ បានចូលទៅនិយាយជាមួយប៉ាម៉ាក់របស់ខ្ញុំពីរឿងនេះដែរ។

«ប៉ា! ម៉ាក់! និយាយអីចឹង ប៉ានិងម៉ាក់ មានអារម្មណ៍យ៉ាងម៉េចដែរ ពេលតា នួន ជា ស្លាប់បែបនេះ»។

ម៉ាក់ តបដោយធម្មតាថា «រឿងហ្នឹង វាកន្លងហួសទៅយូរឆ្នាំហើយ ម៉ាក់ដូចជាធម្មតា គ្មានអារម្មណ៍អីជិតជាមខ្លាំងជាមួយព្រឹត្តិការណ៍ហ្នឹងផង»។

ប៉ា បានឆ្លើយបន្តពីម៉ាក់ថា «ប៉ាវិញ ក៏ដូចជាធម្មតាដែរហ្នឹង ប្រហែលដោយសារកាលជំនាន់ហ្នឹង កន្លែងប៉ារស់នៅ មិនសូវមានគេធ្វើបាបខ្លាំង ហើយម៉ែឪប៉ា ក៏នៅរស់ដល់ក្រោយបែកអាពត»។

ខ្ញុំឮប៉ា និងម៉ាក់ មានប្រសាសន៍បែបនេះ រាងធូរក្នុងចិត្ត ព្រោះរាល់ថ្ងៃ ខ្ញុំធ្វើការខាងផ្នែកផ្លូវចិត្ត មិនខ្វះទេចាស់ៗដែលធ្លាប់ឆ្លងកាត់ព្រឹត្តិការណ៍សម័យខ្មែរក្រហម បានទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត។

ការនិទានពីការចចចាំរបស់ម្ដាយខ្ញុំនៅក្នុងរបបខ្មែរក្រហម

ចន្លោះពីឆ្នាំ១៩៧៣ ដល់១៩៧៥ ខ្ញុំ បានចាកឆ្ងាយពីគ្រួសារមករស់នៅក្នុងស្រុកកោះសូទិន។ ខ្ញុំទៅធ្វើជាកុមារឈានមុខនៅសម័យបដិវត្តន៍ តាមរយៈឪពុកមាទី២របស់ខ្ញុំ ដែលទៅធ្វើបដិវត្តន៍។ នៅកន្លែងកុមារឈានមុខនោះ ខ្ញុំត្រូវរស់នៅផ្តុំគ្នាជាមួយកុមារដទៃទៀត។ ស្រីនៅដោយស្រី ប្រុសនៅដោយប្រុស ហើយកន្លែងដេកវិញ គេធ្វើរោងផុតពីដី ដេកទល់ជើងគ្នា។ កុមារឈានមុខ អង្គការឲ្យរៀនសូត្របានតិចតួច ក្រៅពីរៀន យើងទៅចម្ការដាំពោត ដាំបន្លែ និងស្រោចទឹកបន្លែ។ លុះដល់ខែពោតទុំ អង្គការឲ្យយើងប្រទ្បេះពោត និងយកពោតទៅជាន់ធ្វើជាអង្ករ ដើម្បីបានយកមកលាយជាមួយអង្ករយកមកដាំជាបាយហូប។ បើពោតណាចាស់ល្មម គេឲ្យយើងយកទៅស្ងោរ ហើយយកមកឈូសលាយជាមួយបាយតែម្តង។

ក្រោយមកទៀត ខ្ញុំ និងកុមារផ្សេងទៀត ត្រូវបានក្រសួងដែលធ្វើថ្នាំកាតាបស្នើឲ្យទៅធ្វើថ្នាំនៅមន្ទីរពេណិជ្ជកម្មរដ្ឋ។ ថ្នាំកាតាប គឺជាថ្នាំជក់ដែលគេយកមកធ្វើជាបារី ដែលភាគច្រើនគេដាំនៅស្រុកកោះសូទិន។ ការងាររបស់ខ្ញុំមិនត្រឹមតែហាន់ថ្នាំនោះទេ ពេលខ្លះគេប្រើខ្ញុំឲ្យរែកទឹកផងដែរ។ យូរៗម្តងទើបខ្ញុំបានទៅលេងម្តាយនៅស្រុកកំណើតនៅឯស្រុកពារាំង ខេត្តព្រៃវែង។ ក្នុងវ័យជាង១០ឆ្នាំ ខ្ញុំមិនបានយល់ដឹងអ្វីច្រើនពីបញ្ហានយោបាយស្រុកទេសឲ្យបានច្បាស់លាស់នោះទេ។ ខ្ញុំបានត្រឹមតែស្តាប់ចាស់ៗដែលធ្វើការជាមួយខ្ញុំ ជជែកគ្នាពីសង្គ្រាមផ្តួលរំលំពួកសាធារណរដ្ឋខ្មែរតែប៉ុណ្ណោះ។ ពេលមួយនៅក្នុងមន្ទីរ

ហាន់ថ្នាំកាតាប ខ្ញុំបានឮចាស់ៗ និយាយគ្នាថា «លុយយើងហ្នឹង បន្តិចទៀតគេលែងចាយហើយ»។ តាម្នាក់ក្បែរនោះបន្ថែមទៀតថា «តិចទៀតម៉ូតូខ្ញុំក៏គេដាក់រួមដែរ ស្អីៗក៏របស់រួមដែរ»។ ឮដូច្នេះ ខ្ញុំ ចេះតែលួចធ្ងល់ក្នុងចិត្តទាំងដៃលសួរនាំពួកគាត់ ប៉ុន្តែគ្មានអ្នកណាប្រាប់។

ពេលមួយ ឪពុកមាទី៤របស់ខ្ញុំ បានមកលេងខ្ញុំ។ រាល់ដង ខ្ញុំធ្លាប់សុំលុយគាត់១០រៀលឬ ២០រៀល ទុកចាយ តែលើកនេះស្រាប់តែគាត់ឲ្យលុយខ្ញុំដល់៥០០រៀល។ ខ្ញុំចាយតែមួយភ្លែតអស់ព្រោះអីវ៉ាន់ចេះតែឡើងថ្លៃទៅៗ។ ប្រហែល៣ ខែក្រោយមក ស្រាប់តែខ្ញុំ បានឮគេថា បែក១៧មេសាហើយ ចំណែកលុយក៏គេលែងចាយដែរ។

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកប៉ុល ពត បានវាយបែកទីក្រុងភ្នំពេញ ដែលពេលនោះ ខ្ញុំ កំពុងតែហាន់ថ្នាំកាតាបនៅឯរោងជាមួយអ្នកធ្វើការផ្សេងទៀត។ មានប្រជាជនជាច្រើនកកកុញ បានធ្វើដំណើរឆ្លងកាត់កន្លែងនោះ ដោយមានកងទ័ពស្លៀកពាក់ខោអាវខ្មៅត្រៀបត្រាអមដំណើរ។ ហេតុការណ៍នេះ បានកើតឡើងនៅពេលដែល កងទ័ពខ្មែរក្រហម វាយបែកទីក្រុងភ្នំពេញ ហើយបានជម្លៀសប្រជាជនឲ្យចាកចេញពីទីក្រុង។ ខ្មែរក្រហម ប្រាប់ប្រជាជនថា ឲ្យចាកចេញមួយរយៈ ព្រោះអាមេរិកនឹងទម្លាក់គ្រាប់បែកមកលើទីក្រុងភ្នំពេញ។ មិនយូរប៉ុន្មាន ខ្ញុំត្រូវបានអង្គការផ្លាស់ឲ្យទៅនៅកន្លែងស្លឹឱសថបុរាណក្នុងមន្ទីរធ្វើឱសថរបស់ក្រសួងសុខាភិបាលសម័យខ្មែរក្រហម។

របបថ្មីដែលកាន់កាប់ដោយក្រុមខ្មែរក្រហមនេះ បានប្រកាសថា ស្រុកមានសន្តិភាពហើយ ដូច្នេះ ឪពុកមាទី២ របស់ខ្ញុំ ត្រូវបានគេរំសាយការងារនៅស្រុកកោះសូទិន ហើយបាននាំខ្ញុំ ត្រលប់មកនៅឯស្រុកកំណើតនៅកំពង់ទ្រា ស្រុកពារាំង ខេត្តព្រៃវែងវិញ។ បន្ទាប់ពីនោះប៉ុន្មានថ្ងៃ ប្អូនស្រីរបស់ខ្ញុំ បានសួរទៅម្តាយរបស់ខ្ញុំថា «ម៉ែម៉េចមិនឲ្យបងមុំចូលរៀនវិញ?» ម្តាយរបស់ខ្ញុំតបថា «មិនបាច់រៀនអីទេ យើងត្រូវចូលធ្វើការជាមួយចាស់ៗនៅក្នុងភូមិទៅ ដើម្បីយករបបស្រូវមកហូបតាមគ្រួសារ»។ ពេលធ្វើការជាមួយចាស់ៗ ខ្ញុំ ត្រូវដកស្ទូង និងកិនស្រូវ

ជាដើម។ ក្រោយមកប្រធានភូមិបានដើរប្រាប់តាមផ្ទះថា គ្រួសារណាមានកូនធំៗ អង្គការឲ្យទៅនៅកងចល័ត ដើម្បីធ្វើស្រូវសម្រាប់ផ្គត់ផ្គង់សហករណ៍។ ពេលចូលទៅកងចល័ត ខ្ញុំលែងបាននៅជុំគ្រួសារទៀតហើយ ព្រោះអង្គការបានបែងចែកកងចល័តឲ្យស្នាក់នៅដាច់ដោយឡែកពីគ្រួសារ។

នៅដើមឆ្នាំ១៩៧៦ ខ្ញុំទៅធ្វើស្រែជាមួយកងចល័តពីភូមិមួយទៅភូមិមួយទៀត។ ចាស់ៗក្នុងភូមិណាស្ទូងឬច្រូតមិនទាន់ អង្គការបានឲ្យក្រុមកងចល័តរបស់ខ្ញុំ ដែលមានអាយុ១៤ទៅ១៥ឆ្នាំ ទៅជួយ។ ខ្ញុំត្រូវទៅជួយស្ទូងស្រូវ ហាលស្រូវ កើបស្រូវដាក់ឃ្លាំង និងយកស្រូវទៅកិន ដើម្បីបានអង្គរដាំបាយហូបរួម។ ក្នុងមួយភូមិ អង្គការចែកចេញជាក្រុមៗ ដើម្បីមកហូបរួម ដែលមានចុងភៅពី៤ទៅ៥នាក់ ចាំធ្វើឲ្យហូប។ បាយដែលដាំហូបរួមនៅពេលនោះមិនមែនដាំដោយប្រើអង្គរសុទ្ធនោះទេ ពេលខ្លះ ចុងភៅដាំលាយដំឡូងនិងពោត។ ខែខ្លះទៀត ចុងភៅដាំបបរលាយដំឡូង ដែលជាបបរគោកៗ។ ឯម្ហូបវិញ មានតែម្ហូរព្រលិត ម្ហូរត្រកួន និងម្ហូរដើមចេកតែប៉ុណ្ណឹង។ នៅពេលអត់ឃ្លានដូច្នេះ ខ្ញុំ តែងតែទៅសុំអំបិលពីចុងភៅជាញយដង យកមកសន្សំទុកឲ្យបានច្រើន រហូតដល់ចុងភៅធ្ងល់តែពួកគេមិនសួរនាំខ្ញុំអ្វីច្រើនដែរ គ្រាន់តែអ៊ូថាសុំម្តងហើយម្តងទៀតមិនចេះចប់។ ក្រៅពីសន្សំអំបិលទុក ខែស្ទូងម្តងៗ ខ្ញុំស្ទូងស្រូវបណ្តើរ និងចាប់ក្តាមបណ្តើរ។ ខ្ញុំ ចាប់ក្តាមបាន ក៏យកមកមូរនឹងចង្កេះខោ ឬជើងខោ។ ខ្ញុំបានយកក្តាមទាំងនោះមកត្រាំជាមួយអំបិលដែលខ្ញុំសន្សំបាននោះ ទុកហូបដោយលួចលាក់មិនឲ្យចុងភៅដឹងឡើយ។ ផុតខែស្ទូង ស្រូវចាប់ផ្តើមបែកគុម្ព ហើយក្តាមក៏មានច្រើនដែរនៅក្នុងស្រែ។ អង្គការបន្តប្រើក្រុមកងចល័តមិនឲ្យទំនេរដៃឡើយ។ ខ្ញុំត្រូវអង្គការប្រើឲ្យធ្វើការតាមវាលស្រែ ដូច្នោះ ខ្ញុំមានឱកាសដើរចាប់ក្តាមយកទៅឲ្យចុងភៅត្រាំហូប ប៉ុន្តែចុងភៅនៅសហករណ៍គ្មានអ្នកណាចេះត្រាំទេ។ ពួកគេ គ្រាន់តែដាក់ក្តាមក្នុងធុងស័ង្កសី រួចដាំទឹកក្តៅចាក់ចូល ធ្វើឲ្យក្តាមត្រាំនោះខូចអស់ហូបមិនកើត។

ពេលដែល ខ្ញុំ ធ្វើការនៅកងចល័ត មាទី២របស់ខ្ញុំ ត្រូវជាប់គុកនៅព្រៃស្រលិត ព្រោះអង្គការចោទប្រកាន់ថា គ្រួសារខាងប្រពន្ធរបស់គាត់ ជាតំណាងរាស្ត្រខេត្តព្រៃវែងតាំងពីសម័យសម្តេចឪ។ ប្រពន្ធរបស់គាត់កូនខ្ចីមិនអាចទៅសួរសុខទុក្ខគាត់បានទេ ដូច្នេះមានតែម្តាយរបស់ខ្ញុំប៉ុណ្ណោះ ដែលលួចលាក់ទៅមើលប្អូនរបស់គាត់ មានយកម្ហូប និងខោអាវ ព្រមទាំងថ្នាំសង្កូវធ្វើទៅមារបស់ខ្ញុំដែរ។ ជាអកុសលរបស់របរដែលម្តាយរបស់ខ្ញុំយកទៅទាំងនោះ មិនដែលបានទៅដល់មារបស់ខ្ញុំឡើយ ព្រោះត្រូវពួកកម្មាភិបាលយកទុកអស់ ហើយថែមទាំងវាយធ្វើបាបប្អូនមារបស់ខ្ញុំទៀត។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ អង្គការចាត់តាំងឲ្យខ្ញុំ និងកងចល័តស្រីៗ ទៅជួយរែកដីជាមួយក្រុមប្រុសៗ ដើម្បីទប់ទន្លេតូច។ ការរែកដីនៅទីនោះ ពិបាកជាងទៅស្ទូងទៅទៀត ព្រោះម្នាក់ៗមិនមានស្បែកជើងពាក់ឡើយ។ យើងត្រូវដើរដោយជើងទទេរហូតពងជើងគ្រប់ៗគ្នា។ ការរែកដីទប់ទន្លេតូចនោះ ត្រូវចំណាយពេលជិត២ឆ្នាំ ទម្រាំអាចចាក់ដីបំពេញស្មើនឹងថ្នល់ ហើយឡានដឹកស្រូវអាចបើកឆ្លងកាត់ទៅមកបាន។ រាល់ពេលរែកដីរួចម្តងៗ គេជាក់ធុងបាយ ដើម្បីយកឲ្យពួកកងចល័តហូប ដោយក្នុងម្នាក់ទទួលបានត្រឹមបាយមួយកូនចានតែប៉ុណ្ណោះ។ នៅមុនពេលហូបបាយ ចុងភៅ បានយកចានរបស់ខ្ញុំ មកដួសបាយវាល់ឲ្យគេគ្រប់គ្នាសិន ព្រោះចានខ្ញុំតូចជាងគេ។ ខ្ញុំ ត្រូវហូបបាយក្រោយគេរហូត។ បាយត្រឹមមួយកូនចានមិនអាចធ្វើឲ្យខ្ញុំ និងក្រុមកងចល័តឯទៀត ហូបឆ្អែតបានឡើយ តែទោះជាហូបមិនឆ្អែតក៏យើងមិនអាចទទួលបានលើសពីមួយចាននោះដែរ។

នៅក្នុងរដូវវស្សាខែកក្កដា និងសីហា ឆ្នាំ១៩៧៨ ទឹកឡើងធំណាស់លិចភូមិអស់ ហើយប្រជាជនទាំងអស់គ្មានកន្លែងនៅទេ។ ពេលនោះ ពួកកងចល័តរបស់ខ្ញុំ ត្រូវអង្គការបញ្ជូនតាមកាណូតទៅសង្កាត់មេសប្រចាន់វិញ ដោយមួយកាណូតនោះមានផ្ទុកមនុស្សប្រហែល៥០នាក់ ជិះកាត់បឹងទ្រាំង បឹងថេ និងស្ទឹងពាំង។ ទឹកលិចល្ហាចល្ហឹម មើលឃើញតែចុងឈើលឹមៗងើបផុតពីផ្ទៃទឹក។ ពេលមកដល់ ផ្ទះរបស់ខ្ញុំទឹកលិចផ្ទះអស់ នៅតែទួលវត្តកំពង់ទ្រាទេ។ ភ្លឺឡើងក្រុមរបស់ខ្ញុំ ត្រូវអង្គការផ្លាស់ឲ្យទៅជួយហាលស្រូវជាមួយចាស់ៗនៅទួលវត្ត

កំពង់ទ្រា។ ចាប់តាំងពីពេលនោះមក ខ្ញុំ បានត្រលប់មករស់នៅក្នុងស្រុកកំណើតរបស់ខ្ញុំវិញ។ ឯកងចល័តផ្សេងទៀត ក៏ទៅនៅតាមភូមិរៀងៗខ្លួន ព្រោះទឹកលិចអស់ហើយ គ្មានកន្លែងណាអាចស្នូង អាចច្រូតបានទៀតទេ។

នៅចុងឆ្នាំ១៩៧៨ អង្គការបានប្រើឲ្យខ្ញុំទៅដកសំណាបស្នូងស្រូវនៅឯស្នាយពល ស្រុកពារាំង។ ថ្ងៃមួយ ខ្ញុំកំពុងតែស្នូងស្រូវ ជាមួយមិត្តផ្សេងទៀត ស្រាប់តែមានគេបោះត្រាក់ (លិខិត ប៉ុនៗបាតដៃ) ពីលើយន្តហោះមក។ នៅលើក្រដាសនោះសរសេរពីឈ្មោះអ្នកនេះក្បត់អ្នកនោះក្បត់។ ខ្ញុំ បានរើសយកមកមើល ឃើញសារក្នុងលិខិតនោះ ខ្ញុំក៏និយាយជាមួយមិត្តមកពីស្រុកថា «ក្បត់ម៉ាបូព៌ាយើងនៅរស់ទេ តែបើក្បត់មួយមជ្ឈិមអី យើងច្បាស់ជាងាប់ហើយ»។ មិនបានប៉ុន្មានផង ក្រុមខ្មែរក្រហម បានជម្លៀសប្រជាជនទាំងភូមិៗ យកទៅសម្លាប់ចោល។ ប្រជាជននៅភូមិបឹងទិញជាដើម ត្រូវខ្មែរក្រហមជម្លៀសឡើងស្ងាត់ពីភូមិ។ ជួនកាល ខ្ញុំសម្លឹងមើលពីត្រើយម្ខាងផ្ទះរបស់ខ្ញុំ បានឃើញមាន់ឆ្កែ ចុះមកផឹកទឹក ហើយភូមិខាងនោះឡើងស្ងាត់ឈឹងលែងមានមនុស្សរស់នៅហើយ។ ពេលនោះ ម្តាយរបស់ខ្ញុំ ត្រូវអង្គការឲ្យទៅច្រូតស្រូវខាងមេមត់។ ឪពុករបស់ខ្ញុំវិញ ជារឿយៗ តែងនាំប្អូនស្រីពៅរបស់ខ្ញុំ ទៅពួននៅបឹងទិញព្យាយាមរកកន្លែងលាក់ខ្លួនរត់ទៅរត់មកជាច្រើនសារ។

លុះជិតដាច់ឆ្នាំ១៩៧៨ កងទ័ពវៀតណាម លើកគ្នាមកជាច្រើននាក់ ចូលមកភូមិកំពង់ទ្រា។ ពួកគេ បានសួរទៅឪពុករបស់ខ្ញុំជាភាសាវៀតណាម ឲ្យជួយគេរកកន្លែងឆ្លងទៅត្រើយម្ខាងទៀត។ ឪពុករបស់ខ្ញុំ បានឆ្លើយប្រាប់កងទ័ពវៀតណាមដោយភាពស្មោះត្រង់។ វត្តមានរបស់កងទ័ពវៀតណាម ធ្វើឲ្យខ្ញុំនិងក្រុមគ្រួសាររបស់ខ្ញុំ កិតភ័យម្តងទៀត ខ្លាចថានឹងមានការបាញ់ប្រហារគ្នា។ ក្រោយមក លោកតារបស់ខ្ញុំ មានវិទ្យុស្តាប់ប៉ុស្តិ៍អាមេរិកាំង បានប្រាប់កូនចៅអំពីព័ត៌មានដែលបានស្តាប់នោះថា «មានគេជិតមករំដោះយើងហើយ»។ ទីបំផុត ក្រុមរំដោះ ក៏រំដោះបានទីក្រុងភ្នំពេញនិងតាមភូមិ ដោយឲ្យប្រជាជនវិលត្រលប់មកផ្ទះវិញ។

ចប់

២៧
រឿងរួចពីនរក

អ្នកនិពន្ធ ៖ កែវ ពិសី

២៧ ~ រឿង រួចពីនរក

ក្រោមកម្តៅព្រះអាទិត្យជះចំពីលើ សមមិត្តសេង កំពុងតែខិតខំប្រឹងប្រែងធ្វើការងារមិនខ្លាចនឿយហត់ ព្រមជាមួយសំឡេងជញ្ជក់មាត់ខ្លាំងៗ ដេញគោឲ្យខំប្រឹងដើរទៅមុខ ហើយជួនកាលលើករំពាត់វាយគោពីខាងក្រោយខ្នងនៅក្នុងវាលស្រែមួយ ដែលដីកន្លែងខ្លះសើម និងដីកន្លែងខ្លះទៀតគោកឆ្អែងក្រញង់។ ម៉ោងជិតដប់ទៅហើយ ពូសេង នៅមិនទាន់ស្រាយគោចេញពីនឹមនង្គ័លរបស់គាត់នៅទេឡើយ ព្រោះដាលនង្គ័លនោះភ្ជួរមិនមុតដីសោះ។ ដីស្រែនោះរឹងពេក ពូសេង យកជើងជាក់លើនង្គ័ល ហើយដៃទាំងពីររបស់គាត់ប្រឹងសង្កត់លើកន្ទុយនង្គ័លបន្ថែមទៀត។ ពូសេង បានធ្វើឲ្យបាក់នង្គ័ល ដែលកំពុងតែភ្ជួរដី ហើយភ្លាមៗនោះ មេកងចល័ត មេកងរង និងបក្សពួកពីរនាក់ទៀត បានដើរសំដៅមករក ពូសេង យ៉ាងលឿន។

មេកងរងបានស្រែកឲ្យពូសេងថា «ឈប់ភ្លាមសមមិត្ត! សមមិត្តឯងម៉េចបានជាក្បត់នឹងអង្គការ មានគំនិតបំផ្លាញទ្រព្យសម្បត្តិរបស់អង្គការដូចច្នេះ? សមមិត្តឯងជាខ្មាំងឬ? យី! អានេះជាពួក សេ-អ៊ី-អា ផងក៏មិនដឹង»។ ពូសេងបាននិយាយអង្វរដល់មេកងរងថា គាត់គ្មានចិត្តក្បត់នឹងអង្គការឡើយ ហើយគាត់គ្រាន់តែចង់ភ្ជួរឲ្យបានមុតល្អ ដូច្នោះខំប្រឹងសង្កត់ខ្លាំងទើបបណ្តាលឲ្យបាក់នង្គ័ល។ មេកងរងស្រែកថាឲ្យពូសេងថា «ហ៊ានតមាត់ ប្រកែកយករួចខ្លួន» និងបានបញ្ជាឲ្យគ្នីគ្នាចាប់ពូសេងយកទៅកសាងចេញព្រោះមេកងរងគិតតាមទ្រឹស្តីអង្គការថា «ទុកក៏មិនចំណេញ ដកចេញក៏មិនខាតដែរ»។ នៅពេលដែលឮមេកងរងបញ្ជា

ឲ្យចាប់ ពូសេង យកទៅរៀនសូត្រ មេកងចល័តបាននិយាយថា «ទេ! កុំទាន់យកទៅកសាងអី! ឥឡូវនេះអង្គការកំពុងតែខ្វះខាតកម្លាំងទៅជួយការពារជួរមុខដូច្នេះឲ្យសមមិត្តនេះ ទៅជួយការពារជួរមុខដើម្បីទប់ទល់ជាមួយវៀតណាមវិញចំណេញជាង»។

នៅចុងឆ្នាំ១៩៧៨ ពូសេង ត្រូវអង្គការបញ្ជូនទៅធ្វើជាកងទ័ពជួរមុខប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាមនៅតាមព្រំដែន ព្រោះកងទ័ពខ្មែរក្រហម ត្រូវកងទ័ពវៀតណាមបាញ់ឲ្យស្លាប់និងរបួសអស់ជាច្រើន ។ កងទ័ពវៀតណាម ចេះតែសម្រុកចូលមកក្នុងទឹកដីខ្មែរឥតដកថយ ហើយបានធ្វើឲ្យកម្លាំងកងទ័ពខ្មែរក្រហមបាក់ស្បាត និងដកទ័ពរត់ចូលក្នុងព្រៃ និងរត់ទៅតាមព្រំដែនអស់។ នៅពេលនោះ អង្គការបានដាក់បញ្ជាឲ្យកងទ័ពខ្មែរក្រហម ដែលនៅរស់រានមានជីវិត ឲ្យរត់ចូលព្រៃភ្នំសម្ងំរក្សាកម្លាំង ដើម្បីយកឱកាសវាយបកកងទ័ពវៀតណាមវិញ។

ពូសេង វិលមកពីជួរមុខវិញ បានគេចខ្លួនចូលមកក្នុងភូមិស្រុក ដោយមិនបានរត់ចូលទៅក្នុងព្រៃភ្នំដូចកងទ័ពដទៃទៀតទេ។ វត្តមានរបស់កងទ័ពវៀតណាមនៅក្នុងភូមិស្រុក បានធ្វើឲ្យចាស់ៗចាប់ផ្តើមមានគំនិតផ្សំផ្គុំ ពូសេងឲ្យរៀបការជាមួយសមមិត្តនារីម្នាក់ ដែលជាកូនអ្នកនៅក្នុងភូមិជាមួយគ្នា ដើម្បីគេចពីគ្រោះថ្នាក់។ ពូសេង និងប្រពន្ធ មិនធ្លាប់ស្គាល់គ្នាពីមុនមកសោះ។ ពុកម៉ែទាំងសងខាងយល់ថា នៅពេលដែល ពូសេង រៀបការរួច ហើយបើអង្គការវិលត្រលប់ចូលមកវិញ ពូសេង នឹងរួចខ្លួនលែងបានធ្វើជាកងទ័ពទៀត។

ពិធីរៀបការរបស់ ពូសេង បានប្រព្រឹត្តទៅដោយមានតែមាន់ស្ងោរមួយគូ បាយមួយឆ្នាំងតូច និងចាស់ៗប្រាំមួយនាក់តែប៉ុណ្ណោះ។ ក្នុងខែមេសា ឆ្នាំ១៩៧៩ កងទ័ពវៀតណាម បាននាំគ្នាចាកចេញពីភូមិស្រុកទៅចូលរួមអបអរឆ្នាំថ្មីនៅឯទីរួមខេត្តតាកែវ។ ឆ្លៀតពេលនោះ កងទ័ពខ្មែរក្រហម បានវិលត្រលប់ចូលមកក្នុងភូមិវិញដូចដើម។ នៅពេលដែលខ្មែរក្រហមចូលមកវិញម្តងនេះ ពួកគេបានជជីកសួរកសមមិត្ត ដែលទើបតែរៀបការកន្លងទៅថ្មីៗនេះ។ ខ្មែរក្រហម បានយកព័ត៌មានពីការរាយការណ៍របស់កងឈ្លបសម្ងាត់ថាមានគូស្នេហ៍ដប់គូដែលទើបតែរៀបការ។

ខ្មែរក្រហម បានចោទថា ប្រជាជនដែលទើបតែរៀបការនាពេលថ្មីៗនេះ គឺសុទ្ធតែជាខ្មាំងក្បត់អង្គការ ព្រោះការរៀបការនេះស្ថិតនៅក្រោមការរៀបចំរបស់កងទ័ពវៀតណាម។ ដូចនេះ ពួកគេត្រូវយកខ្មាំងទាំងនេះទៅរៀនសូត្រចេញទាំងអស់ ហើយខ្មែរក្រហមថែមទាំងបញ្ជាឲ្យយកចាស់ៗដែលជាឪពុកម្តាយខ្មាំងទាំងនេះទៅកសាងដែរ។

ចាស់ៗដែលជាឪពុកម្តាយមួយចំនួនដឹងខ្លួនថានឹងត្រូវខ្មែរក្រហមយកទៅកសាង ក៏នាំគ្នារត់ចេញពីភូមិ។ ចាស់ៗមួយចំនួនទៀត ត្រូវអង្គការយកទៅកសាងបាត់ដំណឹងសូន្យឈឹង។ ចំណែកឯ ពូសេង វិញត្រូវអង្គការចាប់ចងដៃព័ទ្ធមកក្រោយខ្នង ដូចសមមិត្តដទៃទៀតដែរ រួចបណ្តើរឆ្ពោះទៅមុខរណ្តៅ ដែលខ្មែរក្រហមជីករួចជាស្រេចនៅក្បែរមាត់ស្រះនៅភូមិក្រាំងត្រែង។ សមមិត្តនារី១០នាក់ ដែលត្រូវខ្មែរក្រហមចោទថាជាខ្មាំង ត្រូវឈ្លបសម្លាប់ដោយយកកាំបិតស្នោតមកអារករួចរុញទម្លាក់ចូលក្នុងរណ្តៅ។ ប្រពន្ធរបស់ ពូសេង ខំលើកដៃសំពះអង្វរដល់ឈ្លបឲ្យមេត្តាទុកជីវិតឲ្យ ព្រោះគាត់មិនមែនជាខ្មាំងឬអ្នកចូលដៃជាមួយវៀតណាមឡើយ។ កងឈ្លបមិនខ្វីខ្វល់ខ្វាយនឹងសម្តីរបស់ប្រពន្ធពូសេងឡើយ។ កងឈ្លបបានចាប់ក្បាលទាញសក់របស់គាត់មកខាងក្រោយ រួចយកកាំបិតស្នោតមកអារក ហើយធាក់ទម្លាក់ចូលទៅក្នុងរណ្តៅ។ ចំណែកឯមនុស្សប្រុសវិញ ឈ្លបសម្លាប់ដោយអារកឬវាយនឹងត្បូងចបរួចរុញទម្លាក់ចូលក្នុងរណ្តៅជាបន្តបន្ទាប់។ ពូសេង ត្រូវអង្គការយកកាំបិតចំពុះទុង មកចាក់កសម្លាប់គាត់។ កងឈ្លប បានចាក់ក ពូសេង ២កាំបិតហើយ ថែមទាំងចាក់ថែម២កាំបិតទៀត រួចរុញទម្លាក់ចូលទៅក្នុងរណ្តៅ។ បន្ទាប់ពីរុញទម្លាក់ ពូសេង ចូលក្នុងរណ្តៅរួចមានមនុស្សប្រុស២នាក់ទៀត ដែលកងឈ្លបសម្លាប់រួចរុញទម្លាក់ចូលក្នុងរណ្តៅគរពីលើសាកសព ពូសេង។ កងឈ្លប នាំគ្នារាប់និងមើលឃើញថា ពួកគេបានសម្លាប់ប្រជាជនទាំងអស់នោះគ្រប់ចំនួន២០នាក់ តាមការណែនាំហើយនោះ ក៏នៅចាំមើលខ្មោចថាតើខ្មាំងណាមិនទាន់ស្លាប់ និងអាលចាក់សម្លាប់បន្ថែមទៀត។ ពូសេង បានស្តាប់ឮឈ្លបនិយាយគ្នានិងដឹងថាកងឈ្លបនៅចាំមើល គាត់មិនហ៊ាន

កម្រើកខ្លួននោះទេ។ ពូសេង ធ្វើពុតជាស្លាប់ មិនហ៊ានដកដង្ហើមឡើយ។ លុះពេលឈ្លបនាំគ្នាទៅហូបបាយថ្ងៃត្រង់ ពូសេង ប្រឹងត្រដរើបម្រាស់ខ្លួនចេញពីគំនរសាកសពដែលសង្កត់ពីខាងលើគាត់ រួចប្រឹងវារឡើងឲ្យផុតពីរណ្តៅទាំងក្តីវេទនា។ ពូសេង ងើបដើរទាំងឈាមហូរស្រោចពេញខ្លួន សំដៅមកផ្ទះក្នុងភូមិវិញ។ គាត់អស់កម្លាំង ងងឹតមុខ មើលអ្វីលែងឃើញ ប៉ុន្តែគាត់នៅតែប្រឹងដើរទៅមុខទៀត។ ពូសេង បានដើរទៅបុកដើមត្នោត ហើយដួលដេកក្នុងបន្លារពក់ក្បែរគល់ត្នោតសន្លប់បាត់ស្មារតីភ្លាមៗ។ បន្ទាប់ពីដឹងខ្លួនវិញ ពូសេង ខំប្រឹងដើរបន្តសំដៅមកផ្ទះឪពុកម្តាយរបស់គាត់ ដោយគិតថាបើគាត់ស្លាប់សូមស្លាប់នៅក្នុងផ្ទះដែលមានឪពុកម្តាយបានដឹងឮទៅចុះ។ គាត់បានដើរមកដល់ផ្ទះនៅពេលព្រលប់ៗ។ តាយូ និងយាយអេម ដែលជាឪពុកម្តាយរបស់គាត់ នៅពេលឃើញកូនក្នុងសភាពបែបនេះ មានអារម្មណ៍ស្លុតចិត្តជាខ្លាំង អរផង ភ័យផង ហើយបានឲ្យកូនចូលសម្រាកនៅផ្ទះរួចយកទឹកឃ្មុំមកលាបលើមុខរបួសឲ្យ។ បន្ទាប់មក តាយូ និងយាយអេម យកអង្ក្រងបុកជាមួយអំបិលដាក់ចូលក្នុងក្រណាត់ រុំព័ទ្ធពីលើមុខរបួសបន្ថែមទៀត។ លុះព្រឹកឡើង គាត់បាននាំកូនទៅលាក់បំពួននៅទួលព្រៃឫស្សីស្ថិតនៅខាងកើតភូមិ ហើយប្រាប់កូនកុំឲ្យចេញពីទួលព្រៃឫស្សីនោះឲ្យសោះ ព្រោះខ្លាចកងឈ្លបមករកឃើញ។ លុះព្រឹកឡើង តា និងយាយចេញទៅធ្វើការនៅក្នុងការដ្ឋាន ជីកប្រឡាយដូចសព្វដង។ តានិងយាយប្រឹងទប់អារម្មណ៍ឲ្យនៅធម្មតាធ្វើដូចជាគ្មានរឿងអ្វីកើតឡើង។ គាត់ទាំងពីរខំលួចលាក់អាហារ ដែលជារបបរបស់ខ្លួន យកទៅឲ្យកូនហូបនៅពេលយប់ រួចដាក់ថ្នាំលើមុខរបួសឲ្យ ពូសេង។ ថ្នាំដែលយកមកព្យាបាល ពូសេង គឺមានតែទឹកឃ្មុំ និងអង្ក្រងបុកជាមួយអំបិលតែប៉ុណ្ណោះ។ ពូសេង មិនហ៊ានចេញពីទួលព្រៃឫស្សីមកស្នាក់នៅផ្ទះជាមួយឪពុកម្តាយរបស់គាត់ឡើយ។ គាត់ខំសម្ងំនៅទាំងយប់ទាំងថ្ងៃនៅទីនោះ ដើម្បីឲ្យជារបួសសិន។

នៅចុងខែមេសា ឆ្នាំ១៩៧៩ ក្រោយពីចប់កម្មវិធីចូលឆ្នាំថ្មីប្រពៃណីខ្មែររួច កងទ័ពវៀតណាមបានចូលមកតាមភូមិស្រុកវិញ។ កងកម្លាំងខ្មែរក្រហម

បាននាំគ្នារត់ចេញពីភូមិស្រុក លែងហ៊ានវិលត្រលប់មកវិញ។ ម្តងនេះ កងទ័ពវៀតណាម មិនដកទ័ពទៅវិញទេ។ តាយូ និងយាយអេម មានពេលវេលានៅមើលថែទាំកូនប្រុសនិងបិទថ្នាំឫសឈើនានាដែលផ្សំដោយខ្លួនឯងលើស្នាមរបួសរបស់ ពូសេង ជាប្រចាំថ្ងៃ។ ពូសេង ជាសះស្បើយតាំងពីពេលនោះមក។

ក្រោយមកដោយឃើញប្រទេសទទួលបានសន្តិភាព តាយូ និងយាយអេម បានរៀបការឲ្យ ពូសេងជាមួយនឹង មីងរឿង។ បច្ចុប្បន្ននេះ ក្រុមគ្រួសាររបស់ពូសេង ប្រកបមុខរបរធ្វើស្រែ និងចិញ្ចឹមសត្វដោយមានជីវភាពធូរធារ និងកំពុងរស់នៅក្នុងភូមិទួលចារ ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ។

ចប់

២៨

រឿងស្នាមអតីត

អ្នកនិពន្ធ ៖ ហោច សេងអូន

២៨ ~ រឿង ស្ពាមអតីត

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ព្រះសូរិយានៅតែបន្តរះយ៉ាងត្រចះត្រចង់ បាចសាចពន្លឺមកបំភ្លឺកពផែនដី ដើម្បីជាក្តីសង្ឃឹមដល់មនុស្សលោក ប៉ុន្តែប្រជាជាតិទាំងអស់រស់នៅក្នុងព្រះរាជាណាចក្រដ៏តូចមួយនេះ ហាក់ដូចកំពុងរមៀលធ្លាក់ទៅក្នុងរណ្តៅអន្ធការ ដែលបានបង្កើតឡើងដោយពពួកបិសាចអាវខ្មៅមួយក្រុម។ ទីក្រុងដែលប្រៀបបានទៅនឹងឧទ្យាននៃសន្តិភាព បានប្រែក្រឡះទៅជាទីក្រុងជម្លៀសប្រជាជនប្រកបដោយភាពចលាចលក្រៃលែងគួជាទីសង្វេគ។

នៅវេលាព្រឹកថ្ងៃនេះ នៅតាមដងវិថីហាក់ដូចសូប់ស្ងាត់ បែបចង់ប្រកាសប្រាប់ដល់អ្នកទីក្រុងថា មហាព្យុះជិតមកដល់ហើយ។ ម៉ោង ៩ព្រឹក លំហូរមហាជនបានចាប់កញ្ជ្រោលឡើងតាមដងផ្លូវក្រោមសំឡេងបញ្ជាពីពួកកងទ័ពក្មេងៗស្លៀកសម្លៀកបំពាក់ខ្មៅ ប្រៀបដូចមរណសញ្ញារបស់ប្រជាជនខ្មែរ។ ពួកគេ ឈរសម្លុតដល់ហ្វូងប្រជាជនថា «ទៅៗៗៗ! អង្គការឲ្យមិត្តឯងចេញពីភ្នំពេញតែ៣ថ្ងៃទេ! កងទ័ពអាមេរិកនឹងមកទម្លាក់គ្រាប់បែក! ចេញឲ្យរហ័ស! មិនបាច់យកអ្វីទៅជាមួយទេ! នៅទីនោះមានអ្វីៗគ្រប់បែបយ៉ាងដែលមិត្តត្រូវការ ឯផ្ទះសម្បែងរបស់មិត្តៗ អង្គការជាអ្នកមើលថែឲ្យ! .....ចេញ! ចេញទៅ! នៅតាមទិសណាទៅតាមទិសនោះ កុំសេរី!»។

ពាក្យសម្តី និងកាយវិការប្រកបដោយភាពកំណាច ហាក់គ្មាននរណាហ៊ានតវ៉ានឹងបទបញ្ជាថ្មីនេះសោះ។ មនុស្សដើរពពាក់ពពូនគ្នាដូចក្បួនព្យុហយាត្រា។

អ្នកខ្លះទូលរែកបង្វេចរបស់ខ្លួន ដៃកាន់កូនតូចៗ អ្នកខ្លះទៀតបណ្តើរកង់ដឹកអីវ៉ាន់ ក្រោមសែងសូរិយាខែចេត្រហូរញើសរហាម ជាមួយនឹងទឹកមុខស្រងូតស្រងាត់។ អ្នកជំងឺ អ្នករបួស ក៏ត្រូវបង្ខំឲ្យចាកចេញពីក្រុងដែរ។ ក្នុងចំណោមមនុស្សដេរដាសនាគ្រានោះ បុរសវ័យកណ្តាលម្នាក់ អាយុប្រមាណហាសិបប្លាយឆ្នាំ មានមាឌធំក្រអាញ សម្បុរខ្មៅស្រអែម ពុកចង្កាតិចៗ កែវភ្នែកល្អក់ ប្រកបដោយកង្វល់ បានស្តែងឡើងតាមរយៈទឹកមុខរបស់គាត់ដូចប្រជាជនខ្មែរឯទៀតដែរ។ គាត់ឈ្មោះ សំអុរ ជាគ្រូបង្រៀនកម្រិតវិទ្យាល័យនៅបឹងត្របែក កំពុងបណ្តើរកង់ដឹកបាវអង្ករ និងស្ពាយអីវ៉ាន់មួយសំពាយធំពីក្រោយខ្នង ជាមួយស្ត្រីម្នាក់ មានវ័យចំណាស់ប្រហាក់ប្រហែលគ្នា ដៃកាន់កន្ត្រក់អីវ៉ាន់ ហើយមានបង្វេចធំល្មមមួយស្ពាយពីក្រោយ។ ស្ត្រីនោះ ជាភរិយារបស់លោកគ្រូ សំអុរ ដែលមានឈ្មោះថា ធីតា។ នៅជាប់មីង ធីតា មានយុវជនពេញកម្លាំងពីរនាក់ទៀត ដែលជាកូនរបស់លោកគ្រូសំអុរ។ សំអាត ជាកូនស្រីច្បង។ នាងមានអាយុប្រមាណ ១៨ឆ្នាំ មានសម្រស់ផូរផង់ ដែលកំពុងតែស្គាយផង ទូលផង។ ចំណែក សំអាន ជាកំលោះទើបនឹងពេញវ័យអាយុ ១៧ឆ្នាំ កំពុងពន់រែកដោយអីវ៉ាន់សំពោងហើយដៃម្ខាងកាន់ប្អូនប្រុសម្នាក់ទៀតមានអាយុទើបតែ ៨ឆ្នាំ យ៉ាងស្អិតហាក់ខ្លាចរបូតឃ្លាតគ្នា។

មិនមែនចៃដន្យទេ ដែលក្រុមគ្រួសារលោកគ្រូ សំអុរ បានរៀបចំបម្រុងរបស់របរផ្សេងៗជាច្រើនសម្រាប់ដំណើរមួយនេះ ព្រោះគាត់បានដឹងនយោបាយពួកខ្មែរក្រហមខ្លះៗពីតំបន់រំដោះ ដែលជាស្រុកកំណើតរបស់គាត់នៅខេត្តកំពង់ចាម។ ជាងដប់ថ្ងៃក្រោយមក ពួកអ្នកទោសឥតកំហុសទាំងរាប់រយនាក់ បានដើរទៅដល់ភូមិគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ហើយគេបានបញ្ឈប់ក្រុមមនុស្សនៅទីនោះសិន។ វត្តភូមិគគីរ ដែលធ្លាប់ជាទីសក្ការបូជាដ៏ឧត្តមរបស់ប្រជាជនក្នុងស្រុក បានប្រែក្លាយទៅជាជំរំសម្រាកបណ្តោះអាសន្នរបស់ជនអ្នកថ្មើរជើងទៅវិញ។ វត្តអារាម ដ៏ផូរផង់ដែលធ្លាប់តែឮសំឡេងព្រះសង្ឃសូត្រធម៌ និងផ្តល់ដំបូន្មានឲ្យផងនោះ ឥឡូវបានក្លាយទៅជាកសិដ្ឋានចិញ្ចឹមជ្រូក និងដាក់មនុស្សទៅវិញ។ ឱ! សាសនាដ៏ឧត្តមរបស់ខ្មែរអើយ! អ្នកត្រូវជាន់ឈ្លីដោយពួក

បិសាចឥតសាសនាមួយក្រុមតូចនេះទៅវិញ។ នៅជុំវិញវត្តអារាម ដែលជាទីស្នាក់បណ្តោះអាសន្នរបស់អ្នកដំណើរខាងលើ មានសពទាហាន និងប្រជាជនដេកស្លាប់រដូករណែល។ ដោយគ្មានចំណីអាហារហូបគ្រប់គ្រាន់ ប្រជាជនខ្លះ បានលួចយកគ្រឿងអលង្ការ កំណាត់សំពត់ដែលនៅសល់ពីភ្នំពេញទៅដោះដូរយកអង្ករ ត្រីសាច់ ថ្នាំសង្កូវនានា មកដោះទុក្ខមួយគ្រានេះ។

លោកគ្រូ សំអុរ បានសម្រេចចិត្តយកនាឡិកាដៃ និងគ្រឿងអលង្ការខ្លះៗទៅប្តូរយកអង្ករ និងស្បៀងខ្លះសម្រាប់ផ្គត់ផ្គង់ជីវិតគ្រួសាររបស់គាត់។ ម្តងម្កាលនាង សំអាត សំអាន និងសំអាង បានចេញទៅលួចបេះបោចត្រកួន និងរកដំឡូង មកទុកបរិភោគបន្ថែមលើស្បៀងដែលអង្គការបានចែកឲ្យយ៉ាងលាក់លៀមបំផុត។ ប្រសិនបើខ្មែរក្រហមឃើញនោះ គេនឹងចោទថា យើងក្បត់អង្គការ និងបដិវត្តន៍។ លោកគ្រូ សំអុរ និងគ្រួសារ បានសម្រាកនៅភូមិគគីរ ជាងកន្លះខែ ដើម្បីរង់ចាំជើងកប៉ាល់មកដឹកចម្លងទៅខេត្តកំពង់ចាម ជាមួយប្រជាជនជាច្រើនទៀតដោយក្តីអន្ទះសា និងអត់ឃ្លាន។ ពេលកប៉ាល់ទំនើបពីរជាន់ដែលសល់ពីសង្គមចាស់មកដល់មាត់កំពង់ហើយ ខ្មែរក្រហមបានឲ្យមនុស្សដែលបានរៀបបម្រុងទៅខេត្តកំពង់ចាមនោះ ឡើងទៅលើកប៉ាល់ ជាបន្តបន្ទាប់រហូតទាល់តែពេញកប៉ាល់ ទើបកប៉ាល់រោទ៍រំពងសំឡេងចាកចេញទៅតាមដងទន្លេមេគង្គ សំដៅទៅកាន់ខេត្តកំពង់ចាម។ មិនប៉ុន្មានម៉ោងក្រោយមក កប៉ាល់ដ៏ជរាបាននាំអ្នកដំណើរទាំងអស់មកដល់កំពង់ព្រែកពោធិ៍ដោយសុវត្ថិភាព។ អង្គការ បានរៀបចំឲ្យប្រជាជនចំណាកស្រុកទាំងអស់សម្រាកនៅមាត់កំពង់មួយយប់សិន ដើម្បីរង់ចាំរៀបចំបែងចែកទៅតាមទិសដៅរបស់អង្គការចាត់តាំង។

ល្ងាចត្រជាក់ ខ្យល់ជំនោរផាយផាត់រំភើយតិចៗ មកអង្រួនចុងរុក្ខាដែលដុះប្របនឹងមាត់ទន្លេ យោលទៅយោលមកតាមកម្លាំងវាយោ ជួយលួងលោមជនប្រុសស្រីដ៏កំសត់ឲ្យមានអារម្មណ៍ធូរស្រាលទៅតាមជំនោរនេះបន្តិចបន្តួចដែរ។ គេឃើញមានប្រុសកំលោះបីនាក់ឈរចំពីមុខប្រជាជន ហើយបុរសម្នាក់ក្នុងចំណោមនោះ ចាប់និយាយឡើងថា «អង្គការត្រូវការភាពស្មោះត្រង់ពីមិត្តៗ

ទាំងអស់គ្នា ដោយហេតុថា នៅឯទីក្រុងខ្វះអ្នកចេះដឹងដើម្បីជួយការងាររដ្ឋ ដូច្នេះយើងត្រូវការភាពស្មោះត្រង់ពីបងប្អូនទាំងអស់គ្នា នៅទីនេះ យើងមានបញ្ជីចំនួន៣ បញ្ជីទី១ សម្រាប់បងប្អូនមន្ត្រីរដ្ឋការចាស់ បញ្ជីទី២ សម្រាប់បងប្អូនជាគ្រូបង្រៀន ឬសិស្សនិស្សិត ដែលទើបបញ្ចប់ការសិក្សាពីបរទេស ចំណែកបញ្ជីទី៣ សម្រាប់ប្រជាជនសាមញ្ញអ្នកស្រែ កម្មករធម្មតា បើបងប្អូនអាចចុះឈ្មោះទៅតាមស្ថានភាពពិតរបស់បងប្អូនបាន។ អ្វីដែលសំខាន់គឺអង្គការត្រូវការភាពស្មោះត្រង់ពីបងប្អូនទាំងអស់គ្នា»។

ឮដូច្នោះ ប្រជាជនខ្លះដែលជាមន្ត្រីរដ្ឋការពីសង្គមចាស់ បានទៅចុះឈ្មោះក្នុងបញ្ជីទី១ ដោយមិនដឹងពីព្រេងវាសនារបស់ខ្លួននៅថ្ងៃខាងមុខឡើយ។ លោកគ្រូ សំអុរ ហាក់អែអង់ចង់ទៅចុះឈ្មោះក្នុងបញ្ជីទី២បន្តិច ក្នុងបញ្ជីទី៣បន្តិច ប៉ុន្តែ វិចារណញ្ញាណបានប្រាប់គាត់ថា គេជម្លៀសប្រជាជនចេញពីទីក្រុង ចុះហេតុអ្វីទើបគេប្រមូលមនុស្សចូលទៅទីក្រុងវិញ? សំណួរនេះ បានបង្វែរចិត្តលោកគ្រូ សំអុរ ឲ្យនាំក្រុមគ្រួសារទៅចុះឈ្មោះក្នុងបញ្ជីទី៣ទៅវិញ។ ឱ! ព្រេងវាសនានៃប្រជាជនខ្មែរដ៏កំសត់អើយ! អ្នកបានចុះឈ្មោះផ្ញើវាសនាទៅលើបញ្ជីទាំងពីរដោយរំពឹងថា នឹងបានត្រលប់ទៅទីក្រុងដែលជាទីទំនើបវិញឬ? បញ្ជីឈ្មោះទាំងពីរនេះហើយគឺជាលិខិតមរណៈដែលកំពុងតែនាំពួកគេទៅកាន់អវសានៃជីវិតដោយឥតកំហុសសោះ។ អ្នកដែលមិនបានចុះឈ្មោះក្នុងបញ្ជីទាំងពីរនោះ ត្រូវបានខ្មែរក្រហម បញ្ជាឲ្យឡើងជិះរថយន្តទ្រុងដឹកទំនិញចេញពីទីនោះសំដៅទៅទីតាំងថ្មីជាមូលដ្ឋានជាក់លាក់ គឺស្រុកសំបូរ ខេត្តក្រចេះ។ លោកគ្រូ សំអុរ មីងធីតា និងកូនៗទាំង៣នាក់ទៀត បានស្ពាយបង្វែចជាប់ខ្លួន ដែលក្នុងបង្វែចនោះគ្មានសេសសល់របស់សំខាន់អ្វីទៀតឡើយ ព្រោះរបស់សំខាន់ៗបានត្រូវគណៈភូមិឆែកប្រមូលយកអស់ទៅហើយ។

ជាសកវជាច់ថ្លៃ

រយៈពេលជាងពីរខែទើបលោកគ្រូ សំអុរ និងប្រពន្ធកូន បានមកដល់ភូមិចំបក់ជ្រុំ ឃុំសំបូរ ស្រុកសំបូរ ក្នុងខេត្តក្រចេះ ដែលជាទីសំចតពិតប្រាកដ។ មកដល់

ភូមិនេះភ្លាម គាត់បានសម្រាកនៅក្រោមផ្ទះប្រជាជនចាស់បណ្តោះអាសន្នសិន ទំរាំនឹងសាងសង់កូនខ្នមស្នាក់នៅបាន។ អង្គការបានចាត់តាំងឲ្យលោកគ្រូ សំអុរ និងប្រពន្ធរបស់គាត់ ទាំងពីរធ្វើការជាមួយសហករណ៍ក្នុងភូមិ។ ចំណែកឯ សំអាត និងសំអាន ដែលមានវ័យពេញកម្លាំង អង្គការតម្រូវឲ្យទៅធ្វើការនៅក្នុងកងចល័ត។ សំអាត ត្រូវទៅធ្វើការក្នុងកងចល័តនារីនៅឯការដ្ឋានឆ្ងាយពីភូមិប្រហែលដប់គីឡូម៉ែត្រ ហើយសំអាន វិញ អង្គការតម្រូវឲ្យទៅធ្វើការក្នុងកងចល័តយុវជន ដើម្បីលើកទំនប់និងជីកប្រឡាយឆ្ងាយពីភូមិដែរ។ រីឯសំអាង ដែលស្ថិតក្នុងវ័យកុមារ ក៏ត្រូវអង្គការតម្រូវឲ្យចូលក្នុងកងកុមារជួយរើសអាចម៍ធ្វើជីជាក់ស្រែដែរ។ បទបញ្ជាថ្មីគ្មាននរណាហ៊ានតវ៉ាសោះឡើយ ព្រោះម្នាក់ៗសុំតែជីវិតរស់ប៉ុណ្ណោះ។

ស្នូរជួងបានបន្លឺឡើងរៀងរាល់ព្រឹកជាសញ្ញាហៅមិត្តនារី និងមិត្តយុវជន ដែលស្ថិតក្នុងកងចល័តទាំងអស់ ឲ្យមកប្រជុំគ្នាស្តាប់បទបញ្ជាពីមេកងជាមុនសិន មុននឹងចេញទៅបំពេញកិច្ចការរបស់ខ្លួន។ មាណពកំសត់ សំអាត ពាក់ខ្មៅ និងខោខ្មៅ ឈរក្នុងជួរយ៉ាងស្ងៀមស្ងាត់ចាំស្តាប់ពាក្យសម្តីពីមេកងដោយសេចក្តីភ័យខ្លាច។ ក្រោយពីបញ្ចប់ការប្រជុំគ្នាហើយ អង្គការបានបញ្ជាឲ្យទាសករទាំងអស់ទៅធ្វើការតាមអ្វីដែលអង្គការបានដាក់ឲ្យ។ អ្នកធ្វើការក្នុងកងចល័តគឺត្រូវទទួលបន្ទុកនឿយហត់ខ្លាំង ព្រោះជាកម្លាំងស្នូលរបស់អង្គការ។ សំអាតព្យាយាមធ្វើការងារដែលអង្គការបញ្ជាណាស់ ព្រោះខ្លាចមានកំហុស ត្រូវអង្គការយកទៅរៀនសូត្រ។ សុជាតិ ជាមិត្តនារីថ្មីដែល សំអាត ទើបនឹងបានស្គាល់ពេលដែលចល័តមករស់នៅក្នុងកងនេះ។ ពេលល្ងាចបន្ទាប់ពីហូបបាយរួច សុជាតិ និង សំអាត បានលួចទៅបេះត្រកួន និងចាប់កូនសត្វល្អិតតូចៗ យកមកបរិភោគគ្រាន់ចម្អែតក្រពះបន្ថែមលើរបបអាហារដែលអង្គការផ្តល់ឲ្យ។ ក្រោយពីបេះត្រកួនរួច សុជាតិ បានឲ្យ សំអាត យកមកផ្ទះមុន ដោយខ្លួនចាំទៅរកជីកក្តួចបន្តិចទៀតឲ្យបានច្រើនជាងនេះ។ សុជាតិ និយាយទាំងប្រុងប្រយ័ត្នថា «សំអាត ឯងយកត្រកួននេះទៅផ្ទះមុនទៅ! ចាំខ្ញុំទៅជីកក្តួចនិងដំឡូងខ្លះយកទៅតាមក្រោយ ព្រោះឥឡូវពិបាករកឱកាសចេញមកណាស់»។ សំអាតតបវិញថា «ក្រែងមិនល្អទេ

ដឹង? ចាំទៅទាំងអស់គ្នាតែម្តងទៅក្រែងយ៉ាងម៉េចយ៉ាងម៉ាបានជួយគ្នាណា»។ «ឯងទៅមុន ទៅ គ្នាច្រើនមិនល្អទេក្រែងមេកងចាប់បានយើងមិនរស់ទេ ខ្ញុំចេះប្រយ័ត្នខ្លួនហើយ» មិត្តនារី សុជាតិ និយាយកាត់។

សំអាត ក៏ដើរចេញពីទីនោះ ទុកឲ្យ សុជាតិ ជាមិត្តរកដីកដំឡូងតែឯង។ ពេលមិត្តនារី សុជាតិ ដីកដំឡូងបានហើយ កំពុងវិលត្រលប់មកផ្ទះវិញ ជាអកុសល ត្រូវមេកងនារីចាប់បាន។ នាងមេកងនោះខឹងខ្លាំងណាស់ ហើយបានចោទ សុជាតិ ថាក្បត់នឹងអង្គការ ជាខ្មាំងបង្កប់ខ្លួន ព្រោះមិនស្មោះត្រង់នឹងអង្គការ។ មេកងនារីចាប់ សុជាតិ ទៅចងក្រោមដើមឈើទាំងយប់ ហើយសម្តែតសួរនាងថា

«យ៉ាងម៉េចមិត្តនារី អង្គការមានរបបអាហារគ្រប់ឲ្យមិត្តឯងហើយ ម្តេចមិត្តហ៊ានទៅលួចបេះបោចបន្លែបង្ការដែលជាកម្មសិទ្ធិរបស់អង្គការអីចឹង? មិត្តជាខ្មាំង? មិត្តជាពួកសេ-អ៊ី-អា បង្កប់ខ្លួន ចាំស៊ើបដំណឹងពីអង្គការយើងឬ?»។

«អត់ទេមិត្តបង! ខ្ញុំមិនមែនជាខ្មាំងប្រឆាំងនឹងអង្គការអីទេ ខ្ញុំស្មោះនឹងអង្គការណាស់ ដែលខ្ញុំលួចមករកដំឡូងនេះ ព្រោះខ្ញុំឃ្លានពេកមិត្តបង! សូមអធ្យាស្រ័យឲ្យខ្ញុំផងទៅមិត្តបង!»។

ធីតាកំសត់និយាយទាំងទឹកភ្នែករហាមដោយក្តីកិតក័យ។ ទោះនាងខំអង្វរមេកងយ៉ាងណាក៏ដោយ តែសម្តីនាងហាក់ដូចគ្មានឥទ្ធិពលលើមេគ្នាធម៌បន្តិចសោះឡើយ។ មេកងបានយក សុជាតិ ទៅកសាងទាំងកណ្តាលយប់ដោយមិនបានផ្តែផ្តាំអ្វីបន្តិចសោះឡើយ។

សំអាត មកដល់រង់ចាំ សុជាតិ មិត្តសម្លាញ់បាត់យូរមិនឃើញវិលវិញសោះ ក៏កើតចិត្តមិនស្រួល។ សំអាត ចាំយូរពេកក៏ដេកលក់ក្នុងផ្ទះជាមួយមិត្តនារីឯទៀតៗទាំងក្តីមន្ទិលក្នុងចិត្ត។ ថ្ងៃបន្ទាប់ ពេល សំអាត បានទៅធ្វើការនៅការដ្ឋានដូចសព្វដង នាង ពុំឃើញសុជាតិ ទេ។ នាងខំសួរគេឯងដៃរតែគ្មាននរណាបានដឹងសោះឡើយ។ ថ្ងៃត្រង់សម្រាក ជួងបានបន្លឺឡើងហៅមនុស្សម្នាទាំងអស់ឲ្យមកហូបបាយថ្ងៃត្រង់។ សំអាត បានប្រញាប់រួសរាន់មករោងអាហារ ដើម្បីទទួលរបបបាយថ្ងៃត្រង់ដោយក្តីស្រែកឃ្លាន។ មុនចាប់ហូបបាយ សំអាត បានទទួល

ដំណឹងមរណភាពរបស់មិត្តសម្លាញ់ពីមាត់មេកងកំណាច ដែលបានស្រែកប្រកាសក្តែងៗពីបទវិន័យក្នុងរោងបាយនោះ។ ទឹកនេត្រារបស់ សំអាត បានរមៀលធ្លាក់មកស្រោចផែនថ្ពាល់ទាំងសងខាង ជាសញ្ញាក្តុកក្តួលរំជួលចិត្តពេកក្រៃ ចំពោះការបាត់បង់មិត្តសម្លាញ់នេះ តែនាងខំសម្រួលតរិយាបថវិញ ដើម្បីកុំឲ្យគេចាប់ថ្នាក់នាងបាន។ ប្រជាជនរាប់រយនាក់នៅក្នុងរោងបាយ បានហូបបាយម្នាក់មួយកូនចានជាមួយសម្លដែលគេឲ្យមួយចានមួយក្រុម។ អាហារនេះមានរសជាតិឆ្ងាញ់ណាស់ ចំពោះជនដែលស្រែកឃ្លានអាហារក្នុងពេលនេះ។ គ្មានសម្លវិសេសឯណាជាងសម្លម្ហូរត្រកួន សម្លប្រហើរ សម្លល្វែត្រពាំង សម្លកកូរដែលស្លទាំងខ្ទះៗឲ្យពួកទាសករជាងរយនាក់បរិភោគនោះទេ។

ក្រោយសម្រាកថ្ងៃត្រង់រួច សំអាត បានត្រលប់ទៅធ្វើការនៅការដ្ឋានវិញទាំងក្នុងខ្លួនធើងធោង។ សែងសូរិយោពេលរសៀលបានកំពុងដុតចំហុយប្រជាជនខ្មែរឲ្យរងទារុណកម្មតែតែអស់កម្លាំងថែមទៀត។ សំអាត បានរបួតចបពីដៃ រាងកាយដួលទាំងដំហរទៅលើដីដោយរោគខ្យល់មួយរំពេច។ មិត្តនារីឯទៀតឃើញដូច្នេះក៏មកមើលជួយយកអាសាដោយក្តីអាណិត តែត្រូវមេកងនារីស្រែកបន្ទោសដោយសម្តីកំណាចថា «នែ៎ មិត្តទាំងអស់គ្នា! ឆាប់ចេញភ្លាមទៅ ទៅធ្វើការតាមមុខនាទីរៀងខ្លួនទៅ! មិត្តមិនមែនពេទ្យទេ...ចេះដឹងអី! សក់អ្នកណា ក្បាលអ្នកហ្នឹង»។ មិត្តនារីទាំងអស់ក៏បំបែកគ្នាទៅធ្វើការជីកប្រឡាយរៀងៗខ្លួនវិញ។ មេកងនារីបាននាំ សំអាត មកសម្រាកនៅផ្ទះវិញ។ ល្ងាចឡើង សំអាត បានដឹងខ្លួនធូរពីដំងឺបន្តិចងើបឡើងអង្គុយហូបបបរភ្លាវ ដែល ចាន់ ជាមិត្តនារីរួមផ្ទះជាមួយលួចយកអង្ករដាំឲ្យនាង។ សំអាត ហូបបណ្តើរសួរទៅ ចាន់ ជាមិត្តបណ្តើរថា «ចាន់ឯងបានបបរនេះពីណាមកឲ្យខ្ញុំ? ខ្ញុំអរគុណណាស់»។ ចាន់ ឆ្លើយតបយ៉ាងទន់ភ្លន់ទៅវិញថា «គ្មានគុណស្រ័យអីទេបងអាត។ បងខំហូបទៅឲ្យមានកម្លាំងនឹងបានទៅធ្វើការនៅការដ្ឋានយើងបន្ត បើបងមិនធូរទេ អង្គការនឹងបញ្ជូនបងទៅពេទ្យហើយ។ បើបងទៅទីនោះដូចរង់ចាំស្លាប់ដដែលហ្នឹង ព្រោះនៅពេទ្យនោះគ្មានថ្នាំអីទេ គឺមានតែថ្នាំអាចម៍ទន្សាយ ជួយអីមិនបានទេ។ ឈឺអីក៏ថ្នាំហ្នឹងដែរបងអើយ»។

ល្ងាចមួយ ក្រោយបរិភោគបាយរួច មេកងបានហៅ សំអាត ទៅប្រជុំជាមួយមិត្តនារីផ្សេងៗទៀតដោយគ្មានមូលហេតុ។ តាមការពិត គេហៅមកប្រជុំពីបញ្ហារៀបការគូស្រករទេតើ! ឈ្មោះរបស់ សំអាត ព្រមជាមួយឈ្មោះមិត្តនារីឯទៀតៗត្រូវបានអង្គការ ស្នើដាក់ក្នុងបញ្ជីរៀបការជាមួយយុវជនផ្សេងទៀតដែលអង្គការបានរៀបចំឡើង។ សំអាត ត្រលប់មកពីប្រជុំវិញដោយចិត្តមួរម៉ៅក្នុងអារម្មណ៍។

«រៀបការ?..... តើខ្ញុំពិតជាត្រូវរៀបការមែនឬ? កូនកំលោះជានរណា? នៅឯណា? គេរៀបការយ៉ាងដូចម្តេចទៅ បើឪពុកម្តាយរបស់ខ្ញុំមិនដឹងផងនោះ?» សំណួរទាំងនេះបានផុសពេញខួរក្បាលរបស់ សំអាត។

ថ្ងៃកំណត់ពិធីរៀបការចូលមកដល់ អង្គការបានរៀបចំវគ្គរៀបការនេះចំនួនសាមសិបគូដោយគ្មានឪពុកម្តាយចូលរួមសោះឡើយ។ មេកងក្នុងសហករណ៍បានឈរនៅចំពោះមុខជនប្រុសស្រីទាំងឡាយដែលរៀបបម្រុងផ្សំផ្គុំឲ្យ។ មុននឹងចាប់ផ្តើមហៅឈ្មោះមិត្តយុវជន និងមិត្តនារីទាំងនោះឡើងប្តេជ្ញាយកគ្នាជាប្តីប្រពន្ធ តាមបំណងរបស់អង្គការកំណត់នោះ ប្រធានសហករណ៍បានពោលឡើងថា «បងប្អូនឃើញទេ កាលពីសម័យមុន បើបងប្អូនគ្មានប្រាក់កុំស្មានថា បងប្អូនរៀបការបានអីចឹង។ ឥឡូវទោះបងប្អូនគ្មានលុយក៏បងប្អូនអាចរៀបការចាប់ដៃគ្នាបានដែរ ហើយមិនរវល់ដល់ក្រុមគ្រួសារទៀតផង»។ ប្រធានសហករណ៍បញ្ចប់សម្តីនេះរួច បានចាប់ហៅឈ្មោះអ្នកដែលត្រូវរៀបការឲ្យឡើងមកចាប់ដៃគ្នាប្តេជ្ញាមុខប្រធានសហករណ៍ក្នុងបរិយាកាសស្ងប់ស្ងាត់។ សំអាត ត្រូវផ្សំផ្គុំជាមួយមិត្តយុវជនម្នាក់ ដែលមានអាយុស្របាលៗគ្នា ហើយមានរូបរាងសង្ហាគ្រាន់បើ តែត្រូវរបួសពិការដៃឆ្វេងក្នុងគ្រាធ្វើបដិវត្តន៍។ យុទ្ធជននោះឈ្មោះ សុផល បានឡើងចាប់ដៃមិត្តនារី សំអាត ប្តេជ្ញានៅចំពោះអង្គការកំណាចខ្មែរក្រហម។ ក្រោយពីបានបញ្ចប់ពិធីរៀបការនេះហើយ អង្គការបានឲ្យគូស្វាមីភរិយាថ្មីថ្មោងទាំងនេះទៅសម្រាកក្នុងកូនខ្ទមតូចៗដែលសង់ពីឈើប្រក់ស្បូវដែលជាផ្ទះសម្រាប់ការផ្សំដំណេក។ ទោះបីស្រលាញ់ ឬមិនស្រលាញ់ក៏ដោយ ប្តីប្រពន្ធទាំងអស់ដែលទើបនឹងរៀបការរួច ត្រូវតែសម្រាកនៅជាមួយគ្នាក្រោមការឃ្លាំមើលដោយ

កងឈ្លប។ ថ្ងៃនោះ សំអាត អង្គុយស្ងៀមនៅក្នុងខ្ទមដោយមិនចេញស្តី ថែមទាំងមានទឹកមុខព្រួយបារម្ភ ស្រាប់តែមានសម្តីស្រាលត្រជាក់រសាត់មកប្រលោមសោតារបស់នាងថា «ម្តេចមិនមកសម្រាក? នាងខ្លាចខ្ញុំឬ? យើងទាំងពីរជាប្តីប្រពន្ធគ្នាហើយ មកសម្រាកមក កុំឲ្យមានបញ្ហាជាមួយអង្គការណា»។ «ចា៎ មិនអីទេ! ខ្ញុំចូលដេកឥឡូវហើយ» សំអាត ឆ្លើយតបដោយក្តីគួរសម។

ទោះបីរស់នៅជាមួយគ្នាដោយគ្មានមនោសញ្ចេតនាយ៉ាងណាក្តី សំអាត និង សុផល អាចរស់នៅជាមួយគ្នាចុះសម្រុងជាធម្មតា។ ប្រហែលជានិស្ស័យហើយទើបបណ្តាលឲ្យ សុផល និង សំអាត រស់នៅ ចុះសម្រុងគ្នាយ៉ាងនេះ។

និទសលុះអវសាន

រយៈពេលជាងមួយឆ្នាំកន្លះហើយដែលក្រុមគ្រួសារបានរស់នៅឃ្លាតពីគ្នា។ សំអាន ដែលទៅធ្វើការក្នុងកងចល័តយុវជន បានចល័តពីតំបន់មួយទៅតំបន់មួយ។ មកដល់ខែតុលា ឆ្នាំ១៩៧៦ សំអាន បានចល័តមកដល់ស្រុកស្នួល ខេត្តក្រចេះ។ មកដល់ទីនេះ បន្ទុកការងាររបស់ សំអាន កាន់តែធ្ងន់ទៅៗ។ ចំណែករបបអាហារវិញ កាន់តែតិច ធ្វើឲ្យប្រជាជនបាក់កម្លាំង ហើយឈឺស្លាប់ជារឿយៗ។ សំអាន ខំធ្វើការមិនហ៊ានប្រហែសសោះឡើយ ព្រោះក្នុងចិត្ត សំអានតែងរំពឹងថាពេលណាមួយនឹងបានទៅជួបឪពុកម្តាយវិញជាក់ជាមិនខាន។

នៅចុងរដូវវស្សា ភ្លៀងធ្លាក់ឥតលស់ថ្ងៃ ម៉ាំងនៅក្នុងស្រុកព្រៃផង សំអានបានធ្លាក់ខ្លួនឈឺគ្រុនចាញ់ក្តៅរងារញ័រញាក់គួរជាទីសង្វេគក្រៃលែង។ ទោះបីជាគ្រុនរងារញាក់យ៉ាងនេះទៅហើយ សំអាន នៅតែខំត្រដរទៅការដ្ឋានធ្វើការព្រោះគ្មានជម្រើសទេ។ អង្គការភ្នែកម្ខាស់ មិនជឿងាយៗថាយើងឈឺឡើយ។ អង្គការអាចចោទយើងថាធ្វើពុតជាឈឺក្បត់នឹងអង្គការ។ មកដល់ការដ្ឋានធ្វើការមិនបានប៉ុន្មានផង សំអាន បានដួលសន្លប់បាត់ស្មារតី ហើយត្រូវមេកងយកទៅមន្ទីរពេទ្យ ដែលមានមូលដ្ឋាននៅក្នុងវត្តស្រុក។ សំអាន បានដេកសម្រាកនៅក្នុងព្រះវិហារជាមួយអ្នកជំងឺជាច្រើននាក់ទៀត ដែលគ្មានសង្ឃឹមថានឹងបានរួចជីវិតរស់ទៀតឡើយ។ សំអាន ដេកញ័រទទ្រើតដោយរោគាញ៉ាំញីឥតមេត្តា។ សំអាន

ធឹកតែថ្នាំដែលសូន្យចេញពីរុក្ខជាតិបុរាណដាក់ក្នុងដបទឹកក្រូចមានពណ៌ខ្មៅ សណ្ឋានដូចអាចម៍ទន្សាយ តែហាក់ពុំមានប្រសិទ្ធភាពចំពោះរោគរបស់ សំអាន ទាល់តែសោះ។ រាងកាយ សំអាន ដេកអស់សង្ឃឹមដោយអារម្មណ៍វិលវល់ក្នុងរូបកាយស្គមគ្មានកម្លាំងនឹកដល់ឪពុកម្តាយ និងបងស្រីប្អូនប្រុស មិនដឹងអ្នកទាំងនោះរស់នៅមានសេចក្តីសុខ ឬក្តីវេទនាយ៉ាងណាទេ? បីថ្ងៃក្រោយមក ព្រលឹង សំអាន បានក្រោកចាកពីរូបកាយដ៏ទ្រុឌទ្រោមទៅកាន់ពិភពថ្មីមួយទៀត ដែលគ្មាននរណាអាចដឹងថានៅទីណាឡើយ។

លោកគ្រូ សំអុរ បានមករស់នៅក្នុងភូមិចំបក់ជ្រុំ រយៈពេលយូរគ្រាន់បើដែរ។ គាត់ខំរស់លាក់ប្រវត្តិ ដើម្បីរក្សាជីវិតរបស់គាត់ ព្រោះបើអង្គការដឹង គាត់នឹងមិនរស់ឡើយ។ រៀងរាល់ថ្ងៃ អង្គការ បានឲ្យលោកគ្រូធ្វើស្រែក្នុងភូមិជាមួយប្រជាជនចាស់។ ល្ងាចថ្ងៃមួយ មុនពេលហូបបាយ អង្គការបានបង្ហាញជនកងកម្លាំងចល័តថ្មី ដែលបានចល័តមកពីស្រុកផ្សេងឲ្យមកជួយធ្វើការក្នុងតំបន់នោះ។ ក្នុងចំណោមជនចំណូលថ្មី មានម្នាក់ជាអតីតកូនសិស្សលោកគ្រូ សំអុរ ពីសង្គមចាស់ ដែលមានគំនុំក្តៅដូចភ្លើងជាមួយពួកអ្នកមានទ្រព្យធន។ អតីតកូនសិស្សនេះហើយជាអ្នកនាំខ្សែជីវិតលោកគ្រូ សំអុរ ទៅកាន់ភាពជូរចត់។ លោកគ្រូ សំអុរ មិនបានចាប់អារម្មណ៍ចំណាំមុខសិស្សរបស់គាត់ឡើយ។ ក្រោយបានមករស់ក្នុងភូមិនេះ កងចល័តយុវជន ត្រូវអង្គការប្រគល់ការងារស្នូលក្នុងឃុំឲ្យធ្វើ គឺជីកប្រឡាយ។ សាម៉ែត ជាអតីតសិស្សលោកគ្រូ សំអុរ បានផុសការសងសឹកចំពោះលោកគ្រូ សំអុរ ឡើងក្នុងអារម្មណ៍ភ្លាម។ សាម៉ែត គុំនឹងលោកគ្រូ សំអុរ ព្រោះកាលពីសង្គមមុន លោកគ្រូ សំអុរ បានរារាំងសិស្សរបស់គាត់កុំឲ្យធ្វើបដិវត្តន៍ផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ។ សាម៉ែត តែងតែលួចសម្លឹងទៅលោកគ្រូ សំអុរ ជារឿយៗ។

រាត្រីត្រជាក់ខ្យល់សំណើមទឹកភ្លៀងដើមរដូវវស្សាបានបក់តិចៗអង្រួនរុក្ខជាតិទាំងឡាយដែលឈរអរាំតាមខ្យល់ហាក់ដូចជាគ្មានកង្វល់ជាមួយមនុស្សលោកសោះ។ លោកគ្រូ សំអុរ ហៀបនឹងផ្តុំពន្លត់ភ្លើងចន្ទុះចូលសម្រាកជាមួយ មីង

ធីតា ក្នុងខ្នមទៅហើយ ស្រាប់តែមានស្រមោលខ្មៅស្នង់ៗមកពីចម្ងាយ។ សាម៉ែត និងកងឈ្លប ៤នាក់ ដើរសំដៅមកកូនខ្នមរបស់លោកគ្រូ សំអុរ។ មកដល់ភ្លាម សាម៉ែត ចាប់ស្រដីភ្លាមថា «សុខសប្បាយទេលោកគ្រូ សំអុរ?» លោកគ្រូ សំអុរ តបដោយកិតភ័យវិញថា «បាទ!ខ្ញុំសុខទេក្មួយ ម្តេចហៅខ្ញុំគ្រូអីចឹង?» ។ ឮ លោកគ្រូ សំអុរ សួរដូច្នោះ សាម៉ែត និយាយដោយទឹកមុខមាំមកកាន់លោកគ្រូ វិញថា «លោកគ្រូ សំអុរ ឯងពូកែលាក់ពុតណាស់! ខ្លួនឯងជាគ្រូបង្រៀនកាលពី សង្គមចាស់ គ្រូឯងស្មានតែខ្ញុំមិនដឹងឬ? កាលពីសង្គមសាធារណរដ្ឋខ្មែរ ខ្ញុំបាន រៀនជាមួយលោកគ្រូឯងដែរតើ តែប្រហែលគ្រូឯងមិនចាំខ្ញុំទេមើលទៅព្រោះខ្ញុំ វាក្រ រៀនមិនពូកែដូចគេ។ ខ្ញុំក៏ឈប់រៀនចូលបដិវត្តន៍ទៅ។ ឥឡូវនិស្ស័យបាន បណ្តាលឲ្យខ្ញុំបានមកជួបលោកគ្រូម្តងទៀតហើយ។ តើលោកគ្រូមានអីចង់ ប្រកែកជាមួយអង្គការទៀតទេ? ឥឡូវសមមិត្តឯងត្រូវស្នើឲ្យទៅជួយធ្វើការឲ្យ អង្គការថ្នាក់លើនៅទីក្រុង មិត្តឯងឆាប់រៀបចំទៅ យើងចេញទៅឥឡូវនេះ»។ លោកគ្រូ សំអុរ ភ័យណាស់ ក៏និយាយអង្វរវិញថា «តែឥឡូវខ្ញុំធ្វើការបម្រើអង្គការ ថ្នាក់លើណា លោកក្មួយមិនហានជំទាស់បញ្ជាអង្គការម្តងណាទេលោកក្មួយ! សូម លោកក្មួយអាណិតកុំធ្វើអីខ្ញុំលោកក្មួយ»។ ចំណែក មីងធីតា ក៏ជួយអង្វរ សាម៉ែត ដែរ ប៉ុន្តែ សាម៉ែត មិនព្រមឡើយ។

ដំណើរឃ្លាតលើកនេះ លោកគ្រូ សំអុរ បានដឹងច្បាស់ណាស់ថាខ្លួនរបស់គាត់ ប្រាកដជាមិនអាចត្រលប់មកជួបប្រពន្ធកូនខ្លួនវិញឡើយ។ មុនពេលចាកចេញ ពីប្រពន្ធកំសត់ទៅតាមពួកឈ្លប និង សាម៉ែត លោកគ្រូ សំអុរ បានផ្តែផ្តាំប្រពន្ធ ខ្លួនថា «អស់ពីខ្ញុំទៅចូលឯងមើលថែខ្លួន និងកូនស្រីប្រុសយើងឲ្យបានល្អ។ ខ្ញុំ មិនបាននៅមើលថែឯងទៀតទេ»។ ពាក្យសម្តីតែប៉ុន្មានម៉ាត់នេះប៉ុណ្ណោះ ជាទ្រព្យ ចុងក្រោយដែលលោកគ្រូ សំអុរ បានបន្សល់ទុកឲ្យ មីងធីតា។ មីងធីតា អង្គុយ មើលកងឈ្លបបណ្តើរប្តីរបស់គាត់ចាកចេញទៅដោយទឹកភ្នែករហាម។

ឱ! ឈាមអ្នកចេះដឹងខ្មែរទាំងឡាយ តើអ្នកខុសអ្វីទើបអង្គការខ្មែរក្រហម ប្រហារជីវិតអ្នកដោយឥតស្តាយស្រណោះអីចឹង? អ្នកគ្មានកំហុសទេ តែអ្នកត្រូវ

ចោទថា ក្បត់នឹងអង្គការទៅវិញ។ ចុះអ្នកដែលលើកដៃពិឃាដជីវិតមនុស្សរាល់គ្នានោះ អ្នកស្មោះនឹងអង្គការមហាលោតផ្លោះ មហាអស្ចារ្យ មហារុងរឿងខ្លាំងប៉ុណ្ណាទៅ? ឈាមខ្មែរហូរដូចសមុទ្រក្នុងមហានគរ ទឹកភ្នែកខ្មែរហូរជាទន្លេជន់ក្នុងផ្ទៃប្រទេស វប្បធម៌ខ្មែរដែលបុព្វបុរសបានបន្សល់ទុកឲ្យ បានរលាយសាបសូន្យដូចផ្សែងក្នុងអាកាសរវើហា។ បន្ទាប់ពីលោកគ្រូ សំអុរ ត្រូវអង្គការស្នើយកទៅបាត់ទៅ មីងធីតា នៅតែខំធ្វើការតតួញរាឡើយ ព្រោះតែខ្លាចអំណាចអង្គការ។ ម្យ៉ាងទៀត មីងធីតា នៅមានក្តីរំពឹងមួយទៀតថានឹងបានជួបមុខកូនប្រុសស្រីរបស់គាត់វិញ នៅថ្ងៃណាមួយ។

សល់តែសំបកកាយ

នៅខែធ្នូ ឆ្នាំ១៩៧៨ កម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានចាប់កញ្ជ្រោលឡើងក្នុងខេត្តក្រចេះ។ កងទ័ពវៀតណាម បានវាយសម្រុកចូលប្រទេសកម្ពុជាលើកងកម្លាំងពួកខ្មែរក្រហមយ៉ាងសន្ធាប់ហើយធ្វើឲ្យកងទ័ពខ្មែរក្រហមដកថយពីសមរភូមិប្រយុទ្ធជាបន្តបន្ទាប់។ លុះដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាម បានកាន់កាប់ទីក្រុងភ្នំពេញ ហើយប្រទេសកម្ពុជា បានប្តូររបបដឹកនាំថ្មី។ ខេត្តក្រុងនានាត្រូវរំដោះឲ្យប្រជាជនមានសិទ្ធិសេរីភាពពេញលេញជាបន្តបន្ទាប់។ ដោយឡែកប្រជាជននៅក្នុងខេត្តក្រចេះ ត្រូវបានរំដោះខ្លួនពីអង្គការកំណាចតាំងពីចុងខែធ្នូមកម្ល៉េះ ព្រោះតំបន់នោះជាតំបន់បូព៌ា។

មីងធីតា ក៏ដូចជាប្រជាជនដទៃទៀត បាននាំគ្នាទៅរកកូនដែលបានរស់នៅបែកគ្នាតាំងពីយូរមកហើយ។ មីងធីតា បានជួបនឹង សំអាង នៅក្នុងភូមិមួយស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិចំបក់ ដែលគាត់ស្នាក់នៅ។ សេចក្តីរីករាយបានកើតឡើងចំពោះ សំអាង ដែលបានបែកពីម្តាយរបស់ខ្លួនប្រមាណជាងបីឆ្នាំមកហើយ។ ចំណែកនាង សំអាត និងសុផល បានវិលមករកមីងធីតា នៅភូមិចំបក់ដែរបន្ទាប់ពីបានទទួលដំណឹងពីអ្នកភូមិ។

ជិត៣ខែ ទើបមីងធីតា និងកូនៗបានវិលត្រលប់មកដល់ភូមិកំណើតខ្លួនវិញនៅក្រុងកំពង់ចាម។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ប្រជាជនខ្មែរម្នាក់

នៅសល់តែបាតដៃទទេ គ្មានទ្រព្យធនអ្វីឡើយ។ ម្នាក់ៗខិតខំធ្វើស្រែយកស្រូវចិញ្ចឹមជីវិតក្នុងជីវភាពថ្មីបន្ទាប់ពីបញ្ចប់របបខ្មៅងងឹតនេះ។ ចំណែកឯ សំអាត មិនបានលះលែងពី សុផល ជាប្តីដែលអង្គការបានរៀបចំផ្សំផ្គុំឲ្យទេ។ អ្នកទាំងពីររស់នៅក្នុងក្រុងកំពង់ចាមជាទឹកដីកំណើតជាទីស្នេហាក្នុងជីវភាពថ្មីមួយជាមួយម្តាយ និងប្អូនប្រុស។

អ្វីៗគ្រប់បែបយ៉ាងបានក្លាយទៅជាស្រមោលអតីតខ្មៅងងឹតជិតជាប់ក្នុងការចងចាំរបស់ប្រជាជនខ្មែរគ្រប់គ្នា ហើយការចងចាំនេះ គឺជាការចងចាំដ៏ឈឺចាប់មួយក្នុងសតិអារម្មណ៍របស់ប្រជាជនខ្មែរ។ យើងមិនអាចលុបស្នាមអតីតនេះពីការចងចាំរបស់យើងបានឡើយ ប៉ុន្តែយើងសូមផ្ញើស្នាមអតីតនេះ ក្នុងបេះដូងរបស់ខ្មែរគ្រប់ជំនាន់សម្រាប់ជាបទពិសោធន៍ និងមេរៀនប្រវត្តិសាស្ត្ររបស់ខ្មែរតទៅ៕

ចប់

២៩

រឿងស្នាមជាន
ជីវិត

អ្នកនិពន្ធ ៖ ស៊ុន ឥណ្ណៈ

២៩ ~ រឿង ស្នាមជាន់ជីវិត

សប្បាយប្រែជាទុក្ខ

ថ្ងៃចូលឆ្នាំខ្មែរត្រូវជាឆ្នាំថោះ បានកន្លងផុតទៅមួយថ្ងៃ ប្រជាជនកម្ពុជាទទួលបានក្តីសប្បាយរីករាយសារជាថ្មីម្តងទៀតចំពោះជ័យជម្នះរបស់ខ្មែរក្រហមទៅលើរបប លន់ នល់។ ម៉ោងប្រហែលជា៩និង៣០នាទីព្រឹក ក្រុមខ្មែរក្រហមមានប្រដាប់ដោយអាវុធ ចូលមកកាន់កាប់ទីក្រុងភ្នំពេញ។ យុវជន យុវនារី ក្មេងចាស់ ប្រុសស្រី បានអបអរសាទរចំពោះជ័យជម្នះនេះជាខ្លាំង។ អ្នកខ្លះឈរតម្រៀបជាជួរទទួលស្វាគមន៍នូវវត្តមានរបស់កងកម្លាំងខ្មែរក្រហម រីឯអ្នកដែលមានផ្ទះជាប់ដងផ្លូវ ក៏ចេញមកទទួលស្វាគមន៍ព្រមទាំងមានកាន់ក្រណាត់ អាវសំពត់ពណ៌ស លើកបក់គ្រវីក្នុងគោលបំណងបង្ហាញជាសញ្ញាថាខ្លួនបានព្រមចុះចូលជាមួយជ័យជម្នះរបស់ខ្មែរក្រហមហើយ។

ចំណែកឯនៅម្តុំផ្សារមេឃ(ទួលទំពូង) ឯណោះវិញ មានគ្រួសារមួយដែលជាអ្នកមានមុខមានមាត់ក្នុងជួររដ្ឋាភិបាលខ្មែរកាលពីសម័យសង្គមចាស់។ ការមកដល់របស់ខ្មែរក្រហម បានធ្វើឲ្យទឹកមុខរបស់សមាជិកគ្រួសារនោះ ពោរពេញទៅដោយភាពភ័យខ្លាចខុសប្លែកពីក្រុមគ្រួសារដទៃទៀត។ ក្រុមគ្រួសារនោះបានដឹងយ៉ាងប្រាកដថា ជ័យជម្នះរបស់ពួកខ្មែរក្រហម គឺជាជ័យជម្នះរបស់កងកម្លាំងកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា។

បន្ទាប់មកសំឡេងឧគ្ឃោសនាសព្ទ បានបន្លឺឡើងក្រោមកម្តៅព្រះអាទិត្យវេលាថ្ងៃត្រង់។ សំឡេងនោះបានបន្លឺឡើងថា «ពួកយើងបានយកជ័យជម្នះលើ

របប លន់ នល់ ដែលពោរពេញទៅដោយអំពើពុករលួយ និងបក្ខពួកនិយម។ ដូច្នេះ សូមបងប្អូនកុំបារម្ភតទៅទៀតអី ប៉ុន្តែកងកម្លាំងអាមេរិកនៅបន្តទម្លាក់គ្រាប់បែកនៅក្នុងក្រុងភ្នំពេញនៅឡើយ។ ម្យ៉ាងវិញទៀត ពួកយើងនៅពុំទាន់មានសមត្ថភាពដឹកស្បៀងផ្គត់ផ្គង់ប្រជាជននៅទីប្រជុំជនរួមទាំងបងប្អូននៅក្រុងភ្នំពេញទេ។ ដូច្នេះពួកយើងសូមឲ្យបងប្អូនចាកចេញពីក្រុងភ្នំពេញតែក្នុងរយៈពេលពីរទៅបីថ្ងៃតែប៉ុណ្ណោះ។ សូមបងប្អូនកុំព្រួយបារម្ភអី!»។

សំឡេងបន្លឺឡើងបានបញ្ចប់ ប្រជាជននាំគ្នា រូតរះប្រញាប់ប្រញាល់រៀបចំអីវ៉ាន់របស់របរនិងសម្លៀកបំពាក់។ អ្នកខ្លះយកលុយទាំងគរទាំងបាវ ហើយអ្នកខ្លះទៀតយកតែខោអាវមួយកាតាបកាបូបតូចតែប៉ុណ្ណោះ។ ចំណែកក្រុមគ្រួសាររបស់ តាស៊ុន ដែលសមាជិកគ្រួសាររបស់គាត់ទាំងអស់កំពុងញាប់ដៃញាប់ជើងរៀបចំអីវ៉ាន់។ នៅក្នុងចំណោមសមាជិកទាំងអស់ មីងចំរើន ដែលជាកូនរបស់តាស៊ុន កំពុងតែពពោះជិតគ្រប់ខែ។ យាយសយ ដែលជាម្តាយ បានសួរទៅកូនថា «អារើនកូន អើចុះប្តីឯង អាផាត វាយ៉ាងម៉េចយ៉ាងម៉ាហើយកូន?»។ មីងចំរើនតបទៅម្តាយវិញថា «ចាស៎ម៉ែ ប្តីកូនគាត់ទៅរាមជួញប្រែទំនិញ បីបួនខែហើយអត់ទាន់ឃើញគាត់មកវិញទេ កូនបារម្ភណាស់ម៉ែ»។ យាយសយតបទៅវិញថា «កុំគិតបារម្ភអីកូន ឥឡូវយើងត្រូវចាកចេញពីផ្ទះយើងសិន បើមានកិច្ចមែនពិតកូនគង់តែបានជួបនឹងប្តីកូនជាពុំខាន»។

ស្រាប់តែពេលនោះមានសំឡេងមួយទៀត បានបន្លឺឡើងថា «ម៉ែ ពុក មីអូន រៀបចំអីវ៉ាន់ហើយឬនៅ? ប្រញាប់ឲ្យលឿនឡើងព្រោះពួកកងខ្មែរក្រហមគេយកកាំភ្លើងមកសម្លុតគំរាមឲ្យពលរដ្ឋចុះចេញពីផ្ទះឲ្យប្រញាប់»។

តាស៊ុន ឮដូច្នោះ ក៏ប្រញាប់និយាយទៅកាន់ក្រុមគ្រួសាររបស់គាត់ថា «គោះម៉ែ មីអូន យើងប្រញាប់ទៅឲ្យលឿន»។

បន្ទាប់មកក្រុមគ្រួសាររបស់ តាស៊ុន បានធ្វើដំណើរចាកចេញពីផ្ទះទាំងទឹកមុខស្រពាប់ស្រពោនលាយឡំនិងភាពស្តាយស្រណោះអាឡោះអាល័យដល់ទីកន្លែងកំណើតរបស់ខ្លួន។ ប្រមាណជាពីរម៉ោងសោះ ប្រជាជនក្នុងទីក្រុងភ្នំពេញ

បានចាកចេញពីលំនៅឋានរបស់ខ្លួន ហើយទីក្រុងភ្នំពេញដែលធ្លាប់តែឡូយឆាយ ស៊ីវិល័យ ប្រែក្លាយទៅជាទីក្រុងខ្មោច ដោយមានតែផ្ទះគ្មានមនុស្សនៅ មានតែផ្សារតែគ្មានអ្នកលក់និងអ្នកទិញ ហើយមានសាលារៀន ប៉ុន្តែគ្មានគ្រូបង្រៀន និងសិស្សរៀន។

ក្លាយជាម្ហូយនៅកណ្តាលកោះ

សូរកាំភ្លើងបន្លឺគំរាមដល់បណ្តាជន ឲ្យជម្លៀសខ្លួនទាំងបង្ខំទៅតាមមូលដ្ឋានសហករណ៍ដែលខ្មែរក្រហមបានចាត់តាំង។ ក្រុមគ្រួសាររបស់ តាស៊ុន ត្រូវបានកងខ្មែរក្រហមជម្លៀសទៅសហករណ៍មួយស្ថិតនៅក្នុងខេត្តកណ្តាល។ នៅក្នុងពេលធ្វើដំណើរតាមផ្លូវ មីងចំរើន បានឈឺពោះសម្រាលកូន។ តាស៊ុន, យាយសយ និងពូសម ក័យខ្លាំងណាស់ មុខរបស់ពួកគាត់ឡើងស្លេកស្លាំងគ្រប់គ្នា។ ខណៈពេលនោះ ជួនជាមានឆ្មបម្នាក់ឈ្មោះ វី ដែលជាអ្នកនៅក្បែរផ្ទះរបស់ តាស៊ុន ក៏ត្រូវបានខ្មែរក្រហមជម្លៀសមកជាមួយ តាស៊ុន ដែរ រួចបានជួយសម្រាលកូនឲ្យមីងចំរើន។ ខណៈពេលដែលមីងចំរើន ឈឺពោះសម្រាលកូន គឺក្រុមគ្រួសាររបស់តាស៊ុន កំពុងឈប់សម្រាកនៅលើកោះហៃអាន ដែលស្ថិតនៅក្នុងខេត្តកណ្តាល។

សម្រែកទ្រហោយំ លាយឡំនឹងភាពខំប្រឹងប្រែងញ័រដៃញ័ររជើង ខំអស់ពីពោះគួបផ្សំនឹងសំឡេងមីងវី ជាឆ្មបស្រែកឡើងថា «ខំប្រឹងឡើងមីអូន ចេញក្បាលហើយ ខំៗ ឡើង!»។ រយៈពេលតែមួយរំពេចសោះ ទារិកាមួយបានកើតចេញមកព្រមទាំងជាប់ឈាមប្រឡាក់ពេញខ្លួននៅកណ្តាលកោះ ក្រោមកម្តៅព្រះអាទិត្យម៉ោងប្រហែលជា៣រសៀល។ បន្ទាប់មក មីងវី ជាឆ្មបបានកាត់ទងសុក និងសម្អាតទារិកា រួចផ្តាំយាយសយ ឲ្យជួយមើលថែម្តាយកូនតូចផងខ្លាចក្រែងកើតទាស់។ ក្រោយមកយាយសយ យកអង្ករនិងរបស់របរខ្លះៗ ដែលដាក់យកមកជាមួយពេលចេញពីផ្ទះនៅភ្នំពេញ មកជូនមីងវី ជាឆ្មបតាមទំនៀមទម្លាប់ខ្មែរ។ រួច តាស៊ុន ចាប់កាន់បីចៅ ហើយមើលទៅមុខចៅទាំងទឹកភ្នែក ដោយនិយាយថា «ចៅកំសត់តា បើសិនជាចៅកើតពេលយើងមានបាន មានផ្ទះរស់នៅ ហើយប្រទេសមានសុខសន្តិភាព មិនដឹងជាល្អយ៉ាងណានោះទេ តាអាណិតឯងណាស់»។ មួយស្របក់

ក្រោយមក មីងចំរើន បានភ្ញាក់ពីសន្លប់។ តាស៊ុន បានយកចៅទៅដាក់ឲ្យនៅជិតម្តាយ។ មីងចំរើន អរពេកអាណិតដល់កូន ក៏យំឱបកូនរួចដាក់ឈ្មោះឲ្យកូនស្រីកំសត់នេះថា «នាងផល»។

ក្រោយពីរៀបចំចាត់ចែងរួចមក ក្រុមគ្រួសារនេះបានបន្តដំណើរទៅមុខទៀត ដោយមិនបង្អែបង្អង់ខ្លាចក្រែងពួកខ្មែរក្រហមវាយនឹងដងកាំភ្លើង ឬចោទថាជាខ្មាំងប្រឆាំងនឹងអង្គការ។

អនិច្ចាអាសូរដល់ក្រុមគ្រួសារដ៏កំសត់នេះណាស់ ធ្លាប់តែស្រណុកសុខស្រួលមានទ្រព្យសម្បត្តិ មានបុណ្យសក្តិ ប៉ុន្តែដោយសារតែសង្គ្រាមត្រូវនិរាសព្រាត់ប្រាសពីភូមិ ពីផ្ទះ ទៅតាមអ្វីដែលអង្គការបង្គាប់ជាជាច់ខាត ហើយបើសិនជាប្រឆាំងគឺត្រូវស្លាប់ទាំងពូជ។

ព្រាត់បង ព្រាត់ឪ

មកដល់សហករណ៍ភ្លាម ក្រុមគ្រួសាររបស់ តាស៊ុន ត្រូវបានអង្គការចាត់តាំងឲ្យទៅរស់នៅឯភូមិដែលមានដាក់តែប្រជាជនថ្មី។ តាស៊ុន, ពូសម បានចាត់ចែងរៀបចំដាំបង្គោល ដើម្បីសាងសង់ខ្ទមសម្រាប់ស្នាក់នៅ។ នាវេលាយប់អធ្រាត្រម៉ោងប្រហែល១ទៀបភ្លឺ កងឈ្លបបានមកដល់ខ្ទមរបស់ តាស៊ុន រួចសួរថា

«តើមិត្តណាមួយឈ្មោះ ស៊ុន អង្គការត្រូវការជាបន្ទាន់ភ្លាម?»។ នៅក្នុងចិត្តរបស់ តាស៊ុន គិតទុករួចជាស្រេចហើយថា ប្រាកដជាអង្គការយកគាត់ទៅសួរធ្វើបាប ឬសួរចម្លើយជាក់ជាមិនខាន។ តាស៊ុន មិនហ៊ានប្រកែក ក៏សម្រេចចិត្តទៅជាមួយកងឈ្លប។ មកដល់ទីស្នាក់ការ កម្មាភិបាលខ្មែរក្រហមព្រែកហូរភ្លាម តាស៊ុន ត្រូវបានកងឈ្លបចាប់ចងដៃនឹងខ្សែ ហើយមានកម្មាភិបាលម្នាក់សួរទៅកាន់ តាស៊ុន ជាភាសាបារាំងថា «Etes-vous un officier ou pas?»។ តាស៊ុនតបទៅវិញភ្លាមៗថា «សូមទោសលោក ខ្ញុំអត់ចេះស្តាប់ទេ»។

គ្រាន់តែឮដូច្នេះ កម្មាភិបាលខ្មែរក្រហមនោះ បានលើកយករូប តាស៊ុន ពាក់ផ្តាយមួយ ដែលជាមេបញ្ជាការកងយោធា។ តាស៊ុន ឃើញដូច្នោះ ខំប្រឹងអង្វរលោកធំ តែទោះជាយ៉ាងណា ពួកកម្មាភិបាលខ្មែរក្រហមមិនព្រមស្តាប់

ដោយសម្អាងថាមិត្តឯងក្បត់នឹងអង្គការដោយហ៊ានកុហក ព្រមទាំងពុំមានភាពស្មោះត្រង់ជាមួយអង្គការ។ បន្ទាប់មកពួកកម្មាភិបាលខ្មែរក្រហម បានបញ្ជាឲ្យកងឈ្លបចាប់ តាស៊ុន យកទៅកសាង។

កសាងៗប៉ុន្តែតាមធាតុពិតគឺយកទៅសម្លាប់ចោលសោះ។ នាវេលាយប់នោះ តាស៊ុន បានលាចាកលោកទៅយ៉ាងអាណោចអាធ័មជាទីបំផុត នៅកណ្តាលវាលស្រែក្នុងជង្គុកឆ្នឹង។ ចំណែកឯយាយសយ ឯណោះវិញ ពីមួយថ្ងៃទៅមួយថ្ងៃទន្ទឹមរង់ចាំតែផ្លូវប្តី ដោយក្នុងចិត្តរបស់គាត់នឹករឭកដល់ប្តីជាពន់ពេក។ ទោះជាយ៉ាងណាក៏ដោយ យាយសយ បានព្យាយាមធ្វើចិត្ត និងពុំហ៊ានមាត់កអ្វីទាំងអស់។

កន្លងផុតបានរយៈពេលប្រហែលមួយអាទិត្យ កងឈ្លបមួយក្រុម ដែលមានគ្នាចំនួន៣នាក់ បានមកម្តងទៀត។ លើកនេះកងឈ្លបសួរកេ ពូសម វិញម្តង។ ពេលឃើញដូច្នោះ ពូសម ព្យាយាមរត់គេចទៅសហករណ៍ដទៃ ប៉ុន្តែទោះបីជាខំគេចយ៉ាងណាក៏ដោយ ពូសម ពុំអាចរត់គេចខ្លួនរួចពីក្រសែភ្នែកពួកខ្មែរក្រហមបានឡើយ។ ពេលដែលពួកខ្មែរក្រហមបានរកឃើញ ពូសម គេបានចាប់ចងគាត់នឹងខ្សែនីឡុង ហើយគ្របក្បាលគាត់នឹងថង់ រួចសម្លាប់គាត់នឹងចបទម្លាក់ចូលក្នុងទំនប់ប្រឡាយ ដែលមើលទៅមានសភាពគួរឲ្យអាណិតជាពន់ពេក ព្រោះពូសម ស្លាប់ទាំងប្រកាច់ និងម្យ៉ាងវិញទៀត គាត់ស្លាប់ទៅទាំងពុំទាន់មានប្រពន្ធកូននៅឡើយទេ។

ចំណែកយាយសយ និងមីងចំរើន ព្រមទាំងទារិកាកំសត់ឯណោះវិញ គួរឲ្យអនិច្ចាអាណិតជាពន់ពេក។ ម្តាយចាស់ កូនខ្ចី ក្មេងទើបតែនឹងកើតមិនដឹងទៅពឹងពាក់អ្នកណាបាន ក៏ទ្រាំរស់ទាំងត្រដរ ដោយមិនតបតនឹងអ្វីទាំងអស់។

សុខទុក្ខរបស់ខ្ញុំនៅក្នុងរបបយង់ឃ្នង

២ឆ្នាំកន្លងផុតទៅ ទារិកាតូចក៏ចេះដើរបានតិចៗ ហើយអាចបៅទឹកបបរបានខ្លះៗដែរ។ យាយសយ និងមីងចំរើន បានរួចខ្លួនពីការតាមប្រមាញ់សម្លាប់ដោយសារតែមានអ្នកមូលដ្ឋានចាស់ម្នាក់ឈ្មោះ ចន តាមជួយការពារដោយយកលេសថា ខ្លួននិងស្ត្រីទាំងពីរនាក់ គឺជាសាច់ញាតិនឹងគ្នា ហើយយាយសយ

បាននិយាយកុហកទៅអង្គការទៀតដែរថា គាត់ កូននិងចៅជាគ្រួសារក្រីក្រ ដើរលក់តែនំគម នំអន្សម និងនំអាកោបន្តិចបន្តួចតែប៉ុណ្ណោះ។ ខណៈពេលនោះ ទាំងយាយសយ មីងចំរើន និងកូនតូច ត្រូវបានអង្គការផ្លាស់ឲ្យទៅសហករណ៍ថ្មីនៅឯព្រៃកកំពឹសវិញ។

នៅក្នុងសហករណ៍ មីងចំរើន ធ្វើការងារនៅក្នុងក្រុមកងចល័តស្ត្រី ដែលគាត់ត្រូវរែកដី លើកទំនប់ ជួនធ្វើស្រែ ស្ទូង ច្រូតស្រូវ ហើយពេលខ្លះទៀត គាត់ត្រូវទៅជួយជាំពោត សណ្តែកនិងដំឡូងជាដើម។ រីឯយាយសយ និងកូនតូច ត្រូវនៅផ្ទះ ដោយហេតុថា យាយសយ មានវ័យចំណាស់ រីឯក្មេងតូចជួយអីមិនបាន ទើបខ្មែរក្រហមមិនប្រើឲ្យធ្វើការទេ។

ពេលព្រឹកព្រលឹមពុំទាន់ ហ្វូងមនុស្សឈរតម្រៀបគ្នាជាជួរ ចាំយករបបអាហារ ដែលមានតែបបរវាវដូចទឹកទន្លេ មានតែអង្ករបួនដប់គ្រាប់តែប៉ុណ្ណោះ។ ទោះជាយ៉ាងណា អ្នកទាំងអស់នោះនៅតែពុំហ៊ានប្រកែកតវ៉ា សុខចិត្តធ្មេចភ្នែកហូបតែបបរនោះដោយគិតថា បើមិនស៊ី គឺត្រូវតែស្លាប់។ ចំណែកឯ មីងចំរើនវិញ នៅពេលដែលគាត់ត្រូវមេកងចល័តចាត់ឲ្យទៅមើលពោត ឬទៅកាច់ពោត គាត់តែងតែលួចលាក់ពោតជាក់សៀតនៅនឹងចង្កេះយកមកឲ្យម្តាយស្ងោរក្នុងកំសៀវទឹកក្តៅទុកគ្រាន់ហូបបន្ថែមពីលើបបរនោះ។

នៅក្នុងឆ្នាំ១៩៧៧ មីងចំរើន ត្រូវបានប្រធានកងចល័តបង្គាប់ឲ្យទៅជួប។ ពេលនោះ ទាំងមីងចំរើននិងយាយសយ មានចិត្តភ័យជាពន់ពេក ហើយនៅរំពេចនោះ កូនតូចក៏បន្លឺសំឡេងយំឡើង។ មីងចំរើន លាម្តាយរួចថើបកូនតូចនិងដើរទៅតាមក្រុមកងឈ្លបដែលមកហៅគាត់។

កណ្តាលរាត្រី មីងចំរើន និងសមមិត្តដទៃៗទៀត បានមកដល់ស្នាក់ការរបស់កម្មាភិបាលខ្មែរក្រហម។ ពេលនោះ អង្គការបានចាប់ផ្សុំផ្គុំគ្នា ដោយមានប្រហែលជា៣០ទៅ៤០គូ។ ក្នុងការផ្សុំផ្គុំនោះ ក៏មានមីងចំរើន ដែរ។ ក្នុងចិត្តរបស់ មីងចំរើន ដំបូងឡើយស្មានតែអង្គការចាប់ខ្លួនយកទៅសម្លាប់ដូចបងនិងឪពុករបស់គាត់ ប៉ុន្តែតាមជាតុពិត អង្គការបានយកគាត់មកផ្សុំផ្គុំឲ្យរៀបការទាំង

បង្ខំបែបនេះទៅវិញ។ នៅពេលនោះ មីងចំរើន ត្រូវបានអង្គការជ្រើសរើសផ្សំផ្គុំជាមួយសមមិត្ត ចន ដែលជាអ្នកមានគុណមកលើខ្លួននិងម្តាយ។ មីងចំរើន ពុំដែលគិតចង់រៀបការជាមួយសមមិត្ត ចន ដែលគាត់ចាត់ទុកត្រឹមតែជាបងប្រុសនោះទេ។ មីងចំរើន មានស្វាមីភក្តីចំពោះតែ ពូផាត ដែលជាប្តីរបស់គាត់តែម្នាក់ប៉ុណ្ណោះ។ រីឯ ពូចន វិញ គាត់ក៏គិតដូចមីងចំរើន ដែរ។ ពូចន ត្រឹមតែចាត់ទុកមីងចំរើន ជាប្អូនស្រីតែប៉ុណ្ណោះ។ ទោះជាអ្នកទាំងពីរពុំបានស្រលាញ់គ្នា អ្នកទាំងពីរត្រូវតែរៀបការទាំងបង្ខំចិត្ត ដោយសារតែនេះ ជាការគោរពសង្កត់របស់អង្គការ។ បើប្រឆាំងគឺត្រូវតែស្លាប់។

នៅយប់ថ្ងៃផ្សំដំណេក ពូចន បានប្រាប់ទៅ មីងចំរើន ថា «មិនបាច់ភ័យបារម្ភ ឬព្រួយអ្វីទេ យើងគ្រាន់តែធ្វើពុតជាប្តីប្រពន្ធនឹងគ្នាទៅបានហើយ។ ខ្ញុំដឹងថាអារើន ឯងមានប្តី មានកូនរួចហើយ។ ចំណែកឯខ្ញុំ ក៏មានប្រពន្ធរួចហើយដែរ គ្រាន់តែយើងបែកគ្នាដោយសារសង្គ្រាមប៉ុណ្ណោះ។ ដូច្នេះយើងគ្រាន់តែរៀបការបង្ក្រប់កិច្ចទៅបានហើយ»។ មីងចំរើនតបវិញដោយទឹកចិត្តត្រេកអរថា «ចាស់បង ខ្ញុំដឹងថាបងមានបំណងល្អមកលើប្អូន និងគ្រួសារ។ ប្អូនផ្ទាល់ និងបង គ្រាន់តែសម្តែងដើម្បីរក្សាជីវិតពួកយើងតែប៉ុណ្ណោះ»។ នៅក្នុងពេលនោះ ទាំងពូចន ទាំងមីងចំរើន និយាយឱ្យឺបៗគ្នាតែប៉ុណ្ណោះ ព្រោះខ្លាចក្រែងតែមានអ្នកឮរួចចាប់ខ្លួនអ្នកទាំងពីរយកទៅសម្លាប់ចោល។

បន្ទាប់ពីយប់នោះមក ពីមួយថ្ងៃទៅមួយថ្ងៃ មីងចំរើន ក្នុងនាមជាម្តាយផង កូនផង ត្រូវរ៉ាប់រងស៊ូទ្រាំថែមទាំងជួយដល់ម្តាយជារៀងទៀត ទោះជាលួចលាក់ឬកុហកអ្វីឡើយ ឲ្យតែអាចមានរបស់ហូប គឺគាត់ធ្វើបានទាំងអស់។ ថ្ងៃមួយពេលដែល មីងចំរើន ត្រូវអង្គការចាត់ឲ្យទៅបាចទឹកចេញពីស្រែ មីងចំរើន បានលបលួចយកកង្កែបនិងត្រី ដាក់ទុកក្នុងក្រមា ហើយពេលមកដល់ផ្ទះវិញទើបឲ្យយាយសយ ធ្វើជាដាំទឹក រួចអាំងត្រីនិងកង្កែបនោះ នៅក្នុងរងើកភ្លើងក្រោមឆ្នាំងឬកំសៀវទឹកនោះ។

បានសុខសាន្តត្រាណា

នាដើមខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានកើតឡើង។ កងកម្លាំងរណសិរ្ស បានបន្តពង្រីកការវាយរំដោះតាមភូមិ ស្រុក ខេត្ត និងក្រុងមួយចំនួន ហើយនៅទីបញ្ចប់កងកម្លាំងរណសិរ្ស បានវាយរំដោះក្រុងភ្នំពេញបាននៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ វេលាម៉ោង១២ និង៣០នាទី។

របប បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ដ៏សែនខ្មៅងងឹត ត្រូវបានបញ្ចប់ ប្រៀបបានទៅនឹងស្រមោលនៃស្បែរត្រីងងឹតរសាត់ចាកចេញបាត់ទៅដោយសារតែកម្លាំងរស្មីនៃពន្លឺព្រះអាទិត្យ។ របប ប៉ុល ពត បានបញ្ចប់ កម្ពុជា បានទទួលនៅរបបថ្មី ហើយប្រជាជនទាំងអស់បានវិលត្រលប់មកកាន់ស្រុកកំណើតជួបជុំបងប្អូន សាច់ញាតិ និងអាចបង្កបង្កើតផលបានដោយខ្លួនឯងវិញ។

ក្រោយពីរបបព្រៃផ្សៃយង់ឃ្នងនេះបានបញ្ចប់ មីងចំរើន យាយសយ និងកុមារីផែល ដែលមានអាយុ៤ឆ្នាំ បានវិលមកកាន់ផ្ទះនៅឯទួលទំពូងស្ថិតក្នុងទីក្រុងភ្នំពេញវិញ។ នៅពេលមកដល់ផ្ទះរបស់ខ្លួន មីងចំរើន បានឃើញមានប្រជាជនមួយគ្រួសារ បានមកស្នាក់នៅក្នុងផ្ទះរបស់ តាស៊ុន យាយសយ រួចទៅហើយ។ មីងចំរើន ពុំឈ្លោះប្រកែកទាមទារអ្វីឡើយ ប៉ុន្តែគាត់បែរជាផ្តាំផ្ញើនឹងម្ចាស់ផ្ទះថ្មីវិញថា «បើសិនជាឃើញមានសមាជិក ឬមានអ្នកមកសួរកខ្ញុំនិងម្តាយរបស់ខ្ញុំ សូមបងជួយប្រាប់ថា ខ្ញុំនិងម្តាយនឹងទៅស្នាក់នៅផ្ទះនៅឯម្តុំវត្តឈូកវ៉ាស្រុកកំណើតខាងម្តាយរបស់ខ្ញុំ»។ ផ្តាំផ្ញើរួច មីងចំរើន យាយសយ និងកុមារីផែល ក៏ទៅស្នាក់នៅផ្ទះម្តុំឈូកវ៉ាវិញ។

ថ្លែងពីពូផាត ឯណោះវិញ វេលាដែលគាត់រកស៊ីជួញនៅដើមឆ្នាំ១៩៧៥ គាត់មានកិព្វសំណាងណាស់។ ពូផាត ត្រូវបានកងកម្លាំងទ័ពជើងទឹកអាមេរិកជួយសង្គ្រោះពេលដែលពួកខ្មែរក្រហមបម្រុងនឹងបាញ់សម្លាប់គាត់។ កងទ័ពទាំងអស់នោះបានយក ពូផាត ទៅរស់នៅប្រទេសអាមេរិក។ ខណៈពេលដែលពូផាតស្នាក់នៅប្រទេសអាមេរិក គាត់តែងតែនឹករឭក និងសញ្ជឹងគិតពីក្រុមគ្រួសារ ប្រពន្ធ និងកូនក្នុងផ្ទៃពោះរបស់ប្រពន្ធគាត់ដែលគាត់ពុំទាន់ទាំងឃើញមុខផងនោះ។ គាត់តែងតែប្រាថ្នាថានឹងបានវិលមកកាន់មាតុប្រទេសជួបជុំក្រុមគ្រួសារវិញ។

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺ១២ឆ្នាំ ក្រោយពីខ្មែរក្រហមដួលរលំនិង បានទទួលកិច្ចព្រមព្រៀងទីក្រុងប៉ារីសមក ពូផាត បានវិលត្រលប់មកកាន់ប្រទេស កម្ពុជាវិញ។ គ្រាន់តែមកដល់ភ្លាម ពូផាត ដើរតម្រង់ឆ្ពោះទៅផ្ទះប្រពន្ធ របស់គាត់ នៅម្តុំផ្សារទួលទំពូង។ នៅពេលដែលពូផាតដើរទៅដល់ខាងមុខផ្ទះ គាត់មាន ទឹកមុខសប្បាយខុសប្លែកពីសព្វមួយដង។ ក្នុងចិត្តរបស់គាត់គិតថាបន្តិចទៀត នឹងបានជួបមុខប្រពន្ធ ហើយនឹងឃើញមុខកូនជាទីស្រលាញ់ជាលើកដំបូង។ ការ ស្រមៃនិងអារម្មណ៍សប្បាយរីករាយរបស់ពូផាត ត្រូវបានរលាយអស់។ នៅពេល មកដល់ខាងមុខផ្ទះ ពូផាត បានឃើញបុរសម្នាក់ រួចសួរបុរសដែលជាម្ចាស់ផ្ទះ ថ្មីនោះថា «អត់ទោសបងប្រុស! តើបងប្រុសមានឃើញស្ត្រីដែលជាម្ចាស់ផ្ទះ នេះពីមុនមកកាន់ផ្ទះនេះទេ»។ បុរសនោះតបវិញថា «បាទ លោកប្អូន ខ្ញុំឃើញ គាត់ គឺមានស្ត្រីចំណាស់ម្នាក់ ស្ត្រីវ័យកណ្តាលម្នាក់ និងក្មេងស្រីម្នាក់។ គាត់ ប្រាប់ថាបើសិនជាពេលណាមានអ្នកមករកគាត់នៅផ្ទះនេះ សូមប្រាប់ថាគាត់ ទៅរស់នៅស្រុកខាងម្តាយនៅម្តុំវត្តឈូកវ៉ា»។ គ្រាប់តែឮដូច្នោះភ្លាម ពូផាត បាន អរគុណ ហើយលាបុរសនោះទៅតាមស្វែងរកប្រពន្ធ កូន និងម្តាយក្មេក។ ពេល ទៅដល់វត្តឈូកវ៉ា គាត់បានចូលទៅបន់ស្រន់ដោយប៉ងប្រាថ្នាថា សូមឲ្យជួប ប្រពន្ធនិងកូនស្រីបណ្តាលចិត្តរបស់គាត់។ បន់ស្រន់រួច ពូផាត តាមស្វែងរក បន្តនៅក្នុងភូមិក្បែរៗនោះ។ ពេលនោះ គាត់បានឃើញក្មេងស្រីម្នាក់ដើរលក់ នំគម និងអាកោ ហើយមានបុរសម្នាក់រត់កង់ឌុបជ្រុលបុកនឹងថាសដាក់នំលក់ របស់ក្មេងស្រីនោះ។ រីឯពូកង់ឌុបនោះ ហេតុតែខ្លាចផង ប្រញាប់ដឹកម៉ូយផង ក៏ ជិះបង្ហូសផុតទៅ។ ពូផាត ដើរមកដល់ ហើយឃើញក្មេងស្រីនោះ ក៏ជួយលើក ថាសនំឡើង។ នៅពេលដែលនាងងើបមុខឡើង ពូផាត កត់សម្គាល់ក្នុងចិត្តថា ក្មេងស្រីនោះមានទម្រង់មុខស្រដៀងទៅនឹងមុខមាត់របស់គាត់។ ក្រោយពីបាន សួរនាំក្មេងស្រីនោះរួចមក ពូផាត ជួយជូនក្មេងស្រីនោះទៅដល់ផ្ទះ។ នៅពេល ទៅដល់ផ្ទះ ពូផាត បានឃើញ មីងចំរើន ដែលជាប្រពន្ធ និងយាយសយ ដែលជាម្តាយក្មេក។ ឃើញដូចនេះ ពូផាត ស្ទុះរត់ទៅឱបប្រពន្ធ ហើយមីងចំរើន

ប្រាប់ ពូផាត ថា «ក្មេងស្រីដែលបងបានជួបនេះគឺជាកូនស្រីរបស់បង»។ អ្នកទាំងអស់គ្នាយំឱបគ្នាដោយក្តីនឹករឭកជាពន់ពេក។

ក្រោយមក ពូផាត បានយកប្រពន្ធ កូន និងម្តាយក្មេក ទៅរស់នៅប្រទេសអាមេរិក។ អស់រយៈពេលដប់ឆ្នាំនៅសហរដ្ឋអាមេរិក យាយសយ បានស្លាប់ដោយសារតែគាត់មានជំងឺ និងជរាភាព។ បន្ទាប់ពីមរណភាពរបស់ យាយសយ ពូផាត និងមីងចំរើន បានសម្រេចចិត្តវិលត្រលប់មករស់នៅក្នុងប្រទេសកម្ពុជាវិញ។ ចំណែកឯកូនស្រីរបស់ មីងចំរើន មានប្តីជាជនជាតិអាមេរិក និងមានកូនប្រុសមួយដ៏ស្រស់សង្ហា។ អ្នកទាំងអស់គ្នា បានសម្រេចចិត្តវិលមកកាន់មាតុប្រទេសវិញ ហើយរស់នៅយ៉ាងមានសុភមង្គលនៅក្រោមម្លប់នៃសុខសន្តិភាព។

ចប់

៣០

រឿងពពកខ្មៅ

អ្នកនិពន្ធ ៖ បែន អេត្រី

៣០ ~ រឿង ៣ពកខ្មៅ

នៅពេលខ្មែរក្រហមទទួលបានជ័យជម្នះ និងចូលមកគ្រប់គ្រងក្នុងខេត្តកំពង់ធំ គ្រួសាររបស់ខ្ញុំ សាច់ញាតិ ព្រមទាំងប្រជាជនជាច្រើនទៀត បានធ្វើដំណើរចាកចេញពីទីរួមខេត្តកំពង់ធំ ទៅជ្រកកោននៅក្នុងវត្តក្តីសែន(ហៅវត្តសែនសេរី) អស់រយៈពេលប្រហែលមួយអាទិត្យ។ អង្គការបែងចែកមនុស្សជា ៣ផ្នែកផ្សេងៗគ្នា។ ប្រជាជនណាដែលធ្លាប់ធ្វើជា យោធា ខ្មែរក្រហមហៅឈ្មោះឡើងឡានទាំងក្រុមគ្រួសារជាបន្តបន្ទាប់យកទៅភូមិរលួស ដាក់ចូលទៅក្នុងរណ្តៅហើយចុចមីនសម្លាប់តែម្តង។ បន្ទាប់មកខ្មែរក្រហម បន្តហៅឈ្មោះប្រជាជនដែលមានមុខងារ គឺជាគ្រូបង្រៀនដាក់ឡានយកទៅសម្លាប់ចោលនៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ។ គោលដៅចុងក្រោយរបស់ខ្មែរក្រហម ទាំងរូបខ្ញុំ គ្រួសារ និងប្រជាជនផ្សេងទៀត ត្រូវខ្មែរក្រហម ឲ្យធ្វើដំណើរដោយថ្មើរជើង សំដៅទៅកាន់ស្រុកសន្ទុក ហើយដាក់យើងពង្រាយនៅតាមភូមិផ្សេងៗ ដូចជាភូមិប្រាសាទ ភូមិលាវ និងភូមិតាំងក្រសាំង។ ចំណែកឯជនជាតិខ្មែរ-អ៊ីស្លាមវិញ ខ្មែរក្រហមមិនទាន់មានវិធានការយកទៅសម្លាប់នៅឡើយទេ។ ខ្មែរក្រហម គ្រាន់តែឲ្យបងប្អូនខ្មែរ-អ៊ីស្លាមទៅរស់នៅក្នុងព្រៃកៃតា និងព្រៃទំនប់លោកតា ដើម្បីកាប់ចម្ការ ដាំស្រូវ ដំណាំផ្សេងៗ និងធ្វើស្រែវស្សា។ ស្ត្រីៗ ខ្មែរក្រហម ទុកឲ្យដេរសម្លៀកបំពាក់ មើលក្មេង ត្បាញកន្ទេល ដេរស្លឹក និងក្រងស្បូវ។ ប្រជាជនដំទង់ៗ ត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងចល័ត ដោយឲ្យលើកទំនប់ ជីកប្រឡាយ ស្ទូងស្រូវ នេសាទត្រី និងឡើងត្នោតជាដើម។ ចំណែករបបអាហារ ខ្មែរក្រហមឲ្យយើងហូបបាយពេលថ្ងៃត្រង់ និងហូបបបរសម្រាប់អាហារពេលល្ងាច។

នៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្មែរក្រហមកាន់តែរឹតបន្តឹងខ្លាំងទៅៗ។ ខ្មែរក្រហម បានបំបែកប្តីប្រពន្ធ និងកូនឲ្យចេញពីគ្នា។ ការងារកែដី បើយើងកែអស់មួយម៉ែត្រគូប ត្រូវថែមមួយម៉ែត្រគូបទៀត ទៅតាមបញ្ជារបស់អង្គការ។ ប្រជាជនណាហ៊ានតវ៉ា ប្រជាជននោះគឺជាខ្មាំងក្បត់អង្គការ និងត្រូវយកទៅសម្លាប់ចោល។ ឯការរស់នៅរបស់ខ្ញុំក៏ដូចជាក្រុមគ្រួសារផ្សេងៗទៀតដែរ។ ខ្មែរក្រហមបានរៀបចំឲ្យរស់នៅដាច់ដោយឡែកចេញពីគ្នារវាងអ្នកថ្មី និងអ្នកមូលដ្ឋាន។ ផ្ទះសម្បែង ត្រូវសាងសង់ដោយខ្លួនឯង។ ខ្មែរក្រហម មិនអនុញ្ញាតឲ្យប្រជាជនប្រកបមុខរបរចិញ្ចឹមជីវិតដោយឯកជនឡើយ។ ប្រជាជនមួយចំនួនរស់នៅដោយសារតែដាំដំឡូងជ្វានិងដំឡូងមី។ ប្រជាជនគ្មានម្ហូបអាហារហូបឡើយ។ ចំណែកឯកុមារ ខ្វះខាតនៅក្នុងការហូបចុក។ កុមារ និងទារក មិនអាចទទួលបានជីវជាតិគ្រប់គ្រាន់នោះទេ ព្រោះម្តាយរបស់ពួកគេគ្មានអ្វីហូបគ្រប់គ្រាន់។ មិនតែប៉ុណ្ណោះ មនុស្សចាស់ជរា មិនអាចស៊ូទ្រាំនឹងការរស់នៅបែបនេះ មានអ្នកខ្លះអត់ឃ្លានស្លាប់ក៏មានដែរ។

ប្រជាជន ១៧ មេសា ក្នុងឆ្នាំ១៩៧៧

អង្គការបានឲ្យខ្ញុំ និងប្រជាជនថ្មីផ្សេងទៀត ទៅរស់នៅតាមផ្ទះរបស់ប្រជាជនមូលដ្ឋាន។ ប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ទទួលបានរបបអាហារផ្សេងពីគ្នា។ ប្រជាជនមូលដ្ឋាន ទទួលបានបាយទាំងព្រឹកល្ងាច ចំណែកឯប្រជាជនថ្មី ខ្មែរក្រហមផ្តល់ឲ្យតែបបរនោះទេ ហើយថែមទាំងពុំសូវមានម្ហូបអាហារគ្រប់គ្រាន់។ ជួនពេលខ្លះ ប្រជាជនមូលដ្ឋានមួយចំនួនមានទឹកចិត្តល្អ បានឲ្យម្ហូបអង្ករ ដំឡូង និងបន្លែដល់ប្រជាជនថ្មីដែរ។

ក្រោយមក ខ្មែរក្រហមកែប្រែទម្រង់នៃការហូបចុក។ ក្នុងមួយភូមិ ខ្មែរក្រហមបានដាក់ឲ្យមានរោងបាយ៤កន្លែង។ ទោះបីជាប្រជាជនដាំដំណាំ និងចិញ្ចឹមសត្វដោយខ្លួនឯង ប៉ុន្តែប្រជាជនគ្មានសិទ្ធិយកមកធ្វើម្ហូបបានឡើយ។ ពេលស្ល គឺអ្នកនៅរោងបាយ ជាអ្នកដើរប្រមូលចាប់ និងបេះយកទៅដាក់រោងបាយរួម។

ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅនៅកងចល័ត ទៅលើកទំនប់ឈ្មោះ«កែតា»។ យុវជន យុវនារីជាច្រើននាក់ បានចូលរួមលើកទំនប់ «កែតា»។ ខ្ញុំនៅចាំឈ្មោះសមមិត្ត ដែលធ្លាប់ធ្វើការងារផ្ទាល់ជាមួយខ្ញុំមួយចំនួនដូចជាសមមិត្តស៊ុយ សមមិត្តហោ សមមិត្តពេន សមមិត្តនារីសឿន និងសមមិត្តនារីវ៉ែម។ ការធ្វើការងារនៅក្នុងកងចល័ត បានជួបប្រទះនឹងការលំបាកជាច្រើន។

ថ្ងៃមួយ សមមិត្តពក ដែលជាប្រធានតំបន់ បានមកទស្សនកិច្ចត្រួតពិនិត្យមើលទៅលើគុណភាពសមិទ្ធផលទំនប់ «កែតា» និងសកម្មភាពការងាររបស់កងចល័តនីមួយៗ ដើម្បីបូកសរុបកាងារ។ នៅក្នុងក្រុមរបស់មិត្តនារីតឿន ខ្ញុំរែកដីពេលថ្ងៃមិនគ្រប់គ្រាន់ ត្រូវបន្តរែកដីដល់ពេលយប់រហូតដល់ម៉ោងប្រាំបួនយប់។ ពេលនោះ កម្លាំងរបស់ខ្ញុំយ៉ាប់ឃឺន ស្ទើរតែទ្រាំលែងបានទៅហើយ។ ខ្ញុំមិនដែលឃើញប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីឈ្លោះប្រកែកគ្នានោះទេ ព្រោះប្រជាជនម្នាក់ៗរកតែពេលដេក និងពេលហូបសឹងតែមិនបាន។

ថ្ងៃមួយសមមិត្តស៊ុយ បានដឹងថា មេកងបានចាត់តាំងខ្លួន និងសមមិត្តពេនឲ្យទៅកងចល័តមួយទៀតដែលស្ថិតនៅក្នុងភូមិបន្ទាយយមរាជ និងភូមិត្រញ៉ាក។ សមមិត្តស៊ុយ បាននិយាយលាទៅកាន់សមមិត្តនៅក្នុងកងចល័តរបស់ខ្លួនថា «អ្នកទាំងអស់គ្នា ខ្ញុំលាសិនហើយ។ យើងមិនដឹងថាតើថ្ងៃណាបានជួបគ្នាវិញទេ»។ មិត្តនារីសឿន បានតបទៅវិញថា «មិនដឹង យ៉ាងណាទេ! សមមិត្តស៊ុយអើយ! ខ្ញុំមិនចង់ឲ្យសមមិត្តស៊ុយ ឯងបែកពីខ្ញុំទេ ព្រោះខ្ញុំមានចិត្តស្រលាញ់យ៉ាងខ្លាំងអំពីអាកប្បកិរិយាស្លូតបូត សុភាពរាបសា សំដីសំដៅទន់ភ្លន់ណាស់។ ខ្ញុំស្ទើរទប់ទឹកភ្នែកពុំបាន ដោយសមមិត្តស៊ុយ ឯងធ្លាប់ជួយខ្ញុំច្រើនណាស់ ជួយតាំងពីដងទឹកអណ្តូងឲ្យខ្ញុំងូត ជួយកាច់ឧស បង្កាត់ភ្លើង ជួយលើកដាក់ខ្ញុំពេលដែលខ្ញុំមានជំងឺមិនអាចដើរបាន ដាំបបរឲ្យខ្ញុំហូប បង្កាត់ភ្លើងឲ្យខ្ញុំអាំងពេលរដូវរងា ថែមទាំងផ្ញើនំអន្សមឲ្យខ្ញុំហូបទៀត»។ សមមិត្តស៊ុយ ក៏ឆ្លើយតបទាំងអួលដើមកថា «មិត្តនារីសឿនឯង ធ្លាប់សួរសុខទុក្ខខ្ញុំអំពីបញ្ហាសុខភាព ធ្លាប់ជួយរកចៃពីក្បាលរបស់ខ្ញុំ ហើយយើងធ្លាប់បញ្ចុកចេកគ្នាលេង ហូ! ច្រើនណាស់រាប់មិនអស់ទេ»។ ពេលនោះ

សមមិត្តពេន ក៏បានហៅ សមមិត្តស៊ុយ ថា «មកមិត្តស៊ុយ ដល់ពេលវេលាដែលត្រូវចេញដំណើរទៅហើយ។ សមមិត្ត មិត្តនារីខ្ញុំលាសិនហើយ មិនដឹងថ្ងៃណាបានជួបគ្នាទៀតទេ»។ មិត្តនារីសឿន នៅតែអ៊ូតិចៗថា «ស្រណោះមិត្តស៊ុយណាស់ មិនដឹងទៅនោះលំបាក ឬស្រួលទេ។ បើការរស់នៅស្រួលខ្ញុំសប្បាយចិត្ត។ ខ្ញុំមិនបាននៅជិតច្បាស់ជាគ្មានភាពកក់ក្តៅទេ មើលទៅ!»។

ខ្ញុំធ្វើដំណើរអស់រយៈពេលប្រហែលជិតពីរម៉ោងពីទំនប់ «កែតា»មកបន្ទាយយមរាជ។ ស្រាប់តែមកដល់ ខ្ញុំឃើញមនុស្សជាច្រើនសុទ្ធតែជាក្រុមកងចល័តស្នងស្រូវ និងដឹកសំណាប។ ខ្ញុំចូលទៅដល់ភ្លាម មេកងបានចាត់ឲ្យប្រជាជនថ្មីធ្វើជាសមាជិកក្រុម រីឯប្រជាជនមូលដ្ឋានដូច សមមិត្តពេន ធ្វើជាប្រធានក្រុម។ អង្គការហៅ សមមិត្តពេន ទៅបំពាក់បំប៉នអំពីរបៀបគ្រប់គ្រង និងប្រើប្រាស់អំណាចផ្តាច់ការទៅលើកូនក្រុមរបស់ខ្លួន។ មិនយូរប៉ុន្មាន សមមិត្តពេន ត្រូវអង្គការបញ្ជូនមកហ្វឹកហ្វឺននៅតំបន់កប់សេះ ស្ថិតនៅឃុំប្រាសាទ ស្រុកសន្ទុក។ ក្រោយមកអង្គការបានបញ្ជូនខ្ញុំឲ្យមកតំបន់កប់សេះនេះដែរ ដើម្បីហ្វឹកហ្វឺនរបៀបគ្រប់គ្រងនិងវិធីសាស្ត្រនៃរបៀបស៊ើបការណ៍សម្ងាត់។

ឆ្នាំ១៩៧៨

នៅក្នុងឆ្នាំនោះ អង្គការកាន់តែរឹតបន្តឹងដោយគ្មានទុកឲ្យនរណាម្នាក់នៅទំនេរឡើយ។ ប្រជាជនគ្រប់គ្នាត្រូវធ្វើការងារតាំងពីកុមារ រហូតដល់មនុស្សចាស់។ កងកុមារ ត្រូវមេកងឲ្យដើររើសអាចម៍គោ ចំណែកឯចាស់ៗ ត្រូវមេកងឲ្យនៅតាមផ្ទះធ្វើជី និងមើលកុមារតូចៗ។ ចំណែកឯ ប្រជាជនដែលពេញកម្លាំង មេកងឲ្យទៅធ្វើការនៅក្នុងកងចល័ត។

អង្គការបានគម្រាមថា «សមមិត្ត ឬមិត្តនារីណា ដែលហ៊ានប្រឆាំងនឹងអង្គការនោះអង្គការនឹងយកទៅរៀនសូត្រ»។ ពេលនោះខ្ញុំរៀនហ្វឹកហ្វឺនចប់ ហើយត្រូវអង្គការឲ្យការងារជាច្រើនឲ្យខ្ញុំធ្វើ។ ការងាររបស់ខ្ញុំទីមួយ គឺដើរស៊ើបការណ៍នៅពេលយប់ ចំពោះប្រជាជនណាដែលរៀបការហើយមិនចុះសម្រុងនឹងគ្នា។ បើខ្ញុំដឹងថាប្តីប្រពន្ធនោះមិនចុះសម្រុងនឹងគ្នាទេ ខ្ញុំត្រូវរាយការណ៍ទៅឲ្យអង្គការ

ភ្លាម។ ចំណែកឯការងារទីពីររបស់ខ្ញុំ គឺទទួលមើលការខុសត្រូវដល់ប្រជាជនជម្លៀសមកពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ខាងកងចល័ត។ អង្គការបានឲ្យខ្ញុំធ្វើជាគ្រូបង្រៀនដែរ។

ភាពភ័យខ្លាចបំផុតនោះ គឺក្រុមខ្មែរក្រហម បានយកមនុស្សយកទៅរៀនសូត្រ ជាពិសេស ជនជាតិចាម និងប្រជាជន ដែលលួចស្រលាញ់គ្នាត្រូវអង្គការចោទថាខុសសីលធម៌ ហើយត្រូវយកទៅសម្លាប់ចោលនៅពេលយប់។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

រដូវប្រូតកាត់បានចូលមកដល់ ហើយប្រជាជនមមាញឹកក្នុងការប្រមូលផលណាស់។ គ្រប់កងចល័តកំពុងតែធ្វើសកម្មភាពយ៉ាងសកម្មរួមទាំងខ្ញុំផងដែលកំពុងតែជួយដឹកកណ្តាប់។ ថ្ងៃមួយម៉ោងប្រហែលជា១០ព្រឹក ខ្ញុំឮសន្ធឹករថក្រោះ ដែលជាកម្លាំងកងទ័ពវៀតណាម និងកងទ័ព ហេង សំរិន បានមកដល់ និងធ្វើការវាយរំដោះប្រទេស បានធ្វើឲ្យខ្មែរក្រហម រត់ចែកជើងគ្នាចូលក្នុងព្រៃតាមជាយដែន។ ប្រជាជនខ្មែរទាំងអស់ប្រញាប់ប្រញាល់រត់រកបងប្អូន ដើម្បីត្រលប់មករកស្រុកកំណើតរៀងៗខ្លួនវិញ។ ខ្ញុំនិងមិត្តនារីសឿន បានជួបគ្នាវិញ ហើយលាគ្នាទៅកាន់ស្រុកកំណើត។

ចប់

៣១

រឿងជីវិតក្រោមពពកខ្មៅ

អ្នកនិពន្ធ ៖ អេង ម៉ី

៣១ ~ រឿង ជីវិតក្រោមពពកខ្មៅ

រឿងរ៉ាវរបស់ អានី នៅក្នុងរបបខ្មែរក្រហម ការងារនៅក្នុងកងកុមារ

ព្រលឹមស្រាងៗ ក្មេងៗអាយុប្រហែល១០ឆ្នាំ ដែលក្នុងនោះ ក្មេងស្រីម្នាក់ឈ្មោះ អានី មានអាយុច្រើនជាងគេបន្តិច គឺជាអ្នកដឹកនាំក្មេងៗផ្សេងទៀតទៅរើសអាចម៍គោ ស្រោចដំណាំ បន្ទាប់មកនាំគ្នាទៅជាន់អង្ករ លុះថ្ងៃត្រង់ ទើបនាំគ្នាមកហូបបាយនៅឯរោងបាយជុំគ្នាវិញ។ បន្ទាប់ពីហូបបាយរួច អានី នាំក្មេងៗទៅជាន់អង្ករទៀត ឲ្យបានទៅតាមចំនួនអង្ករ ដែលអង្គការបានកំណត់ទុក។ លុះល្ងាចបន្តិច អានី ត្រូវចែកក្មេងៗខ្លះឲ្យទៅស្រោចដំណាំ ហើយខ្លះទៀតទៅទទួលក្របី។

ការងារនៅក្នុងកងកុមារក៏ជាក់កំហិតមិនខុសពីការងារនៅក្នុងកងចល័តប៉ុន្មានដែរ។ ប្រសិនបើជាន់ស្រូវឲ្យអង្គការមិនបានគ្រប់ចំនួន ដែលបានកំណត់ទុកនោះទេ អង្គការនឹងចោទ ហើយនិយាយថា «មិត្តឯងមិនគោរពវិន័យ និងបទបញ្ញត្តិរបស់អង្គការ មិត្តឯងខ្ជិលមិនសហការគ្នា មិត្តឯងនៅរើសអើង មិនចង់ធ្វើការជាមួយគ្នា មិត្តឯងចង់នៅប្រើរបបសក្តិភូមិនៅទីនេះគឺមិនបានទេ ពេលខ្លះគេចោទយើងថា យើងធ្វើពុតជាឈឺដើម្បីគេចពីការងារ»។

ប្រជាជនខ្លះ ត្រូវបានអង្គការយកទៅកសាង ព្រោះតែប្រកែកតវ៉ានឹងអង្គការ។ អានី តែងតែភ័យខ្លាច និងលួចយំជារៀងរាល់ថ្ងៃ ព្រោះអានី ជាក្មេងស្រីម្នាក់ដែលអង្គការតែងតែចាំឃ្លាំមើល។ អង្គការបានចោទ បងប្អូននិងក្រុមគ្រួសាររបស់ អានី

ថាជាពួកនាយទុន ព្រោះអង្គការ បានសង្កេតឃើញ អានី សម្បុរសាច់ញាតិថ្មីៗ ដែលជម្លៀសពីកន្លែងផ្សេងមកសុំរស់នៅជាមួយ។ អង្គការ តែងហៅ អានី ទៅស្តីឲ្យនៅពេលដែលរងបន្លែឬដំណាំត្រូវមាន់កាយ។ អានី តែងទៅលួចពួនយំម្នាក់ឯង បន្ទាប់ពីអង្គការស្តីឲ្យ។ អានី មានខោអាវតែមួយសម្រាប់ជាប់នឹងខ្លួនប៉ុណ្ណោះ។ ខោរបស់នាងរហែករយ៉ៃ ហើយពេលដែលនាងទៅសុំខោអាវពីអង្គការបន្ថែមមួយកំប្លេទៀត អង្គការមិនឲ្យទេ។ អានី បានសម្រេចចិត្តទៅលួចយកខោអាវសេសសល់ពីឪពុក និងពូ ដែលអង្គការ បានយកទៅកសាង(សម្លាប់ចោល)យកមកត្រាំក្នុងកក់ចំនួន១ថ្ងៃ១យប់សិន ទើបយកមកស្លៀក។

ធ្វើការចារនៅក្នុងកងចល័ត

នៅពេលដែល អានី មានវ័យធំល្មម អង្គការបានចាត់បញ្ជូល អានី ទៅក្នុងក្រុមកងចល័ត។ ថ្ងៃដំបូង អានី មានអារម្មណ៍ថា មានគេស្រលាញ់រាប់អាននាងច្រើនណាស់។ នាង មានអារម្មណ៍ល្អក្នុងការមកនៅកន្លែងថ្មីនេះ។ ថ្ងៃមួយ ពេលបាយថ្ងៃត្រង់ គេហៅ អានី មកហូបបាយ ហើយពេល អានី មកដល់បើកគម្របឆ្នាំងដើម្បីដួសសម្ល នាងឃើញសុទ្ធតែអន្ទង់។ អានី ខ្លាចខ្លាំងណាស់ ហើយមិនហ៊ានហូបបាយទេ។ នាងបានរត់ឡើងលើផ្ទះ ហើយមានស្ត្រីវាងចំណាស់ម្នាក់បានស្រែកសួរ អានី ថា «ហេតុអីមិនចុះមកហូបបាយ?»។ អានីឆ្លើយតបវិញថា «ខ្ញុំមិនហូបទេ ខ្ញុំខ្លាចអន្ទង់ ខ្ញុំមិនហូបអន្ទង់ទេ»។ ស្ត្រីចំណាស់នោះឮហើយអាណិត អានី។ គាត់ បានដួសបាយមួយចាន ហើយដាក់ឆែប៉ូវមួយដុំឲ្យ អានី ហូប។

ថ្ងៃបន្ទាប់ អានី បានទៅស្រែ ដើម្បីជួយស្នងជាមួយប្រជាជនផ្សេងទៀត។ ថ្ងៃនោះ អានី មានអារម្មណ៍ភ័យខ្លាចខ្លាំងណាស ព្រោះនាងបានឃើញស្តែងនឹងភ្នែកពេលអង្គការចាប់អូសមិត្តដែលកំពុងស្នងជាមួយគ្នាចេញពីក្នុងស្រែដោយមិនដឹងជាយកទៅទីណាទេ។ អានី ខំតាំងចិត្ត និងសម្រួលអារម្មណ៍ ធ្វើមិនដឹងមិនឮអ្វីទាំងអស់ ហើយបន្តការស្នងរបស់នាងតាមធម្មតា។ រហូតដល់ពេលហូបបាយថ្ងៃត្រង់ អានី នៅតែមិនអាចបំភ្លេចរូបភាពទាំងអស់នោះបាន។ ទឹកភ្នែករបស់នាងបានហូរស្រក់ចុះពេលកំពុងហូបបាយថ្ងៃត្រង់។ នាងហូបបណ្តើរ ហើយស្រមៃពីខ្សែជីវិតរបស់នាងនៅថ្ងៃស្អែកបណ្តើរ។

ពេលរាត្រីបានមកដល់អានី ដេកមិនលក់ទេ។ នាងនៅតែស្រមៃឃើញរូបភាពកាលពីថ្ងៃម្តងហើយម្តងទៀត។ អានី ចាប់ផ្តើមយំខ្សឹកខ្សួលស្រណោះខ្លួនមិនដឹងថាថ្ងៃស្អែកនឹងមានអ្វីកើតឡើងទៀតនោះទេ។ នាងប្រឹងបិទភ្នែក ហើយបន់ស្រន់ដល់ទេវតា សូមឲ្យជួយថែរក្សាការពារជីវិតរបស់នាងសម្រាប់ថ្ងៃស្អែកនេះ។

លុះស្អែកឡើង សកម្មភាពចាប់ប្រជាជននៅតែកើតឡើងដដែលពីមួយថ្ងៃទៅមួយថ្ងៃជាបន្តបន្ទាប់។ វាពិតជាសាហាវព្រៃផ្សៃខ្លាំងណាស់ ហើយអំពើឃោរឃៅទាំងនោះធ្វើឲ្យអានី មានអារម្មណ៍តក់ស្លុត និងដក់នៅក្នុងចិត្តយ៉ាងខ្លាំង។ រាល់យប់អានី តែងតែបន់ស្រន់នៅក្នុងចិត្ត សូមឲ្យទេវតាជួយថែរក្សាការពារប្រទេសមួយនេះឲ្យបានរួចផុតពីរបបសាហាវយង់ឃ្នងនេះផង។ អានី ចេះតែស្រមើស្រមៃថាបើនៅតែយ៉ាងនេះទៀតមិនយូរទេប្រាកដជាដល់វេននាងហើយ។

ជារៀងរាល់ថ្ងៃប្រជាជនទាំងអស់នាំគ្នាខំប្រឹងធ្វើការងារយ៉ាងសស្រាក់សស្រាំ ធ្វើយ៉ាងណាឲ្យទទួលបានភោគផលដូចដែលអង្គការបានកំណត់។ ប្រជាជនម្នាក់ៗ ហូបចុកមិនគ្រប់គ្រាន់ ដេកមិនស្តប់ស្តល់ ហើយរាងកាយវិញស្តមស្តាំងក្បាលជង្គង់ធំជាងក្បាលមនុស្សទៅទៀត។

រឿងរ៉ាវរបស់ក្រុមគ្រួសារ យាយ ណែម នៅក្នុងរបបខ្មែរក្រហម

ក្រុមគ្រួសាររបស់យាយណែម ត្រូវបានខ្មែរក្រហមសម្លាប់ចោលស្ទើរតែទាំងអស់។ ព្រឹត្តិការណ៍ទាំងអស់នេះធ្វើឲ្យគាត់នៅចងចាំនិងដក់ជាប់ក្នុងឆាកជីវិតគាត់ជានិច្ច។ យាយណែម បានក្លាយទៅជាស្ត្រីមេម៉ាយនៅអាយុជាង២០ឆ្នាំ ហើយត្រូវរ៉ាប់រងចិញ្ចឹមកូនចំនួន៤នាក់។ ឪពុករបស់ យាយណែម គឺជាដង្កៀបក្របី និងអ្នកលក់ឈើ។ ឯប្តីរបស់យាយណែម គឺជាគ្រូពេទ្យ។ ចំណែកបងប្អូនពូមីងរបស់យាយណែម គឺ សុទ្ធតែជាខ្សែទាហាន។ ដូច្នេះហើយទើបក្រុមគ្រួសាររបស់គាត់ ត្រូវបានខ្មែរក្រហម ធ្វើបាបនិងចោទថាជាពួកសក្តិភូមិ មិនចង់ធ្វើការងារ ចង់ស៊ីកម្លាំងពលកម្មអ្នកដទៃ ដែលទាំងនេះជាមូលហេតុធ្វើឲ្យខ្មែរក្រហមយកក្រុមគ្រួសាររបស់គាត់ទៅកសាងម្នាក់ម្តងៗជាបន្តបន្ទាប់។

នៅក្នុងរបបខ្មែរក្រហម ប្តីរបស់យាយណែម ត្រូវបានអង្គការបញ្ជូនឲ្យទៅជីកប្រឡាយនៅស្រុកឆ្ងាយពីផ្ទះ។ គាត់មានឱកាសលួចមកលេងប្រពន្ធកូន តែពេលណាដែលមានប្រជាជនឈឺក្នុងក្រុមកងចល័តរបស់គាត់ ហើយត្រូវសែងមកព្យាបាលតែប៉ុណ្ណោះ។ នឹកឃើញថ្ងៃមួយ ប្តីរបស់យាយណែម ត្រូវ ឈ្លបមកប្រាប់ថា យប់ស្អែកអង្គការនឹងនាំយកទៅរៀនសូត្រ។ ពេលនោះក្រុមគ្រួសារជាពិសេសយាយណែម ភ័យខ្លាចខ្លាំងណាស់។ បងប្អូនរបស់យាយណែម បានប្រាប់ប្តីរបស់យាយណែមថា កុំឲ្យទៅតាមកងឈ្លប។ ពួកគេថែមទាំងប្រាប់ឲ្យប្តីរបស់យាយណែមរត់ទៀត ព្រោះពួកគេដឹងមុនថា បើហ៊ានតែទៅតាមកងឈ្លបគេនឹងសម្លាប់ចោលហើយ។ ប្តីរបស់យាយណែម មិនជឿទេ ហើយថែមទាំងឆ្លើយតបត្រលប់ទៅយាយណែម និងសាច់ញាតិថា គាត់មិនជឿទេដែលខ្មែរសម្លាប់ខ្មែរគ្នាឯងនោះ។ ចាប់តាំងពីថ្ងៃនោះមក មិនដែលឃើញវត្តមានប្តីយាយណែម ត្រលប់មករកប្រពន្ធកូនវិញទេ។ យាយណែម តែងតែរង់ចាំប្តីពីមួយថ្ងៃទៅមួយថ្ងៃ តែមិនឃើញវិលត្រលប់មកវិញសោះ។ ថ្ងៃមួយមានអ្នកស្គាល់គ្នាមកប្រាប់យាយណែម ថា ប្តីរបស់គាត់ត្រូវបានកងឈ្លបយកទៅសម្លាប់នៅក្នុងវត្តមួយ។ គ្រាន់តែឮភ្លាម យាយណែម ស្ទើរតែគាំងបេះដូង ដូចត្រូវគេយកកាំបិតមកពុះជ្រៀកយកថ្លើមប្រម៉ាត់។ គាត់ស្ទើរតែភ្លាយទៅជាមនុស្សវិកលចរិកភ្លាមៗពេលបានទទួលដំណឹងនោះ។ ទោះជាយ៉ាងណា យាយណែម បានខំប្រឹងធ្វើចិត្ត និងតាំងស្មារតី ដោយសង្ឃឹមថារស់នៅដើម្បីចិញ្ចឹមកូនទាំងបួនរបស់គាត់។

រាល់ព្រឹក យាយណែម ត្រូវទៅដកស្ទូងនៅឆ្ងាយពីកូនតូចៗរបស់គាត់។ កូនបងរបស់គាត់ នៅមើលថែប្អូនតូចៗនៅឯផ្ទះ។ ឯប្អូនប្រុសរបស់យាយណែមវិញ ត្រូវអង្គការធ្វើបាបខ្លាំងណាស់។ អង្គការ ឃ្លាំមើលប្អូនប្រុសរបស់គាត់ជានិច្ច។ បើប្អូនរបស់គាត់ហ៊ានឈប់សម្រាកពីការងារតែបន្តិច អង្គការនឹងចោទថាគាត់ខ្ជិល ហើយពេលហូបបាយ គាត់តែងតែទទួលបានរបបតិចជាងគេ។ អង្គការចាំមើលតែប្អូនរបស់យាយណែម ម្នាក់គត់ ព្រោះគាត់មានប្រវត្តិជានិស្សិត ហើយឪពុករបស់គាត់ជានាយទាហានសក្តិប្រាំ។ ដូចនេះ ប្អូនរបស់ យាយណែម មានឈ្មោះក្នុងបញ្ជីរបស់អង្គការរួចទៅហើយ។

ថ្ងៃមួយមិនដឹងជាប្អូនរបស់យាយណែម ធ្វើអ្វីខុសទេ ស្រាប់តែកងឈ្លបចាប់គាត់ចងដៃចងជើងរួចបោះទម្លាក់ទៅក្នុងទឹក។ មួយសន្ទុះធំទើបកងឈ្លបលើកគាត់ឡើងមកវិញ រួចក៏ទម្លាក់គាត់ម្តងទៀតរហូតទាល់តែគាត់សន្លប់ទើបលើកគាត់ឡើង។ លុះយប់ឡើង កងឈ្លបយកគាត់ទៅសម្លាប់តែម្តង។ ក្រុមគ្រួសារនិងសាច់ញាតិរបស់យាយណែម ត្រូវបានអង្គការយកទៅសម្លាប់ជាបន្តបន្ទាប់។

កូនៗយាយណែម ត្រូវអង្គការយកទៅរៀនសូត្រជាមួយនឹងកុមារដទៃទៀត។ ព្រឹកឡើង កូនយាយណែម បានឡើងលើរទេះរួចជាស្រេចត្រៀមនឹងចេញដំណើរទៅតាមកងឈ្លបនោះ ប៉ុន្តែសំណាងល្អស្រាប់តែសំឡេងគ្រាប់បានបែកផ្ទុះឮសូរផ្ងេងផាំងក្តុងក្តាំង។ ពួកក្មេងៗ ភ័យខ្លាច នាំគ្នាចុះពីរទេះរត់ពួន។ កូនបងរបស់យាយណែម បានរត់ទៅរកប្អូនៗហើយនាំគ្នាមកពួននៅក្នុងត្រង់សេ។ ចំណែកឯ កូនពៅរបស់យាយណែម នៅតូចណាស់ វាភ័យស្រែកយំស្ទើរគាំង។

ការប្រយុទ្ធគ្នានៅតែបន្ត គ្រាប់បែកនៅតែបន្តផ្ទុះ។ មិនយូរប៉ុន្មានកងទ័ពវៀតណាម និងកងទ័ពរណសិរ្ស បានទទួលជ័យជម្នះពីពួកខ្មែរក្រហម។ យាយណែម បានដើររកកូនគ្រប់ទិសទី។ គាត់ស្រែកហៅកូនបណ្តើរយំបណ្តើរ។ គាត់ប្រឹងស្រែកដង្ហោយហៅឈ្មោះប្តីរបស់គាត់ ដើម្បីសូមឲ្យជួយថែរក្សាសុខសុវត្ថិភាពដល់កូនទាំង៤។ នៅទីបំផុត យាយណែម បានជួបកូនទាំង៤នាក់។ គាត់យំឱបកូនដោយក្តីរំភើបក្រៃលែង។

ស្រមោលអន្ទាការដ៏កំសត់ជូរចត់ វេទនា និងទុក្ខព្រួយទាំងអស់ បានរសាត់អណ្តែតបាត់ ហើយបន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា និងជនពិការជាច្រើនបន្តស្វះស្វែងរស់នៅរហូតដល់បច្ចុប្បន្ននេះ។

ចប់

៣២

រឿងក្រមួចផ្កាអពមង្គល

អ្នកនិពន្ធ ៖ ថូ សំណាង

៣២ ~ រឿង ករម្រចង្អាអពមង្គល

ព្រះទិនករហាក់បណ្តែតខ្លួនមកបំភ្លឺពិភពលោកយ៉ាងយឺតយ៉ាវ និងស្ងប់ស្ងាត់បំផុត។ មេឃចាប់ផ្តើមភ្លឺបន្តិចម្តងៗ មនុស្សជាច្រើនកំពុងងើបឡើងជ្រួលច្រាល់ មានរូបរាងស្គមស្គាំង ស្លេកស្លាំង ក្នុងដៃរបស់ពួកគេមានកាន់ចបនិងបង្គី ស្លៀកពាក់ខោអាវខ្មៅដូចៗគ្នា។

ខ្ញុំក្រឡេកមើលបុរសចំណាស់ម្នាក់ កែវភ្នែករបស់គាត់មានសភាពច្របូកច្របល់។ គាត់ដើរច្រិមច្រុមៗ។ ខ្ញុំភ្ញាក់ព្រើត មានបុរសម្នាក់ បានស្រែកសម្តែតបុរសចំណាស់នោះថា «សមមិត្តកន នៅច្រិមច្រុមៗរកផ្លូវទៅនរកឬ?»។ ខ្ញុំឃើញសមមិត្តកន ក័យញ៉ូវដៃញ៉ូវជើង។ ខ្ញុំសែនខ្លោចចិត្តនឹងពាក្យគំរាមទៅកាន់ សមមិត្តកន ដែលមានវ័យចំណាស់នោះ។

ចាត់ដំបូងឆ្នាំ១៩៧៦

ក្រឡេកមើលទេសភាពដ៏ស្ងាត់ជ្រងំនៃវាលស្រែរដូវលម្ហើយ វាលស្រែទើបតែប្រមូលផលស្រូវរួចដែលមានសភាពសោះកក្រោះ។ តាមផ្លូវនៅតាមវាលស្រែគ្មានមនុស្សដើរ ស្ងាត់សូន្យឈឹង ហើយតាមផ្លូវក្នុងភូមិវិញ មានផ្ទះជាច្រើនដែលគ្មានមនុស្សរស់នៅ ស្មៅដុះស៊ុបទ្រុបគ្មានអ្នកថែទាំ សាលារៀនគ្មានគ្រូ គ្មានសិស្ស មន្ទីរពេទ្យគ្មានអ្នកជំងឺ វត្តអារាមគ្មានសំឡេងសូត្រធម៌ ឮតែសំឡេងក្មេងច្រៀងថា «យើងខ្ញុំកុមារ ស្រលាញ់អង្គការឥតមានព្រំដែន...»។ នៅខាងចុងភូមិរបស់យើងមានក្រោលគោមួយ និងមានខ្នុះគ្នោតចំនួន៤ ហើយមានស្ត្រីចំនួន ២នាក់កំពុងរុញឧស។ បើយើងទៅឲ្យជិត យើងនឹងធុំក្លិនឈ្ងុយពីខ្នុះ គ្នោតទាំង៤ ដែលជាក្លិន

បបរពុះ មានសភាពរាវស្ទើរតែគ្មានគ្រាប់អង្ករ។ ខ្ញុំកំពុងតែស្រង់ក្លិនទឹកបបរពុះស្រាប់តែសំឡេង«ម៉ឹង!ម៉ឹង!ម៉ឹង!» ស្នូរជ្រួងបានបន្លឺឡើងបីដងបន្ទាប់មកឮសូរទេះដែចេញពីក្នុងក្រោលគោ ដែលបុរសម្នាក់បាននិយាយឡើងថា «សមមិត្តទាំងអស់គ្នាមកចូលរួមប្រជុំក្នុងថ្ងៃនេះ មានដឹងថាអង្គភាពមានដំណឹងអ្វីប្រាប់ទេ?»។

សម្តីបុរសម្នាក់ ក្នុងសម្លៀកបំពាក់ខ្មៅ ពាក់ស្បែកជើងកង់ឡាន ព្រមទាំងមួរជើងខោម្ខាង ហើយនៅលើកមានបង់ក្រមា ពោរពេញទៅដោយទឹកមុខញញឹមឡកឡាយ និងកែវភ្នែកក្រហមមុត បាននិយាយថា «តាំងពីថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ មក យើងសម្រេចតាមផែនការបានល្មមគួរសមហើយអង្គការជាស្ថាប័នឯករាជ្យមហាអស្ចារ្យ មហាលោតផ្លោះ ព្យាយាមលុបបំបាត់របបសក្តិភូមិមូលធននិយម គ្មានការសង្កត់សង្កិនលើគ្នា គោលបំណងរបស់អង្គការ គឺរស់នៅដោយខ្លួនឯង ដូច្នេះទើបយើងខំបង្កើនផលស្រូវក្នុងដី១ហិកតា ឲ្យបានបីតោនដោយកម្លាំងយើងផ្ទាល់»។ ស្នូរទេះដែប្រាវៗ លាន់ឮឡើងហើយក៏បញ្ចប់ទៅវិញ។ នារីម្នាក់ភ្នែកមុតស្រួច សក់ខ្លីត្រឹមក សម្លឹងមករួចស្រែកសម្តែងយ៉ាងឮៗព្រមទាំងលើកដៃទាំងពីរឡើងលើ ថា «សមមិត្តប្រធានសហករណ៍ឈុំ និយាយត្រឹមត្រូវណាស់ សមមិត្តទាំងអស់ត្រូវប្រឹងប្រែងដើម្បីអង្គការមហារុងរឿងរបស់ពួកយើង»។

មេសហករណ៍ និងមេកងឈ្លប បានឲ្យប្រជាជនមូលដ្ឋាន និងប្រជាជន ១៧មេសា ឈរជាពីរជួរ ហើយជួរនីមួយៗ បែរមុខរកគ្នា ដែលមានចំនួនប្រហែលជា៧០នាក់។ ក្នុងមួយជួរៗ មានតាំងពីវ័យជំទង់ដល់វ័យចំណាស់។ កម្មាភិបាលម្នាក់ប្រកាសឈ្មោះម្តងពីរនាក់ មានប្រុសម្នាក់ និងស្រីម្នាក់។ អ្នកដែលឮឈ្មោះត្រូវឡើងទៅខាងមុខដើម្បីបង្ហាញពីការព្រមព្រៀង។

កម្មាភិបាលប្រកាសឡើងថា «សមមិត្តសុវណ្ណ និងសមមិត្តនារីកល្យាណ»។ ពេលនោះ សមមិត្តកល្យាណ ដែលកំពុងតែភ្លឹក ស្រាប់តែភ្ញាក់ដើរចេញពីជួរមកខាងមុខ។ សមមិត្ត សុវណ្ណ ចេញពីជួរខាងក្រោយមកដែរ ដោយទឹកមុខតប់ប្រមល់។ រួចកម្មាភិបាលបញ្ជាឲ្យពួកគេចាប់ដៃគ្នា និងមើលមុខគ្នា។ ពួកគេជួបគ្នា ហើយស្រាប់តែភ្ញាក់ព្រើត រួចចាប់ដៃគ្នា ដោយទឹកមុខស្រងូតស្រងាត់។

ឈ្លបនារី ម្នាក់ឃើញដូច្នោះបានសួរយ៉ាងរហ័សថា «សមមិត្តទាំងពីរស្គាល់ឬ?»។ អ្នកទាំងពីរ នៅស្ងៀមមិនតបត។ ការហៅឈ្មោះចេះតែបន្តរហូតដល់អស់ មានគូតិចណាស់ ដែលសប្បាយចិត្តដោយការចាប់គូបង្ខំឲ្យរៀបការនេះ។ សមមិត្តនារីខ្លះទើបតែប្តីស្លាប់ចោល អ្នកខ្លះទៀតត្រូវឪពុកម្តាយលាចាកលោកថ្មីៗ អ្នកខ្លះត្រូវកម្មាភិបាលខ្មែរក្រហមចាប់គូឲ្យជាមួយអ្នកដែលមានវ័យស្មើឪពុករបស់ខ្លួន។ ក្រោយពីចាប់គូរួចអស់ហើយ កម្មាភិបាលទាំងនោះតម្រូវឲ្យគូស្រករថ្មីទាំងអស់គោរពទង់ជាតិ និងភ្លេងជាតិ។ ក្រោយពីគោរពទង់ជាតិ និងភ្លេងជាតិរួច កម្មាភិបាល និងប្រធានសហករណ៍ តម្រូវឲ្យគូស្រករថ្មីប្តេជ្ញានៅមុខអង្គការថា «យើងខ្ញុំសូមប្តេជ្ញាថានឹងស្មោះត្រង់ជាមួយអង្គការ ស្មោះត្រង់ប្តីមួយប្រពន្ធមួយ ខិតខំបង្កើនផលស្រូវ ខិតខំបម្រើអង្គការ ឥតព្រំដែនមហាអស្ចារ្យ មហារុងរឿងនៃយើង ជយោកម្ពុជាប្រជាធិបតេយ្យ»។ រួចស្នុះទេះដៃក៏លាន់ឡើងក្រោយពីចប់កម្មវិធីរៀបការ ពួកគេត្រូវតម្រង់ជួរកាន់ចានម្នាក់មួយៗ ដើម្បីទៅទទួលបបរ។ បបរនោះ គ្មានអ្វីក្រៅពីបបរសារាវៗ ដែលចុងភៅបានចែកឲ្យម្នាក់២វែកកន្លះជាមួយអំបិល១កូនដុំនោះទេ។

បន្ទាប់ពីសូរិយាអស្តង្គតទៅ រាត្រីផ្សំដំណេកគូស្នេហ៍ដែលអង្គការចាប់ផ្តុំឲ្យបានចូលមកដល់។ ក្រុមកងឈ្លប និងមេកងចល័ត បានដើរត្រួតពិនិត្យតាមខ្នមស្បូវពីខ្នមមួយទៅមួយ ក្រែងមានគូណាមិនចុះសម្រុងនឹងគ្នា។ ក្រឡេកមើលខ្នមស្បូវតូចរបស់ សុវណ្ណ និងកល្យាណ ឯនោះវិញ កំពុងតែសន្ធនាគ្នាខ្សឹបៗ។

កល្យាណ៖ «បងសុវណ្ណ! ខ្ញុំពិតជាមិនធ្លាប់សង្ឃឹមថាបានជួបបងទេ តាំងពីបែកពីបង ខ្ញុំនឹកបងរហូត»។

សុវណ្ណ៖ «បងក៏នឹកអូនដែរ កល្យាណ! ជួបអូនលើកនេះ បងហាក់មានកម្លាំងមហិមាទប់ទល់នឹងទុក្ខទាំងឡាយ តើហេតុអ្វីកាលនោះអូនឈប់រៀន?»។

កល្យាណ៖ «បងអើយ អូនសែននឹកវិទ្យាល័យនេតយ៉ង នឹកការសិក្សា នឹកលោកគ្រូ អ្នកគ្រូ និងមិត្តភក្តិណាស់ តែថ្ងៃចុងក្រោយ ដែលអូនទៅចូលរួមពិធីជប់លៀងសិស្សពូកែក្នុងវិទ្យាល័យអ៊ែបឃុត ដែលបងរៀននោះ ផ្ទះអូនត្រូវ

ភ្លើងឆេះគ្មានសល់ ហើយម្តាយរបស់អូនដែលកំពុងសម្រាន្តលក់ ត្រូវភ្លើងឆេះស្លាប់ដោយមិនដឹងខ្លួន» និយាយដល់ត្រឹមនេះ កល្យាណ ស្រក់ទឹកភ្នែកយំខ្សឹកខ្សួល។ សុវណ្ណ ឃើញដូច្នោះក៏លួងលោម កល្យាណ ឲ្យឈប់យំបន្តិចរួច កល្យាណ សួរតបទៅ សុវណ្ណ វិញ។

កល្យាណ៖ «ចុះបងក្រោយបញ្ចប់ការសិក្សាឆ្នាំ១៩៧៣ នោះ?»។

សុវណ្ណ៖ «ក្រោយបញ្ចប់ការសិក្សា បងបានទៅរស់នៅជាមួយឪពុកម្តាយនៅឯភ្នំពេញ ព្រោះជីតារបស់បងបានលាចាកលោកហើយ។ ពីឆ្នាំ១៩៧៣ ដល់ ១៩៧៥ ការប្រកបការងារឪពុកម្តាយរបស់បងនៅទល់មុខផ្សារស៊ីឡឹបនោះ មានសភាពមមាញឹក និងជោគជ័យណាស់ ព្រោះមានមន្ត្រីរបស់រដ្ឋាភិបាលសេនាប្រមុខ លន់ នល់ មកទិញជាប្រចាំ។ រីឯនៅចុងឆ្នាំ១៩៧៤ មន្ត្រីទាំងនោះបានដឹងពីសភាពការស្រុកទេសមិនស្រួល។ ពួកគេបានដើរបំផុសបំផុលប្រជាជននៅតាមទីជនបទនានាឲ្យក្រោកឡើងប្រឆាំងរបប លន់ នល់។ មន្ត្រីធំៗទាំងនោះ បានដាក់ខោអាវធំម្នាក់ពីរបីឈុតត្រៀមចាកចេញទៅក្រៅស្រុក ដើម្បីគេចពីសង្គ្រាម។ ពួកគេបានបបួលឪពុកម្តាយរបស់បងទៅជាមួយដែរ ប៉ុន្តែឪពុកម្តាយរបស់បងមិនយល់ព្រមព្រោះយើងមិននឹកស្មានថាមានព្រឹត្តិការណ៍ទាំងអស់នេះកើតឡើងទេ»។

និយាយដល់ត្រឹមនេះ សុវណ្ណ បានដកដង្ហើមធំ ទឹកមុខស្រពាប់ស្រពោនយ៉ាងខ្លាំង។ មួយសន្ទុះទើប សុវណ្ណ និយាយរៀបរាប់បន្តទៀត។

សុវណ្ណ៖ «ក្រោយពេលចាកចេញពីខេត្តបាត់ដំបងមកភ្នំពេញ បងមិនបានបន្តការសិក្សាទៀតទេ។ អំឡុងឆ្នាំ១៩៧៤ បងបានចាប់អារម្មណ៍វិធីតែងនិពន្ធកំណាព្យ។ បងចេះតែងនិពន្ធខ្លះៗ បងក៏ចេះរៀនសរសេរកំណាព្យរឿងខ្លីៗទាក់ទងនឹងតថភាពសង្គម តែមិនទាន់បានបោះពុម្ពស្នាដៃណាមួយទេ ស្រាប់តែអកុសលសម័យខ្មៅងងឹតនេះបានចូលមកដល់ អូនអើយមកពីហាងបងគ្មានឱកាសឃើញមុខឪពុកម្តាយរបស់បងផង មិនដឹងថាពួកគាត់ស្លាប់ឬរស់ទេ ភ្នំពេញច្របូកច្របល់ហើយប្រែជាស្ងាត់សូន្យ។ បងត្រូវខ្មែរក្រហមជម្លៀសចេញពីភ្នំពេញរហូតមកដល់កំពង់ឆ្នាំង និងទើបតែឆ្នាំ១៩៧៦ នេះ បងមកដល់បាត់ដំបង»។

កល្យាណ៖ «រាល់យប់អូនបន់ឲ្យតែសម័យនោះឆាប់អន្តរាយទៅទេ ត្រចៀកអូនឮតែសម្រែកសោះកក្រោះ ឃើញគ្រួសារបែកបាក់គ្នា ក្មេងប្រដៅចាស់ សម្លៀកបំពាក់ប្រពៃណីគ្មានទេ សំពត់បត់ហូលជាមួងភ្លេងបុណ្យសពក៏គ្មាន ឮតែបទ យើងខ្ញុំកុមារស្រលាញ់អង្គការឥតមានព្រំដែន... អូនស្រណោះណាស់មាតុភូមិយើងកំសត់ណាស់»។

សុវណ្ណ៖ «ឈប់យំទៅអូន ត្រូវតាំងជំហរស្រោចស្រង់ជាតិយើងរួមគ្នា»។

ភ្លាមៗនោះ ស្រាប់តែឮសំឡេងកងឈ្លបស្រែកមកថា «សមមិត្តសុវណ្ណ! សមមិត្តកល្យាណ រស់នៅជាមួយគ្នាមិនចុះសម្រុងមែនទេ?»។ សុវណ្ណ និងកល្យាណឆ្លើយរួមគ្នាថា «មិនមានរឿងបែបនេះទេសមមិត្តបង»។

កងឈ្លប៖ «អង្គការមានភ្នែកដូចម្ន៎ាស់ ធ្វើអ្វីកុំគិតថាអាចលាក់បាំងអង្គការបានឲ្យសោះ! យល់ទេ?»។

សុវណ្ណ និង កល្យាណ «សមមិត្តបង ពិតជាគ្មានមែន!»។

កងឈ្លប៖ «ល្អហើយអីចឹង! ឆាប់នាំគ្នាដេកទៅ» និយាយត្រឹមនេះកងឈ្លបក៏បន្តដើរទៅពិនិត្យមើលខ្ទមផ្សេងៗទៀត។

ក្រោយពីមេកងឈ្លប ភាព ចេញទៅ សុវណ្ណ និងកល្យាណ មើលមុខគ្នាហើយបញ្ចេញស្នូរដង្ហើមយ៉ាងស្ងប់ស្ងាត់ រួចនាំគ្នាចូលដេកទៅ។

ម៉ោង៤ទៀបភ្លឺ ស្នូរជួងរបស់អង្គការ បានបន្លឺឡើងយ៉ាងទៀងទាត់ជារៀងរាល់ថ្ងៃ។ ប្រជាជនខ្មែរម្នីម្នាចេញពីខ្ទមទាំងព្រះអាទិត្យមិនទាន់រះដើម្បីសំដៅទៅស្រែក្នុងភូមិខ្សោយ ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង។ សុវណ្ណ និងកល្យាណម្នីម្នាធ្វើដំណើរទៅកន្លែងរៀងៗខ្លួន។ សុវណ្ណ ធ្វើការនៅកងចល័តបុរស កាប់ដីភ្ជួរដី ដែលទើបតែប្រមូលផលរួច។ ចំណែក កល្យាណ វិញធ្វើការក្នុងកងចល័តនារី ត្រូវទៅប្រមូលផលស្រូវដាក់ក្នុងបាវ។

ចាត់ដំបងឆ្នាំ១៩៧៧

ក្រោយពីរស់នៅជុំប្រពន្ធមួយរយៈ សុវណ្ណ និងសមមិត្តបុរសឯទៀត បានអង្គការចាត់ឲ្យទៅសង់ទំនប់ទឹកនៅតំបន់ស្ទឹងចាស់។ ពេលឃ្លាតពីប្រពន្ធ សុវណ្ណ

បានប្រគល់បន្ទោងរូបផ្កាចំប៉ាមួយដួន កល្យាណ ព្រោះ សុវណ្ណ គិតថា បន្ទោងរូបផ្កាចំប៉ានេះ ជាវត្ថុស័ក្តិសិទ្ធិ ដែលអាចជួយឲ្យ កល្យាណ ជួបសេចក្តីសុខបាន។ ចំណែក សុវណ្ណ វិញគ្មានជំនឿថានឹងមានជីវិតវិលត្រលប់មកវិញទេ។

អង្គការ បានចាត់ឲ្យប្រជាជនទាំងអស់លើកទំនប់ទឹកដើម្បីធ្វើស្រែនៅក្នុងភូមិបឹងទឹម។ ការលើកទំនប់នេះ គ្មានឧបករណ៍ទំនើបទេ មានតែចប និងបង្គី តែចតួចប៉ុណ្ណោះ។ នៅខាងភូមិបាសែតវិញ អង្គការបានបញ្ជាឲ្យរុញយកថ្មប្រាសាទបុរាណទៅទប់ធ្វើទំនប់។ សុវណ្ណ មើលឃើញសភាពខ្ទេចខ្ទីនៃទម្រង់ប្រាសាទបាសែតដែលខ្មែរក្រហមកំពុងតែបំផ្លាញខ្ទេចខ្ទីដោយក្តីស្រណោះ។

ថ្ងៃបន្ទាប់ សុវណ្ណ បានទៅជួបប្រធានសហករណ៍និងស្នើសុំដោយផ្ទាល់ថា «លោកបងសមមិត្តប្រធាន ខ្ញុំមកនេះមានការស្នើសុំរឿងមួយ» ពេលនោះប្រធានសហករណ៍ បានបើកភ្នែកធំៗ ហើយសម្លឹងទៅកាន់សុវណ្ណ ប៉ុន្តែ សុវណ្ណ នៅតែបន្តនិយាយទៀតថា «ទំនប់ដែលសមមិត្តប្រធានបងឲ្យខ្ញុំទប់នោះជិតរួចហើយ ថែមទាំងមាំអាចទប់ទឹកបានល្អតាមផែនការរបស់អង្គការបានកំណត់ដែរ ដូច្នេះខ្ញុំស្នើបង្ហើយការងារទប់នេះដោយយកដីខ្សាច់ច្រកបាវហើយទប់ទឹកជំនួសថ្មប្រាសាទវិញ ដូចសមមិត្តប្រធានបង ជាអ្នករស់នៅក្នុងភូមិនេះស្រាប់ ប្រាសាទនេះ... » សុវណ្ណនិយាយមិនទាន់ចប់ផង ប្រធានសហករណ៍នោះយកដងកាំភ្លើងវាយចំក្បាល សុវណ្ណ ធ្វើឲ្យមានឈាមហូរតក់ៗ រួចប្រធានសហករណ៍ ស្រែកសម្តែតថា «សមមិត្តឯងប្រដៅយើងមែនទេ?»។ ទោះបីជាប្រធានសហករណ៍នោះសម្តែតយ៉ាងណាក៏ដោយ សុវណ្ណនៅតែនិយាយដោយលែងខ្លាចស្លាប់ ស្របពេលដែលឈាមស្រក់តក់ៗទប់ជំហរស្ទើរតែលែងជាប់បន្តទៀតថា «លោកបងសមមិត្តតាំងពីដើមមកលោកបងឃើញប្រាសាទនេះរហូតមុនខ្ញុំទៅទៀត បើប្រាសាទនេះបាត់បង់លោកបងស្តាយទេ?» និយាយរួច សុវណ្ណ អួលដើមក។ ឮ សុវណ្ណ និយាយចំចំណុច មួយសន្ទុះមក ប្រធានសហករណ៍ ឆ្លើយតបទាំងត្រឹមត្រូវវិញថា «អឺ! ត្រូវទប់ទំនប់ឲ្យល្អ ឈប់សួរយើងរឿងប្រាសាទនេះទៀត»។ ឮដូច្នោះ សុវណ្ណ អរណាស់ ហើយនិយាយអរគុណទៅប្រធានសហករណ៍ បន្ទាប់មកដួលទៅលើដីដោយសារតែឈាមស្រក់ហូរខ្លាំងពេករហូតទប់ជំហរលែងបាន។

បន្ទាប់ពីសាងសង់ទំនប់រួចហើយ សុវណ្ណ និងសមមិត្តឯទៀត ដែលនៅរស់បានវិលត្រលប់មកវិញ។ កល្យាណ អរណាស់ ដែលប្តីនាងមានជីវិតវិលត្រលប់មកជួបគ្នាវិញនៅចុងឆ្នាំ១៩៧៧។

អំឡុងឆ្នាំ១៩៧៨

ក្រោមការគ្រប់គ្រងក្នុងរបបខ្មែរក្រហម ប្រជាជនកាន់តែហោចទៅៗ សុខភាពប្រជាជនកាន់តែទ្រុឌទ្រោម ប្រជាជនដែលនៅមានជីវិតរស់ សុទ្ធតែប្រថុយជីវិតពីការលួច។ អង្គការកាន់តែតឹងតែងពីមួយថ្ងៃទៅមួយថ្ងៃ បើពួកខ្មែរក្រហមសង្ស័យថាអ្នកណាជាខ្មាំងហើយ អ្នកនោះច្បាស់ជាស្លាប់ដោយគ្មានការជំនុំជម្រះក្តីឡើយ។ ពួកគេតែងតែនិយាយថា «ស៊ូសម្លាប់ខុសប្រសើរជាងមិនសម្លាប់»។

ព្រឹកនេះ នៅរោងបាយប្រជុំក្រោលគោ មានការប្រជុំធំមួយរបស់អង្គការ។ ប្រធានសហករណ៍បានចាប់ផ្តើមសួរថា «តើមានសមមិត្តណា ចេះអក្សរឬធ្លាប់ធ្វើជាគ្រូបង្រៀនទេ? អង្គការសុំឲ្យឡើងមកខាងមុខនេះ ដើម្បីអង្គការយកទៅបណ្តុះបណ្តាល រួចយកមកបង្រៀនកុមារ»។ ប្រជាជនខ្លះត្រេកអរណាស់ព្រោះពួកគេមិនយល់ពីផែនការរបស់អង្គការ បែរជាឡើងទៅទាំងទឹកមុខមានសង្ឃឹមដោយគិតថាអង្គការច្បាស់ជាគិតដល់ពួកគេ។ ពេលនោះ ប្រជាជនដែលឡើងទៅតាមការស្នើរបស់អង្គការមានប្រហែលជា៣០នាក់។ សុវណ្ណ និងកល្យាណ អង្គុយជិតគ្នាឥតមានមាត់មួយមាត់។ ស្រាប់តែពេលនោះ មានស្ត្រីវ័យចំណាស់ម្នាក់ដែលអង្គុយក្បែរហ្នឹងមានគំនិតចង់ឲ្យ សុវណ្ណ បានល្អ បានជួយប្រាប់អង្គការថា «ក្មួយនេះចេះអានស្ទាត់ណាស់ សូមអង្គការជួយបណ្តុះបណ្តាលផង»។ ពេលនោះ សុវណ្ណ និងកល្យាណ ភ្ញាក់ក្រញាង ឆ្ងល់ថាតើគាត់ដឹងរឿងនេះមកពីណាបើ សុវណ្ណ និងកល្យាណ ខំលាក់យ៉ាងនេះហើយនោះ។ ដូចពាក្យចាស់ៗនិយាយមែន ក្រជាសខ្ចប់ភ្លើងមិនជាប់ទេ ទោះបីជា សុវណ្ណ ចង់ឬមិនចង់និយាយក៏មិនអាចប្រកែកបានឡើយ។

យប់នោះ សុវណ្ណ អង្គុយក្បែរភរិយា អារម្មណ៍របស់ សុវណ្ណ ហាក់មានក្តីអាឡោះអាល័យជាខ្លាំង ហើយ សុវណ្ណ និយាយតិចៗថា «ប្រពន្ធសម្លាញ់ បងនឹងត្រូវទៅឆ្ងាយពីអូនឆាប់ៗនេះហើយ។ ពេលបងមិននៅជិត អូនត្រូវថែទាំខ្លួនឲ្យល្អ

ណា» សុវណ្ណយកដៃវែកសក់ប្រពន្ធថ្នមៗ រួចបន្តទៀតថា «កុំបារម្ភពីបងអី បងច្បាស់ជាត្រលប់មកជួបអូនវិញ អូនត្រូវតែជាស្រីរឹងមាំ បងនឹងអស់បារម្ភណា»។ កល្យាណ អួលដើមក ទឹកភ្នែកស្រក់មកតិចៗឥតឈប់ឈរ ដៃរបស់នាងញ័ររួចនាងយកដៃអង្អែលមុខប្តី ហើយថើបដោយក្តីស្រលាញ់អាណិតពន់ពេក។ កល្យាណ បាននិយាយទៅកាន់ សុវណ្ណ វិញថា «ប្តីសម្លាញ់!កុំព្រួយអី ក្តីស្រលាញ់បងជាអាវក្រោះដ៏រឹងមាំការពារអូនជានិច្ច» និយាយចប់ កល្យាណ ជូនទឹកភ្នែកថ្នមៗ។

សុវណ្ណ និងកល្យាណ ប្រុងដាក់ខ្នងដល់រនាបទៅហើយ ស្រាប់តែឮសូរសំឡេងស្រែកហៅពីក្រៅខ្ទម ដែលជាសំឡេងកម្មាភិបាលខ្មែរក្រហមថា «សមមិត្ត សុវណ្ណ ឆាប់ចេញមក! ដល់ពេលត្រូវទៅបណ្តុះបណ្តាលហើយ»។ សុវណ្ណ និង កល្យាណ មានកែវភ្នែកពោរពេញដោយភាពល្វីងជូរចត់ណាស់ សុវណ្ណ ងិនថើប ថ្ងាសប្រពន្ធហើយនិយាយថា «ថៃខ្លួនណាអូន កុំតាមបងអី បងទៅសិនហើយ»។ សុវណ្ណដើរតាមកម្មាភិបាលខ្មែរក្រហម ដោយមិនងាកក្រោយទេ ព្រោះមិនចង់ឲ្យ កល្យាណ នឹកអាឡោះអាល័យ។ កល្យាណយំខ្សឹកខ្សួលម្នាក់ឯងស្រណោះអាណិតប្តីពន់ពេក។

តាំងពីបែកប្តីមក កល្យាណ ក្រៀមក្រំស្រងេះស្រងោចណាស់។ កល្យាណ រង់ចាំប្តីពីមួយថ្ងៃទៅមួយថ្ងៃ ដោយគ្មានដំណឹងអ្វីបន្តិចសោះឡើយ។ រាងកាយ របស់ កល្យាណ មានសភាពទ្រុឌទ្រោម ជួនកាលសន្លប់បាត់ស្មារតីក៏មានដែរ។ ទីបំផុត កល្យាណ ដឹងថានាងមានផ្ទៃពោះ។ អារម្មណ៍ជាម្តាយ ធ្វើឲ្យកល្យាណ រំកើបពន់ពេកណាស់។ កល្យាណ បានចាប់ផ្តើមថែរក្សាសុខភាពឡើងវិញដើម្បីកូន។ ហេតុផលនេះហើយ បានធ្វើឲ្យ កល្យាណ ប្រឹងប្រែងរស់បន្តទៀត។

ផ្ទៃពោះរបស់ កល្យាណ កាន់តែធំកាន់តែទំហំការងារដែលខ្មែរក្រហមដាក់ឲ្យធ្វើពីមួយថ្ងៃទៅមួយថ្ងៃ ក៏កាន់តែ កើនឡើងឥតឈប់ឈរដែរ។ កាលពីមួយរយៈពេលមុន ប្រជាជនអាចទទួលបានរបបបបរខាប់គ្រាន់បើ តែឥឡូវនេះមេសហករណ៍ បែរជាកាត់បន្ថយបបរហេតុតែចង់បញ្ជូនផលស្រូវឲ្យបានគ្រប់ចំនួនកំណត់។ របបអាហារមិនគ្រប់គ្រាន់បែបនេះ ធ្វើឲ្យ កល្យាណ នឹកគិតបារម្ភពីសុខភាពនាងដែលកំពុងតែត្រូវការជីវជាតិដើម្បីកូននៅក្នុងពោះ។

ថ្ងៃមួយម៉ោងប្រមាណជា ៨យប់ កល្យាណ មានភាពឈឺចាប់ក្នុងពោះយ៉ាងខ្លាំង។ ថ្ងៃនោះគឺជាថ្ងៃដល់ពេលដែល កល្យាណ សម្រាលកូនហើយ។ យប់សម្រាលកូននោះ គ្មានឆ្មប ជួយបង្កើតកូនឲ្យនោះទេ មានតែអ៊ំចាស់ៗ ពីរបីនាក់ មកជួយមើលថែ ដោយទឹកចិត្តចេះជួយគ្នាក្នុងគ្រាលំបាកតែប៉ុណ្ណោះ។ កល្យាណ ស្រែកដោយភាពឈឺផ្សា ញើសហូរជោគថ្ងាស រង្វង់មុខស្លេកស្លាំង។ នាងហាក់គ្មានកម្លាំងសម្រាលកូនសោះ តែដោយទឹកចិត្តជាម្តាយចង់ឃើញមុខកូន កល្យាណ ខំប្រឹងសព្វគ្រប់ទើបបង្កើតកូនរបស់នាងបាននៅរាត្រីដ៏សែនសោកសង្រេងនោះ។ បង្កើតកូនរួចភ្លាម កល្យាណ ប្រឹងនិយាយជាមួយសំឡេងខ្សាវៗថា «អ៊ំ!ខ្ញុំសុំមើលមុខកូនរបស់ខ្ញុំបន្តិច»។ ឮដូច្នោះហើយ អ៊ំ បានលើកទារិកាតូចនោះដាក់លើទ្រូងរបស់ កល្យាណ។ កល្យាណ យកដៃឱបក្រសោបញញឹម និងមើលមុខកូនឆ្អៀងផ្អងទោះបីជានាងហត់ល្វើយយ៉ាងណាក៏ដោយ។ ឃើញទម្រង់មុខកូនហើយ ធ្វើឲ្យកល្យាណ នឹករឭកដល់ប្តីជាពន់ពេក ហើយនិយាយទាំងអួលដើមកថា «កូនម្តាយ» រួច កល្យាណ យំខ្សឹកខ្សួលអមជាមួយទឹកភ្នែក។

ក្រោយសម្រាលកូនបានចំនួន៣ថ្ងៃ កល្យាណ ត្រូវវិលទៅធ្វើការវិញ។ ទារិកាតូចពិតជាកំសត់ណាស់ ព្រោះ កល្យាណ ពុំសូវមានទឹកដោះបំបៅនោះទេ ដូច្នេះចេះតែធ្វើឲ្យកូនយំឥតឈប់។ កល្យាណ ពិតជាសែនខ្លោចផ្សាក្នុងចិត្តណាស់ពេលដែលកូនស្ថិតក្នុងសភាពដូច្នោះ។

នៅចុងឆ្នាំ១៩៧៨ ពាក្យចចាមអារ៉ាម ដែលថាកងទ័ពវៀតណាម បានបង្កើតរណសិរ្សដើម្បីមកជួយប្រជាជនខ្មែរល្បីឮសុះសាយ។ រហូតដល់មានលេចឮឈ្មោះរណសិរ្សមួយថា «រណសិរ្ស ២ធ្នូសង្គ្រោះជាតិកម្ពុជា» បានបង្កើតឡើង។ ទីបំផុត កងទ័ពវៀតណាម និងកងទ័ពសង្គ្រោះកម្ពុជា បានវាយកម្ចាត់ពួកខ្មែរក្រហមនៅភ្នំពេញ និងស្ទើរពេញផ្ទៃប្រទេសមែន។

ការប្រយុទ្ធរំដោះនៅខេត្តបាត់ដំបង បានធ្វើឲ្យកម្មាភិបាលខ្មែរក្រហមខ្លះប្រធានសហករណ៍ សហការី និងប្រជាជនខ្មែរស្លាប់អស់ច្រើននាក់ណាស់។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រជាជនខ្មែរបានស្រាកស្រានពីសេចក្តី

វេទនាមួយនេះ។ ក្រោយសង្គ្រាមបានបញ្ចប់ ប្រជាជនខ្លះនៅតែរស់ក្នុងភាពភ័យខ្លាច បាក់ស្បាត ព្រោះពួកគាត់មិនទាន់ជឿជាក់ថា ពួកគាត់ត្រូវបានរំដោះពិតប្រាកដមែនឬអត់ ដោយបទពិសោធន៍ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច មានប្រជាជនជាច្រើនយល់ខុសថាប្រទេសជាតិនឹងរុងរឿងក្រោមការគ្រប់គ្រងពីរបបខ្មែរក្រហម។

នៅលើស្ពានថ្មទល់មុខសាលាខេត្តបាត់ដំបង ដែលលាតសន្ធឹងកាត់ដងស្ទឹងសង្កែ កល្យាណ ឈរបីកូនតូច សម្លឹងមើលសោកនាដកម្មក្រោយសង្គ្រាម ដែលមានប្រជាជនខ្លះពិការដៃជើង ខ្លះស្ពាយបង្វេចទៅស្រុកកំណើតវិញ ខ្លះទូលរែកចានឆ្នាំង ហើយប្តីប្រពន្ធខ្លះដែលអង្គការរៀបចំឲ្យនោះ ក៏ចែកផ្លូវគ្នាវិញ។ តាមដងផ្លូវ មានក្មេងៗយំទ្រហឹង វង្វេងម្តាយ វង្វេងសាច់ញាតិ ហើយមានសំណង់ជាច្រើនខូចខាត ចំណែក កល្យាណ វិញ ត្រូវព្រាត់ប្រាស់ក្រុមគ្រួសារ និងប្តីជាទីស្រលាញ់។

ចប់

៣៣

រឿងប្រឌ្ឋាយទឹកភ្នែក

អ្នកនិពន្ធ ៖ ម៉ឿង ពិសិត

៣៣ ~ រឿង ប្រឡាយទឹកភ្នែក

ព្រះទិនករគោចរមិនបង្អង់តម្រង់ទៅទិសខាងលិច ហាក់ត្របាក់ពាំនាំនូវភាពសោកសៅ ការឈឺចាប់ និងសេចក្តីព្រាត់ប្រាស់ ឲ្យលិចបាត់តាមរស្មីព្រះអាទិត្យ។ ប្រជាជនប្រុសស្រី ហាក់ត្រេកអរសប្បាយនឹងពន្លកសន្តិភាព ដែលកំពុងលូតលាស់ចេញជារូបរាងផុតពីរបបនរកអវិចី។ រយៈពេលត្រឹមតែ៣ឆ្នាំ ៨ខែ ២០ថ្ងៃ គឺជាថ្ងៃដែលប្រជាជនខ្មែរពិបាកនឹងបំភ្លេចបាននូវទារុណកម្មក្នុងរបបប្រល័យពូជសាសន៍ដ៏សាហាវឃោរឃៅនៅក្នុងប្រទេសកម្ពុជា ដែលបានកើតឡើងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

ម្តាយរបស់ខ្ញុំ អង្គុយត្រចោមក្បាលជង្គង់ផ្អែកនឹងជញ្ជាំងស្លឹកត្នោតក្បែរបង្អួច។ កែវភ្នែករបស់គាត់សម្លឹងចំចង្កៀងប្រេងកាត ដែលកំពុងតែឆេះហឹមៗរៀបរលត់ តែចិត្តវិញ្ញាណរបស់គាត់ហាក់រសាត់អណ្តែតរកស្មានមិនត្រូវ។ ម្តាយរបស់ខ្ញុំនៅស្ងៀមហាក់មិនចង់និយាយស្តីអ្វីសោះ។ យូរៗម្តង គាត់បានយកម្រាមដៃកំបុតរបស់គាត់ទៅជូតទឹកភ្នែក ដែលកំពុងហូរស្រក់ដោយមិនដឹងខ្លួនប្រកបដោយទឹកមុខស្រពាប់ស្រពោន។ ភាពសញ្ជប់សញ្ជឹងនោះ បានកាត់ផ្តាច់ចោលនៅពេលដែលសំឡេងបងប្រុសរបស់ខ្ញុំស្រែកហៅម៉ែក្បែរមាត់ជណ្តើរក្រោមផ្ទះ។

ទឹកភ្នែកថ្មីៗនៅសើមជាប់ថ្ពាល់ជ្រីវជ្រួញរបស់ម្តាយខ្ញុំ បានកញ្ឆក់យកដួងចិត្តបងប្រុសរបស់ខ្ញុំឲ្យក្រៀមក្រំទៅតាម។ រួចបងប្រុសរបស់ខ្ញុំ បាននិយាយលួងលោមម្តាយរបស់ខ្ញុំថា «ម៉ែ! ម៉ែគួរតែចែករំលែកប្រាប់ខ្ញុំនូវបញ្ហាដែលម៉ែបានជួបប្រទះ ទោះបីជាខ្ញុំជួយស្រោចស្រង់អ្វីវិញមិនបាន តែអាចធ្វើឲ្យម៉ែកាត់បន្ថយនូវភាព

ស្ងៀមស្ងាត់ក្រសោបឱបទុក្ខតែម្នាក់ឯងបែបនេះដែរ។ ខ្ញុំដឹងថាការឈឺចាប់ ភាពព្រាត់ប្រាស់នោះវាមានទំហំធំធេង តើមានអ្វីទៀតនៅពីក្រោយការឈឺចាប់របស់ម៉ែដែលកូនមិនទាន់បានដឹង? ខ្ញុំទើបដឹងថា ពុកនិងយាយតា ត្រូវបានខ្មែរក្រហមសម្លាប់យ៉ាងព្រៃផ្សៃ ហើយឃាតករ គឺជាពូម្នាក់ដែលរស់នៅជិតផ្ទះយើង។ គេគ្មានការឈឺចាប់ឬសោកស្តាយអ្វីឡើយ។ គំនុំឈាមនេះ ត្រូវប្តូរនឹងឈាមរបស់វាមកស្រោចស្រពបូជាព្រលឹងដូនតាយើងវិញ»។

ឮដូច្នោះ ទឹកភ្នែកម្តាយរបស់ខ្ញុំ ហូរស្រក់បន្តទៀត រួចគាត់បានបង្ហាញស្នាមញញឹមសោះកក្រោះហើយឆ្លើយតបទៅបងប្រុសរបស់ខ្ញុំវិញថា «នរៈ! កូននៅក្មេងណាស់។ គ្រប់យ៉ាងអង្គការជាអ្នករៀបចំ។ វាបានបញ្ចប់ទៅយ៉ាងល្អហើយ ហើយកូនខំគាស់កកាយមកធ្វើអ្វីទៀត។ បើការសម្លាប់សងសឹកមិនចេះចប់មិនចេះហើយនោះ តើពេលណាក្នុក់ភ្លើងសង្គ្រាមបានរលត់ផុតពីប្រទេសជាតិយើង?»។ បងប្រុសរបស់ខ្ញុំ ឆ្លើយតបទៅម្តាយរបស់ខ្ញុំប្រកបដោយភ្លើងកំហឹងថា «អង្គការ! អង្គការ! គ្រប់យ៉ាងសុទ្ធតែអង្គការជាអ្នកធ្វើ តែមកដល់ពេលនេះ ខ្ញុំមិនទាន់ដឹងថា តើអង្គការជាអ្នកណា? អង្គការមានស្នាក់ការនៅកន្លែងណាខ្លះ? ហើយអង្គការបានទទួលទោសអ្វីខ្លះទេពីទោសកំហុសដែលបានប្រព្រឹត្តទៅលើប្រជាជនខ្មែរ? គ្រប់យ៉ាងអង្គការជាអ្នកធ្វើ តែទង្វើគ្រប់យ៉ាងខ្ញុំឃើញមនុស្សដែលគ្មានការតែងតាំងពីអង្គការជាអ្នកប្រព្រឹត្ត ដូចជាការស្លាប់របស់ពុក និងយាយតារបស់ខ្ញុំជាដើម។ បើខ្ញុំមិនបានសងសឹក ជីវិតកូនប្រុសដូចខ្ញុំរស់នៅនាំទម្ងន់ផែនដីនេះទេ។ ខ្ញុំមិនខ្វល់ថា អង្គការជានរណានោះទេ។ ខ្ញុំគ្រាន់តែដឹងថាពូម្នាក់ហ្នឹង សម្លាប់ឪពុកនិងយាយតារបស់ខ្ញុំ។ ឈាមត្រូវសងដោយឈាម» ។

ឃើញបងប្រុសរបស់ខ្ញុំមានកំហឹងពេញខ្លួនយ៉ាងនេះ ម្តាយរបស់ខ្ញុំហាក់ដូចជាបារម្ភ ហើយបន្តនិយាយលួងលោមគាត់ថា «កូនម្តាយ! ភាពកត្តញ្ញូរបស់កូនធ្វើឲ្យម៉ែក្តុកក្តួលណាស់។ កូនខឹង កូនស្អប់ កូនឈឺចាប់វាជារឿងត្រឹមត្រូវចំពោះរឿងដែលកូនបានជួបប្រទះ ប៉ុន្តែការសម្លាប់សងសឹក ដើម្បីបង្ហាញពីភាពកត្តញ្ញូ

ចំពោះអ្នកមានគុណ វាជារឿងថោកទាបបំផុត។ កូនសម្លាប់គេហើយ តើខ្មោចយាយតាឯងរស់ឡើងវិញទេ? កូនសងសឹកហើយ តើកូនមានសេចក្តីសុខនឹងរស់នៅសុខស្រួលទេ? នៅពេលដែលកូនកំពុងហែលក្នុងរណ្តៅភ្នំភ្លើងសង្គ្រាម កូនតែងតែស្រែកដង្ហោយហៅរកសន្តិភាព តែពេលនេះសន្តិភាពមានចំពោះមុខកូនហើយ តើពេលណាកូនបើកចិត្តទទួលយក? កូនមើល! ម្រាមដៃរបស់ម៉ែកំបុត ស្នាមរបួសមិនទាន់ជាសះនៅឡើយ។ ម៉ែមិនឲ្យកូនបំភ្លេចរឿងរ៉ាវទាំងអស់នោះទេ តែម៉ែ ក៏មិនឲ្យកូនបំផ្លាញដៃរ។ គ្រប់យ៉ាងតែងតែមានហេតុនិងផល។ ប្រទេសជាតិយើងហាក់ស្រស់បំព្រងឡើងវិញហើយ គ្រប់យ៉ាងទុកពេលវេលាជាអ្នកដោះស្រាយទៅចុះ។ អតីតកាលដែលធ្វើឲ្យកូនឈឺចាប់កូនបំភ្លេចវាចុះ ព្រោះការចងចាំនោះវាអាចក្លាយជាអណ្តាតភ្លើងដុតកម្ចោចខ្លួនប្រាណកូនវិញបាន។ ថ្ងៃលិចទៅហើយឲ្យវាលិចទៅចុះ សង្ឃឹមស្អែកថ្មីពិភពលោករបស់កូននឹងស្រស់ថ្លាសមនឹងយុវជនសម័យថ្មី។ កូនបោះចោលគំនុំ និងការសងសឹករបស់កូនទៅ ងាកមកទាញបិចនិងសៀវភៅត្រលប់ទៅសិក្សាវិញ។ ទោះបីជាវាយឺតបន្តិចក្នុងការចាប់ផ្តើម តែសេចក្តីបញ្ចប់របស់កូននឹងភ្លឺស្វាងត្រចះត្រចង់។ ប្រទេសជាតិមានសង្គ្រាមគេត្រូវការអ្នកក្លាហាន រីឯប្រទេសជាតិសុខសាន្តត្រាណ គេត្រូវការអ្នកមានចំណេះដឹង។ កូនត្រូវចាំថាគ្មាននរណាល្អឥតខ្ចោះនោះទេ។ កូនខឹងនឹងទង្វើគេដែលធ្វើមកលើឪពុក និងយាយតាឯង តែឯងមានចាប់ភ្លឺកនឹកដល់ទង្វើកូនដែលធ្វើទៅលើគេទេ។ កូនបញ្ឈប់វាទៅ កុំឲ្យគ្រប់យ៉ាង វាអាក្រក់ជាងនេះ។ ម៉ែបានបាត់បង់គ្រប់យ៉ាងហើយ ម៉ែមិនចង់បាត់បង់កូនម្នាក់ទៀតទេ។ បើពុក និងយាយតារបស់កូននៅរស់ ពួកគាត់នឹងចង់ឃើញកូនក្លាយជាមនុស្សល្អ មានអធ្យាស្រ័យប្រកបដោយទំនួលខុសត្រូវ»។

បន្ទាប់ពីម្តាយរបស់ខ្ញុំនិយាយចប់ បងប្រុសរបស់ខ្ញុំ និងខ្ញុំ នាំគ្នាយំឱបម្តាយដោយភាពឈឺចាប់ រួចបងប្រុសរបស់ខ្ញុំ ក៏អង្អែលមុខរបួសម្តាយរបស់ខ្ញុំថ្នមៗដើម្បីលួងលោមចំពោះការឈឺចាប់។

ឃប់១២រោច ចុងឆ្នាំ១៩៧៦

រាត្រីព្រាត់ដួងខែមេឃប្រែជាស្រអាប់។ យប់នេះជាយប់១២រោច ចុងឆ្នាំ ១៩៧៦ ដែល ប៉ុល ពត ប្លន់ដណ្តើមទឹកដីប្រទេសកម្ពុជាមកគ្រប់គ្រងអស់ រយៈពេលយូរគួរសមដែរហើយ។ ក្រោមការគ្រប់គ្រង ពួកមេដឹកនាំទាំងនោះ បាន បែងចែកជាភូមិភាគ ថ្នាក់តំបន់ និងសហករណ៍ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ប្រជាជន។ ប្រជាជនទាំងថ្មីទាំងចាស់ខិតខំធ្វើការឡើងហួសកម្លាំងពេញមួយថ្ងៃៗ ព្រោះត្រូវមកចូលរួមប្រជុំធំក្នុងថ្ងៃនេះ។ នៅក្នុងអង្គប្រជុំនោះ អង្គការ បានអញ្ជើញ កម្មាភិបាលខ្មែរក្រហមឲ្យមានមតិសំណេះសំណាល ណែនាំនូវគោលនយោបាយ ខ្លះៗ។ កម្មាភិបាលនោះនិយាយថា «អង្គការធ្វើបែបនេះគឺដើម្បីឲ្យប្រជាជនមាន សិទ្ធិ និងការរស់នៅស្មើៗគ្នា។ អង្គការចង់លុបបំបាត់ពួកមូលធននិយម ដែល ចូលចិត្តកេងប្រវ័ញ្ចអ្នកក្រឲ្យក្លាយជាទាសកររបស់ខ្លួន ហើយអង្គការលើកតម្កើង ពួកអធនឲ្យរស់នៅមានសមភាពគ្នា។ ពុកម៉ែបងប្អូនមើលដែកដែលនៅលើដី វានឹងមានច្រែះជាក់ជាមិនខាន។ ដែកនោះនឹងចាប់ផ្តើមស៊ីច្រែះឡើងពេញតួ ខ្លួនរបស់វា។ ច្រែះ មិននៅស្ងៀម ថែមទាំងប្រឹងបៀមជញ្ជក់ដែករហូតដាច់ដោច ក្លាយជាដី។ ដែកស៊ីច្រែះ ហើយច្រែះក៏ត្រូវស៊ីដែកវិញ។ បងប្អូនទាំងអស់គ្នា ត្រូវប្រឹងបន្ត ដើម្បីអង្គការយើងទាំងមូល។ យើងហូបបបរមែន តែកុំឲ្យទន់ជ្រាយ ដូចបបរ។ យើងត្រូវខិតខំធ្វើការងារ កុំខ្ជិលច្រអូស ហើយត្រូវស្មោះនឹងអង្គការ។ ជយោ! អង្គការមហាអស្ចារ្យ មហាលោតផ្លោះ ជយោ! ជយោ! ជយោ!» អង្គប្រជុំ ត្រូវបានបញ្ចប់បន្ទាប់ពីសូរសព្ទស្រែកកងរំពង។ សូរសព្ទនោះមិនទាន់បាត់ផង ក៏ មានសំឡេងស្រែកបន្តថា «ធ្វើស្រែប្រវាស់មេយ ស៊ីបាយ ធ្វើស្រែប្រវាស់ប្រឡាយ ស៊ីបបរ»។ សំឡេងនោះក៏ស្ងប់ស្ងាត់បាត់ទៅតាមហ្វូងមនុស្ស តែមេក្រុម មេកង ហាក់សម្លឹងតាមរកប្រភពសំឡេងនោះមិនបង្អង់សោះ។

សំឡេងមាន់រងាវចាប់ផ្តើមបន្លឺឡើង។ ដុំភ្លើង ចាប់ផ្តើមឆេះសន្ធោសន្ធៅនៅ ទិសបូព៌ា។ មនុស្សម្នា ចាប់ផ្តើមធ្វើការដើម្បីអង្គការយើង។ ពេលនោះ ខ្ញុំពពោះ ជាង៨ខែ ប៉ុន្តែនៅតែទៅធ្វើការដូចប្រជាជនផ្សេងៗទៀត។ ជាធម្មតា ការងារ

របស់ខ្ញុំ តែងតែមានគេជួយ តែអ្នកជួយថ្ងៃនេះហាក់បាត់ទៅតាមពាក្យសម្តីដែលគាត់និយាយពេលប្រជុំចប់នោះទៅហើយ។ ថ្ងៃត្រង់ណាស់ទៅហើយ សំឡេងជ្រូកស្រែកពីក្នុងព្រះវិហារស្ថិតក្នុងវត្តកោះខ្សាច់ ដែលស្រែកខ្លាំងៗប្រណាំងនឹងពោះរបស់ខ្ញុំកំពុងតែកូរឃ្លានដូចគ្នា។ ក្នុងរោងបាយ ប្រជុំដោយហ្វូងមនុស្សជាច្រើន ហាក់មិនចាប់អារម្មណ៍នឹងដៃជើង សម្លៀកបំពាក់ដែលកខ្វក់សុទ្ធតែភក់ឡើយ។ ស្លាបព្រាមួយនៅជាប់នឹងខ្លួន ត្រូវដកមកហូបបបរកគ្រាប់អង្ករស្ទើរតែគ្មាន។ យើងមិនទាន់ហូបហើយស្រួលបួលផង មេកង ស្រែកហៅយើងឲ្យទៅជីកប្រឡាយបន្តទៀត។ សំឡេងប្រកូកប្រកាសនោះមិនទាន់សាបរលាបផង មានសំឡេងមួយទៀតស្រែកថា «បន្តិចទៀតឈានទៅដល់ឧស្សាហកម្មសម័យ នឹងមានម៉ាស៊ីនបញ្ចុកបាយពួកយើងលែងហត់ដួសហូបដោយខ្លួនឯងហើយ។ ហូបបបរប៉ុណ្ណឹងម៉េចឆ្អែត ផឹកទឹកទៅឆ្អែតល្មម»។

ព្រះសុរិយាហាក់ឈឺផ្សារនឹងទារុណកម្មអមនុស្សធម៌នេះ បានដុះកម្តៅដុតកម្លោចផែនដីនេះឲ្យ ក្រៀមស្វិតដោយមិនអាណិតសត្វលោកឡើយ។ ព្រះពាយហាក់អត់ទ្រាំពុំបាន ក៏ច្រានដុំពពកខ្មៅឲ្យបាំងបិទពន្លឺនោះទៅ។ ព្រះពិរុណនៅស្ងៀមបៀមទុក្ខ ក្លាហានបង្ហូរទឹកភ្លៀងដូចគេហែកមេឃ ដើម្បីបន្ថយនូវកាពឈឺចាប់។ ខ្ញុំធ្វើការក្រោមកម្តៅថ្ងៃពេញមួយថ្ងៃ ឥឡូវក្រោមតំណក់ទឹកភ្លៀងដ៏ខ្លាំងថែមទៀត។ រាងកាយរបស់ខ្ញុំទាំងមូលមិនអាចទ្រាំទ្រនឹងរបត់អាកាសធាតុនេះបានឡើយ។ ដៃខ្ញុំស្ពឹក ជើងខ្ញុំញ័រ ហើយត្រចៀកខ្ញុំខ្ទរស្តាប់អ្វីលែងបាន។ ចបនិងបង្គីរបស់ខ្ញុំ បានធ្លាក់ទៅមួយចំហៀងខ្លួន រួចខ្ញុំដួលទៅម្ខាងទៀត។ អ្នកនៅក្បែរនោះបានជួយរឹតគក់ច្របាច់ឲ្យខ្ញុំ។ មេកងមកដល់ក៏និយាយថា «គ្រូនញាក់គ្រូនញ័រ គ្រូនគ្រាក់ទ័រគ្រូនឡាន គ្រូនបាយបាន មិត្តឯងត្រូវតែកែចេញ កុំលាក់កម្លាំងពលកម្មបែបហ្នឹងទៀត ប្រយ័ត្នអង្គការយកទៅរៀនសូត្រ»។

បង្កើតភូនលើខ្នងប្រឡាយ

ខ្ញុំឈ្មោះ ស៊ីលាក។ ថ្ងៃនោះ ទឹកភ្នែករបស់ខ្ញុំហូរស្រក់ប្រណាំងនឹងទឹកភ្លៀងប្រកបដោយភាពឈឺចាប់ក្រៃលែង។ កម្លាំងកាយរបស់ខ្ញុំហាក់មិននៅសេសសល់

ទៀតទេ តែចិត្តដែលខឹងសម្បាររបស់ខ្ញុំ បានធ្វើឲ្យខ្ញុំប្រឹងប្រែងធ្វើការងារបន្តទៀត។ មេយចាប់ផ្តើមងងឹត មនុស្សម្នា ស្រូតរូតធ្វើដំណើរប្រញាប់ទៅផ្ទះរៀងៗខ្លួន។ ខ្ញុំប្រឹងឱបពោះដើរលើខ្នងប្រឡាយ ដែលរអិលដូចលាបខ្លាញ់។ ទារកក្នុងផ្ទៃរបស់ខ្ញុំ ហាក់ចង់ឃើញពន្លឺព្រះអាទិត្យហើយ។ ទោះខ្ញុំខំប្រយ័ត្នប្រយែងដើរលើខ្នងប្រឡាយយ៉ាងណាក៏មិនអាចទប់ខ្លួនដើរលើផ្លូវខ្នងអណ្តើកនោះបានដែរ។ ខ្ញុំបានដួលបោកពោះលើផ្លូវធ្លាក់ចូលទៅក្នុងប្រឡាយ។ ខ្ញុំខំកាយខំលូនដើម្បីរកទីទួលសម្រាកឲ្យផុតពីទឹកដែលដក់ក្នុងប្រឡាយនោះ។ ពោះរបស់ខ្ញុំកាន់តែឈឺឡើងៗ មេយក៏កាន់តែងងឹតទៅៗ ចំណែកឯខ្លែងស្រាក់ ចាប់ផ្តើមយំបន្លឺសំឡេងឡើងរំពងពេញព្រៃហាក់ផ្តល់សញ្ញាអ្វីមួយទៅកាន់បរិវារ។ ថ្ងៃនោះ ខ្ញុំធ្វើការធ្ងន់ពេញមួយថ្ងៃមិនបានសម្រាកទាល់តែសោះ តើមានកម្លាំងឯណានឹងបង្កើតកូន? រួចខ្ញុំប្រឹងប្រែងយ៉ាងឈឺចាប់ដើម្បីឲ្យឆ្លងផុតការបង្កើតកូនរបស់ខ្ញុំបានដោយសុវត្ថិភាព។ ភ្លាមៗនោះ សំឡេងរបស់ទារកយំកងរំពងពេញព្រៃ ខ្ញុំបានបង្ហាញស្នាមញញឹមទាំងទឹកភ្នែកហូរ រួចត្របកភ្នែកទាំងគូរបស់ខ្ញុំចាប់ផ្តើមបិទសន្សឹមៗ។

ស្នូរជើងថ្មមៗដើរលើខ្នងប្រឡាយយឺតៗ ភ្នែករវេរវាសហាក់ភ័យខ្លាចនឹងរឿងអ្វីមួយ។ បុរសនោះឈ្មោះ ណារ៉ុង ដែលមានរាងខ្ពស់ ធ្ងឹងធំ និងមាឌស្តើងបន្តិច ព្រោះតែគ្មានអាហារហូបគ្រប់គ្រាន់។ សូរសំឡេងក្មេងយំ បានជាស់សតិរបស់ ណារ៉ុង ឲ្យនៅមិនស្ងប់ ចង់ដឹងថាតើជាសំឡេងពិត ឬជាសំឡេងបោកប្រាស់សម្រាប់ផ្តល់ជាសញ្ញាអ្វីមួយ? ណារ៉ុង ដើរលបៗចូលកាន់តែជិត ដើម្បីស្រាយចម្ងល់នោះ។ អូ!ក្មេងតើ។ ចុះកូននរណាគេមកនៅក្នុងប្រឡាយនេះ? ណារ៉ុង មានចិត្តស្ទាក់ស្ទើរមិនចង់ជួយព្រោះខ្លាចនាំទុក្ខដល់ខ្លួន ប៉ុន្តែដោយចិត្តសប្បុរស ណារ៉ុង បានប្រថុយដើរចូលទៅជួយវិញ។

ណារ៉ុង ស្រឡាំងកាំងស្ទើររលត់វិញ្ញាណ។ ទឹកភ្នែកចាប់បើផ្តើមហូរ រួចយកដៃលើកយកកូនចងក្នុងថ្នក់ក្រមាក្រពត់ទៅក្រោយខ្នង។ បន្ទាប់មក ណារ៉ុង លើកត្រកងករិយាដែលកំពុងដេកដួលយកទៅខ្ទមកម្សត់។ ណារ៉ុង ដាក់ប្រពន្ធ

ថ្នមៗឲ្យគេង រួច ណារ៉ុង បានដាក់បបរសណ្តែតបាយជាមួយនឹងស្ករគ្នោត ដែលគាត់បានលួចយកមកទុកឲ្យប្រពន្ធរបស់គាត់។ ថ្ងៃនោះ នរៈ កូនរបស់ខ្ញុំ បានលួចរត់ពីកងឈ្លបមកផ្ទះដែរ។ បបរសណ្តែកនោះហើយ ដែលធ្វើឲ្យខ្ញុំមានជីវិតរហូតមកដល់សព្វថ្ងៃនេះ។ គ្រួសាររបស់ខ្ញុំនៅជុំគ្នា មានខ្ញុំ បងរ៉ុង ម៉ែពុករបស់ខ្ញុំ នឹងកូនច្បងរបស់ខ្ញុំឈ្មោះ នរៈ។ ពួកយើងបរិភោគបបរសណ្តែកនោះយ៉ាងរីករាយប្រកបដោយសុភមង្គល។ ថ្ងៃនេះហើយជាថ្ងៃដែលខ្ញុំមានសេចក្តីសុខបំផុតនៅក្នុងរបបខ្មែរក្រហម។ ប្តីរបស់ខ្ញុំ បានដាក់ឲ្យខ្ញុំកើយលើភ្លៅរបស់គាត់ រួចគាត់អង្អែលសក់ខ្ញុំថ្នមៗពោរពេញដោយក្តីស្រលាញ់។ ទឹកភ្នែកខ្ញុំរំភើបហូរស្រក់ដោយមិនដឹងខ្លួន។ ស្វាមីរបស់ខ្ញុំបង្អួសត្រដុសដោយខ្នង់ច្រមុះរបស់គាត់ ដើម្បីជូតទឹកភ្នែកឲ្យខ្ញុំកុំឲ្យបន្តស្រក់ទៀត។

ការជួបជុំក្រុមគ្រួសារ គឺជាសេចក្តីសុខមិនអាចបំភ្លេចបាន។ ការព្រាត់ប្រាស់ជាអវិចីជីវិតដែលមនុស្សគ្រប់គ្នាមិនចង់ឆ្លងកាត់។ យប់នេះ គឺជាយប់ដែលខ្ញុំមិនចង់ឲ្យភ្លឺ។ ពន្លឺព្រះអាទិត្យហាក់ចូលមកជ្រុតបំផ្លាញសុភមង្គលរបស់ខ្ញុំ។ នរៈ កូនរបស់ខ្ញុំ បានទៅកន្លែងធ្វើការងារវិញតាំងពីព្រហាមស្រាងៗម្ល៉េះ ព្រោះខ្លាចអង្គការចាប់បានថ្កោលទោសអួសដំណើរ។ ប្តីរបស់ខ្ញុំ នៅជួយបម្រើខ្ញុំមួយព្រឹកទៀតមុននឹងគាត់ចាកចេញទៅធ្វើការងារនៅកន្លែងគាត់វិញនៅឯថ្នាក់តំបន់។ ថ្ងៃនោះស្រាប់តែមានសំឡេងបើកទ្វារយ៉ាងខ្លាំង ធ្វើឲ្យខ្ញុំរំភើបចិត្ត ព្រោះខ្ញុំគិតក្នុងចិត្តថាបងណារ៉ុង នឹងយកបបរឲ្យខ្ញុំ។ ប៉ុន្តែអ្វីៗខុសពីការរំពឹងទុករបស់ខ្ញុំ។ ពេលនោះស្រាប់តែមេកងស្រែកសួរយ៉ាងសន្ធាប់ថា «ឯណាប្តីនាងឯង?»។ ខ្ញុំកន្ត្រាក់ភ្ញាក់ឡើងក្រញាងដូចរន្ទះបាញ់ប្រាំបីទិសអីចឹង។ ខ្ញុំឆ្លើយឡើងទាំងញ័រមាត់ទទ្រើតថា «ខ្ញុំមិនដឹងទេ សមមិត្តបង»។ មេកងទាំង៣នាក់ ដើរឆែកឆេរគ្រប់កន្លែង ប៉ុន្តែនៅតែរកប្តីរបស់ខ្ញុំមិនឃើញ ទើបមេកងរបូតមាត់សួរមកខ្ញុំថា «នាងកើតកូនហើយ? ម៉េចមិនទៅពេទ្យឲ្យគេជួយបង្កើត?» ខ្ញុំឆ្លើយតបទៅមេកងវិញថា «មិនអីទេព្រោះកូនខ្ញុំកើតដូចមិនពិបាកដែរ»។ ខ្ញុំហាក់ធូរទ្រូងបន្តិចនៅពេលដែលមេកងរកចាប់ប្តីរបស់ខ្ញុំមិនបាន។

ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមសម្លាប់

ខ្ញុំកំពុងតែភ្លឺកក្នុងពិភពវេរវាយ ត្រូវបានកាត់ផ្តាច់ចោលនៅពេលដែលមានសំឡេងត្រហេបត្រហបហាក់ភ័យជ្រួលច្របល់មកពញ្ជាក់អារម្មណ៍របស់ខ្ញុំ ដោយមានគេមកប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំត្រូវបានអង្គការផ្លាស់ប្តូរឲ្យទៅកាច់ពោតនៅឯព្រៃរនាមវិញ ព្រោះកូនរបស់ខ្ញុំ បានប្រាប់អង្គការថា ប្តីរបស់ខ្ញុំមកលេងផ្ទះដោយយកសណ្តែកនិងស្ករត្នោតជាច្រើនឲ្យយើងហូបទៀត។ ពាក្យមួយឃ្លានោះហាក់ដូចជាមានកាំបិតមកចាក់ចំបេះដូងខ្ញុំអីចឹង។ ខ្ញុំគ្មានអ្វីក្រៅពីទឹកភ្នែកបញ្ជាក់ពីភាពឈឺចាប់របស់ខ្ញុំទេ។ កូនរបស់ខ្ញុំប្រៀបដូច ក្រជាសសមួយផ្នាំង មិនចេះកូតកុហកនោះទេ។ ក្មេងគឺជាមនុស្សស្មោះត្រង់ណាស់ ខ្ញុំមិនអាចស្តីបន្ទោសឬដាក់កំហុសលើកូនរបស់ខ្ញុំបានទេ។ ប្តីរបស់ខ្ញុំទៅបានសុខ មានតែអ្នកនៅរស់ទេ ទើបទទួលទុក្ខបន្តទៀត។ កម្សួលចិត្តគិតវិលវល់តែម្នាក់ឯងរបស់ខ្ញុំ បានឈប់នឹងថ្កល់ពេលមានសំឡេងមកប៉ះត្រចៀករបស់ខ្ញុំថា «នាងត្រូវទៅធ្វើការវិញនៅស្អែកនេះ។ កូនរបស់នាងដាក់នៅក្នុងកុមារដ្ឋាន ពេលសម្រាកពីការងារចាំនាងមកបំបៅកូនចុះ។ មនុស្សស្រីគ្មានប្រយោជន៍បោចចាបស្អីទេ។ ងាកកូន ងាកកើត ងាប់កប់បង្ហើយទៅ អង្គការមិនខាតកម្លាំងពលកម្មច្រើន»។

ម៉ែពុកជាចំណែកអាហារ

ម៉ែពុករបស់ខ្ញុំ ជរាណាស់ទៅហើយ។ គាត់មិនអាចធ្វើការងារអ្វីបានក្រៅពីដេកនៅលើកន្ទេលស្លឹកត្នោតនោះទេ។ ពេលពួកគាត់ធ្វើការងារមិនកើត ពួកគាត់ក៏គ្មានរបបអាហារប្រចាំថ្ងៃដែរ។ យប់ជ្រៅទៅហើយ ព្រោះតែខ្ញុំរវល់ទៅប្រជុំជាមួយមេកង។ ពេលប្រជុំចប់ ខ្ញុំស្រូតដំណើរមកខ្ទមកម្សត់របស់ខ្ញុំយ៉ាងលឿន។ ខ្ទមស្លឹកកម្សត់ហាក់ឈរធ្មឹងមិនចង់ស្តី។ បរិវេណខាងក្នុងងងឹតសូន្យរកពន្លឺបន្តិចគ្មាន។ ខ្ញុំខំស្រែកហៅម៉ែពុកយ៉ាងខ្លាំង តែគ្មានសំឡេងឆ្លើយតបមកវិញសោះ។ ពួកគាត់សម្រាកនៅលើគ្រែឫស្សី ហើយប្រឹងនិយាយមួបៗថា «លាក! លាកកូន! កូនមកហើយមែនទេ។ ម៉ែពុកឃ្លានណាស់។ គេមិនឲ្យម៉ែពុកហូបទេ ព្រោះយើងមិនអាចធ្វើការឲ្យគេ»។ ឮដូច្នោះហើយ ខ្ញុំអាណិតពួកគាត់ស្ទើរខ្លោចចិត្ត។ ខ្ញុំបានយក

បាយ ចំណែកខ្ញុំ ដែលខ្ញុំរំលែកទុកឲ្យគាត់ហូប។ បាយមួយកូនដុំតូចឲ្យពួកគាត់ហូបឆ្អែតម្តេចនឹងកើតទៅ។ ម៉ែពុករបស់ខ្ញុំជាមនុស្សចាស់ ហើយយំទារបាយហូបដូចកូនក្មេងតាមចិត្តគាត់ចង់ខ្លាំងៗមកកាន់ខ្ញុំថា «ម៉ែឃ្លានណាស់ ប្រសិនបើបានស្ករត្នោតនិងសណ្តែកមកបបរដូចកាលអាអន្ធិតបបរឲ្យហូបនោះ ប្រហែលធ្លាញ់ហើយ ម្ល៉ះសមពុកម៉ែអាចមានកម្លាំងបន្តរស់ទៅមុខទៀតបាន។ ហឺ! មិនអាចទេ ទ្រាំតាមកម្មរបស់យើងចុះពុកវា»។ ទឹកភ្នែករបស់ខ្ញុំទប់ពុំបានពេលឮម្តាយខ្ញុំនិយាយដូច្នោះ។ ណាចិត្តនឹកប្តីផង ណាខ្លោចចិត្តអាណិតម៉ែពុកផង។ ឱ! នេះហើយជាជីវិតនរកលោកិយរបស់ខ្ញុំ។

ខ្ញុំទៅលួចស្ករត្នោត

ព្រះចន្ទហាក់ខ្ជិលរះបំភ្លឺទ្វីបលោកដ៏ឃោរឃៅនេះ។ ចំណែកឯឆ្កែចចកលួលើយ។ ហាក់ប្រកួកហៅគ្នាដើម្បីស្វែងរកអាហារ។ អាសូរដល់រូបខ្ញុំ សរសៃខ្ចីខំដើរលបៗកាត់គំនរសាកសពស្អុយរលួយហាក់មិនខ្លាចរអើមឡើយ។ រីឯ ភ្នែករំពៃគ្រប់ទិសខ្លាចមានមនុស្សតាមទាន់។ នៅក្នុងឃ្លាំងជាក់ស្តែ មានសភាពស្ងាត់ជ្រងំ។ ខ្ញុំ ខំឆែកឆេរគ្រប់ទីកន្លែង ដើម្បីស្វែងរកស្ករត្នោត។ ពេលនោះខ្ញុំឈប់នៅមួយកន្លែង ហើយខំបាយកស្ករត្នោតពីពាងដោយប្រុងប្រយ័ត្នខ្លាចមានគេឮ។ ពេលខ្ញុំបានស្ករគួរសមដៃរហើយ ខ្ញុំដើរថយក្រោយលបៗដោយអារម្មណ៍ភ័យខ្លាចខ្លាំងណាស់។ ខ្ញុំភ័យផង ងងឹតផងក៏ទង្គិចនឹងខ្នះកូរស្ករធ្លាក់ឮសូរ តូង។ អ្នកល្បាតនៅទីនោះ បានរត់មកមើលយ៉ាងប្រញាប់។ ស្រាប់តែសំឡេងស្រែកប្រកបដោយអារម្មណ៍ខឹងបន្លឺឡើងថា «ហាងមករកអីទីនេះ?» ខ្ញុំ តបទៅគេទាំងញញីញញ័រថា «ខ្ញុំ! ខ្ញុំ! មករកស្ករ។ ម្តាយរបស់ខ្ញុំគាត់ឃ្លានណាស់។ សូមអស់លោកអភ័យទោសឲ្យខ្ញុំផង»។ ពួកគេតបមកខ្ញុំវិញថា «ព្រហើនណាស់នាង ហ៊ានក្បត់អង្គការ។ នាងដឹងទេថានឹងត្រូវស្លាប់ទេ»។ ឮដូច្នោះ ខ្ញុំប្រញាប់អង្វរគេថា «សូមលោកអាណិតខ្ញុំផង ខ្ញុំខ្លាចហើយ ខ្ញុំវាងហើយ»។ ឮខ្ញុំនិយាយអង្វរដូច្នោះ ពួកគេស្រាប់តែសើចចំអកឲ្យខ្ញុំ ហើយនិយាយថា «ទោសក្បត់សមូហភាពរបស់នាងសមតែស្លាប់ មុននឹងស្លាប់ម្រាមដៃរបស់នាងសមតែជាប់ដែរ ទុកជា

មេរៀននៃការហ៊ានល្មើសនេះ»។ ពួកគេ បានវាយខ្ញុំឲ្យសន្លប់ រួចយកបាវគ្របមុខ ខ្ញុំ ហើយចងជើងជាប់គ្នា និងចងដៃក្រពត់ទៅក្រោយខ្នង។ ក្នុងចំណោមពួកគេ មានម្នាក់ចាប់ដៃរបស់ខ្ញុំផ្ចាប់នឹងគល់ឈើ ហើយម្នាក់ទៀតទាញកាំបិតឡើង ភ្នែតសស្ងាចត្រៀមប្រហារ។ ពួកគេរៀបនឹងកាត់ម្រាមដៃរបស់ខ្ញុំទៅហើយ ស្រាប់តែ មានក្មេងម្នាក់តូចជាងគេ បានមកដល់។ បុរសម្នាក់កាន់កំបិតនោះ បានហុចកាំបិតឲ្យទៅក្មេងតូចដែលទើបមកដល់ ដើម្បីបង្រៀនឲ្យក្មេងនោះមាន ភាពក្លាហានហ៊ានកម្ចាត់ខ្មាំងសត្រូវដូនអង្គការ។ ក្មេងនោះយំផង ភ័យផង ដៃញ័រទ្រើត ហាក់មិនហ៊ានកាត់ម្រាមដៃរបស់ខ្ញុំទាល់តែសោះ។ ពួកអមនុស្សធម៌ នោះកាន់តែបង្ខំឲ្យក្មេងនោះធ្វើតាមខ្លួន ហើយបើមិនធ្វើតាមបញ្ជារបស់ពួកគេទេ ជីវិតក្មេងនោះក៏គេនឹងសម្លាប់ដែរ។ ក្មេងតូច មិនអាចប្រកែកតបតបានក៏ធ្វើទាំង បង្ខំចិត្ត ដោយមិនដឹងថាខ្ញុំជានរណានោះទេ ព្រោះឈ្លបទាំងនោះបានឃ្លុំមុខ របស់ខ្ញុំជិត ហើយមេយក៏ងងឹតដែរ។ ចប់បេសកកម្មរួច ក្មេងតូច ក៏រត់ចេញពីទី នោះទៅទាំងទឹកភ្នែកហូររហាម ព្រោះដៃដ៏ល្អស្អាតរបស់គេបានប្រលាក់ឈាម ទៅហើយ។ កុមារនោះគឺជា នរៈ កូនប្រុសរបស់ខ្ញុំ។ ថ្ងៃនោះ ខ្ញុំគ្មានសង្ឃឹមថា អាចតស៊ូនឹងជីវិតរបស់ខ្ញុំបានទេ។ ពួកគេ បានច្រកខ្ញុំចូលទៅក្នុងបាវ រួចអូសខ្ញុំ យកទៅចោលក្នុងរណ្តៅសាកសព។

រស់ឡើងវិញក្នុងគំនរសាកសព

កន្លងផុតមួយយប់មួយថ្ងៃ សាកសពនៅក្នុងបាវ ដែលពួកគេមិនចងមាត់ ហាក់កម្រើកឡើងវិញ។ ខ្ញុំខំប្រឹងស្រវាស្រទេញងើបចេញពីគំនរសាកសពទាំង ឈឺមុខរបួស។ ខ្ញុំងើបផុតពីមាត់រណ្តៅ ព្រះសុរិយាក៏ទន់ទាបរៀបអស្តង្គតទៅ ហើយ។ ខ្ញុំដើរផង រត់ផង យំផង ដើម្បីទៅរកម៉ែពុករបស់ខ្ញុំ។ ម៉ែពុករបស់ខ្ញុំ មានវ័យចាស់ទៅហើយ ណាមួយពួកគាត់បានជាច់អាហារពីរបីថ្ងៃទៀត។ ដូច្នេះ ពួកគាត់មិនអាចទ្រាំទ្របានក៏លាចាកលោកទាំងពីរអ្នកព្រមគ្នាទៅ។

ពេលបានដំណឹងថាម៉ែពុករបស់ខ្ញុំបានចាកចេញទៅគ្មានថ្ងៃវិលត្រលប់ មកវិញនោះ ខ្ញុំ បានទៅយកកូនតូចរបស់ខ្ញុំពីកុមារដ្ឋាន ហើយឱបកូនយំលើខ្នង

ប្រឡាយដែលខ្វែងខ្វាត់។ ពេលនោះ ខ្ញុំខ្សោយទៅៗ ក៏សន្លប់ស្តូកស្តឹងនៅលើខ្នងប្រឡាយនោះ ចំណែកកូនរបស់ខ្ញុំដែលដាច់ដោះជាច្រើនថ្ងៃ ក៏ចេះតែខំប្រឹងបឺតជញ្ជក់មិនដឹងអ្វីឡើយ។

យប់១៥រោចហាក់គ្មានរស្មី ធ្វើឲ្យភពផែនដីទៅជាងងឹតអន្ធការ។ ជីវិតរស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែគ្មានសេរី ហាក់ដូចអស់ន័យថាបានសាន្តត្រាណ។ សិទ្ធិរស់រាន សិទ្ធិដើរហើរ សិទ្ធិក្នុងការបញ្ចេញមតិត្រូវបានកប់ជ្រៅនៅក្នុងក្រឌីបេះដូងរបស់អង្គការ។ រាត្រីដ៏ស្ងប់ស្ងាត់នោះ សន្សើមក៏ចាប់ផ្តើមធ្លាក់។ យូរៗម្តង សត្វលលកខ្មោចបន្លឺសំឡេងគួរឲ្យខ្លាច។ រាត្រីព្រាត់ខែធ្វើឲ្យផ្ទៃមេឃអួរអាប់ ទឹកភ្នែកជន់ជោរហូរកាត់ប្រឡាយ ហូរទៅសែនឆ្ងាយឯនាយជើងមេឃ។

ចប់

៣៤

រឿងរលកជីវិត

អ្នកនិពន្ធ ៖ លី ឡាវ៉ុន

៣៤ ~ រឿង រលកជីវិត



នៅក្នុងខែមេសា ឆ្នាំ១៩៧០ ភូមិឈើទាល ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ បានធ្លាក់ នៅក្រោមអំណាចគ្រប់គ្រងរបស់កងទ័ពរំដោះជាតិឬ ហៅថាកងទ័ពខ្មែរក្រហមទៅហើយ។ រហូតដល់ឆ្នាំ១៩៧៤ ប្រជាជននៅទីនោះ កាន់តែរស់នៅក្នុងភាពតានតឹងនិងភ័យខ្លាចនូវអំណាចគ្រប់គ្រងរបស់ខ្មែរក្រហម ព្រោះ ខ្មែរក្រហម បានចាប់កំហុសអ្នកដែលហ៊ានប្រឆាំង យកទៅឃុំឃាំង និងបាត់ខ្លួនជាបន្តបន្ទាប់។ គ្រួសារ ដែលមានកូន ឬប្តីប្រពន្ធ បម្រើឲ្យឬមានទំនាក់ទំនងជាមួយអ្នកធ្វើការឲ្យរដ្ឋាភិបាល លន់ នល់ ត្រូវខ្មែរក្រហមជម្លៀសចេញឲ្យទៅរស់នៅជនបទឆ្ងាយដាច់ស្រយាល ដូចជានៅលើទឹកដីដែលងាយរងគ្រោះនឹងជំងឺគ្រុនចាញ់ជាដើម។

ពេលនោះ ការបំពាក់បំប៉នមនោគមវិជ្ជា បានអូសទាញ យុវជន យុវនារី ជាច្រើនឲ្យចូលរួមក្នុងជួរបដិវត្តន៍។ ខ្មែរក្រហម ឲ្យយុវជន យុវនារី កុមារនិងកុមារី បង្កើតជាក្រុមតាមភូមិ ដើម្បីបង្កើតរបាំច្រៀងរាំ ច្រៀងសរសើរតែគុណបដិវត្តន៍ និងកំទេចខ្មាំងសម្រាប់អូសទាញប្រជាជនបន្ថែមទៀតឲ្យចូលបម្រើបដិវត្តន៍ ។

ផ្នែកអប់រំ សុខាភិបាល ពុទ្ធសាសនា បានធ្លាក់ចុះនិងត្រូវលុបបំបាត់។ ទីផ្សារ ស្ងាត់ជ្រងំ សាលារៀននិងមន្ទីរពេទ្យបិទទ្វារ ព្រះសង្ឃត្រូវខ្មែរក្រហមឲ្យទៅយាមខ្មាំងជាមួយនឹងប្រជាជនដទៃទៀត។ ប្រជាជនគ្មានសេរីភាពក្នុងការធ្វើដំណើរដោយខ្លួនឯងទៀតទេ។

ម្តាយឪពុករបស់ខ្ញុំ បាននាំចៅប្រុសកំព្រាទៅកាប់ព្រៃអូរសាវ៉ាយដើម្បីសង់លំនៅឋាន និងដាំដំណាំចិញ្ចឹមជីវិត។ ប្រជាជនជាច្រើនគ្រួសារ បានទៅកាប់ព្រៃ

សាងសង់លំនៅឋាននៅព្រៃអូរសោរ៉ាយដែរ ព្រោះយើងអស់សង្ឃឹមពីជំនួញជួញដូរទៀតហើយ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៤ ក្មួយប្រុសរបស់ខ្ញុំ ជាយុវជនពេញវ័យ ត្រូវខ្មែរក្រហមតម្រូវឲ្យទៅធ្វើការនៅការដ្ឋានព្រៃក្បាលដំរី។ ពេលនោះ ប្រជាជនក្នុងភូមិ ចេះតែមានការភ័យខ្លាច ព្រោះមានដំណឹងពីអ្នកស្រុកថា ទាហាន លន់ នល់ ចេញវាយលុកកៀងយកប្រជាជនទៅនៅខាង លន់ នល់ ហើយប្រជាជនដែលនៅសេសសល់ខ្លះ ខ្មែររំដោះ បានជម្លៀសឲ្យចេញទៅឆ្ងាយពីស្រុកភូមិហើយ ព្រោះមានយន្តហោះមកទម្លាក់គ្រាប់បែក ឆេះផ្ទះសម្បែងអស់គ្មានសល់ ប្រជាជនរស់នៅលំបាកវេទនាណាស់។

ចាកចេញពីផ្ទះសម្បែង

ក្តីព្រួយភ័យរបស់ប្រជាជន បានក្លាយទៅជាការពិត។ ម៉ោងប្រហែល៥ល្ងាច ពួកមិត្តៗបានដើរ មកប្រាប់គ្រប់ៗផ្ទះថា ឲ្យរៀបចំអីវ៉ាន់ ចាកចេញពីផ្ទះជាបន្ទាន់ និងមានការវាយតគ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហមហើយ។ ឮដំណឹងនេះភ្លាម ខ្ញុំស្តុតរន្ធត់ណាស់។ ខ្ញុំឱបកូនយំ។ ពេលនោះកូនប្រុសរបស់ខ្ញុំ ទើបតែមានអាយុ១១ខែតែប៉ុណ្ណោះ។ ឱកូនអើយ! យើងខាននៅផ្ទះយើងទៀតហើយ។ យើងមិនដឹងជាទៅជ្រកកោននៅទីណានោះទេ។ ប្តីរបស់ខ្ញុំបានឃាត់ខ្ញុំកុំឲ្យយំ។ គាត់ឲ្យខ្ញុំខំតែរៀបចំអីវ៉ាន់សំខាន់ៗ ដែលអាចយកទៅរួចជាពិសេសគ្រឿងឧបភោគ កន្ទេល មុង ភួយ ខ្នើយ ថ្នាំពេទ្យ និងប្រាក់កាសជាដើម។ បងស្រី បងថ្លៃ និងបងប្រុសរបស់ខ្ញុំ បានមកដល់។ ពួកគាត់ បានពិភាក្សាគ្នាគិតរារែកមិនចង់ចាកចេញទៅទេ ចង់រង់ចាំសិន។ ខ្ញុំយល់ថា បើចង់ទៅណាត្រូវតែប្រញាប់ទៅយកឪពុកម្តាយរបស់យើងមកនៅជុំគ្នា ព្រមទាំងក្មួយផង មិនត្រូវទៅចោលគ្នាទេ។ ខ្ញុំដឹងថា ពេលមានសង្គ្រាមដូច្នេះ ប្រសិនបើយើងបែកគ្នា យើងច្បាស់ជាបែករហូតហើយ ព្រោះម្តាយឪពុករបស់ខ្ញុំចាស់ជរាផង។ យើងកំពុងតែពិភាក្សាគ្នា ស្រាប់តែពួកមិត្ត បានមកបង្ខំមិនឲ្យយើងរារង់ទេ។ ខ្ញុំបាននាំគ្នាលើកអីវ៉ាន់ដាក់រទេះគោតែមួយ ជាមួយបងស្រីរបស់ខ្ញុំ។ ខ្ញុំមានកូនតែមួយទេ ប៉ុន្តែបងប្រុស និងបងស្រីរបស់ ខ្ញុំ មានកូនច្រើន។

នៅតាមផ្លូវ កងទ័ពខ្មែរក្រហម បានចង្អុលឲ្យយើងចាកចេញទៅឲ្យឆ្ងាយពីស្រុកសំដៅទៅនៅជិតព្រៃខាងជើង។ ពួកយើងបានធ្វើដំណើរទៅដល់ចុងភូមិ ហើយបានទៅជួបជុំគ្នា ដែលមានរទេះគោជិត១០០រទេះ ក៏នាំគ្នាសម្រាកនៅក្នុងទីនោះ។ បុរសៗបានពិភាក្សាយល់ស្របគ្នារាវង់ ដោយមិនចេញទៅណាទៀតទេ។ លុះដល់ជិតភ្លឺ ឮសូរសំឡេងគ្រាប់កាំភ្លើងបាញ់តបតគ្នាបន្តិច ក៏មានគ្រាប់បែកធ្លាងមកផ្ទួនៗ។ កងទ័ពខ្មែរក្រហម បានដេញពួកយើងទៀតឲ្យចេញទៅ ព្រោះខ្លាចមានគ្រោះថ្នាក់។ ពួកយើង បានចាកចេញពីទីនោះគ្រប់ៗគ្នា។ បងប្អូនរបស់ខ្ញុំទាំងបីគ្រួសារ បានយល់ស្របធ្វើដំណើរទៅភូមិអូរសារ៉ាយតែម្តង។ នៅពេលទៅដល់ភូមិ ម្តាយឪពុករបស់ខ្ញុំ ហាក់បីដូចជាត្រេកអរលាយឡំនឹងភាពភ័យព្រួយផង ប៉ុន្តែក្រោយមក ពួកគាត់ធូរចិត្តវិញ បន្ទាប់ពីមានប្រជាជនជាច្រើនបានបររទេះមកដល់ភូមិជាហូរហែ។ ប្រជាជនទាំងនោះបានប្រាប់យើងថា យន្តហោះបានទម្លាក់គ្រាប់បែកឆេះផ្ទះអស់មួយជួរនៅភូមិថ្នល់ចាស់ខាងជើង ហើយផ្ទះខ្លះទាហាន បើកទ្វារចូលយករបស់មានតម្លៃអស់។

បន្ទាប់ពីពួកយើង បានស្នាក់នៅជុំគ្នាទាំងបីគ្រួសារបានប្រហែល១០ថ្ងៃ កងទ័ពខ្មែរក្រហម បានប្រាប់គ្រប់គ្រួសារថាឲ្យទៅកាប់ព្រៃសង់ផ្ទះស្នាក់នៅទីនោះជារៀងរហូតដោយមិនឲ្យទៅផ្ទះវិញទេ។ លុះយើងបានសង់ផ្ទះគ្រប់ៗគ្រួសារហើយ ព្រៃកប់រស់នោះ បានក្លាយទៅជាភូមិកប់រស់ ដែលមានប្រជាជនរស់នៅអ៊ូអរ។ យើងរស់នៅទីនោះបានប្រហែល១ខែ ថ្ងៃមួយប្តីរបស់ខ្ញុំ បានមកពីផ្ទះបងស្រីរបស់ខ្ញុំ ដោយមានទឹកមុខសែនស្រងូតស្រងាត់។ ខ្ញុំឃើញទឹកមុខគាត់យ៉ាងដូច្នោះក៏ចាប់ផ្តើមនិយាយសួរគាត់ថា «មានរឿង អីបង?»។ គាត់ឆ្លើយតបប្រាប់មកខ្ញុំវិញថា «គេចាប់បុរសៗ ប្រហែលជាង១០នាក់ មានស្រីចំណាស់ម្នាក់ដែរ សុទ្ធតែជាអ្នកភូមិយើងផង និងភូមិផ្សេងផង»។ ខ្ញុំបន្តសួរគាត់ថា «ចុះបងប្រុសរបស់ខ្ញុំ ដែលរស់នៅក្នុងភូមិលាបទងដែរនោះ។ ខ្ញុំគិតថា ប្រហែលជាកងទ័ពខ្មែរក្រហម រកឃើញថាប្រជាជនមានកំហុសអ្វីមួយហើយ បានចាប់ខ្លួនដូច្នេះ»។ ឮដូច្នោះប្តីរបស់ខ្ញុំនិយាយបន្តទៀតថា «កំហុសយើងមិនដឹងប្រាកដ

តែគ្មានអ្វីក្រៅពីគេចោទថាយើងចង់រត់ទៅនៅជាមួយខ្មាំងព្រោះគេដឹងច្បាស់ថា គេចាប់ពួកក្បាលម៉ាស៊ីន ឬ មេខ្លោងមុនយូរហើយ»។ ខ្ញុំដកដង្ហើមធំ ភ័យបារម្ភណាស់ ខ្លាចមានឈ្មោះសមាជិកគ្រួសាររបស់ខ្ញុំដែរ។

ខ្មែរក្រហមហៅប្តីខ្ញុំទៅមណ្ឌលកសាងខ្លួន

១ក្រោយមក ប្រហែលជាម៉ោង១រសៀល មានមិត្តម្នាក់ ដែលជាអ្នកគ្រប់គ្រងភូមិ បានមកប្រាប់ ដំណឹងដល់ប្តី និងបងថ្លៃរបស់ខ្ញុំ ឲ្យរៀបចំខ្លួននៅពេលល្ងាចនេះ ពួកគេនឹងនាំខ្លួនទៅមណ្ឌលកសាងខ្លួន។ ខ្ញុំរន្ធត់ចិត្តណាស់ នឹកឃើញថាយើងព្រាត់គ្នាហើយ។ ទឹកភ្នែករបស់ខ្ញុំហូរទល់មុខគ្នាជាមួយនឹងប្តីរបស់ខ្ញុំ ចំណែកឯកូនប្រុសរបស់ខ្ញុំ ក្រោកពីអង្រឹង មកស្រវាឱបឪពុក ហើយស្រែកហៅថា ប៉ាប៉ា។ ទុក្ខរបស់ខ្ញុំពីនាក់ប្តីប្រពន្ធគ្មានអ្វីប្រៀបបាន។ ពេលនោះ ប្តីរបស់ខ្ញុំលើកកូនពទៅអង្គុយលើអង្រឹងមើលមុខកូនទាំងទឹកភ្នែកហូររហាម ហើយពោលទៅកូនទាំងអួលដើមកថា «កូនប្រុសប៉ា! ប៉ាត្រូវចាកចោលកូននិងម៉ាក់នៅពេលល្ងាចនេះហើយ។ ប៉ាស្រលាញ់កូនណាស់កូនប្រុសប៉ា! មិនដឹងជាប៉ាបានវិលមកជួបមុខកូនវិញឬទេ? កូនខំញ៉ាំបាយណាកូន កូនឈប់អិមទឹកដោះម៉ាក់ទៅណាកូន»។ ខ្ញុំខំពង្រឹងជំហររបស់ខ្លួនឯង ហើយនិយាយជាមួយប្តីរបស់ខ្ញុំថា «បងតាមមើលទៅបងមានកំហុសស្រាលទេ បានជាគេមកឲ្យដឹងមុនអីចឹង។ ចំពោះអ្នកដែលចាប់ទៅមុនៗ គេគ្មានឲ្យដំណឹងទេ មកដល់ចាប់ចងតែម្តង។ បងសម្រួលអារម្មណ៍ ឲ្យបានធូរស្រួលណាបង។ បងនឹងបានត្រលប់វិលវិញ។ បងពង្រឹងស្មារតីដើម្បីថែទាំសុខភាព។ បងត្រូវពាក់អាវពីរជាន់ ខោពីរជាន់ អាវក្នុងខោក្នុងពីរជាន់ដូចគ្នា។ បងសម្រាន្តឲ្យលក់សិនទៅ ខ្ញុំទៅដាំបាយសិន»។

និយាយលើកទឹកចិត្តប្តីរួច ខ្ញុំយកកូនមកជិតខ្លួនរបស់ខ្ញុំនិងរៀបចំធ្វើម្ហូប។ ពេលនោះកូនប្រុសរបស់ខ្ញុំចេះដើរតេះតតៈ និងចេះហៅម៉ាក់ប៉ាទៅហើយ។ លុះម្ហូបអាហារចម្អិនរួចស្រេច ប្តីរបស់ខ្ញុំបានក្រោកទៅងូតទឹក រួចខ្ញុំហៅគាត់ឲ្យហូបបាយ។ គាត់ថាមិនឃ្លានទេ ហើយក៏ហូបមិនចូលដែរ។ គាត់និយាយប្រាប់ខ្ញុំជាបណ្តាំថា «អូនមានផ្ទៃពោះជិត២ខែមែន? តាមគំនិត និងក្តីអាណិតអូន

បងចង់ឲ្យអូនជំនុំបងប្អូនត្រូវរកវិធីណាកុំឲ្យសាច់មួយដុំនេះនៅតទៅទៀតបាន ព្រោះបងមើលទៅឃើញតែផ្លូវវេទនាពេកណាស់។ អូននិងកូនប្រហែលជាមិនរស់នៅទីកន្លែងនេះជិតម្តាយឪពុកយើងទៀតទេ មើលទៅប្រាកដគេនឹងជម្លៀសទៅឆ្ងាយហើយ។ កូនមានតែមួយរក្សាឲ្យល្អ កុំបណ្តោយឲ្យឈឺស្រាលទៅជាធ្ងន់។ ដល់វ័យកូនអាចទទួលការអប់រំបានអប់រំកូនឲ្យមានគំនិតល្អ បង្រៀនកូនឲ្យចេះលេខអក្សរ កុំឲ្យងងឹតអាប់អួ។ អូនត្រូវត្រៀមកុំប្រហែស បើទៅណាកុំឲ្យដាច់ស្បៀងអាហារ ថ្នាំព្យាបាល ព្រោះយើងបានទិញទុកការពារហើយ»។ ប្តីរបស់ខ្ញុំនិយាយត្រឹមនេះ ខ្ញុំបង្ខំគាត់ឲ្យហូបបាយ ទើបគាត់ហូប។ ខ្ញុំបង្ខំគាត់ឲ្យហូបឲ្យបានច្រើន ហើយគាត់និយាយទៀតថា «អូនត្រូវពង្រឹងជំហរឲ្យរឹងប៉ឹង ទៅនៅទីណារៀបខ្លួនឲ្យចុះសម្រុងនឹងគេ ចេះបត់បែនតាមកាលៈទេសៈ»។ និយាយដល់ត្រឹមនេះ គាត់ទៅស្លៀកពាក់តាមការណែនាំរបស់ខ្ញុំ ដោយមានហ៊ុមកក្រមារួចលើកកូនថើបបង្អួរទឹកភ្នែកម្តងទៀត ស្រាប់តែកងទ័ពខ្មែរក្រហមបានមកហៅឲ្យទៅជាមួយនឹងបងថ្លៃរបស់ខ្ញុំ។ គេបណ្តើរពួកគាត់ទៅតាមសម្រួល។ ប្តីរបស់ខ្ញុំងាកក្រោយមើលមកផ្ទះ។ ខ្ញុំស្ទុះចូលទៅក្នុងផ្ទះឱបកូនដោយទ្រូងអួលណែនស្ទើរបែកធ្លាយទៅហើយ។ ចំណែកបងស្រីរបស់ខ្ញុំវិញ ក៏មិនខុសអ្វីពីខ្ញុំដែរចំពោះក្តីទុក្ខបារម្ភទៅលើប្តីរបស់គាត់។ ម្តាយឪពុករបស់ខ្ញុំ បានឮដំណឹងនេះភ័យព្រួយចំពោះកូនអំពីសភាពការណានទៅរកក្តីនិរាសព្រាត់ប្រាស់នេះណាស់។

៣រាត្រីកន្លងទៅហើយដែលប្តីរបស់ខ្ញុំបានចាកចេញទៅ។ នៅក្នុងរាត្រីចន្ទពេញបូណ៌មី ប៉ុន្តែពុំមានឃើញពន្លឺព្រះចន្ទទេ ព្រោះផ្ទៃមេឃខ្មៅងងឹតនិងធ្លាក់ភ្លៀងយ៉ាងច្រើនលាយឡំនឹងផ្គរលាន់ស្រែកគ្រហឹមពេញមេឃ ផ្លេកបន្ទោរធ្វាត់ឆ្វែលគ្រប់ទិសទី។ ខ្ញុំនឹកខ្លោចចិត្តអាណិតប្តី អាណិតកូន អាណិតខ្លួន អាណិតម្តាយឪពុក ដែលជារាត្រូវទីពឹងកូន។ គិតសព្វគ្រប់ចង្កៀតទ្រូង ខ្ញុំបានស្រែកយំបន្ធូរអារម្មណ៍ យំបន្លំនឹងសំឡេងទឹកភ្លៀងដែលកំពុងតែស្រក់ចុះឆ្លើយឆ្លងជាមួយផ្គរ។ ក្នុងចិត្តរបស់ខ្ញុំនឹកថា តើថ្មើរនេះបងកំពុងធ្វើអី? តើគេឲ្យបងធ្វើអ្វី? តើបងនៅទីណា ហើយមានជម្រកសម្រាប់ជ្រកភ្លៀងដែរឬទេ?

បន់ព្រះអង្គនាគប្រក់

ខ្ញុំផ្តេកខ្លួនក្បែរកូនរបស់ខ្ញុំ បានធ្វើឲ្យខ្ញុំនឹកឃើញនូវរឿងមួយដែលខ្ញុំគិតថាជាទីពឹងពាក់ចុងក្រោយ។ ខ្ញុំបានយកធូបមកអុជនឹកឧទ្ទិសដល់ព្រះអង្គនាគប្រក់នៅក្នុងព្រះវិហារវត្តក្តីដើរ។ កន្លងមក ព្រះអង្គ ធ្លាប់មានបារមីស័ក្តិសិទ្ធិណាស់ជាទីពឹងរបស់ជនពុទ្ធបរិស័ទជាច្រើន។ ពេលនេះ ខ្ញុំអុជធូបដោយប្រណម្យរំឭកដល់ព្រះអង្គ សូមអង្វរព្រះអង្គឲ្យជួយការពាររក្សាប្តីរបស់ខ្ញុំ ឲ្យគេលើកលែងទោសឲ្យ និងកុំឲ្យគេធ្វើទារុណកម្ម ហើយឲ្យបានរស់មានជីវិតបានត្រលប់មកជួបជុំក្រុមគ្រួសារវិញ។ ខ្ញុំនឹងថ្វាយតង្វាយដល់ព្រះអង្គ។ បន្ទាប់ពីបន់ស្រន់រួច ខ្ញុំបានចូលដំណេក ប៉ុន្តែមិនទាន់គេងលក់ទាំងស្រុងនោះទេ ខ្ញុំស្រាប់តែឃើញរូបព្រះអង្គនាគប្រក់នៅចំពោះមុខអណ្តែតទាំងបល្ល័ង្កនៅនឹងកន្លែងញាប់ញ័ររំជួល ប៉ុន្តែមានឆព្វណ្ណរង្សីស្រអាប់។ ខ្ញុំដឹងខ្លួនច្បាស់ថា ព្រះអង្គនឹងទទួលបាននូវអ្វីដែលខ្ញុំបានបន់ដល់ព្រះអង្គ។ ខ្ញុំយល់ថា ព្រះអង្គនឹងយល់ពីទុក្ខសោករបស់ខ្ញុំមែន ហើយប្តីរបស់ខ្ញុំ អាចនៅមានជីវិតពិតប្រាកដ។ ៤៥ថ្ងៃក្រោយ បងថ្លៃរបស់ខ្ញុំ បានដោះលែងរួចពីការលត់ដំកសាងខ្លួនមកដល់ផ្ទះវិញ ខ្ញុំត្រេកអរណាស់។ ខ្ញុំសួរពីប្តីរបស់ខ្ញុំ។ គាត់ថាចាំគេលែងលើកក្រោយទៀត។ ឮដូច្នោះហើយខ្ញុំនឹកក្នុងចិត្តថា តើលើកក្រោយយូរប៉ុណ្ណាទៅ រួចខ្ញុំពកូនដើរត្រលប់មកផ្ទះដោយក្នុងទ្រូងល្អិតល្អែ។

ជម្លៀសប្រជាជនចេញពីភូមិ

កន្លងបានប្រហែល២ថ្ងៃ ខ្មែរក្រហម បានមកប្រាប់អំពីគោលដៅជម្លៀសប្រជាជនចេញពីភូមិក្នុងថ្ងៃស្អែក ហើយខ្មែរក្រហម ក៏បានមកឆែកឆេររើរកអីវ៉ាន់ដែលសំខាន់ៗ។ ពួកគេរឹបអូសយកអីវ៉ាន់ដោយគំរាម។ ក្រុមគ្រួសាររបស់ខ្ញុំនៅសល់អង្ករពោក់កណ្តាលធុង ប្រហុកអំបិល ស្ករត្នោត ចានឆ្នាំង កំសៀវទឹក និងថ្នាំពេទ្យបានខ្លះដែរ។ ពេលនោះ ចំនួនមនុស្សប្រហែល៣០គ្រួសារ ត្រូវបានជម្លៀសជាមួយខ្ញុំ។ យើងធ្វើដំណើររយៈពេលមួយយប់មួយថ្ងៃទើបដល់ទិសដៅ។

បងប្អូនរបស់ខ្ញុំទាំងបីគ្រួសារត្រូវជម្លៀសក្នុងដំណើរជាមួយគ្នា។ នៅពេលធ្វើដំណើរជិតដល់ភូមិ សមមិត្តដែលនាំយើងទៅ បានជួបជាមួយនឹងសមមិត្ត២នាក់

ផ្សេងទៀត។ សមមិត្ត២នាក់នោះបាននិយាយឲ្យយើងដឹងថាប្រហែលជា៥ថ្ងៃទៀត អង្គការនឹងដោះលែងអ្នកជាប់ទោសឲ្យមកជុំគ្រួសារវិញ។ ឮដូច្នោះ ពួកយើងនឹកត្រេកអរក្នុងចិត្តណាស់ទោះបីជាយើងរសាត់ទៅដល់ទីណាក៏ដោយ ឲ្យតែយើងបាននៅជួបជុំរួមសុខរួមទុក្ខជាមួយគ្នាក៏អស់ចិត្តដែរ។

គ្រានោះ អង្គការបានយកពួកយើងទៅផ្ញើតាមភូមិចំនួន២ គឺ ភូមិអូរអង្គរ និងភូមិកោះណូ។ ខ្ញុំនិងបងរបស់ខ្ញុំ បានទៅនៅភូមិអូរអង្គរ។ គេធ្វើរោងវែងឲ្យយើងស្នាក់នៅជាច្រើនគ្រួសារចូលគ្នា ហើយក៏មានប្រជាជនខ្លះរស់នៅលើផ្ទះអ្នកភូមិដែរ។ ប្រជាជនដែលមកនៅក្នុងភូមិនេះមុនសុទ្ធតែញាតិមិត្តធ្លាប់ស្គាល់គ្នា។ ប្រជាជនដែលមករស់នៅទីនេះមុន៣ខែនៅសល់តែស្ត្រីៗនិងកុមារទេ ចំណែកឯបុរសៗ ត្រូវអង្គការកំទេចចោលអស់តាំងពីពេលមកដល់ដំបូងម្ល៉េះ។ ប្រជាជននៅក្នុងភូមិអូរអង្គរ រស់នៅរួម ហូបបាយរួម។ ដំបូងៗ យើងមានបាយហូប ប៉ុន្តែក្រោយមក ដោយជិតអស់ស្រូវ ទើបយើងប្តូរមកហូបបបរវិញ។

ដំណឹងពីប្តីរបស់ខ្ញុំ

ថ្ងៃនេះ ខ្ញុំបានមករស់នៅក្នុងទឹកដីអូរអង្គរបាន៦ថ្ងៃ ហើយខ្ញុំនៅតែចងចាំសម្តីរបស់សមមិត្តដែលនិយាយថានឹងមានលែងអ្នកទោសឲ្យមករស់នៅជួបជុំគ្រួសារវិញ។ រាល់ពេលល្ងាចមុនថ្ងៃជិតលិច ខ្ញុំតែងតែពកូនទៅអង្គុយរង់ចាំមើលផ្លូវប្តី។ ខ្ញុំរង់ចាំមើលផ្លូវប្តីរបស់ខ្ញុំពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុន្តែនៅតែមិនឃើញគាត់ត្រលប់មកវិញដូចសម្តីរបស់សមមិត្តបាននិយាយសោះ។ ជីវិតរបស់ខ្ញុំ អាណោចអាធ័មណាស់។ យប់ឡើងអង្គុយបំពេរកូនម្នាក់ឯង ទឹកភ្នែកហូរឥតឈប់ ព្រោះយំអាណិតកូន អាណិតប្តី និងក្រុមគ្រួសារ។ ខ្ញុំតែងតែនឹកដល់សុខទុក្ខរបស់ម្តាយឪពុកជារបស់ខ្ញុំមិនដឹងជាយ៉ាងណាបើយើងជាច់ខ្សែរយៈអស់ហើយ។

ថ្ងៃមួយ ខ្ញុំបានជួបជាមួយបុរសអ្នកស្រុកជាមួយគ្នាម្នាក់ដែលជាប់ទោសតំណាលគ្នាជាមួយនឹងប្តីរបស់ខ្ញុំ។ អង្គការបានឲ្យគាត់ទៅធ្វើការនៅការដ្ឋានក្បែរភូមិរបស់ខ្ញុំ ហើយបានមកសម្រាកនៅភូមិ។ នារីៗ ដែលមានប្តីជាប់ទោស បាននាំគ្នាទៅសួរដំណឹងប្តីគ្រប់គ្នា។ បុរសនោះឈ្មោះ នី សែល បានឆ្លើយប្រាប់យើងថាគាត់មិនដឹងទេ ព្រោះគាត់បានរួចទោសមកយូរដែរមកហើយ។ ដោយឃើញ

ទឹកមុខរបស់ខ្ញុំអស់សង្ឃឹម គាត់បានប្រាប់ខ្ញុំថា កាលគាត់នៅទីនោះ គាត់បានឃើញ ម៉ែង ហ៊ីរ (ប្តីរបស់ខ្ញុំ) តែមិនអីទេ ម៉ែង ហ៊ីរ មិនកើតអីទេ។ ខ្ញុំដឹងក្នុងចិត្តថា គាត់កុហកខ្ញុំ។ ខ្ញុំអស់សង្ឃឹមណាស់ ខ្ញុំយំឡើងស្ងួតទឹកភ្នែកអស់ទៅហើយ។ ក្នុងរយៈពេល៣ខែនេះ ខ្ញុំគិតរកទៀនធូបអុជឧទ្ទិសដល់ប្តី ព្រោះខ្ញុំប្រាកដក្នុងចិត្តថា គាត់ស្លាប់ពិតមែនហើយ។

១ខែក្រោយមក នៅល្ងាចថ្ងៃមួយ ខ្ញុំបាននាំកូនទៅងូតទឹកអណ្តូងក្រោយរោងស្នាក់។ ខ្ញុំស្រាប់តែឮសំឡេងមីងហួរ ដែលមកពីភូមិសាត្រាម និយាយដោយត្រេកអរប្រាប់អ្នករស់នៅជាមួយគ្នាថា អ្នកទោសចំនួន៤នាក់ ត្រូវអង្គការលែងឲ្យរួចខ្លួន និងមកដល់ភូមិសាត្រាមហើយ។ គាត់បន្ថែមទៀតថា គាត់ឃើញច្បាស់ណាស់ព្រឹកនេះអង្គការជូនពួកគេមកនៅភូមិអូរអង្គរហើយ។ ពេលនោះ ស្ត្រីៗដែលមានប្តីជាប់ទោសឡើងទៅលើផ្ទះសួរនាំគាត់អំពីកិនភាគអ្នកទោសទាំងនោះ។ ខ្ញុំឮភ្លាមសង្ស័យថាប្រាកដជាមានប្តីរបស់ខ្ញុំដែរ។ បន្ទាប់ពីមុជទឹកឲ្យកូនរួច ខ្ញុំងូតទឹករួចពកូនដើរមកលើរោង ហើយទៅសួរមីងហួរផ្ទាល់។ តាមដែលគាត់ប្រាប់ ខ្ញុំជឿប្រាកដថាជាប្តីរបស់ខ្ញុំហើយ។ ខ្ញុំញញឹមក្នុងចិត្តរួចត្រលប់មករោងវិញ ស្រាប់តែបងស្រីនិងម្តាយមីងរបស់ខ្ញុំ បានមកប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំត្រលប់មកវិញហើយ។ ខ្ញុំត្រេកអរក្នុងចិត្តណាស់ ខ្ញុំនិយាយជាមួយកូនថា ប៉ាកូនមកវិញហើយ។

លុះព្រឹកឡើងខ្ញុំដាំបបរវង់ចាំប្តី។ ម៉ោងប្រហែល៩ព្រឹក ខ្ញុំឃើញគាត់ពីចម្ងាយមានទទូរក្រមាជិតមុខ។ បងស្រីរបស់ខ្ញុំទៅទទួលគាត់មុន។ ពេលដែលគាត់មកដល់មុខរោងហើយបើកក្រមាឡើង ខ្ញុំស្ទើរតែមិនជឿនឹងរូបរាងរបស់គាត់។ ពុទ្ធោ! ប្តីរបស់ខ្ញុំស្គមស្គាំងមើលមិនយល់ សាច់ឡើងខ្មៅស្រអាប់។ គាត់ឃើញខ្ញុំភ្លាម គាត់ហូរទឹកភ្នែករហាម ហើយពោលប្រាប់ទាំងអស់គ្នាថា «ខ្ញុំមិននឹកស្មានថា ខ្ញុំបានរស់មកដល់ទីនេះទេ។ ពេលដែលខ្ញុំដើរទប់ខ្លួននឹងឈើច្រត់ អង្គការនៅតែឲ្យខ្ញុំទៅធ្វើការទៀត។ ប្រសិនបើនៅតែ១០ថ្ងៃទៀតខ្ញុំមិនអាចដើរមកដល់ទេ»។ និយាយរួចប្តីរបស់ខ្ញុំបានកិលទៅរកកូន រួចនិយាយជាមួយកូនថា «កូនប្រុសប៉ា ចាំប៉ាបានទេ?»។ ពេលនោះបងរបស់ខ្ញុំនិងខ្ញុំ បានឆ្លើយព្រមគ្នាថា «អង្គការមិនឲ្យហៅប៉ាម៉ាក់ទេ គេឲ្យហៅថា ឪវិញ ដើម្បីឲ្យសមស្របនឹងការរស់នៅក្នុងភូមិស្រុកនេះ»។

រយៈពេល១ខែ ខ្ញុំខំរកអាហារបំប៉នសុខភាពប្តីរបស់ខ្ញុំ។ ខ្ញុំបានទៅជួបអ្នកនៅរោងបាយ សុំបើកអង្ករយកមកដាំហូបខ្លួនឯង ដើម្បីឲ្យសុខភាពរបស់គាត់ឆាប់បានរឹងមាំឡើងវិញ។ យើងសំណាងណាស់ ប្តីរបស់ខ្ញុំមានញាតិធម៌នៅភូមិក្រយាបានផ្ទើចេកឲ្យយើងជិត២ស្នង។ ក្រោយមក ម្តាយឪពុករបស់ខ្ញុំ បានសុំច្បាប់អង្គការមកសួរសុខទុក្ខយើងទៀត ព្រមទាំងមានអង្ករ ត្រីឆ្អើរ ដំឡូងមី ដំឡូងជ្វា និងដំឡូងក្រៀម យកមកផ្ទើដែរ។ ខ្ញុំនិងបងប្អូនទាំងអស់គ្នា ត្រេកអរណាស់ព្រោះឃើញម្តាយឪពុករបស់ខ្ញុំនៅមានសុខភាពល្អ។ គាត់ថា គាត់ខំពង្រឹងជំហរថែមទាំងខំដាំដំណាំយកផលដើម្បីជួយកូន។ មិនយូរប៉ុន្មាន អ្នកភូមិដាច់ស្បៀង ហើយអង្គការបានបើកសិទ្ធិឲ្យអ្នកភូមិទៅរកទិញស្បៀងអាហារចិញ្ចឹមខ្លួនឯង។ អង្គការឈប់ចិញ្ចឹមយើងហើយ។

អង្គការឲ្យយើងចាកចេញពីភូមិអង្គរ

មិនយូរប៉ុន្មាន ស្រាប់តែឮដំណឹងថាថ្នាក់លើឲ្យពួកយើងចាកចេញពីភូមិអូរអង្គរ តែមិនដឹងទៅលើឬទៅក្រោមទេ។ យើងភ័យខ្លាចគ្រប់គ្នា ព្រោះយើងមិនដឹងថាតើអង្គការកំពុងចាប់កំហុសយើងឬយ៉ាងណានោះទេ។ ល្ងាចនោះមេភូមិ បានមកប្រាប់យើងថា ស្អែកនេះអង្គការឲ្យយើងចុះទៅភូមិក្រយាវិញ។ ឮដូច្នោះ គ្រប់គ្នាហាក់បីដូចជាត្រេកអរវិញ ហើយប្រញាប់រៀបចំអីវ៉ាន់រង់ចាំពេលព្រឹកមកដល់។ ពេលល្ងាចនោះ កូនប្រុសរបស់ខ្ញុំ ញញឹមរីករាយចុះដើរលេងលើស្មៅនៅមុខរោងស្នាក់ ព្រោះតាំងពីមករស់នៅភូមិអូរអង្គរមក កូនប្រុសរបស់ខ្ញុំមិនចុះជាន់ដើរលើដីសោះ។ លុះព្រឹកឡើង យើងពុំបានចេញដំណើរភ្លាមៗនោះទេ។ យើងចេញដំណើរពីភូមិថ្ងៃជិតត្រង់ដែរហើយ។ ប្រជាជនម្នាក់ៗមានទឹកមុខរីករាយណាស់។ លុះមកដល់ភូមិក្រយា ខ្ញុំ សំណាងដែរ បានមករស់នៅជាមួយក្រុមគ្រួសាររបស់យាយតាមួយ ដែលមានចិត្តល្អ។ ពេលនោះខ្ញុំមានផ្ទៃពោះ៧ខែ អង្គការបានឲ្យខ្ញុំនៅកិនស្រូវក្នុងម្នាក់ឲ្យបានមួយកញ្ជើ។ ចំណែកឯ បុរសនិងយុវជន ត្រូវអង្គការចាត់ឲ្យទៅធ្វើការងារឆ្ងាយពីភូមិបន្តិច។

ខ្ញុំបង្កើតបានកូនស្រីម្នាក់យ៉ាងស្រស់ស្អាត។ ធ្មបបុរាណនៅក្នុងភូមិបានជួយដល់ខ្ញុំ។ ខ្ញុំនិងប្តី សប្បាយត្រេកអរណាស់ បានឃើញកូនកើតមកដោយ

សុវត្ថិភាពថែមទាំងមានគ្រប់កាយសម្បទាអីចឹង។ ខ្ញុំកូនខ្ចីទើបបានជាង១ខែ ខ្ញុំទទួលដំណឹងពីមេភូមិថា អង្គការត្រូវដម្លៀសពួកយើងចេញពីភូមិទៀតហើយ តែមិនដឹងទៅខាងណានោះទេ។ ក្រោយមកទើបយើងដឹងថា អង្គការឲ្យយើងទៅចាប់ដីកាប់ព្រៃសង់លំនៅឋានឯកជននៅប្រហែល៨គីឡូម៉ែត្រពីភូមិក្រយា ប៉ុន្តែត្រូវរស់នៅក្រោមការគ្រប់គ្រងពីមេភូមិដដែល។ ទៅដល់ភូមិថ្មីឈ្មោះថា ភូមិធ្លក ពួកយើងបានរៀបចំសង់ផ្ទះតូចៗ ហើយនាំគ្នាកាប់ឆ្ការព្រៃដាំដំណាំ និងជីកអណ្តូងយកទឹកប្រើប្រាស់។ យើងរស់នៅក្នុងភូមិធ្លកបានប្រហែល២ខែ ក៏ទទួលបានដំណឹងថា អង្គការឈប់ឲ្យមានការចាយលុយនិងទិញដូរអ្វីទៀតហើយ។ ថ្ងៃនោះ គឺជាថ្ងៃ១៧មេសា ដែលខ្មែរក្រហម វាយបែកភ្នំពេញ។

ចាប់ពីខែធ្នូ ឆ្នាំ១៩៧៥មក

ខែធ្នូ ឆ្នាំ១៩៧៥ យើងបានដំណឹងពីរដ្ឋអំណាចមកថា ពួកយើងរស់នៅឯកជនសួនតួពេក ដូច្នោះអង្គការត្រូវបញ្ជូនឲ្យទៅកាប់ព្រៃរស់នៅទួលការវិញ ព្រោះទីកន្លែងនោះ ជីមានជីវជាតិល្អ។ យើងស្តាយណាស់ ព្រោះយើងទើបតែនាំគ្នាសាងសង់ខ្នមនិងដាំដំណាំបានយ៉ាងច្រើននៅក្នុងភូមិនេះ ហើយត្រូវអង្គការដម្លៀសឲ្យទៅនៅកន្លែងថ្មីទៀតដែលគ្មានអ្វីសោះ។ យើងត្រូវទៅរស់នៅភូមិបុស្សធំ ត្រូវរស់នៅជាមួយអ្នកភូមិចាស់ ហើយហូបរួមទៀត។ នៅភូមិបុស្សធំ យើងត្រូវទៅធ្វើការងារជាមួយអ្នកភូមិរាល់ថ្ងៃ ប៉ុន្តែក្រោយមក អង្គការបានចាត់ឲ្យបុរសៗទៅស្រែនៅឆ្ងាយៗអស់ទៀត។

អង្គការបានឲ្យខ្ញុំ ទៅកាប់ដីលើកប្រព័ន្ធភ្លឺស្រែ។ ពេលនោះ កូនស្រីរបស់ខ្ញុំចេះដើរហើយ។ ខ្ញុំយកកូនស្រីទាំងពីររបស់ខ្ញុំទៅជាមួយ ដោយឲ្យកូនៗអង្គុយលេងក្រោមម្លប់ឈើ ចំណែកខ្ញុំធ្វើការបណ្តើរភ្នែករំពៃមើលកូនបណ្តើរ។ នៅពេលដែលខ្មែរក្រហមទទួលបានអំណាចពេញលេញ ខ្មែរក្រហមចាប់ផ្តើមលើកតម្កើងអ្នកទីទាល់ក្រ និងអ្នកមិនចេះអក្សរឲ្យធ្វើជាមេភូមិឬអ្នកដឹកនាំ។

រហូតដល់ខែមេសា ឆ្នាំ១៩៧៨ ខ្ញុំបង្កើតបានកូនប្រុសម្នាក់ទៀត។ ប៉ុន្តែអកុសល កូនស្រីរបស់ខ្ញុំ ស្លាប់ដោយបង្ខំក្នុងរយៈពេលតែ១ម៉ោងប៉ុណ្ណោះ។

ពេលនោះ ខ្ញុំនៅសរសៃខ្ចីនៅឡើយ ព្រោះខ្ញុំទើបតែសម្រាលកូនបានជាង២ខែ។ ខ្ញុំនិងប្តី កើតទុក្ខស្ទើរតែឆ្កួតវង្វេង មិនអាចធ្វើអ្វីបានឡើយក្រៅពីសោកស្តាយកូន។

ក្រោយមក អង្គការ បានចាត់ឲ្យប្តីរបស់ខ្ញុំទៅដាំបន្លែនៅភូមិមាត់ស្ទឹងអូរចក។ ចំណែកខ្ញុំ អង្គការ ឲ្យទៅជួយធ្វើការនៅរោងបាយ។ យប់ថ្ងៃមួយ អង្គការបានហៅពួកយើងគ្រប់គ្នាឲ្យទៅប្រជុំ ដែលមានប្រធានសង្កាត់ជានារីម្នាក់ និងបុរសម្នាក់ បានលើកនិយាយបែងចែកតាមគ្រួសារ ដោយមានដាក់ឈ្មោះជាបញ្ជីគ្រួសារត្រៀម និងគ្រួសារពេញសិទ្ធិ។ សម្តីរបស់មិត្តនារី បានសង្កត់ធ្ងន់ៗថា «អង្គការត្រូវតែរែងស្ទៀងយកតែដើមៗ រែងហើយរែងទៀត។ កម្មសិទ្ធិសួនតូម្នាក់ៗ គឺមានតែចាន១ ស្លាបព្រា១ប៉ុណ្ណោះ។ អ្វីៗជារបស់អង្គការ ទាំងអស់ ព្រោះអង្គការជាអ្នកចិញ្ចឹមយើង គឺយើងរស់ដោយសារអង្គការ»។

៣ខែក្រោយមក គឺនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពេលនោះស្រុកយើងមានសង្គ្រាមម្តងទៀត ប្រជាជនភ័យផងអរផង ព្រោះសំឡេងផ្ទុះអាវុធរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានចូលមកដល់ស្រុកស្នោង។ ពេលនោះ ខ្ញុំឃើញពួកសមមិត្ត ដែលជាកូនចៅរបស់អង្គការ បានរត់ចែកជើងគ្នា។ អ្នកខ្លះទៅពួនរស់នៅក្នុងព្រៃ និងអ្នកខ្លះត្រលប់ទៅផ្ទះវិញតាមរកម្តាយឪពុករបស់ខ្លួន។

កំណាព្យ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

ប្រាំពីរមករា ចិតសិបប្រាំបួន ថ្ងៃខ្មែររួចខ្លួនពីមរណា
ឆ្លងផុតទុក្ខភ័យសែនវេទនា យល់ភ័ព្វវាសនាជីវិតថ្មី។
ប្រាំពីរមករា ខ្មែរអបអរ ប្រែមុខមាត់ល្អមានសេរី
មិននឹកស្មានសោះផុតប្រល័យ ដែលខ្មែរគ្រប់វ័យឈឺចាប់ណាស់។
ប្រាំពីរមករា រួចទោសទណ្ឌា បក្សប្រជាជនជួយសង្គ្រោះ
ឲ្យយើងរាល់គ្នា បានរួចរស់ ពីទមិឡទុយ៌សប្រុងប្រហារ។
គុកឥតជញ្ជាំងទុក្ខគ្មានល្ហែ បីឆ្នាំប្រាំបីខែខ្មែរឈឺផ្សា
ពុំមានលេចមុខវីរៈណា មកជួយខេមរាឲ្យធូរស្រាល។

យើងខ្ញុំដែលបានរួចជីវិត ចាំជាប់ក្នុងចិត្តហើយរាងចាល
ស្អប់ណាស់ខ្លាចណាស់អតីតកាល ល្វីងហិលរោលរាលប្រៃជូរចត់។
គ្មានរោគអ្វីស្មើរោគស្រេកឃ្លាន រោគវាយគំរាមបីដូចសត្វ
ប្រើហួសកម្លាំងដួលហៅវហត់ រោគគ្មានឱសថជួយការពារ។

ចប់

៣៥

រឿងផែនដីពណ៌ខ្មៅ

អ្នកនិពន្ធ ៖ វច្ឆ សុភាវ

៣៥ ~ រឿង ផែនដីពណ៌ខ្មៅ

ថ្ងៃរៀបការចៅរបស់ខ្ញុំ ខិតជិតចូលមកដល់ ខ្ញុំហាក់មានអារម្មណ៍រំភើបក្រៃលែង។ ចៅរបស់ខ្ញុំ បានរៀនចប់ជំនាញគ្រូពេទ្យ រីឯគូដណ្តឹងរបស់ចៅខ្ញុំវិញ ធ្វើជាគ្រូពេទ្យដូចគ្នានឹងចៅរបស់ខ្ញុំដែរ។ ខ្ញុំឃើញកូនចៅរបស់ខ្ញុំ មានជីវភាពគួរសមដូចបច្ចុប្បន្ននេះ បានធ្វើឲ្យខ្ញុំនឹកសង្វេគដល់ជីវិតរបស់ខ្ញុំនៅក្នុងរណ្តៅទុក្ខ កាលពីជាង៤០ឆ្នាំមុន។ ជិតកន្លះសតវត្សទៅហើយ ខ្ញុំនៅតែចងចាំគ្រប់ហេតុការណ៍ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ វាហាក់បីដូចជាទើបនឹងកើតឡើងថ្មីៗសម្រាប់ខ្ញុំ។

នារាត្រីមួយនៅក្នុងរបបខ្មែរក្រហម ឆ្កែព្រូសផង ស្រែកលូផង គួរឲ្យព្រឺឆ្អឹងខ្នងណាស់។ ម៉ោងមិនទាន់៨យប់ផង ខ្ញុំចាប់ងងុយដេក និងអស់កម្លាំងយ៉ាងខ្លាំង ព្រោះតែភាពហត់នឿយពីការងាររបស់ខ្ញុំ ដែលបានធ្វើនៅពេលថ្ងៃ។ ខ្ញុំបានប្រុះខ្លួនដេកទៅ ប៉ុន្តែមួយសន្ទុះក្រោយមក ស្រាប់តែមានហេតុការណ៍អាក្រក់បានកើតឡើង។ ក្មួយប្រុសរបស់ខ្ញុំឈ្មោះ លីម រាករូសយ៉ាងខ្លាំង។ សំឡេងថ្ងូររបស់ក្មួយខ្ញុំ ធ្វើឲ្យខ្ញុំស្ងាងពីងងុយដេកវិញ។ ខ្ញុំស្ទុះងើប ហើយទៅអង្គុយក្បែរជើងក្មួយរបស់ខ្ញុំ ដែលកំពុងតែប្រះននៀលនៅលើគ្រែក្រាលកន្ទេលស្លឹកត្នោតមួយនៅខាងក្រោមផ្ទះ។ ម្តាយរបស់ខ្ញុំ បានស្ទាបអង្អែលចៅដោយការព្រួយបារម្ភយ៉ាងខ្លាំង។ ឪពុកម្តាយរបស់ក្មួយខ្ញុំមិននៅទេ។ ពួកគាត់ ត្រូវអង្គការចាត់ឲ្យទៅធ្វើការងារនៅតំបន់ផ្សេង។ មួយសន្ទុះក្រោយមក ម្តាយរបស់ខ្ញុំ បានឲ្យខ្ញុំនៅយាមក្មួយ ហើយគាត់ប្រាប់ខ្ញុំថា គាត់ទៅរកបបរក្រែងបានបន្តិចឲ្យចៅហូប។ បន្ទាប់ពី

ម្តាយរបស់ខ្ញុំនិយាយរួច គាត់ក៏ងើបឡើងសំដៅទៅខាងលិចត្រពាំងធំ។ ទីនោះគឺជារោងបាយ។ ខ្ញុំអាចមើលឃើញម្តាយរបស់ខ្ញុំ ដើរទៅរហូតដល់រោងបាយតាមពន្លឺព្រះចន្ទ។ ខ្ញុំគិតទុកក្នុងចិត្តថា ម្តាយខ្ញុំមិនពិបាករកបបរនោះទេ ព្រោះនៅយប់នោះ ជាពេលដែលឪពុករបស់ខ្ញុំនៅយាមរោងបបរ។ ប៉ុន្តែអ្វីៗខុសពីការគិត។ ម្តាយរបស់ខ្ញុំត្រលប់មកវិញដោយដៃទទេ។ គាត់ដាក់ខ្លួនអង្គុយក្បែរចៅ ហើយនិយាយទាំងអួលដើមកថា «ទ្រាំទៅចៅអើយ! យាយរកបបរមិនបានទេ! គេមិនឲ្យយើងឡើយ»។ ឃើញដូច្នោះ ខ្ញុំបានសួរទៅកាន់ម្តាយរបស់ខ្ញុំថា «ម៉ែបានជួបឪដែរឬទេ?» ម្តាយរបស់ខ្ញុំឆ្លើយតបមកវិញថា «បានជួប ប៉ុន្តែគាត់មិនហ៊ាននិយាយនឹងចុងភៅទេ»។ ខ្ញុំឃើញម្តាយរបស់ខ្ញុំយំ ហើយខ្ញុំសួរទៅគាត់បន្តទៀតថា «ម៉េចក៏ម៉ែយំអីចឹង?»។ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំវិញថា «កូនអើយ! យាយផុនបានបបរឲ្យម៉ែចំនួនមួយកំប៉ុងអង្ករ។ បបរឆ្អិនដួសដាក់ចានហើយ ស្រាប់តែលោកប្អូន ផន ដែលជាប្រធានរោងបាយមកដល់ល្មម។ គាត់ បានកញ្ឆក់យកបបរពីដៃម៉ែ ហើយសួរនាំគំរាមម៉ែថា «ស្អីហ្នឹងយកទៅណា?» ម៉ែប្រាប់ ផន ទាំងញញីញញ័រពីរឿងសុំបបរនេះ ហើយ ផន ស្រាប់តែទាញបបរពីដៃរបស់ ម៉ែ ចាក់ចោល ថែមទាំងគំរាមទៀតថា «កុំឲ្យមានលើកទីពីរទៀត»។ លើកនេះ ផន យល់ដល់ឪពុករបស់កូនដែលខំយាមរោងបាយបានយ៉ាងល្អមិនដែលបាត់របស់របរ។ ម្តាយរបស់ខ្ញុំនិយាយដល់ត្រឹមនេះ ក៏ឈប់និយាយជាមួយខ្ញុំ រួចបែរមុខទៅមើលចៅវិញ។ ម្តាយរបស់ខ្ញុំបានលួងលោមចៅថា «សម្ងំដេកសិនទៅចៅយាយ ចាំយាយរកអីមកឲ្យហូប»។ និយាយចប់ ម្តាយរបស់ខ្ញុំ បានដើរចេញទៅក្រោយផ្ទះមួយស្របក់ ស្រាប់តែឃើញគាត់ដើរចូលមកមានកាន់មាន់មួយដែលបោចរួចហើយស្រេច។ គាត់បានបង្កាត់ភ្លើងដាក់ស្ងោរមាន់នោះនៅក្នុងកំសៀវទឹកទាំងប្រជុំយប្រថាន។ មាន់មិនទាន់ឆ្អិនផង បងព្រឹក ដែលជាឈ្លបបានដើរមកយកការណ៍ដល់ផ្ទះរបស់ខ្ញុំល្មម។ បងព្រឹក ពូកែខាងរាយការណ៍ណាស់។ បងព្រឹក បានស្រែកសួរម្តាយរបស់ខ្ញុំថា «ធ្វើស្អីហ្នឹងសមមិត្តសេង»?។ ឮដូច្នោះ ម្តាយរបស់ខ្ញុំ បានឆ្លើយតបទាំងតក់ស្លុតទៅវិញថា «ចៅរបស់ខ្ញុំ អាឈឺម វាពាក

ពេញតែផ្ទះដេកស្អិនស្អុយពេញហ្នឹងទៅហើយ»។ ពេលឮថាស្អុយលាមក បងព្រឹកគ្រាន់តែអើតតាមមាត់ទ្វារួចសួរទៀតថា «ចុះចង្រ្កាននោះដុតអ្វី»? ម្តាយរបស់ខ្ញុំកុហក បងព្រឹកថា «នែ! នែ! ដាំទឹកក្តៅឲ្យវាងឹត ក្រែងលោឆាប់បានធូរស្បើយ។ បន្ទាប់មក បងព្រឹក បានក្រឡេកមើលជុំវិញបរិវេណផ្ទះ ដែលមានបំភ្លឺដោយពន្លឺភ្លើងចង្កៀងប្រេងកាត រួចក៏និយាយទាំងគំរោះគំរើយថា «អើ! អីចឹងអញទៅហើយ កុំនាំគ្នាធ្វើអ្វីផ្តេសផ្តាសឲ្យសោះរឿយ»។

ខ្ញុំនិងម៉ែ បានធូរទ្រូង ហើយនៅពេលយប់ស្ងាត់បន្តិចក៏ពន្លត់ចង្កៀង រួចលើកយកមាន់ស្ងោរក្នុងកំសៀវនោះមកឲ្យក្មួយរបស់ខ្ញុំហូប។ ខ្ញុំនិងម៉ែ ក៏បានហូបបន្តិចម្នាក់ដៃរ។ មាន់ស្ងោរនោះ ពិតជាឆ្ងាញ់អស្ចារ្យណាស់។ ទឹកស្ងោរមាន់មួយដំណាក់ក៏យើងហូបមិនឲ្យសេសសល់ដៃរ។ យើងមិនដែលបានហូបបែបនេះជាយូរណាស់មកហើយ។

មាន់រងារទៀបភ្លឺ មេកង ឡើងប្រកាសហៅគ្នាទៅភ្ជួរស្រែ។ ថ្ងៃនេះក្រុមរបស់ខ្ញុំមានប្រាំបីនង្គ័ល និងរនាស់ពីរ ហើយមេក្រុមបានដាក់កម្រិតថា មួយព្រឹកត្រូវភ្ជួរស្រែឲ្យរួចមួយហិកតា។ ខ្ញុំដឹកគោ និងលីនង្គ័លទៅភ្ជួរចាប់ពីភូមិប្រហូតទៅដល់ភូមិត្បែង ដែលមានចម្ងាយប្រហែល ៦គីឡូជារៀងរាល់ព្រឹក។ ពេលថ្ងៃរះចំលើក្បាល ក្រុមរបស់ខ្ញុំ បានភ្ជួរជីអស់មួយហិកតា រួចហើយយើងនាំគ្នាដាក់គោឲ្យគោស៊ីស្មៅ រួចយើងដើរសំដៅទៅរោងបាយ។ អំណាចនៃសេចក្តីស្រេកឃ្លានពិតជាធំធេងណាស់។ យើងមិនទាន់បានហូបផង ប៉ុន្តែម្នាក់ៗមានទឹកមុខស្រស់ឡើងវិញនៅពេលទៅដល់រោងបាយ។ ខ្ញុំបានចំណែករបស់ខ្ញុំតែមួយវែកទេ ហើយបាយនោះទៀតរាវដូចជាបបរអីចឹង។ ខ្ញុំហូបតែបីទៅបួនម៉ាត់ក៏អស់ទៅហើយ។ ខ្ញុំនិងក្រុមភ្ជួររាស់ទាំងអស់ទទួលទានបាយថ្ងៃត្រង់មិនបានសម្រាកផង ក៏បំបែកគ្នាដឹកគោ លីនង្គ័លរៀងៗខ្លួនវិញ។ ពួកយើងធ្វើការនៅទីនោះអស់រយៈពេលប្រហែល ១ខែ ពិបាកវេទនាណាស់ ទម្រាំតែអង្គការបញ្ជូនយើងត្រលប់មកភូមិវិញ។

ពេលវេលាចេះតែកន្លងផុតទៅ រដូវកាលចេះតែផ្លាស់ប្តូរឥតឈប់ឈរ ប៉ុន្តែគោលការណ៍របស់អង្គការមិនដែលផ្លាស់ប្តូរឡើយ។ អង្គការនៅតែបង្ខំប្រជាជន

ឲ្យធ្វើការងារធ្ងន់ធ្ងរ និងបែកឃ្លាតពីក្រុមគ្រួសារ។ ចូលមកដល់ពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៦ អង្គការបានរៀបចំពិធីប្រកាសឲ្យមានការរៀបការចំនួន១៥គូ។ នៅក្នុងនោះ ខ្ញុំក៏ត្រូវអង្គការចាត់តាំងឲ្យរៀបការដែរ។ ការរៀបការនោះ បានប្រព្រឹត្តទៅនៅត្រង់វត្តព្រហូត។ ប្តីប្រពន្ធទាំង១៥គូនោះ រៀបការមិនដល់មួយព្រឹកផង។ យើងរៀបការគ្មានអាចារ្យ គ្មានកម្មវិធីធ្វើឡើងតាមបែបប្រពៃណីខ្មែរអ្វីនោះទេ។ ពួកយើងគ្រាន់តែឡើងប្តេជ្ញាថាស្រលាញ់គ្នា និងស្មោះស្ម័គ្រចំពោះអង្គការតែប៉ុណ្ណោះ។ មេកងធំ បានជូនពរឲ្យពួកយើងនិងឲ្យប្តេជ្ញាស្រលាញ់គ្នាជារៀងរហូតទៅ។ ពេលវេលារៀបការនៅក្នុងរបបខ្មែរក្រហម ជាពេលមួយយ៉ាងពិសេសសម្រាប់ខ្ញុំនិងគូផ្សេងទៀតដែរ។ យើងមានអាហារហូបមិនខ្វះឡើយ ដោយមានទាំងសាច់ជ្រូកមាន់ទាពាសពេញចាន។ ចំណែកឯ មេកងធំវិញ ចម្លែកណាស់។ គាត់សប្បាយចិត្តជាមួយខ្ញុំអស់ពីចិត្តពីថ្លើម។ ព្រឹកថ្ងៃបន្ទាប់នៅកន្លែងបុកស្រូវ ខ្ញុំឮប្រជាជននៅទីនោះនិយាយថា មេកងធំឈ្មោះ យ៉ែម ដែលរឹករាយខ្លាំងនៅថ្ងៃមង្គលការយើងកាលពីម្សិលមិញបាន ចងកសម្លាប់ខ្លួននៅលើដើមខ្វិតឯវាលខាងជើងទៅហើយ។ គាត់សម្លាប់ខ្លួននេះ ព្រោះគាត់បានដឹងមុនថាមេកងឈ្មោះ កាយ ត្រូវអង្គការយកទៅសម្លាប់។ ដូច្នេះលើកនេះ ដល់វេនអង្គការយកគាត់ទៅសម្លាប់ម្តងហើយ ព្រោះកាលពីម្សិលមិញថ្នាក់លើបានមកហៅគាត់។

ខ្ញុំឯណោះវិញ ក្រោយពេលរៀបការរួចបានមិនដល់មួយសប្តាហ៍ផង ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើជីកសិកម្មនៅឃុំថ្មពេជ្រ ស្រុកមេមត់ ខេត្តកំពង់ចាម។ ខ្ញុំត្រូវបែកឃ្លាតពីប្រពន្ធរបស់ខ្ញុំ ដែលទើបតែនឹងរៀបការថ្មីៗ ពុកម៉ែ និងបងប្អូនជាទីស្រលាញ់ពេញបេះដូងទាំងក្តីអាឡោះអាល័យ។ នៅទីនោះ ខ្ញុំត្រូវជីកថ្មតាំងតែពីព្រឹកព្រលឹមរហូតទល់ព្រលប់។ ខ្ញុំគ្មានអាហារបរិភោគគ្រប់គ្រាន់ឡើយ សូម្បីតែមួយពេល។ ដោយខ្វះអាហារហូបពេក ខ្ញុំក៏មិនខុសអ្វីពីសមមិត្តអ្នកជីកថ្មឯទៀតដែរ គឺម្នាក់ៗស្ថិតក្នុងសភាពស្គមស្គាំងស្បែកដណ្តប់ឆ្អឹង ខំប្រឹងរស់យ៉ាងយ៉ាប់ស្នើតែស្លាប់។ មិនយូរប៉ុន្មាន ខ្ញុំត្រូវអង្គការបញ្ជូនមកស្រុកវិញ ដោយសារមានព្រឹត្តិការណ៍ធំមួយបានកើតឡើងនៅភូមិភាគបូព៌ា គឺលោក សោ កឹម ដែលជា

ប្រធានភូមិភាគបូព៌ា បានធ្វើការបះបោរប្រឆាំងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ឡានមួយគ្រឿងជូនខ្ញុំ និងសមមិត្ត៤នាក់ទៀតមកដល់ម្តុំបឹងខ្ញី។ មកដល់ទីនោះ យើងបានចុះពីលើឡានបែកគ្នាតាមទិសដៅរៀងៗខ្លួនព្រោះគ្មានផ្លូវសម្រាប់ឡានបើកបរទៅមុខបន្តទៀតទេ។ ខ្ញុំដើរហួតដល់វត្តស្នាវ នៅម៉ោងប្រហែល៦ល្ងាច។ ពេលនោះ នៅក្នុងវត្តមានរៀបចំសម្តែងសិល្បៈ ហើយមានតួល្បីៗនៅថ្នាក់ស្រុក ដែលបម្រើឲ្យគោលនយោបាយរបស់អង្គការ។ ពិតជាចៃដន្យមែន ក្នុងចំណោមមនុស្សជាច្រើន ខ្ញុំបានជួប នាងឈន ដែលជាតួសម្តែងល្បីម្នាក់នៅក្បែរផ្ទះរបស់ខ្ញុំ និងប្អូនប្រុសរបស់នាងម្នាក់ទៀតគឺ សំអុល។ ខ្ញុំជួបអ្នកទាំងពីរបានធ្វើឲ្យខ្ញុំមានកម្លាំងចិត្តឡើងវិញបន្តិច។ ពួកយើងបានជជែកគ្នាអស់រយៈពេលប្រហែល៥នាទីតែប៉ុណ្ណោះ។ ឈន បានផ្ញើសំបុត្រតាមខ្ញុំមកផ្ទះ។ ឈន បានប្រាប់ខ្ញុំថា នាងមិនដឹងពេលណាបានជួបមុខម៉ែឪរបស់នាងម្តងទៀតទេ ព្រោះនាងជាប់ដើរសម្តែងសិល្បៈ។ បន្តិចក្រោយមក ខ្ញុំ និងសំអុល ដែលមានអាយុទើបតែ១៣ឆ្នាំ បាននាំគ្នាដើរតម្រង់ទៅភូមិចារ។ ប្រហែលម៉ោង៩យប់ មានមនុស្សចិត្តល្អម្នាក់បានមកនិយាយប្រាប់យើងថា «ក្មួយទាំងពីរកុំដើរទៅតាមផ្លូវត្រង់ទៅត្បូងនេះព្រោះបើជួបក្រុមយាម នឹងមានគ្រោះថ្នាក់ដល់ជីវិតប្រាកដណាស់»។ ខ្ញុំបានលើកដៃសំពះអរគុណនិងលាអ៊ំស្រីនោះ ហើយធ្វើដំណើរចេញមក។

ខ្ញុំ និងសំអុល សម្រេចចិត្តដើរតម្រង់សំដៅទៅទិសខាងលិច។ យប់កាន់តែងងឹតខ្លាំងទៅៗ យើងទាំងពីរនាក់ ត្រូវដើរឈ្ងោកមុខមើលផ្លូវ។ លុះយើងដើរដល់ពាក់កណ្តាលវាល ខ្ញុំវង្វេងទិសមិនដឹងទិសខាងលិចឬ ទិសខាងកើតអ្វីសោះ។ ខ្ញុំបានសួរទៅសំអុលថា «សំអុល! តើឯងដឹងថាមុខទៅណាសំដៅទៅផ្ទះយើងទេ? អញដូចជាកាំង ហើយទន់ដៃទន់ជើងអស់ហើយ»។ សំអុលយំតិចៗ ហើយឆ្លើយថា «ខ្ញុំក៏មិនដឹងដែរបងបឿន! អត់ដឹងលិចកើតទេ»។ ខ្ញុំឆ្លើយទៅវិញថា «នែ! កុំយកយំជាគ្នាវ៉ឺយ! វាមិនស្លាប់ទេ នោះអញឃើញភ្លើងប្តងៗហើយ ប្រហែលជាវត្តចំបក់! តោះយើងទៅ»។ ពួកយើងទាំងពីរនាក់ បានដើរសំដៅទៅរកពន្លឺភ្លើងនោះ។

កងទ័ពវៀតណាមចូលមក

ពេលវេលាចេះតែរំកិលខ្លួនទៅមុខសន្សឹមៗតាមដំណើរព្រះអាទិត្យ។ ជាង៣ឆ្នាំកន្លងទៅហើយដែលខ្ញុំនិងប្រជាជនជាច្រើន បានរស់នៅក្នុងភពដ៏ខ្មៅងងឹតប្រៀបបានទៅគុកដែលឥតជញ្ជាំង។ ចូលដល់ចុងឆ្នាំ១៩៧៨ នៅភូមិភាគបូព៌ា តែងតែឮសំឡេងគ្រាប់លាន់គ្រាំងៗជារឿយៗ។ ប្រជាជនម្នាក់ៗកើតសេចក្តីតក់ស្លុតបាត់បង់ស្មារតីពុំដឹងជីវិតទៅជាយ៉ាងណាទៀតនោះទេ។ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ កងកម្លាំងរបស់ខ្មែរក្រហម បានដើរកេណ្ឌប្រជាជននៅភូមិរបស់ខ្ញុំឲ្យប្រមូលកូនចៅ និងយកប្រដាប់ប្រដាប្រើប្រាស់ចាកចេញពីផ្ទះធ្វើដំណើរទៅទិសខាងលិចដោយស្រែកប្រកាសថា កងទ័ពវៀតណាមមកទាន់ឥឡូវហើយ។

ថ្ងៃនោះ ខ្ញុំវិលមុខយ៉ាងខ្លាំងងើបមិនរួចសោះ។ ម្តាយរបស់ខ្ញុំក័យផងយំផង។ ខ្ញុំខំប្រឹងងើបឡើងទឹមគោលើកអីវ៉ាន់កំប៊ុកកំប៉ុកដាក់រទេះគ្រប់សព្វអស់ហើយក៏បររទេះទៅតាមប្រជាជនផ្សេងទៀត។ ចំណែកឪពុកម្តាយរបស់ខ្ញុំ រែកអីវ៉ាន់មួយចំនួនដោយថ្មើរជើងជាមួយប្រជាជនដទៃទៀតដើរស្អែកស្តះតាមផ្លូវ។ រទេះគោរបស់ខ្ញុំ បានឆ្លងដល់ភូមិម្រេញ។ ខ្ញុំមិនធ្វើដំណើរទៅទិសខាងលិចត្រង់ទេ ប៉ុន្តែខ្ញុំធ្វើដំណើរទៅទិសខាងជើងវិញ។ ខ្ញុំនិងក្រុមគ្រួសារមកដល់ត្រង់សាលាឃុំត្រពាស្រែ រួចខ្ញុំក៏បានឈប់បររទេះ។ ប្រពន្ធនិងក្មួយរបស់ខ្ញុំ យកបាយទៅឲ្យម្តាយរបស់ខ្ញុំនៅឯខាងត្បូងថ្ពល់។ ពេលនោះ កងទ័ពវៀតណាម បានមកទាន់ក្បួនភៀសខ្លួនរបស់ប្រជាជន។ កងទ័ពវៀតណាមទាំងអស់នោះ ដើរហែជាជួរយ៉ាងមានសណ្តាប់ធ្នាប់ ពាក់មួកកន្តឹប មានអាវុធគ្រប់ដៃនិងស្ពាយជុំវិញខ្លួន។ ដោយឃើញសភាពបែបនេះ ខ្ញុំនឹកក្នុងចិត្តថា ឱជីវិតខ្ញុំ ឪពុកម្តាយ ប្រពន្ធកូន បងប្អូនក្មួយ និងអ្នកភូមិរបស់ខ្ញុំ ច្បាស់ជាអន្តរាយនៅក្នុងពេលនេះហើយ។ ខ្ញុំក្រឡេកមើលទៅកងកម្លាំងខ្មែរក្រហមវិញ ធ្វើដំណើរកាន់តែលឿនទៅមុខ។ ប្រជាជនចាប់ផ្តើមជ្រួលច្របល់យ៉ាងអនាធិបតេយ្យ។ ម្នាក់ៗក័យបាត់ព្រលឹងពីក្នុងខ្លួនអស់ទៅហើយ ព្រោះកងទ័ពវៀតណាមបានគ្រប់គ្រងជុំវិញប្រជាជន។

កងទ័ពវៀតណាម បានប្រកាសជាភាសាខ្មែរដឹនៗថា «បងប្អូនទាំងអស់គ្នា នាំគ្នាត្រលប់ទៅផ្ទះវិញ គោស៊ីស្រូវអស់ហើយ»។ កងទ័ពវៀតណាមនិយាយដូច្នេះដដែលៗជាច្រើនដង។ ស្អែកឡើងត្រូវថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំនិងប្រជាជនភៀសខ្លួនទាំងអស់ បានត្រលប់ទៅផ្ទះសម្បែងវិញដោយសុវត្ថិភាព។

ចប់

៣៦

រឿងខ្សែជីវិតកុមារត្រូវបានជម្លៀសក្នុងរបបប៉ុល ពត

អ្នកនិពន្ធ ៖ អេង ង៉ាន់ឆ

៣៦ ~ រឿង ខ្សែជីវិតកុមារ ត្រូវបានជម្លៀសក្នុង របប ប៉ុល ពត

ខ្ញុំឈ្មោះ យ៉ាន់ ថន ភេទស្រី កើតឆ្នាំ១៩៦៧ ។ ខ្ញុំមានស្រុកកំណើតនៅក្នុងភូមិកោងកាងទី៣ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម។ ឪពុករបស់ខ្ញុំឈ្មោះ ក្រឹម យ៉ាន់ និងម្តាយរបស់ខ្ញុំឈ្មោះ ធីត ណន ។ ខ្ញុំគឺជាកូនទី៥ ក្នុងចំណោមបងប្អូនចំនួន ១០នាក់ ។ ខ្ញុំមានកូនចំនួន ៦នាក់ ស្រីចំនួន ៤នាក់ និងប្រុសចំនួន ២នាក់ ។ កូនស្រីច្បងរបស់ខ្ញុំ បានស្លាប់នៅពេលដែលខ្ញុំឆ្លងទន្លេ ។ សព្វថ្ងៃនេះ ខ្ញុំគឺជាកសិករ និងជួញដូរត្រីដែរ ។

ដំណើរជីវិតពេលជម្លៀសលើកដំបូងក្នុងរបបខ្មែរក្រហម

បន្ទាប់ពីរបបខ្មែរក្រហមទទួលបានជ័យជម្នះ និងឡើងគ្រប់គ្រងប្រទេសកម្ពុជា ក្រុមខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឲ្យទៅរស់នៅតាមជនបទ និងប្រជាជនដែលនៅរស់នៅជនបទមួយចំនួន ត្រូវជម្លៀសចេញពីភូមិកំណើតឲ្យទៅរស់នៅ និងធ្វើការនៅទីកន្លែងផ្សេងៗ។ បន្ទាប់ពីក្រុមខ្មែរក្រហមចូលមកគ្រប់គ្រងក្នុងស្រុកកំណើតរបស់ខ្ញុំបានរយៈពេលប្រហែល ២ទៅ ៣ខែ ខ្មែរក្រហមបានផ្លាស់ប្តូរការរស់នៅរបស់ប្រជាជននៅក្នុងភូមិ ។ ខ្មែរក្រហម បានឲ្យស្រីៗទាំងអស់កាត់សក់ខ្លីត្រឹមក ស្លៀកខោអាវខ្មៅ បង់កក្រមា ពាក់ស្បែកជើងកង់ឡាន និងត្រូវប្តេជ្ញាថាស្មោះស្ម័គ្រនឹងអង្គការ ។ គ្មាននរណាម្នាក់ហ៊ានបដិសេធនឹងការបញ្ជានេះឡើយ ។

នៅពេលព្រឹកព្រលឹមថ្ងៃមួយ គ្រួសាររបស់ខ្ញុំ រួមមាន ឪពុកម្តាយនិងបងប្អូន កំពុងតែលុបមុខលាងជើង លាងដៃ រៀបនឹងហូបបាយ ស្រាប់តែកងតូចឈ្មោះ ហូល និងយ៉ូន បានមកប្រាប់យើងថា «ដល់ពេលដែលយើងត្រូវជម្លៀសទៅនៅភូមិស្មោងហើយ»។ ខ្មែរក្រហម បានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំចេញពីស្រុកកំណើតទៅនៅក្នុងភូមិកោងកាងទី៣ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម ឲ្យទៅរស់នៅឯភូមិស្មោង ឃុំស្មោង ស្រុកកំចាយមារ ខេត្តព្រៃវែងវិញ។ យើងមិនអាចប្រកែកបានឡើយ។ ក្រុមគ្រួសាររបស់ខ្ញុំ បានធ្វើដំណើរចេញពីស្រុកកំណើតទាំងព្រឹក ដោយមានរទេះមួយទឹមក្របីសម្រាប់ចាស់ៗ និងក្មេងៗជិះ រីឯបងប្អូនដែលមានវ័យជំទង់ និងខ្ញុំ ត្រូវធ្វើដំណើរដោយថ្មើរជើង។ ការជម្លៀសនោះ មិនមែនកើតមានតែចំពោះគ្រួសាររបស់ខ្ញុំនោះទេ ប៉ុន្តែក៏មានក្រុមគ្រួសារផ្សេងៗជាច្រើនទៀតត្រូវជម្លៀសចេញពីស្រុកកំណើតដូចខ្ញុំដែរ។

យើងមានការនឿយហត់ណាស់នៅថ្ងៃទីមួយនៃការធ្វើដំណើរចាកចេញពីផ្ទះរបស់ខ្ញុំ។ អាកាសធាតុក្តៅហួតហែង។ ខ្ញុំចេះតែដើរយ៉ាងលឿនតម្រង់ទៅរកដីភក់ និងកន្លែងដែលមានដើមឈើច្រើន។ នៅពេលនោះ ខ្ញុំដើរពាក់ស្បែកជើងកង់ឡាន និងសម្លៀកបំពាក់ពណ៌ខ្មៅ ដែលអង្គការបានបើកឲ្យ។ យើងធ្វើដំណើរហូតដល់ថ្ងៃត្រង់ ក៏នាំគ្នាឈប់សម្រាកក្រោមដើមឈើ ហូបបាយ ហើយសម្រាកបានរយៈប្រហែល២ម៉ោង ទើបយើងបន្តដំណើរទៅមុខទៀត។ លុះដល់ពេលល្ងាច គ្រួសាររបស់ខ្ញុំ បានឃើញផ្ទះមួយនៅក្នុងភូមិ ដែលគ្មានមនុស្សរស់នៅ។ នៅផ្ទះនោះមានតែជ្រូក មាន់ និងទាតែប៉ុណ្ណោះ។ នៅខាងក្នុងផ្ទះ មានចានឆ្នាំង និងអីវ៉ាន់ផ្សេងៗទៀត។ យើងបានសម្រេចចិត្តស្នាក់នៅទីនោះមួយយប់។ ពេលរាត្រីចូលមកដល់ យើងមានភ្លើងចង្កៀងមួយ និងភ្លើងចន្លុះមួយសម្រាប់បំភ្លឺ។ យើងដេកជុំគ្នា ម្នាក់ៗមានខោអាវតែមួយសម្រាប់ ដេកលើកន្ទេលរំចេក ហើយយកក្រមាធ្វើជាភួយដណ្តប់ការពាររងា និងមូសខាំ។ នៅយប់នោះ ខ្ញុំយល់សប្តិឃើញថា យើងមានការធ្វើដំណើរទៅមុខទាំងហៅហត់ អស់កម្លាំង ស្ទើរតែមិនអាចបន្តដំណើរទៅមុខបាន ហើយត្រូវក្រុមខ្មែរក្រហម ធ្វើបាបបង្ខំឲ្យធ្វើដំណើរ

ទៅមុខទៀតដោយមិនខ្វល់ថាគ្រួសាររបស់ខ្ញុំ និងប្រជាជនដទៃទៀត កំពុងតែពិបាក។ ខ្ញុំក្លាក់ឡើងទាំងកណ្តាលយប់ដោយតក់ស្លុតខ្លាំងណាស់ ហើយម៉ែរបស់ខ្ញុំលួងលោមខ្ញុំឲ្យដេកបន្តទៀត។

ថ្ងៃទីពីរបានចូលមកដល់ យើងត្រូវបន្តដំណើរទៅខាងមុខទៀត។ មុននឹងចេញដំណើរ បងស្រីណាក់ និងម៉ុម បានជួយធ្វើម្ហូបម៉ែរបស់ខ្ញុំសម្រាប់ទុកហូបបន្តទៀត។ ម៉ែបានវេចបាយខ្ចប់ជាមួយនឹងស្លឹកឈូកដែលមានអំបិល និងសាច់មាន់លីងសម្រាប់ទុកហូបនៅតាមផ្លូវ។ ខ្ញុំ គឺជាអ្នកច្រកទឹកទុកដាក់លើរទេះទុកផឹកតាមផ្លូវដែរ។

យើងបន្តដំណើរទៅមុខក្រោមកំដៅថ្ងៃក្តៅហែង ធ្វើឲ្យយើងអស់កម្លាំងណាស់។ នៅពេលបាយថ្ងៃត្រង់ គ្រួសាររបស់ខ្ញុំ បានឈប់សម្រាកនៅក្រោមដើមឈើធំមួយ។ បងប្រុសរបស់ខ្ញុំ ពីរនាក់ឈ្មោះ យ៉ុង និងយ៉ាយ បានដឹកក្របីម្នាក់មួយទៅចងឲ្យស៊ីស្មៅក្បែរវាលស្រែ និងប្រឡាយទឹក។ ឪពុករបស់ខ្ញុំ បានយករទេះទៅទុកដាក់ឲ្យបានត្រឹមត្រូវ។ យើងនាំគ្នាហូបបាយជុំគ្រួសារនៅក្រោមដើមឈើនោះ។ មុននឹងហូបបាយ ម្តាយរបស់ខ្ញុំ បានយកបាយបន្តិចម្ហូបបន្តិចទៅសែនអ្នកតានៅក្រោមដើមឈើដោយនិយាយតិចៗថា «លោកតាអើយលោកតាដែលថែរក្សាព្រៃប្រឹក្សានៅទីនេះ កូនចៅសែនឲ្យហើយ សុំឲ្យកូនចៅសុខសប្បាយ កុំឲ្យមានបញ្ហាអីមកយាយីឲ្យសោះ»។

មកដល់ភូមិស្មោច

ក្រុមគ្រួសាររបស់ខ្ញុំ ទៅដល់ភូមិស្មោង នៅម៉ោងប្រហែល៣រសៀល។ នៅក្នុងភូមិ ខ្ញុំឃើញមានទាំងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ដែលទើបតែជម្លៀសចូលមកជាច្រើននាក់។ ប្រធានកងតូចឈ្មោះ វ៉ែន និងផាន ដែលមានអាយុ ប្រហែល៦០ឆ្នាំ បានមកទទួលគ្រួសាររបស់ខ្ញុំ និងអ្នកភូមិផ្សេងទៀត។ គាត់បាននិយាយមកកាន់យើងថា «សមមិត្តទាំងអស់គ្នាមករស់នៅកន្លែងថ្មីនេះ ហើយត្រូវតែប្តេជ្ញាខិតខំជួយធ្វើការឲ្យអស់ពីកម្លាំងកាយចិត្ត យើងនឹងចែកផ្ទះមួយសម្រាប់គ្រួសារនីមួយៗ ហើយការងារសម្រាប់សមមិត្តដែលមានវ័យចំណាស់

គឺត្រូវរែងអង្ករ ត្បាញមួក មើលក្មេងៗ ហើយអ្នកខ្លះត្រូវទៅជីកប្រឡាយដែរ។ ចំណែក សមមិត្តវ័យជំទង់វិញ ត្រូវតែទៅធ្វើស្រែ។ រីឯ សមមិត្តកុមារ ត្រូវទៅកើបដីលាមកសត្វនិងលាមកមនុស្សយកទៅដាក់តាមវាលស្រូវ ហើយបើសល់ពេលទំនេរ ត្រូវជួយមើលប្អូនៗ»។

រំពេចនោះ ខ្ញុំបានសម្លឹងឃើញផ្ទះនៅខាងជើងផ្លូវក្បែរកន្លែងនោះ ដែលមានទំហំប្រហែល៤ម៉ែត្រ មានជណ្តើរ និងសសរធ្វើពីឈើជញ្ជាំងផ្ទះបាំងធាងដូងប្រក់ស្បូវ មានទ្វារមួយ និងគ្មានបង្អួចទេ។ នៅខាងក្រោមផ្ទះ គ្មានគ្រែនោះទេ ហើយនៅខាងមុខផ្ទះមានអណ្តូងទឹកមួយ ពងអុងមួយ ដែលកងតូចបានចែកឲ្យស្នាក់នៅ។ គម្លាតពីផ្ទះមួយទៅផ្ទះមួយមានចម្ងាយពីគ្នាប្រហែល ៥ម៉ែត្រ។ នៅលើផ្ទះ មានរនាបធ្វើអំពីឫស្សី គ្មានចានឆ្នាំង អង្ករ និងគ្រឿងហូបឡើយ។ មិនតែប៉ុណ្ណោះ នៅក្នុងផ្ទះ ខ្ញុំឃើញមានតែកន្ទេលរំចែកមួយ និងកួយចាស់ៗចំនួន៣ តែប៉ុណ្ណោះ។ មកដល់ផ្ទះស្នាក់នៅភ្លាម យើងនាំគ្នារៀបចំទុកដាក់អីវ៉ាន់ដែលយើងមាន ហើយទៅហូបបាយនៅក្នុងរោងបាយ។ បន្ទាប់មក ខ្ញុំទៅដឹកទឹកដាក់ពងអុងនៅក្បែផ្ទះ ហើយនាំគ្នាងូតទឹកផ្លាស់សម្លៀកបំពាក់ថ្មី ដែលអង្គការបានចែកឲ្យក្នុងម្នាក់២សម្រាប់។ នៅពេលយប់ គ្រួសាររបស់ខ្ញុំ ដេកនៅជុំគ្នានៅលើកន្ទេលរំចែកនិងដណ្តប់កួយរួមគ្នា។

ការងារប្រចាំថ្ងៃរបស់ខ្ញុំ

នៅពេលព្រឹកព្រលឹមស្រាងៗ ប្រហែលម៉ោង ៤ទៀបភ្លឺ មាន់កំពុងរងាវ មនុស្សម្នាកំពុងតែដេកលក់ស្កប់ស្កល់ ស្រាប់តែពួកកងតូច ឈ្មោះវ៉ែន និងផាន បានបង្ខំឲ្យខ្ញុំក្រោកពីដេកទៅកើបអាចម៍គោក្របីនៅក្នុងក្រោលគោយកទៅដាក់តាមវាលស្រែ។ ខ្ញុំត្រូវយកចប ដើម្បីទៅកើបដីដាក់ក្នុងបង្គី ប៉ុន្តែប្រសិនបើអាចម៍គោក្របីដែលស្ងួត ខ្ញុំត្រូវរើសដោយដៃ។ ខ្ញុំទៅដាក់ដីទាំងយប់ដែលមានគ្នាប្រហែលជាង១០នាក់ ដែលមានកុមារស្រីៗដូចគ្នា។ នៅតាមផ្លូវ យើងមានការភ័យខ្លាចណាស់ ព្រោះយើងដើរលើភ្លឺស្រែទាំងនៅងងឹត ហើយអាកាសធាតុធ្លាក់ខ្យល់ត្រជាក់ទៀត។ ពេលខ្លះ ខ្ញុំធុញនឹងការបង្ខំធ្វើការងារទាំងនេះណាស់ ប៉ុន្តែខ្ញុំមិន

ហ៊ាននិយាយទេ ព្រោះខ្លាចពួកខ្មែរក្រហមធ្វើបាប និងបង្អត់អាហារ។ ខ្ញុំត្រូវក្រោកពីទៀបភ្លឺរហូតដល់ម៉ោង៦ព្រឹកទើបបានសម្រាក ហើយម៉ោង ១១ថ្ងៃត្រង់ ខ្ញុំចាប់ផ្តើមបន្តការងាររហូតដល់ម៉ោង ៥ល្ងាច។ នៅចន្លោះម៉ោងពី ៦ព្រឹក ទៅម៉ោង ១១ថ្ងៃត្រង់ ពួកកងតូច ឲ្យខ្ញុំសម្រាក ប៉ុន្តែក៏បានឲ្យខ្ញុំជួយមើលប្អូនប្រុសពីរនាក់ ដែលមានឈ្មោះ ម៉ៅ និងនាថ។ ក្នុងមួយថ្ងៃៗ ខ្ញុំត្រូវធ្វើការងារចំនួន ៩ទៅ ១០ម៉ោង ឬអាចលើសនេះទៀតក៏មានដែរ។ ខ្ញុំនៅតែខិតខំធ្វើការងារដោយមិនហ៊ាននឈប់សម្រាកឡើយ។ ខ្ញុំលួចយំស្ទើរតែរាល់ថ្ងៃ ដោយសារតែខ្ញុំមិនដែលបានដេកគ្រប់គ្រាន់ទេ។ ខ្ញុំអស់កម្លាំងណាស់ ថែមទាំងគ្មានអាហារហូបចុកទៀតផង។ ខ្ញុំធ្លាប់បានសួរទៅកាន់មេក្រុមស្រីរបស់ខ្ញុំឈ្មោះ ថាន ថា «តើហេតុអ្វីបានជាឲ្យខ្ញុំធ្វើការងាររច្រើនម៉ោងលើសលប់រាល់ថ្ងៃហ្នឹងយ៉ាងនេះ? មេក្រុម ថាន ក៏ឆ្លើយថា «អង្គការឲ្យយើងធ្វើការរហូតហើយខំដាក់ដីឲ្យស្រូវដើម្បីកើតបានផលស្រូវច្រើន»។

ខែកត្តិកចូលមកដល់ ខ្យល់រំហើយធ្លាក់មកពីទិសខាងជើង ខ្ញុំនិងកុមារដទៃទៀត នាំគ្នាបោកបែន កណ្តាប់ស្រូវ។ ទិន្នផលស្រូវដែលប្រមូលបាននោះត្រូវមនុស្សវ័យចំណាស់ផ្សេងទៀតជាច្រើនមកកើប ហាល ហើយប្រមូលទុកនៅក្នុងឃ្លាំងដាក់ស្រូវ។ បន្ទាប់ពីបោកបែនស្រូវហើយ ខ្ញុំត្រូវធ្វើកិច្ចការផ្សេងមួយទៀត គឺរលាស់ចំបើងនិងកងចំបើងទុកមួយកន្លែងឲ្យមានរបៀបរៀបរយ។ ចំបើងទាំងអស់នោះទុកសម្រាប់គោក្របីស៊ី។ ថ្ងៃមួយ ខ្ញុំធ្លាក់ខ្លួនឈឺ ហើយបានសុំមេក្រុមរបស់ខ្ញុំសម្រាកមួយថ្ងៃ។ មេក្រុមរបស់ខ្ញុំតបវិញថា «សមមិត្តអាចសម្រាកបាន ប៉ុន្តែថ្ងៃស្អែកត្រូវទៅធ្វើជម្មតាវិញ»។

របបអាហារប្រចាំថ្ងៃ

នៅពេលដែលស្នូរសំឡេងជួងបន្លឺឡើង គ្រួសាររបស់ខ្ញុំ ត្រូវទៅហូបបាយនៅឯរោងបាយសហករណ៍រួមគ្នា។ រោងបាយនោះ មានចម្ងាយពីផ្ទះអ្នកភូមិប្រហែលជា១០០ម៉ែត្រ។ រោងបាយមានទំហំធំ ហើយអាចឲ្យអ្នកភូមិអង្គុយហូបបាយបានរាប់រយនាក់។ នៅជិតរោងបាយមានអណ្តូង ពាងទឹក វាលស្រែ និងផ្ទះរបស់

អ្នកភូមិ។ នៅពេលល្ងាចទៅហូបបាយ ខ្ញុំបានជួបមនុស្សជាច្រើននាក់ ដោយម្នាក់ៗសុទ្ធតែហៅវាត់ខ្លាំង។ មុនពេលហូបបាយប្រជាជនម្នាក់ៗត្រូវដើរទៅកាន់ចានដែកស្លាបព្រាដែក ម្នាក់មួយៗនិងតម្រង់ជួរម្តងម្នាក់ៗដើម្បីរង់ចាំទទួលអាហារ។

នៅក្នុងផ្ទះបាយ ខ្ញុំឃើញមានអ្នកដាំបាយធ្វើម្ហូបចំនួន៣នាក់ ដែលមានអាយុប្រហែល ៥០ឆ្នាំទៅ ៦០ឆ្នាំ។ ពួកគាត់បានដួសបាយ និងសម្លទុកមួយឆ្នាំងៗ ហើយដួសចែកទៅឲ្យប្រជាជនដោយប្រើជញ្ជីងថ្លឹង។ ប្រសិនបើប្រជាជនណាដែលធ្វើការងារច្រើនអាចទទួលបានអាហារមួយពេលចំនួន ៣ខាំ។ ខ្ញុំគឺជាកុមារ ទទួលបានអាហារត្រឹមតែចំនួន១ខាំទេ។ ចំណែកម្ហូបវិញ ភាគច្រើនសុទ្ធតែជាសម្លម្ហូត្រកួន សម្លដើមចេក និងពេលខ្លះដាក់សាច់ត្រី ហើយពេលខ្លះទៀតដាក់សាច់ជ្រូកដែរ ប៉ុន្តែភាគច្រើន ម្ហូបទាំងនោះមិនបានដាក់សាច់ឡើយ គឺដាក់តែអំបិល និងទឹក។ យើងទទួលបានសម្លក្នុងម្នាក់ចំនួន១វែក។ ពេលយើងហូបហើយ យើងត្រូវយកចាន ស្លាបព្រា ទៅលាងសម្អាត ហើយដាក់ផ្តាប់នៅលើគ្រែតែម្តង ដោយយើងរៀបចានដាក់ផ្សេង និងស្លាបព្រាដាក់ផ្សេង។

យើងទទួលបានត្រឹមតែអាហារចំនួន២ពេលតែប៉ុណ្ណោះក្នុងមួយថ្ងៃគឺពេលព្រឹក និងពេលល្ងាច។ ទោះបីជាយើងមិនមានអីហូបក៏ដោយ ក៏យើងមិនហ៊ានទៅយកបាយម្ហូបនិងលួចអីហូបដែរ ព្រោះយើងខ្លាចអង្គការយកទៅសម្លាប់។ យើងតែងតែផឹកទឹកបំបាត់ភាពស្រេកឃ្លាន។ សំណាងល្អដែរ ក្នុងមួយសប្តាហ៍ម្តង ចុងភៅបានធ្វើបង្អែមសម្រាប់ចែកគ្នាហូប ដែលភាគច្រើនចុងភៅធ្វើនំអាកោ។ នំអាកោនោះ ត្រូវចុងភៅយកទៅចំហុយ មានពណ៌ស និងមានទំហំប៉ុនកំភួនជើង ហើយមានរសជាតិផ្អែម ព្រោះចុងភៅបានដាក់ស្ករយ៉ាងច្រើន។ មេកងក៏ឲ្យយើងហូបទឹកស្ពោតដោយសេរីដែរជារៀងរាល់សប្តាហ៍។

ការស្លៀកពាក់ប្រចាំថ្ងៃ

មេក្រុម ជាអ្នកចែកសម្លៀកបំពាក់ដល់ក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនផ្សេងៗទៀត។ ក្នុងម្នាក់ៗយើងទទួលបានសម្លៀកបំពាក់ចំនួន ២សម្រាប់។ អាវនោះ គឺជាអាវដែលមានសាច់ក្រណាត់បើកកពណ៌ខ្មៅ ពណ៌អាចម៍សេះ

និងមានឡេវចំនួន៥។ អាវសម្រាប់មនុស្សប្រុសភាគច្រើនគឺដៃខ្លី ប៉ុន្តែសម្រាប់មនុស្សស្រីវិញ ភាគច្រើនគឺដៃវែង។ អាវដែលខ្ញុំទទួលបានពេលខ្លះមានទំហំធំជាងខ្លួនរបស់ខ្ញុំ។ ខ្ញុំបានដេរអាវនោះដោយដៃ ដើម្បីបញ្ចូលឲ្យវាមានទំហំអាចពាក់ទៅល្មម។ នៅពេលដេក ខ្ញុំពាក់អាវដៃខ្លីនិងពេលធ្វើការងារវិញ ខ្ញុំពាក់អាវដៃវែង ដើម្បីការពារកម្តៅថ្ងៃនៅពេលថ្ងៃត្រង់។ ចំណែកខោវិញ មេក្រុមបានចែកឲ្យយើងទៅតាមទំហំចង្កេះរបស់កុមារ។ ខោក៏ធ្វើពីក្រណាត់ពណ៌ខ្មៅ និងពណ៌អាចម៍សេះដែរ។ ខោមានចង្កេះកៅស៊ូ មានប្រវែងត្រឹមស្មងជើងខោសម្រាប់ស្រីៗ ចំណែកឯខោសម្រាប់ប្រុសៗ និងកុមារប្រុសវិញមានប្រវែងត្រឹមជង្គង់។ ម៉ែរបស់ខ្ញុំបានសួរទៅសមមិត្ត វ៉ែន និងផាន ថា «សម្លៀកបំពាក់ទាំងអស់នេះតើសមមិត្តបានមកពីណា»? ពួកគេបានឆ្លើយតបមកម៉ែរបស់ខ្ញុំវិញថា «កុំចង់ដឹងអី ខិតខំតែធ្វើការងារតាមបញ្ជារបស់អង្គការទៅបានហើយ»។ ឮដូច្នោះហើយ ម៉ែរបស់ខ្ញុំ បានដើរចេញទៅកន្លែងរ៉ែងអង្ករធម្មតា។ គាត់មិនហ៊ានសួរនាំទៅពួកគេទៀតទេ។

ខ្ញុំតែងតែបោកខោអាវរបស់ខ្ញុំ និងខោអាវប្អូនៗជារៀងរាល់ថ្ងៃបន្ទាប់ពីត្រលប់មកពីធ្វើការវិញ។ នៅពេលនោះ គ្មានសាប៊ូសម្រាប់បោកខោអាវទេ។ ខ្ញុំបោកជាមួយនឹងទឹកទទេ ដែលដឹកយកមកពីអណ្តូងនៅក្បែរផ្ទះ។ ពេលបោកខោអាវហើយ ខ្ញុំយកទៅហាលនៅខាងក្រោយផ្ទះ។ ក្រៅពីសម្លៀកបំពាក់ ខ្ញុំក៏ទទួលបានក្រមាដែរ។ ក្រមា អាចប្រើប្រាស់បានច្រើនបែបណាស់មិនថាបង់ក ជូតញើស ផ្លាស់ងូតទឹក និងធ្វើជាភួយដណ្តប់ដេកពេលយប់។ ក្រមានោះគ្បាញឡើងដោយអំបោះថ្នៃចេញជាពណ៌ក្រឡេក្រឡា ក្រហមលាយស ដែលមានបណ្តោយ ១ម៉ែត្រ និងទទឹងកន្លះម៉ែត្រ។ ក្រមារបស់ខ្ញុំ បានប្រើជារៀងរាល់ថ្ងៃ ប្រើទាល់តែរហែក និងពុកផុយអស់។ ម៉ែរបស់ខ្ញុំឃើញដូច្នោះបាននាំខ្ញុំឲ្យទៅសុំក្រមាពីមេក្រុម ហើយមេក្រុមបានឲ្យក្រមាខ្ញុំមួយ ថែមទាំងបានណែនាំខ្ញុំឲ្យប្រើប្រាស់ដោយប្រយ័ត្នដើម្បីកុំឲ្យឆាប់ខូច។ ខ្ញុំមានមួកធ្វើពីស្លឹកត្នោតសម្រាប់ពាក់ការពារកំដៅថ្ងៃនៅពេលទៅធ្វើការដែរ។ ចាស់ៗ ដែលរស់នៅក្នុងភូមិ គឺជាអ្នកធ្វើមួកនេះ។

បាត់បង់សិទ្ធិសេរីភាព

ក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមបំបែកសមាជិកគ្រួសារនីមួយៗ ឲ្យទៅរស់នៅកន្លែងផ្សេងៗពីគ្នា។ ឪពុក និងបងស្រីរបស់ខ្ញុំ ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅ និងធ្វើការងារនៅកន្លែងផ្សេងទៀត។ ខ្ញុំនឹកឪពុកនិងបងស្រីរបស់ខ្ញុំណាស់ មិនដឹងថាពេលណាបានជួបគាត់ទៀតទេ។ រហូតដល់ឆ្នាំ១៩៧៨ ខ្មែរក្រហមកាន់តែរឹតបន្តឹងខ្លាំងឡើងៗ។ មនុស្សម្នាមិនហ៊ាននិយាយជាមួយគ្នាទេនៅពេលជួបគ្នាម្តងៗ។ នៅពេលដែលខ្ញុំជួបនឹងកុមារផ្សេងទៀត ក៏ខ្ញុំមិនហ៊ាននិយាយស្តីជាមួយពួកគេឡើយ ប៉ុន្តែប្រសិនបើយើងចង់និយាយគ្នា ក៏និយាយដោយលួចលាក់ដែរ។ នៅពេលយប់ មានកងឈ្លបមកនៅក្រោមផ្ទះរបស់ប្រជាជនចាំស៊ើបការណ៍ខ្លាចក្រែងគ្រួសារណាមានគំនិតក្បត់ ពួកគេនឹងរាយការណ៍ឲ្យទៅថ្នាក់លើភ្លាម។ រាល់ពេលយប់ ខ្ញុំមិនហ៊ាននិយាយអ្វីច្រើនទេ ក្រៅពីខំសម្ងំដេករហូតដល់ព្រឹក។

នៅក្នុងឆ្នាំ១៩៧៨ ដដែល នៅយប់មួយ ឪពុក និងបងស្រីរបស់ខ្ញុំ បានលួចចេញពីភូមិមកលេងជាមួយយើង។ ឪពុករបស់ខ្ញុំ បាននិយាយសំឡេងឮៗថា គាត់លួចចេញមកលេងយើងនេះដោយសារតែនឹកយើងខ្លាំងពេក។ ពេលនោះ កងឈ្លបបានឮប៉ុន្តែពួកគេមិនបានឡើងទៅចាប់យើងទាំងយប់នោះទេ។ គ្រួសាររបស់ខ្ញុំបានដេកជុំគ្នាទាំងសប្បាយចិត្ត ព្រោះគិតថាគ្មានអ្នកណាដឹងទេ។ ព្រឹកឡើងមានរំងាវប្រហែលជាម៉ោង៣ទៀបភ្លឺ ឪពុក និងប្រុសស្រីរបស់ខ្ញុំ បានចាកចេញទៅវិញ។

ជម្លៀសលើកទី២

នៅពេលព្រឹកឡើង កងតូចឈ្មោះ ផាន បានមកដល់ផ្ទះគ្រួសាររបស់ខ្ញុំស្នាក់នៅ រួចនិយាយប្រាប់យើងថា «ដល់ពេលដែលគ្រួសារសមមិត្តត្រូវទៅនៅជុំគ្នាវិញហើយ»។ នៅពេលនោះខ្ញុំកំពុងតែយកចំបើងទុកហើយផានបានប្រាប់ខ្ញុំថាមិនធ្វើការនៅទីនេះទៀតទេ ហើយត្រូវផ្លាស់ប្តូរទៅធ្វើការងារនៅកន្លែងផ្សេងនៅតំបន់សម្បកមាន់វិញ។ ខ្ញុំឆ្ងល់ក៏សួរទៅ ផាន វិញថា «តើតំបន់សម្បកមាន់នៅឯណាវិញ»? ផាន ក៏ស្រែកដាក់មកខ្ញុំថា «សមមិត្តឯងកុំនិយាយច្រើន ស្តាប់តាមបញ្ជារបស់អង្គការទៅបានហើយ»។ ឮដូច្នោះហើយ ខ្ញុំមិនហ៊ាននិយាយអ្វីទៀតទេ គឺបានត្រឹមតែនៅស្ងៀម។

អ្នកភូមិដែលរស់នៅក្នុងភូមិស្មោង បានមកប្រាប់ខ្ញុំថា «សមមិត្ត កុំទៅតាមអង្គការអី។ អង្គការយកទៅកសាងរៀនសូត្រ ហើយមានមនុស្សជាច្រើន ដែលអង្គការបានយកទៅតំបន់សម្បកមាន់ មិនដែលឃើញត្រលប់មកវិញនោះទេ»។ រំពេចនោះ ផាន បានឆ្លើយតបទៅនឹងអ្នកភូមិដែលប្រាប់ខ្ញុំនោះថា «សមមិត្តទាំងអស់គ្នាកុំមកចេះដឹងរឿងគ្រួសារសមមិត្តផ្សេងអី! ប្រយ័ត្នត្រូវបញ្ជូនទៅតំបន់សម្បកមាន់ដែរទៅ»។ អ្នកភូមិបានឮដូច្នេះហើយ មិនហ៊ាននិយាយអ្វីទៀតទេ។ ពួកគាត់បានដើរចេញទាំងភ័យខ្លាច ហើយទៅធ្វើការរៀងៗខ្លួនបាត់អស់ទៅ។

បន្តិចក្រោយមក ម៉ែរបស់ខ្ញុំ បាននិយាយសូមអង្វរ ផាន ថា «ប្តីនិងកូនស្រីរបស់ខ្ញុំ គាត់មិនដែលមកលេងខ្ញុំទេ ហើយពួកគេទើបតែមកលេងខ្ញុំម្តងនេះ ដោយសារតែគាត់នឹកបងប្អូន និងប្រពន្ធពេក ទើបគាត់មកលេង។ ខ្ញុំបានប្រាប់គាត់ថាមិនឲ្យមកលេងទៀតដែរ ព្រោះមិនត្រូវនឹងគោលការណ៍របស់អង្គការ»។ ផាន បានឆ្លើយតបវិញថា «មិនបានទេ ត្រូវតែបញ្ជូនឲ្យរស់នៅកន្លែងផ្សេង ដើម្បីកុំឲ្យគ្រួសារផ្សេងយកគំរូតាម»។

ម៉ែ និងបងស្រីម៉ុមរបស់ខ្ញុំ បានរៀបចំសម្លៀកបំពាក់ និងច្រកទឹកសម្រាប់ផឹកនៅតាមផ្លូវ ចំណែកឯបងប្រុសយ៉ុង និងយ៉ាយ ទៅដឹកក្របីមកទឹមរទេះសម្រាប់ធ្វើដំណើរទៅកាន់តំបន់សម្បកមាន់។ ការធ្វើដំណើរតាមផ្លូវមិនខុសប្លែកពីការជម្លៀសលើកដំបូងនោះទេ គ្រាន់តែគោលដៅដែលយើងត្រូវទៅកន្លែងខុសគ្នាពីការជម្លៀសលើកដំបូង។ នៅតាមផ្លូវទៅសម្បកមាន់ យើងហត់ខ្លាំងណាស់បែកញើសជោកអាវ យើងបានសុំ ផាន ឈប់សម្រាកផឹកទឹកនៅក្រោមដើមឈើសិន ដើម្បីយកកម្លាំងបន្តដំណើរទៅមុខទៀត។ ផាន អនុញ្ញាតឲ្យសម្រាកបាន តែមិនអាចឈប់សម្រាកបានយូរពេកទេ ព្រោះប្រញាប់ទៅដល់គោលដៅ។ នៅពេលសម្រាក ម៉ែបានខ្សឹបប្រាប់ខ្ញុំ និងបងប្រុសបងស្រីរបស់ខ្ញុំថា «ពេលយើងធ្វើដំណើរទៅដល់ពាក់កណ្តាលផ្លូវ ម៉ែនឹងយកលេសថាចុកពោះ ហើយកូនៗទាំងអស់គ្នាត្រូវនាំគ្នាយំឲ្យពួកវាអាណិត»។ ម៉ែរបស់ខ្ញុំបានបន់ស្រន់ដល់ព្រះពុទ្ធរូបព្រះអង្គខ្មៅនៅវត្តបូរណញ្ញាណកោងកាងថា «ឱព្រះអង្គអើយ សូមព្រះអង្គមេត្តាជួយកូនចៅផង ពេលនេះកូនចៅមានទុក្ខលំបាកធ្ងន់ណាស់»។

យើងធ្វើដំណើរហូតដល់យប់ រួចឈប់សម្រាក។ ម៉ែរបស់ខ្ញុំ បានដេកហើយ សុបិន្តថា មានព្រះអង្គខ្មៅមួយអង្គហោះមក ហើយញញឹមដាក់គាត់ ថែមទាំងផ្តល់ក្តីសង្ឃឹមដល់គាត់ដែរ។ លុះស្អែកឡើង ម៉ោងប្រហែល ១១ថ្ងៃត្រង់ ស្រាប់តែមេឃងងឹតឈឹង ហើយមានភ្លៀងធ្លាក់យ៉ាងខ្លាំង។ គ្រួសាររបស់ខ្ញុំមិនបានឈប់សម្រាកឡើយ ព្រោះត្រូវ ផាន បញ្ជាឲ្យបន្តដំណើរទៅមុខទាំងរងាញាក់ញ័រដៃជើង និងទឹកមុខស្លេកស្លាំង។ ពេលធ្វើដំណើរហូតដល់ពាក់កណ្តាលផ្លូវ ម៉ែរបស់ខ្ញុំ ធ្វើពុតជាឈឺចុកពោះ។ ពេលនោះ ខ្ញុំ និងបងប្អូនផ្សេងទៀតយំខ្លាំងៗ ដើម្បីឲ្យពួកកងតូចអាណិតអាសូរ កុំឲ្យគ្រួសាររបស់ខ្ញុំបន្តដំណើរទៅមុខទៀត។ ផាន បាននិយាយថា «ទោះជាឈឺខ្លាំងយ៉ាងណា ក៏យើងត្រូវតែធ្វើដំណើរទៅមុខទៀត មិនត្រូវឈប់ឡើយ»។ ម៉ែរបស់ខ្ញុំ យំអង្វរ ផាន និងវ៉ែន ថា «ខ្ញុំមិនអាចបន្តដំណើរទៅមុខបានទៀតទេ ព្រោះខ្ញុំចុកពោះខ្លាំងណាស់»។ ចំណែកខ្ញុំ និងបងប្អូនផ្សេងទៀតយំអង្វរព្រមៗគ្នាដែរ។ វ៉ែន ទន់ចិត្តអាណិតយើងមិនចង់ឲ្យធ្វើដំណើរបន្តទៅមុខទៀតទេ។ វ៉ែន បាននិយាយទៅកាន់ ផាន ថា «ឥឡូវគ្រួសារសមមិត្តណាន មើលទៅលំបាកណាស់។ គ្រួសារសមមិត្តណាន ទើបតែធ្វើខុសម្តងទេ គួរលើកលែងទោសឲ្យគ្រួសារសមមិត្តទៅ សមមិត្តផាន»។ សមមិត្តផានតបវិញថា «មិនអាចលើកលែងទោសឲ្យបានទេ បើលើកលែងទោសឲ្យនោះសមមិត្តផ្សេងនឹងយកតម្រាប់តាមមិនខានឡើយ»។ សមមិត្តវ៉ែន នៅតែព្យាយាមនិយាយសម្រួលទៅសមមិត្តផានថា «សមមិត្តផ្សេងដែលធ្លាប់ធ្វើលើកមុនៗយកទៅតំបន់សម្បកមាន់ ខ្ញុំ មិនដែលសុំទេ ប៉ុន្តែលើកនេះខ្ញុំសុំ។ គ្រួសារសមមិត្តណាន និងគ្រួសារសមមិត្តផ្សេងទៀត មិនប្រព្រឹត្តបែបនេះទៀតឡើយ»។

ការព្យាយាមអង្វររបស់សមមិត្តវ៉ែន បានធ្វើឲ្យកងតូច ផាន បានសម្រេចចិត្តយល់ព្រមឲ្យគ្រួសាររបស់ខ្ញុំត្រលប់ទៅរស់នៅក្នុងភូមិស្មោងវិញ។ គ្រួសាររបស់ខ្ញុំអរគុណដល់កងតូច វ៉ែន បានជួយគ្រួសាររបស់ខ្ញុំ ហើយយើងបានធ្វើដំណើរត្រលប់មកភូមិស្មោងវិញទាំងចិត្តរីករាយ។

ការធ្វើដំណើរត្រលប់មកភូមិស្មោងវិញ ត្រូវចំណាយអស់រយៈពេល១ថ្ងៃកន្លះទើបមកដល់។ គ្រួសាររបស់ខ្ញុំ ធ្វើដំណើរដោយភាពសប្បាយរីករាយឡើងវិញ។ ការធ្វើដំណើរត្រលប់មកវិញ យើងមិនសូវហត់នឿយនោះទេ។ ពេលមេឃក្តៅខ្លាំង យើងក៏ឈប់សម្រាកហូបបាយផឹកទឹកតាមធម្មតាដែរ។ នៅពេលយប់ ម៉ែរបស់ខ្ញុំយល់សប្តិទៀតថា «ព្រះអង្គខ្មៅហោះមកហើយញញឹមដាក់គាត់»។ ថ្ងៃចុងក្រោយនៃការធ្វើដំណើរត្រលប់មកភូមិស្មោងវិញ យើងមិនហ៊ានឈប់សម្រាកអ្វីទេ។ យើងត្រូវប្រញាប់មកដល់ភូមិវិញ ដើម្បីធ្វើការងារបន្តដែលអង្គការបានកំណត់ឲ្យ។

ជម្លៀសលើកទី៣

បន្ទាប់ពីរួចផុតពីការជម្លៀស គ្រួសាររបស់ខ្ញុំនៅក្នុងភូមិស្មោងរហូតមិនដែលកើតមានបញ្ហាអ្វីទៀតនោះទេ។ យើងរស់នៅក្នុងភូមិស្មោងរហូតដល់ខែមករាឆ្នាំ១៩៧៩ ទើបគ្រួសាររបស់ខ្ញុំ និងប្រជាជនផ្សេងទៀត ត្រូវបានជម្លៀសចេញពីភូមិរយៈពេល២ថ្ងៃ។ សមមិត្ត ផាន បានប្រាប់ដល់ប្រជាជនទាំងអស់ថា ដល់ពេលដែលត្រូវជម្លៀសទៅរស់នៅឯខាងលិចទន្លេមេគង្គហើយ។ គ្មានអ្នកណាហ៊ាននិយាយតវ៉ាអ្វីទេ ព្រោះខ្លាចអង្គការធ្វើបាប។ គ្រួសារនីមួយៗ មិនបានរៀបចំសម្លៀកបំពាក់នោះទេ គ្រាន់តែមានទឹកនិងអាហារបន្តិចបន្តួចយកទៅតាមខ្លួនតែប៉ុណ្ណោះ។ គ្រួសាររបស់ខ្ញុំ បានដិះរទេះចេញទៅទាំងព្រឹកដោយមិនបានយកអ្វីទៅតាមខ្លួនច្រើនឡើយ។

យើងធ្វើដំណើរទៅដល់សួង។ នៅតាមវាលស្រែមានភាពស្ងប់ស្ងាត់ មានស្រែខ្លះច្រូតស្រូវអស់ និងស្រែខ្លះទៀតមិនទាន់បានច្រូតនៅឡើយទេ ព្រោះប្រជាជននៅតំបន់នោះ ត្រូវបានពួកខ្មែរក្រហម ជម្លៀសទៅរស់នៅខាងលិចទន្លេមេគង្គដែរ។ យើងចេះតែធ្វើដំណើរទៅមុខទៀតរហូត ហើយដល់ពេលយប់ទើបយើងបោះតង់ឈប់សម្រាកនៅលើភ្លឺស្រែ។ បងយ៉ុង និងបងយ៉ាយ ទៅរកចាប់ត្រីមកធ្វើជាម្ហូបអាហារ ចំណែកម៉ែរបស់ខ្ញុំមើលថែប្អូននាថ និងម៉ៅ។ ខ្ញុំ និងបងស្រីម៉ុមនាំគ្នាទៅរកឧសមកបង្កាត់ភ្លើងដាំបាយ និងសម្រាប់ដុតត្រី។ ក្រោយពេលដែលដាំបាយ និងដុតត្រីឆ្អិន យើងនាំគ្នាហូបបាយតែបន្តិចម្នាក់តែប៉ុណ្ណោះ។ យើងមិនអាចហូបឆ្អែតបានទេ ព្រោះយើងទុកអង្ករខ្លះសម្រាប់ថ្ងៃស្អែកទៀត។

ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ យើងចាប់ផ្តើមធ្វើដំណើរទៅមុខទៀត។ លុះទៅដល់ ជុប យើងឃើញមានចម្ការកៅស៊ូជាច្រើនហិកតា។ នៅក្នុងចម្ការកៅស៊ូនោះមានខ្ទម និង ផ្ទះ ប៉ុន្តែមិនឃើញមានមនុស្សរស់នៅទេ។ ក្រោយមក យើងធ្វើដំណើរទៅជិតដល់ទន្លេ ក៏មានគ្រួសារជាច្រើនទៀតដែលទៅដល់ទីនោះដែរ។ ខ្ញុំបានរកមើលឪពុក និងបងស្រីណាក់ ប៉ុន្តែខ្ញុំមិនឃើញពួកគាត់ទាល់តែសោះ។ ខ្មែរក្រហមបានបង្ខំគ្រួសាររបស់ខ្ញុំ និងគ្រួសារផ្សេងទៀត ឲ្យឆ្លងទន្លេមេគង្គ ដើម្បីយកទៅសម្លាប់នៅខាងលិចទន្លេមេគង្គ។ ភ្លាមៗនោះ ស្រាប់តែមានស្នូរគ្រាប់កាំភ្លើង និងសំឡេងយន្តហោះ វាយប្រហារទៅលើក្រុមខ្មែរក្រហម។ គ្រួសាររបស់ខ្ញុំ បាននាំគ្នារត់ឡើងមកទិសខាងកើតវិញ។ យើងរត់គេចពីការតាមសម្លាប់របស់ខ្មែរក្រហម និងរត់គេចពីគ្រាប់កាំភ្លើង និងគ្រាប់បែក ដែលកំពុងវាយទៅលើខ្មែរក្រហម។ ខ្ញុំរត់យ៉ាងលឿនកាត់ព្រៃកៅស៊ូ និងវាលស្រែ។ នៅពេលដែលខ្ញុំកំពុងតែរត់ៗ ស្រាប់តែខ្ញុំត្រូវឆ្លងកាត់ត្រពាំងមួយ ដែលគ្មានស្ពានឆ្លងទេ ព្រោះខ្មែរក្រហមបានកម្ទេចស្ពាននោះចោលហើយ។ ខ្ញុំពិបាកឆ្លងត្រពាំងនោះណាស់ ព្រោះខ្ញុំមិនចេះហែលទឹក។ រំពេចនោះមានក្តារនៅសល់ពីសំណល់ស្ពានអណ្តែតលើទឹក ហើយខ្ញុំបានខំទៅតោងក្តារនោះសម្រាប់ហែលឆ្លងទឹកត្រពាំង។ ជីវិតរបស់ខ្ញុំ ស្ទើរតែស្លាប់ដោយសារតែរត់គេចពីគ្រាប់កាំភ្លើង និងគ្រាប់បែក ប៉ុន្តែខ្ញុំនៅតែខិតខំជម្នះពីសេចក្តីស្លាប់នោះ។

រហូតពេលយប់ សមាជិកគ្រួសាររបស់ខ្ញុំ មិនទាន់បានជួបគ្នាអស់នៅឡើយ។ ខ្ញុំជួបជុំជាមួយម៉ែ និងបងប្អូន ប៉ុន្តែឪពុក និងបងស្រីរបស់ខ្ញុំ មិនទាន់បានជួបជុំគ្នានៅឡើយ។ ខ្ញុំគិតថាលែងបានជួបពួកគាត់ទៀតហើយ ព្រោះយើងមិនបានដឹងដំណឹងពីគាត់ទាល់តែសោះ។ យប់នោះ បងប្រុសទាំងពីរនាក់របស់ខ្ញុំទៅចាប់ត្រីធ្វើម្ហូប ចំណែកឯម៉ែ និងបងស្រីម៉ុម រៀបចំតង់សម្រាប់ដេក។ រីឯខ្ញុំវិញទៅរកឧសមកបង្កាត់ភ្លើង។ លុះព្រឹកឡើងថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គ្រួសាររបស់ខ្ញុំបានបន្តដំណើរទៅភាគខាងកើតរហូតដល់ភូមិកោងកាង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាមវិញ។

ជួបជុំគ្រួសារឡើងវិញ

នាពេលល្ងាចដល់ស្រុកកំណើតភ្លាម កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាមិនទាន់ឲ្យយើងទៅរស់នៅក្នុងភូមិវិញទេ។ យើងតម្រូវឲ្យស្នាក់នៅក្នុងជំរំនៅវត្តបូរណញ្ញាណកោងកាង មួយរយៈពេលសិន។ នៅក្នុងវត្តគ្មានព្រះសង្ឃនោះទេ។ ខ្ញុំចេះតែព្យាយាមខំសម្លឹងមើលក្រែងបានឃើញឪពុក និងបងស្រីរបស់ខ្ញុំ។ ពេលនោះស្រាប់តែខ្ញុំបានឃើញឪពុករបស់ខ្ញុំ ហើយស្រែកប្រាប់ម៉ែរបស់ខ្ញុំថា «នោះពុក និងបងស្រីណាក់ម៉ែ»។ ម៉ែរបស់ខ្ញុំ បានក្រឡេកទៅមើលឃើញ ហើយសប្បាយចិត្តយ៉ាងខ្លាំង។ ចំណែកឪពុក និងបងស្រីរបស់ខ្ញុំវិញ នៅពេលឃើញយើងហើយក៏ស្ទុះរត់មកជួបគ្នាទាំងទឹកភ្នែក។ នៅពេលនោះ ប្រជាជនដែលរស់នៅក្នុងវត្តទទួលបានការឧបត្ថម្ភពីអគ្គស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន ដែលចុះមកចែករួមមាន តង់ អង្ករ និងម្ហូបអាហារ។ ក្នុងមួយគ្រួសារទទួលបានតង់មួយ។ គ្រួសាររបស់ខ្ញុំ រស់នៅក្នុងជំរំក្នុងវត្តអស់រយៈពេលជិត១ខែ ទើបបានត្រលប់ទៅរស់នៅផ្ទះក្នុងភូមិវិញ។

ចប់

៣៧
រឿងចិត្តចងចាំ

អ្នកនិពន្ធ ៖ សាម សុនិត

៣៧ ~ រឿង ចិត្តចងចាំ

ថ្ងៃ២០ ឧសភា ទិវាជាតិនៃការចងចាំ

ថ្ងៃចន្ទ ទី២០ ខែឧសភា ឆ្នាំ២០១៩ **ម៉ោង**៨ព្រឹក នៅក្នុងបរិវេណវត្តសុគន្ធារាម ហៅវត្តស្គន់ ស្ថិតនៅក្នុងភូមិប៉ាណា ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ខ្ញុំបានចូលរួមក្នុងកម្មវិធីទិវាជាតិនៃការចងចាំ។ សូរសំឡេងអានវិយោគកថា និងស្នូតកំណាព្យ បានលាន់ឮឡើងយ៉ាងពីរោះលន្លង់លន្លោច ស្រងេះស្រងោច ប្រកបដោយអត្ថន័យសែនកម្សត់អន្ទងបេះដូង និង មនោសញ្ចេតនារបស់ខ្ញុំឲ្យនឹករឭក ដល់ស្លាកស្នាមជីវិតកាលពីអតីតកាល។

មិនអាចបំភ្លេចបាន

សង្គ្រាម! សង្គ្រាម! សង្គ្រាម! សង្គ្រាមបានបង្កិនបង្ហោចគ្រប់បែបយ៉ាង។ ឃ្លានេះ ខ្ញុំធ្លាប់តែបានឮនៅក្នុងស្នាដៃប្រលោមលោកខ្មែររឿង «គូលីកំណែន» ជាស្នាដៃរបស់លោក អ៊ឹម ចុក ដែលបានបង្ហាញពីសោកនាដកម្មនិងមហន្តរាយនៃសង្គ្រាមនៅក្នុងប្រទេសកម្ពុជានាសម័យក្រោមនឹមអាណានិគមបារាំងនិងជប៉ុន។ មកដល់ពេលនេះ សង្គ្រាមបានចាប់ផ្តើមរះឡើងម្តងទៀតក្នុងមាតុភូមិដ៏សែនកម្សត់របស់ខ្ញុំ ថែមទាំងផ្តល់នូវផលវិបាកនិងឥទ្ធិពលដ៏ខ្លាំងក្លាលើសពីខ្លឹមសារនៅក្នុងប្រលោមលោករាប់រយលានដងទៅទៀត។

ដើមឆ្នាំ១៩៧៣ ក្នុងរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយលោក សេនាប្រមុខ លន់ នល់ ខ្ញុំគឺជាគ្រូពេទ្យទាហានម្នាក់រស់នៅក្នុងបន្ទាយស្លឹកក្បែរមន្ទីរពេទ្យរុស្សីក្នុងគ្រួសារមួយដែលរស់នៅប្រកបដោយសេចក្តីសុខ និង

សុភមង្គល ជាមួយនឹងបងប្អូនប្រុសស្រី៧នាក់។ ម្តាយរបស់ខ្ញុំជាមេផ្ទះ។ នៅពេលនោះ ស្ថានភាពរបស់ប្រទេសជាតិ កំពុងតែជួបប្រទះនូវអសន្តិសុខ និងបញ្ហាប្រឈមមុខដាក់គ្នាយ៉ាងខ្លាំងរវាងកងទ័ពរបស់សាធារណរដ្ឋខ្មែរ និងកងទ័ពរំដោះ ហើយបានបង្កជាសោកនាដកម្ម ជម្លោះ អំពើហិង្សា និងភាពភ័យខ្លាចដល់ប្រជាជនខ្មែរទូទាំងប្រទេស។

ថ្ងៃមួយ ឪពុកម្តាយរបស់ខ្ញុំ បានទទួលដំណឹងពីស្រុកកំណើតនៅភូមិប៉ាណា ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម មកថា ជីដូនខាងឪពុករបស់ខ្ញុំ បានទទួលមរណភាព។ ឪពុក អ៊ំប្រុស និងខ្ញុំ បានធ្វើដំណើរចេញពីទីក្រុងភ្នំពេញឆ្ពោះមកកាន់ស្រុកកំណើត ដើម្បីចូលរួមពិធីបុណ្យសពតាមប្រពៃណី។ បន្ទាប់ពីពិធីបុណ្យសពបានបញ្ចប់ ឪពុករបស់ខ្ញុំ ត្រូវមានការកិច្ចត្រលប់ទៅភ្នំពេញវិញជាបន្ទាន់ ព្រោះស្ថានភាពប្រទេសជាតិហាក់ដូចជាកំពុងតែឈានទៅរកសមុទ្រទុក្ខភ័យនៃសង្គ្រាមក្នុងជម្លោះរវាងខ្មែរគ្នាឯងប្រកបដោយមហិច្ឆតា ដោយមានការលូកដៃកូរកាយពីសំណាក់បរទេសជាខ្នងបង្អែក។ ក្នុងកាល:ទេស:បែបនេះ ឪពុកនិងអ៊ំប្រុសរបស់ខ្ញុំ ត្រូវបង្ខំចិត្តត្រលប់ទៅភ្នំពេញវិញទាំងមិនអស់ចិត្ត។ ចំណែក ខ្ញុំ ត្រូវបានអ៊ំស្រីខាងម្តាយ ឃាត់ឲ្យនៅលេងស្រុកកំណើតជាមួយបងប្អូនសាច់ញាតិមួយរយៈសិន។ ការបែកគ្នានៅពេលនោះ ខ្ញុំសង្កេតឃើញទឹកមុខឪពុករបស់ខ្ញុំហាក់ដូចជាបង្កប់នូវក្តីបារម្ភ និងពោរពេញទៅដោយទុក្ខព្រួយ។ វាហាក់ដូចជាប្រផ្នូលឲ្យគាត់បានដឹងជាមុនថា ការបែកគ្នាលើកនេះជាការបែកគ្នាអស់មួយជីវិត។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំមិនដែលបានឃើញមុខរបស់គាត់រហូតទល់សព្វថ្ងៃនេះ។

រំលងមកបានប្រហែល២ថ្ងៃបន្ទាប់ពីឪពុករបស់ខ្ញុំត្រលប់ទៅទីក្រុងភ្នំពេញវិញ ភ្លើងសង្គ្រាមចាប់ផ្តើមឆេះឡើងយ៉ាងសន្ធោសន្ធៅ។ កងទ័ពរំដោះ បានបិទផ្លូវនៅមុំឡជ្រុងខាងលិចទីប្រជុំជនស្គន់ ដោយរំលំដើមចំបក់ដ៏ធំយ៉ាងបិទផ្លូវលែងឲ្យទៅមក។ ខ្ញុំលែងបានវិលត្រលប់ទៅជួបជុំគ្រួសារវិញ ហើយក៏បានសម្រេចចិត្តរស់នៅជាមួយអ៊ំស្រីខាងម្តាយរបស់ខ្ញុំនៅក្នុងភូមិស្រាមលិច ឃុំស្រម៉រ ស្រុកជើងព្រៃ ខេត្តកំពង់ចាម រហូតមក។

ឆ្នាំ១៩៧៤ កងទ័ពរំដោះបានវាយផ្តាច់និងគ្រប់គ្រងទីប្រជុំជនស្ទើរទាំងមូល។ ពេលនោះហើយដែលខ្ញុំបានមើលឃើញយ៉ាងច្បាស់ពីផលវិបាកនិងមហន្តរាយនៃសង្គ្រាមស៊ីវិលរវាងកងទ័ព លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ ជារៀងរាល់ថ្ងៃ ប្រជាជនរស់នៅយ៉ាងលំបាកវេទនា ព្រាត់ប្រាស់ក្រុមគ្រួសារ ញាតិមិត្ត បងប្អូន ភ្នែកនៅនឹងកញ្ចឹងក រត់គេចតែពីគ្រាប់ផ្លោងរត់ចូលក្នុងរណ្តៅត្រង់សេគ្មានបានប្រកបរបររកស៊ីធ្វើការអ្វីឡើយ ព្រមទាំងខ្វះខាតម្ហូបអាហារហូបចុកទៀត។

ដើមឆ្នាំ១៩៧៥ កងទ័ពរំដោះបានវាយផ្តាច់យកបានខេត្តកំពង់ចាមទាំងមូល។ រហូតមកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហម បានគ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុង ដោយបានជម្លៀសប្រជាជនចេញពីទីក្រុងឆ្ពោះទៅកាន់គោលដៅផ្សេងៗគ្នា។ ដើមខែឧសភា ឆ្នាំ១៩៧៥ ពេលវេលានៃការរង់ចាំ ក្នុងការជួបជុំគ្រួសាររបស់ខ្ញុំបានមកដល់។ ខ្ញុំបានជួបជាមួយម្តាយរបស់ខ្ញុំនៅភូមិថ្មី ឃុំស្រម៉រ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ពួកគាត់ត្រូវបានពួកខ្មែរក្រហមបណ្តេញ និងជម្លៀសទាំងបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញឆ្ពោះមកកាន់ទឹកដីស្ទើរក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ អារម្មណ៍រំភើប និងត្រេកអរនៅពេលនោះពិតជាមានទំហំធំធេងមិនអាចពិពណ៌នាបានឡើយ ព្រោះខ្ញុំតែងតែគិតថាប្រហែលជាយើងបែកគ្នាអស់មួយជីវិតហើយ។ ម្តាយរបស់ខ្ញុំ បានស្ទុះរត់មកឱបខ្ញុំទាំងទឹកភ្នែក អមនឹងស្នាមញញឹមដ៏ក្រៀមក្រំ ដោយពោលថា៖

ម្តាយ៖ «សុផល! សុផល! សុផល! ម៉ែស្មានថា មួយជាតិនេះ ម៉ែលែងបានឃើញរូបកូនទៀតហើយ!»។

ខ្ញុំ៖ «ម៉ែ!ម៉ែ!ម៉ែ!» ខ្ញុំស្រែកហៅម៉ែព្រោះខ្ញុំរំភើបណាស់ពេលឃើញគាត់ ហើយខ្ញុំរត់ទៅចាប់ក្រសោបឱបប្រាណដ៏កក់ក្តៅរបស់គាត់យ៉ាងមានសេចក្តីសុខជាទីបំផុត រួចសួរទៅកាន់គាត់ថា «ចុះប៉ាទៅណាបាត់ហើយម៉ែ?»។

ម្តាយ៖ «ប៉ាកូន! ប៉ាកូន! គាត់ស្លាប់បាត់ហើយ» និយាយរួច គាត់ស្រែកទ្រហោយំខ្លាំងៗ។

ខ្ញុំ៖ «ហេតុអ្វីបានជាប៉ាស្លាប់?»។

ម្តាយរបស់ខ្ញុំអង្អែលខ្នងខ្ញុំលាយឡំនឹងសម្តីអួលដើមកថា៖

ម្តាយ៖ «គាត់ស្លាប់ពេលគាត់ចុះទៅជួយសង្គ្រោះទាហានរបួសនៅអរិយក្សត្រ គាត់ត្រូវពួកទាហានរំដោះបាញ់សម្លាប់ អ៊ំអិន របស់កូន ជាអ្នកប្រាប់ម៉ែ »។

ខ្ញុំ៖ «ពុទ្ធោប៉ា! ប៉ាស្លាប់ព្រោះតែសង្គ្រាម ប៉ាស្លាប់ព្រោះតែលះបង់ជីវិតដើម្បីជាតិ ហេតុអ្វីបានជាព្រហ្មលិខិតមិនអាណិត និងជួយសង្គ្រោះប៉ាខ្ញុំផង?»។

បន្ទាប់ពីបានជួបគ្នាម្តងនោះមក ខ្ញុំ និងម្តាយ លែងបានជួបគ្នា ព្រោះពួកយើងសុទ្ធតែរវល់រៀងៗខ្លួន។ ខ្ញុំជាប្រជាជនចាស់ ឯម្តាយខ្ញុំជាប្រជាជនថ្មី។ ទោះបីជាភូមិដែលខ្ញុំរស់នៅ និងភូមិដែលម្តាយរបស់ខ្ញុំរស់នៅស្ថិតនៅក្នុងស្រុកតែមួយ និងមានចម្ងាយផ្លូវត្រឹមតែ៨គីឡូម៉ែត្រពីគ្នាក៏ដោយ ខ្ញុំ និងម្តាយ ហាក់បីដូចជារស់នៅក្នុងពិភពលោកពីរផ្សេងគ្នា។ យើងពិបាកជួប ពិបាកនិយាយ និងពិបាកសព្វបែបយ៉ាងរកអ្វីមកប្រៀបប្រដូចមិនបានឡើយ។

ក្នុងវ័យ១៤ឆ្នាំ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យកាប់ដើមទន្ទ្រានខែត្រយកមកធ្វើជីនៅពេលព្រឹក និងមើលគោមួយភូមិនៅពេលរសៀលជាមួយចាស់ៗចំនួន៣នាក់។ អង្គការបានរៀបចំឲ្យមានរោងបាយរួម និងដកហូតនូវរាល់ទ្រព្យសម្បត្តិជាក់ជាសហករណ៍រួមគ្នា។ ខ្ញុំមានតែចានដែកមួយ និងស្លាបព្រាមួយទុកសម្រាប់ហូបបបរវេរដូចទឹក។ ក្នុងបបរមួយខ្ទះគ្នោតធំ មេចុងភៅដាក់អង្ករតែ២កំប៉ុង និងលាយជាមួយគ្រាប់ពោតតែ៥កំប៉ុងតែប៉ុណ្ណោះ ហើយអនុញ្ញាតឲ្យយើងហូបក្នុងមួយថ្ងៃពីរពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច។

ប្រជាជនម្នាក់ៗមានរូបរាងស្គមស្គាំង ស្លេកស្លាំង ហើយត្រូវទទួលរងនូវភាពអត់ឃ្លានយ៉ាងធ្ងន់។ នៅពេលមានជំងឺម្តងៗ អង្គការបានអនុញ្ញាតឲ្យយើងទៅបើកថ្នាំអាចម៍ទន្សាយ ដែលគេជឿថាជាថ្នាំទិព្វអាចព្យាបាលបានជំងឺ១០០មុខ។ ខ្ញុំបានឃើញរាល់ទិដ្ឋភាពយ៉ាងខ្លោចផ្សាជាច្រើន។ ពេលខ្លះខ្ញុំបានឃើញកម្មាភិបាលខ្មែរក្រហមក្មេងៗ ធ្វើទារុណកម្មលើប្រជាជនថ្មី ដោយវាយដំ និងទាត់ធាក់យ៉ាងសាហាវឃោរឃៅ។ ជាងនេះទៅទៀត ខ្ញុំបានឃើញក្រុមឈ្លបចាប់ចងប្រជាជនជាខ្សែៗ យកទៅសម្លាប់ដោយគ្មានអាណិតអាសូរ។

ដើមខែកក្កដា ឆ្នាំ១៩៧៧ ស្ថានភាពនៃការរស់នៅរបស់ប្រជាជនខ្មែរកាន់តែមានសភាពតានតឹងខ្លាំង និងរឹតបន្តឹងគ្រប់ពេលវេលា។ អង្គការបានចាប់ផ្តើមធ្វើវិសុទ្ធកម្ម និងរៀបចំផែនការកម្ទេចប្រជាជនថ្មីរួមជាមួយកម្មាភិបាលខ្មែរក្រហមថ្នាក់មូលដ្ឋានមួយចំនួន ដែលជាប់ការសង្ស័យថាជាខ្មាំងប្រឆាំងនឹងអង្គការ។ ថ្ងៃមួយម៉ោងប្រហែលជា៧ព្រឹក ខ្ញុំត្រូវបានប្រធានកងចាត់តាំងឲ្យទៅកាប់ដើមទន្ទ្រានខែត្រនៅព្រៃខាងលិចភូមិដូចសព្វមួយដង ស្រាប់តែខ្ញុំបានឃើញកងទ័ពអាវខ្មៅក្មេងៗចំនួន៣នាក់ អូសកាំភ្លើងសឹងតែមិនផុតពីដី កំពុងតែបណ្តើរអ្នកទោសដែលជាប្រជាជនថ្មីមួយខ្សែធំឆ្ពោះទៅកាន់ព្រៃខាងលិចវត្តស្គន់។ អ្នកទោសទាំងនោះមានទឹកមុខស្រងូតស្រងាត់ឈានជើងដើរមួយៗដូចមនុស្សអស់សង្ឃឹមក្រោមសម្រែកជេរប្រទេចពីពួកកងទ័ពអាវខ្មៅនោះ។ ពេលនោះ ខ្ញុំបានជួបជាមួយ យាយ សួន ជាអ្នកចៀស្តែ និងឆែថាវនៅខាងត្បូងវត្តស្គន់។ គ្រាន់តែគាត់ក្រឡេកឃើញខ្ញុំភ្លាម យាយ សួន បានស្ទុះមកជួបខ្ញុំនិងខ្សឹបប្រាប់ខ្ញុំថា គាត់បានឃើញកងទ័ពអាវខ្មៅមួយក្រុម ចាប់បណ្តើរម្តាយ និងបងប្អូនរបស់ខ្ញុំមួយពូជពីភូមិថ្មីឆ្ពោះទៅកាន់ ព្រៃខាងលិចវត្តតាំងពីព្រឹកព្រលឹមម្ល៉េះ។ គ្រាន់តែបានឮដំណឹងនោះភ្លាម អារម្មណ៍របស់ខ្ញុំចាប់ផ្តើមភ័យតក់ស្លុតញ័រដៃញ័ររជើងព្រមជាមួយទឹកភ្នែកស្រក់ហូរដោយនឹកស្រមៃដល់ទិដ្ឋភាពចាប់មនុស្សដែលខ្ញុំធ្លាប់បានឃើញរៀងរាល់ថ្ងៃ។ ពេលនេះ រឿងរ៉ាវទាំងអស់នេះ បានកើតឡើងលើគ្រួសាររបស់ខ្ញុំហើយ។ តើម្តាយ និងបងប្អូនប្រុសស្រីរបស់ខ្ញុំទាំងអស់មានវាសនាដូចអ្នកទាំងនោះឬយ៉ាងណា?

វេលាម៉ោង៥ល្ងាច ខ្ញុំកំពុងតែដេញគោចេញពីវត្តស្គន់ឆ្ពោះទៅកាន់ក្រោលគោរួមនៅខាងលិចវត្ត ទាំងគ្មានព្រលឹងវិញ្ញាណនៅក្នុងខ្លួនសោះ។ ពេលនោះ ស្រាប់តែមានគោមួយនឹមបានបោលរត់ចេញពីហ្វូងឆ្ពោះទៅកាន់ព្រៃខាងលិចភូមិ។ ខ្ញុំចេះតែដេញតាមគោរហូតដល់ក្នុងព្រៃ ស្រាប់តែខ្ញុំបានឃើញកងទ័ព៥នាក់កំពុងតែឈរនៅក្នុងព្រៃថែមទាំងមានមេក្រូចាក់ឮសូរទ្រហឹងគ្រប់ទិសស្តាប់អ្វីមិនឮទេ។ គ្រាន់តែឃើញខ្ញុំភ្លាម កងទ័ពម្នាក់ស្ទុះចេញមកទាំងមានកាន់កាំភ្លើងនៅដៃ ហើយបាន

ស្រែកសម្លុតខ្ញុំថា «តើឯងជាអ្នកណា? មកទីនេះមានការអ្វីដែរ?»។ ខ្ញុំបានឆ្លើយតបទៅវិញថា «បាទ ខ្ញុំជាអ្នកមើលគោ ខ្ញុំមកនេះដើម្បីរកគោមួយនឹមដែលបានបាត់ ខ្ញុំបានឃើញវារត់តម្រង់មកទីនេះ»។ ខ្ញុំនិយាយស្ទើរមិនចប់ប្រយោគផង កងទ័ពនោះស្រែកជាក់ខ្ញុំថា «ទៅវិញទៅ នៅទីនេះគ្មានគោដែលឯងចង់រកទេ ទៅ! ទៅ! ទៅ!»។ បន្ទាប់ពីបានចេញមកវិញ ខ្ញុំបានលួចសម្លឹងមើលទិដ្ឋភាពនៅក្នុងព្រៃខាងលិចភូមិ ព្រោះខ្ញុំចេះតែមានអារម្មណ៍សង្ស័យមិនអស់ចិត្ត។ ខ្ញុំ បានឃើញពួកទាហានអាវខ្មៅបានបញ្ជាឲ្យពួកអ្នកទោសជីករណ្តៅធំៗជ្រៅៗនៅក្នុងព្រៃខាងលិចភូមិ ដើម្បីទុកកប់សាកសពដែលពួកវាបានសម្លាប់។ ខ្ញុំបានឃើញរណ្តៅជាច្រើនលាយឡំនឹងក្លិនស្អុយសាកសពមិនដឹងថាស្លាប់តាំងពីពេលណានោះទេ។

ព្រឹត្តិការណ៍ក្នុងរាត្រីមង្គលរាជ បានជិតជាមនុវស្លាកស្នាមជីវិតសែនឈឺចាប់មិនអាចបំភ្លេចបានក្នុងបេះដូងរបស់ខ្ញុំរហូតដល់សព្វថ្ងៃនេះ។ តើប្រជាជនទាំងអស់នោះមានទោសកំហុសអ្វី បានជាពួកគេត្រូវទទួលរងនូវអំពើអមនុស្សធម៌យ៉ាងនេះ?

ស្លាកស្នាមអនុស្សារ

ម៉ោង១១ព្រឹក កម្មវិធីគោរពវិញ្ញាណក្ខន្ធនៅក្នុងទិវាជាតិនៃការចងចាំបានឈានដល់ទីបញ្ចប់។ ខ្ញុំភ្ញាក់ព្រើតហាក់បីដូចជាមនុស្សទើបភ្ញាក់ពីដំណេក ដែលកំពុងតែយល់សុបិនអាក្រក់យ៉ាងតក់ស្លុត។ បន្តិចក្រោយមក ខ្ញុំខំព្យាយាមសម្រួលអារម្មណ៍ឡើងវិញ ហើយបានដឹងខ្លួនយ៉ាងច្បាស់ថា វាជារឿងពិតនៃជីវិតខ្ញុំនៅក្នុងរបបខ្មែរក្រហម។ ថ្វីត្បិតតែរយៈពេលជាង៤០ឆ្នាំ បានកន្លងផុតបាត់ក៏ពិតមែន តែស្លាកស្នាមអនុស្សាវរីយ៍នៃខ្សែជីវិតរស់នៅដ៏ឈឺចាប់ក្នុងរបបខ្មែរក្រហម នៅតែជិតជាមជាប់ដូចជាទើបនឹងកើតឡើងថ្មីៗ។ ព្រោះតែសង្គ្រាម ព្រោះតែភាពលោភលន់ និងមនោគមវិជ្ជាអសីលធម៌របស់មេដឹកនាំដ៏ល្ងង់ខ្លៅ បានកែប្រែជោគវាសនាប្រទេសកម្ពុជាឲ្យដើរថយក្រោយ និងមានវិប្បដិសារីអស់មួយជីវិត។

ចប់

៣៨

រឿងចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦

អ្នកនិពន្ធ ៖ រៀម សារុំម

៣៨ ~ រឿង ចុចឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦

ទិដ្ឋភាពតក់ស្លុតមួយ បានលេចឡើងនៅក្នុងកូនក្រុងតូចស្ថិតក្នុងភូមិភាគខាងលិចនៃប្រទេសកម្ពុជា។ កូនរថយន្តបរត់ខ្ចាត់ខ្ចែងស្ទើរតែគ្រប់វិថី ដែលមានអ្នកជិះក្នុងកូនរថយន្តបនោះមិនលើសពី១០នាក់ឡើយក្នុងរថយន្តនីមួយៗ។ សំឡេងឧគ្ឃោសនាសព្ទ បានលាន់ឮបន្តបន្ទាប់គ្នាតាមរលកសំឡេងដ៏មុតស្រួចរបស់យុវជនវ័យប្រហែល២០ឆ្នាំម្នាក់។ យុវជននោះបានស្រែកប្រកាសថាឲ្យប្រជាពលរដ្ឋទាំងឡាយដែលរស់នៅក្នុងក្រុងប៉ៃលិន ត្រូវតែចាកចេញពីគេហដ្ឋានរបស់ខ្លួនត្រឹមតែរយៈពេល ៣ថ្ងៃប៉ុណ្ណោះ ដើម្បីរៀបចំស្រុកទេសកម្ចាត់ពួកខ្មាំងសត្រូវ ដែលបានបង្កប់ខ្លួននៅក្នុងតំបន់នេះ។ ប្រជាជនខ្មែរពាប់ពាន់នាក់ត្រូវបានជម្លៀសចេញអស់ពីក្រុងប៉ៃលិន។ ប៉ៃលិន គឺជាតំបន់មួយដែលសម្បូរទៅដោយវប្បធម៌ជាតិដ៏មានតម្លៃមហាសាល។ នៅទីនោះ មានជនជាតិជាច្រើនរស់នៅរួមមាន ព្នង គួយ និងកូឡា(ភូមា) ជាដើម។

ស្នូរអាវុធលាន់ឮដូចលាជផ្ទុះនៅទីជិតទីឆ្ងាយក្រោមការបញ្ជារបស់ក្រុមឈុតខ្មៅមួយក្រុមទៅលើគ្រួសារអ្នករស់នៅក្នុងតំបន់ត្បូងកណ្តៀង ព្រោះគ្រួសារខ្លះស្ទាក់ស្ទើរចិត្តក្នុងចាកចេញពីផ្ទះទាំងទទឹងទិសដូច្នេះ។ គ្រប់ផ្ទះបានបិទទ្វារចោលយ៉ាងស្ងាត់ជ្រងំត្រឹមតែរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ។ សំឡេងទ្រហោយំស្ដាយស្រណោះទ្រព្យសម្បត្តិផ្ទះសម្បែង និងការមិនចង់ឃ្លាតចោលពីលំនៅរបស់

អ្នកស្រុក បានបន្លឺឡើងធ្វើឲ្យឮដល់ក្រុមឈ្មុតខ្មៅ ធ្វើឲ្យពួកគេខឹងសម្បាមិនពេញចិត្តរាល់ទង្វើទាំងអស់នេះឡើយ។ ប្រជាជនខ្លះ ត្រូវកងទ័ពអាវខ្មៅបាញ់សម្លាប់ចោលនៅនឹងកន្លែងភ្លាមៗ ដោយសារតែពួកគេមិនព្រមចាកចេញពីផ្ទះ។

នៅតាមផ្លូវជាតិលេខ៥៧ ពីប៉ៃលិនទៅបាត់ដំបង មនុស្សជាច្រើននាក់ដើរតម្រង់មករកស្រុកផ្សេងៗ ដែលអង្គការបានកំណត់ឲ្យពួកគេស្នាក់នៅនិងធ្វើការជាបណ្តោះអាសន្ន។ ទាហាន លន់ នល់ ជាច្រើន ដែលអង្គការចាត់ទុកថាជាសត្រូវ ត្រូវបានសម្លាប់ដេកហើមស្តឹងពាសពេញផ្លូវ។ គ្រាន់តែប៉ុន្មានថ្ងៃប៉ុណ្ណោះ អ្វីៗសព្វបែបយ៉ាងប្រែប្រួលខុសប្រក្រតីទាំងស្រុង ជាពិសេសរបៀបរបបគ្រប់គ្រងដោយអង្គការថ្មីមួយនេះ។ យុវជនអាវខ្មៅក្មេងៗស្តាយកាំភ្លើងដើរល្បាតយ៉ាងអង់អាច ព្រមទាំងមានទឹកមុខមាំគួរឲ្យខ្លាចរអាក្រៃលែង។ ប្រជាជនធ្វើដំណើរចេញពីក្រុងប៉ៃលិនយឺតយូរខ្លាំងណាស់ ព្រោះមានចំនួនមនុស្សច្រើនពេកត្រូវសម្រុកចេញព្រមៗគ្នា។ លុះមកដល់បន្ទាយក្បែរដីក្រហម អង្គការបានប្រកាសឲ្យហូងមនុស្សទាំងអស់ឈប់សម្រាកដាំបាយហូបរៀងៗខ្លួន។ យើងដាំបាយយ៉ាងលំបាកទម្រាំនឹងបានហូប។ ពេលដម្លៀស យើងខ្វះទាំងទឹក ខ្វះទាំងម្ហូបចំណែកក្មេងៗស្រែកយំ ព្រោះអត់អាហារយូរពេក។ លុះហូបចុកមិនទាន់នឹងរួចស្រួលបួលផង យើងត្រូវចូលដេកនៅក្នុងកូនមុងតូចៗរបស់យើង ខណៈក្រុមគ្រួសារផ្សេងទៀត បានយកលំហាមេយទាំងមូលធ្វើដំបូលផ្ទះ។

បីថ្ងៃកន្លងផុតទៅ ហូងមនុស្សទាំងឡាយចេះតែបន្តដំណើរទៅតាមទិសដៅដែលអង្គការបានបែងចែកតំបន់ឲ្យ។ ក្តីសង្ឃឹមដែលអង្គការបានសន្យាថាឲ្យយើងវិលត្រលប់មកកាន់ផ្ទះសម្បែងវិញនោះ ក៏លែងមានទៀតដែរ។ អង្គការកំពុងតែដុតដៃដុតជើងបោសសម្អាតពួកខ្មាំងយ៉ាងមមាញឹក។ ហូងមនុស្ស ត្រូវបានកាត់ជាផ្នែកៗ ផ្នែកខ្លះត្រូវទៅខាងអូរអណ្តូង ត្រែង ដំណាក់ស្តៅ និងមួយចំនួនទៀតត្រូវទៅខាងភ្នំដូនមាយ ច្រាំងចោត រូងអំពុះឃ្លាំង និងកំពង់គល់។ ការងារនៅតាមមូលដ្ឋាន ដែលអង្គការដាក់ឲ្យពិតជាលំបាកខ្លាំងណាស់។ មនុស្សមួយចំនួនធំដូចជា អតីតកុងសែវៀកែត្បូង និងមន្ត្រីរាជការ សុទ្ធសឹងតែជាអ្នកមិនធ្លាប់ធ្វើការ

ងារធ្ងន់ៗ ហើយគួបផ្សំនឹងការហូបចុកមិនគ្រប់គ្រាន់ផង បានធ្វើឲ្យអ្នកទាំងនោះបាក់កម្លាំងស្គមស្គាំងស្បែកដណ្តប់ឆ្អឹង។ ក្មេងៗមួយភាគធំ បានស្លាប់ជាបន្តៗដោយសារកង្វះអាហារ និងឈឺគ្មានថ្នាំលេបជាដើម។

សុរិយាអស្តង្គតរលត់បាត់ទៅ បានបន្សល់ទុកនូវចំហាយក្តៅៗចេញពីដីខ្សាច់នៅតាមផ្លូវរទេះគោ។ នរៈពាក់អាវខ្មៅ មានឈ្នួតក្បាលនឹងក្រមាស្មាលីកាំបិតខ្វែវដើរចេញពីចម្ការឫស្សីជាជួរៗយ៉ាងមានរបៀបក្នុងសភាពហេវហត់ខ្លាំង។ ក្នុងនោះមានបុរសម្នាក់ដៃលមានឆ្អឹងធំ សម្បុរសជ្រះបន្តិច បានដើរចូលក្នុងកូនខ្ទមប្រក់ស្លឹកដូង ដៃលអង្គការបានប្រគល់ឲ្យជាកម្មសិទ្ធិ។ គាត់បានយកកាំបិតទៅបញ្ឈរនៅក្បែរកូនឆ្នាំងដាំថ្នាំបុរាណមួយសម្រាប់អ្នកទើបតែសម្រាលកូនរួច។

មីខែម៖ «យ៉ាងម៉េចដៃរពុកវា ការងារថ្ងៃនេះ?»។

ពូម៉ឺន ដើរទៅសិតទឹកថ្នាំហូប បន្ទាប់ពីគាត់ឱនឈ្ងោកមើលកូនទារកដ៏គួរឲ្យស្រលាញ់របស់គាត់ រួចឆ្លើយតបទៅនឹងសំណួររបស់ប្រពន្ធគាត់ថា៖

ពូម៉ឺន៖ «ការងារដៃលអង្គការដាក់ឲ្យកាប់ឆ្ការព្រៃនោះពិតជាលំបាកណាស់ ពីព្រោះដីព្រៃនោះមានទំហំធំហើយព្រៃក្រាស់ទៀត ចំណែកអ្នកកាប់ព្រៃមានតែ១០នាក់ទេ។ ម៉្យាងទៀត អង្គការបង្ខំយើងធ្វើឲ្យរួចរាល់ក្នុងថ្ងៃនេះតែម្តង។ អង្គការ បានប្រាប់យើងថា ស្អែកនឹងត្រូវទៅកាប់ព្រៃផ្សេងទៀតមិនអាចធ្វើការងារប៉ុណ្ណោះត្រាំត្រែងយូរថ្ងៃឡើយ។ កូនប្រុសយើងមានយំធ្វើទុក្ខម៉ែវាឯងទេ?»។ ដាក់មីងខែមនៅមុខវិញ «ធ្វើទុក្ខអីទេ ឃើញដេករហូត។ ចុះពុកវាឯងទៅកាប់ព្រៃមានជួបអ្នកស្គាល់ទេ?»។

ពូម៉ឺន៖ «ខ្ញុំបានជួបនឹងអ្នកស្គាល់មុខម្នាក់កាលយើងនៅរកស៊ីត្បូងនៅបរតាំងស៊ូ ថែមទាំងធ្លាប់មានទាស់ពាក្យសម្តីនឹងគ្នាពីរឿងត្បូងម្តងទៀតផង»។ មីងខែម៖ «ណាគេទៅពុកវា?»។

ពូម៉ឺនរៀបនឹងឆ្លើយតបទៅវិញ ស្រាប់តែសមមិត្តម៉ែងដើរចូល រួចមីងខែមនិយាយថា «ហ៊ាម៉ែង!»។

សមមិត្តម៉ែង៖ «ត្រូវហើយ...ខ្ញុំគឺម៉ែង...ថៅកែភ្ជួងម៉ែង ពីមុននរណាៗក៏ស្ទើបនឹងខ្ញុំដែរ យី! ដូចជាធំក្លិនកូនខ្ចី? អ្នកណាគេទើបឆ្លងទន្លេឬ? ឬក៏សមមិត្តខែម ឯង? អូ...កូនប្រុសនេះស្អាតថ្លោសគ្រាន់បើណាស់តើ!» និយាយរួចសមមិត្តម៉ែង ឈរមើលមុខទារកនោះ។

ពូម៉ឺន៖ «ចុះសមមិត្តហេតុអ្វីបានជាសមមិត្តម៉ែងឯងដឹងថាពួកយើងនៅទីនេះ?»។

សមមិត្តម៉ែងសើចរួចនិយាយថា៖

សមមិត្តម៉ែង៖ «ខ្ញុំស៊ើបទម្រាំនឹងដឹងគឺអស់រយៈមួយអាទិត្យទើបបានដឹង។ ខ្ញុំមកនេះមិនមែនមានបំណងអាក្រក់នោះទេ ធម្មតាមិត្តធ្លាប់រួមអាជីពពីមុនមក ចេះតែចង់សួរសុខទុក្ខគ្នាទៅ។ ម៉្យាងទៀតរឿងទាស់គ្នាពីមុនៗ យើងបំភ្លេចវាចោលទៅ ព្រោះវាកន្លងហួសយូរខែឆ្នាំហើយ។ ប្រហែលសមមិត្តទាំងពីរមានការងឿងឆ្ងល់ហើយមើលទៅ ដែលបានឃើញខ្ញុំស្លៀកពាក់ឈុតខ្មៅ មានស្តាយកាំភ្លើងដូច្នេះនោះ។ ខ្ញុំសុំប្រាប់សមមិត្តឲ្យដឹងទៅចុះ អង្គការបានចាត់តាំងឲ្យខ្ញុំមើលការខុសត្រូវនៅតំបន់នេះ ហើយខ្ញុំក៏មានការទំនាក់ទំនង សម្ងាត់ជាមួយអង្គការជាយូរឆ្នាំហើយដែរ តាំងពីមុនខ្ញុំធ្វើជាថៅកែភ្ជួងនៃប៉ៃលិននេះម្ល៉េះ»។

ពូម៉ឺន៖ «ចឹងបានន័យថាសមមិត្តម៉ែង ធ្វើជាគិញសម្ងាត់នេះយូរហើយមែនទេ?»។

សមមិត្តម៉ែង អង្គុយឆ្អឹះរងើកភ្លើងបន្តិចមុនឆ្លើយនូវសំណួរនេះ។

សមមិត្តម៉ែង៖ «ត្រឹមត្រូវហើយ។ ដូចដែលខ្ញុំបានប្រាប់ខាងដើមអីចឹង គឺខ្ញុំធ្វើយូរឆ្នាំហើយ ពីព្រោះអង្គការមានផែនការច្បាស់លាស់ដើម្បីលុបបំបាត់ចោលនូវវណ្ណៈមូលធននិយម អំពើជិះជាន់ទៅលើអ្នកទន់ខ្សោយ គ្មានអ្នកមាន គ្មានអ្នកក្រ ព្រមទាំងគ្មានអ្នកណាបម្រើអ្នកណាឡើយ»។

ពេលនោះស្រាប់តែទារករើបម្រះខ្លួនស្រែកយំឮសូរង៉ាៗ ព្រោះឮសំឡេងមនុស្សចម្លែកនិយាយ។ មីងខែម បែរមកលើកត្រកងកូនថ្នមៗ រួចបំបៅដោះកូននៅជ្រុងម្ខាងក្នុងកូនខ្នម។

សមមិត្តម៉ែង៖ «ខ្ញុំមកនេះ គ្រាន់តែចង់មកប្រាប់សមមិត្តទាំងពីរនាក់ឲ្យមានការប្រុងប្រយ័ត្នបន្តិច ពីព្រោះអង្គការនឹងមានផែនការថ្មីមួយទៀត ដើម្បីស្រាវជ្រាវរកអតីតបញ្ញវន្ត មន្ត្រីរាជការ ទាហាន សិល្បករ កវីនិពន្ធ និងអ្នកមានចំណេះដឹងទាំងឡាយ បោសសម្អាតចោល។ ខ្ញុំត្រលប់ទៅវិញហើយ ប្រសិនបើមានការអី សមមិត្តឯងអាចប្រាប់ខ្ញុំបាននៅពេលជួបខ្ញុំលើកក្រោយ។ ខ្ញុំលាសិនហើយ»។

សមមិត្តម៉ែង ដើរចេញពីកូនខ្ចមបាត់ទៅ ចំណែកឯពូម៉ឺន និងមីងខែម បានត្រឹមតែដកដង្ហើមធំមើលមុខគ្នាតែប៉ុណ្ណោះ ពីព្រោះតាមសម្តីរបស់សមមិត្តម៉ែង អង្គការនឹងបន្តស្រាវជ្រាវមកដល់ពួកគាត់ទាំងពីរជាមិនខានឡើយ។

ទោះបីសមមិត្តខែម សម្រាលកូនបានត្រឹមតែ៣ថ្ងៃក៏ដោយ អង្គការបានបញ្ជាឲ្យគាត់មកជួយការងារនៅជិតៗផ្ទះដោយយកកូនទៅទុកឲ្យចាស់ៗមើលថែជំនួសនៅក្នុងរោងកុមារ។ មិនយូរប៉ុន្មាន សមមិត្តខែម ត្រូវសមមិត្តនារីផ្សេងទៀតច្រណែន ហើយបានរាយការណ៍ដល់ថ្នាក់លើ។ ស្អែកឡើង សមមិត្តខែម ត្រូវអង្គការបញ្ជាឲ្យទៅធ្វើការនៅចម្ការវិញម្តងជាមួយសមមិត្តប្រុសស្រីឯទៀត។ ថ្ងៃក៏កាន់តែខ្ពស់ ចំណែកពោះវិញកាន់តែកូវដែរ រួចមានសំឡេងស្រែកខ្លាំងៗពីពួកអាវខ្មៅថា «ព្រឹកនេះសមមិត្តទាំងអស់គ្នាសម្រាកសិនចុះ ពីព្រោះដល់ម៉ោងបាយថ្ងៃត្រង់ហើយ លុះបាយថ្ងៃត្រង់រួចចាំយើងចាប់បន្តការងារទៀត»។

ប្រជាជននាំគ្នាសម្រុកដើរតម្រង់មកកាន់រោងបាយដោយក្តីស្រែកឃ្លានជាពន់ពេក។

២ឆ្នាំកន្លងទៅយ៉ាងតឹងតែងជាទីបំផុតរកអ្វីមកប្រៀបផ្ទឹមពុំបាន។ ស្ថានភាពនយោបាយនៅតែអូសបន្លាយឲ្យកាន់តែពិបាកទៅៗក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ប្រជាជនទាំងឡាយ ធ្វើការយ៉ាងសស្រាក់សស្រាំទាំងយប់ទាំងថ្ងៃ ធ្វើយ៉ាងណាឲ្យទទួលបានផលទ្វេដង។

ដំណក់ទឹកភ្លៀងកំពុងតែស្រោចស្រប់លើដំបូលកូនខ្ចមរបស់ប្រជាជនគ្រប់ៗគ្នា។ សមាជិកគ្រួសារទាំងអស់គ្នាស្ទើរតែគ្មានអ្វីយកមកដណ្តប់បិទបាំងកាយ

ឲ្យបានសមរម្យនោះទេ។ ឆ្នាំនោះ គឺជាឆ្នាំដែលសម្បូរទៅដោយទឹកភ្លៀងខ្លាំង។ ប្រជាជនទាំងអស់ដែលរស់នៅតាមមូលដ្ឋានភ្នំដូនមាយ ច្រាំងចោត កំពង់គល់ រូង និងអំពុះឃ្លាំង ត្រូវបានអង្គការឲ្យមកធ្វើការកសិកម្មរួមគ្នានៅតំបន់ច្រាំងចោត និងនៅតាមតំបន់រូង។ ការធ្វើការនៅតំបន់ទាំងពីរនេះជួបការលំបាកខ្លាំងណាស់ ព្រោះយើងគ្មានគ្រឿងយន្ត ឬគោក្របីទឹមភ្ជួររាស់នោះឡើយ។ យើងត្រូវពឹងទៅលើកម្លាំងមនុស្សសុទ្ធសាធដើម្បីធ្វើស្រែឲ្យបានសម្រេចតាមផែនការរបស់អង្គការ។

ថ្ងៃណាក៏ដូចថ្ងៃណាដែរ ផ្ទៃមេឃពោរពេញទៅដោយដុំពពកពណ៌ខ្មៅស្ទើរតែមើលមិនឃើញព្រះអាទិត្យ ហើយព្យុះពពកខ្មៅ ហោះយ៉ាងលឿនមកដល់មូលដ្ឋានច្រាំងចោទ ដែលជាកន្លែងប្រជាជនជាច្រើនកំពុងតែមមាញឹកនឹងការងារកាប់គាស់ដីសម្រាប់ធ្វើស្រែវស្សា។ ម្នាក់ៗមិនហ៊ានឈប់សម្រាកឡើយ ដោយនៅទ្រាំទទឹកភ្លៀងជោកជាំរហូតដល់ម៉ោងសម្រាក។

ចូលដល់ឆ្នាំ១៩៧៩ កងចក្រនយោបាយវិលយ៉ាងត្រជាក់នឹកស្មានមិនដល់។ សំឡេងអាវុធគួចធំ លាន់ឮគ្រប់ទិសទីទាំងអស់។ កងទ័ពខ្មែរក្រហមមានការប្រជុំសម្ងាត់ពីផែនការទប់ស្កាត់នូវការវាយលុករបស់កងទ័ពវៀតណាមដែលកំពុងចូលមកដល់ប្រទេសកម្ពុជា។ ការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាមកាន់តែខ្លាំងឡើងៗពីមួយទៅមួយថ្ងៃ បណ្តាលឲ្យប្រជាជនរត់កាត់វាលកាត់ព្រៃផ្សងជីវិតមករស់នៅតាមព្រំដែនប្រទេសថៃ។ ទីបំផុត កងទ័ពវៀតណាម ទទួលបានជោគជ័យនិងរំដោះប្រទេសកម្ពុជាពីរបបខ្មែរក្រហមបាន។ ពេលនោះ ប្រជាជនភាគច្រើន បានរត់មករស់នៅក្នុងជំរំជនភៀសខ្លួនរួមមាន ជំរំចាស់ ជំរំខាវអ៊ីដាង ជំរំបន្ទាយអំពិល រហូតដល់ជំរំចុងក្រោយគេគឺជំរំសាយធូ។

ចប់

៣៩

រឿងជីវិតជាប់គុក ឥតជញ្ជាំង

អ្នកនិពន្ធ ៖ ពៅ ស្រីនិច

៣៩ ~ រឿង ជីវិតជាប់គុក ឥតជញ្ជាំង

រដូវប្រមូលផលបានមកដល់ នៅតាមវាលមានមនុស្សម្នាកុះករកំពុងតែច្រូតកាត់ស្រូវ និងប្រមូលផលដាក់លើរទេះយកមកផ្ទះរៀបចំទុកដាក់។ ជានិច្ចកាល ពេលប្រជាជនកំពុងតែច្រូតកាត់ តែងតែមានឮសំឡេងខ្ទរញ៉ូរដីពីចម្ងាយ ធ្វើឲ្យប្រជាជនមានការភិតភ័យយ៉ាងខ្លាំង ហើយពេលបានឮសំឡេងបែបនេះម្តងៗ ប្រជាជនតែងនាំគ្នារត់ប្រជៀតគ្នាទៅរកលេណដ្ឋាន(ត្រង់សេ)នៅក្បែរខ្លួន ដើម្បីគេចចេញពីគ្រាប់បែក។ ប្រហែលកន្លះម៉ោងក្រោយមកពេលដែលសំឡេងស្ងប់ស្ងាត់ ប្រជាជននាំគ្នាលូនចេញមកតិចៗរួចប្រមូលស្រូវ គោក្របី និងរបស់របរផ្សេងទៀតត្រលប់ទៅផ្ទះរៀងៗខ្លួន។

ការភ័យរន្ធត់បែបនេះ ត្រូវបានកាត់បន្ថយបន្តិចម្តងៗ បន្ទាប់ពីបានឮដំណឹងមកថាមានក្រុមកងទ័ពតស៊ូរំដោះឬហៅថា កងទ័ពខ្មែរក្រហម នៅតាមជាយដែនដីនិងភូមិស្រុក មកជួយរំដោះប្រជាជនឲ្យរួចផុតពីសង្គ្រាមដែលកំពុងតែកើតឡើង។ មិនយូរប៉ុន្មាន កងទ័ពខ្មែរក្រហម បានវាយយកបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលប្រជាជននាំគ្នាអបអរសាទរទៅនឹងរបបថ្មីនេះយ៉ាងច្រើនកុះករដោយសង្ឃឹមថាសង្គ្រាមនឹងត្រូវបញ្ចប់។ ប៉ុន្តែអ្វីៗមិនដូចការរំពឹងទុករបស់ប្រជាជនឡើយ។ ប្រមាណជា៣ម៉ោងក្រោយមក កងទ័ពខ្មែរក្រហមបានប្រកាសថាប្រជាជនទាំងអស់នឹងត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញឲ្យទៅ

ជនបទរយៈពេល២ឬ៣ថ្ងៃ ដោយមិនចាំបាច់យករបស់របរទៅនោះទេ។ ចំណែកឯប្រជាជននៅតាមតំបន់ជនបទវិញ ខ្មែរក្រហមបានចាត់ឲ្យធ្វើស្រែចម្ការ ដាំបន្លែ ហើយប្រជាជនខ្លះ ត្រូវដម្លៀសចេញពីភូមិទៅនៅកន្លែងផ្សេងដែរ។

ក្នុងចំណោមប្រជាជនខ្មែររងគ្រោះទាំងអស់ក៏មានគ្រួសារតាយី យាយនូដែរ។ តាយី យាយនូមានកូនចំនួន៣នាក់។ កូនប្រុសច្បងរបស់គាត់ឈ្មោះយូ មានអាយុ២៨ឆ្នាំ បានបួសធ្វើជាព្រះសង្ឃ ហើយ កូនស្រីចំនួន២នាក់ទៀត ដែលម្នាក់ឈ្មោះនី មានអាយុ២៤ឆ្នាំ និងម្នាក់ទៀតឈ្មោះ នឿន មានអាយុទើបតែ១៣ឆ្នាំ។ កូនស្រីទាំងពីរនាក់ រៀនបានតិចតួច ហើយនៅជួយធ្វើការងារផ្ទះនិងស្រែចម្ការ។ នៅក្នុងភូមិដែលតាយីរស់នៅ មាន តាធឹម តាវុធ ធ្វើជាមេភូមិ និងពួកកងឈ្លបជាច្រើននាក់ទៀត ភាគច្រើនជាអ្នកដែលមិនបានរៀនសូត្រទេ។

ក្រោយពីខ្មែរក្រហម ចូលមកកាន់កាប់ភូមិរបស់តាយីបានមួយរយៈ តាយីបានធ្លាក់ខ្លួនឈឺ។ គាត់ត្រូវខ្មែរក្រហម វាយធ្វើបាបដោយចោទគាត់ថាមានជាប់សាច់ឈាមនឹងសម្តេចសីហនុ ថែមទាំងគាត់ធ្លាប់ធ្វើជាទាហាននៅក្នុងរបបសាធារណរដ្ឋខ្មែរដែរ។ តាយី ត្រូវអង្គការចាត់ឲ្យធ្វើស្រែនិងការងាររផ្សេងៗទៀតដូចប្រជាជនដទៃ។ បន្ទាប់ពីធ្វើស្រែជាលក្ខណៈប្រវាស់ដៃគ្នាបែបសហករណ៍បាន១ឆ្នាំ មេភូមិបានចាត់បញ្ជូនប្រជាជនមួយចំនួនដែលជាកងចល័តបុរស នារី កុមារ និងចាស់ជរា ឲ្យធ្វើការទៅតាមតំបន់រៀងៗខ្លួនវិញ ហើយបានប្រមូលយករបស់របរ និងទ្រព្យសម្បត្តិរបស់ប្រជាជនដាក់រួមដែរ។ គ្រួសាររបស់យាយនូ ត្រូវបានអង្គការបំបែកចេញពីគ្នា។ កូនប្រុសច្បងរបស់គាត់ ត្រូវបានអង្គការផ្សឹកឲ្យទៅធ្វើស្រែនៅក្នុងឃុំឆ្ងាយពីភូមិ។ ចំណែក នី វិញនៅជាមួយកងចល័តនារី ត្រូវធ្វើស្រែនៅក្នុងខេត្តព្រៃវែង ហើយយាយនូ និងនឿន ជាកុមារត្រូវឲ្យនៅធ្វើស្រែក្នុងភូមិដដែល។ យាយនូ ត្រូវបានអង្គការចាត់ឲ្យដាំបន្លែ ស្រោចទឹកដំណាំ និងរែកទឹកជាក់ពាង។ គាត់ធ្វើការមិនដែលហ៊ានប្រកែកឡើយ និងស៊ូទ្រាំអត់ធ្មត់ខ្លាំងណាស់ ទោះបីជាពេលខ្លះគាត់ឈឺក៏ដោយ។ ឯក្រុមកុមារវិញ នឿន ត្រូវអង្គការចាត់ឲ្យទៅមើលគោ រើសអាចមន៍គោក្របីហើយពេលខ្លះទៅជញ្ជូនសំណាបឲ្យចាស់ៗស្ងួង។ នឿន ជាក្មេងឧស្សាហ៍ហើយឆ្លាតណាស់។

រៀងរាល់ព្រឹកព្រហាមម៉ោង៣ ព្រឹក យាយនូ ត្រូវក្រោកទៅធ្វើចម្ការ រែកទឹក និងដងទឹកជាក់ៗ ហើយពេលខ្លះទៅជួយធ្វើស្រែ។ នៅក្នុងរបបខ្មែរក្រហម គ្មាននរណាម្នាក់មានពេលទំនេរបានសម្រាកឡើយ។ ម្នាក់ៗត្រូវធ្វើការរហូតដល់ម៉ោង១១ទើបបានហូបបបរវាវៗហូប។ លុះហូបរួច ពួកគេត្រូវចាប់ផ្តើមធ្វើការបន្តរហូតដល់ម៉ោង៥ល្ងាចទៀតទើបបានទៅផ្ទះសម្រាក។ ចំណែក នឿន ត្រូវក្រោកតាំងពីម៉ោង៥ព្រឹក ទៅដឹកគោយកទៅស្រែ បន្ទាប់មកដើររើសអាចមន៍គោរហូតដល់ម៉ោងសម្រាកថ្ងៃត្រង់ រួចពេលរសៀលត្រូវដឹកជញ្ជូនកណ្តាប់ដាក់តាមវាលស្រែទល់ម៉ោង៥ល្ងាច ទើបបានសម្រាក។ ការជួបជុំគ្នារវាងម្តាយ និងកូនបានតែពេលយប់នោះទេ ហើយមិនអាចនិយាយអ្វីបានច្រើនដែរ ព្រោះមានកងឈ្លបដើរយកការណ៍នៅតាមផ្ទះនៅពេលយប់ៗ។

ចំណែក ពូយូ ដែលជាសង្ឃទើបតែសឹកថ្មីៗ ត្រូវអង្គការចាត់ឲ្យធ្វើស្រែនៅក្នុងឃុំ។ គាត់ជាអ្នកចេះដឹងគួរសមដែរ ព្រោះគាត់បានបួសរៀនសូត្រនៅក្នុងវត្ត។ ថ្ងៃមួយ ពូយូ មានគំនិតថា មិនអាចនៅទ្រាំទ្រនឹងរបបផ្តាច់ការឃោរឃៅរបស់ខ្មែរក្រហមទៀតបានទេ។ គាត់បានលួចទៅរកគ្នីគ្នាពិភាក្សាក្នុងគោលបំណងរត់ចូលទៅទៅក្នុងព្រៃតស៊ូប្រឆាំងនឹងរបបនេះ។ ឈាង មានគំនិតស្របជាមួយនឹង ពូយូ ដែរ។ គាត់បានស្គាល់ប្រជានធំមួយនៅក្នុងក្រុមតស៊ូ។ ក្រោយពីបានស៊ើបសួរបានដឹងរកឃើញថាមានអ្នកចង់រត់ដូចគ្នា ឈាង និងពូយូ បានលួចទៅជជែកគ្នារៀបចំផែនការ ដើម្បីរត់ទៅតស៊ូនៅក្នុងព្រៃមួយនៅមិនឆ្ងាយពីទីកន្លែងដែលគាត់រស់នៅប៉ុន្មាននោះទេ។ ក្រោយរៀបចំផែនការបានច្បាស់លាស់ហើយ គាត់បានប្រមូលគ្នាលួចរត់ទៅចូលក្នុងព្រៃនៅពេលយប់ឆ្ពោះតម្រង់ទៅរកព្រៃក្រសាំង និងព្រៃចម្ការចេក ដែលនៅជាប់នឹងព្រំដែនវៀតណាម។ ពូឈាង និងពូយូ បានវង្វេងបាត់ចេញពីក្រុម ហើយសម្រេចចិត្តត្រលប់មកវិញ ដោយកុហកមេកូមិថា ពួកគាត់ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅឆ្ងាយរយៈពេល៣ថ្ងៃនោះ។ ពូយូ មិនដែលបានមកជួបជុំម្តាយ និងប្អូនៗនោះទេ ដោយសារជំរំដែលគាត់រស់នៅស្ថិតនៅឆ្ងាយពិបាកលួចរត់ស្តាត់មកជួបពេក។

ពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជនបាក់កម្លាំងជាច្រើននាក់ ហើយនៅពេលសាច់ញាតិបានជួបគ្នា ក៏សឹងតែមើលគ្នាមិនស្គាល់ ដោយសារតែរូបរាងស្គមស្គាំង។ នី រស់នៅឆ្ងាយពីផ្ទះ ព្រោះគាត់ត្រូវមកធ្វើស្រែចល័តតាមតំបន់នៅឯខេត្តព្រៃវែង។ ក្រៅពីធ្វើស្រែ នី ត្រូវអង្គការចាត់ឲ្យជួយការងារនៅក្នុងផ្ទះបាយដែរ ព្រោះអង្គការទើបតែយកចុងភៅម្នាក់ទៅសម្លាប់។ ក្រោយពីបានធ្វើជាអ្នកដាំស្លមួយរយៈពេលប្រធានកងចល័ត បានសម្គាល់ឃើញថា នី ជាមនុស្សបរិសុទ្ធស្មោះត្រង់នឹងអង្គការក៏បានបញ្ជូន នី ទៅកាន់ភូមិទួលចារ។ ពេលទៅដល់ភូមិទួលចារ នី បានធ្វើជាអ្នកដាំស្លដដែល។ ទោះបីជា ភូមិទួលចារ នៅក្បែរផ្ទះក៏ដោយ ក៏នីមិនអាចមកជួបនឹងក្រុមគ្រួសារបានឡើយ។

ចំណែក នឿន ដែលឈានចូលដល់អាយុ១៤ឆ្នាំ និងកុមារផ្សេងទៀត ត្រូវអង្គការចាត់ឲ្យដីកព្រៃកនៅតំបន់មួយឆ្ងាយពីម្តាយ។ នឿន ត្រូវដើរនិងដេកផ្លូវ២យប់ ទើបបានទៅដល់កន្លែងដីកព្រៃក។ លុះទៅដល់ទីនោះភ្លាម គ្មាននរណាម្នាក់ បានសម្រាកឲ្យស្រួលខ្លួននោះទេ។ ពួកគេ ត្រូវចាប់ផ្តើមធ្វើការភ្លាមៗ តាំងពីម៉ោង៨ទៀបភ្លឺ ដល់ថ្ងៃត្រង់ទើបបានសម្រាកហូបបាយម្តង និងបន្តរហូតដល់ល្ងាច ទើបបានសម្រាកហូបបាយម្តងទៀត ហើយបន្តដីកផងរែកដីផងរហូតម៉ោង៩ឬ១០យប់ ទើបបានមកដេកសម្រាកនៅតាមជំរំជាមួយក្រុមរបស់ពួកគេ។ ការដីកព្រៃកនៅទីនោះ បានចំណាយពេល២ខែ ទើបរួចរាល់។ បន្ទាប់មក ក្រុមកុមារ ត្រូវបានបញ្ជូនមកភូមិស្រុកវិញ។ ពួកគេគ្រប់គ្នាត្រេកអរជាខ្លាំង ព្រោះបានមកជួបជាមួយពុកម៉ែនៅឯផ្ទះវិញ។

ថ្ងៃមួយ យាយនូ រំភើបចិត្តជាខ្លាំង ព្រោះកូនប្រុសច្បងរបស់គាត់ បានលួចមកជួបគាត់។ ពេលនោះ ពូយូ មានដំណឹងមកប្រាប់ យាយនូ ថា មានក្រុមអ្នកតស៊ូនៅក្នុងព្រៃជាយដែនកំពុងតែត្រៀមកម្លាំងសហការជាមួយនឹងក្រុមកងទ័ពវៀតណាម ដើម្បីរំដោះប្រជាជនឲ្យរួចផុតពីគុកឥតជញ្ជាំងនេះ។ មិនយូរប៉ុន្មាន អង្គការ បានប្រជុំនិយាយដាស់តឿនប្រជាជនថា បើមាននរណាម្នាក់ហ៊ានរត់ចូលតស៊ូប្រឆាំងនោះ នឹងត្រូវសម្លាប់ ព្រោះវាជាអំពើក្បត់នឹងអង្គការ។

ការកាប់សម្លាប់ ចេះតែកើតមានក្នុងភូមិដោយសារការមិនទុកចិត្តគ្នា។ តាធឹម និងតាវុធ ដែលជាមេភូមិ ត្រូវបានពួកមេតំបន់យកទៅសម្លាប់ ព្រោះត្រូវគេរាយការណ៍ទៅថ្នាក់លើថា តាធឹម និងតាវុធ ជួយសម្រាលការងារឲ្យប្រជាជន។ បន្ទាប់ពីមេភូមិទាំងពីរត្រូវបានអង្គការសម្លាប់មក តាជឹម ប្រធានរោងបាយ ក៏ត្រូវបានអង្គការយកទៅសម្លាប់ដែរ ព្រោះគាត់បានលួចដួសបាយយកទៅឲ្យម្តាយរបស់គាត់ដែលកំពុងតែដេកឈឺ។

ចំណែក ក្រុមអ្នកតស៊ូ បានធ្វើការវាយប្រហារនៅតាមតំបន់ខ្លះៗ។ ស្នូរកាំភ្លើងចាប់ផ្តើមលាន់ឮគ្រប់ទីកន្លែង។ ប្រជាជនហាក់ដូចជាត្រេកអរចំពោះការវាយប្រហារនេះណាស់ព្រោះពួកគេជឿថាមានអ្នកតស៊ូចូលមកជួយប្រជាជនហើយ។ ជាអកុសល យាយនូ និងនឿន ត្រូវប្រធានភូមិថ្មី ដែលទើបតែចូលមកធ្វើការជំនួសតាធឹម និងតាវុធ នោះបានបញ្ជាឲ្យគាត់និងអ្នកភូមិមួយចំនួនទៀត ផ្លាស់ទៅរស់នៅនិងធ្វើការនៅភូមិភាគពាយព្យ ដែលគេហៅថាជីខ្លាញ់។ អង្គការ ជម្លៀសអ្នកទាំងអស់នោះដើម្បីធ្វើជាអ្នកនាំផ្លូវ ទៅវាយប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាម។ ខ្មែរក្រហមគិតថា ប្រសិនបើមានប្រជាជនច្រើននៅជាមួយពួកគេ កងទ័ពវៀតណាមមិនហ៊ានវាយនោះទេ ព្រោះខ្លាចត្រូវប្រជាជនស្លាប់បន្ថែមទៀត។

លុះព្រឹកឡើងអ្នកភូមិដែលត្រូវជម្លៀស ត្រូវក្រោកចាកចេញទៅពីព្រលឹមស្រាងៗ។ យាយនូ និងនឿន មានគំនិតមួយថា បើពួកគាត់ដើរយឺតអាចពន្យារពេលឲ្យកងទ័ពវៀតណាមមកជួយពួកគាត់បាន។ គាត់មិនហ៊ានធ្វើដំណើរទៅលឿននោះទេ ចំណែកប្រជាជនផ្សេងទៀត បានធ្វើដំណើរទៅមុខយ៉ាងសកម្មដោយសារពួកគេគិតថាកន្លែងថ្មីអាចនឹងប្រសើរជាងមុន។ ប្រជាជនជាច្រើនបានស្លាប់នៅពេលជម្លៀសដោយសារគ្មានអាហារ និងធ្លាក់ខ្លួនឈឺគ្មានថ្នាំធឹកព្យាបាល។ យាយនូ និងនឿន បានដើរទៅដល់គោកព្រាល ហើយមិនអាចធ្វើដំណើរទៅមុខបានទៀតទេ ព្រោះមានការវាយប្រហារនៅខាងមុខ។ ពួកខ្មែរក្រហម បានជម្លៀសប្រជាជនឲ្យត្រលប់ក្រោយវិញ។

ប្រជាជនត្រេកអរណាស់ពេលបានត្រលប់មកភូមិវិញ។ ប៉ុន្តែខ្មែរក្រហមកាន់តែរឹតបន្តឹងបន្ថែមខ្លាំងជាងមុនទៅទៀត។ ១ខែក្រោយមក ខ្មែរក្រហម បានជម្លៀសប្រជាជនម្តងទៀត។ ម្តងនេះ ខ្មែរក្រហមជម្លៀសចេញទៅដោយមិនត្រលប់មកវិញនោះទេ។ ផ្ទះប្រជាជននីមួយៗមានរទេះសេះ និងខាងមុខមានស្បៀងមួយចំនួនដែរ។ ប្រជាជនជាច្រើន ធ្វើដំណើរបានទៅដល់ពាក់កណ្តាលផ្លូវ ហើយសំណាងល្អ ពួកគេបានជួបនឹងកងទ័ពវៀតណាម ដែលកំពុងតែវាយចូលមករួចរំដោះប្រជាជនទាំងអស់នោះពីខ្មែរក្រហមបាន។ ក្នុងនោះមានយាយនូ និងកូនៗ ដែរដែលបានរួចជីវិតពីការជម្លៀសនោះ។ ក្រុមគ្រួសាររបស់យាយនូ បានជួបជុំគ្នាវិញនៅស្រុកកំណើតរបស់គាត់។

នៅក្នុងភូមិ មានការបែងចែករបស់របរនិងដីធ្លីដើម្បីធ្វើស្រែចម្ការចិញ្ចឹមជីវិតតាមក្រុម និងក្រោយមកតាមគ្រួសារឡើងវិញ។ តាំងពីពេលនោះមក ក្រុមគ្រួសាររបស់យាយនូ បានរស់នៅជួបជុំគ្នាយ៉ាងកក់ក្តៅ ទោះបីជានៅមានការខ្វះខាតរបស់របរនិងអាហារខ្លះក៏ដោយ។

ចប់


Documentation Center of Cambodia

៤0

រឿង ជីវិតជាសកល ឆាតូមិតាគ ពាយព្យ

អ្នកនិពន្ធ ៖ ហាច ភិរម្យ

៤0 ~ រឿង ជីវិតជាសកររបស់ភូមិភាគពាយព្យ

នៅពេលកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះ ខ្ញុំគឺជាក្មេងវត្តកំពុងស្នាក់នៅក្នុងវត្តកែវវិជ័យ ស្ថិតនៅក្នុងភូមិស្វាយលួង ឃុំកណ្តៀង ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ នៅក្នុងរបបខ្មែរក្រហម ភូមិស្វាយលួងស្ថិតនៅក្នុងតំបន់៧ នៃភូមិភាគពាយព្យ។ ថ្ងៃមួយ មានកងទ័ពខ្មែរក្រហមចំនួន៣ឡាន ដែលមានកាន់កាំភ្លើងគ្រប់ដៃ បានសម្រុកចូលមកក្នុងបរិវេណវត្តកែវវិជ័យ។ កងទ័ពខ្មែរក្រហមម្នាក់ បានស្រែកប្រកាសតាមឧបករណ៍បំពងសំឡេងដែលកាន់ជាប់នឹងដៃថា «កុំឲ្យមានការរត់ប្រសេចប្រសាចឲ្យសោះ។ ព្រះសង្ឃនិមន្តចូលទៅក្នុងកុដិទៅ រីឯតាអាចារ្យ យាយជី និងក្មេងវត្ត ចូលទៅសំណាក់រៀងៗខ្លួនដើម្បីរងចាំការប្រកាសឲ្យកោះប្រជុំ»។

មួយសន្ទុះក្រោយមក ការប្រកាសលាន់ឮសារជាថ្មីម្តងទៀត។ កងទ័ពខ្មែរក្រហមទាំងអស់នោះ ប្រកាសឲ្យលោកសង្ឃ មនុស្សចាស់ និងក្មេងៗ ដែលស្នាក់នៅក្នុងវត្តនាំគ្នាឡើងមកកាន់ព្រះវិហារ។ កងទ័ពខ្មែរក្រហម បានប្រាប់យើងមិនឲ្យគោរពប្រណិប័តន៍សាសនាទៀតឡើយ ថែមទាំងទុករយៈពេលឲ្យលោកសង្ឃសឹកដោយខ្លួនឯងក្នុងអំឡុងពេល៣ខែ។ កងទ័ពខ្មែរក្រហម បានព្រមានថា ប្រសិនបើលោកសង្ឃណាមិនសឹកទេនោះ អង្គការនឹងចាប់ផ្សឹកឲ្យហើយអង្គការនឹងយកទៅសម្លាប់ប្រសិនបើមិនស្តាប់តាមអង្គការទេនោះ។

នៅក្នុងខេត្តពោធិ៍សាត់ មានកន្លែងមួយឈ្មោះថាទួលប្រជ្រៃ មានទីតាំងស្ថិតនៅក្នុងឃុំស្រែស្តុក ស្រុកកណ្តៀង ជាទីកន្លែងដែលពួកខ្មែរក្រហមបានយកទាហាន និងមន្ត្រីរាជការប្រហែល៥០០នាក់ ទៅសម្លាប់ដោយមិនបានកាត់ក្តីរកខុសត្រូវទេ។ ប្រមាណជាង៣ខែក្រោយមក អង្គការបានប្រកាសអនុវត្តច្បាប់របស់ពួកគេជាបន្តបន្ទាប់។ ខ្មែរក្រហម បានចាត់វិធានការឲ្យប្រជាជនរស់នៅរួមជាក់ទ្រព្យសម្បត្តិរួម ធ្វើការងាររួម និងហូបរួម។ អង្គការ បានចាប់ផ្តើមបែងចែកកម្លាំងពលកម្មប្រជាជនទៅតាមប្រភេទ។ យាយៗ ត្រូវឲ្យទៅមើលក្មេងៗ។ តាៗ អង្គការឲ្យទៅធ្វើបង្គី អង្រុត ឬចាំចម្ការជាដើម ហើយមនុស្សវ័យកណ្តាលវិញ អង្គការឲ្យទៅធ្វើស្រែចម្ការ នេសាទត្រី ឡើងត្នោត និងការងារផ្សេងៗទៀតដែលអង្គការចាត់តាំង។ រីឯយុវជន អង្គការឲ្យទៅរែកដី ជីកប្រឡាយ និងលើកប្រព័ន្ធភ្លឺស្រែ។ ចំណែកកងកុមារ អង្គការឲ្យទៅដើររើសស្មៅនៅតាមស្រែ ឬចម្ការក្រោយពេលព្យុរាស់ កាប់ដើមទន្ទ្រានខែត្រ និងដើររើសអាចម៍គោយកមកធ្វើជី។

នៅក្នុងឆ្នាំ១៩៧៦ ប្រធានកងបានឲ្យខ្ញុំទៅរស់នៅក្នុងផ្ទះមួយ។ ផ្ទះនោះធ្វើអំពីឈើ ហើយមានប្រក់តែដំបូលទេ។ អង្គការបានឲ្យពួកខ្ញុំហូបរួម ដេករួម និងធ្វើការរួម។ នៅពេលនោះខ្ញុំមានអាយុ១៥ឆ្នាំ ខ្ញុំមិនដែលបានទៅសាលារៀនទៀតឡើយ ព្រោះពេលនោះ ខ្មែរក្រហមចូលមកកាន់កាប់ភូមិរបស់ខ្ញុំ។

រដូវវស្សាបានចូលមកដល់ ការងារបស់ពួកយើងកាន់តែធ្ងន់និងច្រើនជាងមុន ប៉ុន្តែអង្គការមិនឲ្យអាហារយើងហូបចុកគ្រប់គ្រាន់នោះទេ។ នៅពេលដែលគ្មានភ្លៀងធ្លាក់ អង្គការបានបញ្ជាឲ្យពួកយើងទៅបាចទឹកចូលស្រែសំណាប។ នៅពេលភ្លៀងធ្លាក់ខ្លាំងលិចសំណាប អង្គការបានបញ្ជាឲ្យយើងទៅបាចទឹកចេញពីស្រែវិញ។ ក្រុមរបស់ខ្ញុំបានចាប់ផ្តើមបាក់កម្លាំងម្តងបន្តិចៗ ទ្រាំស្ទើរលែងចង់បានទៅហើយ។ យើងធ្វើការនៅកណ្តាលវាលស្រែក្រោមទឹកដំណក់ភ្លៀង។ ខ្ញុំរងារណាស់ព្រោះខ្ញុំគ្មានអាវភ្លៀងទេ។ ខ្ញុំ ត្រូវដេកទាំងខោអាវសើម ព្រោះខ្ញុំមានខោអាវតែមួយសម្រាប់នេះតែប៉ុណ្ណោះ។ ថ្ងៃខ្លះរងារពេក ខ្ញុំបានយកខោអាវទៅឆ្អើរភ្លើងឲ្យបានស្ងួតបន្តិចទើបយកមកពាក់វិញ។ ទោះបីជាអង្គការ បានហាមឃាត់យើងមិនឲ្យ

បេះបោចបន្លែផ្លែឈើដែលជាសម្បត្តិរួមហូបក៏ដោយ ប៉ុន្តែខ្ញុំនៅតែលួច។ ខ្ញុំមិនអាចអត់ធន់នឹងភាពស្រេកឃ្លានបានឡើយ។ ខ្ញុំបានទៅលួចបូតគ្រាប់សណ្តែកគ្រាប់ល្ង និងគ្រាប់ស្រូវ ច្រកដាក់ក្នុងក្រមាយកទៅត្រាំក្នុងទឹករួចរង់ចាំមួយស្របក់ឲ្យគ្រាប់ធញ្ញជាតិរីកសិន បានខ្ញុំចាប់ផ្តើមស្រង់យកមកកាយកប់ដីស្តើងៗ ហើយបង្កាត់ភ្លើងពីលើ។ ខ្ញុំត្រូវមានស្មារតីប្រុងប្រយ័ត្នជានិច្ចទាំងនៅពេលលួច ចម្អិន និងពេលហូប ព្រោះប្រសិនបើអង្គការចាប់បាន គេនឹងយកខ្ញុំទៅរៀនសូត្រហើយ។ ពេលខ្លះ ខ្ញុំត្រូវកងឈ្លបសួរនាំដែរថា ហេតុអ្វីខ្ញុំមិនដេកពេលយប់ ហើយក្រោកមកបង្កាត់ភ្លើងធ្វើអ្វី?។ ខ្ញុំបានដោះសារថា មកពីខ្ញុំរងោពេក ហើយមូសខាំខ្លាចក្រែងស្អែកឈឺទៅធ្វើការមិនកើត។

ខ្ញុំមានសមមិត្តល្អម្នាក់ឈ្មោះ កែវ។ កែវ គឺជាដៃគូធ្វើការជាមួយខ្ញុំ។ ពួកយើងស្គាល់ចិត្តគ្នា និងចេះជួយគ្នានៅពេលធ្វើការងារ និងអាចធ្វើការបត់បែនតាមកាលៈទេសៈជាមួយគ្នា។ នៅក្នុងរបបខ្មែរក្រហមដល់ពេលយប់កាលណាកងល្បាតកាន់កាំភ្លើង ១ដើមជាមួយនឹងពិលមួយដើរឆ្លុះពិនិត្យមើលការងារតាមវាលស្រែក្រែងមាននរណាមិនធ្វើការងារ ហើយបើរកឃើញថាមានអ្នកណាមិនធ្វើការងារមែន អ្នកនោះប្រាកដជាត្រូវអង្គការស្តីបន្ទោស ឬចាប់យកទៅធ្វើទារុណកម្មជាមិនខានទេ។ រាល់ពេលមេយងងឹត ខ្ញុំនិងកែវចាប់ផ្តើមអនុវត្តផែនការ ដោយឲ្យម្នាក់សម្រាក និងម្នាក់ទៀតជាអ្នកបាចទឹកតិចៗទៅតាមកម្លាំងជៀសវាងស្ងាត់ពេកក្រែងកងល្បាតដឹង។ កន្លែងសម្រាករបស់យើង គ្មានអ្វីទៅណាក្រៅពីយកភ្លឺស្រែធ្វើជាខ្នើយ និងដេកត្រាំទឹកនោះឡើយ។ ពេលខ្លះ ខ្ញុំដេកលក់បានមួយភ្លែតដែរ។ ថ្ងៃមួយខ្ញុំដេកលក់ហើយសមមិត្តកែវដាស់ព្រោះកងល្បាតបានឆ្លុះពិលជិតមកដល់ទីតាំងធ្វើការរបស់ខ្ញុំហើយ។ ខ្ញុំក៏ស្រវេស្រវាក់ធុងទឹកមកបាចទឹកតាមធម្មតាវិញ។

រដូវបាចទឹកបានកន្លងផុត ពេលនោះមេកងឈ្មោះ អុន ហៅ តាខ្សែតី បានឲ្យពួកខ្ញុំទៅដកស្ទូងវិញម្តង។ ក្នុងរដូវស្ទូង ខ្ញុំពិបាកខ្លាំងណាស់។ ខ្ញុំហូបតែបបរគ្មានរសជាតិសោះ ហើយត្រូវទៅធ្វើការងារទាំងថ្ងៃ ទាំងយប់និងគ្មានថ្ងៃសៅរ៍អាទិត្យឡើយ ដើម្បីសម្រេចបានតាមផែនការរបស់អង្គការ។ ឈានចូលរដូវប្រាំង

មេកង បានបញ្ជូនខ្ញុំឲ្យទៅច្រូតស្រូវវិញម្តង។ បន្ទាប់ពីអស់ការងារស្ទូង និងច្រូត មេកងបានបញ្ជូនខ្ញុំឲ្យទៅកាប់ព្រៃ និងច្រូតស្មៅវិញម្តង។ នៅពេលនោះ ចុងភៅដាក់អង្ករតែបួនកំប៉ុងលាយជាមួយបន្លែត្រកួន ជួនកាលដាក់ព្រលឹតឫសគល់ចេក ក៏មានដែរនៅក្នុងបបរមួយខ្ទះត្នោតយ៉ាងធំ។ ខ្ញុំ ពេលខ្លះ បានឃើញសត្វឈ្លើងនៅក្នុងបបរក៏មានដែរ។ ដោយពិបាកស៊ូទ្រាំនឹងការធ្វើបាបនេះបាន សមមិត្តរួមការងារខ្លះស្លាប់ជាបន្តបន្ទាប់ ឯសមមិត្តផ្សេងទៀតរួមទាំងខ្ញុំដែរនោះ បានចាប់ផ្តើមឈឺរាករូស។ អ្នកខ្លះរាកដល់ថ្នាក់ធ្លាក់ឈាម អ្នកខ្លះទៀតគ្រុនញាក់ ក៏នៅតែអង្គការហៅឲ្យមកធ្វើការទៀត។ នៅពេលដែលខ្ញុំឈឺ ខ្ញុំតែងតែទៅបើកយកថ្នាំពីពេទ្យ។ ពេទ្យខ្មែរក្រហមឲ្យថ្នាំខ្មៅគ្រាប់ៗ ដូចៗគ្នាទៅអ្នកជំងឺ ទោះបីជាយើងឈឺអ្វីក៏ឲ្យថ្នាំនោះដែរ។ សមមិត្តខ្លះឈឺខ្លាំងដេកត្រែនៅពេទ្យ អ្នកជំងឺខ្លះត្រូវដេកកន្ទេលនៅនឹងកម្រាលឥដ្ឋ។ នៅក្នុងមន្ទីរពេទ្យនោះកខ្វក់ណាស់គ្មានអនាម័យទេ។

អង្គការ បានអនុវត្តផែនការរបស់ខ្លួន គឺស្រាវជ្រាវស្វែងរកចាប់ខ្លួនអ្នកណាដែលជាប់និន្នាការទោហានរបស់របបលន់ នល់ យកទៅសម្លាប់ចោលឥតឈប់ឈរឡើយ។ ខ្ញុំសង្កេតឃើញមានប្រជាជនថ្មីជាច្រើនដែលជម្លៀសមកពីភ្នំពេញ និងខេត្តផ្សេងៗមកកាន់តំបន់ដែលខ្ញុំរស់នៅ។ ខ្ញុំបានស្គាល់ មិត្តសាន។ ឪពុករបស់គាត់ជាមន្ត្រីរឹងម្តាយរបស់គាត់វិញគឺជាអាជីវករ។ មិត្តសាន បានរៀបរាប់ប្រាប់ខ្ញុំថាក្រុមគ្រួសាររបស់គាត់ត្រូវជម្លៀសមកពីភ្នំពេញ។ ម្តាយរបស់គាត់ បានស្លាប់នៅតាមផ្លូវ ព្រោះគាត់អត់អាហារ និងឈឺគ្រុនគ្មានថ្នាំលេប។ រីឯឪពុករបស់គាត់ត្រូវអង្គការចាប់ខ្លួនបាត់ដំណឹងសូន្យឈឹង។ ខ្ញុំ និងមិត្តដទៃទៀត នាំគ្នាជួយការងារមិត្តសាន ព្រោះមិត្តសាន គឺជាកូនអ្នកទីក្រុងមិនចេះការងារស្រែចម្ការអ្វីបន្តិចសោះឡើយ។ ពេលខ្លះ យើងនាំគ្នាចែកអាហារ ដែលពួកយើងលួចចម្អិនយកមកឲ្យមិត្តសាន ហូបថែមទៀតផង។ មិត្តសាន នៅតែមិនអាចទ្រាំទ្របាននៅការរស់នៅបែបនេះទេ។ សុខភាពរបស់គាត់ ចេះតែចុះខ្សោយបន្តិចម្តងៗ រហូតដល់ស្លាប់។

ក្នុងឆ្នាំ១៩៧៧ មេកងបានបញ្ជូនយើងឲ្យទៅធ្វើការនៅភូមិធ្លាមអំបិល។ អង្គការ បានហៅយើងឲ្យទៅប្រជុំរួចចែក ចប បង្គី និងស្បែកជើង ដើម្បីទៅជីក

ប្រឡាយឈ្មោះ ហុងចារឹក ដែលស្ថិតក្នុងសហករណ៍ស្បា ស្រុកកណ្តៀង ក្នុងតំបន់៧។ មេកងតម្រូវឲ្យយើងជីកដីជម្រៅ១.៥គីប ឲ្យបានក្នុងមួយថ្ងៃ។ បើធ្វើបានតាមផែនការ យើងនឹងបានហូបបាយ ប៉ុន្តែបើអ្នកណាធ្វើមិនបានតាមផែនការកំណត់ទេនោះ អង្គការនឹងនាំទៅកសាង ឬណែនាំ ហើយឲ្យហូបបបរវា។ នៅក្នុងភូមិធ្លក បានយកមនុស្សឲ្យអូសនង្គ័លជំនួសឲ្យសត្វគោ។ អង្គការយកមនុស្សប្រាំនាក់ទឹមជាមួយនង្គ័លមួយ ដោយឲ្យបួននាក់អូស និងម្នាក់កាន់យាមនង្គ័ល។

ក្រោយមក មេកងបានបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅកន្លែងផ្សេងវិញ។ នៅកន្លែងថ្មី ខ្ញុំត្រូវលើកប្រព័ន្ធភ្លឺស្រែ ដែលមានទទឹង ១ម៉ែត្រ ខ្នងកំពូលភ្លឺទទឹង ៧តឹក និងមានកំពស់ ៥តឹក ហើយមេកងបានដាក់ផែនការឲ្យយើងក្នុងម្នាក់ៗ ធ្វើឲ្យបានបណ្តោយ២០ម៉ែត្រ។ ខ្ញុំខំប្រឹងធ្វើការតាំងពីម៉ោង ៤ទៀបភ្លឺ ដល់ម៉ោង ១១ព្រឹក និងបន្តពីម៉ោង ១រសៀល ដល់ម៉ោង ៥ល្ងាច។ ខ្ញុំ និងប្រជាជនផ្សេងទៀតធ្វើការងារមិនបានគ្រប់ទៅតាមផែនការនោះទេ។ មេកងបានដកយករបបអាហារខ្ញុំ និងប្រជាជនផ្សេងៗទៀតដែល ធ្វើការមិនគ្រប់ទៅតាមផែនការ ដោយមានការកាត់បន្ថយពីអាហារបាយ ៣វែក នៅសល់តែ២វែក។ ខ្ញុំមិនពេញចិត្តនឹងទង្វើដែលមេកងធ្វើមកលើពួកយើងនោះទេ ហើយខ្ញុំបានចេញមុខតវ៉ាជាមួយមេកងថា «សមមិត្តបង! របបអាហារពួកខ្ញុំមានតែ៣វែកទេ ហើយឥឡូវដោយសារពួកខ្ញុំធ្វើការមិនគ្រប់តាមផែនការ សមមិត្តបងបន្ថយរបបអាហារខ្ញុំសល់តែ ២វែក អីចឹង តើពួកខ្ញុំមានកម្លាំងឯណាទៅធ្វើការនៅថ្ងៃស្អែកទៀត ម្យ៉ាងទៀតពួកខ្ញុំសុទ្ធសឹងតែជាក្មេងៗ ដែលពុំធ្លាប់ធ្វើការងារហ្នឹងផង»។ ពេលនោះមេកងខឹងនឹងខ្ញុំខ្លាំងណាស់ ហើយតបមកខ្ញុំវិញថា «សមមិត្តព្រហើនម្ល៉េះ ហើយហ៊ានប្រឆាំងនឹងបញ្ជារបស់អង្គការទៀត ទាំងដែលសមមិត្តធ្លាប់ដឹង ធ្លាប់ឃើញហើយថានឹងទទួលបានលទ្ធផលបែបណានោះ»។ មេកងនិយាយរួច ក៏ដើរចេញទៅទាំងខឹងសម្បាយ៉ាងខ្លាំង។ មិត្តរួមការងារផ្សេងទៀត មើលមកខ្ញុំទាំងអស់សង្ឃឹម។ លុះថ្ងៃស្អែកឡើង ខ្ញុំទៅលើកភ្លឺស្រែដូចរាល់ដងរហូតដល់ល្ងាច។ ពេលខ្ញុំកំពុងដើរត្រលប់មកពីលើកភ្លឺស្រែវិញ ស្រាប់តែ សមមិត្តវី បានមកហៅខ្ញុំថា«សមមិត្ត

ហែន សមមិត្តបង ឲ្យហៅទៅជួប»។ ឮដូច្នោះហើយ ខ្ញុំ បានដើរតាម សមមិត្តវី រហូតដល់កន្លែងមេកង រួចខ្ញុំសួរទៅមេកងថា «សមមិត្តបង ហៅខ្ញុំមានការអ្វីដែរ? » និយាយរួច ខ្ញុំស្រាប់តែក្រឡេកមើលជញ្ជាំង ក៏ឃើញមានកងឈ្លបចំនួន ៤នាក់ ឈរនៅទីនោះ។ ពួកឈ្លបបានស្ទុះមកចាប់ខ្ញុំ រួចបណ្តើរយកខ្ញុំចេញទៅ។ នៅតាមដងផ្លូវ ខ្ញុំគ្មានគិតឃើញអ្វីឡើយក្រៅពីយល់ឃើញថាខ្លួនខ្ញុំប្រាកដជាស្លាប់ជាមិនខានឡើយ។ បើខ្ញុំប្រុងរត់គេចប្រាកដជារត់គេចមិនរួចឡើយ ហើយបើខ្ញុំតដៃក៏មិនឈ្នះគេដែរ ព្រោះកងឈ្លបទាំងនោះមានអាវុធគ្រប់គ្នាទាំងអស់។ កងឈ្លបឈ្មោះ ប៉ោង និង ឈឹង មានកាំភ្លើងម៉ាកអាកាម្នាក់មួយដើម និងចបកាប់ ១ដែរ។ ចំណែកឯឈ្មោះ ឆោម មានកាំភ្លើងម៉ាកអឹមសឺ ១ដើម និងឈ្មោះចាន់ មានកាំបិតផ្គាក់១។ កងឈ្លប បានបណ្តើរខ្ញុំទៅដល់កន្លែងសម្លាប់ដែលស្ថិតនៅឆ្ងាយពីភូមិបន្តិច។ ខ្ញុំបានឃើញរណ្តៅមួយ ដែលជីករួចជាស្រេច។ កងឈ្លប បានឲ្យខ្ញុំលុតជង្គង់មុខរណ្តៅ ហើយក៏ដើរទៅឆ្ងាយពីខ្ញុំប្រហែលជា៤ម៉ែត្រ ដើម្បីពិភាក្សាគ្នាសិន។ នៅពេលកំពុងលុតជង្គង់ខាងមុខរណ្តៅនោះ ខ្ញុំបានត្រឹមតែទន្ទេញពាក្យថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងរំឭកដល់គុណម្តាយឪពុករបស់ខ្ញុំស្ងាត់ៗតែម្នាក់ឯង។ បន្តិចក្រោយមក ពួកឈ្លប បានដើរមកជិតខ្ញុំ ហើយ ប៉ោង និងឆោម បានអាមេកាំភ្លើងនៅពីខាងក្រោយខ្នងរបស់ខ្ញុំ។ ឈឹង បានឈរកាន់ចប និងចាន់ បានដើរក្រឡឹងជុំវិញនិងសួរចម្លើយ ដោយបានសម្តែងជាក់ខ្ញុំខ្លាំងៗថា «ហេតុយ៉ាងម៉េចបានជាមិត្តឯងថ្លើមធំហ៊ានប្រឆាំងនឹងអង្គការ?»។ ខ្ញុំបានឆ្លើយតបទៅវិញទាំងសំឡេងញ័រៗថា «សុំទោសមិត្តបង ខ្ញុំមិនហ៊ានប្រឆាំងនឹងអង្គការទេ ព្រោះខ្ញុំនៅក្មេង ហើយការងារដែលមិត្តបងជាក់ឲ្យខ្ញុំធ្វើ ក៏ខ្ញុំមិនបានប្រកែកដែរ។ ប៉ុន្តែការងារខ្លះខ្ញុំមិនធ្លាប់ធ្វើទេ ទើបខ្ញុំធ្វើមិនបានតាមផែនការរបស់អង្គការ។ សមមិត្តបងជួយគិតខ្ញុំមើល មិនមែនមានតែខ្ញុំតែម្នាក់ឯងទេដែលធ្វើមិនរួចតាមផែនការ តែមេកងប្រកាន់តែខ្ញុំម្នាក់ទៅវិញ»។ ពួកឈ្លបនៅតែបន្តសួរចម្លើយខ្ញុំបន្តទៀត។

មិត្តចាន់ៈ «ឪពុករបស់មិត្តឯងធ្លាប់ធ្វើទាហានមែនទេ?»។

ខ្ញុំៈ «ពុករបស់ខ្ញុំគឺជាអ្នកស្រែ»។

មិត្តចាន់ៈ «ម៉ែរបស់មិត្តធ្លាប់ធ្វើពេទ្យឬ?»។

ខ្ញុំៈ «ពុក និងម៉ែរបស់ខ្ញុំសុទ្ធតែជាអ្នកធ្វើស្រែចម្ការនៅក្នុងភូមិធ្លកនេះ នរណាក៏ស្គាល់គាត់ដែរ»។

នៅពេលសួរចម្លើយចប់ មិត្តឈឹង បានកាន់ចបដើរមកខាងក្រោយខ្នងរបស់ខ្ញុំ។ ខ្ញុំព្រឺឆ្អឹងខ្នងណាស់ ហើយខំបិទភ្នែក ព្រោះខ្ញុំគិតថា ប្រាកដជាត្រូវមិត្តឈឹង វាយនឹងដងចបនោះសម្លាប់ខ្ញុំចោលហើយ។ ប៉ុន្តែ មិត្តឈឹង បែរជាចាប់សក់ក្បាលរបស់ខ្ញុំជាប់លើកឡើងលើឲ្យក្រោកឈរនិងបង្វិលក្បាលរបស់ខ្ញុំឲ្យមើលមុខគាត់ រួចនិយាយថា «មិត្តឯងទៅសម្រាកចុះ ហើយក៏បង្វិលក្បាលខ្ញុំឲ្យទៅមុខ និងទាត់កំប៉ែះគូទខ្ញុំមួយជើងថែមទៀត»។

ពេលនោះយប់ហើយ គុណទឹកដោះម្តាយថ្លៃ ខ្ញុំមិននឹកស្មានថា ខ្ញុំអាចរួចជីវិតឡើយ។ ខ្ញុំដើរមកការដ្ឋានវិញទាំងក្នុងខ្លួនគ្មានព្រលឹងបន្តិចសោះឡើយ។ ពេលមកដល់វិញ ក្រុមមិត្តសម្លាញ់របស់ខ្ញុំ មកទទួល និងសាកសួរពីដំណើររឿងដែលពួកឈ្លបចាប់ខ្ញុំទៅ។ ខ្ញុំខំប្រឹងសម្រួលអារម្មណ៍ រួចនិយាយរៀបរាប់ប្រាប់ទាំងនៅតក់ស្លុតនៅឡើយ។ មិត្តសម្លាញ់របស់ខ្ញុំ បានមកឱបខ្ញុំជុំជិត ហើយនិយាយទាំងទឹកភ្នែកមកកាន់ខ្ញុំថា «ឯងអស់អីហើយ»។ រួចខ្ញុំក៏ទៅងូតទឹក ហើយចូលទៅដេក។ ភ្លាមៗនោះមានមនុស្សពីរនាក់ដើរសំដៅចូលមកកន្លែងខ្ញុំសម្រាក។ មេឃងងឹតពេក ខ្ញុំមើលមិនស្គាល់ថាជានរណាទេ។ មនុស្សពីរនាក់នោះបានហៅឈ្មោះខ្ញុំ ហើយយកបាយមួយចានមកឲ្យខ្ញុំ ថែមទាំងមានត្រីប្រឡាក់ឆ្អិនមួយក្បាលដែរ។ ពួកគេគឺជាសមមិត្តរួមកងជាមួយនឹងខ្ញុំនៅផ្នែកចុងភៅ។ ខ្ញុំបានទទួលយកអាហារទាំងនោះ ប៉ុន្តែខ្ញុំមិនទាន់ហូបទេ ព្រោះខ្ញុំចង់ទុកបាយនេះឲ្យ មិត្តអេង មិត្តយ៉ុន មិត្តឃន និងមិត្តជាច្រើនទៀត។ ពួកគាត់បានសួរខ្ញុំថា «ម៉េចក៏មិនហូបបាយទៅ?» ខ្ញុំឆ្លើយតបទៅវិញថា «ហូបធ្វើអី?»។ ពេលនោះក្នុងចិត្តរបស់ខ្ញុំគិតថា យប់ជ្រៅបន្តិចប្រាកដជាកងឈ្លបយកខ្ញុំទៅសម្លាប់ចោលហើយ ដូច្នេះបាយម្ហូបអស់ទាំងនេះទុកឲ្យមិត្តរបស់ខ្ញុំដែលនៅរស់ទៅចុះ។

គិតរួចហើយខ្ញុំក៏ចូលដេក។ ខ្ញុំដេកលក់ស្រួលណាស់នៅយប់នោះរហូតទាល់តែមេកងផ្តុំកញ្ចែឲ្យងើបទៅធ្វើការទើបខ្ញុំភ្ញាក់ឡើងសម្អាតមុខមាត់ ហើយហៅមិត្តរួមការងារហូបបាយដែលខ្ញុំយកលាក់ទុកពីយប់មិញ។ ក្រោយមក មេកងបានប្តូរឲ្យខ្ញុំទៅធ្វើជាចុងភៅម្តង។ នៅពេលដាំគ្មាននរណាបង្រៀនយើងពីរបៀបដាំបាយឆ្នាំងធំឡើយ ដូច្នេះខ្ញុំដាំបាយនៅ ព្រោះឆ្នាំងនោះធំពេក ហើយខ្ញុំស្មានជាក់ទឹកដាំបាយមិនត្រូវ។ មេកងបានកោះហៅខ្ញុំទៅកសាងស្តីបន្ទោស ហើយគំរាមយកទៅសម្លាប់នៅក្នុងគុក០៧។ នៅតំបន់ ខ្ញុំរស់នៅ មានគុកពីរកន្លែងសម្រាប់ឃុំឃាំង ធ្វើទារុណកម្ម និងសួរចម្លើយអ្នកទោស គឺគុក០៧ និងគុក០៨។ គុក០៧ មានទីតាំងនៅភូមិសា្ទ ជាកន្លែងដាក់អ្នកទោសល្មើសនឹងច្បាប់របស់អង្គការ ដូចជាបានលួចហូបចំណីអាហារម្នាក់ឯង ឬធ្វើការមិនគ្រប់តាមផែនការជាដើម។ ចំណែក គុក០៨ វិញ ស្ថិតនៅភូមិក្បាលឈើពុក ជាកន្លែងដាក់អ្នកទោសជាប់និន្នាការរបស់ លន់ នល់ រួមមាន ប៉ូលីស ទាហាន និងមន្ត្រីរាជការដែលអង្គការបានស្រាវជ្រាវចាប់បាន ឬប្រជាជនដែលក្រោកតវ៉ាប្រឆាំងនឹងអង្គការជាដើម។

នៅក្នុងឆ្នាំ១៩៧៧ ប្រជាជននៅក្នុងកងរបស់ខ្ញុំទាំងចាស់ទាំងក្មេងរងទុក្ខវេទនាកាន់តែខ្លាំងទៅៗ គ្មានស្គាល់ពេលវេលាស្បើយឡើយ។ អង្គការបានឲ្យប្រជាជនក្នុងកងតាមដានគ្នាទៅវិញទៅមកស្វែងរកអ្នកចេះដឹង មន្ត្រី ទាហាន ឬប៉ូលីស នៅក្នុងរបបចាស់ ដើម្បីយកទៅសម្លាប់ចោល។ ដូចឪពុកមារបស់ខ្ញុំឈ្មោះ គឹម ជឿន ត្រូវអង្គការចោទប្រកាន់ថាជាអតីតទាហាន លន់ នល់។ មេកងឈ្មោះខន បានតាមសម្លាប់ឪពុកមារបស់ខ្ញុំ ប៉ុន្តែគាត់បានដឹងខ្លួនជាមុន ក៏បានរត់ចោលប្រពន្ធ និងកូនបាត់សូន្យឈឹង។ ប៉ុន្មានខែក្រោយមក មេកង និងឈ្លបបានមកចាប់ប្រពន្ធ និងកូនរបស់គាត់ទៅសម្លាប់គ្មានសេសសល់ម្នាក់ទេ។ ការសម្លាប់ក្រុមគ្រួសាររបស់ឪពុកមាខ្ញុំ ធ្វើឲ្យប្រជាជនក្នុងភូមិខ្លាចខ្លាំងណាស់។ ប្រជាជនម្នាក់ៗគិតតែពីប្រឹងធ្វើការងារមិនហ៊ានតវ៉ាទេ។

រហូតមកដល់ឆ្នាំ១៩៧៨ ខ្ញុំលែងរស់នៅក្រោមការគ្រប់គ្រងរបស់មេកងឈ្មោះ ខុន ទៀតហើយ។ ខ្ញុំប្តូរមករស់នៅក្រោមការគ្រប់គ្រងរបស់មេកងឈ្មោះ

សឿន វិញម្តងនៅក្នុងកងសិប្បកម្មរបស់សហករណ៍វិញម្តង។ នៅក្នុងកងសិប្បកម្ម ខ្ញុំ ធ្វើរនាស់ នង្គ័ល រទេះ គ្បាល់បុក គ្បាល់កិន គ្បាល់ជាន់ គ្បាល់បក់ ផ្លែពូថៅ ផ្លែកាំបិត ស្លផាល និងធ្វើជន្លួញនង្គ័លជាដើម។ ថ្ងៃខ្លះ មេកងសឿន បានឲ្យ ខ្ញុំដើរកបន្លែមកទុកក្នុងកង។ ខ្ញុំបានដើរដកព្រលឹត រំចង់ និងត្រកួន យកមក ឲ្យចុងភៅធ្វើម្ហូប។ ជួនកាល មេចុងភៅនាំខ្ញុំទៅបើករបបនៅពាណិជ្ជកម្មប្រចាំ សហករណ៍ ដែលអ្នកគ្រប់គ្រងមានឈ្មោះ ជាន់ ហៅ យាយជាន់។ ថ្ងៃមួយ ក្រោយពីបើកអង្ករ អំបិល និងប្រហុករួច ខ្ញុំបានដើរកាត់ផ្ទះពាណិជ្ជសហករណ៍ ហើយបានឃើញក្នុងផ្ទះរបស់គាត់មានមាសយ៉ាងច្រើនប្រហែលជាជិត១តោន។ មាសទាំងអស់នោះ ត្រូវបានពួកមេកងប្រមូលពីប្រជាជនគ្រប់កងយកមកទុក។

ក្រោយមកមេកងបានផ្លាស់ការងារខ្ញុំឲ្យទៅខាងផ្នែកនេសាទត្រីជាមួយ តាព្រិន វិញ។ យើងទៅនេសាទនៅភូមិស្បាក្រោម ដែលមានចម្ងាយរហូតដល់ទៅ ៧គីឡូម៉ែត្រ។ ខ្ញុំត្រូវរកត្រី និងបន្លែមកដាក់ឲ្យខាងកងសិប្បកម្មដែរ។ ខ្ញុំត្រូវដើរ ចេញទៅនេសាទនៅពេលព្រឹក និងត្រលប់មកកងសិប្បកម្មវិញនៅពេលល្ងាចជារៀងរាល់ថ្ងៃ។ ថ្ងៃមួយ ញ៉ាង ដែលជាអ្នកនេសាទជាមួយខ្ញុំឈឺ ដូច្នោះខ្ញុំពុំបានចេញទៅនេសាទត្រីទេ។ ថ្ងៃនោះ ខ្ញុំឃើញពួកមេកង និងកងឈ្លប បានដើញតាមសម្លាប់សមមិត្តអាម ហៃ។ កងឈ្លបមានគ្នា ៧នាក់ ដែលកងឈ្លបម្នាក់ឈ្មោះ ម៉ី មួយ ជាមេកងឈ្លប និងជាមេគុកធំ ០៨ នៅភូមិក្បាលឈើពុក បានតាមសម្លាប់សមមិត្តអាម ហៃ តែម្នាក់ឯង។ អាម ហៃ មិនព្រមឈប់រត់គេចទេ ទើបពួកកងឈ្លបបាញ់សម្លាប់រួចមេគុក ម៉ី មួយ បានដកពូថៅចេញពីស្មៅតចង្កេះពុះក្បាលអាម ហៃ បន្ថែមទៀតពោរពេញដោយកំហឹង។ បន្ទាប់ពីសម្លាប់រួច កងឈ្លប បានហៅពូៗ ដែលនៅធ្វើការងារនៅក្នុងកងសិប្បកម្មឲ្យយកសាកសព សមមិត្តអាម ហៃទៅកប់។

ថ្ងៃមួយទៀតក្នុងឆ្នាំដដែលនេះ នៅពេលដែលខ្ញុំកំពុងសម្រាកក្រោមដើមក្រសាំងបន្ទាប់ពីរែកត្រីពីភូមិក្រចាប់មកកាន់សហករណ៍វិញ ខ្ញុំបានឃើញឈ្មោះ ចាន់ ដែលជាកងឈ្លបបណ្តើរស្ត្រីម្នាក់ជាមួយនឹងកូនតូចៗរបស់គាត់ចំនួន២នាក់ ទៀតនៅត្រង់ចំណុចដើមភូមិធ្លក ត្រង់ស្ពានឆ្លងទៅភូមិក្បាលឈើពុក។ ស្ត្រី

នោះបាននិយាយទៅកាន់កងឈ្លបថា «មិត្តអូន! ខ្ញុំសុំសម្រាកមួយភ្លែតមក»។ និយាយហើយ គាត់បានដាក់កូនចុះពីលើស្មា និងដាក់បង្វេចចុះពីលើក្បាល រួចដាក់គូទអង្គុយបំបៅកូន។ ស្រាប់តែរំពេចនោះ កងឈ្លប បានយកកាំបិតផ្តាក់គោះក្បាលស្ត្រីនោះរហូតហូរឈាមសស្រាក់។ ខ្ញុំឃើញដូចច្នោះខឹងខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនដឹងជាជួយគាត់ដោយវិធីណាទេ។ ខ្ញុំបានត្រឹមតែដកដង្ហើមធំប្រឹងសម្រួលអារម្មណ៍លើកសង្រែកត្រីបន្តរែកត្រលប់ទៅកងវិញ។

លុះថ្ងៃក្រោយមកទៀត ខ្ញុំបានរែកត្រី និងបន្លែ យកមកដាក់ដល់កង រួចទៅបើករបបអាហារប្រចាំថ្ងៃដើម្បីត្រលប់ទៅភូមិក្រចាប់វិញដូចសព្វដង។ ពេលនោះស្រាប់តែពួកកងឈ្លបចំនួន ៦នាក់ប្រចាំសហការណ៍ មកព័ទ្ធរោងសិប្បកម្មនិងបិទទ្វារជាប់ធ្វើឲ្យខ្ញុំភិតភ័យយ៉ាងខ្លាំង ព្រោះមិនដឹងថាពួកឈ្លបមកចាប់អ្នកណាទេ។ ខ្ញុំបានឃើញពូម្នាក់ឈ្មោះ វិន បានស្ទុះមួ៉ម្នាឡើងទាញកាំបិតផ្តាក់កាន់ជាប់ដៃ។ រីឯ កងឈ្លបវិញ បានបើកទ្វារសម្រុកចូលក្នុងបំណងចង់ចាប់គាត់ទាំងរស់។ ពូវិន មិនញញើតក្នុងការតតាំងជាមួយពួកកងឈ្លបទាំងអស់នោះឡើយ។ គាត់បានប្រើកាំបិតផ្តាក់គ្រីគ្រាត់ដើម្បីការពារខ្លួនរបស់គាត់មិនឲ្យកងឈ្លបចាប់បានឡើយ។ ឃើញដូច្នោះ ពួកកងឈ្លបនិយាយទៅកាន់គាត់ថា «អាក្បត់! ឯងព្រហើនហ៊ានតដៃក្បត់ជាមួយអង្គការផងឬ?» ពូវិនក៏ស្រែកតបវិញថា «អញមិនក្បត់ទេ! ពួកអាឯងទេដែលក្បត់ជាតិឯង! សម្លាប់ជាតិ និងប្រជាជនដែលស្លូតត្រង់នោះ»។ ពូវិន និងកងឈ្លប ជេរប្រទេចគ្នាទៅវិញទៅមកយ៉ាងតឹងសរសៃក ស្រាប់តែរំពេចនោះស្នូរកាំភ្លើងបានផ្ទុះឡើងផ្ទួងៗៗ ចំនួន៣គ្រាប់។ ឈ្លបម្នាក់ឈ្មោះ ឆោម គឺជាអ្នកបាញ់ ពូវិន បណ្តាលឲ្យគាត់ដួលនៅក្នុងរោង ហើយឈ្លបឈ្មោះ ញ៉ាណ បានកាប់ពីលើខ្លួនគាត់បន្ថែមទៀតរួចអូសយកទៅចោលប្រហែលជា២០ម៉ែត្រពីរោងសិប្បកម្ម។ ខ្ញុំបានមើលឃើញអំពើឃោរឃៅរបស់កងឈ្លបដោយផ្ទាល់ភ្នែក។ ពួកឈ្លបបានហៅប្រជាជននៅក្នុងកងសិប្បកម្មឲ្យចូលប្រជុំ។ ឈ្លបម្នាក់ឈ្មោះ ឆោម បាននិយាយមកកាន់ពួកខ្ញុំថា «មើលគំរូឲ្យហើយទៅ! នេះហើយអ្នកក្បត់អង្គការវាត្រូវតែទទួលលទ្ធផលអីចឹង»។

ខ្ញុំបានបន្តការងារនេសាទត្រីរហូតដល់ថ្ងៃទី ០៧ ខែមករា ឆ្នាំ ១៩៧៩។ កងសិប្បកម្មព្រមទាំងកងផ្សេងៗទៀត ត្រូវបានកងទ័ពរំដោះ មានខ្មែរ និងវៀតណាមមកកៀងយកទៅទីរួមខេត្តពោធិ៍សាត់អស់។ ចំណែកក្រុមនេសាទត្រីដែលរស់នៅក្នុងកងផ្សេងៗពីគ្នា បានរត់មកនៅជុំគ្នា។ យើងមានគ្នាសរុបចំនួន១៨នាក់។ យើងភិតភ័យខ្លាំងណាស់ខ្លាចកងឈ្លបមកចាប់សម្លាប់ចោលដោយចោទថាយើងចុះចូលជាមួយកងទ័ពរំដោះជាតិ។ យើងបានសម្រេចចិត្តនាំគ្នាគេចចេញពីជំរំទៅដេកនៅក្នុងព្រៃអស់រយៈពេល៣យប់៣ថ្ងៃ ទើបស្វែងរកឃើញផ្លូវចូលទៅកាន់ខេត្តពោធិ៍សាត់វិញ។ ពេលនោះ ឪពុករបស់ខ្ញុំ ក៏បានមកជុំជាមួយខ្ញុំដែរ។ ពួកយើងចាប់ផ្តើមធ្វើដំណើរផ្សងព្រេងនៅពេលយប់ពីភូមិក្រចាប់មកកាន់ទីរួមខេត្តពោធិ៍សាត់ កាត់តាមភូមិត្រពាំងថ្មមកដល់ភូមិកញ្ជរ រួចឆ្លងស្ទឹងមកតាមភូមិផ្ទះគរ និងព្រៃស្លឹក រហូតមកដល់ខាងក្រោយវត្តពោធិ៍។ មិនទាន់ដល់វត្តពោធិ៍ផង ស្រាប់តែមានកងទ័ពខ្មែរក្រហមដេញបាញ់យើងពីខាងក្រោយលាន់ឮសូរប្រាវៗ។ សំណាងល្អពេលនោះ មានកងទ័ពរំដោះជាតិនៅខាងមុខពួកយើងបានចេញមកជួយ។ ពួកយើងនៅកណ្តាល នាំគ្នាក្រាបចុះ ព្រោះខ្លាចត្រូវគ្រាប់កាំភ្លើងដែលកងទ័ពទាំងពីរក្រុមកំពុងតែប្រយុទ្ធគ្នា។ រំពេចនោះកងទ័ពរំដោះបានស្រែកមកកាន់ពួកយើងថា «បើប្រជាជនខ្មែរឲ្យលើកដៃឡើង»។ ពួកយើងក៏នាំគ្នាលើកដៃឡើង ហើយស្រែកតបទៅវិញថា «ពួកយើងជាប្រជាជនទេ»។ ពេលឮពួកយើងស្រែកហើយ កងទ័ពរំដោះជាតិបានរត់សំដៅមករកយើង។ ក្រោយមកខ្ញុំបានជួបជាមួយនឹងឪពុកម្តាយ បងស្រី ព្រមទាំងក្មួយៗ។

ចប់

៤១

រឿង ជីវិតបុប្ផា ក្នុងស្បែកអន្ធការ

អ្នកនិពន្ធ ៖ សុិញ្ញ រស់

៤១ ~ រឿង ជីវិតបុច្ឆា ក្នុងស្បែកអន្ធការ



សភាវៈតែងប្រែប្រួលឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ។ កង់ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ក៏ធ្វើដំណើរផ្លាស់ប្តូរមិនឈប់ឈរពីរបបចាស់ឆ្ពោះទៅរបបថ្មីដែរ។ ស្ថានការណ៍វឹកវរចាប់ផ្តើមកើតមាននៅតាមទីក្រុង និងទីប្រជុំជននានាទូទាំងប្រទេសកម្ពុជា ព្រោះក្រុមខ្មែរក្រហមប្រឆាំងនឹងរបប លន់ នល់ តាំងពីមុនឆ្នាំ១៩៧៥មកម្ល៉ះ។

ប្រជាជននៅស្រុកសំឡូតទាំងអស់រស់នៅធម្មតា មិនមានជ្រួលច្របល់អ្វីឡើយ ព្រោះខ្មែរក្រហម បានចូលមកគ្រប់គ្រងតំបន់សំឡូតតាំងពីមុនថ្ងៃ១៧មេសាមកម្ល៉ះ ហើយមិនទាន់មានការរឹតត្បិតសិទ្ធិសេរីភាពប្រជាជនទេ។ ពេលរសៀលថ្ងៃមួយ ហូ យន់ និងហ៊ូ នឹម ដែលជាអតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃសម័យសង្គមរាស្ត្រនិយម និងជាមេភូមិភាគពាយព្យក្នុងសម័យ ប៉ុល ពត នោះ បានចុះមកផ្សព្វផ្សាយអំពីជ័យជម្នះរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ហូ យន់ និងហ៊ូ នឹម បានប្រាប់ពីគោលការណ៍របស់របបកម្ពុជាប្រជាធិបតេយ្យថា របបកម្ពុជាប្រជាធិបតេយ្យនឹងផ្តល់សិទ្ធិឲ្យប្រជាជនដូចសម័យសង្គមរាស្ត្រនិយម ថែមទាំងយាងសម្តេចព្រះ នរោត្តម សីហនុ មកគ្រប់គ្រងដូចកាលពីមុន។ ប្រជាជនរស់នៅក្នុងតំបន់សំឡូតនេះ មានការគោរពរបបរាជានិយមតាំងពីសម័យបុរាណកាលព្រមទាំងស្រលាញ់ពេញចិត្តការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ណាស់

ស្របពេលខ្មែរក្រហមបានចូលមកគ្រប់គ្រងស្រុកសំឡូតជាយូរមកហើយផង នោះ ប្រជាជនដែលរស់នៅក្នុងភូមិអូរដោ និងភូមិផ្សេងៗទៀត ចាប់ផ្តើមមានចិត្តស្រលាញ់របបអាវខ្មៅកាន់តែខ្លាំងឡើងតាំងពីពេលនោះមក។

ស្ទើរតែមិនជឿទាល់តែសោះថាទឹកដីធម្មជាតិរបស់ស្រុកសំឡូតបានលាក់ទុកបុប្ផាមួយទងមានរូបឆោមលោមពណ៌ស្រស់បំព្រងក្នុងវ័យ១៦ឆ្នាំ ឈ្មោះ នាង ហឿន កើតក្នុងត្រកូលកសិករក្រីក្រមួយក្នុងភូមិអូរដោ។ នាងហឿន ជាកូនរបស់តាខឹម និងយាយលុយ។ នាងហឿន ជាកូនច្បងក្នុងគ្រួសារ ដែលមានស្មារតីក្លាហានជាងគេក្នុងសហគមន៍របស់នាង។

មិនយូរប៉ុន្មានក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនគ្រប់តំបន់ទាំងអស់ទូទាំងប្រទេស។ មេឃុំ បានជម្លៀសអ្នកភូមិអូរដោឲ្យទៅរស់នៅភូមិតានន ដែលឆ្ងាយពីគ្នាប្រហែល៤គីឡូម៉ែត្រ។ នាងហឿន ដែលមាននិស្ស័យខុសប្លែកពីប្រជាជនផ្សេងៗ បានឆ្លៀតសួរទៅមេឃុំថា «លោកអំឲ្យពួកយើងទៅនៅទីនោះធ្វើអី? ហើយទៅប៉ុន្មានថ្ងៃដែរ?ធ្ងល់ណាស់តាំងពីខ្ញុំកើតមកមិនដែលមានអ្នកណាឲ្យចេញអស់ពីភូមិអីចឹងសោះ!» មេឃុំឆ្លើយយ៉ាងកំបុតៗតបទៅ នាងហឿន វិញថា «មិនដឹងទេ!ទៅដល់ដឹងហើយ»។

ពេលទៅដល់ទឹកដីថ្មី ក្រុមគ្រួសាររបស់ នាងហឿន និងអ្នកភូមិផ្សេងៗទៀត បាននាំគ្នាសង់ខ្ទមតូចៗក្បែរគ្នាជាក្រុមៗស្នាក់នៅ។ ពេលកំពុងហុចស្បូវកណ្តប នាងហឿន បានសួរទៅឪពុករបស់គាត់ដោយការងឿងឆ្ងល់។

នាងហឿន៖ «ពុក! ខ្ញុំធ្ងល់ណាស់ថាគេឲ្យយើងមកទីនេះធ្វើអី?»
ប្តីតាខឹម៖ «អើ!អញធ្វើម៉េចដឹង បើអញមិនមែនជាអ្នកធំផង។ បើឯងចង់ដឹងចាំពេលមេឃុំមកចាំសួរគាត់ទៅ!»។

នាងហឿន៖ «ខ្ញុំបានសួរគាត់ម្តងហើយកាលនៅឯអូរដោ ប៉ុន្តែគាត់ថាពេលមកដល់នឹងដឹងហើយ!ដល់ឥឡូវនេះ យើងមកដល់បានពីរថ្ងៃហើយនៅតែមិនទាន់ដឹងទៀត ដឹងត្រឹមតែថាឲ្យសង់ខ្ទមសិន»។

យាយលុយដែលនៅរៀបកណ្តាបស្បូវក្បែរកូនដៃរក៏ព្រលយសម្តីថា «ណ្តើយ! មេហឿនអ្តើយ! កុំទៅខ្វល់ច្រើនពេកហាង! កិច្ចការជាតិវាជារឿងរបស់អ្នកធំឬ អ្នកមុខអ្នកការគេទេ ឯងនៅក្មេងសោះមកចង់ចេះដឹងស្តីដែរ! យីមេនេះ!»។ នាងហឿន ជដែកមិនឈ្នះម៉ែឪ ក៏ខឹងមុខឡើងក្រហម រួចនិយាយតបទៅវិញខ្លាំងៗថា «តែយើងជាប្រជាជនរបស់ប្រទេសនេះដែរតើម៉ែពុក! រឿងអីមិនត្រូវចេះដឹងនោះ។ ចុះបើគេយកយើងទៅសម្លាប់ ឬឲ្យយើងទៅរស់នៅឆ្ងាយអត់បាយអត់ទឹកតើម៉ែព្រមទៅទេ?» នាងហឿន និយាយបន្ថែមទាំងញ័រមាត់។ ចំណែកឯតាខឹម ឮកូននិយាយបែបនោះក៏តបយ៉ាងលឿនថា «មេហឿនអ្តើយ! កុំទៅខ្វល់ច្រើនពេកហាង! ពុកនិងម៉ែឯង កើតមុនឯងឃើញពន្លឺព្រះអាទិត្យមុនឯង ហើយកាលពុកនៅក្មេងសម័យសម្តេចឪមិនដែលចេះគិតរឿងជាតិដូចមេហាងឯងផង ចេះរស់សុខស្រួលរហូតមកបង្កើតក្បាលហាងបាន»។

នៅដើមខែមិថុនា ឆ្នាំ១៩៧៥ ថ្នាក់លើបានកំណត់ឲ្យអ្នកស្រុកធ្វើស្រែរួមគ្នា កាត់ផ្តាច់ស្រែដែលជាកម្មសិទ្ធិឯកជន តែនៅមានកម្មសិទ្ធិឯកជនចំពោះទ្រព្យសម្បត្តិ ផ្ទះសម្បែង និងសម្ភារប្រើប្រាស់ជាដើម។ ពេលនោះ ប្រជាជនធ្វើស្រែជាក្រុមរួមគ្នា ប៉ុន្តែនៅហូបបាយតាមផ្ទះរៀងៗខ្លួននៅឡើយ។

ថ្ងៃមួយគ្រួសារ នាងហឿន និងប្រជាជនផ្សេងទៀត កំពុងតែនាំគ្នាដកស្ទូងរួមគ្នា ស្រាប់តែឮសំឡេងច្រៀងយ៉ាងពីរោះរណ្តំល្បើយៗអមជាមួយសំឡេងហួចខិតកាន់តែជិតទៅៗថា «ស្រីតូចទ្រមែ ដើរតាមភ្លឺស្រែស្រងៃបាំងបាត់ ហាអើយ! បងខំដើរស្តាត់ សុំស្លាមួយម៉ាត់ អូនដាច់មេត្តា ពិតមែនហើយអូនដាច់មេត្តា»។

អ្នកស្រុក និងនាងហឿន ឈរងោកមកក្រោយស្រាប់តែឃើញ កងទ័ពនៅឯផ្លូវចុងម្ខាងស្រែមួយក្រុមប្លែកមុខសាច់ឈាមមិនមែនជាអ្នកភូមិតាននឬភូមិអូរដោទេ។ ក្រុមកងទ័ព មានរាងខ្ពស់ស្រឡះ សម្បុរសជ្រះសុទ្ធតែសង្ហារៗមានគ្នា៥នាក់ ប្រដាប់ដោយអាវុធគ្រប់ដៃ ព្រមទាំងមានឯកសណ្ឋានពណ៌អាចម៍សេះ និងបង់ក្រមាក។ កងទ័ពទាំងនោះមានសីលធម៌ណាស់ ដោយបានលើកដៃសំពះអ្នកស្ទូងពីចម្ងាយ ហើយនិយាយថា «ជម្រាបសួរលោកអ៊ំ!»។ តាខឹម យាយលុយ និងអ្នកស្ទូងផ្សេងទៀត កាលបើឮដូច្នេះ ក៏លើកដៃសំពះជម្រាបសួរត្រលប់ទៅវិញ។

វុទ្ធី ដែលជាបុរសសង្ហាជាងគេក្នុងចំណោមកងទ័ពទាំង៥នាក់ បានក្រឡេកឃើញ នាងហឿន រួចសួរដោយមានចិត្តចាប់អារម្មណ៍ចំពោះ នាងហឿនថា «ចុះសមមិត្តនារីមុខឡើងក្រហមយ៉ាងនេះក្តៅដៃឬទេ?»។ កាលបើបានឮសម្តីក្លែមនំយស្នេហាបែបនេះ នាងហឿន មុខកាន់តែក្រហមជាងមុន ហើយថែមទាំងក្លាហានផងនោះ ក៏ឆ្លើយតបទៅវិញថា «ធ្វើការហាលក្តៅ បើមិនឲ្យក្តៅឲ្យអីវិញចុះ?»។

ដោយសារឥទ្ធិពលមន្តស្នេហ៍របស់ នាងហឿន កងទ័ពទាំងនោះ បានដាក់អាវុធទុកក្រោមដើមសង្កែ ហើយមួរជើងខោចុះជួយស្ងួង ដោយកែវភ្នែកលួចរំពៃមើល នាងហឿន ជាប់រហូត។ លុះដល់ថ្ងៃត្រង់អ្នកស្ងួងក៏នាំគ្នាសម្រាកមកហូបបាយនៅផ្ទះរៀង។ខ្លួន រីឯកងទ័ពខ្មែរក្រហមទាំង៥នាក់នោះ ក៏លាត្រលប់ទៅកន្លែងវិញ។

ក្រោយមក វុទ្ធី ចាប់ផ្តើមមានទំនាក់ទំនងស្នេហាជាមួយ នាងហឿន។ ពន្លកស្នេហ៍រវាងអ្នកទាំងពីរ ចាប់ផ្តើមដុះលាស់ត្រួយក្នុងចិត្តរៀង។ខ្លួន។ នៅពេលនោះ ស្ថានភាពនយោបាយ មិនទាន់តឹងតែងខ្លាំងនៅឡើយទេ។ ប្រជាជនមានសិទ្ធិដើរហើរធម្មតា គ្រាន់តែប្លែកត្រង់ថាមានកងទ័ពដើរល្បាតនៅតាមភូមិស្ទើររាល់ថ្ងៃ។ រាល់ពេលល្បាត វុទ្ធី តែងចូលសួរសុខទុក្ខឪពុកម្តាយរបស់នាងហឿនមិនដែលរំលងម្តងណាឡើយ។ ឯនាងហឿន វិញ កាន់តែស្រលាញ់ វុទ្ធី ស្ទើរតែទប់ចិត្តមិនបានសារភាពស្នេហ៍ប្រាប់ទៅវុទ្ធីទៅហើយ។ ចំណែកឯ វុទ្ធី ក៏លង់ស្នេហ៍ទៅលើ នាងហឿន ខ្លាំងណាស់ដែរ។

ចូលដល់រដូវកាន់បិណ្ឌ នៅតំបន់សំឡូត លែងមានវត្តអារាមទៀតហើយ។ បញ្ហានេះមិនមែនមកពីគោលការណ៍របស់បក្សកុម្មុយនីស្តនោះទេ ប៉ុន្តែដោយសារតែគ្រាប់ផ្លោងកើតឡើងមកពីការប្រឈមមុខដាក់គ្នារវាងរបប លន់ នល់ និងខ្មែរក្រហម ចេះតែយាយីឥតឈប់ឈរ ទើបព្រះសង្ឃនាំគ្នាលាចាកសិក្ខាបទអស់។ ថ្ងៃភ្ជុំបិណ្ឌខិតជិតមកដល់ ហូ យន់ បានចុះមកផ្សព្វផ្សាយពីគោលនយោបាយបក្សកុម្មុយនីស្ត ថា តម្រូវឲ្យធ្វើយ៉ាងណាមានសាមគ្គីគ្នា លុបបំបាត់បទចម្រៀង

ពីរបបចាស់ ណែនាំឲ្យមានចម្រៀងចលនាបែបបដិវត្តន៍តាមសហគមន៍វិញ។ នាងហឿន ដែលមានសំឡេងច្រៀងពីរោះជាងគេក្នុងភូមិ ត្រូវជ្រើសរើសជាអ្នកចម្រៀង។ ពីរថ្ងៃក្រោយមក នាងហឿន ត្រូវខ្មែរក្រហមជម្លៀសចេញពីតំបន់នេះទៅឆ្ងាយពីគ្រួសារដើម្បីយកទៅរៀនវប្បធម៌នយោបាយថ្មីបំពាក់ស្មារតីបដិវត្តន៍ ហើយស្របពេលជាមួយគ្នានោះដែរ វុទ្ធី ក៏ត្រូវបានប្តូរឲ្យទៅធ្វើការកន្លែងផ្សេង។ តាំងពីពេលនោះមក នាងហឿននិង វុទ្ធី លែងបានជួបមុខគ្នាទៀត។ នាងហឿន ចាប់ផ្តើមមានក្តីទុក្ខព្រោះព្រាត់ពីវុទ្ធី ។ទោះជាទុក្ខធំប៉ុណ្ណាក៏នាងហឿនមិនហ៊ានប្រឆាំងនឹងខ្មែរក្រហមទេ។ ស្នូរជួងបន្លឺឡើងជាសញ្ញាប្រាប់ដល់អ្នកសិល្បៈថា ដល់ម៉ោងត្រូវហាត់បន្តហើយ។ នាងហឿន កំពុងតែគិតសង្ស័យចំពោះរបបខ្មែរក្រហម បានស្ទុះងើបឈរួចបបួលនាងអេង និងមិត្តភក្តិរួមក្រុមផ្សេងទៀតមានគ្នាប្រហែល២០នាក់ទៅហាត់បន្ត។

នាងហឿន ក្រោយពីធ្វើចិត្តបានពី វុទ្ធី ក៏បានជួបស្នេហ៍ថ្មីជាមួយអ្នកចម្រៀងបដិវត្តន៍ដូចគ្នាឈ្មោះឌុច មានអាយុ៣២ ឆ្នាំ។ ឌុច មានសម្រស់ដូចអ្នកស្រុកផ្សេងៗទៀតដែរ គឺមានសម្បុរខ្មៅស្រអាប់ សក់រួញ កម្ពស់សមល្មម សាច់ឈាមជាអ្នកស្រុកចម្ការ។ ពីមុន ឌុច ជាអ្នកភូមិតានន ប៉ុន្តែក្រោយពីខ្មែរក្រហមជម្លៀសអ្នកភូមិអូរដោមកនៅតានន អ្នកភូមិតាននក៏ត្រូវខ្មែរក្រហមជម្លៀសមកនៅភូមិស្រែជីពៅវិញ។ មុនជម្លៀស កំលោះចាស់នេះ ធ្លាប់បានបួសរៀនជាព្រះសង្ឃនៅវត្តស្រែជីពៅបាន៥វស្សាដែរ។

ដោយស្រលាញ់ នាងហឿន ពេក ឌុច បានដាច់ចិត្តទៅពឹង នាងអេង ដែលជាមិត្តភក្តិរបស់នាងហឿន ឲ្យធ្វើជាមេអណ្តើកឲ្យ ហើយនាងអេង ក៏យល់ព្រម។ នាងហឿន ពេលដឹងថា ឌុច មានចិត្តស្រលាញ់មកលើខ្លួន ហើយមើលឃើញពីការព្យាយាម តស៊ូ ប្រឹងប្រែងរបស់ ឌុច ផង ថែមទាំងមានការណែនាំពីនាងអេង ដែរនោះ នាងហឿន ក៏ចាប់ផ្តើមមានពន្លកស្នេហ៍ថ្មី។ ក្រោយពេលស្គាល់គ្នាមួយរយៈ ឌុច បានស្គាល់ពីសាវតារបស់ នាងហឿន យ៉ាងច្បាស់ថាអ្នកទាំងពីរមានជាប់សាច់ឈាមនឹងគ្នាដែរ។ រយៈពេលបីខែកន្លងផុតទៅ ការសិក្សា

វិជ្ជាសិល្បៈ ត្រូវបញ្ចប់។ សិល្បករបដិវត្តន៍ទាំងអស់ ត្រូវត្រលប់មកកាន់ភូមិរៀងៗខ្លួនវិញ។ ចាប់តាំងពីថ្ងៃត្រលប់មកវិញ ឌុច បានទៅលេងផ្ទះ នាងហឿន រៀងរាល់ថ្ងៃមិនដែលរំលងថ្ងៃណាឡើយ។ ឯ នាងហឿន វិញ ចាប់ផ្តើមមានចំណងចិត្តលើ ឌុច កាន់តែខ្លាំងឡើងដែរ។ ចំណែកយាយលុយ និងតាខឹម ក៏យល់ពីបំណងរបស់កូនៗ ហើយមិនប្រកាន់ខឹងអ្វីឡើយ។

នៅខែដើមខែមករា ឆ្នាំ១៩៧៦ តំបន់សំឡូត មានសភាពជាធម្មតា ដោយមិនទាន់មានការរឹតត្បិតឬលុបបំបាត់ជំនឿទំនៀមទម្លាប់ប្រពៃណីនៅឡើយទេ។ ជួនជាចៃដន្យ អំឡុងពេលដែល ឌុច ទៅលេងនៅផ្ទះរបស់ នាងហឿន កាន់តែញឹកញាប់ នាងហួយ ដែលជាប្អូនរបស់ នាងហឿន ធ្លាក់ខ្លួនឈឺធឹកថ្នាំអ្វីក៏មិនបាត់ដែរ។ តាខឹមនិងប្រពន្ធ បារម្មណ៍ណាស់ក៏បាននាំគ្នាទៅបូលរកគ្រូមើលតាមជំនឿពីបុរាណ ហើយរកឃើញ ដូនតា ប្រកាន់ ឌុច និង នាងហឿន។ ក្រោយមកចាស់ទុំ បានឲ្យ ឌុច និងនាងហឿន រៀបការជាមួយគ្នានោពាក់កណ្តាលខែមករា ឆ្នាំ១៩៧៦ ដោយមានការចូលរួមយ៉ាងច្រើនកុះករពីបងប្អូនទាំងសងខាង ភ្ញៀវកិត្តិយស និងកងយោធាបដិវត្តន៍ជាច្រើនក្រុម។ បន្ទាប់ពី ឌុច និងនាងហឿន រៀបការរួច ប្អូនស្រីពៅរបស់នាងហឿន ក៏ជាសះស្បើយព្រមគ្នាដែរ។

ទោះបីជាមិនទាន់មានការអនុវត្តគោលការណ៍ខ្មែរក្រហមក្តី ពួកខ្មែរក្រហមមិនឲ្យតំបន់សំឡូតនៅក្រៅគោលការណ៍របស់ខ្លួនឡើយ។ ភាពធូររលុងនេះមិនមែនមកពីមូលហេតុដែលខ្មែរក្រហមគ្រប់គ្រងតំបន់សំឡូតមុនគេប៉ុណ្ណោះទេ តែវាជាការអន្តរាគមន៍ពីថ្នាក់លើមួយចំនួន ដូចជា ហ៊ូ យន់ និងហ៊ូ នឹម ជាដើម។ ក្រោយមក ស្ថានការណ៍ចាប់ផ្តើមតឹងរឹងខ្លាំងចាប់តាំងពីពេល ហ៊ូ យន់ និងហ៊ូ នឹម បាត់មុខ។

នៅដើមខែកុម្ភៈ ឆ្នាំ១៩៧៦ ប្រជាជនភូមិតានន ត្រូវអង្គការជម្លៀសបំបែកគ្នា ព្រោះអង្គការបានស៊ើបដឹងថាអ្នកភូមិនេះសុទ្ធតែជាបងប្អូនជាប់ខ្សែឈាមនឹងគ្នា។ គោលដៅនៃការបំបែករបស់អង្គការនេះ គឺដើម្បីងាយស្រួលកាត់ផ្តាច់មនោសញ្ចេតនា។ នាងហឿន ត្រូវជម្លៀសឲ្យទៅនៅចម្ការដើលួស ឆ្ងាយពីឪពុក

ម្តាយរបស់នាងប្រហែល ១០គីឡូម៉ែត្រ។ រំលងបានពីរបីថ្ងៃ នាងហឿន បានជួប វុទ្ធី ដោយចៃដន្យ ស្របពេលដែល ឌុច ចេញទៅកេឌុស។ ស្នេហារវាង នាងហឿន និង វុទ្ធី បានក្លាយទៅជាអតីតកាលទៅហើយ ដូច្នេះ នាងហឿន បានសុំ វុទ្ធី ធ្វើជាបងធម៌។ មុនពេលត្រលប់ទៅវិញ វុទ្ធី បានផ្តែផ្តាំ នាងហឿនទាំងទឹកមុខ ស្រពោនថា «ប្អូនស្រី! ត្រូវស្រលាញ់គ្នាដល់ចាស់កោងខ្នងណា! ទោះបីមានរឿង អ្វីក៏ដោយប្អូនត្រូវចេះអត់ឱនឲ្យគ្នា»។ នាងហឿន តបទៅ វុទ្ធី ទាំងអួលដើមកថា «ចាសបង! »។

វុទ្ធី ផ្តែផ្តាំបន្ថែមទៀតថា « ស្រុកទេសយើងប្រែប្រួលកាន់តែយ៉ាប់ ហើយ យើងនឹងជួបទុក្ខលំបាកវេទនាជាងស្លាប់ទៅទៀត» និយាយចប់ វុទ្ធីក៏ដើរចេញ ទៅ។ ពេលប្តីមកដល់ នាងហឿន ក៏ប្រាប់ពីដំណើររឿងស្រុកទេសដែល វុទ្ធី បាននិយាយប្រាប់នាង។

នៅចុងខែកុម្ភៈ ឆ្នាំ១៩៧៦ អង្គការបានជម្លៀសប្រជាជនស្ទើរតែមួយឃុំ សំឡូតឲ្យទៅនៅជំនាប់សាប ដែលនៅឆ្ងាយពីនោះប្រហែល២០គីឡូម៉ែត្រ។ អង្គការបានរៀបចំប្រជាជនជាជួរជាប់ៗគ្នា និងបែងចែកបុរសស្ត្រីដែលនៅលីវឲ្យ នៅផ្សេងពីគ្នា ប៉ុន្តែអ្នកមានគ្រួសារ រស់នៅជាគ្រួសារដដែល។ ពេលនោះ អង្គការ លែងគិតថានរណាជាប្រជាជនមកពីទីក្រុង ឬជនបទទៀតហើយ។ អង្គការ បាន ចាប់ផ្តើមឲ្យប្រជាជនរស់នៅជាសហករណ៍ ប៉ុន្តែមិនទាន់ឲ្យស្លៀកសម្លៀកបំពាក់ ខ្មៅនៅឡើយទេ។ ចំណែកឯកម្មសិទ្ធិវិញ ក៏មិនទាន់កាត់ផ្តាច់ទាំងស្រុងដែរ។

នៅខែមេសា ឆ្នាំ១៩៧៦ រដូវចូលឆ្នាំបានឈានចូលមកដល់ អង្គការបាន ប្រារព្ធធ្វើពិធីចូលឆ្នាំ ដោយបានប្រកាសឲ្យប្រជាជនថាជាថ្ងៃចូលឆ្នាំប្រពៃណីជាតិ។ ក្នុងថ្ងៃចូលឆ្នាំ អង្គការបានបើកអង្គមេទិញ ធំមួយដើម្បីផ្សព្វផ្សាយនយោបាយ មហាលោតផ្លោះ រួមមាន របៀបរស់នៅ ការហូបចុក ការស្លៀកពាក់ និងការ កាត់ផ្តាច់កម្មសិទ្ធិឯកជនទាំងអស់។ តាំងពីពេលនោះមក ប្រជាជនបាត់បង់សិទ្ធិ សេរីភាពទាំងស្រុង។ ស្រីៗតម្រូវឲ្យកាត់សក់ខ្លីត្រឹមស្មា និងរៀបចំរចនាសម្ព័ន្ធក្រុម សហករណ៍ ដូចជា មេក្រុម មេកង និងមេពួកជាដើម។ អង្គការប្រារព្ធពិធីបុណ្យ

ចូលឆ្នាំមួយព្រឹកពេញ លុះដល់ពេលរសៀល អង្គការបានឲ្យប្រជាជនចាប់ផ្តើមទៅធ្វើការរៀងៗខ្លួនតាមមុខសញ្ញាដែលបានកំណត់។ ចាប់តាំងពីពេលនោះមក ការហូបចុក ប្តូរមកហូបរួមគ្នាទាំងអស់ និងទទួលបានរបបអាហារតែ២ដង ប៉ុណ្ណោះក្នុងមួយថ្ងៃ។ អង្គការ មានរៀបចំរោងបាយនិងចុងភៅ ប៉ុន្តែអាហារដែលធ្វើឲ្យប្រជាជនហូប មិនបានគ្រប់គ្រាន់ទេ។ សំណាងល្អ តំបន់ដែលខ្ញុំរស់នៅគឺជាតំបន់ព្រៃភ្នំ មានដំណាំបន្លែធម្មជាតិជាច្រើនអាចឲ្យប្រជាជនហូបចម្អែតក្រពះបាន។ ការលំបាកទាំងអស់នេះបានធ្វើឲ្យ ប្រជាជន ចាប់ផ្តើមស្រេកសាច់ស្គមស្គាំង និងធ្លាក់ខ្លួនឈឺ។

ស្បែអន្ធការ បានគ្រប់ដណ្តប់លើប្រជាជនឃុំសំឡូតគ្រប់គ្នា។ សម្លៀកបំពាក់ត្រូវផ្លាស់ប្តូរមកជាពណ៌ខ្មៅឬអាចម៍សេះគ្រប់ៗគ្នា។ យើងត្រូវធ្វើការងារចាប់ពីម៉ោង ៦ កន្លះព្រឹក ដល់១១ព្រឹក និងពេលរសៀលចាប់ពីម៉ោង១ដល់៥ល្ងាច។ ចំណែកវេនយប់ យើងត្រូវផ្លាស់វេនគ្នា ហើយពេលធ្វើការ យើងមិនអាចជជែកគ្នាលេងបានទេ ប៉ុន្តែយើងអាចច្រៀងលេងកំដរបរិយាកាសឲ្យដំណើរការងារសប្បាយរីករាយបាន តែត្រូវច្រៀងចម្រៀងដែលទាក់ទងនឹងបដិវត្តន៍លើកស្ទួយដល់របបខ្មែរក្រហម។ ចំណែកស្ត្រីសម្រាលកូន អង្គការអនុញ្ញាតឲ្យឈប់សម្រាកកន្លះខែ ក្រោយមកឲ្យទៅមើលកូនក្មេង បំបៅដោះក្មេងចំនួន២ខែកន្លះ។ លុះគ្រប់៣ខែ ទើបអង្គការអនុញ្ញាតឲ្យទៅធ្វើការធម្មតា។ យប់ឡើង ប្តីប្រពន្ធ អាចនៅជាមួយគ្នាបាន ប៉ុន្តែយើងមិនអាចជជែកគ្នាបានទេ ព្រោះកងឈ្លបឃ្លាំចាំស្តាប់យើងគ្រប់ពេលវេលា។

លុះដល់ខែមេសា ឆ្នាំ១៩៧៨ ចំថ្ងៃចូលឆ្នាំ អង្គការបានរៀបចំកម្មវិធីចម្លែកដែលមិនធ្លាប់មានពីមុនមកទេ។ ថ្ងៃនោះ អង្គការបានធ្វើនំបញ្ចុកឲ្យប្រជាជនហូបមួយឆ្អែត។ ហឿន និងប្តី បានដឹងពីផែនការចង់បោកគ្រាប់បែកសម្លាប់មនុស្សនៅពេលហូបនំបញ្ចុក ក៏ខ្សឹបគ្នាជាមួយប្រជាជនផ្សេងដែលទុកចិត្តថា បើអង្គការប្រុងដកគន្លឹះគ្រាប់បែក យើងត្រូវប្រួតគ្នាហក់ទៅសំពងទាំងអស់គ្នាដើម្បីតទល់។ ប៉ុន្តែមិនដឹងជា ហេតុអ្វីបានជាអង្គការរំសាយគម្រោងបោកគ្រាប់បែកនេះទៅវិញ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមនិងកងទ័ពរដ្ឋាភិបានបានចូលមករំដោះប្រជាជន ប៉ុន្តែនៅសហការណ៍ជំនាប់សាប មិនទាន់បានរំដោះទេ។ កងទ័ពខ្មែរក្រហមនៅគ្រប់គ្រងជាធម្មតា ទោះបីជាតំបន់ផ្សេងរំដោះបានក៏ដោយ។

រហូតដល់ព្រឹកម៉ោងប្រហែល ៩ ចុងខែមេសា ឆ្នាំ១៩៧៩ ឳុច ចាប់ផ្តើមធូរល់ព្រោះគ្មានឃើញមេកងបញ្ជាឲ្យធ្វើការដូចរាល់ដង។ ចំណែកក្រឡេកមើលទៅក្រោលគោ ឳុច បានឃើញគោបែកហ្វូង ហើយបាត់មេក្រុម មេកង មេពួកអស់ នៅសល់តែកម្មាភិបាលខ្មែរក្រហមតូចៗថ្នាក់ទាប។ លុះឃើញសភាពការណ៍អំណោយផលដូច្នេះ ប្រជាជនទាំងអស់បានសម្រេចនាំគ្នារត់ទៅចូលក្នុងព្រៃ។ ប្រជាជនខ្លះចាប់បានគោ ខ្លះចាប់បានមាន់ និងខ្លះបានអង្ករ យកទៅជាប់ខ្លួនជាមួយ។ ឳុច និងនាងហឿន យកបានអង្ករមួយការ៉ុង ចាប់បានគោមួយនឹម រួចទាញរទេះនាំគ្រួសារចូលព្រៃជាមួយបងប្អូននៅក្បែរអូរដោ។ មួយសប្តាហ៍ក្រោយមក ស្នូរកាំភ្លើងបានខិតកាន់តែជិតទៅៗ។ ឳុច និងនាងហឿន កាន់តែមានអារម្មណ៍ភ័យផងអរផង ដ្បិតមិនដឹងថាជាសំឡេងកាំភ្លើងរបស់ក្រុមរំដោះឬក្រុមខ្មែរក្រហម។

នៅម៉ោង១០ព្រឹក កងទ័ពរំដោះ បានចូលមកដល់។ ប្រជាជនស្រុកអូរដោបាននាំគ្នាត្រលប់មកស្រុកកំណើតរបស់ខ្លួនវិញ។ ឳុចនិងនាងហឿន បានកាន់ដៃគ្នាហែលឆ្លងផុតពីស្បែងងឹតនេះ។

ចប់

៤២

រឿង ជីវិតប្រចាំថ្ងៃ ក្នុងរបប ប៉ុល ពត

អ្នកនិពន្ធ ៖ ប៉ុក សុខអ៊ាវី

៤២ ~ រឿង ជីវិតប្រចាំថ្ងៃ ក្នុងរបប ប៉ុល ពត

ក្រុមគ្រួសាររបស់ខ្ញុំ មានសមាជិកចំនួន ៩នាក់។ យើងរស់នៅជួបជុំគ្នានៅក្នុងខ្ទមតូចមួយ គ្មានជញ្ជាំង មានត្រឹមតែដំបូលប្រក់ស្បូវ។ យើងយកក្រណាត់បាំងធ្វើជាជញ្ជាំងគ្រាន់ការពារខ្យល់នៅពេលយប់។ នៅក្នុងរបបខ្មែរក្រហមខ្ញុំបានបែកបាក់សាច់ញាតិចំនួន ៤នាក់។ នៅក្នុងឆ្នាំ១៩៧៧ ឪពុករបស់ខ្ញុំឈឺធ្ងន់ពុំមានថ្នាំព្យាបាលរហូតដល់ស្លាប់ ហើយយើងបានបូជាសពរបស់គាត់នៅក្បែរផ្ទះ។ បងប្រុសច្បងរបស់ខ្ញុំ ត្រូវអង្គការស្នើយកទៅបាត់ទាំងពាក់កណ្តាលអធ្រាត្របន្ទាប់ពីគាត់ត្រលប់មកពីសួរសុខទុក្ខម៉ែរបស់ខ្ញុំដែលធ្លាក់ខ្លួនឈឺហើមដៃហើមជើងនិងរាករូស។ ថ្ងៃនោះ បងប្រុសរបស់ខ្ញុំមកដល់ផ្ទះប្រហែលជាម៉ោង ៨ យប់។ គាត់បានប្រាប់ម៉ែរបស់ខ្ញុំថា «ម៉ែខ្ញុំឃ្លានដល់ហើយ ម៉ែមានអីហូបទេ?» ម៉ែឆ្លើយតបវិញថា «កូនអើយ មិនមានអីហូបទេ ម៉ែគេឲ្យតែបបរបន្តិចបន្តួចប៉ុណ្ណោះ» បងប្រុសរបស់ខ្ញុំក៏តបទៅម៉ែវិញថា «ខ្ញុំសុំដកដំឡូងនៅក្បែរផ្ទះបានទេ?ខ្ញុំចង់ស្ងោរឲ្យបានមួយកូនឆ្នាំងយកទៅហូបនៅកងម៉ែ» ម៉ែខ្ញុំក៏បាននិយាយថា «កូនប្រយ័ត្នប្រយែងណា៎ ព្រោះគេហាមមិនឲ្យមានភ្លើងក្នុងផ្ទះពេលយប់ទេ អង្គការទើបតែប្រជុំថ្មីៗ»។

បងប្រុសរបស់ខ្ញុំ ក៏ស្ទុះចេញទៅក្រៅផ្ទះមួយភ្លែត រួចពេលត្រលប់មកវិញមានកាន់ដំឡូងឈើ ២កូនមើមវែងៗ ហើយចាប់ផ្តើមដីករណ្តៅតូចស្មើនឹង

ឆ្នាំងនៅចំកណ្តាលផ្ទះ រួចបង្កាត់ភ្លើងដាក់ដំឡូងស្ងោរក្នុងកំសៀវទឹក។ មិនយូរប៉ុន្មាន ស្រាប់តែមានកងឈ្លប ២នាក់ស្លៀកពាក់ពណ៌ខ្មៅស្គាយកាំភ្លើង ២ដើម មកដល់ហើយសួរថា «មិត្តឯងធ្វើអ្វី?» បងរបស់ខ្ញុំឆ្លើយតបទៅវិញភ្លាមៗថា «បាទមិត្តបង ខ្ញុំដាំទឹកផឹក!»។ ឈ្លបនោះនិយាយបន្តទៀតថា «មិត្តឯងបើកគម្រប់កំសៀវមើលទឹកឬដំឡូង?»។ ខ្ញុំឮហើយភ័យណាស់សម្ងំក្នុងភួយគ្របក្បាលជិត ប៉ុន្តែខ្ញុំក៏បើកបង្ហើបជើងភួយតិចៗ ដើម្បីលបមើលហេតុការណ៍ដែលកំពុងតែកើតឡើងចំពោះបងប្រុសរបស់ខ្ញុំម្តងម្កាលដែរ។កងឈ្លបនោះនិយាយបន្ថែមទៀតថា «មកទៅជាមួយយើង» និយាយចប់ហើយក៏បណ្តើរបងប្រុសរបស់ខ្ញុំចេញទៅដោយមានតែក្រមាមួយស្លៀកជាប់នៅនឹងខ្លួនតែប៉ុណ្ណោះ។ បងប្រុសរបស់ខ្ញុំបានចាកចេញទៅទាំងមិនបានលាម៉ែពុកបងប្អូននិងប្រពន្ធកូន ជាទីស្រលាញ់ទាល់តែសោះ។ ចាប់តាំងពីពេលនោះ បងប្រុសរបស់ខ្ញុំ បានបាត់ដំណឹងសូន្យឈឹងរហូតមកដល់សព្វថ្ងៃនេះ។

ក្រោយៗមក អ្នកស្រុកចាប់ផ្តើមបាត់ខ្លួនក្នុងគ្រួសារម្តងមួយៗ ភាគច្រើននៅសល់តែមនុស្សស្រី និងក្មេងតូចៗ។ អីវ៉ាន់ដែលមានតម្លៃក្បាទុកក្នុងផ្ទះ ត្រូវកងឈ្លបលីចោលពាសពេញដី។ បងប្រុសទីពីររបស់ខ្ញុំ ទ្រាំនឹងការឈឺចាប់ផ្លូវចិត្តមិនបាន ក៏សុំម៉ែរត់ចេញពីកងទាំងយប់ ហើយក៏បាត់ដំណឹងសូន្យរហូតសព្វថ្ងៃនេះដែរ។ ក្មួយរបស់ខ្ញុំអាយុទើបតែបាន៦ខែ ក៏បាក់ទឹកដោះស្លាប់ទៀត។ គ្រួសាររបស់ខ្ញុំនៅសល់សមាជិកតែ ៥នាក់នោះទេមកដល់ចុងឆ្នាំ១៩៧៧។

បងប្អូនរបស់ខ្ញុំត្រូវបែកបាក់គ្នាទាំងអស់។ ខ្ញុំត្រូវអង្គការឲ្យចុះធ្វើស្រែក្រោម។ ប្អូនស្រីរបស់ខ្ញុំ ត្រូវអង្គការឲ្យទៅរែកដីលាមកនៅកងផ្សេង។ ប្អូនប្រុសរបស់ខ្ញុំ អង្គការឲ្យទៅនៅជាមួយកងកុមារឆ្ងាយពីម្តាយរបស់ខ្ញុំទៀត។ ចំណែកបងថ្លៃស្រីរបស់ខ្ញុំ ត្រូវនៅមើលម្តាយរបស់ខ្ញុំដែលកំពុងតែដេកឈឺហើមដៃហើមជើងនិងរាករូស។ ខ្ញុំត្រូវចុះទៅធ្វើស្រែក្រោមនៅឆ្ងាយដល់ឆ្នេរសមុទ្រមិនបានត្រលប់មកវិញទេ។ ថ្ងៃមួយនៅពេលខ្ញុំកំពុងតែស្ងួងស្រូវ ស្រាប់តែបានជួបនឹងកុមារម្នាក់ដែលធ្លាប់ស្គាល់ខ្ញុំ ហើយកុមារនោះបានប្រាប់ខ្ញុំថា «បងស្រី! ម៉ែរបស់បង

ឯងឈឺធ្ងន់ណាស់ បងមិនគិតឡើងទៅមើលគាត់ខ្លះទេឬ?»។ ឮហើយ ខ្ញុំក៏ឯក់ក្បាល។ ពេលល្ងាចជិតយប់ក្រោយពីស្ងួងរួច ខ្ញុំក៏ជាប់ចិត្ត សុំមេកងទៅមើលម៉ែឈឺមួយភ្លែត។ មេកងនោះឆ្លើយថា «មិត្តនារីឯងពេទ្យឬ? បើសិនជាមិត្តនារីឯងជាពេទ្យទៅមើលចុះ»។ ពាក្យនេះមានន័យថា មេកងមិនឲ្យខ្ញុំទៅមើលម្តាយរបស់ខ្ញុំទេ ហើយបើទៅពិតជាមានទោសជាមិនខាន។ ខ្ញុំស្ងាក់ស្ងើរក្នុងចិត្តណាស់។ យប់បន្តិចខ្ញុំក៏លួចរត់ចេញពីកង ដើម្បីទៅមើលម៉ែឈឺនៅឯផ្ទះ។ មកដល់ផ្ទះ ខ្ញុមងងឹតឈឹងរកតែភ្លើងដុតបំភ្លឺមើលមុខម៉ែបន្តិចមិនបាន។ ខ្ញុំបានសួរសុខទុក្ខគាត់តិចៗ ព្រោះខ្លាចឈ្លបឮ។ ខ្ញុំដេកឱបម៉ែរបស់ខ្ញុំបានមួយយប់កក់ក្តៅណាស់។ ពេលត្រលប់មកវិញ ម្តាយរបស់ខ្ញុំបានផ្តាំថា «កូនអើយ! បើម៉ែស្លាប់ទៅ កូនត្រូវចេះស្រលាញ់បងប្អូន ចេះជួយគ្នាទៅវិញទៅមកណាកូន ម៉ែមិនអីទេណាកូន»។ ម្តាយរបស់ខ្ញុំផ្តាំខ្ញុំរួចហើយ គាត់ក៏ហុចកញ្ចប់មាសឲ្យខ្ញុំមួយថង់ជាក់ជាប់ទុកនឹងខ្លួន ដើម្បីថែរក្សាទុកសម្រាប់ថ្ងៃក្រោយស្រុកសាន្តត្រាណយកមកប្រើប្រាស់។ ម៉ែផ្តាំហើយ ខ្ញុំយំឱបម៉ែរួចម៉ែតឿនខ្ញុំថា «ប្រញាប់ទៅកូនឲ្យទាន់គេចុះស្ងួង ព្រោះកូនលួចរត់មកប្រយ័ត្នមេកងចាប់កូនយកទៅទៀតណាកូន កុំគិតពីម៉ែអី ថ្ងៃណាថ្ងៃនឹងទៅចុះកូន»។ ខ្ញុំសំពះលាម៉ែចុងក្រោយទាំងទឹកភ្នែកអួលណែនបំពង់ក ហើយរត់ចេញពីផ្ទះយ៉ាងលឿនខ្លាចទៅមិនទាន់ចុះស្ងួង។

មេឃមិនទាន់ភ្លឺច្បាស់នៅឡើយទេ តែខ្ញុំរត់ផងដើរផងខ្លាចមិនទាន់ពេលទៅស្ងួង។ សំណាងអាក្រក់ ខ្ញុំបានជួបកងទ័ពប្រហែល ១០នាក់ ដើរឈ្លបតាមផ្លូវជាតិលេខ៤។ កងទ័ពបានស្រែកសួរខ្ញុំពីផ្លូវម្ខាងទៀតថា «មិត្តនារីទៅណាទាំងព្រឹកមានសុំច្បាប់គេឬអត់?»។ និយាយរួចកងទ័ពទាំងអស់នោះ បានដើរហួសទៅ។ ខ្ញុំដើរយ៉ាងលឿនទៅមុខ ហើយបានជួបនឹងកងទ័ព ៣នាក់ទៀតកំពុងជិះកង់។ ពួកគេឈប់កង់ ហើយស្រែកសួរខ្ញុំទៀតថា «មិត្តនារីឯងលួចរត់ពីកងមែនទេ? មកទៅជាមួយយើង»។ វាបក់ដៃហៅខ្ញុំ ពីថ្នល់ម្ខាងទៀត។ ខ្ញុំដើរចូលមករកកងទ័ពទាំងនោះ ហើយពួកគេបានបណ្តើរខ្ញុំយកមកដាក់គុកនៅព្រៃនប់។ ខ្ញុំភ័យណាស់ នឹកថាជីវិតខ្ញុំពិតជាស្លាប់មុនម៉ែហើយ។ ខ្ញុំសូត្រធម៌នៅក្នុងខ្លួន

បន់ស្រន់ដូនតាសូមឲ្យលោកជួយឲ្យកងទ័ពទាំងនោះដោះលែងខ្ញុំឲ្យបានជួបម៉ែរបស់ខ្ញុំវិញ។ ខ្ញុំយកខ្សែដៃនិងខ្សែក ដែលម៉ែឲ្យ មូរលាក់ក្នុងជើងខោ ហើយខ្ញុំមូរជើងខោឡើងត្រឹមភ្លៅ។ ពួកឈ្លបនាំខ្ញុំទៅផ្ទះឈើមួយកន្លែងលើភ្នំបត់សិរមាន់ ហើយរុញទ្វារឈើឲ្យខ្ញុំចូលទៅក្នុងរួចប្រាប់ថា «មិត្តនារីឯងកុំរត់ ប្រយ័ត្នណា!»។ និយាយរួច កងឈ្លបក៏ទាញទ្វារបិទឮសូរគ្រាំង។ ខ្ញុំបានឃើញប្រជាជនដែលត្រូវពួកកងទ័ពឈ្លបចាប់មកទុកក្នុងផ្ទះឈើនោះ មានទាំង ស្រី ប្រុសនិងចាស់ ហើយត្រូវដាក់ខ្នោះជើងទាំងពីរជាប់ៗគ្នា ចំណែក ដៃទាំងពីរត្រូវចងច្រវាក់ក្រពាត់ទៅក្រោយ។ ខ្ញុំមានវាសនាជាងប្រជាជនផ្សេងទៀតដោយសារខ្ញុំអត់មានជាប់ខ្នោះជើងដៃទេ។ ខ្ញុំនៅឈរមើលប្រជាជនក្នុងគុកបានប្រហែលជា ២ម៉ោង ស្រាប់តែមានសំឡេងមនុស្សដើរចូលមក បើកទ្វារ។ ខ្ញុំកើតគំនិតមួយ គឺសុំកងឈ្លបទៅបត់ជើងនៅខាងក្រៅ។ កងឈ្លប បានអនុញ្ញាតឲ្យខ្ញុំចេញមកក្រៅ។ ខ្ញុំបានចេញក្រៅរកកន្លែងបត់ជើង មិនដឹងដើរទៅបត់កន្លែងណាក៏ឆ្លៀងដើរទៅមុខទៅក្រោយម្តងងើប ម្តងអង្គុយ ស្រាប់តែឃើញមេកងឈ្លបក្នុងភូមិដីៈកង់ចូលចំកន្លែងឃុំមនុស្ស។ ខ្ញុំឃើញដូច្នោះ ក៏រត់ចេញទៅជួបគាត់មុន។ ខ្ញុំនិយាយថា «លោកពូមេកងជួយខ្ញុំផង ខ្ញុំមករកសុំថ្នាំពេទ្យយកទៅផ្ញើម៉ែឈឺនៅឯកង ឥឡូវគេហៅខ្ញុំមកទីនេះធ្វើអ្វី?»។ ឮខ្ញុំនិយាយដូច្នោះ មេកងថា «មិត្តនារីឯងទៅវិញចុះ»។ ខ្ញុំអរអើយសែនអរ ក៏ឆាប់រត់ចេញពីទីនោះយ៉ាងលឿនសំដៅទៅកន្លែងស្នង។ ទៅដល់ភ្លាម ខ្ញុំចុះស្នងភ្លាម។ ខ្ញុំមានសំណាងល្អណាស់ថ្ងៃនេះ ព្រោះអត់មានមេកងនៅស្នងជាមួយខ្ញុំទេ។ ខ្ញុំរួចខ្លួនបានមួយគ្រាដោយពុំមានអ្នកដឹងថាខ្ញុំលួចរត់ទៅជួបម៉ែទេ។ ប្រហែលជាមួយអាទិត្យក្រោយមក ខ្ញុំបានទទួលដំណឹងអាក្រក់ពីក្មេងឃ្វាលគោប្រាប់ខ្ញុំថា «បងស្រី! ម៉ែបងឯងស្លាប់ហើយ គេយកទៅកប់ក្បែរផ្ទះ»។ ឮហើយ ខ្ញុំស្ទើរតែគាំងបេះដូងមួយរំពេច។ ឪពុកម្តាយរបស់ខ្ញុំស្លាប់ទាំង ២នាក់។ បងប្រុសបង្កើតចំនួន ២នាក់ទៀតត្រូវបាត់ខ្លួន។ ប្អូនប្រុសរបស់ខ្ញុំ រស់នៅឆ្ងាយមិនដែលបានជួបមុខគ្នាទៀត។

ថ្ងៃបន្ទាប់មក ភ្លៀងធ្លាក់ខ្លាំងណាស់ទាំងថ្ងៃទាំងយប់មិនរាំងសោះ។ ខ្ញុំនៅធ្វើស្រែក្រោមក្បែរសមុទ្រ។ ខ្ញុំដេកក្នុងរោងជាមួយនឹងប្រជាជនធ្វើស្រែដូចគ្នា។ ខ្ញុំស្រាប់តែទទួលអារម្មណ៍ថាមានទឹកប្រឡាក់ចុងជើងរបស់ខ្ញុំត្រជាក់ៗ។ ខ្ញុំភ្ញាក់ឡើងឮសូរសន្ធឹកទឹកហូរគួរឲ្យខ្លាចណាស់។ ខ្ញុំស្ទុះក្រោកភ្លាមប្រមូលយកអីវ៉ាន់មករៀបចំចងទុកមួយស្បោង។ ទឹកឡើងលិចកន្លែងខ្ញុំដេកទទឹកជោកខ្នង។ ពេលនោះ គ្មាននរណាម្នាក់ភ្ញាក់ទេ មានតែខ្ញុំក្រោកម្នាក់ឯង។ ខ្ញុំឮសូរមេកង ៣នាក់ ស្ទុះក្រោកឡើងស្ងៀកពាក់រឹបៗ រួចបបួលគ្នាថា «តោះមិត្ត»។ ភ្លាមនោះ មេកងស្ទុះទៅស្រាយខ្សែទូក ហើយទាញច្រវាក់រៀបអុំទូកចេញ។ ខ្ញុំឃើញហើយមិនចាំសួរឬសុំការអនុញ្ញាតទេ រួចខ្ញុំក៏លោតឡើងលើទូកជាមួយមេកងភ្លាម ហើយយើងធ្វើដំណើរឡើងមកផ្លូវជាតិលេខបួនមកទំនប់ព្រែនប៉វិញ។ យើងអុំទូកឡើងមកបញ្ចាស់ទឹក។ ខ្ញុំមើលទៅឃើញទឹកសស្គុស ហូរគ្មានឮសូរសំឡេងឡើយ។ ខ្ញុំភ័យជាងគេ អារម្មណ៍របស់ខ្ញុំពេលនោះគិតដល់អ្នកដែលកំពុងដេកលង់លក់ក្នុងដំណេកត្រូវស្លាប់ឬរស់យ៉ាងណាទេ។ ទឹកហូរខ្លាំងណាស់ ព្រោះបាក់ទំនប់មួយ។ លុះថ្ងៃស្អែកឡើង គ្មានព័ត៌មានថាមានមនុស្សស្លាប់ប៉ុន្មានឬនៅសល់ប៉ុន្មានទេពីការបាក់ទំនប់នោះ។ ខ្ញុំ ក៏មិនបានឃើញប្រជាជនត្រលប់ចូលមកភូមិវិញដែរ។

ចប់

៤៣
រឿង ជីវិតពិត កុមារ សុខ ខេង

អ្នកនិពន្ធ ៖ ឆ្ង សុីសារិទ្ធ

៤៣ ~ រឿង ជីវិតពិតកុមារ សុខ ខេង

សុខ ខេង កើតនៅឆ្នាំ១៩៦៥ នៅភូមិសោបក្រោម ឃុំសោប ស្រុកព្រៃក ប្រសព្វ ខេត្តក្រចេះ ក្នុងត្រកូលគ្រួសារកសិករ។ នៅពេលមានអាយុប្រហែល ៧ឆ្នាំ សុខ ខេង បានចូលរៀននៅសាលាវត្តសោបក្រោម ឃុំសោប ស្រុកព្រៃកប្រសព្វ ដែលមានព្រះសង្ឃជាគ្រូបង្រៀន។ សុខ ខេង មានបងប្រុសច្បងម្នាក់ឈ្មោះ សុខ ខេម មានអាយុលើស សុខ ខេង តែ៥ឆ្នាំប៉ុណ្ណោះ។ សុខ ខេង និងបងប្រុស តែងតែដើរ ទៅរៀននៅសាលាវត្តជាមួយគ្នា។ នៅពេលស្រុកទេសប្រែប្រួល សុខ ខេង និង បងប្រុស ត្រូវឪពុកម្តាយយកមកឲ្យរស់នៅជាមួយជីដូនជីតា ខាងម្តាយ ព្រោះ ពួកគាត់ត្រូវចេញទៅធ្វើស្រែនៅឯស្រុកឆ្ងាយ។ ក្រៅពីការសិក្សា សុខ ខេង ត្រូវចេញទៅឃ្វាលគោជាមួយកុមារដទៃនៅក្នុងភូមិ។

នៅក្នុងអំឡុងឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមឡើងកាន់អំណាច សុខ ខេង មានអាយុទើបតែ១១ឆ្នាំប៉ុណ្ណោះ។ ពេលនោះ សុខ ខេង ត្រូវនៅបែកពីឪពុកម្តាយ ដោយសារតែអង្គការតម្រូវឲ្យឪពុកម្តាយរបស់គាត់ចូលបម្រើការងារទៅទីកន្លែង ផ្សេងៗតាមការចាត់តាំងរបស់អង្គការ។

ជីវិតកុមារក្នុងសម័យ ប៉ុល ពត

សុខ ខេង ត្រូវអង្គការតម្រូវឲ្យរស់នៅក្នុងក្រុមកុមារ។ សុខ ខេង បានរៀនសូត្រខ្លះដែរ តែការរៀនសូត្រនោះ មានតែ ១ពេល ជួនពេលព្រឹក ជួន

ពេលល្ងាច។ ក្រៅពីទៅរៀន អង្គការ បានឲ្យសុខ ខេង និងកុមារផ្សេងទៀត ទៅកាប់ដើមទន្ទ្រានខែត្រយកមកចិញ្ច្រាំធ្វើដី ឬពេលខ្លះត្រូវទៅប្រមូលអាចម៍គោក្របី មកដាក់ក្នុងរណ្តៅដី។ នៅពេលនោះ ស្រុកព្រៃកប្រសព្វ ស្ថិតនៅក្រោមការគ្រប់គ្រងដោយគណៈតំបន់ឈ្មោះ កែ ពក។ នៅប៉ែកខាងលិចទន្លេ ប្រជាជនរស់នៅតាមភូមិឃុំហូបតែបបរទេ មានខែខ្លះធ្លាក់ខ្លួនហូប បបរលាយពោតឬលាយត្រកួនផងក៏មានដែរ។

នៅក្នុងអំឡុងឆ្នាំ១៩៧៧ សុខ ខេង និងកុមារមួយចំនួនទៀត ត្រូវអង្គការចាត់តាំងឲ្យទៅចាំចាបស្រូវប្រាំង។ ដោយភាពស្រេកឃ្លាន ក្រុមកុមារចាំចាបទាំងអស់ បានធ្វើអន្ទាក់ដាក់តាមមាត់ត្រពាំងចាប់បានសត្វស្លាបជារឿយៗ ដូចជាកុក មាន់ទឹក ទាព្រៃ និងមាន់ព្រៃ ជាដើម។ កុមារទាំងនោះ បាននាំគ្នាបង្កាត់ភ្លើងអាំងបោចនៅកន្លែងចាំចាប ដែលពេលខ្លះមានអំបិលជ្រលក់ ហើយពេលខ្លះហូបសាបក៏មាន។

ក្រោយមក អង្គការ មានការរឹតបន្តឹងកាន់តែខ្លាំងឡើងៗ ដោយមានកងឈ្លបដើរស៊ើបតាមក្រោមផ្ទះនៅពេលយប់។ យើងមិនអាចនិយាយគ្នាបានទេ ព្រោះអាចត្រូវអង្គការចោទថាជំនុំគ្នាក្បត់បដិវត្តន៍និងត្រូវយកទៅសម្លាប់ចោល។ នៅចុងឆ្នាំ១៩៧៧ ឪពុករបស់ សុខ ខេង ត្រូវអង្គការចោទថាជាប់និន្នាការរដ្ឋការចាស់ និងជាប់ខ្សែក្បត់។ កាលនោះ មានឡានឃ្លុបសម្រាប់ចាប់កម្មាភិបាលនៅតាមមូលដ្ឋាន ដែល ជាប់ខ្សែក្បត់ ហើយឡាននោះតែងតែបើកឆ្ងែលជារៀងរាល់សប្តាហ៍។ មធ្យោបាយនៃការចាប់មនុស្ស គឺកងឈ្លបហៅប្រជាជនទៅប្រជុំដោយសម្ងាត់ មិនចាប់នៅទីសាធារណៈដែលអាចមានប្រជាជនឃើញឡើយ។

ឪពុករបស់ សុខ ខេង ថ្វីត្បិតតែគាត់មានតួនាទីជាជួរគណៈនៅតាមមូលដ្ឋាន ប៉ុន្តែគាត់ជាមនុស្សស្លូតបូតមានគុណធម៌ពុំមានប្រជាជនណាម្នាក់ស្អប់គាត់ឡើយ។ ថ្ងៃមួយ អង្គការថ្នាក់លើតម្រូវឲ្យឪពុករបស់ សុខ ខេង ឡើងទៅប្រជុំនៅស្រុកព្រៃកប្រសព្វ។ ហេតុតែព្រេងវាសនាខ្ពស់ គាត់ត្រូវបានគណៈស្រុក អាណិតស្រលាញ់ ហើយប្រាប់គាត់វិញថា៖

គណៈស្រុក ៖ «បងឯងត្រលប់ទៅវិញចុះ ទៅជ្រែកកោនជាមួយប្រជាជននៅតាមសហករណ៍ចុះ ព្រោះ ប្រធានកង ប្រធានក្រុមអស់ទាំងនោះសុទ្ធតែបងឯងជាអ្នកចាត់តាំងឡើង ដូច្នេះពួកវាមុខជាលាក់កំបាំងនិងយកអាសារបងមិនខានឡើយ»។

ឪពុកសុខខេង៖ «សមមិត្តប្រធាន តើសភាពការណ៍យ៉ាងណាដែរ?»។

គណៈស្រុក៖ «ហឺ! អីចឹង តើវាសនាសមមិត្តប្រធានគិតយ៉ាងណា?»។

គណៈស្រុក៖ «សម្រាប់ខ្ញុំមានតែបណ្តោយទៅតាមយថាផលហើយ ព្រោះពួកយើងគ្មានផ្លូវអ្វីជាមធ្យោបាយទេ ទៅបងឯងទៅឲ្យស្រួតទៅឡានឃ្លុបមកដល់ឥឡូវហើយ»។

ឪពុកសុខខេង៖ «សូមជូនពរសមមិត្តប្រធានឲ្យជួបតែសំណាងល្អ និងជ័យជម្នះ ខ្ញុំសុំលាសិនហើយ!»។

ឪពុក សុខ ខេង បានជិះកង់វិលត្រលប់ពីស្រុកព្រៃកប្រសព្វ មកកាន់ភូមិសោបក្រោម ឃុំសោប ពោរពេញទៅដោយសេចក្តីទុក្ខព្រួយ។ នៅម៉ោងប្រមាណជា ៥ល្ងាច ម្តាយរបស់ សុខ ខេង កំពុងអង្គុយបៀកម្លូស្លានៅនឹងមាត់ទ្វារផ្ទះ មានការភ្ញាក់ផ្អើលក្នុងចិត្តយ៉ាងខ្លាំង ពេលប្តីរបស់គាត់ជិះកង់ចូលមកដល់ក្រោមផ្ទះមានទាំងបង្វេចខោអាវ និងកន្ទេល ដោយមានទឹកមុខស្រពាប់ស្រពោន។ ភ្លាមនោះគាត់ក៏សួរឡើងថា «ហើយយ៉ាងម៉េចហ្នឹងប៉ាអាខេម ក្រែងថាទៅប្រជុំហ្អី ចុះម៉េចបានជាមានសាក់កាដូនិងកន្ទេលត្រលប់មកវិញអីចឹង?» ឪពុក សុខ ខេង តបទៅវិញថា «ហឺ! ឯងអើយខ្ញុំត្រូវគេរំសាយពីជួរហើយ»។

ក្រោយពួកគាត់ទាំងពីរនាក់បាននិយាយគ្នាអ៊ុះៗ មួយស្របក់ធំរួចមក ឪពុកសុខ ខេង ក៏ប្រញាប់យកកង់ជិះដែលជារបស់កម្មាភិបាលទៅប្រគល់ឲ្យគណៈភ្លាម ព្រោះគាត់ដឹងថាប្រជាជនគ្មានសិទ្ធិលើទ្រព្យសម្បត្តិទាំងអស់ហ្នឹងឡើយ។ នៅថ្ងៃបន្ទាប់មក ឪពុកសុខ ខេង ត្រូវអង្គការចាត់ឲ្យទៅភ្ជួររាស់ដូចប្រជាជនឯទៀតដែរ។ ចំណែកឯម្តាយ សុខ ខេង មានគភ៌៧ខែ បានសុំច្បាប់មេកងសម្រាកពលកម្ម ហើយត្រូវសម្រាកនៅពេទ្យឆ្មបទម្រាំដល់ថ្ងៃសម្រាល។

មិនយូរប៉ុន្មាន ឪពុករបស់ សុខ ខេង ត្រូវអង្គការដកចេញពីកងក្តួរាស់ ហើយឲ្យទៅដឹកព័ស្តុភារចូលទៅផ្គត់ផ្គង់ក្នុងការដ្ឋានមួយ ឈ្មោះថា ការដ្ឋានគោកម្ល។ ការដ្ឋានគោកម្ល នៅឆ្ងាយពីភូមិសោបក្រោមដែរ ហើយឪពុករបស់ សុខ ខេង ត្រូវបរទេះ២ថ្ងៃមួយយប់។ កងកម្លាំងនៅការដ្ឋានគោកម្ល ភាគច្រើនជាកងចល័ត ដែលមានយុវជនពេញកម្លាំងធ្វើពលកម្ម។ ឪពុករបស់សុខ ខេង បានស្នើទៅគណៈ ដើម្បីឲ្យ សុខ ខេង បានរួមដំណើរជាមួយគាត់ទៅកាន់ទីនោះ។

សុខ ខេង និងក្មេងៗទាំងអស់ ក៏ដូចជាប្រជាជននៅទូទាំងប្រទេស រិះរកគ្រប់វិធីបន្តយភាពស្រេកឃ្លាន ព្រោះការហូបតែបបរវេទាំងព្រឹកទាំងល្ងាច ពិតជាបាក់កម្លាំងខ្លាំងណាស់។ នៅពេលដឹកស្បៀងទៅផ្គត់ផ្គង់នៅតាមការដ្ឋាន ឪពុករបស់ សុខ ខេង ត្រូវគ្នាជាមួយអ្នកចាំចម្ការនៅចុងភូមិ។ ឪពុករបស់ សុខ ខេង តែងតែឲ្យ អំបិល ប្រហុក ត្រីងៀត និងថ្នាំជក់ជាដើម ទៅអ្នកចាំចម្ការ។ ចំណែកឯអ្នកចាំចម្ការវិញ តែងតែឲ្យអំពៅពី១០ ទៅ២០ដើមជារៀងរាល់ពេលដែលឪពុករបស់ សុខ ខេង ធ្វើដំណើរដឹកស្បៀងទៅការដ្ឋាន កាត់តាមចម្ការអំពៅដែលគាត់យាមនោះ។ ឪពុករបស់ សុខ ខេង និង សុខ ខេង បានអំពៅហូបតាមផ្លូវរហូតដល់សហករណ៍។ គាត់បានយកអំពៅដែលនៅសេសសល់ព្រមទាំងគ្រឿងឧបភោគបរិភោគ រួមមាន អំបិល ប្រហុក ត្រីងៀត និងថ្នាំជក់ជាដើម ចែកឲ្យប្អូនដែលស្គាល់រាប់អានគ្នានៅក្នុងភូមិចំបក់ផ្អែមដោយលាក់កំបាំង។ សុខ ខេង និងឪពុក តែងតែស្នាក់ក្នុងភូមិនោះមួយយប់រាល់ពេលដឹកស្បៀងទៅការដ្ឋាន។ នៅក្នុងភូមិនោះ សុខ ខេង មានឪពុកមាម្នាក់ ត្រូវជាបងប្រុសរបស់ឪពុកខ្លួន ធ្វើខាងកិនស្រូវ និងប្រពន្ធរបស់គាត់ធ្វើខាងចុងភៅក្នុងសហករណ៍។ ជារឿយៗ ឪពុករបស់ សុខ ខេង តែងតែលួចឲ្យអង្ករ ១០ ទៅ១៥គីឡូក្រាម ឲ្យបងប្រុសរបស់គាត់ រាល់ពេលដែលគាត់វិលត្រលប់មកកាន់ភូមិវិញ។

រយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ មិនមែនជាពេលវេលាយូរណាស់ណាទេ ប៉ុន្តែសម្រាប់ការរស់នៅក្នុងរបបខ្មែរក្រហម ពិតជាយូរណាស់ ព្រោះវាជារបបមួយដែលរស់នៅក្នុងអន្លង់ទុក្ខកម្មគ្រប់បែបយ៉ាង។ ចូលដល់ដើមឆ្នាំ១៩៧៨

សភាពការណ៍ក្នុងស្រុកទេសកាន់តែតឹងតែង។ ក្នុងជួរកម្មាភិបាលនៅតាមមូលដ្ឋានភាគច្រើន ជាពួកមកពីទិសនិរតី។ កម្មាភិបាលមកពីទិសនិរតី តែងតែហៅប្រជាជនទៅរៀនសូត្រ និងផ្សព្វផ្សាយពីសភាពការណ៍ខ្មាំង។ រីឯរបបហូបចុកកាន់តែយ៉ាប់ឃឺនទៅៗ។

ឥឡូវអារាម ក្លាយជាមន្ទីរពេទ្យ

វត្តសោមក្រោម មានបរិវេណធំទូលាយ ហើយត្រូវអង្គការខ្មែរក្រហមយកធ្វើជាមន្ទីរពេទ្យ។ពេទ្យនៅក្នុងវត្តនោះ បានចែកចេញជា២ផ្នែក។ ផ្នែកទី១ គឺពេទ្យឆ្មប សម្រាប់ស្ត្រីមានផ្ទៃពោះគម្រប់៧ខែ ដែលអង្គការអនុញ្ញាតឲ្យសម្រាកនៅទីនោះរហូតដល់សម្រាលកូនរួចរាល់។ ផ្នែកទី២ គឺផលិតឱសថ ដែលភាគច្រើនមានយុវជន យុវនារី នៅទីនោះ។ យុវជន យុវនារី ភាគច្រើនត្រូវចូលទៅក្នុងព្រៃដើម្បីរកកាប់ឈើ វល្លិ ដែលត្រូវយកមកផលិតជាឱសថតាមការបញ្ជារបស់ប្រធានពេទ្យ។ ពេលបានឈើឬវល្លិពីក្នុងព្រៃយកមកដល់កន្លែងហើយ ប្រធានពេទ្យយកទៅចម្រាញ់ផលិតជាថ្នាំគ្រាប់តាមលក្ខណៈបច្ចេកទេស។

សុខ ខេម ធ្វើការនៅក្នុងមន្ទីរពេទ្យនោះ ហើយជារឿយៗ សុខ ខេម ឆ្លៀតមកដេកកំដរម្តាយនៅពេលយប់ ព្រោះម្តាយសរសៃខ្វី ហើយពីវត្តមកផ្ទះមានចម្ងាយប្រហែល ៥០០ម៉ែត្រតែប៉ុណ្ណោះ។

សុខ ខេម ឃ្លាតពីម្តាយ និងម្នុងៗជារៀងរហូត

ក្នុងឆ្នាំ១៩៧៨ យុវជន យុវនារីមួយចំនួននៅមន្ទីរពេទ្យ ត្រូវអង្គការចាត់តាំងឲ្យទៅប្រចាំការនៅតាមអង្គភាពកងចល័ត ដែលត្រូវទៅលើកទំនប់ និងជីកប្រឡាយនៅការដ្ឋានគោកម្ល។ ពេលនោះហើយដែល សុខ ខេង លែង បានជួបមុខបងប្រុសជារៀងរហូត។ ថ្ងៃមួយពេលហូបបាយថ្ងៃត្រង់ស្រាប់តែកុមារម្នាក់លាន់មាត់ថា «នែ៎! ពួកអាដែង អ្នែងមើលនោះ មាននាវាមួយរលត់ម៉ាស៊ីនអណ្តែតចេញពីព្រែកជីកសុទ្ធតែពួកកងចល័ត ហើយស្លៀកពាក់សុទ្ធតែខោអាវខ្មៅថ្មីៗ ខ្លះដិះលើដំបូលខ្លះឈរនៅក្បាលនាវា»។ សុខ ខេង តបថា «អើមែនអ្ហ៎ សុទ្ធតែកងចល័តមែន! បែបប្រហែលគេបញ្ជូនឲ្យទៅធ្វើយោធានៅសមរភូមិហើយមើលទៅ»។ ខណៈនោះ កុមារម្នាក់ទៀត បានស្រែកឡើងថា

«អើ អាខេង! អ្អែងមើល បងអ្អែងតើឈរយួរស្បែកជើងនៅក្បាលនាវានោះ»។ សុខ ខេង បានប្រឹងសម្លឹងមើលតាមដៃដែលកុមារនោះចង្អុលបង្ហាញយ៉ាងអន្ទះសា។ សុខ ខេង បានត្រឹមសម្លឹងមើលទៅបងប្រុសទាំងអួលដើមក ព្រោះនាវានោះនៅឆ្ងាយពីច្រាំងប្រហែល ៥០ម៉ែត្រ មិនអាចនិយាយឆ្លើយឆ្លងគ្នាឮទេ។ ចំណែក សុខ ខេម មានទឹកមុខស្រងូតស្រងាត់ខំឈរសម្លឹងមកប្អូនដោយមិនដាក់ភ្នែកឡើយ។ នាវានោះ ចេះតែអណ្តែតឆ្ងាយៗទៅ សុខ ខេង បានស្ទុះរត់ទៅប្រាប់ម្តាយនៅផ្ទះតាមដំណើរហេតុការណ៍។ ម្តាយរបស់ សុខ ខេង បានឲ្យ សុខ ខេង នៅយោលប្អូនតូចកំពុងដេកក្នុងអង្រឹង ឯគាត់ប្រញាប់ប្រញាល់រត់ដេញតាមនាវាជាប់រហូតតាមបណ្តោយមាត់ទន្លេ។ នាវានោះ បានអែបចូលខាងមួយភ្លែតនៅមុំកំពង់វត្តសោបក្រោម ដើម្បីធ្វើម៉ាស៊ីន និងចាក់ប្រេង ដែលមានចម្ងាយពីផ្ទះរបស់ សុខ ខេង ប្រហែល ១គីឡូម៉ែត្រ។ គួរឲ្យអនិច្ចាម្តាយ សុខ ខេង ណាស់ ខំរត់ទាំងសរសៃខ្ចី ដើម្បីទៅជួបកូនជាទីស្រលាញ់ ប៉ុន្តែពេលរត់ជិតទៅដល់ ម៉ាស៊ីននាវា បានឆេះឡើងវិញ ហើយចាកចេញទៅ។ ម្តាយរបស់ សុខ ខេង បានត្រឹមស្រងេះស្រងោចម្នាក់ឯងមើលនាវាពីក្រោយដែលកំពុងតែបរចាកចេញទៅ។

ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ អង្គការបានផ្លាស់ឪពុករបស់ សុខ ខេង ពីអ្នកដឹកស្បៀងមកធ្វើជាប្រធានមន្ទីរបាយវិញម្តង។ សុខ ខេង ក៏ត្រូវត្រលប់ទៅនៅក្នុងកងកុមារវិញដែរ។ ថ្ងៃមួយ កម្លាំងបាក់ទ័ពរបស់ខ្មែរក្រហម បានដុតឃ្លាំងគ្រាប់ចោល ហើយបានបើកនាវាដ៏ធំមួយគ្រឿងឆ្លងទៅភូមិសោបក្រោម រួចរត់រៀសខ្លួនចូលព្រៃទៅទិសខាងលិចបាត់។ ម៉ោងប្រហែល១០ព្រឹក គឺជាពេលដែលមន្ទីរពេទ្យរៀបចំហូបបរស្រាប់តែនៅឯត្រើយម្ខាងខាងខេត្តក្រចេះ មានផ្សែងហុយទ្រលោមខ្មៅខ្ចុលឡើងទៅលើអមនឹងសំឡេងគ្រាប់ផ្ទុះសូរទ្រហឹងអឺងអាប់ដោយសារតែឆេះឃ្លាំងគ្រាប់នៅមាត់ទន្លេ។ ប្រជាជនភ័យ នាំគ្នារត់លែងហូបបរសល់ម្ហូបទាំងខ្ទះៗ។

បន្ទាប់មកប្រហែលម៉ោង១រសៀល ទើបឃើញកម្មាភិបាលខ្មែរក្រហម ដើរប្រាប់ប្រជាជនយ៉ាងត្រហេបត្រហបថា ឲ្យប្រជាជនរៀបចំរទេះ ហើយត្រូវរៀសខ្លួនឆ្ពោះទៅកាន់ទិសភ្នំដីប៉ែកខាងទឹកដីខេត្តកំពង់ធំ ជាប្រញាប់ទាំងអស់គ្នា។

ពេលនោះ ភាពច្របូកច្របល់បានកើតឡើង គ្មានអ្នកណាស្តាប់អ្នកណាទេ។ ប្រជាជនឈ្លោះគ្នាដណ្តើមរទេះ ដណ្តើមគោក្របី។ ឪពុករបស់ សុខ ខេង បានរៀបចំរទេះ និងគោដើម្បីត្រៀមលក្ខណៈដឹកកូនប្រពន្ធកៀសខ្លួន។ រីឯម្តាយរបស់ សុខ ខេង បានរៀបចំអីវ៉ាន់ចាំបាច់ និងគ្រឿងឧបភោគបរិភោគ សម្រាប់ត្រៀមដំណើរកៀសខ្លួន។ នៅតាមផ្លូវ យូរៗម្តងតែងតែឃើញមានយោធាខ្មែរក្រហមបាក់ទ័ពធ្វើដំណើរតាមផ្លូវឆ្ពោះទៅទិសខាងលិច។ កងទ័ពទាំងនោះមិនមានការពាក់ព័ន្ធនឹងប្រជាជនទេ គឺគេចយកតែរួចខ្លួនពីកងទ័ពវៀតណាម។ ថ្ងៃនោះម៉ោងប្រហែល ៣រសៀល ប្រជាជនជាច្រើន បានធ្វើដំណើរចេញពីភូមិសោបក្រោមឆ្ពោះទៅទិសខាងលិចឈៀងខាងជើង។ ប្រជាជនបររទេះដង្ហែគ្នា ហើយតែងតែជជែកពិភាក្សាគ្នាថាតើត្រូវស្នាក់នៅត្រង់ណាសិន ហើយប៉ុន្មានថ្ងៃទើបទៅដល់ភ្នំជីតាមទិសដៅដែលអង្គការកៀងទៅនោះ?

អវសានៃរបបខ្មែរក្រហម

នៅពេលកងទ័ពវៀតណាមវាយកងទ័ពខ្មែរក្រហម ក្រុមគ្រួសាររបស់ សុខ ខេង និងប្រជាជនជាច្រើនទៀត រស់នៅតាមបណ្តោយអូរដែលគ្មានទឹក ហើយព័ទ្ធជុំវិញទៅដោយព្រៃឈើអស់រយៈពេល ៥ថ្ងៃ។ ក្រោយមក ពេលសភាពការណ៍ស្ងប់ស្ងាត់ ក្រុមគ្រួសាររបស់ សុខ ខេង ក៏បានវិលត្រលប់ចូលក្នុងភូមិសោបក្រោមវិញ។ ក្នុងភូមិមានសភាពស្ងាត់ជ្រងំ ព្រោះប្រជាជនមិនទាន់វិលត្រលប់ចូលមកវិញគ្រប់គ្នាឡើយ។ នៅក្នុងភូមិ មានទាំងកងទ័ពខ្មែរនិងកងទ័ពវៀតណាមរាប់សិបនាក់នៅពង្រាយក្នុងភូមិ។ កងទ័ពទាំងនោះ រាក់ទាក់ជាមួយប្រជាជនណាស់ ហើយបានបញ្ជូនប្រជាជនឲ្យឆ្លងទឹកទៅត្រើយខាងខេត្តក្រចេះ ដើម្បីធានាសុវត្ថិភាពដល់ប្រជាជនពីការប្រយុទ្ធគ្នា។ ក្រុមគ្រួសាររបស់ សុខ ខេង បានចម្លងទាំងគោទាំងរទេះមកដល់ទីរួមខេត្តក្រចេះ រួចស្នាក់នៅក្នុងឃុំអូរឫស្សីដោយសុវត្ថិភាពជាមួយប្រជាជនដទៃទៀត។

ចប់

៤៤

រឿង ទឹកភ្នែកឈាង គុកឥតជញ្ជាំង

អ្នកនិពន្ធ ៖ ជេត សារឿន

៤៤ ~ រឿង ទឹកភ្លៀងលាងគុក ឥតជញ្ជាំង

ក្នុងខែមេសា ឆ្នាំ១៩៧៥ គឺជាខែមួយដែលមាតុភូមិកម្ពុជា ត្រូវភ្លើងសង្គ្រាមគ្រប់ដណ្តប់គ្រប់ទិសទីជំនួសទៅដោយខែមេសា ដែលធ្លាប់តែមានការប្រារព្ធពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរយ៉ាងសប្បាយរីករាយ។ ៣ក់កណ្តាល រាត្រី នាថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ក្រៅពីសំឡេងសើចហ៊ោកញ្ជៀវយ៉ាងកងរំពងពីប្រជាជនក្មេងចាស់ប្រុសស្រី ស្រាប់តែមានសំឡេងស្នូរកាំភ្លើងបានបន្លឺឡើងកាន់តែខិតជិតចូលមកដល់ទីក្រុងភ្នំពេញ។ ប្រជាជន ប្រៃជាភ័យផង អរផង ពេលឮស្នូរកាំភ្លើងប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងទាហាន លន់ នល់។

ម៉ោង៩ព្រឹក ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមទាំងប្រុសទាំងស្រីជាច្រើននាក់ ស្លៀកពាក់ពណ៌ខ្មៅ រុំក្បាលនឹងក្រមា ព្រមទាំងមានកាន់កាំភ្លើងគ្រប់ដៃ បានចូលមកដល់កណ្តាលក្រុងភ្នំពេញ។ ប្រជាជនក្មេងចាស់ប្រុសស្រីឈរនៅតាមផ្លូវស្រែកអបអរ ថែមទាំងមានសំឡេងទះដៃកងរំពងដោយក្តីរីករាយនឹងជ័យជម្នះរបស់កងទ័ពខ្មែរក្រហម។ ប្រជាជនម្នាក់ៗមានក្តីសង្ឃឹមទៅលើជ័យជម្នះរបស់កងទ័ពខ្មែរក្រហមថា ប្រទេសកម្ពុជា នឹងទទួលបានសន្តិភាពពេញលេញវិញ។ មិនយូរប៉ុន្មាន រថយន្តរបស់កងទ័ពខ្មែរក្រហម ដែលបើកពេញផ្លូវ ព្រមទាំងមានកងទ័ពនៅខាងក្នុងរថយន្តនោះស្រែកប្រកាសថា៖

«ពុកម៉ែ បងប្អូន និងសមមិត្តទាំងអស់គ្នា លែងមានទុក្ខភ័យអ្វីទៀតហើយ កងទ័ពបដិវត្តន៍កម្ពុជាមករំដោះបងប្អូនចេញពីចក្រពត្តិអាមេរិកហើយ ដូច្នេះស្រុកយើងមានក្តីសុខវិញហើយ» ។

ទន្ទឹមនឹងក្តីរីករាយ ប្រជាជនក៏មានភាពតក់ស្លុតដែរ ពេលបានឃើញទាហានលន់ នល់ ជាច្រើននាក់ ត្រូវកងទ័ពខ្មែរក្រហមចាប់ចងស្លាបសេកបណ្តើរទាំងខ្សែៗរួចបាញ់រះសម្លាប់ដួលពាសពេញផ្លូវ។ មិន តែប៉ុណ្ណោះ កងទ័ពខ្មែរក្រហមបានបាញ់កាំភ្លើងឡើងលើ ហើយស្រែកបន្ទរតាមក្រោយស្នូរកាំភ្លើងថា ៖

«ចេញ!បងប្អូនពុកម៉ែនាំគ្នាចេញពីទីក្រុងភ្នំពេញឲ្យប្រញាប់ប្រយ័ត្នចក្រពត្តិអាមេរិកទម្លាក់គ្រាប់បែកស្លាប់ ទាំងអស់គ្នាឥឡូវហើយ! អង្គការស្នើឲ្យបងប្អូនពុកម៉ែ ចេញតែរយៈពេល ៣ថ្ងៃនោះទេ រួចចាំត្រលប់មកផ្ទះវិញ។ បើសមមិត្តណារឹងទទឹងនឹងបញ្ជារបស់អង្គការ សមមិត្តនោះត្រូវតែស្លាប់» ។

ទីបំផុត ប្រជាជនដែលរស់នៅក្នុងក្រុងភ្នំពេញទាំងចាស់ ទាំងក្មេង ទាំងប្រុសទាំងស្រី មនុស្សពិការ អ្នកជំងឺ និងកុមារ ត្រូវបង្ខំចិត្តចាកចេញពីទីក្រុង ដោយសារតែខ្លាចនឹងការគំរាមកំហែងរបស់កងទ័ពខ្មែរក្រហម។ នៅតាមដងផ្លូវមានសភាពចង្អៀតណែនណាន់តាន់តាប់ប្រជាជនម្នាក់ៗទូលបង្វេច និងរែកសង្រែក ដែលមានចានឆ្នាំង ក្ងាយមុង កន្ទេលខ្នើយ សម្លៀកបំពាក់ និងស្បៀងអាហារ សម្រាប់បម្រុងក្នុងការចាកចេញរយៈពេល ៣ថ្ងៃនេះ។

ខ្ញុំ ត្រូវកងទ័ពខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ជាមួយប្រជាជនជាច្រើននាក់ទៀតដែរ។ ខ្ញុំមានសមាជិកគ្រួសារទាំងអស់ចំនួន ១១នាក់ រួមមានឪពុកម្តាយរបស់ខ្ញុំ មានវ័យចាស់ជរា បងប្រុសរបស់ខ្ញុំ ជាគ្រូបង្រៀន បងថ្លៃស្រី បងស្រី បងប្រុសបង្កើតចំនួន ២នាក់ទៀត គឺជានិស្សិត និងក្មួយៗចំនួន ៣នាក់ទៀតដែលនៅតូចៗ។ យើងរស់នៅម្តុំមន្ទីរពេទ្យលោកសង្ឃ។ គ្រួសាររបស់ខ្ញុំបានចាកចេញពីផ្ទះតាមបញ្ជារបស់កងទ័ពខ្មែរក្រហម នៅវេលាម៉ោង ២រសៀលថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥។ ពេលចាកចេញយើងបានទាញទ្វារផ្ទះ និងទ្វារបងបិទចាក់សោយ៉ាងរឹងមាំ។ សមាជិកគ្រួសាររបស់ខ្ញុំម្នាក់ៗ មានទូល

និងស្ពាយបង្វែចសម្លៀកបំពាក់រួមជាមួយស្បៀងអាហារទុកហូបតាមផ្លូវបន្តិចបន្តួចរៀងៗខ្លួន។ គ្រួសាររបស់ខ្ញុំ បានធ្វើដំណើរពីមុំមន្ទីរពេទ្យលោកសង្ឃឆ្ពោះទៅតាមផ្លូវជាតិលេខ៤ តាមការចង្អុលបង្ហាញរបស់កងទ័ពខ្មែរក្រហម។ ខ្ញុំឃើញប្រជាជនម្នាក់ៗបែកញើសជោកប្រឡាក់ពេញខ្លួន ព្រោះខំប្រឹងធ្វើដំណើរទូលរែកបង្វែចរៀងៗខ្លួន។ នៅតាមចិញ្ចើមផ្លូវជាតិលេខ៤ ទាំងសងខាង ខ្ញុំឃើញមានសាកសពរបស់ទាហាន លន់ នល់ ជាច្រើនដេកស្លាប់ពាសពេញផ្លូវ។ ខ្ញុំក៏បានឃើញទាហាន លន់ នល់ ជាច្រើនទៀតដែលកងទ័ពខ្មែរក្រហមចាប់បាននៅក្បែរនោះ។ ទាហាន លន់ នល់ ខ្លះត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់ដោយគ្មានបានស្រែកសូម្បីតែមួយម៉ាត់ រីឯទាហាន លន់ នល់ ខ្លះទៀតស្រែកថ្ងូរឈឺចាប់ប្រកាច់ននៀលយ៉ាងលំបាកវេទនាមុននឹងស្លាប់។ ប្រជាជនម្នាក់ៗឃើញដូច្នោះហើយភ័យខ្លាចយ៉ាងខ្លាំង មិនហ៊ាននិយាយស្តីអ្វីទេ។

យើងមិនអាចធ្វើដំណើរបានលឿននោះទេ ព្រោះយើងត្រូវប្រជ្រៀតជាមួយនឹងប្រជាជនជាច្រើននាក់ទៀតនៅលើដងផ្លូវ។ ក្រុមគ្រួសាររបស់ខ្ញុំ បានចំណាយពេលជាង ៥ម៉ោង គឺចាប់ពីម៉ោង ២រសៀល ដល់ម៉ោង៧យប់ ទើបយើងអាចធ្វើដំណើរមកដល់មុខបន្ទាយទាហានប៉ាវ៉ា ដែលមានចម្ងាយប្រហែល ៣គីឡូម៉ែត្រប៉ុណ្ណោះពីមន្ទីរពេទ្យលោកសង្ឃ។ នៅពេលនោះ ឪពុករបស់ខ្ញុំ មានអាយុជាង ៧០ឆ្នាំទៅហើយ។ គាត់មានជំងឺលើសឈាមស្លាប់មួយចំហៀងខ្លួន។ គាត់ដើរមិនរួចទេ ប៉ុន្តែគាត់នៅតែប្រឹងប្រែងដើរដោយឈើច្រត់របស់គាត់ទាំងត្រដាបត្រដួស ដែលពេលខ្លះគាត់ដួលទៅលើដីដោយសារតែប្រជ្រៀតគ្នាខ្លាំង។ ទៅដល់កន្លែងមួយ ឪពុករបស់ខ្ញុំ ដើរដួលហើយមិនអាចក្រោកឈរវិញបាន។ គាត់បានគ្រវីក្បាលសម្រក់ទឹកភ្នែកថ្ងូរប្រាប់កូនៗ និងប្រពន្ធថា «ពុកទៅមុខទៀតលែងរួចទៀតហើយកូនអើយ»។ យើងទាំងអស់គ្នាអួលដើមកនិយាយអ្វីមិនរួចឡើយ ក្រៅពីនាំគ្នាសម្រក់ទឹកភ្នែកតាមគាត់។

នៅពេលដែលយើងធ្វើដំណើរអស់កម្លាំង យើងក៏បាននាំគ្នាឈប់សម្រាកហូបបាយដែលយើងបានវេចខ្ចប់មកពីផ្ទះស្រាប់។ ក្រោយហូបបាយរួច ម្នាក់ៗ

នាំគ្នាក្រាលក្រណាត់ដេកកើយបង្វេចនៅលើស្មៅ។ ខ្ញុំបិទភ្នែកដេកមិនលក់ចេះតែនឹកគិតដល់ពាក្យដែលកងទ័ពខ្មែរក្រហមយកមកប្រើនៅពេលនោះដូចជា ពាក្យថា អង្គការ មិត្ត សមមិត្ត កម្មាភិបាល ឈ្លើយសឹក និង ស្នើ ជាដើម។ ខ្ញុំមិនដឹងថាពាក្យទាំងអស់នោះមានអត្ថន័យយ៉ាងដូចម្តេចទេ។ នៅយប់នោះ ទាំងក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនជាច្រើនទៀត ដេកតម្រៀបគ្នាពាសពេញវាលស្រែ។ ព្រឹកព្រលឹមស្រាងៗឡើង គ្រួសាររបស់ខ្ញុំ នាំគ្នាក្រោកពីដំណេក បន្តដំណើរទៅឯស្រុកកំណើតរបស់យើងនៅខេត្តព្រៃវែង តាមអង្គការប្រាប់។ មិនទាន់បានប៉ុន្មាននាទីផង កងទ័ពខ្មែរក្រហម បានទាញកាំភ្លើងបាញ់រះឡើងលើ និងស្រែកខ្លាំងៗថា៖

«ពុកម៉ែបងប្អូនស្នើសុំចេញដំណើរទៅទៀត កុំនៅយូរ អាមេរិកាំង មកទម្លាក់គ្រាប់បែកស្លាប់ទាំងអស់គ្នាឥឡូវហើយ! ចេញ! ប្រញាប់ចេញឲ្យលឿនឡើង»។

បុរសមាឌធំម្នាក់ដែលដេកក្បែរខ្ញុំកាលពីយប់មិញមិនព្រមក្រោកសោះ។ ខ្ញុំបានយកដៃទៅជាស់អង្រួនគាត់ឲ្យក្រោកឡើងដើម្បីបន្តដំណើរទៅមុខទៀត។ ខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះបុរសដែលខ្ញុំជាស់នោះ គឺជាសាកសពទាហានលន់ នល់ ដែលកងទ័ពខ្មែរក្រហមបានបាញ់សម្លាប់។ នៅពេលដឹងថាគ្រួសាររបស់យើងត្រូវធ្វើដំណើរទៅឆ្ងាយទៀត យើងក៏បានចោលបង្វេចមិនចាំបាច់មួយចំនួនដើម្បីយកកង់មកជឹកឪពុករបស់ខ្ញុំវិញ។ យើងធ្វើដំណើរបាន ២យប់ ក៏មកដល់ផ្លូវបំបែកផ្លូវជាតិលេខ៣ រួចយើងបានបន្តដំណើរទៅតាមផ្លូវរទេះភ្លើងទៅកាន់ស្រុកព្រៃកប្បាស ខេត្តតាកែវ ដើម្បីឆ្ពោះទៅកាន់ខេត្តព្រៃវែង។ យើងត្រូវធ្វើដំណើរឆ្លងកាត់ស្រុកកោះធំ សំដៅទៅកំពង់ចម្លងអ្នកលឿង។

នៅពេលដែលក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនជាច្រើនទៀត ធ្វើដំណើរមកដល់ផ្លូវរថភ្លើងផ្លូវជាតិលេខ៣ នៅម៉ោងប្រហែល ៧យប់ ស្រាប់តែមានកងទ័ពខ្មែរក្រហមក្មេងៗមួយក្រុម មានវ័យប្រហែល ១៥ឆ្នាំ ស្ពាយកាំភ្លើងគ្រប់ៗដៃមកស្ទាក់នៅចំពីមុខយើង ដើម្បីស្រង់ស្ថិតិ និងឆែកឆេរក្នុងបង្វេចក្រែងមានលាក់អាវុធ។ កងទ័ពខ្មែរក្រហម បានប្រាប់យើងថា នៅពេលដែលពួកគេសួរអី ឲ្យឆ្លើយ កុំលាក់បាំងនឹងអង្គការ ហើយប្រសិនបើធ្វើមន្ត្រីរាជការ ឬធ្វើទាហាន

ប្រាប់ឲ្យត្រង់ស្រួលអង្គការឲ្យទៅធ្វើការនៅកន្លែងនោះវិញ។ ប្រសិនបើកុហក អង្គការនឹងសម្លាប់ចោលហើយ។ ពួកយើងស្រឡាំងកាំងម្តងទៀត ហើយក៏ប្រគល់បង្វែចឲ្យកងទ័ពខ្មែរក្រហមឆែកឆេរ។ ក្រុមគ្រួសាររបស់ខ្ញុំ បានប្រាប់ទៅកងទ័ពខ្មែរក្រហមថា យើងគឺកម្មករ អ្នកខ្លះជាសិស្សនិស្សិត និងខ្លះទៀតគឺជាគ្រូបង្រៀន ។ គ្រាន់តែឮយើងប្រាប់ថាមានសមាជិកគ្រួសាររបស់យើងធ្វើជាគ្រូបង្រៀន កងទ័ពខ្មែរក្រហម បានឲ្យក្រុមគ្រួសាររបស់ខ្ញុំ ឈរនៅម្តុំជាមួយនឹងអ្នកជាប់និន្នាការទាហានលន់ នល់ រាប់រយនាក់ផ្សេងទៀត។ កងទ័ពខ្មែរក្រហមនិយាយថា «ពួកខ្មាំងនៅឈរម្តុំសិន»។ នៅពេលឮកងទ័ពខ្មែរក្រហមហៅថាពួកខ្មាំង ក្រុមគ្រួសាររបស់ខ្ញុំ ភ័យខ្លាចខ្លាំងណាស់ ព្រោះគិតថាពេលនេះយើងច្បាស់ជាលែងបានធ្វើដំណើរទៅស្រុកកំណើតហើយ។ បន្ទាប់ពីយើងរង់ចាំនៅទីនោះប្រហែលជាងកន្លះម៉ោង ស្រាប់តែកងទ័ពខ្មែរក្រហម បានយកចំណងមកចងស្លាបសេកប្រជាជនដែលកងទ័ពចាត់ទុកថាជាប់និន្នាការទាហាន លន់ នល់ រាប់រយនាក់បណ្តើរជាជួរតាមថ្នល់រថភ្លើងទៅទិសខាងត្បូង។ ក្រុមគ្រួសាររបស់ខ្ញុំ ក៏ត្រូវកងទ័ពខ្មែរក្រហមនាំទៅជាមួយនឹងទាហាន លន់ នល់ ដែរ ប៉ុន្តែកងទ័ពខ្មែរក្រហមមិនបានចងចំណងយើងទេ។ ឪពុករបស់ខ្ញុំឃើញដូច្នោះក៏សួរទៅកងទ័ពខ្មែរក្រហមថា «តើចៅៗបណ្តើរពួកខ្ញុំទៅណា»? កងទ័ពខ្មែរក្រហមបានប្រាប់មកឪពុករបស់ខ្ញុំវិញយ៉ាងខ្លីថា «អង្គការថ្នាក់លើឲ្យយកទៅរៀនសូត្រ»។ ឪពុករបស់ខ្ញុំក៏សួរទៀតថា «តើអង្គការជានរណាទៅ? តើរៀនសូត្រអំពីអ្វី»? កងទ័ពខ្មែរក្រហមម្នាក់ដែលបណ្តើរ គ្រួសាររបស់ខ្ញុំនៅខាងក្រោយគេឆ្លើយថា «បន្តិចទៀតដឹងហើយ»។

ឪពុករបស់ខ្ញុំ ជិះកង់លែងកើតទៀតហើយ ព្រោះយើងធ្វើដំណើរលើផ្លូវរថភ្លើងរដិបរដុបណាស់។ គាត់បានដើរទប់ជាមួយឈើច្រត់របស់គាត់វិញ។ ឪពុករបស់ខ្ញុំ ដើរបានចម្ងាយប្រហែល ៥គីឡូម៉ែត្រ គាត់ក៏ដើរទៅមុខលែងរួចទៀត។ ពេលនោះ យប់ងងឹតសូន្យឈឹង មើលអ្វីសឹងតែមិនឃើញសោះ ឪពុករបស់ខ្ញុំបានឈប់ ហើយលើកដៃសំពះអង្វរកងទ័ពខ្មែរក្រហមថា « ចៅអើយចៅ តាទៅមុខ

ទៀតលែងរួចហើយ តាសុំអង្វរចៅដោះលែងគ្រួសាររបស់តាទៅ។ គ្រួសាររបស់តាមិនបានជាប់និន្នាការទាហានស្អីនោះទេ»។ បងប្រុសរបស់ខ្ញុំដែលជាគ្រូបង្រៀនក៏បានដកយកនាឡិកាដៃរបស់គាត់ពីក្នុងបង្វែចខោអាវហុចឲ្យកងទ័ពខ្មែរក្រហមម្នាក់នោះរួចនិយាយតិចៗ ថា «ខ្ញុំគ្មានអ្វីសងគុណសមមិត្តទេ មានតែនាឡិកានេះសមមិត្តយកទៅប្រើចុះ»។ កងទ័ពខ្មែរក្រហមមិននិយាយស្តីអ្វីឡើយ ហើយសម្លឹងមើលទៅក្រុមឈ្លើយសឹកដែលបានធ្វើដំណើរឃ្លាតចាកចេញពីគ្រួសាររបស់ខ្ញុំជិតកន្លះគីឡូម៉ែត្រ។ សមមិត្តលូកដៃយកនាឡិកាដាក់ហោប៉ៅអាវរបស់គេរួចក៏ប្រាប់ទៅឪពុកខ្ញុំថា «ញោមប្រញាប់គេចខ្លួនចូលភូមិក្បែរៗនេះទៅ កុំដើរតាមផ្លូវរទេះភ្លើងឲ្យសោះ ខ្លាចអង្គការច្រឡំថាជាខ្មាំង»។ និយាយរួច កងទ័ពខ្មែរក្រហមម្នាក់នោះ ប្រញាប់រត់តាមដួរចំណាប់ខ្មាំងឲ្យទាន់ដើម្បីការពារកុំឲ្យចំណាប់ខ្មាំងគេចខ្លួន។ ឯក្រុមគ្រួសាររបស់ខ្ញុំ មិនបង្អង់យូរក៏នាំគ្នាគេចចូលទៅសំងំនៅក្នុងភូមិរបស់ប្រជាជនមូលដ្ឋាន មិនហ៊ានក្អកឡើយ។ មិនដល់មួយម៉ោងផង ស្រាប់តែយើងឮស្នូរកាំភ្លើងលាន់ឮកងរំពងនៅតាមផ្លូវរថភ្លើង។ ស្នូរកាំភ្លើងនោះជាស្នូរកាំភ្លើងបាញ់សម្លាប់ឈ្លើយសឹកដែលរួមដំណើរជាមួយខ្ញុំមុននេះបន្តិច។

នៅយប់នោះ គ្រួសាររបស់ខ្ញុំ គ្មានអាហារហូបចូលពោះទាល់តែសោះ។ យើងនឿយហត់ខ្លាំង ណាស់ ហើយក៏សម្រេចចិត្តចូលផ្ទះប្រជាជនមូលដ្ឋានដែលរស់នៅក្នុងតំបន់រំដោះមួយកន្លែង។ ខ្ញុំអាណិតឪពុករបស់ខ្ញុំពេក ក៏ដាច់ចិត្តទៅដាស់ម្ចាស់ផ្ទះ ដែលកំពុងតែសំងំដេកមិនទាន់លក់ដោយសំឡេងខ្សឹបថា « ពូអើយ! មានសល់បាយកកទេ ឲ្យខ្ញុំសុំមួយដុំឲ្យពុកហូបមក»។ ពូម្ចាស់ផ្ទះនោះបានដាស់ប្រពន្ធរបស់គាត់ឲ្យទៅយកបាយកកមួយដុំពីក្នុងឆ្នាំងហុចមកឲ្យខ្ញុំ។ ខ្ញុំរំភើបពន់ពេក រួចប្រញាប់អរគុណគាត់ និងរត់យកបាយកកមួយដុំនោះហុចឲ្យម្តាយនិងឪពុករបស់ខ្ញុំហូបជាមួយដុំអំបិល។ ចំណែកពួកខ្ញុំជាកូននិងចៅៗ បាននាំគ្នាបង្កាត់ភ្លើងដាំបាយនៅក្រោយផ្ទះ។ ពេលនោះ នៅតាមផ្លូវលំខាងមុខផ្ទះ មានក្រុមកងទ័ពខ្មែរក្រហម កំពុងតែរត់ដេញចាប់ពួកឈ្លើយសឹកទាហាន លន់ នល់ ដែលរត់គេចចេញពីចំណង ហើយបណ្តើរយកទៅបាញ់សម្លាប់

ចោល។ កងទ័ពខ្មែរក្រហមស្រែកខ្លាំងៗថា «ចាប់វាឲ្យបាន ពួកអាឈ្លើយសឹកបម្រើអាមេរិកកាំង! ចង់រត់ទៅណាក៏មិនរួចដែរ»។ នៅរំលងពីផ្ទះដែលខ្ញុំកំពុងតែជាំបាយចម្ងាយប្រហែល៣០ម៉ែត្រ ស្រាប់តែមានស្នូរបាញ់កាំភ្លើងប្រាវៗ សម្លាប់ពួកឈ្លើយសឹក។ គ្រួសាររបស់ខ្ញុំកាន់តែតក់ស្លុត ប៉ុន្តែក្រោយមកសភាពការណ៍ប្រែជាស្ងប់ស្ងាត់បន្តិច ហើយគួបផ្សំបាយក៏ឆ្អិន យើងទាំងអស់គ្នាប្រញាប់ប្រញាល់ដួសបាយមកហូបជាមួយដុំអំបិលរៀងៗខ្លួន និងរកកន្លែងសំងំដេកមួយស្របក់។

ម៉ោង៨ទៀបភ្លឺយើងក្រោកឡើង រួចបន្តដំណើរទៅមុខទៀត។ យើងបានលា និងអរគុណម្ចាស់ផ្ទះជាអនេក។ មុនចាកចេញ ម្ចាស់ផ្ទះ បានប្រាប់យើងឲ្យមានការប្រុងប្រយ័ត្នពាក្យសម្តី ជាពិសេសនៅពេលអង្គការសួរថាយើងធ្វើការងារអ្វី? ម្ចាស់ផ្ទះប្រាប់ឲ្យយើងឆ្លើយថាធ្វើគូលីកម្មករ។ គ្រួសាររបស់ខ្ញុំអរគុណម្ចាស់ផ្ទះម្តងហើយម្តងទៀត និងចងចាំការទូន្មានរបស់គាត់ក្នុងចិត្តមិនភ្លេចឡើយ។ អស់រយៈពេលជិតមួយខែ គ្រួសាររបស់ខ្ញុំ បានធ្វើដំណើរឆ្លងកាត់តំបន់រំដោះ ទើបមកដល់ស្រុកកំណើតនៅតំបន់២៣ ស្ថិត ក្នុងភូមិអាគ្រាជ ឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ មកដល់ក្នុងភូមិ ក្រុមគ្រួសាររបស់ខ្ញុំ បានដាច់ស្បៀងអាហារ។ យើងនាំគ្នាដើររើសពោត និងមើមដំឡូងយកមកស្ងោរហូបជំនួសបាយ។ មកដល់ស្រុកកំណើតមិនទាន់បានប៉ុន្មានផង កម្មាភិបាលភូមិបានចុះមកស្រង់ស្ថិតិសួរនាំអំពីនិន្នាការនយោបាយគ្រួសាររបស់ខ្ញុំ និងគ្រួសារថ្មីផ្សេងៗទៀត។ អង្គការបានបែងចែកវណ្ណៈប្រជាជនជា ៣ ប្រភេទគឺទី១ ប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ ទី២ សន្តិសម្ព័ន្ធ សំដៅដល់ប្រជាជនដែលមាននិន្នាការក្នុងរបប លន់ នល់ តែរស់នៅក្នុងតំបន់រំដោះ និងទី៣ ប្រជាជនមូលដ្ឋាន សំដៅដល់ប្រជាជនតស៊ូរស់នៅក្នុងតំបន់រំដោះដែលខ្មែរក្រហមកាន់កាប់។ គ្រួសាររបស់ខ្ញុំស្ថិតនៅក្នុងប្រជាជនប្រភេទទី១។ អង្គការ បានសង់ខ្ទមតូចមួយឲ្យយើងរស់នៅ និងស្ថិតក្រោមការឃ្លាំមើលរបស់កម្មាភិបាលខ្មែរក្រហមជាប់ជានិច្ច។ ក្រោយមកទៀត អង្គការបានឲ្យយើងរស់នៅជាសហករណ៍ គឺអ្វីៗត្រូវដាក់រួមទាំងអស់។ គ្រួសាររបស់ខ្ញុំ ក៏ដូចគ្រួសារជម្លៀសមកពីទីក្រុងឯទៀតដែរ ត្រូវបាន

អង្គការបំបែកចាត់តាំងឲ្យធ្វើពលកម្មជាសមូហភាព។ ប្រជាជនដែលមានវ័យចាស់ជរា ដូចជា ឪពុកម្តាយរបស់ខ្ញុំ អង្គការឲ្យវេញខ្សែគោក្របីរឹងយាយៗវិញ អង្គការឲ្យមើលថែចៅៗ។ ប្រជាជនពេញវ័យ ពេញកម្លាំងដូចខ្ញុំ ត្រូវអង្គការចាត់ចូលជាយុវជនឈានមុខ ហើយត្រូវរ៉ាប់រងការងារធ្ងន់ៗ។ សម្រាប់កុមារតូច ដូចជាក្មួយរបស់ខ្ញុំវិញ អង្គការឲ្យកាប់ស្លឹកឈើ និងកើបអាចម៍គោ ធ្វើជាជីដាក់ស្រែចម្ការ។ យើងត្រូវរស់នៅជាសមូហភាព ហើយអង្គការក៏តម្រូវឲ្យយើងហូបចុកជារួម ដោយទទួលបានរបបអាហារស្មើៗគ្នា។

នៅក្នុង ភូមិអាគ្រាជ ទាំងមូល ក្រុមគ្រួសារជម្លៀសចេញពីក្រុងភ្នំពេញ និងខេត្តស្វាយរៀង មានទាំងអស់ជាង ១០០គ្រួសារ ត្រូវបានអង្គការឲ្យរស់នៅសហករណ៍ជាមួយគ្នា ក្រោមការឃ្លាំមើលរបស់អង្គការគ្រប់វិនាទី។ ប្រជាជនទាំងអស់ ត្រូវអង្គការចាត់ទុកថាជាប្រជាជនថ្មីជាប់និន្នាការនយោបាយជាមួយនឹងរបបចាស់ ថែមទាំងជាមុខសញ្ញាត្រូវអង្គការកម្ទេចដែរ។ មិនបានប៉ុន្មានផង ប្រជាជនប្រុសៗជាង៥០នាក់ ត្រូវអង្គការចាត់ឈ្មោះឲ្យទៅរៀនសូត្រនៅចំណុចឫស្សីម្រេញ ស្ថិតនៅឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ អង្គការបានស្រាវជ្រាវដឹងថាប្រុសៗទាំង ៥០នាក់នោះ ធ្លាប់ធ្វើជាមន្ត្រីរាជការ ជាពិសេសធ្លាប់ធ្វើជាទាហាន លន់ នល់។ ក្រុមគ្រួសាររបស់ប្រុសៗទាំង៥០នាក់នោះ រួមមាន ឪពុកមា បងបង្កើត បងថ្លៃ និងបងជីដូនមួយរបស់ខ្ញុំ សរុបទាំងអស់ ៧នាក់ ត្រូវកងឈ្លបស្ពាយកាំភ្លើងមកបណ្តើរចេញពីខ្ទមទាំងយប់ម្នាក់ម្តងៗ ដើម្បីយកទៅជួបជុំជាមួយប្រជាជនដែលជាប់ពាក់ព័ន្ធនយោបាយ លន់ នល់ រាប់សិបនាក់ផ្សេងទៀតនៅក្នុងវត្តឯករាជ្យ ដែលជាមន្ទីរឃុំ។ ក្រុមគ្រួសាររបស់ខ្ញុំមានភាពតក់ស្លុតណាស់។ យើងម្នាក់ៗបានត្រឹមតែលួចសម្រក់ទឹកភ្នែក ព្រោះយើងដឹងច្បាស់ណាស់ថា ពាក្យរៀនសូត្រ ភាគច្រើនយកទៅធ្វើទារុណកម្ម និងសម្លាប់ចោល។ ថ្ងៃនោះ ក្រុមឈ្លប បានបណ្តើរសាច់ញាតិរបស់ខ្ញុំទាំង ៧នាក់ ដែលមានតែបង្វេចសម្លៀកបំពាក់តិចតួច និងអំបិលគ្រាប់ខ្មៅមួយកញ្ចប់ម្នាក់ៗ នៅលើស្មាទៅជាមួយ ដោយធ្វើដំណើរកាត់ស្បែរត្រឹងងឹតសូន្យឈឹង។

បីថ្ងៃក្រោយមក សមមិត្ត ប្រធានភូមិអាគ្រាជ បានចុចឈ្មោះខ្ញុំ និងក្រុមយុវជនចំណូលថ្មីទាំងអស់ឲ្យយកចប និងបង្គីទៅលើកដីលុបផ្លូវជាតិលេខ១ឲ្យល្អឡើងវិញ។ យើងត្រូវលើកចាប់តាំងពីស្ពានកំពង់ត្របែកទៅទិសខាងកើតជាប់ព្រំប្រទល់តំបន់២៤ ខេត្តស្វាយរៀង។ ផ្លូវជាតិលេខ១ ត្រូវខ្ទេចខ្ទាំ ព្រោះកងទ័ពរំដោះជីកបំផ្លាញចោលក្នុងពេលមានសង្គ្រាមជាមួយរបបសាធារណរដ្ឋខ្មែរក្នុងឆ្នាំ១៩៧៣។ ឮដូច្នោះ បងប្អូនរបស់ខ្ញុំម្នាក់ៗ ភ័យអស់ព្រលឹងហើយ ដោយនឹកគិតថាខ្ញុំត្រូវអង្គការយកទៅរៀនសូត្រទៀតហើយ។

ថ្ងៃមួយពេលកំពុងធ្វើការ ខ្ញុំបានចោលកន្ទុយភ្នែកទៅទិសខាងលិចប្រហែលជាង ១០០ម៉ែត្រ ក៏បានឃើញ កងឈ្លបចំនួន ៥នាក់ កំពុងបណ្តើរក្រុមអ្នកទោសជាង ១០០នាក់ មកជាមួយប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ឲ្យមកធ្វើពលកម្មលុបថ្នល់ជាតិលេខ១។ ខ្ញុំចេះតែលួចចោលភ្នែកសម្លឹងទៅអ្នកទោសទាំងអស់នោះ។ ប្រជាជនមូលដ្ឋានម្នាក់ បានលួចខ្សឹបប្រាប់ខ្ញុំថា អ្នកទោសទាំងអស់នេះគឺជាពួកឈ្លើយសឹកដែលអង្គការបានយកមករៀនសូត្រ។ ពេលឮយ៉ាងនេះ ខ្ញុំភ្ញាក់ខ្លួនព្រើតរួចសម្លឹងមើលជាថ្មីម្តងទៀតក្រែងឃើញឪពុកមា និងសាច់ញាតិរបស់ខ្ញុំ ដែលអង្គការបានយកទៅរៀនសូត្រកាលពីបីថ្ងៃមុន។ ភ្នែករបស់ខ្ញុំបានត្រឹមតែឃើញព្រឹលៗ និងប្រហាក់ប្រហែលពួកគាត់ខ្លះៗតែប៉ុណ្ណោះ។ ពុទ្ធោអើយ! ខ្ញុំរន្ធត់ចិត្តណាស់ ព្រោះក្រុមឈ្លើយសឹកទាំងអស់នោះសុទ្ធតែមានរាងកាយស្គមស្គាំង និងសក់កន្ទ្រើង ហើយកំពុងតែនាំគ្នាប្រឹងរែកដីទាំងដួលច្រងាប់ច្រងិលក្រោមកម្តៅថ្ងៃក្តៅហែង។ នៅពេលចប់ម៉ោងការងារម៉ោង ៥កន្លះល្ងាច ទាំងប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន នាំគ្នាយកចប និងបង្គីវិលមកសហករណ៍ក្នុងភូមិអាគ្រាជវិញ។ ចំណែក ក្រុមឈ្លើយសឹក ត្រូវកងឈ្លបបណ្តើរយកទៅឃុំខ្លួនបង្អត់អាហារនៅមន្ទីរឃុំឃាំងក្នុងឃុំកន្សោមអក។ ចាប់តាំងពីពេលនោះមក ឪពុកមា បងបង្កើត បងថ្លៃ និងបងជីដូនមួយរបស់ខ្ញុំ ដែលអង្គការយកទៅរៀនសូត្រនោះបាត់ដំណឹងសូន្យឈឹង។

នៅក្នុងសហករណ៍អាគ្រាជដែលខ្ញុំរស់នៅ ក៏មិនខុសអ្វីនឹងកន្លែងផ្សេងដែរ។ អង្គការបានកំណត់ការហូបចុក ដោយឲ្យហូបបបរមួយថ្ងៃតែពីរពេល គឺថ្ងៃត្រង់ និងល្ងាច។ មិនថាចាស់ ក្មេង ឬអ្នកពេញកម្លាំងនោះទេ គឺត្រូវហូបជាសមូហភាព នៅរោងបាយសហករណ៍តែមួយ និងត្រូវកំណត់តាមរបបបបរពីរវែកក្នុងម្នាក់ៗ។ ទោះបីជាការហូបចុកឆ្អែត ឬមិនឆ្អែត គឺយើងមិនអាចតវ៉ាបានឡើយ។ ប្រសិនបើហ៊ានតវ៉ា អង្គការនឹងយកយើងទៅរៀនសូត្រ។

ថ្ងៃមួយនៅក្នុងឃុំព្រៃឈរ អង្គការបានរៀបចំការរៀបការជារួមដល់ក្រុមយុវជន យុវនារីបដិវត្តន៍ចំនួន ៣៤គូ ដែលអង្គការផ្គូផ្គងឲ្យរួចជាស្រេច។ គ្មាននរណាអាចប្រកែកនឹងការរៀបចំឲ្យរៀបការនេះបានឡើយ។ ការរៀបការ មិនបានធ្វើពិធីអ្វីធំដុំក្រៅពីឲ្យមួយគូៗស្លៀកពាក់ខោខ្មៅ អាវខ្មៅ បង់កក្រមា និងកាន់ដៃគ្នាឡើងប្តេជ្ញាចិត្តថានឹងស្រលាញ់គ្នាអស់មួយជីវិត និងបម្រើអង្គការអស់មួយជីវិត។ ការរៀបការពេលនោះ គឺជាពិធីពិសេសមួយសម្រាប់ប្រជាជនរស់នៅឃុំព្រៃឈរ ព្រោះអង្គការបានកាប់គោចំនួន ៥ក្បាល និងធ្វើម្ហូបយ៉ាងឆ្ងាញ់ឲ្យប្រជាជនហូបរួម។

នៅខែកញ្ញា ឆ្នាំ១៩៧៨ ជារដូវបុណ្យភ្ជុំបិណ្ឌ ទឹកទន្លេមេគង្គ បានឡើងជន់លិចវាលស្រែយ៉ាងល្ហល្ហាចមើល ទៅសស្ងាចប្រៀបដូចទឹកសមុទ្រ។ អង្គការបានចាប់ផ្តើមចល័តប្រជាជនពីតំបន់មួយទៅតំបន់មួយផ្សេងទៀត។ គ្រួសារបងស្រីរបស់ខ្ញុំចំនួន ២គ្រួសារ រួមជាមួយនឹងបងប្អូនជីដូនមួយ ៣គ្រួសារទៀត ត្រូវអង្គការជម្លៀសពីឃុំព្រៃឈរ ស្រុកកំពង់ត្របែក ឲ្យទៅរស់នៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងវិញ។ បងស្រីរបស់ខ្ញុំទាំង ២គ្រួសារ និងបងជីដូនមួយ ៣គ្រួសារទៀត បានមកលាម្តាយ និងបងប្អូនរបស់ខ្ញុំទាំងទឹកភ្នែក។ ពួកគាត់បាននាំគ្នារែកពុនបង្វេចសម្លៀកបំពាក់ និងដឹកដៃក្មួយតូចៗចាកចេញពីសហករណ៍ភូមិអាគ្រាជ ធ្វើដំណើរថ្មើរជើងកាត់តាមផ្លូវជាតិលេខ១ ឆ្ពោះទៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលមានកម្មាភិបាលភូមិម្នាក់ជាអ្នកនាំផ្លូវ។ ចាប់តាំងពីពេលនោះមក ខ្ញុំលែងបានជួបពួកគាត់រហូតមកដល់សព្វថ្ងៃនេះ។

ស្របពេលនោះ ទឹកជំនន់បានជន់ពន្លិចឃុំមួយចំនួនក្នុងស្រុកកំពង់ត្របែក រួមទាំង ឃុំកន្សោមអក ដែលជាឃុំមានមន្ទីរឃុំឃាំងរបស់ខ្មែរក្រហមធំមួយនៅត្រង់ចំណុចឫស្សីម្រេញ។ ទឹកជំនន់បានលិចដល់ដំបូលរោងមន្ទីរឃុំឃាំង ប៉ុន្តែយើងមិនដឹងថា អង្គការយកអ្នកទោសរាប់រយនាក់ដែលជាប់ឃុំទៅណានោះទេ។ នៅពេលមានទឹកជំនន់ខ្លាំង សាកសពអ្នកទោសជាច្រើននាក់ បានផុសចេញពីរណ្តៅដីហើមអណ្តែតលើទឹក ដោយម្នាក់ៗមានចំណងជាប់នឹងដៃជើង និងខ្លះទៀតកំបុតក្បាលមើលទៅគួរឲ្យរន្ធត់ណាស់។ ក្រុមឈ្លបដែលជាសន្តិសុខប្រចាំមន្ទីរឃុំឃាំងឫស្សីម្រេញ ខ្លាចប្រជាជនឃើញ និងអង្គការថ្នាក់លើដឹង ក៏បាននាំគ្នាបញ្ជោះទូកជិះប្រមូលសាកសពគ្រប់ច្រកល្ហក ហើយដឹករណ្តៅកប់សពទាំងអស់នោះសារជាថ្មី។

អង្គការ បានចាត់តាំងខ្ញុំឲ្យទៅជីកដីសណ្តទន្លេ នៅឃុំពាមមន្ទារ និងក្រោយមកអង្គការបានឲ្យខ្ញុំទៅវាយថ្មនៅភ្នំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង វិញម្តង ដើម្បីយកដុំថ្មមកធ្វើទ្វារបិទបើកទឹកនៅស្រុកកំពង់ត្របែកជាមួយកងទ័ពខ្មែរក្រហមមួយក្រុម ដែលអង្គការបានដាក់ពិន័យដោយសារគោរពសីលធម៌បដិវត្តមិនបាន។ ខ្ញុំធ្វើការងារនៅទីនេះបានជាងកន្លះខែ ក៏អស់ស្បៀង ទើបខ្ញុំសុំការអនុញ្ញាតពីមេកងទៅភូមិយកស្បៀងមកហូប។ ពេលធ្វើដំណើរដោយថ្មើរជើងក្នុងចម្ងាយជិត៥០គីឡូម៉ែត្រ ខ្ញុំបានទៅដល់ភូមិអាគ្រាជវិញ នៅពេលព្រលប់។ បន្ទាប់មក ខ្ញុំដើរសំដៅទៅកាន់រោងបាយសមូហភាព ដើម្បីស្រស់ស្រូបអាហារ និងរាយការណ៍ប្រាប់មេចុងភៅថា អង្គការនៅភ្នំឈើកាច់ឲ្យមកយកស្បៀងអាហារបន្តការងារវាយថ្មភ្នំ។ មេចុងភៅ មិននិយាយអ្វីឡើយ ហើយធ្វើមុខក្រញូវដាក់ខ្ញុំ។ មេចុងភៅបានដួសបបរសមួយចានហុចឲ្យខ្ញុំហូបជាមួយទឹកត្រី។ ក្រោយហុតបបរអស់មួយចានយ៉ាងឆ្ងាញ់រួច និងដោយសារអស់កម្លាំងមកពីចម្ងាយផង ខ្ញុំក៏ទៅដេកនៅក្នុងរោងយុវជនដែលជាកន្លែងដេករួម។ នៅពេលទៅដល់រោងយុវជន សមមិត្តប្រធានយុវជន បានចាត់តាំងឲ្យខ្ញុំទៅដេកនៅរោងចាំស្រូវ ព្រោះគាត់ខ្លាចគោស៊ីស្រូវ។ រោងចាំស្រូវនោះស្ថិតនៅចម្ងាយជាងមួយគីឡូម៉ែត្រពីរោងយុវជន ហើយខ្ញុំដេកនៅទីនោះជាមួយមីង

និងលោកតាម្នាក់ជាអ្នកមូលដ្ឋាន។ រោងចាំស្រូវ គឺជាកន្លែងស្ងាត់ជាច់ស្រយាលពីលំនៅឋានរបស់ប្រជាជន។ ខ្ញុំដើរកាត់ភ្លៀងចេញពីរោងយុវជនមិនបានប៉ុន្មានផង ស្រាប់តែឃើញកងឈ្លប ៣នាក់ កាន់កាំភ្លើង អា-កា គ្រប់ដៃកំពុងបណ្តើរមនុស្សស្រីមួយក្រុមកាត់តំណក់ទឹកភ្លៀង និងកូនក្មេងតូចៗខ្លះអាយុ ៣ទៅ ៤ឆ្នាំ ដើរតោងដៃម្តាយស្រែកយំទារបាយហូប ទាំងរអិលជើងដួលប្រឡាក់ភក់ស្រមាមប៉ាកពាសពេញផ្លូវ។ កងឈ្លបបណ្តើរប្រជាជនជិត ១០០នាក់ នៅលើផ្លូវលំពីផ្លូវជាតិលេខ១ ឆ្ពោះទៅមន្ទីរឃុំក្នុងវត្តឯករាជ្យទាំងយប់ងងឹតមើលមិនយល់។ ឃើញភាពខ្លោចផ្សាយ៉ាងដូច្នេះ ខ្ញុំប្រញាប់បន្ទាបខ្លួនដើរឱនៗទៅបាំងនឹងដើមត្នោតធំមួយដើមកុំឲ្យកងឈ្លបឃើញ។ ខ្ញុំបានឮស្ត្រីវ័យ ជាង ៤០ឆ្នាំម្នាក់យំអង្វរកងឈ្លបថា «មិត្តអើយមិត្ត! ពួកខ្ញុំមិនដឹងអីទេ ហេតុអីអង្គការចោទពួកខ្ញុំថាខ្មាំង? កូនខ្ញុំតូចៗវាមិនដឹងអីទេ សូមមិត្តមេត្តាឲ្យបាយវាហូបផង វាឃ្លានខ្លាំងណាស់»។ ឯស្ត្រីខ្លះទៀតក្នុងភាពរងាញ័រញាក់ដោយទទឹកភ្លៀងនោះ គិតតែទ្រហោយំរៀបរាប់ថា «អ្នកណាខុសសម្លាប់អ្នកនោះទៅ ខ្ញុំមិនពាក់ព័ន្ធនឹងប្តីជាប់និន្នាការទាហាននោះទេ ខ្ញុំនៅតែផ្ទះមិនដឹងអីសោះ ហេតុអីអង្គការចាត់ទុកខ្ញុំជាខ្មាំង? លែងខ្ញុំទៅមិត្តខ្ញុំសុំអង្វរ»។ ចំណែកស្ត្រីពិការជើងម្នាក់ទៀត ដើរស្ពាយបង្វេចមួយជាប់នឹងខ្នងស្រែកយំឮជាងគេ ព្រោះដឹងថាអង្គការយកខ្លួនទៅសម្លាប់។ គាត់បានស្រែកខ្លាំងៗថា « លោកអើយ!មើលចុះ ខ្មែរសម្លាប់ខ្មែរ»។ សម្រែកនេះធ្វើឲ្យឈ្លបម្នាក់ដែលដើរនៅជួរកណ្តាលគំហកឲ្យស្ត្រីនោះថា «អង្គការមិនមែនសម្លាប់ខ្មែរទេ គឺសម្លាប់ខ្មាំង»។ មួយសន្ទុះ ពួកគេបានដើរផុតពីខ្សែភ្នែករបស់ខ្ញុំបាត់ទៅ។ ប្រហែលជាជាងកន្លះម៉ោង ក្រុមស្ត្រីនិងក្មេងៗ ត្រូវកងឈ្លបយកទៅឃុំខ្លួនក្នុងបន្ទប់ថ្នាក់រៀននៃសាលាបឋមសិក្សាឯករាជ្យ នៅទល់មុខមន្ទីរឃុំ ស្ថិតក្នុងវត្តឯករាជ្យ។ ពួកគេបានស្រែកទ្រហោយំយ៉ាងទ្រហឹងទាំងក្មេង និងមនុស្សចាស់ថា «ម៉ែអើយកូនឃ្លានបាយណាស់!» ឯស្ត្រីជាម្តាយបានត្រឹមអង្វរសមមិត្តកងឈ្លបថា «មិត្តអើយ មុននឹងស្លាប់មេត្តាឲ្យបាយកូនខ្ញុំហូបមួយចម្អែតមក» ហើយអ្នកខ្លះទៀតអស់សង្ឃឹមក្នុងជីវិតក៏ស្រែកឮខ្លាំងៗលែងខ្លាចស្លាប់ថា «អ្នកមានបុណ្យអើយ ជួយជីវិតខ្ញុំផង»។

ខ្ញុំបានបិទភ្នែកទទួលការឈឺចាប់ជំនួសពួកគេដែលគ្មានកំហុស ហើយខ្ញុំចេះតែគិតថាស្អែកឬខានស្អែកដល់វេនខ្ញុំម្តងហើយ។ បន្ទាប់មក ខ្ញុំបានចាកចេញពីដើមត្នោតដើរសំដៅទៅកាន់កន្លែងចាំស្រូវទាំងយប់ងងឹតសូន្យ ហើយដោយអស់កម្លាំងខ្លាំងពេក ខ្ញុំបានសុំលោកតាដែលចាំស្រូវជាមួយគ្នាដេកមុន។ គ្រាន់តែបិទភ្នែកបានមួយសន្ទុះ ស្រាប់តែឮសំឡេងមនុស្សស្រែកយំល្វើយៗមកប៉ះត្រចៀកខ្ញុំក្នុងចម្ងាយប្រហែលជាជិត១០០ម៉ែត្រពីរោង។ សំឡេងនោះបានស្រែកថា «ម៉ែអើយ! ជួយកូនផង! តើខ្ញុំមានកំហុសអីបានជាសម្លាប់ខ្ញុំ? សម្លាប់ខ្ញុំចុះ កុំសម្លាប់កូនខ្ញុំអី! លោកអ្នកមានបុណ្យអើយមកជួយខ្ញុំផង ខ្ញុំមិនបំភ្លេចគុណអ្នកទេ»។ ពេញមួយយប់ ខ្ញុំពិតជារន្ធត់នឹងសម្រែកទាំងនេះណាស់។ ខ្ញុំឱបលោកតាដែលដេកជាមួយខ្ញុំ រួចសួរទៅគាត់តិចៗថា «តើនេះជាសំឡេងអ្វី?»។ លោកតាបានតបតិចៗស្តាប់ស្ទើរមិនឮមកខ្ញុំវិញថា «អង្គការសម្លាប់មនុស្សដែលត្រូវចោទថាជាខ្មាំង»។ ខ្ញុំក៏សួរគាត់ទៀតថា «តើខ្មាំងទាំងនេះជាស្ត្រី និងក្មេងៗដែលអង្គការនាំមកពីតំបន់២៤ កាលពីព្រលប់មែនទេ?»។ លោកតា ក៏ងក់ក្បាលជាក់ខ្ញុំ។ ខ្ញុំកាន់តែរន្ធត់ និងស្លុតចិត្តមែនទែន ហើយខ្ញុំក៏ទាញភួយកញ្ជាស់មករុំខ្លួនកុំឲ្យញ័រញាក់ រួចប្រឹងបិទភ្នែកដេកទាល់តែលក់។

លុះព្រលឹមស្រាងៗឡើង ខ្ញុំបានជម្រាបលាលោកតា ដើម្បីយកស្បៀងអាហារទៅការដ្ឋានវាយថ្មឯភ្នំឈើកាច់វិញ។ ខ្ញុំបានចាកចេញពីខ្ទម ហើយលួចសម្លឹងមើលទៅក្រោមដើមខ្វិតធំមួយដើមនៅចម្ងាយជាង ១០០ម៉ែត្រ ពីរោងដែលខ្ញុំដេក។ កន្លែងនោះគឺជាកន្លែងដែលឮសំឡេងសម្លាប់មនុស្សកាលពីយប់មិញ។ ខ្ញុំឃើញទង់ជាតិពណ៌ក្រហមមួយកំពុងបក់រវិចៗ តាមជំនោរខ្យល់ដោតដោយដងឫស្សីកម្ពស់ជាងពីរម៉ែត្រពីដី ។ ខ្ញុំក៏ឃើញកងឈ្លប ៤នាក់ កំពុងកាយដីកប់រណ្តៅសាកសពទាំងនោះ។ ពេលដើរទៅកាន់រោងបាយ ដើម្បីយកស្បៀងទៅហូប ខ្ញុំឃើញបន្ទប់សាលារៀន ដែលឃុំឃាំងមនុស្សកាលពីព្រលប់បាត់មនុស្សអស់រលីង ហើយឃើញតែក្រណាត់អាវ សំពត់ ដែលសេសសល់តិចតួច ត្រូវខ្យល់បើងចេញពីបន្ទប់ថ្នាក់រៀននោះ។ ចាប់តាំងពីពេលនោះមក ខ្ញុំនៅធ្វើការវាយថ្មនៅភ្នំឈើកាច់ជារៀងរហូត ហើយមិនដែលបានវិលត្រលប់មកមូលដ្ឋានភូមិអាគ្រាជវិញនោះទេ។

នៅអំឡុងឆ្នាំ១៩៧៩ នៅតាមព្រំដែនខ្មែរនិងវៀតណាម ក្នុងខេត្តព្រៃវែង និងស្វាយរៀង សំឡេងផ្ទុះអាវុធប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហម បានកើតមានយ៉ាងក្តៅគគុក។ ពីមួយថ្ងៃទៅមួយថ្ងៃ កងទ័ពខ្មែរក្រហមស្លាប់ និងរបួសជាច្រើននាក់ ហើយអ្នកស្លាប់នោះ ត្រូវបានកងទ័ពផ្សេងទៀតសែងនឹងអង្រឹងមកកប់ក្នុងបូជនីយដ្ឋានក្បាលថ្នល់ ដែលបច្ចុប្បន្នជាវិទ្យាល័យកំពង់ត្របែក។ ចំណែកនៅភូមិភាគបូព៌ា ខេត្តកំពង់ចាម និងក្រចេះ វិញ ចលនាអ្នកតស៊ូ ក៏បានកម្រើកឡើងប្រឆាំងនឹងរបបខ្មែរក្រហម ធ្វើឲ្យមានការរង្គោះរង្គើពេញផ្ទៃប្រទេស។

ថ្ងៃមួយខណៈពេលដែលខ្ញុំ កំពុងគាស់រម្លើងជុំថ្មធំៗនៅលើកំពូលភ្នំឈើកាច់ ទម្លាក់ទៅដី ខ្ញុំបានឃើញយន្តហោះមួយគ្រឿងហោះយ៉ាងខ្ពស់ បាចត្រាក់សព្រាតពេញផ្ទៃមេឃ ដែលវាជាត្រាក់របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិ ក្រោមការដឹកនាំតស៊ូរំដោះជាតិពីរបបខ្មែរក្រហម។ មិនបានប៉ុន្មានផង សំឡេងរថក្រោះរបស់វៀតណាមជាច្រើនគ្រឿង បានលូនចូលមកសន្សឹមៗតាមបណ្តោយផ្លូវជាតិលេខ១ ពីព្រំប្រទល់ប្រទេសវៀតណាមនិងខេត្តស្វាយរៀង ឆ្ពោះទៅក្រុងភ្នំពេញ រួមជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ ដែលមានទង់ជាតិសម្គាល់ប្រាសាទកំពូល៥ បក់រវិចៗមកជាមួយផង។ សកម្មភាពទាំងនេះ បានធ្វើឲ្យក្រុមកងទ័ពខ្មែរក្រហមបាក់ទ័ពរត់ចោលជួរអស់។ ខ្ញុំត្រេកអរណាស់ព្រោះមានអ្នកមកជួយរំដោះប្រទេសជាតិនិងប្រជាជន។ ខ្ញុំប្រញាប់ចាកចេញពីភ្នំឈើកាច់មកដល់តំបន់អ្នកលឿងនៅម៉ោងប្រហែល ៦ល្ងាច។ ពេលនោះ ខ្ញុំឃើញកងទ័ពខ្មែរក្រហម កំពុងតែភ័យបាក់ស្បាតដណ្តើមគ្នារត់ឡើងសាឡាងដែលមានតែមួយគ្រឿងរួមជាមួយរថយន្តសណ្តោងកាំភ្លើងយន្តបាញ់យន្តហោះ ៣ទៅ៤គ្រឿង នៅលើសាឡាង។ សាឡាងមិនបង្គង់យូរក៏ប្រញាប់ចាកចេញពីច្រាំងទន្លេទាំងតក់ក្រហល់ ធ្វើឲ្យរថយន្តកងទ័ពរបស់ខ្មែរក្រហមមួយចំនួនទៀតឡើងសាឡាងមិនទាន់ក៏ជ្រុលល្បឿនធ្លាក់ចូលក្នុងទឹកទន្លេលិចទឹកបាត់អស់។ រីឯកងទ័ពថ្មើរជើងវិញនាំគ្នាកាប់ដើមចេកនិងស្ពាយកាំភ្លើងម្នាក់មួយដើមៗ ហែលឆ្លងទឹកទន្លេមេគង្គឆ្ពោះទៅទិសខាងលិចដោយខ្លះ

ហែលរួចខ្លួន និងខ្លះទៀតលង់ទឹកស្លាប់កណ្តាលទន្លេក៏មានដែរ។ ក្នុងនោះដែរ ឃ្លាំងអាវុធដ៏ធំមួយកន្លែងរបស់កងទ័ពខ្មែរក្រហមនៅខាងជើងតំបន់អ្នកលឿង ត្រើយខាងកើត ត្រូវដុតបំផ្លាញចោលទាំងស្រុងធ្វើឲ្យផ្ទុះកក្រើករហូតដល់ភ្លឺ។ ជាឱកាសល្អមួយ ខ្ញុំ បានលូនចេញពីតំបន់អ្នកលឿង ព្រោះខ្ញុំខ្លាចគ្រាប់កាំភ្លើងហោះមកត្រូវ ហើយធ្វើដំណើរឆ្ពោះទៅទិសបូព៌ា ដែលជាភូមិកំណើតរបស់ខ្ញុំ។ លុះពេលព្រឹកស្អែកឡើងត្រូវជាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានឮដំណឹងថា ទីក្រុងភ្នំពេញ បានរំដោះទាំងស្រុង។ ដំណឹងនេះធ្វើឲ្យខ្ញុំ និងប្រជាជនផ្សេងទៀត មានក្តីរំភើបឥតឧបមា។ ខ្ញុំចាត់ទុកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាទឹកភ្លៀងលាងគុកឥតជញ្ជាំង។

ចប់

៤៥

រឿង នរក ភ្នែកស្រស់

អ្នកនិពន្ធ ៖ ហុង ឥណ្ណាសុធីរ

៤៥ ~ រឿង នរកភ្នែកស្រស់

ថ្ងៃមួយអំឡុងខែកក្កដា ឆ្នាំ២០០៥ ម៉ាក់ ម៉ាក់យាយ និងអ៊ំអ្នកជិតខាងពីរបីនាក់ បាននាំគ្នាអង្គុយ នៅមុខទូរទស្សន៍រាងបួនជ្រុងមួយដោយការតាំងចិត្តស្តាប់យ៉ាងយកចិត្តទុកដាក់ចំពោះកម្មវិធីទូរទស្សន៍ដែលកំពុងតែចាក់ផ្សាយ។ ពេលនោះ ខ្ញុំមានអាយុត្រឹមតែ ១២ឆ្នាំ ប៉ុណ្ណោះ ប៉ុន្តែខ្ញុំអាចដឹងបានថា កម្មវិធីទូរទស្សន៍ គឺកំពុងចាក់ផ្សាយពីការបើកសវនាការកាត់ក្តីលោក កាំង ហ្គិកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរស-២១ ឬគុកទួលស្លែង នៅក្នុងរបបខ្មែរក្រហម។

ពេលនោះ ខ្ញុំពិតជាមិនបានចាប់អារម្មណ៍នូវអ្វីដែលចាស់ៗកំពុងនិយាយគ្នាសោះឡើយ ព្រោះខ្ញុំមិនទាំងដឹងផងថា ឌុច គឺជានរណានោះទេ។ វាចំណាយពេលយូរខ្លាំងណាស់ ទម្រាំតែការកាត់ក្តីបានចេញលទ្ធផល។ ម៉ាក់យាយរបស់ខ្ញុំដែលធ្លាប់តែស្ងប់ស្ងាត់ ក៏ស្រាប់តែនិយាយឡើងដោយសំឡេងញ័រទេទ្រើតថា៖

«មនុស្សអាក្រក់បែបនេះ ទោះជាជាប់គុកមួយជីវិតក៏មិនសមដែរ បើសិនជាវាមកឈរនៅត្រង់នេះ អញមុខតែវាយវាឲ្យស្លាប់ហើយ»។

ឮដូច្នោះ ម៉ាក់របស់ខ្ញុំតបថា៖

«កុំរន្ធត់ចិត្តពេកម៉ែ យ៉ាងណាជាប់គុកមួយជីវិតនេះក៏បានដែរ គាត់នឹងបានចំណាយពេលនៅក្នុងគុក ហើយក្បាក់រឭកពីកំហុសរបស់គាត់»។

ម៉ាក់យាយរបស់ខ្ញុំកាន់សាសនាព្រះពុទ្ធ។ គាត់ចូលចិត្តធ្វើបុណ្យ ហើយមានចិត្តល្អខ្លាំងណាស់ ប៉ុន្តែថ្ងៃនេះគាត់បែរជាបង្ហាញពីភាពស្អប់ កំហឹង និងការគុំកួន ទើបខ្ញុំទ្រាំមិនបានក៏សួរគាត់ថា៖

«ម៉ាក់យាយខឹងគាត់ខ្លាំងម្ល៉េះ! ម៉េចបានចង់ឲ្យគាត់ស្លាប់?»

ម្តាយរបស់ខ្ញុំ ដកដង្ហើមធំមើលមុខខ្ញុំ ហាក់បីដូចជាចង់ពិចារណាថាតើគួរនិយាយប្រាប់ខ្ញុំឬអត់។ គាត់នៅស្ងៀមមួយសន្ទុះ ទើបនិយាយប្រាប់ខ្ញុំដោយទឹកមុខស្លូតថា៖

«ម៉ាក់ ប៉ា ម៉ាក់យាយ អ៊ំ ពូ មីងរបស់កូន សុទ្ធតែជនរងគ្រោះ ដែលនៅរស់ពីសម័យ ប៉ុល ពត»។

ម៉ាក់របស់ខ្ញុំនិយាយប្រាប់ខ្ញុំយឺតៗ ព្រមទាំងអង្អែលស្មាញ័រទេទ្រើតរបស់ម៉ាក់យាយ ជាការលួងលោម។ ម៉ាក់យាយដោះវ៉ែនតាចេញ ហើយក៏យំតិចៗ ព្រោះគាត់ទប់អារម្មណ៍មិនបាននៅពេលដែលម្តាយរបស់ខ្ញុំនិយាយរឿងរ៉ាវទាំងអស់នោះឡើងវិញ។ ខ្ញុំបានសួរទៅម៉ាក់របស់ខ្ញុំបន្តដោយចង់ដឹងអំពីរឿងរ៉ាវទាំងអស់នោះថា៖

«នៅពេលនោះ តើមានរឿងអីកើតឡើងខ្លះម៉ាក់?»

ម៉ាក់របស់ខ្ញុំតបថា៖

«និយាយទៅ ម៉ាក់មិនដឹងថាកូនអាចយល់ដែរឬទេបើសិនជាពួកយើងនិយាយពីភាពឈឺចាប់ទាំងនោះ តែម៉ាក់ចង់ឲ្យកូនដឹង ហើយធ្វើយ៉ាងណាកុំឲ្យរឿងអកុសលទាំងនោះកើតឡើងសារជាថ្មីម្តងទៀត»។

ម៉ាក់ខ្ញុំដកដង្ហើមធំម្តងទៀត ហាក់ដូចជាកំពុងខំប្រឹងទប់ការឈឺចាប់ដែលគាត់នៅចងចាំ និងភ័យខ្លាច។ គាត់និយាយរៀបរាប់ ព្រមទាំងងាកទៅមើលម៉ាក់យាយជារឿយៗ។ ម៉ាក់បន្តថា៖

«លោកតារបស់កូន គឺជាអ្នកមានចំណេះចេះដឹងម្នាក់ទទួលបានការគោរពមនុស្សជាច្រើន។ គាត់ជាគ្រូបង្រៀនដល់ព្រះសង្ឃ។ មនុស្សគ្រប់គ្នាហៅលោកតាថាតេជគុណ។ ក្រុមគ្រួសាររបស់យើងពីមុន ជាគ្រួសារមានមុខមាត់ខ្លាំងណាស់។ ឯម៉ាក់យាយ គឺជាកូនចៅចិនដែលកាលពីដំបូងៗ គាត់មិនទាំងចេះនិយាយខ្មែរផង។ ពេលខ្មែរក្រហមចូលមកដំបូង ខ្មែរក្រហមបានសន្យាថា នឹងធ្វើឲ្យប្រទេសកម្ពុជាគ្មានអ្នកមាន គ្មានអ្នកក្រ មានតែភាពស្មើគ្នា។ ពួកយើងក៏ចង់បានសង្គមបែបនោះដែរ ព្រោះយើងមិនចង់ឲ្យមានការរើសអើងវណ្ណៈនិងអំពើពុករលួយឡើយ។»។

បន្ទាប់ពីបានសម្រួលអារម្មណ៍ខ្លះ ម៉ាក់យាយស្រាប់តែនិយាយឡើងកាត់សម្តីម៉ាក់របស់ខ្ញុំ ហាក់ចង់ឲ្យខ្ញុំបានដឹងថា ទោះជាកន្លងមកយូរយ៉ាងណាក៏ដោយ ក៏គាត់មិនអាចភ្លេចពេលវេលាទាំងនោះបានដែរ។

«ម្តាយចៅឯង ត្រូវបានជាក់បញ្ចូលទៅក្នុងកងកុមារ ឯយាយនៅធ្វើការជាមួយអ្នកផ្សេងទៀត។ មួយថ្ងៃៗ យាយនៅតែនឹងស្រែ ធ្វើការដូចជាសត្វ ដើម្បីឲ្យសម្រេចបានតាមការកំណត់របស់អង្គការ ប៉ុន្តែយើងធ្វើយ៉ាងម៉េចក៏ធ្វើមិនគ្រប់ដៃរការងារពីមួយថ្ងៃទៅមួយថ្ងៃកាន់តែច្រើនទៅៗ រកតែពេលដកដង្ហើមមិនបាន គ្មានពេលបានមើលកូនមើលចៅ គ្មានអាហារហូបគ្រប់គ្រាន់ ព្រោះសូម្បីតែដំឡូងដែលយើងដាំបានដោយខ្លួនឯង ក៏យើងគ្មានសិទ្ធិហូបផង»។

ខ្ញុំសួរទៅកាន់ម៉ាក់យាយថា៖

«ហេតុអីទៅយាយ? របស់ដាំខ្លួនឯងសោះ ម៉េចក៏ហូបមិនបាន? ចង់ទុកចោលឲ្យខូចឬយ៉ាងម៉េច?»

ម៉ាក់យាយ៖ «មិនបានទេកូនទោះជាអ្វីក៏ដោយ ក៏ជារបស់អង្គការដែរបើយើងហ៊ានហូបឬចោល យើងអាចត្រូវចោទថា ក្បត់អង្គការ និងត្រូវយកទៅរៀនសូត្រ»។

ខ្ញុំបានបន្តសួរទៅម៉ាក់របស់ខ្ញុំថា៖

«ម៉ាក់ធ្លាប់បានឃើញអង្គការឬទេ? អង្គការមិនមែនមនុស្សទេ វាជាទីកន្លែងទេតើ?»

ម៉ាក់៖ «គ្មាននរណាធ្លាប់បានឃើញថា អង្គការជាអ្វី ប៉ុន្តែរាល់ពេលដែលយើងធ្វើទង្វើដែលមិនត្រូវតាមការចង់បានរបស់អង្គការ កងឈ្លបនឹងនិយាយដាក់យើងថា យើងកំពុងតែក្បត់អង្គការ ហើយលទ្ធផលដែលយើងបានមកវិញពីការមិនធ្វើតាមអង្គការ គឺការធ្វើទារុណកម្មនិងសម្លាប់»។

ខ្ញុំ៖ «ដល់ថ្នាក់ស្លាប់ផង?»។ ខ្ញុំ ភ្ញាក់ផ្អើលណាស់ពេលឮដូច្នោះ។ វាពិតជាមិនសមហេតុផលទាល់តែសោះហើយ ដែលជីវិតមនុស្សត្រូវចាត់ទុកដូចជាជីវិតសត្វបែបនេះ។ បើគ្រាន់តែខុសទាស់តិចតួច ក៏គួរតែអភ័យឲ្យគ្នា តើសង្គមនោះគួរឲ្យខ្លាចយ៉ាងណាទៅ?

ម៉ាក់យាយ៖ «យាយធ្វើការធ្ងន់ខ្លាំងណាស់ ប៉ុន្តែអង្ករដែលបានផ្តល់ឲ្យយើងតែបន្តិចបន្តួចប៉ុណ្ណោះ។ វាមិនគ្រប់គ្រាន់សម្រាប់ឲ្យគ្រួសារ ដែលមានមនុស្សដល់ទៅ១០នាក់ អាចហូបបានគ្រប់នោះទេ ទើបយាយយកអង្ករខ្លះទៅដាំលាយជាមួយនឹងផ្លែចេកខ្ចី ដែលលួចលាក់ទុក។ ទោះជាមិនបានឆ្អែតដូចហូបបាយក៏ពិតមែន ប៉ុន្តែនៅគ្រាន់ជាងបបរអាវដែលមានអង្ករតែពីរបីគ្រាប់ដែរ»។

ខ្ញុំសម្លឹងមើលមុខម៉ាក់យាយ ដែលភ្នែករបស់គាត់ងងឹតមើលអ្វីមិនឃើញទៀតឡើយ។ មកទល់សព្វថ្ងៃនេះ គាត់លែងមើលអ្វីឃើញទាល់តែសោះ។ គាត់ចាំចៅបានដោយសារសំឡេងរបស់ពួកយើង។ ភ្នែករបស់គាត់ភ្លាយជាងងឹតមើលអ្វីមិនឃើញច្បាស់ ក៏អាចមកពីផលប៉ះពាល់នៃការទទួលបានជីវជាតិអាហារមិនបានគ្រប់គ្រាន់ក្នុងពេលដែលគាត់រស់នៅក្នុងរបបខ្មែរក្រហមដែរ។

ម៉ាក់របស់ខ្ញុំក៏បន្តរៀបរាប់ទៀតថា៖

«ម៉ាក់ត្រូវដាក់នៅក្នុងកងកុមារ។ អង្គការតម្រូវឲ្យម៉ាក់ស្នងស្រូវ ប៉ុន្តែម៉ាក់មិនចេះទេ ទើបមានកងឈ្លបតាមដានម៉ាក់ជានិច្ច។ កងឈ្លបគិតថាម៉ាក់ជាកូនអ្នកមាន ឬអ្នកមកពីទីក្រុងដែលនេះមិនមែនជារឿងល្អនោះទេ ព្រោះខ្មែរក្រហមមិនចូលចិត្តអ្នកមានឡើយ។ បើសិនជាយើងមិនចេះធ្វើអ្វីទេ យើងក៏អាចប្រឈមមុខនឹងការចោទប្រកាន់ថាខ្ជិលនិងគ្មានប្រយោជន៍ដល់អង្គការ ហើយអាចត្រូវនាំទៅរៀនសូត្រ។ ដូច្នោះហើយទើបម៉ាក់លួចទៅរៀនពីអ្នកស្រុក។ អ្នកស្រុកប្រាប់ម៉ាក់ថា ម៉ាក់ត្រូវធ្វើការឲ្យបានលឿន និងធ្វើការឲ្យដូចម៉ាស៊ីន ដើម្បីរក្សាជីវិតបានរស់»។

ខ្ញុំ៖ «ម៉ាក់ចុះលោកតា?»

ពេលខ្ញុំសួររួច ខ្ញុំសង្កេតឃើញទឹកមុខម៉ាក់និងម៉ាក់យាយ ប្រែជាស្រពោនមួយរំពេច។ ខ្ញុំពិតជាចង់វាយមាត់ខ្លួនឯងខ្លាំងណាស់។ ឮខ្ញុំសួរពីលោកតា ម៉ាក់យាយស្រាប់តែយំដូចទឹកបាក់ទំនប់។ ភ្នែករបស់គាត់មិនល្អនោះទេ បើសិនជាយំខ្លាំងពេកអាចធ្វើឲ្យឈឺភ្នែកបាន។

ម៉ាក់៖ «ម៉ាក់នៅចាំថា មានពេលមួយនោះ កូនចៅរបស់លោកតា បានជួបលោកតា ក៏លើកដៃសំពះ ព្រមទាំងហៅលោកតាថា តេជគុណ។ ពេលនោះ

ប្រហែលជាមានកងឈ្លប បានឮ ទើបកូនចៅរបស់លោកតាម្នាក់នោះ ត្រូវកងឈ្លបចាប់ខ្លួន។ ក្រោយមក លោកតា ក៏ត្រូវចាប់ខ្លួនដែរ។ ម៉ាក់ចាំបានថា នៅយប់មួយនោះ មានកងឈ្លបខ្មែរក្រហម ចំនួន ៣នាក់ បានទៅរកលោកតា ហើយប្រាប់ថា អង្គការត្រូវការយកលោកតាទៅរៀនសូត្រ។ ពួកយើងសុទ្ធតែដឹងថា ពាក្យនោះមានន័យថាម៉េច ប៉ុន្តែពួកយើងមិនអាចយំបានទេ។ យើងចង់ឃាត់លោកតាទុកក៏មិនបាន។ លោកតា ព្រមចាកចេញទៅតាមកងឈ្លប។ គាត់គ្រាន់តែផ្តាំកូនៗឲ្យចេះស្រលាញ់គ្នា ហើយត្រូវមើលថែម៉ាក់យាយដែលកំពុងមានផ្ទៃពោះផង។

ម៉ាក់របស់ខ្ញុំយំយ៉ាងខ្លាំងពេលគាត់និយាយរួច។ គាត់ប្រាកដជាឈឺចាប់ខ្លាំងណាស់ហើយ ដែល បាត់បង់ឪពុកតាមរបៀបនេះ។ ការបាត់បង់សមាជិកក្នុងគ្រួសារ ទោះដោយហេតុផលណាមួយក៏ដោយ សុទ្ធតែជារឿងឈឺចាប់ ដែលពុំអាចយកអ្វីមកវាស់បានឡើយ។ កាលបើឃើញម៉ាក់របស់ខ្ញុំយំហើយយំទៀតយ៉ាងនេះ កាន់តែធ្វើឲ្យខ្ញុំអាណិតគាត់យ៉ាងខ្លាំង។ ខ្ញុំមិនអាចយល់ពីជម្រៅនៃការឈឺចាប់របស់គាត់បាននោះទេ។ ខ្ញុំមិនដឹងថាតើគាត់ត្រូវទ្រាំនឹងភាពឈឺចាប់ ភាពភ័យខ្លាច និងការបាត់បង់ច្រើនប៉ុណ្ណា។

ខ្ញុំ៖ «ម៉ាក់កុំយំ មនុស្សសាងបាបបែបនោះ មុខជាចុះនរកហើយ»។

ម៉ាក់យាយ៖ «ចៅឯងធ្លាប់ឮអ្នកស្លាប់ណាម្នាក់មកនិយាយរៀបរាប់ពីនរកថាយ៉ាងម៉េចឬអត់?យាយបានជួបហើយនរកនោះ មិនចាំបាច់ទាល់តែពេលស្លាប់នោះទេ ព្រោះយាយអាចប៉ះបានគ្រប់យ៉ាង មើលឃើញពីការស្លាប់ ការភ័យខ្លាច រស់នៅហាក់ដូចជាគិតតែពីសេចក្តីស្លាប់ សូម្បីតែពេលដែលកូនខ្លួនឯងកើតមក ក៏មិនបានមើលថែឲ្យបានល្អ មិនបានងូតទឹក មិនបានហូបគ្រប់គ្រាន់ រាល់ថ្ងៃក្នុងខួរក្បាលមានតែពាក្យថា ស្លាប់ដោយមិនដឹងថាខ្លួនខុសអ្វី។ រូបភាពទាំងអស់នោះអាក្រក់ណាស់ទៅហើយ ប៉ុន្តែការដែលឃើញកូនខ្លួនឯងដែលមានអាយុទើបតែបីខែស្លាប់នៅក្នុងដៃ ហើយជួយអ្វីមិនបាន ហើយសូម្បីតែយំក៏ធ្វើមិនបាននោះទើបអាក្រក់ជាងរូបភាពទាំងអស់នោះទៅទៀត»។

ម៉ាក់និយាយរៀបរាប់បន្តទៀតថា ៖

«នៅសម័យនោះ ពួកយើងបានជួបសុបិន្តអាក្រក់ជាច្រើន អាក្រក់ជាងនរកទៅទៀត មនុស្សដែលធ្លាប់តែជាញាតិមិត្តនឹងគ្នា ក៏អាចកាប់សម្លាប់គ្នាបាន។ លោកតាកូនឯង គាត់អត់មានបានធ្វើអ្វីខុសសោះ តែបែរជាស្លាប់ដោយសារតែគាត់ជាអ្នកមានចំណេះដឹងខ្ពស់។ បើនិយាយពីលោកតាខាងប៉ាកូនឯងវិញ គាត់ក៏បាត់ខ្លួនទៅដោយគ្មាននរណាបានឃើញគាត់ដែរ។ ពួកយើងសន្មត់ថា គាត់បានស្លាប់ ព្រោះមានអ្នកឃើញគាត់ដើរតាមកងឈ្លបខ្មែរក្រហមចេញទៅ គ្រាន់តែយើងរកសាកសពរបស់គាត់មិនឃើញ»។

ខ្ញុំជឿថា ក្មេងជំនាន់ក្រោយដូចជាខ្ញុំ នៅពេលឮរឿងបែបនេះមុខជាលួចមានចិត្តគិតថា គាត់អាចកុហក ព្រោះវាមិនសមថា មានមនុស្សអាចធ្វើអំពើអាក្រក់បែបនេះ។

ខ្ញុំ ៖ «ម៉ាក់! អ៊ំផល ដែលមានស្មារតីមិនសូវល្អ ក៏ជាអ្នកដែលបានរួចខ្លួនដូចជាម៉ាក់ដែរឬ?»

អ៊ំផល ជាអ្នកជិតខាងរបស់យើង ដែលរស់នៅតែម្នាក់ឯង ព្រោះគាត់គ្មានសាច់ញាតិទេ។ យើងតែងតែជាក់វេនគ្នាយកម្ហូបអាហារឲ្យគាត់រៀងរាល់ថ្ងៃ។ យើងជាក្មេងៗខ្លាចគាត់ខ្លាំងណាស់ ព្រោះគាត់ចូលចិត្តស្រែកស្តីបន្ទោសឮៗដល់អ្នកណាក៏មិនដឹងជារៀងរាល់ថ្ងៃ។ ពេលខ្លះគាត់យំដល់សន្លប់ និងមានពេលខ្លះទៀត គាត់ក៏ដើរតាមមនុស្សប្លែកមុខ ព្រោះគិតថាជាកូនរបស់គាត់។

ម៉ាក់ ៖ «អ៊ំផល គាត់ជួបរឿងឈឺចាប់ខ្លាំងណាស់ ម៉ាក់មិនអាចនិយាយរឿងគាត់ទាំងស្រុងប្រាប់កូនបានទេ ព្រោះកូននៅមិនទាន់អាចយល់ពីរឿងអាម៉ាស់ទាំងនោះ។ កូនគ្រាន់តែដឹងថា អ៊ំគាត់បានបាត់បង់សមាជិកគ្រួសារទាំងអស់។ ប្តី និងកូនទាំងប្រាំនាក់របស់គាត់ ត្រូវខ្មែរក្រហមបាញ់សម្លាប់ម្តងម្នាក់ៗនៅនឹងមុខរបស់គាត់ ហើយអ៊ំផល ក៏ត្រូវខ្មែរក្រហមធ្វើបាបទៀតផង គ្មាននរណាម្នាក់ហ៊ានជួយទេ។

ម៉ាក់យាយ ៖ «រយៈពេលជាងបីឆ្នាំ ប្រជាជនគ្រប់គ្នារស់នៅក្នុងសង្គមមួយដែលគ្មានសាសនា គ្មានអ្នកចេះដឹង គ្មានសាមគ្គីភាពនឹងគ្នា គ្មានអនាម័យ ជីវិត

មនុស្សមានតម្លៃអន់ជាងជីវិតសត្វទៅទៀត។ យាយពិតជាធ្លាប់មានគំនិតចង់ស្លាប់មិនតិចដងនោះទេក្នុងមួយថ្ងៃៗ ប៉ុន្តែកូនតូចទាំងអស់ត្រូវការយាយ។ បើសិនជាយាយទៅបាត់ទៀត តើនរណានឹងមើលថែកូនតូចៗនេះ? ហេតុនេះហើយ ទោះថាថ្ងៃស្អែកអាចនឹងត្រូវស្លាប់ឬក៏អត់ យាយមានតែស៊ូក្នុងចិត្តលួចបន់វត្ថុស័ក្តិសិទ្ធិគ្រប់យ៉ាងឲ្យផុតពីសេចក្តីលំបាកអស់នេះ»។

ម៉ាក់យាយតួញភ្ជែរពីទុក្ខលំបាករបស់គាត់ មើលទៅអាចជួយឲ្យគាត់ធូរស្បើយចិត្តបានយ៉ាងច្រើននៅពេលនិយាយចេញមក។ ចំណែកឯម្តាយរបស់ខ្ញុំវិញ ដកដង្ហើមវែងៗ រួចក៏យកដៃមកអង្អែលក្បាលខ្ញុំស្រាលៗ។ គាត់ញញឹមទាំងទឹកភ្នែក។ ខ្ញុំក៏យកដៃជូតទឹកភ្នែករបស់គាត់។ ទោះបីជាខ្ញុំជូតទឹកភ្នែករបស់គាត់យ៉ាងណាក៏នៅតែជូតមិនអស់ឡើយ។

ម៉ាក់៖ «ម៉ាក់មិនចង់គិតទេថាបើម៉ាក់មានកូនៗសម័យនោះ តើដើមទ្រូងម្តាយនឹងឈឺចាប់យ៉ាណាទេ? កូនក្មេងនៅពេលនោះទោះជាបានរៀន តែមិនបានរៀនអ្វីច្រើនក្រៅតែពីរឿងរ៉ាវរបស់អង្គការនោះទេ។ ក្មេងៗចេះអក្សរតិចតួចតែប៉ុណ្ណោះ ព្រោះអង្គការមិនត្រូវការអ្នកចេះដឹងទេ»។

ខ្ញុំ៖ «ម៉ាក់! ចុះហេតុអ្វីក៏មិននាំគ្នារត់? រត់ទៅប្រទេសជិតៗឲ្យគេជួយយើងទៅ?»

ម៉ាក់របស់ខ្ញុំតបសំណួររបស់ខ្ញុំយ៉ាងចិត្តត្រជាក់បំផុត ទោះជាខ្ញុំសួរច្រើនយ៉ាងណា ក៏គាត់នៅតែព្យាយាមពន្យល់ខ្ញុំយ៉ាងអត់ធ្មត់ដែរ។

ម៉ាក់៖ «មានមនុស្សជាច្រើនបានព្យាយាមរត់ ជាពិសេសប្រជាជនដែលត្រូវបានចាត់តាំងឲ្យទៅរស់នៅតាមតំបន់ជាយដែន ប៉ុន្តែអ្នកដែលលួចរត់បានសម្រេចមានមិនច្រើននោះទេ។ អ្នកខ្លះត្រូវស្លាប់តាមផ្លូវដោយសារអត់អាហារ អ្នកខ្លះត្រូវសម្លាប់នៅពេលចាប់បាន អ្នកខ្លះដើរជាន់គ្រាប់មីនផ្ទុះស្លាប់ក៏មាន»។

ម៉ាក់រៀបរាប់បន្តទៀតថា៖

«ម៉ាក់ សប្បាយចិត្តបំផុត ហាក់ដូចជាបានកើតជាថ្មីម្តងទៀតអីចឹងនៅពេលយើងត្រូវបានរំដោះ ហើយម៉ាក់ក៏កាន់តែសប្បាយចិត្តដែលកូនៗអាចកើតមកនៅពេលដែលប្រទេសយើងលែងមានសង្គ្រាម។ យើងបានឆ្លងកាត់នូវ

ភាពយោរយៅមកឆ្អែតឆ្អន់ ហើយយើងមិនចង់ឲ្យវាកើតឡើងទៀតនោះទេ។ កូនដែលជាក្មេងៗត្រូវធ្វើយ៉ាងណា បន្តធ្វើឲ្យប្រទេសជាតិមានការអភិវឌ្ឍន៍ និងថែរក្សាសន្តិភាពនេះទុក»។

ម៉ាក់យាយ៖ «ត្រូវហើយចៅ ម៉ែឯងនិយាយត្រូវ កាលនោះ យាយសច្ចាក្នុងចិត្តហើយថានរណាក៏ដោយដែលចូលមករំដោះយើងបាន ទោះជាចង់ឲ្យយាយទៅបាញ់កាំភ្លើងតទល់ជាមួយខ្មែរក្រហម ទាំងដែលយាយមិនចេះ ក៏យាយព្រមដែរ សុំត្រឹមតែអាចបញ្ឈប់ភាពវេទនានៃការព្រាត់ប្រាស់នោះបាន»។

ម៉ាក់របស់ខ្ញុំបានណែនាំខ្ញុំបន្ថែមទៀតថា៖

«មានមនុស្សជាច្រើន ដែលនៅលាក់ទុករឿងរ៉ាវយោយៅទាំងនោះនៅក្នុងចិត្ត។ អ្វីដែលកូនបានឮពីម៉ាក់នៅពេលនេះ គឺគ្រាន់តែជារឿងរបស់គ្រួសារយើង ហើយវាគ្រាន់តែជាជ្រុងតូចមួយប៉ុណ្ណោះ។ នៅមានរឿងរ៉ាវជាច្រើនទៀតបានកើតឡើង គ្រាន់តែប្រជាជនខ្លះ មិនអាចនិយាយពីរឿងរ៉ាវរបស់ខ្លួនបាន ព្រោះការលើកយករឿងរ៉ាវនោះមកនិយាយ ប្រៀបដូចជាយកអំបិលមកជះលើស្នាមរបួសរបស់ខ្លួនឯងអីចឹង។ ទោះជាកន្លងហួសច្រើនឆ្នាំយ៉ាងណា ឬរហូតដល់ពេលដែលពួកយើងស្លាប់ទៅវិញ ក៏យើងគ្មានថ្ងៃភ្លេចរឿងទាំងអស់នោះបានដែរ។ នរកមួយនោះ នៅតែតាមលងបន្លាចយើងរហូត»។

ក្នុងនាមខ្ញុំជាក្មេងដែលកើតនៅក្នុងពេលដែលប្រទេសមានសន្តិភាព ខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាមិនចាប់អារម្មណ៍ពីរឿងប្រវត្តិសាស្ត្រឡើយ។ ខ្ញុំមិនធ្លាប់មើលសៀវភៅទាក់ទងនឹងប្រវត្តិសាស្ត្រ កាន់តែមិនធ្លាប់ធ្ងល់ថា ប្រទេសកម្ពុជាត្រូវឆ្លងកាត់អ្វីខ្លះទើបបានដូចសព្វថ្ងៃនេះ។ ទើបតែថ្ងៃនេះទេ ដែលខ្ញុំស្រាប់តែមានអារម្មណ៍ថា ខ្ញុំខ្មាសម៉ាក់យាយនិងម៉ាក់របស់ខ្ញុំជាខ្លាំង ដែលមិនបានផ្តល់តម្លៃដល់ការតស៊ូប្រឹងប្រែងរបស់គាត់។ ខ្ញុំពិតជាសោកស្តាយ ដែលខ្ញុំមិនអាចធ្វើអ្វីមួយសម្រាប់ជនរងគ្រោះពីរបបខ្មែរក្រហម បាន។

ចប់

៤៦

រឿង នរកលោកិយ៍ បីឆ្នាំច្បាយ

អ្នកនិពន្ធ ៖ មុត ឡោម

៤៦ ~ រឿង នរកលោកិយ៍បីឆ្នាំឆ្លាយ

វាសនា ពោលពាក្យមួយៗសម្លឹងមុខគូស្នេហ៍ដែលកំពុងតែរលីងរលោងទឹកភ្នែកអួលដើមកនិយាយទៅរកប្រុសស្នេហ៍មិនរួចថា «កត្តាទាំងពីរនេះ ឯងដែលបងបារម្ភខ្លាំងណាស់ តែទោះបីជាមានឧបសគ្គមករាំងយ៉ាងណាក៏ដោយ ឲ្យតែយើងនៅស្មោះនឹងគ្នា ស្រលាញ់គ្នា យើងទាំងពីរនាក់ នៅតែសុំផ្សងបានជួបគ្នាទាំងជាតិនេះ និងជាតិក្រោយទៀត កុំឲ្យយើងឃ្លាតពីគ្នាណា រចនា»។

ក្នុងខណៈពេលនោះ មានឡាន ៥គ្រឿង ផ្ទុកអ្នកដំណើរបានបើកមកដល់។ ឡានមួយគ្រឿងៗ មានមនុស្សចំនួន ៤នាក់ បានបើកចូលមកកាន់វត្តពោធិ៍ក្រឡាញ់។ អ្នកជិះស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ មានកន្សែងបង់កពណ៌ក្រហមពាក់ស្បែកជើងកង់ឡាន ពាក់មួកកាតិបពណ៌គគីរ ថែមទាំងមានកាំភ្លើងវែងខ្លីមកឈប់នៅក្នុងវត្ត។ ប្រជាពលរដ្ឋទាំងចាស់ ទាំងក្មេង ផ្អើលឈូឆរត់ប្រសេចប្រសាចពេញវត្ត។ ឯគូស្នេហ៍ទាំងពីរនាក់ ក៏មកមើលនឹងគេដែរ។ នៅពេលនោះ ស្រាប់តែឮសំឡេងបុរសម្នាក់មានឧធំខ្មៅ មានកាំភ្លើងខ្លីជាប់នៅនឹងចង្កេះ រួចយកឧបករណ៍បំពងសំឡេងមកប្រកាសក្តែងៗយ៉ាងខ្លាំងថា៖

«ពុកម៉ែទាំងអស់គ្នា កុំភិតភ័យ សមមិត្តបងយើងទាំងអស់គ្នានេះ ចុះមកតាមអង្គការ មហាលោតផ្លោះ ជាក់ទិសដៅឲ្យមកជួយសង្គ្រោះបងប្អូនឲ្យរួចផុតពីរបបសក្តិភូមិ លន់ នល់ ដែលប្រើអំណាចជិះជាន់ផ្តាច់ការមកលើពុកម៉ែ។ សូមពុកម៉ែ កុំភ័យបារម្ភ សប្បាយរីករាយបន្តទៀតចុះ។ អង្គការបានបើកឱកាសឲ្យពុកម៉ែបានសប្បាយចូលឆ្នាំម្តងទៀតចំនួន ៣ថ្ងៃ»។

ប្រជាជនទាំងអស់គ្នាសប្បាយរីករាយរំភើបក្នុងចិត្តឥតឧបមា ហើយឆ្ងល់គ្រប់គ្នាថា «តើទាហាន លន់ នល់ ទៅណាអស់ បានជាឲ្យពួកខោអាវខ្មៅខ្មែរក្រហមចូលមកបានស្រួលម្ល៉េះ ដោយគ្មានឮផ្ទុះអាវុធអ្វីសោះ»។ ម្នាក់ៗកំពុងតែឆ្ងល់គ្រប់គ្នា ស្រាប់តែមេខ្មែរក្រហមម្នាក់មានរាងទាបក្រអាញ ចាប់ក្បាលមេក្រូមកស្រែកប្រកាសបន្ថែមទៀតថា៖

«ខ្ញុំសូមគោរពពុកម៉ែបងប្អូនទាំងអស់គ្នា។ ស្ងាត់! ពុកម៉ែបងប្អូនកុំឆ្ងល់ឲ្យសោះ ពេលនេះប្រទេសជាតិយើងមានសន្តិភាពហើយ។ យើងបានវាយចូលទីក្រុងភ្នំពេញ។ អង្គការរបស់យើងបានគ្រប់គ្រងភ្នំពេញទាំងមូល។ យើងបានចូលកាន់កាប់ប៉ុស្តិ៍វិទ្យុជាតិ។ ទាហាន លន់ នល់ ទម្លាក់អាវុធចុះ។ យើងរួបរួមគ្នាកសាងប្រទេសជាតិ ដើម្បីសន្តិភាពបញ្ចប់សង្គ្រាមឥតមានអ្នកមាន អ្នកក្រ អ្នកជិះជាន់គេ និងអ្នកដែលត្រូវគេជិះជាន់ទៀតទេ។ យើងមានវណ្ណៈតែមួយគឺជាវណ្ណៈកម្មករ កសិករទាំងអស់គ្នា ដោយឥតមានវណ្ណៈសក្តិភូមិ វណ្ណៈមូលធននិយម ប្រើអំណាចផ្តាច់ការអ្វីទេ។ អង្គការយើងដឹកនាំប្រទេសជាតិរីកចម្រើន មហាលោតផ្លោះ មហាអស្ចារ្យ»។

ពេលនោះ សំឡេងទះដៃរបស់កងទ័ពខ្មែរក្រហម លាន់ឮព្រមៗគ្នា ហើយស្រែកជ័យឃោសខ្លាំងៗថា៖

«ជយោ!ជយោ! អង្គការមហាលោតផ្លោះ មហាអស្ចារ្យ!»។

ពេលនោះបងប្អូនប្រជាពលរដ្ឋសប្បាយចិត្តណាស់នាំគ្នាទះដៃខ្លះស្រែកហ៊ោថាស្រុកយើងសាន្តត្រាណហើយ! សុខសប្បាយហើយ! ចប់សង្គ្រាមហើយ!។ រចនាកាន់ដៃវាសនាជាប់ហើយក្តាប់យ៉ាងណែនហាក់ដូចជាចង់បង្កប់នូវគំនិតអាថ៌កំបាំងអ្វីម្យ៉ាង ដែលផ្ទុយពីគំនិតអ្នកស្រុកភូមិទាំងអស់ តែនាងមិនហ៊ាននិយាយចេញ។

មិនយូរប៉ុន្មាន អង្គការចាប់ផ្តើមជម្លៀសប្រជាជន។ វាសនា ប្រញាប់សួរឪពុករបស់គាត់ថា «បាទពុក! ចុះអង្គការគេឲ្យយើងទៅទីណា? ប៉ុន្មានថ្ងៃទៀតត្រលប់ចូលផ្ទះវិញ» និយាយរួច វាសនា ស្ទុះចូលក្នុងផ្ទះរៀបចំខោអាវបន្តិចបន្តួចឲ្យប្អូនជួយកាន់និង ពជីដូន។

ឪពុក៖ «អង្គការថាទៅវត្តតាប៉ុន ណាកូន។ មិនយូរទេ យើងនឹងបានត្រលប់មកផ្ទះយើងវិញនៅពេលដែលអង្គការរៀបចំភូមិរបស់យើងរួចរាល់»។

ចម្ងាយពីភូមិទឹកជោរ ទៅវត្តតាប៉ុន ចម្ងាយ ២គីឡូម៉ែត្រ។ ប្រជាជនឃុំទឹកជោរ នាំគ្នាដើរទូលអីវ៉ាន់ ខ្លះរែក ខ្លះពុន ខ្លះបររទេះ ខ្លះដើរដឹកដៃកូន និងខ្លះទៀតដឹកអីវ៉ាន់តាមកង់ ម៉ូតូ ឡាន សំដៅមកវត្តតាប៉ុនទាំងអស់គ្នាយ៉ាងគគ្រឹកគគ្រេង ប្រសេចប្រសាចពាសពេញផ្លូវ។ ប្រជាជនខ្លះដើរតាមថ្នល់ និងប្រជាជនមួយចំនួនទៀតដើរកាត់វាល។ វាសនាខំពរជើដូនចាស់បែកញើសហូរជោកខ្លួន។ វាសនាឥតថ្ងូរសូម្បីតែមួយម៉ាត់ឡើយ។ ឯផ្ទៃមេឃខែពិសាខ មានសភាពចង់ធ្លាក់ភ្លៀង មើលទៅមេឃខ្មៅងងឹតមេរដេរដាស មានផ្លេកបន្ទោរ ស្នូរន្ទះបាញ់ ឆ្វេចឆ្វាច ដែលជាសញ្ញាមួយថាមិនយូរប៉ុន្មាន ទឹកភ្លៀងនឹងធ្លាក់ចុះមកយ៉ាងខ្លាំង។ ព្រះអាទិត្យជិតលិចហើយ គ្រាន់តែប្រជាជនប្រុសស្រីចាស់ក្មេងចូលក្នុងវត្តតាប៉ុន ជុំគ្នាបានមួយស្របក់ភ្លៀងធ្លាក់យ៉ាងខ្លាំងលាយឡំនឹងសម្រែកកងទ័ពខ្មែរក្រហមស្រែកគំរាមថា៖

«ពុកម៉ែ ទាំងអស់គ្នាចេញក្រៅវត្តដោយឥតមានយកអីវ៉ាន់ទៅទេ ត្រូវចេញតែមួយរយៈ ចាំអង្គការមើលអីវ៉ាន់ឲ្យនៅទីនេះមិនបាត់ទេ។ អ្នកណាហ៊ានកាន់អីវ៉ាន់តែបន្តិចតាមជាប់នឹងខ្លួន អង្គការយើងនឹងបាញ់ចោល ព្រោះវាបញ្ជាក់ថានៅជាប់កម្មសិទ្ធិផ្ទាល់ខ្លួន ជាប់វណ្ណៈមូលធន ជាប់របបសក្តិភូមិ មិនចេះតស៊ូដូចវណ្ណៈកម្មករកសិករ។ ប្រញាប់ចេញភ្លាមទាំងអស់គ្នាចេញភ្លាម»។ គ្រាន់តែកងទ័ពខ្មែរក្រហមនិយាយរួច ក៏មានការបាញ់កាំភ្លើងទៅលើបីគ្រាប់ជាប់ៗគ្នា។

តាមការពិត នេះគឺជាល្បិចរបស់អង្គការឲ្យយកអីវ៉ាន់ចេញពីផ្ទះមកទុកជុំគ្នានឹងវត្ត ដើម្បីងាយស្រួលកុំឲ្យពិបាកពួកគេប្រមូលតាមផ្ទះ។ យប់នោះ យើងមិនបានចូលមកវត្តយកអីវ៉ាន់វិញទេ។ យើងនាំគ្នាដើរទាំងយប់ងងឹតឈឹង ខ្លួនរងាញ័រចំប្រប់ដូចកូនសត្វ។ ខ្លះហល់ទឹកភ្លៀង មានស្លាប់កូនង៉ែត ក្មេងតូចៗ និងចាស់ជរាដៃរ។ វាសនា បានលាក់ក្រណាត់ភ្លៀងមួយទុកក្នុងអាវ សម្រាប់ការពារទទឹកដល់ជីដូនកំសត់របស់ខ្លួន។ វាសនា ពរជើដូនដើរតាមគេក្រោមដំណក់ទឹកភ្លៀង និងស្នូរន្ទះទាំងងងឹតឈឹងមិនដឹងថាទៅទីណាទេ។ ប្រជាជន នាំគ្នាដើរតាមបញ្ជារបស់កងទ័ពខ្មែរក្រហមនាំផ្លូវខាងមុខ។

យើងទាំងអស់គ្នានាំគ្នាដើរទាំងហេវហត់អស់កម្លាំងយ៉ាងខ្លាំងតាំងពីយប់រហូតដល់ព្រឹក។ ព្រលឹមឡើង យើងធ្វើដំណើរមកដល់វត្តចារក្រោម ស្ថិតក្នុងឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ។ នៅទីនោះ ទាំងប្រជាជន និងព្រះសង្ឃក្នុងវត្តស្ងាត់ជ្រងំ ព្រោះត្រូវដម្លៀសចេញក្នុងថ្ងៃតែមួយដូចគ្នា។ នេះជាទិសដៅរបស់អង្គការឲ្យចេញពីភូមិទៅរស់នៅតាមវាលស្រែ ហើយមិនអនុញ្ញាតឲ្យត្រលប់មករស់នៅក្នុងភូមិវិញនោះទេ។

មេកងទ័ពខ្មែរក្រហមម្នាក់ បានស្រែកប្រកាសថា «ពុកម៉ែ មិត្តទាំងអស់គ្នាសម្រាកជាំបាយស៊ីសិនទៅ»។

យើងកំពុងរកមើលអង្កាមតាមផ្ទះ ស្រាប់តែឮសំឡេងកងទ័ពម្នាក់ ស្រែកមកថា៖

«ឈប់សិនបងប្អូនពុកម៉ែទាំងអស់គ្នា មកដល់ភូមិតាអំ ឃុំប្រាសាទនេះហើយ ចូរកកន្លែងសម្រាកសិនចុះ តែឲ្យសម្រាកក្រៅភូមិតាមមាត់ស្ទឹងវាលស្រែនេះឯង មិនឲ្យចូលទៅក្នុងភូមិទេ»។

នៅទីនោះ មានព្រៃរបោះកូនឈើតូចៗ ដែលប្រជាជនអាចនាំគ្នាធ្វើជម្រកដោយកាច់ស្លឹកឈើប្រក់ធ្វើជាដំបូលការពារកម្តៅថ្ងៃនិងទឹកភ្លៀង។ យើងមិនខុសអ្វីពីសត្វដែលកំពុងតែកាច់សំបុកធ្វើជម្រកឲ្យកូននោះទេ។

លុះព្រឹកឡើង កងទ័ពម្នាក់បានដើរហៅប្រជាជនមកប្រជុំ រួចនិយាយថា៖

«ពុកម៉ែ បងប្អូនទាំងអស់គ្នា អង្គការដាក់ទិសដៅឲ្យពុកម៉ែបងប្អូននៅធ្វើស្រែទីនេះឯង ដោយរៀបជាក្រុម ជាភូមិ ងាយស្រួល អង្គការត្រួតពិនិត្យ ហើយប្រធានភូមិ ប្រធានក្រុម ជ្រើសរើសយកតែអ្នកក្រ អ្នកធ្លាប់កំសត់ ធ្លាប់តស៊ូវណ្ណៈអធនកម្មករ កសិករ ឥតយកអ្នកចេះដឹង អ្នកមានទេ ពិបាកប្រើណាស់ព្រោះមនុស្សទាំងនោះនៅជាប់របបសក្តិភូមិនាយទុកប្រតិកិរិយា។ អង្គការបើករបបអង្ករឲ្យពីរនាក់កន្លះកំប៉ុង និងអំបិលបន្តិច។ យើងខំធ្វើស្រែកើត ពុកម៉ែបងប្អូន ថ្ងៃក្រោយហូបមួយថ្ងៃបីដង មានបង្អែមមួយអាទិត្យម្តងទៀត។ នេះជាគំនិតល្អរបស់អង្គការមហាលោតផ្លោះ មហាអស្ចារ្យ មិនដូចជំនាន់ លន់ នល់ ទេ អ្នកណាមានចេះតែ

មាន បងប្អូនអ្នកខ្សត់គ្នាវេទនានៅតែវេទនា។ ពេលនេះ អង្គការ បានវាយរបបចាស់បង្កើតរបបថ្មី បានហូបស្មើៗទាំងអស់គ្នាមែនទេ បងប្អូន? បើបងប្អូនណាមានមាសប្រាក់ជាប់នឹងខ្លួន ប្រមូលឲ្យអង្គការមកអាចរួចខ្លួនហើយ។ បើអង្គការស៊ើបដឹងថាបងប្អូនមានលាក់ទុក អង្គការនឹងវាយកម្ទេចចោលទាំងពូជ ព្រោះវាជាសកម្មភាពក្បត់នឹងអង្គការ ក្បត់នឹងបដិវត្តន៍»។

បន្ទាប់ពីប្រជុំចប់ភ្លាម ខ្មែរក្រហមបានរៀបចំភូមិ រៀបចំក្រុម ចាប់ចុះធ្វើស្រែ។ បងប្អូនមួយចំនួនឲ្យឡើងទៅប្រមូលស្រូវនៅតាមផ្ទះ នៅតាមភូមិ ប្រគល់ដល់អង្គការកុំឲ្យមានសល់បន្តិចឡើយ។ ពេលទៅប្រមូលស្រូវតាមភូមិ វាសនា និងលោកពូ តុង ឆាយ មានឈ្មោះទៅនឹងគេដែរ គឺទៅប្រមូលស្រូវនៅភូមិទឹកជោរ ដែលជាភូមិកំណើតរបស់ខ្លួន។ ឯអ្នកផ្សេងៗទៀតគ្រប់ៗភូមិ អង្គការក៏បានឲ្យទៅប្រមូលគ្រប់កន្លែងឲ្យអស់ពីផ្ទះរបស់ប្រជាជន។ ស្រូវដែលប្រមូលបានអង្គការមិនដឹងជាដឹកយកទៅទុកជាក់ឯណាអស់ទេ។ លុះព្រឹកឡើង វាសនាបាត់មិនឃើញលោកពូ តុង ឆាយ ក៏សួរគ្នីគ្នាខ្សឹបៗស្ងាត់ៗថា «មីងសំ លោកពូ តុង ឆាយ ព្រឹកនេះមិនឃើញមកប្រមូលស្រូវ?»

ជីវិតរស់នៅតាមសហករណ៍

ឆ្នាំ១៩៧៦ ប្រជាជនចាស់ ដែលហៅថា ពួកមូលដ្ឋាន បានវិលត្រលប់ពីរស់នៅតាមវាលតាមព្រៃ មកនៅតាមភូមិជាមួយប្រជាជនថ្មី ដែលទើបតែជម្លៀសមកពីទីក្រុងដែរ។ នៅក្រោមពន្លឺចង្កៀងប្រេងខ្លាញ់ត្រី ដែលយកក្រណាត់ជាក់ក្នុងចានខ្លាញ់ធ្វើប្រឆេះភ្លឺព្រឹមៗ ក្រោមខ្នមកំសត់ជញ្ជាំងស្លឹកឆ្ពុះ ឪពុករបស់វាសនាមានមុខហើមស្លេកស្លាំង បាននិយាយទៅកាន់ វាសនា ដោយសំឡេងខ្សាវៗ ពេលដែលឃើញវាសនា កំពុងយកបាវចាស់មួយធ្វើជាភួយដណ្តប់ឲ្យប្អូន ដែលកំពុងតែគ្រុនញាក់ ហើយថែមទាំងមានមុខមាត់ និងដៃជើងហើមដោយអត់អាហារ និងធ្វើការបាក់កម្លាំងថា៖

«វាសនា! កូនខំមើល ឡាវទី ឲ្យមែនទែន ព្រោះប្អូននៅក្មេង។ ចំណែកពុកវិញចាស់ហើយ ស្លាប់ចុះកុំគិតអីកូន»។ និយាយរួច គាត់ក៏បិទភ្នែកដង្ហើមលោតដង្ហក់បេះដូងដើរញាប់ខ្លួនញ័រញាក់។

វាសនា ស្ទុះចេញពីប្អូនទៅឱបឪពុកជាទីស្រលាញ់ហើយពោលតិចៗទាំងអួលដើមកថា «ពុកកុំនិយាយយ៉ាងនេះ ពុកមិនអីទេ។ ពុកត្រូវតែរស់នៅជាមួយកូនបន្តទៀត»។ វាសនាមិនហ៊ាននិយាយខ្លាំងទេ ព្រោះខ្លាចកងឈ្លបយប់ដើរស៊ើបការណ៍ឮ។ នៅជិតនោះ យាយលី ដែលជាម្តាយ និងប្អូនប្រុសស្រីពីរនាក់ទៀតរបស់ វាសនា ក៏ខិតមកជិតនោះដែរ។ តាលន បើកភ្នែកព្រឹមៗនិយាយខ្សាវៗសារជាថ្មីទៀត។

តាលន ៖ «ម៉ែវ៉ា! មុននឹងស្លាប់ ខ្ញុំសូមហូបបាយបានមួយម៉ាត់! តើឯងមានអង្ករពីណាមកដាំទេ?»។

យាយលី៖ «ពុកវ៉ា ខ្ញុំបានសន្សំអង្ករបានកន្លះកំប៉ុងពីថ្ងៃមុន។ ពេលទៅច្រូតស្រូវ ខ្ញុំបានដាក់ស្រូវតាមថ្នក់សំពត់យកមកបុកធ្វើជាអង្ករបានខ្លះដែរ។ ព្រឹកនេះចាំក្រោកដាំបាយបានបន្តិចជូនពុកវាឯងហូប»។

ដោយធ្វើការពីថ្ងៃអស់កម្លាំង និងហូបមិនឆ្អែតផង ម្នាក់ៗក៏នាំគ្នាសម្រាក។ អ្នកជំងឺពីរនាក់ឪ និងកូន សម្រាកមិនបានលក់ទេ ចេះតែរើខ្លួន និងដេកថ្ងូរងឹតសៗឥតឈប់។ ជារៀងរាល់យប់ យើងឃើញមានភ្លើងពិលរបស់ កងឈ្លប និងអ្នកភូមិទាំងអស់ដែលរស់នៅតាមសហករណ៍ប្រឹងប្រែងធ្វើការងារទាំងចាស់ក្មេងទាំងយប់ថ្ងៃ។ ប្រជាជនម្នាក់ៗមានការងារធ្វើគ្រប់ៗគ្នាឥតមានណាម្នាក់ដើរមកសួរសុខទុក្ខឬនិយាយគ្នាលេងបានឡើយ។ ប្រជាជនគ្រប់គ្នាផ្តាច់មនោសញ្ចេតនារៀងខ្លួនព្រោះខ្លាចស្លាប់ ហើយបានត្រឹមតែមើលមុខគ្នាយ៉ាងស្រពាប់ស្រពោនរៀងខ្លួន។

ជីវិតរស់នៅតាមកងចល័ត

ពាក្យថា «កងចល័ត» មានពីរ គឺកងចល័តតំបន់ និងកងចល័តតាមសហករណ៍។ កងចល័តតំបន់គឺអង្គការប្រមូលយុវជននារីធ្វើការរែកដី លើកទំនប់ជីកប្រឡាយ នៅតំបន់ណាដែលលំបាកខ្លាំង តាមសមរភូមិក្តៅនៅឆ្ងាយៗ ដូចជាអាងត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ អាងកំពឹងពួយ ខេត្តបាត់ដំបង។ ឯកងចល័តតាមសហករណ៍ គឺជាកងចល័តដែលអង្គការប្រមូលយុវជននារី ឬវ័យកណ្តាលឲ្យធ្វើការលើកទំនប់ លើកភ្លឺស្រែ ជីកប្រឡាយ ធ្វើស្រែនៅតាមភូមិឃុំ និងសហករណ៍ជិតៗលំនៅឋាន។

«នែ! វាសនា ថ្ងៃនេះមិត្តឯងត្រូវនាំកូនក្រុម១០នាក់ រែកកណ្តាប់ស្រូវទៅដាក់ក្រោយវត្តចារលើ»។ មេកងម្នាក់ដាក់ទិសបញ្ជា វាសនា។

វាសនា គឺជាប្រជាជនមូលដ្ឋាន ដូច្នេះអង្គការបានឲ្យ វាសនា មើលការខុសត្រូវប្រជាជនថ្មីដែលជម្លៀសមកទីក្រុង។ នៅពេលធ្វើជាមេក្រុម វាសនា ក៏ធ្វើការដូចកូនក្រុមដែរ។ ថ្ងៃមួយ វាសនា បានរែកកណ្តាប់ស្រូវដាច់ឆ្ងាយពីប្រជាជនផ្សេងទៀតមកដល់កន្លែងដើមស្រូវដែលខ្ពស់លិចក្បាលបាត់ រួច វាសនា បានអង្គុយចុះលូកយកកូនក្រណាត់ប៉ុនបាតដៃពីហោប៉ៅខោ ហើយកាយដីឲ្យគ្រលុកបន្តិច។ វាសនា បាន យកក្រណាត់ទ្រាប់ក្នុងគ្រលុកនោះ រួចបូតគួរស្រូវដាក់ រួចហើយយកដងរែកបុកស្រូវ ដោយភ្នែកលួចមើលជុំវិញខ្លួនទាំងភ័យខ្លាចកងឈ្លបឃើញ។ បុកស្រូវរួច វាសនា ក៏យកមកផ្ដុំនឹងដៃឲ្យជ្រះក្បាលអង្កាមខ្លះ នៅខ្លះ ហើយយកមកហូប។ នៅពេលដែល វាសនា ហូបអង្ករនោះរួច វាសនា បានលុបគ្រលុកនោះវិញ។ វាសនា តែងតែធ្វើយ៉ាងនេះជារៀងរាល់ពេលធ្វើដំណើរឆ្លងកាត់ទីនោះ។ ក្រោយមកទៀត អង្គការឈប់ឲ្យវាសនា រែកកណ្តាប់ស្រូវទៀតហើយ។ អង្គការឲ្យ វាសនា ទៅច្រូតស្រូវម្តង។ វាសនា តែងតែទំពាស៊ីស្រូវ ព្រោះ វាសនា មិនដែលហូបបបរបានឆ្អែតទេ។ ក្រោយមក ពេលឃើញ មិត្តហេង ដែលជាប្រជាជនថ្មីបានស្លាប់ដោយសារទល់លាមក វាសនា ឈប់ហ៊ានហូបស្រូវតទៅទៀត។

វាសនា៖ «ម៉ែ! កូនហូបមិនឆ្អែតទេម៉ែ។ រួចការងាររពេលល្ងាចហើយ កូនមករកបន្លែនៅផ្ទះ ព្រោះនៅកងចល័តឯវាលឥតមានបន្លែទេ មានតែបបរវារ»។ វាសនា លួចរត់មកផ្ទះក្រោយពេលសម្រាកពីការងារនៅពេលល្ងាច ដោយមិនបានប្រាប់មេកងឲ្យដឹងឡើយ។

យាយលី៖ «វាសនា! ថ្ងៃក្រោយមុននឹងកូនមក កូនត្រូវប្រាប់គេឲ្យបានដឹងខ្លាចគេធ្វើបាបកូនណា»។

មិនបង្អង់យូរ វាសនា បានប្រមូលបន្លែ ដូចជា ត្រប់ ផ្ទឹ នរោង ត្រកួន និង ល្អុង បានកន្លះការ៉ុង ដើរផងរត់ផង ទៅកន្លែងធ្វើការវិញទាំងហត់ដង្ហក់។

រៀបការសេរីម្តង ៥០គូ

នៅវាលដង្កៀបក្តាម មនុស្សជាច្រើនមានសម្លៀកបំពាក់ចាស់ៗចម្រុះពណ៌ ហើយប៉ះជាច្រើនបំណះ។ ប្រជាជន មានរាងកាយស្គមស្គែកស្លាំង ថែមទាំងហើមមុខមាត់ដៃជើងដើរស្ទើរមិនរួច កំពុងអង្គុយស្តាប់ការប្រជុំរបស់ តាមោង មេតំបន់៥ ដែលកំពុងនិយាយផ្តារដៃជើងលើវេទិកា ថែមទាំងមានកងទ័ពខ្មែរក្រហមមកការពារយ៉ាងប្រុងប្រយ័ត្ន។ ទង់ប្រាសាទកំពូលបីដែលមានពណ៌ក្រហមបានដាក់ជាច្រើននៅលើវេទិកា។

តាមោង៖ «ពុកម៉ែបងប្អូនទាំងអស់គ្នា! ថ្ងៃនេះអង្គការបានរៀបចំធ្វើមហាសន្និបាតមួយយ៉ាងធំ ឲ្យបងប្អូនជួបជុំសប្បាយរីករាយ។ សម័យ លន់ នល់ គេថាធ្វើបុណ្យត្រូវមានព្រះសង្ឃ ប៉ុន្តែការធ្វើបុណ្យរបស់អង្គការខ្មែរក្រហមយើងមិនចាំបាច់មានព្រះសង្ឃទេ ព្រោះគ្មានប្រយោជន៍មិនឃើញបុណ្យណាមកជួយ។ ជាក់ស្តែង ដូចអង្គការដែលឲ្យបងប្អូនធ្វើទំនប់ប្រឡាយ ធ្វើស្រែកើតបានជាបាយហូបឆ្អែតរាល់ថ្ងៃ។ នេះទើបជាបុណ្យ»។

និយាយរួច កងទ័ពខ្មែរក្រហមនាំគ្នាទះដៃ «ជយោ! ជយោ! អង្គការមហាលោតផ្លោត មហាអស្ចារ្យ»។

វាសនា ក៏មកប្រជុំសន្និបាតជាមួយប្រជាជនដទៃទៀតដែរ។ វាសនា បានយកដៃកេះ តាភឹម ដែលអង្គុយជិត ហើយខ្សិនខ្សឹបថា៖

«កុហកសោះ! អង្គការនេះ ប្រជាជនគ្នាហូបបបរវាវដើរចង់ដួល ថាហូបបាយឆ្អែតទៅរួច»។

តាភឹម៖ «ឈប់និយាយទៅចៅ! ប្រយ័ត្នស្លាប់ អង្គការស្តាប់ឮ ចៅត្រូវធ្វើលង់ ធ្វើគ ធ្វើថ្លង់ ទើបចៅអាយុវែង»។

បីថ្ងៃបន្ទាប់មក អង្គការហៅម្តងមួយគូៗ ឡើងប្តេជ្ញារៀងៗខ្លួនរហូតដល់គ្រប់ ៤៩គូ។ ដោយឡែកនៅគូទី៥០ ដែលជាគូចុងក្រោយ ត្រូវជាគូរបស់ រំដួល និងកងទ័ពកំលោះម្នាក់ បានឡើងកាន់ដៃគ្នាប្តេជ្ញាចិត្ត។ រំដួល មានទឹកមុខស្រពោនទឹកភ្នែកហូររហូត ហើយខំលាក់មិនហ៊ានឲ្យអង្គការដឹងទេ។ នាងយកកន្សែង

ដែលអង្គការប្រគល់ឲ្យជូតទឹកភ្នែក។ វាសនា បានឃើញសង្សារកម្សត់របស់ខ្លួនរៀបការ យំផងក្រៀមក្រំផងក៏ដោយ ក៏ វាសនា មិនហ៊ានឲ្យអង្គការដឹងទេ។ វាសនា នៅតែខំប្រឹងរក្សាទឹកមុខធម្មតា។

បន្ទាប់ពីទាំង ៥០គូ ប្តេជ្ញារួច កងទ័ពខ្មែរក្រហមម្នាក់ស្រែកខ្លាំងៗដាក់មេក្រូថា៖

«អង្គការ រៀបការម្តង ៥០គូនេះ មិនឲ្យខាតការងារត្រូវធ្វើ។ អង្គការយើងដើរមើលពេលផ្សំដំណេកយប់នេះ។ ប្រសិនបើមិត្តនារីណាម្នាក់ហ៊ានប្រឆាំងរៀបការហើយមិនព្រមដេកជាមួយពួកកងទ័ពរបស់យើងទេ នៅពេលអង្គការរបស់យើងឃើញហើយនឹងវាយចោល កុំថាអង្គការកាច»។

នៅពេលយប់ផ្សំដំណេក អង្គការឲ្យដេកជុំគ្នាទាំងអស់ ដោយគ្រាន់តែយកស្លឹកឈើ ឬអ្វីមកបិទបាំងបន្តិចបន្តួចប៉ុណ្ណោះ ហើយមានកងឈ្លប ដើរតាមដានលបមើលនៅយប់នោះដោយប្រុងប្រយ័ត្ន។

ចប់

៤៧
រឿង ផ្តិលកេរជីវិត

អ្នកនិពន្ធ ៖ អ៊ឹម សានី

៤៧ ~ រឿង ផ្តិលកេរជីវិត

រាត្រីទុក្ខព្រួយ

ខ្ញុំអង្គុយសំងំក្នុងលេណដ្ឋាន ដ៏តូចចង្អៀតមួយ ដែលមានឈើក្រាក់គ្របពីលើជាគំនរយ៉ាងច្រើនសម្រាប់ទុកជារនាំងការពារគ្រាប់។ លេណដ្ឋានរបស់ខ្ញុំ នៅសល់តែប្រលោះតូចមួយនៅចំហៀងខាងមុខសម្រាប់ធ្វើជាផ្លូវលូនចេញចូលក្នុងគ្រាមានអាសន្ន។ លេណដ្ឋាននោះ មានរាងជាអក្សរអែល។ នៅខាងក្នុងលេណដ្ឋាន ងងឹតស្អុប ហាប់មិនសូវមានខ្យល់ចេញចូលទូលំទូលាយដូចបរិយាកាសនៅខាងក្រៅឡើយ។ តាមកន្លៀតឈើ មានសត្វគីង្គក់ជាច្រើនក្បាល។ ក្បែរជើងរបស់ខ្ញុំ មានពំនូកដី ដែលស្រមោចក្រហមពូនគរ ដើម្បីយកមកធ្វើជារន្ធទីជម្រកស្នាក់អាស្រ័យ។ មួយផ្នែកទៀតនៅក្នុងលេណដ្ឋាន ខ្ញុំឃើញមានការុងអង្ករ អីវ៉ាន់ និងសម្លៀកបំពាក់មួយចំនួន រាយពាសពេញក្នុងរណ្តៅ។ ម្តាយរបស់ខ្ញុំភ័យខ្លាចខ្លាំងពីការបាញ់ប្រហារគ្នារវាងកងទ័ពជាតិនិងកងទ័ពព្រៃនៃសង្គ្រាមឈាមជ័រខ្មែរឯងតែមួយ ដូច្នេះហើយ គាត់ចេះតែគ្រវែងអីវ៉ាន់ ទាំងអស់នោះចូលឲ្យតែបានៗទៅ។ ដោយសេចក្តីភ័យរន្ធត់ពេក ដៃរបស់ខ្ញុំ ចេះតែស្រវាឱបបង្វែចជាប់យ៉ាងណែន ដោយមិនដឹងថាជារបស់អ្វីនោះឡើយ។ ក្បាលរបស់ខ្ញុំសុទ្ធតែដី។ នៅពេលមានស្នូរកាំភ្លើងធំម្តងៗ រង្គើញ័ររញ្ជួយធ្លាក់ដីស្រោចពីគំនរឈើដូចតំណក់ទឹកភ្លៀង។ ពុករបស់ខ្ញុំ តែងតែយកដីមកពេាយលើក្បាលរបស់ខ្ញុំ ដោយពោលតិចៗថា «សូមព្រះធរណីជួយកូនចៅឲ្យបានផុតពីគ្រោះកាចទាំងឡាយនេះផង»។ យើងមានសម្លៀកបំពាក់មួយចង្កេះបែកញើសជោកខ្លួន។ ឪពុកម្តាយ

បងប្អូន និងញាតិប្រុសស្រីរបស់ខ្ញុំ បានចូលទៅក្នុងលេណដ្ឋាននេះទាំងអស់គ្នា។ ម្នាក់ៗនិយាយរកគ្នាដោយភាសាខ្សឹបខ្សៀវបែបភ័យខ្លាចផង និងត្រចៀកផ្ទៀងចាំស្តាប់គ្រាប់កាំភ្លើងផង។ ម្តងយើងឮសូរគ្រាប់កាំភ្លើងចេញពីទិសខាងជើង ម្តងឮចេញពីទិសខាងលិចបន្តបន្ទាប់ឆ្លើយឆ្លងគ្នាមិនដាច់សោះ។ ខ្ញុំស្តាប់ឮម្តងៗ ភ័យឈឺដល់ដើមទ្រូង។ ក្លិនដី ក្លិនខ្លួនរបស់មនុស្សម្នាក់ៗក្នុងរណ្តៅនេះ បានធ្វើឲ្យខ្ញុំអាចចំណាំបានថា នរណាជានរណាយ៉ាងច្បាស់។ សំឡេងគ្រាប់កាំភ្លើងបាញ់តៗគ្នាបានចប់មួយស្របក់ ប៉ុន្តែមនុស្សនៅក្នុងលេណដ្ឋាន មិនទាន់មាននរណាម្នាក់ហ៊ានលូនចេញឡើយ។ ថ្ងៃណាក៏ដូចថ្ងៃណាដែរ ខ្ញុំតែងតែចូលលាក់ខ្លួនក្នុងលេណដ្ឋានរាល់ពេលណាដែលមានការវាយប្រហារគ្នាដោយកាំភ្លើងពីក្រុមអ្នកចម្បាំងខ្មែរទាំងសងខាង។ យូរៗទៅ ចិត្តរបស់ខ្ញុំមិនចង់ចេញពីលេណដ្ឋានឡើយ ចង់តែនៅសោយសុខត្រឹមតែមួយគ្រួសារ មិនចង់បានអ្វីក្រៅតែពីចង់បានសន្តិភាពឡើយ។ ខ្ញុំនៅក្នុងលេណដ្ឋានជាញឹកញយ។ នៅក្នុងនោះហាក់ធ្វើឲ្យខ្ញុំមានភាពកក់ក្តៅបញ្ចៀសអស់សេចក្តីភ័យខ្លាច ហើយការពារគ្រប់បែបយ៉ាងដល់ខ្ញុំនិងក្រុមគ្រួសារបាន។

យប់កាន់តែងងឹតណាស់ទៅហើយ សំឡេងមនុស្សយំកងរំពងបានបន្លឺឡើងសារជាថ្មី ជំនួសឲ្យសំឡេងកាំភ្លើង អមជាមួយសំឡេងឆ្កែព្រុសដេញតាមតាំងពីចុងភូមិខាងជើងរហូតមកដល់មុខផ្ទះរបស់ខ្ញុំ។ ខ្ញុំខំផ្ទៀងត្រចៀកស្តាប់ដោយស្ងៀមស្ងាត់ស្ទើរតែមិនហ៊ានដកដង្ហើមឡើយ។ បេះដូងរបស់ខ្ញុំលោតខ្លាំងក្នុងទ្រូងដូចកំពុងមានអ្វីបុកចង់ផ្លាយចេញមកក្រៅម្តងៗ។ អារម្មណ៍របស់ខ្ញុំពិតជាភ័យខ្លាចណាស់ រកអ្វីមកប្រៀបពុំបានឡើយ។ ឪពុករបស់ខ្ញុំ និយាយមករកខ្ញុំ និងអ្នកនៅក្នុងលេណដ្ឋានដោយសេចក្តីព្រួយបារម្ភណ៍។ គាត់បានប្រាប់ម្តាយរបស់ខ្ញុំ បងប្អូនសាច់ញាតិ និងខ្ញុំ ថាឲ្យនៅក្នុងលេណដ្ឋាននោះមិនឲ្យចេញទៅណាឡើយ ដរាបណាគាត់ត្រលប់មកវិញ។ បន្ទាប់ពីនិយាយរួច ឪពុករបស់ខ្ញុំ បានលូនចេញទៅខាងក្រៅលេណដ្ឋានសសៀរតាមគុម្ពចេកទៅក្បែរដើមទឹកដោះ និងអែបៗជិតជង្រុកស្រូវដើម្បីតាមរកមើលសំឡេងយំ។

សកម្មភាពរបស់គាត់ដូចគ្រាមានអាសន្នថ្ងៃមុនៗអីចឹង។ គាត់យល់យ៉ាងជាក់ច្បាស់រួចហើយ ទើបគាត់ត្រលប់មកប្រាប់ដល់ខ្ញុំ និងអ្នកនៅក្នុងលេណដ្ឋានឲ្យចេញមកក្រៅរួចរៀបចំអីវ៉ាន់ឲ្យបានឆាប់រហ័សជាទីបំផុត ដើម្បីធ្វើដំណើរចេញពីផ្ទះសម្បែងក្នុងភូមិក្រសាំងទាំងយប់ទៅតាំងទីលំនៅថ្មី នៅឯស្រុកចុងកាល់ តាមការជម្លៀសរបស់កងទ័ពខ្មែរក្រហម។ ខ្ញុំស្ទុះចេញពីក្នុងរណ្តៅយ៉ាងប្រញាប់រួចរត់ទៅយករបស់របរបន្តិចបន្តួចដាក់លើរទេះគោ។ ឪពុករបស់ខ្ញុំ ដឹកគោយកមកទឹមរទេះ។ ចំណែកឯម្តាយរបស់ខ្ញុំ ដៃម្ខាងពប្អូនប្រុសរបស់ខ្ញុំ និងដៃម្ខាងទៀតកាន់ភ្លើងចន្លុះដើរមុខរទេះគោដើម្បីបំភ្លឺផ្លូវ។ បងប្អូនក្នុងភូមិហៅរកគ្នាមកប្រជុំនៅខាងមុខផ្ទះរបស់ខ្ញុំ រួចបររទេះចេញទៅទាំងយប់ងងឹតជាមួយគ្នា។ ខ្ញុំក្រឡេកមើលផ្ទះជាច្រើនដង ប៉ុន្តែដោយសារយប់ងងឹតពេក ហើយរទេះគោបរចេញទៅកាន់តែឆ្ងាយ ខ្ញុំក៏មើលផ្ទះរបស់ខ្ញុំលែងឃើញទៀត។ ទឹកភ្នែករបស់ខ្ញុំ ស្រក់មកដោយមិនដឹងខ្លួនក្នុងយប់ងងឹតឈឹង ហើយគ្មាននរណាម្នាក់បានឃើញ និងដឹងឡើយ។

រាល់ថ្ងៃ ខ្ញុំតែងតែយំរងំក្នុងចិត្ត ត្បិតគឹងទ្រូងនឹងសង្គ្រាមដ៏រ៉ាំរ៉ៃនេះណាស់។ ខ្ញុំតែងតែបង្កើតសំណួរគ្មានចម្លើយសួរខ្លួនឯងជាច្រើនដងរាប់មិនអស់ថា តើហេតុអ្វីបានជាមានសង្គ្រាម? ហេតុអ្វីបានជាគេចង់ប្រហារអ្នកដទៃទៅវិញ ទាំងដែលអ្នកដទៃក៏ចង់មាន ចង់បានដូចជាខ្លួនឯងផងដែរនោះ? តើភាពរីកចម្រើនរុងរឿងរបស់ប្រទេសជាតិ ពិតជាចាំបាច់ត្រូវតែធ្វើសង្គ្រាមកាប់សម្លាប់ជីវិតគ្នាឯងអីចឹងមែនទេ?

រទេះគោចេះតែបន្តដំណើរទៅមុខជានិច្ច ទោះបីជាឆ្លងកាត់កក់ជ្រាំទាំងកណ្តាលយប់ងងឹតក៏ដោយ។ ខ្ញុំអង្គុយងុយងោកលើរទេះ ហើយទោះបីជាត្រូវដីខ្ចាតចេញពីកង់រទេះមកស្រោចលើខ្លួនរបស់ខ្ញុំយ៉ាងណាក៏ដោយ ក៏ខ្ញុំហាក់មិនចាប់អារម្មណ៍ថាជាបញ្ហាធំរបស់ខ្ញុំឡើយ។ អ្វីដែលជាបញ្ហារបស់ខ្ញុំនាពេលនេះគឺជីវិត និងអនាគតរបស់ខ្ញុំ ថាតើត្រូវរសាត់អណ្តែតទៅដល់ទីណា គ្មានអ្នកណាអាចដឹងនិងបកស្រាយបានឡើយ។

ចំពោះមុខនេះ ខ្ញុំក៏ដូចជាបងប្អូនប្រជាពលរដ្ឋក្នុងភូមិដែលកំពុងតែរស់នៅជួបជុំគ្រួសារ ផ្ទះសម្បែង បងប្អូន យ៉ាងសប្បាយរីករាយ ក៏ប្រែប្រួលយ៉ាងលឿនត្រឹមតែមួយរយៈពេលដ៏ខ្លី ទៅជាមនុស្សគ្មានលំនៅឋានច្បាស់លាស់ ចាកចោល

ស្រែចម្ការ រសាត់អណ្តែតទាំងយប់អធ្រាត្រគួរឲ្យអាសូរ។ នេះក៏ព្រោះតែបុព្វហេតុនៃសង្គ្រាម ដែលកើតចេញពីការចង់បាននូវអំណាច បំផ្លិចបំផ្លាញតែជាតិឯងគ្មានក្រែងរអែងចិត្តអាណិតដល់ជីវិតរស់នៅរបស់មនុស្សស្លូតត្រង់បន្តិចឡើយ។

រដូវរំហើយ អាកាសធាតុនាពេលយប់កាន់តែត្រជាក់ ខ្ទុំរងាញាក់ដូចកូនចាបត្រូវទឹកភ្លៀងអីចឹង។ ក្លិនស្រូវស្រាលទុំប្រហើរចេញពីវាលស្រែក្បែរៗដងផ្លូវមិនដាច់ យើងធ្វើដំណើរឆ្លងពីភូមិក្រសាំងកាត់តាមខាងជើងភូមិឈូក បន្តទៅភូមិខ្នារ ភូមិគោកស្ពាន និងភូមិព្រះនគរ រួចឆ្ពោះទៅទីរួមស្រុកចុងកាល់។ ខ្យល់បក់បោកនារាត្រីនេះមិនដាច់ឡើយ។ សំឡេងឆ្កែលូលួយៗ ព្រោះវង្វេងបាត់ម្ចាស់ លាន់សូរគ្រលួចពីក្នុងព្រៃខាងក្រោយហ្វូងមនុស្សដែលកំពុងតែធ្វើដំណើរ។ សូរសព្ទទាំងអស់នេះកាន់តែធ្វើឲ្យចិត្តខ្ទុំក្តុកក្តួលជាពន់ពេក។ គោដើរបណ្តើរ ស៊ីស្មៅបណ្តើរ តែយើងមិនឈប់បង្អង់ឡើយ។ នៅទីបំផុត ខ្ញុំនិងប្រជាជនជាច្រើននាក់បានមកដល់ស្រុកចុងកាល់ បន្ទាប់ពីធ្វើដំណើរពេញមួយយប់ទល់ភ្លឺ។

រាល់ថ្ងៃពេលព្រឹកព្រលឹមថ្មើរនេះ ឪពុករបស់ខ្ញុំ តែងតែទៅច្រូតស្រូវស្រាលខាងត្បូងភូមិក្រសាំងជាមួយនឹងអ្នកភូមិដែលពួកគាត់យកដៃគ្នាច្រូតម្នាក់ម្តងប៉ុន្តែគ្រានេះ បែរជាមកតាំងទីរស់នៅក្នុងវត្តស្ថិតនៅស្រុកចុងកាល់ទៅវិញ។ ស្រូវទាំងអស់ ត្រូវទុកចោលទាំងស្រុងនៅក្នុងភូមិក្រសាំង។ ជីវភាពជាអ្នកស្រែចម្ការ គ្មានអ្វីសប្បាយចិត្តជាងការប្រមូលផលស្រូវ ដែលកំពុងតែទុំពាសពេញវាលស្រែនោះឡើយ។ ខ្ញុំធ្លាប់តែងើបពីព្រឹកព្រលឹមស្រាងៗ ជាំបាយជំនួសដៃជើងឪពុកម្តាយខ្លះ ដើម្បីវេចខ្ចប់ជូនពួកគាត់ចេញដំណើរទៅច្រូតស្រូវ ប៉ុន្តែពេលនេះខ្ញុំត្រូវមកអង្គុយសំកុកនៅលើរទេះគោមិនអាចចេញទៅណាឡើយ។ ខ្ញុំនៅតែមិនអស់ចិត្តចំពោះសកម្មភាពនៃការជម្លៀសនេះ។ អារម្មណ៍របស់ខ្ញុំនៅវិលវល់មិនដាច់ស្រេចឡើយ។ វាហាក់ដូចជាការយល់សប្តិក្នុងរាត្រីមួយអីចឹង។ ខ្ញុំក្រឡេកភ្នែកទៅកន្លែងណាក៏ឃើញតែរទេះដឹកអីវ៉ាន់ និងមនុស្សម្នាឈប់ត្រៀបត្រាក្នុងវត្តអារាមដែរ។ ម្នាក់ៗខ្វល់ខ្វាយក្នុងចិត្តដោះស្រាយមិនចេញឡើយ។ ស្បៀងដែលពួកយើងមានក៏មិនច្រើនទៀត ព្រោះយើងរំពឹងគិតថាបានហូបអង្ករស្រូវថ្មីដែលនឹងប្រមូលផលជាបណ្តើរតាមរបៀបអ្នកស្រុកស្រែចម្ការនៅទីជនបទ។

ខ្ញុំសម្រាកនៅស្រុកចុងកាល់ បានមួយយប់ ហើយត្រូវប្រធានក្រុមចល័តជម្លៀសឲ្យទៅភូមិត្រុំ ស្ថិតនៅក្នុងស្រុកស្រីស្នំ ខេត្តសៀមរាប ជាបន្តទៀត ជាមួយនឹងក្មេងៗក្នុងភូមិ ដែលមានអាយុស្របាលខ្ញុំដែរ។ ការដកទៅលើកនេះ គឺខ្ញុំទៅតែម្នាក់ឯងទេ។ ចំណែកឯក្រុមគ្រួសាររបស់ខ្ញុំ អង្គការបានទុកឲ្យធ្វើដំណើរមួយផ្នែកតាមពីក្រោយឆ្ពោះទៅភូមិត្រុំ ស្រុកស្រីស្នំ ខេត្តសៀមរាប ដូចគ្នាដែរ។ លើកនេះ អង្គការបានបំបែកគ្នា ដោយយកក្មេងៗឲ្យធ្វើដំណើរផ្សេងៗ ឯសមាជិកក្រុមគ្រួសារធ្វើដំណើរជាមួយក្រុមផ្សេង។ ឪពុករបស់ខ្ញុំ បានហុចបង្វែចក្រមាមួយឲ្យខ្ញុំ ហើយគាត់បានផ្តែផ្តាំខ្ញុំថា «កូនយកបង្វែចនេះទៅតាមខ្លួនចុះ ទុកគ្រាន់ប្រើការក្នុងគ្រាមានអាសន្នណាមួយ ហើយកូនកុំចោលវាឲ្យសោះ ព្រោះតទៅវាជាកេរជីវិតរបស់កូនហើយ»។ ខ្ញុំឈោងយកបង្វែចនោះមកឱបជាប់នឹងដើមទ្រូងរបស់ខ្ញុំដោយសេចក្តីរំភើបនិងស្រណោះពន់ពេក។ ខ្ញុំលុតជង្គង់ស្រក់ទឹកភ្នែកឱនក្បាលសំពះលាឪពុកអមដោយអំណរគុណដល់អ្នកមានគុណរបស់ខ្ញុំ។ ស្របគ្នានោះ ប្រធានក្រុមចល័តនិងហ្វូងក្មេងៗមួយក្រុម បានមកដល់ល្មម។ គាត់បានបណ្តើរពួកខ្ញុំចេញទៅ ដែលមានក្មេងៗប្រមាណជាង ៣០នាក់ ដើម្បីរង់ចាំឡើងជិះរថយន្តដឹកខ្សាច់សម្រាប់យកទៅកសាងពីភូមិគោកស្រម៉ យកទៅស្រុកក្រឡាញ់។ មួយសន្ទុះធំ រថយន្តបីគ្រឿងបានមកដល់។ ពួកខ្ញុំ ត្រូវបំបែកគ្នាជាបីក្រុមឡើងជិះរថយន្តនោះ។ រថយន្តនាំមុខ បានមកដល់ស្ពានអូរដីក ដែលជាស្ពានស្ថិតក្នុងព្រំប្រទល់ខេត្តទាំងពីរ គឺខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ។

សំឡេងផ្ទុះលាន់ឮរញ្ជួយព្រះធរណីក្បែរគល់ស្ពាន បែកផ្សែងខ្មួលខ្មាញ់ហុយទ្រលោមនៅលើអាកាស។ ខ្សាច់ស្រោចក្បាលកប់ខ្លួនរបស់ខ្ញុំស្ទើររើមិនរួច។ ឡានឈប់ង៉ក់មិនអាចធ្វើដំណើរទៅមុខមួយរំពេច។ សំឡេងស្រែកយំបន្លឺឡើងដូចជាកូនចាបបែកសំបុក។ ដីចូលភ្នែករបស់ខ្ញុំរកមើលអ្វីមិនឃើញទេ។ ដៃរបស់ខ្ញុំម្ខាងឱបបង្វែចជាប់ ឯដៃម្ខាងទៀត រាវរកមិត្តកក្តិដែលជិះជុំគ្នានៅលើពំនូកខ្សាច់នោះ ដោយប្រវែប្រវារកគ្នាឲ្យគ្រប់ចំនួន។ ឱ! គុណបុណ្យព្រះធរណី លោកពិតជាជួយដល់ជីវិតស្លូតត្រង់វ័យក្មេងខ្ចីរបស់ក្មេងៗទាំងនេះណាស់។ អ្នកហាក់ដូចជាដឹងថា

ក្មេងៗទាំងអស់ គឺកម្លាំងរបស់ជាតិដ៏រឹងមាំដើម្បីបន្តវេនដែលត្រូវតែរស់មើលថែរក្សាការពារប្រទេសមួយនេះឲ្យរួចចាកទុក្ខពីរបបដ៏ខ្មៅងងឹតនេះ។

បង្វែចក្រមារបស់ខ្ញុំរហែកអស់ ខ្ញុំលុតជង្គង់លើកដៃប្រណម្យនឹកដល់គុណបុណ្យឪពុកម្តាយ ដែលជាព្រះដ៏មានអានុភាពថ្លៃថ្លាបំផុតជួយការពារជីវិតរបស់ខ្ញុំក្នុងគ្រាមានអាសន្ននេះ។ ខ្ញុំបោសដីចេញពីបង្វែច និងបើកមើលតាមស្នាមបង្វែចដែលរហែក ដោយទឹកភ្នែកសស្រាក់។ ខ្ញុំឃើញច្បាស់នឹងភ្នែកថានៅក្នុងបង្វែចនោះ គឺជាកូនផ្តិលតូចមួយក្រាស់។ កូនផ្តិលនោះ មានស្នាមអំបែងគ្រាប់បុកចំ ប៉ុន្តែមិនធ្លុះ។ ឱ!ផ្តិលជីវិតខ្ញុំអើយ អ្នកបានជួយខ្ញុំឲ្យរួចផុតពីសេចក្តីស្លាប់និងមានជីវិតរស់នៅបានចាកចេញគេចពីគ្រោះកាចដ៏ចង្រៃនេះហើយ។ ប្រសិនជាគ្មានអ្នកទេ ម្ល៉េះសមកាយរបស់ខ្ញុំនឹងធ្លុះធ្លាយដោយលោហៈផ្ទុះនេះហើយ។ តែកុងឡាន នឹងក្រុមការងាររបស់គាត់ ដែលជិះនៅខាងមុខត្រូវស្លាប់ទាំងអស់។ ប្រធានក្រុមចល័តរត់មករកពួកខ្ញុំ។ ដោយឃើញថា ពួកខ្ញុំគ្មានបញ្ហាអ្វី គាត់ឲ្យពួកខ្ញុំប្រញាប់ឡើងរថយន្តនៅពីក្រោយពីរគ្រឿងទៀតដែលគ្មានបញ្ហានោះ ដើម្បីចេញដំណើរទៅមុខបន្ត។ ខ្ញុំចាប់បង្វែចរហែករបស់ខ្ញុំឡើងជិះរថយន្តម្តងទៀត។

ការធ្វើដំណើរមិនអាចឈប់បង្អង់ឡើយ យើងត្រូវឆ្លងពីភូមិមួយទៅភូមិមួយទៀតរហូតដល់ស្រុកក្រឡាញ់។ ដំបូងឡើយ ប្រធានក្រុមចល័ត បានប្រាប់ខ្ញុំថាយើងត្រូវជម្លៀសមកភូមិត្រុំ ប៉ុន្តែដោយហេតុថា រថយន្តមួយជាន់មីនផ្ទុះខូច ហើយរថយន្តពីរផ្សេងទៀតត្រូវការដឹកខ្សាច់ឲ្យបានរហ័ស ថែមទាំងត្រូវការកម្លាំងក្មេងៗជួយចូកទម្លាក់ខ្សាច់ឲ្យបានរហ័សដៃរនោះ ដូច្នេះហើយទើបបង្ខំឲ្យពួកខ្ញុំបន្តមកដល់ស្រុកក្រឡាញ់ទៀតខុសពីគោលដៅចាស់ដើម្បីជាកម្លាំងជួយចូកទម្លាក់ខ្សាច់។ មេឃកាន់តែងងឹតទៅហើយ ឡានដឹកខ្សាច់ទើបមកដល់ស្រុកក្រឡាញ់។ ខ្ញុំកាយខ្សាច់ទាំងយប់ងងឹតរហូតម៉ោងជិតដប់យប់ទើបអស់ខ្សាច់ពីឡានបានសម្រាក។ ឡានចេញដំណើរត្រលប់ទៅដឹកខ្សាច់បន្តទៀត ប៉ុន្តែគេមិនឲ្យខ្ញុំទៅវិញទេ គឺគេទុកខ្ញុំនិងមិត្តឯទៀត នៅចាំចូកខ្សាច់ទម្លាក់ឯស្រុកក្រឡាញ់នេះរយៈពេលប្រាំយប់ប្រាំថ្ងៃ។ ខ្ញុំប្រឹងប្រែងធ្វើការងារមិនដែលធ្វេសប្រហែស

ឡើយ។ ខ្ញុំខំធ្វើយ៉ាងណាឲ្យតែរក្សាខ្លួន និងជីវិតបាន ទោះជាការងារធ្ងន់ស្រាលឆ្លងកាត់រងាក្តៅបែបណា ក៏ខ្ញុំមិនដែលត្អូញត្អែរមួយម៉ាត់ឡើយ។ ខ្ញុំទ្រាំខាំមាត់សង្កត់ចិត្ត អត់ធ្មត់ក្រាញនៀល ធ្វើរហូតទាំងយប់ទាំងថ្ងៃជានិច្ច។

ជំរំជម្លៀស

ប្រជាពលរដ្ឋដែលជម្លៀសដំបូង ហើយបានមកស្នាក់អាស្រ័យនៅក្នុងស្រុកចុងកាល់នេះ គឺមានតែបីភូមិប៉ុណ្ណោះ ក្នុងនោះមានភូមិក្រសាំង ភូមិប្រាសាទ និងភូមិខ្នារ។ ឥឡូវដំណើរការជម្លៀសនៅតែបន្តទៅភូមិត្រុំ ស្រុកស្រីស្នំ ខេត្តសៀមរាបទៀត។ ក្រុមគ្រួសាររបស់ខ្ញុំ ពេលធ្វើដំណើរតាមផ្លូវ បានឃើញរថយន្តដែលខ្ញុំជិះខូចខាតដោយផ្ទុះមីន។ ពួកគាត់ពិតជារន្ធត់ចិត្តណាស់។ គាត់ព្រួយបារម្ភណ៍ពីខ្ញុំ ក្រែងមានគ្រោះភ័យទាំងឡាយកើតមានចំពោះរូបខ្ញុំ។ គ្រួសាររបស់ខ្ញុំ និងគ្រួសារជម្លៀសទាំងអស់ មកស់នៅក្នុងផ្ទះជាមួយអ្នកភូមិត្រុំ ទាំងអស់គ្នា។ ពេលនោះ ខ្មែរក្រហម បានតម្រូវឲ្យគ្រួសារជម្លៀសចំនួន ១គ្រួសារ ត្រូវស្នាក់នៅជាមួយគ្រួសារអ្នកភូមិត្រុំ ចំនួន ១គ្រួសារដែរ។

ប្រជាជនទាំងអស់នៅក្នុងភូមិត្រុំ ត្រូវសហការណ៍កេណ្ឌយកធ្វើការច្រូតស្រូវនៅឆ្ងាយពីភូមិរហូតដល់ភូមិរំដេង ហើយក្រុមចល័តខ្លះត្រូវបានខ្មែរក្រហម យកទៅឲ្យបិតភ្លឺស្រែនៅតាមវាលស្រែ និងលើកទំនប់នៅត្រពាំងស្រែង និងនៅអាងត្រពាំងថ្ម។ កន្លែងណាក៏ដូចកន្លែងណាដែរ គឺធ្វើការលំបាកលំបិនណាស់ គ្មានអ្នកណាបានហូបឆ្ងាញ់នោះទេ។ ការហូបបាយ គឺត្រូវហូបជាក្រុម ដោយវេចចានម្នាក់មួយជាប់ជានិច្ច។ បន្ទាប់ពីខ្ញុំនៅចូកខ្សាច់អស់ចំនួន ១៥ថ្ងៃ នៅឯស្រុកក្រឡាញ់ យប់មួយខ្ញុំបានមកដល់ជំរំជម្លៀសក្នុងភូមិត្រុំវិញ។ ខ្ញុំ និងមិត្តឯទៀត ត្រូវប្រធានសហការណ៍ជូនទៅរកផ្ទះម្តងម្នាក់ៗ ព្រោះពួកខ្ញុំមិនដឹងថាគ្រួសាររបស់ខ្លួននៅទីណានោះទេ។

ក្នុងរាត្រីដ៏សែនស្ងាត់នៅក្នុងភូមិត្រុំ នារីចល័តទាំងអស់នាំគ្នាងូតទឹករួចហើយទើបបណ្តើរគ្នាទៅយកបាយពីចុងភៅនៅឯចុងភូមិខាងត្បូង ដើម្បីយកមកស្រស់ស្រូបក្នុងពេលល្ងាច។ អាហារពេលល្ងាចរបស់ពួកខ្ញុំ បានក្លាយជាអាហារ

ពេលរាត្រីស្ងើរតែរាល់ៗថ្ងៃ។ ខ្ញុំយកផ្តិលខាត់ដែលឪពុករបស់ខ្ញុំឲ្យ ដើម្បីទុកប្រើប្រាស់ពេលមានការចាំបាច់នានា ដូចជា យកទៅដាក់បាយ និងម្ហូបអាហារតាមការចាំបាច់។ ពេលនោះ អាហាររបស់ក្រុមចល័ត ហូបតែពេលយប់ទេ ហើយពេលខ្លះមានតែដំឡូង ពេលខ្លះមានបាយតែគ្មានសម្ល និងពេលខ្លះទៀតមានតែបបរ មានខ្លោច មានឆៅ។ ទោះជាយ៉ាងនេះក្តីក៏ខ្ញុំមិនរអ៊ូដែរ។ ខ្ញុំទ្រាំលេបឲ្យតែពេញពោះ និងបានរស់បន្តទៅទៀតទេ។

ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំតែងតែឃើញមានការរៀបចំផែនការគ្រប់គ្រង់មនុស្សនៅក្នុងការធ្វើការងាររបស់ក្រុមសហករណ៍នៅភូមិត្រុំ មានសភាពប្លែកៗគ្នា។ ខ្ញុំសង្កេតឃើញខ្មែរក្រហម បែងចែកជា បួនផ្នែកគឺ ក្រុមកុមារ ក្រុមយុវជន ក្រុមមនុស្សវ័យកណ្តាល និងមនុស្សចាស់ជរា។ ក្រុមកុមារ ត្រូវអង្គការ ឲ្យដើររើសអាចម៍គោដើម្បីយកទៅធ្វើជី។ ក្រុមយុវជន ត្រូវអង្គការ ចាត់ជាក្រុមចល័តដើម្បីឲ្យទៅលើកភ្លឺស្រែ ឬច្រូតស្រូវ។ ក្រុមវ័យកណ្តាល ត្រូវអង្គការឲ្យទៅដឹកនាំផងនិងធ្វើការផងតាមក្រុមនីមួយៗ។ រីឯក្រុមមនុស្សចាស់វិញ អង្គការ ឲ្យនៅចាំផ្ទះមើលកូនចៅរបស់ក្រុមការងារដែលទៅធ្វើការនៅខាងក្រៅផ្ទះ។ ចាស់ៗ ម្នាក់ៗទទួលរ៉ាប់រងមើលក្មេងតូចៗចន្លោះពី ៣នាក់ទៅ ៥នាក់។ ចំណែកអាហារសម្រាប់ហូបចុកប្រចាំថ្ងៃវិញ គ្រប់ក្រុមទាំងអស់ មិនតម្រូវឲ្យនរណាម្នាក់ដាំបាយ ឬស្ល្ខួនឯងនោះទេ។ អង្គការ មានចុងភៅម្នាក់សម្រាប់គ្រប់គ្រងលើការងារនេះ។ នៅពេលដល់ម៉ោងបាយព្រឹក បាយថ្ងៃត្រង់ និងបាយល្ងាច ខ្ញុំឮសំឡេងវាយជួងផ្តល់ជាសញ្ញាដល់ក្រុមការងារទាំងអស់ទៅតម្រង់ជួរគ្នាទទួលយកម្ហូបអាហារមកបរិភោគ។

ខ្ញុំពុំដែលមានពេលសម្រាកគ្រប់គ្រាន់ឡើយ។ ក្នុងនាមជាក្មេងស្រីម្នាក់ដែលគ្មានបទពិសោធន៍ធ្វើការងារទាំងអស់នោះ ខ្ញុំពិតជាមានការលំបាកណាស់នូវអ្វីដែលខ្ញុំទទួលបានពីការដាក់ការងារឲ្យធ្វើប្រចាំថ្ងៃពីប្រធានកង។ ការងារទាំងអស់មានទំហំធំហួសពីកម្លាំងកាយ និងសមត្ថភាពរបស់ខ្ញុំ ប៉ុន្តែដើម្បីរក្សាជីវិតឲ្យរស់នៅបាន កិច្ចការធ្ងន់ស្រាលទាំងប៉ុន្មានក្លាយជាការងារធម្មតា ហើយខ្ញុំត្រូវតែតាំងចិត្តធ្វើឲ្យបានទាំងអស់។

ជំងឺបាក់ជំរោយ

រាងកាយរបស់ខ្ញុំស្គមស្គាំង ស្វិតស្រពោនក្រៀមក្រញង់ ខ្មៅក្រញេស មើលមិនយល់ឡើយ។ រាល់ថ្ងៃ ខ្ញុំទៅធ្វើការទាំងខ្លួនមានជំងឺ ដែលបណ្តាលមកពីការធ្វើការងារធ្ងន់បាក់កម្លាំង និងទទួលទានអាហារខ្វះជីវជាតិ។ ចាប់តាំងពីខ្ញុំដឹងថាខ្លួនរបស់ខ្ញុំមានជំងឺបាក់ជំរោយមក ខ្ញុំហាក់មិនសូវសប្បាយចិត្តនឹងការងារទាំងនោះឡើយ។ ម៉្យាងទៀត ខ្ញុំមិនខ្លាចនឹងការគំរាមកំហែងរបស់ប្រធានកងទៀតទេ។ ពួកគេតែងតែប្រើសម្តីគំហកខ្លាំងៗដាក់ខ្ញុំ។ មេកងថា ខ្ញុំជាមនុស្សពុតធ្វើជាឈឺ ម៉្យាងទៀតមេកងចេះតែមករំអុកដាក់ខ្ញុំម្តងហើយម្តងទៀតថា ខ្ញុំជាមនុស្សឈឺសតិអារម្មណ៍ទៅវិញ។ ឪពុកម្តាយរបស់ខ្ញុំ ពេលឃើញខ្ញុំធ្លាក់ខ្លួនឈឺដូច្នេះ ពួកគាត់ពិបាកចិត្តណាស់។ ឪពុកម្តាយរបស់ខ្ញុំ មិនដែលបញ្ចេញឲ្យខ្ញុំឃើញថា ពួកគាត់មានការពិបាកចិត្ត ព្រោះតែរូបខ្ញុំឡើយ។ ពួកគាត់តែងតែបង្ហាញទឹកមុខស្រស់ញញឹមដាក់ខ្ញុំ និងលើកទឹកចិត្តខ្ញុំជានិច្ច។

រាល់យប់ក្នុងរដូវច្រូត ខ្យល់តែងតែបក់មកពីទិសខាងជើងត្រជាក់ណាស់ ប៉ុន្តែខ្លួនរបស់ខ្ញុំ បែរជាក្តៅទៅវិញ។ ឪពុករបស់ខ្ញុំ តែងតែអុជធូបបន់ស្រន់ដល់វត្ថុស័ក្តិសិទ្ធិឲ្យមកជួយបីបាច់ថែរក្សាខ្ញុំឲ្យបានឆាប់ជាសះស្បើយពីជំងឺឡើងវិញ។ ឪពុករបស់ខ្ញុំ តែងតែធ្វើដំណើរទៅដងទឹកពីប្រាសាទ និងស្ពានទាំងអស់ដើម្បីយកមកឲ្យខ្ញុំផឹក និងពពោកលើខ្លួនប្រាណរបស់ខ្ញុំ ដោយរំពឹងទុកថា ទឹកទាំងនោះអាចជួយធ្វើឲ្យខ្ញុំ ជាសះស្បើយបាន។ ឪពុករបស់ខ្ញុំ បានយកទឹកដាក់ក្នុងផ្តិលខាត់ប្រហែលមួយថ្នាំងដៃឲ្យខ្ញុំផឹកបន្តិចរួចយកមកដាក់ពីលើពោះរបស់ខ្ញុំ ដើម្បីឲ្យកម្តៅក្នុងខ្លួនរបស់ខ្ញុំឆាប់ចុះត្រជាក់។ ចំណែកម្តាយរបស់ខ្ញុំវិញយកបបរមកបញ្ចុកខ្ញុំ។ បងប្អូន និងអ្នកជិតខាង តែងតែនាំគ្នាមកសួរសុខទុក្ខខ្ញុំ មិនដែលដាច់ឡើយ។ កម្លាំងចិត្តទាំងអស់របស់ពួកគាត់ បានជំរុញកម្លាំងចិត្តរបស់ខ្ញុំ ឲ្យខិតខំតស៊ូនឹងជំងឺរហូតបានធូរស្បើយ។

ឪពុករបស់ខ្ញុំនិយាយមករកខ្ញុំដោយសេចក្តីសង្ឃឹមថា «កម្តៅខ្លួនចុះត្រជាក់ហើយ ចំណែកទឹកមុខរបស់កូនក៏កាន់តែប្រសើរថ្លាជាងមុនដែរ បារមីវត្ថុស័ក្តិសិទ្ធិពិតជាជួយកូនរបស់ពុកឲ្យជាសះស្បើយហើយ»។

ខ្ញុំញញឹមទៅរកគាត់ដោយក្តីរំភើបក្នុងចិត្ត បើទោះជាខ្ញុំកំពុងតែដេកនៅនឹងកន្ទេលក្រោកមិនទាន់រួចស្រួលបួលក៏ដោយ។ ម្តាយរបស់ខ្ញុំ លូកដៃស៊កពីក្រោមករបស់ខ្ញុំ រួចលើកខ្ញុំឡើងឲ្យអង្គុយ។ ខ្ញុំដាក់ភ្នែកទៅទីណាក៏ឃើញសុទ្ធតែពណ៌លឿងទាំងអស់ គ្មានឃើញអ្វីស្រស់បំព្រងដូចគ្រាមុនឡើយ។ ភាពឆេងឆោងនៅមិនទាន់ចាកឆ្ងាយពីខ្ញុំទេ។ ខ្ញុំប្រឹងហូបបបរឲ្យបានច្រើន ដើម្បីឲ្យសុខភាពរបស់ខ្ញុំកាន់តែរឹងមាំជាងមុន។ ឪពុករបស់ខ្ញុំអង្គុយក្បែរខ្ញុំ ដោយដៃកាន់កន្សែងជ្រលក់ទឹកជូតដៃជើង និងដងខ្លួនឲ្យខ្ញុំ។

ម្តាយរបស់ខ្ញុំ បាននិយាយមកខ្ញុំថា «ថ្ងៃនេះកូនហូបបបរបានច្រើនណាស់កូនស្រីម៉ែជាហើយ»។ ខ្ញុំញញឹមទៅរកគាត់។ ឪពុករបស់ខ្ញុំនៅតែបន្តពពោកទឹកឲ្យខ្ញុំរហូតទាល់តែខ្ញុំមានអារម្មណ៍ថារងារហូតដល់ខ្ញុំទាញភួយយកមកដណ្តប់ ទើបគាត់ឈប់ជូតឲ្យខ្ញុំ។ ថ្នាំដែលខ្ញុំផឹកព្យាបាលជំងឺរបស់ខ្ញុំជាប្រភេទថ្នាំបុរាណ រួមមានការផ្សំពីទឹកដោះខ្លា ឆ្អឹងសត្វ ស្បែកសត្វ សំបកសិប្បសត្វ ឫសឈើ សំបកឈើ ខ្លឹមឈើ និងផ្លែឈើ ដែលឈើខ្លះ ក៏ជាប្រភេទឈើពុលដែរ។ ថ្នាំទាំងអស់នោះ គឺជាឱសថស័ក្តិសិទ្ធិណាស់។ ថ្នាំទាំងនោះ ត្រូវយកមកដុសនឹងដុំថ្មមួយដុំជាមួយនឹងទឹក។ ខ្ញុំសង្កេតឃើញថា ថ្នាំខ្លះត្រូវដុសម្តង ថ្នាំខ្លះត្រូវដុសពីរដង ឯខ្លះទៀតត្រូវដុសបីដង តម្រូវតាមប្រភេទជំងឺ ដូចជា ថ្នាំបញ្ចុះកម្តៅ ឈឺក្បាល និងវិលមុខជាដើម។

ព្រលឹងជីវិត

ព្រលឹងហាក់ហោះចូលមកនៅក្នុងខ្លួនរបស់ខ្ញុំវិញ ខ្ញុំត្រូវតែខំហូបចំណីអាហារដើម្បីឲ្យសុខភាពឆាប់រឹងមាំ ពិសេសដើម្បីបានឃើញទិដ្ឋភាពស្រុកភូមិរបស់ខ្ញុំសារជាថ្មីម្តងទៀត ដែលនឹងស្ថិតក្នុងសុខសន្តិភាពយ៉ាងសុខសាន្ត។

ថ្ងៃនេះស្ថានភាពជំងឺរបស់ខ្ញុំកាន់តែប្រសើរឡើង ខ្ញុំអាចដើរបាន និងធ្វើអ្វីៗបានដូចធម្មតាវិញ។ ឪពុកម្តាយរបស់ខ្ញុំ និងបងប្អូនអ្នកជិតខាងទាំងអស់ក៏មានចិត្តសប្បាយរីករាយដោយឃើញខ្ញុំបានជា និងមានសាច់ឈាមល្អប្រសើរដូចដើមវិញ។

ពេលវេលាមួយបានមកដល់ ខ្ញុំនិងក្រុមគ្រួសារ និងអ្នកភូមិទាំងអស់ អាចធ្វើដំណើរត្រលប់ទៅភូមិកំណើតវិញ។ គ្រាន់តែប៉ុន្មានខែកន្លងមកនេះ ស្រូវទុំដួលរាបដល់ដី ខ្លះត្រូវភ្លើងឆេះគ្មានសល់ ខ្លះទៀតដុះសារឡើងវិញ។ សត្វចាប បក្សាបក្សី

ហិចហើរចុះទន្ទ្រានស៊ីស្រូវទាំងកង ទាំងហ្វូងតាមចិត្តស្ទើរគ្មានសល់បន្តិចឡើយ។ ក្នុងភូមិមានផ្ទះតែគ្មានមនុស្សនៅ មានផ្លូវប៉ុន្តែគ្មានមនុស្សដើរ ស្មៅដុះច្រូងច្រាង ក្លាយជាកន្លែងមូស និងពពួកសត្វផ្សេងៗរស់នៅទៅវិញ។ ដើមដូង ដើមត្នោត ដើមស្វាយ ដើមខ្នុរ និងដើមទឹកដោះ ដែលខ្ពស់ៗ មួយចំនួនត្រូវបានបាក់ចុះមកដី ដែលបណ្តាលមកពីត្រូវគ្រាប់កាំភ្លើងប្រយុទ្ធតគ្នាក្នុងពេលមានសង្គ្រាម។

ភូមិកំណើតដ៏កម្សត់របស់ខ្ញុំ មិននឹកស្មានថា ខ្ញុំអាចវិលមកជួបអ្នកសារជាថ្មីសោះ។ ខ្ញុំប្រាថ្នាថានឹងរស់នៅក្នុងស្រុកនេះ មិនចាកចេញដោយសារសង្គ្រាមទៀតឡើយ។ បើទោះបីជាខ្ញុំត្រូវបាត់បង់ជីវិតក៏ដោយ ក៏សូមឲ្យខ្ញុំស្លាប់នៅក្នុងស្រុកកំណើតទៅចុះ។

ម្តាយរបស់ខ្ញុំ បានចូលទៅរៀបចំផ្ទះ និងអុជធូបបន់ស្រន់នៅកន្លែងព្រះភូមិដែលរៀបដាក់តម្កល់ក្នុងផ្ទះ។ គាត់ប្រាប់ដល់ជំនាងផ្ទះថា ម្ចាស់ផ្ទះមកវិញហើយ សូមឲ្យសុខសប្បាយក្នុងការរស់នៅជួបតែសេចក្តីសុខចម្រុងចម្រើន។ ខ្ញុំមើលម្តាយរបស់ខ្ញុំដោយស្ងៀមស្ងាត់។ ឪពុករបស់ខ្ញុំ ជាមនុស្សឧស្សាហ៍ កាលបើឃើញផ្ទះសុទ្ធតែស្មៅដុះជុំជិតយ៉ាងនេះ គាត់ក៏បានយកខ្វៃ និងចបមកឆ្ការជម្រះឲ្យស្រឡះល្អមួយរំពេច។ ខ្ញុំជួយប្រមូលសំរាមដុតឲ្យស្រឡះល្អ។ ខ្ញុំសែនអាណិតឆ្កែនិងឆ្មារបស់ខ្ញុំណាស់។ ពួកគេរស់នៅទីនេះដោយគ្មានម្ចាស់មួយរយៈកាលកន្លងទៅនេះមិនដឹងថាបានអ្វីស៊ីនោះទេ។ គ្រាន់តែឃើញម្ចាស់មកដល់ផ្ទះ ឆ្កែនិងឆ្មារបស់ខ្ញុំ បានរត់មកឱបផងយំស្រែកផងនៅចំពោះមុខយើង ដូចជាចង់ប្រាប់ថា គេនឹកណាស់ គេព្រួយណាស់ គេវេទនាណាស់។ ខ្ញុំលុតជង្គង់ទាំងពីរយកដៃត្រកងពីក្រោមទ្រូងរបស់ឆ្កែនិងឆ្មារបស់ខ្ញុំ រួចឱបដោយក្តីស្រលាញ់និងនឹករឭក។ ទឹកភ្នែករបស់ខ្ញុំ បានហូរមកដោយសេចក្តីរំភើបចំពោះការវិលត្រលប់មកសារជាថ្មីរបស់ក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជនកម្ពុជាទាំងអស់។

ចប់

៤៨

រឿង ពេលដែលខ្ញុំបើកភ្នែក

អ្នកនិពន្ធ ៖ ជួន ខ្មៅ

៤៨ ~ រឿង ពេលដែលខ្ញុំបើកភ្នែក

ខ្ញុំបើកភ្នែកសម្លឹងមើលពិភពលោកមួយនេះ ដូចជាតូចចង្អៀតណាស់។ មនុស្សម្នាទាំងឡាយបានមកប្រមូលផ្តុំគ្នារស់នៅជាកង ជាពួក តាមលំដាប់វ័យ រួមមាន កុមារ យុវជន និងមនុស្សចាស់។ កង ឬក្រុមនីមួយៗ ធ្វើការរួម ហូបរួម និងស្នាក់នៅរួមគ្នា។ សកម្មភាពការងារចេះតែបន្តទៅមុខពោរពេញដោយថាមពល គ្មានការរាថយឡើយ។

ស្នូរគាំង បន្លឺឡើងជាសញ្ញាសម្រាប់ដាស់មនុស្សឲ្យក្រោកពីដំណេក ទទួលទានអាហារ ចេញទៅធ្វើការ និងឈប់សម្រាកពីការងារឲ្យបានទៀងទាត់។ ក្មេងតូចៗដើររើសអាចម៍គោ កាប់ដើមទន្ទ្រានខែត្រ ទុកសម្រាប់ធ្វើជី។ ចាស់ៗ បិតបូស្សីធ្វើកព្រែង ល្អីកញ្ជើ និងវៃញ្ញែគោ។ មនុស្សពេញវ័យ ដូចជាក្រុមយុវជន យុវនារី គឺជាកម្លាំងឈានមុខ។ នៅក្នុងរបបខ្មែរក្រហម មានប្រឡាយខ្នាត់ខ្នែង ទំនប់តូចធំ លាតសន្ធឹងល្វឹងល្វើយ ភ្លឺស្រែត្រង់ដូចបន្ទាត់ និងផ្ទៃស្រែមានសណ្ឋាន ដូចក្រឡាចត្រង្គ។ រីឯសម្ភារវិញ មិនមានអ្វីទំនើបជាងចប និងបង្គីសោះឡើយ។ ចុះហេតុអ្វីបានជាប្រជាជនមានកម្លាំងមហាសាលអាចសម្រេចកិច្ចការច្រើនសន្ធឹក សន្ធាប់យ៉ាងនេះ?

ពេលយើងសម្លឹងមើលពីរបបអាហារនៅក្នុងរបបខ្មែរក្រហមវិញ ពិតជាមិន គួរឲ្យជឿសោះថា ប្រជាជនអាចសម្រេចបានកិច្ចការទាំងអស់ដែលអង្គការបាន កំណត់ឲ្យនោះទេ។ ប្រជាជនម្នាក់ៗទទួលបានបបរវាវសុទ្ធតែទឹកមើលឆ្លុះដល់ បាតចាន ជួនបបរលាយជាមួយនឹងព្រលឹត ឬស្លឹកដំឡូងមី ដែលត្រូវចុងភៅដួស

ចែកដោយមានបរិមាណកំណត់។ ក្មេងៗភាគច្រើន មិនអាចទ្រាំជាមួយនឹងភាពអត់ឃ្លាននេះបានទេ។ សូម្បីតែខ្ញុំ ក៏មិនអាចអត់ទ្រាំនឹងភាពអត់ឃ្លាននេះបានដែរ រហូតមានថ្ងៃមួយ ខ្ញុំស្រែកជេរចុងភៅរឿងឲ្យបបរតិចក៏មានដែរ។ ខ្ញុំពិតជាសំណាងហើយដែលអង្គការមិនយកទោស កុំអីខ្ញុំគ្មានជីវិតរស់ដល់សព្វថ្ងៃនេះទេ។

នៅក្នុងរបបខ្មែរក្រហម ទោះបីប្រជាជនកើតគ្រុនក្តៅ គ្រុនចាញ់ញ័រញាក់ ខ្យល់ចាប់ ឬពាក្យរូសយ៉ាងណាក៏ដោយ ក៏អង្គការមិនអនុញ្ញាតឲ្យយើងឈប់សម្រាកពីការងារបានដែរ។ ប្រសិនបើយើងស្នើសុំច្បាប់ឈប់សម្រាក អង្គការនឹងចោទយើងថាខ្ជិល ធ្វើពុត ឬយកលេសប្រឆាំងនឹងអង្គការ។ ប្រជាជនដែលប្រឆាំងនឹងអង្គការ ត្រូវចាត់ទុកថាជាខ្មាំង។ ប្រជាជនដែលជា ខ្មាំង គឺត្រូវតែកម្ទេចចោល។ ហេតុនេះហើយ ប្រជាជនម្នាក់ៗត្រូវតែខិតខំធ្វើការទាំងឈឺ មិនថាយប់ឬថ្ងៃ ភ្លៀង ឬក្តៅឡើយ។ ប្រជាជនម្នាក់ៗមានសភាពស្គេកស្គាំង ស្គមរាងរៃ និងហើមហត់ ដែលបណ្តាលមកពីរបបអាហារមិនគ្រប់គ្រាន់ ធ្វើការហួសកម្លាំង។ នៅពេលមានប្រជាជនឈឺជំងឺអ្វីក៏ដោយ គ្រូពេទ្យខ្មែរក្រហម ឲ្យត្រឹមតែថ្នាំបុរាណដែលមានរូបរាងមូលខ្មៅស្រដៀងនឹងអាចម៍ទន្សាយលេប ហើយយកទឹកដូងមកធ្វើជាសេរ៉ូម។ មនុស្សស្លាប់ជាបន្តបន្ទាប់ដោយជំងឺ គ្រាប់កាំភ្លើង និងការសម្លាប់ផង។

កុងរបស់ខ្ញុំចេះតែហើមរហូត មើលមិនជាទេ។ ទីបំផុតគាត់មិនអាចទ្រាំទ្រនឹងជំងឺ ការងារ និងភាពអត់នេះបាន។ មុននឹងស្លាប់ គាត់បានផ្តាំ ឲ្យយើងយកផ្ទឹងរបស់គាត់ទៅទុកនៅស្រុកកំណើតផង។ យើងមិនអាចធ្វើតាមបណ្តាំរបស់គាត់បានទេ ព្រោះសង្គ្រាមចេះតែអូសបន្លាយទៅៗ។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្មែរក្រហម ចេះតែផ្លាស់ប្រជាជនទៅធ្វើការនិងរស់នៅពីកន្លែងមួយទៅកន្លែងមួយទៀតមិនទៀងទាត់ឡើយ។ ប្អូនប្រុសរបស់ខ្ញុំ ឃ្លានរហូតដល់ដាច់ពោះស្លាប់។ ក្រោយមក ប្រធានសហករណ៍ បានតែងតាំងឪពុករបស់ខ្ញុំ ជាអ្នកផ្គត់ផ្គង់ស្បៀង។ អង្ករ ត្រីខ អំបិល ទឹកត្រី និងស្ករ ត្រូវបែងចែកទៅតាមគោលដៅដែលអង្គការបានកំណត់ឲ្យ។ ប្រជាជនគោរពស្រលាញ់ និងចូលចិត្តឪពុករបស់ខ្ញុំណាស់ ព្រោះគាត់ជាមនុស្សស្មោះត្រង់ និងមានទឹកចិត្តល្អ។

ពេលយប់ ផ្ទះរបស់ខ្ញុំគ្មានពន្លឺភ្លើងបំភ្លឺនោះទេ។ យប់មួយនោះ មានសម្លេងធ្លាក់ឮសូរតែក្នុងលើរនាបក្តារកណ្តាលផ្ទះ។ ម្តាយរបស់ខ្ញុំ បានរំកិលតិចៗរាវរករបស់ដែលធ្លាក់នោះ។ តាមពិត វាជាកញ្ចប់បាយដែលឪពុករបស់ខ្ញុំបោះពីខាងក្រៅផ្ទះចូលមក។ បាយនោះពិតជាធ្ងាញ់ណាស់ក្នុងភាពអត់ឃ្លានបែបនេះ។ ប្រហែលមានតែគ្រួសាររបស់ខ្ញុំទេ ដែលមានវាសនាបានហូបបាយរឹងក្នុងពេលដែលប្រជាជនជាច្រើនហុតតែបបររាវស្ទើរតែគ្មានគ្រាប់អង្ករ។ មិនជាយូរប៉ុន្មានមានលេចឮពាក្យពីថ្នាក់លើមកថា ឪពុករបស់ខ្ញុំបម្រើរបបឯកជន ដែលផ្ទុយនឹងគោលការណ៍របស់អង្គការ។ ពុកដឹងខ្លួនថា មិនយូរប៉ុន្មានឡើយ អង្គការនឹងហៅគាត់ទៅរៀនសូត្រ។

លុះព្រឹកឡើង ឌឹម ដែលជាប្រធានសហករណ៍ និងជាអ្នករាយការណ៍ទៅថ្នាក់លើ ត្រូវអង្គការបណ្តើរចេញទៅ។ ឪពុករបស់ខ្ញុំកាន់តែអស់ជំនឿចិត្តថាអាចបន្តជីវិតរស់នៅបន្តទៀត។ ថ្ងៃនោះ គាត់អង្គុយសំលៀងកាំបិតបណ្តើរនឹកគិតបណ្តើរថា ព្រឹកនេះ ឌឹម ព្រឹកស្អែកអាចនឹងដល់វេនគាត់ម្តង។ ឪពុករបស់ខ្ញុំតាំងចិត្តថា ប្រសិនបើឮសំឡេងមនុស្សចម្លែកមកហៅ គាត់នឹងមិនឲ្យចូលមកចាប់គាត់បានជាដាច់ខាត។ គាត់ស៊ូស្លាប់នឹងគ្រាប់កាំភ្លើង ក៏មិនឲ្យពួកគេធ្វើទារុណកម្មឡើយ។ យប់នោះ គាត់ដេកមិនលក់សោះរហូតជិតភ្លឺ។ បន្ទាប់មកសំឡេងផ្ទុះអារុធចាប់ផ្តើមកក្រើកសារជាថ្មីម្តងទៀត មានស្នូរកាំភ្លើងដៃ កាំភ្លើងម៉ាស៊ីន និងគ្រាប់ផ្លោងចម្រុះស្ទើរពេញមួយផែនដី។ ប្រជាជនទាំងអស់ត្រូវបង្ខំឲ្យចាកចេញពីកន្លែងរស់នៅ។ ដំណើរប្រសេចប្រសាចយ៉ាងឥតសណ្តាប់ធ្នាប់ បានគ្របជិតផ្ទៃដងផ្លូវ ដោយមានកងទ័ពខ្មែរក្រហម ដើរអម។

យើងមិនដឹងថាខ្មែរក្រហមឲ្យយើងធ្វើដំណើរឆ្ពោះទៅកាន់ទីណានោះទេ។ ខ្ញុំស្ពាយបង្វែចមួយ ឪពុករបស់ខ្ញុំ រែកកំណាត់បាវដាក់ចានឆ្នាំងម្ខាង និងធុងដាក់អង្ករម្ខាង ម៉ែរបស់ខ្ញុំទូលបាវ ដៃម្ខាងពប្អូនប្រុសរបស់ខ្ញុំ។ ចំណែកឯបងស្រីរបស់ខ្ញុំវិញ កណ្តៀតកន្សែលម្ខាង កៅស៊ូតង់ម្ខាង ហើយបងប្រុសរបស់ខ្ញុំទូលបង្វែចខោអាវ និងស្ពាយថង់មួយ។ យើងធ្វើដំណើរ ផុតពីផ្លូវ យើងត្រូវដើរចូល

ព្រៃកាត់បន្លាចុះទឹកត្រឹមជង្គង់ ហើយនៅទីបំផុតយើងបានទៅដល់ទីទួលមួយ។ ប្រជាជនទាំងអស់បានឈប់សម្រាក ជាក់សម្លាយជាក់អំរែកចុះ ហើយប្រជាជនទាំងអស់បានបោះតង់ និងចម្អិនអាហារ។

ភ្លៀងវស្សាចេះតែបង្អុរចុះមិនដាច់ ការធ្វើដំណើររបស់យើងនៅតែបន្តទៅមុខ។ ដោយយប់ងងឹតពេក បងស្រីរបស់ខ្ញុំក៏វង្វេងមិនដឹងទៅដល់ទីណា។ ឪពុករបស់ខ្ញុំ បានស្រែកហៅនិងតាមរកពីរយប់ពីរថ្ងៃ នៅតែមិនឮបងស្រីរបស់ខ្ញុំឆ្លើយតប។ ព្រលឹមស្រាងៗព្រឹកថ្ងៃទីបី យើងស្រាប់តែឃើញបងស្រីរបស់ខ្ញុំកំពុងតែអង្គុយនៅក្រោមតង់របស់គ្រួសារមួយនៅក្បែរនោះ។ ម៉ែសប្បាយចិត្តបន្តិច ព្រោះបានកូនស្រីមកវិញ។ ប្រហែលមួយសប្តាហ៍ អ្នកដំណើរទាំងអស់បានមកដល់ជំរំជនភៀសខ្លួន ដែលស្ថិតនៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ។

ក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជនខ្មែរជាច្រើនទៀត បានផ្ទៀវាសនា នៅក្នុងជំរំស្ថិតនៅតាមទល់ដែនខ្មែរ-ថៃជាច្រើននាក់។ ស្នាមញញឹម បានផុសចេញមកបណ្តើរៗចេញពីទឹកមុខប្រជាជនទោះបីជាសង្គ្រាមមិនទាន់បានរលត់ផុតយ៉ាងណាក៏ដោយ។ នៅពេលនោះ អង្គការសហប្រជាជាតិ បានផ្តល់ឲ្យ រួមមានទឹក ស្បៀង របស់ប្រើប្រាស់ និងថ្នាំពេទ្យ សម្រាប់ការស្នាក់នៅទីនោះ។ អ្នកកាន់បុងពណ៌ក្រហម ត្រូវឈរតម្រង់ជួរទទួលអំណោយមុនអ្នកកាន់បុងពណ៌ស។ ថ្ងៃមួយ ឪពុករបស់ខ្ញុំ ត្រូវបានអ្នកគ្រប់គ្រងជំរំនោះណែនាំឲ្យរៀបចំឡើងយន្តហោះទៅកាន់បរទេស ប៉ុន្តែគាត់បានបដិសេធ។ ឪពុករបស់ខ្ញុំយល់ថា គាត់មិនបានរៀនសូត្រ គ្មានចំណេះដឹងជ្រៅជ្រះ មិនដឹងជាទៅរកស៊ី ឬធ្វើការអ្វីនៅប្រទេសគេឡើយ។

សង្គ្រាមនៅតែមិនទាន់បញ្ចប់។ រៀងរាល់ពេលរសៀលគ្រាប់ផ្លោងស្ទើរតែគ្រប់ប្រភេទ បានជះមកពីទិសខាងជើងដូចជាទឹកភ្លៀង។ ពេលនោះ ខ្ញុំកើតកញ្ជ្រឹលមិនសូវមានកម្លាំងទេ។ ជួនកាល ខ្ញុំរត់ចូលលេណដ្ឋានមិនទាន់ ក៏ក្រាបចុះក្នុងជ្រលងទឹក។ រហូតមកដល់ពេលនេះ ខ្ញុំចាំមិនបានទេថា ឪពុករបស់ខ្ញុំបាននាំក្រុមគ្រួសារត្រលប់មកកាន់ខេត្តបាត់ដំបងវិញតាំងពីពេលណាទេ។ ខ្ញុំគ្រាន់តែ

ចាំបានថា ពេលម៉ោងចេញលេង ខ្ញុំបានរត់មកផ្ទះហូបបាយកកលាយទឹកត្នោត ព្រោះសាលារៀនរបស់ខ្ញុំនៅជាប់នឹងរបងផ្ទះ។ ជាញឹកញាប់ ខ្ញុំឃើញម៉ែសម្រក់ទឹកភ្នែករាល់ពេលដែលគាត់ទទូចសុំឲ្យឪពុករបស់ខ្ញុំជូនត្រលប់ទៅស្រុកកំណើត។ ម៉ែរបស់ខ្ញុំ ធ្ងន់ត្រចៀកស្តាប់ពុំសូវឮតាំងពីកំណើតរបស់ខ្ញុំម្ល៉េះ ព្រោះតែសំឡេងយន្តហោះ និងសំឡេងទម្លាក់គ្រាប់បែកខ្លាំងពេក។ បន្ទាប់មក ឪពុករបស់ខ្ញុំបានសម្រេចចិត្តធ្វើតាមពាក្យទទូចសុំទៅស្រុកកំណើតរបស់ម៉ែ។

រទេះគោមួយអាចផ្ទុកមនុស្សបានមួយគ្រួសារល្មម។ នៅពេលដែលយើងមកដល់ភូមិមួយ យើងបានឈប់រទេះបន្តិច ហើយមានសាច់ញាតិរបស់យើងជាច្រើនចេញមកទទួលរាក់ទាក់ និងសួរសុខទុក្ខក្រុមគ្រួសាររបស់ខ្ញុំ។ ពួកគាត់សុទ្ធតែជាសាច់ញាតិខាងឪពុករបស់ខ្ញុំ រួមមាន បងជីដូនមួយ ក្មួយៗ និងចៅៗ ដែលកំពុងតែរស់នៅលើទឹកដីខេត្តកំពត។ យើងរីករាយលាយឡំជាមួយនឹងទឹកភ្នែក។

ល្ងាចបន្តិច រទេះរបស់យើងបានមកដល់ភូមិកន្លង់ដែលជាទឹកដីញាតិខាងម្តាយរបស់ខ្ញុំ។ សំឡេងសើចក្អាកក្អាយបានផុសឡើងចេញពីក្នុងភូមិភ្នំកន្លង់ ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត នៅពេលដែលពួកយើងបានមកដល់។ បងប្អូន ក្មួយៗ និងអ្នកភូមិបានមកផ្តុំគ្នា សួរសុខទុក្ខ និងសំណេះសំណាលជាមួយក្រុមគ្រួសារខ្ញុំរហូតដល់យប់ជ្រៅ។ ម៉ែបានសម្រក់ទឹកភ្នែកក្នុងក្តីរីករាយពេលបានមកជួបជុំបងប្អូនរបស់គាត់។ ប្រហែលជាពីរឆ្នាំតាំងពីក្អែកខ្មៅបានហើរចេញផុតទៅ ខ្ញុំបានបើកភ្នែកក្រឡេកមើលពិភពលោកនេះសារជាថ្មីម្តងទៀត។ គ្រប់ពណ៌ទាំងអស់ បានរីកស្គុសស្គាយឡើងនៅលើសម្លៀកបំពាក់ប្រជាជនខ្មែរគ្រប់រូប មិនមែនមានតែពណ៌ខ្មៅដូចនៅក្នុងរបបខ្មែរក្រហមទេ។

ចប់

៤៩

រឿង ស្នែកដៅក្នុងចិត្ត

អ្នកនិពន្ធ ៖ ប្រុស សុខ

៤៩ ~ រឿង ភ្នែកដៅក្នុងចិត្ត

សូរសំឡេងឡានបើកលើផ្លូវជាតិដោយល្បឿនយឺតៗ ប៉ុន្តែសន្ធឹកឡានមិនអាចឈ្នះសំឡេងសត្វរៃកណ្តឹង ដែលកំពុងស្រែកច្រៀងយ៉ាងសប្បាយនៅលើចុងឈើអមតាមផ្លូវទេ។ ឡានបើកភ្លើងផ្តល់ជាសញ្ញាទៅក្បែរម្ខាងចិញ្ចើមផ្លូវដើម្បីចត ព្រោះទ្វារកញ្ចក់ឡានផ្នែកខាងក្រោយរបើក។ វាយោបក់មកធ្វើឲ្យដើមឈើរោរប្រៀបដូចជាកំពុងរាំទៅតាមរៃច្រៀង។ ឯស្លឹកឈើទុំជ្រុះចាក់មែក ព្រមទាំងនាំក្លិនផ្កាដំណែលបក់មកប៉ះនឹងច្រមុះស្ត្រីម្នាក់ដែលនៅក្នុងឡាន។ សំឡេងឡានមួយផ្សេងទៀត បានមកពីក្រោយហើយស៊ីផ្លេឡើង។ រំពេចនោះ ឡានទាំងពីរក៏ចេញដំណើរលើរុក្ខវិថីខ្វែងខ្វាត់បាត់ស្រមោលទៅ។ មនុស្សម្នាអ៊ូអរសើចសប្បាយឆ្លងកាត់ផ្លូវ ធ្វើដំណើរឆ្ពោះទៅកាន់សំឡេងភ្លេងប្រពៃណីខ្មែរ ដែលលាន់ឮចេញពីក្នុងព្រៃ។ ប្រជាជនស្លៀកសម្លៀកបំពាក់ថ្មីប្លែកៗពណ៌ស្រស់ឆើតឆាយ អ្នកខ្លះដើរ អ្នកខ្លះជិះកង់ម៉ូតូ និងអ្នកខ្លះជិះឡានដែរ បានមកចតកកកុញក្រោមដើមរុក្ខាខ្ពស់ៗនៅពីមុខបរិវេណប្រាសាទ។ ចំណែកឯ ឡានទាំងពីរ ក៏បានមកចតនៅទីនោះដូចគ្នាដែរ។

ក្រោយពីចតស្រួលហើយ ទ្វារឡានបានបើក។ ស្ត្រីចំណាស់ម្នាក់ បានចេញមកពីក្នុងឡានរួចចោលភ្នែកមើលទៅកាន់ប្រាសាទដោយស្នាមញញឹម។ ពេលនោះ ស្រាប់តែមានក្មេងស្រីអាយុប្រហែល ៨ឆ្នាំម្នាក់ រត់មក ហើយស្រែកហៅថា យាយ។ ស្ត្រីនោះបែរមុខទៅរកម្ចាស់សំឡេង រួចបន្ទន់ជង្គង់ បើកដៃទាំងពីរចាំឱបក្មេងស្រីនោះ។ រីអ្នកផ្សេងទៀត ដើរតាមពីក្រោយ ហើយញញឹមទាំងអស់គ្នា។

ពេលមកដល់ក្បែរក្មេងស្រី បុរសវ័យចំណាស់ម្នាក់ដែលឈរក្បែរប្រពន្ធបាន និយាយចំអន់ទៅចៅស្រីថា «ចៅស្រីកំហូចនេះ មិននឹកដល់តាសោះ នឹកតែយាយ»។ ក្មេងស្រីនោះក៏តប «លោកតាមានយាយ សន្យា នៅក្បែរកក់ក្តៅហើយ តែលោកយាយ សោកណ្តា ត្រូវការកម្តៅពីខ្ញុំ»។ ម្នាក់ៗសើចផងញញឹមផងបិទមាត់មិនជិតហើយធ្វើដំណើរទៅកាន់កន្លែងដែលគេកំពុងតែលេងភ្លេងត្រុដិនៅក្នុងបរិវេណប្រាសាទ។ មកដល់កន្លែង លេងរបាំត្រុដិ គ្រប់ៗគ្នាញញឹមសើចសប្បាយ ដើម្បីនាំយកសិរីសួស្តីឆ្នាំថ្មី។ លើកលែងតែ យាយសោកំណា បែរជាមានទឹកមុខស្រពោន អារម្មណ៍ហាក់បីដូចជាមិនបានគិតដល់ការសម្តែងរបាំត្រុដិឡើយ។ ប្អូនប្រុសរបស់ យាយសោកំណា ឃើញបងស្រីមុខស្រពោនក៏ដើរមកក្បែរ ហើយនិយាយថា «ម៉េចបានជាមុខស្រពោនម្ល៉េះ មិនស្រួលខ្លួនមែនទេ?»។ ទោះបី តាសត្យា ដែលជាប្អូនប្រុសនិយាយទៅកាន់គាត់ពីរបីដងយ៉ាងណាក៏ដោយ ក៏យាយសោកំណា មិនព្រមតបនឹងប្អូនប្រុសរបស់គាត់ទេ។ នៅពេលចៅស្រីឃើញតាហៅយាយច្រើនដង ហើយយាយមិនព្រមតប ទើបនាងដើរទៅអង្រួនដៃយាយ។ យាយសោកំណា ភ្ញាក់ ក្រញាង ទើបតបសម្តីទៅចៅស្រីនិងប្អូនប្រុសថា គាត់សុំនៅស្ងៀមម្នាក់ឯងបន្តិច។ ចៅស្រីចង់ទៅតាមយាយ តែត្រូវតាចាប់ដៃជាប់ហើយនិយាយ «ឲ្យយាយចៅនៅម្នាក់ឯងចុះ។ នេះប្រហែលជាគាត់នឹកដល់រឿងអតីតកាលហើយមើលទៅ»។ ចៅស្រីមើលទៅយាយទាំងបារម្ភ។ តាសត្យា បានប្រាប់កុំឲ្យចៅស្រីបារម្ភពេក ទើបនាងបែរទៅមើលត្រុដិបន្តទៅទៀត។

យាយសោកំណា អង្គុយលើផ្ទាំងថ្មមួយមិនឆ្ងាយប៉ុន្មានពីទីកន្លែងសម្តែងរបាំត្រុដិប៉ុន្មានទេ។ គាត់អង្គុយដូចគ្មានព្រលឹងក្នុងខ្លួនអីចឹង។ ភ្លាមនោះ ស្រាប់តែមានស្ត្រីជំទង់ម្នាក់ រត់ទៅទង្គិចនឹងតួសម្តែងជាសត្វប្រើសបម្រុងដួល ធ្វើឲ្យគាត់នឹកឃើញដល់ខ្លួនរបស់គាត់កាលពី៥០ឆ្នាំមុន ដែលធ្លាប់បានដើរទៅទង្គិចនឹងតួសម្តែងជាសត្វប្រើសដូចគ្នា។ គាត់សើចបន្តិច រួចក៏នឹកដល់ ប៉ា ម៉ាក់ មីង និងសាច់ញាតិរបស់គាត់ ដែលបានឆ្លងកាត់របបខ្មែរក្រហមជាមួយគ្នានៅលើទឹក

ដីនេះ។ ពេលកំពុងតែស្តុងចិត្តទៅក្នុងរឿងរ៉ាវអតីតកាល ស្រាប់តែសំឡេងអ្នកច្រៀងត្រុដិបានជាស់ស្មារតីរបស់គាត់ត្រលប់មកវិញ។ យាយសោភ័ណ បានដកប្រាក់ជាក់ក្នុងថង់យាមរបស់អ្នកសម្តែងតួសត្វប្រើសនោះ រួចដើរត្រលប់ទៅរកក្រុមគ្រួសារវិញ។

ទិដ្ឋភាពទាំងនោះ បានបើកភ្នែកដែលបិទជាយូរឆ្នាំមកហើយឲ្យភ្លឺឡើងវិញ។ មិនថា យាយសោភ័ណ សើចសប្បាយ ញញឹមរីករាយឬធ្វើសកម្មភាពអ្វីនោះទេ ចិត្តរបស់គាត់នៅតែបន្តជិតជាមរឿងឈឺចាប់និរាសព្រាត់ប្រាស់ដែលបានកើតឡើងចំពោះគាត់និងក្រុមគ្រួសារនៅក្នុងរបបខ្មែរក្រហម។ យាយសោភ័ណ នៅតែមានស្នាមញញឹម ប៉ុន្តែរូបរាងកាយរបស់គាត់បានប្រែប្រួលទៅជាស្តមអាប់រស្មីខុសពីពេលមុនរហូតដល់ធ្លាក់ខ្លួនឈឺ។ គាត់ដឹងខ្លួនរបស់គាត់ច្បាស់ថាមិនអាចរស់នៅលើផែនដីនេះបានយូរទៀតទេ។

ក្នុងពេលវិស្សមកាលតូច យាយសោភ័ណ បានឲ្យប្រពន្ធក្មួយប្រុសរបស់គាត់ ជួយកត់ត្រារឿងរ៉ាវ ដែលគាត់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ដើម្បីទុកឲ្យចៅស្រីបានអាននៅពេលធំដឹងក្តីដូចខាងក្រោម៖

ក្នុងវ័យ១៥ឆ្នាំ យុវតីម្នាក់ ស្លៀកសម្លៀកបំពាក់ពណ៌ស ក្រងសក់ទម្លាក់មកលើស្មាខាងមុខ បានមើលទៅរូបគំនូរប្រាសាទអង្គរ ដែលតាំងនៅលើជញ្ជាំងទាំងទឹកមុខអាឡោះអាល័យ។ យុវតី គិតស្រមៃក្នុងចិត្តម្នាក់ឯងថា «ឱ!ប្រាសាទដ៏ល្អឆើតឆាយអើយ អ្នកបានផ្តល់ក្តីសុខដល់ខ្ញុំ និងគ្រួសារច្រើនឆ្នាំទៅហើយ។ ទោះខ្ញុំមិនបានកើតនៅលើទឹកដីអង្គរមែន តែខ្ញុំហាក់មិនចង់ឃ្លាតឆ្ងាយពីអ្នកទេ។ អ្នកបានផ្តល់អនុស្សាវរីយច្រើនណាស់ដល់ខ្ញុំ។ អ្នកក៏ជានិមិត្តរូបនៃភាពរឹងមាំស្ថិតស្ថេរជារៀងរហូត។ ទោះបីជាខ្ញុំមិនអមតៈ តែខ្ញុំនឹងធ្វើជាមនុស្សរឹងមាំ និងចងចាំអ្នករហូតដល់ជីវិតចុងក្រោយ»។ យុវតី និយាយរួចក៏បែរទៅម្ខាងទៀត ទើបចោលភ្នែកទៅប៉ះរូបគំនូរបាំត្រុដិ។ យុវតី ក៏ស្រមៃដល់ពេលមួយដែលនាង និងក្រុមគ្រួសារបានទៅទស្សនាប្រាសាទអង្គរវត្តនាពេលបុណ្យចូលឆ្នាំខ្មែរ។ នាងញញឹម ព្រោះនឹកដល់ពេលដែលខ្លួនបានរត់ទង្គិចប្រើសកំពុងសម្តែង។ យុវតី ចងចាំយ៉ាង

ច្បាស់នៅកែវភ្នែកដ៏មុតថ្លានិងសម្តីស្រទន់របស់យុវជនម្នាក់។ យុវតី បានទស្សនាប្រាសាទនានាក្នុងតំបន់អង្គរ ហើយក្នុងចិត្តនឹកគិតថានឹងអាចបានជួបយុវជនម្នាក់នោះ ក្នុងពេលណាមួយមិនខាន។ យុវតី ហាក់បីដូចជាកំពុងតែមានអារម្មណ៍អណ្តែតរសាត់ ហើយមិនខ្វាយខ្វល់ពីអ្វីទាល់តែសោះ ខណៈពេលដែលស្ត្រីពីរនាក់កំពុងមមាញឹករៀបចំរបស់របរ និងបត់សម្លៀកបំពាក់នៅក្នុងបន្ទប់។ ភ្លាមនោះក៏មានបុរសម្នាក់ កាន់ដៃក្មេងប្រុសដែលមានអាយុ ៧ឆ្នាំ ដើរចូលមកក្នុងផ្ទះ។ ស្ត្រីវ័យ២០ឆ្នាំម្នាក់ បែរជាឃើញក៏លាន់មាត់ថា «បងសោភ័ី!នោះក្មួយ សត្យា និងបង កុសល ត្រលប់មកវិញហើយតើ!»។ និយាយរួច នាងក៏ចេញទៅក្រៅបន្ទប់ដើរតម្រង់ទៅរកក្មួយប្រុស។ ក្មួយប្រុស សត្យា ក៏លែងដៃរបស់ប៉ា រត់តម្រង់មករកមីងដូចគ្នា។ សត្យា ឱបមីងរួចរត់ទៅឱបម្តាយ ដែលកំពុងមមាញឹកដៃ។ កុសល ដើរចូលទៅក្នុងបន្ទប់ហើយសួរថា៖

កុសល៖ «កល្យាណ! តើ សោភ័ណ រៀបចំសម្លៀកបំពាក់ហើយឬនៅបានជាមកឈរមើលរូបគំនូរដូចជាគ្មានព្រលឹងព្រលៃយ៉ាងនេះ?»

កល្យាណ៖ «ចាស៎បង! ប្រហែលជាមិនទាន់រៀបចំទេមើលទៅ ព្រោះឃើញនាងឈរមើលគំនូរនេះមួយព្រឹកទៅហើយ?»

សោភ័ី៖ មិនអីទេ! ចាំខ្ញុំរៀបចំឲ្យកូនក៏បានដែរ។ និយាយអីចឹងយ៉ាងម៉េចទៅហើយរឿងជួលឡានទៅកំពង់ផែនោះ» សោភ័ី និយាយផងដៃបត់ខោអាវផង។

កុសល៖ «មានយ៉ាងម៉េច! តែកុងឡានមិនចង់ទៅប៉ុន្មានទេ ត្បិតអីស្ថានភាពដូចជាមិនសូវស្រួលសោះ។ ប៉ុន្មានថ្ងៃនេះមានកងទ័ពអាវខ្មៅច្រើនណាស់កាន់អាវុធដើរនៅតាមផ្លូវ ហើយរាំងស្ទះចំពោះការធ្វើដំណើរទៅភ្នំពេញទៀត» កុសល និយាយព្រមទាំងដើរទៅបង្អួចចោលភ្នែកសម្លឹងមើលទៅខាងក្រៅ។

សោភ័ី៖ «អីចឹងយើងធ្វើម៉េចទៅ?» សោភ័ី ឈប់បត់ខោអាវសិនរួចនិយាយបែរទៅប្តី។

កុសល៖ «កុំភ័យអី ! ប្រហែលជាវាបិទ ព្រោះលន់ នល់ ទើបតែដួល តែស្អែកនឹងបើកផ្លូវមិនខានទេ។ រៀបចំរបស់របរឲ្យតែរួចទៅ»។

និយាយចប់ កុសល ក៏ដើរចេញពីបន្ទប់សំដៅទៅរក សោភ័ណ។ ចំណែក សោភី មើលមុខកូនប្រុសញញឹម ទាំងមិនចង់ រួចយកដៃអង្អែលក្បាលកូន។ កល្យាណ បានឲ្យក្មួយចេញទៅលេងខាងក្រៅបន្ទប់ជាមួយប៉ា រួចនាងមកអង្គុយជិតបងថ្លៃ ហើយនាងចាប់ដៃបងដោយនិយាយសម្តីលួងលោមកុំឲ្យបងបារម្ភពេក។ សត្យា រត់ចេញពីបន្ទប់ទៅតាមប៉ា និងបងស្រី ដែលកំពុងតែមើលរូបគំនូរ។ កុសល ផ្តើមនិយាយលួងកូនកុំឲ្យព្រួយបារម្ភស្តាយរូបគំនូរ។ ពេលនោះ សោភ័ណ ភ្ញាក់នឹងសំឡេងរបស់ប៉ា រួចបែរមកនិយាយទៅកាន់ប៉ាថា «ខ្ញុំមិនមែនស្តាយគំនូរទេ តែខ្ញុំសប់សែ្ងងនឹងស្នាដៃវិចិត្រករដែលផ្ចិតផ្ចង់ម៉ត់ចត់គួស ចេញជារូបគំនូរមួយៗយ៉ាងស្រស់ស្អាតដូចពិតៗតែម្តង។ អ្វីដែលកូនកំពុងមើល និងចងចាំ គឺសំណង់ប្រាសាទ និងស្នាដៃសិល្បៈជាច្រើន ដែលបុព្វបុរសបន្សល់ទុកមកជាយូរលង់មក។ មិនគួរហេតុអ្វី យើងថែរក្សាមិនបានឬនេះមកពីសង្គ្រាមច្រើនពេក?»។

និយាយដល់ត្រឹមនេះ ស្រាប់តែ សត្យា រត់មកដល់បងស្រីល្មម។ សោភ័ណ បែរទៅប្អូនព្រមទាំងទាញថ្ពាល់ទាំងសងខាងរបស់ សត្យា។ ស្នាមញញឹម និងសំឡេងសើចក្អាកក្អាយ ដោយការរត់ប្រលែងគ្នារបស់បងស្រី និងប្អូនប្រុស ពោរពេញទៅដោយភាពសប្បាយរីករាយ។ ស្នាមញញឹម និងសំណើចទាំងអស់នេះ គឺជាស្នាមញញឹមនិងសំណើចចុងក្រោយ ដែលសមាជិកគ្រួសារនេះមាននៅលើទឹកដីអង្គរ។

ព្រឹកព្រលឹមស្រាងៗ កុសល ប្រាប់ប្រពន្ធឲ្យទៅដាស់កូនៗលុបលាងមុខ។ ថ្ងៃនេះ កុសល មិនបានទទួលទានអាហារពេលព្រឹកទេ ព្រោះប្រញាប់ចេញដំណើរ។ ឡានមកដល់ខាងមុខផ្ទះ កល្យាណ និងសោភ័ណ ដើរចូលទៅក្នុងឡានមុន។ តែកុងឡាន និង កុសល បានយកអីវ៉ាន់ទៅដាក់ក្នុងឡាន។ ចំណែក សោភី កាន់កាបូបនិងចាប់ដៃកូនប្រុសដើរមកតាមពីក្រោយ។ ពេលមនុស្សឡើងឡានគ្រប់គ្នាហើយ ឡានក៏ចាប់ផ្តើមចេញដំណើរទៅ។ ប៉ុន្តែឡានចេញដំណើរមិនទាន់បានទៅដល់កំពង់ផែផង ស្រាប់តែមានកងទ័ពឃាត់ឡាន។ តែកុងឡាន មិនចង់មានរឿងជាមួយនឹងកងទ័ព ក៏បានបត់ឡានត្រលប់ទៅផ្លូវមួយទៀតដើម្បីរកកន្លែងឈប់សួរដំណឹង។ តែកុងឡាន បានកាន់បារីមួយកញ្ចប់តម្រង់ទៅរកកងទ័ព ដែលឈរ

ដាក់រនាំងនៅលើផ្លូវ។ តែកុងឡាន បានឲ្យបារីដល់កងទ័ពនោះ រួចសួរដើងរឿងគ្រប់យ៉ាង។ គាត់ក៏មកប្រាប់ កុសល វិញ។ ពេល កុសល ដឹងរឿងហេតុហើយ ក៏បានហៅប្រពន្ធចេញពីឡាន។ គាត់និយាយគ្នាមួយសន្ទុះក៏បែកគ្នា។ សោភី ប្រែមុខស្រពោនរួចចូលទៅក្នុងឡានវិញ ប៉ុន្តែ កុសល មិនបានចូលទៅជាមួយទេ។ ពេលចូលដិះក្នុងឡានវិញ សោភី បានប្រាប់ទៅកូនៗថា «នៅពេលកូនឃើញប៉ា កូនមិនត្រូវហៅប៉ាជាដាច់ខាត គឺយើងត្រូវធ្វើមិនស្គាល់គ្នា»។ សោភ័ណ ធូល់ខ្លាំងណាស់ ហើយសួរទៅម្តាយថា ហេតុអ្វីត្រូវធ្វើបែបនោះ ប៉ុន្តែ សោភី មិនប្រាប់មូលហេតុដល់កូនទេ ថែមទាំងនិយាយសម្តែតដល់កូនៗទៀត។ ឡានបើកត្រលប់ទៅផ្ទះវិញ ហើយតែកុងឡាន បានដាក់សមាជិកគ្រប់គ្នាចុះ រួចក៏បើកឡានចេញបាត់ទៅ។ មកដល់ផ្ទះ សោភី ហាក់ដូចជាមានអារម្មណ៍មិននឹងនសោះ ហើយប្តូរទៅជាមនុស្សធាប់ឆេវឆាវ មិនថ្នាក់ថ្នមកូនដូចពេលមុន។ កល្យាណ រៀបចំអាហារឲ្យក្មួយៗរួច។ កល្យាណ បានដើរតម្រង់ទៅរកបងថ្លៃ ដែលកំពុងតែអង្គុយអស់សង្ឃឹម។ កល្យាណ បានសួរនាំ សោភី ពីរឿងហេតុដែល កុសល មិនអាចត្រលប់មកផ្ទះវិញថា៖

កល្យាណ៖ «បងភី! តើបងប្រុសមានរឿងអ្វី បានជាគាត់មិនព្រមត្រលប់មកផ្ទះជាមួយយើងដូច្នេះ?ហើយគាត់បាននិយាយអ្វីខ្លះជាមួយបង?» កល្យាណ និយាយតិចៗ ព្រោះមិនចង់ឲ្យក្មួយៗឮ។

សោភី៖ «ឯងដឹងទេ! កងទ័ពទាំងនោះ កំពុងតែតាមចាប់និស្សិត សាស្ត្រចារ្យ មន្ត្រីរាជការ បញ្ញវន្ត និងអ្នកចេះដឹងទាំងឡាយ ហើយកងទ័ពចង់ជម្លៀសប្រជាជនចេញពីក្រុង។ បង កុសល ជាមន្ត្រីរាជការ ខ្លាចក្រែងតែកងទ័ពស្គាល់មុខ ទើបគាត់មិនចង់នាំទុកដល់យើង ហើយព្យាយាមនៅឆ្ងាយៗ។ គាត់ផ្តាំយើងគ្រប់គ្នាត្រូវប្រយ័ត្នសម្តីផង» សោភី និយាយទាំងសស្លន់សស្លោ ហើយកាន់ដៃប្អូនស្រីជាប់។

កល្យាណ៖ «តើយើងត្រូវធ្វើដូចម្តេចទៀតបង?»

សោភី៖ «ល្ងាចនេះ មានរទេះមួយនឹងចេញពីក្រុង គឺរទេះ អ៊ំជង់។ គាត់ស្គាល់ជិតស្និទ្ធនឹងបងឯងណាស់។ គាត់នឹងនាំយើងទៅស្រុករបស់គាត់» សោភីនិយាយមិនទាន់ចប់សម្តី ក៏មានសំឡេងគោះទ្វារឮឡើង។

សោភ័ណ បានលបស្តាប់ម្តាយ និងមីង និយាយគ្នា ភ័យពេកទើបគ្រវាសដៃ ចំប្អូនធ្វើឲ្យដួលបុកក្បាលនឹងទ្វារ។ សោភ័ណ និងប្អូន យំរៀងៗខ្លួន។ កល្យាណ បានបើកទ្វារឃើញក្មួយទាំងពីរយំឱបគ្នា គាត់បានឲ្យក្មួយ២ដើរទៅរកម្តាយ ដែលកំពុងអង្គុយនៅលើគ្រែ។ កូនៗបានយំឱបម្តាយគួរឲ្យសង្វែគ។

នៅក្នុងផ្ទះនេះ ថ្ងៃមុនពោរពេញទៅដោយស្នាមញញឹម និងសំណើចសប្បាយ ប៉ុន្តែថ្ងៃនេះប្រែក្លាយទៅជាទុក្ខសោក និងការព្រាត់ប្រាស់។ សមាជិកគ្រួសារទាំងអស់អង្គុយយ៉ាងស្ងៀមស្ងាត់ ផ្ទៀងត្រចៀកចាំស្តាប់សំឡេងនានា។ ក្នុងផ្ទះស្ងាត់ជ្រងំមានតែភ្លើងទៀនបំភ្លឺព្រឹមៗស្ទើរតែរលត់ដោយសារខ្យល់បក់តាមបង្អួច។ កល្យាណ បានដើរទៅបិទបង្អួចដើម្បីកុំឲ្យទៀនរលត់ ខណៈពេលដែលបងស្រីឱបកូនទាំងពីរក្នុងរង្វង់ដៃនៅលើគ្រែដូចគ្មានព្រលឹងនៅក្នុងខ្លួន។ ពេល កល្យាណ កំពុងតែទាញបង្អួចបិទ ក៏ឃើញស្រមោលមនុស្សស្ទុងៗលបចេញពីចំហៀងផ្ទះ។ តាមពន្លឺដួងខែ ដែលរះត្រចះត្រចង់ និងបញ្ចេញពន្លឺច្បាស់ទើបកល្យាណ ដឹងថាជាបងប្រុសរបស់គាត់។ កល្យាណ បានស្ទុះទាញបង្អួចបិទឮសូរកឹង រហូតធ្វើឲ្យ សោភី និងក្មួយភ្ញាក់ស្មារតី។ កល្យាណ ដើរទៅបើកទ្វារបណ្តើរនិយាយពីបងប្រុសដែលគាត់បានឃើញតាមបង្អួចបណ្តើរ។ ក្មួយៗ និងសោភី ក៏កម្រើកខ្លួនដើរទៅតាម កល្យាណ។ ចេញទៅដល់កន្លែងទទួលភ្ញៀវ សោភី កល្យាណ និងកូនៗ បានឃើញ កុសល ពិតមែន ហើយបានយំឱបគ្នាទាំងទឹកមុខក្រៀមក្រំ។ សកម្មភាពជួបជុំ និងការសន្ទនាមិនយូរប៉ុន្មានក៏ត្រូវបំបែកដោយសារ កល្យាណ បានស្រែកប្រាប់ពេលឃើញស្រមោលរទេះគោចូលមកដល់។ កុសល ងាកមើលហើយក៏ងាកមកមើលមុខប្រពន្ធនិងកូន រួចនិយាយផ្តាំកូនៗថា ត្រូវតែធ្វើមិនស្គាល់គ្នា។ សោភី យំតិចៗ ចំណែកឯកូនទាំងពីរយំទឹកភ្នែកហូររហាមឱបប៉ា។ កល្យាណ បានចូលទៅយកបង្វែច ហើយអ្នកទាំងអស់ ក៏ចេញដើរសំដៅទៅរទេះ ដែលកំពុងតែឈប់ចាំនៅក្រោមដើមគគីរ។ អ៊ំជង់ និងប្រពន្ធរបស់គាត់ ឈ្មោះ មីងភូ ជាម្ចាស់រទេះនៅរង់ចាំយ៉ាងរីករាយត្បិតអី អ៊ំជង់ និង កុសល ស្គាល់រាប់អានគ្នាយូរមកហើយតាំងតែពី កុសល ធ្វើជាអ្នកបើកឡានជូនសម្តេចតា យាង

មកទតការសម្តែងសិល្បៈនៅអង្គរវត្តម្ល៉ោះ។ កុសល មិននិយាយអ្វីច្រើនជាមួយ អំជង់ ទេ ក្រៅពីការផ្តែផ្តាំប្តីប្រពន្ធទាំងពីរឲ្យជួយមើលថែប្រពន្ធកូន និងប្អូនស្រី ឲ្យបានល្អ។ កុសល បន្តនៅក្នុងក្រុងចាំមើលស្ថានភាពកងទ័ពអាវខ្មៅធ្វើអ្វីទៀត? ហើយ កុសល បាននិយាយទៅកាន់អ្នកទាំងអស់គ្នាមុននឹងចាកចេញថា បើនៅ មានជីវិត «ខ្ញុំនឹងទៅរកអ្នកទាំងអស់គ្នា»។ បន្ទាប់ពី កុសល ផ្តែផ្តាំរួចហើយ គាត់ បានប្រាប់ឲ្យ អំជង់ បរទេះចេញទៅជាប្រញាប់ខ្លាចក្រែងមានកងទ័ពមកទាន់។ អំជង់ បរទេះគោចេញឆ្ងាយបណ្តើរៗពី កុសល។ ចំណែក កែវភ្នែវទាំងបួនគូមាន ដំណក់ទឹកភ្នែកតិចៗនៅតែសម្លឹងទៅរក កុសល មិនព្រិចសោះឡើយ។ កុសល ប្រញាប់ចូលទៅក្នុងផ្ទះ។ រទេះគោបរទៅដល់ផ្លូវបំបែកទៅប្រាសាទបាគងក៏បត់ ចូល។ សោភី បើកបង្ហេចមិនឃើញរូបថត គាត់ក៏សុំចុះទៅយករូបថតសិន ប៉ុន្តែ គាត់បានផ្តាំថាបើមានហេតុការណ៍មិនស្រួលឲ្យ អំជង់ ចេញរទេះចោលចុះ។ លុះ សោភី ចេញផុតបានបន្តិច កងទ័ពបានមកដល់ល្មម ហើយបញ្ជាឲ្យម្ចាស់ រទេះគោឆាប់ចេញពីទីនោះ ព្រោះកងទ័ពត្រូវបោសសម្អាតក្រុង។ ដោយមិនអាច ទ្រាំនឹងការគំរាមរបស់កងទ័ពបាន រទេះគោ ក៏បរចេញចោល សោភី បាត់ទៅ។

សោភី ពេលដើរទៅដល់ផ្ទះ តែមិនឃើញប្តីសោះ។ គាត់ខំដើរតម្រង់ទៅទូ ហើយដកយករូបថតគ្រួសាររបស់គាត់ដាក់ចូលក្នុងបង្ហេច រួចត្រលប់ទៅកន្លែង រទេះគោវិញ តែមិនឃើញកូនៗឡើយ។ កងទ័ពបានដេញ សោភី ទៅម្ខាង ចូលជាមួយប្រជាជនផ្សេងៗទៀត។ កងទ័ព បានជម្លៀស សោភី ចេញទៅ តាមទិសដៅដែលរទេះ អំជង់ បរទៅដែរ។ រយៈពេលមួយថ្ងៃពីរយប់ ប្រហែល ម៉ោង៨ព្រឹក រទេះគោបានបរមកដល់ផ្ទះ។ អំជង់ ដាក់ជន្ទុលរទេះ ហើយដឹកគោ ទៅចងនឹងទ្រុងឲ្យស៊ីចំបើង។ អ្នកជិះនៅលើរទេះក៏ចុះមកដី។ មីងកូ បានរៀបចំ លើករបស់របរនៅលើរទេះដាក់មកក្រោម។ អំជង់ វិញចងគោរួចក៏ហៅឲ្យអ្នកទាំង បីចូលទៅអង្គុយលើគ្រែចំហៀងផ្ទះ។ អំជង់ បានយកក្រមាបត់ជាពីររួចបក់មូស ទម្លាក់អង្គុយមុន។ ចំណែក កល្យាណ និងសោភ័ណ នាំគ្នាជួយកាន់របស់របរ មីងកូ រួចដើរតម្រង់ទៅគ្រែ។ គ្រប់គ្នាដាក់របស់របរចុះស្រួលហើយ ក៏នាំគ្នាអង្គុយ

លើត្រែ។ អ៊ំជង់ ដកដង្ហើមធំរួចនិយាយថា «សង្ឃឹមថា សោភ័ និង កុសល មិនអីទៅចុះ»។ អ៊ំជង់ និយាយបានត្រឹមតែប៉ុណ្ណោះ សត្យា ក៏យំ តែ កល្យាណ បានលួងលោម ទើប សត្យាបាត់យំវិញ។ សោភ័ណ មិនជាបារម្ភអីនោះទេ ព្រោះគិតស្មានថា ម៉ាក់ របស់នាង បានជួបនឹងប៉ា។ អ៊ំជង់និយាយបន្តថា «ឯង កុំបារម្ភអី យ៉ាងម៉េចយ៉ាងណា អ៊ំ នឹងពឹងអ្នកស្គាល់ឲ្យជួយស៊ើបសួរដំណឹងម៉ែពុកឯង»។ និយាយរួច អ៊ំជង់ ទៅរកកន្លែងឲ្យក្មេងៗសម្រាក ព្រោះតែក្មេងៗ អត់ងងុយពីរយប់ពេលធ្វើដំណើរផង។ លុះថ្ងៃរះឡើងខ្ពស់បន្តិច មីងភូ ឡើងទៅមើលក្មេងៗ ហើយជាស់ឲ្យក្រោកទៅលុបលាងមុខហូបបាយ។ ថ្ងៃនេះ កូនរបស់មីងភូ ក៏ត្រលប់មកផ្ទះដែរ។ សោភ័ណ ក្តៅខ្លួនតិចៗ ហើយមិនស្រួលក្នុងពោះ ក៏ចង់ទៅរកបន្ទប់ទឹក។ មីងភូ បង្ហាញទៅព្រៃនៅខាងក្រោយផ្ទះ។ អ៊ំជង់ ធ្លាប់ដឹងពីរបៀបរស់នៅរបស់ សោភ័ណ ក៏បានឲ្យ មីងភូ ជូនទៅព្រៃដើម្បីបត់ជើង តែ សោភ័ណ ប្រកែកមិនព្រម ព្រោះខ្មាសអៀន។ បន្ទាប់ពី សោភ័ណ ចេញពីព្រៃវិញមិនបានមើលមុខក្រោយឆ្វេងស្តាំនោះទេ។ សោភ័ណ គិតតែពីឈ្លោកបោសស្លឹកឈើ ដែលជាប់នឹងសម្លៀកបំពាក់។ ចំណែកឯ កងទ័ព ជាច់ជួរម្នាក់ មិនដឹងជាមកពីមុំណានោះទេ បានរុកចូលតាមរបងផ្ទះរបស់ អ៊ំជង់ ប៉ះនឹងសំបុកអង្រ្កង ហើយវល់តែឈ្លោកញ៉ិចសត្វអង្រ្កងមិនបាន មើលឆ្វេងស្តាំ ធ្វើឲ្យអ្នកទាំងពីរភ្ញាក់គ្នារៀងៗខ្លួន។ សោភ័ណ បម្រុងនឹងដួល តែត្រូវកងទ័ពនោះទម្លាក់កាំភ្លើងចុះភ្លាម ហើយចាប់ សោភ័ណ ជាប់។ សោភ័ណ មើលភ្នែកកងទ័ពនោះ ហើយចាំបានថាជាមនុស្សតែម្នាក់ដែលបានជួយនាងកាលនៅអង្គរវត្ត។ ភ្នែក សោភ័ណ សម្លឹងមិនព្រិចសោះទៅកាន់កងទ័ព ដើម្បីឲ្យកាន់តែច្បាស់ហូតទាល់តែ កងទ័ពនោះសួរថា «នាងមិនអីទេឬ?»។ សោភ័ណ មិនព្រមឆ្លើយនឹងកងទ័ពទេ ទើបកងទ័ពស្រែកគំហកសួរម្តងទៀតថា «កើតអីក៏អត់?» រួចកងទ័ពនោះលែងដៃ សោភ័ណ ធ្វើឲ្យនាងដួលអុកគូទទៅនឹងដីភ្លាម។ សោភ័ណ ស្ទុះងើបយ៉ាងលឿនរួចឈ្លោកមុខចុះ។ សំឡេងគំហករបស់កងទ័ពធ្វើឲ្យមនុស្សគ្រប់គ្នានៅក្នុងផ្ទះរត់សំដៅមកមើល។ មីងភូ សប្បាយចិត្តណាស់ពេលឃើញកូនរបស់

គាត់ដែលជាកងទ័ពនោះ។ ឯ អ៊ំជង់ វិញប្រញាប់សួរសោភ័ណថា «តើក្មួយមិនអីទេ?»។ កងទ័ពមើលមុខ សោភ័ណ រួចនិយាយថា «បានក្មួយមកពីណានេះ អីក៏រឡេះរឡេះម្ល៉េះ?» រួច កងទ័ពនោះ ដើរទៅគ្រែដោយគ្មានចាប់អារម្មណ៍នឹងអ្នកណាសោះឡើយ។ «យីស!អាកូននេះ!មើលវាធ្វើ» អ៊ំជង់ និយាយត្រឹមនេះក៏នាំ សោភ័ណ ទៅគ្រែ។ គ្រប់គ្នាទទួលទានបាយបណ្តើរ អ៊ំជង់ និយាយបណ្តើរថា «នាងយ៉ាន(កល្យាណ) ក្មួយភាន់ (សោភ័ណ) ក្មួយ(យ៉ា)សត្យា អើយ កងទ័ពនេះ គឺជាវិចិត្រកូនពៅរបស់អ៊ំ ដែលធ្វើជាកងទ័ពស្មគ្រចិត្ត ត្រូវបានចាត់តាំងឲ្យការពារជាតិតាមព្រំដែន។ កូនច្បងៗរបស់អ៊ំ មានប្តីប្រពន្ធបែកផ្ទះទៅភូមិផ្សេងអស់ហើយ នៅតែវិចិត្រទេ»។ សោភ័ណ គិតផងហូបផងដោយដឹងច្បាស់ណាស់ថា វិចិត្រ គឺជាមនុស្សម្នាក់ដែល សុភ័ណ បានជួបនៅលើទឹកដីអង្គរនោះ ព្រោះកែវភ្នែករបស់ វិចិត្រ នៅតែមានរស្មីស្រទន់ដូចមុនដដែល។

ក្រោយថ្ងៃ១៧មេសា អ្វីៗនៅក្នុងភូមិចាប់ផ្តើមប្តូរផ្លាស់ ព្រោះមានប្រជាជនមិនដែលឃើញមុខជាបន្តបន្ទាប់ទៅរស់នៅលើទួលមួយឆ្ងាយពីភូមិ។ ប្រជាជនក្នុងភូមិម្នាក់ៗមមាញឹកតែយកខោអាវពណ៌មកជ្រលក់ឲ្យក្លាយជាពណ៌ខ្មៅទាំងអស់តាមបញ្ជារបស់មេភូមិ។ ប្រជាជនខ្លះទៀតរវល់តែរៀបចំឧបករណ៍ ស្រូវពូជ និងភ្ជួរស្រែ ព្រោះភ្លៀងដើមខែចាប់ផ្តើមធ្លាក់មកជាបន្តបន្ទាប់។ ម្នាក់ៗផ្ចិតផ្ចង់នឹងការងារណាស់ គ្មានពេលចាប់អារម្មណ៍នឹងវត្តមានរបស់មនុស្សចំណូលថ្មីទេ។ ចំណែកផ្ទះ អ៊ំជង់ មិនខុសពីផ្ទះផ្សេងទៀតទេ គឺត្រូវប្រមូលផ្តុំដោយមនុស្សបីបួន គ្រួសារកំពុងជ្រលក់អាវខោ និងក្រណាត់ឲ្យប្រែទៅជាខ្មៅ។ អ៊ំជង់ និងប្រុសៗវ័យចំណាស់ពីរបីនាក់ កំពុងតែកាប់សំបកដើមគ សំបកស្មាច់ និងសំបកឈើផ្សេងៗទៀត ដែលមានជ័រខ្មៅៗយកទៅត្រាំក្នុងទឹក។ អ្នកខ្លះទៀត នាំគ្នាជួសជុលរនាស់ និងនង្គ័ល។ ឯ មីងភូ និងស្រីៗដាំទឹកកូរ ហើយជ្រលក់ខោអាវក្រណាត់។ កល្យាណ សោភ័ណ និងក្មេងស្រីជំទង់ៗ យកខោអាវក្រណាត់ទៅហាលខ្លះបត់ខ្លះ ថែមទាំងហាលស្រូវ និងរៀបពូជស្រូវដែរ។ ឯ សត្យា និងក្មេងៗផ្សេងទៀតនាំគ្នារត់លេងយ៉ាងសប្បាយ។ សោភ័ណ ពេលឃើញកងទ័ពនាំមនុស្សចូលក្នុងភូមិក៏កើតចិត្តនឹកក្រែងមានម៉ាក់ប៉ារបស់ខ្លួនដែរ។ សោភ័ណ្ឌ ពេលមើលឃើញកងទ័ព

កំពុងតែរវល់ជជែកអួតកាំភ្លើងគ្នា ក៏បានដើរលបៗទៅមុខផ្លូវ។ ចៃដន្យ វិចិត្រ មើលឃើញ សោភ័ណ ក៏ដើរទៅសម្លុតថា «នាងភ័ណចង់ទៅណា?»។ សោភ័ណ បែរមើលទៅចំភ្នែក វិចិត្រ ដែលកំពុងសម្លឹងតម្រង់មករកខ្លួន។ សោភ័ណ ភ័យពេក ក៏យកដៃក្តោបពោះ ទើប វិចិត្រ គិតថា សោភ័ណ ចង់ទៅបន្ទប់ទឹក ហើយចង្អុលឲ្យទៅក្រោយផ្ទះ។ សោភ័ណ មិនហ៊ាននិយាយអ្វីបានត្រឹមតែងក់ក្បាល។ ពេលនាងដើរត្រលប់ទៅវិញ តែភ្នែករបស់នាងក្រឡេកទៅមើលកងទ័ពដែលនាំមនុស្សដើរតាមផ្លូវ។ វិចិត្រ ដឹងថា សោភ័ណ ចង់ដឹងដំណឹងពីពុកម៉ែជាមិនខានឡើយ បានមានអាកប្បកិរិយាដូច្នេះ។ វិចិត្រ បានដើរទៅមុខផ្លូវ រួចឆ្លៀតសួរទៅកងទ័ពដូចគ្នាបានដឹងរឿងសព្វគ្រប់ រួចត្រលប់ទៅកន្លែងកងទ័ពក្មេងៗពីរនាក់ ដែលនៅក្បែរ សោភ័ណ។ តាមពិត វិចិត្រ មិនមែនយល់ច្បាប់ភ្លេចឪពុកម្តាយ សាច់ញាតិបងប្អូនទេ ប៉ុន្តែ វិចិត្រ ត្រូវខ្មែរក្រហមបង្ខឹកឲ្យស្មោះស្ម័គ្រនឹងទ័ព មិនយល់ញាតិទើប វិចិត្រ ចចេសរឹងរូសបែបនេះ។ វិចិត្រ ចងចាំទាំងអស់កាលគ្រាដើរលេងនៅប្រាសាទអង្គរជាមួយនឹង សោភ័ណ ប៉ុន្តែ វិចិត្រ ធ្វើជាមិនស្គាល់មិនចងចាំអ្វីទាំងអស់ ព្រោះមិនចង់ឲ្យមនោសញ្ចេតនារបស់ខ្លួនកាន់តែកើតឡើង។ វិចិត្រ បានដើរទៅក្បែរកងទ័ពផ្សេងទៀត ដែលមានវ័យក្មេងជាងខ្លួនបន្តិច រួចនិយាយថា «ឯងគិតថាក្នុងចំណោមជនជម្លៀសទាំងអស់នេះ មានពុកម៉ែឯងទេ?»។ «ធ្វើម៉េចមានបើគាត់រវល់តែការងារគាត់?» កងទ័ពក្មេងទាំងនោះតបទៅ វិចិត្រ វិញទាំងឆ្ងល់។ «ត្រូវ! គ្មានទេ! ពុកម៉ែនាងក៏គ្មានដែរ?» វិចិត្រ និយាយផង ទាំងជៀងភ្នែកមើលទៅរកនារី ដែលបត់ខោអាវនៅក្បែរនោះ។ «បើដឹងអីចឹងសួរយើងដែរ?» កងទ័ពទាំងពីរនោះឆ្លើយរួច ក៏នាំគ្នាដើរចេញទៅ។ នារីៗក្បែរនោះ ពេលស្តាប់ឮដូច្នោះហួសចិត្តលួចសើចតិចៗ។ សោភ័ណ ចង់សើចដែរ រួចភ្លាត់ដៃធ្វើឲ្យពំនូកខោអាវដួល ហើយត្រូវកងទ័ពក្មេងៗទាំងនោះគំហកដាក់ឲ្យ ទើបនាងរវៃសរវៃរើសយកខោអាវមករៀបសារជាថ្មីម្តងទៀត។ នារីៗស្ងាត់មាត់ ហើយ សោភ័ណ លួចមើលមុខ វិចិត្រ ទាំងញញឹម ព្រោះ សោភ័ណ បានដឹងពីបំណងរបស់ វិចិត្រ។ វិចិត្រ ឃើញ សោភ័ណ មើលមកខ្លួនក៏នឹកខ្មាសនាង រួចក៏ដើរចេញទាំងមុខក្រហមប្រឿងៗបាត់ទៅ។

រាត្រីខែភ្លឺបានជះពន្លឺចូលតាមបង្អួច សោភ័ណ ដេកមិនលក់សោះ។ នាងរសាប់រសល់ដេកមិនលក់ធ្វើឲ្យ កល្យាណ ភ្ញាក់។ សោភ័ណ ក្រោកអង្គុយ ហើយ កល្យាណ ក៏ក្រោកអង្គុយដែរ រួចនាំគ្នាជជែកថា៖

កល្យាណ៖ «មីងដឹងថាក្មួយបារម្ភពីប៉ាម៉ាក់ តែក្មួយមិនត្រូវអត់ងងុយបែបនេះទេ ព្រោះអាចធ្វើឲ្យក្មួយឈឺបាន។ ណាមួយយើងត្រូវមានការងារធ្វើច្រើនទៀតនៅថ្ងៃស្អែក» កល្យាណ និយាយរួចបែរមើលទៅគ្រួសាររបស់ អំជង់។

សោភ័ណ៖ «មីង!មិនឲ្យខ្ញុំបារម្ភយ៉ាងម៉េចបាន បើដូចប៉ា...» សោភ័ណ និយាយមិនទាន់ចប់ផងកល្យាណ បានយកដៃក្តោបមាត់ក្មួយភ្លាម។

កល្យាណ៖ «ក្មួយមិនត្រូវរំឭកពីឈ្មោះប៉ាទេ!ប្រយ័ត្នមានអ្នកណាឮយើងច្បាស់ជាវឹកធំហើយ»។

សោភ័ណ៖ «ខ្ញុំគ្រាន់តែចង់ដឹងថាគាត់នៅឯណា?» សោភ័ណ ដកដៃមីងចេញព្រមទាំងយំតិចៗ។

កល្យាណ៖ «តើយើងធ្វើម៉េចទើបអាចដឹងបានបើកងទ័ពច្រើនយ៉ាងនេះ?» កល្យាណ បានយកដៃទាំងពីរទប់ស្មារបស់ក្មួយឲ្យបែរមកនិយាយចំមុខគ្នា ហើយ អំជង់ ក៏កម្រើកខ្លួន។

អំជង់៖ «ក្មួយកុំបារម្ភអី! ស្អែកពេលដែល វិចិត្រ យកស្បៀងទៅសហករណ៍ចាំអំឲ្យ វិចិត្រ ជួយស៊ើបរកឲ្យ។ ឆាប់ដេកទៅក្មួយ ព្រោះស្អែកយើងមានការងារច្រើនទៀត» អំជង់ តបពីកន្លែងដេកដែលនៅមិនឆ្ងាយប៉ុន្មានពីគ្នា។

កល្យាណ និង សោភ័ណ ក្រោយពេលបានឮសម្តី អំជង់ ដូច្នោះ ក៏ដាក់ខ្នងដេកទៅវិញ។ ឯ វិចិត្រ ក៏បានស្តាប់ឮការសន្ទានរបស់អ្នកទាំងបីដែរ តែ វិចិត្រ ធ្វើជាសំងំដេកលក់មិនកម្រើកខ្លួន។ លុះស្អែកឡើង វិចិត្រ បរទេះប្រមូលស្បៀងនិងពូជស្រូវទៅដាក់តាមកងនីមួយៗ ហើយឆ្លៀតស៊ើបរកឪពុកម្តាយរបស់ សោភ័ណ។ វិចិត្រ គឺជាកងសេដ្ឋកិច្ចរត់ការខាងស្បៀងហូបចុកនិងស្លៀកពាក់ ទើបការចូលទៅតាមក្រុមជនជម្លៀសមិនជាបញ្ហាអ្វីទេ។ ដល់ទីទួលដែលជនជម្លៀសពីទីក្រុងរស់នៅ វិចិត្រ បានឃើញ សោភី។ វិចិត្រ បាននិយាយគ្នាជាមួយនឹង

សោភី ដឹងរឿងរ៉ាវសព្វគ្រប់បែបយ៉ាងហើយក៏បំបែកគ្នាទៅ។ ចាប់ពីពេលនោះមក សោភ័ណ មិនសូវបារម្ភពេកទេ ព្រោះបានដឹងដំណឹងថាមានម្តាយនៅក្បែរខ្លួន។

ក្រោយពីភូមិភាគឧត្តរ បានប្តូរអ្នកដឹកនាំពី កុយ ធួន ទៅ កែ ពក វិញ ស្ថានភាពប្រជាជនក្នុងតំបន់ បានផ្លាស់ប្តូរស្ទើរតែទាំងស្រុង។ ប្រជាជនមូលដ្ឋានត្រូវប្រមូលចានឆ្នាំងជាក់ជាសមូហភាពរួម ហើយថែមទាំងរស់នៅដោយ ហូបរួម ដេករួម ធ្វើការរួមគ្នា និងគ្មានអ្វីជាកម្មសិទ្ធិនោះទេ។ មេភូមិមេឃុំត្រូវផ្លាស់ប្តូរជាប្រធានសហករណ៍វិញ។ ក្នុងសហករណ៍នីមួយៗ ត្រូវបែងចែកជាពីរផ្នែក គឺអ្នកមូលដ្ឋានចាស់ និងមូលដ្ឋានថ្មី។ ក្មេងៗត្រូវនៅតាមកងក្មេងៗ។ ចាស់ៗដែលគ្មានកម្លាំងត្រូវមើលថែទាំក្មេងតូចៗដែលមានអាយុក្រោម៦ឆ្នាំ ពេលឪពុកម្តាយមិននៅ។ ចំណែកយុវជនចាប់ពីអាយុ ១៥ឆ្នាំឡើង ទាំងស្រីទាំងប្រុស ត្រូវធ្វើការងារយ៉ាងសកម្ម។ ឯក្មេងចាប់ពីអាយុ ៦ឆ្នាំឡើងដល់ ១៤ឆ្នាំ ត្រូវទៅឃ្វាលគោក្របី។ ក្មេងៗខ្លះទៀត ធ្វើជាកងឈ្លបរបស់ខ្មែរក្រហម ដែលខ្មែរក្រហមបង្រៀនឲ្យជឿជាក់តែលើអង្គការ ហើយអង្គការជាអ្នកមានគុណដ៏ធំធេង។ រីឯសហករណ៍ធ្លកកំបុតត្រូវគ្រប់គ្រងដោយ ប្រធានរៀម។ ក្នុងសហករណ៍ទាំងអស់ មានតែសហករណ៍ដឹកនាំដោយ ប្រធានរៀម ទេ ដែលមិនសូវមានការធ្វើទារុណកម្មធ្ងន់ធ្ងរ ព្រោះគាត់មិនសូវតឹងតែង ហើយអ្នកមូលដ្ឋានចាស់មិនជារើសអើងអ្នកមូលដ្ឋានថ្មីទេ។ ប៉ុន្តែទោះជាយ៉ាងណាក៏នៅតែមានអ្នកចង់បានមុខមាត់រាយការណ៍ទៅថ្នាក់លើដើម្បីផ្គាប់ចិត្តដែរ។ កល្យាណ ត្រូវប្រធានសហករណ៍រើសឲ្យធ្វើជាគ្រូបង្រៀន ទើបគាត់មានឱកាសបាននៅក្បែរ សត្យា។ មីងភូ និងអ៊ំជង់ ធ្វើខាងចុងភៅ។ ឯ សោភ័ណ វិញ ត្រូវធ្វើការងារខាងរោងអំបោះគ្បាញ។ ប្រជាជនពេញសិទ្ធិអង្គការ មិនសូវផ្តោតឬចាប់កំហុសអ្វីឡើយ លើកលែងតែប្រជាជនត្រៀម និងប្រជាជនថ្មី បានអង្គការតឹងរឹង។ សោភី ស្ថិតក្នុងប្រជាជនត្រៀម ហេតុដូចនេះទើបគាត់ត្រូវខិតខំធ្វើការងារ ដើម្បីបានក្លាយជាប្រជាជនពេញសិទ្ធិ។ ទំនាក់ទំនងនិងដំណឹងគ្រួសាររវាង សោភី និងកូនៗ នៅជាប់គ្នាជានិច្ច តាមរយៈ វិចិត្រ ដែលជាអ្នកដឹកស្បៀង ដឹកទឹក ឲ្យសហករណ៍ទាំងមូល។ ផ្ទុយទៅវិញ វត្តមានកុសល នៅតែស្ងាត់ឲ្យឈឹងមិនឮដំណឹងអ្វីទាល់តែសោះ។

ថ្ងៃមួយក្នុងឆ្នាំ១៩៧៧ ថ្នាក់ដឹកនាំ កែ ពក បានផ្តាស់ប្តូរពីភូមិភាគឧត្តរ ទៅភូមិភាគកណ្តាលវិញ។ ភូមិភាគនេះ ត្រូវគ្រប់គ្រងដោយ កង ចាប វិញម្តង។ មុនទៅកាន់ភូមិភាគថ្មីនៅភូមិភាគឧត្តរ ព្រឹត្តការណ៍រន្ធត់មួយបានកើតឡើងនៅសហករណ៍មួយមិនឆ្ងាយពីសហករណ៍ដែលសោភ័ណកំពុងរស់នៅនោះទេ។ សហករណ៍នោះ ត្រូវធ្វើវិសុទ្ធកម្ម ព្រោះអង្គការគិតថានៅក្នុងសហករណ៍មានសេសសល់ទាហានពីរបបសាធារណរដ្ឋ ហើយមានជនចង់ក្បត់នឹងអង្គការទើបអ្នកមូលដ្ឋានថ្មីទាំងអស់ ព្រមទាំងប្រជាជនត្រៀមត្រូវអង្គការប្រមូលយកទៅសម្លាប់ចោលនៅវត្តលលៃ គ្មានលើកលែងសូម្បីតែកូនក្មេង។ ពេលនោះ អង្គការបានប្រើពាក្យស្លោកថា «សម្លាប់ច្រឡំ ជាជាងលែងច្រឡំ» ហើយពាក្យខ្លះផ្សេងទៀតថា «ទុក្ខក៏មិនចំណេញដកចេញក៏មិនខាត»។ ប្រជាជនដែលកំពុងបោកបែន ពោយនិងហាលស្រូវ បានឈរមើលអ្នកទាំងនោះ។ ចំណែក កុសល បានរត់មកដល់សហករណ៍នេះ ហើយត្រូវកងទ័ពចាប់។ សោភ័ណ បានឃើញយ៉ាងច្បាស់ពេលប៉ារបស់ខ្លួនត្រូវចង់ដៃក្រពាត់ទៅក្រោយ ព្រមទាំងមានកងទ័ពវាយទាត់។ សោភី ស្តូតអស់ស្មារតីពេលឃើញប្តីត្រូវអង្គការចាប់បែបនេះ។ កងទ័ពបានអូស កុសល ឡើងរថយន្តដែលបិទធាងដូងជិត រួចក៏បើកចេញពីទីនោះ។ ម្តាយនិងកូនទាំងពីរ ចង់រត់ទៅជួយឪពុក ប៉ុន្តែត្រូវ មីងកូ និងអ៊ំជង់ ចាប់ជាប់។ ប្រជាជនមិនហ៊ានសូម្បីតែស្រក់ទឹកភ្នែកចេញមកក្រៅទោះបីជាមានរឿងអ្វីក៏ដោយ ប៉ុន្តែទឹកភ្នែកនៅក្នុងចិត្តវិញហូរដូចជាទឹកទន្លេ។

ខែកត្តិកឆ្នាំនេះ មុនប្រមូលផលស្រូវ ប្រធានសហករណ៍ បានរៀបចំពិធីមង្គលការតាមការចាត់តាំងរបស់ថ្នាក់លើ។ នៅក្នុងរោងមួយល្វែង មានមនុស្សពីរជួរ គឺមិត្តនារីនៅម្ខាង និងមិត្តបុរសម្ខាង។ មិត្តនារី និងមិត្តបុរស មកពីគ្រប់សហករណ៍ មានចំនួន ៣០គូ។ ប្រធានសហករណ៍ ចាប់ផ្តើមចាប់គូរហូតដល់អស់គូ។ គូស្វាមីភិរិយាថ្មីកាន់ដៃគ្នាសច្ចាស្មោះស្ម័គ្របម្រើអង្គការអស់មួយជីវិត។ ក្នុងពិធីរៀបការនេះ គ្មានឪពុកម្តាយ ឬអាណាព្យាបាល ចូលរួមទេ គឺមានតែប្រធានសហករណ៍ និងម្ចាស់សាមីខ្លួនតែប៉ុណ្ណោះ។ ក្នុងគូទាំង៣០ មាន កល្យាណ ដែរ

ដែលត្រូវរៀបការ។ កល្យាណ និងស្រីៗផ្សេងទៀត ត្រូវប្រធានអង្គការចាប់គូ ជាមួយអតីតកងទ័ពពិការ។ កល្យាណ ត្រូវរស់នៅជាមួយ នាយតុត ទាំងចិត្ត មិនបានស្រលាញ់ ហើយមិនដែលស្គាល់គ្នាទាល់តែសោះ។ កល្យាណ ជា គ្រូបង្រៀន ដូច្នោះហើយទើប នាយតុត ត្រូវផ្លាស់មករស់នៅតាម កល្យាណ។ នាយតុត ចូលធ្វើការងារខាងជួលជុលសម្ភារ និងបង្វឹកក្មេងៗប្រើកាំភ្លើង។ គាត់ត្រូវរួមរស់នៅជាមួយគ្នាបីយប់ ដែលមានការឃ្លាំមើលពីកងឈ្លបស្ទើរ តែគ្រប់ពេលវេលា។ នាយតុត ជាមនុស្សល្អណាស់ គាត់មិនដែលបង្ខំចិត្ត កល្យាណទេ។ គាត់គ្រាន់តែដេកក្បែរ កល្យាណ និយាយចុះសម្រុងគ្នាធម្មតា ដើម្បី បន្លំកងឈ្លប។

បន្ទាប់ពីរៀបមង្គលការរំលងបានប្រហែលមួយខែ ស្រាប់តែប្រធាន សហករណ៍ចាត់យក យុវជន យុវនារីសកម្ម ទៅធ្វើការនៅរោងស្រូវភ្នំពេញ។ សោភី ក្រោយពីបានក្លាយជាប្រជាជនពេញសិទ្ធិ ត្រូវបានប្រធានសហករណ៍ ជ្រើសរើស។ ចំណែក សោភ័ណ ពេលដឹងថាម្តាយរបស់ខ្លួន បានទៅភ្នំពេញ នាង ចង់ទៅតាមណាស់ តែគ្មានឈ្មោះនឹងគេ។ ពេលនោះ មានយុវតីម្នាក់ មិនចង់ទៅ ភ្នំពេញឡើយ ទើបសោភ័ណប្តូរឲ្យនាងមកធ្វើការក្នុងរោងត្បាញ ហើយ សោភ័ណ ទៅភ្នំពេញជំនួសវិញ។ សោភ័ណ និងម្តាយ បានចាកចេញពីសហករណ៍ដោយ ទុកឲ្យប្អូនប្រុសនៅជាមួយមីង ព្រោះការទៅធ្វើការនៅភ្នំពេញលើកនេះផ្សងព្រេង មិនដឹងថាស្លាប់ឬរស់ឡើយ។ វិចិត្រ មិនហ៊ានមកជួបមុខ សោភ័ណ ឡើយ នៅពេលដឹងថា សោភ័ណ ត្រូវឃ្លាតឆ្ងាយ។ វិចិត្រ ទៅអង្គុយសំកុកតែម្នាក់ឯង ទោះពេលហូបបាយក៏វិចិត្រ មិនទៅហូបដែរ។ រថយន្តបរចេញផុតទៅ វិចិត្រ បាន ត្រឹមតែមើលពីចម្ងាយ។ ចំណែក កល្យាណ ដឹងច្បាស់ថា វិចិត្រ កំពុងតែមានចិត្ត ចំពោះ សោភ័ណ តែគាត់មិនហ៊ានប្រាប់ សោភ័ណ ឡើយត្បិតថាអ្នកមានស្នេហា នៅពេលនោះនឹងត្រូវចោទប្រកាន់ថាក្បត់អង្គការ។ មិនខុសអ្វីដែល កល្យាណ កំពុងមានចិត្តលើ នាយតុត ដែរ តែ កល្យាណ មិនអាចបង្ហាញអារម្មណ៍បានទេ ព្រោះ កល្យាណ ជាស្រី ហើយធ្លាប់បដិសេធមិនឆ្លងរាត្រីជាមួយ នាយតុត ពេល

រៀបការរួចថ្មីៗ។ ចំណែក សត្យា វិញ ទោះបីពេលធ្វើការច្រើនជាងពេលរៀន ការហូបចុកមិនគ្រប់គ្រាន់ និងត្រូវធ្វើការងារហួសកម្លាំង ក៏ សត្យា ខិតខំចំណាំអក្សរដែល កល្យាណ បានបង្រៀនណាស់ ហើយថែមទាំងចេះប្រកបបានទៀត។

ក្រោយពីថ្ងៃរំដោះ៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនសប្បាយចិត្តណាស់។ កងទ័ពខ្មែរក្រហម នាំគ្នារត់ចូលព្រៃអស់។ ប្រជាជនម្នាក់ៗចាកចេញពីសហករណ៍ទៅរកស្រុកកំណើតរៀងៗខ្លួនវិញ។ ឆ្មាំជង្រុកស្រូវ ក្រោយដឹងថាកងទ័ពខ្មែរក្រហមបែកក៏នាំគ្នារត់ចោលស្រូវអង្ករ។ ប្រជាជនខិតខំប្រមូលយកអង្ករទៅដាំបាយបរិភោគរហូតខ្លះហល់បាយស្លាប់ក៏មានដែរ។ អ្នកមានគ្រួសារប្រពន្ធកូនរត់រកគ្នាយំទ្រហឹងគួរឲ្យសង្វេគម្តងទៀត។ ទិដ្ឋភាពបែបនេះមិនមែនតែនៅតំបន់ភ្នំពេញ និងតំបន់សៀមរាបនោះទេ គឺកើតឡើងគ្រប់តំបន់ទាំងអស់នៅក្នុងប្រទេសកម្ពុជា។

ពេលស្ថានភាពប្រសើរឡើង កល្យាណ បាននាំក្មួយ សត្យា ទៅភ្នំពេញវិញទាំងប្រញាប់ប្រញាល់។ ក្រុមគ្រួសាររបស់ អ៊ំជង់ និងនាយតុត មកជួបជុំគ្នាទាំងអស់។ កល្យាណ និងក្មួយប្រុស បានរៀបបង្វែច រង់ចាំរថយន្ត កងទ័ពសង្គ្រោះ។ ពេលរថយន្តមកដល់ កល្យាណ និងក្មួយប្រុស សំពះលា អ៊ំជង់ មីងកូ និងស្វាមីរបស់នាង ដោយនិយាយថា៖

កល្យាណ៖ «ពូមីង!ខ្ញុំជម្រាបលាសិនហើយ។អរគុណសម្រាប់ការផ្តល់ជម្រក និងការថែទាំរបស់អ្នកទាំងពីរ។ កុំតែមានអ្នកទាំងពីរប្រហែលខ្ញុំគ្មានជីវិតទេ»។

អ៊ំជង់៖ «មិនអីទេ!យើងនេះក៏សប្បាយណាស់ដែរ ដែលបានរួចផុតជីវិតពីរបបនេះ។ តែអ្វីដែលយើងខ្មាសនោះ គឺមិនអាចជួយជីវិត កុសល បាន»។

កល្យាណ៖ «កុំបន្ទោសខ្លួនឯងអី គួរតែបន្ទោសរបបយង់ឃ្នងនេះ។ លោកអ៊ំ និងគ្រួសារធ្វើបានល្អបំផុតហើយសម្រាប់ខ្ញុំ»។

សត្យា៖ «មែនហើយលោកអ៊ំ» សត្យា និយាយរួចរត់ទៅឱបលា អ៊ំជង់។

កល្យាណ៖ «អ្នកតុត ខ្ញុំក៏អរគុណអ្នកណាស់ ដែលរក្សាភាពបរិសុទ្ធឲ្យខ្ញុំ។ បើអ្នកមិនមែនជាមនុស្សល្អទេ ប្រហែលពេលនេះខ្ញុំមិនអាចឈរនៅទីនេះបានឡើយ»។

នាយតុត៖ «បាទ! មិនអីទេអ្នកនាង» នាយតុត ឈរកោន់ឈើច្រត់ និងដៃម្ខាងដាក់ទៅក្រោយនៅក្បែរនោះដែរ។

កល្យាណ៖ «មើលទៅ អ្នកតុត ចង់មានពាក្យអីនិយាយមែនទេ?» កល្យាណមើលទៅ នាយតុតហាក់ដូចមានអ្វីចង់និយាយទើបសួរ។

នាយតុត៖ «គ្មានទេ! ខ្ញុំគ្រាន់តែចង់ជូនរបស់នេះដល់អ្នក ហើយជូនពរឲ្យអ្នក និងក្មួយ សុខសប្បាយតាមផ្លូវឆាប់ជួបក្រុមគ្រួសារ» និយាយរួច នាយតុតបានហុចប្រអប់ឈើមួយទៅឲ្យ កល្យាណ។

កល្យាណ៖ «ចាស៎!អរគុណ!» កល្យាណ ទទួលយកដោយស្នាមញញឹម រួចបែរមកនិយាយបន្ថែមទៀតថា «ខ្ញុំអរគុណអ្នកទាំងអស់គ្នា។ ពេលខ្ញុំបានជួបជុំក្រុមគ្រួសារ ហើយប្រទេសមានសុខសាន្តគ្រាណាពេញលេញ ខ្ញុំនឹងមកលេងអ្នកទាំងអស់គ្នាវិញ»។

សត្យា៖ «បងវិចិត្រ ខ្ញុំលាសិនហើយ! តើបងមានពាក្យពេចន៍អ្វីចង់ប្រាប់បងស្រីរបស់ខ្ញុំ សូមបងផ្តាំតាមខ្ញុំមក?» វិចិត្រ រត់ទៅឱប សត្យា ហើយនិយាយដាក់ត្រចៀកខ្សឹបៗ គ្រប់គ្នាឮតិចៗ។

វិចិត្រ៖ «បើឯងជួបបងស្រីមែន ជួយប្រាប់នាងផងថា ខ្ញុំមិនបានភ្លេចនាងទេ។ ខ្ញុំនឹងចាំនាងនៅអង្គរ» សត្យា ញញឹមរួចងក់ក្បាល ហើយលើកដៃលាគ្រប់គ្នា។

រថយន្តដែលពោរពេញទៅដោយមនុស្សក្មេងចាស់មានរបស់របរពេញដៃ បានចាកចេញបាត់ស្រមោលសូន្យឈឹងពីទឹកដីអង្គរ។ នៅតាមផ្លូវ មានសាកសពជាច្រើនស្លាប់គរលើគ្នា។ រយៈពេលជាងមួយសប្តាណ៍ទើបរថយន្តបើកទៅដល់ភ្នំពេញ។ សំឡេងរថយន្តតិចៗបន្តិចល្បឿន ដើម្បីដាក់ កល្យាណ និងសត្យា ចុះ។ សត្យា បានជួបម្តាយ និងបងស្រី ក៏រត់ឱបគ្នាប្រកបដោយទឹកមុខរីករាយ។ រថយន្តដាក់របស់របរចុះហើយក៏បន្តដំណើរទៅមុខទៀត។

សំឡេង តែតៗៗ នៅខាងមុខផ្ទះ ហើយទ្វារឡានក៏បានបើក ដោយឃើញប្តីប្រពន្ធមួយគូចុះពីឡាន និងមានប្តីប្រពន្ធចាស់ចេញទៅទទួល។ មួយសន្ទុះក៏ឮសំឡេងបុរសចំណាស់ម្នាក់ស្រែកហៅថា «ចៅស្រី!មកនេះម៉ាក់ប៉ាឯងទិញនំចំណីផ្លែឈើច្រើនណាស់។ មកជួយរៀបចំដើម្បីទទួលទេវតាឆ្នាំថ្មីនៅថ្ងៃស្អែក និងឆាប់

បានទៅលេងប្រាសាទអង្គរវត្តទាំងអស់គ្នា»។ «ចាស៎!លោកតា ខ្ញុំអានសៀវភៅបញ្ចប់មួយទំព័រនេះសិន» សំឡេងក្មេងស្រីជំទង់ស្រែកឆ្លើយតបចេញពីសួនច្បារវិឡាខាងក្រោយ។ ក្មេងស្រីជំទង់នោះ អានសៀវភៅបញ្ចប់រួចទុកដាក់សៀវភៅយ៉ាងស្អាតក្បែរប្រអប់ឈើមានដាក់រូបថតជុំគ្នារវាងគ្រួសារ កុសល និងគ្រួសារអ៊ំជង់ ពីខាងលើ។ នាងរត់មកជួយរៀបចំនំចំណី ផ្លែឈើ ដាក់ចាន ហើយទុកលើតុខាងក្រោយរូបថតចំនួន ៥ផ្ទាំងធំៗនោះ រួមមាន ផ្ទាំងរូបថត កុសល សោភី កល្យាណ សោភ័ណ និងរូបថតជុំគ្នាពីរគ្រួសារ កុសល និងអ៊ំជង់ ដែលថតនៅអង្គរវត្តមួយផ្ទាំងទៀតដែលកំពុងព្យួរនឹងជញ្ជាំង។ សមាជិកគ្រួសារទាំងអស់ជួបជុំគ្នាទទួលទានអាហារពេលល្ងាចយ៉ាងសប្បាយរីករាយនិងមានសេចក្តីសុខ។

ចប់

៥០

រឿង អត់ទេ មិនដែលសង្ឃឹម ថាអស់ទេ

អ្នកនិពន្ធ ៖ ឡឿន គីមហេង

៥០ ~ រឿង អត់ទេ មិនដែល សច្ចឹមថារស់ទេ

ថ្ងៃមួយ ខ្ញុំបានដើរជាមួយនឹងអ៊ំស្រីម្នាក់ ដែលមានអាយុប្រហែល ៦០ឆ្នាំឡាយ មកដល់តុបាយថ្ងៃត្រង់នៅកន្លែងធ្វើការរបស់ខ្ញុំ។ បន្ទាប់មក អ៊ំស្រី បានអង្គុយចុះរួច និយាយថា «ជីវិតរបស់ខ្ញុំនៅក្នុងសម័យខ្មែរក្រហម បានប្រឈមមុខនឹងការលំបាក និយាយមិនត្រូវ»។ បន្ទាប់មក អ៊ំប្រុសម្នាក់ទៀត មានអាយុប្រហែល ៥០ឆ្នាំឡាយ ជាមិត្តរួមការងាររបស់ខ្ញុំ បានអញ្ជើញមកដល់ដែរ។ ខ្ញុំបានជម្រាបប្រាប់គាត់ទាំងពីរនាក់ថា ខ្ញុំចង់ស្តាប់អំពីរឿង៉ាវជីវិតរស់នៅប្រចាំថ្ងៃរបស់គាត់ក្នុងសម័យខ្មែរក្រហម ដែលបានគ្រប់គ្រងនិងដឹកនាំប្រទេសកម្ពុជា រវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

ដំបូង ទាំង អ៊ំស្រីនិងអ៊ំប្រុស បាននិយាយថា គាត់មិនដឹងជាត្រូវរៀបរាប់ប្រាប់ខ្ញុំយ៉ាងម៉េចនោះទេ។ ខ្ញុំបានឆ្លើយតបប្រាប់គាត់វិញថា ខ្ញុំនឹងសួរសំណួរងាយៗទៅកាន់គាត់តែប៉ុណ្ណោះ។ ខ្ញុំបានពន្យល់ដល់ អ៊ំស្រី និងអ៊ំប្រុស អំពីសារសំខាន់នៃការកត់ត្រារឿង៉ាវ ដែលបានកើតឡើងចំពោះគាត់នៅក្នុងសម័យខ្មែរក្រហមថា ការកត់ត្រានេះ ដើម្បីឲ្យមនុស្សគ្រប់ៗជំនាន់បានដឹង និងខំជៀសវាងឲ្យផុត កុំឲ្យកើតសង្គ្រាមបែបនេះឡើងជាថ្មីម្តងទៀត។ ក្រោយយល់ពីបំណងរបស់ខ្ញុំហើយ អ៊ំស្រីនិងអ៊ំប្រុស បានយល់ព្រមឲ្យខ្ញុំសួរនិងកត់ត្រា។ គាត់បានឲ្យតម្លៃលើកិច្ចការកត់ត្រារបស់ខ្ញុំណាស់ ព្រោះគាត់បានរាយរាប់ប្រាប់ខ្ញុំយ៉ាងលម្អិតលើសពីការរំពឹងទុករបស់ខ្ញុំទៅទៀត។

គាត់ទាំងពីរនាក់ បាននិយាយរៀបរាប់អំពីសាច់រឿងរបស់គាត់ស៊ីចង្វាក់គ្នាបានល្អណាស់ គឺមានតែខ្ញុំទេដូចមិនដឹងអ្វីសោះជុំវិញព្រឹត្តិការណ៍ទាំងអស់នេះ។ រាល់ពេលដែលគាត់ និយាយគ្នាអំពីភាពយោរយៅដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហម ខ្ញុំមានតែតបសម្តីទៅកាន់គាត់វិញថា «តើមែនឬលោកអ៊ំ?»។ ខ្ញុំឆ្ងល់ថា តើមានអ្វីល្អបន្តិចឬទេនៅក្នុងសម័យខ្មែរក្រហម? គាត់បានឱនមុខមើលទៅលើដៃជើងរបស់គាត់ ដែលស្ថិតនៅក្រោមតុកញ្ចក់ ហើយឆ្លើយតបជាមួយខ្ញុំព្រមគ្នាទាំងពីរនាក់ថា «គ្មានទេ!»។

ខ្ញុំគឺជាក្មេងធំឡើងក្នុងសង្គមគ្រួសារ ដែលយកចិត្តទុកដាក់លើរូបរាងកាយរបបអាហារ ពេលវេលាគេង ពេលរៀន ពេលកំសាន្ត និងថែមទាំងយកចិត្តទុកដាក់ទាំងផ្លូវអារម្មណ៍របស់ខ្ញុំ រួមមានការប្រើប្រាស់ពាក្យសម្តី និងទង្វើ ព្រោះតែខ្ញុំជាមនុស្សពិការ។ ខ្ញុំពិបាកជឿណាស់ថា មនុស្សជាតិតែមួយបែរជាប្រព្រឹត្តអំពើអមនុស្សធម៌ដាក់គ្នាដូចអ្វីដែលកើតមានឡើងនៅក្នុងសម័យខ្មែរក្រហមដូច្នោះ។ ខ្ញុំកាន់តែឆ្ងល់ទៀតថា ប្រជាជនដែលនៅរស់រានមានជីវិតទាំងអស់ អាចរស់នៅបានដោយរបៀបណា? អ៊ំស្រី បានរៀបរាប់យ៉ាងខ្លីថា៖

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុ២៥ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅក្នុងខេត្តកំពង់ឆ្នាំង។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំត្រូវជម្លៀសទៅតំបន់ សហករណ៍កំផែន។ ខ្ញុំចាំមិនច្បាស់ទេថាតើខ្ញុំបានមកដល់ស្រុកណាខ្លះ និងខេត្តណាខ្លះ។ ខ្ញុំមានបងប្អូនចំនួន ៥នាក់ ហើយខ្មែរក្រហមបានជម្លៀសយើងមកជាមួយគ្នា។ យើងធ្វើការនៅក្នុងសហករណ៍ផ្សេងៗគ្នា។ ខ្ញុំធ្វើការងារនៅក្នុងកងចល័ត។ ការងារដែលខ្ញុំធ្វើ ភាគច្រើនធ្វើស្រែចម្ការ។

បន្ទាប់មក អ៊ំប្រុស បាននិយាយអំពីជីវិតរបស់គាត់ថា៖

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុប្រហែលជា ១៥ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅខេត្តព្រៃវែង។ ក្រោយមក ខ្ញុំត្រូវខ្មែរក្រហមជម្លៀសមកនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំធ្វើការងារនៅក្នុងកងចល័តកុមារឈានមុខ ដែលការងាររបស់ខ្ញុំភាគច្រើន គឺជីកប្រឡាយ។ ពេលព្រឹក ខ្ញុំត្រូវទៅធ្វើការនៅម៉ោង ៦ព្រឹក រហូតដល់ម៉ោង ១២ថ្ងៃត្រង់ទើបបានសម្រាកហូបបាយ។ បន្ទាប់ពីហូបបាយថ្ងៃត្រង់រួច ខ្ញុំ

អាចអង្គុយសម្រាកបន្តិចនៅក្បែរប្រឡាយដែលខ្ញុំកំពុងតែជីក។ រហូតដល់ម៉ោង ១រសៀល សំឡេងជួងបានបន្លឺឡើងជាសញ្ញាប្រាប់ថា យើងត្រូវធ្វើការងារបន្តទៀត។ ទោះបីជាមេឃក្តៅឬក្តៀង សកម្មភាពបំពេញការងាររបស់កងចល័តរបស់ខ្ញុំនៅតែបន្តរហូតដល់ម៉ោង ៧យប់ ទើបខ្ញុំអាចសម្រាកហូបបាយបាន។ ក្រុមកងចល័តរបស់ខ្ញុំ នៅតែបន្តធ្វើការដល់ម៉ោង ១២ភ្លឺទៀត នៅក្រោមពន្លឺភ្លើងចន្ទះ។ នៅពេលដល់ម៉ោងបាយថ្ងៃត្រង់ យើងទាំងអស់គ្នាត្រូវមកហូបអាហារនៅរោងបាយដែលមានរៀបតុឲ្យអង្គុយរួចជាស្រេច។ យើងទទួលបានបបរម្នាក់មួយចានជាមួយនឹងសម្លមួយចានហូបគ្នាចំនួន ៥នាក់។ ខ្ញុំមិនចូលចិត្តបបរលាយដើមចេកនោះទេ។ បបរនោះមើលទៅដូចជាបបរបាយសម្រាប់ជ្រូកស៊ី ប៉ុន្តែខ្ញុំនៅតែហូបវា ព្រោះខ្ញុំដឹងថាគ្មានជម្រើសអ្វីទៀតឡើយ។ ជួនកាល អាហារមិនអាចបំពេញក្រពះរបស់ខ្ញុំបានគ្រប់គ្រាន់ ខ្ញុំបានស្វែងរកស្លឹកឈើទ្រមូង ឬស្លឹកថ្នឹង យកមកហូបនៅពេលទៅបត់ជើងនៅក្នុងព្រៃ។ ជួនកាលទៀត ខ្ញុំបានលួចចាប់សត្វលាក់ទុកសម្រាប់យកមកចម្អិននៅពេលដែលខ្ញុំចុះច្រូតឬស្វូង។ ខ្ញុំឧស្សាហ៍បានបរិភោគទំពាំងឫស្សីផៅណាស់ ឬពេលខ្លះខ្ញុំបានបេះផ្លែនោងដុតហូប។ ខ្ញុំមិនសូវបានងូតទឹកទេ។ ខ្ញុំមានតែក្រមាមួយ ដែលយកទៅជ្រលក់ជ័រដើមឈើឲ្យប្រែទៅជាពណ៌ខ្មៅ។ ប្រជាជនភាគច្រើននៅក្នុងរបបខ្មែរក្រហមមានសត្វចៃ និងសង្កើចខាំ ព្រោះយើងមិនមានពេលសម្អាតខ្លួនប្រាណនោះទេ។ នៅពេលដែលយើងធ្វើការចប់គឺយើងអស់កម្លាំងរហិតរហៃស្រវាំរកតែកន្លែងសម្រាកតែប៉ុណ្ណោះ មិនបាននៅខ្វាយខ្វល់រឿងមុជទឹកកក់សក់ឬដុសធ្មេញអ្វីឡើយ។ អ្វីៗជាទ្រព្យសម្បត្តិរបស់អង្គការទាំងអស់។ ប្រជាជនក្រុមគ្រួសារ និងសាច់ញាតិ មិនអាចនិយាយលេងឬរាក់ទាក់ជាមួយគ្នាបានទេ។ ចំពោះការងារវិញ ប្រសិនបើមាននរណាម្នាក់ធ្វើមិនរួចតាមការកំណត់របស់អង្គការប្រជាជននោះនឹងទទួលពិន័យ ដោយដាក់ការងារឲ្យធ្វើបន្ថែមច្រើនឡើងៗ។ ខ្ញុំធ្លាប់បានទទួលរងពិន័យនេះច្រើនដងរហូតដល់ខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់។ ជើងទាំងពីររបស់ខ្ញុំហើមប្រេះចេញខ្លាញ់ ហើយមេកងបានហៅរទេះដឹកខ្ញុំយកទៅពេទ្យ។ ខ្ញុំបានសម្រាកព្យាបាលជំងឺប្រហែលកន្លះខែរហូតដល់ជាសះស្បើយទើបខ្ញុំត្រលប់មកការដ្ឋានវិញ។

នៅក្នុងមន្ទីរពេទ្យ ខ្ញុំបានទទួលថ្នាំដែលមានរសជាតិផ្អែមមួយថ្ងៃចំនួន ៥គ្រាប់។ កុមារភាគច្រើនគឺជាក្មេងកំព្រាព្រោះកុមារទាំងអស់នោះត្រូវបំបែកចេញពីក្រុមគ្រួសារតាំងពីទើបកើតមកម្ល៉េះ។ ពេលក្មេងៗមានអាយុ ៥ឆ្នាំ អង្គការឲ្យក្មេងៗជើររើសលាមកសត្វទុកលាយជាមួយលាមកមនុស្សធ្វើជាជីសម្រាប់ដាក់ស្រែ។ កូនតូចដែលនៅបៅដោះ អាចបៅដោះម្តាយបានតែ១ដងក្នុងមួយថ្ងៃគឺនៅម៉ោង ១២ថ្ងៃត្រង់ ពេលដែលម្តាយសម្រាកញ៉ាំបាយថ្ងៃត្រង់។ ថ្ងៃមួយ បងស្រីរបស់ខ្ញុំយំនឹកកូនតូចរបស់គាត់អំឡុងពេលធ្វើការ ហើយត្រូវមេកងស្តីប្រដៅមិនឲ្យគិតដល់កូនឡើយ។

ការងាររបស់ខ្ញុំក្រៅពីធ្វើកសិកម្ម គឺជីករណ្តៅទុកកប់សាកសព។ មនុស្សគ្រប់គ្នាមិនអាចនិយាយជជែកគ្នាលេងបានទេ។ នៅក្នុងមួយឆ្នាំ មានបុណ្យកំសាន្តតែបីដងប៉ុណ្ណោះ គឺ បុណ្យចូលឆ្នាំខ្មែរ មានអាហារដូចជា សាច់ជ្រូក សាច់មាន់ និងសាច់គោ ដែលយើងអាចហូបបានមួយឆ្អែត។ ពិធីបុណ្យទីពីរ គឺ បុណ្យភ្ជុំបិណ្ឌ មាននំអន្សមជ្រូកហូប ហើយក៏ជាថ្ងៃដែលអាចហូបបាយបានឆ្អែតដែរ។ ពិធីបុណ្យទីបី គឺ បុណ្យមេទិញ។ វាដូចជាបុណ្យគម្រប់ខួបឬបុណ្យរំឭកដឹងគុណរបបខ្មែរក្រហម។

អ៊ំស្រីនិងអ៊ំប្រុស មិនដែលមានសង្ឃឹមថារស់រានមានជីវិតពីសម័យខ្មែរក្រហមនោះទេ។ គាត់បានផ្អែកខ្នងទៅលើកៅអី មានទឹកមុខស្លូតមើលចំមកខ្ញុំ។ បន្ទាប់ពីស្តាប់រឿង៉ាវរបស់គាត់មក ខ្ញុំមានអារម្មណ៍ដូចមនុស្សឈឺ។ រឿងហេតុសាហាវដែលបានកើតឡើងចំពោះគាត់ ហាក់ដូចជាសាហាវព្រៃផ្សៃពេកដែលខ្ញុំ មិនអាចទទួលយកបាននោះទេ។

ចប់

៥១

រឿង រត់

អ្នកនិពន្ធ ៖ ស៊ុយ លីនប៉ាវ

៥១ ~ រឿង រត់

ព្រឹកព្រលឹមមិនទាន់ ខ្ញុំត្រូវរួតរះក្ងាក់ពីដំណេក ដើម្បីរៀបចំខ្លួនទៅសាលារៀន។ ព្រឹកនេះ ម៉ូតូរបស់ខ្ញុំខូច ខ្ញុំត្រូវហៅម៉ូតូកង់បី ដើម្បីធ្វើដំណើរទៅកាន់សាកលវិទ្យាល័យរបស់ខ្ញុំ។ ម៉ូតូកង់បីដែលខ្ញុំជិះ បានឈប់ទ្រឹងនៅមួយកន្លែង ព្រោះតែការកកស្ទះចរាចរណ៍។ ខ្ញុំ និងអ្នកបើកបរ បាននិយាយគ្នាលេងអំពីមុខរបរកសុី ហើយគាត់បានគ្នួញត្អែរប្រាប់ខ្ញុំថាថា សព្វថ្ងៃនេះ គាត់ពិបាករកលុយណាស់ ហើយទំនិញចេះតែឡើងថ្លៃ ធ្វើឲ្យគាត់ជួបការលំបាកក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសាររបស់គាត់។ បន្ទាប់មក គាត់បានលាន់មាត់ថា គាត់ចង់រៀលត្រលប់ទៅរស់នៅក្នុងរបបខ្មែរក្រហមវិញ។ ខ្ញុំក្ងាក់ផ្អើលខ្លាំងណាស់នៅពេលដែលឮថា គាត់ចង់រៀលត្រលប់ទៅរស់នៅក្នុងរបបខ្មែរក្រហម ដែលមនុស្សគ្រប់គ្នាតែងតែខ្លាចរអា ប៉ុន្តែការពិតនេះគ្រាន់តែជាពាក្យសម្តីនិយាយលេងសើចរបស់គាត់តែប៉ុណ្ណោះ។ រំឭកដល់រឿងនេះ អ្នកបើកបរម៉ូតូកង់បីបានរៀបរាប់ប្រាប់ខ្ញុំពីបទពិសោធជីវិតរបស់គាត់ថា៖

ក្មួយអើយ នៅក្នុងរបបខ្មែរក្រហម យើងមិនអាចរកសេចក្តីសប្បាយបានឡើយ។ យើងមិនដែលបានហូបឆ្អែត ថែមទាំងភ័យខ្លាចអង្គការយកយើងទៅសម្លាប់គ្រប់ពេលវេលាទាំងអស់។ នៅពេលនោះ ខ្ញុំមានអាយុប្រហែល ១២ឆ្នាំតែប៉ុណ្ណោះ។ ខ្ញុំគឺជាប្រជាជនចាស់ រស់នៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ខ្ញុំធ្វើការងារនៅក្នុងកងកុមារ ដែលអង្គការបានឲ្យខ្ញុំធ្វើការងារ ដូចជា កាប់ដើមទន្ទ្រានខែត្រ និងប្រមូលលាមកសម្រាប់ធ្វើជី។ នៅពេលនោះ ខ្ញុំធ្វើការងារចល័ត

ជាច្រើនកន្លែងណាស់។ ក្រៅពីប្រមូលជី និងរែកដីដំបូក អង្គការបានចាត់តាំងឲ្យ ខ្ញុំទៅដាំដំឡូងនៅតំបន់មួយឈ្មោះ ព្រៃបារាំង។ ខ្ញុំបានទៅជាមួយបុរសម្នាក់នៅ ក្បែរផ្ទះរបស់ខ្ញុំ។ យើងទៅ ព្រៃបារាំង មានទាំងក្មេងទាំងចាស់។ យើងរស់នៅ ទីនោះខ្វះខាតអង្ករហូបណាស់។ យើងបានស្វែងរកទំពាំងព្រៃមកស្ងោរហូប លាយជាមួយនឹងអង្ករសម្រាប់អាហាររបស់យើង។ ខ្ញុំរស់នៅទីនោះលំបាកពេក ក៏បានលួចរត់ចេញដោយមិនឲ្យប្រធានកងដឹងទេ។ នៅពេលដែលខ្ញុំមកដល់ត្រឹម អូរអន្លង់អង្គញ់ ទឹកអូរនោះហូរខ្លាំងណាស់ ធ្វើឲ្យខ្ញុំមិនហ៊ានហែលឆ្លងកាត់ទេ។ សំណាងល្អ មានអ្នកដឹកពោតបររទេះកាត់ទីនោះ។ គាត់បានលែងគោឲ្យហែល ឆ្លងទឹកអូរ ហើយឆ្លងទៅយកក្បូនមក ដើម្បីចម្លងរទេះគោរបស់គាត់។ គាត់ បានឃើញខ្ញុំនៅអង្គុយក្បែរនោះ ក៏បានបបួលខ្ញុំឲ្យទៅជាមួយ។ ភ្លាមៗនោះ ខ្ញុំដូចជាស្នាក់ស្មើរដែរ ប៉ុន្តែដោយចង់ឆ្លងអូរត្រលប់ទៅផ្ទះវិញ ខ្ញុំយល់ព្រម ទៅជាមួយគាត់។ បន្ទាប់មក ខ្ញុំបានជិះរទេះដឹកពោតទៅជាមួយគាត់ ប៉ុន្តែមិន ហ៊ានប្រាប់គាត់តាមត្រង់ថា ខ្ញុំទៅភូមិនោះទេ ព្រោះខ្លាចគាត់ដឹងថាខ្ញុំលួចរត់។ នៅពេលនោះ អង្គការមិនសូវតាមដានកុមារដែលរត់គេចនោះទេ។ នៅពេល មកដល់ភូមិមិនបានប៉ុន្មានថ្ងៃផង ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅឃ្វាលគោនៅ ឯទន្លេសាប។ ខ្ញុំសប្បាយចិត្តណាស់ ព្រោះនៅទីនោះ ខ្ញុំបានហូបឆ្អែត។ មាន ថ្ងៃមួយធ្វើឲ្យខ្ញុំចងចាំមិនភ្លេចនោះទេ នៅពេលដែលអង្គការ បានចាត់តាំងខ្ញុំ ឲ្យទៅការដ្ឋាន បញ្ជាជី។ អង្គការឲ្យកុមារដូចជាខ្ញុំម្នាក់ធ្វើការជាមួយនឹងយុវជន ម្នាក់ ប៉ុន្តែត្រូវរែកដីឲ្យបានមួយថ្ងៃ ៩ម៉ែត្រគូប។ ពេលនោះគឺជារដូវប្រាំង សែន វេទនាណាស់។ ខ្ញុំនៅតែចងចាំរូបភាពទាំងអស់នោះមិនភ្លេចឡើយ។ ខ្ញុំធ្វើការងារ ធ្ងន់ជារៀងរាល់ថ្ងៃ ប៉ុន្តែអង្គការឲ្យខ្ញុំហូបតែបបរទេ។ ក្នុងចានបបរ គឺមានតែទឹក និងគ្រាប់អង្ករពីរបីគ្រាប់តែប៉ុណ្ណោះ។ បបរនោះ បានដួសដាក់ចាននិងថែម ទឹកប្រហុក ច្រូចដាក់ឲ្យបន្តិចរួចជាស្រេចជាប្រចាំថ្ងៃនៅលើតុ។ នៅពេលយប់ អង្គការបានឲ្យយើងដេកទល់ជើងគ្នាក្នុងរោងប្រក់ស្លឹកស្នោត ហើយរនាបក្រង កូនឈើឬឫស្សីនឹងរពាក់ និងទុកចន្លោះកណ្តាលសម្រាប់ដើរ។ ខ្ញុំមានមិត្តភក្តិ ម្នាក់ តែងតែមកបបួលខ្ញុំរត់រាល់យប់ ព្រោះមិត្តភក្តិរបស់ខ្ញុំនឹកផ្ទះខ្លាំងពេក។

ថ្ងៃមួយនៅម៉ោងប្រហែលជា ២ទៀបភ្លឺ មិត្តភក្តិរបស់ខ្ញុំ បានមកគោះស្មាខ្ញុំ ហើយសួរមកកាន់ខ្ញុំថា «តោះ!រត់ទៅផ្ទះ?» ខ្ញុំបានបដិសេធ ព្រោះខ្ញុំខ្លាចអង្គការចាប់បាន ហើយណាមួយទៀតពោតលីងដែលម្តាយរបស់ខ្ញុំលីងទុកឲ្យខ្ញុំមកតាមខ្លួននោះមិនទាន់អស់នៅឡើយទេ។ ម្តាយរបស់ខ្ញុំ តែងតែលួចលីងពោតឲ្យខ្ញុំដាក់តាមខ្លួនទុកហូបខ្លាចក្រែងថ្ងៃណាមួយខ្ញុំគ្មានអ្វីហូប។ មិត្តភក្តិរបស់ខ្ញុំតែងតែមកបបួលខ្ញុំរាល់ថ្ងៃ ហើយបានធ្វើឲ្យខ្ញុំសម្រេចចិត្តរត់ទៅជាមួយគ្នា។ ខ្ញុំបានស្លៀកពាក់ខោអាវទាំងអស់របស់ខ្ញុំជាប់នឹងខ្លួនដោយមិនរៀបជាបង្វេចទេ ព្រោះខ្លាចអង្គការចាប់បានថាខ្ញុំលួចរត់។ ខ្ញុំលួចរត់ច្រើនដងណាស់ អាចថាមកពីពេលនោះ ខ្ញុំនៅក្មេងពេកមិនបានគិតអ្វីឲ្យបានច្បាស់លាស់។ នៅពេលដែលខ្ញុំយល់ថា នៅកន្លែងណាដែលមិនសូវស្រួលហើយ ខ្ញុំដឹងតែរត់មកវិញជាមិនខាន។ ពេលនោះ មិនមែនតែខ្ញុំទេដែលទទួលរងអំពើអមនុស្សធម៌បែបនេះ។

ការសន្ទនារបស់ខ្ញុំ និងអ្នកបើកម៉ូតូកង់បី បានបន្តអូសបន្លាយយ៉ាងយូរទម្រាំតែគាត់ដឹកខ្ញុំមកដល់មុខសាកលវិទ្យាល័យរបស់ខ្ញុំ។ ខ្ញុំបានស្វែងយល់អំពីជីវិតរបស់កុមារ ដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម។ តើមានមនុស្សប៉ុន្មាននាក់នៅក្នុងរបបខ្មែរក្រហម ដែលធ្លាប់ឆ្លងកាត់បទពិសោធជីវិតលួចរត់មកផ្ទះ ដោយមិនត្រូវអង្គការចាប់ខ្លួនដូចគាត់?

ចប់

៥២

រឿង ខ្សែជីវិត កងកុមារ

អ្នកនិពន្ធ ៖ អិន ចាន់ពេញ

៥២ ~ រឿង ខ្សែជីវិតកងកុមារ

មីងលី គឺជាមនុស្សម្នាក់ក្នុងចំណោមប្រជាជនរាប់សែននាក់ដែលបានឆ្លងកាត់ការរស់នៅដោយគ្មានសិទ្ធិសេរីភាព និងគ្មានការជួបជុំបងប្អូនក្រុមគ្រួសារឡើយ។ អ្វីៗត្រូវរស់នៅជាក្រុមទៅតាមការចាត់តាំងរបស់អង្គការ។ មនុស្សចាស់ត្រូវរស់នៅក្រុមមនុស្សចាស់ យុវជនត្រូវនៅក្រុមយុវជន ក្មេងត្រូវនៅក្រុមក្មេង ប្រុសនៅដោយប្រុស ស្រីនៅដោយស្រី លើកលែងតែគូស្វាមីដែលទើបតែរៀបការរួច និងក្មេងមិនទាន់អាចធ្វើអ្វីបានប៉ុណ្ណោះ ទើបអាចនៅជាមួយគ្នាបាន។ មីងលីបានចែករំលែកបទពិសោធជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហម ថា៖

ខ្ញុំទើបតែមានអាយុ ៨ឆ្នាំទេនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែខ្ញុំបានឆ្លងកាត់នូវរឿងរ៉ាវដ៏សែនជូរចត់ជាច្រើន។ ខ្ញុំរស់នៅជាមួយក្រុមគ្រួសាររួមមាន ឪពុកម្តាយ និងបងប្អូនស្រីប្រុសចំនួន ៨នាក់។ ខ្ញុំគឺជាកូនទី៦។ បងស្រីទាំងពីរនាក់របស់ខ្ញុំគឺជាកូនភ្លោះ។ គាត់មានអាយុ១១ឆ្នាំ និងបងប្រុសទាំងបីនាក់របស់ខ្ញុំ មានអាយុច្រើនជាងគ្នាពីរៗឆ្នាំ រីឯប្អូនប្រុសស្រីទាំងពីររបស់ខ្ញុំ នៅតូចៗនៅឡើយ។

មុនឆ្នាំ១៩៧៥ យើងរស់នៅជួបជុំគ្នាយ៉ាងសុខសាន្ត ប៉ុន្តែ បន្ទាប់ពីខ្មែរក្រហមក្តោបក្តាប់ប្រទេសកម្ពុជាបានទាំងស្រុង ជីវិតបងប្អូនយើងទាំងប្រាំបីនាក់ មិនដែលបានជួបជុំគ្នាឡើយ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបែកគ្នាទាំងអស់។ ម្តាយរបស់ខ្ញុំត្រូវទៅធ្វើចុងភៅ និងឪពុករបស់ខ្ញុំ ត្រូវទៅធ្វើការជាទម្ងន់។ រីឯបងប្រុសរបស់ខ្ញុំចូលក្នុងកងយុវជនឈានមុខ។ ចំណែកបងទី៣ ត្រូវទៅមើលគោរាប់សិបក្បាល។ បងទី១ និងទី២ ត្រូវអង្គការចាត់តាំងឲ្យចូលក្នុងក្រុមធ្វើកសិកម្ម និងប្រព័ន្ធ

ធារាសាស្ត្រ។ ចំណែកខ្ញុំនិងបងស្រីទាំងពីរនាក់ ត្រូវបានអង្គការប្រើឲ្យដើររើសអាចម៍គោនិងទៅរៀន។

ក្រៅពីកម្សត់ ក៏មានរឿងរ៉ាវខ្លះសប្បាយដែរ។ ខ្ញុំបានដើររើសអាចម៍គោជួនកាលរត់លេងតាមវាលស្រែដេញចាប់គ្នាលេង និងមើលប្អូនតូចៗ ពេលខ្លះខ្ញុំវាយប្អូនឲ្យយំ ដើម្បីគេចខ្លួន។ ពេលរៀន ខ្ញុំខ្ជិលណាស់។ ខ្ញុំអត់ចង់ចូលរៀនទេព្រោះខ្ញុំស្អប់គ្រូ។ អ្នកគ្រូកាចណាស់វាយខ្ញុំស្ទើរតែរាល់ថ្ងៃ។ អង្គការ ឲ្យខ្ញុំរៀននៅក្រោមដើមព្រីង គ្មានអគារសម្ភារសម្រាប់រៀនត្រឹមត្រូវនោះទេ។ ចំពោះគ្រូបង្រៀនវិញ គឺមានចំណេះដឹងតិចតួច និងគ្មានគរុកោសល្យអ្វីឡើយ ចេះត្រឹមតែអក្សរ ក,ខ,គ និងស្រះតែប៉ុណ្ណោះ។ គ្រូបង្រៀនតែពីរបីអក្សរទេរៀងរាល់ថ្ងៃនោះ។

ជីវិតរបស់ខ្ញុំត្រូវរស់នៅយ៉ាងវេទនា ពេលយប់ម្តងៗខ្ញុំកម្រនៅដេកជាមួយក្មេងៗឯទៀតណាស់។ ខ្ញុំបានរត់ទៅផ្ទះដែលម្តាយរបស់ខ្ញុំស្នាក់នៅមានចម្ងាយប្រហែលជា ៥គីឡូម៉ែត្រ។ ពេលខ្លះ ខ្ញុំត្រូវរត់ពួនពីកងចល័ត និងពេលខ្លះទៀតខ្ញុំវង្វេងផ្លូវរកផ្ទះមិនឃើញ ត្រូវដេកកណ្តាលផ្លូវតែម្នាក់ឯងទាំងរងា ទាំងភ័យព្រោះសុទ្ធតែព្រៃមានសត្វសាហាវរស់នៅ។ ទោះបីជាខ្ញុំវង្វេងផ្លូវយ៉ាងណា ក៏ខ្ញុំមិនអាចបញ្ឈប់គំនិតរត់ទៅរកម្តាយរបស់ខ្ញុំបានដែរ។

នៅគ្រាមួយ ខ្ញុំឃ្លានយ៉ាងខ្លាំង ព្រោះមិនបានហូបបាយពេញមួយថ្ងៃ។ ខ្ញុំលើកតែដៃស្ទើរមិនរួចផង។ ខ្ញុំខំដើរទៅកន្លែងម្តាយរបស់ខ្ញុំ។ ពេលទៅដល់ភ្លាមម្តាយរបស់ខ្ញុំឃើញសភាពខ្ញុំបែបនោះ ក៏បានស្រវាស្រទេញរកអីមកឲ្យខ្ញុំហូប។ គាត់បានយកបាយក្តាំង ១ដុំ ដែលនៅសល់ពីព្រឹកមកឲ្យខ្ញុំ។ ខ្ញុំហូបបាយនោះភ្លាម មានកម្លាំងណាស់។ វាគឺជាបាយដែលឆ្ងាញ់បំផុតក្នុងជីវិតរបស់ខ្ញុំ។ បន្ទាប់ពីខ្ញុំហូបបាយនោះមិនទាន់បានពាក់កណ្តាលផង ស្រាប់តែមានមីងម្នាក់ទៀតនៅផ្ទះបាយជាមួយម្តាយរបស់ខ្ញុំ បានមកកញ្ឆក់បាយក្តាំងរបស់ខ្ញុំ ហើយស្តីបន្ទោសឲ្យម្តាយរបស់ខ្ញុំខ្លាំងៗថា «យី! ម៉េចមិត្តឯងធ្វើអីចឹង តែអង្គការចាប់បានជាក់ទោសទាំងអស់គ្នាឥឡូវហើយ»។ ម្តាយរបស់ខ្ញុំ យំអាណិតខ្ញុំជាពន់ពេក ពេលឃើញដៃរបស់ខ្ញុំញ័រទទ្រើតឃ្លានស្ទើរតែដាច់ខ្យល់។ ខ្ញុំ និងម្តាយងាកមកយំឱបគ្នាយ៉ាង

ខ្សឹបខ្សួល។ ម្តាយរបស់ខ្ញុំ បានលួងលោមខ្ញុំថា «ទ្រាំសិនទៅកូនបន្តិចទៀតលែងអីហើយ»។ រំពេចនោះ គាត់បានទៅយកដំឡូងមួយដុំ ដែលគាត់ទុកហូបខ្លួនឯងមកឲ្យខ្ញុំ។ ម្តាយរបស់ខ្ញុំសុខចិត្តអត់ហូបខ្លួនឯង។

ឆ្នាំ១៩៧៨ ជាថ្ងៃដែលខ្ញុំមិនចង់រឭកនោះទេ។ ថ្ងៃមួយម៉ោង ២រសៀលជាង ខ្ញុំបានទទួលដំណឹងថា ឪពុករបស់ខ្ញុំស្លាប់ដោយសារថ្នាំធ្លាក់កិន។ ពេលនោះអារម្មណ៍របស់ខ្ញុំឈឺចាប់គ្មានអ្វីប្រៀបស្មើបានឡើយ។ ពេលខ្ញុំរត់ទៅដល់កន្លែងនោះ ខ្ញុំបានឃើញម្តាយរបស់ខ្ញុំយំរហូតដល់សន្លប់។ បងស្រីទាំងពីរនាក់របស់ខ្ញុំកំពុងយំឱបជើងឪពុកទាំងសងខាង។ ខ្ញុំលត់ជង្គង់ចុះយំក្បែរនោះដែរ។ អារម្មណ៍ដែលបាត់បង់អ្នកជាទីស្រលាញ់ ពិតជាពិបាកទទួលយកណាស់មិនថានៅពេលណានោះទេ។ ក្រោយពីយំឡើងខ្សោះខ្លួន បងធំរបស់ខ្ញុំ បានមកដល់ ហើយយកសពឪពុករបស់ខ្ញុំទៅផ្ទះដែលគាត់ស្នាក់នៅ។ អង្គការបានរៀបចំបញ្ចុះសពឪពុករបស់ខ្ញុំដោយមិនឲ្យទុកយូរឡើយ ហើយក៏គ្មានធ្វើបុណ្យឲ្យបានត្រឹមត្រូវតាមប្រពៃណីសាសនាទេ។ ម្តាយរបស់ខ្ញុំ ក្លាយជាស្ត្រីមេម៉ាយ ព្រមទាំងទទួលបន្ទុកមើលថែកូនទាំង ៨នាក់តែម្តាក់ឯង។

រឿងរ៉ាវមិនទាន់ចប់នៅឡើយទេ។ ជីវិតក្រោយពេលឪពុកស្លាប់ គ្រួសាររបស់ខ្ញុំ ត្រូវជួបរឿងឥតឈប់ឈរ។ ម្តាយរបស់ខ្ញុំមានអ្នកតាមស្រលាញ់ ដោយមិនយល់ដល់ខ្មោចឪពុកខ្ញុំដែលទើបនឹងស្លាប់ទាល់តែសោះ។ មិនតែប៉ុណ្ណោះអ្នកដែលស្រលាញ់ម្តាយរបស់ខ្ញុំនោះ គឺជាមិត្តភក្តិឪពុករបស់ខ្ញុំទៅទៀត។ តើស្ត្រីមានកូន ៨នាក់ ហើយនៅមានអ្នកតាមស្រលាញ់ទៀត យើងគិតមើលថាតើគាត់ស្អាតណាមែនទេ? ការពិតមិនមែនទេ ម្តាយរបស់ខ្ញុំមិនស្អាតណាស់ណាទេ តែលោកពូនោះលួចស្រលាញ់ម្តាយរបស់ខ្ញុំតាំងពីនៅក្រមុំម្ល៉េះ។ ចុះហេតុអ្វីបានជាគាត់ចិត្តស្មោះម្ល៉េះ? ទីបំផុតម្តាយរបស់ខ្ញុំនៅតែបដិសេធលោកពូនោះដដែល។ ម្តាយរបស់ខ្ញុំស្មោះត្រង់ជាមួយឪពុករបស់ខ្ញុំណាស់ ទោះបីជាគាត់ស្លាប់ហើយក៏ដោយ។

ក្រោយៗមក ចេះតែមានអ្នកច្រណែនហើយរួមគ្នាទម្លាក់កំហុសមកលើម្តាយរបស់ខ្ញុំ។ គាត់ត្រូវបានចោទប្រកាន់ពីរបីដងដែរ ប៉ុន្តែគាត់ជាមនុស្សស្មោះត្រង់និងល្អ ទើបទេវតាតាមថែរក្សាគាត់ឲ្យរួចផុតពីបញ្ហាចោទទាំងពួងនោះ។

ម្តាយរបស់ខ្ញុំតែងតែណែនាំខ្ញុំធ្វើជាមនុស្សល្អ និងគិតអ្វីដែលល្អៗ។ ពេលនោះ ខ្ញុំនៅក្មេងងងឹតលង់នៅឡើយ ថែមទាំងបានសួរគាត់វិញថា «ម៉ែៗ ម៉ែតែងតែណែនាំខ្ញុំឲ្យធ្វើមនុស្សល្អ មិនគិតអាក្រក់ទៅលើនរណា ចុះម៉េចមនុស្សល្អគេធ្វើបាបហូតអីចឹង?»។ រំពេចនោះ ម្តាយរបស់ខ្ញុំ បានឱប ហើយអង្អែលក្បាលរបស់ខ្ញុំថ្នមៗ។

រឿងវេទនាចេះតែកើតឡើងមកលើសមាជិកគ្រួសាររបស់ខ្ញុំឥតឈប់ឈរ ទាល់តែសោះអស់ពីរឿងមួយចូលដល់រឿងមួយផ្សេងទៀត។ ម៉ោងខ្ទង់ ៥ល្ងាច នៅចុងឆ្នាំ១៩៧៨ បងស្រីទាំងពីរនាក់របស់ខ្ញុំ ចាប់ផ្តើមញ័រញាក់យ៉ាងខ្លាំង ព្រោះត្រូវទឹកត្មៀងពីរថ្ងៃជាប់ៗគ្នា។ គាត់ក្តៅឡើងប្រកាច់ ព្រោះគាត់គ្មានសម្លៀកបំពាក់សម្រាប់ផ្លាស់ប្តូរទេ។ ហេតុនេះ គាត់ទាំងពីរនាក់ ត្រូវស្លាប់ទាំងវ័យក្មេង ព្រោះតែគ្មានអ្នកមើលថែ និងថ្នាំព្យាបាលបានត្រឹមត្រូវនិងទាន់ពេលវេលា។

ម្តាយរបស់ខ្ញុំទើបតែបាត់បង់ប្តីមិនទាន់បានប៉ុន្មានផង កូនទាំងពីរនាក់ក៏ស្លាប់ចោលទៀត។ គាត់ពិបាកចិត្តណាស់។ រីឯខ្ញុំក៏ឈឺគ្រុនដែរ តែមិនធ្ងន់ធ្ងរទើបអាចរួចរស់ជីវិតបាន។ ម្តាយរបស់ខ្ញុំចង់សម្លាប់ខ្លួន ប៉ុន្តែគាត់នឹកឃើញដល់កូនៗដែលរស់នៅគ្មានទីពឹង។ ប៉ុន្មានខែក្រោយមក ម្តាយរបស់ខ្ញុំ ត្រូវដកចេញពីកន្លែងចុងភៅ ហើយទៅធ្វើការងារដូចប្រជាជនឯទៀតដែរ។

នៅឆ្នាំបន្ទាប់ របបអាហារ កាន់តែតិចទៅៗ ចំណែកឯ ការងារចេះតែកើនឡើង។ សម្លដែលចុងភៅស្លឲ្យយើងហូប មានតែបន្លែព្រលឹត និងជាងគ្រាវតែប៉ុណ្ណោះ។ បន្លែទាំងនោះ ចុងភៅ មិនបានបកសំបកចេញឲ្យបានត្រឹមត្រូវនិងអនាម័យទេ គឺហាន់ស្លទាំងសំបកតែម្តង។ ចំណែកម្ហូបវិញមានតែកូនទាប៉ុនៗកជើងពីរឬបីសម្រាប់ស្លមួយខ្ទះត្នោត មើលទៅទឹកឡើងខ្មៅ។ បើម្ហូបវិញ ចុងភៅដាក់ចូលទៅក្នុងសម្លទាំងឫស។ យើងហូបសម្លបែបនេះស្ទើរតែរាល់ថ្ងៃ។ មនុស្សម្នាក់ៗគ្មានកម្លាំងដើម្បីធ្វើការឡើយ។ អ្នកខ្លះដូចជាម្តាយរបស់ខ្ញុំជាដើម បានដាច់ចិត្តទៅលួចដំឡូងយកមកដុតចម្អែតក្រពះបន្ថែម។ សំណាងដែរ ដែលម្តាយរបស់ខ្ញុំប៉ះចំថ្នាក់លើដែលមានចិត្តធម៌ មិនដាច់ចិត្តចាប់ម្តាយរបស់ខ្ញុំនៅពេលឃើញគាត់លួចយកអាហារទាំងនោះ។ ថ្នាក់លើរបស់គាត់តែងតែប្រាប់គាត់ថា «ហូបៗចុះ តែកុំឲ្យគេមកទាន់ប្រយ័ត្នមានរឿងទាំងអស់គ្នា»។

បងធំរបស់ខ្ញុំ រស់នៅភូមិភាគខុសពីម្តាយ និងបងប្អូនឯទៀត។ ថ្នាក់លើរបស់គាត់តឹងតែងខ្លាំងណាស់ចំពោះរបបអាហារ។ ថ្នាក់លើរបស់គាត់ហាមដាច់ខាត ហើយឲ្យតែឃើញប្រជាជនលួច ថ្នាក់លើនឹងសម្លាប់ចោលហើយ។ ថ្ងៃមួយពេលបងធំរបស់ខ្ញុំមកលេងផ្ទះ គាត់បានសួរយើងថា «មានដំឡូងហូបទេ»។ ខ្ញុំមើលទៅគាត់ប្រហែលជាឃ្លានខ្លាំងណាស់ សូម្បីដៃក៏កាន់ដំឡូងលែងចង់ជាប់ដែរ ហើយមើលទៅរាងកាយស្គមស្គាំងស្ទើរមើលលែងស្គាល់ថាជាបងរបស់ខ្ញុំទៅហើយ។ ល្ងាចបន្តិចទៅហើយ ខ្ញុំឆ្ងល់ម៉េចបងរបស់ខ្ញុំមិនទាន់ទៅកន្លែងគាត់វិញអីចឹង។ ខ្ញុំក៏សួរគាត់ថា បង «អត់ទៅកន្លែងវិញទេហី?» បងរបស់ខ្ញុំបានលើកដៃបិទមាត់របស់ខ្ញុំ ហើយនិយាយថា «កុំមាត់បងមកនេះ ប្រធានបងមិនឲ្យមកទេ បងលួចរត់មកតើ អូនកុំប្រាប់គេថាបងនៅទីនេះណា!»។ ឮដូច្នោះហើយ ខ្ញុំក៏ងក់ក្បាល។

មួយសន្ទុះក្រោយមក ខ្ញុំបានលាបងប្រុសរបស់ខ្ញុំទៅកន្លែងម៉ែវិញ។ ខ្ញុំធ្វើដំណើរមិនទាន់បានឆ្ងាយប៉ុន្មានផង ក៏ឮសំឡេងឆោឡោថា «ចាប់វាឲ្យជាប់» ហើយឮសំឡេងស្រែកថា «អ៊ុយៗៗ»។ ខ្ញុំគិតថា អង្គការចាប់បងរបស់ខ្ញុំហើយ។ ខ្ញុំបានរត់មកកន្លែងដែលទើបនឹងជួបគាត់ តែមិនបានឃើញគាត់ឡើយ។ ខ្ញុំអស់សង្ឃឹមក៏អង្គុយចុះហើយយំតែម្នាក់ឯង។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនបានទទួលដំណឹងអ្វីពីគាត់ទាល់តែសោះ ហើយយើងទាំងអស់គ្នាគិតថាគាត់ស្លាប់បាត់ហើយ។

ក្រោយពីបានឆ្លងកាត់រឿងរ៉ាវកម្សត់ជាច្រើន ជីវិតគ្រួសាររបស់ខ្ញុំ បានមករស់នៅជួបជុំគ្នាវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ប៉ុន្តែសមាជិកគ្រួសាររបស់ខ្ញុំបានស្លាប់អស់ ៤នាក់ទៅហើយ។ ពេលដែលបែកខ្មែរក្រហមថ្មីៗ យើងត្រូវរស់នៅលំបាកបន្តទៀត ដោយសារខ្វះខាតស្បៀងអង្ករ។ ពួកយើងត្រូវទៅហូបបាយដែលដាំលាយដំឡូងនិងក្តួច សឹងតែគ្រប់ពេលវេលា ជួនកាលគ្មានសូម្បីដំឡូងនិងក្តួចហូបផង។ យើងត្រូវដាំបាយលាយគល់ល្អុងឬគល់ចេក ដោយដាក់អង្ករតិចតួច។

បច្ចុប្បន្ននេះ ខ្ញុំមានគ្រួសារ ហើយប្អូនៗ និងបងៗរបស់ខ្ញុំដែលនៅរស់ សុទ្ធតែមានក្រុមគ្រួសារដូចគ្នា។ ចំណែកម្តាយរបស់ខ្ញុំ បានស្លាប់ទៅហើយដោយសារជំងឺពុំរ៉ៃ ដែលបង្កមកពីការទទួលរងទារុណកម្មទាំងផ្លូវកាយនិងផ្លូវចិត្តក្នុងរបបខ្មែរក្រហម។ ម្តាយរបស់ខ្ញុំស្លាប់បន្ទាប់ពីជួបជុំក្រុមគ្រួសារបាន ៣ឆ្នាំ។ រៀងរាល់ថ្ងៃខ្ញុំនៅតែនឹកដល់ឪពុក ម្តាយ និងបងៗរបស់ខ្ញុំ ដែលបានស្លាប់ទៅជានិច្ច។

ចប់

៥៣

រឿង ឆ្លងទន្លេ

អ្នកនិពន្ធ ៖ គង់ សារិទ្ធ

៥៣ ~ រឿង ឆ្លងទន្លេ

នៅជាប់របងផ្ទះតៀមមួយដែលមានរានហាលនៅពីខាងមុខផ្ទះ ខ្ញុំកំពុងតែដេកបំបៅដោះកូន ដែលមានអាយុប្រហែលជាង ២ឆ្នាំ និង កូនប្រុសម្នាក់ទៀតរបស់ខ្ញុំ មានអាយុប្រហែលជា ៤ឆ្នាំ នៅក្បែរនោះដែរ។ កូនប្រុសរបស់ខ្ញុំ កំពុងតែយំរអុកទារកអាហារ។ រំពេចនោះ កងទ័ពខ្មែរក្រហម ពីរនាក់ ស្លៀកសម្លៀកបំពាក់ខ្មៅ ដៃកាន់កាំភ្លើង បានស្រែកគំហក និងគំរាមកំហែងដល់ខ្ញុំឲ្យលួងលោមកូនឲ្យបាត់យំ។ មួយសន្ទុះក្រោយមក មានកងទ័ព ៤នាក់ទៀត បានដើរមកចាប់កុមារវាយដោយរំពាត់ឲ្យបាត់យំ។ ខ្ញុំបានស្ទុះទៅចាប់បីត្រកងកូន និងយកក្រមាខ្ចប់មាត់កុំឲ្យកូនខ្ញុំយំឮសំឡេងខ្លាំងចេញមក។ បន្ទាប់ពីក្រុមកងទ័ពខ្មែរក្រហមទៅបាត់ ខ្ញុំបានលើកកូនបីដាក់លើត្រែ ហើយខ្ញុំស្រាប់តែភ័យស្លន់ស្លោភ្លាមៗ ព្រោះកូនរបស់ខ្ញុំបានបាត់មាត់បាត់កលែងនិយាយស្តីអ្វីទាំងអស់។ អ្នកនៅក្បែរៗនោះពុំមានអ្នកណាហ៊ានសួរនាំ ឬជួយសង្គ្រោះកូនរបស់ខ្ញុំទេ ព្រោះកងទ័ពបានប្រកាសកាលពីពេលល្ងាចថា មិនឲ្យប្រជាជនម្នាក់ៗចេះជួយឈឺឆ្អាលរឿងអ្នកដទៃឡើយ។

ខ្ញុំឈ្មោះ ខេមរា។ ខ្ញុំបានបីកូនស្រីដៃម្ខាង និងដៃម្ខាងទៀតប្រឹងរឹតទ្រូងកូនប្រុសរបស់ខ្ញុំ ដែលមិនដឹងខ្លួន។ បន្តិចក្រោយមក បុរសស្លៀកសម្លៀកបំពាក់ខ្មៅម្នាក់ បានដើរចេញពីផ្ទះមកឈរជិតខ្ញុំ។ ពេលឃើញដូច្នោះ ខ្ញុំភ័យញ័រខ្លួនចំប្រប់។ បុរសនោះ បានចូលមកជួយកោសរឹតលាបប្រេងកូឡាទាល់តែកូនរបស់ខ្ញុំដឹងខ្លួនឡើងវិញ រួចគាត់បានបើកកញ្ចប់បាយឲ្យខ្ញុំ និងកូនៗហូបទាំងអស់គ្នា។ ខណៈនោះ កងទ័ពខ្មែរក្រហមពីរនាក់ផ្សេងទៀត បានមកដល់ ហើយសួរដេញដោលដោយងឿងឆ្ងល់អំពីប្រភពបាយដែលខ្ញុំទទួលបានយកមកហូបនេះ។ បុរស

នោះបាននិយាយសម្តីសុភាពរាបសាប្រាប់ទៅកាន់កងទ័ពខ្មែរក្រហមទាំងពីរនាក់វិញថា «ខ្ញុំគឺជាកងទ័ពរំដោះ ហើយមេបញ្ជាការតំបន់បានបញ្ជាឲ្យខ្ញុំនៅយាមការពារកំពង់ចម្លងនេះ។ ខ្ញុំមានឯកសារបញ្ជាក់។ ស្ត្រីនេះនិងកូនៗ ត្រូវជាប្រពន្ធ និងកូនរបស់ខ្ញុំ»។ បន្ទាប់ពីកងទ័ពខ្មែរក្រហម ចាកចេញទៅបាត់ បុរសនោះបានរៀបរាប់ប្រាប់ខ្ញុំថា គាត់ឈ្មោះ ជា វីរៈ គឺជាប្រធានផ្នែកការពារសន្តិសុខនៅលើសាឡាងជាងពីរខែមកហើយ ចាប់តាំងពីមានការប្រយុទ្ធគ្នាក្តៅគគុកវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ ខ្ញុំបានលើកដៃសំពះអរគុណដល់វីរៈ ជាពន់ពេកដែលបានមកជួយសង្គ្រោះជីវិតកូនប្រុសរបស់ខ្ញុំ។ បន្ទាប់ពីវីរៈចាកចេញទៅ ខ្ញុំនិងកូនទាំងពីរនាក់ បានសំងំដេកនៅលើគ្រែទ្រុឌទ្រោមមួយ។

ពេលព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម បានភ្ជង់កាំភ្លើងសម្តែងឲ្យប្រជាជនចាកចេញពីវិទ្យាល័យទួលស្វាយព្រៃ។ ខណៈនោះ ខ្ញុំបានសុំអង្វរកងទ័ពខ្មែរក្រហម ដើម្បីរង់ចាំប្តីរបស់ខ្ញុំចេញពីក្រសួងវិចិត្រសិល្បៈមកទទួលខ្ញុំនៅម៉ោង១១ ប៉ុន្តែកងទ័ពខ្មែរក្រហមមិនយល់ព្រមជាដាច់ខាត ថែមទាំងបាញ់កាំភ្លើងចំចន្លោះជើងរបស់ខ្ញុំ ធ្វើឲ្យខ្ញុំភ័យតក់ស្លុតជាខ្លាំង។ ខ្ញុំត្រូវបង្ខំចិត្តចាកចេញជាមួយកូនតូចៗទាំងពីរនាក់ ដោយដៃម្ខាងរបស់ខ្ញុំដឹកដៃកូនប្រុស និងដៃម្ខាងទៀតរបស់ខ្ញុំពកូនស្រី ហើយក្បាលរបស់ខ្ញុំទួលបង្វែចខោអាវ រួចដើរមកជាមួយហ្វូងមនុស្សដ៏ណែនណាន់តាន់តាប់កាត់តាមផ្លូវជាតិលេខ១ឆ្ពោះមកដល់កំពង់ចម្លងអ្នកលឿងត្រើយខាងលិច។ ខ្ញុំសំងំឆ្មៃចភ្នែកមួយស្រឡេត ហើយស្រាប់តែភ្ញាក់ក្រញាងដោយសារតែឮសូរគ្រាប់កាំភ្លើងផ្ទុះផ្ងរផាំងៗ។ ភ្លាមៗនោះសំឡេងស្រែកទួញយំខ្សឹកខ្សួលលាន់ឡើងមិនដាច់សូរសោះក្នុងពេលរាត្រីដ៏សែនក្រៀមក្រំនេះ។ ខ្ញុំភិតភ័យណាស់ខ្លាចកូនទាំងពីរនាក់របស់ខ្ញុំភ្ញាក់ ហើយស្រែកយំទៀត អាចនឹងត្រូវកងទ័ពខ្មែរក្រហមសម្លាប់កូនខ្ញុំមិនខានទេ។ ខ្ញុំបន់ឲ្យតែមេឃធាប់ភ្លឺនឹងបានបន្តដំណើរទៅស្រុកកំណើតរបស់ខ្ញុំនៅឯខេត្តព្រៃវែង។ កងទ័ពខ្មែរក្រហម បានដើរប្រមូលយករបស់របរ ដូចជា ម៉ូតូ កង់ នាឡិកា មាសប្រាក់ វិទ្យុ ម៉ាញ៉េ ស្បែកជើង និងកាតាបល្អៗ ពីប្រជាជនទាំងអស់ ហើយប្រសិនបើប្រជាជននៅរឹងទទឹងមិនព្រមឲ្យទេ កងទ័ពខ្មែរក្រហម នឹងបាញ់សម្លាប់ចោលភ្លាម។

មេឃចាប់ភ្លឺស្រាងៗ មាន់ចាប់ផ្តើមរងាវបញ្ចេញសំឡេងកងរំពងជាស់ប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញឲ្យក្រោកឡើង ដើម្បីត្រៀមបន្តដំណើរទៅមុខទៀត។ វីរៈ បានមកជួបខ្ញុំម្តងទៀត ហើយបានឲ្យខ្ញុំយកសំបុត្រមួយកាន់នៅដៃឲ្យជាប់ ដើម្បីបង្ហាញដល់កងទ័ពខ្មែរក្រហមក្រែងទទួលបានការអនុគ្រោះខ្លះ។ វីរៈ យកថង់អង្ករប្រហែលជាពីរគីឡូ ទឹកមួយប៊ីដុង សារុងចំនួនពីរ និងអាវពីរប្រគល់ឲ្យមកខ្ញុំ។

ពេលដែលខ្ញុំជម្លៀសចេញពីទីក្រុងភ្នំពេញ ខ្ញុំពុំបានជួបប្តីរបស់ខ្ញុំទេ។ រហូតដល់ខ្ញុំធ្វើដំណើរមកដល់ព្រៃកឯង ទើបបានជួបប្តីរបស់ខ្ញុំកំពុងតែនៅជាមួយលោក សុិន ស៊ីសាមុត លោក គង្គ ប៊ុនឈឿន អ្នកនិពន្ធបទចម្រៀង និងតារាភាពយន្តជាច្រើននាក់ទៀត។ ប្តីរបស់ខ្ញុំ បានជិះកង់ឆុបខ្ញុំ មកសម្រាកនៅក្នុងវិទ្យាល័យព្រះបាទជ័យវរ្ម័នទី៧ មួយយប់។ ព្រឹកម៉ោង៥ ខ្ញុំនិងប្តី បានធ្វើដំណើរបន្តមកទៀតដោយជិះកង់ផងបណ្តើរកង់ផងរហូតមកដល់មុខសាលាកំពង់ភ្នំ។ កងទ័ពខ្មែរក្រហម ពីរនាក់ បានមកខ្ចីកង់ប្តីរបស់ខ្ញុំ។ ពេលនោះ ប្តីរបស់ខ្ញុំមិនឲ្យកង់ទៅកងទ័ពខ្មែរក្រហមទេ។ គាត់បាននិយាយទៅកាន់កងទ័ពខ្មែរក្រហមថា «ខ្ញុំមានកង់តែមួយទុកឆុបប្រពន្ធនិងកូនតូចពីរនាក់របស់ខ្ញុំទៅកំពង់ចម្លងអ្នកលឿង»។ កងទ័ពខ្មែរក្រហមម្នាក់ បានភ្ជង់កាំភ្លើងដាក់ប្តីរបស់ខ្ញុំ ហើយកងទ័ពម្នាក់ទៀតបានចាប់ក្របួចកអាវរបស់គាត់រួចទះកំផ្លៀង។ ភ្លាមៗនោះ ប្តីរបស់ខ្ញុំ បានដួលដេកក្រាបនៅលើផ្លូវថ្នល់។ កងទ័ពខ្មែរក្រហម បានលើកជើងជាន់លើខ្នងប្តីរបស់ខ្ញុំទៀត និងទាត់ធាក់ប្តីរបស់ខ្ញុំយ៉ាងធ្ងន់ធ្ងរ។ ខ្ញុំភ័យតក់ស្លុតខ្លាំងណាស់ ហើយក្រាបសំពះអង្វរកងទ័ពទាំងអស់នោះកុំឲ្យធ្វើបាបប្តីរបស់ខ្ញុំ។ កងទ័ពម្នាក់ដែលមានវ័យក្មេង បានបាញ់កាំភ្លើងបីគ្រាប់តាមចន្លោះជើងខ្ញុំជាលើកទីពីរ ធ្វើឲ្យខ្ញុំទន់ដៃទន់ជើងរបូតធ្លាក់កូនពីលើដៃ។ ចំណែកប្តីរបស់ខ្ញុំ ត្រូវកងទ័ពខ្មែរក្រហមអូសយកទៅដាក់នៅចិញ្ចើមផ្លូវក្បែរអ្នករបួស និងសាកសពជាច្រើន ដែលកំពុងតែដេកដួលនៅទីនោះ។ បន្ទាប់មក កងទ័ពខ្មែរក្រហមបានបាញ់រះបង្ហើរក្បាលជាច្រើនគ្រាប់បង្ខំឲ្យអ្នកជម្លៀសទាំងអស់បន្តដំណើរ

ទៅមុខទៀតនិងហាមមិនឲ្យងាកក្រោយជាដាច់ខាត។ ខ្ញុំគ្មានសង្ឃឹមថាប្តីរបស់ខ្ញុំនៅរស់រានមានជីវិតទេ ព្រោះសូម្បីតែខ្លួនរបស់ខ្ញុំ និងកូនរបស់ខ្ញុំទាំងពីរនាក់ក៏ពុំមានសង្ឃឹមថានឹងអាចរស់នៅបានដល់ថ្ងៃស្អែកផង។ ម៉ោង៦ព្រឹក អ្នកដំណើរទាំងអស់នឹងត្រូវឆ្លងសាឡាងទៅអ្នកលឿងត្រើយខាងកើត។ នៅពេលដែលឆ្លងសាឡាង យើងត្រូវតែរក្សាភាពស្ងៀមស្ងាត់ ធ្វើយ៉ាងណាខ្ញុំត្រូវតែលួងលោមកូនតូចៗកុំឲ្យយំ ព្រោះនៅពេលដែលមានសំឡេងក្មេងយំឮខ្លាំងៗ ហើយធ្វើឲ្យកងទ័ពខ្មែរក្រហមទើសចិត្ត កងទ័ពនោះនឹងអាចបាញ់សម្លាប់យើងចោល។ ខ្ញុំភិតភ័យណាស់។ កូនប្រុសរបស់ខ្ញុំ ក្តៅខ្លួន និងផ្តាសាយទៀត។ ខ្ញុំគិតក្នុងចិត្តថាប្រសិនបើខ្ញុំនិងកូនឆ្លងទន្លេផុតចាត់ទុកថាជាសំណាងធំណាស់សម្រាប់ខ្ញុំ។

ព្រលឹមស្រាងៗ កងទ័ពខ្មែរក្រហម បានដើរមកប្រកូកប្រកាសឲ្យប្រជាជនជម្លៀសទាំងអស់ត្រៀមខ្លួនឆ្លងទន្លេ។ ប្រជាជនជម្លៀសគ្រប់ៗគ្នាបានប្រញាប់ប្រញាល់រៀបចំបង្វេចដែលមានរបស់របរបន្តិចបន្តួចរបស់ខ្លួនយកទៅតាម។ ដៃម្ខាងរបស់ខ្ញុំបានដឹកដៃកូនប្រុស ហើយដៃម្ខាងទៀតពកូនស្រីតូច និងទូលបង្វេច។ ពេលនោះ ខ្ញុំឈឺពោះណាស់ ហើយមិនដឹងថើរណាបានខ្ញុំអាចឆ្លងសាឡាងផុតទេ។ កូនរបស់ខ្ញុំបានហុចកញ្ចប់បាយឲ្យមកខ្ញុំ ប៉ុន្តែខ្ញុំមិនឃ្លានសោះ។ កងទ័ពខ្មែរក្រហម បានកាន់កាំភ្លើងច្រូងច្រាងគ្រប់ដៃ ហើយបានឈរបង្គាប់បញ្ជាអ្នកជម្លៀសជាង ២០០នាក់ ដើរចុះក្នុងសាឡាង។ ខ្ញុំនិងកូន ដើរច្រឹមច្រុមស្ទើរទប់ខ្លួនមិននឹង។ ខ្ញុំឈានជើងមួយៗតាមក្រោយដំណើររបស់ប្រជាជនជម្លៀសដទៃទៀត។ សន្តិសុខប្រចាំសាឡាងឃើញដូច្នេះបានមកជួយខ្ញុំយួរបង្វេច និងដឹកដៃកូនរបស់ខ្ញុំទៅឈរនៅកន្ទុយសាឡាងឲ្យបានស្រួល។

នៅពេលសាឡាង បើកបរចេញ ខ្ញុំស្រាប់តែឈឺពោះកាន់តែខ្លាំងទ្រាំលែងបានភ្លាមៗ។ ខ្ញុំខំប្រឹងខាំមាត់សង្កត់ចិត្តអត់ធ្មត់មិនហ៊ានស្រែកទេ រួចយកដៃរឹតពោះដែលកំពុងតែចុកចាប់។ កូនទាំងពីរនាក់របស់ខ្ញុំរបូតដៃចេញពីខ្ញុំ ហើយស្រែកទ្រហោយំ។ កូនប្រុសរបស់ខ្ញុំ រត់ឆ្លេឆ្លាដោយភាពភ័យតក់ស្លុត ហើយស្រែកហៅខ្ញុំយ៉ាងខ្លាំងៗ។ កូនប្រុសរបស់ខ្ញុំបានស្រែកប្រាប់ប្រជាជនផ្សេងទៀតដើម្បីសុំជំនួយថា «ជួយម៉ែរបស់ខ្ញុំផង»។

ចំណែកឯកូនស្រីរបស់ខ្ញុំវិញ នៅអង្គុយជិតខ្ញុំ ហើយត្រូវកងទ័ពខ្មែរក្រហមចំនួន ៤នាក់ស្ទុះមកទះកំផ្លៀងមួយដៃបណ្តាលឲ្យដួលផ្ទប់ទៅនឹងដៃកបង្កាន់ដៃសាឡាង។ កូនរបស់ខ្ញុំយំកាន់តែខ្លាំងឡើងៗ។ កងទ័ពម្នាក់លើកកូនខ្ញុំបីមួយសន្ទុះ ប៉ុន្តែកូនរបស់ខ្ញុំនៅតែបន្តយំស្ទើរតែគាំងម្តងៗ។ សន្តិសុខសាឡាង បានសុំយកកូនរបស់ខ្ញុំមកលួងលោមឲ្យបាត់យំវិញ ប៉ុន្តែកងទ័ពខ្មែរក្រហមទាំងនោះមិនយល់ព្រមទេ ថែមទាំងបោះកូនរបស់ខ្ញុំពីដៃកងទ័ពម្នាក់ទៅដៃកងទ័ពម្នាក់ទៀតឡើងវិលជុំចុះឡើងៗ ៣ដង រួចស្រែករាប់ពីមួយដល់បី ហើយបោះឡើងលើកម្ពស់ប្រហែលជាពីរម៉ែត្រ បន្ទាប់មក កងទ័ព ៤នាក់ បានយកចំពុះទុងកាំភ្លើងជាក់ទ្រូងពីក្រោម។ ពេលនោះ កូនរបស់ខ្ញុំធ្លាក់ចុះមកត្រូវចំទ្រូងហូរឈាមស្លាប់មួយរំពេច។ កងទ័ពខ្មែរក្រហម បានបោះកូនរបស់ខ្ញុំចូលទៅក្នុងទឹកតែម្តង។ ខណៈនោះ សមមិត្ត វីរៈ ដែលជាប្រធានសន្តិសុខ បានប្រាប់ឲ្យជួយសង្គ្រោះជីវិតរបស់ខ្ញុំ ដែលកំពុងតែដេកស្តូកស្តឹង។

នៅពេលដែលសាឡាងចូលទៅចតនៅកំពង់ចម្លងអ្នកលឿងត្រើយខាងកើត ភ្លាម វីរៈ បានប្រញាប់រត់ចុះមកលើកខ្ញុំឡើង។ ឈាមខ្ញុំហូរប្រឡាក់ដោកសំពត់។ វីរៈ បានចាប់លើកខ្ញុំបីត្រកងឡើង ហើយស្រែកស្ទើរតែភ្លាត់សំឡេងថា «ឱពុទ្ធោអើយ! ប្អូនស្រីឆ្លងទន្លេ! ឈាមច្រើនណាស់! នាងសម្រាលបានកូនប្រុសមួយ»។ បន្ទាប់មក វីរៈ បានឲ្យសន្តិសុខម្នាក់ទៀតលើកបីទារកឡើងទៅមាត់ច្រាំងទន្លេត្រើយខាងកើត។ នៅពេលដែលខ្ញុំមានកម្លាំងបន្តិច ខ្ញុំបានស្រែកហៅកូនប្រុសនិងកូនស្រីរបស់ខ្ញុំ។ ខ្ញុំបានព្យាយាមក្រោកឈរទាំងត្រដាបត្រដួស និងលើកដៃទាំងពីររបស់ខ្ញុំ រង់ចាំទទួលយកកូនប្រុសរបស់ខ្ញុំពីសន្តិសុខដែលកំពុងតែហុចមកឲ្យខ្ញុំ។ ភ្លាមៗនោះ ខ្ញុំស្រាប់តែឮស្នូរកាំភ្លើងផ្ទុះ ផាំង! ផាំង! ពីរគ្រាប់ផ្ទួនៗគ្នាត្រូវចំខ្នងសន្តិសុខ ដែលកំពុងបីកូនពៅរបស់ខ្ញុំបណ្តាលឲ្យគាត់ដួលច្រងាង។ ចំណែកទារកដែលខ្ញុំមិនទាន់បានឃើញមុខ និងពុំទាន់បានបំបៅដោះផង ក៏របូតជ្រុះពីដៃសន្តិសុខរមៀលតាមផ្លូវធ្លាក់ចូលក្នុងទឹកទន្លេបាត់។ ខ្ញុំ ជាម្តាយមិនទាន់បានដាក់ដៃចុះទេ ហើយឈរស្រឡាំងកាំងភាំងស្មារតីដួលអុកគូទនឹងដីបានត្រឹមតែ

ទ្រហោយំ។ តើឲ្យខ្ញុំរស់មានន័យអ្វីទៀត? ខ្ញុំមិនចង់រស់នៅទៀតទេ។ ពេលនេះ កងទ័ពខ្មែរក្រហមបានសម្លាប់ប្តីរបស់ខ្ញុំ និងសម្លាប់កូនជាទីស្រលាញ់ទាំង៣នាក់របស់ខ្ញុំទៀត ហើយថ្ងៃណាមួយខ្មែរក្រហមនឹងសម្លាប់ខ្ញុំ និងប្រជាជនខ្មែរជាច្រើននាក់ទៀតជាមិនខានឡើយ។ វីរៈ បានជួយចាប់លើកខ្ញុំបណ្តើរឡើងទៅលើមាត់ច្រាំងទន្លេអ្នកលឿងត្រើយខាងកើត ហើយគាត់បាននិយាយលួងលោមខ្ញុំកុំឲ្យអស់សង្ឃឹមនិងត្រូវពង្រឹងស្មារតីឡើង ដើម្បីរួមកម្លាំងគ្នាវាយកម្ទេចរបបខ្មែរក្រហមដ៏សែនកំណាចនេះឲ្យបរាជ័យវិញ។

ខ្ញុំបាននិពន្ធបទចម្រៀងមួយបទចំណងជើងថា «វាសនានាងខេមរា» ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធស្វាមី និងកូនទាំងបីនាក់របស់ខ្ញុំ ព្រមទាំងឪពុកម្តាយបងប្អូនទាំង ៧នាក់ និងជនរួមជាតិខ្មែរ ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។

«វាសនានាងខេមរា»

ពពកពាលខ្មៅកាចសាហាវណាស់ ថ្ងៃម្តែមេសាចិតសិបប្រាំចាំជាក់ច្បាស់
ពួកអាពតពាលខ្មៅកាចសាហាវណាស់ ដេញខ្មែរពីផ្ទះឲ្យជួបចំបែង។
ជម្លៀសពលរដ្ឋពីក្រុងភ្នំពេញ កើតទុក្ខទោម្នេញកណ្តោចកណ្តែង
អនិច្ចារូបខ្ញុំសល់តែម្នាក់ឯង ទុក្ខទោសហួសថ្លែងទៅទន្លេធំ។
អង្គការកំណាចសម្លាប់ស្វាមី កូនខ្ញុំទាំងបីគ្រាន់តែទួញយំ
ចាប់បោះចាប់បាញ់ចាប់បោកវាយដំ កូនគេកូនខ្ញុំស្លាប់ពាយរង្គាល។
ស្លាប់គ្មានកំហុសស្លាប់ព្រោះស្មោះត្រង់ ជាតិខ្មែរបាត់បង់ក្តៅផ្សារោលរាល
សូមទេពាជួយកម្ចាត់ជនពាល ជួយខ្មែរឆ្លងវាលពិឃាតព្រៃផ្សៃ។

ចប់

៥៤
រឿង រួចពីចំណង

អ្នកនិពន្ធ ៖ ឥណ្ឌា សារ៉ែត

៥៤ ~ រឿង រួចពីចំណង

ខ្ញុំឈ្មោះ តាក់ សុត កើតនៅក្នុងឆ្នាំ១៩៥៧ មានស្រុកកំណើតនៅភូមិប្រហ៊ូត ឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង។ ឪពុករបស់ខ្ញុំឈ្មោះ ស្រី ហ៊ុន និងម្តាយរបស់ខ្ញុំឈ្មោះ គង់ ប៉ាន។ ឪពុកម្តាយរបស់ខ្ញុំ គឺជាកសិករ។ ខ្ញុំគឺជាកូនប្អូនបង្អស់ក្នុងចំណោមបងប្អូនចំនួន ៦នាក់ មានប្រុស ៥នាក់ និងស្រី ១នាក់។ ចាប់តាំងពីរបបសង្គមរាស្ត្រនិយមមក ក្រុមគ្រួសាររបស់ខ្ញុំរស់នៅក្នុងកម្រិតជីវភាពមធ្យម។ ខ្ញុំ បានចូលរៀនដល់ថ្នាក់ទី១០ នៅសាលាបឋមសិក្សាវត្តប្រហ៊ូត។

នៅក្នុងឆ្នាំ១៩៧០ ខ្ញុំបានឈប់រៀន។ សាលាបានបិទទ្វារ ព្រោះស្ថានភាពប្រទេសជាតិច្របូកច្របល់។ បន្ទាប់ពី សម្តេច នរោត្តម សីហនុ ត្រូវ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ចេញពីអំណាច ប្រជាជនក្នុងស្រុកមេសាង បាននាំគ្នាធ្វើបាតុកម្មបះបោរយ៉ាងធំមួយ។ គោលបំណងរបស់ក្រុមបាតុករ គឺទាមទារឲ្យសម្តេច នរោត្តម សីហនុ យាងមកដឹកនាំប្រទេសជាតិវិញ។ ប្រជាជនក្នុងភូមិប្រហ៊ូត បាននាំគ្នាចូលរួមចលនាបាតុកម្មនេះ ដោយអាជ្ញាធរតម្រូវឲ្យសមាជិកក្នុងក្រុមគ្រួសារយ៉ាងហោចណាស់មានម្នាក់ចូលរួម។ ពេលនោះមានការប្រកាសឲ្យប្រជាជនចូលរួមធ្វើបាតុកម្ម និងតម្រូវឲ្យប្រជាជនស្រែកថា «ជយោ សម្តេចឪ អ្នកណាមិនទៅសម្លាប់ចោល»។ ដូច្នេះ ប្រសិនបើប្រជាជនណាមិនចង់ទៅ ក៏ត្រូវតែទៅចូលរួមធ្វើបាតុកម្មដែរ។ ខ្ញុំមានវ័យជំទង់ ហើយបានចូលរួមដង្ហែបាតុកម្មជាមួយនឹងប្រជាជនដទៃទៀតដែរ។ ក្បួនបាតុកម្មដង្ហែចេញពីភូមិប្រហ៊ូត ទៅជួបជុំគ្នានៅផ្សារមេសាង ឬហៅថា ថ្នល់កែងមេសា(សព្វថ្ងៃនេះស្ថិតនៅខាងត្បូងបឹងមេសាង)។

ចាប់តាំងពីឆ្នាំ១៩៧១ ការរស់នៅរបស់អ្នកភូមិនៅក្នុងមូលដ្ឋានមានការចែងចែកវណ្ណៈជាបួន គឺវណ្ណៈកសិករក្រ, វណ្ណៈកសិករកណ្តាលក្រោម, វណ្ណៈអនុជន និងវណ្ណៈសក្តិភូមិ។ គ្រួសាររបស់ខ្ញុំ ត្រូវបានអង្គការចាត់ទុកក្នុងថ្នាក់វណ្ណៈកសិករកណ្តាលក្រោម សំដៅលើកសិករដែលមានជីវភាពមធ្យម មានផ្ទះក្បឿងមួយខ្នង ឬពីរខ្នង មានចិញ្ចឹមសត្វគោក្របី ស្រូវ អង្ករ ការហូបចុកគ្រប់គ្រាន់ មានកង់ជិះ និងមានវិទ្យុស្តាប់ជាដើម។ ចាប់តាំងពីពេលនោះមក រដ្ឋអំណាច បានតម្រូវឲ្យប្រជាជនទៅធ្វើស្រែសាមគ្គី។ រដ្ឋអំណាច បានចែកជាក្រុមទៅតាមវណ្ណៈផ្សេងៗគ្នា គឺវណ្ណៈកសិករក្រ ត្រូវប្រវាស់ដៃជាមួយកសិករក្រ។ បន្ទាប់ពីប្រមូលផលរួច យើងបែងចែកទៅផ្ទះរៀងខ្លួនតាមកម្លាំងពលកម្មដែលយើងធ្វើបាន។ យើងនៅតែរស់ដោយភាពភ័យខ្លាច ព្រោះនៅក្នុងភូមិតែងតែបាញ់ផ្លោងនិងទម្លាក់គ្រាប់បែកជារឿយៗមកលើភូមិដ្ឋានអ្នកស្រុក។ សំណាងល្អដែរ ភូមិដែលខ្ញុំរស់នៅមានប្រព័ន្ធធារាសាស្ត្រព័ទ្ធជុំវិញ រួមមាន ព្រែកទំនប់និងប្រឡាយ ហើយផ្លូវនៅក្នុងភូមិមិនស្រួលធ្វើដំណើរទេ ធ្វើឲ្យទាហាន នល់ លន់ ពិបាកបើករថក្រោះចូលណាស់។ នេះជាសំណាងរបស់អ្នកភូមិរបស់ខ្ញុំដែរ។ ក្រុមគ្រួសារនីមួយៗ សុទ្ធសឹងតែបានជីកលេណដ្ឋានសម្រាប់រត់ពួនការពារខ្លួនពីការបាញ់ផ្លោងឬទម្លាក់គ្រាប់បែក។

នៅក្នុងឆ្នាំ១៩៧៣ មានការទម្លាក់គ្រាប់បែកយ៉ាងច្រើន។ ការទម្លាក់គ្រាប់បែកទាំងអស់នោះ ធ្វើឲ្យអ្នកភូមិរងរបួស និងស្លាប់អស់ជាច្រើននាក់។ នៅពេលនោះ មានការប្រយុទ្ធគ្នានៅសមរភូមិប្រហិត រវាងកងទ័ពវៀតកុង និងពួកធៀវគី។ ទ័ពវៀតកុង ជាអ្នកជួយខាងខ្មែរក្រហម និង កងទ័ពធៀវគី ជួយខាងទាហាន នល់ នល់។ កងទ័ពវៀតកុង តែងតែលាក់ខ្លួននៅព្រៃខាងត្បូងវត្តប្រហិត ចំណែកកងទ័ពធៀវគីវិញ តែងលាក់ខ្លួននៅត្រើយម្ខាងនៃព្រែកវត្តប្រហិត ដែលស្ថិតក្នុងភូមិពន្លៃ ឃុំអង្គរសេ។ ក្រោយពីមានការប្រយុទ្ធគ្នាទៅវិញទៅមកអស់រយៈពេលមួយព្រឹក កងទ័ពទាំងសងខាងបានស្លាប់បាត់បង់ជីវិតអស់ជាច្រើននាក់។ ចុងក្រោយ កងទ័ពធីវគី បានដកថយ ថែមទាំបានកៀរអ្នកភូមិពន្លៃឲ្យជួយលើកស្បៀង និងលីអីវ៉ាន់។ ប្រជាជននៅក្នុងភូមិ បានជួយដឹកជញ្ជូនស្បៀងកងទ័ពធីវគីរហូតជិតដល់ខេត្តស្វាយរៀង ទើបកងទ័ពធីវគី ដោះលែងប្រជាជនឲ្យត្រលប់មកផ្ទះវិញ។ ការ

ទម្លាក់គ្រាប់បែក និងការបាញ់ផ្លោងពីទាហាន លន់ នល់ មកពីសមរភូមិក្រោលគោ បានធ្វើឲ្យប្រជាជនក្នុងភូមិប្រហិតរងរបួសនិងស្លាប់អស់មួយចំនួន។ គ្រួសារមួយស្លាប់សមាជិកគ្រួសារអស់ ៤នាក់ ដោយសារការផ្លោងគ្រាប់ចំលេណដ្ឋានរបស់គាត់។ នៅពេលនោះ ស្ថានភាពក្នុងភូមិរបស់ខ្ញុំស្ថិតនៅក្នុងភាពវឹកវរខ្លាំងណាស់។ ខ្ញុំឃើញមានយន្តហោះជាច្រើនគ្រឿងហោះចុះហោះឡើងហាក់ដូចជាចង់មើលស្ថានការណ៍នៅក្នុងភូមិឬចង់ទម្លាក់គ្រាប់បែកបន្ថែមទៀត។ រាល់ពេល ឃើញយន្តហោះម្តងៗ ប្រជាជនក្នុងភូមិបាននាំគ្នាយកគោ ក្របី និង សម្ភារចាំបាច់រត់ទៅភូមិត្រពាំងស្រែដើម្បីគេចខ្លួន។ បន្ទាប់ពីយន្តហោះត្រលប់ទៅវិញ ទើបប្រជាជនក្នុងភូមិ នាំគ្នាត្រលប់មកផ្ទះរៀងៗ ខ្លួនវិញ។ ប្រជាជនជាច្រើន បានស្ម័គ្រចិត្តធ្វើទ័ពព្រៃនៅពេលដែលមានការប្រកាសជ្រើសរើសកងទ័ពដើម្បីផ្តួលរំលំរបប លន់ នល់ តាមការឃោសនារបស់សម្តេចតា។

នៅក្នុងខែមីនា ឆ្នាំ១៩៧៤ ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើជាកងទ័ពខ្មែរក្រហមជាមួយយុវជនផ្សេងទៀតនៅក្នុងភូមិ។ ខ្ញុំធ្វើជាកងទ័ពប្រចាំស្រុកមេសាង។ នៅពេលនោះ ខ្ញុំបានប្រយុទ្ធជាមួយនឹងទាហាន លន់ នល់ ថែមទាំងវាយដណ្តើមបានទីរួមខេត្តព្រៃវែង វិញដែរ។ ទោះបីជាខ្ញុំស្ថិតនៅក្នុងស្ថានភាពលំបាក និងប្រឈមជាមួយគ្រាប់របស់ខ្មាំងយ៉ាងណា ក៏ខ្ញុំមិនដែលរុញរាដែរ។ កងទ័ពទាំងអស់ហូបអាហារក្រៀមរាល់ថ្ងៃ ហើយយើងទទួលបានអាហារម្តង ៣ពេល។ សមរភូមិរបស់ខ្ញុំ មានការប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ។ កងទ័ពខ្មែរក្រហមជាច្រើននាក់បានបាត់បង់ជីវិត ដោយការទម្លាក់គ្រាប់បែក និង គ្រាប់ផ្លោង ចូលមកក្នុងបន្ទាយ។

បន្ទាប់ពីកងទ័ពខ្មែរក្រហមវាយដណ្តើមបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីរួមខេត្តព្រៃវែង ត្រូវដណ្តើមបាននៅពេលនោះដែរ។ បន្ទាប់ពីទទួលបានជ័យជម្នះ ខ្ញុំបានត្រលប់មកសមរភូមិក្រោយវិញ។ ប្រជាជនជាច្រើននាក់នៅរង់ចាំអបអរសាទរជ័យជម្នះរបស់យើង។ ប្រជាជនខ្លះច្រៀងផងរាំផងវាយស្គរផង ព្រោះគិតថាប្រទេសជាតិលែងមានសង្គ្រាមទៀត។ ក្រោយមកឧបករណ៍ភ្លេងបុរាណដូចជាស្គរ ជាដើម ត្រូវបានកម្ទេចចោល ថែមទាំងមានការធ្សឹកព្រះសង្ឃដោយបង្ខំដែរ។

ក្តីសង្ឃឹម និងភាពសប្បាយរីករាយ ការតស៊ូលះបង់ ធ្វើឲ្យខ្ញុំអស់សង្ឃឹមជាពន់ពេក។ នៅក្នុងខែមីនា ឆ្នាំ១៩៧៦ សម្តេចតា បានប្រកាសអំពីការសុំយាងចូលនិវត្តន៍ និងលាលែងជាតំណែងព្រះប្រមុខរដ្ឋ។ ក្រោយមក ខ្ញុំមិនបានឮទ្រង់ធ្វើសេចក្តីថ្លែងការណ៍អ្វីទៀតឡើយ។ ក្រុមខ្មែរក្រហម បានបណ្តុះគំនិតប្រជាជនឲ្យស្អប់របបរាជានិយម។ ខ្មែរក្រហម បានឲ្យប្រជាជនយកទ្រព្យសម្បត្តិជាក់ជារបស់រួម និងការហូបចុកក្នុងរោងបាយរួម។ យើងហូបមិនឆ្អែតនោះទេទោះបីជាយើងធ្លាប់តស៊ូលះបង់ជីវិតយកជ័យជម្នះឲ្យខ្មែរក្រហមក៏ដោយ។ យើងមានតែបបរជាមួយសម្លម្ហូរត្រកួនបង់ប្រហុក និងបន្លែទេ។ សូម្បីតែស្ករសម្ហូរ និងអំបិលមិនមានបង់ចូលក្នុងសម្លផង។ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅធ្វើការងារក្នុងកងចល័ត ដោយឲ្យខ្ញុំលើកភ្លឺស្រែ នៅឃុំស្មោងខាងជើង ស្រុកកំចាយមារ។ រហូតមកដល់ចុងឆ្នាំ១៩៧៦ ខ្មែរក្រហម បានបញ្ជូនខ្ញុំឲ្យត្រលប់មកវិញ។ នៅពេលដែលខ្ញុំមកដល់ភូមិវិញ ប្រធានភូមិ បានចាត់តាំងឲ្យខ្ញុំធ្វើការងារនៅក្នុងរោងម៉ាស៊ីនកិនស្រូវក្នុងភូមិព្រៃគុយ ឃុំតាំងស្រែ។ រោងម៉ាស៊ីនកិនស្រូវនោះ ជារបស់អាចារ្យតុង ដែលត្រូវខ្មែរក្រហម យកមកធ្វើជាទ្រព្យសម្បត្តិរួម កិនអង្ករផ្តត់ផ្តង់នៅទូទាំងឃុំតាំងស្រែ។ នៅទីនោះ ខ្ញុំជាអ្នកកាន់ម៉ាស៊ីនកិនស្រូវ ហើយឈ្មោះ ជាវ គឺជាអ្នកជួសជុលម៉ាស៊ីន និងវ៉ៃម៉ាស៊ីន។ ការងារទាំងនោះ មិនងាយស្រួលទេ ទោះបីជាកិនដោយប្រើម៉ាស៊ីនក៏ដោយ។ នៅក្នុងមួយថ្ងៃ ខ្ញុំត្រូវកិនស្រូវទាំងអស់ដែលមាននៅក្នុងភូមិចំនួនប្រហែល ១០០ថាំង។ ខ្ញុំត្រូវរៀបចំខ្លួនឲ្យរួចរាល់ និងចាប់ផ្តើមធ្វើការនៅម៉ោង ៧ព្រឹក រហូតដល់ម៉ោង ៥ល្ងាច។ ពេលខ្លះ ខ្ញុំធ្វើមិនទាន់ឲ្យបានរួចរាល់តាមការកំណត់របស់អង្គការ ខ្ញុំត្រូវតែបន្តខំកិនឲ្យហើយរហូតដល់ម៉ោង៨យប់ ទើបអាចសម្រាកបាន។ ខ្ញុំបានធ្វើការងារជាអ្នកកិនអង្ករហូតដល់ដើមឆ្នាំ១៩៧៨។

នៅខែឧសភា ឆ្នាំ១៩៧៨ ខ្មែរក្រហម ចាប់ផ្តើមអនុវត្តគោលនយោបាយវិសុទ្ធកម្ម។ ប្រជាជនទាំងអស់ត្រូវតែសុទ្ធមិនមែនជាពួកខ្មាំងឬពួកក្បាលយួនខ្លួនខ្មែរនោះទេ។ ប្រជាជនភូមិភាគបូព៌ា គឺជាគោលដៅនិងមុខសញ្ញាក្នុងការធ្វើវិសុទ្ធកម្ម។ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំ រស់នៅមិនបានសុខសាន្តនោះទេ។

ក្រៅពីធ្វើការងារលំបាក និងហូបមិនឆ្អែត នៅក្នុងឆ្នាំ១៩៧៨ ក៏មានការប៉ះទង្គិចគ្នារវាងកងទ័ពវៀតណាមនិងកងទ័ពខ្មែរក្រហមដែរ។ តំបន់មួយចំនួននៃភូមិភាគបូព៌ា បានក្លាយទៅជាសមរភូមិ ដែលធ្វើឲ្យប្រជាជនមានភាពភ័យខ្លាចយ៉ាងខ្លាំង។ រវាងជនជាតិខ្មែរនិងជនជាតិខ្មែរគ្នាឯង បានចោទប្រកាន់និងលាបពណ៌គ្នាទៅវិញទៅមក។ ប្រជាជនជាច្រើន ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយអយុត្តិធម៌។ ខ្ញុំពិតជាមានការភ័យខ្លាចខ្លាំងណាស់ចំពោះការកាប់សម្លាប់នេះ។ ខ្ញុំនិងប្រជាជនមួយចំនួន បានលួចរត់ទៅវត្តជីផុច សុំឲ្យអង្គការនៅទីនោះជួយនិងស្នាក់នៅបណ្តោះអាសន្ន ព្រោះកម្មាភិបាលខ្មែរក្រហមនៅទីនោះមានចិត្តសន្តោសប្រណីជាងកម្មាភិបាលខ្មែរក្រហម គ្រប់គ្រងនៅក្នុងភូមិរបស់ខ្ញុំ។

រសៀលថ្ងៃមួយនៅក្នុងវត្តជីផុច ខ្ញុំបានជួបប្រទះនឹងព្រឹត្តិការណ៍រន្ធត់ចិត្តយ៉ាងខ្លាំង។ ខ្ញុំបានឃើញរថក្រោះចំនួន ៣គ្រឿង បានបើកមកពីទិសខាងលិច និងមានកងទ័ពចំនួន ៣ឡាន ដែលមានមនុស្សប្រមាណ ៤០នាក់។ ក្រុមកងទ័ពទាំងនោះមានដៃកាន់អាវុធគ្រប់ៗដៃ។ បន្តិចក្រោយមក ឡានបានឈប់ទម្លាក់កងទ័ពចុះនៅក្នុងបរិវេណវត្តជីផុច ដោយមិនដឹងថាមានបំណងធ្វើអ្វីនោះទេ។ កម្មាភិបាលខ្មែរក្រហមដែលគ្រប់គ្រងនៅវត្តជីផុត បាននាំគ្នារត់បាត់អស់នៅសេសសល់តែប្រជាជនទេ។ នៅពេលយប់ កងទ័ពខ្មែរក្រហម បានបញ្ជាឲ្យអ្នកភូមិស្រីប្រុសចំនួន ១០០នាក់ នៅក្នុងវត្តចូលទៅដេកនៅក្នុងព្រះវិហារ។ ក្រោយមកប្រហែលជាម៉ោង ១២ រំលងអធ្រាត្រ កងទ័ពខ្មែរក្រហម បានហៅអ្នកភូមិចំនួន ១០នាក់ចេញមកក្រៅជាបន្តបន្ទាប់។ ខ្ញុំគឺជាមនុស្សម្នាក់នៅក្នុងចំណោមប្រជាជន ១០នាក់ ដែលខ្មែរក្រហមបានបណ្តើរចេញពីព្រះវិហារសំដៅទៅកាន់ក្លោងទ្វារខាងជើងវត្ត។ ខ្ញុំឃើញមានកងទ័ពខ្មែរក្រហម ១០នាក់ ចាំយាមនៅទីនោះ។ កងទ័ពទាំងអស់នោះបានទាញកាំភ្លើងក្លង់យើងឲ្យនៅស្ងៀម រួចទាញខ្សែធាងគ្នោតមកចងយើងប្រតែងប្រតោងជាប់គ្នា។ នៅពេលដែលកងទ័ពបានចងមកដល់ខ្ញុំ ស្រាប់តែអស់ខ្សែធាងគ្នោត។ កងទ័ពខ្មែរក្រហម បានយកក្រមាមកទាក់ជាមួយស្មារបស់ខ្ញុំទាំងសងខាង និងទាញដៃរបស់ខ្ញុំមកខាងក្រោយ។ យើងត្រូវកងទ័ពខ្មែរក្រហម

បណ្តើរចេញទៅ។ ដៃយើងជាប់ចំណង ថែមទាំងមានកងទ័ពខ្មែរក្រហមដើរតាមពីខាងមុខផងនិងខាងក្រោយផង នាំយើងសំដៅទៅទួលព្រៃខាងជើងវត្តជីផុច ដែលមានដើមឈើតូចធំដុះត្រៀបត្រា មានទាំងចម្ការដំឡូង និង ចម្ការត្រសក់នៅក្បែរៗនោះ។ ក្រមាដែលកងទ័ពខ្មែរក្រហម ចងខ្ញុំមិនជាប់ខ្លាំងនោះទេ ដូច្នេះហើយ ខ្ញុំដើរបណ្តើរ ខ្ញុំព្យាយាមស្រាយក្រមាបណ្តើរទៅតាមអ្វីដែលខ្ញុំអាចធ្វើទៅបាន។ នៅពេលដែលយើងដើរជិតដល់ក្បែរទួល កងទ័ពខ្មែរក្រហម បាននាំមនុស្សពីរនាក់យកទៅមុនដោយនិយាយថា «នាំអាពីរនាក់នេះទៅជួបអង្គការមុនទៅ» ដោយទុកកងទ័ពខ្មែរក្រហមចំនួន ៥នាក់ចាំយាមប្រជាជនដែលនៅសេសសល់។ នៅចម្ងាយប្រហែលជា ៦០ម៉ែត្រ ខ្ញុំបានឮសំឡេងដូចជាវាយក្បាលគោនឹងត្បូងចបឬខ្នងពូថៅ។ ខ្ញុំគិតដឹងច្បាស់ក្នុងចិត្តថា មនុស្សពីរនាក់ដែលកងទ័ពខ្មែរក្រហមនាំទៅនោះប្រាកដជាយកទៅសម្លាប់ហើយ។ ខ្ញុំក្រោកឈរបន្តិចសម្លឹងរកផ្លូវរត់។ កងទ័ពខ្មែរក្រហម បានស្រែកហាមខ្ញុំមិនឲ្យក្រោកឈរនោះទេ។ ខ្ញុំមានអារម្មណ៍ថា ចំណងខ្សែនៅនឹងដៃរបស់ខ្ញុំជិតរបូត ហើយខ្ញុំស្រាប់តែមានគំនិតចង់រត់គេចខ្លួនភ្លាមៗ។ ទោះបីជាខ្ញុំគ្មានសង្ឃឹមថានឹងអាចរត់គេចផុតពីខ្មែរក្រហមក៏ដោយ ក៏ខ្ញុំមិនចង់ស្លាប់ដោយការវាយនឹងត្បូងចបបែបនេះដែរ។ ប្រសិនបើខ្ញុំរត់ ខ្ញុំអាចត្រូវកងទ័ពខ្មែរក្រហមបាញ់ដោយគ្រាប់កាំភ្លើង ដែលអាចឆាប់ស្លាប់ស្រួលជាងវាយនឹងត្បូងចប។ បន្ទាប់ពីខ្ញុំគិតរួចហើយ ជើងរបស់ខ្ញុំ បានឡើងរត់យ៉ាងត្របាញ់។ កងទ័ពខ្មែរក្រហមបានបាញ់ខ្ញុំ។ គ្រាប់កាំភ្លើងបាញ់កៀកៗនឹងជើងរបស់ខ្ញុំ ប៉ុន្តែមិនត្រូវខ្ញុំទេ។ កងទ័ពខ្មែរក្រហមទាំងអស់នោះមិនបានតាមមករកខ្ញុំភ្លាមៗនោះទេ ព្រោះខ្លាចប្រជាជនផ្សេងទៀតមានឱកាសរត់ដែរ។ ខ្ញុំបានរត់ទៅតាមផ្លូវដែលកងទ័ពខ្មែរក្រហមទាំងអស់នោះបានបណ្តើរខ្ញុំមក។ នៅពេលដែលខ្ញុំរត់ទៅដល់ខាងជើងភ្លោងទ្វារវត្តជីផុច មានមនុស្សម្នាជាច្រើននៅទីនោះផ្អើលនឹងសំឡេងកាំភ្លើងដែលកងទ័ពខ្មែរក្រហមបានបាញ់ខ្ញុំ។ កងទ័ពខ្មែរក្រហមផ្សេងទៀត បានឃើញខ្ញុំ ហើយស្រែកគំរាមឲ្យខ្ញុំឈប់ ប៉ុន្តែខ្ញុំនៅតែព្យាយាមរត់គេចចេញ។ ពេលនោះ ខ្ញុំបានឮកងទ័ពខ្មែរក្រហមម្នាក់ស្រែកឲ្យ

បាញ់សម្លាប់ខ្ញុំបន្ទាប់ពីខ្ញុំរត់បានចម្ងាយ ១០ម៉ែត្រចេញពីទីនោះ។ សំណាងល្អ ខ្ញុំអាចគេចផុតពីគ្រាប់កាំភ្លើងដោយសុវត្ថិភាព។ នៅពេលដែលខ្ញុំរត់បានចម្ងាយប្រហែលជា ២០០ម៉ែត្រ ខ្ញុំបានឈប់កាច់បង្គោលឈើមួយទំហំប៉ុនកដៃទុកការពារខ្លួន។ ម៉ោងប្រហែលជា ២លែងអង្រាត្រ ខ្ញុំបានធ្វើដំណើរដល់ផ្លូវបំបែកទៅភូមិព្រៃត្រខុប និងថ្មស ហើយខ្ញុំបានជួបអ្នកយាមដែលមានគ្នីគ្នាប្រហែលជា ៣០នាក់។ មុនខ្ញុំដើរសំដៅរកអ្នកយាម ខ្ញុំបានស្រាយក្រមាពីដៃមករុំបង្គោលឈើធ្វើដូចជារុំកាំភ្លើងមកឱបនឹងខ្លួនរួចដើរចូលទៅ។ ខ្ញុំបានស្រែកសួរអ្នកយាមថា «បងប្អូនមានឃើញខ្មាំងរត់មកផ្លូវនេះទេ?»។ អ្នកខ្លះឆ្លើយថា «មិនឃើញ» ហើយអ្នកខ្លះឆ្លើយថា «បើឃើញវិញចិញ្ចាំតែម្តង ពួកអាក្បត់!»។ «អ្នកទាំងអស់គ្នាមានឮសំឡេងកាំភ្លើងដែលខ្ញុំបានបាញ់ទេ? ខ្ញុំដេញជិតទាន់ខ្មាំងទៅហើយ តែវារត់មកក្បែរៗនេះ»។ ដូច្នេះសូមបងប្អូនទាំងអស់គ្នាថយប្រហែលជា ១០០ម៉ែត្រ ចៀសវាងខ្ញុំបាញ់ចំត្រូវបងប្អូន»។ ក្រុមកងទ័ពទាំងនោះ បានថយបន្តិច។ ខ្ញុំខំប្រឹងរត់ពួយសំដៅទៅក្នុងភូមិខ្លាចកងទ័ពខ្មែរក្រហមតាមមកទាន់។ ខ្ញុំ បានរត់កាត់វាលស្រែ និង ឆ្លងព្រៃក កាត់តំបន់រលួស។ ខ្ញុំធ្វើដំណើរហូតដល់ម៉ោង ៤ភ្លឺ ទើបបានខ្ញុំមកដល់ផ្ទះរបស់ខ្ញុំនៅក្នុងភូមិប្រហ៊ូត។ ខ្ញុំមិនហ៊ាននៅផ្ទះទេ។ ខ្ញុំខ្លាចកងទ័ពខ្មែរក្រហមតាមចាប់ ព្រោះខ្មែរក្រហមបានដឹងថា ខ្ញុំគឺជាអ្នកភូមិប្រហ៊ូត។ ខ្ញុំបានរត់ទៅរស់នៅក្នុងព្រៃខាងត្បូងវត្តប្រហ៊ូតជាបណ្តោះអាសន្នសិន។ បងប្អូន និងម៉ែរបស់ខ្ញុំ បានផ្លាស់ប្តូរវេនគ្នាលួចយកបាយមកឲ្យខ្ញុំហូប។ ក្រោយមកខ្ញុំឮថាអង្គការលែងឲ្យសម្លាប់មនុស្ស ហើយអ្នកដែលមានកាន់អាវុធ ត្រូវប្រមូលយកមកឲ្យអង្គការវិញ។ ពេលនោះហើយដែលខ្ញុំបានត្រលប់ចូលមករស់នៅក្នុងភូមិវិញ។

នៅខែមិថុនា ឆ្នាំ១៩៧៨ ខ្ញុំ ត្រូវអង្គការបង្ខំឲ្យរកគូស្រករ។ នៅទីបំផុត ខ្ញុំបានស្នើឲ្យមេកងតូចទៅសួរចិត្តនារីម្នាក់ឈ្មោះ ឌឹក សាវង្ស រស់នៅភូមិត្បែងក្បែរភូមិរបស់ខ្ញុំ។ អង្គការ បានរៀបការឲ្យយើងរួមជាមួយគូស្រករដទៃទៀតប្រមាណជាង៧០គូ។ ពិធីរៀបការនេះបានរៀបចំឡើងនៅវត្តក្រាំងចេតិយ ដែលស្ថិតនៅភូមិត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង។ បន្ទាប់ពីខ្ញុំរៀបការរួចបានប្រហែលជាកន្លះ

ខែ អង្គការបានបញ្ជូនឲ្យខ្ញុំនិងប្រពន្ធទៅលើកទំនប់ទឹកនៅឯភូមិស្វាយជោរ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ យើងលើកទំនប់នៅទីនោះបានប្រហែលជាកន្លះខែប៉ុណ្ណោះ។ ក្រោយមក អង្គការបានចាត់ឲ្យយើងនៅយាមទឹកបន្តទៀត ដោយបានចែកតួនាទីឲ្យយើងយាមចន្លោះ ៥ម៉ែត្រ មានអ្នកយាមម្នាក់ក្រែងមានដាច់ឬជ្រាបទឹកត្រង់ណា។ បន្ទាប់ពីទឹកស្រកទៅវិញ ទើបយើងបានត្រលប់មកផ្ទះវិញ។

ក្នុងខែធ្នូ ឆ្នាំ១៩៧៩ ខ្ញុំបានមករស់នៅភូមិកំណើតវិញ។ ខ្ញុំរស់នៅជួបជុំប្រពន្ធនិងគ្រួសារបានមួយ រយៈពេល ទើបអង្គការ បានហៅប្រជាជនទាំងអស់ក្នុងឃុំមកប្រជុំផ្សព្វផ្សាយផែនការ។ អង្គការ បានប្រកាសថា «បងប្អូនយើងមួយចំនួនមានឈ្មោះត្រូវទៅរស់នៅតំបន់កណ្តាល។ នៅទីនោះសម្បូរសប្បាយណាស់ មានសុទ្ធតែមើមត្រាវធំៗ ត្រីក៏សម្បូរ និងបាយស្រូវអង្គរមិនខ្វះទេ»។ ពេលនោះ ខ្ញុំ ប្រពន្ធ ឪពុកម្តាយក្មេក និងបងប្អូនសាច់ញាតិខាងរបស់ប្រពន្ធខ្ញុំ មានឈ្មោះត្រូវបញ្ជូនទៅរស់នៅតំបន់កណ្តាលដែរ។ តំបន់កណ្តាល ស្ថិតនៅខាងលិចក្រុងពោធិ៍សាត់ប្រហែលជា ១០គីឡូម៉ែត្រ។ ទៅដល់តំបន់កណ្តាល ខ្ញុំរស់នៅភូមិអន្លង់សំបួរ ឃុំស្វាយស ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ ដំបូងខ្ញុំជាមួយនឹងប្រពន្ធ និងគ្រួសារ ធ្វើដំណើរដោយថ្មើរជើងដោយមានតែអម្រែកខោអាវទេ។ រយៈពេលបីយប់ ទើបយើងធ្វើដំណើរទៅដល់អ្នកលឿង រួចហើយយើងត្រូវចុះទូកបន្តដំណើរទៅទៀត។ យើងបានដេកក្នុងទូកមួយយប់រហូតដល់ម៉ោង ៧ព្រឹក ទើបទូកចេញដំណើរទៅទៀត ដោយមានផ្ទុកអ្នកដំណើរប្រហែលជា ៥០០នាក់ទៅ ៦០០នាក់។ នៅម៉ោង ១១កន្លះ យើងបានធ្វើដំណើរទៅដល់ច្បារអំពៅ។ ទូកឈប់នៅត្រង់ច្រាំងបាក់ ហើយមានឡានមកចាំទទួលយើង។ អង្គការ បានយកយើងទៅដាក់ឲ្យសម្រាកនៅច្បារអំពៅ។ ពេលល្ងាច អង្គការបានចែកបាយឲ្យយើងហូបរួចអង្គការបានបញ្ចាំងកុនឲ្យយើងមើលអំពីនយោបាយរបស់អង្គការមហាលោតផ្លោះ មហាអស្ចារ្យ ថែមទាំងបានបញ្ចាំងកុនពីការចាប់បានជនជាតិវៀតណាម ដែលខ្មែរក្រហមចាត់ទុកថាជាសត្រូវឈ្លានពានទឹកដី។ យើងមើលកុនរួចហើយ អង្គការបានឲ្យយើងឡើងឡាន រួចដឹកយើងយកទៅដាក់នៅ

ស្ថានីយរថភ្លើងទាំងយប់។ បន្ទាប់ពីសម្រាកក្នុងស្ថានីយរថភ្លើងបានមួយយប់ ម៉ោងប្រហែលជា ៧ព្រឹក ទើបរថភ្លើងចេញដំណើរ ហើយម៉ោងប្រហែលជា ១១កន្លះ រថភ្លើងបានធ្វើដំណើរមកដល់ខេត្តពោធិ៍សាត់។ អ្នកដំណើរទាំងអស់ត្រូវសម្រាកមួយយប់នៅពោធិ៍សាត់។ លុះព្រឹកឡើង មេកងបានមកទទួលយើងទៅតាមក្រុមរៀងៗខ្លួន។ ក្នុងមួយកងៗមានប្រហែលជា ១០០គ្រួសារ ហើយធ្វើដំណើរចេញពីក្រុងពោធិ៍សាត់ ទៅកាន់ភូមិមួយទៀតចម្ងាយប្រហែលជិត១០គីឡូម៉ែត្រដោយថ្មើរជើង។ ពេលនោះជារដូវស្រូវទុំ អង្គការ បានចាត់ឲ្យស្រីៗទៅច្រូតស្រូវ។ ខ្ញុំ ត្រូវមេកងចាត់ឲ្យធ្វើជាអ្នករែកទឹកត្នោតនិងបោកស្រូវ។ យើងរស់នៅខេត្តពោធិ៍សាត់ ជួបការលំបាកខ្លាំងណាស់។ ការហូបចុកពីមួយថ្ងៃទៅមួយថ្ងៃកាន់តែខ្វះខាត។ ចុងភៅ បានវាល់បបរចែកគ្នាដោយពេលព្រឹកទទួលបានបបរមួយពោះចាន និងពេលល្ងាចទទួលបបរមួយចានចង្កឹះ។ អាហារនេះយើងទទួលបានតែក្នុងពេលរដូវច្រូតកាត់តែប៉ុណ្ណោះ។ ប្រសិនបើខុសពីរដូវច្រូតកាត់ អង្គការ ឲ្យយើងហូបអង្ករ១កំប៉ុងសម្រាប់មនុស្សរហូតដល់ ៤០នាក់។ ខ្ញុំនិងប្រពន្ធ មានសំណាងដែរចំពោះការហូបចុក ព្រោះយើងបានស្គាល់អ៊ំស្រីម្នាក់ឈ្មោះ ម៉ុក ជាប្រពន្ធប៉ូលីសស័ក្តិ៣ពីសង្គមចាស់។ ម៉ុក គឺជាប្រជាជន១៧មេសា ហើយប្តីរបស់គាត់ បានស្លាប់ដោយសារអត់អាហារ។ ក្រោយមក ម៉ុក ធ្វើជាអ្នកអោយស្រូវ។ ល្ងាចឡើងនៅពេលស្ងាត់ ម៉ុក តែងច្រកស្រូវក្នុងបាវក្រចៅលាក់នៅពំនូកចំបើង។ គាត់តែងហៅខ្ញុំឲ្យទៅជួយលើយកបាវក្រចៅជាក់ក្នុងរណ្តៅដែលជីករួច។ បន្ទាប់មក យើងបានបុកស្រូវល្មមគ្រប់គ្រាន់តែសម្រាប់ហូបមួយពេលៗ។ យើងចំណាយពេលប្រហែល ១០នាទី ទើបបុកស្រូវបានជាអង្ករហូប។

លុះដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ពេលព្រឹកឡើង ខ្ញុំបានឃើញមានយន្តហោះប្រហែល ៥គ្រឿងហោះមកពីទិសខាងកើតឆ្ពោះទៅទិសខាងលិច។ ខ្ញុំឮសូរសំឡេងឡានិងរថភ្លើងបើកគគ្រឹកគគ្រេងឥតឈប់ឈរៀងរាល់យប់ទល់ភ្លឺ។ ចំណែកទិសខាងកើតវិញ ខ្ញុំឮសូរតែសំឡេងគ្រាប់បែក គ្រាប់កាំភ្លើងធំឥតដាច់សូរសោះ។ ក្នុងចិត្តខ្ញុំអរផងភ័យផង ព្រោះខ្ញុំគិតថាប្រហែលជាអាចមានមនុស្សមកជួយរំដោះ ហើយចិត្តមួយទៀតនឹកខ្លាចថាមានសង្គ្រាមធ្ងន់ធ្ងរកើតឡើង។

រហូតដល់ព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៩ មានមនុស្សម្នាក់ឈ្មោះ សេង ពិសិដ្ឋ ហៅ ស៊ាន ធ្លាប់រែកទឹកត្នោតមកជាមួយខ្ញុំ បានទៅរែកទឹកត្នោតនៅក្បែរផ្លូវជាតិ ក៏ឃើញមានសុទ្ធតែកងទ័ពវៀតណាមដិះឡានមកពីទិសខាងលិច។ ស៊ាន បាននិយាយរឿងរ៉ាវទាំងអស់ប្រាប់ខ្ញុំ ហើយថែមទាំងប្រាប់ឲ្យខ្ញុំនៅរង់ចាំកន្លែងដែលគាត់ទៅបើកអង្ករ។ យើងបានបបួលគ្នារត់មកស្រុកវិញ។ ខ្ញុំបានទៅបបួលសាច់ញាតិមួយចំនួនខាងប្រពន្ធខ្ញុំដែលនៅក្នុងកងផ្សេងៗមកជាមួយខ្ញុំដែរ ប៉ុន្តែគាត់មិនជឿខ្ញុំទេ ហើយថែមទាំងពោលពាក្យមិនគប្បីគំរោះគំរើយដាក់ខ្ញុំទៀតផង។ គាត់បានស្តីបន្ទោសឲ្យខ្ញុំថា «កុំមកធ្វើជាមេបះបោរប្រយ័ត្នរស់មិនបានយូរ ហើយទៅស្រុកវិញបានអីហូប ក្រែងដាច់ពោះស្លាប់តាមផ្លូវ»។ ម៉ោងប្រហែលជា៩ព្រឹក ខ្ញុំ ប្រពន្ធរបស់ខ្ញុំ ឪពុកម្តាយក្មេក បងស៊ាន និងសាច់ញាតិមួយចំនួនទៀតរបស់យើង បានចាប់ផ្តើមរត់ចេញពីភូមិសំដៅមកខេត្តពោធិ៍សាត់ ដោយមានអម្រែកខោអាវ និងអង្ករបន្តិចបន្តួច សម្រាប់ចែកគ្នាហូបនៅតាមផ្លូវ។យើងដើរផងរត់ផងរហូតដល់ក្រុងពោធិ៍សាត់ ម៉ោងប្រហែលជា ៤រសៀល។ ខ្ញុំបានឃើញសាកសពប្រជាជនខ្មែរជាច្រើនដែលត្រូវកងទ័ពខ្មែរក្រហមកៀរសម្លាប់គរលើគ្នាមានទាំងក្មេង ចាស់ ប្រុសស្រី នៅពាសពេញផ្លូវ។

ខេត្តពោធិ៍សាត់ បានរំដោះនៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៩។ ពេលដែលយើងមកដល់ក្រុងពោធិ៍សាត់ កងទ័ពខ្មែរក្រហម មិនឲ្យពួកខ្ញុំទៅណាទៀតទេ ព្រោះសភាពការណ៍មិនទាន់បានស្ងប់ស្ងាត់ទាំងស្រុង។ ដូច្នេះ យើងត្រូវបន្តរស់នៅខេត្តពោធិ៍សាត់ មួយរយៈពេលទៀត។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩ ខេត្តពោធិ៍សាត់ រងការផ្ទុះអាវុធសារជាថ្មីម្តងទៀត ដោយកងទ័ពខ្មែរក្រហម បានវាយលុកសម្រុកចូលក្នុងខេត្តពោធិ៍សាត់បានសម្រេច ប៉ុន្តែសភាពការណ៍នេះត្រូវបានកងទ័ពរណសិរ្សគ្រប់គ្រងបាន។ នៅពេលនោះ កងទ័ពខ្មែរក្រហមជាច្រើននាក់ បានស្លាប់ដោយសារបាក់ទ័ព។ រហូតដល់ខែឧសភា ឆ្នាំ១៩៧៩ កងទ័ពខ្មែរក្រហម ត្រូវកងទ័ពរណសិរ្សបោសសម្អាតរឹងប្រជាជនដែលបានជាប់គាំងនៅក្នុងក្រុងពោធិ៍សាត់ ភាគច្រើន

គឺជាប្រជាជនមកពីខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តកណ្តាល ត្រូវបានកងទ័ពរណសិរ្សអនុញ្ញាតឲ្យវិលត្រលប់មកស្រុកកំណើតវិញ។ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំ មានស្បែកជើងកង់ឡានចាស់រឹង ឪពុកម្តាយក្មេករបស់ខ្ញុំ បានកាត់គារវត្នោតចងច្នៃធ្វើស្បែកជើង ពាក់សម្រាប់ធ្វើដំណើរ។ យើងត្រូវដើរដោយថ្មើរជើងអស់រយៈពេលប្រហែល ១ខែ ទើបបានមកដល់ស្រុកកំណើតនៅក្នុងខែមិថុនា ឆ្នាំ១៩៧៩។ ខ្ញុំបានជួបជុំបងប្អូនសាច់ញាតិរបស់ខ្ញុំនៅក្នុងភូមិវិញដោយរីករាយ។ បន្ទាប់មករដ្ឋអំណាច បានបែងចែកដីឲ្យយើងធ្វើស្រែចម្ការសម្រាប់ចិញ្ចឹមជីវិតតរៀងមក។



៥៥

រឿង ខាសនាដូន ចាស់ខ្ញុំ

អ្នកនិពន្ធ ៖ ឡឿន ជាវីន

៥៥ ~ រឿង ទាសនាដូនចាស់ខ្ញុំ

ជីវិតស្ត្រីមេម៉ាយ

ស្ត្រីវ័យប្រហែល ៣៨ឆ្នាំ មានសម្បុរស្រអែម ច្រមុះខ្ពស់ល្មម សក់ត្រឹមស្មា និងមានរាងស្គមស្គាំងហាក់ពុំសូវមានកម្លាំងតស៊ូនឹងការងារឡើយ ប៉ុន្តែ គាត់ពូកែខាងសម្តីខ្លាំងណាស់។ ក្រោយរបបខ្មែរក្រហមចាប់ផ្តើមបានកន្លះឆ្នាំ គឺក្នុងខែតុលា ឆ្នាំ១៩៧៥ ប្តីរបស់គាត់ បានធ្លាក់ខ្លួនឈឺក្អកធ្លាក់ឈាម។ ទោះបីជាគាត់ចង់យកប្តីទៅព្យាបាលនៅមន្ទីរពេទ្យ ក៏គាត់បានត្រឹមតែគិតមិនហ៊ានធ្វើឡើយ សូម្បីតែនិយាយក៏គាត់មិនហ៊ានដែរ។

ចុងក្រោយ ប្តីរបស់គាត់ បានស្លាប់ទាំងអាឡោះអាល័យចោលប្រពន្ធកូន ហើយបានបន្សល់ទុកនូវពាក្យបណ្តាំថា «ខ្ញុំសុំទោស! ឯងត្រូវមើលថែកូនឲ្យបានល្អផងណា និងត្រូវចេះបត់បែនជីវិតទៅតាមរបបសង្គមផង»។ ពេលវេលាចេះតែកន្លងផុតទៅ ជីវិតម្តាយ និងកូនទាំង ៥នាក់ ត្រូវរស់នៅធ្វើការគ្មានទេពាក្យថានឿយហត់។

យាយលុច ជាឈ្មោះស្ត្រីមេម៉ាយកូន ៥នាក់នោះ។ ការងាររបស់ យាយលុច គឺត្រូវចេញទៅច្រូតស្រូវនៅតាមវាលស្រែ។ គាត់ខិតខំប្រឹងប្រែងធ្វើការខ្លាំងណាស់ ទោះបីជារូបរាងគាត់ស្គមស្គាំងហាក់គ្មានកម្លាំងក៏ពិតមែន ប៉ុន្តែគាត់មានចិត្តអំណត់តស៊ូនឹងការងារ ថែមទាំងធ្វើការប្រកបដោយស្មារតីរឹងមាំជានិច្ច។ គាត់មិនហ៊ានប្រព្រឹត្តអ្វីដែលខុសឆ្គងនឹងច្បាប់របស់អង្គការនោះទេ ព្រោះគាត់ខ្លាចអង្គការយកគាត់ទៅដាំដំឡូង ឬយកទៅរៀនសូត្រចោលកូនៗ។ នៅពេលព្រលប់ថ្ងៃមួយពេលដែល យាយលុច ត្រលប់ដល់ផ្ទះជួបជុំកូន ស្រាប់តែកូនច្បងរបស់គាត់លួចសួរថា៖

កូនច្បង៖ «ម៉ែ! ម៉ែ! ហេតុអ្វីអង្គការឲ្យម៉ែធ្វើការយូរម្ល៉េះ?»

យាយលុច៖ «ទេ! ទេ! កុំនិយាយអីចឹង ប្រយ័ត្នមានគេឮណាកូន» យាយលុច ស្ទុះយកដៃទៅបិតមាត់កូនកុំឲ្យនិយាយខ្លាចអង្គការស្តាប់ឮអាច មានគ្រោះថ្នាក់ដល់ជីវិត។

កូនច្បង៖ «មានរឿងអីម៉ែ បានខ្ជប់មាត់ខ្ញុំបែបនេះ?»

យាយលុច៖ «គ្មានរឿងអ្វីទេកូន ម៉ែចង់ឲ្យកូនឯងទាំងអស់គ្នាឡើងទៅលើ ផ្ទះដេកមុនម៉ែទៅ ចាំម៉ែងូតទឹកហើយ ម៉ែទៅដេកតាមក្រោយ»។

កន្លងមួយរាត្រីយ៉ាងលឿន សំឡេងមាន់រងាវក៏ចាប់ផ្តើមបន្លឺឡើងល្វើយៗ ជាសញ្ញាដាស់ប្រជាកសិករឲ្យភ្ញាក់ស្មារតីរៀបចំប្រាណចេញទៅធ្វើការច្រូតស្រូវ នៅវាលស្រែតាមផែនការរបស់ថ្នាក់លើកកំណត់ឲ្យ ឲ្យបានរួចរាល់មុនថ្ងៃលិច។ ថ្ងៃត្រង់ហើយ ប្រជាកសិករក៏ឈប់សម្រាកអាហារ ប៉ុន្តែគ្មានបាយហូបទេ គឺមានតែ បបរអាវៗមួយវែកម្នាក់ប៉ុណ្ណោះ។ ទោះបីហូបបបរមិនឆ្ងាញ់ និងមិនឆ្អែតទៅតាម ចិត្តឃ្លានក៏ដោយ ក៏ប្រជាកសិករមិនហ៊ានសូរនាំឡើយ ព្រោះខ្លាចអង្គការចោទ ថាប្រឆាំងនឹងអង្គការ ជាពួកមូលធននិង មិនលះបង់គំនិតរបបចាស់ចោល។ ល្ងាចនេះ អង្គការ មានការប្រជុំមួយ ដើម្បីណែនាំពីមាគ៌ាបក្សឲ្យបានជ្រួតជ្រាប ដល់ទឹកចិត្តរបស់ប្រជាជនខ្មែរឲ្យស្មោះស្ម័គ្រចំពោះតែអង្គការ។

ម៉ោង៨ទៀបភ្លឺ សមាជិកគ្រួសាររបស់ យាយលុច បានភ្ញាក់ដឹងខ្លួនទាំងម្តាយ ទាំងកូន ព្រោះតែឮសំឡេងឡូឡាររបស់កម្មាភិបាលមួយក្រុមប្រហែលជាមាន គ្នា ៨នាក់ មកយកស្ត្រីម្នាក់ឈ្មោះ ស្បាយ ដែលជាប្រជាជនថ្មីរស់នៅក្បែរនោះ ហើយបណ្តើរយកទៅរៀនសូត្រ។ គ្មាននរណាម្នាក់ហ៊ានជួយ ស្បាយ ឡើយ។ នៅពេលឃើញបែបនេះហើយ យាយលុច បានខ្សឹបប្រាប់កូនៗថា៖

យាយលុច៖ «កូនៗទាំងអស់គ្នា ស្តាប់ម៉ែណា! កូនកុំធ្វើអ្វីដែលខុសនឹង ច្បាប់អង្គការឲ្យសោះ ម៉ែពិតជាខ្លាចណាស់ ហើយម៉ែប្រាកដជាស្លាប់តាមកូន មិនខាន បើកូនម៉ែជួបរឿងបែបនេះ»។

កូនៗឆ្លើយព្រមគ្នា ៖ «បាទ! ចាស៎ !ម៉ែ»។

ដើមឆ្នាំ១៩៧៦ អង្គការនៅតែបន្តមាគ៌ាមហាអស្ចារ្យរបស់ខ្លួនជានិច្ច ដោយមិនខ្វល់ពីប្រជាជន ដែលធ្វើការយ៉ាងលំបាកលំបិននោះឡើយ។ ពីមួយថ្ងៃទៅមួយថ្ងៃ អង្គការ បានចាត់ឲ្យប្រជាជនធ្វើការមិនឈប់ឡើយ។ បន្ទាប់ពីរដូវច្រូតស្រូវ អង្គការឲ្យប្រជាជនទៅជីកប្រឡាយទឹក ដើម្បីទុកធ្វើជាប្រព័ន្ធសម្រាប់ធ្វើស្រែបន្តទៀត។ យាយលុច ត្រូវអង្គការចាត់ឲ្យទៅលើកប្រឡាយឲ្យបានប្រវែង ៣០ម៉ែត្រ និងជម្រៅ ១ម៉ែត្រកន្លះ ឲ្យរួចមុនថ្ងៃលិច។ យាយលុច ពេលនោះហាក់ទ្រុឌទ្រោមកម្លាំងទៅហើយ ព្រោះរាល់ថ្ងៃគាត់ធ្វើការហួសកម្លាំង ហូបមិនឆ្អែតគ្រប់គ្រាន់ និងមិនបានសម្រាកពេញភ្នែកទៀត ប៉ុន្តែ យាយលុច នៅតែបន្តធ្វើការងារឲ្យរួចទៅតាមផែនការរបស់ថ្នាក់លើទាល់តែបាន។ យប់ណាស់ហើយទើប យាយលុចមកដល់ផ្ទះ ហើយឃើញកូនៗ អង្គុយចាំឲ្យរហង់ចាំមើលផ្លូវម្តាយ។ យាយលុច ចាប់ផ្តើមហូរទឹកភ្នែករហាមកាត់ផែនថ្ពាល់ដ៏ជ្រីវជ្រួញរបស់គាត់ ហើយក៏បាននិយាយទាំងអួលដើមកថា ៖

យាយលុច ៖ «កូនៗនៅចាំអីទៀត កូនទៅដេកមុនម៉ែទៅ»។

កូនទីពីរ ៖ «ម៉ែ!ខ្ញុំនៅចាំម៉ែ ព្រោះខ្លាចម៉ែទៅចោលពួកខ្ញុំ»។

គ្រាន់តែឮសម្តីនេះភ្លាម ទឹកភ្នែក យាយលុច កាន់តែហូរខ្លាំងឡើងៗ និងនឹកស្រណោះដល់សម្តីរបស់ប្តីកាលនៅរស់។ ម៉្យាងទៀត អាណិតកូនៗដែលនៅតូចៗ ត្រូវមករស់រងទុក្ខវេទនាជាមួយអង្គការ។

កូនស្រីពៅ ៖ «ម៉ែ! ម៉ែ! ខ្ញុំឃ្លានណាស់ម៉ែ» កូនស្រីពៅរបស់ យាយលុច មានអាយុប្រហែល៥ឆ្នាំ។

យាយលុចឮកូនស្រីពៅនិយាយបែបនេះហើយ ក៏ស្ទុះទៅដឹកដៃកូនឡើងលើផ្ទះ និងព្យាយាមសំងំយ៉ាងស្ងាត់ឈឹង ព្រោះខ្លាចបែកការណ៍សម្ងាត់។ តាមពិត យាយលុច ពេលធ្វើដំណើរមកផ្ទះវិញ បានដើរកាត់ចម្ការដំឡូងជ្វាមួយកន្លែង ហើយស្របពេលស្ងាត់គ្មានមនុស្សដើរ គាត់ក៏បានលួចដកដំឡូងពីរបីមើមមកឲ្យកូនៗគាត់។

យាយលុច៖ «ស្ងាត់ស្ងៀមណាកូន! នេះម៉ែមានដំឡូងផ្ងាពីរបីមើមដែរ កូនស៊ីទៅ ម៉ែលាងទឹករួចហើយ» កូនបងប្រុសៗពីរនាក់មិនស៊ីទេ តែកូនស្រីប្អូនបីនាក់ចែកគ្នាស៊ីដោយស្ងៀមស្ងាត់បំផុត ប្រកបដោយស្មាមញ្ញឹមតិចៗ បើទោះបីជាដំឡូងនោះមិនបានចម្អិនក៏ដោយ។

ល្ងាចនេះ យាយលុច មើលទៅដូចជាស្លេកស្លាំងណាស់។ គាត់មានដំណើរមួយៗមិនរហ័សដូចសព្វមួយដងទេ។ គាត់ដើរៗឈប់សម្រាកដូចរកកលចង់ដួល តែគាត់នៅតែប្រឹងដើរហួតទាល់តែដល់ផ្ទះទើបដួលសន្លប់មុខកូនៗរបស់គាត់។ ពេលនោះអ្នកជិតខាងបានចូលទៅជួយគ្រាមកក្រោមផ្ទះ ដើម្បីកោសខ្យល់ឲ្យបានធូរស្បើយ ប៉ុន្តែកងឈ្លប បានចូលមកឃើញស្តីបន្ទោសឲ្យថា៖

សមមិត្តហំ៖ «នែ៎!ពួកឯងធ្វើអី? ម្តេចក៏មកផ្តុំក្បាលគ្នានៅទីនេះ? យី! ពួកអាឯងមិនខ្លាចអង្គការទេឬ?»

អ្នកជិតខាង៖ «ទេ!សមមិត្តបង! ពួកខ្ញុំមកមើលសមមិត្ត លុច ដួលសន្លប់មិញនេះ»។

យាយលុច៖ «ខ្ញុំមិនអីទេ!» យាយលុច ដឹងខ្លួនតិចៗរួចឆ្លើយតបទៅកងឈ្លប។

សមមិត្តហំ៖ «អើ!វាមិនអីទេ! ឆាប់ទៅកន្លែងរៀងៗខ្លួនវិញទៅ។ តិចអញប្តឹងថ្នាក់លើឥឡូវហ្នឹង!»។

អ្នកទាំងអស់គ្នា បានរំសាយគ្នាទៅវិញតាមកន្លែងរៀងៗខ្លួនអស់ទៅ នៅសល់តែកងឈ្លប ដែលបានស្តីបន្ទោសឲ្យ យាយលុច បន្តទៀតថា៖

សមមិត្តហំ៖«នែ៎! សមមិត្តឯង កុំធ្វើពុតជាឈឺអី ប្រយ័ត្នអង្គការយកទៅរៀនសូត្រ»។

យាយលុច៖ « ចាស៎ សមមិត្តបង ខ្ញុំនឹងខំប្រឹងធ្វើការបម្រើមាគ៌ាបក្សឲ្យបានខ្លាំងក្លាបំផុត»។

ក្រោមកម្តៅព្រះអាទិត្យដែលកំពុងដុតរោលមកលើផែនដីយ៉ាងខ្លាំង ប៉ុន្តែក្រុមមនុស្សដែលស្លៀកពាក់ខោអាវពណ៌ខ្មៅ ស្បែកជើងកង់ឡាន មានក្រមា

ម្នាក់មួយ ខ្លះបង់ក ខ្លះទទូរនឹងក្បាល កំពុងសម្រុកធ្វើការងាររៀងៗខ្លួន។ គ្មាននរណាហ៊ានឈប់សម្រាកទេ ព្រោះ សមមិត្តប្រធាន ដើរត្រួតពិនិត្យការងាររបស់ប្រជាកសិករយ៉ាងម៉ត់ចត់បំផុត ហើយបើមានអ្នកណាហ៊ានល្មើសបញ្ហា អង្គការនឹងយកទៅធ្វើការកន្លែងផ្សេងភ្លាមជាមិនខាន។

ថ្ងៃនេះ យាយលុច បានទៅធ្វើការងារដូចសព្វមួយដង។ គាត់ខំបំពេញការងារឲ្យរួចរាល់មុនថ្ងៃលិច ដើម្បីបានសម្រាកយកកម្លាំងបានយូរបន្តិច។ នៅពេល យាយលុច កំពុងធ្វើការយ៉ាងមមាញឹក ស្រាប់តែមនុស្សម្នាក់បានដើរមកសួរគាត់ថា៖

សមមិត្តប្រធានកង៖ «យ៉ាងណាហើយសមមិត្តប្អូន ឮថាដួលសន្លប់នោះ?»

យាយលុចភ្ញាក់ព្រើតស្មានថាអ្នកណា។ នៅពេលដឹងថាជាសមមិត្តបង គាត់ក៏ឆ្លើយតបទៅវិញថា៖

«មិនអីទេសមមិត្តបង ខ្ញុំបានស្រួលខ្លួនវិញហើយ»។

សមមិត្តប្រធានកង៖ «អើ! បើបានអីចឹងល្អហើយ! ឯងត្រូវមើលថែសុខភាពខ្លួនឯងផង កុំគិតខ្វល់ច្រើនពេក»។

កិច្ចសន្ទនារវាងអ្នកទាំងពីរបានបញ្ចប់យ៉ាងស្ងៀមស្ងាត់បំផុត មិនឲ្យអ្នកណាដឹងឮបាននោះទេ ព្រោះខ្លាចអង្គការភ្នែកម្នាស់ចោទថាជាមនុស្សកម្ពែលពីសង្គមចាស់។ តាមពិតអ្នកទាំងពីរ ជាមនុស្សស្គាល់គ្នាយ៉ាងស្និទ្ធស្នាលកាលដែលរស់នៅក្នុងសង្គមមុន ហើយធ្លាប់បានសន្យានឹងគ្នាថា ទោះជាមានរឿងអ្វីក៏ពួកគាត់ពុំចោលគ្នាឡើយ។

គ្រួសារឯកម្ម

សង្គមរស់នៅលំបាកលំបិន មនុស្សគ្រប់គ្នាទ្រាំរស់ទាំងត្រដរប្រៀបដូចជាអ្នកជំងឺរង់ចាំពេទ្យសង្គ្រោះ។ យប់ថ្ងៃល្ងាចព្រឹកពិតជារហ័សណាស់សម្រាប់ពេលវេលាប៉ុន្តែវាពិតជាយឺតណាស់សម្រាប់មនុស្សដែលកំពុងតែជួបវិបត្តិ។ ឱ! ជីវិតមនុស្សត្រូវរងកម្មគ្រប់សារពើពីសង្គមទាំងដែលខ្លួនពុំបានប្រព្រឹត្តខុសអ្វីសោះ។ ជីវិតគ្រួសារ យាយលុច ចាប់ផ្តើមជួបរឿងទុក្ខសោកសង្រេងទៀតហើយ។ ពីមុន យាយលុច បាត់បង់ប្តីជាទីស្រលាញ់ មកឥឡូវនេះ យាយលុច ត្រូវបាត់បង់កូនស្រីទី៤ ឈ្មោះ ថាវី ត្រូវស្លាប់ ព្រោះតែនាងកើតជំងឺគ្រុនក្តៅខ្លាំងគ្មានថ្នាំមកព្យាបាល។

នៅក្នុងសង្គមគថ្លង់ សង្គមមិនខ្វល់ខ្វាយ បានធ្វើឲ្យមនុស្សម្នាក់ៗ លែងមានរឿងរ៉ាវដដែកវែកញែកគ្នាទៀតហើយ។ មនុស្សគ្រប់គ្នាសុទ្ធតែលាក់ការណ៍រៀងៗខ្លួន ការពារខ្លាចហេតុការណ៍អាក្រក់កើតមានចំពោះខ្លួននិងសាច់ញាតិ។ ល្ងាចនេះ នៅក្នុងគ្រួសាររបស់ យាយលុច ហាក់ដូចជាប្រញាប់ឡើងទៅលើខ្នមសំងំដេកយ៉ាងស្ងាត់ជ្រងំជាងរាល់សព្វដង។ ភ្នែករបស់ យាយលុច កំពុងលួចសម្លឹងមើលទៅឆ្ងាយហាក់ខ្វល់ខ្វាយក្នុងចិត្តមិនអាចទ្រាំបាន ព្រោះតែ សុខ ដែលជាកូនប្រុសទី២ របស់គាត់ បានទៅលួចបេះផ្លែចេកស្រគាលរបស់អ្នកដទៃបានប្រហែលបួនប្រាំផ្លែយកមកទុកចែកគ្នាហូប។ យាយលុច ភ័យស្លន់ស្លោ ជាខ្លាំង។

យាយលុច៖ «កូន សុខ បានផ្លែចេកមកពីណាមក?»

សុខ៖ «បាទម៉ែ ខ្ញុំលួចបេះរបស់គេនៅចុងភូមិណាម៉ែ»។

កូនបង៖ «ហ្អែង! អាសុខ កុំចេះតែហ៊ានរបស់គេ»។

សុខ៖ «ខ្ញុំឃ្លានណាស់បង ពេលគ្មានមនុស្ស ខ្ញុំក៏លួចបេះតែម្តងទៅ»។

កូនស្រីពៅ៖ «ចែកឲ្យខ្ញុំផងអាបង» នាងបានស្នុះទៅសុំផ្លែចេកពីបងយ៉ាងរហ័ស។

យាយលុច៖ «អើ! ឈប់ជជែកគ្នាទៀតទៅ ប្រយ័ត្នមានគេឮឆាប់ស៊ីឲ្យលឿនឡើង ចាំម៉ែមើលផ្លូវឲ្យណា»។

ពេលឮម្តាយនិយាយដូច្នោះ កូនៗរបស់ យាយលុច ខំប្រឹងស៊ីចេកទាំងសម្បក មាត់ញាត់ពេញស្ទើរតែពុំបានទំពាឲ្យម៉ត់ផង គ្រាន់តែដាក់ក្នុងមាត់ហើយលេបយកៗ។

ក្រោមកម្តៅក្តៅហែង ប្រជាជនម្នាក់ៗ ប្រឹងប្រែងលើកដីធ្វើផ្លូវថ្នល់យ៉ាងសកម្ម ដើម្បីឲ្យរួចផុតពីការធ្វើបាប វាយដំ ទាត់ធាក់ពីកម្មាភិបាលខ្មែរក្រហម។ ពេលកំពុងតែធ្វើការ បុរសម្នាក់ មានរាងស្គមខ្លាំង ប្រហែលជាមិនស្រួលខ្លួន បានទម្លាក់អង្គុយចុះ ដើម្បីឲ្យស្រួលខ្លួនឡើងវិញ។ ស្រាប់តែ កងឈ្លបឃើញ ក៏ស្រែកគំរាមសម្តីតខ្លាំងៗដាក់ថា៖

កងឈ្លប៖ «យើស! អាខ្ចិលច្រអូស ហ្អែងហ៊ានមិនធ្វើការផង ហ្អែងដឹងទេហ្អែងធ្វើនេះល្មើសនឹងច្បាប់របស់អង្គការហើយ»។

ពូស៊ីម ដែលជាបុរសរាងស្គមនោះ បានឆ្លើយតបថា៖ «បាទ! សមមិត្តបង ខ្ញុំទើបតែនឹងសម្រាកមិញទេ ព្រោះខ្ញុំវិលមុខ»។

កងឈ្លប៖ «អើ! ឆាប់ងើបមកធ្វើការភ្លាម តិចអញប្តឹងអង្គការថា មិត្តឯងមិនខំធ្វើការទៅ» កងឈ្លបនិយាយរួចក៏យករំពាត់វាត់បុរសនោះពីរបីខ្ទាប់យ៉ាងខ្លាំង។

ទិដ្ឋភាពនេះបានធ្វើឲ្យបងប្អូនប្រជាកសិករ ដែលកំពុងតែធ្វើការនៅទីនោះ គ្មាននណាម្នាក់ហ៊ានហាមាត់ស្តីរកគ្នាឡើយ។ ម្នាក់ៗប្រឹងតែធ្វើការងាររបស់ខ្លួនយ៉ាងខ្លាំង ហើយក៏មិនហ៊ានសួរនាំរឿងរ៉ាវរបស់បុរសនោះដែរ ព្រោះខ្លាចឈ្លបឃើញនឹងកើតជារឿងធំមិនខាន។ រំលងបានមួយសប្តាហ៍ក្រោយមក អង្គការបានផ្លាស់ ពូស៊ីម ឲ្យទៅធ្វើការនៅកន្លែងផ្សេងបាត់ទៅ ហើយក៏គ្មានអ្នកណាដឹងថា អង្គការបញ្ជូន ពូស៊ីម ទៅធ្វើការនៅទីណាដែរ។

ថ្ងៃនេះ ពេលត្រលប់មកពីរើសអាចម៍គោវិញ កូនស្រីទី៣ ឈ្មោះ វេច បានចូលទៅសំងំដេកតែមិនលក់ ព្រោះនាងក្អកខ្លាំងណាស់។ ពេលឃើញបែបនេះ យាយលុច ក៏សួរ៖

យាយលុច៖ «កូន វេច កូនកើតអី? ម្តេចកូនក្អកខ្លាំងម្ល៉េះ?»

កូនវេច៖ «ចាស៎! ម៉ែ ខ្ញុំក៏មិនដឹងដែរ គ្រាន់តែប៉ុន្មានថ្ងៃមុន ខ្ញុំក្អកដែរតែក្អកតិចៗ ប៉ុន្តែពេលនេះខ្ញុំក្អកមិនបាត់សោះ»។

គ្រាន់តែឮសម្តីកូនស្រីនិយាយបែបនេះភ្លាម យាយលុច ធ្លាក់ថ្លើមក្តុក។ គាត់ពិតជាខ្លាចកូនស្រីរបស់គាត់ឆ្លងជំងឺពីប្តីរបស់គាត់ណាស់។ ជំងឺក្អកចេះតែតាមយាយី វេច ហើយពីមួយថ្ងៃទៅមួយថ្ងៃ ជំងឺនេះចេះតែធ្ងន់ធ្ងរឡើងៗមិនបានធូរស្បើយទាល់តែសោះទោះបីជា យាយលុច ខំលួចទៅរកថ្នាំខ្មែរយកមកឲ្យផឹកក៏មិនបាត់ដែរ។ ក្រោយរំលងបាន ៣ខែកន្លះ គឺជាពេលវេលាចុងក្រោយរបស់ វេច។ យាយលុច ស្រែកយំរហូតបាត់ស្មារតី។ សពរបស់ វេច ក៏ដូចជាខ្មោចឪពុករបស់នាង និងប្អូនស្រីរបស់នាងដែរ គឺពុំបានធ្វើបុណ្យឧទ្ទិសឲ្យតាមប្រពៃណីខ្មែរនោះទេ ព្រោះនៅក្នុងរបបខ្មែរក្រហម គ្មានវត្ត គ្មានព្រះសង្ឃ គ្មានយាយជី តាជីនោះទេ គឺមានតែអ្នកធ្វើការរួមគ្នាក្នុងហានៈស្មើគ្នាតែប៉ុណ្ណោះ។

កូនស្រីពៅ ៖ «ម៉ែ! ខ្ញុំនឹកមីបងណាស់។ មីបងទៅណាយូរម្ល៉េះ?»

កូនប្រុសច្បង ៖ «មី អូន! កុំនឹកមីបងអី មីបងទៅធ្វើការនៅកន្លែងឆ្ងាយណាស់?»

កូនប្រុសទីពីរ ៖ «មីអូនអើយ! កុំគិតភ័យទៀត បន្តិច មីបងនឹងមកលេងហើយ»។

យាយលុច ៖ «មិនអីទេកូន តិចទៀតមីបងមកវិញហើយ» យាយលុចនិយាយទាំងទឹកភ្នែក។

បងប្រុសប្រឹងលួងលោមប្អូនស្រី កុំឲ្យនាងយំរហូតដល់នាងដេកលក់បាត់ទៅ ប៉ុន្តែបងប្រុសទាំងពីរនេះក៏នឹកអាឡោះអាល័យនឹង វេច មិនស្ទើរនោះទេ តែធ្វើម្តេចបើកម្មវាសនាបែបនេះ។ យាយលុច ដេកមិនលក់ទេ ហើយសព្វថ្ងៃ ជីវិត យាយលុចរស់នៅដូចបាត់វិញ្ញាណ ព្រោះតែសមាជិកគ្រួសាររបស់គាត់ បានចាកចោលគាត់គ្មានថ្ងៃត្រលប់មកវិញម្តងម្នាក់ៗស្ទើរតែអស់ទៅហើយ។ យាយលុច បានត្រឹមតែបួងសួងដល់ទេវតាឲ្យជួយតាមថែរក្សាកូនៗរបស់គាត់ទាំងបីនាក់ដែលកំពុងនៅមានជីវិតនេះ។

ព្រឹកស្អែកឈានចូលមកដល់ ប្រជាកសិករម្នាក់ៗ ខិតខំប្រឹងប្រែងធ្វើការងារទៅតាមបញ្ជារបស់អង្គការយ៉ាងសស្រាក់សស្រាំ ពុំមាននរណាម្នាក់ហ៊ានឈប់សម្រាកឡើយ។ ពេលវេលាបាយថ្ងៃត្រង់ ប្រជាជនម្នាក់ៗ ខ្លះកាន់ចាន ខ្លះកាន់ស្លាបព្រា មកតម្រង់ជួរដើម្បីទទួលបានអាហាររៀងៗខ្លួន ដើម្បីចម្អែតក្រពះដែលកំពុងតែស្រេកឃ្លាន។ ដោយឡែក យាយលុច បានលួចឆ្នក់ឱកាសនេះ ស្កាត់ទៅជួបកូនស្រីរបស់គាត់នៅក្នុងកងកុមារ ដែលនៅឆ្ងាយពីកន្លែងធ្វើការរបស់គាត់ប្រហែលជា ១គីឡូម៉ែត្រ ដើម្បីយកអាហារបន្តិចបន្តួចឲ្យកូនបានស៊ីឆ្អែត ព្រោះគាត់ខ្លាចនាងឈឺម្នាក់ទៀត។ ទោះបីជា យាយលុច ដឹងថា ធ្វើបែបនេះអាចប្រឈមនឹងសេចក្តីស្លាប់ក៏ដោយ ក៏គាត់នៅតែបំពានដែរ ដើម្បីរក្សាជីវិតកូនរបស់គាត់។

កម្មយើង

កូនប្រុសច្បងរបស់ យាយលុច ត្រូវបានអង្គការចាត់ឲ្យទៅធ្វើការនៅកន្លែងផ្សេងឆ្ងាយពីផ្ទះ។ ថ្ងៃនេះ កងឈ្លប បានមកស្តីបន្ទោសខ្លាំងៗឲ្យ យាយលុច ដែលហ៊ានបំពានច្បាប់របស់អង្គការ ប៉ុន្តែដោយជីវិតមិនទាន់អស់ យាយលុច ក៏បានរួចខ្លួន។

កូនស្រីពៅ៖ «ម៉ែ! ម៉ែ! មកពីណាម្តេចក៏បាត់យូរម្ល៉ៃ?»

កូនប្រុសទី២៖ «ម៉ែ! កូនភ័យកូនខ្លាចណាស់»។

យាយលុច៖ «កុំបារម្ភកូនម៉ែ ម៉ែមិនអីទេ។ កូនឃ្លានទេ?»

កូនប្រុសទី២៖ «កូនឆ្អែតហើយ កូនមិនឃ្លានទេ។ តែ មីអូន ប្រហែលជាឃ្លានទេដឹង?»

យាយលុច៖ «មកស៊ីដំឡូងទេកូន ម៉ែ ដើរមកតាមផ្លូវឃើញក៏លួចយក ២មើម ទុកឲ្យកូនៗដែរ»។

និយាយដល់ត្រង់នេះ ទឹកភ្នែករបស់ យាយលុច ស្រក់ហូរមកហាម និងមិននិយាយស្តីអ្វីទាំងអស់។

ជីវភាពរាល់ថ្ងៃរបស់ប្រជាជនចាស់ និងប្រជាជនថ្មីគ្រប់គ្នា កាន់តែយ៉ាប់យឺនទៅហើយ។ រូបកាយម្នាក់ៗនៅតែស្បែកដណ្តប់ឆ្អឹង ស្គមស្គាំង ស្លេកស្លាំង គ្មានកម្លាំងកំហែងទេ។ សេចក្តីទុក្ខវេទនា សេចក្តីព្រាត់ប្រាស់កំព្រាគ្រប់រូបភាព បានក្លាយទៅជាទិដ្ឋភាពនិងទម្លាប់ដ៏សាមញ្ញនៅក្នុងក្រសែភ្នែករបស់អង្គការហើយនៅតែអូសបន្លាយក្នុងស្មារតីរបស់ប្រជាជនទូទាំងប្រទេស។

យប់នេះខែរះភ្លឺចាំងច្បាស់ឆ្លុះមកលើភពផែនដីដែលពោរពេញដោយភាពអយុត្តិធម៌។ រាត្រីនេះនៅផ្ទះរបស់ យាយលុច មានភាពស្ងាត់ស្ងៀមបង្កប់ដោយភាពរីករាយក្នុងចិត្ត ដោយសារតែកូនប្រុសច្បងរបស់គាត់ បានមកលេងជាមួយម្តាយ និងប្អូនៗ ក្រោយពីបានបែកគ្នាទៅធ្វើការជាចុងភៅអស់មួយរយៈពេលយូរមក។

យាយលុច៖ «កូនយឿន ឡើងមកលើផ្ទះមកកូន» យាយលុច និយាយទាំងរំភើប ព្រោះបានជួបមុខកូន។

កូនយឿន៖ «បាទម៉ែ កូនឡើងទៅឥឡូវហើយ។ មក អាអូន មីអូន បង នឹកពួកឯងណាស់»។

ប្អូនប្រុស៖ «បងប្រុស ខ្ញុំនឹកបងណាស់។ ខ្ញុំស្មានតែមិនបានជួបបងទេ?» ប្អូនប្រុសនិយាយដោយរំភើប និងយំឱបបងប្រុស។

ប្អូនស្រី៖ «បងប្រុស បងដេកនៅផ្ទះដែរឬទេ? ខ្ញុំចង់ដេកជុំជាមួយបងប្រុស និងម៉ែណាស់» ប្អូនស្រីនិយាយផងយំផង។

កូនយឿន៖ «ម៉ែ! ខ្ញុំមិនបានដេកនៅផ្ទះទេ ព្រោះខ្ញុំត្រូវត្រលប់ទៅកន្លែងវិញ ខ្លាចថ្នាក់លើដឹងនឹងចាប់កំហុស មានរឿងជាមិនខាន»។

យាយលុច៖ «មិនអីទេកូនប្រុស បានឃើញមុខកូនប៉ុណ្ណឹងក៏ម៉ែសប្បាយចិត្តដែរ។ កូនត្រូវថែរក្សាខ្លួនផងណាកូន» យាយលុច យំរៀបរាប់ខ្សឹកខ្សួលហាក់មិនចង់ឲ្យកូនប្រុសត្រលប់ទៅវិញទេ។

ក្រោយពីកូនប្រុសច្បងត្រលប់ទៅធ្វើការតាមការចាត់តាំងលើកនោះមក កូនសុខ ដែលជាកូនប្រុសបន្ទាប់ បានធ្លាក់ខ្លួនឈឺយ៉ាងធ្ងន់ដោយមិនដឹងពីមូលហេតុឡើយ។ ទោះបីជាព្យាបាលដោយថ្នាំខ្មែរយ៉ាងណា ក៏នៅតែមិនបានធូរស្បើយឡើយ។ សុខ ធ្លាក់ខ្លួឈឺតែកន្លះខែប៉ុណ្ណោះ ក៏បានស្លាប់ចោលម្តាយ និងប្អូនស្រីដ៏កម្សត់ទៀត។ ការបាត់បង់កូនប្រុសលើកនេះ ពិតជាធ្វើឲ្យ យាយ លុច ខូចចិត្តកាន់តែខ្លាំង។ ទោះបីជាត្រូវខូចចិត្តយ៉ាងណាក៏ដោយ ក៏ យាយ លុច នៅតែរឹងមាំជានិច្ច ដើម្បីប្រឈមនឹងការរស់នៅក្នុងស្បែងងឹតនេះ។

កូនយឿន៖ «ម៉ែ! ម៉ែ! ហេតុអ្វីប្អូនប្រុសទៅចោលខ្ញុំ?» យឿន និយាយរួចរត់យំមកឱបម្តាយ។

យាយលុច៖ «កូនប្រុស កូនកុំយំអី កូន សុខ ប្អូនរបស់កូនទៅបានសុខហើយ» ម្តាយនិយាយលួងលោមកូនយ៉ាងផ្អែមល្ហែមនិងរឹងមាំ តែក្នុងចិត្តស្ទើរតែផុតដង្ហើមទៅហើយ។

មានពេលមួយ អង្គការ បានឲ្យ យឿន មករស់នៅជុំគ្រួសារវិញ។ សេចក្តីស្រេចឃ្លានពីមួយថ្ងៃទៅមួយថ្ងៃបានធ្វើឲ្យ យាយលុច ហ៊ានប្រថុយប្រថានលួច

ទៅសុំស្រូវបងប្អូននៅស្រុកលើបានមួយកញ្ជើ ដើម្បីយកមកទុកឲ្យកូនប្រុសកូនស្រីរបស់គាត់។ ប៉ុន្តែព្រៃមានត្រចៀកពិតមែន គ្រាន់តែ យាយលុច យកស្រូវមកដល់ផ្ទះភ្លាម មេភូមិក៏មកដល់ដែរ។ បងមេភូមិនោះ បានប្រាប់ យាយលុច ថាអង្គការដឹងរឿងអស់ ហើយ ស្អែកនេះនឹងមកយក យាយលុច ឯងហើយ។ គ្រាន់តែឮប៉ុណ្ណឹងភ្លាម យាយលុច ភ័យញ័រដូចកូនសត្វត្រូវទឹក ព្រោះដឹងខ្លួនថានឹងត្រូវស្លាប់ចោលកូននៅថ្ងៃស្អែកនេះហើយ។

មុឈ្យជួយ

ដោយសារសេចក្តីភ័យខ្លាចនេះហើយធ្វើឲ្យ យាយលុច ធ្លាក់ខ្លួនឈឺខ្លាំងភ្លាមៗត្រូវបញ្ជូនទៅសង្គ្រោះនៅស្រុកស្អាងយ៉ាងលឿនបំផុត។ ការបញ្ជូនត្រឹមនេះក៏មិនអាចជួយ យាយលុច បានដែរ។ សំណាងល្អ អង្គការ ត្រូវបញ្ជូន យាយលុច ចេញទៅធ្វើចម្ការដំឡូងជាមួយប្រជាកសិកររនៅខេត្តកំពង់ចាមទៀត។ ចំណែកឯយឿន ដែលមកតាម យាយលុច ត្រូវបែកពីម្តាយត្រឹមស្រុកស្អាង ហើយបានដើរសាត់អណ្តែតទាំងមិនដឹងទិសតំបន់ទៅរក យាយលឿន នៅភូមិចេកដែលត្រូវជាម្តាយមីងរបស់ យាយលុច។

ព្រលឹមស្អែកក៏មកដល់ កងឈ្លប បានមកចាប់ យាយលុច ដូចតាមេភូមិនិយាយមែន ប៉ុន្តែតាមេភូមិ បានប្រាប់ទៅកងឈ្លបវិញថា យាយលុច ធ្លាក់ខ្លួនឈឺជិតស្លាប់ហើយ មិនបាច់ចាប់នោះទេ ព្រោះមិនយូរទេ យាយលុច នឹងស្លាប់មិនខានឡើយ។ រឿងរ៉ាវរបស់ យាយលុច ពេលនោះក៏ត្រូវបញ្ចប់។ តាមពិត យាយលុច ពិតជាឈឺមែន ប៉ុន្តែតាមេភូមិ បានយកឱកាសនេះ មកជួយបញ្ចៀស យាយលុច ចេញឲ្យផុតដើម្បីសង្គ្រោះជីវិតគាត់ឲ្យរួចពីសេចក្តីស្លាប់។

ក្រោយភ្លៀងមេឃពិតជាស្រឡះ ពពកអួរអាប់ក៏ចាប់ផ្តើមរសាត់ផាត់តាមខ្យល់ បន្សល់តែភាពស្រស់បំព្រងនៃជីវិតរបស់ប្រជាជនគ្រប់រូបដែលបានរួចផុតពីក្រញាំរបស់ពួកសត្វគ្មានសាសនា។ នៅតាមភូមិស្រុកទូទាំងប្រទេសកម្ពុជា ក៏ចាប់ផ្តើមមានសេរីភាពក្នុងការរស់នៅឡើងវិញ។ សង្គមក៏ចាប់ផ្តើមមានការចាយលុយមានសាសនា មានទំនៀមទម្លាប់ប្រពៃណីវប្បធម៌ និងមានគ្រប់យ៉ាងឡើងវិញ។

ជីវិតជួបព្យុះភ្លៀងបោកបក់យ៉ាងខ្លាំងរបស់ យាយលុច ត្រូវបានធម្មជាតិផ្តល់វាសនាឲ្យស្រស់បំព្រងដូចមនុស្សផ្សេងៗទៀតដែរ។ យាយលុច បានរស់នៅជួបជុំយឿន និងកូនស្រីពៅយ៉ាងសុខសប្បាយចាប់តាំងពីពេលនោះមក។ ប៉ុន្តែចិត្តរបស់យាយលុច នៅតែនឹកដល់ប្តី និងកូនប្រុសស្រី ដែលស្លាប់យ៉ាងអាល័យបំផុត។

ជីវិតរបស់ យាយលុច ក្លាយជាស្ត្រីមេម៉ាយ រស់នៅជាមួយកូនប្រុសស្រី២នាក់ក៏ពិតមែន ប៉ុន្តែយាយលុច មិនដែលបាត់បង់សេចក្តីសង្ឃឹមម្តងណាឡើយ។ ផ្ទុយទៅវិញ យាយលុច ខិតខំប្រឹងប្រែងពុះពារឧបសគ្គគ្រប់បែបយ៉ាងដោយមិនរួញរា និងមិនខ្លាចនឿយហត់ឡើយ។ រឿងរ៉ាវគ្រប់យ៉ាងត្រូវបានផ្លាស់ប្តូរទាំងស្រុងវាសនារបស់ យាយលុច ក៏ត្រូវកែប្រែពីភាពកម្សត់ទុរគតមកភាពសប្បាយរីករាយជាមួយជីវភាពដ៏សាមញ្ញនៃជីវិតអ្នកស្រែចម្ការ ៕

ចប់

៥៦

រឿង ស្រមោលអតីតកាល

អ្នកនិពន្ធ ៖ ទិញ ស៊ីណាត

៥៦ ~ រឿង ស្រមោលអតីតកាល

មនោរា គឺជាកុមារីម្នាក់ដែលមានសម្បុរខ្មៅស្រអែម សក់ពណ៌ខ្មៅស្រឡូន និងមានមាឌតូចល្អិត។ មនោរា ជាក្មេងស្រីចូលចិត្តអានសៀវភៅ ហើយភាគច្រើនសៀវភៅដែល មនោរា ចូលចិត្តអាន គឺជាប្រវត្តិសាស្ត្ររបស់ខ្មែរក្រហម។ ទោះបីជា មនោរា មានអាយុត្រឹមតែ ១២ឆ្នាំ ប៉ុន្តែការគិតរបស់ មនោរា បានជ្រាលជ្រៅ និងល្អិតល្អន់ខ្លាំងណាស់។ ឆ្នាំសិក្សាថ្មីនេះ មនោរា ចូលរៀនថ្នាក់ទី៧ហើយ។ នាងរស់នៅជាមួយយាយជរា និងតាពិការជើងម្ខាង នៅក្នុងភូមិអណ្តើកហែប ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ មនោរា ជាកូនកំព្រា ព្រោះកាលពីសម័យខ្មែរក្រហម ឪពុកម្តាយរបស់នាង បានស្លាប់បាត់បង់ជីវិតបន្ទាប់ពីកើត មនោរា រួចភ្លាមៗ។ ក្រោយមក នាង បានមករស់នៅជាមួយយាយនិងតា ដោយមិនបានស្គាល់មុខឪពុកម្តាយទេ។ នៅថ្ងៃមួយពេល មនោរា មានអាយុប្រហែលជាពីរឆ្នាំ តារបស់នាងបានពិការជើងដោយសារជាន់មីន បន្ទាប់ពីលួចបេះដំណាំក្រោយត្រលប់មកពីលើកទំនប់វិញ។

ថ្ងៃមួយពេលដែល មនោរា ត្រលប់មកពីសាលារៀនវិញ នាងបានឃើញអ៊ំស្រីម្នាក់ដើរទូលនំអាកោលក់នៅក្នុងភូមិ។ មនោរា នឹកឃើញដល់យាយ ដែលចូលចិត្តហូបនំអាកោខ្លាំងណាស់ ដូចនេះនាងក៏បានស្រែកហៅអ្នកលក់នំថា៖

មនោរា៖ «មីង មីង!ឈប់សិន»។

អ្នកលក់នំ៖ «អ៎! ក្មួយ មនោរា ទេ ហើយនេះចេញពីរៀនហើយឬ?»

មនោរា៖ «ចា៎ ចេញហើយមីង ចុះមីងលក់នំអស់ហើយនៅ។ ខ្ញុំចង់ទិញ

នំអាកោពីរឲ្យយាយហូប ព្រោះគាត់ចូលចិត្តខ្លាំងណាស់មីង។ យាយគាត់តែងតែប្រាប់ខ្ញុំថា នៅពេលដែលញ៉ាំនំនេះពេលណាធ្វើឲ្យបេះដូងគាត់រំជួលដូចជារំភើបចង់យំបន្តិច ចង់សើចបន្តិច ខ្ញុំមិនសូវយល់ពីចិត្តរបស់យាយដែរ» នាងនិយាយបណ្តើរ រកមើលលុយបណ្តើរ។

អ្នកលក់នំ៖ «អើ នំមីងនៅតើក្មួយ។ នេះអស់ប្រាំរយរៀលណា។ ល្អហើយដែលឯងឆ្លាតចេះដឹងពីរបស់ដែលយាយឯងចូលចិត្ត។ ប្រសិនកូនមីងនៅរស់មិនដឹងជាល្អប៉ុនណាទេ។ ពេលនេះប្រហែលជា កូនមីង ធំជាងឯងហើយ។ មីងក៏មិនលំបាកដូចសព្វថ្ងៃនេះដែរប្រសិនបើកូនមីងនៅរស់នោះ។ ជីវិតរស់នៅជាស្ត្រីមេម៉ាយមិនស្រួលទេ ហើយគ្មានកូន គ្មានចៅនឹងគេទៀត។ មីងឈប់និយាយហើយបើនិយាយទៅក៏មិនដឹងបានអីមកវិញដែរ» គាត់និយាយទាំងទឹកមុខស្រពោន កែវភ្នែករលើងរលោងចង់យំ។

មនោរា៖ «សូមទោសមីងដែលឮបែបនេះ ចុះកូនមីងគាត់ស្លាប់ដោយសារអីដែរ?»

អ្នកលក់នំ៖ «កូនមីងស្លាប់កាលពីសម័យខ្មែរក្រហម ព្រោះអត់មានអាហារហូបចុកគ្រប់គ្រាន់ទេក្មួយ។ ឥឡូវមីងត្រូវទៅលក់បន្តទៀត ហើយមីងក៏មិនចង់រំឭកពីរឿងនេះដែរ ព្រោះវាធ្វើឲ្យមីងឈឺចាប់គ្រប់ពេលនិយាយចេញមកចង់តែយំទេ»។

និយាយហើយ មីងលក់នំអាកោ ក៏ក្រោកដើរចេញទៅបាត់ទុកឲ្យ មនោរា ឈរភ្លឹកមិនដឹងថានឹងរកពាក្យអ្វីមកនិយាយតបតពេលឃើញគាត់ពិបាកចិត្តបែបនេះ។

ពេលដើរចេញមក មនោរា ចេះតែនឹកឆ្ងល់ហើយនឹកឆ្ងល់ទៀតថា «តើរឿងនេះយ៉ាងម៉េចទៅ ហេតុអ្វីបានជាមនុស្សម្នា គ្រាន់តែរំឭកពីរឿងនេះ ធ្វើឲ្យគាត់មានអារម្មណ៍ថាប៉ះទង្គិច ទោះបីជាឥឡូវរបបខ្មែរក្រហម បានកន្លងផុតទៅហើយក៏ដោយនោះ។ តើក្នុងរឿងមួយនេះមានអ្វីនៅពីក្រោយ ខ្ញុំនៅតែមិនយល់ថាអ្វីទៅជាក្បាលរបស់រឿង អ្វីទៅជាខ្លួនរបស់រឿង និងអ្វីជាចុងបញ្ចប់នៃរឿង»។ ការឆ្ងល់នេះ ស្ទើរតែធ្វើឲ្យ មនោរា ដើរហួសផ្ទះទៅហើយ កុំតែបានយាយស្រែកហៅទាន់។

មនោរា៖ «ជម្រាបសួរយាយ ខ្ញុំមកពីសាលាវិញហើយ»។

យាយ៖ «ល្អហើយចៅ ចុះអារម្មណ៍ឯងវិល់តែគិតពីអី មនោរា បានជាដើររហូតហួសផ្ទះបែបនេះអីចឹង?»

មនោរា៖ «យាយ! ខ្ញុំមិនដឹងថា ត្រូវនិយាយពីណាទៅមុនទេ។ អីចឹងយប់នេះ ចៅសូមឲ្យយាយ និងតា និទានរឿងប្រវត្តិសាស្ត្រឲ្យចៅស្តាប់ម្តងបានទេ?»។

គ្រាន់តែឮបែបនេះ យាយផេម ប្រញាប់សួរចៅភ្លាមថា៖

យាយ៖ «ចុះរឿងអីទៅដែលចៅចង់ស្តាប់នោះ?»

មនោរា៖ «គឺរឿងរបបខ្មែរក្រហមហ្នឹងណាយាយ»

យាយ៖ «មនោរា ល្អហើយចៅ ដែលចៅចង់ចេះ ចង់ដឹងពីប្រវត្តិសាស្ត្រ ប៉ុន្តែយាយពិបាកក្នុងការធ្វើអារម្មណ៍នៅពេលដែលនិយាយរឿងនេះម្តងៗ»។

មនោរា៖ «លោកយាយ យើងញ៉ាំបាយសិនទៅអីចឹងកុំទាន់គិតអី។ ចាំពេលលោកយាយមានអារម្មណ៍ល្អពេលណាចាំរៀបរាប់ឲ្យចៅស្តាប់ក៏បានមិនអីទេណា»។

យាយឮដូចច្នោះ ក៏សម្លឹងមើលមុខចៅដោយក្តីអាណិតអាសូរ ហើយឱបចៅទាំងទឹកភ្នែករលីងរលោង បន្ទាប់មកអ្នកទាំងពីរក៏ទៅញ៉ាំបាយជុំគ្នា។ ពេលយប់មកដល់ មនោរា ចាប់ផ្តើមធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឲ្យ។ ពេលកំពុងធ្វើលំហាត់ នាងក៏ចាប់ផ្តើមគិតដល់សម្តីរបស់មីងលក់នំ ហើយចាប់ផ្តើមសង្កេតឃើញពីអាកប្បកិរិយា យាយផេម រួចនាងឆ្ងល់ថា «ហេតុអីបានជាមីង និងយាយមានប្រតិកម្មដូចគ្នាម្ល៉េះ»។

យាយ៖ «យ៉ាងម៉េចហើយចៅ លំហាត់ពិបាកដែលទេថ្ងៃនេះ មានអីឆ្ងល់សួរយាយ និងតា បានណា។ តែរឿងអានវិញយាយតាមិនចេះទេ ព្រោះជំនាន់នោះយាយមិនបានរៀនអក្សរទេ»។

តា៖ «យាយនឹកឃើញជំនាន់នោះ យើងមិនមែនជាគូព្រេងនឹងគ្នាទេ។ ពេលដែលបានឯងដំបូង ខ្ញុំដូចជាមិនស្រលាញ់ឯងសោះ តែបែរជារស់នៅជាមួយគ្នាយូរៗទៅក៏ស្រលាញ់គ្នាវិញ។ ខ្ញុំមិនយល់សោះយាយវាអើយ» មនោរាស្តាប់ឮដូចនេះ នាងញញឹមហើយក៏សួរទៅយាយ និងតា វិញទាំងអៀន។

មនោរា៖ «ចុះកាលនោះ ស្នេហាយាយនិងតាយ៉ាងម៉េចទៅ?»

យាយ៖ «វាពិបាកណាស់ចៅអើយសម័យពីដើម។ យាយមិនដែលដើរចេញពីផ្ទះទេ ហើយតារបស់ឯងនេះមកបានជួបជាមួយយាយ។ យាយ និងតា មិនដែលបានជួបមុខគ្នាទេមុនរៀបការ។ លុះដល់ធំឡើងក៏ចាស់ៗរៀបចំឲ្យជាគូនឹងគ្នា»។ យាយនិយាយចប់ តាក៏តបទៅវិញ៖

តា៖ «កាលនោះយាយឯងកូនអ្នកមានរស់នៅភ្នំពេញ ឯតាវិញជាកូនអ្នកស្រែចម្ការរស់នៅស្រុកបាត់ដំបងនេះផ្ទាល់តែម្តង។ ពេលគ្រួសារយាយឯងមកលេងបងប្អូននៅខេត្តនេះ ក៏ឃើញតា។ ពួកគេក៏ចាប់អារម្មណ៍និងតា តែតាមិនពេញចិត្តទេ ព្រោះពេលនោះ តាក៏មានមនុស្សដែលតាស្រលាញ់ហើយ តែក្រុមគ្រួសាររបស់តា ពេញចិត្តជាមួយយាយឯង រួចក៏ចេះតែនិយាយហើយនិយាយទៀតរហូតដល់ម្តាយរបស់តាស្លាប់បាត់ ក៏តានៅមិនទាន់ព្រមដែរ។ ក្រោយមកក៏តាមិនទាន់ព្រមទៀត រហូតដល់ពុកតា ស្លាប់ចោលដែរ។ មុនពេលដែលពួកគាត់ស្លាប់ សុទ្ធតែឲ្យតាត្រូវរៀបការជាមួយយាយឯងជាដាច់ខាត បើពុំនោះទេ ពួកគាត់ប្រាកដជាបិទភ្នែកមិនជិតឡើយ ទោះបីជាពួកគាត់ស្លាប់ក៏ដោយ»។

មនោរា ក៏ហាមាត់កាត់សម្តីរបស់តាថា៖ «តាក៏សម្រេចចិត្តយកយាយទៅមែនទេ?»

តា៖ «មែនហើយ ពេលនោះយាយឯងសប្បាយចិត្តខ្លាំងណាស់ ប៉ុន្តែតាមិនសប្បាយចិត្តទេ។ ក្រោយមកទៀតតាបានបែកពីមនុស្សស្រីដែលតាស្រលាញ់ហើយចាប់ផ្តើមមកកសាងជីវិតជាមួយយាយរបស់ឯងរហូតបានម៉ាក់ឯងហ្នឹងណា»។

មនោរា៖ «នេះពិតជាស្នេហាដ៏លំបាកមែនទែនតា។ ហើយចុះស្នេហារវាងម៉ែនិងពុកវិញ តើបែបណាទៅតាយាយ?»

ពេលឮសំណួរនេះ តានិងយាយ ចាប់ផ្តើមងាកមើលមុខគ្នាដូចជាមិនចង់និយាយ។ មនោរា ឃើញដូច្នោះ ក៏សួរតានិងយាយថា «យ៉ាងមិចទៅយាយតាចៅចង់ដឹងណាស់ តើគាត់ទាំងពីរមានរឿងអីដែរ? លំបាកដូចតានិងយាយដែលឬទេ? ហើយមានអ្វីដែលពុកនិងម៉ែធ្លាប់មានអនុស្សាវរីយផ្អែមល្ហែមនឹងគ្នា

នោះ?» ឮដូច្នោះយាយក៏និយាយតបទៅចៅថា «មនោរា ចៅនៅក្មេងណាស់ មិនគួរដឹងរឿងនោះទេ»។

មនោរា ក៏ទម្លាក់ទឹកមុខវិញ ហើយសួរតបទៅតាវិញម្តង។

មនោរា៖ «យ៉ាងម៉េចទៅតា គ្រប់រឿងដែលខ្ញុំសួរ មិនថាយាយ មិនថាតា និងមីងលក់នំអាកោទេ គឺមិនចង់ឆ្លើយ។ គាត់តែងតែថាខ្ញុំជាក្មេងរហូត។ ប្រសិនបើចៅចង់ដឹងរឿងរ៉ាវកើតមាននៅពេលនោះ លោកតាប្រាប់ចៅបានទេ?ចៅសូមអង្វរណា»។

យាយ៖ «មនោរា យប់ហើយចៅ យាយគិតថា យើងចូលដេកសិនទៅ ព្រោះស្អែកព្រឹកចៅត្រូវងើបទៅរៀនពីព្រលឹមផង។ ប្រយ័ត្នងើបយឺតណាចៅ! មកឆាប់ចូលគេងទៅ»។

មនោរា៖ «អត់ទេយាយ ខ្ញុំមិនគេងទេបើតាយាយ មិនព្រមឆ្លើយសំណួរដែលខ្ញុំសួរ។ ខ្ញុំប្រាកដជាស្វែងរកចម្លើយនេះនៅថ្ងៃណាមួយមិនខាន»។

តាឮដូចច្នោះ ក៏ដកដង្ហើមធំរួចតបទៅចៅវិញដោយសំឡេងថ្នមៗថា «មិនមែនតានិងយាយ មិនចង់ប្រាប់ចៅទេ ប៉ុន្តែរឿងនោះ បានធ្វើឲ្យយើងគ្រប់គ្នាបាក់ស្បាតខ្លាំងណាស់»។ មនោរា ឮដូចច្នោះ ក៏ចាប់ផ្តើមនិយាយ ព្រោះវាជាពេលដែលនាងចង់ដឹងបំផុតនូវរឿងរ៉ាវដែលកើតមានឡើងទៅលើគ្រួសាររបស់នាង តែត្រូវបានឈប់វិញដោយយាយជាអ្នកកាត់សម្តីថា៖

«ខ្ញុំគិតថា យប់ហើយតា នាំចៅដេកសិនទៅ។ មនោរា ចាំស្អែកយាយនិងតានិយាយប្រាប់ណាយើងសន្យា»។

មនោរា ឮបែបនេះ ចាប់ផ្តើមមានក្តីសង្ឃឹមទៅលើសំណួររបស់នាងជាច្រើនដែលកំពុងតែផុសចេញពីការចង់ដឹងរឿងរ៉ាវទាំងអស់នោះ។ មនោរានឹកក្នុងចិត្តថា «ស្អែកនេះ ខ្ញុំពិតជាបានស្តាប់រឿងទាំងអស់នេះហើយ»។

ក្រោយពីការសន្ទនាបានបញ្ចប់ទៅ អ្នកទាំងបីនាក់ បានចូលដេកលង់លក់យ៉ាងស្កប់ស្កល់នាពេលរាត្រីខ្យល់ត្រជាក់នារដូវស្លឹកឈើជ្រុះ។ ម៉ោង ៥ទៀបភ្លឺ យាយផេម និងតាកុំ ភ្ញាក់ពីដំណេកចេញមកក្រៅផ្ទះបង្កាត់ភ្នក់ភ្លើង ដើម្បីអាំង

កម្តៅខ្លួន។ រីឯ មនោរាវិញ គេងលក់ដោយមិនដឹងយាយនិងតាភ្ញាក់មុនឡើយ។ ពេលកំពុងតែបង្កាត់ភ្លើង យាយ ស្រែកសួរតា។

យាយ៖ «តាវាអើយ មានដកដំឡូងមកអត់ល្ងាចមិញ?»

តា៖ «មានតើយាយវា មើលទុកឲ្យខ្ញុំទៅរកមើលវិញ មើលល្ងាចមិញ ខ្ញុំទុកនៅក្បែរទ្រុងមាន់នេះតើ! នេះឃើញហើយ!»។

យាយឮហើយត្រេកអរ ក៏យកដំឡូងពីដៃតានិងគ្រាប់ខ្នុរដែលគាត់ទុកពីល្ងាចមិញមកដុតជាមួយគ្នាសំរាប់ឲ្យចៅយកទៅរៀនពេលព្រឹក។ មនោរា ភ្ញាក់ឡើង ហើយដើរមករកតានិងយាយ។

យាយ៖ «ក្រោកហើយចៅ? ងើបលឿនម្ល៉េះថ្ងៃហ្នឹងទើបតែម៉ោង៥កន្លះតើចៅ?»

មនោរា៖ «ខ្ញុំឮសំឡេងយាយនិងតាជជែកគ្នា ហើយក៏ក្រោកមកតែម្តងទៅ។ នោះដំឡូវដុតមែនយាយក្លិនឈ្ងុយខ្លាំងណាស់ ខ្ញុំឃ្លានហើយ»។

យាយ៖ «អើ! ចាំមួយភ្លែតទៀតទៅ ឲ្យដំឡូងផុយជាងហ្នឹងបន្តិចសិនបានឆ្ងាញ់ជាប់មាត់តែម្តងណា»។

បីនាក់តាយាយនិងចៅ កំពុងតែអាំងភ្លើងនិងដុតដំឡូង ស្រាប់តែមានសំឡេងសត្វខ្លែងស្រាក់ហើរកាត់ហើយយំទៀត។ ឮដូចច្នោះ មនោរា ក៏ខិតមកជិតយាយសួរ។

មនោរា៖ «សំឡេងអីហ្នឹងយាយ?»

យាយ៖ «ហើរទៅឆ្ងាយទៅវើយប្រយ័ត្នចាប់វះពោះប្រឡាក់អំបិល»។តាក៏តបទៅ មនោរាវិញ។

តា៖ «សត្វហ្នឹងហៅថាខ្លែងស្រាក់ណាចៅ។ពេលដែលឮវាយំបែបនេះ យើងត្រូវស្រែកជេរវាដោយពាក្យណាដែលអាក្រក់ ព្រោះចាស់ៗពីដើមគាត់និយាយថាសត្វហ្នឹងចង្រៃខ្លាំងណាស់ ឲ្យតែយំនៅផ្ទះអ្នកណា ប្រាកដជាឲ្យហេតុចម្លែក ឬមានអ្នកស្លាប់ជាមិនខានទេ»។

មនោរា៖ «ពិតមែនហើយ សំឡេងវាគួរឲ្យខ្លាចខ្លាំងណាស់»។

បន្ទាប់មក យាយ តានិងចៅ បន្តអាំងដំឡូងហូបរហូតដល់ម៉ោង ៦ភ្លឺ ហើយ មនោរា ក៏ក្រោកឡើងទៅងូតទឹក រៀបចំខ្លួនទៅរៀន ហើយ យាយ ក៏ រៀបចំដំឡូងដាក់ថង់ឲ្យ មនោរា យកទៅសាលា។ ព្រឹកនេះ ជាព្រឹកដែល មនោរា សប្បាយចិត្តជាងគេបំផុត ព្រោះតែយប់នេះ មនោរា ប្រាកដជាបានស្តាប់នូវរឿងរ៉ាវ ពីរបបខ្មែរក្រហម ដែលនាងតែងតែឆ្ងល់ជាយូរមកហើយ។

មនោរា៖ «សុភាព ខ្ញុំសុំខ្ចីបិកឯងបន្តិចបានទេ ព្រោះព្រឹកមិញរៀបចំអីវ៉ាន់ រួចហើយ តែនៅភ្លេចដាក់បិកមកទៀត»។

សុភាព៖ «ឯងនេះភ្លេចរហូត ហើយបានអីញ៉ាំថ្ងៃនេះ?»។

មនោរា៖ «បានដំឡូង យាយ និងតា ដើបដុតឲ្យព្រឹកមិញនេះ»។

សុភាព៖ «ញ៉ាំដំឡូងមើលតែសម័យ ប៉ុល ពត។ នៃ៎ឥឡូវនេះ គេឈប់ ញ៉ាំដំឡូងហើយ គេញ៉ាំតែបាយសាច់ជ្រូកពងទា ឬផ្លែឈើទេ ព្រោះឥឡូវរបស់ ញ៉ាំមានច្រើនណាស់ មិនមែនញ៉ាំដំឡូងបែបហ្នឹងទេ»។

គ្រាដែល សុភាព និងមនោរា កំពុងតែជជែកគ្នា សំណាង នៅជិតនោះ ក៏បាននិយាយទៅកាន់អ្នកទាំងពីរ។

សំណាង៖ « សម័យខ្មៅងងឹតមួយនោះ ប្រសិនបើឯងក៏មិនអាចរស់ បានដែរ»។

មនោរា ឮគេនិយាយគ្នាបែបនេះ ក៏នឹកគិតទៅដល់អ្វីដែលនាងបានគិតពី របបខ្មែរក្រហម។ នាងឆ្ងល់ថា ចុះកុមាររស់នៅយ៉ាងម៉េចទៅសម័យនោះ? តើ ពួកគេមានកម្លាំងដៃរទេ បានរៀនសូត្រត្រឹមត្រូវ ឬមួយក៏ត្រូវធ្វើការដូចជាមនុស្ស ពេញវ័យដែរ?

កំពុងតែសញ្ជឹងគិតដល់ត្រឹមនេះ ជួងបានបន្លឺឡើងម៉ឺងៗ។ បន្ទាប់ពីឮស្នូរ ជួង សិស្សគ្រប់គ្នាម្ដីម្នាចេញលេងយ៉ាងសប្បាយរីករាយ។

សំណាង៖ «អេ! ម៉ោងក្រោយនេះរៀនអីទៅ មនោរា? យើងភ្លេចបាត់ ហើយ»។

មនោរា៖ «ម៉ោងប្រវត្តិវិទ្យា! មែនហើយៗ ម៉ោងប្រវត្តិត្រូវហើយ ម៉ោងប្រវត្តិ សំណាងល្អណាស់»។

សំណាង៖ «មិចក៏ឯងសប្បាយចិត្តម្ល៉េះឲ្យតែឮដល់ម៉ោងប្រវត្តិ?»

មនោរា៖ «ខ្ញុំមិនដឹងទេ ប៉ុន្តែ ខ្ញុំមានអារម្មណ៍ថា ឲ្យតែដល់ម៉ោងនេះ ខ្ញុំពិតជាចាប់អារម្មណ៍ចង់រៀនសូត្រណាស់។ ប្រហែលមកពីខ្ញុំស្រលាញ់ប្រវត្តិសាស្ត្រពេកទេដឹង។ ម្យ៉ាងទៀត សំណាង ឯងដឹងទេគ្រប់ពេលដែលខ្ញុំបានអាន ឬស្តាប់ចាស់ៗគាត់និយាយគ្នា ខ្ញុំតែងតែស្តាប់ ហើយសួរគាត់ពីមូលហេតុនៃរឿងរ៉ាវដែលគាត់បាននិយាយនោះ»។

សំណាង៖ «ឯងពូកែហើយ មនោរា ដែលចេះចាប់អារម្មណ៍រឿងទាំងអស់នេះ។ ខ្ញុំគិតថា សព្វថ្ងៃភាគតិចណាស់ដែលក្មេងៗមានវ័យប្រហាក់ប្រហែលយើង បានយល់ដឹងពីរឿងប្រវត្តិសាស្ត្រ»។

ម៉ោងប្រវត្តិសាស្ត្របានមកដល់ លោកគ្រូ ពន្យល់មេរៀនបានល្អណាស់ ហើយថែមទាំងធ្វើឲ្យ មនោរា កាន់តែយល់ដឹងច្បាស់។ តាមពិតទៅ របបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម គឺជាគុកឥតជញ្ជាំង ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ជាថ្ងៃដែលធ្វើឲ្យមនុស្សជាច្រើនត្រូវស្លាប់នៅលើទឹកដីកំណើតរបស់ខ្លួន។

លោកគ្រូ៖ «មនោរា ប្អូនមានអីចង់សួរមែនទេ បានជាធ្វើមុខឆ្ងល់អីចឹង?»

មនោរា៖ « លោកគ្រូ តើពួកគេខ្លាចខ្មោចទេកាលសម័យនោះ?» សំឡេងសើចបានផ្ទុះឡើងបន្ទាប់ពី មនោរា បានសួរសំណួរនេះទៅកាន់គ្រូ។ លោកគ្រូឮដូចច្នោះហើយក៏ញញឹមរួចឆ្លើយ។

លោកគ្រូ៖ «តាមពិតទៅសម័យនោះ គេលែងខ្លាចខ្មោចហើយប្អូន។ អ្វីដែលគេខ្លាចបំផុតនោះ គឺខ្លាចសេចក្តីស្លាប់ច្រើនជាង ព្រោះម្នាក់ៗនៅពេលដែលឮថាយកនរណាម្នាក់ទៅកសាង ឬយកទៅឲ្យរៀន គឺចាប់ផ្តើមនាំគ្នាភ័យខ្លាចជាងខ្មោចទៅទៀតណា!។ លោកគ្រូក៏ចម្លែកចិត្តដែរកាលនោះ ព្រោះតំបន់ដែលលោកគ្រូរស់នៅ ដូចជាមិនពិបាកនោះទេ ព្រោះយើងមានបាយហូបឆ្អែត ហើយការងារក៏មិននឿយហត់ទៀត។ គ្រាន់តែយកគោទៅឃ្វាលមកវិញ មានអ្នកដាំបាយឲ្យទៀត មិនពិបាកអីទេ»។

ស្តាប់ដល់កន្លែងនេះ មនោរា អត់មានចម្ងល់ទៀតទេ ប៉ុន្តែមិត្តរួមថ្នាក់របស់មនោរា ម្នាក់បានចោទជាសំណួរមួយគួរឲ្យចាប់អារម្មណ៍ ថា «លោកគ្រូ! តើការសម្លាប់នេះ មានការបញ្ជាពីខាងណាមកដែរ បើប្រជាជនមិនបានធ្វើអ្វីខុសផង និងគ្រាន់តែធ្វើការហត់អស់កម្លាំងចង់ហូបឆ្ងាញ់ ហេតុអីចាំបាច់សម្លាប់ពួកគាត់? បើថាអ្នកចេះដឹងទៅត្រូវយកទៅសម្លាប់ ព្រោះខ្លាចធ្វើបដិវត្តន៍។ ចុះប្រជាជនលួចហូប វាខុសធ្ងន់មែនទេ? ខ្ញុំដូចជាមិនយល់សោះត្រង់ចំណុចនេះ?»

លោកគ្រូ៖ «ល្អណាស់!សំណួរនេះជាអ្វីដែលគ្រប់គ្នាគួររៀនសួរតាមគាត់ ព្រោះការហូបរបស់ដែលគេមិនឲ្យហូបនោះ វាមិនខុសទេសម្រាប់យើង។ ប៉ុន្តែវាជាច្បាប់របស់អង្គការនៅជំនាន់ខ្មែរក្រហម។ សមមិត្តទាំងអស់ ត្រូវតែគោរពតាម បើពុំនោះទេនឹងត្រូវយកទៅសម្លាប់ចោល។ អ្វីក៏ដោយឲ្យតែធ្វើខុស ទោះអំបិលមួយគ្រាប់ ក៏ត្រូវស្លាប់ដែរ» គ្រូនិយាយចប់ សិស្សម្នាក់ក៏បានសួរតទៀត។

សិស្ស៖ «ចុះលោកគ្រូ! ឥឡូវយើងបានរួចផុតហើយ។ តើអ្នកដែលបានរំដោះចេញពី ថ្ងៃទី៧ មករា តើពួកគាត់រស់នៅយ៉ាងម៉េចដែរ?» ឮសំនួរនេះ មនោរា អង្គុយយ៉ាងត្រង់ភ្លឹងសម្លឹងមុខគ្រូ ដោយយកចិត្តទុកដាក់។

លោកគ្រូ៖ «គ្រូមិនអាចពណ៌នាឲ្យប្អូនទាំងអស់គ្នាបានស្តាប់គ្រប់ជ្រុងជ្រោយលម្អិតពេកនោះទេ។ លោកគ្រូជឿថា ក្នុងចំណោមប្អូនទាំងអស់គ្នា ក៏មានសមាជិកគ្រួសារខ្លះនៅរស់រានមានជីវិតពីរបបខ្មែរក្រហមដែរ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ គ្រួសារស្ទើរតែគ្រប់គ្នាបានបាត់បង់សាច់ញាតិ បងប្អូន ហើយអ្នកនៅរស់ខ្លះពិការក៏មានដែរ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានជួបនឹងការប៉ះទង្គិចផ្លូវចិត្តក៏មានច្រើន»។

ការបកស្រាយរបស់លោកគ្រូ បានបង្ហាញឲ្យសិស្សយល់ពីផលប៉ះពាល់របស់ពួកគេ បន្ទាប់ពីបានឆ្លងកាត់រឿងរ៉ាវដល់អាក្រក់មួយនេះ។

ម៉ឹង។!។។។ ជួងចេញទៅផ្ទះ បានដាស់អារម្មណ៍សិស្សគ្រប់គ្នាឲ្យរៀបចំកាតាប និងសម្ភារផ្សេងៗដាក់ចូលកាបូបដើម្បីត្រលប់ទៅផ្ទះវិញ។ ដោយឡែកថ្នាក់ប្រវត្តិសាស្ត្រនេះវិញទេ មិនចង់ចេញសោះ ព្រោះសិស្សនិងគ្រូកំពុងតែដេញដោលគ្នាសួរសំណួរនិងចម្លើយទៅវិញទៅមកយ៉ាងសកម្ម។

មនោរា ដើរបណ្តើរគិតបណ្តើរថាតើគួរសួរអ្វីចំពោះយាយ និងតាល្ងាចនេះ? ចុះបើសួរទៅ យាយនិងតា អត់សប្បាយចិត្ត តើខ្ញុំគួរតែធ្វើយ៉ាងម៉េច?

មួយសន្ទុះក្រោយមក មនោរា បានទៅដល់ផ្ទះ ហើយរៀបចំញ៉ាំបាយជាមួយយាយ និងតា យ៉ាងសប្បាយរីករាយ។ ពេលញ៉ាំរួច មនោរា យកចានទៅលាងរៀបចំទុកដាក់យ៉ាងមានរបៀប។ យាយផេម ក៏បានសួរចៅ។

យាយ៖ «ធ្វើកិច្ចការហើយឬនៅចៅ?»យាយផេម សួរទៅចៅស្រី។

មនោរា៖ «ចាស រួចហើយយាយ។ ខ្ញុំកំពុងតែរៀបចំសៀវភៅ ប៊ិក ទុកវិញ។ និយាយអីចឹង យាយ និងតា ត្រៀមខ្លួនរួចហើយនៅសម្រាប់រឿងនិទាននៅយប់នេះ?»

តា៖ «អើ! តាមិនភ្លេចទេ តោះពន្លត់ចង្កៀងផងយាយវា ខ្លាចឆាប់អស់ភ្លើង» តានិយាយចប់ មនោរា បានចូលទៅក្នុងមុងហើយសម្លឹងមើលទៅបង្អួចដែលកំពុងបើកចំហមានពន្លឺព្រះច័ន្ទភ្លឺថ្លាចែងចាំងចូលមកក្នុងផ្ទះ។ មនោរា សម្លឹងមើលមុខតា ហើយដាក់ក្បាលរបស់នាងកើយលើដៃយាយ រួចនាងក៏ចាប់ផ្តើមសួរទៅតា។

មនោរា៖ «តា! តើរាល់ថ្ងៃនេះ តា និងយាយ រស់យ៉ាងម៉េចដែរ បន្ទាប់ពីបានឆ្លងកាត់រឿងរ៉ាវពីរបបខ្មែរក្រហមហើយ?»

តា៖ « មនោរា ចៅសម្លាញ់ចិត្តតាអើយ! តាសប្បាយចិត្តណាស់ ដែលមានចៅស្រីម្នាក់ដ៏សែនឆ្លាត បែបនេះ។ តាសូមអរគុណដល់គុណបុណ្យ ដែលឯងបានកើតជាចៅតា»។ តាដកដង្ហើមធំ រួចហើយនិយាយបន្តទៀតថា «ការរស់នៅសព្វថ្ងៃនេះ ទោះបីជាមានសុខសន្តិភាព ប៉ុន្តែ តា មិនចង់ឲ្យចៅស្រីរបស់តាលំបាកទេ។ តាចង់ឲ្យចៅរៀនសូត្របានចប់សព្វគ្រប់មានការងារធ្វើ មានអនាគតល្អ។ តាក៏មិនចង់ឮពាក្យថាសង្គ្រាមដែរ។ នៅក្នុងរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃ តាតែងតែដេកមិនលក់បក់មិនល្ហើយជារៀងរាល់យប់ ព្រោះតាជួបការលំបាកខ្លាំងណាស់ រស់នៅវេទនាគ្រប់បែបយ៉ាង ទាំងផ្លូវកាយ និងផ្លូវចិត្ត ផលដំណាំហៀរហូរតែមិនអាចហូបបាន ការងារធ្វើមិនឈប់ដាក់កំហិតបង្ខំ ការសម្លាប់មនុស្សឃើញនៅនឹងមុខ ហើយតាក៏មិនដឹងថា គោលនយោបាយរបស់អ្នកដឹកនាំនៅជំនាន់ខ្មែរក្រហមចង់បានបែបណាបានជាធ្វើដូច្នោះ»។

មនោរា៖ «ចុះយាយវិញយ៉ាងម៉េចដែរសព្វថ្ងៃនេះ?»

យាយ៖ «យាយពិតជាពិបាកក្នុងការនិយាយជាងតាឯងទៅទៀត។ មានតែតាឯងម្នាក់គត់ដែលយល់អារម្មណ៍យាយ ព្រោះឪពុកម្តាយរបស់ឯង ត្រូវកងឈ្លបយកទៅសម្លាប់ ដោយសារតែការលួចបេះត្រសក់ហូប។ បន្ទាប់មក តាឯង ត្រូវទៅធ្វើការនៅកន្លែងឆ្ងាយៗ ហើយយាយនៅតែពីរនាក់ឯង។ កាលនោះ ឯងទើបតែមានអាយុប៉ុន្មានខួបទេ។ យប់មួយជាយប់ដែលយាយឈឺចាប់ខ្លាំងណាស់នៅពេលតាឯងមិននៅ។ ពេលនោះ ក្រុមឈ្លប ដើរយាមល្បាតពេលយប់។ វាបានឃើញយាយនៅតែម្នាក់ឯង ក៏បានចាប់រំលោភយាយ ។ យាយ ពិតជាឈឺចាប់ណាស់ ហើយរូបភាពថ្ងៃនោះ នៅតែជក់ជាប់នឹងកែវភ្នែករបស់យាយរៀងរហូត។ យាយ រឹតតែបារម្មណ៍ភ័យខ្លាចកងឈ្លបយកទៅសម្លាប់។ ណាមួយបារម្មណ៍ពីចៅនិង ប្តី។ យាយ ពិតជាមិនដឹងត្រូវធ្វើយ៉ាងម៉េចទេ។ ប៉ុន្តែសំណាងហើយដែលកងឈ្លបរំលោភយាយហើយ វាមិនយកយាយទៅសម្លាប់ដូចនារីផ្សេងៗទៀតនៅក្នុងភូមិ។ ពេលនោះ យាយសំពះសុំអង្វរករពួកកងឈ្លបទាំងនោះណាស់ តែពួកគេមិនព្រម» យាយនិយាយមិនទាន់ចប់ស្រួលបួលផង ក៏ស្រែកទ្រហោយំ មនោរា ក៏ជួយជូតទឹកភ្នែកឲ្យយាយ។ រួច យាយ និយាយបន្តទៀតថា «អីចឹងបានជាពេលខ្លះ យាយ ដល់ថ្នាក់ដេកយល់សប្តិទៀតក៏មានដែរ ព្រោះរឿងវ៉ាវទាំងអស់នេះនៅតាមលងបន្លាចយាយគ្រប់ពេលវេលា»។

មនោរា៖ «ចៅសុំទោសផងដែលឲ្យ យាយនិងតា រំឭករឿងទាំងអស់នេះ។ ចៅគ្រាន់តែចង់ដឹងថាតើការពិតវាយ៉ាងម៉េច។ បន្ទាប់ពីមានអ្នកស្រាវជ្រាវសរសេរចេញជាសៀវភៅប្រវត្តិសាស្ត្រមក តើការស្រាវជ្រាវនោះពិតដែរឬទេ ហើយថ្ងៃនេះ ចៅ បានរៀនសូត្រច្រើនណាស់ពីសាលា។ លោកគ្រូ បាននិយាយអំពីរឿងនេះដែរ។ អីចឹងយើងធាប់គេងទៅយាយតា។ ស្អែកយើង ងើបដុតដំឡូវទៀត។ ឥឡូវ រឿងវ៉ាវទាំងអស់នេះរំលងផុតហើយ»។

ការនិទានរឿងនៅយប់នោះ គឺជារឿងដែលគួរឲ្យខ្ពោចផ្សាបំផុតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមពីរនាក់ក្នុងចំណោមអ្នករស់រានមានជីវិតជាច្រើនលានអ្នកនៅក្នុងរបបខ្មែរក្រហម។ ការឈឺចាប់នៅតែជាស្រមោលតាមលងបន្លាចពួកគាត់គ្រប់ពេលវេលា។

មិនយូរប៉ុន្មាន មនោរា បានបញ្ចប់ថ្នាក់ទី១២ ហើយឡើងមករៀនបន្តនៅទីក្រុងភ្នំពេញ ដោយជ្រើសរើសយកមុខវិជ្ជាសង្គមកិច្ច នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ចប់

៥៧

រឿងស្រមោលអតីតកាល

អ្នកនិពន្ធ ៖ ហឺស ថេត

៥៧ ~ រឿង ស្រមោលអតីតកាល

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាពេលវេលាមួយដែលប្រជាជនខ្មែរគ្រប់រូបសប្បាយរីករាយនឹងថ្ងៃចូលឆ្នាំខ្មែរ ហើយប្រជាជន ក៏ទើបតែប្រមូលផលស្រូវបានដែរ។ ភាពសប្បាយរីករាយរបស់ប្រជាជនខ្មែរ ក៏រលត់បាត់មួយពព្រិចភ្នែកអស់ខ្ទេចខ្ទីគ្មានសល់ នៅពេលដែលក្រុមកុម្មុយនីសខ្មែរក្រហម ដណ្តើមបានអំណាចគ្រប់គ្រងប្រទេសកម្ពុជា។ កងទ័ពខ្មែរក្រហម បានចូលមកក្នុងទីក្រុងភ្នំពេញនៅវេលាម៉ោងប្រហែល ៩និង៣០នាទីព្រឹក ដោយមានកាន់អាវុធគ្រប់ដៃ ថែមទាំងបានទទួលការស្វាគមន៍ពីប្រជាជនយ៉ាងច្រើនកុះករ។ កងទ័ពខ្មែរក្រហមទាំងអស់ ស្លៀកសម្លៀកបំពាក់ឯកសណ្ឋានពណ៌ខ្មៅ និងពណ៌អាចម៍សេះដូចៗគ្នា។ កងទ័ពខ្មែរក្រហម ភាគច្រើនមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ។

បន្ទាប់ពី កងទ័ពខ្មែរក្រហម បានចូលមកដល់ទីក្រុងភ្នំពេញមិនបានប៉ុន្មានម៉ោងផង ក៏មានការប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ ផ្លាស់ទៅរស់នៅតាមជនបទ។ ខ្មែរក្រហម បានប្រាប់ប្រជាជនថា «អង្គការត្រូវការបោសសំអាតខ្មាំងនៅក្នុងទីក្រុងឲ្យអស់» ហើយថែមទាំងប្រាប់ទៀតថា «កងទ័ពអាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅក្នុងទីក្រុង ដែលអាចបណ្តាលឲ្យប្រជាជនមានគ្រោះថ្នាក់ដល់ជីវិត ដូច្នេះហើយ អង្គការតម្រូវឲ្យប្រជាជនចាកចេញពីផ្ទះមួយរយៈពេលសិន»។

បន្ទាប់ពីមានការប្រកាសដូច្នេះ ប្រជាជនម្នាក់ៗ បានរៀបចំសម្ភារនិងប្រមែប្រមូលសមាជិកក្រុមគ្រួសារចាកចេញយ៉ាងប្រញាប់ប្រញាល់។ គ្មាននរណាម្នាក់ ហ៊ានរឹងទទឹងមិនចាកចេញពីទីក្រុងឡើយ ព្រោះខ្លាចកងទ័ពខ្មែរក្រហម

ធ្វើបាប។ ប្រជាជនជាច្រើនពាន់គ្រួសារ បានចាកចោលពីទីលំនៅរបស់ខ្លួន សំដៅទៅទីជនបទ ដែលជាស្រុកកំណើតរបស់ខ្លួននិងតាមការចាត់តាំងរបស់ខ្មែរក្រហម។

ខ្ញុំឈ្មោះ ចាន់ មានអាយុ ១៦ឆ្នាំ កំពុងតែដើរញាប់ដៃញាប់ជើងដើម្បីចាកចេញពីទីក្រុងភ្នំពេញ សំដៅទៅស្រុកកំណើតរបស់ខ្ញុំយ៉ាងតក់ក្រហល់។ ខ្ញុំគ្មានយួរសម្ភារអ្វីជាប់ខ្លួននោះទេ ព្រោះខ្ញុំធ្វើដំណើរទៅរកឪពុកម្តាយរបស់ខ្ញុំនៅឯស្រុកកំណើត។

មុនខ្មែរក្រហមឡើងកាន់អំណាច ជីវភាពគ្រួសាររបស់ខ្ញុំជួបបញ្ហាលំបាកខ្លាំងណាស់ ទើបខ្ញុំសម្រេចចិត្តមករកកន្លែងធ្វើការនៅឯទីក្រុងភ្នំពេញ ហើយសូមជ្រកកោននៅវត្តអារាម។ នៅពេលកំពុងតែដើរក្នុងចំណោមមនុស្សជាច្រើនក្នុងពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ស្រាប់តែលេចចេញបុរសម្នាក់មកឈរនៅចំពីមុខខ្ញុំ ហើយសួរមកខ្ញុំថា៖

«ឯងគឺជាអ្នកណា? ហេតុអ្វីបានជាឯងមានរូបថតនេះនៅហ្នឹងឯង»? បុរសម្នាក់នោះសួរមកកាន់ខ្ញុំដោយទឹកមុខខឹងជាខ្លាំង។

«ខ្ញុំមិនដឹងទេ» ខ្ញុំឆ្លើយតបទៅវិញដូច្នេះ ព្រោះខ្ញុំដឹងព័ត៌មានខ្លះៗថាខ្មែរក្រហមនឹងសម្លាប់អ្នកចេះដឹង ឬមន្ត្រីពីរបបចាស់។

បុរសក្នុងរូបថតនោះគឺជាគ្រូរបស់ខ្ញុំ។ គាត់បានបង្រៀនខ្ញុំកាលពីពេលដែលខ្ញុំនៅមានអាយុប្រហែលជា ៥ឆ្នាំ។ ផ្ទះលោកគ្រូនៅក្បែរផ្ទះរបស់ខ្ញុំ ដូច្នោះហើយទើបខ្ញុំ និងគាត់ មានភាពជិតស្និទ្ធគ្នាខ្លាំង។ កាលខ្ញុំនៅពីតូច លោកគ្រូ តែងតែសួរខ្ញុំថា «តើខ្ញុំចង់ចេះអានអក្សរដែរទេ?»។ ចាប់ពីពេលនោះមកខ្ញុំក៏ចាប់ផ្តើមចេះអានអក្សរខ្មែរខ្លះៗ។ លោកគ្រូបង្រៀនខ្ញុំមិនបានយូរប៉ុន្មាន គាត់ក៏មកភ្នំពេញដើម្បីស្វែងរកការងារជាគ្រូបង្រៀននៅតាមស្ថាប័ននានា។ គាត់ក៏បានធ្វើការងារឲ្យទាហាន លន់ នល់ ដើម្បីរកលុយសម្រាប់ចិញ្ចឹមម្តាយកំសត់ ដែលមានវ័យជរានៅឯស្រុកកំណើត។ នៅពេលដែលគាត់មកនៅភ្នំពេញ គាត់បានឲ្យរូបថតរបស់គាត់មកខ្ញុំមួយសន្លឹក ដើម្បីអាចឲ្យខ្ញុំរកគាត់ឃើញពេលដែលខ្ញុំមករស់នៅទីក្រុង

ភ្នំពេញ។ រហូតដល់ពេលនេះហើយ ខ្ញុំនៅតែមិនដឹងថាគាត់នៅទីណានោះទេ។ ខ្ញុំបានសម្លឹងទៅបុរសដែលស្លៀកពាក់ខោអាវកងទ័ព ហើយមានកាំភ្លើងជាប់នឹងដៃដោយធ្ងល់ថា «ហេតុអ្វីបានជាកងទ័ពម្នាក់នោះស្គាល់លោកគ្រូរបស់ខ្ញុំដែរ»។ កងទ័ពម្នាក់នោះហាក់បីដូចជាមានគំនុំនឹងលោកគ្រូរបស់ខ្ញុំខ្លាំងណាស់។

«បើមិនមែនជារបស់ឯង តើវាជារបស់អ្នកណា?» កងទ័ពនោះសួរមកខ្ញុំម្តងទៀតដោយប្រើពាក្យសំដីឮខ្លាំងៗ។

«គឺខ្ញុំប្រាប់ហើយថាខ្ញុំមិនដឹងទេបើមិនជឿឆែកមើលទៅ» ខ្ញុំនៅតែនិយាយកុហកទៅកងទ័ពម្នាក់នោះ ព្រោះខ្ញុំមិនចង់ឲ្យលោកគ្រូដែលមានគុណចំពោះខ្ញុំត្រូវស្លាប់នោះទេ។ បន្ទាប់មកកងទ័ពម្នាក់នោះ បានចាប់យកកាបូបដាក់ខោអាវរបស់ខ្ញុំទៅឆែកមើលក្រែងមានរូបថតផ្សេងទៀត ប៉ុន្តែកងទ័ពនោះរកមិនឃើញអ្វីនោះទេ ហើយក៏ដើរទៅវិញបាត់ទៅ។

អស់រយៈពេល ២យប់ ៣ថ្ងៃកន្លងមកហើយ ដែលខ្ញុំនឹងប្រជាជនដទៃទៀតធ្វើដំណើរនិងសម្រាកនៅតាមផ្លូវបែបនេះ។ ខ្ញុំគិតថាប្រហែលគ្រប់រយៈ ៣ថ្ងៃ ខ្មែរក្រហមនឹងឲ្យខ្ញុំ និងប្រជាជនទាំងអស់ ត្រលប់ទៅទីក្រុងវិញ។ អ្វីៗមិនដូចការគិតរបស់ខ្ញុំនោះទេ ព្រោះការធ្វើដំណើរទៅមុខចេះតែបន្តឥតឈប់ឈរឡើយ។ ពេលចាកចេញពីទីក្រុងភ្នំពេញ ខ្ញុំសង្ឃឹមថានឹងបានទៅជួបឪពុកម្តាយរបស់ខ្ញុំនៅឯស្រុកកំណើត ក្នុងខេត្តកំពង់ធំ ដូច្នេះហើយខ្ញុំមិនបានយកសម្ភារអ្វីមកតាមខ្លួនទេ។ នៅពេលធ្វើដំណើរ ខ្ញុំបានឮកងទ័ពខ្មែរក្រហមនិយាយគ្នាថា នឹងឲ្យប្រជាជនទាំងអស់ទៅរស់នៅកន្លែងដែលអង្គការជាអ្នករៀបចំឲ្យ។ ខ្ញុំអស់សង្ឃឹមណាស់ពេលដែលឮដូច្នោះ។

មិនយូរប៉ុន្មាន ខ្ញុំក៏មកដល់កន្លែងដែលអង្គការរៀបចំឲ្យស្នាក់នៅ។ មុននឹងអង្គការអនុញ្ញាតឲ្យប្រជាជនចូលទៅកន្លែងស្នាក់នៅ ក្រុមកងទ័ព បានឲ្យយើងឈរតម្រង់ជួរដើម្បីឆែកឆេរមើលអីវ៉ាន់សិន។ កងទ័ពទាំងអស់នោះ បានប្រមូលយកនូវទ្រព្យសម្បត្តិមានតម្លៃរបស់ប្រជាជនទាំងមាសពេជ្រ កងដៃ កងជើង ខោអាវល្អៗ និងសម្ភារជាច្រើនទៀតទុក ហើយអនុញ្ញាតឲ្យប្រជាជនទាំងអស់

យកតែខោអាវទៅតាមខ្លួនតែមួយសម្រាប់ជាប់នឹងខ្លួនតែប៉ុណ្ណោះ។ ចំណែកឯប្រជាជនខ្លះទៀតដែលធ្លាប់បម្រើឲ្យរាជការ លន់ នល់ ត្រូវកងទ័ពខ្មែរក្រហមចាប់ខ្លួន ហើយយកទៅសម្លាប់ចោល។

នៅក្នុងសម័យខ្មែរក្រហម មានការបែងចែកប្រជាជនជាពីរប្រភេទ គឺប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន។ ប្រជាជនថ្មី គឺជាប្រជាជនដែលខ្មែរក្រហមជម្លៀសចេញពីទីក្រុង ឬទីប្រជុំជននានាក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ ខ្មែរក្រហម បានចាត់ទុកប្រជាជនថ្មីថាជាពួក ១៧មេសា និងជាប្រជាជនបញ្ញើក្អែក។ ចំណែកឯ ប្រជាជនមូលដ្ឋានវិញ គឺជាប្រជាជនដែលរស់នៅទីតាំងនោះយូរមកហើយ។ ខ្ញុំ គឺជាប្រជាជនថ្មី ព្រោះខ្ញុំទើបតែជម្លៀសមកដល់ថ្មីៗនេះ។ នៅពេលដែលយើងមកដល់កន្លែងស្នាក់នៅ កងទ័ពខ្មែរក្រហម បានឲ្យយើងយកខោអាវទៅជ្រលក់ជាពណ៌ខ្មៅទាំងអស់ ហើយចែកក្រមាពណ៌ក្រហមឲ្យមកយើងម្នាក់មួយៗ ទៀត។

ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរក្នុងរបបខ្មែរក្រហមពិតជាលំបាកណាស់។ កុមារត្រូវអង្គការឲ្យទៅធ្វើការនៅក្នុងកងកុមារ និងជាអ្នកកាន់អាវុធសម្រាប់ធ្វើសង្គ្រាម។ ចំណែកមនុស្សចាស់វិញ មាននាទីមើលថែទាំទារកដែលទើបនឹងកើត មើលសត្វពាហនៈ និងត្បាញកន្ត្រែងល្អីជាដើម។ ចំពោះមនុស្សប្រុសស្រីពេញកម្លាំងដែលមានអាយុចាប់ពី ១៤ឆ្នាំឡើងទៅ អង្គការប្រើឲ្យទៅកាប់ដី រែកដី លើកប្រព័ន្ធភ្លឺស្រែ លើកទំនប់ ជីកប្រឡាយ កាប់ឈើធ្វើផ្ទះ និងធ្វើស្រែ។ ការងារនីមួយៗមានការកំណត់គោលដៅច្បាស់លាស់។ ប្រសិនបើយើងធ្វើមិនបានសម្រេចតាមគោលដៅរបស់អង្គការទេ យើងនឹងទទួលទោសឬត្រូវអង្គការចោទថាជាជនក្បត់អង្គការ។ ប្រជាជនម្នាក់ៗត្រូវធ្វើការងារជាង ១២ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍។ យើងមិនដែលទទួលបានអាហារគ្រប់គ្រាន់នោះទេ។ ប្រជាជនទាំងអស់ត្រូវធ្វើការរួម ហូបរួម រស់នៅរួម និងចែករំលែកការកម្សាន្តជាសមូហភាពដោយគ្មានអ្នកមាននិងអ្នកក្រឡើយ។

អំឡុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ខ្មែរក្រហម បានឲ្យកុមារទៅធ្វើសង្គ្រាម ជាមួយនឹងកងទ័ពវៀតណាមនៅសមរភូមិមុខ ដោយគ្មានការរៀនសូត្រអំពីការធ្វើសង្គ្រាមបានត្រឹមត្រូវឡើយ។ កុមារជាច្រើនបានស្លាប់នៅក្នុងសមរភូមិ។ មិនតែប៉ុណ្ណោះ កុមារត្រូវខ្មែរក្រហមបណ្តុះមនោគមន៍ឲ្យបម្រើស្មោះស្ម័គ្រនឹងអង្គការ និងមិនលើកលែងឲ្យនរណាម្នាក់ឡើយ សូម្បីតែឪពុកម្តាយឬសាច់ញាតិរបស់ខ្លួន។

ថ្ងៃមួយ ម៉ោងប្រហែល ១រំលងអាធ្រាត កុមារីម្នាក់ឈ្មោះ ធារី ដែលមានអាយុត្រឹមតែ ៧ឆ្នាំប៉ុណ្ណោះ បានរាយការណ៍ពីឪពុកម្តាយរបស់នាងទៅប្រាប់អង្គការ។ ធារី បានរកឃើញរូបថតរបស់ឪពុកនាង ដែលបានថតជាមួយនឹងទាហានលន់ នល់ និងករណីដែលម្តាយរបស់នាង បានលួចអង្ករមួយក្តាប់ដើម្បីយកឲ្យយាយរបស់នាង ដែលកំពុងតែដេកឈឺនៅផ្ទះ។ ធារី បានរាយការណ៍ទៅអង្គការថា ម្តាយឪពុករបស់នាងមិនស្តាប់បញ្ជារបស់អង្គការនោះទេ។

«ប្រធានយឺន! ខ្ញុំបានឃើញរូបថតនេះនៅនឹងខោអាវរបស់ឪពុកខ្ញុំកាលពីព្រឹកមិញនេះ ហើយនេះគឺជាអង្ករដែលម្តាយរបស់ខ្ញុំលួចយកទៅឲ្យយាយរបស់ខ្ញុំ» ធារីរាយការណ៍ទៅប្រធានយឺនពីឪពុកម្តាយរបស់នាង។

ក្រោយពីស្តាប់ ធារី រាយការណ៍រួចហើយ ប្រធានយឺន មិននៅបង្អង់យូរឡើយ ក៏ដើរសំដៅទៅចាប់ ឪពុកម្តាយរបស់ ធារី ភ្លាម។ ម្តាយឪពុករបស់ ធារី បាននិយាយអង្វរប្រធានយឺនថា៖

«ឱ!លោកប្រធានអើយ សូមជួយយោគយល់ពួកខ្ញុំទាំងពីរនាក់ផងទៅ»។ ឪពុកម្តាយរបស់ ធារីនិយាយមិនទាន់នឹងចប់ផង ស្រាប់តែ ប្រធានយឺន និយាយគំហកទៅវិញខ្លាំងៗថា៖

«យើងមិនខ្វល់នោះទេ ពួកឯងមិនបានស្តាប់តាមសម្តីរបស់អង្គការ ដូច្នេះពួកឯងទាំងពីរសមតែស្លាប់»។

ប្រធានយឺន និយាយរួចហើយក៏បញ្ជាឲ្យ ធារី សម្លាប់ឪពុកម្តាយរបស់នាងថា «ធារីឯងសម្លាប់ពួកវាឲ្យអស់ទៅ! លឿនឡើង បើឯងមិនធ្វើឯងនឹងត្រូវមានទោស»។

ធារី មិនដឹងធ្វើយ៉ាងណានោះទេ ព្រោះម្ខាងជាម្តាយឪពុក និងម្ខាងទៀត គឺជាអង្គការ ដែលបានជួយខ្លួនឲ្យមានបាយហូបរាល់ថ្ងៃ។ ធារី គិតបានមួយសន្ទុះ ក៏បានទាញកាំបិតមកអាករម្តាយ និងឪពុករបស់នាងដោយមិនអាល័យសោះ។

យប់មួយមនុស្សម្នាបានដេកលង់លក់យ៉ាងស្ងៀមស្ងាត់ដោយសារតែអស់កម្លាំង ដោយឡែកនៅតែខ្ញុំម្នាក់ប៉ុណ្ណោះ ដែលនៅមិនទាន់ដេក ព្រោះក្រពះរបស់ខ្ញុំវាកូរមិនឈប់សោះ។ កាលពីពេលថ្ងៃ ខ្ញុំបានហូបបបរសមួយវែកតែប៉ុណ្ណោះ។ ខ្ញុំទ្រាំនឹងភាពឃ្លាននេះមិនបាន ក៏សម្រេចចិត្តចុះទៅរកមើលអ្វីហូបនៅខាងក្រៅផ្ទះ។ ខ្ញុំបានដើរទៅក្នុងចម្ការពោត ហើយបេះផ្លែពោតមួយផ្លែយកមកហូបទាំងឆៅ។ ថ្ងៃទីមួយ ដែលខ្ញុំបានចូលលួចបេះពោតហូបនោះ គ្មានអ្នកណាឃើញខ្ញុំឡើយ ហើយថ្ងៃក្រោយមកទៀត ខ្ញុំក៏ចាប់ផ្តើមចេញទៅលួចពោតទៀតនៅពេលដែលខ្ញុំឃ្លាន។ ប៉ុន្តែមានថ្ងៃមួយនោះសំណាងមិនល្អ ខ្ញុំត្រូវកងឈ្លបចាប់បាន។

កងឈ្លបស្រែកថា «អ្នកណាគេនៅទីនោះ! ឆាប់ចេញមកបើមិនចង់ឲ្យយើងទៅអូសក្បាលឯងដោយខ្លួនឯងនោះទេ»។

នៅពេលនោះ ខ្ញុំភ័យខ្លាំងណាស់មិនដឹងធ្វើយ៉ាងណានោះទេ។ ប្រសិនបើខ្ញុំរត់ គឺមានតែស្លាប់ ប៉ុន្តែបើខ្ញុំបង្ហាញខ្លួន ក៏ខ្ញុំត្រូវស្លាប់ដែរ។ ខ្ញុំសម្រេចចិត្តបង្ហាញខ្លួន ព្រោះខ្ញុំគិតថាបើយើងធ្វើខុសត្រូវហ៊ានទទួលការពិត។ ពេលនោះខ្ញុំក៏ចេញមកជួបនឹងកងឈ្លប។

«គឺខ្ញុំ» ខ្ញុំនិយាយអោក់អ្ឿល ព្រោះខ្ញុំភិតភ័យពេក។

មិត្តជា សួរមកខ្ញុំថា «ហេតុអីបានជាមកនៅទីនេះ! ឯងមកលួចបេះពោតមែនទេ? ឯងឆាប់យកវាមកនេះ លើកនេះ ខ្ញុំជាអ្នកចាប់ឯងបានគិតថាខ្ញុំជួយឯងទៅចុះ តែលើកក្រោយកុំធ្វើបែបនេះទៀត ព្រោះបើមានអ្នកផ្សេងគេឃើញ ឯងនឹងត្រូវស្លាប់ហើយ។ សំណាងហើយដែលជាខ្ញុំនោះ ទៅឆាប់ទៅដេកវិញទៅ»។

«អរគុណណាស់ មិត្តបង» ខ្ញុំអរគុណទៅកាន់គាត់ភ្លាមៗជាមួយអារម្មណ៍សប្បាយរីករាយស្ទើរតែហោះ រួចខ្ញុំដើរយ៉ាងប្រញាប់ប្រញាល់មកកន្លែងដេកវិញ។

ការងាររបស់ខ្ញុំនាពេលនោះមានច្រើនណាស់ រួមមាន រែកដី ជីកប្រឡាយ និងធ្វើការនៅការដ្ឋាន។ ថ្ងៃមួយ ខ្ញុំឃើញក្មេងប្រុសមួយក្រុម ខ្ញុំក៏បានចូលទៅសួរ។

ចាន់៖ «អេ!ពួកឯងមកធ្វើអីនៅទីនេះ? មិនខ្លាចគេចាប់ពួកឯងទៅសម្លាប់ទេអី?»

«គ្មានអ្នកណាឃើញទេបង»ក្មេងម្នាក់ក្នុងចំណោមក្មេងប្រុសបួននាក់ឆ្លើយតបមកវិញ។

ចាន់៖ «ហើយពួកឯងនាំគ្នាធ្វើអី?»

«កំពុងចាប់សត្វល្អិត ដូចជា ក្អែប ពស់ កណ្តុប ហ្នឹងណា ព្រោះពួកខ្ញុំឃ្លានណាស់បង» ក្មេងប្រុសនោះនិយាយមកគួរឲ្យអាណិតណាស់ ព្រោះពួកគេមិនដែលមានអ្វីហូបនោះទេ រួចនិយាយបន្ថែមទៀតថា «បងសាកហូបទេ?»។ ខ្ញុំទទួលសត្វល្អិតពីក្មេងប្រុសម្នាក់ ហើយក៏ដាក់ចូលក្នុងមាត់ទំពាយ៉ាងអោ តែពេលហូបទៅមានអារម្មណ៍ឆ្ងាញ់ដែរ ក៏សុំពីពួកគេមកហូបថែមទៀត។

បន្ទាប់មកមានមនុស្សម្នាក់មកដល់ ក៏ស្រែកសួរយើងថា «ពួកឯងទាំងប្រាំនាក់កំពុងធ្វើអី? នេះពួកឯងមកលួចស៊ីអី? មកនេះពួកឯងទាំងអស់គ្នានឹងត្រូវមានទោសពីបទលួចលាក់នឹងអង្គការ»។ មនុស្សម្នាក់នោះ បានចាប់យើងវាយក្នុងម្នាក់ ១០ដំបង ហើយនិយាយគំរាមទៀតថា «បើយើងដឹងថាពួកឯងលួចស៊ីអីម្តងទៀត ពួកឯងនឹងត្រូវស្លាប់ជាខ្មោចយាមទីនេះជាមិនខានទេ»។

យប់មួយ ខ្ញុំបានឃើញកងឈ្លបដើរចូលទៅក្នុងផ្ទះ។ ថ្ងៃនោះ ខ្ញុំបានទៅលួចស្តាប់ឮពួកគេនិយាយគ្នាថា៖

«មិត្តយឿន អង្គការឲ្យយកទៅកសាង» ខ្ញុំមិនយល់ពាក្យដែលបុរសម្នាក់នោះនិយាយទេ ប៉ុន្តែខ្ញុំបានឮអឺស្រីម្នាក់យំ។ ហេតុតែធ្ងល់ពេក ទើបខ្ញុំលួចដើរទៅតាមស្តាប់ពួកគេ។ ភ្លាមៗនោះ ពួកគេឈប់ដើរ ហើយក៏ទាញកាំបិតមកអាករ មិត្តយឿនស្លាប់ភ្លាមៗ។ ខ្ញុំភ័យពេកក៏ដើរត្រលប់ទៅផ្ទះវិញយ៉ាងលឿន ប៉ុន្តែរំពេចនោះ មានមនុស្សម្នាក់មកចាប់ខ្ញុំពីក្រោយ។ ខ្ញុំភ័យស្ទើរតែដួលទៅនឹងដី ប៉ុន្តែពេលងាកមកមើលក៏ឃើញ មិត្តរស់។ មិត្តរស់បានសួរមកខ្ញុំថា «នេះឯងមកធ្វើអីនៅទីនេះ មិនដឹង

អីទេថាកន្លែងនេះជាកន្លែងហាមឃាត់មិនឲ្យមាននរណាមកជាជាច់ខាត»។ ខ្ញុំបានឆ្លើយតបទៅវិញថា «គឺខ្ញុំមិនដឹង ក៏ដើរមកឲ្យដឹងនឹងហើយ»។ មិត្តរស់និយាយថា «យើងប្រាប់ឯងចុះ ព្រោះយើងមកនៅទីនេះយូរជាងឯង។ កាលដែលអង្គការប្រើពាក្យថាយកទៅកសាងនេះ គឺមានន័យថា អង្គការយកទៅសម្លាប់ចោលហើយ»។ និយាយចប់ ពួកយើងក៏ត្រលប់មកផ្ទះវិញរៀងៗខ្លួន។

ថ្ងៃស្អែកឡើង ពួកយើង ត្រូវអង្គការចាប់ឲ្យឈរជាជួរយ៉ាងវែង ដោយមានបុរសមួយជួរនឹងនារីមួយជួរ។ ពេលនោះ ខ្ញុំមិនដឹងថាអង្គការចង់ឲ្យយើងធ្វើអ្វីនោះទេ។ ប្រធានអង្គការ បានមកដល់ ហើយនិយាយថា៖

«ថ្ងៃនេះ អង្គការ បានឲ្យពួកឯងរៀបការហ្នឹងគ្នា ដោយមានជាក់រៀបឈរជាជួរៗ។ ប្រសិនបើពួកឯងឈរចំអ្នកណាដែលនៅទល់មុខគ្នា ហើយពេលអង្គការបើកក្រណាត់នោះមក អ្នកនោះហើយគឺជាប្រពន្ធ ឬប្តីរបស់ពួកឯង»។

ខ្ញុំឈរនៅចំជួរខាងមុខគេបង្អស់។ នៅពេលដែលអង្គការបានបើកក្រណាត់មក ខ្ញុំរីករាយណាស់ពេលបានឃើញប្រពន្ធរបស់ខ្ញុំ គឺជានារីដ៏ស្រស់ស្អាតម្នាក់។

បន្ទាប់មក អង្គការ និយាយថា «បានហើយពួកឯងបានឃើញដៃគូរបស់ពួកឯងហើយ ដូច្នេះពួកឯងត្រូវរៀបការឥឡូវនេះដោយប្តេជ្ញាថា ស្មោះស្ម័គ្រនិងបម្រើអង្គការរហូតតទៅ»។

គូស្នេហ៍ទាំងអស់ យល់ព្រមនិយាយតាមពាក្យដែលប្រធានអង្គការម្នាក់នោះណែនាំ។ ខ្ញុំក៏នឹកអាណិតដល់គូខ្លះដែលបានប៉ះចំជនពិការ។ ចំណែកឯ គូស្នេហ៍របស់ខ្ញុំវិញ យើងពេញចិត្តនឹងរស់នៅជាមួយគ្នាទៅវិញទៅមក។ បន្ទាប់ពីរៀបការរួច ពួកខ្ញុំ ត្រូវបានអង្គការឲ្យរស់នៅជាមួយគ្នាចំនួន ៣ថ្ងៃតែប៉ុណ្ណោះ។ បន្ទាប់មក អង្គការបានឲ្យយើងទៅធ្វើការងាររៀងៗខ្លួន។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ធឿន។ យើងស្រលាញ់គ្នាណាស់។ ទោះបីជា យើងរៀបការក្នុងរបបមួយដែលព្រៃផ្សៃក៏ដោយ ក៏ពួកយើងសុខចិត្តរស់នៅជាមួយគ្នារហូតដល់ចាស់កោងខ្នងដែរ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហម បានដួលរលំ ហើយប្រជាជនម្នាក់ៗបានត្រលប់ទៅរកក្រុមគ្រួសាររៀងខ្លួនវិញ។ រយៈពេល ៣ឆ្នាំ ៨ខែ

២០ថ្ងៃនេះ បានធ្វើឲ្យប្រជាជនគ្រប់ស្រទាប់វណ្ណៈបាក់ស្បាតយ៉ាងខ្លាំង។ទោះបីជាយើងរួចផុតពីរបបខ្មែរក្រហមក៏ដោយ ប៉ុន្តែរបបនេះ បានបន្សល់ទុកកុមារកំព្រា ជនពិការ ស្ត្រីមេម៉ាយ និងចាស់ជរា ដែលឈឺពុំរ៉ែជាច្រើននាក់ទៀត ឲ្យនៅតស៊ូអត់ធ្មត់នឹងជីវិតដ៏សែនលំបាកលំបិន។

នេះជារឿងរ៉ាវជីវិតរបស់ ចាន់ នៅក្នុងរបបខ្មែរក្រហម ដែលបានរៀបរាប់ប្រាប់ដល់កូនស្រីរបស់គាត់ឈ្មោះ ទេវី បន្ទាប់ពី ទេវី បានទទូចស្នើសុំចង់ដឹងពីជីវិតម្តាយរបស់នាងនៅក្នុងរបបខ្មែរក្រហម។

ចប់

៥៨

រឿង អង្គការ ចោរប្លន់

អ្នកនិពន្ធ ៖ ក្រូច លីហ៊ាន់

៥៨ ~ រឿង អង្គការចោរប្លន់

កងទ័ពដែលត្រូវបាញ់សម្លាប់

មុនពីរថ្ងៃ ពេលដែលកងទ័ពរំដោះខ្មែរក្រហម ទទួលបានជ័យជម្នះលើរបប សាធារណរដ្ឋខ្មែរ ដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ នៅកណ្តាលទីក្រុង ភ្នំពេញ បានកើតចលាចល ហើយមន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ដែល ធ្លាប់តែហឺហា ចាប់ផ្តើមភ័យខ្លួន។ អ្នកខ្លះរត់ចោលតួនាទី ហើយអ្នកខ្លះទៀត រៀបចំបង្វេចរត់ឡើងយន្តហោះ ចាកចោលមាតុភូមិជាទីស្នេហា។

ក្នុងថ្ងៃដដែលនោះ នៅភូមិទន្លៀង ឃុំរមាំងថ្កោល ស្រុកស្វាយទាប ខេត្ត ស្វាយរៀង សំឡេងគ្រាប់កាំភ្លើងលាន់ឮកងរំពងបណ្តាក់បន្តគ្នាឥតដាច់សូរ ចាប់តាំងពីម៉ោង៤ទៀបភ្លឺ។ ឪពុកម្តាយរបស់ខ្ញុំនិងអ្នកភូមិផ្សេងទៀត ឱបកូនចៅ ពួនសំងំនៅក្នុងផ្ទះគ្រប់ៗគ្នាមិនហ៊ានចេញមកក្រៅមើលហេតុការណ៍ដែលកំពុង តែកើតឡើងឡើយ។

លុះដល់ព្រឹកព្រហាមថ្ងៃរះឡើង សូរគ្រាប់កាំភ្លើង ដែលបានបាញ់គ្នាដណ្តើម ជ័យរវាងកងទ័ពខ្មែរក្រហម និងទាហាន លន់ នល់ នោះក៏ស្ងាត់សូន្យវិញ។ នៅត្រង់ចំណុចស្ពានទន្លៀង (ស្ពានតាលៀង) មានសេសសល់សំណល់សម្បក គ្រាប់កាំភ្លើងជាច្រើនស្អេកស្កះ ថែមទាំងមានសាកសពកងទ័ពខ្មែរក្រហម និង ទាហាន លន់ នល់ មួយចំនួនទៀតស្លាប់យ៉ាងអាណោចអាធ័ម។

ទាហាន លន់ នល់ ម្នាក់ ដែលអ្នកស្រុកស្គាល់អត្តសញ្ញាណយ៉ាងច្បាស់ថា ជាអ្នកមានស្រុកកំណើតនៅភូមិភាគបូព៌ា បានដេកស្លាប់ក្នុងថ្ពុកឈាមគួរឲ្យរន្ធត់

ជាពន់ពេក។ សាកសពទាហានម្នាក់នោះដេកស្លាប់ផ្កាប់មុខ ជើងម្ខាងនៅលើស្ពាន និងជើងម្ខាងទៀតធ្លាក់យោលយោកសំយ៉ុងចុះក្រោម ហើយមានឈាមហូរប្រឡាក់អាវស្ទើរពេក់កណ្តាលខ្លួន។ ដៃរបស់សាកសពកាន់កាំភ្លើងជាប់ ហើយគ្រាន់តែផ្ងារមុខសាកសពរបស់ទាហាននោះឡើងភ្លាម ស្រាប់តែមនុស្សគ្រប់គ្នានៅទីនោះស្រងាកចិត្តរួចលាន់មាត់ថា៖

«អ្ហាក!! នេះ បងយោ នៅបាវិតទេតើ»។

ប្រជាជនម្នាក់ៗមានទឹកមុខតក់ស្លុតជាអនេកនៅពេលបានឃើញសភាពការណ៍បែបនេះ។ គ្រាប់កាំភ្លើងរបស់ក្រុមខ្មែរក្រហម បានបាញ់មកចំត្រង់សៀតផ្តាខាងឆ្វេងរបស់ បងយោ។ សាកសពទាហានដទៃទៀត មានប្រឡាក់ឈាមក្រហមឆ្អិនឆ្អៅដេកស្តូកស្តឹងពាសពេញដី។ សាកសពខ្លះត្រូវគ្រាប់កាំភ្លើងទម្លុះចំកណ្តាលថ្ងាស សាកសពខ្លះធ្លាយពោះ ហើយសាកសពខ្លះទៀតត្រូវគ្រាប់ចំកណ្តាលដើមទ្រូង។ ប្រហែលជាមួយម៉ោងក្រោយមក ឡានដំរីទឹកសម្រាប់ដឹកទាហាន ដែលបើកបរដោយបុរសវ័យប្រមាណជាសែសិបឆ្នាំម្នាក់ មានស្លៀកពាក់ឯកសណ្ឋាន និងជានាយទាហានរបស់ លន់ នល់ បានបើកមកដល់។ មនុស្សម្នាជាច្រើន បានមកចោមរោមមើលយ៉ាងច្រើនដេរដាសនៅលើស្ពានទន្លៀង។ ក្មេងៗស្រែកយំក្រោយពីបានមើលឃើញរូបភាពមនុស្សស្លាប់ពីការប្រយុទ្ធនេះ។ សាកសពរបស់ទាហាន លន់ នល់ ទាំងអស់ត្រូវអ្នកភូមិនាំគ្នាជួយសែងម្តងមួយៗដាក់លើឡាន។ រីឯសាកសពរបស់កងទ័ពខ្មែរក្រហម ត្រូវអ្នកភូមិចាប់អូសដូចខ្មោចសត្វយកទៅដាក់គរជាគំនរលើគ្នារួចដុតចោលនៅកណ្តាលវាលស្រែ។ ឡានដំរីទឹកដឹកសាកសព បានបើកទៅមុខយឺតៗលើកំណាត់ផ្លូវជាតិលេខ១ តម្រង់ទៅទិសខាងកើតឥតងាកក្រោយឡើយ។ ឡានដីរីទឹកនៅតែបន្តដំណើរនៅមុខតិចៗឥតឈប់ឈរម្តងឆ្ពើងទៅឆ្វេងម្តងឆ្ពើងទៅស្តាំតាមស្ថានភាពផ្លូវខូចខាត។ នៅពេលដែលឡានដំរីទឹកបានបើកមកដល់ ភូមិតាបឹបឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង ក៏បានកំពុងបើកបរចូលទៅក្នុងភូមិ ធ្វើឲ្យអ្នកភូមិគ្រប់គ្នាបែរភ្នែកក្រឡេកមើល។ ស្ត្រីវ័យប្រហែល ៣០ឆ្នាំ ស្លៀកសំពត់បត់

ពណ៌ទឹកបិកក្រម៉ៅ និងអាវប៉ោងស្មាដៃត្រឹមកែងខំរត់ចុះពីលើផ្ទះប្រក់ក្បឿងមួយ។ នៅក្នុងដៃរបស់ស្ត្រីនោះ មានពក្មេងស្រីម្នាក់អាយុប្រហែល ៤ឆ្នាំ ប្រកបដោយទឹកមុខញញឹមញញែម។ មិនយូរប៉ុន្មាន អ្នកបើកឡានបាននិយាយទៅកាន់ស្ត្រីនោះឡើងថា «ក្រាញ់! បងយោ ប្តីក្មួយឯងត្រូវកងទ័ពខ្មែរក្រហមបាញ់ស្លាប់ហើយ!» ជីដូនមួយរបស់ខ្ញុំ ក៏សួរតបទៅវិញទាំងអារម្មណ៍រន្ធត់ថា «ថាម៉េចពូ ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមបាញ់ឬពូ?» ទាហាន លន់ នល់ នោះ ក៏បានឆ្លើយបញ្ជាក់ទៀតថា «អឺ! យោ ប្តីឯងហ្នឹងគេបាញ់ស្លាប់កាលពីព្រឹកមិញនេះនៅស្ពានទន្លៀងហើយឥឡូវ សាកសពពូដឹកមកហើយនៅខាងក្រោយនេះក្មួយ»។

គ្រានៃតែឮដំណឹងដ៏គួរឲ្យសង្វេគនេះភ្លាម ជីដូនមួយរបស់ខ្ញុំ ក៏ដាក់កូនស្រីពៅរបស់គាត់ចុះពីលើដៃរួចក៏ប្រញាប់រត់ឡើងទៅលើឡាន។ នៅពេលបានឃើញសាកសពប្តីជោកជាំដោយឈាម ជីដូនមួយរបស់ខ្ញុំស្រែកទ្រហោយំខ្លាំងៗ។ អ្នកភូមិក្បែរៗនោះ ក៏រត់ឈូឆរមកមើល។ សុគង់ ដែលជាកូនស្រីច្បងអាយុប្រហែល ៥ឆ្នាំរបស់ជីដូនមួយរបស់ខ្ញុំ បានឃើញហេតុការណ៍បែបនេះហើយក៏ប្រញាប់រត់មកប្រាប់ឪពុករបស់ខ្ញុំដែលកំពុងនៅខាងក្រោយផ្ទះ។

មិនបានមួយថ្ងៃពេញផង ស្រាប់តែឮវិទ្យុជាតិផ្សាយនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថា កងទ័ពខ្មែរក្រហម កាន់កាប់ទីក្រុងភ្នំពេញបានសម្រេច ហើយតទៅនេះ របបលន់ នល់ បានដួលរលំ ជំនួសដោយរបបកម្ពុជាប្រជាធិបតេយ្យ ចូលមកគ្រប់គ្រងប្រទេសជាតិវិញ។

ឃាតករជាន់ឈាន?

អ្វីៗផ្ទុយខុសស្រឡះពីការសង្ឃឹមទុកថាប្រទេសកម្ពុជានឹងទទួលបានសុខសន្តិភាពក្រោយពេលផ្លាស់ប្តូររបបដឹកនាំថ្មី។ ខេត្តស្វាយរៀង កងទ័ពខ្មែរក្រហមបានបង្ខំឲ្យប្រជាជនចុះចេញពីផ្ទះសំបែង ធ្វើដំណើរម្តងទៅនេះនិងម្តងទៅនោះដូចកៀងគោកៀងក្របីទៅតាមទំនើងចិត្ត។ គ្មានប្រជាជនណាម្នាក់ ហ៊ានហាមាត់ប្រឆាំងនឹងកងទ័ពខ្មែរក្រហមឡើយ។ ប្រសិនបើនរណាហ៊ានប្រឆាំង នោះនឹងមានឈ្មោះថាជាខ្មាំង ហើយវាសនាចុងក្រោយរបស់ខ្មាំង គឺគេចមិនផុតពីសេចក្តីស្លាប់ឡើយ។

គ្រួសាររបស់ខ្ញុំនិង ក្រាញ់ បានប្រមូលយករបស់មានតម្លៃមួយចំនួនទៅតាមខ្លួន រួមមាន ខ្សែកមាសទម្ងន់ ៥ជី ដែលជាចំណងដៃស្នេហាពីស្វាមីអកុ័ព្ធ និងនាឡិកាដៃចាស់មួយ។ សុគង់ គឺជាកូនស្រីច្បងនៅក្នុងគ្រួសារ ធ្វើជាអ្នកបររទេះដឹកចានឆ្នាំង និងអង្ករសម្រាប់ប្រើប្រាស់ហូបចុកប្រចាំថ្ងៃ។ លូ គឺជាកូនទី២ ជាអ្នកកាន់កន្ទេលមួយដើរតាមក្រោយរទេះឥតដាច់ឆ្ងាយឡើយ។ ចំណែក សុខា ដែលជាកូនស្រីពៅ អង្គុយលើអីវ៉ាន់ក្នុងរទេះ។ ទាំងបួននាក់ម្តាយនិងកូន ធ្វើដំណើរសំដៅទៅទិសខាងលិច។ នៅតាមបណ្តោយថ្នល់ជាតិលេខ១ មានមនុស្សម្នាជាច្រើនចាកចេញពីផ្ទះ ហើយមើលទៅក៏គ្មានគោលដៅដូចយើងដែរ។

យើងធ្វើដំណើរមកដល់មន្ទីរពេទ្យបង្អែកជីពូ មានចំងាយប្រមាណ ១៥គីឡូម៉ែត្រ ពីឃុំបាវិត។ ក្រាញ់ រន្ធត់ចិត្តជាពន់ពេកនៅពេលដែលឃើញអ្នកជំងឺរួយចំណាស់ ដែលត្រូវកូនចៅរុញលើរទេះចេញពីមន្ទីរពេទ្យទាំងអ្នកខ្លះនៅព្យួរសេរ៉ូមជាប់ដៃនៅឡើយ។ ចាស់ៗកោងខ្នងមួយចំនួនដែលដើរមិនរួចត្រូវកូនចៅឲ្យអង្គុយក្នុងរទេះដឹកអីវ៉ាន់ រួចអូសចេញទៅ។ សម្រែកស្រែកហៅចៅ លាន់ឮរងំនៅក្នុងហ្វូងមនុស្សស្រីប្រុសចាស់ក្មេងទាំងឡាយ។ ក្មេងៗខ្លះយំលាន់រំពង ព្រោះវង្វេងរកឪពុកម្តាយមិនឃើញ។

ដើរពេញមួយថ្ងៃទៅហើយ ក្រាញ់ នៅមិនទាន់ឃើញនរណាដែលខ្លួនស្គាល់សោះ។ ក្រាញ់ ដើរយូរៗទៅស្រាប់តែវង្វេងបាត់កូនប្រុសតែមួយរបស់គាត់។ ក្រាញ់ស្រែកខ្លាំងៗថា «លូ លូ! កូនឯងទៅណា?»។

ក្រាញ់ ស្រែកផងយំផង ដៃម្ខាងពកូនពៅជាប់នៅនឹងចង្កេះ។ ក្រាញ់ ខំស្រែកហើយស្រែកទៀត តែនៅតែរកមិនឃើញទាល់តែសោះ។ ក្រាញ់ ទាល់គំនិត ក៏បានស្រែកសួរគេសួរឯង ប៉ុន្តែគ្មាននរណាស្គាល់ឡើយ។ លុះ ក្រាញ់ ដើរបានទៅមុខប្រហែលកន្លះគីឡូម៉ែត្រ ស្រាប់តែឃើញកូនរបស់ខ្លួន។ សុគង់ ឃើញ ប្អូនហើយប្រាប់ម្តាយយ៉ាងត្រេកអរ ថា «ម៉ែៗ នោះអាអូនម៉ែ! វានៅពីក្រោយឡានគេនោះ»។

គ្រាន់តែ សុគង់ ប្រាប់ភ្លាម ក្រាញ់ ក៏ស្ទុះទៅភ្លែតទះកូនប្រុសពីរបីដៃខ្លាំងៗ រួចក៏ស្តីបន្តោសឲ្យជាច្រើន។ លូលូ មិនបានដឹងទាល់តែសោះថាម្តាយរបស់ខ្លួន

កំពុងស្រែកយំរក ដូច្នេះហើយក៏ធ្វើភ្នែកម៉ង់ៗដូចមិនដឹងរឿងអី។ បន្តិចក្រោយមក លូលូ និយាយប្រាប់ទៅម្តាយថា «ម៉ែ អម្បាញ់មិញ ខ្ញុំដើរតាមឡាននោះ ហើយក្លិនបំពង់ស៊ីមាំងឡាននោះក្រអូបណាស់ម៉ែ»។ ក្រាញ់និយាយទាំងខឹងផងអរផងថា «អើ! បើក្រអូបទៅតាមឡានគេទៅ កុំមកតាមអញ កូនពិបាកៗរបៀបហ្នឹង អញមិនចង់បានទេ»។

នឹកទៅហួសចិត្ត ក្រាញ់ក៏លាន់មាត់សើចម្នាក់ឯងទាំងកណ្តាលហ្វូងមនុស្ស។ ពីមួយថ្ងៃទៅមួយថ្ងៃ ក្រាញ់ និងកូនៗ ធ្វើដំណើរទៅមុខរហូត។ យប់នៅត្រង់ណា សម្រាកនៅត្រង់ហ្នឹង។ មកដល់ភូមិត្របែកប្រហោង ឃុំតាសួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដដែល ក្រាញ់ បានជួបនឹងបងប្អូនជីដូនមួយរបស់គាត់ឈ្មោះ ចូក និងចន។ ទៅដល់ភ្លាម ក្រាញ់ ត្រេកអរណាស់ ដែលបានជួប ចូក និងចន។ ចូក និងចន គឺជាបងប្អូនបង្កើតនឹងគ្នា។ ចូក គឺជាបងរបស់ចន ដែលទើបតែរៀបការហើយថ្មីៗ។ រីឯ ចន វិញ គឺជាគ្រូបង្រៀន និងមិនទាន់រៀបការទេ។ ពួកគាត់ បានសួរសុខទុក្ខគ្នាទៅវិញទៅមកយ៉ាងយូរ។

ចូក៖ «ចុះប្តី ក្រាញ់ ឯងទៅណាបានមិនឃើញ?» គ្រាន់តែឮសំណួរនេះ ក្រាញ់ ផ្លាស់ប្តូរទឹកមុខស្រងូតស្រងាត់ រួចក៏យំរៀបរាប់។

ក្រាញ់៖ «បង ចូក អ្ហើយ ឪសុគង់ ត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់ហើយ ស្លាប់ប៉ុន្មានថ្ងៃមុននេះឯង»។

ចូក៖ «អូហ៎ អាណិតគ្នាណាស់ ! បងឮគេខ្សឹបខ្សៀវគ្នាថា ពួកខ្មែរក្រហមអស់នោះស្អប់អ្នកនិយមពួកលោកសេរីណាស់ ជាពិសេសគឺ លន់ នល់ តែម្តង។ ថ្ងៃមុននោះ បងឃើញខ្មែរក្រហមបាញ់សម្លាប់ប្រពន្ធទាហាន លន់ នល់ ខ្មែរម្នាក់។ ទោះបីជាស្ត្រីនោះខំយំអង្វរយ៉ាងណា ក៏កងទ័ពខ្មែរក្រហមទាំងអស់នោះមិនស្រណោះដៃរហើយនិយាយថាបើជីកស្មៅត្រូវជីកទាំងឫស។ ក្រាញ់ឯងប្រយ័ត្នណា បើខ្មែរក្រហមសួរត្រូវនិយាយថាធ្វើស្រែទាំងពីរនាក់ប្តីប្រពន្ធ»។

ក្រាញ់ ភ័យណាស់ នៅពេលដែលបានស្តាប់សម្តី បងចូក រួចក៏សួរត្រលប់ទៅវិញ។

ក្រាញ់៖ «អីចឹង បងមានដឹងទេថា ពួកខ្មែរក្រហមនោះជានរណា? ហើយមកពីណាឲ្យប្រាកដទៅបង?»

ចូក៖ «បងក៏មិនដឹងច្បាស់ដែរថានរណាជាអ្នកបញ្ជា និងមកពីខាងណាទេ។ បងគ្រាន់តែដឹងថាពួកនេះ ជាអ្នកផ្តួលរំលំរបប លន់ នល់។ ដូចនេះ មនុស្សរបស់របប លន់ នល់ គឺជាមុខសញ្ញាទីមួយដែលវាត្រូវកម្ចាត់ចោល»។

ក្រាញ់៖ «ពុទ្ធោ ជាខ្មែរដូចគ្នាសោះ អីចឹងពួកវាហ្នឹងហើយ គឺជាឃាតករបាញ់សម្លាប់ប្តីរបស់ខ្ញុំ»។

និយាយបណ្តើរ ក្រាញ់ និងកូនៗ ព្រមទាំងបងជីដូនមួយ ក៏សម្រេចចិត្តធ្វើដំណើរទៅទិសខាងលិចទាំងអស់គ្នា។

អង្គការចោរប្លន់

ឃុំលាច ស្រុកភ្នំក្រវាញ ក្នុងទឹកដីខេត្តពោធិ៍សាត់ គឺជាលំនៅឋានចុងក្រោយរបស់ ក្រាញ់ និងកូនៗទាំងបីនាក់ ដែលបានផ្លាស់មករស់នៅតាមបញ្ជារបស់អង្គការ។ រីឯ ចូក ប្រពន្ធគាត់ និងចន រស់នៅឆ្ងាយពី ក្រាញ់ រំលងប្រហែលបួនប្រាំផ្ទះ។

រទេះរុញត្រូវគ្រែវែងចោលអស់គ្មានសេសសល់ សម្លៀកបំពាក់ពណ៌ឆើតឆាយដែល ក្រាញ់ ស្រលាញ់បំផុតនោះ ត្រូវកងទ័ពខ្មែរក្រហមដកយកទៅអស់។ សក់ម៉ូតស្តែក្តោបដែលពេញនិយមរបស់ក្រាញ់ និងស្ត្រីឯទៀតកាលពីជំនាន់នោះ ត្រូវអង្គការបង្ខំឲ្យកាត់ខ្លីត្រឹមកគ្រប់ៗគ្នា។ ពីមួយថ្ងៃទៅមួយថ្ងៃ របបអាហារកាន់តែខ្វះខាតទៅៗ ដែលធ្វើឲ្យក្រាញ់ធ្លាក់ខ្លួនឈឺរកដួលម្តងៗ ប៉ុន្តែក្រាញ់នៅតែខំប្រឹងធ្វើការងារដោយមិនហ៊ានតវ៉ាជាមួយអង្គការឡើយ។

ទោះជាជួបការលំបាកយ៉ាងណា ក្រាញ់ នៅតែខិតខំប្រឹងប្រែងរស់ដើម្បីកូនៗ។ ថ្ងៃមួយនៅរដូវច្រូតកាត់ចុងឆ្នាំ១៩៧៦ នៅកណ្តាលវាលស្រែក្រោមពន្លឺព្រះអាទិត្យក្តៅហែង ក្រាញ់ បានដួលផ្តាប់មុខលើពំនូកស្រូវដែលទើបនឹងច្រូតថ្មីៗ។ មនុស្សគ្រប់គ្នាបានត្រឹមតែឈរសម្លឹងមើល មិនមាននរណាម្នាក់ហ៊ានចូលមកជួយគ្រានោះទេ។ បន្តិចក្រោយមក ស្រាប់តែ សមមិត្តនារីយ៉ាន់ ដែលជាប្រធាន

កងនារី បានឃើញ ក្រាញ់ ដួលហើយក៏ដើរចូលមកជួយ។ មិត្តយ៉ាន់ គឺជាស្ត្រីកំព្រាដែលមានអាយុស្រករនឹង ក្រាញ់ ដែរ។ គាត់គឺជាប្រជាជនមូលដ្ឋានមានស្រុកកំណើតនៅក្នុងភូមិលាច។ មិត្តយ៉ាន់ មានចិត្តសប្បុរសនឹង ក្រាញ់ ណាស់។ យប់មួយ មិត្តយ៉ាន់ បានយកដំឡូងមួយប៉ុនកដៃមនុស្សចាស់មកឲ្យ ក្រាញ់ រួចនិយាយថា «ក្រាញ់ ឯងហូបទៅកុំឲ្យឈឺ ហើយកុំបារម្ភណ៍ពីកូនៗអី ពួកវាមិនអីទេ» និយាយរួច មិត្តយ៉ាន ក៏ដើរចេញទៅវិញស្ងាត់ៗ។

កន្លងហួសប្រហែល៦ខែ អង្គការ បានស៊ើបដឹងពីជីវប្រវត្តិពិតរបស់ ចន។ ល្ងាចឡើងម៉ោងប្រហែល៦ល្ងាច បន្ទាប់ពីអង្គការបានដឹងអំពីប្រវត្តិរបស់ ចន ឈ្លបជំទង់ៗបីនាក់ មានកាំភ្លើងគ្រប់ដៃ និងពីរនាក់ទៀតមានកាន់ចបជីកដើរសំដៅមកផ្ទះ ចូក។ ក្រាញ់ លួចមើលតាមប្រហោងជញ្ជាំងស្លឹកឃើញឈ្លប ៣នាក់ បណ្តើរចូក និងប្រពន្ធ និងចន ឲ្យដើរពីមុខដោយចងដាក់ដៃទៅខាងក្រោយខ្នង រួចដើរសំដៅទៅវាលស្រែព្រៃក្រោយផ្ទះ។ នៅម៉ោងមួយរំលងអធ្រាត្រ សភាពការណ៍ស្ងប់ស្ងាត់គួរឲ្យខ្លាច ក្រាញ់ កំពុងតែលង់លក់នៅលើគ្រែ ដែលមានភ្នែកហើមផង ព្រោះយំនឹកស្រណោះ ចូក ប្រពន្ធនិងចន។ បន្តិចក្រោយមក ក្រាញ់ ឮសំឡេងប្រឹបៗនៅជញ្ជាំងផ្ទះម្ខាង។ ក្រាញ់ ក្រឡេកមើលទៅឃើញ ចន មានក្បាលប្រឡាក់សុទ្ធតែឈាម។ ចន បានហែកជញ្ជាំងរួចលូនចូលមកខាងក្នុងផ្ទះ។ ក្រាញ់ ខ្លាចផងយំផងពេលឃើញក្បាលរបស់ ចន រលាត់ស្បែកចេញលលាដ៏។ នៅពេលដែលឃើញ ចន មានសភាពបែបនោះ ក្រាញ់ ស្ទុះទៅដកធាងគ្រាវទាំងយប់មកទំពាយ៉ាងម៉ដ្តប្រហែលមួយក្បង់ដៃ រួចបិតលើក្បាលរបស់ ចន ហើយទាញស្បែកក្បាលមកគ្របនិងយកក្រមារុំពីលើបន្ថែមទៀត។ នោះគឺជាពេលវេលាចុងក្រោយដែល ក្រាញ់ បានជួបនឹង ចន។

ចន និយាយទាំងឈឺចាប់ថា «ក្រាញ់ អ្ហើយ! បងចូក និងប្រពន្ធ ស្លាប់បាត់ហើយ គឺពួកខ្មែរក្រហមបីនាក់នោះវាយសម្លាប់។ ដំបូងវាបណ្តើរពួកបងចេញពីផ្ទះទៅដល់វាលឆ្ងាយណាស់ រួចវាឲ្យបងជីករណ្តៅកប់ខ្មោចខ្លួនឯង។ ពេលជីករួចវាឲ្យបងលុតជង្គង់ចុះរួចយកក្រណាត់ចងភ្នែក។ បងឮសំឡេង ផ្ទងៗ ខ្លាំងៗ គឺ

ពួកវាវាយចំកញ្ចឹងក។ បន្ទាប់មក វាវាយបងមួយត្បូងចបមួយទំហឹងរលាត់ស្បែកក្បាល។ ឈ្លបស្មានតែបងស្លាប់ហើយ វាក៏ចេញទៅវិញ។ បងគិតថាមិនរស់ទេ»។

ឮដូច្នោះ ក្រាញ់ យំផងនិយាយផង នឹកគិតពីសុវត្ថិភាពរបស់ខ្លួន និងចនខ្លាចក្រែងឈ្លបមកឃើញ ហើយនិយាយទាំងក្តីអាឡោះអាល័យថា «បងចន រត់ទៅបង រត់ទៅទិសខាងជើងណាបង កុំទៅនិរតី ព្រោះពួកនោះសាហាវណាស់ ខ្ញុំជួយបងមិនបានច្រើនទេ»។

និយាយរួច ក្រាញ់ ទៅយកផ្លែស្វាយ ដែលសមមិត្តនារីយ៉ាន់ ឲ្យពីល្ងាចឲ្យទៅ ចន។ ចន ក៏ចាកចេញទៅ។ ចាប់តាំងពីថ្ងៃនោះមក ចន បាត់ដំណឹងរហូត។

ចំណែក លូ និងសុខា ត្រូវអង្គការចាត់ឲ្យចូលក្នុងកងកុមារ និងមានតួនាទីដើររើសអាចម៍គោមកធ្វើជី។ រីឯ សុគង់ មានរូបរាងកាយតូចល្អិតត្រូវអង្គការតម្រូវឲ្យឃ្វាលគោ។ ថ្ងៃមួយ សុគង់ ឈឺពោះរាករូសមិនឈប់សោះរហូតដល់ស្គមរីងរៃ។ ពេលបានឮថា កូនស្រីឈឺ ក្រាញ់ ចេះតែរសាប់រសល់អាណិតកូន រួចក៏ដាច់ចិត្តយកនាឡិកាដៃចាស់ដែលបានរក្សាទុក ទៅដូរយកថ្នាំអាចម៍ទន្សាយពីអ្នកជិតខាងបានចំនួន ៣គ្រាប់ រួចក៏យកទៅឲ្យកូន។ នៅពេលលេបហើយ សុគង់នៅតែមិនបានធូរស្រាលអ្វីឡើយ។ ក្រាញ់ សម្រេចចិត្តសុំការអនុញ្ញាតពីប្រធានភូមិទៅមើលកូន ប៉ុន្តែប្រធានភូមិមិនអនុញ្ញាតឡើយ។ មិនតែប៉ុណ្ណោះ ប្រធានភូមិបាននិយាយគំរាមកំហែង ក្រាញ់ យ៉ាងខ្លាំង។ លុះដល់ល្ងាចបន្តិច ប្រធានកងនារីយ៉ាន់ បានមកជួប ក្រាញ់ ហើយនេះក៏ជាលើកចុងក្រោយរបស់ យ៉ាន់ ដែរ។ មិត្ត យ៉ាន់ និយាយលួងលោមកុំឲ្យ ក្រាញ់ ថា«កុំតវ៉ានឹងអង្គការអី បើអង្គការឲ្យធ្វើអីចេះតែធ្វើតាមហ្នឹងទៅ។ រីឯរឿងកូនចៅនៅកងកុមារ ពួកវាមិនអីទេ»។

នៅក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមកាន់តែកាចសាហាវទៅៗ និងមិនទុកចិត្តគ្នាឡើយ។ សមមិត្តនារី យ៉ាន់ ត្រូវប្រធានសន្តិសុខភូមិយកទៅកម្ទេចចោលដោយចោទថាជាឧនុកក្នុងរបស់ឃួន។ ក្រាញ់ ទើបតែដឹងអំពីរឿងវ៉ាវសម្លាប់របស់មិត្ត យ៉ាន់ ក្រោយខ្មែរក្រហមក៏ដួលរលំ។

រហូតមកដល់ចុងឆ្នាំ១៩៧៨ ប្រធានសន្តិសុខភូមិដែលជាមនុស្សកាចសាហាវរបស់អង្គការនៅពេលបានដឹងថាកងទ័ពវៀតណាមចូលមកកាន់តែកៀកក៏នាំប្រពន្ធកូនរត់ចេញពីភូមិទៅតំបន់ភាគខាងលិចភ្លាមមិនរង់ចាំយូរឡើយ។ ក្រាញ់បានឃើញសភាពការណ៍ខុសប្រក្រតី ព្រោះប្រជាជនខ្លះទូលបង្គំចមានស្រូវអង្ករដឹកដៃកូនចៅធ្វើដំណើរទៅទិសខាងកើត ឯប្រជាជនខ្លះទៀតមានដឹកស្រូវទាំងរទេះៗទុកធ្វើជាស្បៀងនៅតាមផ្លូវត្រលប់ទៅស្រុកវិញរៀងៗខ្លួនវិញ។ នៅពេលដែលដឹងថា របបខ្មែរក្រហម ដួលរលំភ្លាម ក្រាញ់ បានរត់ទៅរកកូនៗទាំងបីនាក់របស់ខ្លួនភ្លាម។ សុគង់ មានរូបរាងស្គម ព្រោះមានជំងឺ។ ចំណែកឯ លូលូ បានខំរត់ទៅយករទេះនិងគោបានមួយនឹមដែរ។ ក្រាញ់ ត្រេកអរណាស់។ ទាំងបួននាក់ម្តាយ និងកូន បានជិះរទេះគោពីឃុំលាច រហូតមកដល់ភ្នំពេញ។ សភាពនៅទីក្រុងភ្នំពេញ ត្រូវបានបំផ្លិចបំផ្លាញស្ទើរតែគ្រប់ទីកន្លែងទាំងអស់ដោយសារសង្គ្រាម។

មកដល់មុំផ្សារថ្មី ក្រាញ់ និងកូនៗ ចាប់យកបានផ្ទះថ្មមួយល្វែងកម្ពស់បីជាន់។ នៅក្នុងផ្ទះនោះមានសុទ្ធតែលាមកគួរឲ្យខ្ពើមគ្រប់ទីកន្លែង។ ក្រាញ់ និងកូនប្រុស ខិតខំបោសសម្អាតយ៉ាងស្អាត ប៉ុន្តែក្រោយមករយៈពេល១អាទិត្យ ក្រាញ់ និងកូន បានសម្រេចចិត្តចាកចេញទៅរស់ឯឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀងវិញ ព្រោះនៅភ្នំពេញគ្មានទឹក និងគ្មានភ្លើងសម្រាប់ប្រើប្រាស់នោះទេ។ ក្រាញ់ និងកូនៗ បានជិះរទេះគោមកដល់មុំកៀនស្វាយ ហើយបានឃើញឡានរបស់កងទ័ពវៀតណាមដែលជិះសំដៅទៅកាន់ទិសខាងកើតដូចគ្នា ក្រាញ់ ក៏យកខ្សែកដែលនៅសល់កាត់ជាពីរបំណែកដោយមួយផ្នែកទុកខ្លួនឯង និងមួយផ្នែកទៀតយកឲ្យកងទ័ពវៀតណាម ដើម្បីសុំឡានជិះទៅកាន់ស្រុកកំណើត។

មកដល់ ឃុំបាវិត ក្រាញ់ ត្រេកអរម្តងទៀត ដោយនឹកក្នុងចិត្តថានឹងបានជួបជុំអ្នកជិតខាងនិងកសាងជីវិតថ្មីលើទឹកដីកំណើតរបស់ស្វាមី ជាមួយកូនៗ។ ចូលមកដល់ភូមិ ក្រាញ់ ធ្លាក់ថ្លើមក្តុក និងស្រែកទ្រហោយំប្រទេចផ្តាសាដល់ខ្មែរក្រហមនៅពេលបានឃើញសភាពផ្ទះរបស់ខ្លួន ៕

៥៩

រឿង អង្គការ ទុរយស

អ្នកនិពន្ធ ៖ ភួង សុគន្ធ

៥៩ ~ រឿង អង្គការឆ្មុះយស

ក្រោយពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច មន្ត្រីរាជការ កងទ័ព គ្រូបង្រៀន និស្សិតបញ្ញវន្ត សាស្ត្រាចារ្យ និងព្រះសង្ឃ ត្រូវខ្មែរក្រហមព្យាយាម លុបបំបាត់ ហើយកម្មាភិបាលខ្មែរក្រហម បានចាប់អ្នកទាំងអស់នោះ យកទៅសួរចម្លើយ និងសម្លាប់ចោលទាំងពូជ។ ប្រជាជនទូទាំងប្រទេស ត្រូវអនុវត្ត និងដើរតាមមាគ៌ា ដែលមានឈ្មោះថា អង្គការ។ ការងារអ្វីៗទាំងអស់ ត្រូវស្ថិតក្រោមឱវាទរបស់ អង្គការ។

ឪពុករបស់ខ្ញុំ គឺជាអតីតគ្រូបង្រៀននៅក្នុងសម័យសង្គមរាស្ត្រនិយម។ នៅក្នុងភូមិរបស់ខ្ញុំពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំតែងតែមានឃើញប្រជាជនចំណូលថ្មីចូលមកមិនដាច់សោះ។ ឪពុករបស់ខ្ញុំប្រាប់ថា «ពុកបានស្តាប់វិទ្យុផ្សាយថា បីថ្ងៃទៀត គឺមានពួកកងទ័ពអាមេរិក មកទម្លាក់គ្រាប់បែកនៅក្រុងភ្នំពេញ។ ដូចច្នេះ អង្គការ សំណូមពរដល់ប្រជាជនទាំងអស់ ដែលរស់នៅក្នុងក្រុងភ្នំពេញ ឲ្យជម្លៀសចេញទៅតាមជនបទទាំងអស់គ្នា ដើម្បីបញ្ចៀសគ្រោះថ្នាក់មកលើប្រជាជន»។ ខ្ញុំឃើញសភាពការណ៍ពីមួយថ្ងៃទៅមួយថ្ងៃចេះតែផ្លាស់ប្តូរខុសពីមុនទាំងអស់ ទាំងការរស់នៅ ការហូបចុក និងការធ្វើការងារ។ អ្វីៗត្រូវ អង្គការ ឲ្យធ្វើរួមទាំងអស់។ ខ្ញុំបានប្រាប់ឪពុកខ្ញុំថា «ម្សិលមិញ កូនឮអ៊ំប្រធានភូមិថា ឲ្យក្មេងៗ កុមារ ទៅរកដីលេខ១ ហើយក្នុងកុមារម្នាក់ ត្រូវតែរកឲ្យបានមួយ១ស្បោង។ តើដីលេខ១នោះជាអ្វីទៅពុក?» ឪពុករបស់ខ្ញុំងាកមកមើលមុខខ្ញុំ ហើយនិយាយដោយទឹកមុខបារម្មណ៍ថា «ដីលេខ១ គឺជាលាមកមនុស្ស និងសត្វ។ កូនមិន

ត្រូវទៅណាផ្តេសផ្តាសដូចមុននោះទេ ចាប់ពីថ្ងៃនេះទៅ ពុក និងម៉ែរបស់ឯង មិនបាននៅជួបជុំកូន និងប្អូនទៀតទេ ព្រោះអង្គការ តម្រូវឲ្យពុក និងម៉ែឯង ទៅជីកប្រឡាយ លើកទំនប់ ស្ងួងស្រូវ នៅឯព្រៃកជីក ឆ្ងាយឯណោះ លុះយប់ឡើងបានត្រលប់មកផ្ទះវិញ»។

សំឡេងជួងបានបន្លឺឡើងជាបន្តបន្ទាប់ ៣ដង ដើម្បីប្រមែប្រមូលប្រជាជនទាំងចាស់ ទាំងថ្មី ឲ្យទៅធ្វើការ។ កងទ័ពខ្មែរក្រហមបួនប្រាំនាក់ មានកាន់កាំភ្លើងគ្រប់ដៃ បានស្រែកគំរាមថា «ឆាប់ទៅធ្វើការងារទៅ។ សមមិត្តទាំងអស់គ្នាគឺជាមនុស្សរបស់អង្គការ។ អង្គការឲ្យធ្វើអី គឺត្រូវតែធ្វើហ្នឹង ជាដាច់ខាត។ កងប្រវត្តិសាស្ត្រដើរទៅមុខជានិច្ច នរណាហ៊ានលូកជើងដាច់ជើង នរណាហ៊ានលូកដៃដាច់ដៃ។ អ្វីៗទាំងអស់គឺ អង្គការ ជាអ្នកសម្រេច ដូច្នេះហើយ យើងគ្រប់គ្នាត្រូវទុកចិត្តមកលើអង្គការតែមួយប៉ុណ្ណោះ។ អង្គការមិនធ្វើឲ្យបងប្អូន និងសមមិត្តទាំងអស់គ្នាអស់សង្ឃឹមនោះទេ»។ បន្ទាប់ពីកងទ័ពនោះនិយាយចប់ សំឡេងទះដៃក្នុងអង្គប្រជុំបានលាន់ឮព្រមៗគ្នា។ ការប្រជុំនេះ ជាការប្រជុំលើកដំបូងដែលខ្ញុំបានចូលរួមនិងមាន ប្រជាជនប្រហែល ៦០នាក់ បានអង្គុយស្តាប់យ៉ាងយកចិត្តទុកដាក់។

បន្ទាប់មកប្រធានអង្គប្រជុំបាននិយាយបន្តទៀតថា «សូមជម្រាបដល់បណ្តាសមមិត្តទាំងអស់គ្នា អង្គការ តម្រូវឲ្យសមមិត្តយើងទាំងអស់គ្នាសារភាព និងសម្តែងភាពស្មោះត្រង់ចំពោះអង្គការថា តើពីមុនមកមិត្តណាធ្លាប់ធ្វើអ្វីខ្លះ? ត្រូវប្រាប់ឲ្យត្រង់មក ដើម្បីងាយស្រួល អង្គការ ចាត់តាំងឲ្យទៅធ្វើការដូចដើមវិញ កុំឲ្យមានការភ័យខ្លាចអីណា»។ ឮដូចនោះ មានអ៊ំ ពូ មីង មួយចំនួនបានលើកដៃឆ្លើយសារភាពយ៉ាងប្រញាប់ ថា «ខ្ញុំឈ្មោះ ញាញ់ អតីតជាគ្រូបង្រៀនភាសាបាលីជាន់ខ្ពស់។ ប្រជាជនខ្លះទៀតបានសារភាពថា ធ្លាប់ធ្វើជានគរបាលសម័យលន់ នល់ និងអ្នកខ្លះទៀតធ្លាប់ធ្វើជាគ្រូបង្រៀន ជាមេភូមិ មេឃុំ មន្ត្រី និងនិស្សិតច្បាប់ពីបរទេស ជាដើម»។ ប្រជាជនទាំងអស់នោះ បានឆ្លើយតាមត្រង់មិនហ៊ានលាក់លៀមទេ ព្រោះសង្ឃឹមថានឹងបានទៅធ្វើការនៅកន្លែងដើមវិញ។

សំឡេងទះដៃយ៉ាងកងរំពងបានបន្លឺឡើង។ ប្រធានអង្គប្រជុំនិយាយថា «សូមអរគុណចំពោះសមមិត្តទាំងអស់គ្នាខ្លាំងណាស់ដែលបានសារភាពយ៉ាងក្បោះក្បាយពីជីវប្រវត្តិដ៏ត្រឹមត្រូវរបស់ខ្លួនបង្ហាញដល់អង្គការ។ យើងនឹងមិនភ្លេចគុណបងប្អូនទេ។ អង្គការ និងយកចិត្តទុកដាក់ដល់បងប្អូន មើលថែកូនចៅសមមិត្តទាំងអស់ ឲ្យមានហូបចុកឆ្អែត មានអ្នកថែទាំត្រឹមត្រូវ ទំនុកបម្រុងឲ្យរៀនសូត្រ សូមបងប្អូនកុំមានការព្រួយបារម្ភអ្វីឡើយ ហើយត្រូវជឿជាក់លើអង្គការ»។

ភ្លាមៗនោះមានសមមិត្តម្នាក់លើកដៃរាយការណ៍ថា «ខ្ញុំឈ្មោះ ម៉ុន អតីតជាកងទ័ពសម្តេចឪ សូមធ្វើការសម្តែងភាពស្មោះត្រង់ចំពោះមុខអង្គការ។ សូមរាយការណ៍ពី មិត្តយ៉េង សមមិត្តនារីគាំ និងមិត្តដែន ព្រោះខ្ញុំបានឃើញមិត្តទាំងបីនាក់នេះ បានទៅលួចដកដំឡូងយកមកស្ងោរហូបកាលពីយប់មិញ ក្បត់នឹងការណែនាំរបស់អង្គការ»។

«ល្អណាស់!» ប្រធានភូមិ បាននិយាយសរសើរដល់ មិត្តម៉ុន ដែលមានចិត្តក្លាហាន ហ៊ាននិយាយពាក្យពិត រួចប្រធានភូមិបាននិយាយបន្តទៀតថា «តើមានមិត្តណាដឹងរឿងអ្វីទៀតទេ? សូមលើកឡើងនិយាយនៅទីនេះឲ្យអស់មក»។

«ចាសមិត្ត នាងខ្ញុំឈ្មោះ ទ្រី សូមធ្វើការរាយការណ៍ចំពោះ មិត្តហុន និងសមមិត្តនារីដេត ដែលជាកងទ័ព បានលួចស្នេហាគ្នានៅនឹងចង្កេះដំបូកក្រោយភូមិកាលពីយប់ម្សិលមិញ។ នេះជាអំពើមិនគួរគប្បីទាល់តែសោះ ព្រោះខុសសីលធម៌ធ្ងន់ធ្ងរសូមអង្គការជ្រាប»។

«តើមាននរណាមានយោបល់ទៀតទេ?» មិត្តសៃ ប្រធានភូមិសួរ រួចនិយាយបន្តទៀតថា «សរុបមក អង្គការ ដ៏ភ្លឺស្វាងរបស់យើង នឹងកម្ទេចចោលឲ្យអស់ពួកបនក្បត់ ក្រុមសក្តិភូមិ អ្នកដែលមានវណ្ណៈជិះជាន់ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះសមមិត្តដែលស្មោះត្រង់ប្តូរផ្តាច់ជាមួយអង្គការ»។ បន្ទាប់ពីប្រជុំចប់ អង្គការ បានដាក់ផែនការឲ្យប្រជាជនខំធ្វើស្រែក្នុងមួយហិកតាឲ្យបានចំនួន ៣តោន ហើយក្នុង ១ឆ្នាំ ប្រជាជនត្រូវធ្វើស្រែចំនួនបីដង។

ទោះបីជាអង្គការទទួលបានទិន្នផលស្រូវច្រើនប៉ុណ្ណា ក៏ប្រជាជនហូបមិនដែលបានឆ្អែតឡើយ។ ខ្ញុំមិនអាចទ្រាំទ្រនឹងភាពអត់ឃ្លានបានទេ។ ថ្ងៃមួយ ខ្ញុំបានទៅលួចដកមើមត្រាវនៅក្នុងថ្លុកក្បែររោងបាយរួមកណ្តាលភូមិ។ ពេលនោះ ប្រហែលជាម៉ោង៩យប់ កងឈ្លបចំនួន ៤នាក់ កាន់កាំភ្លើងគ្រប់ដៃ បានឃើញ ខ្ញុំរួចស្រែកគំរាមថា «តើអាអ្នែង គឺជាកូនអាណា ហេតុអ្វីបានជាអ្នែងហ៊ានក្បត់អង្គការមកលួចដកមើមត្រាវរបស់អង្គការដូចច្នេះ?» ព្រមទាំងចាប់ចងដាក់ដៃខ្ញុំទៅក្រោយ ហើយទាត់ធាក់ខ្ញុំយ៉ាងខ្លាំង។

ខ្ញុំឆ្លើយទាំងភ័យថា «បាទមិត្តពូ ខ្ញុំឈ្មោះ សម្បត្តិ។ សូមអភ័យទោសឲ្យខ្ញុំផង ព្រោះក្មួយឃ្លានពេក ណាមួយម៉ែខ្ញុំមិនស្រួលខ្លួនច្រើនថ្ងៃមកហើយ។ គាត់បាក់កម្លាំងព្រោះធ្វើការធ្ងន់ពេក ហើយមិនមានអ្វីហូបទៀត»។ ទោះជាខំអង្វរកយ៉ាងណា ក៏កងឈ្លបនោះមិនព្រមដែរ ព្រមទាំងនិយាយថា «មិនបានទេ! មិនបានជាដាច់ខាត! អង្គការមិនអនុញ្ញាតឲ្យយកមើមត្រាវទៅទេ។ ក្បាលនរណាសក់អ្នកហ្នឹង គ្មានមនោសញ្ចេតនាអ្វីទាំងអស់ គ្មានការអាណិតអាសូរអ្វីទាំងអស់ស្តាប់បានទេ?តើអាអ្នែង នៅក្រុមកងចល័តមួយណា?» រួចខ្ញុំឆ្លើយតបទៅវិញភ្លាមៗថា «បាទ!មិត្តពូ ខ្ញុំនៅកងចល័តកុមារតំបន់២១ ស្រុកកំចាយមារ ផ្នែកផលិតនិងរកជី ចិញ្ចាំដើមទន្ទ្រានខែត្រ ផលិតជីលេខមួយ»។ កងឈ្លបនោះនៅតែមិនអស់ចិត្ត បានដេញសួរប្រវត្តិឪពុកម្តាយរបស់ខ្ញុំថែមទៀតថា «ល្អណាស់ ខំធ្វើការទៅ តើឪពុកម្តាយឯងកាលពីមុនធ្វើការងារស្អី? ប្រាប់ឲ្យត្រង់មកបើប្រាប់ការពិតដល់អញ អញនឹងឲ្យឪពុកម្តាយឯងរស់ស្រួល។ អង្គការនឹងឲ្យទៅធ្វើការងារដូចដើមវិញ»។ ខ្ញុំដឹងសភាពការណ៍ ហើយបានឆ្លើយបង្វែរថា «បាទ មិត្តពូ ពុកម៉ែរបស់ខ្ញុំ ពីមុនជាកម្មករសំណង់ធម្មតាទេ ពួកគាត់ពុំចេះអក្សរទេ»។

ខ្ញុំព្រឺក្បាលខ្លាកៗ ហើយប្រញាប់រត់ទៅកន្លែងរោងធ្វើជីវិញទាំងឃ្លាន។ នៅតាមផ្លូវ ខ្ញុំបានចូលទៅក្នុងភូមិ ហើយបានឃើញការប្រជុំរបស់មេភូមិដែលមានកម្មាភិបាលខ្មែរក្រហមចំនួន ៤នាក់ ព្រមទាំងប្រជាជនជាច្រើននាក់ កំពុងតែសួរនាំពីបញ្ហាធ្វើកសិកម្ម និងនិយាយដដែលៗអំពីការធ្វើបដិវត្តន៍ ថែមទាំងគំរាមកំហែងប្រជាជន ដោយលើកឡើងពីផែនការកម្ចាត់ពួកខ្មាំងដែលមានបំណងចង់ក្បត់។

ថ្ងៃមួយម៉ោងប្រហែល៩យប់ ខ្ញុំបានឃើញកម្មាភិបាលខ្មែរក្រហមចំនួន ៣នាក់បានសួរចម្លើយប្រជាជនមួយសន្ទុះ ហើយក្រោយមកក៏ឃើញមាន កម្មាភិបាលខ្មែរក្រហមទាំងនោះ ចាប់ចងដៃរបស់ប្រជាជន និងចងរុំក្នែកទាំង គូបណ្តើរចេញទៅត្រពាំងខាងក្រោយភូមិ។ ពីមួយថ្ងៃទៅមួយថ្ងៃ សោកនាដកម្ម បែបនេះកើតឡើងច្រើនណាស់ ដែលខ្មែរក្រហម បានធ្វើបាបប្រជាជនខ្មែរ ស្លូតត្រង់។

មិនយូរប៉ុន្មាន ឪពុកម្តាយរបស់ខ្ញុំ ត្រូវអង្គការជម្លៀសឲ្យទៅធ្វើការនៅកន្លែង ផ្សេងជាច្រើនខែ។ ឪពុកនិងម្តាយរបស់ខ្ញុំបារម្មណ៍ចំពោះកូនៗណាស់ ហើយផ្តែផ្តាំ យ៉ាងច្រើនថា «សម្បត្តិ កូនម៉ែ កូនត្រូវឧស្សាហ៍ទៅអើតមើលប្អូនឯងផងណា។ ម៉ែនិងពុក ត្រូវអង្គការផ្លាស់ទៅការដ្ឋានផ្សេងហើយ ពីរបីថ្ងៃចាំពុកម៉ែ សុំប្តាប់ ប្រធានកងមកលេងកូនណា។ ដូច្នេះកូនមិនត្រូវដើរលេងផ្តេសផ្តាសទេ និងចេះ ប្រយ័ត្នពាក្យសម្តីផងកូន»។

ខ្ញុំស្រាប់តែបានឮសំឡេងស្រែកបញ្ជាខ្លាំងៗចេញពីផ្ទះរបស់ ពូធោម ថា «តើពួកមិត្តឯងចិត្តជាប់ដៃរទេ?» ពូធោម ស្រែកសួរទៅកម្មាភិបាលពីរនាក់ ផ្សេងទៀត ដែលទើបនឹងផ្លាស់មកថ្មី។ ពូធោម គឺជាកម្មាភិបាលខ្មែរក្រហម ជាន់ខ្ពស់ ដែលអង្គការចាត់តាំងមកកាន់កាប់នៅតំបន់នេះ ហើយគាត់មានឋានៈ ជាប្រធាននយោបាយប្រចាំតំបន់។ កម្មាភិបាលខ្មែរក្រហមទាំងពីរនាក់នោះ បានឆ្លើយទាំងអង់អាចថា «បាទ!បាទ! មិត្តបង រឿងសម្លាប់មនុស្សជាជំនាញ របស់ខ្ញុំ។ ខ្ញុំធ្លាប់កម្ទេចខ្មាំងរាប់សិបនាក់មកហើយ»។ ពូធោម និយាយបន្តទៀត ថា «ល្អ! មិត្តឯងទាំងពីរនាក់នៅជាមួយខ្ញុំចុះ តែមិត្តឯងត្រូវដឹងថា ត្រូវលះបង់ ឲ្យអស់រឿងគ្រួសារនិយម គ្មានមនោសញ្ចេតនា គ្មានគំនិតសួនតួនិយម ចិត្តត្រូវ ជាប់ខាត ស្មោះត្រង់ជាមួយអង្គការឲ្យបាន»។ មនោគមនវិជ្ជារបស់ខ្មែរក្រហម បានធ្វើឲ្យមនុស្សកាន់តែសាហាវទៅៗ ហ៊ានសម្លាប់ទាំងសាច់ញាតិនិងក្រុម គ្រួសាររបស់ខ្លួន។

ពីមួយថ្ងៃទៅមួយថ្ងៃ អង្គការកាន់តែតឹងរឹងឡើងៗ។ ប្រជាជនបន្តស្លាប់ដោយសារជំងឺ ការសម្លាប់ និងភាពអត់ឃ្លាន។ លុះដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨ អង្គការ បានរៀបចំផែនការទៅវាយយកទឹកដីវៀតណាម។ ពេលនោះ កងទ័ពខ្មែរក្រហម បានស្លាប់ជាច្រើននាក់ដោយសារការវាយបករបស់កងទ័ពវៀតណាម។

ខ្ញុំមានអាយុត្រឹមតែ ១៨ឆ្នាំប៉ុណ្ណោះ ហើយអង្គការ តម្រូវឲ្យខ្ញុំចូលបម្រើក្នុងជួរកងទ័ព ដើម្បីទៅប្រយុទ្ធនឹងកងទ័ពវៀតណាម។ ចំណែកឪពុកម្តាយរបស់ខ្ញុំ ត្រូវអង្គការផ្លាស់ឲ្យទៅជីកស្តារប្រឡាយនៅឯតំបន់ព្រៃកជីក (អន្លង់រុន) ស្ថិតនៅក្នុងភូមិថ្កូវ ឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម។

ទោះបីជាកងទ័ពខ្មែរក្រហមខ្លាំងយ៉ាងណាក៏ដោយ ប៉ុន្តែការរួបរួមគ្នារវាងកងទ័ពវៀតណាមនិងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ បានកំចាត់កងទ័ពខ្មែរក្រហមពីមួយថ្ងៃទៅមួយថ្ងៃរហូតទទួលបានជ័យជម្នះ។ នៅខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជា ត្រូវបានរំដោះចេញពីការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយប្រជាជនទូទាំងប្រទេសបានជួបជុំសាច់ញាតិ និងចាប់ផ្តើមកសាងជីវិតឡើងវិញពីបាតដៃទទេរហូតដល់សព្វថ្ងៃនេះ។

ចប់

៦០

កំណាព្យ

អ្នកនិពន្ធ ៖ លឹម ចាន់គឹមហៀង

๖๐ ~ កំណាព្យ

ជីវិតអន្ធការរបស់ម៉ែ
បទពាក្យច្រាំបី

ខ្ញុំសូមអភិវន្ទបន្ទន់ឥរិយា　　បន្ទាបប៉ាកកាជាក់លើកម្រាមដៃ
គោរពគារវៈលោកអ្នកប្រុសស្រី　　សូមជូនរឿងខ្លីអត្ថន័យពិតជាក់។
អក្ខរាថ្លាថ្លែងចែងចងកាព្យា　　រៀបរាប់ពណ៌នារឿងរ៉ាវទិនទាក់
អ្នកម្តាយកំសត់អត់មានលៀមលាក់　　ឆ្លងកាត់ជ្រៅរាក់សម័យ ប៉ុល ពត។
អ្នកម្តាយឈ្មោះ ទាង វ័យរាងចូលចាស់　　វ័យហុកសិបក្រាស់ចាស់ចាំប្រវត្តិ
អ្នកម្តាយហើបហាវាចាផ្ចាល់មាត់　　ប្រាប់រឿងដូរចត់ដៃលលោកឆ្លងកាត់។
លោកថាកូនអ្ហើយម្តាយចាំដឹងឮ　　ម្តាយនឹកឡើងព្រឺទឹកភ្នែកហូរកាត់
ទ្រូងក្តៅក្តុកក្តួលឆួលថ្លើមប្រមាត់　　ម្តាយបានបង់បាត់ព្រាត់បែកបងប្អូន។
សម័យអន្ធការមេសាចិតប្រាំ　　ម្តាយដក់ចិត្តចាំមិនងាយសាបសូន្យ
កាលៈងងឹតឥតភ្លឺទេកូន　　ប្រជាបងប្អូនឈឺចាប់ឥតល្ហែ។
ប្រវត្តិសាស្ត្រច្បាស់កត់ឆ្លាក់ចារ　　បនពតប្រហារធ្វើបាបរាស្ត្រខ្មែរ
រាស្ត្ររាប់លាននាក់ចាំជាក់ឥតប្រែ　　អាសូររាស្ត្រខ្មែរងងុកក្ខវេទនា។
កូនអ្ហើយម្តាយប្រាប់សារសព្វអត្ថន័យ　　ម្តាយកាលក្មេងវ័យមាំកាយអង្គា
ឆ្លងកាត់សព្វយ៉ាងចាំដល់ជរា　　ម្តាយនឹងពណ៌នាប្រាប់ជីវភាពម្តាយ។

ជីវភាពឆ្នាំ១៩៧៣-១៩៧៤
បទពាក្យប្រាំបី

អ្នកម្តាយឈ្មោះ ទាង មានស្រុកកំណើត ប្រាសាទភូមិកើត ឃុំវិហារធំ
ស្រុកកំពង់សៀមបងប្អូនជុំ កំពង់ចាមចំខេត្តលោករស់នៅ។
ឆ្នាំចិតសិបបីវិយគាត់ជំទង់ ជំទើរទ្រើសទ្រង់នាមជាប្អូនពៅ
បងប្អូនច្រើននាក់បែកបួនផ្លូវ ព្រាត់ចាកលំនៅទៅឋានទីទៃ។
បងស្រីឈ្មោះ មួយ មានប្តីវិយសាម នៅកំពង់ចាមចាកដែនស្រុកព្រៃ
បងប្រុសឈ្មោះ ទ្រី ក៏លះលកលៃ ករិយាការថ្មីក៏នាំទៅបាត់។
បងប្រុសទីបីធ្វើជាទាហាន ចោលប្អូនឥតមានអ្នកណាអារកាត់
ចូលជុំកងទ័ពរំដោះស្ងៀមស្ងាត់ នៅសល់តែគាត់ប្អូនពៅម្នាក់ឯង។
ពុកម៉ែស្លាប់ចោលឥតនៅរស់រាន សាច់ញាតិក៏គ្មានកណ្តោចកណ្តែង
នៅរស់កំព្រារងាចំបែង រសាត់ដូចខ្លែងហោះគ្មានគោលដៅ។
ចិតបីចិតបួនគាត់ពួនគ្រាប់ផ្លោង អ្នកស្រុកភូមិផងភ័យនាំកូនចៅ
ម៉ែទាងជំទង់ដ៏សែនល្ងង់ខ្លៅ រត់ចោលលំនៅទៅតាមអ្នកស្រុក។
សន្ធឹកគ្រាប់បែកពុះហែកធរណី រាល់ថ្ងៃវក់រីរស់គ្មានក្តីសុខ
យន្តហោះសន្ធាប់បោះគ្រាប់គ្រប់មុខ លន់ នល់ រុលរុកវាយលុកទ័ពថ្មី។
ទ័ពថ្មីមានន័យកងទ័ពរំដោះ ស្ម័គ្រលះដោយស្មោះចំពោះទឹកដី
កំចាត់របប លន់ នល់ អប្បិយ រកជីវភាពថ្មីជូនដល់ខេមរា។
នារីក្មេងខ្ចីភ័យញ័រចំប្រប់ លើកម្រាមដៃដប់បន់ដល់ដួងតា
សូមបានរួចរស់បន្តជីវ៉ា បំណងប្រាថ្នាសូមជួយបង។។
មិនអាចស៊ូទ្រាំអ្នកស្រុកមូលមីរ ចាកចោលដែនទីនាំអ្នកភូមិផង
រត់ចូលក្នុងព្រៃបង្កើតជាកង កាប់ឈើវៃចងសង់ខ្ទមលើទួល។
នារីកំសត់រស់សែនលំបាក រត់ចោលចេញចាកផ្ទះចិត្តប្រែប្រួល
ទារុណកាយចិត្តឥតស្រណុកស្រួល រស់នៅលើទួលខំដីកលេណដ្ឋាន។

ស្ងាត់ស្រុកស្ងាត់ភូមិដុំទួលឆ្ងាយផ្ទះ មនុស្សគរដេរដាសក្នុងព្រៃស្មសាន
ភ្លៀងរន្ទះផ្គរញាប់ញ័រសព្វប្រាណ ភួយមុងឆ្នាំងចានទទឹកគ្មានសល់។
ម៉ែ ទាង ត្រូវគេចាប់ធ្វើកងឈ្លប ដើរមើលគ្រប់សព្វឲ្យបានជិតដល់
លីសែងទាហានត្រដរខ្យល់ រងគ្រោះហេតុផលតតាំង លន់ នល់។
ទាហានរំដោះដាច់ជើងដាច់ដៃ រុំចងដោះស្បែទប់ឈាមពុះពារ
ទាហានណាស្លាប់គរកប់កុំឆ្ងល់ ម៉ែ ទាង ឥតកលខំតាមបញ្ជា។
ទិដ្ឋភាពគាត់ជួបក៏ញ័ររន្ធត់ ក្រមុំទុរគតឥតហ៊ានរុញរា
លើកបីចាប់កាន់ខ្មោចជនពិការ លំបាកម្តេចម្តាខាំមាត់អត់ទ្រាំ។

ជីវភាពរស់នៅក្នុងរបប ប៉ុល ពត
បទពាក្យប្រាំពីរ

ចិតប្រាំស្ងប់ស្ងាត់ចប់ លន់ នល់ រំដោះបានផលជួបជោគជ័យ
បដិវត្តន៍កម្ទេចចោលអស់ន័យ ប្តូរសង្គមថ្មី គឺ ប៉ុល ពត។
ម៉ែ ទាង យាងយារចូលភូមិស្រុក សង្ឃឹមបានសុខរីកមុខមាត់
ប្រជាភូមិផងវិលនិវត្តន៍ ប្រមូលទូទាត់គ្នាមកផ្ទះ។
ការស្មោនខានខកខុសបំណង ខុសចិត្តគិតប៉ងផ្ទុយស្រឡះ
គេចាត់រៀបចំគេប្តូរផ្លាស់ ចោលរបបចាស់ចូលរឿងថ្មី។
អ្នកស្រុកក្មេងចាស់ត្រូវគេហៅ ឲ្យស្លៀកពាក់ខ្មៅខ្មែរគ្រប់វ័យ
ស្រីៗគេឲ្យកាត់សក់ខ្លី រត់តាមបែបថ្មីតាមផែនការ។
អ្នកម៉ែរស់នៅដូចគេឯង កាប់គាស់លីសែងកិច្ចសព្វសារ
ធ្វើស្រែធ្វើភ្លឺទប់គង្គា ជំទង់កំព្រាប្រឹងតស៊ូ។
សំណាងសម័យមិនទាន់តឹង អាចរស់អាចប្រឹងអាចគន់គូរ
អាចហូបអាចភ្លក់ក្តៅចត់ជូរ សេរីនៅធូរៀងៗខ្លួន។
មេកងមេឈ្លបចេះយោគយល់ ចេះគិតឫសគល់ហាក់ហ៊ំហួន

មានសិទ្ធិរស់នៅផ្ទះរៀងខ្លួន អាចជុំបងប្អូនញាតិសាច់សា។
សំណាងវាសនាជួបបងស្រី បងធំវិលវែមកគេហា
នាំប្តីកូនប្រុសតូចសង្ហា ចាកចោលចំការចូលស្រុកភូមិ។
អ្នកម៉ែស្ទះឱបកាយបងស្រី រំជួលហឫទ័យហើយស្រែកយំ
អំណាចចិត្តនឹងបែកពេលធំ ព្រាត់ចាកទ្រនំចោលប្អូនពៅ។
ចិត្តមួយត្រេកអរសែនរំភើប រកកលឱនងើបស្មានមិនត្រូវ
ប្អូនស្រីរាល់ថ្ងៃចាំមើលផ្លូវ ចាំបងមកនៅផ្ទះយើងវិញ។
ឱបងស្រីធំខ្ញុំនឹកណាស់ បែកគ្នាក្រៃលក្រាស់ទ្រូងទុក្ខម្នេញ
បងប្អូនបួននាក់បែកចាកចេញ ឥឡូវជួបវិញឃើញតែបង។
នេត្រាបងស្រីយំព្រិចៗ ឆ្លើយតបពាក្យពេចន៍សៀងសាសង
ថាបងនៅឆ្ងាយយ៉ាប់ឆ្លើយឆ្លង ទ្រូងសែនសៅហ្មងចង់ជួបជួន។
រៀបរាប់អស់អាទិ៍ចប់សេចក្តី ពីរនាក់បងស្រីនាំប្តីកូន
ឡើងសម្រាកផ្ទះរៀងៗខ្លួន រស់ជុំបងប្អូនរៀងតទៅ។
ចិតសិបប្រាំមួយដាក់រាស៏ ដំណឹងមកថ្មីឮក្តៅៗ
បងប្រុសឈ្មោះ ឡ ទាហានខ្មៅ បានលាលោកទៅពេលរំដោះ។
បងប្អូនពីរនាក់ធ្លាក់ថ្លើមក្អួក រលោងទឹកមុខទុក្ខក្រៀមក្រោះ
រឭកនឹងឃើញប្រុសកម្លោះ កាលគាត់នៅរស់សែនសង្ហា។
ពេលនេះបងបាត់ព្រាត់ក្សិណក្សយ ប្អូននៅសព្វថ្ងៃពីរអាត្មា
បងប្រុសធំមិនដឹងទៅណា ឱព្រេងវាសនាម្តេចមិនទៀង។

ជីវភាពឆ្នាំ១៩៧៧-១៩៧៨
បទកាកគតិ

វេលាប្តូរផ្លាស់ លើទឹកដីចាស់ កន្លែងដើមដឹង
តែអ្វីដែលប្តូរ ពីធូរមកតឹង ចិតប្រាំពីរនឹង
ចាប់ផ្តើមព្រួយភ័យ។

ធ្លាប់រស់ជួបជុំ ចូលក្នុងទ្រនំ បងក្មួយបងថ្លៃ
ដូចអ្នកភូមិស្រុក ហូបចុករាល់ថ្ងៃ តាមផ្ទះទីទៃ
លៃរៀងៗខ្លួន។

ឆ្នាំថ្មីនាទី ចិត្តសិបប្រាំំពីរ ប្រមូលជួបជួន
ហូបជុំរោងបាយ តាមកងរៀងខ្លួន បើក្រាញ់លាក់ពួក
គេចោទចាប់ចង។

មេកងឡើងថ្មី បញ្ចេញថ្វីដៃ ឥតយល់ប្អូនបង
មេកងពីមុន អាសន្នចាប់ចង សុទ្ធជាប់ចំណង
ប្រហារសូន្យបង់។

ពូជខ្មែរអ្នកធំ មុខការជិតជុំ ជាប់ទោសរហង់
ចោទចាក់សម្លាប់ ចងចាប់តាមចង់ ទោះត្រឹមត្រូវបង់
ក៏កំចាត់ចេញ។

មាគ៌ាបដិវត្តន៍ សូត្រចាំរត់មាត់ ទុកមិនចំណេញ
បើអត់តម្លៃ ទុកថ្វីដកចេញ គោលការណ៍ពោរពេញ
មានអ្វីត្រូវខាត។

ស្រីៗអត់ប្តី រៀបចំក្រុមថ្មី ក្រុមកងចល័ត
នាទីសព្វគ្រប់ ថ្ងៃយប់ចែងចាត់ លីសែងកាប់កាត់
ការច្រើនស្អេកស្កះ។

មានប្រពន្ធប្តី ហៅកណ្តាលវ័យ ក៏ការក្រៃលែងក្រាស់
ធ្វើស្រែធ្វើស្រូវ ឥតប្រែក្រឡាស់ ប្រឹងឲ្យឃើញច្បាស់
ទើបស្មោះអង្គការ។

រីឯក្មេងៗ ឥតមានដើរលេង ស្រែកច្រៀងឡូឡា
ហៅក្មេងចល័ត គេចាត់ធ្វើការ ស្រាលធ្ងន់ម្តេចម្តា
លៃតាមកម្លាំង។

រីក្រុមចាស់ៗ ចាត់ចែងនៅផ្ទះ ការងារចូកចាំង
យាយៗមើលចៅ ហៅមកឃុំគ្រង តាៗវិញម្តង
ធ្វើខាងកសិកម្ម។

ម៉ែ ទាង នៅខ្ចី ជំទង់ជាស្រី ក្មេងខ្ចីខែឆ្នាំ
ធ្វើកងចល័ត ការចាត់ប្រចាំ អត់ធ្មត់ស៊ូទ្រាំ
ប្រឹងដើម្បីរស់។

កិច្ចការម៉ែធ្វើ សព្វគ្រប់សារពើ រុករុលឈ្មុលឈ្មុស
កាប់គាស់រែកដី រាល់ថ្ងៃគ្មានលស់ លើកទំនប់ធ្នស់
ប្រព័ន្ធភ្លឺស្រែ។

ធ្វើច្រើនហូបតិច របបកលកិច្ច ឥតអាចកែប្រែ
ពីរពេលមួយថ្ងៃ គេច្នៃឡប់ឡែ ហូបមិនឆ្អែតទេ
ទឹករាវពេញចាន។

ដូចបងជា រែកពន់វាសនា គ្មានក្តីសុខសាន្ត
បងស្រីពពោះ កើតភ្លោះពីរប្រាណ តែបុណ្យមិនបាន
ស្លាប់មួយសល់មួយ។

អ្នកម៉ែខ្នះខ្នែង តស៊ូប្រឹងប្រែង លកលៃគិតជួយ
ចែដន្យពេកពិត ជីវិតជួបព្រួយ ប្តីបងស្រី មួយ
គេហៅកសាង។

ម៉ែស្រក់ទឹកភ្នែក អាសូរពន់ពេក ជីវិតឥតព្រាង
បងស្រីឱបបុត្រ តក់ស្លុតនៅម្ខាង ប្រកាច់ប្រងាង
ព្រោះប្តីត្រូវស្លាប់។

គេចោទថាខ្សែ ចិនជាប់ឪម៉ែ គេស៊ើបដឹងស្រាប់
នៅខេត្តរកស៊ី នាទីគេប្រាប់ ត្រូវតែសម្លាប់
កម្ពែលមូលធន។

ឱ! អនិច្ចា ប្តីបាត់សង្ខារ រស់សែនទារុណ
ម៉ែ ទាង រ៉ាប់រង លើបងសែនធ្ងន់ ចិញ្ចឹមរែកពន់
ក្មួយពីរអាត្មា។

ម៉ែ ទាង តែងលួច ស្តរត្នោតមើមក្តួច ស្រូវផ្លែផល្លា
ដំឡូងអង្គរ លាក់ជាយក្រមា ជូនបងពិសា
បញ្ចុកក្មួយផង។

គេប្រើយប់ថ្ងៃ ជិតឆ្ងាយម្តេចក្តី បញ្ជាមេកង
ហៅហត់ល្ហិតល្ហៃ ជើងដៃទាំងសង ស្តឹកទប់ម្តង។
ចង់ដេកដួលដី។

គេប្រើមកឆ្ងាយ ចាកភូមិអន្លាយ មកភ្នំប្រុសស្រី
ចាកភូមិប្រាសាទ ធ្វើការភូមិថ្មី ខ្លួនអត់មានប្តី
ប្តូរធ្វើចុងភៅ។

ចុងភៅដីថ្មី លួចលាក់លកលៃ ទុកគេយកទៅ
ចិញ្ចឹមបងស្រី ក្មួយថ្លៃមើលផ្លូវ តិចតួចម្តេចត្រូវ
យកទៅឲ្យបាន។

និស្ស័យបងប្អូន ដូចទឹកនិងក្បួន ជាប់ជាសន្តាន
អ្នកម៉ែបានជួប ប្រសព្វច្បាស់ប្រាណ បងប្រុសនាឋាន
យកទៅឲ្យបាន។

បងប្រុសទីពីរ គាត់ឈ្មោះ ហ៊ាទ្រី ដុំកូនរួមផ្ទៃ
ប្អូនស្នុះឱបបង ត្រកងក្នុងដៃ ឱ!ព្រះម្ចាស់ថ្លៃ
បងបែកទៅណា?

រៀបរាប់សារសេព្ធ ប្អូនបងត្រងត្រាប់ ប្រវត្តិសាវតារ
បងទ្រី ស្តាំងស្តម ទ្រុឌទ្រោមកាយា ព្រោះច្រើនធ្វើការ
តែហូបមិនគ្រប់។

យល់អស់សេចក្តី បងប្រុសប្អូនស្រី ណាត់គ្នាពេលយប់

លួចដើរកាត់ព្រៃ លកលៃឲ្យសព្វ ដើម្បីត្រលប់
ជួបបងស្រីធំ។
សន្ធិយារាត្រី ក្រាលគ្របលើដី ងងឹតជិតជុំ
សន្សើមទឹកធ្លាក់ ខ្លែងស្រាក់ស្រែកយំ ពពកខ្មៅដុំ
រុំជិតមេឃា។
ដល់ផ្ទះលបៗ ព្រោះខ្លាចកងឈ្លប ឃើញចងពាជា
បីនាក់ប្អូនបង សាសងរកគ្នា ឱបក្អួយកំព្រា
ដោយក្តីខ្លោចផ្សា។
វេលាជួបគ្នា ពាក្យពោលសន្ធនា បានខ្លីខ្លឹមសារ
ក៏ត្រូវឃ្លាតកាយ ចាកឆ្ងាយផ្សេងគ្នា ទៅបម្រើការ
តាមកងទីទៃ។
កាលពេលវេក់វី ឆ្នាំចិតប្រាំពីរ ចូលចិតប្រាំបី
អ្នកម៉ែ បងទ្រី នាទីភិតភ័យ គេចោទចងដៃ
ចាប់ប្រុងប្រហារ។
បងទ្រី គេចាប់ គេចោទរាយរាប់ ប្រហើរចិន្តា
លួចមួបចំណី លាក់លៃមិនមាត់ ទោសនេះកំណាត់
ត្រូវក្ស័យសូន្យបង់។
ដៃចងស្លាបសេក ក្រោមលំហមេឃ ថ្ងៃរះក្រឡង់
អ្នកម៉ែភ័យភិត នៅជិតអែបអប បងប្រុសឈរត្រង់
ម៉ែយំអង្វរ។
ហេតុភ័ព្វសំណាង បុណ្យព្រេងបានសាង ជួបកុសលល្អ
មេកងយល់យោគ ដោយលោកចិត្តធម៌ យល់ម៉ែស្មោះសរ
បងប្រុសស្លូតត្រង់។
ឱ!ជីវិតថ្លៃ ផុតកម្មចង្រៃ បុណ្យល្អទ្រើសទ្រង់
ឈប់លៃងលួកលាន់ ក្រែងលង់ជាប់ផុង ធ្វើឲ្យត្រូវត្រង់
តាមបទបញ្ជា។

ជីវិតនីពីរ
បទពាក្យប្រាំពីរ

វេលាប្តូរផ្លាស់ចាស់យាងចូលឆ្នាំថ្មី　　ចប់ចិតប្រាំបីចូលចិតប្រាំបួន
ប៉ុល ពត រឹតត្បិតពិតលំបាកផ្ទួន　　ប្រជាព្រួយខ្លួនខ្លាចគេប្រហារ។
សភាពប្រែប្រួលមិនស្រួលសេចក្តី　　បនពតភិតភ័យព្រោះដឹងច្បាស់ការ
មានក្រុមតស៊ូហ៊ានប្តូរសង្ហារ　　តទល់អង្គការ ប៉ុល ពត នេះនៃ។
ឱ!ភូមិប្រាសាទ ឃុំវិហារធំ　　អាសូរម្តាយខ្ញុំរន្ធត់ហឫទ័យ
ភ្នែកបើកក្រឡែតឃើញបនអប្បិយ　　ចាប់អូសទាញដៃប្រហារជនខ្មែរ។
មិនដឹងគំនិតថាគិតអ្វី?　　ចាប់មនុស្សប្រល័យថ្ងៃយប់ឥតល្ហែ
ចងកាប់វាយដំឈាមជាបពេញស្រែ　　ឃើញពិតឥតប្រែម៉ែញ៉ែរចំប្រប់។
បង្ខំរន្ទាន់កើនស្លាប់បន្ត　　ប្រមូលកៀរគរចោទខុសគ្រប់សព្វ
ម៉ែបន់ព្រះជួយលើកម្រាមដៃដប់　　ទ្រូងតឹងទល់ហប់ស្ទើរបង់សង្ហារ។
គុណបុណ្យព្រះពុទ្ធព្រះធម៌ព្រះសង្ឃ　　គុណពុកម៉ែផងតាមគ្រងជីតា
កងទ័ពរំដោះប្រាំពីរមករា　　ប្រៀបបានទេវតាចេស្តាអង់អាច។
បនពតបាក់បែកចែកជើងខ្ទេចខ្ទី　　រត់ចាកចោលទីបាក់បបខ្លបខ្លាច
លែងហ៊ានតតាំងច្បាំងដោយអំណាច　　បនចិត្តបិសាចវិនាសសាបសូន្យ។
បានសុខស្ងប់ស្ងាត់ម៉ែស្កាត់ជួបបង　　ប្រុសស្រីត្រកងសាច់ឈាមប្អូនបង
លំនៅកំសត់ប្រាកដជួបជួន　　យំឱបបងប្អូនក្រោមមេឃស្រឡះ។
របប ប៉ុល ពត ពិតឥតកែច្នៃ　　គេចាប់ប្រល័យប្រុសស្រីក្មេងចាស់
ម៉ែបាត់បងប្រុសម្នាក់ពិតជាច្បាស់　　បងថ្លៃល្អល្អះក៏ត្រូវសោបសូន្យ។
បងប្អូនសាច់ញាតិឯទៀតក៏បង់　　ចុងក្រោយត្រឹមបង់បីនាក់បងប្អូន
ប្រវត្តិឈឺចាប់ប្រាប់តកូនចៅ　　ឲ្យចាំខ្ជាប់ខ្លួនរឿងម៉ែឆ្លងកាត់។

និពន្ធដោយ៖ ឈ ឈុនឡា និង ឌឹង ណារ៉ុង

ចប់

៦១

កំណាព្យ

អ្នកនិពន្ធ ៖ ឈ ឈុនឡា និង ឌឹង ណារ៉ុង

๖๑ ~ កំណាព្យ

សំណោកប្រាសាទ
បទពាក្យប្រាំពីរ

សំណង់ប្រាសាទដល់ស្តឹមស្តៃ បាក់ធ្លាក់លើដីច្រើនអនេក
គន់មើលទិដ្ឋភាពគួរសង្វេគ មិនសមបាក់បែកសោះឡើយណា។
សម្បត្តិវប្បធម៌ដ៏វិចិត្រ ប្រៃជាក្រៀមស្វិតគួរខ្លោចផ្សា
ដោយសារសង្គ្រាមគ្មានមេត្តា ប្រជាខេមរាស្តាយពន់ពេក។
សិលាបានធ្លាក់លើធរណី តូចធំមូលមីច្រើនអនេក
នៅពេលបានឃើញគួរសង្វេគ និងស្រក់ទឹកភ្នែកសែនអនិច្ចា។
ឱ! បន្ទាយអើយខ្ញុំខ្លោចចិត្ត ដើមឈើរោមរឹតពេញកាយា
បាត់បង់សោភ័ណនិងរចនា រួមទាំងអក្ខរាសឹងបាត់បង់។
ស្នាដៃដូនតាពិតជាក់ស្តែង ខិតខំខ្នះខ្នែងដ៏ផ្ចិតផ្ចង់
មានឈ្មោះល្បាញល្បីលើសរាល់អង្គ ទឹកចិត្តស្មោះត្រង់ល្អពន់ពេក ។
ឈ្មោះអ្នកកសាងកុំមន្ទិល រ៉ែនទី៧សែនល្អឯក
មានកេរ្តិ៍ល្បាញល្បីច្រើនអនេក គេឯងកោតខ្លាចគ្រប់ទិសា។
កសាងប្រាសាទជាស្នាដៃ នាមឈ្មោះនោះនៃបន្ទាយឆ្មា
ហើយអាយុកាលច្រើនក្រៃណា ចារជាអក្ខរាលើប្រាសាទ។

រីយុវជនសម័យថ្មី គួរគិតឃ្មាតខ្មីខំសង្វាត
រក្សាវប្បធម៌ដ៏ស្រស់ស្អាត គង់វង្សដរាបតរៀងអើយ។

ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២៤

រឿងពិតសិរីសោភ័ណ
បទភាគតតិ

ដំណើរវថ្លើង ទាំងគេទាំងយើង បានដឹងហើយណា
វាពិតជាក្តៅ មួម៉ៅកាយា មនុស្សគ្រប់អាត្មា
តែងថាគ្រប់គ្នា។
ជិះលើកដំបូង មនុស្សម្នាព្រោងព្រាត គ្រប់ៗអង្គា
ទាំងប្រុសទាំងស្រី ថាក្តៅគ្រប់គ្នា វាគឺមិនជា
ដូចពេលយើងគិត ។
ថ្ងៃទីម្ភៃបី ជួបជុំប្រុសស្រី វេលាពេលព្រឹក
ឡើងជិះរថភ្លើង យ៉ាងច្រើនសន្ធឹក មានបាយមានទឹក
គ្រាន់ហូបតាមផ្លូវ។
ដំណើរនេះណា ចុះកម្មសិក្សា តាមការតម្រូវ
ក្នុងខែផល្គុន កៀកចុងរដូវ ទេសភាពមើលទៅ
ពិតជាក្រៀមស្វិត។
ចុងខែមីនា តាមព្រៃព្រឹក្សា គួរឲ្យអាណិត
មានភ្លើងឆេះព្រៃ សែនក្រៃខ្លោចចិត្ត នេះជារឿងពិត
មិនប្រតិដ្ឋឡើយ។
ដំណើរនេះណា មជ្ឈមណ្ឌលឯកសារ បានគិតទុកហើយ
ថាមកចង់ដឹង អំពីចម្លើយ ពួកគាត់បានស្បើយ
ពីក្តីមរណៈ។
សែនឈឺចាប់ពិត ដឹងរឿងនោះនិត្យ ក្នុងចិត្តអួលអាក់

របប ប៉ុល ពត ព្រៃផ្សៃអបលក្ខណ៍ ខ្មែរងគ្រោះថ្នាក់
ទូទាំងបុរី។
ខ្មែរស់រងកម្ម រយៈពេលបីឆ្នាំ មិនដែលហ៊ានស្តី
ប្រាំបីខែទៀត វាជាងឆ្នាំបី និងថែមម្តៃថ្ងៃ
សិរីគ្មានទេ។
របបកម្ពុជា រងទុក្ខវេទនា មិនដែលទំនេរ
ប្រើឲ្យធ្វើការ វាស្តីវាយជេរ ខ្មែរងទុក្ខទ្វេ
ធ្ងន់ហួសប្រមាណ។
ខ្មែរទាំងប្រុសស្រី ធ្វើការយប់ថ្ងៃ មិនដែលខកខាន
កាប់គាស់ដឹកដៀវ ញើសស្រោចពេញប្រាណ ធ្វើតាមដើមដាន
បញ្ជាថ្នាក់លើ។
ចំណីចំណុក ទាំងគ្រឿងហូបចុក គ្រប់សព្វអំពើ
មិនឲ្យហូបឆ្អែត តាមហេតុវាធ្វើ ប្រជាជាន់ស្នើរ
បាត់បង់ជីវិត។
ដំណាំទាំងឡាយ ក្រូចចេកដូងស្វាយ ខ្នុរទៀបឬខ្ចិត
របស់ខ្លួនឯង គេបែរប្រែប្រិត ជាក់ជាកំហិត
របស់អង្គការ។
រឿងរ៉ាវខាងលើ សព្វគ្រប់អំពើ ដែលខ្ញុំបានចារ
ស្ថិតនៅក្នុងក្រុង សោកស្តាយណាណេះណា ទុកជាឯកសារ
ដល់ក្មេងជាន់ក្រោយ។
ឃុំព្រះនេត្រព្រះ ខ្ញុំបានដឹងច្បាស់ អំពីចម្លើយ
ជាសាច់រឿងពិត មិនប្រតិដ្ឋឡើយ ជាតិខ្មែរយើងអើយ
រស់សែនវេទនា។
មានរឿងច្រើនទៀត ខ្ញុំខំខ្មីឃ្មាត ចងជាអក្ខរា
តាមបទកំណាព្យ ឃ្លោងឃ្លាខ្លឹមសារ អំពីពាក្យថា
អង្គការប៉ុលពត។

ចប់ប៉ុណ្ណឹងចុះ	បើសិនត្រូវខុស	សូមលោកមេត្តា
ថ្វីដ្បិតខ្ញុំតែង	កំណាព្យនេះណា	ខុសត្រូវម្តេចម្តា
	ឯវិចប់ហោង។	

ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២៤

ទុក្ខសោកបាកាន
បទពាក្យព្រហ្មគីតិ

ដំណើរទៅពោធិ៍សាត់ ខ្ញុំបានស្តាត់ពីចម្ងាយ
តាមដងផ្លូវសែនឆ្ងាយ នឹងអធិប្បាយប្រាយប្រាប់ត។
ពីបទកាកគតិ ចេញជាវគ្គព្រហ្មគីតិមក
ឆ្ពោះទៅស្រុកបាកាន ជាភូមិឋានតំបន់ពីរ។
ឮថាខេត្តពោធិ៍សាត់ មិនស្ងប់ស្ងាត់ពីដំណឹង
តំបន់នៅត្រង់ហ្នឹង ខ្មែរសុទ្ធសឹងតែបាត់សូន្យ។
និរាសប្រាស់ព្រាត់គ្នា ពូមីងមានិងបងប្អូន
ឪពុកម្តាយព្រមទាំងកូន ដូចជាក្បួនរសាត់ឆ្ងាយ។
របបដ៏អប្បិយ ជិះជាន់ឈ្លីខ្មែរទាំងឡាយ
បាត់បង់ស្លាប់ខ្ចាត់ខ្ចាយ ពុំរលាយទុក្ខកើនទ្វេ។
សព្វគ្រប់ទីកន្លែង កាប់គាស់សែងមិនទំនេរ
មិនមានថ្ងៃស្រួលទេ ទោះយើងគេដូចតែគ្នា។
នៅក្នុងភូមិរំលេច ចាំមិនភ្លេចគ្រប់អង្គា
ស្លាប់ច្រើនគរជើងគ្នា ពូមីងមាមិនសេសសល់។
នៅវត្តចន្ទរង្សី មានចេតិយដែលតម្កល់
ធាតុឆ្អឹងដែលនៅសល់ តម្កល់ទុកគ្រាន់បូជា។
ចាប់ពីចិតសិបប្រាំ ខ្មែរឯកម្មគ្រប់វេលា

ចេញពីភូមិនានា មកជុំគ្នានៅជនបទ។
ខ្លះមកតាមរថភ្លើង ខ្លះថ្មើរជើងមិនកំណត់
មិនធ្លាប់គិតថារត់ ឲ្យរួចផុតពីអង្គការ។
ជម្លៀសទាំងយប់ថ្ងៃ ជនប្រុសស្រីគ្រប់រូបា
បង្ខំឲ្យធ្វើការ គ្មានមេត្តាគ្រាប្រណី។
ធ្វើការទាំងល្ងាចព្រឹក ទោះបាយទឹកក៏គ្មានធី
ទម្រាំដល់ពេលថ្ងៃ ទើបបានស៊ីគ្រប់អង្គា។
ហើយបានក៏មិនឆ្អែត ត្រឹមមួយវែកចែករាល់គ្នា
ទោះខំធ្វើការងារ ក៏ពួកវាឲ្យមិនគ្រប់។
រីកោគផលដំណាំ ដែលយើងដាំដុះគ្រប់មុខ
ក៏មិនឲ្យស៊ីចុក វាគ្រាន់ទុកផ្គាប់អង្គការ។
ចេកដូងដំឡូងគ្រាវ និងអំពៅច្រើនផងណា
បានផ្លែកោគផល្លា ឲ្យអង្គការអ្នកចាត់ចែង។
សង្វេបប៉ុណ្ណឹងចុះ ជនស្រីប្រុសដឹងជាក់ស្តែង
ដ្បិតសាច់រឿងនៅវែង សុំលើកលែងតែត្រឹមនេះ។
ហៃ! ជនសម័យថ្មី ជាយុវវ័យមានចំណេះ
ស្រាវជ្រាវប្រវត្តិសាស្ត្រ ឲ្យបានច្បាស់ពីសាវតារ។
បំផុសនូវគំនិត ឈ្វេងយល់ពិតពីអក្ខរា
បានកត់លើសិលា ខំរក្សាតទៅអើយ។

ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២៤

ចប់

៦២

កំណាព្យ

អ្នកនិពន្ធ ៖ ឈ ឈុនឡា

៦២ ~ កំណាព្យ

សាច់រឿងពិតរបស់លោកអ៊ឹ ឆាំង ឃុ
បទពាក្យប្រាំពីរ

ពេលព្រឹកពន្លឺកពេញរស្មី ចូលដល់ថ្ងៃថ្មីសែនស្រស់ថ្លា
ជួបជុំមិត្តភក្តិច្រើនអស្ចារ្យ មានចិត្តហានក្លាគ្រប់ៗគ្នា។
គន់មើលយុវជនទាំងស្រីប្រុស ស័ក្តិសមឥតទាស់រូបកាយា
ហើយបាននិយាយពីកិច្ចការ ក្បោះក្បាយណាស់ណាល្អពន់ពេក។
បានជួបនាយកនៃអង្គការ គាត់មានវាចាយ៉ាងទន់ភ្លន់
លើករឿងគាត់ជួបកាលមុន សង្វេគពេកពន់គួរអនិច្ចា។
និយាយរឿងពិតដែលជាក់ស្តែង កាលគ្រានៅក្មេងដឹងហេតុការណ៍
បែកបាក់បងប្អូនក្រុមគ្រួសារ ជួបក្តីមរណាសែនសង្វេគ។
បងប្អូនកូនក្មួយនិងបងថ្លៃ ប៉ុល ពត ចង្រៃបានបំបែក
សម្លាប់ទាំងអស់មិនអល់អែក កូនតូចយំស្រែកព្រោះឃ្លានបៅ។
ពុកម្តាយស្លាប់ចោលកូនអស់ហើយ តែមិនយូរឡើយរឿងតទៅ
កូនបានស្លាប់ទៀតមិនឈប់នៅ សឹងផុតពូជផៅទាំងអស់គ្នា។

ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤

ចប់

ប្រវត្តិភូមិ

សេចក្តីផ្តើម

មជ្ឈមណ្ឌលឯកសារកម្ពុជា បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា តាំងពីឆ្នាំ២០០៤ ដើម្បីបង្កើតកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ជាការចាប់ផ្តើមដំបូងនៃកិច្ចការនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅឆ្នាំ២០០៧។ ចាប់តាំងពីពេលនោះមក សៀវភៅនេះជាភាសាខ្មែរ និងភាសាអង់គ្លេស ចំនួនជាងមួយលានក្បាល ត្រូវបានចែកចាយដល់សាធារណជន និងក្រសួង មន្ទីរ ព្រមទាំងគ្រឹះស្ថានសិក្សារដ្ឋនិងឯកជនប្រមាណជាង១៧០០ នៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ២០០៩ សៀវភៅណែនាំគ្រូបង្រៀនសម្រាប់ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ត្រូវបានបោះពុម្ពឡើងដើម្បីជាជំនួយដល់ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមសាលារៀន។ នៅឆ្នាំដដែល មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ជាមួយគ្រូបង្គោលចំនួន៣៩រូប មកពីក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅឆ្នាំ២០១០ និងឆ្នាំបន្តបន្ទាប់មកទៀត មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតវគ្គបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលកំពុងបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌-ពលរដ្ឋវិទ្យា និងភាសាខ្មែរ ចំនួនប្រមាណជាង៥៣ន់នាក់ មកពីទូទាំងប្រទេស ហើយគ្រូបង្គោលថ្នាក់ជាតិទាំង៣៩រូប ដែលទទួលបានការបណ្តុះបណ្តាលរួចហើយ គឺជាអ្នកបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានទាំងនោះ។

សម្រាប់ការអនុវត្តក្នុងដំណាក់កាលទីពីរ និងទីបីរបស់ខ្លួន មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងថ្មីៗបន្ថែមទៀត ដើម្បីបម្រើដល់ការពង្រឹងពង្រីកវិស័យអប់រំពីអំពើប្រល័យពូជសាសន៍ ឲ្យកាន់តែទូលំទូលាយជាងមុន។ គម្រោងវេទិកាថ្នាក់រៀនសម្រាប់សិស្សវិទ្យាល័យ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦ ដើម្បីលើកកម្ពស់ការស្វែងយល់បន្ថែម និងការចងចាំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ វេទិកានេះ ក៏ជាទម្រង់នៃវេទិកាពិភាក្សាមួយ ដើម្បីជំរុញលើកទឹកចិត្តសិស្ស ឲ្យត្រិះរិះពិចារណាស៊ីជម្រៅពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងរិះរកមធ្យោបាយនានាដើម្បីបង្ការការកើតឡើងវិញនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតយុទ្ធសាស្ត្រថ្មីមួយដែលជាចំណុចរបត់នៃកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចបានគោលដៅសំខាន់ៗរបស់គម្រោង និងដើម្បីផ្តល់ឱកាសដល់ប្រជាជនកម្ពុជានៅតាមមូលដ្ឋានជាច់ស្រយាលក្នុងការចូលរួមកសាងប្រវត្តិសាស្ត្ររបស់ខ្លួន។ តើមានអ្វីកើតឡើងចំពោះសហគមន៍ក្នុងប្រទេសកម្ពុជា? តើមានមនុស្សប៉ុន្មាននាក់ដែលដឹងថារឿងអ្វីកើតឡើង? តើរឿងរ៉ាវដែលកើតឡើងមានការចែករំលែកដល់សហគមន៍ ឬប្រជាជនទូទាំងប្រទេសដែរឬទេ? ដើម្បីដោះស្រាយចម្ងល់ទាំងនេះ យុទ្ធសាស្ត្រថ្មីរបស់គម្រោងនឹងផ្តោតជាសំខាន់ចំពោះគ្រូបង្រៀនមូលដ្ឋាន ដែលត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូមូលដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីឆ្នាំ២០០៩ រហូតដល់ការបណ្តុះបណ្តាលនៅខេត្តបាត់ដំបងក្នុងខែតុលា ឆ្នាំ២០១៦។ សម្រាប់ដំណាក់កាលដំបូងនៃគម្រោង មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងបញ្ចប់ក្នុងរយៈពេលពីរឆ្នាំ (ឆ្នាំ២០១៧-២០១៨)។ គ្រូបង្រៀនទាំងអស់អាចស្ម័គ្រចិត្តដើម្បីចូលរួមធ្វើការងារនេះ។

ប្រវត្តិភូមិជាអ្វី?

ប្រវត្តិភូមិ គឺជារឿងរ៉ាវដែលប្រមូលបានពីភូមិ ឬសហគមន៍។ និយាយឲ្យសាមញ្ញ វាអាចសំដៅទៅលើអ្វីដែលជារឿងរ៉ាវ និងបទពិសោធន៍ផ្ទាល់ខ្លួន អំពីពេលវេលា ទីកន្លែង ឬព្រឹត្តិការណ៍ជាក់លាក់ណាមួយដែលត្រូវបានកត់ត្រា និង

ចែករំលែក។ នេះមានន័យថា រឿងរ៉ាវនិងបទពិសោធន៍ទាំងអស់របស់អ្នកភូមិ ត្រូវបានកត់ត្រាពីស្ថានភាពជីវិតរស់នៅក្នុងសង្គម វប្បធម៌ ភូមិសាស្ត្រ នយោបាយ និងសាសនា។ អ្នកភូមិមានរឿងរ៉ាវដែលត្រូវប្រាប់ ហើយរឿងរ៉ាវទាំងនេះនៅតែត្រូវបានលើកមកជជែកតាមរយៈការអប់រំ។ ប៉ុន្តែនេះជាការអប់រំក្រៅប្រព័ន្ធ ដែលមានតួនាទីសំខាន់ក្នុងការចែករំលែករឿងដល់គ្នាទៅវិញទៅមក។ ប្រវត្តិសាស្ត្រភូមិស្រដៀងគ្នាទៅនឹងប្រវត្តិសាស្ត្រផ្ទាល់មាត់ដែរ។ យោងតាមលោក ដូណាល់ រីតឈី នៅក្នុងមគ្គុទ្ទេសក៍ដ៏ពេញនិយមរបស់គាត់ បានឲ្យដឹងថា ការចងក្រងប្រវត្តិសាស្ត្រផ្ទាល់មាត់ ចង់សំដៅទៅលើ “ការប្រមូលការចងចាំជារួម និងការអត្ថាធិប្បាយផ្ទាល់ខ្លួនអំពីសារសំខាន់ជាប្រវត្តិសាស្ត្រតាមរយៈការសម្ភាសន៍ដែលបានកត់ត្រាទុក”។ សរុបមក ប្រវត្តិភូមិ គឺជាវិធីសាស្ត្រមួយក្នុងការប្រមូល និងរក្សាទុកព័ត៌មានប្រវត្តិសាស្ត្រ តាមរយៈការសម្ភាសន៍ដែលបានកត់ត្រាជាមួយអ្នកចូលរួមក្នុងព្រឹត្តិការណ៍អតីតកាល និងរបៀបរស់នៅ។

ហេតុអ្វីត្រូវមានប្រវត្តិសាស្ត្រភូមិ?

រឿងរ៉ាវចេញពីភូមិ គឺជាផ្នែកមួយនៃ "ទឹកដីនៃការផ្សះផ្សា" ដែលអាចផ្តល់ចម្លើយចំពោះមូលហេតុ និងរបៀបដែលអំពើប្រល័យពូជសាសន៍ត្រូវបានកើតឡើង និងបង្ហាញពីភាពធន់របស់សហគមន៍កម្ពុជាក្នុងការរស់រានមានជីវិត និងកសាងជីវិតឡើងវិញ ព្រមទាំងបង្ហាញពីស្ថានភាពជីវិតនាពេលបច្ចុប្បន្ន។ ជាងនេះទៅទៀត ការចងក្រង «រឿងរ៉ាវចេញពីភូមិ» គឺអាចប្រើប្រាស់ជាសម្ភារឧបទេសសម្រាប់ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀនទូទាំងប្រទេស និងជាជំនួយដ៏ល្អសម្រាប់សិស្សានុសិស្សក្នុងការស្វែងយល់បន្ថែមពីជីវិតរស់នៅក្នុងរបបខ្មែរក្រហមរបស់អ្នករស់រានមានជីវិតទាំងឡាយ។

ក្នុងតួនាទីជាអ្នកគ្រប់គ្រង ណែនាំ និងបង្រៀន គ្រូបង្រៀនមានការទទួលខុសត្រូវបន្ថែមទៀត គឺមិនត្រឹមតែអប់រំសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកទឹកចិត្តអ្នកទាំងនោះឲ្យចងក្រងរឿងរ៉ាវរបស់ឪពុកម្តាយ ជីដូនជីតា សាច់ញាតិ និងអ្នកជិតខាងរបស់ខ្លួន ដើម្បីរក្សាការចងចាំពីអតីតកាលដ៏ឈោរឈៅដែលជាព្រឹត្តិការណ៍ពិត និងដើម្បីដំណើរការផ្សះផ្សា

នៅក្នុងគ្រួសារ និងសង្គមជាតិ។ គ្រូបង្រៀន មានតួនាទីយ៉ាងសំខាន់ក្នុងការប្រមូល និងសរសេររឿងរ៉ាវដែលនឹងត្រូវបោះពុម្ពជាសៀវភៅជារៀងរាល់ឆ្នាំ។ គ្រូបង្គោលថ្នាក់ខេត្តម្នាក់ៗ ដែលមកពីគ្រប់ស្រុកទាំងអស់នៃប្រទេសកម្ពុជា ត្រូវបានលើកទឹកចិត្តឲ្យសរសេរសោច់រឿងចេញពីភូមិចំនួនបីដែលអាចបោះពុម្ពបាន។ តាមរយៈយុទ្ធសាស្ត្រនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអាចបោះពុម្ពរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានចំនួន ៥៤០រឿងជារៀងរាល់ឆ្នាំ។ រឿងទាំងនេះ នឹងផ្តល់នូវការឆ្លើយតបជាក់ស្តែងកាន់តែរឹងមាំចំពោះសំណួរថា «ហេតុអ្វីបានជាខ្មែរក្រហមប្រព្រឹត្តអំពើឃោរឃៅបែបនេះនៅចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩ និងបង្ហាញឲ្យឃើញកាន់តែច្បាស់ថែមទៀតពីកត្តាដែលនាំដល់ការប្រព្រឹត្តអំពើឃោរឃៅទាំងនេះ។ សរុបមក រឿងរ៉ាវចេញពីភូមិទាំងនេះ នឹងផ្តល់នូវការពិពណ៌នាសង្ខេបអំពីរូបភាពទាំងមូលនៃប្រវត្តិសាស្ត្រខ្មែរក្រហម។

តើអ្វីជាគោលបំណងនៃប្រវត្តិសាស្ត្រភូមិ?

មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ជឿជាក់ថាការអប់រំពីអំពើប្រល័យពូជសាសន៍ និងមធ្យោបាយផ្សេងទៀតដើម្បីផ្សព្វផ្សាយចំណេះដឹងពីអំពើឃោរឃៅរបស់ខ្មែរក្រហម អាចដឹកនាំសង្គមកម្ពុជាឆ្ពោះទៅរកការបង្រួបបង្រួមជាតិ និងការព្យាបាលរបួសផ្លូវចិត្តជាបុគ្គល។ នេះជាស្ពានឆ្ពោះទៅរកយុត្តិធម៌អន្តរកាល ឬគណៈកម្មការស្វែងរកការពិតនៅកម្ពុជា។ ដូច្នេះគម្រោងនេះមានគោលបំណង៖

១- បម្រើជាគណៈកម្មាធិការស្វែងរកការពិត និងការផ្សះផ្សា។

២- ជាយន្តការយុត្តិធម៌អន្តរកាល។

៣- កសាងការចងចាំពីមូលដ្ឋាន។

៤- បណ្តុះបណ្តាលគ្រូមូលដ្ឋានឲ្យក្លាយជាអ្នកប្រវត្តិសាស្ត្រភូមិ ដោយឲ្យពួកគាត់បន្តចូលរួមអប់រំពីអំពើប្រល័យពូជសាសន៍ តាមរយៈការសរសេរប្រវត្តិសាស្ត្រចេញពីភូមិ ឬសហគមន៍របស់ខ្លួន។

៥- ពង្រឹងសមត្ថភាពគ្រូមូលដ្ឋាន ឲ្យមានភាពឆ្លាតវៃក្នុងការធ្វើការស្រាវជ្រាវ ដើម្បីអាចផ្ទេរចំណេះដឹងនេះដល់សិស្សរបស់ខ្លួនបាន។

ឧស្សាហដ្ឋីស្វែងរកការពិត

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នស្រាវជ្រាវកម្ពុជាឯករាជ្យមួយ ដែលប្តូរផ្តាច់ក្នុងការចងក្រងឯកសារស្តីអំពីប្រវត្តិនៃអំពើប្រល័យពូជសាសន៍ ប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ១៩៧៥ដល់១៩៧៩។ របបកម្ពុជាប្រជាធិបតេយ្យនេះ ត្រូវបានស្គាល់ជាទូទៅថាជារបបប្រល័យពូជសាសន៍ ឬរបបខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់បដិសន្ធិឡើងជាផ្លូវការនៅក្នុងខែមករា ឆ្នាំ១៩៩៥។ មជ្ឈមណ្ឌលឯកសារកម្ពុជារហូតមកទល់បច្ចុប្បន្ននេះបានទទួលការគាំទ្រពីសំណាក់អង្គការមូលនិធិអន្តរជាតិ និងបណ្តាប្រទេសនានាចំនួន៣៩ នៃទ្វីបចំនួន៤ គឺអាមេរិក, អឺរ៉ុប, អាស៊ី និង អូសេអានី។ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ការស្វែងរកយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជាតាមរយៈតុលាការឯករាជ្យមួយ គឺទាមទារឲ្យមានការចូលរួមត្រួតពិនិត្យឲ្យបានដិតដល់ពីសំណាក់សាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់ ជាពិសេសបំផុតនោះ គឺជនរងគ្រោះដោយរបបខ្មែរក្រហម។ ជនរងគ្រោះទាំងអស់ ត្រូវសមនឹងទទួលបាននូវតុលាការស្របច្បាប់មួយដែលអាចស្វែងរកយុត្តិធម៌បានដោយត្រឹមត្រូវ និងមិនលម្អៀង។ ហេតុដូច្នេះ ជនរងគ្រោះទាំងអស់ត្រូវការចាំបាច់ឲ្យមានការផ្តល់ព័ត៌មានជាលម្អិតស្តីអំពីដំណើរការតុលាការ និងរឿងក្តីនានា ដោយរាប់បញ្ចូលទាំងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមទៀតផង ដើម្បីផ្សារខ្លួនភ្ជាប់ទៅនឹងដំណើរការនេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជានឹងដើរតួនាទីជា «និរសោ» ឲ្យជនរងគ្រោះពីរបបខ្មែរក្រហមលើបញ្ហាទាំងអស់ខាងលើ។ ដើម្បីសម្រេចភារកិច្ចនេះបានមជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅបើកយុទ្ធនាការអប់រំមួយតាមរយៈការផ្សព្វផ្សាយចំណេះដឹងអំពីនីតិវិធីតុលាការកាត់ទោសរបបខ្មែរក្រហម និងរឿងរ៉ាវប្រវត្តិសាស្ត្រនានាដែលពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហម ដោយផ្អែកលើឯកសារដើមទាំងស្រុង។ ឯកសារទាំងអស់នោះមានតម្កល់នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រមទាំងប្រភពផ្សេងៗទៀត រួមមានមហាវិទ្យាល័យច្បាប់ធំៗនៅសហរដ្ឋអាមេរិក និងអឺរ៉ុប, អង្គការក្រៅរដ្ឋាភិបាលនានា, អ្នកជំនាញការច្បាប់ និងអ្នកប្រវត្តិវិទូអំពីប្រទេសកម្ពុជាក្នុងនោះរួមមានទាំងក្រុមប្រឹក្សា និងទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

មជ្ឈមណ្ឌលឯកសារកម្ពុជា និងធ្វើការផ្សព្វផ្សាយជូនដល់ជនរងគ្រោះពីរបបខ្មែរក្រហមតាមរយៈទស្សនាវដ្តីមួយដែលចេញផ្សាយរៀងរាល់ខែ។ ទស្សនាវដ្តីនេះមានឈ្មោះថា «ស្វែងរកការពិត» ដែលអស់លោកអ្នកកំពុងអាន។ នៅក្នុងប្រទេសកម្ពុជា មានប្រភពព័ត៌មានឯករាជ្យតិចតួចស្ដួចស្ដើងណាស់។ សារព័ត៌មានវិទ្យុ ទូរទស្សន៍ ភាគច្រើន បានសម្រេចចិត្តឈរនៅលើបញ្ហានយោបាយម្ខាងៗ។ សូម្បីតែវិទ្យុផ្សាយសម្លេងរបស់សហរដ្ឋអាមេរិក ដែលផ្សាយជាភាសាខ្មែរក៏ត្រូវបានមជ្ឈដ្ឋានមួយចំនួនចាត់ទុកថា មាននិន្នាការនយោបាយទៅរកបក្សសម្ព័ន្ធណាមួយដែរ។ ទស្សនាវដ្តី «ស្វែងរកការពិត» នឹងបំពេញនូវតម្រូវការដ៏សំខាន់ចាំបាច់នេះក្នុងការបង្កើតឲ្យមាននូវប្រភពផ្សព្វផ្សាយចំណេះដឹងជាភាសាខ្មែរ និងឯករាជ្យមួយស្ដីអំពីបញ្ហាតុលាការ និងប្រវត្តិសាស្ត្រខ្មែរក្រហម។ ដើម្បី ធានាឲ្យមានយុត្តិធម៌មួយត្រូវបានកើតចេញពីអង្គតុលាការឯករាជ្យហើយថែមទាំងត្រូវបានសាធារណជន ជាពិសេស ប្រជាជនកម្ពុជា ដែលរួចផុតពីសេចក្ដីស្លាប់ក្នុងរបបខ្មែរក្រហមបានឃើញដោយផ្ទាល់នឹងផ្នែកថា «យុត្តិធម៌» ពិតជាត្រូវបានធ្វើឡើងមែននោះចាំបាច់គឺតម្រូវឲ្យមានការលើកកម្ពស់នូវការយល់ដឹងជាទូទៅជាសាធារណៈអំពីនីតិវិធី ច្បាប់ថាតើ នីតិវិធីនៅក្នុងតុលាការខ្មែរក្រហមត្រូវបាន

ឆ្លើយតបពេញលេញដែរឬទេ? ទស្សនាវដ្តីស្វែងរកការពិតនឹងបំពេញតួនាទីបន្ថែមទៀតជា «អ្នកឃ្លាំមើលនិងការពារ» ក្នុងដំណើរកាត់ទោស ហើយនឹងធ្វើកំណត់នូវកម្រិតនៃការជ្រៀតជ្រែកផ្នែកនយោបាយឲ្យបានប្រហាក់ប្រហែលនឹងសារព័ត៌មានខ្មែរដែលមានលក្ខណៈសេរី និងឯករាជ្យអាចធ្វើទៅបាន។ ទោះជាក្នុងស្ថានភាពណាក៏ដោយ ការផ្តល់ជូនព័ត៌មានថ្មីៗ និងការពន្យល់ជាទូទៅអំពីដំណើរការទាំងឡាយ ដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់តុលាការនឹងមានតម្លៃធំធេងណាស់ដល់ជនរងគ្រោះដោយសាររបបខ្មែរក្រហម និងសាធារណជនកម្ពុជាទាំងមូល។

ជាការពិតណាស់មានការវែកញែកតាមផ្លូវសីលធម៌និងផ្លូវច្បាប់ដ៏គួរឲ្យជឿជាក់មួយថា ប្រជាជនកម្ពុជាដែលសេសសល់ពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម ហើយដែលធ្លាប់បានទទួលរងនូវការរំលោភសិទ្ធិយ៉ាងកម្រោល គឺមានសិទ្ធិក្នុងការយល់ដឹងនូវការពិតនៃព្រឹត្តិការណ៍ទាំងឡាយ ដែលបានកើតឡើង។ ជាក់ស្តែងគ្រប់ពេលដែលខ្ញុំសាកសួរទៅដល់ជនរងគ្រោះពីរបបខ្មែរក្រហមរាប់ពាន់នាក់ ជនរងគ្រោះស្ទើរតែគ្រប់គ្នាទាំងអស់នោះបានរៀបរាប់ និងចោទសួរនូវចម្ងល់ដូចគ្នាថាតើ រឿងរ៉ាវខ្មែរក្រហមនេះបានកើតឡើងយ៉ាងដូចម្តេច? ជាពិសេសចង់ដឹងថានរណាជាអ្នកបញ្ជាឲ្យសម្លាប់មនុស្ស និងដោយសារមូលហេតុអ្វី?។ ការបោះពុម្ពផ្សាយដោយសច្ចភាពនូវរឿងហេតុ ដែលកើតឡើងនៅចំពេលដែលតុលាការខ្មែរក្រហមហៀបនឹងចាប់ដំណើរការ នឹងផ្តល់នូវយន្តការប្រាប់ការពិតមួយ។ នេះគឺជាផ្នែកមួយដ៏សំខាន់នៃការបង្រួបបង្រួមជាតិ។ ដូចជានៅប្រទេសអាហ្វ្រិកខាងត្បូងមានការចាក់ផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ នូវដំណើរការសវនការមួយភាគធំរបស់គណៈកម្មាធិការបង្រួបបង្រួម និងការពិត។ កម្ពុជាពុំមានការផ្សព្វផ្សាយព័ត៌មាន តាមវិទ្យុ ទូរទស្សន៍ដែលមានលក្ខណៈឯករាជ្យពិតប្រាកនៅឡើយទេ ម្ល៉ោះហើយដោយមូលហេតុថា មាននិន្នាការនយោបាយសារព័ត៌មានទាំងនោះនឹងមិនទំនងជារៀបរាប់បកស្រាយនូវការពិតទាំងសងខាងអំពីរឿងរ៉ាវនានាដូចដែលបានកើតឡើងនោះទេ។ ដូច្នេះហើយទើបទស្សនាវដ្តីមួយដែលរួមចំណែកដល់ទីបញ្ចប់ អំពីដំណើរការកាត់ទោសរបបខ្មែរក្រហម គឺ

មិនគ្រាន់តែជួយបំពេញចន្លោះខ្វះខាតផ្នែកផ្សព្វផ្សាយព័ត៌មានតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំពេញតួនាទីពិសេសមួយទៀត គឺការព្យាបាលរបួសផ្លូវចិត្តរបស់ជនរងគ្រោះទៀតផង តាមរយៈការផ្សព្វផ្សាយនូវអ្វីដែលជាការពិត។ ភាពឯករាជ្យទាំងស្រុង និងភាពស្វ័យគ្រប់គ្រងខ្លួនឯងដោយពេញលេញព្រមទាំងលទ្ធភាពផ្សព្វផ្សាយ ចែកចាយព័ត៌មានជាភាសាខ្មែររបស់ទស្សនាវដ្តីស្វែងរកការពិត ទូទាំងប្រទេសកម្ពុជាគឺមានសារសំខាន់ធំធេងណាស់។

ទស្សនាវដ្តីស្វែងរកការពិតនឹងក្លាយទៅជាប្រភពព័ត៌មានតែមួយគត់នៅក្នុងប្រទេសកម្ពុជាដែលបំពេញទៅតាមលក្ខណៈវិនិច្ឆ័យទាំងអស់នោះ។ មិនតែប៉ុណ្ណោះទៀតសោត ទស្សនាវដ្តីស្វែងរកការពិត ក៏អាចចុះផ្សាយនូវប្រធានបទ និងបញ្ហានានាដទៃទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រភពព័ត៌មានដ៏ច្រើនលើសលប់លើប្រធានបទនិងបញ្ហាទាំងអស់នោះ ប៉ុន្តែប្រហែលជាមិនឈានឆ្ពោះទៅរកការពាក់ព័ន្ធនឹងការកាត់ទោសរបបខ្មែរក្រហមទេ។ ឧទាហរណ៍ ដូចជាប្រធានបទស្តីអំពីអំពើហិង្សាលើស្ត្រីភេទនៅក្រោមរបបខ្មែរក្រហម និងអំពើហិង្សាទៅលើ ជនជាតិភាគតិច និង ព្រះសង្ឃជាដើម។ល។ ទស្សនាវដ្តីស្វែងរកការពិតនឹងអាចក្លាយជាប្រភពព័ត៌មានមួយនៅក្នុងចំណោមប្រភពព័ត៌មាននានានៅក្នុងពិភពលោក ស្តីអំពីបញ្ហាអ្វីដែលសាធារណជនតែងតែមើលរំលង។ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមបញ្ជាក់ឲ្យអស់កង្វល់ថាទស្សនាវដ្តីស្វែងរកការពិត នឹងក្លាយទៅជាទស្សនាវដ្តីតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលផ្សព្វផ្សាយអំពីបញ្ហានេះជាភាសាខ្មែរ។ បណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាប្រភពឯកសារដ៏ពិសិដ្ឋនៅក្នុងប្រទេសកម្ពុជាដែលស្ថិតនៅក្នុងភាពឯករាជ្យ។ ព័ត៌មានដែលចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជាគឺមានលក្ខណៈឯករាជ្យលើផ្លូវនយោបាយ ហើយមិនផ្សព្វផ្សាយដើម្បីបម្រើឲ្យផលប្រយោជន៍ ឬគោលបំណងផ្នែកនយោបាយណាមួយឡើយ។

លើសពីនេះទៅទៀត ទស្សនាវដ្តីស្វែងរកការពិតផ្ទាល់ខ្លួនឯងអាចប្រើប្រាស់ធ្វើជាឯកសារប្រវត្តិសាស្ត្រទូទៅសម្រាប់កត់ត្រាដំណើរការរបស់ប្រទេសជាតិមួយ

ដែលកំពុងត្រួតពិនិត្យអតីតកាលរបស់ខ្លួនឡើងវិញ ហើយនឹងកំពុងតែបោះជំហាន ទៅមុខជាមួយនឹងដំណើរការ បង្រួបបង្រួមជាតិជាពិសេសគឺប្រតិកម្មដែលកំពុង លេចឡើងជាបន្តបន្ទាប់ ជុំវិញបញ្ហាកាត់ទោសរបបខ្មែរក្រហម ដែលកំពុងត្រូវ បានបញ្ចូលនៅក្នុងដំណើរការរឿងទាំងអស់នោះ។ ប្រជាជនកម្ពុជាគឺជាចំណាត់ ខ្មាំងចំពោះអតីតកាលរបស់ខ្លួន។ ប្រជាជនកម្ពុជាទាំងអស់មិនអាចអស់បញ្ហា និងចម្ងល់នៃភាពហ្មងសៅពីក្នុងខ្លួន ឬមានសេរីភាពពេញលេញបានទេ ដរាបណា មិនទាន់មានយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍។ កម្ពុជាអាចបោះជំហាន ទៅមុខ និងប្រែក្លាយខ្លួនទៅជាសង្គមប្រជាធិបតេយ្យរឹងមាំមួយបាន លុះត្រាតែ ប្រជាជនរបស់ខ្លួនត្រូវបានអនុញ្ញាតឲ្យយល់ដឹងការពិតអំពីអតីតកាលដ៏ភ័យរន្ធត់ របស់ប្រទេសជាតិខ្លួន។ សិស្សានុសិស្សនាបច្ចុប្បន្ននេះពុំមានការចងចាំអំពី ព្រឹត្តិការណ៍សំខាន់ៗទសវត្សរ៍ ឆ្នាំ៧០ រីឯកម្មវិធីសិក្សាផ្នែកប្រវត្តិវិទ្យាក្នុង ទស្សវត្សរ៍ ឆ្នាំ៨០ ទៀតសោតត្រូវបានទទួលរងនូវការរិះគន់យ៉ាងខ្លាំងដោយសារ ការបកស្រាយអំពីរបបខ្មែរក្រហមជាលក្ខណៈនយោបាយតែប៉ុណ្ណោះ។ ប្រជាជន កម្ពុជាភាគច្រើនត្រូវការចម្លើយចំពោះជោគវាសនារបស់ក្រុមគ្រួសារដែលបាន បាត់ខ្លួន ឬបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមដើម្បីឲ្យខ្លួនបានសូប់នៅក្នុងចិត្ត។ យុវវ័យកម្ពុជាជំនាន់ក្រោយ ត្រូវការយល់ដឹងអំពីអតីតកាលដែលញាំញីទៅដោយ បញ្ហាស្មុគស្មាញនានារបស់ជាតិខ្លួន ប្រសិនបើយុវវ័យជំនាន់ឥឡូវ ត្រូវជំនះបាន លើកេរមរតកដ៏ល្វីងជូរចត់នេះហើយកសាងអនាគតមួយប្រកបដោយសន្តិភាព តាមគន្លងលទ្ធិប្រជាធិបតេយ្យ។

ទស្សនាវដ្តីស្វែងរកការពិតនឹងជួយនាំខ្លួនជនទាំងឡាយណាដែលបាន ប្រព្រឹត្តបទឧក្រិដ្ឋនានានៅក្នុងរបបខ្មែរក្រហមទៅឲ្យតុលាការវិនិច្ឆ័យទោស។ ការដាក់ទណ្ឌកម្មចំពោះជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋនានា គឺជាអំពើ មួយដ៏មានអត្ថន័យ និងមហិទ្ធិឫទ្ធិខ្លាំងក្លាបំផុតដែលអាចផ្ញើជូន និងជម្រាបប្រាប់ ដល់ប្រជាជាតិខ្មែរទាំងអស់ថា ខ្លួនមានសិទ្ធិសេរីភាពស្មើៗគ្នាចំពោះមុខច្បាប់ នៅក្នុងសង្គមប្រជាធិបតេយ្យ។ លទ្ធផលដ៏មានសារសំខាន់បំផុតនៃតុលាការ

ខ្មែរក្រហម គឺឥទ្ធិពលរបស់តុលាការនេះទៅលើ «វប្បធម៌នៃភាពគ្មានទោស» នៅកម្ពុជា។ បច្ចុប្បន្ននេះ ស្ទើរតែជាទូទៅមន្ត្រីរាជការកម្ពុជាជាច្រើន ក្នុងនោះមានអ្នកនយោបាយ ប៉ូលីស និង ទាហាន ហើយសូម្បីតែប្រជាជនសាមញ្ញបានសុខចិត្ត ទទួលយកដោយចាត់ទុកថា វប្បធម៌នៃ «ភាពនិរទេស ឬភាពគ្មានទោស» នេះជាប្រការមួយដែលមិនអាចជៀសផុតបាន ហើយថែមទាំងបានសុខចិត្ត ទទួលយកថា «អ្នកខ្លាំងយកអ្វីៗគ្រប់យ៉ាងដែលអាចយកបាន ឯអ្នកខ្សោយទទួលរងនូវអ្វីៗគ្រប់យ៉ាងដែលត្រូវទទួលរង ហើយគ្មាននរណាម្នាក់សង្ឃឹមថា បទដ្ឋានច្បាប់នឹងចូលមកធ្វើអន្តរាគមន៍កែប្រែទម្លាប់នេះឡើយ»។ ប៉ុន្តែការធ្វើយ៉ាងណាដើម្បីដាក់ទណ្ឌកម្មឲ្យបានលើឧក្រិដ្ឋជនសាហាវយង់ឃ្នងបំផុត នាសតវត្សរ៍ទី២០ កន្លងមកថ្មីៗនេះ ដូចជាមេដឹកនាំខ្មែរក្រហមជាដើម គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត ដែលតាមរយៈសកម្មភាពនេះកម្ពុជាអាចជម្រះចោលនូវវប្បធម៌នៃភាពគ្មានទោស ហើយពង្រឹងមូលដ្ឋានគ្រឹះមួយដែលមិនងាយបែកបាក់សម្រាប់សង្គមកម្ពុជាថ្មីមួយដែលកសាងឡើងផ្អែកលើបទដ្ឋានច្បាប់។ នេះគឺជាគន្លឹះដ៏វិសេសវិសាលក្នុងការជួយប្រទេសកម្ពុជា ឲ្យប្រែក្លាយទៅជានីតិរដ្ឋដ៏ពិតប្រាកដមួយ។

គោលបំណងសំខាន់ៗរបស់ទស្សនាវដ្តីស្វែងរកការពិតមានជាអាទិ៍គឺ ទី១៖ គាំទ្រតុលាការឯករាជ្យមួយដើម្បីធ្វើការវិនិច្ឆ័យលើបទឧក្រិដ្ឋនានា ដែលប្រព្រឹត្តឡើងដោយរបបខ្មែរក្រហមរវាងឆ្នាំ១៩៧៥-១៩៧៩ និងលើសពីនេះទៀតគឺដើម្បីអប់រំ និងរួមចំណែកដល់ការស្ថាបនាមូលដ្ឋានច្បាប់នៅក្នុងប្រទេសកម្ពុជា។ ទី២៖ ជំរុញឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពី៖ ក- នីតិវិធីនៃដំណើរការរបស់តុលាការខ្មែរក្រហមនិង ខ- ប្រវត្តិសាស្ត្រ នៃរបបខ្មែរក្រហមដោយផ្អែកលើឯកសារដើមដែលមានតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាប័ននានា។ ទី៣៖ បំពេញនាទីជាវេទិកាមួយសម្រាប់ការជជែកវែកញែកស្តីអំពីដំណើរការរបស់តុលាការ និងប្រវត្តិសាស្ត្រខ្មែរក្រហម និង ទី៤៖ បំពេញនាទីជាប្រភពផ្តល់ព័ត៌មានសម្រាប់ប្រជាជាតិកម្ពុជាដើម្បីបានយល់ដឹង និងបានជជែកវែកញែកនូវអ្វីដែលកំពុងកើតឡើង ឬមិនបានកើតឡើងជាលក្ខណៈអន្តរជាតិ ឧទាហរណ៍

លក្ខន្តិកទីក្រុងរ៉ូម រឿងក្តីពីណូដេ អតីតមេដឹកនាំនៅ ប្រទេសឈីលី ឬ ក៏រឿងក្តីមីឡូសូវិក បច្ចុប្បន្នមេដឹកនាំនៅប្រទេសយូហ្គូស្លាវីជាដើម។ ព្រឹត្តិការណ៍ដែលកំពុងបាន និងមិនបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺជៈឥទ្ធិពលលើបទដ្ឋានអន្តរជាតិ នេះ ហើយខ្ញុំជឿថា អ្នកអាននឹងចង់ដឹងរឿងរ៉ាវពីខាងក្រៅ ក៏ដូចគ្នាពីខាងក្នុងប្រទេសដែរ។ ក្រុមអ្នកជំនាញការច្បាប់ អ្នកប្រាជ្ញ និងប្រវត្តិវិទូអំពីបញ្ហាកម្ពុជា និងអ្នកយកព័ត៌មានឯករាជ្យដែលមានបទពិសោធន៍ខ្ពស់នឹងធ្វើការវាយតម្លៃលើអត្ថបទនៃទស្សនាវដ្តីស្វែងរកការពិត។ ជាបន្ថែមទៀតនឹងមានក្រុមប្រឹក្សានិពន្ធដែលចំណុះដោយអ្នកជំនាញផ្នែកច្បាប់ និងប្រវត្តិសាស្ត្រត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យអត្ថបទរបស់ទស្សនាវដ្តីស្វែងរកការពិតមុនពេលចេញផ្សាយ។

ទស្សនាវដ្តីស្វែងរកការពិតស្វាគមន៍ និងលើកទឹកចិត្តដល់ការចូលរួមផ្តល់មតិយោបល់ពីសាធារណជនទូទៅចំពោះដំណើរការកាត់ទោសរបបខ្មែរក្រហម និងចំពោះការអានជាទូទៅនៃប្រវត្តិសាស្ត្រដ៏គួរឲ្យតក់ស្លុតមួយ។ ខ្ញុំសង្ឃឹមថា ទស្សនាវដ្តីស្វែងរកការពិត អាចជួយធ្វើជាមិត្តដ៏ល្អដ៏កម្រកបានដល់អ្នកអានគ្រប់ៗរូប។ ទស្សនាវដ្តីស្វែងរកការពិតគឺអាចជាមិត្តដ៏ពិតម្នាក់ដែលតាមរយៈមិត្តម្នាក់នេះ អ្នកអានអាចសិក្សា និងពិភាក្សាជាមួយ នៅពេលដែលអ្នកអានមានការចង់ដឹងចង់យល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមឲ្យកាន់តែច្បាស់ថែមទៀត។ ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណគុណដល់បងប្អូនខ្មែរគ្រប់រូប ជាពិសេសបងប្អូននៅតាមភូមិជនបទដាច់ស្រយាល ដែលតែងតែបានជួយជ្រោមជ្រែងរូបខ្ញុំក្នុងការស្រាវជ្រាវនានា និងបានជួយធ្វើឲ្យរូបខ្ញុំបានមកដល់គោលដៅដ៏ប្រពៃសព្វថ្ងៃនេះ។ ថ្វីបើខ្ញុំមិនអាចចងចាំឈ្មោះទាំងអស់គ្នាឲ្យបានគ្រប់ៗរូបយ៉ាងណាក៏ដោយ ខ្ញុំសូមបញ្ជាក់ប្រាប់ឲ្យបានដឹងថា ពូ អ៊ំ មា មីង បងប្អូនទាំងអស់គ្នាស្ថិតនៅក្នុងបេះដូងរបស់ខ្ញុំរៀងរាល់ថ្ងៃ យ៉ាងកក់ក្តៅជាទីបំផុត។ សូមបន្តការចូលរួមចំណែកដើម្បីស្វែងរកការពិត និងយុត្តិធម៌ជូនដល់ជនរងគ្រោះនៃរបបខ្មែរក្រហម។ ដោយសេចក្តីគោរពនិងរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

អ្នកនិពន្ធ

រឿង ចាយភ្នាំង
អ្នកនិពន្ធ៖ អ៊ុច សំណាង
ទីលំនៅបច្ចុប្បន្ន៖ ភូមិឡកំបោរ សង្កាត់ស្វាយប៉ា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។
ការងារ៖ អនុប្រធានក្រុមការងារស្រាវជ្រាវយុទ្ធសាស្ត្រយោធា អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ។
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ។

រឿង ពេលដែលម៉ែឃ្លាតទៅ
អ្នកនិពន្ធ៖ អៀ ហុកនីម
ទីកន្លែងកំណើត៖ ភូមិស្វាយភ្លើង ឃុំស្វាយភ្លើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។
ការងារ ៖ ធ្វើជាកសិករ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។
ការសិក្សា៖ បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម សាកលវិទ្យាល័យ RMIT ប្រទេសអូស្ត្រាលី។

រឿង ស្នាមដំបៅ
អ្នកនិពន្ធ៖ វ៉ា មឿន
ទីលំនៅបច្ចុប្បន្ន៖ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពន់ទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។
ការងារ៖ ទីប្រឹក្សាអង្គការម្លប់បៃតង
ការសិក្សា៖ ឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩ ផ្នែកផែនការអប់រំនៅប្រទេសបារាំង។
ឆ្នាំ១៩៨១ សាលាគរុកោសល្យវិជ្ជាជាន់ខ្ពស់ បច្ចុប្បន្នសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

រឿង ក្រោមមេឃតែមួយ
អ្នកនិពន្ធ៖ ឃុត សុខឿន
ទីលំនៅបច្ចុប្បន្ន៖ ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។
ការងារ៖ អ្នកតំណាងប្រចាំប្រទេសកម្ពុជា នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីប្រព័ន្ធផ្សព្វផ្សាយសកល
ការសិក្សា៖ បិញ្ញាបត្រផ្នែកអប់រំ (TEFL) ពីសាកលវិទ្យាល័យបៀលប្រាយនៅឆ្នាំ២០០៥។
ឆ្នាំ២០០១ បញ្ចប់ការសិក្សាផ្នែកគរុកោសល្យ និងការបង្រៀនភាសាអង់គ្លេសពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃវែង។

រឿង ព្រះអាទិត្យឥតពន្លឺ
អ្នកនិពន្ធ៖ គង់ ច័ន្ទវ៉ាន់ណេង
ទីលំនៅបច្ចុប្បន្ន៖ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ការងារ៖ អ្នកនិពន្ធធុរកិច្ច
ការសិក្សា៖ កំពុងសិក្សាថ្នាក់បរិញ្ញបត្រ
ជាន់ខ្ពស់ នៅសាកលវិទ្យាល័យជាតិ
គ្រប់គ្រង។
ឆ្នាំ២០១៨ បរិញ្ញាបត្រកាសាអង់គ្លេសនៅ
សាកលវិទ្យាល័យ អាស៊ីអឺរ៉ុប ។

រឿង មួយថ្ងៃ មួយយប់
អ្នកនិពន្ធ៖ ម៉ៅ សុវណ្ណឌី
ទីលំនៅបច្ចុប្បន្ន៖ រស់នៅភូមិដីរីជាន់ខ្លា
សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន
ខេត្តកំពង់ធំ។
ការងារ៖ មន្ត្រីចូលនិវត្តន៍

រឿង ជើងមេឃពណ៌ក្រហម
អ្នកនិពន្ធ៖ ឆាន់ វុត្ថា
ទីលំនៅបច្ចុប្បន្ន៖ ភូមិព្រៃធំ ឃុំស្មោង
ខាងត្បូង ស្រុកកំចាយមារ ខេត្តព្រៃវែង។
ការងារ៖ អ្នកនិពន្ធ
ការសិក្សា៖ ឆ្នាំ២០១៣-២០១៥ រៀននៅ
សកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកព័ត៌មាន
វិទ្យា តែរៀនមិនចប់ព្រោះបញ្ហាជីវភាព និង
សុខភាព។

រឿង មិនព្រមរៀបការ
អ្នកនិពន្ធ៖ គីម សាត
ទីលំនៅបច្ចុប្បន្ន៖ ភូមិសេរីសុខា ឃុំក្រែក
ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
ការងារ៖ គ្រូបង្រៀន
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់ នៅពុទ្ធិក
សាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតី
តេជោហ៊ុន សែន កំពង់ចាម ឯកទេសអក្សរ
សាស្ត្រខ្មែរ។

រឿង អាប់សែ
អ្នកនិពន្ធ៖ រឹម ទិត្យបញ្ញា
ទីលំនៅបច្ចុប្បន្ន៖ ភូមិមីល សង្កាត់ដង្កោ
ខណ្ឌដង្កោ រាជធានីភ្នំពេញ។
ការងារ៖ គ្រូបង្រៀន
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់ សាកល
វិទ្យាល័យភូមិន្ទភ្នំពេញ។

រឿង ឈ្លើយសឹក
អ្នកនិពន្ធ៖ ច័ន្ទ មុនី
ទីលំនៅបច្ចុប្បន្ន៖ ភូមិ១២ សង្កាត់បឹងកក់២
ខណ្ឌទួលគោក រាជធានីភ្នំពេញ។
ការងារ៖ នាយសេនាធិការង
កងទ័ពជើងគោក នៃកងយោធពល
ខេមរភូមិន្ទ។

រឿង ផ្សែងអ័ព្ទ
អ្នកនិពន្ធ៖ រ៉ែត សារ៉ុន

រឿង ការចងចាំម្តាយខ្ញុំ
អ្នកនិពន្ធ៖ ហ៊ិត វាសនា

រឿង នៅពីក្រោយសំឡេងច្រៀង
អ្នកនិពន្ធ៖ ម៉ក់ ខេមរិន្ទ
ទីលំនៅបច្ចុប្បន្ន៖ ភូមិក្រឡាញ់ ឃុំក្រឡាញ់
ស្រុកក្រឡាញ់ ខេត្តសៀមរាប។
ការងារ៖ គ្រូបង្រៀនកម្រិតមូលដ្ឋាន នៅ
អនុវិទ្យាល័យភូមិគំរូ ស្រុកក្រឡាញ់
ខេត្តសៀមរាប។
ការសិក្សា៖ បញ្ចប់បរិញ្ញាបត្រគណិតវិទ្យា
សាកលវិទ្យាល័យឯកទេសនៃកម្ពុជា
(CUS)។

រឿង រឿងជីវិត
អ្នកនិពន្ធ៖ នាក់ សុភឿន

រឿង ដង្កើមស្នេហ៍ ក្បែរកម្លាំងត្បូងចប
អ្នកនិពន្ធ៖ គាំង យ៉ែន

រឿង គ្រួសារខ្ញុំក្នុងរបបឥណពិឃាត
អ្នកនិពន្ធ៖ រ័ត្ន សេនា
ទីកន្លែងកំណើត៖ ភូមិអង្គ្រង ឃុំស្វាយរំពា ស្រុកស្វាយទាប ខេត្តស្វាយរៀង។
ការងារ៖ កងយោធពលខេមរភូមិន្ទ (នាយការិយាល័យអប់រំចិត្តសាស្ត្រ)
ការសិក្សា៖ សិក្សាផ្នែកជំនាញចិត្តសាស្ត្រ។

រឿង ជីវិតខ្មៅក្នុងរបប ប៉ុល ពត
អ្នកនិពន្ធ៖ ឈាង សោភ័ណ្ឌ
ទីលំនៅបច្ចុប្បន្ន៖ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។
ការងារ៖ ចាងហ្វាងការផ្សាយស្ថាប័នព័ត៌មាន ស៊ី អេស ភី (CSP TV News)
ការសិក្សា៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ ឯកទេសគ្រប់គ្រងពាណិជ្ជកម្ម។

រឿង អន្ទះផ្លែឫស្សី
អ្នកនិពន្ធ៖ កែវ ពុទ្ធិន
ទីលំនៅបច្ចុប្បន្ន៖ ភូមិត្បែងប្រជាប់ ឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។
ការងារ៖ ជាមន្ត្រីរាជការ បម្រើការងារនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ។
ការសិក្សា៖ បរិញ្ញាបត្រឯកទេសអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
ឆ្នាំ២០១៦-២០១៧ វិទ្យាស្ថានជាតិអប់រំ។

រឿង រស្មីពន្លឺក្រោមដំបូលមេឃនៃភពចិត
អ្នកនិពន្ធ៖ តែ ហេងលី

រឿង ភូមិខ្ញុំក្នុងសម័យ ប៉ុល ពត
អ្នកនិពន្ធ៖ សង ហេង
ទីកន្លែងកំណើត៖ រស់នៅភូមិសាលាឃុំ ឃុំទ្រៀល ស្រុកតាំងគោក ខេត្តកំពង់ធំ។
ការងារ៖ នាយកអនុវិទ្យាល័យឧទុម្ពរ ឃុំស្រឡៅ ស្រុកតាំងគោក ខេត្តកំពង់ធំ។
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់ អក្សរសាស្ត្រខ្មែរ។

រឿង ភ្ជុំរីករាយដ៏តូចចង្អៀត៖ ខ្សែជីវិតខ្ញុំក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
អ្នកនិពន្ធ៖ កែវ សាន

រឿង កុមារភាពដ៏កចលំតំ
អ្នកនិពន្ធ៖ យុន សុភាព
ទីកន្លែងកំណើត ៖ រស់នៅភូមិត្រាច ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។
ការងារ ៖ គ្រូបង្រៀនកម្រិតឧត្តម ឯកទេសប្រវត្តិវិទ្យា នៅវិទ្យាល័យព្រះធាតុ ខេត្តសៀមរាប។

រឿង អត់ដឹងខ្យល់
អ្នកនិពន្ធ៖ ឱម ចែតច័ន្ទថារី
ទីលំនៅបច្ចុប្បន្ន៖ ប្រទេសស្វីស
ការងារ៖ អ្នកនិពន្ធឯករាជ្យ
ការសិក្សា៖ អនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈ ពីសាកលវិទ្យាល័យឯកទេសនៃកម្ពុជា។

រឿង ខោសំពត់សម្លុយ
អ្នកនិពន្ធ៖ ម៉ៅ សំអុន

រឿង ក្រួសារខ្ញុំ
អ្នកនិពន្ធ៖ ធី ចាន់នី
ទីលំនៅបច្ចុប្បន្ន៖ ភូមិព្រៃដំរី ឃុំព្រៃតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង។
ការងារ៖ ធ្វើការនៅក្រុមហ៊ុនឯកជន
ការសិក្សា៖ បរិញ្ញាបត្រអក្សរសាស្ត្រ អង់គ្លេស សាកលវិទ្យាល័យអន្តរជាតិឌូវី ខេត្តបាត់ដំបង។

រឿង ក្រោមមេឃឥតចឹត
អ្នកនិពន្ធ៖ លឹម ផាន់ណា
ទីលំនៅបច្ចុប្បន្ន៖ សង្កាត់ដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។
ការងារ៖ អ្នកនិពន្ធ
ការសិក្សា៖ បរិញ្ញាបត្រចិត្តវិទ្យា សាកលវិទ្យាល័យកូមិន្នភ្នំពេញ។
- បរិញ្ញាបត្រជើបាលពាណិជ្ជកម្ម ជំនាញគណនេយ្យ សាកលវិទ្យាល័យមេគង្គកម្ពុជា។
- បរិញ្ញាបត្រជាន់ខ្ពស់ឯកទេស ចិត្តវិទ្យា សាកលវិទ្យាល័យកូមិន្នភ្នំពេញ។

រឿង រួចពីនរក
អ្នកនិពន្ធ៖ កែវ ពិសី
អាសយដ្ឋានបច្ចុប្បន្ន ៖ ភូមិស្វាយ ឃុំសំរោង ស្រុកសំរោង តាកែវ។
ការងារ៖ ប្រធានការិយាល័យបណ្តុះបណ្តាល នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រ ខ្មែរ សាកលវិទ្យាល័យឯកទេសនៃកម្ពុជា (CUS)។

រឿង ស្នាមអតីត
អ្នកនិពន្ធ៖ ហេង សេងអូន

រឿង ស្នាមជាន់ជីវិត
អ្នកនិពន្ធ៖ ស៊ុន វណ្ណៈ

រឿង ពពកខ្មៅ
អ្នកនិពន្ធ៖ បែន អេគ្រី
កន្លែងកំណើត ៖ រស់នៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម ឯកទេស អក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក។
ការសិក្សា ៖ នៅឆ្នាំ១៩៨៣ ដល់ ឆ្នាំ១៩៨៥ រៀនកម្រិតសិក្សាទី២ ក្នុងខេត្តកំពង់ធំ។

រឿង ជីវិតក្រោមពពកខ្មៅ
អ្នកនិពន្ធ៖ អេង ម៉ី

រឿង កម្រងផ្កាអពមង្គល
អ្នកនិពន្ធ៖ ចូ សំណាង

រឿង ប្រឡាយទឹកត្រែក
អ្នកនិពន្ធ៖ មឿង ពិសិត
ទីកន្លែងកំណើត ៖ រស់នៅភូមិច្រប់ ឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម ឯកទេស អក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យអូរតាប៉ោង។
ការសិក្សា៖ បរិញ្ញាបត្រសាកលវិទ្យាល័យ អង្គរខេមរា ខេត្តពោធិ៍សាត់។

រឿង រលកជីវិត
អ្នកនិពន្ធ៖ លី ឡាវុន
ទីលំនៅបច្ចុប្បន្ន ៖ ភូមិសាលាកន្សែង

សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប
ខេត្តសៀមរាប។
មុខរបរ៖ អ្នកកាត់ដេរ
ការសិក្សា៖ ថ្នាក់ទី៧(ចាស់) សង្គមស្មើនឹង
កម្រិតអនុវិទ្យាល័យបច្ចុប្បន្ន។

រឿង ផែនដីពណ៌ខ្មៅ

អ្នកនិពន្ធ៖ វង្ស សុភាជ
ទីកន្លែងកំណើត៖ រស់នៅភូមិប្រហ៊ូត ឃុំ
ត្រពាំងស្រែ ស្រុកមេសា ខេត្តព្រៃវែង។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម ឯកទេស
អក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យមេសា ខេត្ត
ព្រៃវែង។
ការសិក្សា៖ ឆ្នាំ២០១៣ បរិញ្ញាបត្រឯកទេស
អក្សរសាស្ត្រខ្មែរ វិទ្យាស្ថានក្រុងអង្គរ
ខេត្តព្រៃវែង។
ឆ្នាំ២០១៧ ដល់ឆ្នាំ ២០១៩ បរិញ្ញាបត្រ
ជាន់ខ្ពស់ វិទ្យាស្ថានខេមរាសាស្ត្រ ក្រុង
ព្រៃវែង។

រឿង ខ្សែជីវិតកុមារត្រូវបាន ជម្លៀសក្នុងរបប ប៉ុល ពត

អ្នកនិពន្ធ៖ អេង វ៉ាទូច

រឿង ចិត្តចងចាំ

អ្នកនិពន្ធ៖ សាម សុនិត(បច្ចុប្បន្នអ្នកនិពន្ធ
ស្លាប់ដោយសារជំងឺគ្រុនឈាម)
ទីលំនៅបច្ចុប្បន្ន៖ ភូមិប៉ាណា ឃុំសូទុព្វ
ស្រុកជើងព្រៃ ខេត្តកំពង់ចាម។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម និង ជានា
យករង វិទ្យាល័យស្ពន់។
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់ សាកល
វិទ្យាល័យវេស្ទើន។

រឿង ចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦

អ្នកនិពន្ធ៖ អៀម សារ៉ុម
ទីលំនៅបច្ចុប្បន្ន៖ ភូមិអញ្ជាញ សង្កាត់អូរចារ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម ឯកទេស
ភាសាអង់គ្លេស នៅវិទ្យាល័យសាលាហ្វាពន្លឺ
សិល្បៈ។
ការសិក្សា៖ បរិញ្ញាបត្រសេដ្ឋកិច្ច សាកល
វិទ្យាល័យ យូអិមអឺ ក្រុងបាត់ដំបង។

រឿង ជីវិតជាប់គុកឥតជញ្ជាំង

អ្នកនិពន្ធ៖ ពៅ ស្រីនិច

រឿង ជីវិតឆាសករនាគូមិភាគ ពាយព្យ

អ្នកនិពន្ធ៖ ហាច កិរម្យ
ទីលំនៅបច្ចុប្បន្ន៖ ភូមិពោធិ៍តាកួយ សង្កាត់
លលកសរ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។
ការងារ៖ គ្រូបង្រៀន ឯកទេស
ភាសាអង់គ្លេស សាលាបែលធីអន្តរជាតិ។
ការសិក្សា៖ បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស
និង បរិញ្ញាបត្រផ្នែកច្បាប់។

រឿង ជីវិតបុច្ឆាក្នុងស្បែអន្ធការ

អ្នកនិពន្ធ៖ សុិញ រស់

រឿង ជីវិតប្រចាំថ្ងៃ ក្នុងរបបប៉ុល ពត ប្រជាធិបតេយ្យ

អ្នកនិពន្ធ៖ ប៉ុក សុខម៉ារី
ទីលំនៅបច្ចុប្បន្ន៖ រស់នៅសង្កាត់ចោមចៅ
ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។
ការងារ៖ អ្នកកាសែតនៅភ្នំពេញប្រេស
(Phnom Penh Press News)

រឿង ជីវិតពិតកុមារ សុខ ខេង
អ្នកនិពន្ធ៖ នូ ស៊ីសារិទ្ធ
ទីកន្លែងកំណើត៖ ភូមិសោបក្រោម ឃុំសោប ស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ។
ការងារ៖ ចូលនិវត្តន៍
ការសិក្សា៖ រៀនបានត្រឹមថ្នាក់ទី៧

រឿង ទឹកភ្នែកលាងគុកឥតជញ្ជាំង
អ្នកនិពន្ធ៖ ជើត សារឿន
ការងារ៖ នាយករងការសែតនគរវត្ត
ទីលំនៅបច្ចុប្បន្ន៖ រស់នៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។
ការសិក្សា៖ មធ្យមសិក្សាបត្រភាគ១ Bac1 នៅក្នុងឆ្នាំ១៩៧៤។

រឿង នរកភ្នែកស្រស់
អ្នកនិពន្ធ៖ ហុង វណ្ណសុធីរ
ទីលំនៅបច្ចុប្បន្ន៖ រស់នៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។
ការងារ៖ គ្រូបង្រៀន សាលាបឋមសិក្សាប្រាសាទគោកចក ខេត្តសៀមរាប។
ការសិក្សា៖ បរិញ្ញាបត្រផ្នែកចិត្តវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

រឿង នរកលោកិយ៍បីស្ងាំឆ្លាយ
អ្នកនិពន្ធ៖ មុត ឡោម

រឿង ផ្តិលកេរជីវិត
អ្នកនិពន្ធ៖ អឹម សានី
ទីកន្លែងកំណើត៖ នៅភូមិក្រសាំង ឃុំបុស្សរ ស្រុកសំរោង ខេត្តឧត្តរមានជ័យ។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម វិទ្យាល័យហ៊ុនសែនឧត្តរមានជ័យ។
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់ វិទ្យាសាស្ត្រ អប់រំ សាកលវិទ្យាល័យឯកទេសនៃកម្ពុជា (CUS)។

រឿង ពេលដែលខ្ញុំបើកភ្នែក
អ្នកនិពន្ធ៖ ជួន ខ្មៅ
ទីលំនៅបច្ចុប្បន្ន៖ រស់នៅភូមិ៣ សង្កាត់១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។
ការងារ៖ គ្រូបង្រៀន កម្រិតឧត្តមនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ក្រុងព្រះសីហនុ។
ការសិក្សា៖ បរិញ្ញាបត្រ ឯកទេសគីមី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

រឿង ភ្នែកនៅក្នុងចិត្ត
អ្នកនិពន្ធ៖ ប្រុស សុខ

រឿង អត់ទេ មិនដែលសង្ឃឹមថារស់ទេ
អ្នកនិពន្ធ៖ ជឿន គឹមហេង

រឿង រត់
អ្នកនិពន្ធ៖ ស៊ុយ លីនប៉ាវ
កន្លែងកំណើត ៖ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
ការងារ៖ អ្នកបង្កើតមាតិកា និងអ្នកនិពន្ធ
ការសិក្សា៖ វិទ្យាស្ថានបច្ចេកទេសកម្ពុជា ។

រឿង ខ្សែជីវិតកងកុមារ
អ្នកនិពន្ធ៖ អិន ចាន់ពេញ

រឿង ឆ្លងទន្លេ
អ្នកនិពន្ធ៖ គង់ ការិទ្ធ
ទីលំនៅបច្ចុប្បន្ន៖ រស់នៅភូមិស្លែងរលើង សង្កាត់អូរបែកភ្ម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម ឯកទេសអក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យហ៊ុនសែនបុរី១០០ខ្នង។

ការសិក្សា៖ ឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៨៧
សិក្សាវគ្គបណ្តុះបណ្តាលគ្រូ។

រឿង រឿងរួចពីចំណង
អ្នកនិពន្ធ៖ វណ្ណ សារ៉ែត
ទីលំនៅបច្ចុប្បន្ន៖ ភូមិត្បែង ឃុំត្រពាំងស្រែ
ស្រុកមេសាង ខេត្តព្រៃវែង។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម ឯកទេស
អក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យមេសាង។
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេស
អក្សរសាស្ត្រខ្មែរ។

រឿង ទាសនាជូនចាស់ខ្ញុំ
អ្នកនិពន្ធ៖ នឿន ដារីន
ទីកន្លែងកំណើត៖ ភូមិអង់ឃ្លាំ ឃុំប្រឡាយ
ស្រុកស្ទោង ខេត្តកំពង់ធំ។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម វិទ្យាល័យ
អង្គរខេត្តសៀមរាប។
ការសិក្សា៖ បរិញ្ញាបត្រ សាលកវិទ្យាល័យឯ
ទេសនៃកម្ពុជា(CUS)។

រឿង ស្រមោលអតីតកាល
អ្នកនិពន្ធ៖ ហឹស ថេត

រឿង ស្រមោលអតីតកាល
អ្នកនិពន្ធ៖ វិញ ស៊ីណាត

រឿង អន្តការចោរប្លន់
អ្នកនិពន្ធ៖ ក្រូច លីហ៊ន់
ទីលំនៅបច្ចុប្បន្ន ៖ សង្កាត់ទួលស្វាយព្រៃ២
ខណ្ឌចឹងកេងកង រាជធានីភ្នំពេញ។
ការងារ៖ អាជីវករ និងអ្នកនិពន្ធ
ការសិក្សា៖ សាកលវិទ្យាល័យន័រតុន។

រឿង អន្តការឧុះយស
អ្នកនិពន្ធ៖ កួង សុគន្ធ
ទីលំនៅបច្ចុប្បន្ន៖ ភូមិលេខ៣ សង្កាត់
កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។
ការងារ៖ នគរបាល
ការសិក្សា៖ សាកលវិទ្យាល័យជាតិ
កំចាយមារ។

រឿង ជីវិតអន្ធការរបស់អ្នកម៉ែ
(កំណាព្យ)
អ្នកនិពន្ធ៖ លឹម ចាន់គឹមហៀង
ទីលំនៅបច្ចុប្បន្ន៖ ភូមិប្រាសាទ ឃុំវិហារធំ
ស្រុកកំពង់សៀម ខេត្តកំពង់ចាម។
ការងារ៖ គ្រូបង្រៀនកម្រិតឧត្តម ឯកទេស
អក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យព្រែកហ្លួង។
ការសិក្សា៖ បរិញ្ញាបត្រជាន់ខ្ពស់ សាកល
វិទ្យាល័យភូមិន្ទភ្នំពេញ។